# ព្រះត្រៃបិដក

## ប្រែរួមនឹង ព្រះអដ្ឋកថា

## ភាគ១៥

ពុទ្ធសករាជ ២៥៥៣
ច្បាប់ពិនិត្យ លើកទី១

# ព្រះ

# សុត្តន្តបិដក

## និង

## បបញ្ចសូទនី អដ្ឋកថា

### សេចក្ដីប្រែជាភាសាខ្មែរ

## មជ្ឈិមនិកាយ

## មូលបណ្ណាសក តតិយភាគ

## មជ្ឈិមបណ្ណាសក ចតុត្ថភាគ

## ១៥

## បាលីប្រែ ២២-២៣



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ១៤

## មហាយមកវគ្គ

## ចូឡគោសិង្គសាលសូត្រទី ១

[ ១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងព្រះពន្លាឥដ្ឋ ទៀបនាទិកគ្រាម ។ សម័យនោះឯង ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ ព្រះកិមិលៈមានអាយុ នៅក្នុងព្រៃឈ្មោះគោសិង្គសាលវ័ន ។ គ្រានោះ ព្រះមានព្រះភាគ ចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅក្នុងព្រៃគោសិង្គសាលវ័ននោះ ។ អ្នករក្សាព្រៃបានឃើញព្រះមានព្រះភាគ កំពុងស្តេចទៅអំពីចម្ងាយ លុះឃើញហើយក៏និយាយនឹងព្រះមានព្រះភាគយ៉ាងនេះថា នែសមណៈ សូមលោកកុំចូលទៅក្នុងព្រៃនុ៎ះឡើយ ព្រោះក្នុងព្រៃនុ៎ះ មានកុលបុត្រ ៣ រូប ជាអ្នកប្រាថ្នានូវប្រយោជន៍បម្រុងខ្លួន សូមលោកកុំធ្វើនូវសេចក្តីអផ្សុកដល់កុលបុត្រទាំងនោះឡើយ ។ ព្រះអនុរុទ្ធមានអាយុ បានឮពាក្យអ្នករក្សាព្រៃ កំពុងជជែកនឹងព្រះមានព្រះភាគ លុះឮហើយ ក៏បាននិយាយនឹងអ្នករក្សាព្រៃយ៉ាងនេះថា ម្នាលអ្នករក្សាព្រៃដ៏មានអាយុ អ្នកកុំឃាត់ព្រះមានព្រះភាគឡើយ ព្រោះព្រះមានព្រះភាគជាសាស្តាចារ្យរបស់យើង ទ្រង់ស្តេចមកដល់ហើយ ។ លំដាប់នោះ ព្រះអនុរុទ្ធមានអាយុ ក៏ចូលទៅរកព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងព្រះនន្ទិយៈមានអាយុផងព្រះកិមិលៈមានអាយុផង យ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ ចូរ

លោកមកនេះ ម្នាលលោកមានអាយុទាំងឡាយ ចូរលោកមកនេះ ព្រះមានព្រះភាគ ជាបរមគ្រូនៃយើង ព្រះអង្គស្តេចមកដល់ហើយ ។ គ្រានោះ ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ ក្រោកទទួលព្រះមានព្រះភាគ មួយអង្គទទួលបាត្រ និងចីវររបស់ព្រះមានព្រះភាគ មួយអង្គក្រាលអាសនៈ មួយអង្គទៀតតម្កល់ទឹកទុកសម្រាប់លាងព្រះបាទ ។ ព្រះមានព្រះភាគ ក៏គង់លើអាសនៈដែលភិក្ខុក្រាលថ្វាយ លុះគង់រួចក៏ទ្រង់ឲ្យលាងព្រះបាទ ។ ចំណែកព្រះថេរៈមានអាយុទាំងនោះ នាំគ្នាថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។

[ ២ ] ព្រះមានព្រះភាគ បានត្រាស់នឹងព្រះអនុរុទ្ធមានអាយុ ដែលអង្គុយក្នុងទីដ៏សមគួរហើយ យ៉ាងនេះថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំង-ឡាយល្មមអត់ធន់បានឬទេ អ្នកទាំងឡាយល្មមប្រព្រឹត្តទៅបានស្រួលឬទេ អ្នកទាំងឡាយមិនលំបាកដោយអាហារបិណ្ឌបាតទេឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយ ល្មមអត់ធន់បាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយ ល្មមប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស មួយទៀត ខ្ញុំព្រះអង្គទាំងឡាយ មិនបានលំបាកដោយបិណ្ឌបាតទេ ។ ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយព្រមព្រៀងស្រុះស្រួល មិនទាស់ទែងគ្នា ដូចជាទឹកដោះលាយទឹក រមិលមើលគ្នាទៅវិញទៅមកដោយចក្ខុគួរឲ្យស្រឡាញ់ទេឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំង-ឡាយជាអ្នកព្រមព្រៀងស្រុះស្រួល មិនទាស់ទែងគ្នា ដូចទឹកដោះលាយទឹក

រមិលមើលគ្នាទៅវិញទៅមក ដោយចក្ខុគួរឲ្យស្រឡាញ់តែម្យ៉ាង ។ ម្នាល អនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយព្រមព្រៀង ស្រុះស្រួល មិនទាស់ទែងគ្នា ដូចទឹកដោះលាយទឹក រមិលមើលគ្នាទៅវិញទៅមកដោយចក្ខុគួរឲ្យស្រឡាញ់ ដូចម្តេចខ្លះ ។

[ ៣ ] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ ក្នុងទីនេះ យ៉ាងនេះថា អាត្មាអញពេញហៅមានលាភ អាត្មាអញពេញហៅបានស្រួល ត្រង់ដែលអាត្មាអញ នៅជាមួយនឹងពួកសព្រហ្មចារី មានសភាពយ៉ាងនេះ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ បានតាំងកាយកម្មប្រកបដោយមេត្តា ទៅរកលោកមានអាយុទាំងនេះ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ តាំងវចីកម្មប្រកបដោយមេត្តា តាំងមនោកម្មប្រកបដោយមេត្តា ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញដាក់ចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅតាមអំណាចនៃចិត្តរបស់លោកមានអាយុ ទាំងនេះឯង ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ក៏ដាក់ចិត្តរបស់ខ្លួន ឲ្យប្រព្រឹត្តទៅតាមអំណាចនៃចិត្តរបស់លោកមានអាយុទាំងនេះឯង បពិត្រព្រះអង្គដ៏ចម្រើន តាមពិត កាយរបស់ខ្ញុំព្រះអង្គទាំងឡាយ ទីទៃពីគ្នាមែន ប៉ុន្តែ ចិត្តមានទំនងជាមួយគ្នា ។ ចំណែកនន្ទិយៈមានអាយុ ។បេ។ ចំណែកកិមិលៈមានអាយុ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គក៏មានសេចក្តីត្រិះរិះក្នុងទីនេះយ៉ាងនេះថា អាត្មាអញពេញជាមានលាភ អាត្មាអញពេញជា

បានស្រួលហើយ ត្រង់ដែលអាត្មាអញនៅជាមួយនឹងពួកសព្រហ្មចារី មាន សភាពយ៉ាងនេះដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ បានតាំងកាយ-កម្មប្រកបដោយមេត្តា ទៅរកលោកមានអាយុទាំងនេះ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ តាំងវចីកម្មប្រកបដោយមេត្តា ... តាំងមនោកម្មប្រកបដោយមេត្តា ទាំងទីចំពោះមុខ និងទីកំបាំងមុខ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះមាន សេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញដាក់ចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅតាមអំណាចចិត្ត របស់លោកមានអាយុទាំងនេះឯង ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះក៏ដាក់ចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅតាមអំណាចនៃចិត្តរបស់លោកមានអាយុទាំងនេះឯង បពិត្រព្រះអង្គដ៏ចម្រើន តាមពិតកាយរបស់យើងខ្ញុំព្រះអង្គទីទៃពីគ្នាមែន ប៉ុន្តែ ចិត្តមានទំនងជាមួយគ្នា ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គព្រមព្រៀង ស្រុះស្រួល មិនទាស់ទែងគ្នា ដូចទឹកដោះលាយទឹក រមិលមើលគ្នាទៅវិញទៅមក ដោយចក្ខុគួរឲ្យស្រឡាញ់យ៉ាងនេះឯង ។

[ ៤ ] ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានខ្លះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គសុទ្ធតែជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន តែមួយចំណែក ។ ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស

មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានយ៉ាងណាខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្ដាយើងខ្ញុំព្រះអង្គក្នុងទីនេះ លោកណាត្រឡប់ពីបិណ្ឌបាតអំពីស្រុកមុនគេ លោកនោះ ក៏រៀបក្រាលអាសនៈ តម្កល់ទឹកឆាន់ និងទឹកសម្រាប់ប្រើប្រាស់ តម្កល់ទុកនូវភាជន៍សម្រាប់រំលែកបិណ្ឌបាតដែលមានច្រើន លោកណាត្រឡប់អំពីបិណ្ឌបាតអំពីស្រុកក្រោយគេ បើមានភត្តដ៏សេសសល់អំពីភត្តដែលលោកអង្គណាបរិភោគហើយ បើចង់បរិភោគ ក៏បរិភោគទៅ បើមិនចង់បរិភោគទេ ក៏ចាក់ចោលក្នុងទីដែលប្រាសចាកតិណជាតិ មានពណ៌ខៀវ ឬចាក់ចោលក្នុងទឹកដែលប្រាសចាកសត្វ ភិក្ខុនោះទុកដាក់អាសនៈ ទុកដាក់ទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ ទុកដាក់ភាជន៍សម្រាប់ផ្ទេរបិណ្ឌបាត នឹងបោសសម្អាតរោងភត្ត លោកណាឃើញក្អមសម្រាប់ដាក់ទឹកឆាន់ ក្អមដាក់ទឹកប្រើប្រាស់ ឬក្អមសម្រាប់ដាក់ទឹកទុកក្នុងវច្ចកុដិ មានទឹកតិចឬទទេ ភិក្ខុនោះតែងដងង ( ទឹកទុក ) បើភិក្ខុនោះ មិនអាចនឹងលើកភារៈនោះរួចទេ ក៏ហៅភិក្ខុជាគម្រប់ពីរមកដោយវិការនៃដៃ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទុកដាក់ដោយការជួយគ្នាដោយដៃ មិនបាច់បញ្ចេញវាចា ព្រោះកិច្ចការនោះជាបច្ច័យឡើយ បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត យើងខ្ញុំព្រះអង្គតែងអង្គុយប្រជុំគ្នា ដោយធម្មីកថាពេញមួយយប់ រាល់ថ្ងៃទី ៥ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានយ៉ាងនេះ ។

[ ៥ ] ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ចុះផាសុវិហារធម៌ ( ធម៌

ជាទីនៅសប្បាយ ) ដ៏វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈបាន ក្រៃលែងជាងមនុស្សធម៌ ដែលលោកទាំងឡាយជាអ្នកមិនប្រមាទ មានព្យាយាម មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បានត្រាស់ដឹងយ៉ាងនេះហើយ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះដែលយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ប្តីក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រាថ្នាស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំង-ឡាយជាកំណត់ ក៏បានចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្ក វិចារៈ មានបីតិ និងសុខ ដែលកើតអំពីវិវេក បពិត្រព្រះអង្គដ៏ចម្រើន នេះឯងជាផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈបាន ដ៏ក្រៃលែងជាងមនុស្សធម៌ ដែលយើងខ្ញុំព្រះអង្គជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បានត្រាស់ដឹងហើយ ។ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈអាចធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលអ្នកទាំងឡាយត្រាស់ដឹងហើយ ដើម្បីកន្លងនូវផាសុវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវផាសុវិហារធម៌នុ៎ះ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះ ប្តីក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រាថ្នាឲ្យស្ងប់រម្ងាប់ នូវវិតក្ក និងវិចារៈជាកំណត់ ក៏បានចូលទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានរបស់ខ្លួនប្រកបដោយសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក

មិនមានវិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ បពិត្រព្រះអង្គដ៏ចម្រើន នេះជាផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ ។ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលអ្នកទាំងឡាយបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះ ថ្វីក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ក្នុងទីនេះ យើងខ្ញុំព្រះអង្គ ប្រាថ្នាប្រាកដ យើងខ្ញុំព្រះអង្គក៏ប្រាសចាកបីតិ មានតែឧបេក្ខា និងសតិសម្បជញ្ញៈ ទទួលនូវសេចក្តីសុខដោយកាយ បានដល់តតិយជ្ឈាន ដែលព្រះអរិយបុគ្គលទាំងឡាយសម្តែងថា បុគ្គលប្រកបដោយតតិយជ្ឈាន ជាអ្នកមានឧបេក្ខា មានសតិនៅជាសុខនោះ បពិត្រព្រះអង្គដ៏ចម្រើន នេះជាផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែង ជាងមនុស្សធម៌ដទៃទៀត ដែលយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ ។ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលអ្នកទាំងឡាយបានត្រាស់ដឹងហើយ

ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះ ថ្វីក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រាថ្នាជាប្រាកដ យើងខ្ញុំព្រះអង្គបានលះសុខផង លះទុក្ខផង រម្ងត់នូវសោមនស្ស និងទោមនស្សអំពីមុនផង ក៏បានដល់ចតុត្ថជ្ឈាន ដែលមិនមានទុក្ខ មិនមានសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា បពិត្រព្រះអង្គដ៏ចម្រើន នេះជាផាសុវិហារធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ ។ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលពួកអ្នកបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះ ថ្វីក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រាថ្នាជាប្រាកដ យើងខ្ញុំព្រះអង្គកន្លងនូវពួករូបសញ្ញា មិនធ្វើទុកក្នុងចិត្តនូវពួកបដិឃសញ្ញា ដោយប្រការទាំងពួង ក៏ចូលអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន នេះជាផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈក្រៃលែង ជាងមនុស្សធម៌ដទៃទៀត ដែលយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌

នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលពួកអ្នកបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារ ធម៌នុ៎ះមានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះ ថ្វីក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ក្នុងទីនេះ យើងខ្ញុំព្រះអង្គប្រាថ្នាជាប្រាកដ យើងខ្ញុំព្រះអង្គក៏បានកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង បានចូលវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ។បេ។ កន្លងនូវវិញ្ញាណញ្ចាយតនៈដោយប្រការទាំងពួង ក៏បានចូលអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អ្វីតិចតួចក៏មិនមានដូច្នេះ ។បេ។ កន្លងនូវអាកិញ្ចញ្ញាយតនជ្ឈានដោយប្រការទាំងពួង ក៏បានដល់នូវនេវសញ្ញា-នាសញ្ញាយតនជ្ឈាន បពិត្រព្រះអង្គដ៏ចម្រើន នេះជាផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលពួកយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ ។ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះផាសុវិហារធម៌ ជាធម៌វិសេស គឺញាណទស្សនៈ អាចធ្វើខ្លួនឲ្យជាអរិយៈ ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលពួកអ្នកបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ មានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ផាសុវិហារធម៌នោះ ថ្វីក៏មិនមាន

បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ក្នុងទីនេះយើងខ្ញុំព្រះអង្គ ប្រាថ្នាជាប្រាកដ យើងខ្ញុំព្រះអង្គបានកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានចូលសញ្ញាវេទយិតនិរោធ អាសវៈទាំងឡាយរបស់ពួកយើងខ្ញុំព្រះអង្គ ក៏អស់ទៅមិនសល់ ព្រោះបានឃើញច្បាស់ដោយវិបស្សនាបញ្ញា បពិត្រព្រះអង្គដ៏ចម្រើន នេះជាផាសុវិហារធម៌ ជាធម៌វិសេសគឺញាណទស្សនៈអាចធ្វើខ្លួនឲ្យជាអរិយៈ ដ៏ក្រៃលែងជាងមនុស្សធម៌ដទៃទៀត ដែលពួកយើងខ្ញុំព្រះអង្គបានត្រាស់ដឹងហើយ ដើម្បីកន្លងនូវវិហារធម៌នុ៎ះ ដើម្បីរម្ងាប់នូវវិហារធម៌នុ៎ះ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត យើងខ្ញុំព្រះអង្គមិនឃើញច្បាស់នូវផាសុវិហារធម៌ដទៃឲ្យលើសលុបជាង ឲ្យថ្លៃថ្លាជាងផាសុវិហារធម៌នេះទៅទៀតទេ ។ ម្នាលអនុរុទ្ធទាំងឡាយ ត្រូវល្អហើយ ម្នាលអនុរុទ្ធទាំងឡាយ ផាសុវិហារធម៌ដទៃ ដែលលើសលុបជាង ថ្លៃថ្លាជាងផាសុវិហារធម៌នុ៎ះទៅទៀត មិនមានទេ ។

[ ៦ ] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ទ្រង់ក្រោកអំពីអាសនៈស្ដេចចេញទៅ ។ លំដាប់នោះ ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ ក៏តាមហែព្រះមានព្រះភាគទៅ ហើយត្រឡប់មកអំពីទីនោះវិញ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ បាននិយាយនឹងព្រះអនុរុទ្ធមានអាយុយ៉ាងនេះថា យើងទាំងឡាយ បានប្រាប់ព្រះអនុរុទ្ធ

មានអាយុយ៉ាងនេះថា យើងទាំងឡាយ បានទូវវិហារសមាបត្តិទាំងឡាយនេះផង នេះផង ដូច្នេះដែរឬទេ បានជាព្រះអនុរុទ្ធមានអាយុប្រកាស ( គុណ ) របស់យើងជរាបអំពីការអស់ទៅនៃអាសវៈទាំងឡាយ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ។ ព្រះអនុរុទ្ធតបថា លោកដ៏មានអាយុទាំងឡាយ មិនបានប្រាប់ដល់ខ្ញុំយ៉ាងនេះទេថា យើងទាំងឡាយ ជាអ្នកបានទូវវិហារសមាបត្តិទាំងឡាយ នេះផង នេះផង ដូច្នេះមែន ប៉ុន្តែ ខ្ញុំកំណត់ដឹងចិត្តលោកមានអាយុទាំងឡាយ ដោយចិត្តរបស់ខ្ញុំថា លោកមានអាយុទាំងឡាយនេះ បាននូវវិហារសមាបត្តិនេះផង នេះផង ដូច្នេះ ទាំងពួកទេវតាសោត ក៏បានប្រាប់សេចក្តីនុ៎ះដល់ខ្ញុំថា លោកមានអាយុទាំងឡាយនេះ បានទូវវិហារសមាបត្តិនេះផង នេះផង ដូច្នេះ បានជាព្រះមានព្រះភាគ ទ្រង់ត្រាស់សួរបញ្ហាក់នូវបញ្ហា ខ្ញុំក៏បានព្យាករពាក្យនោះរួចហើយ ។

[ ៧ ] គ្រានោះឯង មានយក្សម្នាក់ ឈ្មោះទីឃបរជន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចឋិតនៅក្នុងទីដ៏សមគួរ ។ ទីឃបរជនយក្ស ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា ព្រះតថាគតអរហន្តសម្មា-សម្ពុទ្ធ និងកុលបុត្រទាំង ៣ រូបនេះ គឺព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ គង់នៅក្នុងប្រទេសណា បពិត្រព្រះអង្គដ៏ចម្រើន ប្រទេសនោះ ជាលាភរបស់ពួកអ្នកដែនវជ្ជី បពិត្រព្រះអង្គដ៏ចម្រើន ប្រទេសនោះជាលាភដែលប្រជាជនអ្នកដែនវជ្ជីបានល្អហើយ ។ ពួកភុម្មទេវតា

បានឮសំឡេង របស់ទីឃបរជនយក្សហើយ ក៏ធ្វើសំឡេងលាន់ឮឡើងទៅថា អើហ្ន៎ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ និងកុលបុត្រទាំង ៣ រូបនេះ គឺព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ គង់នៅក្នុងប្រទេសណា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ប្រទេសនោះជាលាភនៃពួកអ្នកដែនវជ្ជី ម្នាលអ្នកទាំងឡាយដ៏ចម្រើន ប្រទេសនោះ ជាលាភដែលប្រជាជនអ្នកដែនវជ្ជីបានល្អហើយ ។ ពួកចាតុម្មហារាជិកទេវតា បានឮសំឡេងរបស់ពួកភុម្មទេវតាហើយ ... ពួកតាវត្តិង្សទេវតា ... ពួកយាមទេវតា ... ពួកតុសិតទេវតា ... ពួកនិម្មានរតីទេវតា ... ពួកបរនិម្មិតវសវត្តីទេវតា ... ពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្ម ក៏ធ្វើសំឡេងលាន់ឮឡើងទៅថា អើហ្ន៎ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ និងកុលបុត្រទាំង ៣ រូបនេះ គឺព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិមិលៈមានអាយុ គង់នៅក្នុងប្រទេសណា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ប្រទេសនោះជាលាភរបស់ពួកអ្នកដែនវជ្ជី ម្នាលអ្នកទាំងឡាយដ៏ចម្រើន ប្រទេសនោះ ជាលាភដែលប្រជាជនអ្នកដែនវជ្ជីបានល្អហើយ ។

[ ៨ ] ក៏ក្នុងខណៈមួយរំពេចនោះ សំឡេងឮកងរំពងរហូតទៅដល់ព្រហ្មលោក ដោយប្រការដូច្នេះថា ម្នាលទីឃៈ ដំណើរនុ៎ះយ៉ាងហ្នឹងហើយ ម្នាលទីឃៈ ដំណើរនុ៎ះយ៉ាងហ្នឹងហើយ ម្នាលទីឃៈ កុលបុត្រទាំង ៣ រូបនុ៎ះចេញចាកផ្ទះអំពីត្រកូលណា បួសក្នុងសាសនា បើត្រកូលនោះ មានចិត្តជ្រះថ្លា រឭកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរឭកនោះ នឹងនាំមកនូវ

ប្រយោជន៍ និងសេចក្តីសុខដល់ត្រកូលនុ៎ះ អស់កាលយូរអង្វែង ម្នាលទីឃៈ កុលបុត្រទាំង ៣ រូបនោះ ចេញចាកផ្ទះអំពីវង្សត្រកូលណា បួសក្នុងសាសនា ប្រសិនបើវង្សត្រកូលនោះ មានចិត្តជ្រះថ្លា រឭកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរឭកនោះ តែងនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ដល់វង្សត្រកូលនុ៎ះ អស់កាលយូរអង្វែង ម្នាលទីឃៈ កុលបុត្រទាំង ៣ រូបនុ៎ះ ចេញចាកផ្ទះអំពីស្រុកណា បួសក្នុងសាសនា ប្រសិនបើអ្នកស្រុកនោះ មានចិត្តជ្រះថ្លា រឭកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរឭកនោះ តែងនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ដល់អ្នកស្រុកនោះ អស់កាលយូរអង្វែង ម្នាលទីឃៈ កុល-បុត្រទាំង ៣ រូបនុ៎ះ ចេញចាកផ្ទះអំពីនិគមណា បួសក្នុងសាសនា ប្រសិនបើអ្នកនិគមនោះ មានចិត្តជ្រះថ្លា រឭកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរឭកនោះ តែងនាំមកនូវប្រយោជន៍ និងសេចក្តីសុខដល់អ្នកនិគមនោះ អស់កាលយូរអង្វែង ម្នាលទីឃៈ កុលបុត្រទាំង ៣ រូបនុ៎ះ ចេញចាកផ្ទះអំពីនគរណា បួសក្នុងសាសនា ប្រសិនបើអ្នកនគរនោះ មានចិត្តជ្រះថ្លា រឭកចំពោះកុល-បុត្រទាំង ៣ រូបនុ៎ះ ការរឭកនោះ តែងនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ដល់អ្នកនគរនោះ អស់កាលយូរអង្វែង ម្នាលទីឃៈ កុលបុត្រទាំង ៣ រូបនុ៎ះ ចេញចាកផ្ទះអំពីជនបទណា បួសក្នុងសាសនា ប្រសិនបើអ្នកជនបទនោះ មានចិត្តជ្រះថ្លា រឭកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរឭកនោះ តែងនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ដល់អ្នកជនបទនោះ អស់កាលយូរអង្វែង ម្នាលទីឃៈ ប្រសិនបើពួកក្សត្រទាំងអស់ មានព្រះហឫទ័យជ្រះថ្លា

រឭកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរឭកនោះ តែងនាំមកនូវប្រយោជន៍ និងសេចក្ដីសុខ ដល់ពួកក្សត្រទាំងអស់ អស់កាលយូរអង្វែង ម្នាលទីឃៈ ប្រសិនបើពួកព្រាហ្មណ៍ទាំងអស់ ។បេ។ ម្នាលទីឃៈ ប្រសិនបើពួកវេស្សៈទាំងអស់ ... ម្នាលទីឃៈ ប្រសិនបើ ពួកសុទ្ទៈទាំងអស់ មានចិត្តជ្រះថ្លា រឭកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរឭកនោះ តែងនាំមកនូវប្រយោជន៍ និងសេចក្ដីសុខដល់ពួកសុទ្ទៈទាំងអស់ អស់កាលយូរអង្វែង ម្នាលទីឃៈ ប្រសិនបើលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មានចិត្តជ្រះថ្លា រឭកចំពោះកុលបុត្រទាំង ៣ រូបនុ៎ះ ការរឭកនោះ តែងនាំមកនូវប្រយោជន៍ដល់លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដល់ពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស អស់កាលយូរអង្វែង ម្នាលទីឃៈ អ្នកចូរមើលកុលបុត្រទាំង ៣ រូបនុ៎ះ ប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីគុណ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយជាកំណត់ ។ ព្រះមានព្រះភាគ បានត្រាស់សេចក្ដីនេះចប់ហើយ ទីឃបរជនយក្សក៏ពេញចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## ចូឡគោសិង្គសាលសូត្រទី ១ ចប់

# អដ្ឋកថា មជ្ឈិមនិកាយ

## ឈ្មោះ បបញ្ចសូទនី

## មហាយមកវគ្គវណ្ណនា

## ចូឡគោសិង្គសាលសូត្រទី ១

[ ១ ] ចូឡគោសិង្គសាលសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **ញាតិកេ វិហរតិ** សេចក្ដីថា ក្នុងស្រុកមួយកន្លែង ក្នុងបណ្ដាស្រុក ២ នៃបុត្ររបស់មា និងបុត្ររបស់អ៊ំ អាស្រ័យស្រះទឹកមួយកន្លែង ឈ្មោះនាទិកា ។ បទថា **គិញ្ជកាវសថេ** បាន ដល់ ទីសម្រាកដែលធ្វើដោយឥដ្ឋ ។ បានឮថា សម័យមួយ ព្រះមានព្រះភាគធ្វើការសង្គ្រោះមហាជន ទ្រង់ចារិកទៅក្នុងដែនវជ្ជី ទ្រង់យាងដល់នាទិកគ្រាម ។ អ្នកស្រុកនាទិកគ្រាមថ្វាយមហាទាន ដល់ព្រះមានព្រះភាគ ស្ដាប់ធម្មីកថា មានចិត្តជ្រះថ្លា ប្រឹក្សាគ្នាថា យើងនឹងធ្វើទីប្រថាប់ថ្វាយដល់ព្រះសាស្ដា លម្អដោយរូបសត្វសាហាវជាដើម ត្រង់ក្ដាក់ដៃជណ្ដើរ និងសសរដោយឥដ្ឋទាំងអស់ សាងប្រាសាទ បូកលាបដោយបាយ-អ ញ៉ាំងមាលាកម្ម និងលតាកម្មជាដើមឲ្យសម្រេច ក្រាលនូវកម្រាលផែនដី គ្រែ និងតាំងជាដើម ថ្វាយដល់ព្រះសាស្ដា ។ តមកទៀត ពួកអ្នកស្រុកក្នុងទីនោះ នាំគ្នាសាងទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃ មណ្ឌប និងទីចង្ក្រមជាដើម

វេរដល់ភិក្ខុសង្ឃ ។ វិហារនោះ បានជាមហាវិហារ ដោយប្រការដូច្នេះ ។ លោកសំដៅយកវិហារនោះ ទើបពោលថា **គិញ្ជកាវសថេ** ដូច្នេះ ។

ប្រគាបឈើ មានសណ្ឋានដូចស្នែងគោ កើតឡើងអំពីដើមនៃដើមឈើធំមួយដើម ក្នុងបទថា **គោសិង្គសាលវនទាយេ** នោះ ។ ព្រៃទាំងអស់នោះ អាស្រ័យដើមឈើនោះ ទើបឈ្មោះថា **គោសិង្គសាលវន** ដូច្នេះ ។ បទថា **ទាយោ** នេះ ជាឈ្មោះនៃព្រៃ ដោយមិនផ្សេងគ្នា ព្រោះដូច្នោះ បទថា **គោសិង្គសាលវនទាយេ** សេចក្តីថា ក្នុងព្រៃឈ្មោះគោសិង្គសាលវ័ន ។ បទថា **វិហរន្តិ** បានដល់ សោយសាមគ្គីរស ។ វេលាកុលបុត្រទាំងនោះជាបុថុជ្ជន លោកពោលទុកក្នុងឧបរិបណ្ណាសកៈហើយ ។ ក្នុងទីនេះ លោកពោលក្នុងកាលដែលភិក្ខុទាំងឡាយជាព្រះវីណាស្រេព ។ ពិតហើយ ក្នុងវេលានោះ កុលបុត្រទាំងនោះ បានធ្វើការពេញចិត្ត បានទូវទីពឹង សម្រេចបដិសម្ភិទា ជាព្រះវីណាស្រេព សោយសាមគ្គីរស នៅក្នុងទីនោះ ។ បទថា **យេន គោសិង្គសាលវនទាយោ តេនុបសង្កមិ** នេះ លោកពោលសំដៅដល់ព្រៃនោះ ។

ព្រះមានព្រះភាគ មិនបានប្រាប់បុគ្គលណាមួយ ក្នុងបណ្តាព្រះធម្មសេនាបតី ព្រះមហាមោគ្គល្លានត្ថេរ ឬព្រះអសីតិមហាសាវ័ក ដោយហោចសូម្បីព្រះអានន្ទត្ថេរដែលជាឃ្មាំងធម៌ ទ្រង់កាន់បាត្រ និងចីវរដោយព្រះអង្គឯង ដូចដំរីចៀសចេញអំពីសត្រូវ ដូចកេសរសីហរាជចេញអំពីហ្វូង ដូចពពកត្រូវខ្យល់បក់ ព្រះមានព្រះភាគ ទ្រង់យាងទៅមួយអង្គឯង ចូលទៅរកយ៉ាងនេះ

ឯង ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគយាងទៅមួយអង្គឯង ក្នុងទីនេះឆ្លើយថា កុលបុត្រទាំង ៣ រមែងសោយសាមគ្គីរស ព្រោះទ្រង់ចង់លើកតម្កើងកុលបុត្រទាំងនោះ និងព្រោះទ្រង់អនុគ្រោះពួកជនដែលកើតខាងក្រោយ និងព្រោះធ្ងន់ក្នុងធម៌ ។ បានឮថា ព្រះមានព្រះភាគនោះ ទ្រង់មានព្រះតម្រិះថា តថាគតនឹងលើកតម្កើងសរសើរកុលបុត្រទាំងនេះ ធ្វើបដិសណ្ឋារៈសម្ដែងធម៌ដល់កុលបុត្រទាំងនោះ ព្រោះទ្រង់លើកតម្កើងយ៉ាងនេះប៉ុណ្ណោះទើបយាងទៅ ។ ព្រះអង្គមានព្រះតម្រិះតទៅថា ក្នុងអនាគត កុលបុត្រទាំង-ឡាយ សម្គាល់ការគួរ នៅព្រមព្រៀងគ្នាថា ព្រះសម្មាសម្ពុទ្ធ យាងទៅកាន់សម្នាក់របស់កុលបុត្រដែលនៅព្រមព្រៀងគ្នាដោយព្រះអង្គឯង ធ្វើបដិសណ្ឋារៈសម្ដែងធម៌សរសើរកុលបុត្រទាំង ៣ បុគ្គលណា គប្បីនៅព្រមព្រៀងគ្នាដូច្នេះ នឹងធ្វើនូវទីបំផុតនៃទុក្ខបានឆាប់រហ័ស ដូច្នេះ ព្រោះដើម្បីទ្រង់អនុគ្រោះដល់ពពួកជនដែលកើតឯក្រោយ ទើបទ្រង់យាងទៅ ។ ធម្មតាព្រះពុទ្ធទ្រង់ជាអ្នកធ្ងន់ក្នុងធម៌ ការធ្ងន់ក្នុងធម៌របស់ព្រះពុទ្ធទាំងនោះ មកហើយក្នុងរថវិនីតសូត្រ ព្រោះដូច្នោះ ទ្រង់ព្រះតម្រិះថា តថាគតនឹងលើកតម្កើងធម៌ ព្រោះការធ្ងន់ក្នុងធម៌នេះ ដូច្នេះ ។ ទើបទ្រង់យាងទៅ ។

បទថា **ទាយបាលោ** ប្រែថា អ្នករក្សាព្រៃ អ្នករក្សាព្រៃនោះ រមែងអង្គុយរក្សាគ្រប់គ្រងត្រង់ទ្វារព្រៃនោះ ដែលគេព័ទ្ធរបងប្រកបទុកដោយប្រការដែលពួកមនុស្សក្នុងប្រទេសដែលគេប្រាថ្នាហើយ រមែងមិននាំផ្កា ផ្លែឈើ ជ័រឈើ ឬទព្វសម្ភារៈក្នុងទីនោះចេញបាន ព្រោះដូច្នេះ ទើបលោកពោលថា

**ធាយថាលោ** ។ បទថា **អត្តកាមរូបា** សេចក្តីថា ជាអ្នកប្រាថ្នាប្រយោជន៍ខ្លួនជាសភាវៈ ។ ពិតហើយ បុគ្គលណាបួសហើយក្នុងសាសនានេះ ចិញ្ចឹមជីវិតដោយអនេសនា ២១ មានវេជ្ជកម្ម ទូតកម្ម និងការនាំដំណឹងជាដើមនេះ មិនទាន់ឈ្មោះថា ជាអ្នកប្រាថ្នាប្រយោជន៍ខ្លួនឡើយ ។ ឯបុគ្គលណា បួសហើយក្នុងសាសនានេះ លះអនេសនា ២១ ហើយតាំងនៅក្នុងចតុប្បារិសុទ្ធិ-សីល រៀនព្រះពុទ្ធវចនៈ អធិដ្ឋានធុតង្គតាមសប្បាយ កាន់យកកម្មដ្ឋានដែលពេញចិត្តក្នុងអារម្មណ៍ ៣៨ លះចន្លោះស្រុកចូលព្រៃ ញុំាងសមាបត្តិឲ្យកើតចម្រើនវិបស្សនាកម្មដ្ឋាន នេះឈ្មោះថា ជាអ្នកប្រាថ្នាប្រយោជន៍ខ្លួន ។ កុលបុត្រទាំង ៣ នោះ ជាអ្នកមានសភាពបែបនេះ ព្រោះដូច្នោះ លោកពោលថា **អត្តកាមរូបា វិហរន្តិ** ។ អ្នករក្សាព្រៃ សូមពរព្រះមានព្រះភាគថា សូមលោកកុំធ្វើនូវសេចក្តីអផ្សុកដល់កុលបុត្រទាំងនោះឡើយ ។

បានឮថា នាយទាយបាលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះ កុលបុត្រទាំងនេះនៅព្រមព្រៀងគ្នា ការចាក់ដោត ជម្លោះ និងវិវាទ រមែងប្រព្រឹត្តទៅក្នុងទីដែលពួកបុគ្គលខ្លះទៅហើយ ទាំង ២ នាក់មិនទៅក្នុងផ្លូវតែមួយ ដូចគោកាច ស្នែងស្រួចវែង ជួនកាល ព្រះសម្ពុទ្ធអង្គនេះ កាលទ្រង់ធ្វើយ៉ាងនេះគប្បីទម្លាយការនៅព្រមព្រៀង របស់កុលបុត្រទាំងនេះ តែព្រះអង្គគួរជ្រះថ្លាមានព្រះឆវីវណ្ណដូចមាស ប្រហែលជាចង់បានក្នុងរស គប្បីទម្លាយអប្បមាទវិហារធម៌របស់កុលបុត្រទាំងនេះ ដោយការពោលសរសើរបុគ្គលអ្នកថ្វាយរបស់ដ៏ប្រណីត និងបុគ្គលឧបដ្ឋាកខ្លួន តាំងអំពីយានទៅដល់ ឯទីលំនៅនៃ

កុលបុត្រទាំងនេះ កំណត់ទុកពិតប្រាកដ គឺបណ្ណសាលា ៣ ទីចង្រ្កម ៣ ទីសម្រាកពេលថ្ងៃ ៣ គ្រែ ៣ តាំង ៣ ឯសមណៈនេះ មានកាយធំ ប្រហែលជាចាស់ជាង នឹងដេញកុលបុត្រទាំងនេះចេញអំពីសេនាសនៈ ក្នុងកាលដែលមិនគួរ ផាសុកនឹងមិនមានដល់កុលបុត្រទាំងនោះក្នុងទីទាំងពួង ដោយប្រការដូច្នេះ នាយទាយបាលមិនប្រាថ្នាយ៉ាងនោះ ទើបសំណូមពរព្រះមានព្រះភាគថា សូមលោកកុំធ្វើនូវសេចក្ដីអផ្សុក ដល់កុលបុត្រទាំងនោះឡើយ ។

សួរថា នាយទាយបាលនោះ ដឹងឬ ទើបហាម ឬមិនដឹង ទើបហាម ឆ្លើយថា ពិតហើយ តាំងអំពីព្រះតថាគតបដិសន្ធិ បាដិហារ្យដែលញ៉ាំងចក្រវាលមួយម៉ឺន ឲ្យកម្រើកជាដើមប្រព្រឹត្តទៅហើយក៏ពិត សូម្បីយ៉ាងនោះ បុគ្គលមិនមានកម្លាំង ជាអ្នកព្រៃ រវល់តែក្នុងព្រៃ មិនអាចកំណត់ដឹងបាដិហារ្យនោះបាន ។ ធម្មតាព្រះសម្មាសម្ពុទ្ធ កាលណា មានភិក្ខុច្រើនពាន់ជាបរិវារយាងទៅ ទើបសម្ដែងពុទ្ធានុភាពដោយព្រះរស្មីមួយព្យាម ដោយអនុព្យញ្ជនៈ ៨០ និងដោយព្រះសិរី គឺមហាបុរិសលក្ខណៈ ៣២ កាលនោះ បុគ្គលនោះសួរថា នុ៎ះជាអ្នកណា ហើយគប្បីស្គាល់ ។ កាលនោះ ព្រះមានព្រះភាគទ្រង់បិទបាំងពុទ្ធានុភាពទាំងអស់នោះក្នុងស្រទាប់ចីវរ ទ្រង់កាន់បាត្រ និងចីវរដោយព្រះអង្គឯង យាងទៅដោយភេទដែលមិនមានអ្នកស្គាល់ ដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី ដែលត្រូវបិទបាំងក្នុងស្រទាប់ពពក ។ នាយទាយបាលមិនដឹងសេចក្ដីនោះ ទើបឃាត់ដោយប្រការនេះ ។ បទថា **ឯតទវោច** សេចក្ដីថា បានឮថា ព្រះថេរៈស្ដាប់វាចារបស់នាយទាយបាលថា **មា សមណ** ដូច្នេះ

ទើបគិតថា អាត្មាអញនៅជាមួយគ្នា ៣ អង្គ មិនមានបព្វជិតដទៃទេ នាយទាយបាលនេះនិយាយដូចគ្នានឹងនិយាយជាមួយបព្វជិត បុគ្គលនោះជានរណាហ្ន៎ ដូច្នេះហើយ ចេញមកអំពីទីសម្រាកពេលថ្ងៃ ឈរនៅត្រង់ទ្វារ សម្លឹងមើលផ្លូវ ក៏បានឃើញព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចេញព្រះរស្មីអំពីព្រះកាយ ដំណាលគ្នានឹងព្រះថេរៈឃើញ ព្រះរស្មីមួយព្យាម មួយអន្ទីដោយអនុព្យញ្ជនៈ ៨០ រុងរឿងដូចបន្ទះមាសដែលផ្សាយចេញ ។ ព្រះថេរៈគិតថា នាយទាយបាលនេះ និយាយជាមួយអគ្គបុគ្គលក្នុងលោក គង់មិនស្គាល់ និយាយដូចនិយាយជាមួយភិក្ខុណាមួយ ដូចលាដៃចាប់អាសិរពិសដែលកំពុងបើកពពារត្រង់ក កាលនឹងឃាត់ ទើបពោលពាក្យជាដើមដូច្នេះថា **មា អាវុសោ ទាយបាល** ដូច្នេះ ។ បទថា **តេនុបសង្កមិ** សេចក្ដីថា ព្រោះហេតុអ្វី មិនធ្វើការទទួលព្រះមានព្រះភាគហើយ ទើបចូលទៅគាល់ ។ បានឮថា ព្រះអនុរុទ្ធ មានសេចក្ដីត្រិះរិះយ៉ាងនេះ ពួកយើង ៣ នាក់ នៅព្រមព្រៀងគ្នា ក៏នឹងមិនមាន យើងនឹងនាំយកមិត្រដែលជាទីស្រឡាញ់ទៅធ្វើការទទួលព្រះមានព្រះភាគជាទីស្រឡាញ់របស់យើង យ៉ាងណា ក៏ជាទីស្រឡាញ់របស់សម្លាញ់នៃយើងយ៉ាងនោះ ដូច្នេះ ជាអ្នកប្រាថ្នានឹងធ្វើការទទួលព្រមដោយបិយមិត្រទាំងនោះ ទើបមិនធ្វើដោយខ្លួនឯង ចូលទៅគាល់ ឯអាចារ្យពួកខ្លះពោលថា ផ្លូវជាទីយាងមករបស់ព្រះមានព្រះភាគ មាននៅខាងចុងបំផុតនៃទីចង្ក្រម ជិតគ្នានឹងបណ្ណសាលារបស់ព្រះថេរៈទាំងនោះ ព្រោះដូច្នោះ ទើបព្រះថេរៈទៅឲ្យសញ្ញាដល់ព្រះថេរៈទាំងនោះ ។ បទថា **អភិក្កមថ** ប្រែថា

មកផ្លូវនេះចុះ ។ បទថា **ចាទេ បក្ខាលេសិ** សេចក្តីថា ព្រះថេរៈកាន់យកទឹកពណ៌កែវមណី ដោយដៃដែលប្រកបដោយក្រឡាសំណាញ់ ស្រដៀងនឹងផ្កាឈូករីក ស្រោចត្រង់ខ្នងព្រះបាទទាំង ២ មានពណ៌ដូចមាស ជម្រះព្រះបាទ ធូលីមិនបានពាល់ត្រូវព្រះវរកាយរបស់ព្រះសម្ពុទ្ធឡើយ ។ សួរថា ព្រោះហេតុអ្វី ទើបចាំបាច់លាង ឆ្លើយថា ដើម្បីកំណត់ឧតុរបស់ព្រះវរកាយ និងដើម្បីឲ្យចិត្តរបស់ភិក្ខុទាំងនោះត្រេកអរ ចិត្តរបស់ភិក្ខុទាំងនោះឆ្អែតដោយសោមនស្សដ៏មានកម្លាំងថា ព្រះមានព្រះភាគទ្រង់លាងព្រះបាទដោយទឹកដែលអញនាំមកហើយ ទ្រង់បានធ្វើការប្រើប្រាស់ដូច្នេះ ព្រោះដូច្នោះ ទើបលាង ។

[ ២ ] បទថា **អាយស្មន្តំ អនុរុទ្ធំ ភគវា ឯតទវោច** សេចក្តីថា បានឮថា ព្រះអនុរុទ្ធនោះ ចាស់ជាងភិក្ខុទាំងនោះ កាលធ្វើការសង្គ្រោះដល់អនុរុទ្ធនោះ ក៏ឈ្មោះថា ធ្វើដល់ភិក្ខុដ៏សេសផងដែរ ព្រោះដូច្នោះ ព្រះមានព្រះភាគបានត្រាស់ពាក្យជាដើមនេះថា **កច្ចិ វោ អនុរុទ្ធា** ដូច្នេះ ព្រោះព្រះថេរៈមួយអង្គ ។ បណ្តាបទទាំងនោះ បទថា **កច្ចិ** ជានិបាត ចុះក្នុងអត្ថថាពាក្យសួរ ។ បទថា **វោ** ជាឆដ្ឋីវិភត្តិ មានអធិប្បាយថា ព្រះមានព្រះភាគត្រាស់សួរដល់ភិក្ខាចារវត្តថា ម្នាលអនុរុទ្ធ ននិយៈ កិមិលៈ ពួកអ្នកល្មមអត់ធន់បានឬ ឥរិយាបថរបស់ពួកអ្នកអត់ធន់បានឬ ល្មមឲ្យប្រព្រឹត្តទៅបានឬ ពួកអ្នកល្មមញ៉ាំងជីវិតឲ្យរស់ គឺបន្តទៅបានឬ មិនលំបាកដោយដុំបាយទេឬ ពួកអ្នករកដុំបាយបានងាយឬ ពួកមនុស្សឃើញពួកអ្នកមកព្រមគ្នាហើយ ទើបសម្គាល់នូវបបរមួយបោយ ឬភិក្ខាមួយវែកដែលគួរប្រគេន ព្រោះដូច្នោះ ក៏

មិនលំបាកដោយបច្ច័យ អាចបំពេញសមណធម៌បាន ឬថា នេះជាវត្តរបស់បព្វជិត កាលបើដូច្នោះ ព្រះអង្គប្រទានចម្លើយហើយ កាលទ្រង់សួរដល់សាមគ្គីរសថា ម្នាលអនុរុទ្ធ កច្ចិ៍យៈ និងកិមិលៈ ពួកអ្នកជារាជបព្វជិតមានបុណ្យច្រើន ពួកមនុស្សមិនប្រគេនដល់ពួកអ្នក ដែលនៅក្នុងព្រៃហើយ នឹងសម្គាល់នូវវត្តដែលគួរឲ្យដល់អ្នកដទៃ ពួកអ្នកធាន់របស់នេះហើយ នៅក្បែរគ្នានឹងគ្នា ដូចកូនម្រឹគ ឬថា ពួកអ្នកមានការព្រមព្រៀងគ្នា ទើបត្រាស់ពាក្យជាដើមថា **កច្ចិ បន វោ អនុរុទ្ធា សមគ្គា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ខីរោទកីភូតា** សេចក្តីថា ទឹកដោះដែលផ្សំលាយគ្នានឹងគ្នា រមែងមិនបែកគ្នា ចូលដល់នូវសភាពតែមួយ ត្រាស់សួរថា ពួកអ្នកនៅដោយសាមគ្គីយ៉ាងនេះឬ ចិត្តប្បាទដល់នូវភាពតែមួយឬ ។ បទថា **បិយចក្ខូហិ** សេចក្តីថា ចក្ខុ គឺការចូលទៅតាំងមេត្តាចិត្តសម្លឹងមើល ឈ្មោះថា បិយចក្ខុ ។ ត្រាស់សួរថា ពួកអ្នកសម្លឹងមើលគ្នានឹងគ្នា ដោយចក្ខុបែបនោះឬ ។ បទថា **តគ្ឃ** ត្រឹមតែជានិបាត ចុះក្នុងអត្ថថា ចំណែកមួយ ដូចលោកពោលថា **អយំ ភន្តេ** ដោយចំណែកមួយ ។ បទថា **យថា** ក្នុងបទថា **យថាកថំ បន** នេះ ត្រឹមតែជានិបាត ។ បទថា **កថំ** ប្រែថា សួរដល់ហេតុ អធិប្បាយថា ពួកអ្នកនៅជាមួយគ្នាយ៉ាងនេះបានដូចម្តេច គឺនៅដោយហេតុអ្វី ពួកអ្នកចូរប្រាប់ហេតុនោះ ដល់តថាគតចុះ ។

[ ៣ ] បទថា **មេត្តំ កាយកម្មំ** បានដល់ កាយកម្មដែលប្រព្រឹត្តទៅដោយអំណាចមេត្តាចិត្ត ។ បទថា **អាវិ ចេវ រហោ ច** បានដល់ ចំពោះមុខ

និងកំបាំងមុខ ។ សូម្បីក្នុងបទក្រៅអំពីនេះ ក៏មានន័យនេះឯង ។

ក្នុងបទនោះ កាយកម្ម និងវចីកម្ម រមែងបានក្នុងការនៅរួមគ្នាចំពោះមុខ ក្រៅអំពីនេះ រមែងបានក្នុងការនៅបែកគ្នា មនោកម្មបានក្នុងទីទាំងអស់ ពិតហើយ កាលនៅរួមគ្នា គ្រែក្ដី តាំងក្ដី កណ្ដៈឈើក្ដី កណ្ដៈដីក្ដី ណាមួយដែលបុគ្គលណាម្នាក់ ទុកក្នុងទីមិនល្អ ខាងក្រៅ វត្ថុនោះ មិនធ្វើការមើលងាយថា វត្ថុនេះ បុគ្គលណាប្រើប្រាស់ហើយ កាន់យកមកទុកដាក់ ដូចដែលខ្លួនទុកដាក់មិនល្អ ឬរាំងប្រយ័ត្នក្នុងឋានៈដែលគួររាំងប្រយ័ត្ន ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។ កាលបុគ្គលណាមួយចៀសចេញទៅ ទុកដាក់សេនាសនបរិក្ខារមិនល្អ ឬឃ្លាំមើលទីដែលគួរឃ្លាំមើល ឈ្មោះថា មេត្តាកាយកម្មកំបាំងមុខ ។ កាលនៅរួមគ្នា ឈ្មោះថា មេត្តាវចីកម្មចំពោះមុខ រមែងមានក្នុងការធ្វើជាដើមយ៉ាងនេះថា សម្មោទនីយកថាដ៏ពីរោះ បដិសណ្ឋារៈសារាណីយកថា ធម្មកថា សរភញ្ញ សួរបញ្ហា ឆ្លើយបញ្ហាជាមួយព្រះថេរៈទាំងឡាយ ។ កាលព្រះថេរៈចៀសចេញទៅ ពោលគុណជាដើមថា ព្រះនន្ទិយត្ថេរ ព្រះកិម្ពិលត្ថេរ ជាសម្លាញ់របស់យើង ដល់ព្រមដោយសីលយ៉ាងនេះ ដល់ព្រមដោយអាចារយ៉ាងនេះ ឈ្មោះថា មេត្តាវចីកម្មកំបាំងមុខ ។ កាលប្រមូលមកយ៉ាងនេះថា សូមនន្ទិយត្ថេរ កិមិលត្ថេរ ដែលជាបិយមិត្ររបស់អញ ជាអ្នកមិនមានពៀរ ជាអ្នកមិនបៀតបៀន ជាអ្នកមានសេចក្ដីសុខចុះ ដូច្នេះ ឈ្មោះថា មេត្តាមនោកម្ម ទាំងចំពោះមុខ ទាំងកំបាំងមុខ ។

បទថា **នានា ហិ ខោ នោ ភន្តេ កាយា** សេចក្ដីថា បុគ្គលណាមួយ

មិនអាចធ្វើកាយឲ្យរួមគ្នាបាន ដូចជាការបុកម្សៅនឹងជីឥដ្ឋ ។ បទថា **ឯកញ្ច បន មញ្ញេចិត្តំ** លោកសម្តែងថា ឯចិត្តរបស់ពួកខ្ញុំព្រះអង្គ ឈ្មោះថា តែមួយដូចគ្នា ព្រោះអត្ថថា រួមគ្នាមិនដាច់សូន្យ មិនប្រាសចាកគ្នា ព្រមព្រៀងគ្នា សួរថា ភិក្ខុទាំងនោះរក្សាចិត្តរបស់ខ្លួន ប្រព្រឹត្តទៅតាមអំណាចចិត្តរបស់លោកក្រៅអំពីនេះដូចម្តេច ឆ្លើយថា ប្រែះកើតឡើងក្នុងបាត្ររបស់ភិក្ខុមួយរូប ចីវររបស់ភិក្ខុមួយរូបសៅហ្មង បរិកណ្ឌកម្ម រមែងមានដល់ភិក្ខុមួយរូប ។ បណ្តាភិក្ខុទាំងនោះ ប្រែះកើតឡើងត្រង់បាត្ររបស់បុគ្គលណា កាលបុគ្គលនោះប្រាប់ថា អ្នកមានអាយុ ប្រែះកើតឡើងត្រង់បាត្ររបស់ខ្ញុំ គួរអប់ ដូច្នេះ ភិក្ខុក្រៅអំពីនេះមិនពោលថា ចីវររបស់ខ្ញុំសៅហ្មង គួរបោក គ្រឿងប្រើប្រាស់របស់ខ្ញុំ គួរធ្វើ ដូច្នេះហើយ ចូលព្រៃ នាំឧសមកកាត់ជាកំណាត់ ទុកលើបាត្រ ដុតបាត្រហើយ បន្ទាប់មក ក៏បោកចីវរខ្លះ ធ្វើរបស់ប្រើប្រាស់ខ្លះ ។ កាលភិក្ខុរូបណាមួយប្រាប់មុនថា អាវុសោ ចីវររបស់ខ្ញុំសៅហ្មង គួរដល់ការបោក បណ្ណសាលារបស់ខ្ញុំទ្រុឌទ្រោម គួរជួសជុលជាថ្មី ដូច្នេះ ក៏មានន័យដូចគ្នា ។

[ ៤ ] បទថា **សាធុ សាធុ អនុរុទ្ធា** សេចក្តីថា កាលភិក្ខុក្រាបទូលខាងដើមថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គមិនលំបាកដោយបិណ្ឌបាត ដូច្នេះ ព្រះមានព្រះភាគ ទ្រង់មិនប្រទានសាធុការ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា កពឡិង្ការាហាររបស់សត្វទាំងនេះ ប្រព្រឹត្តមកជាអាចិណ្ណ ឯលោកសន្និវាសនេះខុសគ្នាដោយច្រើន ។ សត្វទាំងនេះខុសចិត្តគ្នា ទាំងក្នុង

អបាយលោក ទាំងក្នុងទេវតា និងមនុស្សលោក វេលាដែលសត្វទាំងនោះ ព្រមព្រៀងគ្នារកបានលំបាក មានបានម្តងម្កាលប៉ុណ្ណោះ ហេតុដូច្នោះ ព្រះមានព្រះភាគបានប្រទានសាធុការក្នុងទីនេះ ព្រោះការនៅព្រមព្រៀងគ្នា រកបានដោយក្រ ។

ឥឡូវនេះ កាលត្រាស់សួរលក្ខណៈ ការមិនប្រមាទរបស់ភិក្ខុទាំងនោះ ទើបត្រាស់ពាក្យជាដើមថា **កច្ចិ បន វោ អនុរុទ្ធា** ។ បណ្តាបទទាំងនោះ បទថា **វោ** ត្រឹមតែជានិបាត ម្យ៉ាងទៀត ជាបឋមាវិភត្តិ សេចក្តីថា **កច្ចិ តុម្ហេ** ដូច្នេះ ។ បទថា **អម្ហាកំ** គឺក្នុងពួកយើង ៣ នាក់ ។ បទថា **បិណ្ឌាយ បដិក្កមតិ** សេចក្តីថា ត្រាច់ទៅបិណ្ឌបាតក្នុងភូមិខាងក្រោយ ។ បទថា **អវក្ការបាតិំ** សេចក្តីថា បោលបិណ្ឌបាតដែលសល់ លាងភាជនៈនីមួយៗ តាំងទុកដើម្បីរក្សា ។ បទថា **យោ បច្ឆា** សេចក្តីថា បានឮថា ព្រះថេរៈទាំងនោះចូលទៅបិណ្ឌបាតមិនព្រមគ្នា ។ ព្រះថេរៈទាំងនោះ ចេញអំពីផលសមាបត្តិ ជម្រះរាងកាយអំពីព្រលឹម បំពេញបដិបទា ចូលទៅកាន់សេនាសនៈ កំណត់វេលា អង្គុយចូលផលសមាបត្តិ បណ្តាព្រះថេរៈទាំងនោះ អង្គណាដែលអង្គុយមុន ក្រោកឡើងមុន ដោយការកំណត់វេលារបស់ខ្លួន រូបនោះត្រាច់បិណ្ឌបាតត្រឡប់មកកន្លែងឆាន់អាហារ រមែងដឹងថា ភិក្ខុ ២ រូប មកតាមក្រោយ អាត្មាអញមកមុន កាលបើដូច្នោះ រៀបចំបាត្រ ក្រាលអាសនៈជាដើម បើក្នុងបាត្រមានល្មម លោកក៏គង់ឆាន់ បើមានសល់ ចាប់ទុកក្នុងថាសបម្រុង បិទថាសទុកហើយឆាន់ ធ្វើភត្តកិច្ចស្រេចហើយ លាងបាត្រ ជូត

ទឹកឲ្យអស់ ដាក់ក្នុងស្រោម ទុកដាក់អាសនៈ កាន់បាត្រ និងចីវរ ចូលទៅកាន់ទីសម្រាករបស់ខ្លួន ។ សូម្បីរូបទី ២ មកហើយ ដឹងបានថា មួយរូបមកមុន មួយរូបខាងក្រោយ បើក្នុងបាត្រមានភត្តល្មមប្រមាណ លោកក៏ឆាន់ បើមានតិច កាន់យកអំពីថាសបម្រុងហើយឆាន់ បើមានសល់ ដាក់ទុកក្នុងថាសបម្រុង ឆាន់តែល្មមប្រមាណ ចូលទៅកាន់ទីសម្រាក ដូចព្រះថេរៈអង្គមុន ។ សូម្បីរូបទី ៣ មកហើយ រមែងដឹងថា ២ រូបមកមុន អាត្មាអញមកតាមក្រោយ លោកធ្វើភត្តកិច្ចស្រេច ដូចព្រះថេរៈរូបទី ២ ក៏លាងបាត្រជូតឲ្យអស់ទឹក ដាក់ក្នុងស្បោក សាអាសនៈឡើងរក្សាទុក ដាក់ទឹកសល់ទៅក្នុងក្អមផឹក ឬក្អមសម្រាប់ប្រើប្រាស់ ហើយផ្កាប់ឆ្នាំង កាលមានភត្តនៅសល់ក្នុងថាសបម្រុង នាំភត្តនោះទៅ ដោយន័យដែលពោលហើយ លាងថាសបោសប្រាសក្នុងរោងឆាន់ ។ តមក ចាក់សំរាមចោល លើកអំបោសឡើងរក្សាក្នុងទីដែលផុតអំពីកណ្ដៀរ កាន់បាត្រ និងចីវរ ចូលទៅទីសម្រាក នេះជាវត្តក្នុងរោងឆាន់ ក្នុងទីធ្វើភត្តកិច្ចក្នុងព្រៃ ខាងក្រៅវិហាររបស់ព្រះថេរៈទាំង-ឡាយ ទ្រង់សំដៅដល់សេចក្ដីនេះ ទើបត្រាស់ពាក្យជាដើមថា **យោ បឋា** ដូច្នេះ ។

ឯបទជាដើមថា **យោ បស្សតិ** គប្បីជ្រាបថា ជាវត្តខាងក្នុងវិហារនៃព្រះថេរៈទាំងឡាយ ។ បណ្ដាបទទាំងនោះ បទថា **វច្ចកុដំ** ប្រែថា ឆ្នាំងជម្រះ ។ បទថា **រិត្តំ** គឺទទេ ។ បទថា **តុច្ឆកំ** ជាវេវចនៈរបស់បទថា **រិត្តំ** នោះឯង ។ បទថា **អវិសយ្ហំ** បានដល់ មិនអាចនឹងលើកឡើងបាន គឺ

ជូន់ពេក ។ បទថា **ហត្ថវិការេន** គឺដោយសញ្ញាដៃ បានឮថា ព្រះថេរៈទាំង នោះកាន់ក្អមទឹកណាមួយ មានក្អមទឹកផឹកជាដើម ទៅស្រះបោក្ខរណី លាង ខាងក្នុង និងខាងក្រៅហើយ ត្រងទឹកថ្វាទុកត្រង់មាត់ប្រាំង ហៅភិក្ខុអន្តជទៃ មក ដោយវិការនៃដៃ មិនបន្ទឺសំឡេងចំពោះ មិនឧទ្ទិសចំពោះ សួរថា ព្រោះ ហេតុអ្វី មិនបញ្ចេញសំឡេងចំពោះ ឆ្លើយថា សំឡេង គប្បីបៀតបៀនភិក្ខុ ទាំងនោះ ។ សួរថា ព្រោះហេតុអ្វី ទើបមិនចំពោះ ឆ្លើយថា កាលហៅ ដោយមិនចំពោះ ភិក្ខុ ២ រូប គប្បីចេញទៅដោយយល់ថា ខ្ញុំមុនៗ ដូច្នេះ ។ បន្ទាប់អំពីក្នុងការងារ ២ រូបគប្បីធ្វើ អង្គទី ៣ គប្បីសម្រាក លោកជាអ្នក សង្រួមក្នុងសំឡេង ទៅជិតទីសម្រាកពេលថ្ងៃរបស់ភិក្ខុមួយរូប ដឹងថា លោក ឃើញហើយ ធ្វើសញ្ញាដៃ ភិក្ខុនេះរមែងមកដោយសញ្ញានោះ បន្ទាប់អំពីនោះ ជនទាំង ២ យកដៃស្រោក់គ្នា ក្រោកឡើង ដាក់ទឹកលើដៃទាំង ២ ទើបព្រះ មានព្រះភាគត្រាស់សំដៅយកសេចក្តីនោះថា **ហត្ថវិការេន ទុតិយំ អាមន្តេត្វា ហត្ថវិលង្ឃកេន ឧដ្ឋបេម** ដូច្នេះ ។ បទថា **បញ្ចាហិកំ ខោ បន** សេចក្តីថា ពាក្យថា ក្នុងថ្ងៃ ១៤ ឬថ្ងៃ ១៥ តិថីទី ៨ ជាថ្ងៃធម្មស្សវនៈតាមប្រក្រតីមុន ព្រះថេរៈទាំង ២ រូប ស្រង់ទឹកក្នុងវេលាមិនទាន់ងងឹតប៉ុន្មាន រាល់ៗ ថ្ងៃ ធ្វើ វត្តនោះមិនឲ្យដាច់ រមែងទៅកាន់ទីសម្រាករបស់ព្រះអនុរុទ្ធ ។ ព្រះថេរៈទាំង ៣ រូបអង្គុយក្នុងទីនោះ សួរបញ្ហា ឆ្លើយបញ្ហាដល់គ្នានឹងគ្នា ក្នុងព្រះត្រៃបិដក បិដកណាមួយ ព្រះថេរៈទាំងនោះធ្វើយ៉ាងនេះ រហូតដល់អរុណរះឡើង ។ បទ ថា **កច្ចិ បន វោ អនុរុទ្ធា អប្បមត្តា អាតាបិនោ បហិតត្តា វិហរថ** នេះ

ព្រះមានព្រះភាគត្រាស់សំដៅដល់សេចក្តីនោះ ។

ព្រះថេរៈ ត្រូវព្រះមានព្រះភាគ ត្រាស់សួរលក្ខណៈនៃការមិនប្រមាទ ហើយឆ្លើយលក្ខណៈនៃការមិនប្រមាទទីតាំងនៃសេចក្តីប្រមាទ ដោយពាក្យថា វេលាចូលទៅទីកិច្ចាចារ វេលាចេញអំពីទីកិច្ចាចារ ការស្លៀកស្បង់ ការដណ្តប់ចីវរ ការត្រាច់ទៅដើម្បីបិណ្ឌបាតខាងក្នុងភូមិ ធម្មកថា អនុមោទនា ការចេញអំពីភូមិ ហើយធ្វើភត្តកិច្ច ការលាងបាត្រ ការទុកដាក់បាត្រ និងចីវរឲ្យរៀបរយ ទាំងនេះជាការធ្វើឲ្យយឺតយូរសម្រាប់ភិក្ខុពួកដទៃ ព្រោះដូច្នោះ ព្រះថេរៈកាលសម្តែងថា ដែលឈ្មោះថា វេលាប្រមាទ មិនមានដល់ខ្ញុំព្រះអង្គ ព្រោះការបណ្តែតបណ្តោយ មានប្រមាណប៉ុណ្ណេះបានហើយ ទើបឆ្លើយលក្ខណៈនៃការមិនប្រមាទក្នុងទីតាំងនៃសេចក្តីប្រមាទថ្វាយ ។

[ ៥ ] លំដាប់នោះ ព្រះមានព្រះភាគ ប្រទានសាធុការដល់ព្រះថេរៈនោះហើយ កាលនឹងត្រាស់សួរបឋមជ្ឈាន ទើបត្រាស់បទថា **អត្ថិ បន វោ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ឧត្តរិមនុស្សធម្មា** គឺធម៌ដ៏ក្រៃលែងជាងធម៌របស់មនុស្ស ។ បទថា **អលមរិយញាណទស្សនវិសេសោ** បានដល់ គុណវិសេស គឺញាណទស្សនៈ អាចធ្វើភាពជាព្រះអរិយៈ ។ បទថា **កឹ ហិ នោ សិយា ភន្តេ** សេចក្តីថា ព្រោះហេតុអ្វី គុណវិសេសដែលសម្រេចហើយ នឹងមិនសម្រេចទៅវិញ ។ បទថា **យាវទេវ** គឺដរាបណានោះឯង ។ កាលការសម្រេចបឋមជ្ឈាន ដែលព្រះថេរៈឆ្លើយចង្អុលបង្ហាញហើយយ៉ាងនេះ ព្រះមានព្រះភាគ កាលត្រាស់សួរទុតិយជ្ឈានជាដើម ទើប

ត្រាស់ថា **ឯតស្ស បន ភោ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **សមតិក្កមាយ** គឺដើម្បីការឈានកន្លង ។ បទថា **បដិបស្សទ្ធិយា** គឺដើម្បីការស្ងប់រម្ងាប់ ។ បទដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងបទទាំងពួង ។ ឯក្នុងបញ្ហាចុងក្រោយ កាលត្រាស់សួរនិរោធសមាបត្តិ ដែលបានសម្រេចដោយអំណាចលោកុត្តរញាណទស្សនៈ ទើបត្រាស់ថា **អលមរិយញ្ញាណទស្សនវិសេសោ** ដូច្នេះ ។ ព្រះថេរៈឆ្លើយចម្លើយបង្ហាញតាមសមគួរដល់ការសាកសួរ ។ ក្នុងសេចក្ដីនោះ ព្រះថេរៈពោលថា ព្រោះសេចក្ដីសុខដែលមិនបានសោយ ស្ងប់ជាង ប្រណីតជាងសេចក្ដីសុខដែលសោយហើយ ដូច្នោះ ពួកខ្ញុំព្រះអង្គមិនទាន់ពិចារណាឃើញផាសុកវិហារដទៃដែលក្រៃលែងជាង ប្រណីតជាងឡើយ ។

[ ៦ ] បទថា **ធម្មិយា កថាយ** សេចក្ដីថា ភិក្ខុទាំងពួងសម្រេចកិច្ចក្នុងសច្ចៈទាំង ៤ ដោយធម្មកថា ប្រកបដោយអានិសង្សនៃសាមគ្គីរស មិនមានពាក្យណាមួយដែលលោកគប្បីពោលដើម្បីប្រយោជន៍ ដល់ការសម្រេចសច្ចៈទាំងនោះ ឯព្រះមានព្រះភាគត្រាស់អានិសង្ស នៃសាមគ្គីរសដល់ភិក្ខុទាំងនោះថា នេះជាអានិសង្ស និងនេះជាអានិសង្ស ដូច្នេះ ដោយសាមគ្គីរស ។ បទថា **ភគវន្តំ អនុសំយាយិត្វា** គឺតាមជាប់ព្រះមានព្រះភាគ បានឮថា ភិក្ខុទាំងនោះទទួលបាត្រ និងចីវររបស់ព្រះមានព្រះភាគទៅបានបន្តិច ។ ក្នុងវេលាដែលភិក្ខុទាំងនោះជូនព្រះមានព្រះភាគ ទៅដល់ទីបំផុតបរិវេណនៃវិហារ ទើបព្រះមានព្រះភាគត្រាស់ថា ឲ្យបាត្រ និងចីវររបស់តថាគតមកចុះ ពួកអ្នកចូរ

នៅក្នុងទីនេះ ហើយទ្រង់ចៀសចេញទៅ ។ បទថា **តតោ បដិនិវត្តិត្វា** បានដល់ ត្រឡប់អំពីទីដែលទៅហើយ ។ បទថា **កិន្នុ ខោ មយំ អាយស្មន្តោ** សេចក្តីថា ភិក្ខុទាំងឡាយ អាស្រ័យព្រះមានព្រះភាគ សម្រេចគុណ មានបព្វជ្ជាជាដើម ក៏វង្វៀសដោយការពោលគុណរបស់ខ្លួន ពោលហើយ ព្រោះជាបុគ្គលប្រាថ្នាតិចក្នុងមគ្គផលដែលសម្រេច ។ បទថា **ឥមាសញ្ច ឥមាសញ្ច** បានដល់ លោកិយធម៌ និងលោកុត្តរធម៌ មានបឋមជ្ឈានជាដើម ។ បទថា **ចេតសា ចេតោ បរិច្ច វិទិតោ** សេចក្តីថា ព្រះថេរៈកំណត់ចិត្តដោយចិត្ត ហើយដឹងយ៉ាងនេះថា ថ្ងៃនេះ លោកដ៏មានអាយុរបស់យើង ញ៉ាំងវេលាឲ្យកន្លងទៅដោយលោកិយសមាបត្តិ ថ្ងៃនេះ ញ៉ាំងវេលាឲ្យកន្លងទៅដោយលោកុត្តរសម្បត្តិ ។ បទថា **ទេវតាបិ មេ** សេចក្តីថា សូម្បីពួកទេវតាប្រាប់យ៉ាងនេះថា បពិត្រលោកម្ចាស់អនុរុទ្ធដ៏ចម្រើន ថ្ងៃនេះ ព្រះនន្ទិយត្ថេរញ៉ាំងវេលាឲ្យកន្លងទៅដោយសមាបត្តិនេះ ថ្ងៃនេះ ព្រះកិមិលត្ថេរញ៉ាំងវេលាឲ្យកន្លងទៅដោយសមាបត្តិនេះ ។ បទថា **បញ្ហាភិបុដ្ឋេន** សេចក្តីថា យើងត្រៀមមាត់ដោយហេតុមានប្រមាណប៉ុណ្ណេះថា សេចក្តីនោះខ្ញុំដឹងហើយដោយខ្លួនឯង ឬទេវតាប្រាប់ដូច្នេះ ។ លើកពាក្យសម្តីដែលមិនទាន់សួរ ក៏មិនសាកសួរ ។ ឯព្រះមានព្រះភាគត្រូវសួរបញ្ហា គឺត្រូវកំពុងសួរបញ្ហា ទ្រង់ឆ្លើយចន្លលបង្ហាញ ទើបត្រាស់ថា មិនទាន់ពេញចិត្តក្នុងសេចក្តីនោះឬ ។

[ ៧ ] បទថា **ទីឃោ** មកហើយក្នុងគាថាយ៉ាងនេះថា **មណិ មានិចរោ ទីឃោ អថោ សេរីសកោ សហ** គឺជាឈ្មោះរបស់ទេវរាជមួយអង្គ ក្នុងចំនួន

យក្ខសេនាបតីទាំង ២៨ អង្គ យក្ខនេះមកក្រាបទូលព្រះសាស្តា ។ បទថា **បរជនោ** ជាឈ្មោះរបស់យក្ខនោះ ។ បទថា **យេន ភគវា តេនុបសង្កមិ** សេចក្តីថា បានឮថា យក្ខនោះ ត្រូវស្តេចវេស្សវ័ណបញ្ជូនទៅហើយ កាល ទៅកាន់ទីមួយ ឃើញព្រះមានព្រះភាគ ទ្រង់កាន់បាត្រ និងចីវរដោយព្រះអង្គ ឯង ចេញអំពីទីសម្រាកដែលធ្វើដោយឥដ្ឋ ចន្លោះព្រៃគោសិង្គសាលវ័ន គិត ថា ព្រះមានព្រះភាគទ្រង់កាន់បាត្រ និងចីវរដោយព្រះអង្គឯង យាងទៅកាន់ សម្នាក់របស់កុលបុត្រទាំង ៣ ក្នុងព្រៃគោសិង្គសាលវ័ន ព្រះធម្មទេសនានឹង មានច្រើនក្នុងថ្ងៃនេះ ដូច្នេះ អញគប្បីជាអ្នកមានចំណែកនៃទេសនានោះ ដើរ តាមស្នាមព្រះបាទរបស់ព្រះសាស្តា ដោយកាយដែលប្រាកដ ឈរស្តាប់ធម៌ ក្នុងទីដែលមិនឆ្ងាយ កាលព្រះសាស្តាយាងទៅ ក៏មិនទៅឈរក្នុទីនោះ ដើម្បី មើលថា ព្រះថេរៈទាំងនោះនឹងធ្វើអ្វីទៀត ដូច្នេះ ក្នុងខណៈនោះ ឃើញព្រះ ថេរៈទាំង ២ រូបនោះ ជាប់ជំពាក់ក្នុងព្រះអនុរុទ្ធ គិតថា ព្រះថេរៈទាំងនេះ អាស្រ័យព្រះមានព្រះភាគសម្រេចគុណទាំងពួង មានបព្វជ្ជាជាដើម កំណាញ់ ចំពោះព្រះមានព្រះភាគ មិនក្លាហាន លាក់ខ្លួនពន់ពេក ជាអ្នកបិទបាំង ឥឡូវ នេះ អញនឹងមិនឲ្យលោកបិទបាំង អញនឹងប្រកាសគុណរបស់ព្រះថេរៈទាំង នោះនៅលើផែនដី រហូតដល់ព្រហ្មលោក ។ ទើបចូលទៅគាល់ព្រះមានព្រះ ភាគដល់ទីប្រថាប់ ។ បទថា **លាភា ភន្តេ** សេចក្តីថា បពិត្រព្រះអង្គដ៏ ចម្រើន អ្នកដែនវជ្ជីរមែងបានគាល់ព្រះមានព្រះភាគ និងបានឃើញកុលបុត្រ ទាំង ៣ នេះ រមែងបានថ្វាយបង្គំ ប្រគេនទេយ្យធម៌ បពិត្រព្រះអង្គដ៏ចម្រើន

ជាលាភរបស់អ្នកដែនវជ្ជីទាំងនោះ ។ បទថា **សទ្ទំ សុត្វា** សេចក្តីថា បានឮថា យក្ខនោះបញ្ចេញសំឡេងខ្លាំង ដោយអានុភាពនៃយក្ខ បន្ទឹវាចានោះគ្រប ដណ្តប់ដែនវជ្ជីទាំងមូល ។ ព្រោះដូច្នោះ ភុម្មទេវតាដែលស្ថិតនៅត្រង់ដើមឈើ និងភ្នំជាដើមនោះៗ បានឮសំឡេងរបស់យក្ខនោះ ។ លោកសំដៅយកសេចក្តីនោះ ទើបពោលថា **សទ្ទំ សុត្វា** ដូច្នេះ ។ បទថា **អនុស្សាវេសុំ** បានដល់ បានឮសំឡេងខ្លាំងហើយ ក៏ស្រែកប្រកាសតទៅ ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។

[ ៨ ] បទថា **យាវ ព្រហ្មលោកា** បានដល់ រហូតដល់អកនិដ្ឋព្រហ្មលោក ។ បទថា **តញ្ចេបិ កុលំ** សេចក្តីថា គប្បីជ្រាបអត្ថក្នុងបទទាំងពួងយ៉ាងនេះថា កុលបុត្រទាំងនេះចេញអំពីត្រកូលរបស់យើងបួសហើយ មានសីលគុណ ដល់ព្រមដោយអាចារ មានកល្យាណធម៌យ៉ាងនេះ បើត្រកូលនោះមានចិត្តជ្រះថ្លា គប្បីរឭកដល់កុលបុត្រទាំង ៣ នោះយ៉ាងនេះ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ធម្មទេសនាដោយអនុសន្ធិ ដោយប្រការដូច្នេះឯង ៚

**ចូឡគោសិង្គសាលសូត្រ ចប់**

**សូត្រទី ១ ចប់**

# សុត្តន្តបិដក

## មហាគោសិង្គសាលសូត្រទី ២

[ ៩ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃគោសិង្គសាលវ័ន ជាមួយនឹងព្រះថេរៈជាសាវ័ក សុទ្ធតែមាននាមល្បីល្បាញ ជាច្រើនអង្គ គឺព្រះសារីបុត្រមានអាយុ ១ ព្រះមោគ្គ-ល្លានមានអាយុ ១ ព្រះមហាកស្សបមានអាយុ ១ ព្រះអនុរុទ្ធមានអាយុ ១ ព្រះរេវតមានអាយុ ១ ព្រះអានន្ទមានអាយុ ១ មួយអន្លើនឹងព្រះថេរៈ ជាសាវ័ក ដែលសុទ្ធតែមាននាមល្បីល្បាញឯទៀតផង ។គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុ ចេញចាកទីសម្ងំ ក្នុងសាយ័ណ្ហសម័យ ហើយចូលទៅរកព្រះមហាកស្សបមានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះមហាកស្សបមានអាយុយ៉ាងនេះថា ម្នាលអាវុសោកស្សប យើងទាំងឡាយនឹងចូលទៅរកព្រះសារីបុត្រមានអាយុ ដើម្បីស្តាប់ធម៌ ។ ព្រះមហាកស្សបមានអាយុ ទទួលស្តាប់ព្រះមហាមោគ្គល្លានមានអាយុថា ករុណាអាវុសោ ។ គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុ ព្រះមហាកស្សបមានអាយុ និងព្រះអនុរុទ្ធមានអាយុ ក៏ចូលទៅរកព្រះសារីបុត្រមានអាយុ ដើម្បីស្តាប់ធម៌ ។ ព្រះអានន្ទមានអាយុ បានឃើញព្រះមហាមោគ្គល្លានមានអាយុ ព្រះមហាកស្សបមានអាយុ និងព្រះអនុរុទ្ធមានអាយុ កំពុងដើរចូលទៅរកព្រះសារីបុត្រមានអាយុដើម្បីស្តាប់ធម៌ លុះឃើញហើយ ក៏ចូលទៅរកព្រះរេវតៈមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះរេវតៈមានអាយុយ៉ាងនេះថា ម្នាលអាវុសោរេវតៈ ពួកលោកជាសប្បុរសឯណោះ កំពុងចូលទៅរកព្រះសារីបុត្រ

មានអាយុដើម្បីស្តាប់ធម៌ ម្នាលអាវុសោរេវតៈ មក យើងនឹងចូលទៅរកព្រះសារីបុត្រមានអាយុដើម្បីស្តាប់ធម៌ ។ ព្រះរេវតៈមានអាយុ ទទួលស្តាប់ព្រះអានន្ទមានអាយុថា ករុណាអាវុសោ ។ គ្រានោះឯង ព្រះរេវតៈមានអាយុ និងព្រះអានន្ទមានអាយុ ក៏ចូលទៅរកព្រះសារីបុត្រមានអាយុ ដើម្បីស្តាប់ធម៌ ។

[ ១០ ] ព្រះសារីបុត្រមានអាយុ បានឃើញព្រះរេវតៈមានអាយុ និងព្រះអានន្ទមានអាយុ កំពុងដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏និយាយនឹងព្រះអានន្ទមានអាយុយ៉ាងនេះថា អានន្ទមានអាយុ ចូរចូលមក អានន្ទមានអាយុ ជាឧបដ្ឋាករបស់ព្រះមានព្រះភាគ ជាអ្នកដើរជិតជិតតាមព្រះមានព្រះភាគ មកល្អហើយ ម្នាលអាវុសោ អានន្ទ គោសិង្គសាលវ័ននេះ គួរឲ្យរីករាយ រាត្រីសោត ក៏ប្រាសចាកទោស ដើមឈើទាំងឡាយ ក៏មានផ្ការីកស្គុសស្គាយ សព្វកន្លែង មានក្លិនក្រអូប គួរនាដូចក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោអានន្ទ ចុះព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុបណា ។ ព្រះអានន្ទតបថា ម្នាលអាវុសោ សារីបុត្រ ភិក្ខុក្នុងសាសនានេះ ជាអ្នកចេះចាំច្រើន ទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ធម៌ទាំងឡាយណា មានលម្អក្នុងបទដើម មានលម្អក្នុងបទកណ្តាល មានលម្អក្នុងបទចុង ប្រកបដោយអត្ថព្រមទាំងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះ ក៏ចេះចាំច្រើន ស្ទាត់ជំនាញរត់មាត់ពិចារណាដោយចិត្ត ចាក់ធ្លុះប្រពៃដោយទិដ្ឋិ ភិក្ខុនោះ រមែងសម្តែងធម៌ដល់បរិស័ទទាំង ៤ ដោយបទ និងព្យញ្ជនៈទាំងឡាយ ជាបរិមណ្ឌលជាប់តគ្នា

ដើម្បីគាស់រម្លើងនូវអនុស័យ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបនេះ ។

[ ១១ ] កាលបើព្រះអានន្ទមានអាយុ និយាយយ៉ាងនេះហើយ ព្រះសារីបុត្រមានអាយុ បាននិយាយនឹងព្រះរេវតៈមានអាយុ យ៉ាងនេះថា ម្នាលអាវុសោរេវតៈ អានន្ទមានអាយុ បានព្យាករនូវបដិភាណជារបស់ខ្លួនហើយ ឥឡូវនេះ យើងនឹងសួររេវតៈមានអាយុក្នុងសេចក្ដីនោះថា ម្នាលអាវុសោរេវតៈ ព្រៃគោសិង្គសាលវ័ននេះ គួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំង-ឡាយ ក៏មានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូប បីដូចជាក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោរេវតៈ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបណា ។ ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ មានការពួនសម្ងំជាទីរីករាយ ត្រេកអរក្នុងការពួនសម្ងំ ប្រកបរឿយៗ ក្នុងការស្ងប់រម្ងាប់ចិត្តដ៏ប្រព្រឹត្តទៅក្នុងខាងក្នុង មានឈានមិនសាបសូន្យ ឬមិនបានប្រាសចាកឈានប្រកបដោយវិបស្សនាបញ្ញា ទាំងចម្រើននូវសុញ្ញាគារធម៌ទាំងឡាយ ម្នាលអាវុសោសារីបុត្រព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបនេះឯង ។

[ ១២ ] កាលបើព្រះរេវតៈមានអាយុ និយាយយ៉ាងនេះហើយ ព្រះសារីបុត្រមានអាយុ បាននិយាយនឹងព្រះអនុរុទ្ធមានអាយុយ៉ាងនេះថា ម្នាលអាវុសោអនុរុទ្ធ រេវតៈមានអាយុ បានព្យាករបដិភាណជារបស់ខ្លួនហើយ ឥឡូវនេះ យើងនឹងសួរអនុរុទ្ធមានអាយុក្នុងសេចក្ដីនោះថា ម្នាលអាវុសោអនុរុទ្ធ ព្រៃគោសិង្គសាលវ័ន គួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំង-

ឡាយ ក៏មានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូប ដូចជាក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោអនុរុទ្ធ ព្រៃគោសិង្គសាលវ័ន រុងរឿងបានដោយសារភិក្ខុរូបណា ។ ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ មើលឃើញលោកធាតុទាំងមួយពាន់ ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្ស ម្នាលអាវុសោសារីបុត្រ ដូចជាបុរសមានចក្ខុ នៅលើប្រាសាទដ៏ប្រសើរ មើលឃើញមណ្ឌលខ្នងកង់មួយពាន់ ម្នាលអាវុសោសារីបុត្រ ភិក្ខុមើលឃើញលោកធាតុទាំងមួយពាន់ ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សក៏យ៉ាងនោះដែរ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គ-សាលវ័ន រុងរឿងបានដោយសារភិក្ខុរូបនេះឯង ។

[ ១៣ ] កាលបើព្រះអនុរុទ្ធ មានអាយុ និយាយយ៉ាងនេះហើយ ព្រះសារីបុត្រមានអាយុ បាននិយាយនឹងព្រះមហាកស្សបមានអាយុយ៉ាងនេះថា ម្នាលអាវុសោកស្សប អនុរុទ្ធមានអាយុ បានព្យាករនូវបដិភាណរបស់ខ្លួនហើយឥឡូវនេះ យើងនឹងសួរមហាកស្សបមានអាយុក្នុងសេចក្តីនោះថា ម្នាលអាវុសោកស្សប ព្រៃគោសិង្គសាលវ័ន គួររីករាយ រាត្រីក៏ប្រាសចាកទោសឈើទាំងឡាយ ក៏មានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូប បីដូចក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោកស្សប ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបណា ។ ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅក្នុងព្រៃខ្លួនឯងផង សរសើរគុណនៃអ្នកនៅព្រៃផង ជាអ្នកប្រព្រឹត្តបិណ្ឌបាតខ្លួនឯងផង សរសើរគុណនៃអ្នកប្រព្រឹត្តបិណ្ឌបាតផង ជាអ្នកទ្រទ្រង់

សំពត់បង្សុកូលផង សរសើរគុណនៃអ្នកទ្រទ្រង់សំពត់បង្សុកូលផង ជាអ្នកទ្រទ្រង់តែចីវរបីខ្លួនឯងផង សរសើរគុណនៃអ្នកទ្រទ្រង់តែចីវរបីផង ជាអ្នកឥតសេចក្ដីប្រាថ្នាខ្លួនឯងផង សរសើរគុណនៃអ្នកឥតសេចក្ដីប្រាថ្នាផង ជាអ្នកសន្ដោសខ្លួនឯងផង សរសើរគុណនៃសេចក្ដីសន្ដោសផង ជាអ្នកស្ងប់ស្ងាត់ខ្លួនឯងផង សរសើរគុណនៃសេចក្ដីស្ងប់ស្ងាត់ផង ជាអ្នកមិនច្រឡូកច្រឡំខ្លួនឯងផង សរសើរគុណនៃសេចក្ដីមិនច្រឡូកច្រឡំផង ជាអ្នកប្រុងប្រៀប ព្យាយាមខ្លួនឯងផង សរសើរសេចក្ដីប្រុងប្រៀបព្យាយាមផង ជាអ្នកបរិបូណ៌ដោយសីលខ្លួនឯងផង សរសើរការបរិបូណ៌ដោយសីលផង ជាអ្នកបរិបូណ៌ដោយសមាធិខ្លួនឯងផង សរសើរការបរិបូណ៌ដោយសមាធិផង ជាអ្នកបរិបូណ៌ដោយបញ្ញាខ្លួនឯងផង សរសើរការបរិបូណ៌ដោយបញ្ញាផង ជាអ្នកបរិបូណ៌ដោយវិមុត្តខ្លួនឯងផង សរសើរការបរិបូណ៌ដោយវិមុត្តិផង ជាអ្នកបរិបូណ៌ដោយវិមុត្តិញាណទស្សនៈខ្លួនឯងផង សរសើរការបរិបូណ៌ដោយវិមុត្តិញាណទស្សនៈផង ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវននេះ រុងរឿងដោយសារភិក្ខុរូបនេះឯង ។

[ ១៤ ] កាលបើព្រះមហាកស្សបមានអាយុ និយាយយ៉ាងនេះហើយ ព្រះសារីបុត្រមានអាយុ និយាយនឹងព្រះមហាមោគ្គល្លានមានអាយុ យ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន មហាកស្សបមានអាយុ បានព្យាករនូវបដិភាណជារបស់ខ្លួនហើយ ឥឡូវនេះយើងនឹងសួរ មហាមោគ្គល្លានមានអាយុ ក្នុងសេចក្ដីនោះថា ម្នាលអាវុសោមោគ្គល្លាន ព្រៃគោសិង្គសាលវននេះ គួរីករាយ

រាត្រីក៏ប្រាសចាកទោស ឈើទាំងឡាយ ក៏មានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូប បីដូចក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោមោគ្គល្លាន ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបណា ។ ម្នាលអាវុសោសារីបុត្រ ភិក្ខុទាំងឡាយពីររូបក្នុងសាសនានេះ សំដែងនូវអភិធម្មកថា ភិក្ខុទាំងនោះសួរគ្នានឹងគ្នា លុះសួរប្រស្នាហើយ ដោះស្រាយដល់គ្នានឹងគ្នា ក៏មិនបានរុករានគ្នាផង កថារបស់ភិក្ខុទាំងនោះ ប្រព្រឹត្តទៅប្រកបដោយធម៌ផង ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបនេះឯង ។

[ ១៥ ] គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុ បាននិយាយនឹងព្រះសារីបុត្រមានអាយុ យ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ ពួកយើងទាំងអស់គ្នាបានព្យាករ នូវបដិភាណជារបស់ខ្លួនហើយ ឥឡូវនេះ យើងនឹងសួរនូវព្រះសារីបុត្រមានអាយុក្នុងសេចក្ដីនោះថា ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន គួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំងឡាយ មានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូប បីដូចជាក្លិនទិព្វ ផ្សព្វផ្សាយទៅ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបណា ។ ម្នាលអាវុសោមោគ្គល្លាន ភិក្ខុក្នុងសាសនានេះ ញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចខ្លួនផង ភិក្ខុមិនបានប្រព្រឹត្តទៅតាមអំណាចនៃចិត្តផង ភិក្ខុនោះប្រាថ្នាដើម្បីនៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់បុព្វណ្ហ-សម័យ ដោយវិហារសមាបត្តិនោះបាន បើប្រាថ្នាដើម្បីនៅអស់មជ្ឈន្តិក-សម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់មជ្ឈន្តិកសម័យ ដោយវិហារ-

សមាបត្តិនោះបាន បើប្រាថ្នាដើម្បីនៅអស់សាយណ្ហសម័យ ដោយវិហារ-សមាបត្តិណា ក៏នៅអស់សាយណ្ហសម័យ ដោយវិហារសមាបត្តិនោះបាន ម្នាលអាវុសោមោគ្គល្លាន ដូចជាហិបសំពត់ ដ៏ពេញដោយសំពត់ទាំងឡាយ ជ្រលក់ហើយដោយពណ៌ផ្សេងៗ របស់ព្រះរាជា ឬរាជមហាមាត្រ ព្រះរាជា និងមហាមាត្រនោះ ប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណា អស់បុព្វណ្ហសម័យ ក៏ទ្រទ្រង់នូវគូសំពត់នោះៗ បាន អស់បុព្វណ្ហសម័យ បើប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណា អស់មជ្ឈន្តិកសម័យ ក៏ទ្រទ្រង់នូវគូសំពត់នោះៗ បាន អស់មជ្ឈន្តិកសម័យ បើប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណា អស់សាយណ្ហសម័យ ក៏ទ្រទ្រង់នូវគូសំពត់នោះៗ បាន អស់សាយណ្ហសម័យ ម្នាលអាវុសោ-មោគ្គល្លាន ភិក្ខុញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចខ្លួនផង ភិក្ខុមិនបានប្រព្រឹត្តទៅតាមអំណាចរបស់ចិត្តផង ភិក្ខុនោះ ប្រាថ្នាដើម្បីនៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិនោះបាន បើប្រាថ្នាដើម្បីនៅអស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់ មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិនោះបាន បើប្រាថ្នាដើម្បីនៅអស់សាយណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់សាយណ្ហ-សម័យ ដោយវិហារសមាបត្តិនោះបាន ក៏យ៉ាងនោះដែរ ម្នាលអាវុសោមោគ្គល្លាន ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបនេះឯង ។

[ ១៦ ] លំដាប់នោះឯង ព្រះសារីបុត្រមានអាយុ បាននិយាយនឹងព្រះថេរៈមានអាយុទាំងនោះ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ពួកយើងទាំង

អស់គ្នាបានព្យាករបដិភាណតាមសមគួរដល់ខ្លួនហើយ ម្នាលអាវុសោទាំង-ឡាយ មក យើងនឹងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ នឹងក្រាបទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ បើព្រះមានព្រះភាគនឹងព្យាករដល់យើងយ៉ាងណា យើងនឹងចាំទុកនូវសេចក្តីនោះយ៉ាងនោះ ។ ព្រះថេរៈមានអាយុទាំងនោះ ទទួលស្តាប់ព្រះសារីបុត្រមានអាយុ យ៉ាងនេះថា ម្នាលអាវុសោ យ៉ាងហ្នឹងហើយ ។ គ្រានោះឯង ព្រះថេរៈមានអាយុទាំងនោះ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបអភិវាទចំពោះព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ កាលព្រះសារីបុត្រមានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលចំពោះព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ រេវតៈមានអាយុ និងអានន្ទមានអាយុ នាំគ្នាចូលមករកខ្ញុំព្រះអង្គ ដើម្បីស្តាប់ធម៌ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញរេវតៈមានអាយុ និងអានន្ទមានអាយុ កំពុងដើរមកអំពីចម្ងាយ លុះឃើញហើយ បាននិយាយនឹងអានន្ទមានអាយុយ៉ាងនេះថា អានន្ទមានអាយុ ចូរចូលមក អានន្ទមានអាយុ ជាឧបដ្ឋាករបស់ព្រះមានព្រះភាគជាអ្នកដើរជិតដិតតាមព្រះមានព្រះភាគ មកល្អហើយ ម្នាលអាវុសោ អានន្ទព្រៃគោសិង្គសាលវ័ន គួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំងឡាយមានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូប ដូចជាក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោអានន្ទ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបណា បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ អានន្ទមាន

អាយុ បាននិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ ជាអ្នកចេះចាំច្រើន ទ្រទ្រង់នូវពុទ្ធវចនៈ ។បេ។ ដើម្បីគាស់រម្លើងអនុស័យ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបនេះឯង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្រ ត្រូវល្អហើយ អានន្ទព្យាករត្រឹមត្រូវតាមសេចក្តីពិត ម្នាលសារីបុត្រ ព្រោះថា អានន្ទជាអ្នកចេះចាំច្រើន ទ្រទ្រង់ទុកនូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ធម៌ទាំងឡាយណា មានលម្អក្នុងបទដើម មានលម្អក្នុងបទកណ្តាល មានលម្អក្នុងបទចុង ប្រកបដោយអត្ថ និងព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ អានន្ទក៏បានចេះចាំច្រើន ស្ទាត់រត់មាត់ ពិចារណាបានដោយចិត្ត ចាក់ធ្លុះដោយទិដ្ឋិ គឺបញ្ញា អានន្ទនោះតែងសម្តែងធម៌ដល់បរិស័ទទាំង ៤ ដោយបទ និងព្យញ្ជនៈទាំងឡាយ ជាបរិមណ្ឌលជាប់តគ្នាមិនដាច់ ដើម្បីគាស់រម្លើងនូវអនុសយក្កិលេស ។

[ ១៧ ] បពិត្រព្រះអង្គដ៏ចម្រើន កាលបើអានន្ទមានអាយុ និយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយនឹងរេវតៈមានអាយុយ៉ាងនេះថា ម្នាលអាវុសោរេវតៈ អានន្ទមានអាយុបានព្យាករនូវបដិភាណដ៏សមគួរដល់ខ្លួនហើយ ឥឡូវនេះ យើងសូមសួរចំពោះរេវតៈមានអាយុ ក្នុងសេចក្តីនោះថា ម្នាលអាវុសោរេវតៈ ព្រៃគោសិង្គសាលវ័ន គួររីករាយ រាត្រីក៏ប្រាសចាកទោស ឈើទាំងឡាយ មានផ្ការីកស្គុសស្គាយសព្វកន្លែង មានក្លិនក្រអូប បីដូចជាក្លិនទិព្វ ផ្សព្វផ្សាយទៅ ម្នាលអាវុសោរេវតៈ ព្រៃគោសិង្គសាលវ័ន រុងរឿង

ដោយសារភិក្ខុរូបណា បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ រេវតៈមានអាយុ ឆ្លើយតបនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ មានការពួនសម្ងំជាទីរីករាយ ត្រេកអរក្នុងការពួនសម្ងំ ប្រកបរឿយៗ នូវការស្ងប់ស្ងាត់ចិត្ត ប្រព្រឹត្តទៅខាងក្នុង មិនបានប្រាសចាកឈាន ប្រកបដោយវិបស្សនាបញ្ញា ជាអ្នកចម្រើននូវសុញ្ញាគារធម៌ទាំងឡាយ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័នរុងរឿងដោយសារភិក្ខុរូបនោះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសារីបុត្រ ត្រូវល្អហើយ រេវតៈព្យាករត្រឹមត្រូវតាមពិតមែនហើយ ម្នាលសារីបុត្រ ព្រោះថា រេវតៈជាអ្នកមានការពួនសម្ងំជាទីរីករាយ ត្រេកអរនឹងការពួនសម្ងំ ប្រកបរឿយៗ នូវការស្ងប់ស្ងាត់ចិត្ត ប្រព្រឹត្តទៅខាងក្នុង មិនបានប្រាសចាកឈាន ប្រកបដោយវិបស្សនាបញ្ញា ជាអ្នកចម្រើននូវសុញ្ញាគារធម៌ទាំងឡាយ ។

[ ១៨ ] បពិត្រព្រះអង្គដ៏ចម្រើន កាលបើរេវតៈមានអាយុ និយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយនឹងអនុរុទ្ធមានអាយុយ៉ាងនេះថា ម្នាលអាវុសោអនុរុទ្ធ រេវតៈមានអាយុបានព្យាករ ។បេ។ ម្នាលអាវុសោអនុរុទ្ធ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបណា បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ អនុរុទ្ធមានអាយុ បានឆ្លើយតបនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ មើលឃើញលោកធាតុទាំងមួយពាន់ ដោយចក្ខុបីដូចជាទិព្វដ៏បរិសុទ្ធកន្លងនូវចក្ខុជា

របស់មនុស្ស ម្នាលអាវុសោ ដូចជាបុរសមានចក្ខុ នៅខាងលើប្រាសាទដ៏ប្រសើរ ហើយក្រឡេកឃើញមណ្ឌលនៃខ្នងកង់ទាំងមួយពាន់ យ៉ាងណា ម្នាលអាវុសោសារីបុត្រ ភិក្ខុមើលឃើញលោកធាតុទាំងមួយពាន់ ដោយចក្ខុបីដូចជាទិព្វដ៏បរិសុទ្ធកន្លងនូវចក្ខុជារបស់មនុស្ស ក៏យ៉ាងនោះដែរ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបនេះឯង ។ ម្នាលសារីបុត្រ ត្រូវល្អហើយ អនុរុទ្ធព្យាករត្រឹមត្រូវតាមពិតមែនហើយ ម្នាលសារីបុត្រ ព្រោះថា អនុរុទ្ធមើលឃើញលោកធាតុទាំងមួយពាន់ ដោយចក្ខុបីដូចជាទិព្វ ដ៏បរិសុទ្ធកន្លងនូវចក្ខុជារបស់មនុស្ស ។

[ ១៩ ] បពិត្រព្រះអង្គដ៏ចម្រើន កាលបើអនុរុទ្ធនិយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយនឹងមហាកស្សបមានអាយុ យ៉ាងនេះថា ម្នាលអាវុសោកស្សប អនុរុទ្ធមានអាយុ បានព្យាករនូវបដិភាណសមគួរដល់ខ្លួនហើយ ឥឡូវនេះ យើងសូមសួរនូវមហាកស្សបមានអាយុក្នុងសេចក្តីនោះថា ។បេ។ ម្នាលអាវុសោកស្សប ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបណា បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ មហាកស្សបមានអាយុ បាននិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ ភិក្ខុក្នុងសាសនានេះ ជាអ្នកនៅក្នុងព្រៃខ្លួនឯងផង សរសើរនូវគុណនៃអ្នកនៅក្នុងព្រៃផង ជាអ្នកប្រព្រឹត្តបិណ្ឌបាតខ្លួនឯងផង ។បេ។ ជាអ្នកទ្រទ្រង់សំពត់បង្សុកូល ... ជាអ្នកប្រើប្រាស់ចំពោះតែចីវរបី ... ជាអ្នកឥតសេចក្តីប្រាថ្នា ... ជាអ្នកសន្តោស ... ជាអ្នកស្ងប់ស្ងាត់ ... ជាអ្នកមិននៅ

ប្រទូស្សកប្រទូស្ស ... ជាអ្នកមានព្យាយាមតឹងតែងហើយ ... ជាអ្នកបរិបូណ៌ដោយសីល ... ជាអ្នកបរិបូណ៌ដោយសមាធិ ... ជាអ្នកបរិបូណ៌ដោយបញ្ញា ... ជាអ្នកបរិបូណ៌ដោយវិមុត្តិ ... ជាអ្នកបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈខ្លួនឯងផង សរសើរការបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈផង ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបនេះឯង ។ ម្នាលសារីបុត្រ ត្រូវល្អហើយ កស្សបព្យាករត្រឹមត្រូវតាមពិតមែនហើយ ម្នាលសារីបុត្រ ព្រោះថា កស្សបជាអ្នកនៅក្នុងព្រៃខ្លួនឯងផង សរសើរគុណនៃអ្នកនៅក្នុងព្រៃផង ជាអ្នកប្រព្រឹត្តបិណ្ឌបាតខ្លួនឯងផង សរសើរគុណនៃអ្នកប្រព្រឹត្តបិណ្ឌបាតផង ជាអ្នកទ្រទ្រង់នូវសំពត់បង្សុកូលខ្លួនឯងផង សរសើរគុណនៃអ្នកទ្រទ្រង់សំពត់បង្សុកូលផង ជាអ្នកទ្រទ្រង់តែចីវរបីខ្លួនឯងផង សរសើរគុណនៃអ្នកទ្រទ្រង់ចំពោះតែចីវរបីផង ជាអ្នកឥតសេចក្តីប្រាថ្នាខ្លួនឯងផង សរសើរគុណនៃអ្នកឥតសេចក្តីប្រាថ្នាផង ជាអ្នកសន្តោសខ្លួនឯងផង សរសើរគុណនៃសេចក្តីសន្តោសផង ជាអ្នកមានសេចក្តីស្ងប់ស្ងាត់ខ្លួនឯងផង សរសើរនូវសេចក្តីស្ងប់ស្ងាត់ផង ជាអ្នកមិននៅប្រទូស្សកប្រទូស្សខ្លួនឯងផង សរសើរនូវសេចក្តីមិននៅប្រទូស្សកប្រទូស្សផង ជាអ្នកមានព្យាយាមប្រារព្ធខ្លួនឯងផង សរសើរនូវសេចក្តីប្រារព្ធព្យាយាមផង ជាអ្នកបរិបូណ៌ដោយសីលខ្លួនឯងផង សរសើរការបរិបូណ៌ដោយសីលផង ជាអ្នកបរិបូណ៌ដោយសមាធិខ្លួនឯងផង សរសើរ ការបរិបូណ៌ដោយសមាធិផង ជាអ្នកបរិបូណ៌ដោយបញ្ញាខ្លួនឯងផង សរសើរការបរិបូណ៌ដោយបញ្ញាផង ជាអ្នកបរិបូណ៌ដោយវិមុត្តិខ្លួនឯងផង

សរសើរការបរិបូណ៌ដោយវិមុត្តិផង ជាអ្នកបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈ ដោយខ្លួនឯងផង សរសើរការបរិបូណ៌ដោយវិមុត្តិញ្ញាណទស្សនៈផង ។

[ ២០ ] បពិត្រព្រះអង្គដ៏ចម្រើន កាលបើមហាកស្សបនិយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយនឹងមហាមោគ្គល្លានមានអាយុយ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន មហាកស្សបមានអាយុបានព្យាករនូវបដិភាណ សមគួរដល់ខ្លួនហើយ ឥឡូវនេះ យើងសូមសួរមហាមោគ្គល្លានមានអាយុក្នុងសេចក្តីនោះថា ។បេ។ ម្នាលអាវុសោមោគ្គល្លាន ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបណា បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ មោគ្គល្លានមានអាយុ បាននិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ ភិក្ខុពីររូបក្នុងសាសនានេះ សម្តែងនូវអភិធម្មកថា ភិក្ខុទាំងនោះសួរប្រស្នានូវគ្នានិងគ្នា លុះសួរប្រស្នាហើយ ដោះស្រាយដល់គ្នានិងគ្នា ក៏មិនបានរុករានគ្នាផង កថារបស់ភិក្ខុទាំងនោះ ប្រព្រឹត្តទៅប្រកបដោយធម៌ផង ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូបនេះឯង ។ ម្នាលសារីបុត្រ ត្រូវល្អហើយ មោគ្គល្លានព្យាករត្រឹមត្រូវតាមពិតមែនហើយ ម្នាលសារីបុត្រ ព្រោះថា មោគ្គល្លានជាធម្មកថិក ។

[ ២១ ] កាលបើព្រះសារីបុត្រនិយាយយ៉ាងនេះថា ព្រះមហាមោគ្គល្លានមានអាយុក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ខ្ញុំព្រះអង្គបាននិយាយនឹងសារីបុត្រមានអាយុយ៉ាងនេះថា ម្នាលអាវុសោសារីបុត្រ យើងទាំងអស់គ្នាសុទ្ធតែបានព្យាករបដិភាណ តាមសមគួរ

ដល់ខ្លួនហើយ ឥឡូវនេះយើងសូមសួរសារីបុត្រមានអាយុ ក្នុងសេចក្តីនោះថា ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័នគួររីករាយ រាត្រីសោតក៏ប្រាសចាកទោស ឈើទាំងឡាយមានផ្ការីកស្គុសស្គាយ សព្ទកន្ទែង មានក្លិនក្រអូបបីដូចជាក្លិនទិព្វផ្សព្វផ្សាយទៅ ម្នាលអាវុសោសារីបុត្រ ព្រៃគោសិង្គសាលវ័នរុងរឿងដោយសារភិក្ខុរូបណា បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនិយាយយ៉ាងនេះហើយ សារីបុត្រមានអាយុបាននិយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន ភិក្ខុក្នុងសាសនានេះ ញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាច ( ខ្លួន ) ផង ភិក្ខុមិនបានប្រព្រឹត្តទៅតាមអំណាចរបស់ចិត្តផង ភិក្ខុនោះប្រាថ្នាដើម្បីនៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិណាក៏នៅអស់បុព្វណ្ហសម័យដោយវិហារសមាបត្តិនោះបាន បើប្រាថ្នាដើម្បីនៅអស់មជ្ឈន្តិកសម័យដោយវិហារសមាបត្តិណា ក៏នៅអស់មជ្ឈន្តិកសម័យដោយវិហារសមាបត្តិនោះបាន បើប្រាថ្នាដើម្បីនៅអស់សាយណ្ហសម័យដោយវិហារសមាបត្តិណា ក៏នៅអស់សាយណ្ហសម័យដោយវិហារសមាបត្តិនោះបាន ម្នាលអាវុសោមោគ្គល្លាន ដូចជាហិបសំពត់ ដ៏ពេញដោយសំពត់ទាំងឡាយជ្រលក់ដោយពណ៌ផ្សេងៗ របស់ព្រះរាជា ឬរាជមហាមាត្យ ព្រះរាជា និងរាជមហាមាត្យនោះ បើប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណាអស់បុព្វណ្ហសម័យក៏ទ្រទ្រង់នូវគូសំពត់នោះៗ អស់បុព្វណ្ហសម័យ បើប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណា អស់មជ្ឈន្តិកសម័យ ក៏ទ្រទ្រង់នូវគូសំពត់នោះៗ អស់មជ្ឈន្តិក-សម័យ បើប្រាថ្នាដើម្បីទ្រទ្រង់នូវគូសំពត់ណាអស់សាយណ្ហសម័យ ក៏ទ្រទ្រង់

នូវគូសំពត់នោះៗ អស់សាយណ្ហសម័យ ម្នាលអាវុសោមោគ្គល្លាន ភិក្ខុញុំាង ចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចខ្លួនផង ភិក្ខុមិនបានប្រព្រឹត្តទៅតាមអំណាចនៃ ចិត្តផង ភិក្ខុនោះប្រាថ្នាដើម្បីនៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិនោះ បើប្រាថ្នាដើម្បីនៅអស់ មជ្ឈន្តិកសម័យដោយវិហារសមាបត្តិណា ក៏នៅអស់មជ្ឈន្តិកសម័យដោយ វិហារសមាបត្តិនោះ បើប្រាថ្នាដើម្បីនៅអស់សាយណ្ហសម័យ ដោយវិហារ-សមាបត្តិណា ក៏នៅអស់សាយណ្ហសម័យដោយវិហារសមាបត្តិនោះ ក៏យ៉ាង នោះដែរ ម្នាលអាវុសោមោគ្គល្លាន ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារ ភិក្ខុរូបនេះឯង ។ ម្នាលមោគ្គល្លាន ត្រូវល្អហើយ សារីបុត្រព្យាករត្រឹមត្រូវ តាមពិតមែនហើយ ម្នាលមោគ្គល្លាន ព្រោះថា សារីបុត្រ រមែងញុំាងចិត្តឲ្យ ប្រព្រឹត្តទៅក្នុងអំណាចខ្លួនផង សារីបុត្រមិនបានប្រព្រឹត្តទៅតាមអំណាចនៃចិត្ត ផង សារីបុត្រនោះ ប្រាថ្នាដើម្បីនៅអស់បុព្វណ្ហសម័យ ដោយវិហារសមាបត្តិ ណា ក៏នៅអស់បុព្វណ្ហសម័យដោយវិហារសមាបត្តិនោះ បើប្រាថ្នាដើម្បីនៅ អស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិណា ក៏នៅអស់មជ្ឈន្តិកសម័យ ដោយវិហារសមាបត្តិនោះ បើប្រាថ្នានៅអស់សាយណ្ហសម័យ ដោយវិហារ សមាបត្តិណា ក៏នៅអស់សាយណ្ហសម័យ ដោយវិហារសមាបត្តិនោះ ។

[ ២២ ] កាលបើព្រះមោគ្គល្លាន និយាយយ៉ាងនេះហើយ ព្រះសារីបុត្រ មានអាយុ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ ចម្រើន លោកណានិយាយត្រូវ ។ ព្រះអង្គត្រាស់ថា ម្នាលសារីបុត្រ បើ

ដោយបរិយាយ អ្នកទាំងអស់គ្នាសុទ្ធតែនិយាយត្រូវហើយ ប៉ុន្តែអ្នកទាំងឡាយ ចូរស្តាប់ពាក្យរបស់តថាគត ព្រៃគោសិង្គសាលវ័ន រុងរឿងដោយសារភិក្ខុរូប ណានោះចុះ ម្នាលសារីបុត្រ ភិក្ខុក្នុងសាសនានេះ ត្រឡប់មកពីបិណ្ឌបាតវិញ ខាងក្រោយនៃភត្ត ក៏ចូលទៅអង្គុយពែនភ្នែនដោយកាយឲ្យត្រង់ ផ្ចង់សតិឲ្យ ត្រង់ទៅមុខដោយគិតថា ចិត្តរបស់អាត្មាអញមិនរួចចាកអាសវក្កិលេសទាំង-ឡាយ ព្រោះមិនមានសេចក្តីប្រកាន់ដរាបណា អាត្មាអញនឹងមិនទម្លាយភ្នែន នោះដរាបនោះដូច្នេះ ម្នាលសារីបុត្រ ព្រៃគោសិង្គសាលវ័នរុងរឿងដោយសារ ភិក្ខុរូបនេះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សេចក្តីនេះហើយ ព្រះថេរៈ មានអាយុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរ ចំពោះភាសិតរបស់ ព្រះមានព្រះភាគ ។

## មហាគោសិង្គសាលសូត្រទី ២ ចប់

# អដ្ឋកថា
## មហាគោសិង្គសាលសូត្រទី ២

[ ៩ ] មហាគោសិង្គសាលសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **គោសិង្គសាលវនទាយេ** នេះ លោកពោលដើម្បីសម្តែងទីលំនៅ ។ សូត្រដទៃលោកសម្តែងគោចរគ្រាមយ៉ាងនេះមុនថា ព្រះមានព្រះភាគ ប្រថាប់នៅក្នុងវត្តជេតពន គោចរគ្រាមរបស់ព្រះមានព្រះភាគ មិនប្រចាំក្នុងមហាគោសិង្គសាលសូត្រនេះ តែជាគោចរគ្រាមម្តងម្កាល ព្រោះដូច្នោះ លោកសម្តែងដល់លំនៅតែម្យ៉ាងថា ព្រះសូត្រនោះមានព្រៃជាទីតាំង ។ បទថា **សម្ពហុលេហិ** គឺសន្ធឹកសន្ធាប់ ។ បទថា **អភិញ្ញាតេហិ អភិញ្ញាតេហិ** បានដល់ មានកេរ្តិ៍ឈ្មោះប្រាកដក្នុងទីគ្រប់អន្លើ ។ បទថា **ថេរេហិ សាវកេហិ សទ្ធឹ** សេចក្តីថា ព្រម គឺរួមដោយបុគ្គលដែលជាព្រះថេរៈ ព្រោះប្រកបដោយធម៌ធ្វើនូវការមាំទាំ មានការសង្រួមក្នុងបាតិមោក្ខជាដើម ជាព្រះសាវក ព្រោះកើតក្នុងទីបំផុតនៃការស្តាប់ ។

ឥឡូវនេះ កាលទ្រង់សម្តែងព្រះថេរៈទាំងនោះដោយសរុប ទើបត្រាស់ថា **អាយស្មតា ច សារីបុត្តេន** ដូច្នេះជាដើម ។ បណ្តាព្រះថេរៈទាំងនោះ ព្រះសារីបុត្រ មានឈ្មោះបោះសំឡេងក្នុងព្រះសាសនា ដោយសីលគុណជាដើមរបស់ខ្លួន គឺ ប្រាកដហើយ ដូចព្រះអាទិត្យ និងព្រះចន្ទកណ្តាលនភាល័យប្រាកដដល់បុគ្គលអ្នកមានចក្ខុ និងដូចសាគរ ប្រាកដដល់បុគ្គលដែលឈរលើច្រាំងនៃសមុទ្រ ដូច្នោះ ។ គប្បីជ្រាប ភាពដែលព្រះថេរៈនោះជាធំដោយអំណាចនៃគុណ ដែលមកហើយក្នុងព្រះសូត្រនេះតែម្យ៉ាងមិនបាន ។ គួរនឹង

ជ្រាបភាពដែលព្រះថេរៈជាធំ ដោយអំណាចនៃសូត្រទាំងនេះ គឺធម្មទាយាទ-សូត្រ អនង្គណសូត្រ សម្មាទិដ្ឋិសូត្រ ចូឡសីហនាទសូត្រ មហាសីហនាទ-សូត្រ រថវិនីតសូត្រ មហាហត្ថិបទោបមសូត្រ មហាវេទល្លសូត្រ វត្ថុបមសូត្រ ទីឃនខសូត្រ អនុបទសូត្រ សេវិតព្វាសេវិតព្វសូត្រ សច្ចវិភង្គសូត្រ បិណ្ឌ-បាតប្បារិសុទ្ធិសូត្រ សម្បសាទនីយសូត្រ សង្គីតិសូត្រ ទសុត្តរសូត្រ បវា-រណាសូត្រ សុសិមសូត្រ ថេរប្បញ្ហាសូត្រ មហានិទ្ទេស បដិសម្ភិទាមគ្គ ថេរសីហនាទសូត្រ ការបួស ឯតទគ្គៈ ដូច្នេះ ។ ពិតហើយ ក្នុងឯតទគ្គៈ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រជាកំពូលនៃភិក្ខុ ដែលជាសាវកអ្នកមានបញ្ញារបស់តថាគត ។

សូម្បីព្រះមហាមោគ្គល្លានដែលជាធំប្រាកដដូចព្រះថេរៈ មានឈ្មោះបោះសំឡេងដោយគុណ មានសីលជាដើម និងដោយគុណ មកហើយក្នុងព្រះសូត្រនេះ ។

ម្យ៉ាងទៀត គួរជ្រាបសេចក្ដីដែលព្រះថេរៈនោះជាធំ ដោយអំណាចព្រះសូត្រទាំងនេះ គឺអនុមានសូត្រ ចូឡតណ្ហាសង្ខយសូត្រ មារតជ្ជនិយសូត្រ ការញុំាងប្រាសាទឲ្យញាប់ញ័រ ការទូន្មាននន្ទោបនន្ទនាគរាជ ប្រកបដោយឥទ្ធិបាទទាំងអស់ ។ ការទៅកាន់ទេវលោក ក្នុងកាលសម្ដែងយមកប្បា-ដិហារ្យ វិមានវត្ថុ បេតវត្ថុ ការបួស ឯតទគ្គៈ ដូច្នេះ ។ ពិតហើយ ក្នុងឯតទគ្គៈ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាមោគ្គល្លានជាកំពូលនៃភិក្ខុជាសាវក ដែលមានឫទ្ធិរបស់តថាគត ។

សូម្បីព្រះមហាកស្សបដែលជាធំ ប្រាកដមកដូចព្រះថេរៈដែលមានឈ្មោះល្បោះសំឡេងដោយសីលាទិគុណ និងដោយគុណ មកហើយក្នុងព្រះសូត្រនេះ ។ ម្យ៉ាងទៀត គួរជ្រាបភាពដែលព្រះថេរៈនោះជាធំ ដោយអំណាចព្រះសូត្រទាំងនេះ គឺចីវរបរិវត្តនសូត្រ ជិណ្ណចីវរសូត្រ ចន្ទោបមសូត្រ កស្សបសំយុត្តទាំងអស់ មហាអរិយវង្សសូត្រ ការបួសរបស់ព្រះថេរៈ ឯតទគ្គៈដូច្នេះ ។ ពិតហើយ ក្នុងឯតទគ្គៈ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាកស្សប ជាកំពូលនៃភិក្ខុដែលជាសាវកអ្នកទ្រទ្រង់ធុតង្គរបស់តថាគត ។

សូម្បីព្រះអនុរុទ្ធដែលជាធំ ប្រាកដដូចព្រះថេរៈដែលមានឈ្មោះល្បោះសំឡេងដោយសីលាទិគុណ និងដោយគុណ មកហើយក្នុងសូត្រនេះ ម្យ៉ាងទៀត គួរជ្រាបសេចក្តីដែលព្រះថេរៈនោះជាធំ ដោយអំណាចនៃព្រះសូត្រទាំងនេះ គឺចូឡគោសិង្គសូត្រ នឡកបានសូត្រ អនុត្តរិយសូត្រ ឧបក្កិលេសសូត្រ អនុរុទ្ធសំយុត្ត មហាបុរិសវិតក្កសូត្រ ការបួសរបស់ព្រះថេរៈ ឯតទគ្គៈដូច្នេះ ។ ពិតហើយ ក្នុងឯតទគ្គៈ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អនុរុទ្ធ ជាកំពូលនៃភិក្ខុដែលជាសាវកអ្នកមានទិព្វចក្ខុរបស់តថាគត ។

ព្រះរេវតៈ មាន ២ រូប គឺខទិរវនិយរេវតៈ ១ កង្ខារេវតៈ ១ ក្នុងបទថា **អាយស្មតា ច រេវតេន** នេះ ក្នុង ២ រូបនោះ ក្នុងទីនេះ មិនបំណងយកព្រះខទិរវនិយរេវតៈ ដែលជាប្អូនប្រុសរបស់ព្រះធម្មសេនាបតីឡើយ ។ ឯព្រះថេរៈច្រើនដោយសេចក្តីសង្ស័យយ៉ាងនេះថា ទឹកអំពៅគួរឬទេហ្ន៎ ស្ករណ្ឌក

បាយគួរឬទេហ្ន៎ លោកបំណងយករេវតៈក្នុងទីនេះ ។ ព្រះថេរៈនោះ ជាអ្នកធំប្រាកដដូចព្រះថេរៈដែលមានឈ្មោះបោះសំឡេង ដោយសីលាទិគុណ និងគុណមកហើយក្នុងសូត្រនេះ ។

ម្យ៉ាងទៀត គួរជ្រាបព្រះថេរៈនោះជាធំក្នុងការបួស និងក្នុងឯតទគ្គៈនោះពិតហើយ ក្នុងឯតទគ្គៈ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កង្ខារេវតៈជាកំពូលនៃភិក្ខុសាវក ដែលជាអ្នកមានឈានរបស់តថាគត ។

សូម្បីព្រះអានន្ទត្ថេរ ជាអ្នកធំប្រាកដដូចព្រះថេរៈដែលមានឈ្មោះបោះសំឡេងដោយសីលាទិគុណ និងដោយគុណ មកហើយក្នុងព្រះសូត្រនេះ ម្យ៉ាងទៀត គួរជ្រាបភាពដែលព្រះថេរៈនោះជាធំ ដោយអំណាចព្រះសូត្រទាំងនេះ គឺសេលសូត្រ ពាហិតិយសូត្រ អនេញ្ជសប្បាយគោបក្កសូត្រ មោគ្គល្លានសូត្រ ពហុធាតុកសូត្រ ចូឡសុញ្ញតសូត្រ មហាសុញ្ញតសូត្រ អច្ឆរិយព្ភូតសូត្រ ភទ្ទេករត្តិសូត្រ មហានិទានសូត្រ មហាបរិនិព្វានសូត្រ សុភសូត្រ ចូឡនិយលោកធាតុសូត្រ ការបួសរបស់ព្រះថេរៈ ឯតទគ្គៈដូច្នេះ ។ ពិតហើយ ក្នុងឯតទគ្គៈ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ អានន្ទជាកំពូលនៃភិក្ខុសាវក ដែលជាពហុស្សុតរបស់តថាគត ។

បទថា **អញ្ញេហិ ច អភិញ្ញាតេហិ** សេចក្តីថា ព្រះមានព្រះភាគប្រថាប់នៅក្នុងព្រៃគោសិង្គសាលវ័ន មួយអន្លើដោយព្រះថេរៈដែលជាសាវកជាច្រើន ដែលមានឈ្មោះបោះសំឡេងប្រាកដ ព្រោះជាអ្នកមានគុណធំទាំងនេះ និងពួកសាវកដទៃក៏ទេ ។ ពិតហើយ ក្នុងគ្រានោះ ព្រះសារីបុត្រ ខ្ទង់ឯងមានបញ្ញា

ច្រើន នាំពួកភិក្ខុដែលមានបញ្ញាច្រើនដទៃជាច្រើន ទៅហែហមព្រះទសពល ឯព្រះមហាមោគ្គល្លាន ខ្លួនឯងមានឫទ្ធិ ព្រះមហាកស្សប ខ្លួនឯងជាធុតវាទ ឯព្រះអនុរុទ្ធ ខ្លួនឯងបានទិព្វចក្ខុ ព្រះរេវតៈ ខ្លួនឯងត្រេកអរក្នុងឈាន ព្រះអានន្ទ ខ្លួនឯងជាពហុស្សូត នាំពួកភិក្ខុដែលជាពហុស្សូតដទៃ ទៅហែហមព្រះទសពលក្នុងកាលនោះ ។ ព្រះមហាថេរៈ ដែលមានឈ្មោះបោះសំឡេងទាំងនោះ និងព្រះមហាថេរៈដទៃក្នុងកាលនោះ គប្បីជ្រាបថា ពួកភិក្ខុប្រមាណ ៣ ម៉ឺន ហែហមព្រះទសពល ដោយប្រការដូច្នេះឯង ។

បទថា **បដិសល្លានា វុដ្ឋិតោ** សេចក្តីថា ព្រះមហាមោគ្គល្លានចេញអំពីវិវេកក្នុងផលសមាបត្តិ ។ បទថា **យេនាយស្មា មហាកស្សបោ តេនុបសង្កមិ** សេចក្តីថា បានឮថា ព្រះថេរៈចេញអំពីទីពួនសម្ងំ សម្លឹងមើលលោកធាតុនាបច្ចិមទិស បានឃើញសុរិយមណ្ឌល ៥០ យោជន៍ កំពុងអស្តង្គត ដូចកុណ្ឌលកំពុងធ្លាក់ចុះអំពីព្រះកាណ៌ក្សត្រ ដែលកំពុងស្រវឹងក្នុងដងព្រៃ ដូចសំពត់កម្ពលក្រហមដែលគេប្រមូលទុកក្នុងហិប ដូចថាសមាសដែលមានតម្លៃមួយសែនកំពុងធ្លាក់ចុះអំពីក្អក ដែលប្រដាប់ដោយកែវមណី លំដាប់នោះ លោកសម្លឹងមើលលោកធាតុទិសខាងកើត បានឃើញចន្ទមណ្ឌលរះឡើងអំពីផ្ទៃសមុទ្រ មានពណ៌ដូចពពក ដែលប្រដាប់ព្រមទាំងលក្ខណៈ មានទំហំ ៤៩ យោជន៍ លើកំពូលភ្នំចក្រវាលនាទិសខាងកើត ដូចកង់ប្រាក់ភ្ជាប់ត្រង់ដុំវិលទៅ ដូចធារទឹកដោះហូរអំពីស្នូកប្រាក់ និងដូចហង្សស្រដែលត្រដាងស្លាបទាំង ២ ហើរទៅក្នុងនភា ដូច្នោះ ។ បន្ទាប់អំពីនោះ ក៏សម្លឹងមើល

សាលវ័ន ក្នុងសម័យនោះ តាំងអំពីគល់ រហូតដល់ចុង ផ្ការីកស្គុសស្គាយ រុងរឿង ដូចដណ្ដប់ដោយសំពត់បាវ៉ារ ២ ជាន់ ។ ហាក់ដូចចងដោយបាច់មុក្តា ក្នុងកាលកេសរជ្រុះទៅក្នុងទីនោះៗ ផ្ទៃដីហាក់បីដូចជាគ្រឿងបូជា ដែលដេរដាសដោយផ្កា ដែលស្រោចដោយទឹកល័ខ ហ្វូងឃ្មុំស្រវឹងនឹងកេសរផ្កា ហើរទៅក្នុងព្រៃ បញ្ចេញសំឡេង **ហឺ ហឺ** ។ ថ្ងៃនោះ ជាថ្ងៃឧបោសថ គ្រានោះ ព្រះថេរៈគិតថា ថ្ងៃនេះ អាត្មាអញ នឹងញ៉ាំងវេលាឲ្យកន្លងទៅដោយសេចក្ដីត្រេកអរក្នុងអ្វីហ្ន៎ ។ ធម្មតាព្រះអរិយសាវ័កពេញចិត្តក្នុងការស្ដាប់ធម៌ ព្រះថេរៈក៏មានការត្រិះរិះថា ថ្ងៃនេះ អញនឹងទៅកាន់សម្នាក់របស់ព្រះធម្មសេនាបតីថេរៈដែលជាបងប្រុសរបស់អញ ហើយនឹងឲ្យកាលវេលាកន្លងទៅដោយការត្រេកអរក្នុងធម៌ ។ កាលទៅក៏មិនទៅម្នាក់ឯង គិតថា អញនឹងនាំព្រះមហាកស្សបត្ថេរដែលជាមិត្រ ជាទីស្រឡាញ់របស់អញទៅផង ដូច្នេះ ក្រោកអំពីអាសនៈ រលាស់ប្រមក្ខណ្ឌ ចូលទៅរកព្រះមហាកស្សប ។

បទថា **ឯវមាវុសោតិ ខោ អាយស្មា មហាកស្សបោ** សេចក្ដីថា ព្រោះព្រះថេរៈជាអរិយសាវ័ក ស្រឡាញ់ក្នុងការស្ដាប់ធម៌ ដូច្នោះ បានស្ដាប់ពាក្យរបស់មហាមោគ្គល្លានហើយ មិនអាងលេសណាមួយថា អើអាវុសោ លោកទៅចុះ ខ្ញុំឈឺក្បាល ឬឈឺខ្នងឡើយ បែរជាត្រេកអរ ពោលពាក្យជាដើមថា **ឯវមាវុសោ** ។ ព្រះថេរៈទទួលពាក្យហើយ ក្រោកអំពីអាសនៈ រលាស់ប្រមក្ខណ្ឌ និមន្តតាមព្រះមហាមោគ្គល្លានទៅ ។ សម័យនោះ ព្រះមហាថេរៈ ២ រូប រុងរឿងដូចព្រះចន្ទ ២ ដួង រះទន្ទឹមគ្នា ដូចព្រះអាទិត្យ ២ ដួង ដូច

ស្តេចដំរីឆទ្ទន្ត ២ ដូចរាជសីហ៍ ២ ដូចខ្លាធំ ២ ។ សម័យនោះ ព្រះអនុរុទ្ធ អង្គុយត្រង់ទីសម្រាកពេលថ្ងៃ ឃើញព្រះមហាថេរៈ ២ រូប ទៅកាន់សម្នាក់ របស់ព្រះសារីបុត្រ កាលក្រឡេកមើលលោកធាតុទាបស្ចិមទិស បានឃើញ ព្រះអាទិត្យគងជងព្រៃ កាលសម្លឹងមើលលោកធាតុទិសខាងកើត បានឃើញ ព្រះចន្ទកំពុងរះឡើងអំពីជាយព្រៃ កាលសម្លឹងមើលដើមសាលព្រឹក្ស បាន ឃើញដើមសាលព្រឹក្ស មានផ្ការីកស្គុសស្គាយ ថ្ងៃនេះ គិតថា ថ្ងៃនេះ ជាថ្ងៃ ឧបោសថ ហើយព្រះមហាថេរៈទាំងនេះ ដែលជាបងប្រុសរបស់អញ ទៅកាន់ សម្នាក់របស់ព្រះធម្មសេនាបតី ការស្តាប់ធម៌គប្បីមានច្រើន អញនឹងជាអ្នក មានចំណែកក្នុងការស្តាប់ធម៌ ដូច្នេះហើយ ក្រោកអំពីសេនាសនៈ រលាស់ ប្រមក្ខណ្ឌ ដើរតាមស្នាមជើងព្រះមហាថេរៈទៅ ។ ព្រោះដូច្នោះ ទើបលោក ពោលថា គ្រានោះឯង ព្រះមហាមោគ្គល្លាន ព្រះមហាកស្សប និងព្រះអនុរុទ្ធ ចូលទៅរកព្រះសារីបុត្រ ដូច្នេះ ។ បទថា **ឧបសង្កមឹសុ** សេចក្តីថា ព្រះ មហាថេរៈទាំង ៣ រូប ឈរៀងគ្នា រុងរឿងដូចព្រះចន្ទ ដូចព្រះអាទិត្យ និង ដូចរាជសីហ៍ចូលទៅរក ឯព្រះអានន្ទ អង្គុយក្នុងទីសម្រាកពេលថ្ងៃរបស់ខ្លួន ឃើញព្រះមហាថេរៈចូលទៅរកយ៉ាងនេះហើយ គិតថា ការស្តាប់ធម៌ដ៏ច្រើន នឹងមានក្នុងថ្ងៃនេះ សូម្បីអញ ក៏គប្បីជាអ្នកមានចំណែកក្នុងការស្តាប់ធម៌នោះ ហើយអញនឹងមិនទៅតែម្នាក់ឯង នឹងនាំព្រះរេវតត្ថេរមិត្រជាទីស្រឡាញ់របស់ អញទៅដែរ ។ រឿងទាំងអស់គប្បីជ្រាបសេចក្តីពិស្តារ តាមន័យដែលពោល ហើយ ក្នុងការចូលទៅរករបស់ព្រះមហាមោគ្គល្លាន ព្រះមហាកស្សប និង

ព្រះអនុរុទ្ធត្ថេរ ។ ព្រះថេរៈ ២ រូបនោះ ឈររៀងគ្នា រុងរឿងដូចព្រះចន្ទ ២ ដួង ដូចព្រះអាទិត្យ ២ ដួង និងដូចរាជសីហ៍ ២ ចូលទៅរក ដោយប្រការ ដូច្នេះ ។ ព្រោះដូច្នោះ ទើបលោកពោលថា ព្រះសារីបុត្របានឃើញហើយ ដូច្នេះជាដើម ។

[ ១០ ] បទថា **ឯតុ អាយស្មន្តំ អានន្ទំ ឯតទវោច** សេចក្តីថា ព្រះសារីបុត្រឃើញអំពីចម្ងាយ ទើបបានពោលពាក្យជាដើមនេះ ប្រកបដោយឧបចារកថា ដោយលំដាប់ថា សូមលោកម្ចាស់និមន្តមកចុះ ដូច្នេះ ។ ក្នុងបទថា **រមណីយំ អាវុសោ** នេះ បានដល់ ព្រៃដែលជាទីរីករាយ ១ បុគ្គលដែលជាទីរីករាយ ១ ។

ក្នុង ២ យ៉ាងនោះ ឈ្មោះថា ព្រៃដែលដេរដាសដោយដើមខ្លឹង ដើមសាលៈ និងដើមចម្ប៉ាជាដើម មានម្លប់ក្រាស់ មានដើមឈើផ្សេងៗ បញ្ចេញផ្កា ផ្លែ មានទឹកដល់ព្រម ក្រៅអំពីស្រុក ព្រៃនេះឈ្មោះថា ជាទីគួររីករាយ លោកពោលសំដៅយកដោយពាក្យថា ព្រៃទាំងឡាយ ជាទីគួរត្រេកអរ បុគ្គលមានរាគៈ ទៅប្រាសហើយទាំងឡាយ នឹងត្រេកអរក្នុងព្រៃ ដែលមិនជាទីត្រេកអររបស់ជន ព្រោះលោកមានរាគៈទៅប្រាសហើយ ជាអ្នកមានប្រក្រតីមិនស្វែងរកកាម ដូច្នេះ ។

បើព្រៃជាទីទួល មិនមានទឹក មានម្លប់ប៉ុនប៉ើន មានបន្លាស្អេកស្កះ ឯព្រះអរិយៈ មានព្រះពុទ្ធជាដើម ប្រថាប់នៅក្នុងព្រៃនេះ ព្រៃនេះ ឈ្មោះថា បុគ្គលគួរត្រេកអរ លោកពោលសំដៅយកថា ព្រះអរហន្តទាំងឡាយ នៅក្នុង

ទីណា ទោះជាព្រៃក្តី ស្រុកក្តី ទីទាបក្តី ទីខ្ពស់ក្តី ទីនោះជាទីកដីគួររីករាយ ដូច្នេះ ។ ឯក្នុងទីនេះ ដល់ព្រមទាំង ២ យ៉ាងនោះ ។ គ្រានោះ ព្រៃគោសិង្គ-សាលវ័ន មានផ្ការីកស្គុសស្គាយ ក្លិនផ្កាប្រអូបឈ្ងុយឈ្ងប់ ព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គលក្នុងលោកនេះ ព្រមទាំងទេវលោក ប្រថាប់នៅជាមួយភិក្ខុដែល មានឈ្មោះបោះសំឡេងប្រមាណ ៣ ម៉ឺនរូប ។ លោកសំដៅយកព្រៃនោះ ទើបពោលថា ម្នាលអានន្ទ ព្រៃគោសិង្គសាលវ័ន ជាទីគួររីករាយ ដូច្នេះ ។

បទថា **ទោសិនា រត្តិ** គឺប្រាសចាសទោស អធិប្បាយថា វៀរចាក ធនឹតទាំងនេះ គឺអ័ព្ទ ពពក ផ្សែង ធូលី រាហូ ។ បទថា **សព្វផាលិផុល្លា** សេចក្តីថា ដើមសាលៈ មានផ្ការីកក្នុងទីគ្រប់អន្លើ តាំងអំពីគល់រហូតដល់ចុង ឈ្មោះថា មិនទាន់រីក រមែងមិនមាន ។ បទថា **ទិព្វា មញ្ញេ គន្ធា សម្បវន្តិ** សេចក្តីថា ក្លិនក្រអូបជារបស់ទិព្វ រមែងផ្សាយទូទៅ ដូចក្លិនក្រអូបនៃផ្កា មណ្ឌារវៈ ផ្កាចារ ផ្កាប្រទៀង និងលម្អិតខ្លឹមចន្ទន៍ អធិប្បាយថា រមែង ផ្សាយទៅ ដូចទីគួររីករាយរបស់សក្កទេវរាជ សុយាម សន្តុសិត និម្មានរតី បរនិម្មិតវសវត្តី និងស្តេចមហាព្រហ្ម ។ បទថា **កថំ រូបេន អាវុសោ អានន្ទ** សេចក្តីថា ព្រះអានន្ទត្ថេរជាសង្ឃនវកនៃព្រះថេរៈ ៥ រូបនោះ ។ សួរថា ព្រោះ ហេតុអ្វី ទើបព្រះថេរៈសួរសេចក្តីនោះមុន ឆ្លើយថា ព្រោះស្និទ្ធស្នាលគ្នា ។

ព្រះថេរៈ ២ រូបនោះ រាប់អានគ្នានឹងគ្នា ។ ព្រះសារីបុត្តត្ថេរគិតថា ព្រះ អានន្ទត្ថេរឧបដ្ឋាកព្រះសាស្តា ដែលអញគួរធ្វើ ដូច្នេះ ទើបរាប់អានព្រះ-អានន្ទត្ថេរ ។ ព្រះអានន្ទគិតថា ព្រះសារីបុត្តត្ថេរជាអគ្គសាវករបស់ព្រះមាន

ព្រះភាគ ដូច្នេះ ទើបរាប់អានព្រះសារីបុត្តត្ថេរ លោកឲ្យទារកក្នុងត្រកូល បព្វជ្ជា ហើយឲ្យកាន់យកឧបជ្ឈាយ៍ក្នុងសម្នាក់ព្រះសារីបុត្តត្ថេរ ព្រះសារីបុត្រ ក៏បានធ្វើយ៉ាងនោះដូចគ្នា ។ ភិក្ខុអង្គមួយឲ្យបាត្រ និងចីវររបស់ខ្លួន ឲ្យ បព្វជ្ជាហើយ ឲ្យមួយអង្គទៀតជាឧបជ្ឈាយ៍ប្រមាណ ៥០០ រូប ។ ព្រះអានន្ទ បានចីវរជាដើមដែលប្រណីត ហើយប្រគេនព្រះថេរៈប៉ុណ្ណោះ ។ បានឮថា ព្រាហ្មណ៍ម្នាក់គិតថា ការបូជាពុទ្ធរតនៈ និងសង្ឃរតនៈគង់ប្រាកដ ឈ្មោះថា ការបូជាធម្មរតនៈ ដូចម្ដេចហ្ន៎ ។ ទើបចូលទៅគាល់ព្រះមានព្រះភាគទូលសួរ សេចក្ដីនោះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ បើអ្នកប្រាថ្នា នឹងបូជាធម្មរតនៈ ចូរបូជាភិក្ខុដែលជាពហុស្សូតមួយរូបចុះ ។ ព្រាហ្មណ៍ទូល ថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គប្រាប់ភិក្ខុដែលជាពហុស្សូតចុះ ។ ព្រះ មានព្រះភាគត្រាស់ថា អ្នកចូរសួរភិក្ខុសង្ឃចុះ ។ ព្រាហ្មណ៍នោះចូលទៅរក ភិក្ខុសង្ឃពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ប្រាប់ភិក្ខុ ដែលជាពហុស្សូត ។ ភិក្ខុពោលថា នែព្រាហ្មណ៍ គឺព្រះអានន្ទត្ថេរហ្នឹងឯង ។ ព្រាហ្មណ៍បូជាព្រះថេរៈដោយត្រៃចីវរ មានតម្លៃមួយពាន់ ។ ព្រះថេរៈទទួល ត្រៃចីវរហើយ បានទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ ។ ព្រះមានព្រះ ភាគត្រាស់សួរថា ម្នាលអានន្ទ អ្នកបានសំពត់មកអំពីណា ព្រះអានន្ទទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រាហ្មណ៍ម្នាក់ប្រគេន ខ្ញុំព្រះអង្គប្រាថ្នានឹងប្រគេន ចីវរនេះ ដល់ព្រះសារីបុត្រ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ អ្នក ចូរប្រគេនលោកចុះ ។ ព្រះអានន្ទពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះ

សារីបុត្រចៀសទៅកាន់ទីចារិកបាត់ហើយ ។ ព្រះមានព្រះភាគត្រាស់ថា ចូរប្រគេនក្នុងវេលាដែលលោកមកចុះ ។ ព្រះអានន្ទពោលថា ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទទុកហើយ ព្រះមានព្រះភាគសួរថា ចុះសារីបុត្រត្រឡប់មកក្នុងកាលណា ព្រះអានន្ទឆ្លើយថា បពិត្រព្រះអង្គដ៏ចម្រើន ប្រមាណ ១០ ថ្ងៃទៀត ។ ទើបព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យអ្នករាល់គ្នា ទុកអតិរេកចីវរកំណត់ត្រឹម ១០ ថ្ងៃ ។ សូម្បីព្រះសារីបុត្តត្ថេរ បានវត្ថុណាមួយដែលជាទីពេញចិត្ត ក៏ប្រគេនវត្ថុនោះដល់ព្រះអានន្ទត្ថេរយ៉ាងនោះដូចគ្នា ។ ព្រះថេរៈទាំងនោះ រាប់អានគ្នានឹងគ្នាយ៉ាងនេះ ។ ទើបព្រះថេរៈសួរមុន ព្រោះការរាប់អានគ្នា ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា សួរនូវការឃើញនោះ គប្បីសួរតាំងអំពីវត្ថុតូចទៅ ព្រោះដូច្នោះ ព្រះថេរៈគិតថា នឹងសួរព្រះអានន្ទមុន ព្រះអានន្ទនឹងឆ្លើយចន្លុលបង្ហាញតាមបដិភាណរបស់ខ្លួន បន្ទាប់មក ទើបសួរព្រះរេវតៈ អនុរុទ្ធ មហាកស្សប មហាមោគ្គល្លាន ។ ព្រះមហាមោគ្គល្លាននឹងឆ្លើយចន្លុលបង្ហាញតាមបដិភាណរបស់ខ្លួនបន្ទាប់អំពីព្រះថេរៈទាំង ៥ រូប ទើបសួរអញឯអញនឹងឆ្លើយ ចន្លុលបង្ហាញតាមបដិភាណរបស់ខ្លួន ព្រះធម្មទេសនានេះនឹងដល់ទីបំផុត ដល់នូវភាពបរិបូណ៌ដោយពាក្យមានប្រមាណប៉ុណ្ណោះក៏ទេ កាលបើដូច្នោះ ពួកយើងនឹងចូលទៅទូលសួរព្រះទសពល ព្រះសាស្តាទ្រង់នឹងឆ្លើយចន្លុលបង្ហាញដោយសព្វញ្ញុតញ្ញាណ ធម្មទេសនានេះ នឹងដល់ទី

បំផុតដល់នូវភាពបរិបូណ៌ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឧបមាដូចក្ដីកើតក្នុងជនបទ ក្ដីរមែងដល់មេស្រុក កាលមេស្រុកមិនអាចកាត់ក្ដីបាន រមែងដល់ចៅហ្វាយខេត្ត កាលក្ដីមិនដាច់ស្រេច រមែងដល់ចៅក្រម កាលចៅក្រមមិនអាច រមែងដល់សេនាបតី កាលសេនាបតីនោះមិនអាចកាត់ក្ដីបាន រមែងធ្លាក់ដល់ឧបរាជ កាលឧបរាជមិនអាចកាត់ក្ដីបាន រមែងធ្លាក់ដល់ព្រះរាជា តាំងអំពីកាលព្រះរាជាមានព្រះរាជវិនិច្ឆ័យហើយ ក្ដីរមែងកាត់ព្រះរាជឱង្ការ រមែងមិនប្រែប្រួល យ៉ាងណា អញក៏ដូច្នោះ នឹងសួរព្រះអានន្ទមុន ... កាលបើដូច្នោះ ពួកយើងនឹងចូលទៅទូលសួរព្រះទសពល ព្រះសាស្ដាទ្រង់នឹងឆ្លើយឯង ដោយព្រះសព្វញ្ញុតញ្ញាណ ព្រះធម្មទេសនានេះ នឹងដល់ទីបំផុតដល់នូវការបរិបូណ៌ដោយពាក្យមានប្រមាណប៉ុណ្ណេះ ដូច្នេះ ។ ព្រះថេរៈកាលសួរយ៉ាងនេះ ទើបបានសួរព្រះអានន្ទត្ថេរមុន ។

បទថា **ពហុស្សុតោ ហោតិ** សេចក្ដីថា ភិក្ខុនោះស្ដាប់ច្រើន អធិប្បាយថា រៀននវង្គសត្ថុសាសនៈ ដោយអំណាចអក្ខរៈខាងដើម និងខាងចុងនៃបាលី និងអនុសន្ធិ ។ បទថា **សុតធរោ** គឺជាអ្នកទ្រទ្រង់ទុកនូវសុតៈបាន ។ ពិតហើយ ព្រះពុទ្ធវចនៈដែលភិក្ខុបានរៀនតែបាលីបទេសនេះ ភ្លេចភ្លាំងទៅតែបាលីបទេសនេះ មិនគង់នៅដូចទឹកក្នុងក្អមធ្លុះ លោកមិនអាចនឹងពោល ឬប្រាប់សូត្រ ឬជាតកសូម្បីតែមួយ ត្រង់កណ្ដាលបរិស័ទបាន ភិក្ខុនេះមិនឈ្មោះថា ទ្រទ្រង់នូវសុតៈឡើយ ។ ឯព្រះពុទ្ធវចនៈដែលភិក្ខុណារៀនហើយ សូម្បីតែមួយ ពេលដែលខ្លួនរៀនមកហើយនោះឯង កាលលោកមិនធ្វើការស្វាធ្យាយ

សូម្បី ១០ ឆ្នាំ ២០ ឆ្នាំ ក៏មិនភ្លេចភ្លាំង ភិក្ខុនេះឈ្មោះថា ទ្រទ្រង់នូវសុតៈ ។ បទថា **សុតសន្និចយោ** បានដល់ អ្នកសន្សំសុតៈ សុតៈដែលភិក្ខុណាសន្សំទុកក្នុងប្រអប់ គឺហទយៈ គង់នៅដូចស្នាមចារឹកលើថ្ម និងដូចខ្លាញ់រាជសីហ៍ ដែលតម្កល់ទុកក្នុងភាជន៍មាស ភិក្ខុនេះឈ្មោះថា មានសុតៈដែលសន្សំហើយ ។ បទថា **ធតា** បានដល់ តាំងនៅ ទ្រទ្រង់ចាំទុក ជំនាញ ពិតហើយ ព្រះពុទ្ធវចនៈដែលភិក្ខុរបខ្លះរៀន ហើយទ្រទ្រង់ចាំទុក ជំនាញ មិនវិបរិត ភិក្ខុនោះ កាលបុគ្គលណាមួយនិយាយថា សូមលោកម្ចាស់ពោលសូត្រ ឬជាតកនោះ ដូច្នេះ រមែងពោលថា អាត្មាទន្ទេញ ប្រៀបធៀប ផ្ទៀងផ្ទាត់ហើយនឹងដឹង តែសម្រាប់ភិក្ខុរបខ្លះ ទ្រទ្រង់ចាំទុក ជំនាញ ដូចគ្នានឹងភវង្គសោត ។ កាលបុគ្គលណាមួយពោលថា សូមលោកម្ចាស់ពោលសូត្រ ឬជាតកនោះ លោករមែងលើកឡើងពោលសូត្រ ឬជាតកនោះបានភ្លាមមួយរំពេច ។ បទថា **ធតា** លោកសំដៅយកភិក្ខុនោះ ទើបពោលហើយ ។ បទថា **វចសា បរិចិតា** បានដល់ លោកទន្ទេញហើយដោយវាចា ដោយអំណាចនៃសុត្តទសកៈ វគ្គទសកៈ បណ្ណាសទសកៈ ។ បទថា **មនសានុ-បេក្ខិតា** បានដល់ សម្លឹងដោយចិត្ត ។ កាលភិក្ខុណាគិតដោយចិត្តនូវព្រះពុទ្ធវចនៈដែលខ្លួនទន្ទេញហើយដោយវាចា ព្រះពុទ្ធវចនៈ រមែងប្រាកដក្នុងទីនោះៗ គឺប្រាកដដូចរូបប្រាកដដល់បុគ្គល ដែលឈរជុតភ្លើងដ៏ធំដូច្នោះ ។ បទថា **មនសានុបេក្ខិតា** នោះ លោកពោលសំដៅយកភិក្ខុនោះ ទើបពោល ។ បទថា **ទិដ្ឋិយា សុបដិវិទ្ធា** បានដល់ ចាក់ធ្លុះដោយល្អ ដោយបញ្ញា ដោយ

ហេតុ និងផល ។ ក្នុងបទថា **បរិមណ្ឌលេហិ បទព្យញ្ជនេហិ** នេះ ឈ្មោះថា បទព្យញ្ជនៈ ព្រោះធ្វើអត្ថជំឲ្យប្រាកដ ធ្វើបទនោះឲ្យបរិបូណ៌ដោយអក្ខរៈ ពោលព្យញ្ជនៈ ១០ យ៉ាង មិនឲ្យខូច ឈ្មោះថា បទព្យញ្ជនៈដែលស្មើល្អ ម្យ៉ាងទៀត ភិក្ខុណា កាលសម្ដែងធម៌ក្នុងបរិស័ទ អាងសូត្រ ឬជាតកហើយ យកព្រះសូត្រ ឬជាតកដទៃមកអធិប្បាយ ពោលឧបមានៃសូត្រនោះ ឲ្យរឿងនោះកន្លងទៅ ចាប់រឿងនេះ ដាក់រឿងនោះ គេចកែទៅ អធិប្បាយទៅដោយផ្លូវមួយទៀត ដល់ពេលក៏ក្រោកឡើង ឯសូត្រដែលលោកអាងទុក ក៏គ្រាន់តែអាងទុកប៉ុណ្ណោះ ។ ពាក្យរបស់ភិក្ខុនោះ ឈ្មោះថា មិនរាបស្មើគ្នា ។ ឯភិក្ខុណាអាងសូត្រ ឬជាតក មិនយកបទខាងក្នុង សូម្បីតែមួយបទ មកលុបលាងអនុសន្ធិ និងខាងដើម ខាងចុងនៃបាលី តាំងនៅក្នុងន័យដែលអាចារ្យឲ្យទុក ប្រព្រឹត្តទៅដូចកំណាត់ដោយជញ្ជីង ដូចបញ្ចូនទឹកទៅត្រង់អូរដែលជ្រៅ ដូចសេះសិន្ធពអាជានេយ្យតន្ត្រំជើង ពាក្យរបស់ភិក្ខុនោះ ឈ្មោះថា រាបស្មើ លោកសំដៅយកពាក្យដែលមានសភាពបែបនេះ ទើបពោលថា **បរិមណ្ឌលេហិ បទព្យញ្ជនេហិ** ដូច្នេះ ។

ក្នុងបទថា **អនុប្បពន្ធេហិ** សេចក្ដីថា ភិក្ខុណាពោលធម៌តាំងអំពីវេលាផ្ដើមសូត្រ ឬជាតកប្រារព្ធ ប្រញាប់ប្រញាល់ ដូចមនុស្សរលាកភ្លើង ដូចមនុស្សទំពារបស់ក្ដៅ ធ្វើទីដែលកាន់យក និងមិនកាន់យករហ័សៗ ក្នុងអនុ- សន្ធិខាងដើម និងខាងចុងនៃបាលី លំៗ ក្នុងទីនោះៗ ចប់ហើយ ក្រោកទៅ ដូចមនុស្សចិញ្ចឹមទន្សង ត្រាច់ទៅក្នុងចន្លោះស្ទឹកឈើងាប់ ភិក្ខុណា កាល

ពោលធម៌ គ្រាខ្លះក៏លឿន គ្រាខ្លះក៏យឺត គ្រាខ្លះក៏ធ្វើសំឡេងខ្លាំង គ្រាខ្លះធ្វើសំឡេងខ្សឹប ដូចភ្លើងដុតសព គ្រាខ្លះក៏ឆេះ គ្រាខ្លះក៏រលត់ យ៉ាងណា ភិក្ខុនោះ ឈ្មោះថា ធម្មកថិកប្រៀបដូចដូភ្លើងដុតសពនោះដូច្នោះដូចគ្នា កាលបរិស័ទបំណាំងនឹងក្រោក ក៏ចាប់ផ្តើមទៀត ។ សូម្បីភិក្ខុណា កាលពោលឲ្យពិស្តារក្នុងទីនោះបាន តែលោកពោលហាក់ដូចជាដកដង្ហើមទៅ ហាក់ដូចជាស្រែងស្រែ វាចារបស់ភិក្ខុទាំងអស់នេះ ឈ្មោះថា មិនជាប់តគ្នា ។ ឯភិក្ខុណាផ្តើមសូត្រ តាំងនៅក្នុងន័យដែលអាចារ្យឲ្យមិនដាច់ខ្សែឲ្យប្រព្រឹត្តទៅដូចក្រសែទឹក ញុំាងវាចាឲ្យប្រព្រឹត្តទៅមិនដាច់ ដូចទឹកដែលធ្លាក់អំពីអាកាស វាចារបស់ភិក្ខុនោះ ឈ្មោះថា ជាប់តគ្នាដោយលំដាប់ លោកសំដៅយកពាក្យនោះ ទើបពោលថា **អនុប្បពន្ធេហិ** ដូច្នេះ ។ បទថា **អនុសយសមុគ្ឃាតាយ** បានដល់ ដើម្បីដកនូវអនុស័យ ៧ យ៉ាង ។ បទថា **ឯវរូបេន** សេចក្តីថា ព្រៃគោសិង្គសាលនៃ គប្បីល្អដោយភិក្ខុដែលជាពហូសូតបែបនេះ ឬភិក្ខុមានសភាពបែបនេះអង្គុយហើយ ជាយសង្ឃាដី និងជាយសង្ឃាដីទល់គ្នាក្តី ក្បាលជង្គង់ និងក្បាលជង្គង់ទល់គ្នាក្តី គប្បីជ្រាបអត្ថក្នុងវារៈទាំងពួងដោយន័យនេះ ។

[ ១១ ] ភិក្ខុឈ្មោះថា **បដិសល្លានារាមា** ព្រោះអត្ថថា ការពួនសម្ងំជាទីមកត្រេកអរនៃភិក្ខុនោះ ។ បទថា **បដិសល្លានរតោ** គឺត្រេកអរហើយក្នុងការសម្ងំ ។

[ ១២ ] បទថា **សហស្សំលោកានំ** គឺលោកធាតុ ១០០០ ។ ពិត

ហើយ ការសេពធុរៈ ទាក់ទងដោយការពិចារណារបស់ព្រះថេរៈ មានប្រមាណ ប៉ុណ្ណោះ ។ ឯព្រះថេរៈកាលប្រាថ្នា រមែងសម្លឹងមើលបានច្រើនសែនចក្រ-វាល ។ បទថា **ឧបរិបាសាទវរគតោ** បានដល់ បុរសដែលទៅខាងលើ ប្រាសាទដ៏ស្អាត ៧ ជាន់ ឬ ៩ ជាន់ ។ បទថា **សហស្សំ នេមិមណ្ឌលានំ បោលោកេយ្យ** សេចក្ដីថា គប្បីបើកបង្អួចក្រឡេកមើលមណ្ឌលនៃកង់រាប់ពាន់ តាំងនៅត្រង់ជុំខាងចុងនៃកង់ និងចុងនៃកង់ទល់គ្នា ក្នុងបរិវេណប្រាសាទបាន ជុំក្ដី កាំក្ដី ចន្លោះកាំក្ដី ខ្នងកង់ក្ដី ក៏ប្រាកដដល់បុរសនោះ ។ បទថា **ឯវមេវ ខោ អាវុសោ** សេចក្ដីថា ភិក្ខុដែលមានទិព្វចក្ខុនេះ រមែងសម្លឹងមើលលោក-ធាតុ ១០០០ ដោយទិព្វចក្ខុ កន្លងបង់នូវចក្ខុរបស់មនុស្ស ភ្នំសិនេរុ ១០០០ ក្នុងចក្រវាល ១០០០ រមែងប្រាកដ ដូចដុំកង់ប្រាកដដល់បុរសដែលឈរលើ ប្រាសាទនោះ ទ្វីបប្រាកដដូចកាំ មនុស្សដែលឈរនៅលើទ្វីប ប្រាកដដូច ចន្លោះកាំ ភ្នំកណ្ដាប់ចក្រវាល រមែងប្រាកដដូចខ្នងកង់ ។

[ ១៣ ] បទថា **អារញ្ញកោ** គឺជាអ្នកសមាទានអារញ្ញធុតង្គ ។ សូម្បី ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។

[ ១៤ ] បទថា **នោ ច សំសារេន្តិ** គឺមិនជំទាស់គ្នា ។ ពិតហើយ បុគ្គលដែលអាចសួរបញ្ហា ធ្វើឲ្យមានហេតុ មានផល ឈ្មោះថា រមែងជំទាស់ គ្នា អធិប្បាយថា ពួកភិក្ខុរមែងមិនពោលយ៉ាងនេះ ។ បទថា **បវត្តិនី ហោតិ** បានដល់ រមែងប្រព្រឹត្តទៅដូចខ្សែទឹកក្នុងស្ទឹង ។

[ ១៥ ] បទថា **យាយ វិហារសមាបត្តិយា** សេចក្ដីថា ដោយវិហារ-

សមាបត្តិជាលោកិយ ឬលោកុត្តរណា ។

[ ១៦-២១ ] បទថា **សាធុ សាធុ សារីបុត្ត** សេចក្តីថា សាធុការនេះ ព្រះមានព្រះភាគប្រទានដល់ព្រះអានន្ទត្ថេរ ព្រះមានព្រះភាគ ត្រាស់នឹងព្រះសារីបុត្តត្ថេរ ។ ក្នុងទីទាំងពួងក៏មានន័យនេះ ។ បទថា **យថាតំ អានន្ទោ** សេចក្តីថា អានន្ទ កាលព្យាករដោយប្រពៃ គប្បីព្យាករយ៉ាងណា ព្យាករហើយ ដូច្នោះ អធិប្បាយថា ព្រះអានន្ទព្យាករតាមសមគួរ គឺសមគួរដល់អធ្យាស្រ័យរបស់ខ្លួននោះឯង ។

ពិតហើយ ព្រះអានន្ទត្ថេរ ជាពហូសូតដោយខ្លួនឯង សូម្បីអធ្យាស្រ័យរបស់លោក តាំងនៅយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារីក្នុងសាសនា គប្បីជាពហូសូត ដូច្នេះ ។ ព្រោះហេតុអ្វី ព្រោះថា វត្ថុដែលគួរ ឬមិនគួរ វត្ថុដែលមានទោស ឬមិនមានទោស ទោសធ្ងន់ ឬស្រាល កែកុនបាន កែកុនមិនបាន រមែងប្រាកដដល់ភិក្ខុដែលជាពហូសូត ភិក្ខុដែលជាពហូសូត ពិចារណាព្រះពុទ្ធវចនៈដែលខ្លួនរៀនហើយ គិតថា សីល លោកពោលទុកហើយក្នុងទីនេះ សមាធិ លោកពោលទុកហើយក្នុងទីនេះ វិបស្សនាលោកពោលទុកហើយក្នុងទីនេះ មគ្គ ផល និព្វាន លោកពោលទុកហើយក្នុងទីនេះ បំពេញសីលក្នុងទីមករបស់សីល បំពេញសមាធិ ក្នុងទីមករបស់សមាធិ ញុំាងវិបស្សនាឲ្យកាន់យកនូវបទ្ទប់ ក្នុងទីនៃវិបស្សនា ចម្រើនមគ្គ រមែងធ្វើឲ្យជាក់ច្បាស់នូវផល ព្រោះដូច្នោះ អធ្យាស្រ័យរបស់ព្រះថេរៈ រមែងមានយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារីរបស់អញ រៀន ១ និកាយក្តី ២ ក្តី ៣ ក្តី

៤ ក្តី ៥ និកាយក្តី ហើយពិចារណា បំពេញសីលជាដើម ក្នុងទីមកនៃសីលជាដើម គប្បីធ្វើឲ្យជាក់ច្បាស់នូវមគ្គផល និងនិព្វានដោយលំដាប់ ។ សូម្បីក្នុងវារៈដ៏សេស ក៏មានន័យនេះឯង ។

ពិតហើយ ព្រះរេវតៈពេញចិត្តក្នុងឈាន ត្រេកអរហើយក្នុងឈាន ព្រោះដូច្នោះ លោកមានគំនិតយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារីរបស់អញអង្គុយម្នាក់ឯង ធ្វើកសិណបរិកម្ម ញុំាំងសមាបត្តិ ៨ ឲ្យកើត ចម្រើនវិបស្សនាមានឈានជាបទដ្ឋាន គប្បីធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ ព្រោះដូច្នោះទើបព្យាករយ៉ាងនេះ ។

ឯព្រះអនុរុទ្ធមានទិព្វចក្ខុ លោកមានគំនិតយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារីចម្រើនអាលោកកសិណ ឃើញសត្វទាំងឡាយកំពុងចុតិ និងបដិសន្ធិ ក្នុងចក្រវាលច្រើនពាន់ដោយទិព្វចក្ខុ ញុំាំងចិត្តឲ្យសង្វេគ ព្រោះវដ្តភ័យ ចម្រើនវិបស្សនា គប្បីធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ ព្រោះដូច្នោះ ទើបព្យាករហើយយ៉ាងនេះ ។

ឯព្រះមហាកស្សប ជាធុតវាទ លោកមានគំនិតយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារីជាធុតវាទ ញុំាំងតណ្ហា ព្រមទាំងបច្ច័យឲ្យរីងស្ងួត ដោយអានុភាពនៃធុតង្គ ហើយកម្ចាត់កិលេស មានប្រការផ្សេងៗ ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ ព្រោះដូច្នោះ ទើបព្យាករហើយយ៉ាងនេះ ។

ឯព្រះមហាមោគ្គល្លាន ដល់នូវទីបំផុតនៃសមាធិបារមី បែកលំដាប់ចិត្តដ៏សុខុម លំដាប់ខន្ធ លំដាប់ធាតុ លំដាប់អាយតនៈ ការចូលឈាន ការ

ឈមចុះកាន់អារម្មណ៍ ការកំណត់អង្គ ការកំណត់អារម្មណ៍ ការកាត់អង្គ ការកាត់អារម្មណ៍ ចម្រើនដោយតចំណែក ១ ចម្រើនដោយចំណែក ២ ដូច្នោះ ទើបប្រាកដដល់អ្នករៀនអភិធម្មប៉ុណ្ណោះ ។ បុគ្គលមិនបានរៀនអភិធម្ម កាលនឹងពោលធម៌ រមែងមិនដឹងថា នេះជាសកវាទ នេះជាបរវាទ នៅតែសម្តែងបរវាទថា អញនឹងសម្តែងសកវាទ នៅតែសម្តែងសកវាទថា អញនឹងសម្តែងបរវាទ រមែងពោលលំដាប់ធម៌ឲ្យខុស ឯអ្នករៀនអភិធម្ម រមែងសម្តែងសកវាទថា ជាសកវាទពិតប្រាកដ ឬបរវាទ ដោយបរវាទពិតប្រាកដ រមែងមិនពោលលំដាប់ធម៌ឲ្យខុស ព្រោះដូច្នោះ ព្រះថេរៈមានគំនិតយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារីជាអ្នកទ្រទ្រង់អភិធម្ម ញុំាងឈានឲ្យឈមចុះក្នុងទីដ៏សុខុម ចម្រើនវិបស្សនា គប្បីធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ ព្រោះដូច្នោះ ទើបព្យាករហើយយ៉ាងនេះ ។

ព្រះសារីបុត្រ ដល់នូវទីបំផុតនៃបញ្ញាបារមី អាចញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួនបានដោយបញ្ញា អ្នកមានបញ្ញាថោកថយ មិនអាចឡើយ ។ ពិតហើយ បុគ្គលមានបញ្ញាថោកថយ ប្រព្រឹត្តទៅក្នុងអំណាចនៃចិត្តដែលកើតឡើង អន្ទះអន្ទែងហើយ ទៅខាងនោះ ខាងនេះ ២-៣ ថ្ងៃ ក៏ដល់នូវភាពជាគ្រហស្ថ ជួបនូវការវិនាស មិនមែនប្រយោជន៍ ព្រោះដូច្នោះ ព្រះថេរៈមានគំនិតយ៉ាងនេះថា ឱហ្ន៎ សព្រហ្មចារី មិនប្រព្រឹត្តទៅក្នុងអំណាចនៃចិត្ត ញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួន បង្ក្រាបការសេពនៃសត្រូវនិងការអន្ទះអន្ទែងទាំងអស់នៃចិត្តនោះ មិនឲ្យចេញទៅខាងក្រៅ សូម្បីតិច

តូច ៗ ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ ព្រោះដូច្នោះ ទើបព្យាករហើយយ៉ាងនេះ ។

[ ២២ ] បទថា **សព្វេសំ វោ សារីបុត្ត សុភាសិតំ បរិយាយេន** សេចក្តីថា ម្នាលសារីបុត្រ ហេតុនៃការស្អាត ដោយពួកភិក្ខុអ្នកត្រេកអរក្នុងឈានក្តី អ្នកបានទិព្វចក្ខុក្តី អ្នកពុតង្គវាទក្តី អ្នកអភិធម្មក្តី អ្នកមិនប្រព្រឹត្តទៅក្នុងអំណាចនៃចិត្តក្តី សម្រាប់សង្ឃារាមមាន ។ ព្រោះដូច្នោះ ពាក្យរបស់ពួកអ្នកទាំងអស់ ជាសុភាសិតដោយបរិយាយ គឺជាសុភាសិតដោយហេតុនោះឯង មិនជាទុព្ភាសិតឡើយ ។ បទថា **អបិច មមាបិ សុណាថ** សេចក្តីថា ម្យ៉ាងទៀត ពួកអ្នកចូរស្តាប់ពាក្យរបស់តថាគត ។ បទថា **ន តាវាហំ ឥមំ បល្លង្កំ ភិន្ទិស្សាមិ** សេចក្តីថា តថាគតតាំងសេចក្តីព្យាយាម មានអង្គ ៤ នេះហើយ នឹងមិនទម្លាយ គឺមិនដោះភ្នែន អង្គុយដរាបនោះ ។ បានឮថា ព្រះមានព្រះភាគ ទ្រង់លះសិរីរាជសម្បត្តិនេះបានដោយព្រះញាណដ៏ចាស់ក្លា ទ្រង់ចេញអភិនេស្ក្រមណ៍ យាងឡើងពោធិមណ្ឌលដោយលំដាប់ ទ្រង់តាំងសេចក្តីព្យាយាមមានអង្គ ៤ ប្រថាប់គង់ពត់ភ្នែន មានការឈ្នះ មានព្រះហឫទ័យមាំទាំ ទ្រង់បំបែកនូវក្បាលរបស់មារទាំង ៣ ហើយទ្រង់ញ៉ាំងលោកធាតុ ១ ម៉ឺន ឲ្យលាន់ខ្ទរខ្ទារ ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ ក្នុងវេលាទៀបភ្លឺ ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកមហាពោធិបល្ល័ង្ករបស់ព្រះអង្គនោះ ទើបត្រាស់យ៉ាងនេះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់អនុគ្រោះជនដែលកើតខាងក្រោយ ទ្រង់សម្តែងបដិបទា ដែលជាសារៈ

ដល់កល្យាណបុថុជ្ជន ទើបត្រាស់យ៉ាងនេះ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់ឃើញថា ក្នុងអនាគត កុលបុត្រដែលមានអធ្យាស្រ័យយ៉ាងនេះ នឹងពិចារណាឃើញដោយប្រការដូច្នេះ ព្រះមានព្រះភាគ កាលត្រាស់ មហាគោសិង្គសាលសូត្រ ទើបត្រាស់ថា ម្នាលសារីបុត្រ ភិក្ខុក្នុងសាសនានេះ ក្នុងកាលខាងក្រោយកត្ត ... ម្នាលសារីបុត្រ ព្រៃគោសិង្គសាលវ័ន គប្បីរុងរឿងដោយភិក្ខុបែបនេះឯង ។ ភិក្ខុទាំងឡាយ គិតថា ពួកយើងនឹងកាន់យកអធ្យាស្រ័យរបស់ព្រះមានព្រះភាគ ដូច្នេះ ត្រឡប់អំពីបិណ្ឌបាតក្នុងបច្ឆាភត្ត តាំងសេចក្តីព្យាយាមដែលប្រកបដោយអង្គ ៤ មានចិត្តមាំទាំ សម្គាល់ក្នុងសមណធម៌ដែលខ្វនគួរធ្វើថា ពួកយើងមិនទាន់សម្រេចអរហត្ត នឹងមិនទម្លាយភ្នែននេះ ដូច្នេះ ភិក្ខុទាំងនោះបដិបត្តិយ៉ាងនេះហើយ នឹងធ្វើទីបំផុតនៃជាតិ ជរា និងមរណៈបាន ដោយថ្ងៃតិចតួចប៉ុណ្ណោះ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់អនុគ្រោះជនដែលកើតខាងក្រោយនេះ ទ្រង់សម្តែងបដិបទាដែលជាសារៈដល់កល្យាណបុថុជ្ជន ទើបត្រាស់យ៉ាងនេះ ។ បទថា **ឯវរូបេន ខោ សារីបុត្ត ភិក្ខុនា គោសិង្គសាលវនំ សោភេយ្យ** សេចក្តីថា ម្នាលសារីបុត្រ ព្រៃគោសិង្គសាលវ័ន គប្បីរុងរឿងដោយភិក្ខុ ដែលមានសភាពយ៉ាងនេះដោយត្រង់ ដូច្នេះ ។ ហើយទ្រង់បញ្ចប់ព្រះធម្មទេសនាដោយអនុសន្ធិ ដូច្នេះឯង ។៙

**មហាគោសិង្គសាលសូត្រ ចប់**

**សូត្រទី ២ ចប់**

# សុត្តន្តបិដក

## មហាគោបាលសូត្រទី ៣

[ ២៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយក្នុងទីនោះថា នែភិក្ខុទាំងឡាយ ។ ឯភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ។

[ ២៤ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ គង្វាលគោប្រកបដោយអង្គទាំងឡាយ ១១ មិនគួរដើម្បីរក្សានូវហ្វូងគោ មិនគួរដើម្បីញុំាងហ្វូងគោឲ្យចម្រើនឡើងបានឡើយ អង្គ ១១ តើដូចម្តេចខ្លះ ម្នាលភិក្ខុទាំងឡាយ គង្វាលគោក្នុងលោកនេះ ជាអ្នកមិនស្គាល់រូប ( របស់គោ ) ១ មិនឈ្លាសក្នុងលក្ខណៈ គឺភិនភាគស្លាកស្នាម ១ មិនក្តិះពងរុយត្រង់ដំបៅគោ ១ មិនបិទដំបៅ ១ មិនបំពក់ផ្សែង ១ មិនស្គាល់កំពង់ទឹក ១ មិនដឹងថាគោបានផឹកទឹកហើយ ឬនៅឡើយ ១ មិនស្គាល់ផ្លូវ ១ មិនឈ្លាសក្នុងកន្លែងឃ្វាលគោ ១ រីតទឹកដោះមិនឲ្យនៅសល់ ១ គោឧសភទាំងឡាយណាជាបិតា ( បា ) របស់គោ ជាបរិនាយក ( មេហ្វូង ) របស់គោ មិនបូជានូវគោឧសភទាំងនោះដោយគ្រឿងបូជាដ៏ក្រៃលែង ១ ម្នាលភិក្ខុទាំងឡាយ គង្វាលគោប្រកបព្រមដោយអង្គទាំង ១១ នេះឯង មិនគួរដើម្បីរក្សានូវហ្វូង

គោ មិនគួរដើម្បីញ៉ាំងហ្វូងគោឲ្យចម្រើនបានឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបព្រមដោយអង្គទាំងឡាយ ១១ ក៏មិនគួរដើម្បីដល់នូវសេចក្ដីចម្រើនលូតលាស់ពេញទូលាយ ក្នុងធម៌វិន័យនេះ ក៏ដូច្នោះដែរ អង្គទាំង ១១ តើដូចម្ដេចខ្លះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនស្គាល់រូប ១ មិនឈ្លាសក្នុងលក្ខណៈ ១ មិនផ្ចិតផ្ចង់ពងរុយ ១ មិនបិទដំបៅ ១ មិនបំពក់ផ្សែង ១ មិនស្គាល់កំពង់ទឹក ១ មិនដឹងថាខ្លួនបានផឹកទឹកហើយឬនៅឡើយ ១ មិនស្គាល់ផ្លូវ ១ មិនឈ្លាសក្នុងកន្លែងគោចរ ១ រីតយកទេយ្យវត្ថុមិនឲ្យនៅសល់ ១ ភិក្ខុទាំងឡាយណាជាថេរៈ ជាអ្នកដឹងនូវរាត្រីជាអ្នកបួសយូរអង្វែង ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក មិនបានបូជានូវភិក្ខុជាថេរៈទាំងនោះ ដោយការបូជាដ៏ក្រៃលែង ១ ។

[ ២៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនស្គាល់រូបតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះមិនដឹងច្បាស់តាមពិតថា រូបឯណានីមួយរូបទាំងអស់ ( នោះ ) គឺមហាភូតរូបទាំង ៤ ផង ឧបាទាយរូបដែលអាស្រ័យនឹងមហាភូតរូបទាំង ៤ ផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់រូបយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនឈ្លាសក្នុងលក្ខណៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនស្គាល់ច្បាស់តាមពិតថា បុគ្គលពាលមានអំពើជាលក្ខណៈ បណ្ឌិតមានអំពើជាលក្ខណៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនឈ្លាសក្នុងលក្ខណៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនបានផ្ចិតផ្ចង់ពងរុយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុក្នុងសាសនានេះ ញុំាងកាមវិតក្កដែលកើតឡើងហើយ ឲ្យអាស្រ័យនៅ ( ក្នុងសន្តាន ) មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាសទៅ មិនឲ្យសាបសូន្យទៅ ញុំាងព្យាបាទវិតក្កដែលកើតឡើងហើយ ។បេ។ ញុំាងវិហិង្សាវិតក្កដែលកើតឡើងហើយ ។បេ។ ញុំាងអកុសលធម៌ដ៏លាមកទាំងឡាយដែលកើតឡើងរឿយៗ ឲ្យអាស្រ័យនៅ ( ក្នុងសន្តាន ) មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាសទៅ មិនឲ្យសាបសូន្យទៅ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនបានផ្ចិតពងរុយចេញយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនបិទដំបៅតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះឃើញនូវរូបដោយភ្នែក ហើយកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ដ៏លាមកទាំងឡាយ គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវភិក្ខុជាអ្នកមិនសង្រួមនូវឥន្ទ្រិយ គឺភ្នែកនុ៎ះ ដែលមានការមិនសង្រួមនូវឥន្ទ្រិយ គឺភ្នែកណាជាហេតុ ក៏មិនបានប្រតិបត្តិ ដើម្បីសង្រួមនូវឥន្ទ្រិយ គឺភ្នែកនោះ មិនរក្សានូវឥន្ទ្រិយ គឺភ្នែក មិនដល់នូវការសង្រួមក្នុងឥន្ទ្រិយ គឺភ្នែក ស្តាប់នូវសំឡេងដោយត្រចៀក ... ហិតក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ត្រូវនូវផោដ្ឋព្វារម្មណ៍ដោយកាយ ... ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ដ៏លាមកទាំងឡាយ គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវភិក្ខុជាអ្នកមិនសង្រួមនូវឥន្ទ្រិយ គឺចិត្តនុ៎ះ ដែលមានការមិនសង្រួមនូវឥន្ទ្រិយ គឺចិត្តណាជាហេតុ ក៏មិនប្រតិបត្តិ ដើម្បីសង្រួមនូវឥន្ទ្រិយ គឺចិត្តនោះ មិនរក្សានូវឥន្ទ្រិយ គឺចិត្ត មិនដល់នូវការ

សង្រួមក្នុងឥន្ទ្រិយ គឺចិត្ត ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនបានបិទដំបៅយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនបំពក់ភ្នក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនសម្តែងធម៌ដែលខ្លួនបានស្តាប់មកយ៉ាងណា បានរៀនមកយ៉ាងណា ដោយពិស្តារដល់ជនទាំងឡាយដទៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនបំពក់ភ្នក់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់កំពង់ទឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនចូលទៅរកពួកភិក្ខុដែលជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ហើយសាកសួរ ប្រឹក្សាម្តងម្កាលដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្យញ្ជនៈនេះត្រូវរៀនដូចម្តេច សេចក្តីនៃភាសិតនេះដូចម្តេច ឯលោកដ៏មានអាយុទាំងនោះ ក៏មិនបានបើកបង្ហាញនូវសេចក្តីកំបាំងផង មិនបានធ្វើនូវសេចក្តីដែលជ្រៅឲ្យរាក់ងាយផង មិនបានបន្ទោបង់នូវសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យច្រើនប្រការផង ដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់កំពង់ទឹកយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនដឹងថា ខ្លួនបានផឹកទឹកហើយឬនៅឡើយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើគេកំពុងសម្តែងធម៌វិន័យដែលតថាគតប្រកាសហើយ ក៏មិនបាននូវសេចក្តីត្រេកអរក្នុងអត្ថ មិនបាននូវសេចក្តីត្រេកអរក្នុងធម៌ មិនបាននូវបាមោជ្ជដែលប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនដឹងថា ខ្លួនបានផឹកទឹកហើយឬនៅឡើយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់ផ្លូវ តើដូចម្តេច ។ ម្នាលភិក្ខុ

ទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនស្គាល់ច្បាស់នូវផ្លូវប្រកបដោយអង្គ ៨ ដ៏ប្រសើរតាមសេចក្តីពិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនស្គាល់ផ្លូវ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈ្លាសក្នុងកន្លែងគោចរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបានស្គាល់ច្បាស់នូវសតិប្បដ្ឋាន ៤ តាមសេចក្តីពិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនឈ្លាសក្នុងកន្លែងគោចរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នករីតយកទេយ្យវត្ថុមិនឲ្យនៅសល់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មានពួកគហបតីដែលមានសទ្ធា បាននាំយកចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ មកបវារណាចំពោះភិក្ខុក្នុងសាសនានេះហើយ ភិក្ខុមិនស្គាល់ប្រមាណក្នុងការទទួលបច្ច័យទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នករីតយកទេយ្យវត្ថុមិនឲ្យនៅសល់យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបូជាពួកភិក្ខុជាថេរៈ ដឹងនូវរាត្រីបួសយូរអង្វែង ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយកដោយការបូជា ដ៏ក្រៃលែង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបានតម្កល់មេត្តាកាយកម្មក្នុងទីចំពោះមុខ និងទីកំបាំងមុខ មិនតម្កល់មេត្តាវចីកម្ម មិនតម្កល់មេត្តាមនោកម្មក្នុងទីចំពោះមុខ និងទីកំបាំងមុខ ចំពោះភិក្ខុទាំងឡាយដែលជាថេរៈ ដឹងនូវរាត្រី បួសយូរជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបានបូជាពួកភិក្ខុដែលជាថេរៈ ដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក ដោយការបូជាដ៏ក្រៃលែងយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបព្រមដោយធម៌ទាំង ១១ នេះឯង មិន

គួរដើម្បីដល់នូវសេចក្ដីចម្រើនលូតលាស់ពេញទូលាយ ក្នុងធម្មវិន័យនេះបាន ឡើយ ។

[ ២៦ ] ម្នាលភិក្ខុទាំងឡាយ គង្វាលគោប្រកបព្រមដោយអង្គទាំង ១១ ទើបគួរដើម្បីរក្សានូវហ្វូងគោ គួរដើម្បីញ៉ាំងហ្វូងគោឲ្យចម្រើនបាន អង្គទាំង ១១ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ គង្វាលគោក្នុងលោកនេះ ជាអ្នកស្គាល់នូវរូបគោ ១ ឈ្លាសក្នុងលក្ខណៈ ១ ក្ដិះនូវពងរុយ ១ បិទដំបៅ ១ បំពក់ផ្សែង ១ ស្គាល់កំពង់ទឹក ១ ដឹងថា គោបានផឹកទឹកហើយ ឬនៅឡើយ ១ ស្គាល់ផ្លូវ ១ ឈ្លាសក្នុងកន្លែងឃ្វាលគោ ១ រីតទឹកដោះឲ្យនៅសល់ ១ គោឧសភទាំងឡាយណាជាបិតារបស់គោ ជាបរិនាយករបស់គោ រមែងបូជាគោឧសភទាំងនោះ ដោយគ្រឿងបូជាដ៏ក្រៃលែង ១ ម្នាលភិក្ខុទាំងឡាយ គង្វាលគោប្រកបដោយអង្គទាំង ១១ នេះ ទើបគួរដើម្បីរក្សានូវហ្វូងគោ គួរដើម្បីញ៉ាំងហ្វូងគោឲ្យចម្រើនបាន ( យ៉ាងណាមិញ ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបព្រមដោយអង្គទាំង ១១ ទើបគួរដល់នូវសេចក្ដីចម្រើន លូតលាស់ពេញទូលាយក្នុងធម្មវិន័យនេះ យ៉ាងដូច្នោះដែរ អង្គទាំង ១១ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកស្គាល់រូប ១ ឈ្លាសក្នុងលក្ខណៈ ១ ក្ដិះនូវពងរុយ ១ បិទនូវដំបៅ ១ បំពក់ផ្សែង ១ ស្គាល់នូវកំពង់ទឹក ១ ដឹងថាខ្លួនបានផឹកទឹកហើយ ឬនៅឡើយ ១ ស្គាល់ផ្លូវ ១ ឈ្លាសក្នុងកន្លែងគោចរ ១ រីតយកទេយ្យវត្ថុឲ្យនៅសល់ ១ បូជាពួកភិក្ខុដែលជាថេរៈ ដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក ដោយ

ការបូជាដ៏ក្រៃលែង ១ ។

[ ២៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកស្គាល់រូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះដឹងច្បាស់តាមពិតថា រូបឯណានីមួយ ( រូបទាំងអស់នោះ ) គឺមហាភូតរូបទាំង ៤ ផង ឧបាទាយរូបដែលអាស្រ័យនឹងមហាភូតរូបទាំង ៤ ផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកស្គាល់រូបយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឈ្លាសក្នុងលក្ខណៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា បុគ្គលពាលមានអំពើជាលក្ខណៈ បណ្ឌិតមានអំពើជាលក្ខណៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឈ្លាសក្នុងលក្ខណៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកក្តិះនូវពងរុយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងកាម-វិតក្កដែលកើតឡើងហើយមិនឲ្យអាស្រ័យនៅ ( ក្នុងខន្ធសន្តាន ) លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ញុំាងព្យាបាទវិតក្ក ដែលកើតឡើងហើយ ... ញុំាងវិហិង្សាវិតក្កដែលកើតឡើងហើយ ... ញុំាងអកុសលធម៌ដ៏លាមកទាំងឡាយដែលកើតឡើងហើយរឿយៗ មិនឲ្យអាស្រ័យ ( នៅក្នុងខន្ធសន្តាន ) លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកក្តិះនូវពងរុយយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបិទនូវដំបៅតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែកហើយ មិនបានកាន់យកនូវនិមិត្ត មិនបានកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ដ៏លាមកទាំងឡាយ គឺអភិជ្ឈា និងទោមនស្ស គប្បី

ជាប់តាមនូវភិក្ខុជាអ្នកមិនបានសង្រួមនូវឥន្ទ្រិយ គឺភ្នែកនុ៎ះ ដែលមានការមិនសង្រួមនូវឥន្ទ្រិយ គឺភ្នែកណាជាហេតុ ក៏ប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយ គឺភ្នែកនុ៎ះ រក្សានូវឥន្ទ្រិយ គឺភ្នែក ដល់នូវការសង្រួមក្នុងឥន្ទ្រិយ គឺភ្នែក ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ត្រូវផ្សព្វដោយកាយ ... ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈឡើយ ក៏អកុសលធម៌ដ៏លាមកទាំងឡាយ គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវភិក្ខុជាអ្នកមិនបានសង្រួមនូវឥន្ទ្រិយ គឺចិត្តនុ៎ះ ដែលមានការមិនសង្រួមនូវឥន្ទ្រិយ គឺចិត្តណាជាហេតុ ក៏ប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយ គឺចិត្តនុ៎ះ រក្សានូវឥន្ទ្រិយ គឺចិត្ត ដល់នូវការសង្រួមក្នុងឥន្ទ្រិយ គឺចិត្ត ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបិទនូវដំបៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបំពក់ផ្សែង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ សម្តែងធម៌ដែលខ្លួនបានស្តាប់មកយ៉ាងណា បានរៀនមកយ៉ាងណាដោយពិស្តារ ដល់ជនទាំងឡាយដទៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបំពក់ផ្សែងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់កំពង់ទឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានចូលទៅរកពួកភិក្ខុដែលជាថេរៈ ជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកាហើយសាកសួរ ប្រឹក្សាម្តងម្កាលដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្យញ្ជនៈនេះត្រូវរៀងដូចម្តេច សេចក្តីនៃភាសិតនេះដូចម្តេច លោកដ៏មានអាយុទាំងនោះ ក៏បើកនូវសេចក្តីដែលកំបាំងផង ធ្វើនូវសេចក្តី

ដែលជ្រៅឲ្យរាក់ងាយផង បន្ទោបង់នូវសេចក្ដីសង្ស័យក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្ដីសង្ស័យច្រើនប្រការផង ដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់កំពង់ទឹកយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងថាខ្លួនបានផឹកទឹកហើយ ឬនៅឡើយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើគេកំពុងសម្ដែងធម្មវិន័យដែលតថាគតប្រកាសហើយ ក៏បាននូវសេចក្ដីត្រេកអរក្នុងអត្ថ បាននូវសេចក្ដីត្រេកអរក្នុងធម៌ បាននូវបាមោជ្ជដែលប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងថា ខ្លួនបានផឹកទឹកហើយ ឬនៅឡើយយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់ផ្លូវ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្គាល់នូវផ្លូវប្រកបដោយអង្គទាំង ៨ ជាផ្លូវដ៏ប្រសើរតាមសេចក្ដីពិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្គាល់ផ្លូវ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឈ្លាសក្នុងកន្លែងគោចរ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវសតិប្បដ្ឋានទាំង ៤ តាមសេចក្ដីពិត ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឈ្លាសក្នុងកន្លែងគោចរ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នករីតយកទេយ្យវត្ថុឲ្យនៅសល់ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកគហបតីដែលមានសទ្ធា បាននាំយកចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ មកបវារណាចំពោះភិក្ខុក្នុងសាសនានេះហើយ ភិក្ខុស្គាល់ប្រមាណក្នុងការទទួលបច្ច័យទាំងនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នករីតយកទេយ្យវត្ថុឲ្យនៅសល់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបូជាចំពោះភិក្ខុដែលជាថេរៈ ដឹងនូវរាត្រី បួសយូរ ជា

បិតារបស់សង្ឃ ជាសង្ឃបរិនាយក ដោយការបូជាដ៏ក្រៃលែង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ តម្កល់មេត្តាកាយកម្មក្នុងទីចំពោះមុខ និងទីកំបាំងមុខ តម្កល់មេត្តាវចីកម្ម ក្នុងទីចំពោះមុខ និងទីកំបាំងមុខ តម្កល់មេត្តាមនោកម្មក្នុងទីចំពោះមុខ និងទីកំបាំងមុខ ចំពោះភិក្ខុទាំងឡាយដែលជាថេរៈ ដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកបូជាពួកភិក្ខុជាថេរៈ ដឹងនូវរាត្រី បួសយូរ ជាបិតារបស់សង្ឃ ជាសង្ឃបរិនាយក ដោយការបូជាដ៏ក្រៃលែង យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ១១ នេះឯង ទើបគួរដើម្បីដល់នូវសេចក្តីចម្រើនលូតលាស់ពេញទូលាយ ក្នុងធម្មវិន័យនេះបាន ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងនូវសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

### មហាគោបាលសូត្រទី ៣ ចប់

# អដ្ឋកថា

## មហាគោបាលសូត្រទី ៣

[ ២៣ ] មហាគោបាលសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងមហាគោបាលសូត្រនោះ មាន ៣ កថា គឺ **ឯកនាលិកា ១ ចតុរស្សា ១ និស្សិន្នវត្តិកា ១** ។ ការពោលបាលីក្នុងកថាទាំង ៣ នោះ ពោលអត្ថតែមួយបទ ឈ្មោះថា **ឯកនាលិកា** ។ ការសម្តែងនាយគោបាលដែលមិនឈ្លាស សម្តែងភិក្ខុដែលមិនឈ្លាស សម្តែងនាយគោបាលដែលឈ្លាស សម្តែងភិក្ខុដែលឈ្លាស ពោលសង្គ្រោះទុកជា ៤ ពួក ឈ្មោះថា **ចតុរស្សា** ។ ការសម្តែងនាយគោបាលដែលមិនឈ្លាស ទៅដល់ទីបំផុត ការសម្តែងភិក្ខុដែលមិនឈ្លាស ទៅដល់ទីបំផុត ការសម្តែងនាយគោបាលដែលឈ្លាស ទៅដល់ទីបំផុត ការសម្តែងភិក្ខុដែលឈ្លាស ទៅដល់ទីបំផុត នេះឈ្មោះថា **និស្សិន្នវត្តិកា** ។ កថានេះ អាចារ្យទាំងពួង ក្នុងធម្មវិន័យប្រព្រឹត្តមកហើយ ។

[ ២៤ ] បទថា **ឯកាទសហិ ភិក្ខវេ អង្គេហិ** គឺដោយចំណែកនៃទោស ១១ យ៉ាង ។ បទថា **គោគណំ** ប្រែថា ហ្វូងគោ ។ បទថា **បរិហរិតុំ** បានដល់ នាំត្រាច់ទៅ ។ បទថា **ផាតិកាតុំ** បានដល់ ឲ្យដល់នូវសេចក្តីចម្រើន ។ បទថា **ឥធ** គឺក្នុងលោកនេះ ។ បទថា **ន រូបញ្ញូ ហោតិ** បានដល់ រមែងមិនស្គាល់រូបដោយការរាប់ ឬដោយពណ៌ ។ ឈ្មោះថា រមែងមិនស្គាល់ដោយការរាប់ គឺរមែងមិនចេះរាប់គោរបស់ខ្លួនថា ១០០ ឬ

១០០០ ។ នាយគោបាលនោះ កាលមេគោត្រូវសម្លាប់ ឬគេចទៅ រាប់ហ្វូងគោហើយ ដឹងថា ថ្ងៃនេះ មេគោប៉ុណ្ណេះបាត់ទៅ ដូច្នេះ រមែងមិនស្វែងរកដោយចូលព្រៃ ឬត្រាច់ទៅអស់ចន្លោះស្រុក ២-៣ ។ កាលមេគោរបស់អ្នកដទៃចូលទៅកាន់ហ្វូងគោរបស់ខ្លួន រាប់ចំនួនហើយ ដឹងថា គោទាំងនេះប្រមាណប៉ុណ្ណេះ មិនមែនជារបស់ខ្លួន ដូច្នេះ មិនយករំពាត់ដេញវាយចេញទៅ សូម្បីគោរបស់បុគ្គលនោះដែលបាត់ទៅហើយ ក៏បាត់ទៅ ។ នាយគោបាលកៀងមេគោរបស់អ្នកដទៃ ត្រាច់ទៅ ។ ពួកម្ចាស់គោឃើញហើយសម្គុតថា នាយគោបាលនេះ រឹតទឹកដោះគោរបស់ពួកយើង អស់កាលប្រមាណប៉ុណ្ណេះហើយ នាំយកមេគោរបស់ខ្លួនទៅ ។ មេគោរបស់នាយគោបាលនោះ រមែងវិនាសទៅ គេរមែងឃ្លាយចាកការបរិភោគបញ្ចគោរស ។ នាយគោបាលដែលឈ្មោះថា មិនដឹងដោយពណ៌ គឺមិនដឹងថា គោពណ៌សមានប្រមាណប៉ុណ្ណេះ ពណ៌ក្រហមមានប្រមាណប៉ុណ្ណេះ គោពណ៌ខ្មៅមានប្រមាណប៉ុណ្ណេះ ពណ៌ពពាលមានប្រមាណប៉ុណ្ណេះ ពណ៌ខៀវមានប្រមាណប៉ុណ្ណេះ នាយគោបាលនោះ កាលមេគោត្រូវសម្លាប់ ឬគេចទៅ ។ គេរមែងឃ្លាយចាកការបរិភោគបញ្ចគោរស ។ បទថា **ន លក្ខណកុសលោ ហោតិ** សេចក្តីថា រមែងមិនដឹងគ្រឿងសម្គាល់ដែលផ្សេងគ្នា មានរូបធ្នូ រូបប្បក រូបលំពែងជាដើម ដែលខ្លួនធ្វើជាគ្រឿងសម្គាល់ ទុកត្រង់ខ្លួនរបស់មេគោ នាយគោបាលនោះ កាលមេគោត្រូវសម្លាប់ ឬគេចទៅ រាប់ចំនួនគោហើយ ដឹងថាថ្ងៃនេះ គោលក្ខណៈនោះបាត់ទៅ ។បេ។ គាត់រមែងឃ្លាយពីការបរិភោគបញ្ច-

គោរសេ ។ បទថា **ន អាសាដិកំ សាដេតា** សេចក្តីថា ដំបៅរបស់គោ ក្នុងទីដែលជន់ជន្លត់ និងមុតបន្លាជាដើម រុយខៀវតែ្បងត្រង់ដំបៅនោះ ឈ្មោះថា មិនក្តិះពងរុយខៀវទាំងនោះ នាយគោបាលយកឈើក្តិះពងរុយទាំងនោះចេញទៅហើយ គប្បីដាក់ថ្នាំ នាយគោបាលដែលល្ងង់ មិនធ្វើយ៉ាងនោះឡើយ ព្រោះដូច្នោះ ទើបលោកពោលថា មិនក្តិះពងរុយ ។ ដំបៅរបស់គោនៃនាយគោបាលរីករាល បង្កើតជាដំបៅជ្រៅ ពួកសត្វល្អិតបោះរូងចូលក្នុងពោះបានមេគោទាំងនោះ ត្រូវឈឺចាប់គ្របសង្កត់ មិនអាចដើម្បីទំពាស៊ីស្មៅ និងផឹកទឹកបានតាមដែលត្រូវការ ទឹកដោះនៃមេគោទាំងឡាយក្នុងទីនោះ ក៏រីងស្ងួត ពួកគោក៏ខ្សោយកម្លាំង សូម្បីអន្តរាយនៃជីវិតរមែងមានដល់គោទាំង ២ ហ្វូង គោរបស់គេតែងវិនាសខ្លះ គាត់រមែងធ្លាយចាកបញ្ចគោរសខ្លះ ដោយប្រការយ៉ាងនេះ ។ បទថា **ន វណំ បដិច្ឆាទេតា ហោតិ** សេចក្តីថា ដំបៅដែលកើតហើយដល់គោ ដោយន័យដែលពោលហើយ គប្បីយកព្រាល ឬផ្ទៃរុំ ។ នាយគោបាលល្ងង់ខ្លៅ មិនធ្វើយ៉ាងនោះឡើយ ។ កាលបើដូច្នោះ ខ្ទុះរមែងហូរចេញអំពីដំបៅរបស់គោ គោត្រដុសគ្នានឹងគ្នា ព្រោះការបៀតបៀនគ្នានោះ ដំបៅកើតដល់គោដទៃ គោត្រូវឈឺចាប់គ្របសង្កត់ហើយយ៉ាងនេះ មិនអាចដើម្បីនឹងទំពាស៊ីស្មៅតាមដែលត្រូវការបាន ។បេ។ នាយគោបាលនោះរមែងធ្លាយ ។

បទថា **ន ធូមំ កត្តា ហោតិ** សេចក្តីថា ក្នុងរដូវភ្លៀង របោម និងមូសបោមរោមជាដើម កាលហ្វូងគោចូលក្រោលហើយ គួរបំពក់ដោយផ្សែងក្នុងក្រោលនោះ នាយគោបាលមិនឈ្លាស រមែងមិនបំពក់ផ្សែងឲ្យ ហ្វូងគោ

ត្រូវរបោមជាដើមបៀតបៀនមួយយប់ទល់ភ្លឺ ក៏មិនបានដេក ក្នុងថ្ងៃស្អែក ក៏ដេកលក់ត្រង់គល់ឈើជាដើម ក្នុងទីនោះៗ ក្នុងព្រៃ មិនអាចដើម្បីទំពាស៊ីស្មៅតាមសេចក្តីត្រូវការបាន ។បេ។ គេរមែងធ្លាយអំពីការបរិភោគបញ្ចគោរស ។ បទថា **ន តិត្ថំ ជានាតិ** សេចក្តីថា មិនស្គាល់កំពង់រាបស្មើ មិនរាបស្មើ មានសត្វសាហាវ មិនមានសត្វសាហាវ ដូច្នេះ ។ នាយគោបាលនោះ លែងមេគោឲ្យចុះទៅត្រង់ទីដែលមិនមែនជាកំពង់ កាលមេគោទាំងនោះជាន់ដុំថ្មជាដើមត្រង់កំពង់ដែលមិនរាបស្មើ ជើងរមែងបែក មេគោចុះត្រង់កំពង់ជ្រៅ មានសត្វសាហាវៗ មានក្រពើជាដើម ក៏ខាំត្របាក់ គេនឹងត្រូវពោលថា ថ្ងៃនេះ គោបាត់ទៅហើយប្រមាណប៉ុណ្ណេះ ថ្ងៃនេះ ប្រមាណប៉ុណ្ណេះ ហ្វូងគោរបស់គេរមែងវិនាសខ្លះ គេរមែងធ្លាយចាកបញ្ចគោរសខ្លះ ដោយប្រការយ៉ាងនេះ ។ បទថា **ន បិតំ ជានាតិ** សេចក្តីថា មិនដឹងគោដែលបានផឹកទឹក ឬមិនបានផឹក នាយគោបាលគប្បីដឹងគោដែលផឹក និងមិនផឹកយ៉ាងនេះថា គោនេះផឹក គោនេះមិនផឹក គោនេះបានឱកាសត្រង់កំពង់ទឹកសម្រាប់ផឹក គោនេះមិនបាន ដូច្នេះ ។ តែនាយគោបាលនេះ រក្សាហ្វូងគោក្នុងព្រៃអស់មួយថ្ងៃ គិតថា អញនឹងឲ្យផឹកទឹក ដូច្នេះ ក៏កៀងគោទៅត្រង់ស្ទឹង ឬអូរ គោធំ គោតូច យកស្មែងជល់មេគោដែលមិនមានកម្លាំង និងគោដែលមានកម្លាំងតិច ឬចាស់ ខ្លួនបានឱកាសចុះទឹកស្មើដើមទ្រូង ផឹកតាមសេចក្តីប្រាថ្នា គោដ៏សេស កាលមិនបានឱកាស ឈរនៅត្រង់ច្រាំង ផឹកទឹកល្បាយដោយភក់ខ្លះ មិនបានផឹកខ្លះ កាលបើដូច្នោះ នាយគោបាលវាយត្រង់ខ្នង

កៀងឲ្យគោទាំងនោះត្រឡប់ចូលព្រៃទៀត ក្នុងគោទាំងនោះ មេគោដែលមិនបានផឹក ក៏ស្បើយកម្លាំងដោយការស្រេក មិនអាចនឹងទំពាស៊ីស្មៅតាមសេចក្តីត្រូវការបាន ទឹកដោះរបស់មេគោក្នុងទីនោះក៏ដាច់ទៅ ហ្វូងគោក៏ថមថយកម្លាំង ។បេ។ នាយគោបាលនោះ រមែងធ្លាយ ។ បទថា **ន វីថឹ ជានាតិ** សេចក្តីថា មិនដឹងថា ផ្លូវនេះជាផ្លូវរាបស្មើ ផុតអំពីភ័យ ផ្លូវនេះមិនរាបស្មើ គួរវៀស មានភ័យចំពោះមុខ ។ នាយគោបាលនោះ វៀរផ្លូវដែលផុតភ័យរាបស្មើ កៀងហ្វូងគោឲ្យដើរទៅក្នុងផ្លូវមួយទៀត គោប៉ះក្លិនរាជសីហ៍ និងខ្លាជាដើម ឬអន្តរាយអំពីចោរគ្របសង្កត់ ប្រៀបដូចម្រឹគស្មាន់ ឈរអើត-ក មិនអាចទំពាស៊ីស្មៅ ផឹកទឹកមិនបានតាមប្រាថ្នា ទឹកដោះរបស់មេគោក្នុងទីនោះក៏ដាច់ទៅ ។បេ។ នាយគោបាលនោះ រមែងធ្លាយ ។ បទថា **ន គោចរ-កុសលោ ហោតិ** សេចក្តីថា នាយគោបាលគប្បីឈ្លាសក្នុងទីដែលគោត្រាច់រកស៊ី គប្បីដឹងមួយគ្រា ៥ ថ្ងៃ ឬមួយគ្រា ៧ ថ្ងៃ ឲ្យហ្វូងគោដែលត្រាច់រកស៊ីក្នុងទិសមួយហើយ ថ្ងៃស្អែកឡើង មិនគប្បីឲ្យត្រាច់ទៅក្នុងទីនោះ ។ ឯទីដែលហ្វូងគោធ្លាប់ត្រាច់ទៅ ស្មៅអស់រាបដូចមុខស្គរ សូម្បីទឹកក៏ល្អក់ ព្រោះដូច្នោះ ទើបក្នុងថ្ងៃទី ៥ ឬទី ៧ គួរកៀងឲ្យត្រាច់ទៅរកស៊ីក្នុងទីនោះទៀត ព្រោះថា ស្មៅក៏លាស់ជាថ្មី ទឹកក៏ថ្លា ដោយហេតុប្រមាណប៉ុណ្ណេះ ឯនាយគោបាលនោះ មិនស្គាល់កាល ៥ ថ្ងៃម្តង ឬ ៧ ថ្ងៃម្តង តែងរក្សាទីដែលខ្លួនរក្សាហើយនោះរាល់ៗ ថ្ងៃ កាលបើដូច្នោះ ហ្វូងគោរបស់នាយគោបាលនោះ មិនបានទំពាស៊ីស្មៅដែលមានពណ៌ខៀវ កាលទំពាស៊ីស្មៅស្ងួត ផឹកទឹក

ដែលលាយដោយភក់ ទឹកដោះរបស់មេគោក្នុងទីនោះក៏ខះទៅ ។បេ។ នាយគោបាលនោះ រមែងក្ស័យ ។

បទថា **អនវសេសទោហី ច ហោតិ** សេចក្តីថា សាច់ និងឈាមរបស់កូនគោតាំងនៅបានដរាបណា នាយគោបាលអ្នកឈ្លាស គប្បីរឹតទឹកដោះឲ្យនៅសល់ ១-២ នាយគោបាលនេះរឹតទឹកដោះ មិនបានឲ្យនៅសល់សម្រាប់កូនគោឡើយ កូនគោដែលនៅបៅដោះ រមែងទន់ខ្សោយ ដោយឃ្លានទឹកដោះកាលមិនអាចញ៉ាំងខ្លួនឲ្យតាំងនៅបាន ញាប់ញ័រចំប្រប់ ដួលស្លាប់ចំពោះមុខមេ មេឃើញកូនតូចហើយ គិតថា កូនតូចរបស់អញមិនបានបៅដោះរបស់ខ្លួន មិនអាចទំពាស៊ីស្មៅ ផឹកទឹក តាមសេចក្តីត្រូវការបាន ព្រោះសេចក្តីសោកដល់កូន ទឹកដោះត្រង់កន្សោមដោះក៏ដាច់ទៅ ហ្វូងគោរបស់នាយគោបាល រមែងវិនាសផង គាត់រមែងក្ស័យចាកបញ្ចគោរសផង ដោយប្រការយ៉ាងនេះ ។ ឈ្មោះថា **គោបិតរោ** ព្រោះអត្ថថា ធ្វើកិច្ចជាបារបស់គោទាំងឡាយ ។ ឈ្មោះថា **គោបរិណាយកា** ព្រោះអត្ថថា នាំហ្វូងគោ គឺនាំទៅបានតាមពេញចិត្ត ។ បទថា **ន អតិរេកបូជាយ** សេចក្តីថា ពិតហើយ នាយគោបាលអ្នកឈ្លាស ទំនុកបម្រុងគោធំបែបនេះ ដោយការទំនុកបម្រុងពិសេស គឺរមែងឲ្យអាហារដ៏ប្រណីត តាក់តែងដោយគ្រឿងក្រអូបនិងលម្អក្នុងទី ៥ កន្លែង ប្រដាប់ផ្កា ពាក់ចង្កឹមាស និងចង្កឹប្រាក់ត្រង់ស្នែងអុជភ្លើងឲ្យភ្លឺអស់រាត្រី ឲ្យដេកខាងក្រោមពិតានសំពត់ ឯនាយគោបាលនេះរមែងមិនធ្វើការអើពើតែម្យ៉ាង ក្នុងការឲ្យអាហារដ៏ប្រណីតជាដើម មេហ្វូង

កាលមិនបានការទំនុកបម្រុងពិសេស ក៏មិនរក្សាហ្វូងគោ មិនការពារអន្តរាយហ្វូងគោរបស់នាយគោបាល រមែងវិនាសទៅ គាត់រមែងឆ្ងាយចាកបញ្ច-គោរស ដោយប្រការយ៉ាងនេះ ។

[ ២៥ ] បទថា **ឥធ** គឺក្នុងសាសនានេះ ។ បទថា **ន រូបញ្ញូ ហោតិ** សេចក្តីថា រមែងមិនស្គាល់រូបដែលពោលហើយយ៉ាងនេះថា មហាភូតរូប ៤ ដោយអាការ ២ គឺដោយការរាប់ ១ ដោយសមុដ្ឋាន ១ ។ ឈ្មោះថា មិនស្គាល់ដោយការរាប់ គឺមិនស្គាល់ថា ចំណែកនៃរូប ២៥ មកហើយ ក្នុងបាលីយ៉ាងនេះថា អាយតនៈ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត និងកាយ អាយតនៈគឺរូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ អាបោធាតុ ការស្រាលនៃរូប ការទន់នៃរូប ការគួរដល់ការងារ ឧបចយរូប សន្តតិរូប ជរតារូប អនិច្ចតារូប និងកពឡិង្ការាហារ ។ ភិក្ខុនេះប្រៀបដូចនាយគោបាលនោះ មិនស្គាល់រូបនៃគោទាំងឡាយដោយការរាប់ ដូច្នោះ ភិក្ខុមិនស្គាល់ដោយការរាប់ ក៏មិនអាចដើម្បីកំណត់រូបទាញយកនូវរូប កំណត់បច្ច័យ លើកឡើងកាន់សាមញ្ញលក្ខណៈ កំណត់រូប ទាញយកនូវរូប កំណត់បច្ច័យ លើកឡើងកាន់សាមញ្ញលក្ខណៈ ហើយកំណត់អរូប កាន់យកអរូប កំណត់បច្ច័យ លើកឡើងកាន់ត្រៃលក្ខណ៍ ឲ្យកម្មដ្ឋានដល់ទីបំផុតបាន ភិក្ខុនោះ រមែងមិនចម្រើននូវសីល សមាធិ វិបស្សនា មគ្គ ផល និងនិព្វាន ក្នុងសាសនានេះ ដូចហ្វូងគោរបស់នាយគោបាលនោះ រមែងមិនចម្រើនដូច្នោះ ។ ឧបមាដូចនាយគោបាលនោះ រមែង

ឆ្ងាយចាកបញ្ចគោរស យ៉ាងណា ភិក្ខុនោះក៏ឆ្ងាយចាកធម្មក្ខន្ធ ៥ គឺសីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ដែលជារបស់ព្រះអសេក្ខៈ ដូច្នោះ ឈ្មោះថា មិនស្គាល់ដោយសមុដ្ឋាន គឺមិនស្គាល់ថា រូបប្រមាណប៉ុណ្ណេះ មានសមុដ្ឋាន ១ ប្រមាណប៉ុណ្ណេះ មាន ២ សមុដ្ឋាន ប្រមាណប៉ុណ្ណេះ មាន ៣ សមុដ្ឋាន ប្រមាណប៉ុណ្ណោះ មាន ៤ សមុដ្ឋាន ប្រមាណប៉ុណ្ណេះ រមែងមិនតាំងឡើង អំពីសមុដ្ឋានណាឡើយ ដូច្នេះ ។ ភិក្ខុនេះប្រៀបដូចនាយគោបាលនោះ មិន ស្គាល់រូបនៃគោទាំងឡាយដោយពណ៌ ដូច្នោះ ភិក្ខុមិនស្គាល់រូបដោយសមុដ្ឋាន កាន់យកនូវរូប កំណត់រូបហើយ ។បេ។ រមែងឆ្ងាយ ។

បទថា **ន លក្ខណកុសលោ ហោតិ** សេចក្តីថា រមែងមិនដឹងថា កុសលកម្ម អកុសលកម្ម ជាលក្ខណៈពាល និងបណ្ឌិត ដែលពោលហើយយ៉ាងនេះថា ជនពាលមានកម្មជាលក្ខណៈ ជនជាបណ្ឌិតមានកម្មជាលក្ខណៈ ភិក្ខុកាលមិនស្គាល់យ៉ាងនេះ មិនវៀរបុគ្គលពាល មិនសេពគប់បណ្ឌិត កាលមិនវៀរបុគ្គលពាល មិនសេពគប់បណ្ឌិត មិនស្គាល់វត្ថុដែលគួរ មិនគួរ ជាកុសល អកុសល វត្ថុដែលមានទោស មិនមានទោស គរុកាបត្តិ លហុកាបត្តិ សតេកិច្ឆា អតេកិច្ឆា ឋានៈ អឋានៈ កាលមិនដឹងវត្ថុនោះ រមែងមិនអាចកាន់យកកម្មដ្ឋានទៅចម្រើនបាន ភិក្ខុនោះរមែងមិនចម្រើនដោយសីលគុណជាដើម តាមដែលពោលហើយក្នុងសាសនានេះ ដូចហ្វូងគោរបស់នាយគោបាលនោះមិនចម្រើន គឺជាអ្នកឆ្ងាយចាកធម្មក្ខន្ធ ដូចនាយគោបាលឆ្ងាយចាកបញ្ច-

គោរស ដូច្នោះ ។ បទថា **ន អាសាដិកំ សាដេតា ហោតិ** សេចក្តីថា រមែងមិនបន្ទោបង់នូវកាមវិតក្កជាដើម ដែលពោលហើយយ៉ាងនេះថា កាម-វិតក្កកើតឡើងហើយ ដូច្នេះ មិនត្អឹះពង់រុយ ដែលជាអកុសលវិតក្កនេះ កាលត្រាច់ប្រព្រឹត្តក្នុងអំណាចនៃវិតក្ក រមែងមិនអាចកាន់យកកម្មដ្ឋានទៅចម្រើនបាន ភិក្ខុនោះរមែងធ្លាយ ដូចនាយគោបាល ។បេ។ បទថា **ន វណំ បដិច្ឆាទេតា ហោតិ** សេចក្តីថា កាលកាន់យកនិមិត្តក្នុងអារម្មណ៍គ្រប់យ៉ាង ដោយន័យជាដើមថា ឃើញរូបដោយចក្ខុហើយ កាន់យកដោយនិមិត្ត ដូច្នេះ រមែងមិនញុំាងការសង្រួមឲ្យដល់ព្រម ដូចនាយគោបាលនោះ មិនរុំដំបៅ ដូច្នោះ ភិក្ខុនោះកាលបើកទ្វារត្រាច់ទៅ រមែងមិនអាចកាន់យកនូវកម្មដ្ឋានទៅចម្រើនបាន ។បេ។ ភិក្ខុនោះ រមែងធ្លាយ ។

បទថា **ន ធូមំ កត្តា ហោតិ** សេចក្តីថា ភិក្ខុមិនបំពក់ផ្សែង គឺធម្ម-ទេសនា ដូចនាយគោបាលនោះ មិនបំពក់ផ្សែង ដូច្នោះ គឺមិនធ្វើធម្មកថា ឬសរភញ្ញ ឧបនិស្សិន្នកថា ឬអនុមោទនា បន្ទាប់អំពីនោះ ពួកមនុស្សមិនស្គាល់គុណនេះថា ភិក្ខុដែលជាពហុស្សុត មានគុណ ដូច្នេះ មនុស្សទាំងនោះ កាលមិនស្គាល់គុណ និងទោស រមែងមិនធ្វើការសង្គ្រោះដោយបច្ច័យ ៤ លោកកាលលំបាកដោយបច្ច័យ ក៏មិនអាចធ្វើការស្វាធ្យាយនូវព្រះពុទ្ធវចនៈ បំពេញបដិបទា កាន់យកកម្មដ្ឋានទៅចម្រើនបានឡើយ ។បេ។ លោករមែងធ្លាយ ។ បទថា **ន តិត្ថំ ជានាតិ** សេចក្តីថា ភិក្ខុរមែងមិនចូលទៅរកភិក្ខុដែលជាពហុស្សុត ដែលជាបុគ្គលប្រៀបដូចកំពង់ទឹក កាលមិនចូលទៅរក មិនសាកសួរ

កាន់យកបរិបុច្ឆា ឲ្យដឹងយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្យញ្ជនៈនេះគប្បីចងដូចម្តេច អត្ថនៃភាសិតនេះដូចម្តេច បាលីក្នុងទីនេះពោលដូចម្តេច អត្ថក្នុងទីនេះសម្តែងដូចម្តេច ភិក្ខុដែលជាពហុស្សុតទាំងនោះ ដែលលោកមិនបានសាកសួរហើយយ៉ាងនេះ រមែងមិនបើកផ្លូវនូវសេចក្តីដែលកំបាំង មិនបែកចេញសម្តែង មិនធ្វើសេចក្តីដែលជ្រៅឲ្យរាក់ មិនធ្វើសេចក្តីដែលមិនប្រាកដឲ្យប្រាកដដល់លោក ។ បទថា **អនេកវិហិតេសុ ច កង្ខដ្ឋានីយេសុ ធម្មេសុ** បានដល់ រមែងមិនបន្ទោបង់នូវសេចក្តីសង្ស័យណាមួយ ក្នុងសេចក្តីសង្ស័យច្រើនយ៉ាង អធិប្បាយថា សេចក្តីសង្ស័យ ឈ្មោះថា ធម៌ជាទីតាំងនៃសេចក្តីសង្ស័យ រមែងមិននាំសេចក្តីសង្ស័យណាមួយ ក្នុងធម៌នោះចេញទៅបាន ។ លោកមិនចូលទៅរកកំពង់ គឺភិក្ខុដែលជាពហុស្សុតយ៉ាងនេះ ទើបពោរពេញទៅដោយសេចក្តីសង្ស័យ មិនអាចដើម្បីនឹងកាន់យកកម្មដ្ឋានទៅចម្រើនបាន ដូចនាយគោបាល រមែងមិនស្គាល់កំពង់ យ៉ាងណា ភិក្ខុនេះមិនស្គាល់កំពង់ គឺធម៌ ដូច្នោះ កាលមិនដឹង បានសួរបញ្ហាដែលមិនមែនជាវិស័យ ចូលទៅរកភិក្ខុអ្នកចេះអភិធម្ម បានសួរវត្ថុដែលគួរ និងមិនគួរ ចូលទៅរកព្រះវិនយធរ បានសួរការកំណត់រូប និងអរូប លោកទាំងនោះ ត្រូវសួរក្នុងធម៌ដែលមិនមែនវិស័យ រមែងមិនអាចដើម្បីនឹងឆ្លើយបាន ទើបលោកពេញទៅដោយសេចក្តីសង្ស័យដោយខ្លួនឯង ទើបមិនអាចកាន់យកកម្មដ្ឋានទៅចម្រើនបាន ។បេ។ ភិក្ខុនោះ រមែងឆ្ងាយ ។

បទថា **បិតំ ន ជានាតិ** សេចក្តីថា ភិក្ខុរមែងមិនដឹង គឺមិនបាននូវ

បាមោជ្ជដែលប្រកបដោយធម៌ ដូចនាយគោបាលនោះ មិនដឹងថា ឲ្យគោផឹក និងមិនទាន់ផឹក ដូច្នោះ លោកអាស្រ័យបុញ្ញកិរិយាវត្ថុ សម្រេចដោយការស្តាប់ រមែងមិនជួបនូវអានិសង្ស ទៅកាន់ពេលស្តាប់ធម៌ហើយ រមែងមិនស្តាប់ដោយគោរព អង្គុយដេកលក់ រមែងជជែក ជាអ្នកមានចិត្តបញ្ជូនទៅកាន់ទីដទៃ លោកកាលមិនស្តាប់ធម៌ដោយគោរព រមែងមិនអាចដើម្បីនឹងកាន់យកកម្មដ្ឋានទៅចម្រើនបាន ។បេ។ ភិក្ខុនោះ រមែងថ្លាយ ។ បទថា **ន វីថឹ ជានាតិ** សេចក្តីថា ភិក្ខុរមែងមិនស្គាល់ច្បាស់នូវអរិយមគ្គមានអង្គ ៨ តាមសេចក្តីពិតថា ផ្លូវនេះជាលោកិយ ផ្លូវនេះជាលោកុត្តរ ដូច្នេះ ដូចនាយគោបាលនោះ មិនដឹងនូវផ្លូវ និងមិនមែនផ្លូវ ដូច្នោះ កាលលោកមិនដឹងតាំងមាំ ហើយក្នុងផ្លូវដែលជាលោកិយ មិនអាចញុំាងលោកុត្តរធម៌ឲ្យកើតឡើងបាន ។បេ។ ភិក្ខុនោះ រមែងថ្លាយ ។ បទថា **ន គោចរកុសលោ ហោតិ** សេចក្តីថា ភិក្ខុរមែងមិនស្គាល់ច្បាស់សតិប្បដ្ឋាន ៤ តាមសេចក្តីពិតថា ធម៌ទាំងនេះជាលោកុត្តរ ដូចនាយគោបាលនោះមិនដឹងនូវគ្រា ៥ ថ្ងៃ និង ៧ ថ្ងៃ ដូច្នោះ កាលលោកមិនដឹងបណ្តុះញាណរបស់ខ្លួនក្នុងធម៌ដែលសុខុម តាំងមាំក្នុងសតិប្បដ្ឋានជាលោកិយ រមែងមិនអាចញុំាងលោកុត្តរធម៌ឲ្យកើតឡើងបាន ។បេ។ ភិក្ខុនោះ រមែងថ្លាយ ។ បទថា **អនវសេសទោហី** សេចក្តីថា ភិក្ខុកាលមិនស្គាល់ប្រមាណក្នុងការទទួល រមែងរឹតអស់ មិនបានសន្សល់ទុក ឯក្នុងនិទ្ទេសវារៈ ពួកគហបតីដែលមានសទ្ធា បវារណាដល់ភិក្ខុនោះថា **អភិហាត្តុំ បវារេន្តិ** ក្នុងបវារណានេះ បវារណាមាន ២ យ៉ាង គឺ

បវារណាដោយវាចា ១ បវារណាដោយបច្ច័យ ១ ។ ពួកមនុស្សទៅកាន់សម្នាក់នៃភិក្ខុហើយ បវារណាថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ប្រាប់វត្ថុដែលត្រូវការ ដូច្នេះ ឈ្មោះថា បវារណាដោយវាចា ។ ពួកមនុស្សកាន់យកសំពត់ ឬភេសជ្ជៈ មានសប្បិ និងទឹកអំពៅជាដើម ទៅក្នុងសម្នាក់របស់ភិក្ខុ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលតាមសេចក្តីត្រូវការចុះ ដូច្នេះ ឈ្មោះថា បវារណាដោយបច្ច័យ ។ បទថា **តត្រ ភិក្ខុ មត្តំ ន ជានាតិ** អធិប្បាយថា ភិក្ខុមិនស្គាល់ប្រមាណក្នុងបច្ច័យទាំងនោះ មិនទទួលតែល្មមប្រមាណ ដោយន័យដែលពោលទុកក្នុងរថវិនីតសូត្រថា គប្បីដឹងនូវសមត្ថភាពនៃទាយក សមត្ថភាពរបស់ទេយ្យធម៌ គប្បីដឹងកម្លាំងរបស់ខ្លួន ទទួលវត្ថុដែលគេនាំមកប្រគេនទាំងអស់ ។ មនុស្សក្តៅក្រហាយ នឹងមិនបវារណាទៀត ។ កាលលោកលំបាកដោយបច្ច័យ រមែងមិនអាចកាន់យកកម្មដ្ឋានទៅចម្រើនបាន ។បេ។ ភិក្ខុរមែងធ្លាយ ។ បទថា **តេ ន អតិរេក-បូជាយ បូជិតា ហោតិ** សេចក្តីថា ភិក្ខុមិនបូជាភិក្ខុទាំងនោះ ដែលជាព្រះថេរៈ ដោយអតិរេកបូជា មានមេត្តាកាយកម្មជាដើម ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ដូចនាយគោបាល មិនប្រណិប័តន៍គោធំ ដោយការទំនុកបម្រុងពិសេស ដូច្នោះ ព្រះថេរៈគិតថា ភិក្ខុទាំងឡាយ មិនធ្វើសេចក្តីគោរពនិងការកោតក្រែងក្នុងពួកយើងទាំងទាំងឡាយហើយ ទើបមិនបានសង្គ្រោះពួកនវកភិក្ខុ ដោយការសង្គ្រោះ ២ យ៉ាង គឺមិនសង្គ្រោះដោយធម៌ ១ មិនសង្គ្រោះដោយអាមិស ១ មិនទំនុកបម្រុងនវកភិក្ខុដែលលំបាក ខ្វះខាតដោយចីវរ ឬ

បាត្រ វត្ថុដែលជាប់ទាក់ទងដោយបាត្រ ឬទីលំនៅ មិនឲ្យសិក្សាបាលី ឬ អដ្ឋកថា គម្ពីរទាក់ទងដោយធម្មកថា ឬគម្ពីរដែលមានន័យដ៏កំបាំង ពួកនវកភិក្ខុ កាលមិនបាននូវការសង្គ្រោះ ២ យ៉ាងនេះ អំពីសម្នាក់របស់ព្រះថេរៈទាំង-ឡាយ ដោយប្រការទាំងពួង រមែងមិនអាចតាំងនៅក្នុងសាសនានេះបាន ។ ពួកលោករមែងមិនចម្រើនដោយសីលគុណជាដើម ដូចហ្វូងគោរបស់នាយគោបាល រមែងមិនចម្រើន ដូច្នោះ ។ នាយគោបាលនោះ រមែងជាអ្នកឆ្ងាយចាកបញ្ចគោរស យ៉ាងណា លោករមែងជាអ្នកឆ្ងាយចាកធម្មក្ខន្ធ ៥ ដូច្នោះ ។ សុក្កបក្ខលោកប្រកបទុកហើយ គប្បីជ្រាបដោយអំណាចការផ្ទុយគ្នាតាមដែលពោលហើយ ក្នុងកណ្ហបក្ខ ។

**មហាគោបាលសូត្រ ចប់**

**សូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ចូឡគោបាលសូត្រទី ៤

[ ២៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្បែរឆ្នេរទន្លេគង្គា ទៀបក្រុងឧក្កចេលា ក្នុងដែនវជ្ជី ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា នែភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ក៏ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ។

[ ២៩ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា គង្វាលគោជាអ្នកនៅក្នុងដែនមគធៈ ជាមនុស្សអប្បឥតប្រាជ្ញា មិនបានពិចារណានូវត្រើយខាងអាយ ទាំងមិនបានពិចារណានូវត្រើយខាងនាយនៃទន្លេគង្គា ក៏នាំគោទាំងឡាយឲ្យឆ្លង ទៅកាន់ត្រើយខាងជើងនៃដែនវិទេហៈ ត្រង់ទីដែលមិនមែនជាកំពង់ ក្នុងសារទសម័យ នាខែជាចុងនៃរដូវភ្លៀង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកគោក៏ធ្វើនូវការវិលវល់ ក្នុងកណ្តាលខ្សែទឹកទន្លេគង្គា ហើយក៏ដល់នូវសេចក្តីវិនាស បាត់បង់ក្នុងទឹកទន្លេនោះឯង សេចក្តីវិនាសបាត់បង់ទៅនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា គង្វាលគោជាអ្នកនៅក្នុងដែនមគធៈនោះ ជាមនុស្សអប្បឥតប្រាជ្ញា មិនបានពិចារណានូវត្រើយខាងអាយ ទាំងមិនបានពិចារណានូវត្រើយខាងនាយនៃទន្លេគង្គា ក៏នាំគោទាំងឡាយ ឲ្យឆ្លងទៅកាន់ត្រើយខាងជើង នៃដែនវិទេហៈ តាមទីដែលមិនមែនជាកំពង់ ក្នុងសារទសម័យ នាខែជាខាងចុង

នៃវដ្តវត្ថៀន ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី មិនឈ្លាសក្នុងលោកនេះ មិនឈ្លាសក្នុងលោកខាងមុខ មិនឈ្លាសក្នុងទីនៅនៃមារ មិនឈ្លាសក្នុងទីមិនមែនជាទីនៅនៃមារ មិនឈ្លាសក្នុងទីនៅនៃមច្ចុ មិនឈ្លាសក្នុងទីដែលមិនមែនជាទីនៅនៃមច្ចុ ពួកជនណាសម្គាល់នូវពាក្យរបស់សមណព្រាហ្មណ៍ ទាំងអម្បាលនោះ ថាជាពាក្យគួរស្តាប់ គួរជឿ សេចក្តីសម្គាល់របស់ជនទាំងនោះ នឹងប្រព្រឹត្តទៅដើម្បីមិនមែនជាប្រយោជន៍ ដើម្បីទុក្ខអស់កាលយូរអង្វែង ។

[ ៣០ ] ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា គង្វាលគោនៅក្នុងដែនមគធៈ ជាមនុស្សមានប្រាជ្ញា បានពិចារណានូវត្រើយខាងអាយ ទាំងពិចារណានូវត្រើយខាងនាយ នៃទន្លេគង្គា ក៏នាំគោទាំងឡាយឲ្យឆ្លងទៅកាន់ត្រើយខាងជើងនៃដែនវិទេហៈ តាមទីដែលជាកំពង់ក្នុងសារទសម័យ នាខែជាខាងចុង នៃវដ្តវត្ថៀន ។ គង្វាលគោនោះ ចម្លងគោឧសភ ដែលជាបិតារបស់គោ ជាគោបរិនាយកទៅមុន គោទាំងនោះ ក៏ហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល ។ បន្ទាប់ពីនោះ គង្វាលគោ ចម្លងពួកគោដែលមានកម្លាំង និងគោដែលគួរបង្ហាត់បានជាទៃទៀត ឯគោទាំងនោះ បានហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល ។ តពីនោះ គង្វាលគោ ចម្លងគោឈ្មោលស្ទាវ និងគោញីជំទង់ដទៃទៀត ឯគោទាំងនោះ ក៏ហែលកាត់ទទឹងខ្សែទឹកទន្លេគង្គាទៅដល់ត្រើយខាងនាយដោយស្រួលបួល ។ លំដាប់ពីនោះ គង្វាលគោចម្លងកូនគោកំពុង

ជៅជោះ និងកូនគោស្គម មានកម្លាំងថយដទៃទៀត ឯកូនគោទាំងនោះ ក៏ហែលកាត់ទទឹងខ្សែទឹក ទន្លេគង្គាទៅដល់ត្រើយខាងនាយដោយស្រួលបួល ។ ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា កូនគោកំពុងជៅជោះ ជាកូនគោនៅខ្ចី ទើបកើតក្នុងថ្ងៃនោះឯង តែងហែលទៅតាមសំឡេងរបស់មេគោ ឯកូនគោនោះ ហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល រឿងនោះព្រោះហេតុដូចម្តេច ព្រោះថាគង្វាលគោជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ គង្វាលគោនៅក្នុងដែនមគធៈនោះឯង ជាមនុស្សមានប្រាជ្ញា បានពិចារណានូវត្រើយខាងអាយ ពិចារណានូវត្រើយខាងនាយ នៃទន្លេគង្គា ក៏នាំគោទាំងឡាយឲ្យឆ្លងទៅកាន់ត្រើយខាងជើង នៃដែនវិទេហៈ តាមទីដែលជាកំពង់ ក្នុងសរទសម័យ នាខែជាខាងចុងនៃវស្សានរដូវ ( ដូចម្តេចមិញ ) ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ជាអ្នកឈ្លាសក្នុងលោកនេះ ឈ្លាសក្នុងលោកខាងមុខ ឈ្លាសក្នុងទីនៅរបស់មារ ឈ្លាសក្នុងទីដែលមិនមែនជាទីនៅរបស់មារ ឈ្លាសក្នុងទីនៅរបស់មច្ចុ ឈ្លាសក្នុងទីដែលមិនមែនជាទីនៅរបស់មច្ចុ ពួកជនណាបានសម្គាល់នូវពាក្យរបស់សមណៈ និងព្រាហ្មណ៍ទាំងនោះ ថាជាពាក្យគួរស្តាប់ គួរជឿ សេចក្តីសម្គាល់របស់ជនទាំងនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលយូរអង្វែង យ៉ាងដូច្នោះឯង ។

[ ៣១ ] ម្នាលភិក្ខុទាំងឡាយ គោឧសភទាំងឡាយណា ជាបិតារបស់គោ ជាគោបរិនាយក គោឧសភទាំងនោះ បានហែលកាត់ទទឹងខ្សែទឹកទន្លេ

គង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា ជាអរហន្តខីណាស្រព មានព្រហ្មចារ្យនៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួនហើយ មានសំយោជនៈក្នុងភព គឺ តណ្ហាអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះត្រាស់ដឹងនូវធម៌ដោយប្រពៃ ភិក្ខុទាំងនោះអាចកាត់នូវខ្សែនៃមារដោយទទឹង ហើយទៅដល់ត្រើយខាងនាយ គឺព្រះនិព្វានដោយស្រួល មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ គោទាំងឡាយណា ដែលជាគោមានកម្លាំង ជាគោដែលគួរបង្ហាត់បាន គោទាំងនោះ បានហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយ ដោយស្រួលបួល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា មានសំយោជនៈជាចំណែកខាងក្រោមទាំង ៥ អស់ហើយ ជាឱបបាតិកៈ ( សំដៅយកព្រះអនាគាមិបុគ្គល ) បរិនិព្វានក្នុងលោកនោះ មានសភាពមិនបានត្រឡប់ចាកលោកនោះ ភិក្ខុទាំងនោះនឹងកាត់នូវខ្សែនៃមារដោយទទឹងហើយដល់នូវត្រើយខាងនាយ គឺព្រះនិព្វានដោយស្រួលបួល មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ គោឈ្មោលស្ទាវទាំងឡាយ គោញីជំទង់ទាំងឡាយ បានហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ហើយទៅដល់ត្រើយខាងនាយដោយស្រួលបួល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា មានសំយោជនៈ ៣ អស់ហើយ តែនៅមានរាគៈ ទោសៈ និងមោហៈដែលស្រាលស្តើង ជាសកទាគាមិបុគ្គល មកកាន់លោកនេះ តែម្តង

ទៀត ហើយនឹងធ្វើនូវទីបំផុតទុក្ខ ភិក្ខុទាំងនោះនឹងកាត់នូវខ្សែនៃមារ ដោយទទឹង ហើយដល់ត្រើយខាងនាយ គឺព្រះនិព្វានដោយស្រួលបួល មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កូនគោដែលកំពុងបៅដោះទាំងឡាយ និងកូនគោដែលស្គមមានកម្លាំងថយ បានហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ទៅដល់ត្រើយខាងនាយដោយស្រួលបួល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា មានសំយោជនៈ ៣ អស់ហើយ ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានធម៌ជាគ្រឿងត្រាស់ដឹង ប្រព្រឹត្តទៅក្នុងខាងមុខ ភិក្ខុទាំងនោះ បានកាត់នូវខ្សែនៃមារដោយទទឹងហើយ ក៏បានដល់នូវត្រើយខាងនាយ គឺព្រះនិព្វានដោយស្រួលបួល មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កូនគោកំពុងបៅដោះដែលជាកូនគោនៅខ្ចី ទើបតែនឹងកើតហើយក្នុងថ្ងៃនោះឯង ក៏ហែលទៅតាមសំឡេងនៃមេគោ បានហែលកាត់ទទឹងខ្សែទឹកទន្លេគង្គា ដល់ទៅត្រើយខាងនាយដោយស្រួលបួល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ដែលជាធម្មានុសារីបុគ្គល និងសទ្ធានុសារីបុគ្គល ពួកភិក្ខុទាំងនោះនឹងកាត់នូវខ្សែនៃមារដោយទទឹង ហើយដល់នូវត្រើយខាងនាយ គឺព្រះនិព្វានដោយស្រួលបួល ។ ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគត ជាអ្នកឈ្លាសក្នុងលោកនេះ អ្នកឈ្លាសក្នុងលោកខាងមុខ អ្នកឈ្លាសក្នុងទីនៅនៃមារ អ្នកឈ្លាសក្នុងទីដែលមិនមែនជាទីនៅនៃមារ អ្នកឈ្លាសក្នុងទីនៅនៃមច្ចុ អ្នកឈ្លាសក្នុងទីដែលមិនមែនជាទីនៅនៃមច្ចុ ។ ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយ

ណា សម្គាល់នូវពាក្យរបស់តថាគត ថាជាពាក្យគួរស្តាប់ គួរជឿ សេចក្តីសម្គាល់របស់ជនទាំងនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលយូរអង្វែង ។ ព្រះមានព្រះភាគ ព្រះអង្គត្រាស់សូត្រនេះចប់ហើយ ព្រះសុគតជាសាស្តា លុះត្រាស់សូត្រនេះរួចហើយ ទើបសម្តែងគាថានេះតទៅទៀតថា

លោកនេះ និងលោកខាងមុខ ដែលព្រះសម្ពុទ្ធទ្រង់ដឹង បានប្រកាសហើយដោយប្រពៃ លោកណាៗ ដែលមច្ចុមារទៅដល់ក្តី ទៅមិនដល់ក្តី ព្រះសម្ពុទ្ធទ្រង់ដឹងច្បាស់ បានត្រាស់ដឹងនូវលោកទាំងអស់នោះ ហើយបើកទ្វារនៃព្រះនិព្វាន គឺអរិយមគ្គ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេម បានកាត់កម្ចាត់ខ្សែរបស់មារ ហើយធ្វើឲ្យប្រាសចាកដើមបបុស គឺមានះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាអ្នកច្រើនដោយសេចក្តីរីករាយ ចូរប្រាថ្នានូវព្រះនិព្វាន ជាទីក្សេមចុះ ។

ចូឡគោបាលសូត្រទី ៤ ចប់

# អដ្ឋកថា

## ចូឡគោបាលសូត្រទី ៤

[ ២៨ ] ចូឡគោបាលសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះ ជាដើម ។ បណ្តាបទទាំងនោះ បទថា **ឧក្កាចេលាយំ** គឺក្នុងនគរមានឈ្មោះ យ៉ាងនោះ ។ បានឮថា មហាជនកំពុងសាងនគរនោះ ត្រីចេញអំពីក្រសែទឹកគង្គា ឡើងលើគោកក្នុងវេលាយប់ ពួកមនុស្សជ្រលក់សំពត់ក្នុងថាសប្រេងឲ្យសើម ធ្វើគប់ភ្លើងចាប់ត្រី ។ កាលនគរនោះសាងស្រេចហើយ ពួកមហាជន កាលនឹងតាំងឈ្មោះនគរនោះ ទើបឲ្យឈ្មោះនគរនោះថា **ឧក្កាចេលា** ដោយគិតថា ក្នុងថ្ងៃសាងនគរ ពួកយើងចាប់ត្រីបានដោយគប់ភ្លើង ដែលធ្វើអំពីសំពត់ ។ បទថា **ភិក្ខូ អាមន្តេសិ** សេចក្តីថា ទន្លេគង្គាទាំងអស់ រមែងប្រាកដដល់អ្នកអង្គុយក្នុងទីណា ព្រះមានព្រះភាគ ដែលភិក្ខុសង្ឃដ៏ច្រើនហែហម ប្រថាប់គង់ក្នុងទីនោះ ត្រង់ច្នេរខ្សាច់ នាប្រាំងទន្លេគង្គា វេលាល្ងាច កំពុងទតទន្លេគង្គា ដែលហូរពេញកម្លាំង ទ្រង់ព្រះតម្រិះថា មានបុគ្គលណាមួយហ្ន៎ អាស្រ័យទន្លេគង្គានេះហើយ បានទទួលសេចក្តីចម្រើន និងការវិនាសក្នុងកាលមុន ទ្រង់បានឃើញថា ហ្វូងគោច្រើនពាន់ អាស្រ័យនាយគោបាលល្ងង់ម្នាក់ ធ្លាក់ត្រង់អន្លង់ទឹកក្នុងទន្លេគង្គានេះ ចូលទៅកាន់មហាសមុទ្រ ឯហ្វូងគោច្រើនសែន មាននូវសួស្តី សេចក្តីចម្រើន ការមិនមានរោគ ព្រោះអាស្រ័យនាយគោបាលឈ្លាសម្នាក់ ។ កាលទ្រង់ឃើញហើយ ទ្រង់ព្រះតម្រិះថា តថាគតអាស្រ័យហេតុនេះ សម្តែងធម៌ដល់ពួកភិក្ខុនេះ ដូច្នេះ ទើបត្រាស់

ហៅភិក្ខុទាំងឡាយ ។

[ ២៩ ] បទថា **មាគធកោ** គឺអ្នកដែនមគធរដ្ឋ ។ បទថា **ទុប្បញ្ញ-ជាតិកោ** បានដល់ មហាជនដែលមិនមានបញ្ញាជាសភាវៈ ។ បទថា **អសម-វេក្ខិត្វា** បានដល់ មិនកំណត់ គឺមិនពិចារណា ។ បទថា **បតារេសិ** សេចក្តីថា ផ្តើមដើម្បីនឹងឆ្លង ។ បទថា **ឧត្តរំ តីរំ សុវិទេហានំ** សេចក្តីថា ឲ្យគោឆ្លងទៅកាន់ច្រាំងខាងជើង ដោយគិតថា អញនឹងនាំគោអំពីដែនមគធរដ្ឋត្រង់ច្រាំងនៃទន្លេគង្គានេះ ទៅកាន់វិទេហរដ្ឋត្រង់ច្រាំងនោះ នាំគោអំពីមគធរដ្ឋទៅកាន់វិទេហរដ្ឋ ហើយរក្សា ព្រះមានព្រះភាគ ទ្រង់សំដៅយកនាយគោបាលនោះ ទើបត្រាស់ថា **ឧត្តរំ តីរំ សុវិទេហានំ** ដូច្នេះ ។ បទថា **អាមណ្ឌលិកំ ករិត្វា** បានដល់ ធ្វើឲ្យវិលវល់ ។ បទថា **អនយព្យសនំ អាបជ្ជិសុ** បានដល់ ដល់នូវសេចក្តីវិនាស គឺមិនចម្រើន គឺចូលទៅកាន់មហាសមុទ្រ ។ នាយគោបាលនោះ កាលឲ្យគោឆ្លង គប្បីពិនិត្យមើលកំពង់ដែលរាបស្មើ និងមិនរាបស្មើត្រង់ត្រើយអាយនៃទន្លេគង្គា គប្បីកំណត់ផ្នូកខ្សាច់ទុក ២ , ៣ កន្លែង ដើម្បីជាទីសម្រាករបស់គោកណ្តាលទន្លេគង្គា ម្យ៉ាងទៀត គប្បីកំណត់កំពង់ទុក ៣ , ៤ កំពង់ ត្រង់ត្រើយនាយថា គោចុះអំពីកំពង់នេះ នឹងឡើងទៅកំពង់នេះ ចុះអំពីកំពង់នេះ នឹងឡើងទៅកំពង់នេះ ដូច្នេះ ។ ឯនាយគោបាលល្ងង់នេះ មិនពិនិត្យមើលកំពង់សម្រាប់គោ ត្រង់ត្រើយអាយ រាបស្មើ ឬមិនរាបស្មើ មិនកំណត់កោះទុក ២ , ៣ កន្លែង ដើម្បីជាទីសម្រាករបស់គោ ត្រង់កណ្តាលទន្លេគង្គា មិនពិចារណាទីសម្រាប់គោឡើង ៤,៥ កន្លែង ត្រង់ត្រើយ

នាយ ឲ្យគោចូលទៅដោយទីដែលមិនមែនជាកំពង់ ។ កាលនោះ គោធំរបស់នាយគោបាលហែលកាត់ក្រសែទឹកទន្លេគង្គាត្រង់ទីទទឹង ទៅដល់ត្រើយនាយ ព្រោះដល់ព្រមដោយសន្ទុះ និងព្រោះដល់ព្រមដោយកម្លាំង ឃើញច្រាំងដាច់ និងបន្ទាស្អកស្កះហើយ ដឹងថា ទីនោះចេញទៅបានដោយលំបាក ដូច្នេះ មិនមានទីវាលសម្រាប់ឈរ លើគោក ក៏ហែលត្រឡប់មកវិញ ។ គោទាំងឡាយគិតថា គោធំហែលត្រឡប់ហើយ ពួកយើងក៏នឹងត្រឡប់ ដូច្នេះ ក៏ហែលត្រឡប់ទាំងអស់គ្នា ។ ក្នុងទីដែលហ្វូងគោដ៏ច្រើនត្រឡប់ ទឹកវិលតាំងឡើងកណ្តាលទន្លេគង្គា ហ្វូងគោចូលទៅក្នុងទឹកកួចដល់សមុទ្រ គោមួយឈ្មោះថា មិនមានអន្តរាយមិនមានឡើយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា គោទាំងឡាយដល់ហើយនូវសេចក្តីវិនាស មិនមែនប្រយោជន៍ក្នុងទីនោះឯង ។ បទថា **អកុសលា ឥមស្ស លោកស្ស** បានដល់ សមណព្រាហ្មណ៍ដែលជាអ្នកមិនឈ្លាស គឺមុតស្រួច ក្នុងលោកនេះ គឺខន្ធ ធាតុ អាយតនៈ ។ សូម្បីក្នុងបរលោកក៏មានន័យនេះឯង ។ អន្ទាក់មារ លោកហៅថា តេភូមិកធម៌ ដទៃអំពីអន្ទាក់មារ លោកហៅថា លោកុត្តរធម៌ ។ ទីតាំងនៃមច្ចុ លោកហៅថា តេភូមិកធម៌ ទីតាំងនៃអមច្ចុ លោកហៅថា នវលោកុត្តរធម៌ ។ សមណព្រាហ្មណ៍ទាំងនោះ មិនឈ្លាស មិនមុតស្រួចក្នុងធម៌ទាំងនោះ ។ បទថា **មារធេយ្យំ** ដោយអត្ថថា ជាអន្ទាក់របស់មារ គោចរដែលជាឋានៈ ទីនៅ និងទីអាស្រ័យ ឈ្មោះថា **ធេយ្យំ**។ ក្នុងបទថា **មច្ចុធេយ្យេ** ក៏មានន័យនេះឯង ។ បទថា **តេសំ** បានដល់ សមណព្រាហ្មណ៍

ពួកនោះ គឺដែលមានសភាពបែបនោះ ។ គប្បីជ្រាបថា គ្រូទាំង ៦ លោកសម្តែងហើយដោយបទនេះ ។

[ ៣០ ] ព្រះមានព្រះភាគ កាលទ្រង់បញ្ចប់កណ្ហបក្ខយ៉ាងនេះហើយ ទើបទ្រង់សម្តែង សុក្កបក្ខ ត្រាស់ពាក្យជាដើមថា **ភូតបុព្វំ ភិក្ខវេ** ដូច្នេះ ។ បណ្តាបទទាំងនោះ ។ បទថា **ពលវគាវេ** គឺ គោដែលបង្ក្រាបហើយ និងមេគោ ជំទង់ ។ បទថា **ទម្មគាវេ** គឺគោដែលគួរបង្ក្រាប និងគោក្រមុំ ។ បទថា **វច្ឆតរេ** បានដល់ កូនគោមានកម្លាំង ដែលកន្លងភាពជាកូនគោ ។ បទថា **វច្ឆកេ** គឺកូនគោជំទង់ ដែលនៅបៅដោះ ។ បទថា **កិសពលកេ** គឺមានសាច់ឈាម និងកម្លាំងតិច ។

[ ៣១ ] បទថា **តាវទេវ ជាតកោ** គឺកូនគោដែលកើតក្នុងថ្ងៃនោះ ។ បទថា **មាតុ គោរវកេន វុយ្ហមានោ** សេចក្តីថា មេគោបន្លឺសំឡេងគោខាងមុខថា ហុំ ហុំ ឲ្យសញ្ញា ហែលកាត់ខ្សែទឹកទៅ ។ កូនគោហែលទៅតាមមេគោទាំងនោះ ដោយសំឡេងស្រែករបស់មេគោនោះ លោកហៅថា ហែលតាមសំឡេងស្រែករបស់មេគោ ។ បទថា **មារស្ស សោតំ ឆេត្វា** សេចក្តីថា កាត់ក្រសែនៃតណ្ហារបស់មារ ដោយអរហត្តមគ្គ ។ បទថា **ចារំ គតា** បានដល់ ភិក្ខុដល់ត្រើយនៃសង្សារ គឺនិព្វាន ដូចគោធំហែលទៅដល់ប្រាំង ដូច្នោះ ។ បទថា **ចារំ អគមំសុ** សេចក្តីថា ក្នុងខណៈដែលគោធំដល់ប្រាំង គោទាំងឡាយហែលកន្លង ៣ ចំណែក ក្រសែទន្លេគង្គា ហើយឃើញគោធំដល់ត្រើយ ទើបទៅតាមផ្លូវដែលគោធំទាំងនោះទៅហើយ ។ បទថា **ចារំ**

**គមិស្សន្តិ** សេចក្ដីថា បុគ្គលញ៉ាំងកិលេសដែលមគ្គ ៤ គប្បីសម្លាប់ ៣ ចំណែកឲ្យអស់ ហើយតាំងនៅ ឥឡូវនេះ គប្បីជ្រាបក្នុងវារៈទាំងពួង ដោយន័យនេះថា ភិក្ខុកាត់ក្រសែតណ្ហាអស់ទៅដោយអរហត្តមគ្គហើយ នឹងដល់ប្រាំងសង្សារ គឺនិព្វាន ដូចគោដែលកំពុងហែលកាត់ក្រសែទន្លេគង្គា ដល់នូវត្រើយ ដូច្នោះ ។ ភិក្ខុទាំង ២ រូបនេះ គឺធម្មានុសារី សទ្ធានុសារី ជាអ្នកដល់ព្រមដោយមគ្គខាងដើម ។ បទថា **ជានតា** គឺព្រះពុទ្ធទ្រង់ដឹងនូវធម៌ទាំងពួង ។ បទថា **ឧប្បកាសិតោ** ប្រែថា ពោលទុកល្អហើយ ។ បទថា **វិវដំ** ប្រែថា បើកហើយ ។ បទថា **អមតទ្វារំ** បានដល់ អរិយមគ្គ ។ បទថា **និព្វាន-បត្តិយា** គឺបើកដើម្បីប្រយោជន៍ដល់និព្វាននោះ ។ បទថា **វិនឡីតកំ** គឺធ្វើមានះដូចដើមបបុសឲ្យអស់ទៅ ។ បទថា **ខេមំ បត្ថេថ** សេចក្ដីថា ពួកអ្នកជាបុគ្គលប្រាថ្នាអរហត្ត គឺជាអ្នកត្រូវការឲ្យអរហត្តកើតឡើង ដោយកត្តុ-កម្យតាឆន្ទៈ ។ បាលីថា **បត្តត្ថ** ដូច្នេះក៏មាន អធិប្បាយថា ពួកអ្នកបានព្រះសាស្ដាបែបនេះ ឈ្មោះថា សម្រេចហើយដូចគ្នា ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ហើយ ហើយព្រះមានព្រះភាគ ក៏ទ្រង់បញ្ចប់ការសម្ដែងធម៌តាមអនុសន្ធិ ដោយប្រការដូច្នេះ ។

ចូឡគោបាលសូត្រ ចប់

សូត្រទី ៤ ចប់

# សុត្តន្តបិដក

## ចូឡសច្ចកសូត្រទី ៥

[ ៣២ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា ក្នុងមហាវ័ន ទៀបក្រុងវេសាលី ។ សម័យនោះឯង និគន្ថបុត្រ ឈ្មោះ សច្ចកៈ នៅក្នុងក្រុងវេសាលី ជាអ្នកពោលនូវតិរច្ឆានកថា ពោលថា ខ្លួនជាអ្នកប្រាជ្ញ មហាជនសន្មតថា ជាអ្នកមានលទ្ធិល្អ ។ សច្ចកនិគន្ថបុត្រនោះ តែងពោលវាចានាកណ្តាលបរិស័ទ ក្នុងក្រុងវេសាលីយ៉ាងនេះថា បុគ្គលណាដែលអាត្មាអញ លើកឡើងនូវទោស ដោយសម្តីហើយ មិនកក្រើក មិនរំភើប មិនញាប់ញ័រ ទាំងញើសក៏មិនហូរចេញអំពីក្លៀក របស់បុគ្គលណា អាត្មាអញមិនឃើញនូវបុគ្គលនោះ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ជាអ្នកមានពួក មានគណៈ ជាអាចារ្យនៃគណៈ ឬពុំនោះសោត បានប្តេជ្ញាខ្លួនថាជាអរហន្តសម្មាសម្ពុទ្ធទេ ឯអាត្មាអញ បើលើកឡើងនូវទោសដោយពាក្យសម្តី ចំពោះទៅលើបង្គោល ដែលជារបស់គ្មានចេតនាសោះ ឯបង្គោលនោះ លុះអាត្មាអញលើកឡើង នូវទោសដោយពាក្យសម្តីហើយ គប្បីកក្រើករំភើបញាប់ញ័រ ចាំបាច់ពោលទៅថ្វី ដល់មនុស្សជាតផងគ្នា ។

[ ៣៣ ] លំដាប់នោះឯង ព្រះអស្សជិមានអាយុ ស្លៀកស្បង់ ទ្រង់នូវបាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅក្នុងក្រុងវេសាលី ដើម្បីបិណ្ឌបាត ។ សច្ចកនិគន្ថបុត្រ កំពុងដើរសសៀរៗ ទៅ ដើម្បីសម្រាកស្មង ក្នុងក្រុងវេសាលី ក៏បានឃើញព្រះអស្សជិមានអាយុ កំពុងនិមន្តទៅអំពីចម្ងាយ

លុះឃើញហើយ ក៏ចូលសំដៅទៅរកព្រះអស្សជិមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះអស្សជិមានអាយុ លុះបញ្ចប់ពាក្យដែលគួរឲ្យកើតសេចក្តីរីករាយ និងពាក្យដែលគួររឭកហើយ ក៏ឋិតនៅក្នុងទីដ៏សមគួរ ។ លុះសច្ចកនិគន្ថបុត្រ ឋិតនៅក្នុងទីដ៏សមគួរហើយ ទើបពោលពាក្យនេះ នឹងព្រះអស្សជិមានអាយុថា បពិត្រព្រះអស្សជិ ដ៏ចម្រើន ព្រះសមណគោតម តែងទូន្មាននូវសាវកទាំងឡាយដូចម្តេចខ្លះ មួយទៀត ពាក្យប្រៀនប្រដៅរបស់ព្រះសមណគោតម តែងប្រព្រឹត្តទៅច្រើន ក្នុងពួកសាវកទាំងឡាយ មានចំណែកដូចម្តេច ។ ព្រះអស្សជិតបថា ម្នាលអគ្គិវេស្សនៈ ព្រះមានព្រះភាគ ទ្រង់ទូន្មាននូវពួកសាវកយ៉ាងនេះ មួយទៀត ពាក្យប្រៀនប្រដៅតែងប្រព្រឹត្តទៅច្រើន ក្នុងពួកសាវក មានចំណែកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង វេទនាមិនទៀង សញ្ញាមិនទៀង សង្ខារទាំងឡាយមិនទៀង វិញ្ញាណមិនទៀង ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជាខ្លួន វេទនាមិនមែនជាខ្លួន សញ្ញាមិនមែនជាខ្លួន សង្ខារទាំងឡាយមិនមែនជាខ្លួន វិញ្ញាណមិនមែនជាខ្លួន សង្ខារទាំងពួងមិនមែនជាខ្លួន ធម៌ទាំងពួងមិនមែនជាខ្លួន ម្នាលអគ្គិវេស្សនៈ ព្រះមានព្រះភាគ ទ្រង់ទូន្មាននូវសាវកទាំងឡាយ យ៉ាងនេះឯង មួយទៀត ពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ តែងប្រព្រឹត្តទៅច្រើន ក្នុងពួកសាវក មានចំណែកយ៉ាងនេះ ។ បពិត្រព្រះអស្សជិដ៏ចម្រើន យើងទាំងឡាយណា បានស្តាប់ព្រះសមណគោតម មានវាទៈយ៉ាងនេះ យើងទាំងឡាយនោះ ឈ្មោះថា បានស្តាប់នូវវាទៈដែលកម្របានស្តាប់ ធ្វើម្តេច

យើងទាំងឡាយ នឹងទៅជួបព្រះសមណគោតមដ៏ចម្រើននោះបានម្ដងហ្ន៎ ធ្វើម្ដេចហ្ន៎ នឹងមានការចរចាអ្វីនីមួយទៅអេះ ធ្វើម្ដេចយើងទាំងឡាយ នឹងដោះនូវសមណគោតមឲ្យផុតអំពីទិដ្ឋិដ៏លាមកនោះចេញបានហ្ន៎ ។

[ ៣៤ ] សម័យនោះឯង ព្រះបាទលិច្ឆវីចំនួន ៥០០ អង្គ កំពុងតែប្រជុំនៅក្នុងសណ្ឋាគារដ្ឋាន ដោយមានកិច្ចការអ្វីនីមួយ ។ លំដាប់នោះ សច្ចកនិគន្ថបុត្រ ក៏ចូលទៅរកព្រះបាទលិច្ឆវីទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលពាក្យនេះ នឹងព្រះបាទលិច្ឆវីទាំងនោះថា សូមព្រះបាទលិច្ឆវីទាំងឡាយដ៏ចម្រើន អញ្ជើញទៅ សូមព្រះបាទលិច្ឆវីទាំងឡាយដ៏ចម្រើន អញ្ជើញទៅ ខ្ញុំនឹងមានការចរចាជាមួយនឹងព្រះសមណគោតម ក្នុងថ្ងៃនេះ ថាបើព្រះសមណគោតមតតាំងនឹងខ្ញុំ ដូចជាភិក្ខុឈ្មោះអស្សជិ ជាសាវកដែលមានកេរ្តិ៍ឈ្មោះមួយដែរ បានតតាំងនឹងខ្ញុំរួចហើយ ខ្ញុំនឹងទាញមក ច្រានទៅ គ្រវាត់គ្រវែងនូវពាក្យសម្ដី ដោយពាក្យសម្ដីចំពោះព្រះសមណគោតម ដូចជាបុរសមានកម្លាំង ចាប់សត្វចៀមដែលមានរោមវែងឰដ៏រោមទាំងឡាយ ទាញមកច្រានទៅ គ្រវាត់គ្រវែងដូច្នោះឯង ពុំនោះសោត ខ្ញុំនឹងទាញមក ច្រានទៅគ្រវាត់គ្រវែងនូវពាក្យសម្ដីដោយពាក្យសម្ដី ចំពោះព្រះសមណគោតមនោះដូចជាបុរសមានកម្លាំង ជាអ្នកធ្វើការងារក្នុងផ្ទះលក់សុរា ដាក់ចុះនូវកន្ទេលសម្រាប់ដាក់ម្សៅ ក្នុងផ្ទះលក់សុរា ក្នុងអន្លង់ទឹកដែលជ្រៅ ចាប់ត្រង់ជាយទាញ មកច្រានទៅ គ្រវាត់គ្រវែងដូច្នោះឯង ពុំនោះ ខ្ញុំនឹងផ្ដាប់ចុះ ផ្ងារឡើងបោកបោះនូវពាក្យសម្ដី ដោយពាក្យសម្ដី ចំពោះព្រះសមណគោតម ដូចជា

បុរសមានកម្លាំង ជាអ្នកលេងសុរា ចាប់ថាសត្រង់កណ្តាប់មាត់ ផ្កាប់ចុះ ផ្ងារឡើង បោកបោះដូច្នោះឯង ពុំនោះសោត ខ្ញុំនឹងលេងនូវព្រះសមណគោតម ឲ្យមានទំនងដូចជាគេលេងនូវល្បែង លាងសម្បកធ្មៃ ឲ្យដូចគ្នានឹងដំរី ដែលមានអាយុ ៦០ ឆ្នាំ ចុះកាន់ស្រះបោក្ខរណីដ៏ជ្រៅ ហើយលេងនូវល្បែងលាងសម្បកធ្មៃដូច្នោះឯង សូមព្រះបាទលិច្ឆវីទាំងឡាយដ៏ចម្រើន អញ្ជើញទៅ សូមព្រះបាទលិច្ឆវីទាំងឡាយដ៏ចម្រើន អញ្ជើញទៅ ខ្ញុំនឹងមានការចរចា ជាមួយនឹងព្រះសមណគោតមក្នុងថ្ងៃនេះ ។ បណ្តាព្រះបាទលិច្ឆវីទាំងនោះ ព្រះបាទលិច្ឆវីពួកខ្លះ មានព្រះវាចាយ៉ាងនេះថា ព្រះសមណគោតមនឹងលើកឡើងនូវពាក្យសម្តីរបស់សច្ចកនិគន្ថបុត្រដូចម្តេចបាន មានតែសច្ចកនិគន្ថបុត្រទេ ទើបនឹងលើកឡើងនូវពាក្យសម្តីរបស់ព្រះសមណគោតមវិញបាន ។ ព្រះបាទលិច្ឆវីពួកខ្លះ មានព្រះវាចាយ៉ាងនេះថា សច្ចកនិគន្ថបុត្រនោះ នឹងលើកឡើងនូវពាក្យសម្តី របស់ព្រះមានព្រះភាគជាម្ចាស់ដូចម្តេចបាន មានតែព្រះមានព្រះភាគជាម្ចាស់ទេ ទើបលើកឡើងនូវពាក្យសម្តីរបស់សច្ចកនិគន្ថបុត្របាន ។ លំដាប់នោះ សច្ចកនិគន្ថបុត្រ មានព្រះបាទលិច្ឆវីចំនួនប្រាំរយអង្គ ចោមរោម ក៏ចូលសំដៅទៅត្រង់កូដាគារសាលា នាមហាវ័ន ។

[ ៣៥ ] សម័យនោះឯង ភិក្ខុច្រើនរូបកំពុងចង្ក្រមនៅទីវាល ។ គ្រានោះ សច្ចកនិគន្ថបុត្រ ចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលពាក្យនេះនឹងភិក្ខុទាំងនោះថា នែលោកទាំងឡាយដ៏ចម្រើន ឥឡូវនេះ ព្រះគោតមដ៏ចម្រើននោះ គង់នៅក្នុងទីណា យើងទាំងឡាយ ចង់ជួបនឹងព្រះ

គោតមដ៏ចម្រើននោះ ។ ភិក្ខុទាំងនោះតបថា ម្នាលអគ្គិវេស្សនៈ ព្រះមានព្រះភាគជាម្ចាស់អង្គនុ៎ះ ទ្រង់យាងចូលទៅកាន់មហាវ័ន គង់សម្រាកព្រះអង្គក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។ លំដាប់នោះ សច្ចកនិគន្ថបុត្រ ក៏ចូលទៅកាន់មហាវ័ន ជាមួយនឹងព្រះបាទលិច្ឆវី ជាបរិស័ទច្រើនអង្គ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ឯព្រះបាទលិច្ឆវីទាំងនោះ ពួកខ្លះក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ ពួកខ្លះក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ ពួកខ្លះ ក៏គង់ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ ក្នុងទីដ៏សមគួរ ។ ពួកខ្លះ ក៏សម្តែងនាម និងគោត្រ ( របស់ខ្លួន ) ឲ្យឮច្បាស់ក្នុងសំណាក់នៃព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ ពួកខ្លះ ក៏គង់នៅស្ងៀមក្នុងទីដ៏សមគួរ ។

[ ៣៦ ] សច្ចកនិគន្ថបុត្រ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងព្រះមានព្រះភាគថា បើព្រះគោតមដ៏ចម្រើន ធ្វើនូវឱកាសដើម្បីដោះស្រាយនូវបញ្ហារបស់ខ្ញុំបាន ខ្ញុំនឹងសួរនូវហេតុនីមួយ នឹងព្រះគោតមដ៏ចម្រើន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអគ្គិវេស្សនៈ បើអ្នកត្រូវការនឹងសួរ ចូរសួរមកចុះ ។ ព្រះគោតមដ៏ចម្រើន តែងទូន្មានពួកសាវ័ក ដូចម្តេចខ្លះ ពាក្យប្រៀនប្រដៅរបស់ព្រះគោតមដ៏ចម្រើន តែងប្រព្រឹត្តទៅច្រើនក្នុង

ពួកសាវក មានចំណែកដូចម្តេចខ្លះ ។ ម្នាលអគ្គិវេស្សនៈ តថាគតតែងទូន្មាន ពួកសាវកយ៉ាងនេះ ពាក្យប្រៀនប្រដៅរបស់តថាគត តែងប្រព្រឹត្តទៅច្រើន ក្នុងពួកសាវក មានចំណែកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង វេទនាមិនទៀង សញ្ញាមិនទៀង សង្ខារទាំងឡាយមិនទៀង វិញ្ញាណមិនទៀង ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជាខ្លួន វេទនាមិនមែនជាខ្លួន សញ្ញាមិនមែន ជាខ្លួន សង្ខារទាំងឡាយមិនមែនជាខ្លួន វិញ្ញាណមិនមែនជាខ្លួន សង្ខារទាំងពួង មិនមែនជាខ្លួន ធម៌ទាំងពួងក៏មិនមែនជាខ្លួនដែរ ម្នាលអគ្គិវេស្សនៈ តថាគត តែងទូន្មានពួកសាវកយ៉ាងនេះឯង ពាក្យប្រៀនប្រដៅរបស់តថាគត តែងប្រព្រឹត្តទៅច្រើនក្នុងពួកសាវក មានចំណែកយ៉ាងនេះ ។ បពិត្រព្រះគោតមដ៏ ចម្រើន ខ្ញុំព្រះអង្គសូមសម្តែងពាក្យឧបមាបន្តិច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ ថា អើអគ្គិវេស្សនៈ អ្នកឯងចូរសម្តែងពាក្យឧបមាទៅចុះ ។ បពិត្រព្រះគោតម ដ៏ចម្រើន ពីជគាម និងភូតគាមទាំងឡាយណានីមួយ ដល់នូវការចម្រើន លូតលាស់ ធំទូលាយ ពីជគាម និងភូតគាមទាំងអស់នោះ អាស្រ័យនូវផែន ដី តាំងនៅលើផែនដី ពីជគាម និងភូតគាមទាំងនុ៎ះ ក៏តែងតែដល់នូវការ ចម្រើន លូតលាស់ ធំទូលាយយ៉ាងនេះ មានឧបមាដូចម្តេចមិញ បពិត្រព្រះ គោតមដ៏ចម្រើន មួយទៀត ការងារទាំងឡាយ ដែលគួរធ្វើដោយកម្លាំងឯណា នីមួយ គេតែងធ្វើការងារទាំងអស់នោះ អាស្រ័យនូវផែនដី តាំងនៅលើផែន ដី ការងារដែលគួរធ្វើដោយកម្លាំងទាំងនោះ គេតែងធ្វើយ៉ាងនេះ មានឧបមា ដូចម្តេចមិញ បពិត្រព្រះគោតមដ៏ចម្រើន បុរសបុគ្គលនេះ មានរូបជាខ្លួន តាំង

នៅក្នុងរូប ទទួលនូវបុណ្យ ឬបាប បុរសបុគ្គលនេះ មានវេទនាជាខ្លួន តាំងនៅក្នុងវេទនា ទទួលនូវបុណ្យ ឬបាប បុរសបុគ្គលនេះ មានសញ្ញាជាខ្លួន តាំងនៅក្នុងសញ្ញា ទទួលនូវបុណ្យ ឬបាប បុរសបុគ្គលនេះ មានសង្ខារជាខ្លួន តាំងនៅក្នុងសង្ខារទាំងឡាយ ទទួលនូវបុណ្យ ឬបាប បុរសបុគ្គលនេះ មានវិញ្ញាណជាខ្លួន តាំងនៅក្នុងវិញ្ញាណ ទទួលនូវបុណ្យ ឬបាប មានឧបមេយ្យដូច្នោះឯង ។ ម្នាលអគ្គិវេស្សនៈ អ្នកពោលពាក្យយ៉ាងនេះថា រូបជាខ្លួនរបស់អញ វេទនាជាខ្លួនរបស់អញ សញ្ញាជាខ្លួនរបស់អញ សង្ខារទាំងឡាយជាខ្លួនរបស់អញ វិញ្ញាណជាខ្លួនរបស់អញ ដូច្នេះឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំឯងពោលយ៉ាងនេះថា រូបជាខ្លួនរបស់អញ វេទនាជាខ្លួនរបស់អញ សញ្ញាជាខ្លួនរបស់អញ សង្ខារទាំងឡាយជាខ្លួនរបស់អញ វិញ្ញាណជាខ្លួនរបស់អញ ទាំងប្រជុំជនជាច្រើននេះ គេក៏ថាដូច្នេះដែរ ។ នែអគ្គិវេស្សនៈ ឯប្រជុំជនជាច្រើនរបស់អ្នក នឹងធ្វើជាសម្អាងម្តេចបាន ម្នាលអគ្គិវេស្សនៈ អញ្ជើញអ្នកដោះស្រាយតែពាក្យសម្តីរបស់ខ្លួនចុះ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំនៅតែពោលយ៉ាងនេះថា រូបជាខ្លួនរបស់អញ វេទនាជាខ្លួនរបស់អញ សញ្ញាជាខ្លួនរបស់អញ សង្ខារទាំងឡាយជាខ្លួនរបស់អញ វិញ្ញាណជាខ្លួនរបស់អញ ។

[ ៣៧ ] ម្នាលអគ្គិវេស្សនៈ បើដូច្នោះ តថាគតនឹងត្រឡប់សួរទៅអ្នកក្នុងប្រស្នានេះវិញ ប្រស្នាគាប់ចិត្តអ្នកយ៉ាងណា អ្នកត្រូវដោះស្រាយនូវប្រស្នានោះ យ៉ាងនោះចុះ ។ នែអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះដូចម្តេច ព្រះរាជា ជាខត្តិយៈ ដែលបានមុទ្ធាភិសេកហើយ ដូចយ៉ាងព្រះរាជាបសេនទិ-

កោសល ពុំនោះសោត ដូចព្រះរាជាអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ មានអំណាចក្នុងដែនជារបស់ខ្លួន គប្បីប្រព្រឹត្តដើម្បីសម្លាប់នូវបុគ្គលដែលគួរសម្លាប់ ដើម្បីរឹបជាន់នូវបុគ្គលដែលគួររឹបជាន់ ឬដើម្បីនិរទេសនូវបុគ្គលដែលគួរនិរទេសបានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះរាជាជាខត្តិយៈ ដែលបានមុទ្ធាភិសេកហើយ ដូចយ៉ាងព្រះរាជាបសេនទិកោសល ពុំនោះសោត ដូចជាព្រះរាជាអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ មានអំណាចក្នុងដែនជារបស់ខ្លួន គប្បីប្រព្រឹត្តដើម្បីសម្លាប់នូវបុគ្គលដែលគួរសម្លាប់ ដើម្បីរឹបជាន់នូវបុគ្គលដែលគួររឹបជាន់ ឬដើម្បីនិរទេសនូវបុគ្គលដែលគួរនិរទេសបាន បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថាសូម្បីក្សត្រិយ៍ទាំងអម្បាលនេះ ជាពួក ជាគណៈ ដូចពួកក្សត្រិយ៍ដែលនៅក្នុងដែនវជ្ជី និងពួកក្សត្រិយ៍ដែលនៅក្នុងដែនមល្លៈ មានអំណាចក្នុងដែនជារបស់ខ្លួន តែងប្រព្រឹត្តដើម្បីសម្លាប់នូវបុគ្គលដែលគួរសម្លាប់ ដើម្បីរឹបជាន់នូវបុគ្គលដែលគួររឹបជាន់ ឬដើម្បីនិរទេសនូវបុគ្គល ដែលគួរនិរទេសបាន និងបាច់ពោលថ្វីដល់ទៅអំណាចរបស់ព្រះរាជា ជាខត្តិយៈ ដែលបានមុទ្ធាភិសេកហើយ ដូចយ៉ាងព្រះរាជាបសេនទិកោសល ពុំនោះសោត ដូចជាព្រះរាជាអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈក្នុងដែនមគធៈ បពិត្រព្រះគោតមដ៏ចម្រើន អំណាចគប្បីប្រព្រឹត្តទៅទាំងគួរនឹងប្រព្រឹត្តទៅ ។ នែអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះដូចម្តេច អ្នកពោលនូវរូបណាយ៉ាងនេះថា រូបជាខ្លួនរបស់អញ អំណាចរបស់អ្នកប្រព្រឹត្តទៅក្នុងរូបនោះថា រូបរបស់អញ ចូរយ៉ាងនេះទៅ រូបរបស់អញ ចូរកុំ

មានយ៉ាងនេះឡើយបានឬទេ ។ កាលបើព្រះសាស្តា ទ្រង់ត្រាស់យ៉ាងនេះហើយ សច្ចកនិគន្ថបុត្រក៏នៅស្ងៀម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះនឹងសច្ចកនិគន្ថបុត្រ ជាគម្រប់ពីរដងថា នែអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច អ្នកពោលនូវរូបណា យ៉ាងនេះថា រូបជាខ្លួនរបស់អញ អំណាចរបស់អ្នកប្រព្រឹត្តទៅក្នុងរូបនោះថា រូបរបស់អញចូរយ៉ាងនេះទៅ រូបរបស់អញកុំយ៉ាងនេះឡើយបានឬទេ ។ កាលព្រះសាស្តាទ្រង់ត្រាស់យ៉ាងនេះហើយ សច្ចកនិគន្ថបុត្រក៏នៅស្ងៀមជាគម្រប់ពីរដង ។ លំដាប់នោះ ឯងព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះនឹងសច្ចកនិគន្ថបុត្រថា នែអគ្គិវេស្សនៈ អ្នកចូរដោះស្រាយនូវបញ្ហាក្នុងកាលឥឡូវនេះទៅ កាលឥឡូវនេះ មិនមែនជាកាលអ្នកស្ងៀមទេ នែអគ្គិវេស្សនៈ អ្នកណាមួយដែលតថាគតសួរនូវបញ្ហា ប្រកបដោយធម៌ជាគម្រប់ ៣ ដងហើយ នៅតែមិនដោះស្រាយ ក្បាលរបស់អ្នកនោះនឹងបែកជា ៧ ភាគ ក្នុងទីនុ៎ះពុំខាន ។ សម័យនោះឯង មានយក្សម្នាក់ឈ្មោះវជិរបាណីកាន់ដែក ដូចជាកែវវជិរ ដែលឆេះប្រាលរន្ទាល ភ្លឺសន្ធោសន្ធៅ មកសណ្ឋិតនៅឰដ៏អាកាស ជាខាងលើនៃសច្ចកនិគន្ថបុត្រ ពោលពាក្យដូច្នេះថា បើសច្ចកនិគន្ថបុត្រនេះ ដែលព្រះមានព្រះភាគ ទ្រង់សួរបញ្ហាប្រកបដោយធម៌ជាគម្រប់ ៣ ដងហើយ នៅតែមិនដោះស្រាយ អញនឹងបំបែកក្បាលរបស់សច្ចកនិគន្ថបុត្រនោះជា ៧ ភាគ ក្នុងទីនេះឯង ។ ព្រះមានព្រះភាគ និងសច្ចកនិគន្ថបុត្រ ក៏បានឃើញយក្សឈ្មោះវជិរបាណីនោះប្រាកដ ។ គ្រានោះឯង សច្ចកនិគន្ថបុត្រភ័យ តក់ស្លុត រន្ធត់ ព្រឺព្រួចរោម ក៏អាងព្រះ

មានព្រះភាគជាទីពឹង អាងព្រះមានព្រះភាគជាទីពួន អាងព្រះមានព្រះភាគជាទីកម្ចាត់បង់នូវភ័យ ក្រាបទូលសេចក្តីនេះ ចំពោះព្រះមានព្រះភាគថា សូមព្រះគោតមដ៏ចម្រើន សួរនូវបញ្ហានឹងខ្ញុំព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងដោះស្រាយឥឡូវនេះ ។

[ ៣៨ ] ម្នាលអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច អ្នកពោលនូវរូបណាយ៉ាងនេះថា រូបជាខ្លួនរបស់អញ អំណាចរបស់អ្នកប្រព្រឹត្តទៅក្នុងរូបនោះថា រូបរបស់អញចូរយ៉ាងនេះចុះ រូបរបស់អញចូរកុំយ៉ាងនេះឡើយបានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីនេះមិនបានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរដោះស្រាយខ្លួនឯងចុះ ព្រោះពាក្យខាងចុងរបស់អ្នកមិនជាប់តគ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក មិនជាប់តគ្នានឹងពាក្យខាងចុង នែអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច អ្នកពោលនូវវេទនាណា យ៉ាងនេះថា វេទនាជាខ្លួនរបស់អញ អំណាចរបស់អ្នកប្រព្រឹត្តទៅក្នុងវេទនានោះថា វេទនារបស់អញចូរយ៉ាងនេះទៅ វេទនារបស់អញចូរកុំយ៉ាងនេះឡើយបានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីនេះមិនបានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរដោះស្រាយចុះ ព្រោះពាក្យខាងចុងរបស់អ្នកមិនជាប់តគ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់តគ្នានឹងពាក្យខាងចុងដែរ នែអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច អ្នកពោល

នូវសញ្ញាណាយ៉ាងនេះថា សញ្ញាជាខ្លួនរបស់អញ អំណាចរបស់អ្នកប្រព្រឹត្ត ទៅក្នុងសញ្ញានោះថា សញ្ញារបស់អញ ចូរយ៉ាងនេះ សញ្ញារបស់អញ ចូរកុំ យ៉ាងនេះឡើយបានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនបានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុង ចិត្តរួចហើយ ចូរដោះស្រាយចុះ ព្រោះពាក្យខាងចុងរបស់អ្នកមិនជាប់តគ្នានឹង ពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់តគ្នានឹងពាក្យខាងចុង ដែរ នែអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច អ្នកពោលនូវសង្ខារ ណាយ៉ាងនេះថា សង្ខារទាំងឡាយជាខ្លួនរបស់អញ អំណាចរបស់អ្នកប្រព្រឹត្ត ទៅក្នុងសង្ខារទាំងនោះថា សង្ខារទាំងឡាយរបស់អញចូរយ៉ាងនេះទៅ សង្ខារ ទាំងឡាយរបស់អញចូរកុំយ៉ាងនេះឡើយបានឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនបានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិ-វេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរដោះស្រាយចុះ ព្រោះពាក្យខាង ចុងរបស់អ្នក មិនជាប់តគ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់តគ្នានឹងពាក្យខាងចុងដែរ នែអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុ នោះថាដូចម្តេច អ្នកពោលនូវវិញ្ញាណណាយ៉ាងនេះថា វិញ្ញាណជាខ្លួនរបស់ អញ អំណាចរបស់អ្នកប្រព្រឹត្តទៅក្នុងវិញ្ញាណនោះថា វិញ្ញាណរបស់អញចូរ យ៉ាងនេះទៅ វិញ្ញាណរបស់អញចូរកុំយ៉ាងនេះឡើយបានឬ ។ បពិត្រព្រះ គោតមដ៏ចម្រើន ហេតុនេះមិនបានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុង ចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរដោះស្រាយចុះ

ព្រោះពាក្យខាងចុងរបស់អ្នក មិនជាប់តគ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់តគ្នានឹងពាក្យខាងចុងដែរ នែអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច រូបទៀង ឬមិនទៀង ។ បពិត្រព្រះគោតមដ៏ចម្រើន រូបមិនទៀងទេ ។ របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះគោតមដ៏ចម្រើន របស់នោះជាទុក្ខ ។ ចុះរបស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនគួរឃើញយ៉ាងនុ៎ះទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច វេទនា... សញ្ញា... សង្ខារទាំងឡាយ... វិញ្ញាណទៀង ឬមិនទៀង។ បពិត្រព្រះគោតមដ៏ចម្រើន វិញ្ញាណមិនទៀងទេ ។ ចុះរបស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះគោតមដ៏ចម្រើន របស់នោះជាទុក្ខ ។ ចុះរបស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនគួរឃើញយ៉ាងនោះទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច បុគ្គលណាស្អិតជាប់នឹងសេចក្តីទុក្ខ ប្រកបនឹងសេចក្តីទុក្ខ លិចចុះទៅក្នុងសេចក្តីទុក្ខ ឃើញនូវសេចក្តីទុក្ខថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះហើយ បុគ្គលនោះគប្បីកំណត់ដឹងនូវសេចក្តីទុក្ខដោយខ្លួនឯងបាន ឬថា គប្បីធ្វើសេចក្តីទុក្ខឲ្យអស់ទៅបាន តើមានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន នឹងមានដូចម្តេច

បាន បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនមានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកសម្គាល់ហេតុនោះថាដូចម្តេច កាលបើមានហេតុយ៉ាងនេះ ក្រែងអ្នកជាបុគ្គលជាប់ស្អិតនឹងសេចក្តីទុក្ខ ប្រកបនឹងសេចក្តីទុក្ខ លិចចុះទៅក្នុងសេចក្តីទុក្ខហើយ ឃើញសេចក្តីទុក្ខថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះមែនឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ថ្វីក៏មិនមានដូច្នោះ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនុ៎ះយ៉ាងនេះឯង ។

[ ៣៩ ] ម្នាលអគ្គិវេស្សនៈ ដូចជាបុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ទៅស្វែងរកខ្លឹមឈើ ក៏កាន់យកនូវដឹងដ៏មុតចូលទៅកាន់ព្រៃ បុរសនោះឃើញដើមចេកធំក្នុងព្រៃនោះ មានដើមត្រង់សាច់ខ្ចី មិនទាន់កើតមានស្នូលស្នួង ហើយកាត់នូវដើមចេកនោះត្រង់គល់ លុះកាត់គល់រួចហើយ ក៏កាត់ចុង លុះកាត់ចុងរួចហើយ បកស្រទបចេញ កាលដែលបុរសនោះបកស្រទបចេញ ក៏មិនគប្បីបាន សូម្បីនូវស្រាយក្នុងដើមចេកនោះឡើយ នឹងបានខ្លឹមមកពីណា សេចក្តីនេះមានឧបមាយ៉ាងណាមិញ នែអគ្គិ-វេស្សនៈ អ្នកដែលតថាគតជជីកសួរដេញដោល ក៏ទៅជាមនុស្សសោះសូន្យទទេឥតខ្លឹមសារ ចាលចាញ់ក្នុងវាទៈរបស់ខ្លួន មានឧបមេយ្យដូចដើមចេកដូច្នោះឯង នែអគ្គិវេស្សនៈ មួយទៀត វាចានេះ អ្នកបានពោលហើយ នាកណ្តាលបរិស័ទក្រុងវេសាលីថា បុគ្គលណាដែលអាត្មាអញលើកឡើងនូវទោសដោយពាក្យសម្តីហើយ មិនកក្រើកមិនរំកើប មិនញាប់ញ័រ ទាំងញើសក៏មិនហូរចេញអំពីក្លៀករបស់បុគ្គលណា អាត្មាមិនបានឃើញនូវបុគ្គលនោះ

ទោះសមណៈក្តីព្រាហ្មណ៍ក្តី ដែលមានពួកមានគណៈ ជាអាចារ្យនៃគណៈ ឬក៏បានប្តេជ្ញាខ្លួនថា ជាអរហន្តសម្មាសម្ពុទ្ធទេ ឯអាត្មាបើគប្បីលើកឡើងនូវទោសដោយពាក្យសម្តី ចំពោះទៅលើបង្គោលដែលជារបស់គ្មានចេតនាសោះ បង្គោលនោះ លុះអាត្មាលើកឡើងនូវទោស ដោយពាក្យសម្តីហើយ ក៏គប្បីកក្រើករំភើបញាប់ញ័រមិនខាន និយាយទៅថ្វីដល់មនុស្សជាតិផងគ្នា ម្នាលអគ្គិវេស្សនៈ ចំណែកអ្នកមានតំណក់ញើសខ្លះ ហូរចេញអំពីថ្ងាស ទម្លុះសំពត់បង់ក ហើយធ្លាក់ទៅដក់លើផែនដីហើយ នៃអគ្គិវេស្សនៈ ឯតថាគត ឥឡូវនេះ ឥតមានញើសក្នុងកាយទេ ។ ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគ ទ្រង់បើកនូវព្រះកាយ ដែលមានសម្បុរដូចជាពណ៌នៃមាស ក្នុងបរិស័ទនោះ ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សច្ចកនិគន្ថបុត្រក៏អង្គុយស្ងៀម អៀនអន់ ដាក់កសំយុងមុខចុះក្រោម ជ្រប់ស្រងូត មិនក្លៀវក្លា ។

[ ៤០ ] គ្រានោះឯង លិច្ឆវិបុត្រ ឈ្មោះទុម្មុខៈដឹងច្បាស់ថា សច្ចកនិគន្ថបុត្រស្ងៀម អៀនអន់ ដាក់កសំយុងមុខចុះក្រោម ជ្រប់ស្រងូត មិនក្លៀវក្លាហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសម្តែងពាក្យឧបមាបន្តិច ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលទុម្មុខៈ ចូរអ្នកសម្តែងពាក្យឧបមានោះទៅមើល ។ បពិត្រព្រះអង្គដ៏ចម្រើន ដូចជាស្រះបោក្ខរណីនៅជិតស្រុក ឬនិគម មានក្តាមនៅក្នុងស្រះបោក្ខរណីនោះ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ក្មេងប្រុស ឬក្មេងស្រីទាំងឡាយជាច្រើនចេញអំពីស្រុក ឬនិគមនោះ ចូលទៅកាន់ស្រះបោក្ខរណី លុះចូលទៅ

ដល់ហើយ ក៏ចុះទៅកាន់ស្រះបោក្ខរណីនោះ ហើយចាប់ក្ដាមនោះស្រង់អំពីទឹកមកដាក់នៅលើគោក បពិត្រព្រះអង្គដ៏ចម្រើន ក្ដាមនោះហាចេញនូវតង្កៀបណាៗ ក្មេងប្រុស ឬក្មេងស្រីទាំងនោះ ក៏កាច់បំបាក់បំបែកនូវតង្កៀបនោះៗ ដោយកំណាត់ឈើក្ដី ដោយអំបែងក្ដី បពិត្រព្រះអង្គដ៏ចម្រើន កាលបើយ៉ាងនេះហើយ ក្ដាមនោះដែលមានតង្កៀបទាំងអស់ គេកាច់បំបាក់បំបែកអស់ហើយ មិនគួរដើម្បីនឹងចុះទៅកាន់ស្រះបោក្ខរណីនោះទៀតបាន ដូចកាលមុនទេ មានឧបមាដូចម្ដេចមិញ បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីចម្រូងចម្រាស គឺទិដ្ឋិ ពុតត្បុត គឺទិដ្ឋិ និងសេចក្ដីញាប់ញ័រ គឺទិដ្ឋិណានីមួយរបស់សច្ចកនិគន្ថបុត្រ ក៏សេចក្ដីចម្រូងចម្រាសជាដើមនោះ ព្រះមានព្រះភាគ ទ្រង់កាច់បំបាក់បំបែកហើយ បពិត្រព្រះអង្គដ៏ចម្រើន កាលឥឡូវនេះ សច្ចកនិគន្ថបុត្រមិនគួរនឹងមានសេចក្ដីប្រាថ្នាថា នឹងលើកឡើងនូវវាទៈ ចូលទៅរកព្រះមានព្រះភាគទៀតទេ មានឧបមេយ្យដូច្នោះឯង ។ កាលបើទុម្មុខលិច្ឆវិបុត្រនិយាយយ៉ាងនេះហើយ សច្ចកនិគន្ថបុត្រ ក៏ពោលពាក្យនេះ ទៅនឹងទុម្មុខលិច្ឆវិបុត្រថា នែទុម្មុខៈ អ្នកចូរឈប់សិន នែទុម្មុខៈ អ្នកចូរឈប់សិន នែទុម្មុខៈ អ្នកជាបុគ្គលមានមាត់រឹង យើងមិនមែនប្រឹក្សាជាមួយនឹងអ្នកទេ ក្នុងទីនេះ យើងនឹងប្រឹក្សាជាមួយព្រះគោតមដ៏ចម្រើនថា បពិត្រព្រះគោតមដ៏ចម្រើន វាចានេះ ជាវាចារបស់យើងទាំងឡាយផង របស់សមណព្រាហ្មណ៍ដ៏ច្រើនដទៃផង ចូរស្ទេះទុកចុះ ការបញ្ចេញនូវវាចានេះ ក៏ហាក់ដូចជាគ្រាន់តែនិយាយទៅទេ ។

[ ៤១ ] សច្ចកនិគន្ថបុត្រ ក្រាបបង្គំទូលសួរថា សាវករបស់ព្រះគោតម ដ៏ចម្រើន ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ប្រព្រឹត្តតាមដំបូន្មាន ប្រព្រឹត្តកន្លងសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ ដល់នូវសេចក្តីក្លៀវក្លា មិនជឿអ្នកដទៃ ក្នុងសាសនានៃព្រះសាស្តាដោយហេតុមានប៉ុន្មានយ៉ាង ។ ម្នាលអគ្គិវេស្សនៈ រូបណានីមួយជាអតីត អនាគត និងបច្ចុប្បន្ន ជារូបខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី មួយទៀត រូបណានៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី រូបទាំងអស់នោះបានឈ្មោះជារូប សាវករបស់តថាគតក្នុងសាសនានេះ តែងឃើញនូវរូបនុ៎ះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាណានីមួយ ។បេ។ សញ្ញាណានីមួយ ... សង្ខារទាំងឡាយណានីមួយ ... វិញ្ញាណណានីមួយជាអតីត អនាគត និងបច្ចុប្បន្ន ជាវិញ្ញាណខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី មួយទៀតវិញ្ញាណណាដែលមាននៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ បានឈ្មោះថា វិញ្ញាណ សាវករបស់តថាគត តែងឃើញនូវវិញ្ញាណនុ៎ះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ នែអគ្គិវេស្សនៈ សាវករបស់តថាគត ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ប្រព្រឹត្តតាមដំបូន្មាន ប្រព្រឹត្តកន្លងសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ ហើយដល់នូវសេចក្តីក្លៀវក្លា មិនជឿបុគ្គលដទៃក្នុងសាសនានៃព្រះសាស្តា ដោយហេតុ

មានប្រមាណប៉ុណ្ណេះឯង ។

[ ៤២ ] សច្ចកនិគន្ថបុត្រក្រាបទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ភិក្ខុដែលឈ្មោះថាអរហន្តខីណាស្រព មានព្រហ្មចារ្យនៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានគ្រឿងធ្ងន់ដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានសំយោជនៈក្នុងភពអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ ដោយហេតុមានប្រមាណប៉ុន្មាន ។ ម្នាលអគ្គិវេស្សនៈ រូបណានីមួយជាអតីត អនាគត និងបច្ចុប្បន្ន ជារូបខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី មួយទៀត រូបណាមាននៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី រូបទាំងអស់នោះបានឈ្មោះថារូប ភិក្ខុក្នុងសាសនានេះមានចិត្តផុតស្រឡះហើយ ដោយមិនមានសេចក្តីប្រកាន់មាំ ព្រោះឃើញនូវរូបនុ៎ះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាណានីមួយ ... សញ្ញាណានីមួយ ... សង្ខារទាំងឡាយណានីមួយ ... វិញ្ញាណណានីមួយ ជាអតីត អនាគត និងបច្ចុប្បន្ន ជាវិញ្ញាណខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី មួយទៀត វិញ្ញាណណាមាននៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះបានឈ្មោះថា វិញ្ញាណ ភិក្ខុមានចិត្តផុតស្រឡះហើយ ដោយមិនមានសេចក្តីប្រកាន់មាំ ព្រោះឃើញនូវវិញ្ញាណនុ៎ះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ ម្នាលអគ្គិវេស្សនៈ

ភិក្ខុដែលឈ្មោះថាអរហន្តខីណាស្រព មានព្រហ្មចារ្យនៅរួចហើយ មានសោ-ឡសកិច្ចធ្វើរួចហើយ មានគ្រឿងទម្ងន់ដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានសំយោជនៈក្នុងភពអស់ហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ ម្នាលអគ្គិវេស្សនៈ លុះភិក្ខុនោះមានចិត្តផុតស្រឡះយ៉ាងនេះហើយ តែងប្រកបដោយអនុត្តរិយៈទាំង ៣ គឺទស្សនានុត្តរិយៈ ១ បដិបទានុត្តរិយៈ ១ វិមុត្តានុត្តរិយៈ ១ ។ ម្នាលអគ្គិវេស្សនៈ ភិក្ខុមានចិត្តផុតស្រឡះយ៉ាងនេះហើយ តែងធ្វើសក្ការៈគោរពរាប់អានបូជា នូវតថាគតដោយគិតថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹងនូវសច្ចធម៌ទាំង ៤ ហើយ ទ្រង់សម្តែងធម៌ដើម្បីញុំាងពួកជនដទៃឲ្យត្រាស់ដឹងផង ព្រះមានព្រះភាគអង្គនោះ ព្រះអង្គទូន្មាននូវឥន្រ្ទិយហើយ ទ្រង់សម្តែងធម៌ដើម្បីញុំាងសត្វឲ្យទូន្មាននូវឥន្ទ្រិយ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គបានរម្ងាប់បង់នូវកិលេសហើយ ទ្រង់សម្តែងធម៌ដើម្បីញុំាងសត្វឲ្យរម្ងាប់បង់នូវកិលេស ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្លង ( នូវអន្លង់ទាំង ៤ ) ហើយ ទ្រង់សម្តែងធម៌ ដើម្បីញុំាងសត្វឲ្យឆ្លងនូវអន្លង់ទាំង ៤ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គរម្លត់នូវកិលេសហើយ ទ្រង់សម្តែងធម៌ដើម្បីញុំាងសត្វឲ្យរម្លត់កិលេស ។

[ ៤៣ ] កាលដែលព្រះមានព្រះភាគ ទ្រង់សម្តែងយ៉ាងនេះហើយ សច្ច-កនិគន្ថបុត្រ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកកម្ចាត់បង់នូវគុណ ខ្ញុំព្រះអង្គជាអ្នកឃ្នើសឃ្នងដោយ

វាចា ព្រោះហេតុថាខ្ញុំព្រះអង្គបានសម្គាល់នូវព្រះគោតមដ៏ចម្រើន ថាជាបុគ្គល គួរសង្កត់សង្កិននូវវាទៈដោយវាទៈបាន បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីចម្រើនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិននូវដំរីចុះប្រេង សេចក្តីចម្រើនមិនគួរមានដល់បុរស ព្រោះសង្កត់សង្កិននូវព្រះគោតមដ៏ចម្រើនទេ បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីចម្រើនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិនឬលត់នូវគំនរភ្លើងដែលកំពុងឆេះ សេចក្តីចម្រើនមិនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិននូវព្រះគោតមដ៏ចម្រើនទេ បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីចម្រើនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិននូវអាសិរពិសដែលមានពិសដ៏ពន្លឹក សេចក្តីចម្រើនមិនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិននូវព្រះគោតមដ៏ចម្រើនទេ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកកម្ចាត់បង់នូវគុណ ខ្ញុំព្រះអង្គជាអ្នកឃ្នើសឃ្នងដោយវាចា ព្រោះហេតុថា ខ្ញុំព្រះអង្គបានសម្គាល់នូវព្រះគោតមដ៏ចម្រើន ថាជាបុគ្គលគួរសង្កត់សង្កិននូវវាទៈដោយវាទៈបាន សូមព្រះគោតមដ៏ចម្រើន ទទួលភត្តរបស់ខ្ញុំដើម្បីឆាន់ក្នុងថ្ងៃស្អែកជាមួយនឹងភិក្ខុសង្ឃ ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ សច្ចកនិគន្ថបុត្រ បានដឹងច្បាស់នូវកិរិយាទទួលនិមន្តន៍របស់ព្រះមានព្រះភាគហើយ ក៏និយាយនឹងព្រះបាទលិច្ឆវីទាំងនោះថា ព្រះបាទលិច្ឆវីទាំងឡាយដ៏ចម្រើន ចូរស្តាប់ពាក្យរបស់អាត្មា ព្រះសមណគោតម អាត្មានិមន្តហើយ ដើម្បីឆាន់ក្នុងថ្ងៃស្អែកជាមួយនឹងភិក្ខុសង្ឃ បពិត្រទាំងឡាយគួរយកវត្ថុណាមកឲ្យអាត្មា មួយទៀត វត្ថុណា ដែលជារបស់សមគួរដល់ព្រះ

សមណគោតមនោះ បពិត្រទាំងឡាយគួរដឹងវត្ថុនោះៗ ។ លុះកន្លងរាត្រីនោះទៅហើយ ទើបព្រះបាទលិច្ឆវីទាំងនោះ ក៏នាំនូវភត្តាភិហារ ប្រមាណ ៥០០ សម្រាប់ដល់សច្ចកនិគន្ថបុត្រ ។ លំដាប់នោះ សច្ចកនិគន្ថបុត្រ បានតាក់តែងនូវខាទនីយៈ និងភោជនីយៈដ៏ឧត្តម ក្នុងអារាមរបស់ខ្លួនហើយ ចាត់បម្រើឲ្យទៅក្រាបទូលភត្តកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន កាលគួរហើយ ភត្តក៏សម្រេចហើយ ។

[ ៤៤ ] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់ដោយបាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់អារាមរបស់សច្ចកនិគន្ថបុត្រ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ ជាមួយនឹងភិក្ខុសង្ឃ ។ គ្រានោះឯង សច្ចកនិគន្ថបុត្រ ក៏អង្គាសព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយៈ និងភោជនីយាហារដ៏ឧត្តមដោយដៃរបស់ខ្លួន គ្រាតែភិក្ខុសង្ឃហាមឃាត់ ។ គ្រានោះ សច្ចកនិគន្ថ-បុត្រកំណត់ដឹងថា ព្រះមានព្រះភាគ ទ្រង់ឆាន់រួចហើយ ដាក់ព្រះហស្តចុះចាកបាត្រហើយ ក៏កាន់យកនូវអាសនៈទាបមួយ អង្គុយក្នុងទីដ៏សមគួរ ។ លុះសច្ចកនិគន្ថបុត្រ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន បុណ្យណាដែលមានក្នុងទាននេះផង បុណ្យដទៃអំពីទាននេះផង ក៏បុណ្យនោះឯង ចូរប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់ទាយកទាំងឡាយ ។ ព្រះសម្ពុទ្ធបរមគ្រូ ទ្រង់មានព្រះពុទ្ធដីកាថា ម្នាលអគ្គិវេស្សនៈ បុណ្យណាមួយដែលអាស្រ័យនូវទក្ខិណេយ្យបុគ្គល ប្រាកដដូច

អ្នក ដែលជាបុគ្គលមិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ បុណ្យនោះនឹងកើតមានដល់ទាយកទាំងឡាយ នៃអគ្គិវេស្សនៈ មួយទៀត បុណ្យណាដែលអាស្រ័យនូវទក្ខិណេយ្យបុគ្គល ប្រាកដដូចជាតថាគតជាបុគ្គលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈហើយ បុណ្យនោះនឹងកើតមានដល់អ្នក ។

## ចូឡសច្ចកសូត្រទី ៥ ចប់

# អដ្ឋកថា

## ចូឡសច្ចកសូត្រទី ៥

[ ៣២ ] ចូឡសច្ចកសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម បណ្ដាបទទាំងនោះ បទថា **មហាវនេ កូដាគារសាលាយំ** សេចក្ដីថា ព្រៃធំកើតឯង មិនបានដាំ ឈ្មោះថា មហាវន ។ ឯព្រៃមហាវនជិតក្រុងកបិលភស្តុ ជាប់គ្នាជាមួយនឹងព្រៃហិមពាន្ត មិនមានកំណត់ ទល់គ្នានឹងមហាសមុទ្រ ។ ព្រៃនេះ មិនមែនដូច្នោះឡើយ ឈ្មោះថា ព្រៃមហាវន ព្រោះអត្ថថា ជាព្រៃធំមានកំណត់ ។ ឯកូដាគារសាលា កាលសាងអារាមស្រេចហើយ ទើបធ្វើកូដាគារទុកខាងក្នុង ប្រក់ជុំបូលដោយគ្រឿងប្រក់ មានសណ្ឋានដូចសត្វហង្ស និងចាប ប្រក់ហើយ គប្បីជ្រាបថា ជាព្រះគន្ធកុដិរបស់ព្រះមានព្រះភាគ ដល់ព្រមដោយអាការទាំងពួង ។

បទថា **សច្ចកោ និគន្ថបុត្តោ** សេចក្ដីថា បានឮថា ក្នុងកាលមុន បុរសនិគ្រន្ថម្នាក់ និងស្ត្រីនិគ្រន្ថម្នាក់ រៀនបានវាទៈម្នាក់ ៥០០ ហើយគិតថា អញនឹងលើកវាទៈ ដូច្នេះ កាលត្រាច់ទៅក្នុងជម្ពូទ្វីប មកជួបគ្នាក្នុងក្រុងវេសាលី ។ ពួកស្ដេចលិច្ឆវីឃើញហើយ ទើបសួរថា លោកជានរណា លោកជានរណា ដូច្នេះ ។ បុរសនិគ្រន្ថទូលថា ទូលព្រះបង្គំត្រាច់ទៅក្នុងជម្ពូទ្វីប ដោយគិតថា នឹងលើកវាទៈ ដូច្នេះ ។ ស្រីនិគ្រន្ថក៏បានក្រាបទូលយ៉ាងនោះ ។ ស្ដេចលិច្ឆវីត្រាស់ថា បើដូច្នោះ សូមលោកលើកវាទៈដល់គ្នានឹងគ្នាក្នុងទីនេះចុះ ។ ទើបស្រីនិគ្រន្ថសួរវាទៈ ៥០០ ដែលខ្លួនរៀនហើយ ។ បុរសនិគ្រន្ថ

បានឆ្លើយហើយ កាលបុរសនិគ្រន្ថសួរ ស្រីនិគ្រន្ថក៏ឆ្លើយបានទាំងអស់ ។ ជនទាំង ២ មិនមានអ្នកណាឈ្នះ អ្នកណាចាញ់ បានជាអ្នកស្មើគ្នា ។ ស្តេចលិច្ឆវីត្រាស់ថា លោកទាំង ២ នាក់ស្មើគ្នា នឹងត្រាច់ទៅធ្វើអ្វី ចូរនៅក្នុងទីនេះចុះ ព្រះរាជទានផ្ទះ ទ្រង់ឲ្យនូវសួយ ។ ព្រោះការនៅរួមគ្នានៃជនទាំង ២ នាក់នោះ ក៏កើតបានកូនស្រី ៤ នាក់ គឺនាងសច្ចា ១ លោលា ១ បដាចារា ១ សិលាវតកា ១ ធីតាទាំងនោះ ក៏បានជាបណ្ឌិតទាំងអស់គ្នា បានរៀនវាទៈម្នាក់ ៥០០ ដែលមាតាបិតារៀនមកហើយ ។ ស្រីទាំងនោះចម្រើនវ័យ បានពោលនឹងមាតាបិតាថា អ្នកម៉ែ ឈ្មោះថា កុលទារិការបស់យើង មិនត្រូវឲ្យប្រាក់ និងមាសជាដើម ហើយបញ្ជូនទៅកាន់ផ្ទះនៃត្រកូល ឯបុគ្គលណាគ្រប់គ្រងផ្ទះ ដែលអាចញាំញីវាទៈរបស់ស្រីទាំងនោះបាន ស្រីទាំងនោះ នឹងជាបាទបរិចារិការបស់បុគ្គលនោះ បើបុគ្គលណាជាអ្នកបួស អាចញាំញីវាទៈនៃស្រីទាំងនោះបាន ស្រីទាំងនោះក៏នឹងបានបួសក្នុងសម្នាក់របស់បុគ្គលនោះ ពុកម៉ែ នឹងធ្វើដូចម្តេច ដូច្នេះ ។ ស្រី ៤ នាក់ កាន់ភេទជាអ្នកបួស ដោយគិតថា ពួកយើងនឹងធ្វើយ៉ាងនេះឯង គិតថា ឈ្មោះថា ជម្ពូទ្វីបនេះប្រាកដដោយដើមព្រីង ដូច្នេះ ទើបកាន់មែកព្រីង ត្រាច់ទៅ ទៅដល់ស្រុកណា ក៏ដោតទង់ដើមព្រីងលើគំនរធូលី ឬគំនរខ្សាច់ ហើយទើបពោលថា បុគ្គលណាអាចលើកវាទៈ អញ្ជើញអ្នកនោះជាន់ទង់នេះចុះ ចូលទៅកាន់ស្រុក ពួកនាងត្រាច់ទៅគ្រប់ៗ ស្រុកយ៉ាងនេះ ដល់ក្រុងសាវត្ថី ដោតទង់មែកព្រីងទុកត្រង់ទ្វារស្រុក ដូចសព្វមួយដង ប្រាប់ដល់ពួកមនុស្ស ដែលមកដល់ហើយ ចូលទៅ

ខាងក្នុងព្រះនគរ ។ សម័យនោះ ព្រះមានព្រះភាគ ទ្រង់អាស្រ័យក្រុងសាវត្ថី ប្រថាប់នៅក្នុងវត្តជេតពន កាលនោះ ព្រះសារីបុត្រ សួរអាការដែលអាពាធ វល់រៀបចំទឹកន្ទែង ដែលគេមិនទាន់បានរៀបចំ កាលចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ទើបឃើញជាងកិត្តុពួកជទៃ ព្រោះមានកិច្ចច្រើន បានឃើញទង់មែកព្រីងត្រង់ទ្វារស្រុក ទើបសួរក្មេងៗ ថា នេះអ្វីហ្ន៎ ក្មេងៗ បានប្រាប់សេចក្តីនោះ ព្រះថេរៈពោលថា បើយ៉ាងនោះ ពួកអ្នកចូរជាន់ចុះ ។ ពួកក្មេងពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំមិនអាច ពួកខ្ញុំខ្លាច ។ ព្រះថេរៈពោលថា ពួកអ្នកកុំខ្លាចឡើយ ។ ព្រះថេរៈពោលថា បើបរិញ្វាជិកាសួរថា អ្នកណាឲ្យជាន់ទង់របស់ខ្ញុំ ពួកអ្នកគប្បីប្រាប់ថា ព្រះសារីបុត្រ ជាពុទ្ធសាវកឲ្យជាន់ លោកចង់លើកវាទៈ សូមអ្នកនាងម្ចាស់ ទៅកាន់សម្នាក់របស់ព្រះថេរៈឯវត្តជេតពនចុះ ។

ពួកក្មេងស្តាប់ពាក្យរបស់ព្រះថេរៈ ទើបនាំគ្នាជាន់ទង់មែកព្រីង កម្ទេចចោលទៅ ។ ព្រះថេរៈត្រាច់បិណ្ឌបាត ហើយត្រឡប់ទៅកាន់វិហារ ពួកបរិ-ញ្វាជិកាចេញអំពីស្រុកហើយ ទើបសួរថា អ្នកណាឲ្យជាន់ទង់របស់យើង ពួកក្មេងប្រាប់សេចក្តីនោះ ។ ពួកបរិញ្វាជិកាចូលទៅកាន់ស្រុកទៀត ទៅម្នាក់មួយផ្លូវ ហើយប្រាប់ថា បានឮថា ព្រះសារីបុត្រជាពុទ្ធសាវក ចង់លើកវាទៈជាមួយពួកយើង អ្នកណាបំណងនឹងស្តាប់ ចូរទៅចុះ មហាជនទៅហើយ ។ បរិញ្វាជិកាមកហើយកាន់វត្តជេតពនជាមួយមហាជននោះ ។ ព្រះថេរៈគិតថា មាតុគ្រាមនឹងមកក្នុងទីសម្រាករបស់អញ មិនជាផាសុកឡើយ ដូច្នេះ ទើប

អង្គុយកណ្តាលវិហារ ។ បរិព្វាជិកាទៅសួរព្រះថេរៈថា លោកម្ចាស់ ឲ្យជាន់ទង់របស់ខ្ញុំឬ ។ ព្រះថេរៈពោលថា អើ អាត្មាឲ្យជាន់ ដូច្នេះ ។ បរិព្វាជិកាពោលថា ខ្ញុំនឹងលើកវាទៈជាមួយលោកម្ចាស់ ។ ព្រះថេរៈពោលថា សាធុ អញ្ជើញចុះ អ្នកណាសួរ អ្នកណាឆ្លើយ ។ បរិព្វាជិកាពោលថា ខ្ញុំសួរ ។ ព្រះថេរៈពោលថា ពួកនាងជាមាតុគ្រាម អញ្ជើញសួរមុនចុះ ។ ពួកបរិព្វាជិកាទាំង ៤ នាក់នោះ ឈរនៅក្នុងទិសទាំង ៤ បានសួរពន្ធវាទៈ ដែលបានរៀនក្នុងសម្នាក់របស់មាតាបិតា ។ ព្រះថេរៈពោលធ្វើសំណួរមិនឲ្យលំបាក មិនឲ្យមានកំណួច ដូចកាត់ដើមឈូកដោយកាំបិត ដូច្នោះ ។ កាលពោលហើយ ទើបពោលអញ្ជើញឲ្យសួរទៀត បរិព្វាជិកាពោលថា បពិត្រលោកម្ចាស់ ខ្ញុំចេះប៉ុណ្ណេះឯង ។ ព្រះថេរៈពោលថា នាងសួរពន្ធវាទៈហើយ អាត្មាក៏បានឆ្លើយហើយ តែអាត្មានឹងសួរបញ្ហាត្រឹមតែមួយ ចូរនាងឆ្លើយបញ្ហានោះ ។ បរិព្វាជិកាទាំងនោះ ឃើញវិស័យរបស់ព្រះថេរៈ មិនអាចពោលថា បពិត្រលោកម្ចាស់ សួរចុះ ពួកខ្ញុំនឹងឆ្លើយដោះស្រាយ ដូច្នេះ ទើបពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់សួរចុះ បើពួកខ្ញុំដឹង នឹងឆ្លើយបកស្រាយ ។ ព្រះថេរៈពោលថា បញ្ហានេះត្រូវឲ្យកុលបុត្របព្វជ្ជា ឲ្យសិក្សាជាបឋមហើយ ទើបសួរថា អ្វីឈ្មោះថា មានតែមួយ បរិព្វាជិកាទាំងនោះ មិនឃើញខាងដើម មិនឃើញខាងចុង ។ ព្រះថេរៈពោលថា ចូរឆ្លើយមកចុះ បរិព្វាជិកាពោលថា ពួកខ្ញុំមិនឃើញខាងដើម មិនឃើញខាងចុងនៃប្រស្នានេះទេ ព្រះថេរៈពោលថា នាងសួរអាត្មារាប់ពាន់វាទៈ អាត្មាក៏ឆ្លើយហើយ នាងមិនអាច

នឹងឆ្លើយបញ្ហាតែមួយរបស់អាត្មា កាលបើយ៉ាងនេះ អ្នកណាជាអ្នកឈ្នះ អ្នកណាជាអ្នកចាញ់ហ្ន៎ បរិព្វាជិកាពោលថា លោកម្ចាស់ជាអ្នកឈ្នះ ពួកខ្ញុំជាអ្នកចាញ់ ។ ព្រះថេរៈពោលថា គ្រានេះ នាងនឹងធ្វើដូចម្តេច ។ បរិព្វាជិកាប្រាប់ពាក្យដែលមាតាបិតាពោលហើយ ទើបពោលថា ពួកខ្ញុំនឹងបួសក្នុងសម្នាក់របស់លោកម្ចាស់ ។ ព្រះថេរៈពោលថា នាងជាមាតុគ្រាម មិនគួរបួសក្នុងសម្នាក់របស់អាត្មាទេ តែនាងនាំពាក្យរបស់អាត្មា ទៅកាន់សម្នាក់ភិក្ខុនីបួសចុះ ។ បរិព្វាជិកាទទួលថា សាធុ នាំពាក្យរបស់ព្រះថេរៈ ទៅកាន់សម្នាក់ភិក្ខុនីសង្ឃបួសហើយ កាលបួសហើយ ជាអ្នកមិនប្រមាទ ចម្រើនព្យាយាម មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត ។

សច្ចកនិគ្រន្ថនេះ ជាប្អូនប្រុសរបស់បរិព្វាជិកា ៤ នាក់នោះ ជាអ្នកមានបញ្ញាក្រៃលែងជាងបងស្រីទាំង ៤ នាក់នោះ បានរៀនវាទៈ ១ ពាន់អំពីសម្នាក់នៃមាតាបិតា ហើយបន្ទាប់អំពីនោះ បានរៀនលទ្ធិខាងក្រៅច្រើនជាង មិនទៅកាន់ទីណាឡើយ បង្រៀនរាជកុមារឲ្យសិក្សាសិប្បៈនៅក្នុងក្រុងវេសាលីនោះ គេភ័យខ្លាចថា ពោះរបស់គេបែក ព្រោះពេញដោយបញ្ញាច្រើនពេក យកបន្ទះដែកពាសត្រង់ពោះដើរទៅ ។ លោកសំដៅយកនិគ្រន្ថនេះ ទើបពោលថា **សច្ចកោ និគន្ថបុត្តោ** ដូច្នេះ ។

បទថា **ភស្សប្បវាទិកោ** បានដល់ កថាមគ្គ លោកពោលភស្ស ឈ្មោះថា ជាអ្នកលើកវាទៈ ព្រោះអត្ថថា ពោល គឺពោលឆ្លើយភស្សនោះ ។ បទថា **បណ្ឌិតវាទោ** បានដល់ និយាយលើកខ្លួនថា ជាបណ្ឌិត ។ បទថា

**សាធុ សម្មតោ ពហុជនស្ស** សេចក្តីថា រមែងអាងវត្ថុណាមួយមកដោយនក្ខត្តវារៈ ដោយច្រើនវត្ថុនោះៗ រមែងប្រព្រឹត្តទៅយ៉ាងនោះ ព្រោះដូច្នោះជនដ៏ច្រើន រមែងលើកសរសើរថា ជាមេលទ្ធិល្អ ចម្រើន ។ បទថា **វាទេន វាទំ សមារទ្ធោ** បានដល់ លើកកំហុសឡើងដោយយកថាមគ្គ ។

[ ៣៣ ] បទថា **អាយស្មា អស្សជិ** បានដល់ ព្រះអស្សជិត្ថេរ ជាអាចារ្យរបស់ព្រះសារីបុត្តត្ថេរ ។ បទថា **ជង្ឃាវិហារំ អនុចង្កមមានោ** សេចក្តីថា ចង្ក្រមអំពីព្រះដំណាក់នៃស្តេចលិច្ឆវីនោះៗ ដើម្បីទៅកាន់ព្រះដំណាក់នោះៗ ។ បទថា **យេនាយស្មា អស្សជិ តេនុបសង្កមិ** សេចក្តីថា សួរថា ចូលទៅរកព្រោះហេតុអ្វី ឆ្លើយថា ដើម្បីដឹងលទ្ធិ ។ បានឮថា សច្ចកនិគ្រន្ថមានការគិតយ៉ាងនេះថា អញដើរ ដោយគិតថា អញនឹងលើកវាទៈរបស់ព្រះសមណគោតម មិនលើកឡើងថា ខ្ញុំមិនដឹងលទ្ធិរបស់ព្រះសមណគោតម ឯបុគ្គលដែលដឹងលទ្ធិនៃអ្នកដទៃ លើកវាទៈឡើង ឈ្មោះថាលើកឡើងល្អហើយ ឯព្រះអស្សជិត្ថេរនេះ ប្រាកដជាសាវករបស់ព្រះសមណ-គោតម លោកជាអ្នកឈ្លាសក្នុងលទ្ធិរបស់សាស្តានៃខ្លួន អញសួរលទ្ធិនោះហើយ ញ៉ាំងពាក្យសម្តីឲ្យតាំងនៅ ហើយនឹងលើកវាទៈចំពោះព្រះសមណ-គោតមដូច្នេះ ព្រោះដូច្នោះ ទើបចូលទៅរក ។ បទថា **វិនេតិ** សេចក្តីថា សច្ចកនិគ្រន្ថសួរថា សមណគោតមទូន្មានដូចម្តេច ឲ្យសិក្សាដូចម្តេច ដូច្នេះ ។ ព្រោះកាលព្រះថេរៈពោលថា ជាទុក្ខ រមែងជាឱកាសនៃការជំទាស់ ឯមគ្គផលមកហើយដោយបរិយាយថា ជាទុក្ខ កាលព្រះថេរៈពោលថា ទុក្ខ ដូច្នេះ

សច្ចកនិគ្រន្ថនេះ គប្បីសួរព្រះថេរៈថា លោកម្ចាស់អស្សជិដ៏ចម្រើន លោកម្ចាស់បួសដើម្បីអ្វី ។ បន្ទាប់អំពីនោះ ព្រះថេរៈឆ្លើយថា ដើម្បីមគ្គផល គប្បីចាប់ទោសឡើងថា លោកម្ចាស់អស្សជិនេះមិនមែនពាក្យទូន្មានរបស់លោកនោះ អាឃាតយ៉ាងខ្លាំងក្លា រមែងក្តៅដំក្នុងនរកនោះ មិនមានដើម្បីសេចក្តីសុខរបស់លោក លោកនឹងមកប្រឡូកប្រឡំ គ្រាប់ធ្វើទុក្ខឲ្យទ្រុឌទ្រោម ដូច្នោះ មិនគួរធ្វើបរិយាយកថាដល់បុគ្គលជាអ្នកលើកវាទៈ ព្រះថេរៈគិតថា សច្ចក-និគ្រន្ថនឹងតាំងនៅមិនបាន យ៉ាងណា អញនឹងពោលកថាដោយត្រង់ដល់សច្ចកៈនោះ ដូច្នោះ ទើបលើកព្រះតម្រាស់នេះថា **រូបំ ភិក្ខវេ អនិច្ចំ** ជាដើម ដោយអំណាចអនិច្ចំ អនត្តា ។ បទថា **ទុស្សុតំ** គឺមិនគួរស្តាប់ ។

[ ៣៥ ] បទថា **សន្ធាគារេ** បានដល់ សាលា គឺអាគារដែលប្រជុំបង្រៀនអត្ថដល់រាជត្រកូល ។ បទថា **យេន តេ លិច្ឆវី តេនុបសង្កមិ** សេចក្តីថា បានឮថា សច្ចកនិគ្រន្ថនោះ មានគំនិតយ៉ាងនេះថា អញមិនលើកវាទៈចំពោះព្រះសមណគោតម ព្រោះមិនដឹងលទ្ធិក្នុងកាលមុន តែឥឡូវនេះ អញដឹងលទ្ធិដែលព្រះមហាសាវ័ក របស់ព្រះសមណគោតមនោះពោលហើយ ឯស្តេចលិច្ឆវីទាំង ៥០០ នេះ ជាសិស្សរបស់អញ មកប្រជុំគ្នាហើយ អញនឹងទៅព្រមជាមួយស្តេចលិច្ឆវីទាំងនោះ ហើយសឹមលើកវាទៈឡើងចំពោះព្រះសមណគោតម ដូច្នេះ ព្រោះដូច្នោះ ទើបចូលទៅរក ។ បទថា **ញាតញ្ញ-តរេន** សេចក្តីថា បណ្តាបញ្ចវគ្គិយត្ថេរ ដែលមានឈ្មោះបោះសំឡេងទាំងនោះ អង្គណាមួយ ។ បទថា **បតិដ្ឋិតំ** សេចក្តីថា ព្រះអស្សជិត្ថេរនោះ តាំងនៅ

យ៉ាងណា សមណគោតមនឹងតាំងនៅយ៉ាងនោះ កាលបើដូច្នោះ អញនឹងពោលសេចក្តីដទៃទៀត ។ ឥឡូវនេះ កាលនឹងបែរខ្លួនត្រឡប់ ទើបទូលថា ខ្ញុំនឹងធ្វើអ្វីក៏បាន ក្នុងទីនោះ ។ បទថា **អាកឌ្ឍេយ្យ** បានដល់ គប្បីកន្ត្រាក់ឲ្យបែរមុខមករកខ្លួន ។ បទថា **បរិកឌ្ឍេយ្យ** សេចក្តីថា គប្បីទាញមកឲ្យក្រាបនៅខាងមុខ ។ បទថា **សម្បរិកឌ្ឍេយ្យ** សេចក្តីថា ទាញទៅ ទាញមក ។ បទថា **សោណ្ឌិធុត្តោ** ប្រែថា អ្នកលេងសុរា ។ បទថា **ថាលំ កណ្ណេ គហេត្វា** សេចក្តីថា បុគ្គលប្រាជ្ញនឹងលាងខ្ទះសម្រាប់បិតស្រា ចាប់ត្រង់ត្រចៀកទាំង ២ រលាស់កាកចោល ។ បទថា **ឱធុនេយ្យ** បានដល់ ផ្កាប់មុខ ។ បទថា **និទ្ធុនេយ្យ** បានដល់ ផ្ងារមុខឡើង ។ បទថា **និប្ផោដេយ្យ** បានដល់ គប្បីបោករឿយៗ មនុស្សនាំយកសម្បកធ្មៃចងជាបាច់ៗ ត្រាំទឹកដើម្បីធ្វើសំពត់សម្បកធ្មៃ ។ ក្នុងបទថា **សាណធោវិកំ នាម** នេះ ក្នុងថ្ងៃទី ៣ សម្បកធ្មៃទាំងនោះ ជារបស់សើមល្អ ។ បន្ទាប់មក មនុស្សនាំយកទឹកម្សូរ បបរ និងសុរាជាដើមទៅត្រង់ទីនោះ កាន់យកបាច់ធ្មៃទៅបោកលើផែនក្តារ ៣ ជងខាងស្តាំ និងខាងឆ្វេង ឬខាងមុខ គឺលើបន្ទះក្តារខាងស្តាំ ១ ខាងឆ្វេង ១ ខាងមុខ ១ ស៊ីបណ្តើរ ផឹកបណ្តើរ ទំពាបណ្តើរ ទឹកម្សូរ បបរ និងសុរាជាដើម នាំគ្នាលៀងសុរាជាដើម ជាកីឡាធំ ដំរីរបស់ព្រះរាជាឃើញកីឡានោះហើយ ចុះទឹកជ្រៅ យកប្រមោយបូមទឹក ហើយបាញ់លើក្បាលម្តង លើខ្នងម្តង ឆ្អឹងជំនីរទាំងពីរម្តង លើចន្លោះខ្នងម្តង ព្រោះអាស្រ័យហេតុនោះ ការលេងកីឡានោះ ហៅថា លេងបោកធ្មៃ សច្ចកនិគ្រន្ថសំដៅយកការលេងនោះ

ទើបពោលថា កីឡាលានសម្បកផ្ចេ ។

ក្នុងបទថា **កឹ សោ ភវមានោ សច្ចកោ និគណ្ឋបុត្តោ យោ ភគវតោ វាទំ អារោបេស្សតិ** នេះ អធិប្បាយថា សច្ចកនិគ្រន្ថបុត្រនឹងលើកវាទៈជាមួយព្រះមានព្រះភាគ សច្ចកនិគ្រន្ថនោះជាអ្វី ជាយក្សឬ ជាព្រះឥន្ទ្រឬ ជាព្រហ្មឬ ដែលនឹងលើកវាទៈជាមួយព្រះមានព្រះភាគ ឯមនុស្សតាមប្រក្រតីមិនអាចដើម្បីនឹងលើកវាទៈជាមួយព្រះមានព្រះភាគបាន ដូច្នេះ ។

[ ៣៥ ] បទថា **តេន ខោ បន សមយេន** សេចក្តីថា ក្នុងសម័យដែលសច្ចកៈចូលទៅកាន់អារាម ។ សួរថា ចូលទៅក្នុងសម័យណា ឆ្លើយថា ក្នុងវេលាថ្ងៃត្រង់ ។ សួរថា ព្រោះហេតុអ្វី ទើបភិក្ខុទាំងឡាយចង្រ្កមនៅក្នុងសម័យនោះ ឆ្លើយថា ដើម្បីបន្ទោបង់នូវថីនមិទ្ធៈ ដែលមានភោជនដ៏ប្រណីតជាបច្ច័យ ។ម្យ៉ាងទៀត ភិក្ខុទាំងនោះប្រកបសេចក្តីព្យាយាមក្នុងពេលថ្ងៃ ។ កាលភិក្ខុដូច្នោះចង្រ្កម ផ្ទូតទឹកខាងក្រោយអាហារ ឲ្យរាងកាយទទួលសេចក្តីសប្បាយហើយ អង្គុយបំពេញសមណធម៌ ចិត្តក៏មានអារម្មណ៍តែមួយពិត ។ បទថា **យេន តេ ភិក្ខូ** សេចក្តីថា បានឮថា សច្ចកនិគន្ថបុត្រនោះគិតថា ព្រះសមណគោតមនៅទីណា ទើបត្រាច់ទៅដោយជុំវិញ គិតថា នឹងសួរ រួចចូលទៅ កាលសម្លឹងឃើញពួកភិក្ខុសមាទានសំពត់បង្សុកូលជាវត្ត ចង្រ្កមនៅលើទីចង្រ្កមធំ ដូចដំរីព្រៃ ទើបបានទៅកាន់សម្នាក់របស់ភិក្ខុទាំងនោះ ។ បទថា **យេន តេ ភិក្ខូ** ជាដើម សច្ចកនិគន្ថបុត្រពោលសំដៅយកភិក្ខុនោះ ។ បទថា **កហំ នុ ខោ ភោ** សេចក្តីថា ព្រះគោតមដ៏ចម្រើននោះ នៅក្នុងអាវាស

ក្នុងគុហា ឬមណ្ឌបណា ។ បទថា **ឯស អគ្គិវេស្សន ភគវា** សេចក្តីថា បាន
ឮថា ក្នុងកាលនោះ ក្នុងវេលាជិតភ្លឺ ព្រះមានព្រះភាគ ទ្រង់ចូលមហាករុណា
សមាបត្តិ ទ្រង់ផ្សាយបណ្តាញ គឺព្រះសព្វញ្ញុតញ្ញាណ ទៅក្នុងម៉ឺនចក្រវាល
កាលទ្រង់ប្រមើលមើលសត្វដែលគួរទូន្មានឲ្យត្រាស់ដឹង ទ្រង់ឃើញថា ស្អែក
នេះ សច្ចកនិគន្ថបុត្រនាំស្តេចលិច្ឆវីបរិស័ទជាច្រើន នឹងមកលើកវាទៈជាមួយ
តថាគត ដូច្នេះ ។ ដូច្នោះ ទ្រង់ជម្រះព្រះវរកាយអំពីព្រលឹម មានភិក្ខុសង្ឃ
ជាបរិវារ ទ្រង់យាងបិណ្ឌបាតក្នុងក្រុងវេសាលី ទ្រង់ត្រឡប់អំពីបិណ្ឌបាត ទ្រង់
ព្រះតម្រិះថា តថាគតនឹងអង្គុយក្នុងទីសប្បាយ ដើម្បីប្រថាប់គង់ក្នុងបរិស័ទ
មានចំនួនច្រើន ទើបមិនយាងចូលទៅកាន់ព្រះគន្ធកុដិ ប្រថាប់គង់សម្រាក
ពេលថ្ងៃ ត្រង់គល់ឈើមួយកន្លែង ក្នុងព្រៃមហាវ័ន ។ ភិក្ខុទាំងនោះ មក
សម្តែងវត្តដល់ព្រះមានព្រះភាគ ត្រូវសច្ចកនិគ្រន្ថសួរ កាលបង្ហាញព្រះមាន
ព្រះភាគ ដែលប្រថាប់ហើយក្នុងទីឆ្ងាយ ទើបពោលថា អគ្គិវេស្សនៈ នុ៎ះព្រះ
មានព្រះភាគ ដូច្នេះ ។ បទថា **មហតិយា លិច្ឆវិបរិសាយ សទ្ធឹ** អធិប្បាយ
ថា ស្តេចលិច្ឆវីប្រមាណ ៥០០ ហែហមខាងក្រោយ ។ ស្តេចលិច្ឆវីទាំងនោះ
ជាកូនសិស្សរបស់សច្ចកៈនោះ ។ ឯសច្ចកៈខាងក្នុងក្រុងវេសាលី នាំស្តេច
លិច្ឆវីប្រមាណ ៥០០ ដែលបានឮហើយថា ជាអ្នកត្រូវលើកវាទៈ ចូលទៅ
គាល់ព្រះមានព្រះភាគ ដូច្នេះ ដោយច្រើន ពួកមនុស្សនាំគ្នាចេញទៅ ដោយ
គិតថា អញនឹងស្តាប់ការសន្ទនារបស់បណ្ឌិត ២ នាក់ ។ បរិស័ទមានចំនួន
ច្រើនយ៉ាងនេះ កំណត់រាប់មិនបានឡើយ ។ ពាក្យនោះ សច្ចកៈពោលហើយ

សំដៅដល់បរិស័ទនោះ ។ បទថា **អញ្ជលឹ បណាមេត្វា** សេចក្តីថា ជនទាំងនោះជា ២ ចំណែក ពួកគេគិតយ៉ាងនេះថា បើពួកជាមិច្ឆាទិដ្ឋិ ចោទអញថា អ្នក ថ្វាយបង្គំព្រះសមណគោតមធ្វើអ្វី ពួកយើងនឹងប្រាប់ដល់បុគ្គលទាំងនោះថា ថ្វាយបង្គំអ្វី ត្រឹមតែលើកកម្បង់អញ្ជលីប៉ុណ្ណោះ បើពួកសម្មាទិដ្ឋិចោទអញថា ហេតុអ្វី អ្នកមិនថ្វាយបង្គំព្រះមានព្រះភាគ ពួកយើងនឹងប្រាប់ថា ការថ្វាយបង្គំទាល់តែក្បាលដល់ផែនដីឬ ត្រឹមតែអញ្ជលីកម្មក៏មិនជាការថ្វាយបង្គំឬ ។ បទថា **ណាមគោត្តំ** សេចក្តីថា ពួកខ្លះទូលថា ព្រះគោតមដ៏ចម្រើន ខ្ញុំឈ្មោះទត្តៈ ឈ្មោះមិត្តៈ ជាបុត្ររបស់បុគ្គលនោះ មកក្នុងទីនេះហើយ ឈ្មោះថា ប្រកាសនាម ។ ពួកខ្លះទូលថា ព្រះគោតមដ៏ចម្រើន ខ្ញុំឈ្មោះថា វាសិដ្ឋៈ ឈ្មោះថា កច្ចានៈ មកក្នុងទីនេះហើយ ឈ្មោះថា ប្រកាសគោត្រ ។ បានឮថា ជនក្រីក្រទាំងនោះ បានប្រកាសធ្វើយ៉ាងនោះ ដោយគិតថា អញជាកូនរបស់បុរាណត្រកូល នឹងប្រាកដឈ្មោះ និងគោត្រក្នុងកណ្តាលបរិស័ទ ។ ឯពួកណាអង្គុយស្ងៀម ពួកជនទាំងនោះ ជាមនុស្សក្នុងដែនជាប់ស្រយាល និងមនុស្សអន្ធពាល ។ បណ្តាជនទាំងនោះ មនុស្សក្នុងជនបទជាប់ស្រយាលគិតថា អ្នកដែលធ្វើការសន្ទនាគ្នាមួយម៉ាត់ពីរម៉ាត់ នឹងទៅជាអ្នកស្និទ្ធស្នាលគ្នា បើស្និទ្ធស្នាលមាន បើមិនឲ្យភិក្ខា ១ វែក ២ វែក មិនគួរ ដើម្បីឲ្យខ្លួនផុតអំពីការស្និទ្ធស្នាលនោះ ទើបនាំគ្នាអង្គុយស្ងៀម ។ ពួកអន្ធពាលជាអ្នកអង្គុយស្ងៀមក្នុងទីណាមួយ ព្រោះមិនដឹង ដូចដុំដីដែលត្រូវបោះទៅខាងក្រោម ។

[ ៣៦ ] បទថា **កិញ្ចិនេវ ធេសំ** សេចក្តីថា ឱកាសណាមួយ ហេតុ

ណាមួយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ឲ្យសច្ចកនិគ្រន្ថកើតឧស្សាហ៍ក្នុងការសួរបញ្ហា ទើបត្រាស់ថា ម្នាលអគ្គិវេស្សនៈ បើអ្នកត្រូវការសួរ ចូរសួរមកចុះ ។ បទនោះមានសេចក្ដីថា បើអ្នកបំណងនឹងសួរក៏សួរ ក្នុងការឆ្លើយបញ្ហា មិនជាភារៈធ្ងន់សម្រាប់តថាគតឡើយ ម្យ៉ាងទៀត អ្នកបំណងវត្ថុណា ក៏ចូរសួរ តថាគតនឹងឆ្លើយវត្ថុទាំងអស់នោះដល់អ្នក ព្រោះដូច្នោះ ព្រះសមណគោតមបវារណាហើយ ដោយសព្វញ្ញុតញ្ញាណបវារណា ដែលមិនទូទៅដល់ព្រះបច្ចេកពុទ្ធ អគ្គសាវ័ក និងព្រះមហាសាវ័ក ។ ឯលោកទាំងនោះមិនពោលថា បើអ្នកបំណងនឹងពោលថា ពួកយើងស្ដាប់ហើយ នឹងជ្រាបដូច្នេះ ។ ឯព្រះពុទ្ធទាំងឡាយ រមែងបវារណាដោយព្រះសព្វញ្ញុតញ្ញាណ-បវារណាដល់យក្ខ កំពូលមនុស្ស ទេវតា សមណព្រាហ្មណ៍ និងបរិព្វាជកទាំងនោះថា ម្នាលអាវុសោ បើអ្នកបំណងក៏ចូរសួរចុះ ឬថា បពិត្រវាសវៈមហារាជមានព្រះហឫទ័យប្រាថ្នានឹងសួរនូវប្រស្នាណា ចូរសួរនូវប្រស្នានោះចំពោះតថាគតចុះ តថាគតនឹងធ្វើនូវទីបំផុតនៃប្រស្នាទាំងនោះ ថ្វាយមហាបពិត្របាន ។ ឬថា អ្នកទាំងឡាយ តថាគតបើកឱកាសឲ្យហើយ ចូរសួរនូវសេចក្ដីសង្ស័យទាំងអស់របស់ពាវរីព្រាហ្មណ៍ផង របស់អ្នកផង របស់ពួកជនទាំងអស់ផង ចូរប្រាថ្នាទុកក្នុងចិត្តនូវហេតុណាមួយចុះ ។ ឬថា ម្នាលសភិយៈ អ្នកចូរដាក់ចិត្តក្នុងបញ្ហាណាមួយ ចូរសួរតថាគតៗ នឹងឆ្លើយបញ្ហានោះ ឲ្យដល់ទីបំផុតដល់អ្នក សេចក្ដីនោះមិនជាអស្ចារ្យឡើយ ព្រោះព្រះមានព្រះភាគទ្រង់សម្រេចពុទ្ធភូមិហើយ ទ្រង់បវារណាពុទ្ធភូមិនោះយ៉ាងនេះ ។

ចំណែកបុគ្គលដែលតាំងនៅក្នុងបទេសញ្ញាណ គឺ ក្នុងពោធិសត្វភូមិដែលឥសីទាំងឡាយអារាធនាហើយ ដើម្បីប្រយោជន៍ដល់សក្កទេវរាជជាដើម ក្នុងសរភង្គជាតក ទើបជាអស្ចារ្យ ដូចមានគាថាយ៉ាងនេះ ។

បពិត្រកោណ្ឌញ្ញៈ សូមលោកឆ្លើយនូវប្រស្នាទាំងឡាយ
ឥសីទាំងឡាយមានសភាពដ៏ល្អ អារាធនាលោក បពិត្រ
កោណ្ឌញ្ញៈ ការដោះប្រស្នានោះ ជាទំនៀមតែងមានក្នុងពួក
មនុស្ស ប្រស្នាណា មកកាន់សេចក្តីចម្រើន ប្រស្នានុ៎ះ
ជាភារៈរបស់លោក ។

( កាលឥសីទាំងឡាយ អារាធនាដូច្នេះហើយ សរភង្គតាបស ក៏បវារណាថា )

លោកដ៏ចម្រើនទាំងឡាយ ខ្ញុំធ្វើឱកាសឲ្យហើយ ចូរសួរនូវ
ប្រស្នាណានីមួយ ដែលលោកទាំងឡាយប្រាថ្នាហើយដោយ
ចិត្តចុះ ព្រោះថា ខ្ញុំដឹងនូវលោកនេះ និងលោកខាងមុខ
ដោយខ្លួនឯង និងឆ្លើយនូវប្រស្នានោះៗ ប្រាប់លោក
ទាំងឡាយបាន ។

ត្រាច់ទៅ ៣ ដង ក្នុងសម្ភវជាតក និងក្នុងជម្ពូទ្វីប មិនឃើញអ្នកធ្វើទីបំផុតនៃបញ្ហាទាំងឡាយ ត្រូវសុចិរកព្រាហ្មណ៍សួរបញ្ហា កាលឱកាសដែលព្រះអង្គធ្វើហើយ ព្រះអង្គមានព្រះជន្ម ៧ ឆ្នាំអំពីកំណើត ទ្រង់លេងធូលីត្រង់ថ្នល់ ទ្រង់អង្គុយពត់ភ្នែនត្រង់វិថី ទ្រង់បវារណាដោយព្រះសព្វញ្ញុតញ្ញាណ-

បវារណាថា

> បើដូច្នោះ អ្នកឈ្មោះសវ៉ៃ ( និយាយ ) យ៉ាងណា ខ្ញុំនឹងប្រាប់អ្នកយ៉ាងនោះ ព្រះរាជានឹងទ្រង់ជ្រាបនូវប្រស្នានោះ ទោះបីព្រះអង្គធ្វើតាមក្តី មិនធ្វើតាមក្តី ។

កាលបវារណា ដោយព្រះសព្វញ្ញុតញ្ញាណបវារណា ដែលព្រះមានព្រះភាគទ្រង់បវារណាយ៉ាងនេះ សច្ចកនិគ្រន្ថមានចិត្តត្រេកអរ កាលនឹងទូលសួរបញ្ហា ទើបបានពោលពាក្យជាដើមថា **កថំ បន ភោ គោតម** ដូច្នេះ ។

ព្រះមានព្រះភាគ ត្រាស់ដល់សច្ចកនិគ្រន្ថនោះថា អ្នកដ៏ចម្រើន អ្នកឃើញសាវ័កពោលពាក្យដទៃ ព្រះសាស្តាត្រាស់ពាក្យដទៃ តថាគតពោលហើយ មិនមែនឬថា សាវ័ករបស់ព្រះសមណគោតម តាំងនៅហើយ យ៉ាងណា ព្រះសមណគោតមនឹងតាំងនៅយ៉ាងនោះ តថាគតក៏លើកវាទៈ យ៉ាងនោះ កាលត្រាស់ដោយកំណត់ ដែលព្រះអស្សជិត្ថេរពោលហើយខាងដើមថា ឱកាសនៃពាក្យរបស់និគ្រន្ថ ចូរកុំមានយ៉ាងនេះថា និគ្រន្ថនេះរមែងពោលពាក្យដទៃ តថាគតអាចធ្វើអ្វីបាន ក្នុងទីនោះ ទើបត្រាស់ពាក្យជាដើមថា **ឃរំ ខោ អហំ អគ្គិវេស្សន** ដូច្នេះ ។ បទថា **ឧបមា មំ ភោ គោតម បដិភាតិ** សេចក្តីថា សច្ចកនិគ្រន្ថពោលថា ព្រះគោតមដ៏ចម្រើន ឧបមាមួយ រមែងប្រាកដដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងនាំឧបមានោះមក ។ បទថា **បដិភាតុ តំ អគ្គិវេស្សន** ព្រះមានព្រះភាគបានត្រាស់ថា ម្នាលអគ្គិវេស្សនៈ ឧបមា ចូរប្រាកដដល់អ្នក គឺថា សច្ចកនិគ្រន្ថស្ទិទស្ទាលហើយ ចូរនាំឧបមានោះមក ។

បទថា **ពលករណីយា** សេចក្ដីថា ការងារ មានកសិកម្ម និងពាណិជកម្ម ត្រូវធ្វើដោយកម្លាំងដើមដៃ ។ បទថា **រូបត្តាយំ បុរិសបុគ្គលោ** សេចក្ដីថា ឈ្មោះថា **រូបត្តា** ព្រោះអត្ថថា បុគ្គលនោះមានរូបជាខ្លួន លោកសម្ដែងបុគ្គលដែលប្រកាន់ថារូបជាខ្លួន តាំងនៅ ។ បទថា **រូបេ បតិដ្ឋាយ** សេចក្ដីថា តាំងនៅក្នុងរូប ដែលប្រកាន់ថា ជាខ្លួនក្នុងរូបនោះ ។ បទថា **បុញ្ញំ វា អបុញ្ញំ វា បសវតិ** គឺរមែងបានកុសល ឬអកុសល សូម្បីបទ មានវេទនាជាខ្លួនជាដើម ក៏មានន័យនេះឯង ។

បទនេះលោកសម្ដែងដូចម្ដេច លោកឧបមា ព្រមទាំងហេតុដែលគួរត្រាស់ថា បញ្ចក្ខន្ធទាំងនេះ ជាទីនៅអាស្រ័យ ដូចផែនដី ជាទីនៅអាស្រ័យរបស់ពួកសត្វទាំងនេះ សត្វទាំងនោះតាំងនៅក្នុងបញ្ចក្ខន្ធទាំងនេះ រមែងរួបរួមយកកុសលកម្ម និងអកុសលកម្ម លោកកាលបដិសេធខ្លួន ដែលមានសភាពបែបនេះ សម្ដែងថា បញ្ចក្ខន្ធមិនមែនខ្លួន ដូច្នេះ ។ ក្នុងឧបមាដែលនិគ្រន្ថនាំមកប្រៀបធៀបពិតប្រាកដហើយ មិនមានអ្នកដទៃក្រៅអំពីព្រះសព្វញ្ញុពុទ្ធ ដែលឈ្មោះថា អាចកាត់ពាក្យសម្ដីរបស់និគ្រន្ថនោះ ហើយឲ្យទោសក្នុងវាទៈបាន ពិតហើយ បុគ្គល ២ ពួក គឺពុទ្ធវេណី ១ សាវកវេណី ១ ។ ក្នុងសាវកវេណី សាវកទូន្មានខ្លះ ព្រះពុទ្ធទ្រង់ទូន្មានខ្លះ ឯក្នុងពុទ្ធវេណី សាវកមិនអាចទូន្មានបានឡើយ មានតែព្រះពុទ្ធប៉ុណ្ណោះ ទ្រង់ទូន្មានបាន ឯនិគ្រន្ថនេះ ជាពុទ្ធវេណី ព្រោះដូច្នោះ មិនមានអ្នកដទៃណាម្នាក់ អាចកាត់ពាក្យសម្ដីរបស់និគ្រន្ថនោះ ហើយឲ្យទោសក្នុងវាទៈបាន ព្រោះហេតុនោះ ព្រះមាន

ព្រះភាគ ដើម្បីទ្រង់សម្តែងទោសក្នុងវាទៈរបស់សច្ចកនិគ្រន្ថនោះ ដោយព្រះអង្គឯង ទើបត្រាស់ថា **ឆនុ ត្វំ អគ្គិវេស្សន** ដូច្នេះ ។

លំដាប់នោះ និគ្រន្ថគិតថា ព្រះសមណគោតម រមែងបញ្ចាក់នូវវាទៈរបស់អញក្រៃលែងពេក បើទោសណាមួយមានក្នុងខាងលើ ព្រះអង្គនឹងសង្កត់សង្កិនតែអញម្នាក់ឯង ណ្ហើយចុះ អញនឹងទាញវាទៈនេះទៅដាក់ក្បាលមហាជន ព្រោះដូច្នោះ ទើបពោលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំឯងពោលយ៉ាងនេះថា រូបជារបស់ខ្លួនរបស់អញ ។បេ។ វិញ្ញាណជារបស់ខ្លួនរបស់អញ ទាំងប្រជុំជនជាច្រើននេះ គេក៏ថាដូច្នេះដែរ ។ ឯព្រះមានព្រះភាគ ទ្រង់មានវាទៈល្អជាងនិគ្រន្ថរាប់រយគុណ ពាន់គុណ សែនគុណ ព្រោះដូច្នោះ ទើបព្រះតម្រិះថា និគ្រន្ថនេះចង់រួចខ្លួន ទើបទាញវាទៈទៅដាក់លើក្បាលមហាជន តថាគតនឹងមិនឲ្យនិគ្រន្ថនេះរួចខ្លួនទៅបាន តថាគតនឹងដោះវាទៈ អំពីមហាជនហើយសង្កត់សង្កិននិគ្រន្ថនេះតែម្នាក់ឯង ។ លំដាប់នោះ ទើបត្រាស់នឹងនិគ្រន្ថថា **កឹ ហិ តេ អគ្គិវេស្សន** ដូច្នេះជាដើម ។ បទនោះ មានអធិប្បាយថា ប្រជុំជននេះមិនមកលើកវាទៈ ជាមួយតថាគត អ្នកប៉ុណ្ណោះ ត្រាច់ទៅពេញក្រុងវេសាលី មកលើកវាទៈជាមួយតថាគត ព្រោះដូច្នោះ អ្នកចូរប្រកាសវាទៈរបស់ខ្លួនឲ្យទូទៅ អ្នកទាញអ្វី ទៅដាក់លើក្បាលមហាជន ។ និគ្រន្ថនោះ កាលទទួលការពិត ទើបក្រាបទូលថា ព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គពោលយ៉ាងនោះពិត ដូច្នេះជាដើម ។ ព្រះមានព្រះភាគ ទ្រង់បញ្ចាក់វាទៈរបស់និគ្រន្ថ ទ្រង់ប្រារព្ធសំណួរថា **តេនហិ អគ្គិវេស្សន** ដោយប្រការដូច្នេះឯង ។

[ ៣៧ ] បណ្តាបទទាំងនោះ បទថា **តេនហិ** ជានិបាត ចុះក្នុងអត្ថថា ហេតុ ព្រោះអ្នករមែងយល់នូវបញ្ចក្ខន្ធថាជាខ្លួន ដូច្នោះ ។ បទថា **សកស្មឹ វិជិតេ** គឺក្នុងដែនរបស់ព្រះអង្គ ។ បទថា **ឃាតេតាយំ វា ឃាតេតុំ** បានដល់ ដើម្បីឲ្យសម្លាប់បុគ្គលដែលគួរសម្លាប់ គឺបុគ្គលសមគួរត្រូវសម្លាប់ ។ បទថា **ជាបេតាយំ វា ជាបេតុំ** សេចក្តីថា ដើម្បីរឹបជាន់នូវបុគ្គលដែលជាសត្រូវដល់ព្រះរាជា ក្នុងទីដែលគួររឹបជាន់ គឺបុគ្គលដែលត្រូវរឹបជាន់ បានដល់ដើម្បីឲ្យវិនាសទ្រព្យ ។ បទថា **បព្វាជេតាយំ វា បព្វាជេតុំ** សេចក្តីថា ដើម្បីនិរទេស គឺបណ្តេញមនុស្សដែលគួរបណ្តេញចេញទៅអំពីដែនរបស់ព្រះអង្គ ។ បទថា **វត្តិតុញ្ច អរហតិ** លោកសម្តែងថា រមែងប្រព្រឹត្តទៅ គឺគួរដើម្បីប្រព្រឹត្តទៅ និគ្រន្ថសម្តែងហេតុដែលនាំមក ដើម្បីទម្លាយវាទៈរបស់ខ្លួនឯងឲ្យវិសេស ដូចបុគ្គលដែលធ្វើអាវុធឲ្យមុត ដើម្បីសម្លាប់មនុស្ស ដូចបុគ្គលពាល ។ បទថា **ឯវំ មេ រូបំ ហោតុ** សេចក្តីថា សូមរូបរបស់អញយ៉ាងនេះ គឺមានរូបគួរជ្រះថ្លា មានរូបស្អាត ឃើញហើយគួរពេញចិត្ត ដូចសសរមាសដែលប្រដាប់ហើយ តាក់តែងហើយ និងដូចសំពត់ដែលវិចិត្រចាត់ចែងយ៉ាងល្អ ។ បទថា **ឯវំ មេ រូបំ មា អហោសិ** សេចក្តីថា សូមរូបរបស់អញកុំយ៉ាងនេះ គឺពណ៌សម្បុរអាក្រក់ សណ្ឋានមិនល្អ ស្បែកស្ងួតសក់ស្កូវ ខ្លួនមានអាចម៍រុយ ។ បទថា **តុណ្ហី អហោសិ** សេចក្តីថា និគ្រន្ថដឹងនូវភាពដែលខ្លួនភ្ញាំងភ្ញាត់ក្នុងវាទៈនេះ ទើបគិតថា ព្រះសមណគោតម នាំហេតុមកដើម្បីទម្លាយវាទៈរបស់អញ អញសម្តែងហេតុនោះភ្ញាំងភ្ញាត់ទៅ

ព្រោះល្ងង់ បើពោលថា ប្រព្រឹត្តទៅដូច្នេះ ពេលនេះ អញវិនាសហើយ អគ្គិ-វេស្សនៈបានក្រោកឡើង ពោលនឹងស្ដេចទាំងនោះថា អំណាចរមែងប្រព្រឹត្តទៅក្នុងរូបរបស់ខ្ញុំ បើអំណាចប្រព្រឹត្តទៅក្នុងរូបរបស់អ្នក ព្រោះហេតុអ្វី ទើបអ្នកមិនរុងរឿងដូចស្ដេចលិច្ឆវីទាំងនេះ មានរូបស្អាត គួរជ្រះថ្លា តែងរុងរឿងដោយអត្តភាព ដូចទេវតាជាន់តាវត្តិង្ស បើអញពោលថា ប្រព្រឹត្តទៅមិនបាន ព្រះសមណគោតម ទ្រង់ក្រោកឡើង លើកវាទៈថា អគ្គិវេស្សនៈ ក្នុងកាលមុន អ្នកពោលថា អំណាចប្រព្រឹត្តទៅក្នុងរូបរបស់អញ ឥឡូវនេះ ជំទាស់ហើយ កាលគាត់ពោលថា ប្រព្រឹត្តទៅក៏មានទោសម្យ៉ាង ពោលថា ប្រព្រឹត្តទៅមិនបានក៏មានទោសម្យ៉ាង ដោយប្រការដូច្នេះ ក៏នៅស្ងៀមដូច្នេះឯង ។ ព្រះមានព្រះភាគ សួរគម្រប់ ២ ដង សច្ចកនិគ្រន្ថក៏នៅស្ងៀមអស់វារៈ ២ ដង ។ ព្រោះក្បាលរបស់បុគ្គលដែលមិនឆ្លើយ ក្នុងកាលបញ្ហាដែលព្រះមានព្រះភាគត្រាស់សួរហើយ ៣ ដង រមែងបែកជា ៧ ភាគ ។ ធម្មតា ព្រះពុទ្ធទាំងឡាយ មានករុណាជាកម្លាំងក្នុងពួកសត្វ ព្រោះបំពេញបារមីអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ដើម្បីប្រយោជន៍ដល់ពួកសត្វទាំងនោះ ដូច្នោះ ត្រាស់សួរ ២ ដងហើយ ទើបត្រាស់ពាក្យជាដើមថា គ្រានោះឯង ព្រះមានព្រះភាគបានត្រាស់ពាក្យនេះនឹងសច្ចកនិគន្ថបុត្រថា អ្នកចូរដោះស្រាយនូវបញ្ហាក្នុងកាលឥឡូវនេះទៅ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សហធម្មិកំ** គឺមានហេតុ មានផល ។ ឈ្មោះថា **វជិរបាណី** ព្រោះអត្ថថា មានវជិរាវុធនៅក្នុងដៃ ។ បទថា **យក្ខោ**

សេចក្តីថា គប្បីជ្រាបថា បុគ្គលនោះមិនមែនយក្ខ ជាសក្កទេវរាជ ។ បទថា **អាទិត្តំ** គឺមានពណ៌ដូចភ្លើង ។ បទថា **សម្បជ្ជលិតំ** គឺឆេះទ្រលោមដោយល្អ ។ បទថា **សជោតិភូតំ** គឺភ្លឺទូទៅ អធិប្បាយថា ជាណ្តាតភ្លើងតែម្យ៉ាង ។ បទថា **ឋិតោ ហោតិ** សេចក្តីថា យក្ខឈរនិម្មិតរូបគួរខ្លាចបែបនេះ គឺក្បាលធំ ចង្កូមដូចគ្នានឹងត្រយូងចេក ភ្នែកប្រមុះជាដើមគួរខ្លាច ។ សួរថា ព្រោះហេតុអ្វី ទើបយក្ខនោះមកធ្វើយថា មកដើម្បីឲ្យនិគ្រន្ថធ្វើយនូវការយល់ឃើញ ។ ម្យ៉ាងទៀត សក្កទេវរាជ និងមហាព្រហ្ម យាងមកហើយ កាលព្រះមានព្រះភាគដល់នូវការខ្វល់ខ្វាយតិច ក្នុងការសម្តែងធម៌យ៉ាងនេះថា តថាគតគប្បីសម្តែងធម៌ដល់ជនពួកដទៃ ក៏គប្បីដឹងទូទៅដល់ធម៌របស់តថាគតមិនបាន ទ្រង់បានធ្វើបដិញ្ញាថា បពិត្រព្រះមានព្រះភាគ សូមទ្រង់សម្តែងធម៌ចុះ កាលអាណាចក្រមិនប្រព្រឹត្តទៅដល់ព្រះអង្គ ប្រព្រឹត្តទៅដល់ខ្ញុំព្រះអង្គ ពួកខ្ញុំព្រះអង្គនឹងឲ្យប្រព្រឹត្តទៅ ធម្មចក្រ សូមជារបស់ព្រះអង្គ អាណាចក្រជារបស់ខ្ញុំព្រះអង្គ ដូច្នេះ ។ ព្រោះដូច្នោះ ទ្រង់មកដោយគិតថា ក្នុងថ្ងៃនេះអញនឹងឲ្យសច្ចកនិគ្រន្ថខ្លាច ហើយឲ្យធ្វើយបញ្ហា ដូច្នេះ ។ បទថា **ភគវា ចេវ បស្សតិ សច្ចកោ ច និគន្ថបុត្តោ** សេចក្តីថា បើមនុស្សដទៃគប្បីឃើញហេតុនោះ ហេតុនោះក៏មិនគប្បីធ្ងន់ ។ ជនទាំងឡាយនឹងពោលថា ព្រះសមណគោតមទ្រង់ដឹងហើយ នូវសច្ចកនិគ្រន្ថ មិនធ្លាក់ចុះក្នុងវាទៈរបស់ខ្លួន ទ្រង់នាំយក្ខមកបន្ទាច បន្ទាប់អំពីនោះ សច្ចកនិគ្រន្ថក្រាបទូលហើយ ព្រោះខ្លាច ដូច្នេះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ និងសច្ចកនិគ្រន្ថប៉ុណ្ណោះគប្បី

ឃើញ ។ ព្រោះឃើញយក្ខនោះ ញើសក៏ហូរពេញខ្លួនរបស់សច្ចកនិគ្រន្ថនោះ ខាងក្នុងពោះក៏មានសំឡេងខ្លាំង គាត់គិតថា មនុស្សដទៃឃើញឬទេហ្ន៎ កាល សម្លឹងមើល ក៏មិនមានឃើញនរណាសូម្បីតែព្រឹករោម បន្ទាប់អំពីនោះ ការ ខ្លាចនេះ កើតដល់អញប៉ុណ្ណោះ ទើបគិតថា បើអញពោលថា យក្ខ ពួក មនុស្សគប្បីពោលថា មានភ្នែកតែលោកម្នាក់ឬ លោកម្នាក់ឯងឬឃើញយក្ខ ម្ដេចក៏លោកមិនឃើញយក្ខ មុនត្រូវព្រះសមណគោតមទាញទៅក្នុងការបន្ត នៃវាទៈ បែរជាឃើញក្នុងពេលឥឡូវទៅវិញ សម្គាល់ថា គ្រានេះ ក្នុងទីនេះ អញមិនមានទីពឹង ដទៃក្រៅអំពីព្រះសមណគោតម ព្រោះហេតុនោះ ទើប លោកពោលថា គ្រានោះឯង សច្ចកនិគន្ថបុត្រ ។បេ។ ក្រាបទូលសេចក្ដីនេះ ចំពោះព្រះមានព្រះភាគ ។ បទថា **តាណំ គវេសី** គឺស្វែងរកទីពួន ។ បទ ថា **លេណំ គវេសី** គឺស្វែងរកទីការពារ ។ បទថា **សរណំ គវេសី** គឺស្វែង រកទីរឭក ។ ក្នុងបទថា **តាណំ** ព្រោះអត្ថថា ពួន គឺរក្សា ។ ឈ្មោះថា **លេណំ** ព្រោះអត្ថថា ជាទីកំបាំងនៃជន ។ ឈ្មោះថា **សរណំ** ព្រោះអត្ថថា រឭកបាន អធិប្បាយថា រមែងបៀតបៀន គឺកម្ចាត់ការខ្លាច ។

[ ៣៨ ] បទថា **មនសិការិត្វា** សេចក្ដីថា ធ្វើទុកក្នុងចិត្ត គឺត្រិះរិះ ពិចារណា ។ បទថា **ឯវំ មេ វេទនា ហោតុ** គឺសូមវេទនាជាកុសល ជា សុខ ។ បទថា **ឯវំ មេ សញ្ញា ហោតុ** គឺសូមសញ្ញាជាកុសល ជាសុខ គឺចូរប្រកបដោយសោមនស្ស ។ សូម្បីក្នុងសង្ខារ និងវិញ្ញាណ ក៏មានន័យ ដូច្នេះឯង ។ ឯក្នុងបទថា **មា អហោសិ** នេះ គប្បីជ្រាបដោយការពោល

ផុយគ្នា ។ បទថា **កល្លំ នុ** ប្រែថា សមគួរឬហ្ន៎ ។ បទថា **សមនុបស្សិតុំ** សេចក្តីថា ពិចារណាឃើញដោយតណ្ហា មានះ ទិដ្ឋិ យ៉ាងនេះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ បទថា **នោ ហិទំ ភោ គោតម** បានដល់ សេចក្តីនោះ មិនគួរដល់ព្រះសមណគោតម ។

គ្រូពស់ដែលឈ្លាស ឲ្យពស់នោះចឹកហើយ ដកពិសដែលត្រូវពស់ចឹក យ៉ាងណា ព្រះមានព្រះភាគ ទ្រង់ឲ្យសច្ចកនិគន្ថបុត្រពោលក្នុងបរិស័ទនោះ ដោយមាត់នោះឯងថា ខន្ធ ៥ មិនទៀង ជាទុក្ខ ជាអនត្តាយ៉ាងនោះ ដោយប្រការដូច្នេះ ។ បទថា **ទុក្ខំ អល្លីនោ** សេចក្តីថា ជាប់ គឺចូលដល់នូវសេចក្តីទុក្ខក្នុងបញ្ចក្ខន្ធនេះដោយតណ្ហា និងទិដ្ឋិ ។ បទថា **អជ្ឈោសិតោ** សេចក្តីថា គប្បីជ្រាបដោយអំណាចតណ្ហា និងទិដ្ឋិប៉ុណ្ណោះ ។ ក្នុងបទជាដើមថា **ទុក្ខំ ឯតំ មម** អធិប្បាយថា រមែងពិចារណាឃើញទុក្ខក្នុងបញ្ចក្ខន្ធដោយអំណាចតណ្ហា មានះ និងទិដ្ឋិ ។ បទថា **បរិជានេយ្យ** សេចក្តីថា គប្បីកំណត់ដឹងដោយតីរណបរិញ្ញា ថាមិនទៀង ជាទុក្ខ ជាអនត្តា ។ បទថា **បរិក្ខេបេត្វា** សេចក្តីថា នាំនូវការអស់ ការវិនាស មិនឲ្យកើត ។

[ ៣៩ ] បទថា **ឆវិ** ប្រែថា ជំទង់ ។ បទថា **អកុក្កុដជាតំ** សេចក្តីថា ស្នូលស្នូងមួយ ប្រមាណមួយធ្នាប់ កើតខាងក្នុងវេលាចេញត្រយូង អធិប្បាយថា វៀរស្នូលស្នូងនោះចេញ ។ បទថា **រិត្តោ** គឺទទេ គឺវៀរចាកខ្លឹមខាងក្នុង ឈ្មោះថា **រិត្តោ** ព្រោះទទេ ។ បទថា **អបរទ្ធោ** គឺចាញ់ ។ ព្រះមានព្រះភាគ ទ្រង់ប្រកាសភាពដែលសច្ចកនិគន្ថបុត្រនោះមានមាត់រឹង លុះ

ទ្រង់សង្កត់សង្កិន ទើបត្រាស់ព្រះតម្រាស់នេះថា **ភាសិតា ខោ បន តេ** ដូច្នេះ ។ បានឮថា ក្នុងកាលមុន សច្ចកនិគ្រន្ថនោះ ចូលទៅរកគ្រូទាំង ៦ មានបូរណៈជាដើម តែងសួរបញ្ហា ។ ពួកគ្រូទាំងនោះ មិនអាចឆ្លើយបាន ។ គ្រានោះ គាត់លើកវិប្បការធំ ក្នុងកណ្តាលបរិស័ទរបស់គ្រូទាំងនោះ ហើយក្រោកឡើងចៀសចេញទៅ ប្រកាសជ័យជម្នះ ដោយសម្គាល់ថា អញនឹងបៀតបៀនព្រះសម្មាសម្ពុទ្ធយ៉ាងនោះ ប្រកាសថា

អំបែងក្បាលបែកហើយ ដោយការប្រហារតែម្តង ឮដំដើម
ឈើណា ដើមឈើនេះ មានស្លឹកល្អិត ប្រកបដោយបន្លា
តើជាឈើឈ្មោះអ្វី ។

សច្ចកនិគន្ថបុត្រនេះទល់គ្នានឹងខ្លឹម គឺ សព្វញ្ញុតញ្ញាណ សម្រេចប្រភេទដោយចំពោះ គឺ ព្រះញាណ ទើបបានដឹងភាពដែលព្រះសព្វញ្ញុតញ្ញាណរឹងដូចត្រសេះមានចំពុះទន់ ជ្លាប់ចោះឈើដែលមិនមានខ្លឹម ហើយមកចោះដើមគគីរ ដូច្នោះ ។

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសសេចក្តីនោះ ត្រង់កណ្តាលបរិស័ទរបស់សច្ចកនិគ្រន្ថនោះ ទើបត្រាស់ពាក្យជាដើម **ភាសិតា ខោ បន តេ** ដូច្នេះ ។ ក្នុងបទថា **ឆត្តិ ឃតរហិ** នេះ មិនគួរពោលថា ឈ្មោះថា ញើសក្នុងឧបាទិន្នកសង្ខារមិនមាន បុគ្គលនឹងពោលថា ក្នុងឥឡូវនេះមិនមាន ។ បទថា **សុវណ្ណវណ្ណំ កាយំ វិវរិ** គឺព្រះមានព្រះភាគទ្រង់មិនបើកបង្ហាញព្រះកាយទាំងអស់ ។ ធម្មតាព្រះពុទ្ធទ្រង់ដាក់ក្តុំ ទ្រង់បិទព្រះកាយ សម្តែងធម៌នៅ

ក្នុងបរិស័ទ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចាប់សង្កត់ចីវរត្រង់កឲ្យធ្លាក់ ចុះទៅក្រោមប្រមាណ ៤ ធ្នាប់ ហើយកាលចីវរនោះ ធូរចុះទៅក្រោមហើយ រស្មីមានពណ៌មាសជាវង់ៗ ផ្សាយចេញ ដូចទង់ដែងហូរចេញអំពីឆ្នាំង មាស និងដូចផ្លេកបន្ទោរចេញអំពីវលាហកៈ ពណ៌ក្រហមធ្វើចីវរមហា ខន្ធ ដូចគ្នានឹងស្គរមាសប្រទក្សិណផ្សាយទៅក្នុងអាកាស ។ សួរថា ព្រោះ ហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ធ្វើយ៉ាងនេះ ឆ្លើយថា ដើម្បីបន្ទោបង់នូវ សេចក្តីសង្ស័យរបស់មហាជន ។ ឯមហាជន គប្បីសង្ស័យថា ព្រះសមណ-គោតមត្រាស់ថា ញើសរបស់តថាគតមិនមាន ។ ញើសរបស់សច្ចកនិគន្ថ-បុត្រហូរហូត ដូចញើសរបស់បុគ្គលដែលឡើងគ្រឿងយន្ត ព្រះសមណ-គោតមប្រថាប់គង់ដណ្តប់ចីវរក្រាស់ បុគ្គលណានឹងដឹងបានដូចម្តេចថាញើស ខាងក្នុងនឹងមាន ឬមិនមាន ដូច្នេះ ទើបទ្រង់ធ្វើយ៉ាងនោះ ដើម្បីបន្ទោបង់ សេចកីសង្ស័យរបស់មហាជននោះ ។ បទថា **មង្កុភូតោ** គឺអស់អំណាច ។ បទថា **បត្តក្ខន្ធោ** គឺមានកសំយុង ។ បទថា **អប្បដិភាណោ** គឺមិនជួបវត្ថុ ដែលក្រៃលែងជាង ។ បទថា **និសីទិ** គឺអង្គុយយកដៃ ជើង គូសផែនដី ។

[ ៤០ ] បទថា **ទុម្មុខោ** សេចក្តីថា មានមុខមិនគួរស្អប់ ពិតហើយ លិច្ឆវិបុត្រនោះមានរូបស្អាត គួរជ្រះថ្លា ឈ្មោះរបស់គេយ៉ាងនោះ ។ បទថា **អភព្វោ តំ បោក្ខរណឹ បុន ឱតរិតុំ** លោកសម្តែងថា ក្តាម ឈ្មោះថា ដើរមិនបាន ព្រោះជង្គៀបបាក់អស់ មិនអាចចុះកាន់ស្រះបោក្ខរណីនោះបាន ទើបធ្លាក់ជាចំណីរបស់ក្អែក និងស្មាំងជាដើម ក្នុងទីនោះឯង ។ បទថា **វិសូ-**

**កាយិកានិ** គឺទិដ្ឋិដែលជាបន្ទា ។ បទថា **វិសេវិតានិ** គឺប្រព្រឹត្តដោយទិដ្ឋិ ។ បទថា **វិប្ផន្ទិតានិ** គឺអន្ទះអន្ទែងដោយទិដ្ឋិ ។ បទថា **យទិទំ** ក្នុងបទថា **យទិទំ វាទាធិប្បាយោ** នេះ ត្រឹមតែជានិបាត ។ លោកសម្តែងថា ជាការចន្ទុលបង្ហាញវាទៈ មិនគួរចូលទៅគាល់តាមអធ្យាស្រ័យថា អញនឹងលើកវាទៈ តែគួរចូលទៅគាល់ដើម្បីស្តាប់ធម៌ ។ សួរថា បទថា **ទុម្មុខំ លិច្ឆវិបុត្តំ ឯតទវោច** សច្ចកនិគន្ថបុត្របានពោលហើយ ព្រោះហេតុអ្វី ឆ្លើយថា បានឮថា ក្នុងវេលាលិច្ឆវិបុត្រ ឈ្មោះទុម្មុខនោះនាំយកឧបមាមក សូម្បីលិច្ឆវីកុមារដ៏សេស គិតហើយថា និគ្រន្ថនេះធ្វើនូវការមើលងាយ ពួកយើងក្នុងទីដែលរៀនសិប្បៈរបស់ពួកយើងមកយូរហើយ ឥឡូវនេះ ដល់ពេលដែលនឹងឃើញខ្នងសត្រូវ សូម្បីខ្ញុំក៏សូមនាំឧបមាមួយមក នឹងធ្វើសច្ចកនិគ្រន្ថនោះ ដែលធ្លាក់ទៅដោយកណ្តាប់ដៃ ដូចវាយដោយដំបង ដោយប្រការដែលសច្ចក-និគ្រន្ថមិនអាចងើបក្បាលឡើង ក្នុងកណ្តាលបរិស័ទបានទៀត ។ លិច្ឆវីទាំងនោះធ្វើឧបមាទាំងឡាយហើយ អង្គុយរង់ចាំទុម្មុខៈពោលចប់ សច្ចកនិគ្រន្ថដឹងបំណងរបស់លិច្ឆវីទាំងនោះ ទើបគិតថា លិច្ឆវីទាំងអស់នេះ លូកមាត់លូក-ករំពង បើពួកលិច្ឆវីបាននាំឧបមាមកតែមួយ អញនឹងមិនអាចងើបក្បាលឡើងក្នុងបរិស័ទទៀត ណ្ហើយចុះ អញនឹងរុករកទុម្មុខៈ ហើយកាត់នូវវារៈនៃពាក្យសម្តី ដោយប្រការដែលអ្នកដទៃមិនមានឱកាសនឹងទូលសួរបញ្ហាជាមួយព្រះសមណគោតម ព្រោះដូច្នោះ ទើបពោលពាក្យនោះ ។ ក្នុងបទទាំងនោះ បទថា **អាគមេហិ** ប្រែថា ឈប់សិន អធិប្បាយថា កុំកាន់យក

ទៀត ។ បទថា **តិដ្ឋតេសា ភោ គោតម** សេចក្ដីថា ព្រះគោតមដ៏ចម្រើន វាចានេះរបស់ខ្ញុំព្រះអង្គ និងរបស់សមណព្រាហ្មណ៍ដ៏ច្រើនពួកដទៃ សូមលើកទុកសិនចុះ ។ បទថា **វិលាបំ វិលបិតំ មញ្ញេ** សេចក្ដីថា ពាក្យនេះ ជាពាក្យមិនបានការ អធិប្បាយថា គ្រាន់តែពោលទៅទេ ។ម្យ៉ាងទៀត គួរនាំបទថា **កថា** មកពោលក្នុងបទនេះថា **តិដ្ឋតេសា** ។ ឯក្នុងបទថា **វាចា-វិលាបំ វិលបិតំ មញ្ញេ** នេះ មានអធិប្បាយថា ការបន្ទឺវាចានេះគ្រាន់តែជាការពោលៗ ទៅទេ ។

[ ៤១ ] ឥឡូវនេះ សច្ចកនិគន្ថបុត្រ កាលទូលសួរបញ្ហា ទើបពោលពាក្យជាដើមថា **តិដ្ឋតុ វតា** ។ បណ្ដាបទទាំងនោះ បទថា **វេសារជ្ជប្បត្តោ** គឺសម្រេចញាណ ។ បទថា **អបរប្បច្ចយោ** គឺមិនត្រូវជឿអ្នកដទៃ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់ឆ្លើយបញ្ហាដល់សច្ចកនិគន្ថបុត្រនោះ ទើបត្រាស់ពាក្យថា **ឥធ អគ្គិវេស្សន** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ទាំងអស់ហើយ ។

[ ៤២ ] ព្រោះសេក្ខភូមិ ទ្រង់សម្ដែងហើយ ព្រោះត្រាស់ថា **បស្សតិ** ក្នុងបទនេះ ដូច្នោះ កាលទូលសេក្ខភូមិឲ្យក្រៃលែងឡើងទៅ ទើបទូលសួរបញ្ហាប្រការទី ២ ហើយ ។ ព្រះមានព្រះភាគ ទ្រង់ឆ្លើយចន្លុលបង្ហាញបញ្ហានោះដល់គេ ។ បណ្ដាបទទាំងនោះ បទថា **ទស្សនានុត្តរិយំ** ក្នុងបទជាដើមថា **ទស្សនានុត្តរិយេន** បានដល់ បញ្ញាដែលជាលោកិយ និងលោកុត្តរ ។ បទថា **បដិបទានុត្តរិយំ** បានដល់ បដិបទាដែលជាលោកិយ និងលោកុត្តរ ។ បទ

ថា **វិមុត្តានុត្តរិយំ** គឺលោកុត្តរវិមុត្តិ ។ ម្យ៉ាងទៀត បទថា **ទស្សនានុត្តរិយំ** គឺសម្មាទិដ្ឋិដែលជាអរហត្តមគ្គ ព្រោះសំដៅដល់លោកុត្តរធម៌សុទ្ធ ។ បទថា **បដិបទានុត្តរិយំ** គឺអដ្ឋមគ្គដ៏សេស ។ បទថា **វិមុត្តានុត្តរិយំ** គឺវិមុត្តិជាមគ្គផល ។ ការឃើញនិព្វាននៃព្រះខីណាស្រព ឈ្មោះថា ទស្សនានុត្តរិយៈ ។ អដ្ឋមគ្គ ៨ ជាបដិបទានុត្តរិយៈ ។ មគ្គផល គប្បីជ្រាបថា ជាវិមុត្តានុត្តរិយៈ ។ បទថា **ពុទ្ធោ សោ ភគវា** សេចក្តីថា ព្រះមានព្រះភាគអង្គនោះត្រាស់ដឹងហើយនូវសច្ចៈ ៤ ដោយព្រះអង្គឯង ។ បទថា **ពោធាយ** សេចក្តីថា ទ្រង់សម្តែងធម៌ដល់សត្វដទៃ ដើម្បីឲ្យត្រាស់ដឹងសច្ចៈ ៤ ។ បទថា **ទន្តោ** ក្នុងបទជាដើមថា **ទន្តោ** គឺអស់ព្យសន៍ ។ បទថា **ទមថាយ** គឺដើម្បីត្រូវការអស់ព្យសន៍ ។ បទថា **សន្តោ** គឺទ្រង់ស្ងប់ហើយ ដោយការចូលទៅស្ងប់កិលេសទាំងពួង ។ បទថា **សមថាយ** គឺដើម្បីស្ងប់កិលេស ។ បទថា **តិណ្ណោ** គឺឆ្លងឱឃៈ ៤ ។ បទថា **តរណាយ** គឺដើម្បីឆ្លងឱឃៈ ៤ ។ បទថា **បរិនិព្វុតោ** សេចក្តីថា ទ្រង់រម្ងត់ស្និទ្ធហើយ ដោយការរម្ងត់ឥតសេសសល់នៃកិលេស ។ បទថា **បរិនិព្វានាយ** សេចក្តីថា ទ្រង់សម្តែងធម៌ដើម្បីការរម្ងត់ឥតសេសសល់នៃកិលេស ។

[ ៤៣ ] បទថា **ធំសី** គឺបុគ្គលកម្ចាត់គុណ ។ បទថា **បគព្ភា** គឺប្រកបដោយការឃ្នើសឃ្នងដោយវាចា ។ បទថា **អាសាទេតព្វំ** គឺគប្បីចាក់ដោត ។ បទថា **អាសជ្ជ** គឺសង្កត់សង្កិន ។ បទថា **ន ត្វេវ ភវន្តំ គោតមំ** លោកសម្តែងថា អស់កម្លាំងដើម្បីកាន់យកវាទៈរបស់ខ្លួន ទៅទ្រគោះបោះ

បោកដល់បុគ្គលណាមួយឡើយ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើអន្តរាយជីវិតបុគ្គលណាមួយ ដូចដីរជាដើមក៏ទេ ។ តែនិគ្រន្ថនេះនាំឧបមាទាំង ៣ នេះមកហើយ ដើម្បីលើកព្រះមានព្រះភាគក៏ទេ នាំមកដើម្បីលើកខ្លួនប៉ុណ្ណោះក៏ទេ ប្រៀបដូចព្រះរាជាបង្ក្រាបសត្រូវពួកខ្លះបានហើយ កាលទ្រង់សរសើរសត្រូវថា អ្នកក្លាហានយ៉ាងនេះ នឹងជាបុគ្គលដល់ព្រមដោយកម្លាំងយ៉ាងនេះ ។ ក៏សរសើរខ្លួននោះឯង យ៉ាងណា សច្ចកនិគន្ថបុត្រនេះក៏ដូច្នោះ កាលលើកវាទៈព្រះមានព្រះភាគដោយពាក្យជាដើមថា **សិយា ហិ ភោ គោតម ហត្ថិំ បភិន្នំ** រមែងលើកខ្លួនប៉ុណ្ណោះថា អ្នកជាអ្នកក្លាហាន អញជាបណ្ឌិត អញជាពហូសូត ជាអ្នកត្រូវលើកវាទៈ ចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ ដូចដីរចុះប្រេង ដូចគំនរភ្លើងឆេះសន្ធោសន្ធៅ និងដូចអាសិរពិសបើកពពារដូច្នេះ ។

កាលលើកខ្លួនយ៉ាងនេះហើយ កាលនិមន្តព្រះមានព្រះភាគ ទើបក្រាបទូលពាក្យជាដើមថា **អធិវាសេតុ មេ** ។ បណ្តាបទទាំងនោះ បទថា **អធិវាសេតុ** គឺសូមព្រះអង្គទទួលចុះ ។ បទថា **ស្វាតនាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់បុណ្យ និងដើម្បីបីតិបាមោជ្ជដែលនឹងមានក្នុងថ្ងៃស្អែកនេះដល់ខ្ញុំព្រះអង្គដែលធ្វើនូវសក្ការៈក្នុងព្រះអង្គ ។ បទថា **អធិវាសេសិ ភគវា តុណ្ហីភាវេន** អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់មិនឲ្យអវយវៈដែលជាចំណែកកាងកាយ និងព្រះវាចាកម្រើក ទ្រង់ទទួលទុកចំពោះខាងក្នុង ទ្រង់ទទួលហើយដោយតុណ្ហីភាព ។ គឺទ្រង់ទទួលដោយព្រះហឫទ័យ ដើម្បីធ្វើការអនុគ្រោះដល់សច្ចកនិគន្ថបុត្រ ដូច្នេះ ។

បទថា **យមស្ស បដិរូបំ មញ្ញេយ្យាថ** សេចក្តីថា បានឮថា ស្តេចលិច្ឆវីទាំងនោះ នាំថាស ៥០០ សម្រាប់ទៅឲ្យដល់សច្ចកនិគន្ថបុត្រនោះជានិច្ច សច្ចកនិគន្ថបុត្រសំដៅយកភត្តនោះឯង ទើបពោលថា ថ្ងៃស្អែកនេះ ពួកអ្នកគួរសម្គាល់ថា វត្ថុដែលសមគួរ ទើបជារបស់គួរថ្វាយដល់ព្រះសមណ-គោតម គួរនាំរបស់ដែលសមគួរនោះមក ពួកអ្នកជាអ្នកប្រតិបត្តិ រមែងយល់ដល់វត្ថុដែលគួរ មិនគួរ សម មិនសម សម្រាប់ព្រះសមណគោតម ។ បទថា **ភត្តាភិហារំ អភិហរឹសុ** សេចក្តីថា នាំភត្តដែលគួរនាំទៅ ។

[ ៤៤ ] បទថា **បណីតេន** គឺឧត្តម ។ បទថា **សហត្ថា** គឺដោយដៃរបស់ខ្លួន ។ បទថា **សន្តប្បេត្វា** សេចក្តីថា ឆ្អែតល្អ គឺអង្គាសឲ្យឆ្អែតស្កប់ស្កល់ បរិបូណ៌តាមសេចក្តីត្រូវការ ។ បទថា **សម្បវារេត្វា** គឺបវារណាល្អ គឺហាមដោយហត្ថសញ្ញាថា បានហើយ បានហើយ ដូច្នេះ ។ បទថា **ភុត្តាវី** គឺសោយ ។ បទថា **ឱនីតបត្តបាណឹ** គឺដកព្រះហស្តចេញអំពីបាត្រ អធិប្បាយថា គឺនាំព្រះហស្តចេញហើយ ។ បាលីថា **ឱនិត្តបត្តបាណឹ** ដូច្នេះក៏មាន ។ បទនោះ មានសេចក្តីថា ឈ្មោះថា **ឱនិត្តបត្តបាណឹ** ព្រោះអត្ថថា មានបាត្រនាំចេញហើយអំពីដៃ អធិប្បាយថា ព្រះមានព្រះភាគនោះ មានបាត្រដែលនាំចេញហើយអំពីព្រះហស្ត គឺទ្រង់ជម្រះព្រះហស្ត និងបាត្រ ទ្រង់រក្សាបាត្រទុកក្នុងទីសមគួរទាចំណែកម្ខាង ហើយប្រថាប់គង់ ។ បទថា **ឯកមន្តំ និសីទិ** សេចក្តីថា សច្ចកនិគ្រន្ថដឹងនូវព្រះមានព្រះភាគសោយហើយយ៉ាងនេះ ទើបអង្គុយក្នុងឱកាសមួយ ។ បទថា **បុញ្ញញ្ច** គឺបុណ្យក្នុងទាននេះ អធិប្បាយថា

ជាវិបាកក្ខន្ធតទៅ ។ បទថា **បុញ្ញម្ហិ** សេចក្តីថា ជាបរិវារចំពោះវិបាកក្ខន្ធ ។ បទថា **តំ ទាយកានំ សុខាយ ហោតុ** សេចក្តីថា បុណ្យនោះ ចូរមានដើម្បីប្រយោជន៍ដល់ស្តេចលិច្ឆវីទាំងនេះ ។

បានឮថា និគ្រន្ថនោះ កាលនឹងប្រគល់ទាននេះដល់ស្តេចលិច្ឆវីទាំងនោះ ទើបពោលយ៉ាងនេះថា យើងជាបព្វជិត មិនគួរឲ្យទានរបស់ខ្លួន ។ លំដាប់នោះ ព្រះមានព្រះភាគ ព្រោះបុណ្យស្តេចលិច្ឆវីឲ្យដល់សច្ចកនិគ្រន្ថ មិនឲ្យព្រះមានព្រះភាគ ឯសច្ចកនិគ្រន្ថថ្វាយដល់ព្រះមានព្រះភាគ ដូច្នោះ កាលទ្រង់សម្តែងអត្ថនោះ ទើបត្រាស់ពាក្យថា **យំ ខោ អគ្គិវេស្សន** ដូច្នេះជាដើម ។ ព្រះមានព្រះភាគ ទ្រង់ប្រគល់ទក្ខិណាដែលគេថ្វាយដល់ព្រះអង្គ ដល់និគ្រន្ថ ដើម្បីរក្សាទឹកចិត្ត ទក្ខិណានោះ ក៏នឹងជាវាសនាក្នុងអនាគត ដោយប្រការដូច្នេះឯង ៗ។៙

**ចូឡសច្ចកសូត្រ ចប់**

**សូត្រទី ៥ ចប់**

# សុត្តន្តបិដក

## មហាសច្ចកសូត្រទី ៦

[ ៨៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ទៀបក្រុងវេសាលី ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ដោយល្អ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចពុទ្ធដំណើរចូលទៅក្នុងក្រុងវេសាលីដើម្បីបិណ្ឌបាត ។ គ្រានោះ សច្ចកនិគន្ថបុត្រ កំពុងចង្ក្រម កំពុងត្រាច់ទៅដោយលំដាប់ៗ ដើម្បីសម្រាកស្មង ហើយចូលទៅកាន់កូដាគារសាលា នាមហាវ័ននោះ ។ ព្រះអានន្ទមានអាយុ បានឃើញសច្ចកនិគន្ថបុត្រ កំពុងតែដើរមកអំពីចម្ងាយ លុះបានឃើញហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សច្ចកនិគន្ថបុត្រនេះ ជាអ្នកពោលតិរច្ឆានកថា ជាអ្នកពោលថាខ្លួនជាអ្នកប្រាជ្ញ ជនច្រើននាក់សន្មតគាត់ថា ជាអ្នកត្រឹមត្រូវ ឥឡូវនេះកំពុងដើរមក បពិត្រព្រះអង្គដ៏ចម្រើន សច្ចកនិគន្ថបុត្រនេះ ជាអ្នកប្រាថ្នារកទោសព្រះពុទ្ធ ប្រាថ្នារកទោសព្រះធម៌ ប្រាថ្នារកទោសព្រះសង្ឃ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់គង់មួយរំពេច អាស្រ័យសេចក្តីអនុគ្រោះ ។ ព្រះមានព្រះភាគទ្រង់គង់លើអាសនៈដែលគេតាក់តែងហើយ ។ គ្រានោះ សច្ចកនិគន្ថបុត្រ ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ មួយអន្លើដោយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។

[ ៤៦ ] លុះសច្ចកនិគន្ថបុត្រ អង្គុយនៅក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន មានសមណព្រាហ្មណ៍ពួកមួយ ខ្វល់ខ្វាយក្នុងការប្រកបរឿយៗ នូវកាយភាវនា ( វិបស្សនា ) មិនបានខ្វល់ខ្វាយក្នុងការប្រកបរឿយៗ នូវចិត្តភាវនា ( សមថៈ ) ឡើយ ។ បពិត្រព្រះគោតមដ៏ចម្រើន សមណព្រាហ្មណ៍ទាំងនោះ តែងបាននូវទុក្ខវេទនា ដែលកើតឡើងក្នុងសរីរៈ ។ បពិត្រព្រះគោតមដ៏ចម្រើន រឿងរ៉ាវធ្លាប់មានមកថា បុគ្គលដែលមានទុក្ខវេទនា កើតឡើងក្នុងសរីរៈពាល់ត្រូវហើយ នឹងត្រឡប់ទៅជាមនុស្សរឹងភ្លៅក៏មាន បេះដូងនឹងបែកធ្លាយក៏មាន ឈាមក្តៅនឹងក្អួតចេញអំពីមាត់ក៏មាន សមណព្រាហ្មណ៍ទាំងនោះ នឹងដល់នូវកិរិយាឆ្កួតវង្វេងចិត្តក៏មាន ។ បពិត្រព្រះគោតមដ៏ចម្រើន ចិត្តនុ៎ះ របស់បុគ្គលនោះឯង រមែងប្រព្រឹត្តទៅតាមកាយ តែងប្រព្រឹត្តទៅដោយអំណាចនៃកាយ សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះថា បុគ្គលនោះមិនបានអប់រំចិត្ត ។ បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត មានសមណព្រាហ្មណ៍ពួកមួយ បានខ្វល់ខ្វាយក្នុងការប្រកបរឿយៗ នូវចិត្តភាវនា មិនបានខ្វល់ខ្វាយក្នុងការប្រកបរឿយៗ នូវកាយភាវនាឡើយ ។ បពិត្រព្រះគោតមដ៏ចម្រើន ក៏សមណព្រាហ្មណ៍ទាំងនោះ តែងបាននូវទុក្ខវេទនា ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ បពិត្រព្រះគោតមដ៏ចម្រើន រឿងរ៉ាវធ្លាប់មានមកថា បុគ្គលដែលមានទុក្ខវេទនាប្រព្រឹត្តទៅក្នុងចិត្ត ពាល់ត្រូវហើយ នឹងត្រឡប់ទៅជាមនុស្សរឹងភ្លៅក៏មាន បេះដូងនឹងបែកធ្លាយក៏មាន ឈាមក្តៅនឹងក្អួតចេញអំពីមាត់ក៏មាន សមណព្រាហ្មណ៍

ទាំងនោះ នឹងដល់នូវកិរិយាឆ្កួតវង្វេងវង្វាន់ចិត្តក៏មាន ។ បពិត្រព្រះគោតមដ៏ចម្រើន កាយនុ៎ះ របស់បុគ្គលនោះឯង រមែងប្រព្រឹត្តទៅតាមចិត្ត តែងប្រព្រឹត្តទៅដោយអំណាចនៃចិត្ត សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះថា បុគ្គលនោះមិនបានអប់រំកាយ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គគិតយ៉ាងនេះថា សាវកទាំងឡាយរបស់ព្រះគោតមដ៏ចម្រើន តែងខ្វល់ខ្វាយក្នុងការប្រកបរឿយៗ នូវចិត្តភាវនា តែមិនបានខ្វល់ខ្វាយក្នុងការប្រកបរឿយៗ នូវកាយភាវនាឡើយ ។

[ ៤៧ ] ម្នាលអគ្គិវេស្សនៈ ចុះកាយភាវនា អ្នកបានឮមកដូចម្តេច ។ សច្ចកនិគន្ថបុត្រ ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន អចេលកទាំងនេះ គឺនន្ទវច្ឆៈ ១ កិសសង្កិច្ចៈ ១ មក្ខលិគោសាល ១ ជាអ្នកប្រព្រឹត្តលះបង់មារយាទល្អ ស៊ីលិទ្ធដៃ គេហៅថា អ្នកដ៏ចម្រើនចូរមក ក៏មិនព្រមមក គេឃាត់ថា អ្នកដ៏ចម្រើនឈប់សិន ក៏មិនព្រមឈប់ មិនត្រេកអរនឹងចង្ហាន់ដែលគេនាំមកមុន មិនត្រេកអរនឹងចង្ហាន់ដែលគេនាំមកចំពោះខ្លួន មិនត្រេកអរនឹងកិច្ចនិមន្ត អចេលកទាំងនុ៎ះ មិនទទួលចង្ហាន់ ដែលគេនាំចេញអំពីមាត់ឆ្នាំងហើយឲ្យ មិនទទួលចង្ហាន់ដែលគេនាំចេញអំពីមាត់កញ្ឆែហើយឲ្យ មិនទទួលចង្ហាន់ដែលគេដើរកន្លងធរណីទ្វារ ហើយនាំមកឲ្យ មិនទទួលចង្ហាន់ដែលគេដើរកន្លងកំណាត់ឈើហើយនាំមកឲ្យ មិនទទួលចង្ហាន់ដែលគេដើរកន្លងអង្រែហើយនាំមកឲ្យ មិនទទួលចង្ហាន់អំពីដៃមនុស្សពីរនាក់កំពុងបរិភោគ មិនទទួលចង្ហាន់អំពីដៃស្រីមានគភ៌ មិនទទួលចង្ហាន់អំពីដៃស្រីដែលកំពុងបំបៅកូន មិន

ទទួលចង្ហាន់អំពីដៃស្រី ដែលកំពុងកាន់បុរសជាទៃ មិនទទួលចង្ហាន់ក្នុងកន្លែងដែលវេវត្ថុបានមក មិនទទួលចង្ហាន់ក្នុងកន្លែងដែលមានឆ្កែនៅចាំ មិនទទួលចង្ហាន់ត្រង់កន្លែងដែលមានរុយរោមទាំងហ្វូង មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកថ្នាំត្រាំ មួយទៀត អចេលក៍ទាំងនោះ ទទួលចង្ហាន់ចំពោះតែក្នុងផ្ទះមួយ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបាយតែមួយដុំខ្លះ ទទួលចង្ហាន់ចំពោះតែក្នុងផ្ទះពីរ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបាយតែពីរដុំខ្លះ ។បេ។ ទទួលចង្ហាន់ចំពោះតែក្នុងផ្ទះ ៧ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបាយ ៧ ដុំខ្លះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចង្ហាន់ ក្នុងភាជន៍តូចមួយខ្លះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចង្ហាន់ក្នុងភាជន៍តូចពីរខ្លះ ។បេ។ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចង្ហាន់ក្នុងភាជន៍តូច ៧ ខ្លះ ស៊ីអាហារខានមួយថ្ងៃខ្លះ ស៊ីអាហារខានពីរថ្ងៃខ្លះ ។បេ។ ស៊ីអាហារខាន ៧ ថ្ងៃខ្លះ តែងខ្វល់ខ្វាយក្នុងការប្រកបរឿយៗ នូវការបរិភោគបាយផ្លាស់ប្តូរថ្ងៃអស់កន្លះខែមានសភាពយ៉ាងនេះដូច្នេះខ្លះ ។ នៃអគ្គិវេស្សនៈ អចេលក៍ទាំងនោះ តែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្ត ដោយហេតុមានប្រមាណតែប៉ុណ្ណោះឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនមែនមានតែប៉ុណ្ណោះទេ បពិត្រព្រះគោតមដ៏ចម្រើន អចេលក៍ទាំងនោះ ចួនកាលទំពាស៊ីនូវខាទនីយៈទាំងឡាយដ៏ឧត្តមក្រៃលែង បរិភោគនូវភោជនទាំងឡាយ ដ៏ឧត្តមក្រៃលែង ក្រេបជញ្ជាបនូវសាយនីយៈទាំងឡាយដ៏ឧត្តមក្រៃលែង ផឹកនូវទឹកទាំងឡាយដ៏ឧត្តមក្រៃលែង អចេលក៍ទាំងនោះ ឈ្មោះថា ញ៉ាំងកាយនេះឲ្យកាន់យកនូវកម្លាំង ឲ្យចម្រើន

ឲ្យជាត់ជំ ។ ម្នាលអគ្គិវេស្សនៈ ត្រង់ដែលអចេលក៍ទាំងនោះលះបង់នូវអំពើកម្រក្នុងកាលមុន ហើយសន្សំនូវវត្ថុ មានខាទនីយៈជាដើម ក្នុងកាលជាខាងក្រោយ កាលបើធ្វើយ៉ាងនេះ ការចម្រើន និងការមិនចម្រើនរបស់កាយនេះតែងតែមាន ។

[ ៤៨ ] ម្នាលអគ្គិវេស្សនៈ ចុះចំណែកខាងចិត្តភាវនា អ្នកបានឮមកដូចម្តេច ។ សច្ចកនិគន្ថបុត្រ កាលព្រះមានព្រះភាគទ្រង់សួរហើយ ក្នុងចិត្តភាវនា ក៏មិនអាចនឹងដោះស្រាយបាន ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះ នឹងសច្ចកនិគន្ថបុត្រថា នែអគ្គិវេស្សនៈ កាយភាវនាណា ដែលអ្នកបានអប់រំហើយ ក្នុងកាលមុន កាយភាវនានោះមិនប្រកបដោយធម៌ ក្នុងអរិយវិន័យទេ ម្នាលអគ្គិវេស្សនៈ អ្នកមិនអាចដឹងសូម្បីនូវកាយភាវនា តើនឹងអាចដឹងនូវចិត្តភាវនាដូចម្តេចបាន ម្នាលអគ្គិវេស្សនៈ ក៏ឯបុគ្គលមិនបានអប់រំកាយផង មិនបានអប់រំចិត្តផង បុគ្គលបានអប់រំកាយផង បានអប់រំចិត្តផង ដោយប្រការណា អ្នកចូរស្តាប់នូវប្រការនោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែងឥឡូវនេះ ។ សច្ចកនិគន្ថបុត្រ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ៤៩ ] ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាថា នែអគ្គិវេស្សនៈ បុគ្គលដែលមិនបានអប់រំកាយផង មិនបានអប់រំចិត្តផង តើដូចម្តេច ។ នែអគ្គិវេស្សនៈ សុខវេទនាតែងកើតឡើងដល់បុគ្គលជាបុថុជ្ជន ដែលមិនចេះដឹងក្នុងលោកនេះ បុគ្គលជាបុថុជ្ជននោះ លុះសុខវេទនាពាល់ត្រូវហើយ ក៏មានតម្រេកខ្លាំងក្នុង

សេចក្តីសុខផង តែងដល់នូវតម្រេកខ្លាំងដោយសេចក្តីសុខផង បើសុខវេទនានោះ របស់បុគ្គលជាបុថុជ្ជននោះរលត់ទៅ ទុក្ខវេទនាក៏កើតឡើង ព្រោះរលត់ទៅនៃសុខវេទនា បុគ្គលជាបុថុជ្ជននោះ លុះទុក្ខវេទនាពាល់ត្រូវហើយ តែងសៅសោក លំបាកខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេង នៃអគ្គិវេស្សនៈ សុខវេទនានេះរបស់បុគ្គលជាបុថុជ្ជននោះ ដែលកើតឡើងហើយ តែងគ្របសង្កត់ចិត្ត ព្រោះមិនបានអប់រំកាយផង ទុក្ខវេទនាដែលកើតឡើងហើយ តែងគ្របសង្កត់ចិត្ត ព្រោះមិនបានអប់រំចិត្តផង នៃអគ្គិវេស្សនៈ សុខវេទនារបស់បុគ្គលណានីមួយ ដែលកើតឡើងហើយ ដោយចំណែកទាំងពីរយ៉ាងនេះ តែងគ្របសង្កត់ចិត្ត ព្រោះមិនបានអប់រំកាយផង ទុក្ខវេទនាដែលកើតឡើងហើយ តែងគ្របសង្កត់ចិត្ត ព្រោះមិនបានអប់រំចិត្តផង នៃអគ្គិវេស្សនៈ បុគ្គលមិនបានអប់រំកាយផង មិនបានអប់រំចិត្តផងយ៉ាងនេះឯង ។ នៃអគ្គិវេស្សនៈ បុគ្គលដែលបានអប់រំកាយផង បានអប់រំចិត្តផង តើដូចម្តេច ។ នៃអគ្គិវេស្សនៈ សុខវេទនាតែងកើតឡើងដល់បុគ្គលជាអរិយសាវក ជាអ្នកចេះដឹងក្នុងលោកនេះ បុគ្គលជាអរិយសាវកនោះ លុះសុខវេទនាពាល់ត្រូវហើយ ក៏មិនមានតម្រេកខ្លាំងក្នុងសេចក្តីសុខ មិនដល់នូវតម្រេកខ្លាំង ដោយសេចក្តីសុខឡើយ សុខវេទនានោះ របស់អរិយសាវកនោះរលត់ទៅ ទុក្ខ-វេទនាក៏កើតឡើង ព្រោះរលត់ទៅនៃសុខវេទនា អរិយសាវកនោះ លុះទុក្ខ-វេទនាពាល់ត្រូវហើយ ក៏មិនសោកសៅ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងកន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេងឡើយ នៃអគ្គិវេស្សនៈ សុខវេទនា

នោះរបស់អរិយសាវកនោះ ដែលកើតឡើងហើយ មិនគ្របសង្កត់ចិត្ត ព្រោះបានអប់រំកាយផង ទុក្ខវេទនាដែលកើតឡើងហើយ មិនគ្របសង្កត់ចិត្ត ព្រោះបានអប់រំចិត្តផង យ៉ាងនេះឯង នែអគ្គិវេស្សនៈ សុខវេទនារបស់បុគ្គលណាមួយ ដែលកើតឡើងហើយ ដោយចំណែកទាំងពីរ មិនបានគ្របសង្កត់ចិត្ត ព្រោះបានអប់រំកាយផង ទុក្ខវេទនាដែលកើតឡើងហើយ ក៏មិនបានគ្របសង្កត់ចិត្ត ព្រោះបានអប់រំចិត្តផង នែអគ្គិវេស្សនៈ បុគ្គលដែលបានអប់រំកាយផង បានអប់រំចិត្តផង យ៉ាងនេះឯង ។ សច្ចកនិគន្ថបុត្រ ក្រាបទូលថា ខ្ញុំព្រះអង្គជ្រះថ្លា ចំពោះព្រះគោតមដ៏ចម្រើនយ៉ាងនេះ ព្រោះថា ព្រះគោតមដ៏ចម្រើន បានអប់រំកាយផង បានអប់រំចិត្តផង ។

[ ៥០ ] នែអគ្គិវេស្សនៈ វាចាដែលអ្នកពោលហើយនេះ ជាវាចាតន្ទូវគុណ បង្អោនទៅរកគុណ ពិតណាស់ហើយ ប៉ុន្តែ តថាគតនឹងដោះស្រាយប្រាប់អ្នក នែអគ្គិវេស្សនៈ កាលដែលតថាគតកោរសក់ និងពុកមាត់ ពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះ ហើយចូលមកកាន់ផ្នួស សុខវេទនាដែលកើតឡើងហើយ នឹងគ្របសង្កត់ចិត្ត របស់តថាគតនោះក្តី ទុក្ខវេទនាដែលកើតឡើងហើយ នឹងគ្របសង្កត់ចិត្តក្តី ហេតុនេះមិនមានឡើយ ។ សច្ចកនិគន្ថបុត្រទូលសួរដូច្នេះថា សុខវេទនាមានសភាពយ៉ាងណា ដែលកើតឡើងហើយ គប្បីគ្របសង្កត់ចិត្ត ក្រែងសុខវេទនាមានសភាពដូច្នោះ មិនធ្លាប់កើតឡើងដល់ព្រះគោតមដ៏ចម្រើនទេដឹង ទុក្ខវេទនាមានសភាពយ៉ាងណា ដែលកើតឡើងហើយ គប្បីគ្របសង្កត់ចិត្ត ក្រែងទុក្ខវេទនាមានសភាព

ដូច្នោះ មិនធ្លាប់កើតឡើងដល់ព្រះគោតមដ៏ចម្រើនទេដឹង ។

[ ៥១ ] នែអគ្គិវេស្សនៈ ហេតុនោះប្ញីក៏មិនមាន នែអគ្គិវេស្សនៈ ក្នុងកាលមុនអំពីការត្រាស់ដឹង តថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ នៅក្នុងទីឯណោះ មានសេចក្តីត្រិះរិះដូច្នេះថា ការនៅគ្រប់គ្រងផ្ទះ ជាគ្រឿងចង្អៀតចង្អល់ ជាផ្លូវប្រកបដោយធូលី ឯបព្វជ្ជាជាទីឱកាសទំនេរ បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធដោយចំណែកមួយ ដូចស័ង្ខដែលបុគ្គលខាត់ហើយទេ បើដូច្នោះ មានតែអាត្មាអញកោរសក់ និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះបួលទៅកាន់ផ្នួស ។ នែអគ្គិវេស្សនៈ សម័យជាខាងក្រោយ កាលដែលតថាគតនៅជាកំលោះ មានសក់ខ្មៅស្រិល ប្រកបដោយវ័យដ៏ចម្រើន គឺបឋមវ័យ កាលដែលមាតា និងបិតាទាំងឡាយ មិនត្រូវការឲ្យចេញទៅបួស មានព្រះភក្រ្តទទឹកដោយព្រះអស្សុ ទ្រង់ព្រះកន្សែង ក៏នៅតែកោរសក់ និងពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយចេញចាកផ្ទះ បួលមកកាន់ផ្នួស ។ លុះតថាគតបួសរួចហើយ ក៏ស្វែងរកកីកុសល ស្វែងរកសន្តិវរបទ គឺព្រះនិព្វាន ជាគ្រឿងរម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេសដ៏ប្រសើរ ហើយចូលទៅរកអាឡារតាបសកាលាមគោត្រ លុះចូលទៅដល់ហើយ បាននិយាយដូច្នេះ នឹងអាឡារតាបសកាលាមគោត្រថា ម្នាលអាវុសោកាលាមៈ ខ្ញុំប្រាថ្នានឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងធម្មវិន័យនេះ ។ ម្នាលអគ្គិវេស្សនៈ កាលតថាគតបាននិយាយយ៉ាងនេះហើយ ទើបអាឡារ-

កាលាមតាបស ពោលដូច្នេះវិញនឹងតថាគតថា អ្នកមានអាយុចូរនៅចុះ នេះធម៌ដែលប្រាកដដូចជាអ្នកត្រូវការនោះ ជាធម៌ដែលវិញ្ញូបុរស ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង នូវលទ្ធិនៃអាចារ្យជារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅដោយកាលមិនយូរប៉ុន្មាន ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ ក៏រៀនធម៌នោះចាំមួយរំពេច មិនយឺតយូរឡើយ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ ពោលនូវញាណវាទផង ដឹងច្បាស់នូវថេរវាទផង ដោយហេតុគ្រាន់តែបើកបបូរមាត់ ទាំងគ្រាន់តែចរចានូវពាក្យទៅមកប៉ុណ្ណោះឯង មួយទៀត តថាគតប្តេជ្ញាថាឃើញ មិនមែនតែតថាគតតែប៉ុណ្ណោះឡើយ សូម្បីពួកជនដទៃគង់និយាយយ៉ាងនេះដែរ ។ នែអគ្គិវេស្សនៈ តថាគតគិតដូច្នេះថា អាឡារកាលាមតាបស មិនបានប្រកាសថា អាត្មាអញធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង នូវធម៌នេះដោយត្រឹមតែសទ្ធាប៉ុណ្ណោះ ហើយសម្រេចសម្រាន្តនៅដូច្នេះឡើយ តាមពិត អាឡារកាលាមតាបស គ្រាន់តែជាអ្នកយល់ឃើញនូវធម៌នេះប៉ុណ្ណោះទេឬ ។ ម្នាលអគ្គិវេស្សនៈ លំដាប់នោះឯង តថាគតបានចូលទៅរកអាឡារកាលាមតាបស លុះចូលទៅដល់ហើយ បានពោលពាក្យដូច្នេះ នឹងអាឡារកាលាមតាបសថា អាវុសោកាលាមៈ លោកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ចំពោះធម៌នេះ ហើយអាចសម្តែងដល់ត្រឹមណា ។ នែអគ្គិវេស្សនៈ លុះតថាគតបានពោលយ៉ាងនេះហើយ អាឡារកាលាមតាបស ក៏សម្តែងនូវអាកិញ្ចញ្ញាយតនៈ ។ នែអគ្គិវេស្សនៈ តថាគតគិតដូច្នេះថា អាឡារកាលាមតាបសមិនមានសទ្ធាទេ

អាត្មាអញទើបមានសទ្ធា អាឡារកាលាមតាបសមិនមានវិរិយៈទេ អាត្មាអញទើបមានវិរិយៈ អាឡារកាលាមតាបសមិនមានសតិទេ អាត្មាអញទើបមានសតិ អាឡារកាលាមតាបសមិនមានសមាធិទេ អាត្មាអញទើបមានសមាធិ អាឡារកាលាមតាបសមិនមានបញ្ញាទេ អាត្មាអញទើបមានបញ្ញា បើដូច្នោះ អាឡារកាលាមតាបសប្រកាសថា អាត្មាអញបានត្រាស់ដឹងដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌ណា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ តថាគតគប្បីតម្កល់ព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ៗ នៃអគ្គិវេស្សនៈ តថាគតនោះ បានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌នោះមួយរំពេច មិនយឺតយូរឡើយ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ នៃអគ្គិវេស្សនៈ លំដាប់នោះឯង តថាគតបានចូលទៅរកអាឡារកាលាមតាបស លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងអាឡារកាលាមតាបសថា អាវុសោកាលាមៈ លោកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌នេះ ហើយអាចប្រកាសបាន ដោយហេតុមានប្រមាណប៉ុណ្ណេះទេឬ ។ អាឡារកាលាមតាបសតបថា នៃអ្នកមានអាយុ យើងបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌នេះហើយ អាចប្រកាសបានដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។ តថាគតពោលថា ម្នាលអ្នកមានអាយុ យើងបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌នេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង៤ ដោយហេតុមានប្រមាណប៉ុណ្ណេះដែរ ។ អាឡារ-

កាលាមតាបសតបថា នែអ្នកមានអាយុ យើងពេញហៅថា ជាមនុស្សមានលាភ នែអ្នកមានអាយុ អត្តភាពជាមនុស្ស ពេញហៅថា យើងបានដោយល្អ ព្រោះថា យើងបានឃើញនូវព្រហ្មចារីបុគ្គល មានអាយុប្រាកដដូចជាអ្នក យើងបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌ណា ហើយអាចប្រកាសបាន លោកក៏បានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌នោះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ លោកបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវធម៌ណា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ យើងក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌នោះ ហើយអាចប្រកាសបាន យើងដឹងនូវធម៌ណា លោកក៏ដឹងនូវធម៌នោះដែរ លោកដឹងនូវធម៌ណា យើងក៏ដឹងនូវធម៌នោះដែរ យើងជាមនុស្សយ៉ាងណា លោកជាមនុស្សយ៉ាងនោះដែរ លោកជាមនុស្សយ៉ាងណា យើងក៏ជាមនុស្សយ៉ាងនោះដែរ នែអ្នកមានអាយុ អ្នកចូរមកក្នុងកាលឥឡូវនេះ យើងទាំងពីររូបនៅរក្សាគណៈនេះ ។ នែអគ្គិវេស្សនៈ អាឡារកាលាមតាបស ជាអាចារ្យរបស់តថាគត តែគាត់តាំងតថាគតដែលជាសិស្ស ឲ្យត្រឹមស្មើនឹងខ្លួនគាត់ ទាំងបូជាតថាគតដោយការបូជាដ៏ក្រៃលែង ដោយហេតុយ៉ាងនេះឯង ។ នែអគ្គិ-វេស្សនៈ តថាគតក៏មានសេចក្តីត្រិះរិះដូច្នេះថា ធម៌នេះមិនប្រព្រឹត្តទៅដើម្បីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរំលត់នូវរាគាទិក្កិលេស មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បី

ដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ប្រព្រឹត្តទៅបាន ត្រឹមតែកើតក្នុងអាកិញ្ចញ្ញាយតនភពប៉ុណ្ណោះឯង ។ នែអគ្គិវេស្សនៈ តថាគតនោះមិនពេញចិត្តនឹងធម៌នោះ ហើយនឿយណាយចាកធម៌នោះ ក៏ដើរចៀសចេញទៅ ។

[ ៥២ ] នែអគ្គិវេស្សនៈ តថាគតស្វែងរកនូវកឹកុសល ស្វែងរកសន្តិវរបទ គឺព្រះនិព្វានជាគ្រឿងរម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេសដ៏ប្រសើរ ហើយចូលទៅរកឧទ្ទករាមបុត្រតាបស លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងឧទ្ទករាមបុត្រថា អាវុសោរាមៈ យើងប្រាថ្នាដើម្បីប្រព្រឹត្តនូវព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ។ នែអគ្គិវេស្សនៈ កាលបើតថាគតពោលយ៉ាងនេះហើយ ឧទ្ទករាមបុត្រ ក៏និយាយពាក្យនេះនឹងតថាគតថា អ្នកដ៏មានអាយុ ចូរនៅចុះ នេះធម៌ ដែលប្រាកដដូចជាអ្នកត្រូវការនោះ ជាធម៌ដែលវិញ្ញូបុរសគួរធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវលទ្ធិនៃអាចារ្យជារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅដោយមិនយូរប៉ុន្មាន ។ នែអគ្គិវេស្សនៈ តថាគតក៏បានរៀនចប់ធម៌នោះ ចាំមួយរំពេច មិនយឺតយូរឡើយ ។ នែអគ្គិវេស្សនៈ តថាគតនោះ ពោលនូវញាណវាទផង ដឹងនូវថេរវាទផង ដោយហេតុគ្រាន់តែបើកបបូរមាត់ ទាំងគ្រាន់តែចរចានូវពាក្យទៅមកប៉ុណ្ណោះឯងមួយវិញទៀត តថាគតប្តេជ្ញាថាឃើញ មិនមែនតែតថាគតប៉ុណ្ណោះឡើយ សូម្បីពួកជនដទៃ គង់និយាយយ៉ាងនេះដែរ ។ ម្នាលអគ្គិវេស្សនៈ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា រាមបុត្រមិនបានប្រកាសថា អាត្មាអញធ្វើឲ្យជាក់

ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌នេះ ដោយត្រឹមតែសទ្ធាប៉ុណ្ណោះ ហើយសម្រេចសម្រាន្តនៅដូច្នេះឡើយ តាមពិត រាមបុត្រគ្រាន់តែជាអ្នកយល់ឃើញនូវធម៌នេះប៉ុណ្ណោះទេឬ ។ នែអគ្គិវេស្សនៈ លំដាប់នោះឯង តថាគតក៏ចូលទៅរកឧទ្ទករាមបុត្រ លុះចូលទៅដល់ហើយ ក៏ពោលពាក្យនេះ នឹងឧទ្ទករាមបុត្រថា អាវុសោរាមៈ លោកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌នេះ ហើយអាចប្រកាសបាន ដោយហេតុមានប៉ុន្មានទៅ ។ នែអគ្គិវេស្សនៈ លុះតថាគត ពោលពាក្យយ៉ាងនេះហើយ ឧទ្ទករាមបុត្រ ក៏ប្រកាសនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ នែអគ្គិ-វេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា រាមបុត្រមិនមានសទ្ធាទេ ឯអាត្មាអញទើបមានសទ្ធា រាមបុត្រមិនមានវិរិយៈទេ អាត្មាអញទើបមានវិរិយៈ រាមបុត្រមិនមានសតិទេ អាត្មាអញទើបមានសតិ រាមបុត្រមិនមានសមាធិទេ អាត្មាអញទើបមានសមាធិ រាមបុត្រមិនមានបញ្ញាទេ អាត្មាអញទើបមានបញ្ញា បើដូច្នោះ រាមបុត្រ ប្រកាសនូវធម៌ណាថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ អាត្មាអញគប្បីតាំងព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ។ នែអគ្គិវេស្សនៈ តថាគតនោះ ក៏បានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវធម៌នោះមួយរំពេច មិនយឺតយូរឡើយ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ នែអគ្គិវេស្សនៈ លំដាប់នោះឯង តថាគតក៏ចូលទៅរកឧទ្ទករាមបុត្រ លុះចូលទៅដល់ហើយ ក៏ពោលពាក្យនេះ នឹងឧទ្ទករាម-

បុត្រថា អាវុសោរាមៈ លោកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌នេះ ហើយអាចប្រកាសបានដោយហេតុមានប៉ុន្មានទៅ ។ ឧទ្ទករាមបុត្រ តបថា នែអ្នកមានអាយុ យើងបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌នេះ ហើយអាចប្រកាសបាន ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ តថាគតពោលថា នែអ្នកមានអាយុ យើងបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌នេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ដោយហេតុមានប្រមាណប៉ុណ្ណោះដែរ ។ ឧទ្ទករាមបុត្រនិយាយថា ម្នាលអ្នកមានអាយុ យើងហៅពេញថាជាមនុស្សមានលាភ នែអ្នកមានអាយុ អត្តភាពជាមនុស្សឈ្មោះថា យើងបានដោយល្អ ព្រោះថា យើងបានឃើញនូវព្រហ្មចារីបុគ្គលមានអាយុប្រាកដដូចជាអ្នក រាមបុត្របានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌ណា ហើយអាចប្រកាសបាន អ្នកក៏បានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងនូវធម៌នោះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ អ្នកបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងនូវធម៌ណា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ រាមបុត្រក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង នូវធម៌នោះ ហើយអាចប្រកាសបាន រាមបុត្របានដឹងនូវធម៌ណា អ្នកក៏បានដឹងនូវធម៌នោះដែរ អ្នកបានដឹងនូវធម៌ណា រាមបុត្រក៏បានដឹងនូវធម៌នោះដែរ រាមបុត្រជាមនុស្សយ៉ាងណា អ្នកក៏ជាមនុស្សយ៉ាងនោះដែរ អ្នកជាមនុស្សយ៉ាងណា

រាមបុត្រក៏ជាមនុស្សយ៉ាងនោះដែរ នែអ្នកមានអាយុ ឥឡូវនេះ អ្នកចូរមក យើងទាំងពីរនាក់នឹងនៅរក្សាគណៈនេះ ។ នែអគ្គិវេស្សនៈ ឧទ្ទករាមបុត្រជាសព្រហ្មចារីបុគ្គលរបស់តថាគត តាំងតថាគតក្នុងនាទីជាអាចារ្យ ទាំងបូជាតថាគតដោយគ្រឿងបូជាដ៏ក្រៃលែង ដោយប្រការដូច្នោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា ធម៌នេះមិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយចាករាគាទិក្កិលេស មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរម្ងត់នូវកងទុក្ខ មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ប្រព្រឹត្តទៅបានត្រឹមតែកើតក្នុងនេវសញ្ញានាសញ្ញាយតនភពប៉ុណ្ណោះ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះមិនពេញចិត្តនឹងធម៌នោះ ក៏នឿយណាយចាកធម៌នោះ ហើយចៀសចេញទៅ ។

[ ៥៣ ] នែអគ្គិវេស្សនៈ កាលដែលតថាគតស្វែងរកកឹកុសល ស្វែងរកសន្តិវរបទ គឺព្រះនិព្វាន ជាគ្រឿងរម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេសដ៏ប្រសើរ ហើយក៏ត្រាច់ទៅកាន់ចារិកតាមលំដាប់ក្នុងដែនមគធៈ បានដល់សេនានិគម ក្នុងឧរុវេលាប្រទេស ។ តថាគតបានឃើញនូវភូមិភាគ គួរជាទីសប្បាយក្នុងសេនានិគមនោះផង នូវដងព្រៃជាទីជ្រះថ្លាផង នូវស្ទឹងដែលមានទឹកហូរ មានទឹកថ្លា មានកំពង់ដ៏ល្អជាទីសប្បាយផង នូវស្រុកជាទីគោចរជិតល្មមផង ។ នែអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ ភូមិភាគគួរជាទីសប្បាយផង ដងព្រៃជាទីជ្រះថ្លាផង ស្ទឹងមានទឹកថ្លាមានកំពង់

ដ៏ល្អ ជាទីសប្បាយ តែងហូរទៅផង ស្រុកជាទីគោចរក៏ជិតល្មមផង ។ កន្លែងនេះជាកន្លែងគួរដើម្បីប្រព្រឹត្តព្យាយាម នៃកុលបុត្រជាអ្នកមានព្យាយាម ។ នៃអគ្គិវេស្សនៈ តថាគតនោះ ក៏អង្គុយនៅក្នុងទីនោះដោយគិតថា ទីនេះគួរដើម្បីការប្រព្រឹត្តព្យាយាម ។

[ ៥៤ ] នៃអគ្គិវេស្សនៈ សេចក្តីឧបមាទាំង ៣ មិនជាអស្ចារ្យណាស់ណា តថាគតមិនធ្លាប់បានឮមកក្នុងកាលមុនទេ ស្រាប់តែប្រាកដដល់តថាគត ។ នៃអគ្គិវេស្សនៈ ដូចជាកំណាត់ឈើស្រស់នៅមានជ័រ ដែលត្រាំនៅក្នុងទឹក ។ លំដាប់នោះ មានបុរសម្នាក់ កាន់យកឈើពំនួតភ្លើងខាងលើ ( កូនពំនួត ) ដើរមកដោយគិតថា អាត្មាអញនឹងពួតភ្លើងឲ្យកើតឡើង អាត្មាអញនឹងធ្វើភ្លើងឲ្យឆេះឡើង ។ ម្នាលអគ្គិវេស្សនៈ អ្នកសម្គាល់ហេតុនោះដូចម្តេច បុរសនោះកាន់យកឈើពំនួតភ្លើងខាងលើ មកពួតនឹងឈើស្រស់នៅមានជ័រ ដែលត្រាំនៅក្នុងទឹកឯណោះ ហើយគប្បីធ្វើភ្លើងឲ្យកើតឡើង គប្បីធ្វើភ្លើងឲ្យឆេះឡើងបានដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន អំពើនេះមិនបានទេ សេចក្តីនោះ ព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថាកំណាត់ឈើស្រស់ឯណោះ នៅមានជ័រ ថែមទាំងកំណាត់ឈើនោះ ត្រាំនៅក្នុងទឹកទៅទៀត បុរសនោះ បានតែត្រឹមចំណែកនៃសេចក្តីលំបាក សេចក្តីចង្អៀតចង្អល់ឥតប្រយោជន៍ មានឧបមាដូចម្តេចមិញ នៃអគ្គិវេស្សនៈ ពួកជនណានីមួយ ទោះបីជាសមណៈក្តី ព្រាហ្មណ៍ក្តី មានកាយមិនបានចៀសចេញចាកវត្ថុកាមទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ មិនបានលះបង់ មិនបានរម្ងាប់នូវ

សេចក្តីប្រាថ្នាក្នុងកិលេសកាម សេចក្តីស្រឡាញ់ក្នុងកិលេសកាម សេចក្តីជ្រុលជ្រប់ក្នុងកិលេសកាម សេចក្តីស្រេកឃ្លានក្នុងកិលេសកាម សេចក្តីក្តៅក្រហាយក្នុងកិលេសកាម ណដ៏ខាងក្នុងផង ។ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ទទួលទុក្ខវេទនាក្លៀវក្លា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាម ក៏គង់សមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរឡើយ ។ បើទុកជាសមណព្រាហ្មណ៍ទាំងនោះ មិនបានទទួលទុក្ខវេទនាក្លៀវក្លា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាម ក៏គង់សមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរដែរ មានឧបមេយ្យដូច្នោះឯង ។ ម្នាលអគ្គិ-វេស្សនៈ សេចក្តីឧបមាជាដំបូងនេះឯង មិនជាអស្ចារ្យណាស់ណា តថាគតមិនធ្លាប់បានឮមកក្នុងកាលមុនទេ ក៏ស្រាប់តែប្រាកដដល់តថាគត ។

[ ៥៥ ] នែអគ្គិវេស្សនៈ សេចក្តីឧបមាជាគម្រប់ ២ ដទៃទៀត មិនជាទីអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានឮមក ក្នុងកាលមុន ក៏ស្រាប់តែប្រាកដដល់តថាគត ។ ម្នាលអគ្គិវេស្សនៈ កំណាត់ឈើស្រស់នៅមានជ័រដែលដាក់នៅលើគោកឆ្ងាយអំពីទឹក ។ លំដាប់នោះ មានបុរសម្នាក់ កាន់យកនូវឈើពំនួតភ្លើងខាងលើដើរមកដោយគិតថា អាត្មាអញនឹងធ្វើភ្លើងឲ្យកើតឡើង នឹងធ្វើភ្លើងឲ្យឆេះឡើង ។ នែអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះដូចម្តេច បុរសនោះកាន់នូវឈើពំនួតភ្លើងខាងលើ មកពួតនឹងកំណាត់ឈើស្រស់នៅមានជ័រដែលដាក់នៅលើគោក ឆ្ងាយអំពីទឹកឯណោះ ហើយគប្បីធ្វើ

ភ្លើងឲ្យកើតឡើង គប្បីធ្វើភ្លើងឲ្យឆេះឡើង បានដែរឬទេ ។ បពិត្រព្រះគោតម ដ៏ចម្រើន អំពើនេះមិនបានទេ ព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា កំណាត់ឈើស្រស់ឯណោះ ពិតជាដាក់នៅលើគោកឆ្ងាយអំពីទឹកមែន តែថា នៅស្រស់មានជ័រ ឯបុរសនោះ គ្រាន់តែជាអ្នកមានចំណែកនៃសេចក្តីលំបាក និងសេចក្តីចង្អៀតចង្អល់ប៉ុណ្ណោះឯង មានឧបមាដូចម្តេចមិញ នៃអគ្គិវេស្សនៈ ជនទាំងឡាយណានីមួយ ទោះជាសមណៈក្តីព្រាហ្មណ៍ក្តី មានកាយចៀសចេញចាកវត្ថុកាមទាំងឡាយពិតមែនហើយ តែជាសមណព្រាហ្មណ៍ទាំងនោះមិនបានលះបង់ មិនបានរម្ងាប់នូវសេចក្តីប្រាថ្នាក្នុងកិលេសកាម សេចក្តីស្រឡាញ់ក្នុងកិលេសកាម សេចក្តីជ្រុលជ្រប់ក្នុងកិលេសកាម សេចក្តីស្រេកឃ្លានក្នុងកិលេសកាម សេចក្តីក្តៅក្រហាយក្នុងកិលេសកាម ឰដ៏ខាងក្នុង ។ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះសោយនូវទុក្ខវេទនាក្លៀវក្លា រឹងរូស ក្រហល់ក្រហាយដែលកើតអំពីព្យាយាម ក៏គង់សមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរឡើយ ។ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ មិនបានសោយនូវទុក្ខវេទនាក្លៀវក្លា រឹងរូស ក្រហល់ក្រហាយដែលកើតអំពីព្យាយាមទេ ក៏គង់សមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរដែរ មានឧបមេយ្យដូច្នោះឯង ។ នៃអគ្គិវេស្សនៈ សេចក្តីឧបមាទី ២ នេះឯង មិនជាអស្ចារ្យណាស់ណា តថាគតមិនធ្លាប់បានឮមកក្នុងកាលមុន ក៏ស្រាប់តែប្រាកដដល់តថាគត ។

[ ៥៦ ] នែអគ្គិវេស្សនៈ សេចក្តីឧបមាទី ៣ ដទៃទៀតមិនជាទីអស្ចារ្យ ណាស់ណា ដែលតថាគតមិនធ្លាប់ឮមកក្នុងកាលមុន ក៏ស្រាប់តែប្រាកដដល់ តថាគត ។ នែអគ្គិវេស្សនៈ កំណាត់ឈើស្ងួត ជាឈើសោះ ដែលដាក់នៅ លើគោកឆ្ងាយអំពីទឹក ។ លំដាប់នោះ មានបុរសម្នាក់ កាន់នូវឈើពំនួត ភ្លើងខាងលើ ដើរមកដោយគិតថា អាត្មាអញនឹងធ្វើភ្លើងឲ្យកើតឡើង អាត្មា អញនឹងធ្វើភ្លើងឲ្យឆេះឡើង ។ នែអគ្គិវេស្សនៈ អ្នកសម្គាល់នូវហេតុនោះដូច ម្តេច បុរសនោះកាន់នូវឈើពំនួតភ្លើងខាងលើ មកពួតនឹងកំណាត់ឈើស្ងួត ជាឈើសោះ ដែលដាក់នៅលើគោកឆ្ងាយអំពីទឹកឯណោះ ហើយគប្បីធ្វើភ្លើង ឲ្យកើតឡើង គប្បីធ្វើភ្លើងឲ្យឆេះឡើងបានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន គប្បីធ្វើភ្លើងឲ្យឆេះឡើងបាន ព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន ព្រោះ ថា កំណាត់ឈើស្ងួតឯណោះ ជាឈើសោះស្រាប់ ហើយថែមទាំងកំណាត់ ឈើនោះនៅលើគោកឆ្ងាយអំពីទឹកទៅទៀត មានឧបមាយ៉ាងណាមិញ នែ អគ្គិវេស្សនៈ ពួកជនណានីមួយ ទោះបីជាសមណៈក្តី ព្រាហ្មណ៍ក្តី មានកាយ ចៀសចេញចាកវត្ថុកាមទាំងឡាយផង សមណព្រាហ្មណ៍ទាំងនោះបានលះបង់ បាន រម្ងាប់សេចក្តីប្រាថ្នាក្នុងកិលេសកាម សេចក្តីស្រឡាញ់ក្នុងកិលេសកាម សេចក្តីជ្រុលជ្រប់ក្នុងកិលេសកាម សេចក្តីស្រេកឃ្លានក្នុងកិលេសកាម សេចក្តី ក្តៅក្រហាយក្នុងកិលេសកាមឲ្យដ៏ខាងក្នុងផង ។ បើទុកជាសមណព្រាហ្មណ៍ ដ៏ចម្រើនទាំងនោះទទួលទុក្ខវេទនាក្លៀវក្លា រឹងរូស ក្រហល់ក្រហាយ ដែល កើតអំពីព្យាយាម ក៏គង់សមណព្រាហ្មណ៍ទាំងនោះ គួរដើម្បីដឹង ដើម្បីឃើញ

ដើម្បីត្រាស់ដឹងយ៉ាងប្រសើរបាន ។ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះមិនទទួលទុក្ខវេទនាក្លៀវក្លា រឹងរូស ក្រហល់ក្រហាយ ដែលកើតអំពីព្យាយាមទេ ក៏គង់សមណព្រាហ្មណ៍ទាំងនោះ គួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងយ៉ាងប្រសើរបានដែរ មានឧបមេយ្យយ៉ាងនោះឯង នែអគ្គិវេស្សនៈ សេចក្តីឧបមាទី ៣ នេះឯង មិនជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានឮមកក្នុងកាលមុន ក៏ស្រាប់តែប្រាកដដល់តថាគត ។ នែអគ្គិវេស្សនៈ សេចក្តីឧបមាទាំង ៣ នេះឯង មិនជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានឮមកក្នុងកាលមុនទេ ក៏ស្រាប់តែប្រាកដដល់តថាគត ។

[ ៥៧ ] នែអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអាត្មាអញ ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតាន ( ក្រអូមមាត់ ) ដោយអណ្តាត សង្កត់គាបផ្ទប់នូវចិត្តដោយចិត្ត ។ នែអគ្គិវេស្សនៈ តថាគតនោះក៏ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតានដោយអណ្តាត សង្កត់គាបផ្ទប់នូវចិត្តដោយចិត្ត នែអគ្គិវេស្សនៈ កាលដែលតថាគតនោះ ខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតានដោយអណ្តាត សង្កត់គាបផ្ទប់នូវចិត្តដោយចិត្ត ញើសក៏ហូរចេញអំពីក្លៀកទាំងសងខាង ។ នែអគ្គិវេស្សនៈ ដូចបុរសដែលមានកម្លាំង ចាប់បុរសដែលមានកម្លាំងថយជាងខ្លួនត្រង់ក្បាលផង ចាប់ត្រង់កផង គប្បីសង្កត់គាបផ្ទប់ មានឧបមាយ៉ាងណាមិញ នែអគ្គិវេស្សនៈ កាលដែលតថាគតខាំសង្កត់ធ្មេញដោយធ្មេញទាំងឡាយ ទល់ពិតានដោយអណ្តាត សង្កត់គាបផ្ទប់នូវចិត្តដោយចិត្ត ញើសក៏ហូរ

ចេញអំពីក្លៀកទាំងសងខាង មានឧបមេយ្យយ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគតតឹងតែងណាស់ មិនធូរថយ សតិក៏តម្កល់ខ្ជាប់ មិនមានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគតដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារសេចក្តីព្យា-យាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនា មានសភាពដូច្នោះកើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

[ ៥៨ ] នែអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះមានតែអាត្មាអញ ពិចារណានូវអប្បាណកជ្ឈាន គឺឈានដែលគ្មានដង្ហើមចេញចូល ។ នែអគ្គិវេស្សនៈ តថាគតក៏បិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង ។ នែអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង សំឡេងរបស់ខ្យល់ដែលចេញមកអំពីរន្ធត្រចៀកទាំងសងខាង ក៏ឮខ្លាំងក្រៃពេក ។ សំឡេងស្នប់របស់ជាងមាស ដែលកំពុងសប់លាន់ឮខ្លាំង យ៉ាងណាមិញ ម្នាលអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង សំឡេងរបស់ខ្យល់ដែលចេញអំពីរន្ធត្រចៀកទាំងសងខាង ក៏លាន់ឮខ្លាំងយ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគតតឹងតែងណាស់ មិនបន្ធូរបន្ថយ ទាំងសតិក៏តម្កល់ខ្ជាប់ មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោតហើយ ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារសេចក្តីព្យា-

យាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុក្ខណាជាទុក្ខវេទនាមានសភាពដូច្នោះកើតឡើងដល់តថាគត ក៏មិនគ្រប់សង្កត់ចិត្តរបស់តថាគតបានឡើយ ។

[ ៥៩ ] នែអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញពិចារណានូវអប្បាណកជ្ឈាន ។ នែអគ្គិវេស្សនៈ តថាគតក៏បិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ នែអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏ចាក់ដោតនូវក្បាល ។ នែអគ្គិវេស្សនៈ បុរសមានកម្លាំងចាក់ធ្មៀលនូវក្បាលដោយចុងដែកស្រួចដ៏មុត យ៉ាងណាមិញ នែអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏ចាក់ដោតនូវក្បាលយ៉ាងនោះឯង ។ នែអគ្គិវេស្សនៈ សេចក្តីព្យាយាមរបស់តថាគតតឹងតែងណាស់ មិនធូរថយឡើយ សតិក៏តម្កល់ខ្ជាប់ មិនបានវង្វេងភ្លេចឡើយ តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ដោយសារសេចក្តីព្យាយាម ដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុក្ខណាជាទុក្ខវេទនា មានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនគ្រប់សង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

[ ៦០ ] នែអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញពិចារណានូវអប្បាណកជ្ឈានតែម្យ៉ាង ។ នែអគ្គិ-

វេស្សនៈ តថាគតក៏បិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ នែអគ្គិវេស្សនៈ លុះតថាគតនោះ បិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សីសវេទនាដ៏ខ្លាំងក្រៃលែងក៏កើតប្រាកដក្នុងក្បាល ។ នែអគ្គិវេស្សនៈ បុរសមានកម្លាំង រុំក្បាលដោយកំណាត់ព្រ័ត្រដ៏មាំ យ៉ាងណាមិញ នែអគ្គិ-វេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សីសវេទនាដ៏ខ្លាំងក្រៃលែងក៏កើតប្រាកដក្នុងក្បាល ក៏យ៉ាងនោះឯង ។ នែអគ្គិវេស្សនៈសេចក្តីព្យាយាមរបស់តថាគតតឹងតែងណាស់ មិនធូរថយឡើយ ទាំងសតិក៏តម្កល់ខ្ជាប់ មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោតទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះកើតឡើងដល់តថាគត ក៏គ្របសង្កត់ចិត្តរបស់តថាគតមិនបានឡើយ ។

[ ៦១ ] នែអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញពិចារណានូវអប្បាណកជ្ឈាន ។ នែអគ្គិវេស្សនៈ តថាគតនោះ ក៏បិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ នែអគ្គិវេស្សនៈ លុះតថាគតនោះបិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល អំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏សៀតធ្លុះផ្ទៃ ។ នែអគ្គិវេស្សនៈ បុរសអ្នកសម្លាប់

គោ ឬកូនសិស្សនៃបុរសអ្នកសម្លាប់គោដ៏ឈ្លាសវៃ គប្បីអារនូវផ្ទៃដោយកាំបិតសម្រាប់អារគោដ៏មុត យ៉ាងណាមិញ នែអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ ខ្យល់ដ៏ខ្លាំងក្រៃលែង ក៏សៀតធ្លុះនូវផ្ទៃយ៉ាងនោះឯង ។ នែអគ្គិ-វេស្សនៈ សេចក្តីព្យាយាមរបស់តថាគតតឹងតែងណាស់ មិនធូរថយឡើយ ទាំងសតិក៏តម្កល់ខ្ជាប់ មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគតដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ដោយសារសេចក្តីព្យាយាមដ៏លំបាកនោះឯង ។ នែអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនាមានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនបានគ្រប់សង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

[ ៦២ ] ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញពិចារណានូវអប្បាណកជ្ឈាន ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង ក៏បិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផង ។ ម្នាលអគ្គិវេស្សនៈ លុះតថាគតនោះ បិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលអំពីមាត់ផង អំពីច្រមុះផង អំពីត្រចៀកផងហើយ សេចក្តីក្តៅក្រហាយដ៏ខ្លាំងក្រៃលែង ក៏កើតឡើងក្នុងកាយ ។ ម្នាលអគ្គិវេស្សនៈ បុរសមានកម្លាំងពីរនាក់ ចាប់នូវបុរសមានកម្លាំងថយជាងខ្លួនត្រង់ដៃទាំងសងខាង ផ្ទេរកម្តៅ លើរណ្តៅរងើកភ្លើង យ៉ាងណាមិញ ម្នាលអគ្គិវេស្សនៈ លុះតថាគតបិទខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល អំពីមាត់

ផង អំពីប្រមុះផង អំពីត្រចៀកផងហើយ សេចក្ដីក្ដៅក្រហាយដ៏ខ្លាំងក្រៃលែង ក៏កើតឡើងក្នុងកាយ យ៉ាងនោះឯង ។ ម្នាលអគ្គិវេស្សនៈ សេចក្ដីព្យាយាមរបស់តថាគតតឹងតែងណាស់ មិនធូរថយឡើយ ទាំងសតិក៏តម្កល់ខ្ជាប់ខ្ជួន មិនបានវង្វេងភ្លេច តែចំណែកខាងកាយរបស់តថាគត ដែលត្រូវព្យាយាមចាក់ដោត ទៅជាកាយក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ដោយសារសេចក្ដីព្យាយាមដ៏លំបាកនោះឯង ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាទុក្ខវេទនា មានសភាពដូច្នោះ កើតឡើងដល់តថាគត ក៏មិនបានគ្របសង្កត់នូវចិត្តរបស់តថាគតឡើយ ។ ម្នាលអគ្គិវេស្សនៈ មានពួកទេវតា បានឃើញតថាគតដូច្នោះហើយ និយាយយ៉ាងនេះថា ព្រះសមណគោតមធ្វើមរណកាលហើយ ។ ទេវតាពួកខ្លះនិយាយយ៉ាងនេះថា ព្រះសមណគោតម មិនទាន់ធ្វើមរណកាលនៅឡើយទេ តែគង់នឹងធ្វើមរណកាលពុំខាន ។ ទេវតាពួកខ្លះនិយាយយ៉ាងនេះថា ព្រះសមណគោតមមិនបានធ្វើមរណកាលទៅហើយទេ ទាំងនឹងមិនធ្វើមរណកាលឡើយ ព្រះសមណគោតមជាអរហន្ត ទ្រង់គង់ព្រះជន្មាយុដោយពិត ការគង់ព្រះជន្មាយុរបស់ព្រះអរហន្តនោះ មានសភាពយ៉ាងនេះ ។

[ ៦៣ ] ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេក្ដីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអាត្មាអញប្រតិបត្តិ ដើម្បីផ្ដាច់បង់នូវអាហារ ដោយប្រការទាំងពួង ។ ម្នាលអគ្គិវេស្សនៈ លំដាប់នោះឯង ពួកទេវតាចូលទៅរកតថាគតហើយនិយាយដូច្នេះថា បពិត្រព្រះអង្គអ្នកនិទុក្ខ ព្រះអង្គកុំប្រតិបត្តិដើម្បីផ្ដាច់បង់នូវអាហារ ដោយប្រការទាំងពួងឡើយ បពិត្រព្រះអង្គអ្នកនិទុក្ខ បើព្រះ

អង្គនឹងប្រតិបត្តិដើម្បីផ្តាច់បង់នូវអាហារ ដោយប្រការទាំងពួងតទៅ យើងទាំងឡាយនឹងញ៉ាំងឱជាទិព្វ ឲ្យជ្រួតជ្រាបទៅតាមរណ្តៅរោមទាំងឡាយរបស់ព្រះអង្គៗ នឹងរស់នៅដោយឱជាទិព្វនោះបាន ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើអាត្មាអញនឹងប្តេជ្ញាខ្លួនជាអ្នកគ្មានភោជនដោយប្រការទាំងពួងផង ទេវតាទាំងឡាយនេះ នឹងញ៉ាំងឱជាទិព្វឲ្យជ្រួតជ្រាបចូលទៅតាមរណ្តៅរោមទាំងឡាយរបស់អាត្មាអញផង អាត្មាអញនឹងរស់នៅដោយឱជាទិព្វនោះផង អំពើនោះជាអំពើកុហករបស់អាត្មាអញ ។ ម្នាលអគ្គិ-វេស្សនៈ តថាគតនោះឯង ក៏និយាយឃាត់ទេវតាទាំងនោះវិញ តថាគតប្រាប់ថា កុំឡើយ ដូច្នេះ ។

[ ៦៤ ] ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអាត្មាអញបរិភោគនូវអាហារបន្តិចៗ ទោះបីគ្រាប់សណ្តែកបាយក្តី គ្រាប់ពពាយជ្រុំងក្តី គ្រាប់សណ្តែកកង់ក្តី គ្រាប់សណ្តែកទ្រើងក្តី ត្រឹមតែមួយទូកដៃៗ ។ ម្នាលអគ្គិវេស្សនៈ តថាគតក៏បានបរិភោគនូវអាហារបន្តិចៗ ទោះបីគ្រាប់សណ្តែកបាយក្តី គ្រាប់ពពាយជ្រុំងក្តី គ្រាប់សណ្តែកកង់ក្តី គ្រាប់សណ្តែកទ្រើងក្តី ត្រឹមតែមួយទូកដៃៗ ។ ម្នាលអគ្គិវេស្សនៈ កាលដែលតថាគតនោះ បរិភោគអាហារបន្តិចៗ ទោះបីគ្រាប់សណ្តែកបាយក្តី គ្រាប់ពពាយជ្រុំងក្តី គ្រាប់សណ្តែកកង់ក្តី គ្រាប់សណ្តែកទ្រើងក្តី ត្រឹមតែមួយទូកដៃៗ កាយរបស់តថាគតក៏ដល់នូវអាការស្គាំងស្គមក្រៃលែង ។ អវយវៈតូចធំរបស់តថាគត ដូចជាថ្នាំងនៃវល្លិ ឈ្មោះអសីតិកៈ ឬដូចជាថ្នាំងនៃវល្លិ

ប្រេង ព្រោះមានអាហារតិចនោះឯង ។ គគូថរបស់តថាគត ដូចជាស្នាមជើងនៃសត្វអូដ្ឋ ព្រោះមានអាហារតិចនោះឯង ។ ឆ្អឹងខ្នងរបស់តថាគត រដិបរដុបដូចជាលំពង់ឈើ ដែលវល្លិព័ទ្ធវេញ ព្រោះមានអាហារតិចនោះឯង ។ របៀបនៃឆ្អឹងជំនីរទាំងឡាយរបស់តថាគត ក៏រគើមរគាម ដូចជាបង្កង់នៃសាលាចាស់ដ៏រគើមរគាម ព្រោះមានអាហារតិចនោះឯង ។ ប្រស្រីភ្នែកក្នុងរណ្តៅភ្នែករបស់តថាគត ក៏ជ្រៅខូងចុះទៅ ដូចក្រពេញទឹកក្នុងអណ្តូងទឹកជ្រៅ ដ៏ជ្រៅខូងចុះទៅ ព្រោះមានអាហារតិចនោះឯង ។ ស្បែកក្បាល ឰដ៏ក្បាលរបស់តថាគត ដែលអាហារតិចនោះពាល់ត្រូវហើយ ក៏ស្វិតជ្រីវ ដូចជាផ្លែននោងព្រៃ ដែលគេកាត់អំពីខ្ចី លុះខ្យល់ និងកម្តៅថ្ងៃពាល់ត្រូវហើយ ក៏ស្វិតជ្រីវដូច្នោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯងគិតថា អាត្មាអញនឹងស្ទាបស្បែកពោះ ក៏ចាប់ត្រូវលើឆ្អឹងខ្នងទៅវិញ គិតថា អាត្មាអញនឹងស្ទាបឆ្អឹងខ្នង ក៏ចាប់ត្រូវលើស្បែកពោះទៅវិញ ម្នាលអគ្គិវេស្សនៈ ព្រោះថា ស្បែកពោះរបស់តថាគតជាប់នឹងឆ្អឹងខ្នង ព្រោះមានអាហារតិចនោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង គិតថា អាត្មាអញនឹងបន្ទោបង់នូវវច្ចៈ ឬទឹកមូត្រ ក៏ដួលផ្កាប់ក្នុងទីនោះ ព្រោះមានអាហារតិចនោះឯង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯងធ្វើកាយនេះឲ្យស្រួលបួល ដុសខ្លួនប្រាណដោយដៃ ម្នាលអគ្គិវេស្សនៈ កាលបើតថាគតនោះដុសខ្លួនប្រាណដោយដៃ រោមទាំងឡាយមានគល់ស្អុយក៏ធ្លាក់ចុះអំពីកាយ ព្រោះមានអាហារតិចនោះឯង ។ ម្នាលអគ្គិវេស្សនៈ មនុស្សទាំងឡាយបានឃើញតថាគតហើយ ពោលពាក្យយ៉ាងនេះថា ព្រះសមណ-

គោតមមានសម្បុរខ្មៅ ។ មនុស្សពួកខ្លះនិយាយយ៉ាងនេះថា ព្រះសមណ-គោតមមិនខ្មៅទេ ព្រះសមណគោតមសម្បុរសណ្តែកបាយ ។ មនុស្សពួកខ្លះ និយាយយ៉ាងនេះថា ព្រះសមណគោតមមិនមែនសម្បុរខ្មៅ មិនមែនសម្បុរ សណ្តែកបាយទេ ព្រះសមណគោតមមានសម្បុរស្បែកប្រផេះ ។ ម្នាលអគ្គិ-វេស្សនៈ សម្បុរស្បែករបស់តថាគត បរិសុទ្ធ ផូរផង់ដល់ម៉្លោះ ក៏ត្រឡប់ ជាអាប់អន់ ព្រោះមានអាហារតិចនោះឯង ។

[ ៦៥ ] ម្នាលអគ្គិវេស្សនៈ តថាគតនោះឯងមានសេចក្តីត្រិះរិះដូច្នេះថា ជនទាំងឡាយណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងអតីតកាល បាន សោយនូវទុក្ខវេទនា ដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មានកំណត់តែត្រឹមប៉ុណ្ណោះ មិនលើសលុបជាងនេះទៅទៀតទេ ។ ជនទាំង-ឡាយណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងអនាគតកាល នឹងរង នូវទុក្ខវេទនា ដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មាន កំណត់តែត្រឹមប៉ុណ្ណោះ មិនលើសលុបជាងនេះទៅទៀតទេ ។ ជនទាំងឡាយ ណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ក្នុងកាលឥឡូវនេះ តែងរងទុក្ខ-វេទនា ដ៏ក្លៀវក្លា រឹងរូស ផ្សាខ្លោច ដែលកើតអំពីព្យាយាម មានកំណត់តែ ត្រឹមប៉ុណ្ណោះ មិនមានលើសលុបជាងនេះទៅទៀតទេ ។ ចំណែកខាងអាត្មា អញ មិនទាន់បានត្រាស់ដឹងនូវគុណវិសេស គឺញាណទស្សនៈដ៏ឧត្តម ដែល អាចកម្ចាត់បង់នូវកិលេស ដ៏ក្រៃលែងជាងមនុស្សធម៌ ដោយទុក្ករកិរិយា ដ៏ ផ្សាខ្លោចនេះនៅឡើយ ។ ផ្លូវដទៃប្រព្រឹត្តទៅដើម្បីត្រាស់ដឹង គប្បីមានដែរ

ឬហ្ន៎ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា កាល ដែលអាត្មាអញអង្គុយនៅក្រោមម្លប់នៃដើមព្រីងដ៏ត្រជាក់ ក្នុងកិច្ចការរបស់ សក្យរាជជាបិតា ក៏ធ្លាប់បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ ទាំងឡាយ បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្ក និងវិចារៈ មាន បីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះ ហើយសម្រេចសម្រាន្តនៅ ឱហ្ន៎ នុ៎ះឯង ជាផ្លូវនៃការត្រាស់ដឹងហើយទេដឹង ។ ម្នាលអគ្គិវេស្សនៈ វិញ្ញាណ ជាគ្រឿងរឭកតាមនូវស្មារតី ក៏កើតឡើងដល់តថាគតនោះថា ផ្លូវនុ៎ះឯងហើយ ជាផ្លូវនៃការត្រាស់ដឹង ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះ មានសេចក្តីត្រិះរិះ ដូច្នេះថា សេចក្តីសុខណាក្រៅចាកកាមទាំងឡាយ ក្រៅចាកអកុសលធម៌ ទាំងឡាយ អាត្មាអញខ្លាចសេចក្តីសុខនោះឬហ្ន៎ ។ ម្នាលអគ្គិវេស្សនៈ តថាគត នោះ មានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីសុខណា ក្រៅចាកកាមទាំងឡាយ ក្រៅចាកអកុសលធម៌ទាំងឡាយ អាត្មាអញមិនខ្លាចសេចក្តីសុខនោះទេ ។

[ ៦៦ ] ម្នាលអគ្គិវេស្សនៈ តថាគតនោះមានសេចក្តីត្រិះរិះដូច្នេះថា បុគ្គលមានកាយដល់នូវអាការស្គាំងស្គមក្រៃលែងយ៉ាងនេះ មិនងាយបាននូវ សេចក្តីសុខនោះទេ បើដូច្នោះ គួរតែអាត្មាអញ បរិភោគនូវអាហារ ដ៏គ្រោត គ្រាត គឺបាយ និងនំវិញ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង ក៏បរិភោគ នូវអាហារដ៏គ្រោតគ្រាត គឺបាយ និងនំ ។ ម្នាលអគ្គិវេស្សនៈ សម័យនោះឯង ភិក្ខុទាំង ៥ រូប តាមមកបម្រើតថាគត ដោយគិតថា ព្រះសមណគោតមរបស់ យើង នឹងបានត្រាស់ដឹងនូវធម៌ណា លោកនឹងប្រាប់នូវធម៌នោះដល់យើង

ទាំងឡាយ ។ ម្នាលអគ្គិវេស្សនៈ ព្រោះហេតុតែតថាគតបរិភោគនូវអាហារ ដ៏គ្រោតគ្រាត គឺបាយ និងនំ ក្នុងកាលណា ភិក្ខុទាំងប្រាំរូបនោះ លះបង់ រត់ចោលតថាគតក្នុងកាលនោះ ដោយគិតថា ព្រះសមណគោតមប្រកប ដោយ ល្មោភច្រើន ដោះចោលព្យាយាម ត្រឡប់ទៅដើម្បីសេចក្តីល្មោភច្រើន ។

[ ៦៧ ] ម្នាលអគ្គិវេស្សនៈ លុះតថាគតនោះឯង បរិភោគនូវអាហារ ដ៏គ្រោតគ្រាតហើយ ក៏មានកម្លាំង បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាក អកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្ក និង វិចារៈ មានបីតិ និងសុខដែលកើតអំពីសេចក្តីស្ងាត់នោះ ក៏សម្រេចសម្រាន្ត នៅដោយឥរិយាបថទាំង ៤ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមាន សភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់ចិត្តរបស់តថាគតបាន ឡើយ ។ លុះតថាគត រម្ងាប់វិតក្ក និងវិចារៈហើយ ក៏បានដល់នូវទុតិយ-ជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺ សទ្ធា ជាសភាពនៃចិត្តដ៏ខ្ពស់ឯក ឥតមានវិតក្ក និងវិចារៈ មានតែបីតិ និង សុខដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ... ក៏បានដល់នូវតតិយជ្ឈាន ... បាន ដល់នូវចតុត្ថជ្ឈាន ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាល អគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់ចិត្តរបស់តថាគតបានឡើយ ។ កាលដែលចិត្តរបស់តថាគត ខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួល ពោល គឺកិលេស ប្រាសចាក ឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិន

ញាប់ញ័រទៅតាមអារម្មណ៍ ( ដោយអំណាចឈានទាំង ៤ ) ដោយប្រការដូច្នេះហើយ តថាគតបង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ តថាគតនោះរឭកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរឭកឃើញជាតិ ១ ខ្លះ ជាតិ ២ ខ្លះ ។បេ។ រឭកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ គឺរូប និងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះ និងគោត្រត្រកូលជាដើម ដោយប្រការដូច្នេះ ។ ម្នាលអគ្គិវេស្សនៈ វិជ្ជាទី ១ នេះឯង តថាគតបានហើយក្នុងបឋមយាមនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅហើយ វិជ្ជាក៏កើតឡើង សេចក្តីងងឹតខ្ចាត់បាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគត ដូចបុគ្គលដែលមិនប្រមាទមានព្យាយាមញុំាងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែលបាននូវវិជ្ជាទី ១ នោះដែរ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

[ ៦៨ ] កាលបើចិត្តរបស់តថាគតខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួល ពោល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ ដោយប្រការដូច្នេះហើយ តថាគតក៏បង្អោនចិត្តទៅដើម្បីសត្តចុតូបបាតញ្ញាណ ។ តថាគតនោះ មានចក្ខុដូចជាទិព្វដ៏ស្អាត កន្លងហួសចក្ខុរបស់មនុស្សធម្មតា ក៏បានឃើញនូវពួកសត្វដែលច្យុត ដែលកើតឡើង ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានរូបល្អខ្លះ រូបអាក្រក់ខ្លះ មានគតិល្អខ្លះ គតិអាក្រក់ខ្លះ មួយវិញទៀត

តថាគតដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្ម ។បេ។ ម្នាលអគ្គិ-វេស្សនៈ វិជ្ជាទី ២ នេះឯង តថាគតបានហើយក្នុងមជ្ឈិមយាមនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅហើយ វិជ្ជាក៏កើតឡើង សេចក្តីងងឹតខ្ចាត់បាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគត ដូចបុគ្គលដែលមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ដែលបាននូវវិជ្ជាទី ២ ដូច្នោះដែរ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខវេទនាមានសភាពដូច្នេះកើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

[ ៦៩ ] កាលបើចិត្តរបស់តថាគតខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួល ពោល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ។ តថាគតនោះ បានដឹងច្បាស់តាមពិតថា នេះជាទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ បានដឹងច្បាស់តាមពិតថា នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាអាសវៈ បានដឹងច្បាស់តាមពិតថា នេះជាធម៌នាំឲ្យកើតអាសវៈ បានដឹងច្បាស់តាមពិតថា នេះជាទីរលត់អាសវៈ បានដឹងច្បាស់តាមពិតថា នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់អាសវៈ ។ កាលបើតថាគតនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តរបស់តថាគតរួចចាកកាមាសវៈផង ចិត្តរបស់តថាគតរួចចាកភវាសវៈផង ចិត្តរបស់តថាគតរួចចាកអវិជ្ជាសវៈផង ។បេ។

តថាគតដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលអគ្គិវេស្សនៈ វិជ្ជាទី ៣ នេះឯង តថាគតបានហើយក្នុងបច្ឆិមយាមនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅហើយ វិជ្ជាក៏កើតឡើងសេចក្ដីងងឹតខ្ចាត់បាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគត ដូចបុគ្គលដែលមិនប្រមាទ មានព្យាយាមញ៉ាំងកិលេសឲ្យក្ដៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានដែលបាននូវវិជ្ជាទី ៣ ដូច្នោះដែរ ។ ម្នាលអគ្គិវេស្សនៈ ទុកណាជាសុខ-វេទនាមានសភាពដូច្នេះ កើតឡើងដល់តថាគត ក៏មិនគ្របសង្កត់នូវចិត្តរបស់តថាគតបានឡើយ ។

[ ៧០ ] ម្នាលអគ្គិវេស្សនៈ តថាគតធ្លាប់ជាអ្នកសម្ដែងធម៌ដល់បរិស័ទច្រើនរយ ។ ជនម្នាក់ៗ សម្គាល់តថាគតយ៉ាងនេះថា ព្រះសមណគោតមសម្ដែងធម៌ចំពោះអញតែម្នាក់ឯង ។ ម្នាលអគ្គិវេស្សនៈ ចំណែកអ្នកកុំគប្បីយល់ឃើញយ៉ាងនេះថា ព្រះតថាគតសម្ដែងធម៌ ដល់ជនទាំងឡាយនោះដោយប្រពៃ ដើម្បីប្រយោជន៍ឲ្យគ្រាន់តែចេះដឹងប៉ុណ្ណោះ ដូច្នេះឡើយ ។ ម្នាលអគ្គិវេស្សនៈ តថាគតនោះឯង តែងនៅអស់កាលជានិច្ច ដោយផលសមាធិណា កាលបើចប់គាថានោះហើយ តថាគតក៏តម្រង់ ទប់ទល់ តម្កល់ចិត្តខាងក្នុង ធ្វើឲ្យជាចិត្តមានអារម្មណ៍តែមួយ ក្នុងសមាធិនិមិត្តដែលមានហើយ អំពីមុននោះឯងដោយផលសមាធិនោះ ។ សច្ចកនិគន្ថបុត្រពោលថា ពាក្យរបស់ព្រះគោតមដ៏ចម្រើនដែលជាអរហន្តសម្មាសម្ពុទ្ធនេះ ជាពាក្យគួរជឿពិតហើយ ចុះព្រះគោតមដ៏ចម្រើន ធ្លាប់ផ្ទំលក់ក្នុងវេលាថ្ងៃឬទេ ។ ម្នាលអគ្គិវេស្សនៈ

តថាគតត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាបច្ឆាភត្ត ហើយក្រាលនូវសង្ឃាដិមានជាន់ ៤ ហើយផ្ទាប់សិងដោយចំហៀងខាងស្តាំ មានសតិ និងសម្បជញ្ញៈ ចុះស៊ប់កាន់កិរិយាលក់ ក្នុងខែជាទីបំផុតនៃគិម្ហរដូវ ។ បពិត្រព្រះគោតមដ៏ចម្រើន សមណព្រាហ្មណ៍ពួកខ្លះ ពោលនូវកិរិយាដេកលក់នេះឯងជាជាធម៌ ជាគ្រឿងនៅ ប្រកបដោយសេចក្តីវង្វេង ។ ម្នាលអគ្គិវេស្សនៈ បុគ្គលវង្វេងក្តី មិនវង្វេងក្តី មិនមានដោយហេតុប៉ុណ្ណោះឡើយ ម្នាលអគ្គិវេស្សនៈ មួយយ៉ាងទៀត បុគ្គលវង្វេងក្តី មិនវង្វេងក្តី ដោយហេតុណា អ្នកចូរស្តាប់នូវហេតុនោះចុះ ចូរយកចិត្តទុកដាក់ឲ្យស្រួលបួលចុះ តថាគតនឹងសម្តែងឲ្យស្តាប់ ។ សច្ចកនិគន្ថបុត្រ ក៏ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគដូច្នេះថា ព្រះករុណាព្រះអង្គ ។

[ ៧១ ] ព្រះមានព្រះភាគ ទ្រង់សម្តែងដូច្នេះថា ម្នាលអគ្គិវេស្សនៈ បុគ្គលវង្វេងតើដូចម្តេច ម្នាលអគ្គិវេស្សនៈ អាសវៈទាំងឡាយណាជាធម៌ដ៏សៅហ្មង នាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាកជាទុក្ខ ប្រកបដោយជាតិ និងជរាមរណៈតទៅ បុគ្គលណានីមួយមិនបានលះបោលចេញហើយ តថាគតហៅបុគ្គលនោះ ថាជាអ្នកវង្វេង ម្នាលអគ្គិវេស្សនៈ ព្រោះថា បុគ្គលដែលឈ្មោះថាវង្វេង ព្រោះហេតុតែមិនបានលះបង់បោលនូវអាសវៈទាំងឡាយ ម្នាលអគ្គិវេស្សនៈ អាសវៈទាំងឡាយណា ជាធម៌ដ៏សៅហ្មង នាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាកជាទុក្ខ ប្រកបដោយជាតិ និងជរាមរណៈតទៅ បុគ្គលណានីមួយ បាន

លះបង់ចេញហើយ តថាគតហៅបុគ្គលនោះ ថាជាអ្នកមិនវង្វេង ម្នាលអគ្គិ-វេស្សនៈ ព្រោះថា បុគ្គលដែលឈ្មោះថា មិនវង្វេង ព្រោះបានលះបង់នូវអាសវៈទាំងឡាយចេញស្រឡះហើយ ។ ម្នាលអគ្គិវេស្សនៈ អាសវៈទាំង-ឡាយណា ជាធម៌ដ៏សៅហ្មង នាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាកជាទុក្ខ ប្រកបដោយជាតិ និងជរាមរណៈតទៅ តថាគតបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅរបស់ដើមត្នោត ធ្វើមិនឲ្យបម្រើនតទៅទៀត មានសភាពមិនកើតឡើងតទៅ ។ ម្នាលអគ្គិវេស្សនៈ ដើមត្នោតកំបុតក មិនគួរលូតលាស់ដុះឡើងវិញបាន យ៉ាងណាមិញ ម្នាលអគ្គិវេស្សនៈ អាសវៈទាំងឡាយណា ជាធម៌ដ៏សៅហ្មង នាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានវិបាកជាទុក្ខ ប្រកបដោយជាតិ និងជរាមរណៈតទៅ តថាគតបានលះបង់ចេញស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅរបស់ដើមត្នោត បានធ្វើមិនឲ្យបម្រើនតទៅទៀត មានសភាពមិនកើតឡើងតទៅយ៉ាងនេះឯង ។

[ ៧២ ] កាលដែលព្រះមានព្រះភាគ ទ្រង់ប្រកាសយ៉ាងនេះហើយ សច្ចកនិគន្ថបុត្រ ក៏និយាយដូច្នេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់ ( ព្រោះ ) ព្រះគោតមដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គពោលសង្កត់សង្កិន និយាយដោយគន្លងពាក្យជ្រៀតបៀតផ្សេងៗ យ៉ាងនេះ ក៏នៅតែមានព្រះឆវីវណ្ណផូរផង់ ទាំង

សម្បុរព្រះកក្រ្កទៀតក៏ថ្លាស្រស់បស់ ព្រោះថា ព្រះអង្គ សមជាព្រះអរហន្ត-សម្មាសម្ពុទ្ធពិត បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គធ្លាប់លើកឡើងនូវទោស ដោយពាក្យចំពោះបូរណកស្សប ឯបូរណកស្សបនោះ លុះខ្ញុំព្រះអង្គលើកឡើងនូវទោសដោយពាក្យហើយ ក៏បិទបាំងនូវពាក្យដទៃដោយពាក្យដទៃ ហើយប្រាទពាក្យចោលទៅខាងក្រៅ ហើយធ្វើនូវសេចក្តីក្រោធផង ទោសៈផង សេចក្តីមិនត្រេកអរផង ឲ្យប្រាកដឡើង ចំណែកព្រះគោតមដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គ ពោលសង្កត់សង្កិនទិយាយដោយគន្ទងពាក្យជ្រៀតបៀតផ្សេងៗ យ៉ាងនេះ ក៏នៅតែមានព្រះឆវីវណ្ណផូរផង់ ទាំងសម្បុរព្រះកក្រ្កទៀតក៏ថ្លាស្រស់បស់ ព្រោះថា ព្រះអង្គសមជាព្រះអរហន្តសម្មាសម្ពុទ្ធពិត បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គធ្លាប់លើកឡើងនូវទោស ដោយពាក្យចំពោះមក្ខលិគោសាល ... ចំពោះអជិតកេសកម្ពល ... ចំពោះបកុធកច្ចាយនៈ ... ចំពោះសញ្ជយវេលដ្ឋបុត្រ ... លើកឡើងនូវទោសដោយពាក្យចំពោះនិគន្ថ-នាដបុត្រ ឯនិគន្ថនាដបុត្រនោះ លុះខ្ញុំព្រះអង្គលើកឡើងនូវទោសដោយពាក្យហើយ ក៏បិទបាំងនូវពាក្យដទៃដោយពាក្យដទៃ ហើយប្រាទពាក្យចោលខាងក្រៅ ហើយធ្វើនូវសេចក្តីក្រោធផង ទោសៈផង សេចក្តីមិនត្រេកអរផងឲ្យប្រាកដឡើង ចំណែកព្រះគោតមដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គពោលសង្កត់សង្កិនទិយាយដោយគន្ទងពាក្យជ្រៀតបៀតផ្សេងៗ យ៉ាងនេះហើយ ក៏នៅតែមានព្រះឆវីវណ្ណផូរផង់ ទាំងសម្បុរព្រះកក្រ្កទៀតក៏ថ្លាស្រស់បស់ ព្រោះព្រះអង្គសមជាព្រះអរហន្តសម្មាសម្ពុទ្ធពិត ប៉ុណ្ណឹងចុះព្រះគោតមដ៏ចម្រើន ឥឡូវ

នេះ ខ្ញុំព្រះអង្គសូមលាទៅ ព្រោះមានកិច្ចច្រើន មានការងារច្រើន ។ ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាថា ម្នាលអគ្គិវេស្សនៈ ឥឡូវនេះ អ្នកសម្គាល់នូវកាលដែលគួរនឹងត្រឡប់ទៅវិញចុះ ។ លំដាប់នោះ សច្ចកនិគន្ថ-បុត្រត្រេកអរ រីករាយហើយចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកទីអង្គុយ ចៀសចេញទៅ ។

## មហាសច្ចកសូត្រទី ៦ ចប់

# អដ្ឋកថា

## មហាសច្ចកសូត្រទី ៦

[ ៤៥ ] មហាសច្ចកសូត្រ មានបទផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ ដោយ ៣ បទថា **ឯកំ សមយំ ១ តេន ខោ បន សមយេន ១ បុព្វណ្ហសមយំ ១** លោកពោលជាសម័យមួយ ។ វេលាពួកភិក្ខុបដិបត្តិខ្លួន លុបមុខ កាន់បាត្រ និងចីវរ ថ្វាយបង្គំព្រះចេតិយ ហើយឈរនៅក្នុងរោង ត្រិះរិះថា អញនឹងចូលទៅស្រុកណា ។ សម័យបែបនេះ ព្រះមានព្រះភាគ ឃុំសំពត់ ២ ជាន់ ចងវត្ថពន្ធចង្កេះ ទ្រង់ចីវរបង្សុកូលចៀងស្មា ស្ដេចចេញអំពីព្រះគន្ធកុដិ ដែលពួកភិក្ខុចោមរោម ប្រថាប់ឈរត្រង់មុខព្រះគន្ធកុដិ ។ សច្ចកនិគន្ថបុត្រ សំដៅយកសេចក្ដីនោះហើយ ទើបពោលថា **ឯកំ សមយំ តេន ខោ បន សមយេន បុព្វណ្ហសមយំ** ដូច្នេះ ។ បទថា **បវិសិតុកាមោ** បានដល់ ដាក់ព្រះហឫទ័យយ៉ាងនេះថា តថាគតនឹងចូលទៅបិណ្ឌបាត ។ បទថា **តេនុបសង្កមិ** សួរថា សច្ចកនិគន្ថបុត្រ ចូលទៅរកព្រោះហេតុអ្វី ឆ្លើយថា ដោយអធ្យាស្រ័យដើម្បីលើកវាទៈ បានឮថា និគ្រន្ថនោះមានគំនិតយ៉ាងនេះថា គ្រាមុន អញព្រោះមិនបានជាបណ្ឌិត ទើបនាំយកវេសាលីបរិស័ទទាំងអស់ ទៅកាន់សម្នាក់របស់ព្រះសមណគោតម ទើបត្រូវខ្មាសគេក្នុងកណ្ដាលបរិស័ទ តែពេលនេះ អញមិនធ្វើយ៉ាងនោះ ទៅតែម្នាក់ឯង ដើម្បីលើកវាទៈ បើអញអាចឲ្យព្រះសមណគោតមចាញ់បាន នឹងសម្ដែងលទ្ធិរបស់ខ្លួន ហើយធ្វើនូវការឈ្នះ បើព្រះសមណគោតមឈ្នះ

ក៏មិនមានអ្នកណាដឹង ដូចរាំក្នុងទីងងឹត ទើបកាន់យកបញ្ហាបុគ្គលអាក្រាត ចូលទៅរកដោយអធ្យាស្រ័យនៃវាទៈនេះ ។

បទថា **អនុកម្បំ ឧបាទាយ** សេចក្តីថា អាស្រ័យសេចក្តីករុណាដល់សច្ចកនិគន្ថបុត្រ ។ បានឮថា ព្រះថេរៈមានគំនិតយ៉ាងនេះថា កាលព្រះមានព្រះភាគគង់មួយសន្ទុះ និគ្រន្ថនឹងបានគាល់ព្រះពុទ្ធ នឹងបាននូវការស្តាប់ធម៌ ការគាល់ព្រះពុទ្ធ និងការស្តាប់ធម៌ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់និគ្រន្ថនេះ អស់កាលយូរ ព្រោះដូច្នោះ ព្រះថេរៈទូលអារាធនាព្រះមានព្រះភាគ ហើយបត់បង្សុកូលចីវរជា ៤ ជាន់ ធ្វើជាកម្រាល ទើបបានក្រាបទូលថា សូមព្រះមានព្រះភាគប្រថាប់គង់ចុះ ។ ព្រះមានព្រះភាគទ្រង់កំណត់ថា អាននូវពោលហេតុ ទើបប្រថាប់គង់លើអាសនៈដែលរៀបចំថ្វាយ ។

[ ៤៦ ] បទថា **ភគវន្តំ ឯតទវោច** សេចក្តីថា និគ្រន្ថខ្ចប់បញ្ហាដែលជាសារៈ កាន់យកមកដាក់ទុកត្រង់ខាងៗ ។ ក្រាបទូលពាក្យជាដើមនោះថា **ភោ គោតម ។** បទថា **ផុសន្តិ ហិ ភោ គោតម** សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះ រមែងពាល់ត្រូវ គឺរមែងបាន គឺជួបនូវទុក្ខវេទនាដែលកើតក្នុងសរីរកាយ ។ បទថា **ឩរុក្ខម្ភោ** សេចក្តីថា ភ្លៅរឹង អធិប្បាយថា ភ្លៅរឹង តែក្នុងទីនេះ ដោយអត្ថថា ធ្វើឲ្យកាន់កាំង ទើបជាពាក្យអនាគតថា **ភវិស្សតិ ។** បទថា **កាយន្វយំ ហោតិ** គឺចិត្តទៅតាមកាយ គឺប្រព្រឹត្តទៅតាមអំណាចកាយ ។ ឯវិបស្សនា ហៅថា **កាយភាវនា** បុគ្គលដល់នូវ

ការរាយមាយទាំងកាយ និងចិត្ត រមែងមិនមាន និគ្រន្ថពោលដល់ទីមិនមាន មិនកើតប៉ុណ្ណោះ ដោយប្រការដូច្នេះ សមថ: ហៅថា ចិត្តភាវនា ដូច្នេះ ក៏មាន សេចក្ដីថា ភាពរឹងក្លៀវជាដើម នៃបុគ្គលដែលប្រកបដោយសមាធិ រមែងមិនមាន និគ្រន្ថពោលចំពោះវត្ថុដែលមិនមាន ដោយប្រការដូច្នេះ ។ ឯក្នុងអដ្ឋកថា ពោលថា កាលបុគ្គលពោលថា រឿងធ្លាប់មានមកហើយ ក៏នៅតែពោលពាក្យជាដើមថា ឈ្មោះថា ភាពដែលក្លៀវរឹង ក៏នឹងមាន ដែលជាពាក្យអនាគត មិនត្រឹមត្រូវយ៉ាងណា អត្ថក៏មិនត្រឹមត្រូវយ៉ាងនោះ និគ្រន្ថពោលដល់វត្ថុដែលមិនមាន មិនកើត ។ បទថា **នោ កាយភាវនំ** គាត់ពោលសំដៅយកបដិបត្តិខ្ទនឲ្យលំបាក មានការធ្វើសេចក្ដីព្យាយាម ៥ ប្រការជាដើម ។ នេះឈ្មោះថា កាយភាវនារបស់សមណព្រាហ្មណ៍ទាំងនោះ ។ សួរថា និគ្រន្ថនោះឃើញអ្វី ទើបបានពោលយ៉ាងនេះ ឆ្លើយថា បានឮថា និគ្រន្ថនោះ មកកាន់ទីសម្រាកពេលថ្ងៃ សម័យនោះឯង ពួកភិក្ខុទុកដាក់បាត្រ និងចីវរ ហើយចូលទៅដើម្បីពួនសម្ងំក្នុងទីសម្រាកពេលយប់ និងពេលថ្ងៃរៀងៗខ្ទនិគ្រន្ថនោះ ឃើញពួកភិក្ខុទាំងនោះពួនសម្ងំ សម្គាល់ថា ពួកភិក្ខុទាំងនោះប្រឹងប្រែងប្រកបព្យាយាមនូវចិត្តភាវនា តែកាយភាវនា មិនមានដល់ភិក្ខុទាំងនោះ ទើបពោលយ៉ាងនេះ ។

[ ៤៧ ] លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សាកសួរនិគ្រន្ថនោះ ទើបត្រាស់សួរថា ម្នាលអគ្គិវេស្សនៈ ចុះកាយភាវនា អ្នកបានឮមកដូចម្ដេច និគ្រន្ថនោះកាលនឹងពោលកាយភាវនានោះឲ្យពិស្ដារ ទើបទូលពាក្យជាដើមថា

គឺនទ្ធៈដែលជាវច្ឆគោត្រ ។ បណ្តាបទទាំងនោះ បទថា **នន្ទោ** ជាឈ្មោះរបស់អចេលកនោះ ។ បទថា **វច្ឆោ** ជាគោត្រ ។ បទថា **កិសោ** ជាឈ្មោះ ។ បទថា **សង្កិច្ចោ** ជាគោត្រ ។ មក្ខលិគោសាលមកហើយខាងដើមនោះឯង ។ បទថា **ឯតេ** បានដល់ ជនទាំង ៣ នាក់នោះ បានឮថា ជនទាំងនោះបានសម្រេចទីបំផុតនៃតបៈដែលសៅហ្មង ។ បទថា **ឧឡារានិ** គឺភោជនដែលប្រណីតៗ ។ បទថា **គាហេន្តិ នាម** ឈ្មោះថា រមែងឲ្យរាងកាយមានកម្លាំង ។ បទថា **ព្រូហេន្តិ** គឺឲ្យចម្រើន ។ បទថា **មេទេន្តិ** គឺធ្វើឲ្យកើតខ្លាញ់ខាប់ ។ បទថា **បុរិមំ បហាយ** បានដល់ លើកនូវការធ្វើឲ្យលំបាកដូចអំពីមុន ។ បទថា **បុច្ឆា ឧបចិនន្តិ** សេចក្តីថា ឲ្យឆ្អែតស្កប់ស្កល់ គឺឲ្យចម្រើនដោយរបស់គួរទំពាដ៏ប្រណីតជាដើម ។ បទថា **អាចយាបចយោ ហោតិ** គឺសេចក្តីចម្រើន និងសេចក្តីវិនាស រមែងប្រាកដត្រឹមតែសេចក្តីចម្រើន និងសេចក្តីវិនាស កាយនេះមានការចម្រើនតាមកាល មានការវិនាសតាមកាល ។

[ ៤៨ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា កាយភាវនាមិនប្រាកដត្រាស់សួរចិត្តភាវនា ត្រាស់សួរថា ម្នាលអគ្គិវេស្សនៈ ចុះចំណែកខាងចិត្តភាវនា អ្នកបានឮមកដូចម្តេច ។ បទថា **ន សម្បាយាសិ** សេចក្តីថា មិនអាចទូលឲ្យបរិបូណ៌បាន ដូចពាលបុថុជ្ជន ។ បទថា **កុតោ បន ត្វំ** សេចក្តីថា បុគ្គលណាមិនដឹងនូវការចម្រើននៃរាងកាយ ដែលខ្សោយកម្លាំង ជាចំណែកគ្រោតគ្រាតយ៉ាងនេះ បុគ្គលនោះ នឹងដឹងចិត្តភាវនាដ៏ល្អិតសុខុមបាន

អំពីណា ។ ឯក្នុងទីនេះ ព្រះចោទនាលយត្ថេរគិតថា បទនោះមិនឈ្មោះថាជាពុទ្ធវចនៈឡើយ ដាក់ផ្តិតវិជនី បៀសចេញទៅ ។ បន្ទាប់មក ព្រះមហាសិវៈ អានព្រះពុទ្ធវចនៈនោះថា ម្នាលភិក្ខុទាំងឡាយ ការបម្រើនក្តី ការវិនាសក្តី បដិសន្ធិក្តី ចុតិក្តីរបស់កាយដែលជាមហាភូត ៤ នេះ នឹងប្រាកដ ព្រះថេរៈស្តាប់ពាក្យនោះហើយ កំណត់ថា គួរពោលថា កាលកំណត់កាយជាចំណែកគ្រោតគ្រាត វិបស្សនាដែលកើតក៏ជាចំណែកគ្រោតគ្រាត ដូច្នេះ ។

[ ៤៩ ] បទថា **សុខសាភាគី** គឺជាអ្នកប្រកបដោយភាគៈ ក្នុងសេចក្តីសុខ ។ បទថា **សុខាយ វេទនាយ និរោធា ឧប្បជ្ជតិ ទុក្ខា វេទនា** គឺរមែងកើតក្នុងលំដាប់ សម្រេចហើយក្នុងគម្ពីរបដ្ឋាន ព្រោះទុក្ខវេទនានោះ ជាអនន្តរបច្ច័យដល់សុខ និងទុក្ខ តែព្រោះកាលសុខវេទនាមិនទាន់រលត់ ទុក្ខវេទនាក៏មិនកើត ដូច្នោះ ទើបលោកពោលទុកក្នុងទីនេះ ។ បទថា **បរិយាទាយ តិដ្ឋតិ** សេចក្តីថា ឲ្យវេទនាអស់ទៅ ប្រកាន់ទុក ។ បទថា **ឧភតោបក្ខំ** សេចក្តីថា ជា ២ ចំណែកយ៉ាងនេះ គឺសុខមួយចំណែក ទុក្ខមួយចំណែក ។ វិនិច្ឆ័យក្នុងបទថា **ឧប្បន្នាបិ ។បេ។ ចិត្តស្ស** ដូចតទៅនេះថា កាយភាវនាជាវិបស្សនា ចិត្តភាវនាជាសមាធិ ឯវិបស្សនាជាសត្រូវចំពោះសុខ ជិតចំពោះទុក្ខ សមាធិជាសត្រូវចំពោះទុក្ខ ជិតចំពោះសុខ ។ សេចក្តីនេះដូចម្តេច ពិតហើយ កាលព្រះយោគាវចរអង្គុយប្រារព្ធវិបស្សនា កាលរយៈពេលកន្លងទៅយូរ ចិត្តរបស់លោករមែងក្តៅក្រហាយ អន្ទះអន្ទែង ប្រាកដដូចភ្លើងដែលឆេះសន្ទោសន្ទៅក្នុងទីនោះ ញើសហូរអំពីក្លៀក កម្តៅតាំង

ឡើងដល់ក្បាល ដោយហេតុមានប្រមាណប៉ុណ្ណេះ វិបស្សនាជាសត្រូវចំពោះសុខ ជិតចំពោះទុក្ខ ។ កាលទុក្ខផ្លូវកាយ ឬផ្លូវចិត្តកើតហើយ ទុក្ខក្នុងខណៈសមាបត្តិរបស់លោក ដែលជាអ្នកសង្កត់នូវទុក្ខនោះ ចូលសមាបត្តិរមែងប្រាសចាកទុក្ខ ឈមចុះកាន់សេចក្ដីសុខមិនមែនតិច កាលបើយ៉ាងនេះ ទើបសមាធិជាសត្រូវចំពោះទុក្ខ ជិតចំពោះសុខ ។ វិបស្សនា ជាសត្រូវចំពោះសុខ ជិតចំពោះទុក្ខ យ៉ាងណា សមាធិ មិនដូច្នោះឡើយ ។ សមាធិជាសត្រូវចំពោះទុក្ខ ជិតចំពោះសុខ យ៉ាងណា ឯវិបស្សនាមិនដូច្នោះឡើយ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឧប្បន្នាបិ ។បេ។ ចិត្តស្ស ។**

[ ៥០ ] បទថា **អាសជ្ជ ឧបនីយ** បានដល់ ទាក់ទងនឹងការនាំចូលទៅកាន់គុណ ។ បទថា **តំ វត មេ** បានដល់ ចិត្តរបស់តថាគតនោះហ្ន៎ ។

[ ៥១-៥៣ ] បទ ថា **កិញ្ចិ នោ សិយា អគ្គិវេស្សន** សេចក្ដីថា ម្នាលអគ្គិវេស្សនៈ អ្វីនីងមិនមាន អ្វីនឹងមាន អ្នកកុំសម្គាល់យ៉ាងនេះឡើយ សុខវេទនាក្ដី ទុក្ខវេទនាក្ដី តែងកើតដល់អញ តែកាលកើតឡើងហើយ អញនឹងមិនឲ្យគ្របសង្កត់ចិត្ត ។ ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់មានបំណងនឹងសម្ដែងព្រះធម្មទេសនាដែលជាទីមកនៃការជ្រះថ្លាយ៉ាងខ្ពស់ ដើម្បីប្រកាសអត្ថនោះដល់និគ្រន្ថនោះ ទើបទ្រង់ប្រារព្ធមហាភិនេស្ក្រមណ៍តាំងអំពីដើម ក្នុងបទថា **ឥធ ។បេ។ បធានាយ** នោះ នេះទាំងអស់ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងបាសរាសិសូត្រខាងដើម ។ ឯសេចក្ដីផ្សេងគ្នា មានដូច្នេះ គឺការអន្ទុយលើពោធិបល្ល័ង្កនោះ ជាការធ្វើដែលធ្វើបានលំបាកក្នុងសេចក្ដីនេះ ។

[ ៥៤-៥៥ ] បទថា **អល្លកដ្ឋំ** គឺដើមល្វាស្រស់ ។ បទថា **សស្នេហំ** គឺមានជ័រដូចទឹកដោះ ។ បទថា **កាមេហិ** គឺចាកវត្ថុកាម ។ បទថា **អវូបកដ្ឋា** គឺមិនចៀសចេញ ។ កិលេសកាម ក្នុងបទជាដើមថា **កាមច្ឆន្ទោ** គប្បីជ្រាបថា ដោយអំណាចការពេញចិត្ត **សិនេហា** ដោយអំណាចការជាប់ជំពាក់ **មុច្ឆា** ដោយអំណាចការងប់ **បិបាសា** ដោយអំណាចធ្វើនូវការស្រេកឃ្លាន **បរិឡាហា** ដោយអំណាចការតាមដុត ។ បទថា **ឱបក្កមិកា** គឺកើតព្រោះសេចក្តីព្យាយាម ។ បទថា **ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ** ទាំងអស់នេះជាវេវចនៈនៃលោកុត្តរមគ្គ ។

មានឧបមាប្រៀបក្នុងសេចក្តីនេះដូច្នេះថា គឺបុគ្គលនៅមានកិលេសកាម មិនទាន់ចេញចាកវត្ថុកាម ដូចដើមល្វាស្រស់មានជ័រ សើមដោយកិលេសកាម ដូចឈើដែលត្រាំក្នុងទឹក ការមិនសម្រេចលោកុត្តរមគ្គ ដោយវេទនាដែលកើតព្រោះការព្យាយាមរបស់បុគ្គលដែលមានកិលេសកាម មិនទាន់ចេញចាកវត្ថុកាម ទោះយកទៅធ្វើជាឈើកួតភ្លើង ភ្លើងក៏មិនកើត ។ ការមិនសម្រេចលោកុត្តរមគ្គរបស់បុគ្គលទាំងនោះ វៀរចាកវេទនាដែលកើតព្រោះសេចក្តីព្យាយាម ដូចឈើកួតភ្លើង តែបុរសមិនបានកួត ភ្លើងក៏មិនកើត សូម្បីឧបមាទី ២ គប្បីជ្រាបដោយន័យនេះឯង ។ ឯការផ្សេងគ្នាដូច្នេះ គឺ ដំបូងជាឧបមានៃការបួសប្រកបដោយបុត្រ និងភរិយា ឧបមាក្រោយនៃការបួសរបស់ព្រាហ្មណ៍ដែលទ្រទ្រង់ធម៌ ។

[ ៥៦ ] បទថា **កោលាបំ** ក្នុងឧបមាទី ៣ បានដល់ កំណាត់ឈើ

ដែលមិនមានជ័រ ។ បទថា **ថលេ និក្ខិត្តំ** គឺដែលគេចោលលើគោក ឬលើផែនដី ក៏មានឧបមាប្រៀបធៀបក្នុងសេចក្ដីនេះដូច្នេះ គឺ បុគ្គលមាន កិលេសកាម ចេញចាកវត្ថុកាម ដូចឈើស្ងួតល្អ មិនសើមដោយកិលេសកាម ដូចឈើ ដែលគេទុកលើគោកឆ្ងាយអំពីទឹក ការសម្រេចលោកុត្តរមគ្គ ដោយវេទនា សូម្បីកើតព្រោះសេចក្ដីព្យាយាម មានការអង្គុយក្នុងទីវាលជាដើមរបស់បុគ្គល មានកិលេសកាម ចេញចាកវត្ថុកាម ដូចកូនពំនួតភ្លើងដែលស្ងួត កាលបុរស ព្យាយាមកួត ភ្លើងក៏កើត ការសម្រេចលោកុត្តរមគ្គ ដោយសុខាបដិបទា វៀរចាកវេទនាដែលកើតព្រោះសេចក្ដីព្យាយាម ដូចកើតភ្លើង ដោយត្រឹមតែ ការកួតនឹងមែកឈើដទៃ ។ ឧបមានេះ ព្រះមានព្រះភាគ ទ្រង់នាំមកដើម្បី ប្រយោជន៍ដល់ព្រះអង្គ ។

[ ៥៧ ] ឥឡូវនេះ កាលទ្រង់សម្ដែងទុក្ករកិរិយា របស់ព្រះអង្គ ទើបត្រាស់ថា **តស្ស មយ្ហំ** ជាដើម ។ ព្រះមានព្រះភាគ ទ្រង់មិនធ្វើទុក្ករ-កិរិយាហើយ មិនអាចត្រាស់ជាព្រះពុទ្ធបានឬ ទ្រង់ធ្វើក៏ដោយ មិនធ្វើក៏ដោយ ក៏អាចត្រាស់ជាព្រះពុទ្ធបានដែរ ។ សួរថា បើដូច្នោះ ទ្រង់ធ្វើ ព្រោះហេតុអ្វី ឆ្លើយថា តថាគតនឹងសម្ដែងសេចក្ដីព្យាយាមរបស់ខ្លួនដល់លោក ព្រមទាំង ទេវលោក និងគុណ គឺការញ៉ាំញីដោយសេចក្ដីព្យាយាមនោះ និងឲ្យតថាគត ត្រេកអរបាន ។ ពិតហើយ ក្សត្រគង់លើប្រាសាទ ព្រះអង្គក៏បានទទួលរាជ-សម្បត្តិបន្តតាមព្រះរាជប្បវេណី ទ្រង់មិនត្រេកអរយ៉ាងនោះ រាជសម្បត្តិដែល នាំយកពួកពលទៅប្រហារសត្រូវ ២-៣ នាក់ ទម្លាយសត្រូវបានមក សោម-

នសង្រ្គាមដ៏មានកម្លាំង រមែងកើតដល់ព្រះអង្គដែលបានសោយសិរីរាជសម្បត្តិយ៉ាងនោះ ទ្រង់សម្លឹងមើលបរិស័ទ ទ្រង់រំពឹងដល់សេចក្តីព្យាយាមរបស់ខ្លួនហើយ ទ្រង់ត្រិះរិះថា អញធ្វើកម្មនោះ ក្នុងទីនោះ ចាក់យ៉ាងនោះ ប្រហារយ៉ាងនេះ នូវសត្រូវនោះ និងនោះ ទើបបានសោយសិរីរាជសម្បត្តិនេះ យ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះដូចគ្នា ទ្រង់ត្រិះរិះថា តថាគតនឹងបង្ហាញសេចក្តីព្យាយាមដល់លោក ព្រមទាំងទេវលោក ឯការព្យាយាមនោះ នឹងធ្វើឲ្យតថាគតត្រេកអរ ឲ្យកើតសោមនស្សយ៉ាងក្រៃលែង ទើបបានធ្វើទុក្ករកិរិយា ម្យ៉ាងទៀត កាលនឹងអនុគ្រោះពពួកជនដែលកើតឯក្រោយ ទ្រង់ក៏បានធ្វើដូចគ្នា ពួកជនដែលកើតឯក្រោយ នឹងសម្គាល់សេចក្តីព្យាយាមដែលគួរធ្វើថា ព្រះសម្មាសម្ពុទ្ធគង់ទ្រង់បំពេញបារមីអស់ ៤ អសង្ខេយ្យ និងមួយសែនកប្ប ទ្រង់តាំងសេចក្តីព្យាយាម សម្រេចព្រះសព្វញ្ញុតញ្ញាណ នឹងពោលទៅថ្វីដល់ពួកយើងនោះ ដែលមានសភាពយ៉ាងនេះ ព្រះមានព្រះភាគទ្រង់ត្រិះរិះថា ពពួកជននឹងធ្វើទីបំផុតនៃជាតិ ជរា និងមរណៈបាន ដោយឆាប់រួសរាន់ ព្រោះដូច្នោះ កាលទ្រង់អនុគ្រោះពពួកជន ដែលកើតឯក្រោយទើបទ្រង់ធ្វើដូចគ្នា ។ បទថា **ទន្តេហិ ទន្តមាធាយ** បានដល់ សង្កត់ធ្មេញលើដោយធ្មេញក្រោម ។ បទថា **ចេតសា ចិត្តំ** បានដល់ សង្កត់អកុសលចិត្តដោយកុសលចិត្ត ។ បទថា **អភិនិគ្គណ្ហេយ្យំ** គឺគប្បីសង្កត់ ។ បទថា **អភិនិប្បីឡេយ្យំ** គឺគប្បីគ្របសង្កត់ ។ បទថា **អភិនិសន្តាបេយ្យំ** សេចក្តីថា គប្បីធ្វើឲ្យក្តៅក្រហាយ ហើយទម្លាយ ញាំញីដោយសេចក្តីព្យាយាម ។

បទថា **សារទ្ធោ** គឺមានកាយក្រវល់ក្រវាយ ។ បទថា **បធានាភិតុន្នស្ស** សេចក្តីថា មានសតិដែលសេចក្តីព្យាយាមបៀតបៀន គឺចាក់ហើយ ។

[ ៥៨ ] បទថា **អប្បាណកំ** គឺមិនមានខ្យល់ដង្ហើម ។ បទថា **កម្មារគគ្គរិយា** បានដល់ ស្នប់ជាងមាស ។

[ ៦០ ] បទថា **សីសវេទនា ហោន្តិ** សេចក្តីថា វេទនាកើតអំពីក្បាលដ៏មានកម្លាំង ត្រូវខ្យល់វិលវល់ ចេញទៅណាមិនបាន ។ បទថា **សីសវេដ្ឋំ ទទេយ្យ** បានដល់ គប្បីចងរឹតត្រង់ក្បាល ។

[ ៦៣ ] បទថា **ទេវតា** សេចក្តីថា ទេវតាដែលអាស្រ័យនៅក្នុងទីបំផុតនៃទីចង្ក្រមរបស់ព្រះពោធិសត្វ និងជិតបរិវេណបណ្ណសាលា ។ បានឮថា ក្នុងកាលនោះ កាលការក្តៅក្រហាយក្នុងព្រះកាយ ដែលមានប្រមាណក្រៃលែងរបស់ព្រះពោធិសត្វកើតឡើង ទ្រង់អស់ស្មារតី ទ្រង់ប្រថាប់គង់ដួលរលំលើទីចង្ក្រម ។ ទេវតាឃើញព្រះពោធិសត្វនោះ ទើបពោលថា ព្រះពោធិសត្វអស់ព្រះជន្មទៅហើយ ទើបពួកទេវតាទាំងនោះ ទៅក្រាបទូលចំពោះព្រះបាទសុទ្ធោទនមហារាជថា ព្រះឱរសរបស់ព្រះអង្គអស់ព្រះជន្មទៅហើយ ។ ព្រះបាទសុទ្ធោទនមហារាជត្រាស់ថា នែទេវតា កូនរបស់ខ្ញុំត្រាស់ជាព្រះពុទ្ធហើយ ទើបធ្វើកាលកិរិយា បើមិនទាន់ត្រាស់ជាព្រះពុទ្ធទេ មិនធ្វើកាលកិរិយាឡើយ ។ ទេវតាពោលថា បពិត្រមហារាជ មិនអាចជាព្រះពុទ្ធបានឡើយ ដួលនៅលើទីសម្រាប់ធ្វើសេចក្តីព្យាយាម អស់ព្រះជន្មហើយ ។ ព្រះបាទសុទ្ធោទនៈពោលថា ខ្ញុំមិនជឿ ការអស់ព្រះជន្មមិនមានដល់ព្រះឱរសរបស់ខ្ញុំ

ឡើយ ព្រោះមិនទាន់សម្រេចពោធិញ្ញាណ ។ ចំណេរកាលតមក កាលព្រះសម្មាសម្ពុទ្ធទ្រង់ញុំាងធម្មចក្រឲ្យវិលទៅ ទ្រង់យាងទៅកាន់ក្រុងរាជគ្រឹះដោយលំដាប់ ហើយយាងដល់ក្រុងកបិលពស្តុ ព្រះបាទសុទ្ធោទនមហារាជទ្រង់ទទួលបាត្រ នាំព្រះមានព្រះភាគឡើងកាន់ប្រាសាទ ថ្វាយបបរ និងខាទនីយៈ ទូលរឿងនោះក្នុងចន្លោះភត្តថា បពិត្រព្រះមានព្រះភាគ ក្នុងកាលព្រះអង្គធ្វើសេចក្តីព្យាយាម ទេវតាមកប្រាប់ថា នែមហារាជ ឱរសរបស់ព្រះអង្គអស់ព្រះជន្មហើយ ព្រះមានព្រះភាគត្រាស់ថា មហាបពិត្រ ព្រះអង្គជឿឬ ព្រះបាទសុទ្ធោទនៈទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនជឿទេ ។ ព្រះមានព្រះភាគត្រាស់ថា មហាបពិត្រ ឥឡូវនេះ ព្រះអង្គទ្រង់ឃើញអស្ចារ្យតាំងអំពីព្រះសុបិន គង់នឹងជឿឬ សូម្បីតថាគតជាព្រះពុទ្ធ មហាបពិត្រជាពុទ្ធ-បិតា ឯក្នុងកាលមុន កាលនោះ ញាណរបស់តថាគតមិនទាន់ចាស់ក្លា បំពេញពោធិចរិយានៅឡើយ ដើម្បីសិក្សាសិប្បៈក្នុងកាលជាធម្មបាលកុមារ ។ ព្រះមានព្រះភាគត្រាស់មហាធម្មបាលជាតក ព្រោះការកើតឡើងនៃរឿងនេះថា ជនទាំងឡាយ នាំឆ្អឹងពពែមកបង្ហាញថា ធម្មបាលកុមារកូនរបស់អ្នកស្លាប់ហើយ នេះឆ្អឹងរបស់គេ ដូច្នេះ ។ មហាបពិត្រ ក្នុងកាលនោះ ព្រះអង្គបានត្រាស់ថា ការស្លាប់ក្នុងចន្លោះអាយុរបស់កូនខ្ញុំ មិនមានឡើយ ខ្ញុំមិនជឿទេ ដូច្នេះ ។

បទថា **មា ខោ ត្វំ មារិស** បានដល់ ពួកទេវតាដែលស្រឡាញ់រាប់អានមកក្រាបទូល ។ បានឮថា រោហារគួរស្រឡាញ់ គួរពេញចិត្តរបស់ពួក

ទេវតា គឺ មារិស ។ បទថា **អជជ្ជិតំ** គឺមិនមែនភោជន ។ បទថា **ហាលន្តិ វទាមិ** គឺតថាគតពោលថា គ្រប់គ្រាន់ហើយ អធិប្បាយថា តថាគតហាម យ៉ាងនេះថា អ្នកកុំធ្វើយ៉ាងនេះដោយបទនេះ តថាគតនឹងញ៉ាំងអត្តភាពឲ្យ ប្រព្រឹត្តទៅបានហើយ ។

[ ៦៤ ] បទថា **មន្ទុរច្ឆវី** គឺមានសម្បុរប្រផេះ ។

[ ៦៥ ] បទថា **ឯតាវបរមំ** សេចក្ដីថា ប្រមាណនោះ ជាប្រមាណ ក្រៃលែង គឺខ្ពស់បំផុតនៃវេទនាទាំងនោះ ។ បទថា **បិតុ សក្កស្ស កម្មន្តេ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតា** សេចក្ដីថា បានឮថា ក្នុងថ្ងៃនោះ ឈ្មោះថា ជាថ្ងៃវប្បមង្គល គឺ ថ្ងៃច្រត់ព្រះនង្គ័លរបស់ព្រះរាជាៗ ទាំងឡាយ រៀបចំខាទនីយៈ និងភោជនីយាហារជាច្រើនប្រការ លាងជួល់ព្រះនគរឲ្យ ស្អាត តម្កល់ក្អមពេញដោយទឹក លើកទង់ផ្កាលាជាដើមឡើង ប្រដាប់ទូទៅ ក្នុងព្រះនគរ ដូចទេវវិមាន ទាសៈ និងកម្មករទាំងពួង ស្លៀកសំពត់ថ្មី ប្រដាប់ ដោយគ្រឿងក្រអូប និងផ្កាជាដើម ប្រជុំគ្នាក្នុងរាជត្រកូល ក្នុងរាជពិធី ពួក គេប្រកបនង្គ័ល ១០០០ តែក្នុងថ្ងៃនោះ រាជបុរសប្រកបនង្គ័ល ៨០០ ខ្វះ ១ នង្គ័លទាំងអស់ ព្រមទាំងខ្សែចងគោជំទង់រំលេចដោយប្រាក់ ដូចគ្នានឹងរថ របស់ជាណុស្សោណិព្រាហ្មណ៍ ដូច្នោះ ដងនង្គ័លរបស់ព្រះរាជាមានសំណុំ កន្ទុយចាមរីសំយុងចុះ ដែលរំលេចដោយមាសក្លីផ្នែក ស្នែងរបស់គោក្តី ខ្សែ និងជន្ទញក្តី ស្រោបដោយមាស ព្រះរាជាចេញទៅដោយបរិវារធំ ទទួលយក ឱរសទៅដែរ ក្នុងទីប្រកបព្រះរាជពីធីច្រត់ព្រះនង្គ័ល មានដើមព្រីងមួយដើម

មានស្លឹកក្រាស់ មានម្លប់ត្រជាក់ ខាងក្រោមដើមព្រីងនោះ ព្រះរាជាប្រាប់ឲ្យក្រាលទែនបន្ទំរបស់កុមារខាងលើ ចងពិតាន សំយុងដោយផ្កាយមាស ព័ទ្ធដោយរាំងនន ចាត់ចែងនូវការរក្សា ទ្រង់គ្រឿងអលង្ការសព្វយ៉ាង ហែហមដោយពួកអមាត្យ យាងចូលទៅកាន់ ព្រះរាជពិធីច្រត់ព្រះនង្គ័ល ក្នុងទីនោះព្រះរាជាទ្រង់កាន់ដងនង្គ័លមាស ពួកអមាត្យកាន់ដងនង្គ័លប្រាក់ ៨០០ ខ្វះ ១ អ្នកស្រែកាន់នង្គ័លដ៏សេស ៗ ពួកជនទាំងនោះ កាន់ដងនង្គ័លនោះ ភ្ជួរទៅខាងនោះ ខាងនេះ ៗ ឯព្រះរាជាទ្រង់ភ្ជួរខាងនេះ ទៅខាងនោះ ឬអំពីខាងនោះ មកខាងនេះ ៗ ក្នុងទីនេះ ជាមហាសម្បត្តិ ភីលៀងទាំងឡាយអង្គុយចោមរោមព្រះពោធិសត្វ គិតថា អញនឹងឃើញសម្បត្តិរបស់ព្រះរាជា ទើបនាំគ្នាចេញទៅខាងក្រៅរាំងនន ព្រះពោធិសត្វក្រឡេកមើលខាងនោះ ខាងនេះមិនឃើញបុគ្គលណាម្នាក់ ទើបប្រញាប់ក្រោកឡើង អង្គុយពត់ភ្នែន កំណត់ខ្យល់ដង្ហើមចូល-ចេញ ញុំាងបឋមជ្ឈានឲ្យកើត ៗ ភីលៀងទាំងឡាយ រវល់តែត្រាច់ទៅក្នុងរោងរោងអាហារយូរទៅបន្តិច ស្រមោលរបស់ឈើដទៃក៏ជ្រេទៅ តែស្រមោលរបស់ដើមឈើនោះ តាំងនៅជាបរិមណ្ឌលដដែល ៗ ពួកភីលៀងគិតថា ព្រះរាជបុត្រនៅមួយព្រះអង្គឯង ទើបបើករាំងននឡើង ចូលទៅខាងក្នុង ឃើញព្រះពោធិសត្វ គង់ពត់ភ្នែនលើទីបន្ទំ ឃើញបាដិហារ្យនោះហើយ ទើបទៅក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ ព្រះកុមារគង់យ៉ាងនេះ ស្រមោលរបស់ដើមឈើដទៃជ្រេទៅ ស្រមោលដើមព្រីងនៅជាបរិ-មណ្ឌលដដែល ព្រះរាជាយាងទៅដោយរហ័ស ទ្រង់ឃើញបាដិហារ្យ ទ្រង់

ថ្វាយបង្គំព្រះឱរស ដោយព្រះតម្រាស់ថា នេះជាការថ្វាយបង្គំអយ្យបុត្រជាលើកទី ២ ។ បទថា **បិតុ សក្កស្ស កម្មន្តេ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតា** នេះ លោកពោលសំដៅយកពាក្យនេះ ។ បទថា **សិយា នុ ខោ ឯសោ មគ្គោ ពោធាយ** សេចក្ដីថា អានាបានស្សតិបឋមជ្ឈាននេះ គប្បីជាផ្លូវដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងហ្ន៎ ។ បទថា **សតានុសារិវិញ្ញាណំ** សេចក្ដីថា វិញ្ញាណដែលកើតក្នុងលំដាប់នៃសតិដែលកើត ១-២ ខណៈ យ៉ាងនេះថា ការធ្វើវត្តដែលធ្វើបានលំបាកនេះ នឹងមិនជាផ្លូវដើម្បីការត្រាស់ដឹង តែអានាបានស្សតិបឋមជ្ឈាន និងជាអប្បនា ឈ្មោះថា **សតានុសារិវិញ្ញាណ** ។ បទថា **យំ តំ សុខំ** បានដល់ សេចក្ដីសុខក្នុងអានាបានស្សតិបឋមជ្ឈាន ។

[ ៦៦ ] បទថា **បច្ចុបដ្ឋិតា ហោន្តិ** សេចក្ដីថា ទំនុកបម្រុងដោយការធ្វើវត្ត មានការបោសបរិវេណបណ្ណសាលាជាដើម ។ បទថា **ពាហុល្លិកោ** គឺ ប្រាថ្នាច្រើនក្នុងបច្ច័យ ។ បទថា **អាវត្តោ ពាហុល្លាយ** សេចក្ដីថា ជាអ្នកជាប់នៅក្នុងរស វិលមកដើម្បីអាហារដែលប្រណីតជាដើម ។ បទថា **និព្វិជ្ជ បក្កមឹសុ** ពួកបញ្ចវគ្គិយចៀសចេញទៅ ដោយធម្មនិយាម អធិប្បាយថា ទៅតាមធម្មតា ដើម្បីឲ្យឱកាសដល់ព្រះពោធិសត្វបាន កាយវិវេកក្នុងកាលសម្រេចសម្ពោធិញ្ញាណ ហើយកាលទៅ ក៏មិនទៅទីដទៃ ទៅកាន់ក្រុងពារាណសីនោះឯង ។ កាលបញ្ចវគ្គិយទៅហើយ ព្រះពោធិសត្វបាននូវកាយវិវេកអស់កន្លះខែ គង់លើអបរាជិតបល្ល័ង្ក នាពោធិមណ្ឌល ត្រាស់ដឹងសព្វញ្ញុ-

តញ្ញាណហើយ ។

[ ៦៧ ] បទមានបទថា **វិវេច្ចេវ កាមេហិ** ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងភយភេរវសូត្រ ។

[ ៧០ ] បទថា **អភិជានាមិ ខោ បនាហំ** នេះ គឺជាអនុសន្ធិមួយផ្នែក ។ បានឮថា និគ្រន្ថគិតថា អញទូលសួរបញ្ហាមួយដល់ព្រះសមណគោតមៗ ត្រាស់ថា ម្នាលអគ្គិវេស្សនៈ ទេវតាដទៃទៀតសួរតថាគត ម្នាលអគ្គិ-វេស្សនៈ ទេវតាដទៃទៀតសួរតថាគត កាលទ្រង់មិនឃើញទីបំផុត ត្រាស់យ៉ាងនោះ ព្រះអង្គមានសេចក្ដីក្រោធឬ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលអគ្គិវេស្សនៈ កាលតថាគតសម្ដែងធម៌ក្នុងបរិស័ទរាប់រយ បុគ្គលសូម្បីតែម្នាក់ដែលពោលថា ព្រះសមណគោតមក្រោធហើយ មិនមាន ម្យ៉ាងទៀត តថាគតសម្ដែងធម៌ដល់ជនដទៃ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹង ដើម្បីប្រយោជន៍ដល់ការចាក់ធ្លុះ កាលទ្រង់សម្ដែងធម៌ ទើបផ្ដើមទេសនានេះ ។ បណ្ដាបទទាំងនោះ បទថា **អារព្ភ** គឺសំដៅយក ។ បទថា **យាវទេវ** គឺជាពាក្យកំណត់វិធីប្រើ មានអធិប្បាយថា ញុំាងបុគ្គលដទៃឲ្យដឹងនោះឯង ជាការប្រកបធម្មទេសនារបស់តថាគត ព្រោះដូច្នោះ ទើបព្រះតថាគតមិនបានសម្ដែងធម៌ដល់បុគ្គលម្នាក់ ទ្រង់សម្ដែងធម៌ដល់បុគ្គលដែលដឹង ដែលមានទាំងអស់ ព្រះមានព្រះភាគ ទ្រង់សម្ដែងដោយបទថា **តស្មឹ យេវ បុរិមស្មឹ** នេះ ទុកដូចម្ដេច បានឮថា សច្ចកនិគ្រន្ថគិតថា ព្រះសមណគោតម មានព្រះរូបស្អាត គួរស្រឡាញ់ ព្រះទន្តរាបស្មើ ព្រះជិវ្ហាទន់ ការសន្ទនាក៏ពីរោះ

ប្រហែលជាត្រាច់ញ៉ាំងបរិស័ទឲ្យត្រេកអរ ។ ចំណែកឯកគ្គតាចិត្តរបស់ព្រះសមណគោតមនោះ មិនមានដល់ព្រះអង្គទេ លំដាប់នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដើម្បីទ្រង់សម្តែងថា ម្នាលអគ្គិវេស្សនៈ តថាគតត្រាច់ញ៉ាំងបរិស័ទឲ្យត្រេកអរ តថាគតសម្តែងធម៌ដល់បរិស័ទពេញចក្រវាល តថាគតមានចិត្តមិនរួញរា មិនប្រឡាក់ ប្រកបរឿយៗ នូវផលសមាបត្តិ ជាសុញ្ញតៈ ដែលជាមគ្គវិហារធម៌តែម្យ៉ាង ប្រមាណប៉ុណ្ណេះ ដូច្នេះ ។ បទថា **អជ្ឈត្តំ** បានដល់ អារម្មណ៍ដែលជាខាងក្នុងប៉ុណ្ណោះ ។ បទថា **សន្និសីទាមិ** គឺញ៉ាំងចិត្តឲ្យស្ងប់ ។ ពិតហើយ ក្នុងខណៈណាបរិស័ទ រមែងឲ្យសាធុការ ខណៈនោះ ព្រះតថាគតទ្រង់កំណត់ចំណែកខាងដើម ទ្រង់ចូលផលសមាបត្តិ កាលសំឡេងអឹងកងនៃសាធុការមិនទាន់ដាច់ ចេញចាកសមាបត្តិសម្តែងធម៌ តាំងអំពីដែលព្រះអង្គទ្រង់តាំងទុកហើយ ព្រោះថា ការនៅក្នុងភវង្គនៃព្រះពុទ្ធទាំងឡាយ រមែងប្រព្រឹត្តទៅរហ័ស រមែងចូលផលសមាបត្តិបាន ក្នុងគ្រាដកដង្ហើមចូល ក្នុងគ្រាដកដង្ហើមចេញ ។ បទថា **យេន សុទំ និច្ចកប្បំ** សេចក្តីថា តថាគតនៅដោយផលសមាធិ ដែលជាសុញ្ញតៈបានអស់កាលជានិច្ច គឺសម្តែងថា តថាគតផ្គងចិត្ត តាំងមាំក្នុងសមាធិនិមិត្តនោះ ។ បទថា **ឱកប្បនិយមេតំ** នោះ ជាទីតាំងនៃការជឿ ។

សច្ចកៈនោះទទួលថា ព្រះមានព្រះភាគ ជាបុគ្គលមានឯកគ្គតាចិត្ត ឥឡូវនេះ កាលនឹងនាំបញ្ហាដែលខ្លួនលាក់ទុកក្នុងជ្ជក់មកទូលសួរ ទើបពោលថា **អភិជានាតិ ខោ បន ភវំ គោតមោ ទិវា សុបិតា** ។ ឧបមាថា ឈ្មោះថា

ផ្អែស៊ីអាហារ គឺមធុបាយាសដែលចម្អិនដោយទឹកដោះ ផ្សំដោយសប្បិ រហូតពេញពោះ ឃើញលាមកហើយ ទំពាស៊ីមិនបាន ក៏មិនអាចនឹងទៅ កាលទំពាស៊ីមិនបាន ក៏ហិតក្លិន ទើបទៅ បានឮថា កាលផ្អែមិនបានហិតក្លិនហើយទៅ ក៏ឈឺក្បាល យ៉ាងណា ព្រះសាស្ដាក៏ដូច្នោះដូចគ្នា ទ្រង់សម្ដែងធម៌ ជាទីតាំងនៃសេចក្ដីជ្រះថ្លា តាំងអំពីយាងចេញមហាភិនេស្ក្រមណ៍ រហូតដល់ការអស់ទៅនៃអាសវៈ ដូចគ្នានឹងផ្អែឃើញមធុបាយាស ដែលគេចម្អិនដោយទឹកដោះសុទ្ធ ឯសច្ចកៈនោះ ស្ដាប់ព្រះធម្មទេសនាបែបនេះ ក៏មិនកើតសូម្បីត្រឹមតែសេចក្ដីជ្រះថ្លាក្នុងព្រះសាស្ដា ព្រោះដូច្នោះ កាលចូលទៅទូលសួរបញ្ហាដែលលាក់ទុកក្នុងថ្នក់នាំមក ក៏មិនអាចដើម្បីនឹងទៅ ទើបបានពោលយ៉ាងនោះ កាលបើដូច្នោះ ព្រោះថីនមិទ្ធៈដែលព្រះខីណាស្រពទាំងពួង លះបានដោយអរហត្តមគ្គ ។ ឯការក្រវល់ក្រវាយផ្លូវកាយ រមែងមានក្នុងឧបាទិន្នករូបខ្លះ ក្នុងអនុបាទិន្នករូបខ្លះ ពិតហើយ ផ្កាឈូកសជាដើម រីកក្នុងវេលាមួយ ក្ដោបក្នុងវេលាមួយ វេលាល្ងាច ស្លឹកឈើខ្លះដេក វេលាព្រឹកក៏រីក ។ ឧបាទិន្នករូបប៉ុណ្ណោះ មានការក្រវល់ក្រវាយ ឯភវង្គសោតដែលប្រព្រឹត្តទៅដោយការក្រវល់ក្រវាយ លោកបំណងយកការនិទ្រាក្នុងទីនេះ ។ ភវង្គនោះសោត មានដល់ព្រះខីណាស្រព សំដៅយកនិទ្រានោះ ទើបពោលពាក្យជាដើមថា **អភិជានាមហំ**។ បទថា **សម្មោហវិហារស្មឹ វត្តិ** អាចារ្យពួកខ្លះពោលថា **សម្មោហវិហារោ** ប្រែថា នៅដោយការវង្វេង ។

[ ៧២ ] បទថា **អាសជ្ជ អាសជ្ជ** គឺចាក់ដោតហើយ ចាក់ដោតទៀត ។

បទថា **ឧបនីតេហិ** គឺដែលខ្ជួននាំមកពោល ។ បទថា **វចនបថេហិ** ប្រែថា ពាក្យសម្តី ។ បទថា **អភិនន្ទិត្វា** សេចក្តីថា ត្រេកអរទទួលដោយចិត្តអនុ- មោទនាសរសើរដោយពាក្យសម្តី ។ ព្រះមានព្រះភាគត្រាស់ ២ សូត្រនេះ ដល់និគ្រន្ថនេះ ។ ព្រះសូត្រដើមមាន ១ ភាណវារ ព្រះសូត្រនេះមាន ភាណវារពាក់កណ្តាល សួរថា និគ្រន្ថនេះស្តាប់ ២ ភាណវារកន្លះ ហើយ មិនទាន់សម្រេចធម្មាភិសម័យ មិនព្រមបួស មិនទាន់តាំងនៅក្នុង សរណៈ ដូច្នេះហើយ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់សម្តែងដល់ គេទៀត ឆ្លើយថា ដើម្បីជាវាសនាក្នុងអនាគត ។ ពិតហើយ ព្រះមាន ព្រះភាគទ្រង់ជ្រាបថា ឥឡូវនេះ ឧបនិស្ស័យរបស់និគ្រន្ថនេះមិនទាន់មាន តែ កាលតថាគតបរិនិព្វានទៅ បាន ២០០ ឆ្នាំថ្វាយ សាសនានឹងប្រតិស្ឋាននៅ ក្នុងតម្ពបណ្ណិទ្វីប និគ្រន្ថនេះនឹងកើតក្នុងផ្ទះមានត្រកូល ក្នុងតម្ពបណ្ណិទ្វីបនោះ បួសក្នុងវេលាដែលដល់ព្រមហើយ រៀនព្រះត្រៃបិដក ចម្រើនវិបស្សនា សម្រេចអរហត្ត ព្រមដោយបដិសម្ភិទា ជាមហាខីណាស្រព ឈ្មោះថា **កាលពុទ្ធរក្ខិតៈ** ព្រះមានព្រះភាគទ្រង់ឃើញហេតុនេះ ទើបទ្រង់សម្តែងធម៌ ដើម្បីជាវាសនាក្នុងអនាគត ។

កាលព្រះសាសនាប្រតិស្ឋានក្នុងតម្ពបណ្ណិទ្វីបនោះ សច្ចកៈនោះចុតិចាក ទេវលោក កើតក្នុងត្រកូលនៃអមាត្យម្នាក់ ។ ក្នុងស្រុកសម្រាប់ភិក្ខាចារ នៃ ទក្ខិណាគិរីវិហារ បព្វជ្ជាក្នុងវេលាជាកំលោះ អាចបព្វជ្ជាបាន រៀនព្រះបិដក គឺព្រះពុទ្ធវចនៈ បរិហារគណៈ ពួកភិក្ខុជាច្រើនចោមរោមទៅ ដើម្បីសួរសុខ

ទុក្ខព្រះឧបជ្ឈាយ៍ លំដាប់នោះ ឧបជ្ឈាយ៍របស់លោកគិតថា អញនឹងចោទ ពិសោធសទ្ធិវិហារិក ទើបតមមាត់ជាមួយភិក្ខុនោះ ដែលរៀនព្រះត្រៃបិដក គឺ ព្រះពុទ្ធវចនៈមកហើយ មិនបានធ្វើត្រឹមតែការនិយាយ ភិក្ខុនោះក្រោកឡើង ក្នុងវេលាជិតភ្លឺ ទៅកាន់សម្នាក់ព្រះថេរៈ សួរថា បពិត្រលោកម្ចាស់ កាលខ្ញុំ ធ្វើគន្ថកម្ម មកក្នុងសម្នាក់របស់លោកម្ចាស់ ហេតុអ្វី ទើបលោកម្ចាស់តម មាត់ មិនពោល ខ្ញុំមានទោសអ្វីឬ ។ ព្រះថេរៈពោលថា នៃពុទ្ធរក្ខិតៈ លោក ធ្វើការសម្គាល់ថា ឈ្មោះថា បព្វជ្ជាកិច្ចរបស់អញដល់ទីបំផុតហើយ ដោយ គន្ថកម្ម មានប្រមាណប៉ុណ្ណេះឬ ។ ពុទ្ធរក្ខិតៈពោលថា តើខ្ញុំនឹងធ្វើដូចម្តេច វិញ ។ ព្រះថេរៈពោលថា សូមលោកលះគណៈ កាត់បបញ្ចធម៌ ទៅកាន់ ចេតិយបព៌តវិហារ ធ្វើសមណធម៌ចុះ ។ លោកតាំងនៅក្នុងឱវាទរបស់ព្រះ ឧបជ្ឈាយ៍ ធ្វើយ៉ាងនោះ ទើបសម្រេចអរហត្ត ព្រមដោយបដិសម្ភិទា ជាអ្នក មានបុណ្យ ព្រះរាជាទ្រង់បូជា មានពួកភិក្ខុជាច្រើនជាបរិវារ នៅក្នុងចេតិយ បព៌តវិហារ ។

ក្នុងកាលនោះ ព្រះបាទតិស្សមហារាជ ទ្រង់រក្សាឧបោសថកម្ម រមែងនៅ ក្នុងទីសម្ងំរបស់ព្រះរាជា នាចេតិយបព៌ត លោកបានឲ្យសញ្ញាដល់ភិក្ខុដែល ឧបដ្ឋាករបស់ព្រះថេរៈថា កាលណាលោកម្ចាស់របស់យើងដោះស្រាយបញ្ហា ឬពោលធម៌ កាលនោះ អ្នកគប្បីឲ្យសញ្ញាដល់យើងផង ។ ក្នុងថ្ងៃធម្មស្សវនៈ មួយ ព្រះថេរៈដែលពួកភិក្ខុហែហម ឡើងកាន់លានកណ្តកចេតិយ ថ្វាយបង្គំ ចេតិយហើយ ទើបឈរនៅត្រង់គល់ទន្ទាប់ខ្មៅ ។ កាលនោះ ព្រះថេរៈដែល

ជាអ្នកសមាទានបិណ្ឌបាតជាវត្តមួយរូប សួរបញ្ហានឹងពុទ្ធរក្ខិតភិក្ខុនោះ ក្នុងកាឡាមសូត្រ ។ ព្រះថេរៈពោលថា អ្នកមានអាយុ ថ្ងៃនេះ ជាថ្ងៃធម្មស្សវនៈ មិនមែនឬ ភិក្ខុនោះប្រាប់ថា បពិត្រលោកម្ចាស់ ថ្ងៃនេះ ជាថ្ងៃធម្មស្សវនៈ ។ ព្រះថេរៈពោលថា បើយ៉ាងនោះ លោកចូរយកគ្រែមក ខ្ញុំនឹងអង្គុយក្នុងទីនេះ ហើយនឹងធ្វើការស្តាប់ធម៌ ។ លំដាប់នោះ ទើបពួកភិក្ខុក្រាលអាសនៈត្រង់គល់ឈើប្រគេនព្រះថេរៈនោះ ។ ព្រះថេរៈពោលគាថាខាងដើមហើយ ទើបផ្តើមកាឡាមសូត្រ ។ ភិក្ខុកំលោះ ដែលឧបដ្ឋាកព្រះថេរៈនោះ ឲ្យសញ្ញាដល់ព្រះរាជាៗ យាងទៅដល់ កាលគាថាខាងដើមមិនទាន់ចប់ កាលទ្រង់យាងដល់ប្រថាប់ឈរខាងចុងបរិស័ទ ដោយភេទដែលមិនមានអ្នកណាស្គាល់ឡើយ ប្រថាប់ឈរស្តាប់ធម៌ រហូតអស់ ៣ យាម ហើយបានប្រទានសាធុការ ក្នុងវេលាព្រះថេរៈពោលថា ព្រះមានព្រះភាគបានត្រាស់ពាក្យនេះ ដូច្នេះ ។ ព្រះថេរៈជ្រាបហើយ ទើបសួរថា មហាបពិត្រ ព្រះអង្គយាងមកពីអង្កាល់ ។ ព្រះរាជាឆ្លើយថា បពិត្រលោកម្ចាស់ ក្នុងវេលាជិតចប់គាថាខាងដើមនោះឯង ព្រះថេរៈពោលថា មហាបពិត្រ ព្រះអង្គទ្រង់ធ្វើកម្មដែលធ្វើបានលំបាក ។ ព្រះរាជាពោលថា បពិត្រលោកម្ចាស់ នេះមិនឈ្មោះថា ធ្វើវត្ថុដែលធ្វើបានលំបាកឡើយ ការដែលខ្ញុំមិនញ៉ាំងចិត្តឲ្យត្រាច់ទៅក្នុងទីដទៃ សូម្បីក្នុងបទ ១ បទ តាំងអំពីពេលដែលលោកម្ចាស់ផ្តើមធម្មកថា បានធ្វើប្បដិញ្ញាថា ឈ្មោះថាភាពជាធំរបស់អញ ចូរកុំមានដល់តម្ពបណ្ណិទីប ក្នុងទីត្រឹមតែចាក់ដោយជន្ទញ ដូច្នេះ ។ ក្នុងព្រះសូត្រនេះ កាលព្រះពុទ្ធរក្ខិតៈ បានសម្តែងព្រះពុទ្ធគុណទាំង-

ឡាយ ព្រោះដូច្នោះ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ពុទ្ធគុណមាន ប្រមាណប៉ុណ្ណោះឬ ឬមានដទៃទៀត ព្រះថេរៈឆ្លើយថា មហាបពិត្រ ពុទ្ធគុណ ដែលមិនទាន់បានពោលមានច្រើនជាង ដែលអាចក្តី ពោលប្រមាណមិនបាន ព្រះរាជាពោលថា បពិត្រលោកម្ចាស់ សូមឧបមាបន្តិចមកមើល ។ ព្រះថេរៈ ពោលថា បពិត្រមហារាជ ស្រូវសាលីដែលនៅសល់ មានច្រើនជាងក្ួរស្រូវ សាលីដែលជ្រុះមួយក្ួរ ក្នុងស្រែមានប្រមាណ ១០០០ ករីស យ៉ាងណា ពុទ្ធគុណដែលអាចក្តីពោលហើយ តិចពេកណាស់ ដែលនៅសល់ទើបមាន ច្រើន ដូច្នោះ ។ ព្រះរាជាពោលថា បពិត្រលោកម្ចាស់ សូមធ្វើឧបមាបន្តិច ទៀតមកមើល ។ ព្រះថេរៈពោលថា បពិត្រមហារាជ មហាគង្គាពេញដោយ ទឹក បុគ្គលគប្បីចាក់ចូលទៅក្នុងវន្ទម្ពុល ទឹកដែលចូលទៅក្នុងវន្ទម្ពុលមានតិច ទឹកដែលសល់មានច្រើន យ៉ាងណា ពុទ្ធគុណដែលអាចក្តីពោលហើយ តិច តួចទេ ព្រះគុណដែលនៅសល់ ទើបមានច្រើន ដូច្នោះ ។ ព្រះរាជាពោលថា បពិត្រលោកម្ចាស់ សូមធ្វើឧបមាបន្តិចទៀតមកមើល ។ ព្រះថេរៈពោលថា បពិត្រមហារាជ ចម្មតាបក្សី ឬសកុណជាតិតូចៗ ដែលជាសត្វលេងខ្យល់ ហើរលេងក្នុងអាកាសក្នុងលោកនេះ ទីដែលប៉ះស្លាបរបស់បក្សីនោះ ក្នុងអាកាស មានច្រើន ឬ អាកាសដែលសល់មានច្រើន ។ ព្រះរាជាពោលថា បពិត្រ លោកម្ចាស់ លោកម្ចាស់ពោលអ្វី ឱកាសដែលជាទីទទះស្លាបរបស់បក្សីនោះ តិចពេកណាស់ អាកាសដែលសល់មានច្រើន ។ ព្រះថេរៈពោលថា បពិត្រ មហារាជ យ៉ាងនោះឯង ពុទ្ធគុណដែលអាចក្តីពោលហើយ តិចពេកណាស់

គុណដែលនៅសល់ មិនមានទីបំផុត ប្រមាណមិនបាន ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ លោកម្ចាស់ពោលល្អហើយ ពុទ្ធគុណមិនមានទីបំផុត លោកម្ចាស់ឧបមាដោយអាកាសមិនមានទីបំផុតនោះឯង ខ្ញុំជ្រះថ្លា តែមិនអាចធ្វើសក្ការៈដ៏សមគួរដល់លោកម្ចាស់បាន ។ ខ្ញុំសូមថ្វាយរាជសម្បត្តិប្រកបដោយទី ១០០ យោជន៍ ក្នុងតម្ពបណ្ណិទ្វីបនេះដល់លោកម្ចាស់ នេះជាទុគ្គតបណ្ណាការរបស់ខ្ញុំ ព្រះថេរៈពោលថា បពិត្រមហារាជ បណ្ណាការដែលមហាបពិត្រទ្រង់ជ្រះថ្លា ធ្វើហើយ អាចក្តីសូមថ្វាយរាជសម្បត្តិដែលទ្រង់ប្រគេនដល់អាចក្តីដល់មហាបពិត្រទាំងអស់វិញ សូមមហាបពិត្រ ទ្រង់គ្រប់គ្រងដែនដោយធម៌ដោយស្មោះស្មើចុះ ដូច្នេះឯង ៕ល៕

**មហាសច្ចកសូត្រ ចប់**

**សូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ចូឡតណ្ហាសង្ខយសូត្រទី ៧

[ ៧៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងប្រាសាទរបស់មិគារមាតា នាវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ គ្រានោះឯង សក្កទេវរាជជាធំជាងពួកទេវតា ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចឋិតនៅក្នុងទីដ៏សមគួរ ។ លុះសក្កទេវរាជជាធំជាងពួកទេវតា ឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាអ្នកមានចិត្តបង្អោនទៅក្នុងព្រះនិព្វាន ជាទីក្ស័យទៅនៃតណ្ហា ជាអ្នកមានសេចក្តីចូលចិត្តទៀង មានសេចក្តីក្សេមក្សាន្តចាកយោគៈទៀង ជាអ្នកប្រព្រឹត្តដ៏ប្រសើរទៀង មានទីបំផុតទៀងទាត់ ជាបុគ្គលប្រសើរជាងទេវតា និងមនុស្សទាំងឡាយដោយសង្ខេប តើមានប៉ុន្មាន ។

[ ៧៤ ] ព្រះអង្គត្រាស់ថា បពិត្រទេវានមិន្ទៈ ភិក្ខុក្នុងសាសនានេះ បានស្តាប់ពាក្យថា បុគ្គលមិនគួរប្រកាន់នូវធម៌ទាំងពួង ( ដោយអំណាចតណ្ហា និងទិដ្ឋិ ) បពិត្រទេវានមិន្ទៈ លុះភិក្ខុបានស្តាប់ពាក្យនុ៎ះថា បុគ្គលមិនគួរប្រកាន់នូវធម៌ទាំងពួងយ៉ាងនេះហើយ ភិក្ខុនោះរមែងដឹងច្បាស់ នូវធម៌ទាំងពួង លុះដឹងច្បាស់នូវធម៌ទាំងពួងហើយ រមែងកំណត់ដឹងនូវធម៌ទាំងពួង លុះកំណត់ដឹងនូវធម៌ទាំងពួងហើយ រមែងសោយនូវវេទនាណាមួយ ជាសុខ ឬជាទុក្ខ ឬមិនទុក្ខមិនសុខ ភិក្ខុនោះ ជាអ្នកពិចារណាឃើញថា មិនទៀង ពិចារណា

ឃើញថា ជាទីប្រាសចាកតម្រេក ពិចារណាឃើញថា ជាគ្រឿងរម្ងត់ ពិចារណាឃើញថា គួរលះបង់ក្នុងវេទនាទាំងឡាយនោះ កាលបើភិក្ខុនោះ ពិចារណាឃើញថា មិនទៀង ពិចារណាឃើញថា ជាទីប្រាសចាកតម្រេក ពិចារណាឃើញថា ជាគ្រឿងរម្ងត់ ពិចារណាឃើញថា គួរលះបង់ក្នុងវេទនាទាំងឡាយនោះហើយ ក៏មិនបានប្រកាន់នូវធម្មជាតអ្វីតិចតួចក្នុងលោកឡើយ កាលបើមិនប្រកាន់ រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុត ក៏រម្ងត់កិលេសដោយខ្លួនឯងបាន ទើបដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានអប់រំហើយ កិច្ចដែលត្រូវធ្វើ អាត្មាអញក៏បានធ្វើហើយ កិច្ចដទៃក្រៅអំពីកិច្ចនេះ មិនមានឡើយ បពិត្រទេវានមិន្ទៈ ភិក្ខុជាអ្នកបង្អោនចិត្តទៅក្នុងព្រះនិព្វាន ជាទីក្ស័យទៅនៃតណ្ហា ជាអ្នកមានសេចក្តីចូលចិត្តទៀង មានសេចក្តីក្សេមក្សាន្តចាកយោគៈទៀង ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរទៀង មានទីបំផុតទៀងទាត់ ជាបុគ្គលប្រសើរជាងទេវតា និងមនុស្សទាំងឡាយដោយសង្ខេប មានប្រមាណប៉ុណ្ណោះឯង ។ លំដាប់នោះ សក្កទេវរាជ ជាធំជាងពួកទេវតា ត្រេកអរ អនុមោទនានូវភាសិតរបស់ព្រះមានព្រះភាគ ហើយក្រាបបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចស្រាប់តែបាត់ចាកទីនោះមួយរំពេច ។

[ ៧៥ ] ចួនជាសម័យនោះឯង ព្រះមហាមោគ្គល្លានមានអាយុគង់នៅក្នុងទីជិតព្រះមានព្រះភាគ ។ ទើបព្រះមហាមោគ្គល្លានមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ទេវតានោះ បានដឹងនូវភាសិតរបស់ព្រះមានព្រះភាគហើយ

អនុមោទនា ឬមិនបានដឹងទេ ហើយអនុមោទនា ទោះបីទេវតានោះ ដឹងនូវភាសិតរបស់ព្រះមានព្រះភាគ ហើយបានអនុមោទនាក្តី មិនបានដឹង ហើយអនុមោទនាក្តី គួរតែអាត្មាអញស្គាល់ទេវតានោះ ។ គ្រានោះ ព្រះមហាមោគ្គ-ល្លានមានអាយុ ក៏បាត់អំពីវត្តបុព្វារាម ជាមិគារមាតុប្រាសាទមួយរំពេចហើយក៏ទៅប្រាកដនៅនាឋានតាវត្តិង្សទេវលោក ដូចបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញដូច្នោះឯង ។ សម័យនោះឯងព្រះឥន្ទ្រាធិរាជ កំពុងតែក្រសាលសប្បាយរីករាយស្កប់ស្កល់ ដោយតូរ្យតន្ត្រីជាទិព្វទាំងប្រាំរយ ក្នុងឧទ្យានឈ្មោះឯកបុណ្ឌរីកៈ ។ ព្រះឥន្ទ្រាធិរាជ បានឃើញព្រះមហាមោគ្គល្លាន មានអាយុនិមន្តមកពីចម្ងាយលីមៗ លុះឃើញហើយ ក៏បញ្ឈប់នូវតូរ្យតន្ត្រីជាទិព្វទាំងប្រាំរយនោះ ហើយចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងព្រះមហាមោគ្គល្លានមានអាយុថា បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ សូមនិមន្តមកបពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ លោកម្ចាស់និមន្តមកនេះ ជាការស្រួលហើយបពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ លោកម្ចាស់ខានធ្វើបរិយាយដើម្បីនិមន្តមកក្នុងទីនេះ ជាយូរហើយ បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ សូមលោកម្ចាស់និមន្តគង់ចុះ អាសនៈនេះហើយខ្ញុំព្រះករុណា ក្រាលទុកប្រគេន ។ ព្រះមហាមោគ្គ-ល្លានមានអាយុ ក៏គង់លើអាសនៈ ដែលព្រះឥន្ទ្រាធិរាជក្រាលប្រគេន ។ ចំណែកព្រះឥន្ទ្រាធិរាជ ក៏កាន់យកអាសនៈទាបមួយ គង់ក្នុងទីដ៏សមគួរ ។

[ ៧៦ ] លុះព្រះឥន្ទ្រាធិរាជគង់ក្នុងទីដ៏សមគួរហើយ ព្រះមហាមោគ្គ-

ល្លានមានអាយុ បានសួរសេចក្ដីនេះថា បពិត្រកោសិយៈ ព្រះមានព្រះភាគ បានត្រាស់សម្ដែងនូវកិរិយាបង្អោនចិត្តទៅកាន់ព្រះនិព្វាន ជាទីអស់ទៅនៃតណ្ហា ដោយសេចក្ដីសង្ខេបចំពោះមហារាជ ដូចម្ដេចខ្លះ សូមព្រះរាជានុញ្ញាតចុះ ដ្បិតអាត្មាភាពជាអ្នកមានចំណែកដើម្បីស្ដាប់ធម្មកថានេះផង ។ សក្កទេវរាជ មានព្រះរាជឱង្ការតបថា បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ ធ្វើដូចម្ដេចខ្លួនខ្ញុំព្រះករុណាជាអ្នកមានកិច្ចច្រើន មានការងារត្រូវធ្វើច្រើន ដោយការងារដែលត្រូវធ្វើផ្ទាល់ខ្លួនផង ដោយការងារដែលត្រូវធ្វើចំពោះពួកទេវតា ក្នុងជាន់តាវត្តិង្សផង បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ ឯពាក្យដែលខ្ញុំព្រះករុណាបានស្ដាប់ត្រាប់ត្រង ធ្វើទុកក្នុងចិត្ត ចាំទុកស្រួលបួលហើយ ពាក្យនោះក៏បាត់ទៅមួយរំពេច បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ ពីព្រេងនាយមក មានសង្គ្រាមទេវតា និងអសុរលើកជាក្បួនទ័ព បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ ប៉ុន្តែក្នុងសង្គ្រាមនោះពួកទេវតាមានជ័យជម្នះ ឯពួកអសុរក៏បរាជ័យ បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ លុះខ្ញុំព្រះករុណានោះ បានឈ្នះសង្គ្រាមទេវតា និងអសុរហើយ ត្រឡប់មកអំពីទីនោះវិញ ក៏និម្មិតប្រាសាទឈ្មោះវេជយន្ត បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ ប្រាសាទវេជយន្ត ( នោះ ) មានជំបូលមួយរយ ក្នុងជំបូលមួយៗ មានផ្ទះកំពូលប្រាំពីររយៗ ក្នុងផ្ទះកំពូលមួយៗ មានស្រីអប្សរប្រាំពីរៗ នាក់ ក្នុងស្រីអប្សរម្នាក់ៗ មានស្រីបម្រើប្រាំពីរៗ នាក់ បពិត្រព្រះមហាមោគ្គល្លានអ្នកនិទ្ទុក្ខ លោកម្ចាស់ចង់ឃើញកន្លែងដែលគួររីករាយរបស់វេជយន្តប្រាសាទដែរឬទេ ។ ព្រះមហាមោគ្គល្លានមានអាយុ ទទួលនិមន្តន៍ដោយតុណ្ហីភាព ។

[ ៧៧ ] គ្រានោះ ព្រះឥន្ទ្រាធិរាជ និងវេស្សវណមហារាជ ឲ្យព្រះមហាមោគ្គល្លានមានអាយុនិមន្តមុខ ហើយនាំចូលទៅរកវេជយន្តប្រាសាទ ។ ពួកស្រីបម្រើរបស់ព្រះឥន្ទ្រាធិរាជ បានឃើញព្រះមហាមោគ្គល្លានមានអាយុកំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយក៏មានសេចក្តីខ្មាស និងអៀនខ្មាស នាំគ្នាចូលទៅកាន់បន្ទប់រៀងខ្លួន ។ ដូចជាកូនប្រសាស្រីបានឃើញឪពុកក្មេក ហើយមានសេចក្តីខ្មាស និងអៀនខ្មាស យ៉ាងណា ពួកស្រីបម្រើរបស់ព្រះឥន្ទ្រាធិរាជ បានឃើញព្រះមហាមោគ្គល្លានមានអាយុ ក៏មានសេចក្តីខ្មាស និងអៀនខ្មាស នាំគ្នាចូលបន្ទប់រៀងខ្លួន យ៉ាងនោះដែរ ។ គ្រានោះ ព្រះឥន្ទ្រាធិរាជ និងវេស្សវណមហារាជ និមន្តព្រះមហាមោគ្គល្លានមានអាយុ ត្រាច់ជុំវិញ ចូលទៅក្នុងវេជយន្តប្រាសាទ ហើយទូលថា បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ សូមលោកម្ចាស់ទតមើលកន្លែងដែលគួររីករាយ របស់វេជយន្តប្រាសាទនេះផង បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ សូមលោកម្ចាស់ទតមើលកន្លែងដែលគួររីករាយរបស់វេជយន្តប្រាសាទនេះផង ។ ព្រះថេរៈឆ្លើយថា ទីរបស់កោសិយៈមានអាយុ ដែលបានធ្វើបុណ្យទុកក្នុងកាលមុននេះល្អមែន សូម្បីពួកមនុស្សបានឃើញទីណាមួយ ដែលជាទីគួររីករាយ ក៏តែងនាំគ្នានិយាយថា អើហ្ន៎ ទីនេះល្អដូចជាប្រាសាទរបស់ពួកទេវតា ក្នុងជាន់តាវតិង្សដែរ ឯលំនៅរបស់កោសិយៈមានអាយុ ដែលមានបុណ្យធ្វើទុកក្នុងកាលមុននេះ ល្អដោយពិតហើយ ។ គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ទេវតានេះជាបុគ្គលប្រមាទខ្លាំងមែន បើដូច្នោះគួរតែអាត្មាអញ

ធ្វើទេវតានេះឲ្យសង្វេគ ។ ទើបព្រះមហាមោគ្គល្លានមានអាយុ សម្តែងឥទ្ធិ-ឫទ្ធិ ញ៉ាំងវេជយន្តប្រាសាទ ឲ្យកម្រើករំភើបញាប់ញ័រដោយចុងមេជើង តាមសមគួរដល់ឫទ្ធិ ។ គ្រានោះ ព្រះឥន្រ្ទាធិរាជ និងវេស្សវណ្ណមហារាជ និងពួកទេវតាក្នុងជាន់តាវតិង្ស កើតសេចក្តីអស្ចារ្យក្នុងចិត្តថា អើហ្ន៎ អស្ចារ្យណាស់ អើហ្ន៎ ចម្លែកណាស់ ត្រង់ការណ៍ដែលភាពនៃសមណៈ មានឫទ្ធិច្រើន មានអានុភាពច្រើន ( ប៉ុណ្ណេះ ) មិនសមបើញ៉ាំងទិព្វវិមានឲ្យកម្រើករំភើបញាប់ញ័រដោយចុងមេជើងបាន ។

[ ៧៨ ] គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ ដឹងថាព្រះឥន្រ្ទាធិរាជមានសេចក្តីតក់ស្លុត កើតសេចក្តីព្រឺរោមហើយ ក៏មានថេរវាចាទៅរកព្រះឥន្រ្ទាធិរាជថា បពិត្រកោសិយៈ ព្រះមានព្រះភាគ បានត្រាស់នូវកិរិយាបង្អោនចិត្តទៅក្នុងព្រះនិព្វានជាទីអស់ទៅនៃតណ្ហា ដោយសេចក្តីបង្រួញ ( ចំពោះ ) មហារាជដូចម្តេចខ្លះ សូមព្រះរាជានុញ្ញាត ដ្បិតអាត្មាភាពជាអ្នកមានចំណែកដើម្បីស្តាប់ធម្មកថានេះផង ។ សក្កទេវរាជឆ្លើយតបថា បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ កាលនោះ ខ្ញុំព្រះករុណាបានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចឋិតនៅក្នុងទីដ៏សមគួរ បពិត្រព្រះមោគ្គល្លានអ្នកនិទ្ទុក្ខ លុះខ្ញុំព្រះករុណាឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុអ្នកបង្អោនចិត្តទៅកាន់ព្រះនិព្វាន ជាទីក្ស័យនៃតណ្ហា ជាអ្នកមានសេចក្តីចូលចិត្តទៀង ជាអ្នកមានសេចក្តីក្សេមក្សាន្តចាកយោគៈទៀង ជា

អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរទៀង មានទីបំផុតទៀងទាត់ ជាបុគ្គលប្រសើរជាង ទេវតា និងមនុស្សទាំងឡាយដោយសង្ខេប តើមានប៉ុន្មានយ៉ាង បពិត្រព្រះ មោគ្គល្លានអ្នកនិទ៌ុក្ខ កាលបើខ្ញុំព្រះករុណាសួរយ៉ាងនេះហើយ ព្រះមានព្រះ ភាគមាន ព្រះបន្ទូលមកនឹងខ្ញុំព្រះករុណាយ៉ាងនេះថា បពិត្រព្រះអង្គជាធំជាង ពួកទេវតា ភិក្ខុក្នុងសាសនានេះ បានស្តាប់ពាក្យថា ភិក្ខុមិនគួរនឹងប្រកាន់នូវ ធម៌ គឺបញ្ចក្ខន្ធទាំងអស់ឡើយ បពិត្រព្រះអង្គជាធំជាងពួកទេវតា ភិក្ខុបាន ស្តាប់ពាក្យនុ៎ះថា ភិក្ខុមិនគួរនឹងប្រកាន់នូវធម៌ទាំងពួងយ៉ាងនេះហើយ ភិក្ខុ នោះ រមែងដឹងច្បាស់នូវធម៌ទាំងពួង លុះដឹងច្បាស់នូវធម៌ទាំងពួងហើយ រមែងកំណត់ដឹងធម៌ទាំងពួងបាន លុះកំណត់ដឹងនូវធម៌ទាំងពួងហើយ រមែង សោយនូវវេទនាណាមួយ ជាសុខ ឬជាទុក្ខ ឬមិនទុក្ខមិនសុខ ភិក្ខុនោះ ជា អ្នកពិចារណាឃើញថា មិនទៀង ពិចារណាឃើញថា ជាទីប្រាសចាកតម្រេក ពិចារណាឃើញថា ជាគ្រឿងរម្លត់ ពិចារណាឃើញថា គួរលះបង់ក្នុងវេទនា ទាំងឡាយនោះ កាលបើភិក្ខុនោះពិចារណាឃើញថា មិនទៀង ពិចារណា ឃើញថា ជាទីប្រាសចាកតម្រេក ពិចារណាឃើញថា ជាទីរម្លត់ ពិចារណា ឃើញថា គួរលះបង់ក្នុងវេទនាទាំងឡាយនោះហើយ ក៏មិនប្រកាន់ធម្មជាតអ្វី តិចតួចក្នុងលោកឡើយ កាលបើមិនប្រកាន់ ក៏មិនតក់ស្លុត កាលបើមិនតក់ ស្លុត ទើបរម្លត់កិលេសដោយខ្លួនឯងបាន ទាំងដឹងច្បាស់ថា ជាតិរបស់អាត្មា អញអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានអប់រំហើយ កិច្ចដែលត្រូវធ្វើ អាត្មាអញក៏បានធ្វើហើយ កិច្ចដទៃក្រៅអំពីកិច្ចនេះមិនមានឡើយ បពិត្រព្រះ

អង្គដ៏ជាធំជាងពួកទេវតា ក៏ក្លាជាអ្នកបង្អោនចិត្តទៅក្នុងព្រះនិព្វាន ជាទីក្ស័យទៅនៃតណ្ហា ជាអ្នកមានសេចក្តីចូលចិត្តទៀង ជាអ្នកមានសេចក្តីក្សេមក្សាន្តចាកយោគៈទៀង ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរទៀង មានទីបំផុតទៀងទាត់ ជាបុគ្គលប្រសើរជាងពួកទេវតា និងមនុស្សដោយសង្ខេប មានប្រមាណប៉ុណ្ណេះឯង បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ ព្រះមានព្រះភាគ បានត្រាស់សម្តែងនូវកិរិយាបង្អោនចិត្តទៅក្នុងព្រះនិព្វាន ជាទីក្ស័យទៅនៃតណ្ហាដោយសេចក្តីសង្ខេប ចំពោះខ្ញុំព្រះករុណាដូចពណ៌នាមកនេះ ។ គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ ត្រេកអរអនុមោទនាចំពោះភាសិតរបស់ព្រះឥន្ទ្រាធិរាជ ហើយក៏ស្រាប់តែបាត់ចាកតាវត្តិង្សទេវលោក មកប្រាកដក្នុងមិគារមាតុប្រាសាទ នាវត្តបុព្វារាមមួយរំពេច ដូចជាបុរសដែលមានកម្លាំង លាដៃបត់ចូល ឬបត់ដៃដែលលាចេញដូច្នោះឯង ។ កាលដែលព្រះមហាមោគ្គល្លានមានអាយុ ចៀសចេញទៅមិនយូរប៉ុន្មាន ពួកស្រីបម្រើរបស់ព្រះឥន្ទ្រាធិរាជ បានក្រាបទូលសួរចំពោះព្រះឥន្ទ្រាធិរាជដូច្នេះថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ លោកនុ៎ះហើយឬជាព្រះមានព្រះភាគ ជាគ្រូរបស់ព្រះអង្គនោះ ។ សក្កទេវរាជឆ្លើយតបថា ម្នាលនាងអ្នកនិទ៌ុក្ខទាំងឡាយ លោកនោះមិនមែនជាព្រះមានព្រះភាគ ជាគ្រូរបស់យើងទេ លោកនោះគ្រាន់តែជាសព្រហ្មចារី ( អ្នកប្រព្រឹត្តធម៌ដូចគ្នា ) នឹងយើង លោកនុ៎ះហើយ ដែលឈ្មោះព្រះមហាមោគ្គល្លានមានអាយុ ។ ពួកស្រីបម្រើក្រាបទូលថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះអង្គពេញជាមានលាភហើយ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះអង្គពេញជាបានល្អហើយ ត្រង់ដែលព្រះអង្គបាន

សព្រហ្មចារីបុគ្គលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ឱហ្ន៎ លោកនោះទុកដូចជាព្រះមានព្រះភាគ ជាគ្រូរបស់ព្រះអង្គដោយពិតណាស់ ។

[ ៧៩ ] គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចគង់ក្នុងទីសមគួរ ។ លុះព្រះមហាមោគ្គល្លានមានអាយុ គង់ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ធ្លាប់បានសម្ដែងនូវកិរិយាបង្អោនចិត្តទៅក្នុងព្រះនិព្វានជាទីអស់ទៅនៃតណ្ហា ដោយសង្ខេប ជាគ្រឿងតង្វាយដល់ទេវតា ដែលមានសក្តិធំមួយរូបឬទេ ។ ព្រះអង្គត្រាស់ថា ម្នាលមោគ្គល្លាន តថាគតធ្លាប់សម្ដែង ដ្បិតសក្កទេវរាជចូលមករកតថាគតក្នុងទីនេះ លុះចូលមកដល់ហើយ ក៏ក្រាបថ្វាយបង្គំតថាគត រួចឋិតនៅក្នុងទីដ៏សមគួរ ម្នាលមោគ្គល្លាន លុះសក្កទេវរាជឋិតនៅក្នុងទីដ៏សមគួរហើយ បានសួរសេចក្ដីនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុអ្នកមានចិត្តបង្អោនទៅក្នុងព្រះនិព្វាន ជាទីក្ស័យនៃតណ្ហា ជាអ្នកមានសេចក្ដីចូលចិត្តទៀង មានសេចក្ដីក្សេមក្សាន្តចាកយោគៈទៀង ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរទៀង មានទីបំផុតទៀងទាត់ ជាបុគ្គលប្រសើរជាងទេវតា និងមនុស្សទាំងឡាយដោយសង្ខេប តើមានប៉ុន្មាន ម្នាលមោគ្គល្លាន កាលបើសក្កទេវរាជសួរយ៉ាងនេះហើយ តថាគតក៏ឆ្លើយតបទៅនឹងសក្កទេវរាជដូច្នេះថា បពិត្រព្រះអង្គជាធំជាងទេវតាទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានស្ដាប់ពាក្យថា បុគ្គលមិនគួរនឹងប្រកាន់នូវធម៌ទាំងពួង បពិត្រព្រះអង្គ

ជាធំជាងពួកទេវតា លុះភិក្ខុបានស្តាប់ពាក្យនុ៎ះថា បុគ្គលមិនគួរប្រកាន់នូវធម៌ទាំងពួងយ៉ាងនេះហើយ ភិក្ខុនោះរមែងដឹងច្បាស់នូវធម៌ទាំងពួង លុះដឹងច្បាស់នូវធម៌ទាំងពួងហើយ ក៏កំណត់ដឹងនូវធម៌ទាំងពួង លុះកំណត់ដឹងនូវធម៌ទាំងពួងហើយ រមែងសោយនូវវេទនាណាមួយ ជាសុខ ឬជាទុក្ខ ឬមិនទុក្ខមិនសុខ ភិក្ខុនោះពិចារណាឃើញថា មិនទៀង ពិចារណាឃើញថា ជាទីប្រាសចាកតម្រេក ពិចារណាឃើញថា ជាទីគួររម្ងត់ ពិចារណាឃើញថា គួរលះបង់ក្នុងវេទនាទាំងឡាយនោះ កាលបើភិក្ខុនោះពិចារណាឃើញថា មិនទៀង ពិចា-រណាឃើញថា ជាទីប្រាសចាកតម្រេក ពិចារណាឃើញថា គួររំលត់ ពិចា-រណាឃើញថា គួរលះបង់ក្នុងវេទនាទាំងឡាយនោះហើយ ក៏មិនប្រកាន់ធម្មជាតិអ្វីតិចតួចក្នុងលោកឡើយ កាលបើមិនប្រកាន់ ក៏រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុត ក៏រមែងរំលត់កិលេសដោយខ្លួនឯងបាន ទើបដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានអប់រំហើយ កិច្ចដែលត្រូវធ្វើ អាត្មាអញក៏បានធ្វើហើយ កិច្ចដទៃក្រៅអំពីកិច្ចនេះមិនមានឡើយ បពិត្រព្រះអង្គជាធំជាងពួកទេវតា ភិក្ខុជាអ្នកបង្អោនចិត្តទៅក្នុងព្រះនិព្វាន ជាទីក្ស័យទៅនៃតណ្ហា ជាអ្នកមានសេចក្តីចូលចិត្តទៀង មានសេចក្តីក្សេមក្សាន្តចាកយោគៈទៀង ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរទៀង មានទីបំផុតទៀងទាត់ ជាបុគ្គលប្រសើរជាងទេវតា និងមនុស្សទាំងឡាយដោយសង្ខេប មានប្រមាណប៉ុណ្ណេះឯង ម្នាលមោគ្គល្លាន តថាគតធ្លាប់សម្តែងនូវកិរិយាបង្អោនចិត្តទៅក្នុងព្រះនិព្វាន ជាទីក្ស័យទៅនៃតណ្ហាដោយសង្ខេបចំពោះសក្កទេវរាជ ដូចបាន

ពណ៌នាមកនេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ព្រះមហាមោគ្គល្លានមានអាយុ មានសេចក្ដីពេញចិត្តត្រេកអរហើយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## ចូឡតណ្ហាសង្ខយសូត្រទី ៧ ចប់

# អដ្ឋកថា

## ចូឡតណ្ហាសង្ខយសូត្រទី ៧

[ ៧៣ ] ចូឡតណ្ហាសង្ខយសូត្រ មានបទផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះ ក្នុងបទថា **បុព្វារាមេ មិគារ-មាតុ បាសាទេ** បានដល់ ប្រាសាទរបស់មិគារមាតា ក្នុងវិហារឈ្មោះថា បុព្វារាម ក្នុងសេចក្ដីនោះ មានពណ៌នាតាមលំដាប់ដូចតទៅនេះថា

ក្នុងអតីតកាល ក្នុងទីបំផុតនៃមួយសែនកប្ប មានឧបាសិកាម្នាក់ និមន្តព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ហើយថ្វាយទានមួយសែនដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ហើយក្រាបទៀបព្រះយុគលបាទព្រះមានព្រះភាគ ធ្វើការប្រាថ្នាថា ក្នុងអនាគតកាល សូមឲ្យខ្ញុំព្រះអង្គបានជាអគ្គឧបដ្ឋាយិការបស់ព្រះពុទ្ធដូចនឹងព្រះអង្គ ដូច្នេះ ។ នាងអន្ទោលទៅក្នុងទេវតា និងមនុស្សទាំង-ឡាយអស់សែននៃកប្ប ហើយបដិសន្ធិក្នុងគភ៌នាងសុមនទេវី ក្នុងផ្ទះសេដ្ឋីជាកូនរបស់មេណ្ឌក ក្នុងភទ្ទិយនគរ ក្នុងកាលនៃព្រះមានព្រះភាគរបស់យើងទាំងឡាយ ។ ក្នុងថ្ងៃប្រសូត ពួកញាតិបានដាក់ឈ្មោះថា វិសាខា ។ កាលព្រះមានព្រះភាគយាងទៅកាន់ភទ្ទិយនគរ នាងវិសាខា មួយអន្លើដោយពួកទារិកា ៥០០ បានធ្វើការទទួលព្រះមានព្រះភាគ ហើយបានជាព្រះសោតាបន្នក្នុងការជួបគ្រាដំបូងនោះឯង ។ ក្នុងកាលដទៃទៀត នាងទៅកាន់ផ្ទះរបស់បុណ្ណវឌ្ឍនកុមារកូនមិគារសេដ្ឋី ក្នុងនគរសាវត្ថី ក្នុងទីនោះ មិគារសេដ្ឋីបានតាំងនាងទុកក្នុងតំណែងជាម្ដាយ ព្រោះដូច្នោះ ទើបហៅថា មិគារមាតា ។

កាលនាងទៅកាន់ត្រកូលស្វាមី បិតារបស់នាងបានធ្វើគ្រឿងប្រដាប់ ឈ្មោះថា មហាលតាឲ្យ ។ គ្រឿងប្រដាប់នោះ ប្រកបដោយពេជ្រ ៤ នាឡិ កែវមុក្តា ១១ នាឡិ កែវប្រពាល ២២ នាឡិ កែវមណី ៣៣ នាឡិ គ្រឿងប្រដាប់នោះសម្រេចហើយ ដោយរតនៈទាំងនេះ និងដោយរតនៈដទៃ មានពណ៌ ៧ ដោយប្រការដូច្នេះ ។ គ្រឿងប្រដាប់នោះ ពាក់តាំងពីក្បាល រហូតទៅដល់ខ្នងជើង ។ ស្រីដែលមានកម្លាំងស្មើនឹងដំរី ៥ ទើបអាចប្រដាប់បានក្នុងកាលតមក នាងបានជាអគ្គឧបដ្ឋាយិការបស់ព្រះទសពល លះបង់គ្រឿងប្រដាប់នោះសាងវិហារ ដើម្បីព្រះមានព្រះភាគ ដោយទ្រព្យ ៩ កោដិ ឲ្យធ្វើប្រាសាទ ផ្ទៃប្រាសាទប្រមាណមួយករីស ។ ប្រដាប់ដោយបន្ទប់ ១០០០ គឺជាន់លើរបស់ប្រាសាទនោះ មាន ៥០០ បន្ទប់ ជាន់ក្រោមមាន ៥០០ បន្ទប់ ។ នាងវិសាខានោះគិតថា ប្រាសាទសុទ្ធៗ តែម្យ៉ាង មិនស្អាត ទើបឲ្យសាងផ្ទះទិ្វកូដ ៥០០ ចុល្លប្រាសាទ ៥០០ បន្ទប់ ។ សាលាទីឃសាលា ៥០០ ព័ទ្ធជុំវិញប្រាសាទធំនោះ បានធ្វើការឆ្លងវិហារ ៤ ខែ ។ ឈ្មោះថា បរិច្ចាគទ្រព្យក្នុងព្រះពុទ្ធសាសនារបស់ស្រីដទៃ ដូចនាងវិសាខាដែលស្ថិតនៅក្នុងអត្តភាពនៃមាតុគ្រាមមិនមាន ។ ឈ្មោះថា បរិច្ចាគទ្រព្យទុកក្នុងព្រះពុទ្ធ-សាសនារបស់បុគ្គលដទៃ ដូចអនាថបិណ្ឌិកសេដ្ឋី ដែលតាំងនៅក្នុងអត្តភាពនៃបុរសក៏មិនមាន ។ ពិតហើយ អនាថបិណ្ឌសេដ្ឋីនោះ លះបង់ទ្រព្យ ៥៤ កោដិ សាងវិហារឈ្មោះជេតពន ដូចគ្នានឹងមហាវិហារនៃអនុរាធបុរី ក្នុងទីសួន ដែលមានក្នុងទិសទក្សិណនៃនគរសាវត្ថី ។ នាងវិសាខាសាងវិហារ

ឈ្មោះថា បុព្វារាម ក្នុងទីដែលដូចគ្នានឹងអគ្គទេវវិមាន ក្នុងចំណែកទិសខាងកើតនៃនគរសាវត្ថី ។ ព្រះមានព្រះភាគ អាស្រ័យនគរសាវត្ថី នៅប្រថាប់ដើម្បីអនុគ្រោះត្រកូលទាំង ២ នេះ ទើបបានប្រថាប់នៅក្នុងប្រាសាទទាំង ២ នេះជានិច្ច ។ គឺខាងក្នុងវស្សា ១ ប្រថាប់នៅខាងក្នុងវត្តជេតពន វស្សា ១ ប្រថាប់នៅបុព្វារាម ។ តែក្នុងសម័យនោះ ប្រថាប់នៅក្នុងបុព្វារាម ។ ដោយហេតុនោះ ទើបលោកពោលថា **បុព្វារាមេ មិគារមាតុ បាសាទេ** ដូច្នេះ ។

បទថា **កិត្តាវតា នុ ខោ ភន្តេ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ដោយបដិបទាមានប្រមាណប៉ុនណា ។ បទថា **សង្ខិត្តេន តណ្ហាសង្ខយវិមុត្តោ ហោតិ** សេចក្តីថា ដោយសង្ខេប ក្នុងបដិបទាប្រមាណប៉ុនណា ឈ្មោះថា បង្អោនទៅក្នុងធម៌ជាទីអស់តណ្ហា ព្រោះភាពដែលភិក្ខុនោះ មានចិត្តបង្អោនទៅ ធ្វើបដិបទានោះឲ្យប្រព្រឹត្តទៅក្នុងអារម្មណ៍និព្វាន ដែលជាទីអស់ទៅនៃតណ្ហានោះ គឺ សក្កទេវរាជស្តេចទេវតាទូលថា សូមព្រះអង្គសម្តែងបដិបទាដែលជាចំណែកខាងដើមរបស់ភិក្ខុ ដែលមានអាសវៈនោះហើយ ដោយបដិបទាសង្ខេប ដែលបង្អោនទៅ ដើម្បីការអស់តណ្ហា ។ បទថា **អច្ចន្តនិដ្ឋោ** សេចក្តីថា កន្លងចំណែក ពោល គឺអស់ និងវិនាស ឈ្មោះថា **អច្ចន្តនិដ្ឋ** ព្រោះមានការសម្រេចកន្លងចំណែកសុទ្ធៗ អធិប្បាយថា សម្រេចកន្លងចំណែកសុទ្ធៗ គឺសម្រេចរឿយៗ ។ បទថា **អច្ចន្តយោគក្ខេមី** សេចក្តីថា មានឱកាសទូលាយចាកកិលេស ជាគ្រឿងប្រកបកន្លងចំណែករឿយៗ ។ បទថា **អច្ចន្តព្រហ្មចារី** បានដល់ ជាព្រហ្មចារីជានិច្ច ។ ឈ្មោះថា **អច្ចន្ត–**

**បរិយោសាន** ដោយន័យមុន ព្រោះមានការចប់កន្លងចំណែក ។ បទថា **សេដ្ឋោ ទេវមនុស្សានំ** បានដល់ ប្រសើរបំផុត គឺឧត្តមជាងទេវតា និងមនុស្សទាំងឡាយ អធិប្បាយថា សក្កទេវរាជស្តេចទេវតា រមែងទូលសួមព្រះមានព្រះភាគថា ភិក្ខុបែបនេះ រមែងជាអ្នកបដិបត្តិដោយបដិបទាប៉ុនណា សូមព្រះអង្គត្រាស់បដិបទា ដោយសង្ខេបរបស់ភិក្ខុនោះរួសរាន់ចុះ ។ សួរថា ព្រោះហេតុអ្វី ទើបសក្កទេវរាជស្តេចទេវតានោះ ប្រាថ្នាការប្រញាប់ប្រញាល់យ៉ាងនោះ ឆ្លើយថា ព្រោះទ្រង់បំណងទៅលេងកីឡា ។ បានឮថា សក្កទេវរាជនោះបញ្ជាឲ្យលេងកីឡាក្នុងឧទ្យាន ហើយឲ្យមហារាជទាំង ៤ រក្សាក្នុងទិសទាំង ៤ ដែលពួកទេវតាហែហមហើយក្នុងលោកទាំង ២ ទ្រង់គង់លើដំរីឯរាវ័ណជាមួយស្រីស្នំ ២ កោដិកន្លះ ប្រថាប់នៅត្រង់ទ្វារឧទ្យាន កំណត់បញ្ហានេះថា បដិបទាដែលជាចំណែកខាងដើម ដែលបុគ្គលគប្បីសម្រេចរបស់ព្រះខីណាស្រពដែលបង្អោនទៅក្នុងធម៌ ជាទីអស់ទៅនៃតណ្ហា ដោយសង្ខេបមានប្រមាណប៉ុនណាហ្ន៎ ។ ពេលនោះ សក្កទេវរាជមានព្រះតម្រិះថា ប្រស្នានេះ ប្រព្រឹត្តទៅដោយសិរីក្រៃលែងពេកណាស់ បើអញមិនបានសួរបញ្ហានេះហើយ ចូលទៅកាន់ឧទ្យានសោត ត្រូវអារម្មណ៍ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ញាំញីហើយ នឹងកំណត់ប្រស្នានេះទៀតមិនបាន ណ្ហើយចុះ ការលេងកីឡាក្នុងឧទ្យានស្ទេះទុកសិនចុះ អញនឹងទៅក្នុងសម្នាក់របស់ព្រះសាស្តា ទូលសួរបញ្ហានេះ អញសួរបញ្ហានេះហើយ នឹងលេងកីឡាក្នុងឧទ្យានជាក្រោយ ដូច្នេះ ។ ហើយបាត់អំពីកដំរី បានប្រាកដក្នុងសម្នាក់របស់ព្រះ

មានព្រះភាគ ។ ស្តេចមហារាជទាំង ៤ នោះ ក៏ឈររក្សានៅក្នុងទីប្រថាប់ត្រង់នោះឯង ពួកទេវតាជាអ្នកបម្រើក្តី ស្រីស្នំទាំងឡាយក្តី ដំរីឯរាវណក្តី នាគរាជក្តី បានឈរនៅត្រង់ទ្វារនោះឯង ។ សក្កទេវរាជនោះ កាលប្រាថ្នាដោយរហ័ស ដើម្បីបំណាន់នឹងលេងកីឡាដោយអាការយ៉ាងនេះ ទើបត្រាស់ហើយយ៉ាងនេះ ។

[ ៧៤ ] បទថា **សព្វេ ធម្មា នាលំ អភិនិវេសាយ** នេះ អធិប្បាយថា ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ឈ្មោះថា ធម៌ទាំងពួង ធម៌ទាំងអស់នោះមិនគួរ គឺមិនរៀន មិនប្រាថ្នា មិនប្រកបទុក ដោយការប្រកាន់មាំដោយអំណាចនៃតណ្ហា និងទិដ្ឋិ ព្រោះហេតុអ្វី ព្រោះមិនតាំងនៅដោយអាការដែលបុគ្គលនឹងកាន់យកបាន ។ ពិតហើយ ធម៌ទាំងឡាយ មានខន្ធ ៥ ជាដើមនោះ ទោះបីប្រកាន់ថា ជារបស់ទៀង ការមិនទៀងប៉ុណ្ណោះរមែងកើតឡើង ទោះបីប្រកាន់ថា ជាសុខ សេចក្តីទុក្ខប៉ុណ្ណោះរមែងដល់ព្រម ទោះបីប្រកាន់ថា ជាអត្តា អនត្តាប៉ុណ្ណោះរមែងប្រាកដ ព្រោះដូច្នោះ ទើបបុគ្គលមិនគួរប្រកាន់មាំ ។ បទថា **អភិជានាតិ** បានដល់ រមែងជ្រាបច្បាស់ដោយញាតបរិញ្ញាថា មិនទៀង ជាទុក្ខ ជាអនត្តា ។ បទថា **បរិជានាតិ** បានដល់ រមែងកំណត់ដឹងដោយតីរណបរិញ្ញាយ៉ាងនោះឯង ។ បទថា **យំ កិញ្ចិ វេទនំ** បានដល់ សោយនូវអារម្មណ៍ណាមួយ មានប្រមាណតិច ដោយហោច សូម្បីសម្បយុត្តដោយបញ្ចវិញ្ញាណ ។ ព្រះមានព្រះភាគ រមែងសម្តែងការកំណត់អរូបធម៌ដែលកើតឡើងដោយអំណាចនៃវេទនាដល់សក្កទេវរាជ

ដោយបទនេះ ។ បើវេទនាកម្មដ្ឋាន ជាធម៌ដែលព្រះមានព្រះភាគមិនបាន ត្រាស់ទុកខាងដើមសោត ក៏មិនគួរពោលក្នុងទីនេះឡើយ ។ តែកម្មដ្ឋាននោះ ព្រះមានព្រះភាគត្រាស់ទុកខាងដើម ដូច្នោះ គប្បីជ្រាបវេទនាកម្មដ្ឋានដោយ ន័យដែលពោលហើយ ក្នុងសតិប្បដ្ឋាន ។

ក្នុងបទថា **អនិច្ចានុបស្សី** នេះ គប្បីជ្រាបថា ជាអនិច្ចំ ជាអនិច្ចា- នុបស្សា និងអនិច្ចានុបស្សី ។ ក្នុងទីនេះ មានអធិប្បាយថា ក្នុងបណ្ដាបទ ទាំងនោះ បានដល់ បញ្ចក្ខន្ធ ឈ្មោះថា អនិច្ចំ ពិតហើយ បញ្ចក្ខន្ធទាំងនោះ ឈ្មោះថា ជារបស់មិនទៀង ព្រោះអត្ថថា មានការកើតឡើង និងមានការ វិនាសទៅ ។ ការឃើញ ការដឹងនូវបញ្ចក្ខន្ធទាំងឡាយ ដោយការអស់ទៅ សូន្យទៅ ឈ្មោះថា អនិច្ចានុបស្សនា បុគ្គលដែលប្រកបដោយញាណនោះ ឈ្មោះថា អនិច្ចានុបស្សី ។ ព្រោះដូច្នោះ បទថា **អនិច្ចានុបស្សី វិហរតិ** បានដល់ កាលបុគ្គលតាមឃើញដោយភាពជារបស់មិនទៀង ។

ក្នុងបទថា **វិរាគានុបស្សី** បានដល់ វិរាគៈ ២ យ៉ាង គឺខយវិរាគៈ និង អច្ចន្តវិរាគៈ ។ ក្នុង ២ បទនោះ វិបស្សនាជាគ្រឿងឃើញសង្ខារទាំងឡាយ ដោយការអស់ទៅ សូន្យទៅ ឈ្មោះថា ខយវិរាគៈ ។ ឯមគ្គញ្ញាណ ជា គ្រឿងឃើញព្រះនិព្វាន ដែលជាអច្ចន្តវិរាគៈដោយវិរាគៈ ឈ្មោះថា វិរាគា- នុបស្សនា បុគ្គលដែលដល់ព្រមដោយវិរាគៈទាំង ២ យ៉ាងនោះ ឈ្មោះថា វិរាគានុបស្សី ។ បទថា **វិរាគានុបស្សី** លោកពោលសំដៅដល់បុគ្គលនោះ អធិប្បាយថា បុគ្គលតាមឃើញដោយភាពជាវិរាគៈ ។ សូម្បីក្នុងបទថា

**និរោធានុបស្សី** ក៏មានន័យដូចគ្នា ។ ពិតហើយ និរោធក៏មាន ២ យ៉ាងដូចគ្នា គឺខយនិរោធ និងអច្ចន្តនិរោធ ។

**វោស្សគ្គ** គឺការលះបង់ហើយ លោកហៅថា ការលះបង់ ក្នុងបទថា **បដិនិស្សគ្គានុបស្សី** នេះ ។ **វោស្សគ្គ** មាន ២ គឺបរិច្ចាគវោស្សគ្គ និងបក្ខន្ទនវោស្សគ្គ ។ វោស្សគ្គ ២ យ៉ាងនោះ វិបស្សនា ឈ្មោះថា បរិច្ចាគ-វោស្សគ្គ ព្រោះថា វិបស្សនានោះរមែងលះបង់កិលេស និងខន្ធទាំងឡាយដោយអំណាចនៃតទង្គៈ ។ មគ្គ ឈ្មោះថា បក្ខន្ទនវោស្សគ្គ ព្រោះមគ្គនោះរមែងស្ទុះទៅកាន់និព្វានដោយអារម្មណ៍ ។ ម្យ៉ាងទៀត ការលះដោយហេតុទាំង ២ គឺព្រោះការលះបង់ខន្ធទាំងឡាយ កិលេសទាំងឡាយដោយអំណាចនៃសមុច្ឆេទ និងការស្ទុះទៅក្នុងនិព្វាន ដូច្នោះ ឈ្មោះថា បរិច្ចាគវោស្សគ្គព្រោះអត្ថថា លះបង់កិលេសទាំងឡាយ និងខន្ធទាំងឡាយ និរោធ ឈ្មោះថាបក្ខន្ទនវោស្សគ្គ ព្រោះអត្ថថា ចិត្តរមែងស្ទុះទៅក្នុងនិព្វានធាតុ ។ ទាំង ២ យ៉ាងនោះ រមែងស្មើគ្នាក្នុងមគ្គ បុគ្គលដែលដល់ព្រមដោយវោស្សគ្គទាំង ២ នោះ ឈ្មោះថា បដិនិស្សគ្គានុបស្សី ព្រោះភាពដែលបុគ្គលនោះជាអ្នកប្រកបដោយការឃើញ ដោយការលះបង់នេះ ។ ព្រះមានព្រះភាគត្រាស់សំដៅយកពាក្យដែលពោលនោះ ទើបត្រាស់ថា **បដិនិស្សគ្គានុបស្សី** ។

បទថា **ន កិញ្ចិ លោកេ ឧបាទិយតិ** បានដល់ រមែងមិនប្រកាន់មាំមិនប្រកាន់ មិនស្ទាបអង្អែលនូវធម៌ណាមួយ ដែលដល់នូវភាពជាសង្ខារ ដោយអំណាចនៃតណ្ហា រមែងមិនតក់ស្លុត ព្រោះការមិនប្រកាន់មាំ កាលមិនប្រកាន់

ទើបមិនតក់ស្លុត ព្រោះការតក់ស្លុតដោយតណ្ហាទាំងឡាយ រមែងរលត់ទៅចំពោះខ្លួនប៉ុណ្ណោះ ដូច្នោះ ទើបឈ្មោះថា រមែងរលត់ដោយការរម្ងាត់កិលេសឯងនោះឯង ។ បច្ចវេក្ខណៈនៃព្រះខីណាស្រពនោះឯង លោកសម្ដែងដោយបទថា **ខីណាជាតិ** ជាដើម ។ ព្រះមានព្រះភាគដែលសក្កទេវរាជ ស្ដេចទៅតាទូលសួរបដិបទា ដែលជាចំណែកខាងដើមរបស់ព្រះខីណាស្រពដោយសង្ខេប ទ្រង់ធ្វើឲ្យស្ងៀមព្រះហឫទ័យ ព្រមដោយការឆ្លើយបញ្ហា ដោយសង្ខេបរួសរាន់ ដោយប្រការដូច្នេះ ។

[ ៧៥ ] បទថា **អវិទូរេ និសិន្នោ ហោតិ** សេចក្ដីថា ព្រះមហាមោគ្គល្លានគង់នៅក្នុងកូដាគារក្បែរនោះ ។ បទថា **អភិសមេច្ច** បានដល់ មកដល់ព្រមដោយញាណ អធិប្បាយថា ដឹងហើយ ។ សេចក្ដីថា សក្កទេវរាជនោះដឹងបញ្ហាហើយ ទើបត្រេកអរ ឬថា មិនដឹង ហើយត្រេកអរ ព្រោះហេតុអ្វី ទើបព្រះថេរៈមានការគិតយ៉ាងនេះ បានឮថា ព្រះថេរៈមិនបានឮសំឡេងដោះស្រាយបញ្ហារបស់ព្រះមានព្រះភាគ តែបានឮសំឡេងអនុមោទនារបស់សក្កទេវរាជថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីនោះយ៉ាងនោះឯងដូច្នេះ ។ បានឮថា សក្កទេវរាជទ្រង់អនុមោទនាដោយសំឡេងដ៏ខ្លាំង ។ សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបមិនបានឮសំឡេងព្រះមានព្រះភាគ ឆ្លើយថា ព្រោះញុំាងបរិស័ទឲ្យដឹង ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ ទ្រង់សម្ដែងធម៌ សូម្បីបរិស័ទនៅក្នុងទីបំផុតនៃចក្រវាល រមែងបានឮព្រះសូរសៀងដូចគ្នា ។ តែហួសអំពីបរិស័ទហើយ ព្រះសូរសៀងនឹងមិនផ្សាយទៅខាងក្រៅ

សូម្បីត្រឹមមួយផ្ទាប់ឡើយ ព្រោះហេតុអ្វី ទើបមធុរកថាបែបនេះ មិនមានប្រយោជន៍ ។

កាលនោះ ព្រះមានព្រះភាគប្រថាប់គង់ក្នុងបន្ទប់ដ៏ជាសិរី ក្នុងកូដាគារដែលសម្រេចហើយ ដោយកែវ ៧ ប្រការ លើប្រាសាទរបស់មិគារមាតា កូដាគារដែលជាទីនៅរបស់ព្រះសារីបុត្រខាងស្ដាំ របស់ព្រះមហាមោគ្គល្លាននៅខាងឆ្វេង មិនមានប្រហោងជាប់តគ្នាខាងក្នុង ព្រោះហេតុនោះ ទើបព្រះថេរៈមិនឮសំឡេងរបស់ព្រះមានព្រះភាគ ឮតែសំឡេងរបស់សក្កទេវរាជប៉ុណ្ណោះ ។

បទថា **បញ្ចហិ តុរិយសតេហិ** បានដល់ តន្ត្រីប្រកបដោយអង្គ ៥ មានប្រមាណ ៥០០ ។ គ្រឿងតន្ត្រីប្រកបដោយអង្គ ៥ គឺ **អាតតំ** ស្គរជំពាស់ស្បែកតែម្ខាង **វិតតំ** គឺស្គរសម្ភោរ **អាតតវិតតំ** គឺស្គរបណ្ឌវៈ **សុសិរំ** គឺប៉ី ឬស័ង្ខជាដើម និង **ឃនំ** គឺឆាបជាដើម ឈ្មោះថា តន្ត្រីប្រកបដោយអង្គ ៥ ។ ក្នុងគ្រឿងតន្ត្រីទាំងនោះ បណ្ដាស្គរទាំងឡាយ មានស្គរដែលពាស់ស្បែកតែម្ខាង ឈ្មោះថា **អាតត** ។ ស្គរដែលពាស់ស្បែកសងខាង ឈ្មោះថា **វិតត** ។ ស្គរដែលពាសដោយស្បែកទាំងអស់ មានបណ្ឌវៈជាដើម ឈ្មោះថា **អាតតវិតត** ។ គ្រឿងផ្លុំ មានប៉ីជាដើម ឈ្មោះថា **សុសិរ** ឆាបជាដើម ឈ្មោះថា **ឃន** ។

បទថា **សមប្បិតោ** បានដល់ ចូលដល់ហើយ ។ បទថា **សមង្គីភូតោ** ជាវេវចនៈរបស់ **សមប្បិតោ** នោះឯង ។ បទថា **បរិចារេតិ** បានដល់

សោយនូវសម្បត្តិ ឲ្យបម្រើឥន្ទ្រិយទាំងឡាយអំពីសម្បត្តិនោះៗ អធិប្បាយថា ប្រកបដោយតន្ត្រី ៥០០ កំដរ សោយនូវទិព្វសម្បត្តិ ។ បទថា **បដិបណាមេត្វា** បានដល់ ឲ្យឈប់សិន គឺធ្វើមិនឲ្យមានសំឡេងតន្ត្រី ។ ឧបមាដូចក្នុងឥឡូវនេះ ព្រះរាជាទាំងឡាយ ដែលមានសទ្ធាទៅឃើញភិក្ខុដែលគួរដល់ការគោរព ទើបត្រាស់ថា លោកម្ចាស់ឈ្មោះនោះមកហើយ ពួកអ្នកកុំច្រៀង កុំប្រគំតន្ត្រី កុំរាំ ហើយឲ្យផ្អាកការសម្តែង យ៉ាងណា សូម្បីសក្កទេវរាជទតឃើញព្រះថេរៈ ក៏បានធ្វើដូច្នោះ ។

បទថា **ចិរស្សំ ខោ មារិស មោគ្គល្លាន ឥមំ បរិយាយមកាសិ** ជាពាក្យហៅដោយវាចាជាទីស្រឡាញ់ ដោយប្រក្រតីក្នុងលោក ។ ពិតហើយ សត្វលោកឃើញបុគ្គលដែលមកយូរហើយខ្លះ មិនធ្លាប់មកខ្លះ មកក្នុងជាតិរបស់បុគ្គលដែលជាទីពេញចិត្ត នាំគ្នាសួរជាដើមថា អ្នកមកអំពីទីណា មកយូរហើយឬ អ្នកដឹងផ្លូវមកទីនេះបានដូចម្តេច អ្នកវង្វេងផ្លូវមកឬទេ ។ សក្កទេវរាជក៏ត្រាស់យ៉ាងនេះ ដល់ព្រះមហាមោគ្គល្លានត្ថេរ ព្រោះធ្លាប់មកហើយ ពិតហើយ ព្រះថេរៈរមែងត្រាច់ចារិកទៅក្នុងទេវលោកជាធម្មតានោះឯង ។ បណ្តាបទទាំងនោះ បទថា **បរិយាយមកាសិ** ប្រែថា បានធ្វើវារៈ ។ បទថា **យទិទំ ឥធាគមនាយ** អធិប្បាយថា វារៈដែលមកក្នុងទីនេះឯណា បានធ្វើវារៈនោះអស់កាលយូរ ។ បទថា **ឥទមាសនំ បញ្ញត្តំ** សេចក្តីថា សក្កទេវរាជក្រាលបល្ល័ង្កកែវមណីមួយយោជន៍ ទើបត្រាស់យ៉ាងនេះ ដូច្នេះ ។

[ ៧៦ ] បទក្នុង **ពហុកិច្ចា ពហុករណីយា** នេះ សេចក្តីថា កិច្ចទាំង-

ឡាយនៃជនពួកណាច្រើន ជនទាំងនោះ ឈ្មោះថា មានកិច្ចច្រើន ។ បទថា **ពហុករណីយា** នេះ ជាពាក្យវេវចនៈនៃបទថា **ពហុកិច្ចា** នោះឯង ។ បទថា **អប្បេន សកេន ករណីយេន** បានដល់ ករណីយកិច្ចរបស់ខ្លួននោះឯង ។ ឯករណីយកិច្ចរបស់សក្កទេវរាជនោះតិច មិនច្រើនឡើយ តែករណីយកិច្ចនៃទេវតាទាំងឡាយមានច្រើន ពិតហើយ ក្ដីតាំងអំពីផែនដីទៅ ត្រូវការដើមកប្បព្រឹក្ស និងមាតុគ្រាមជាដើម រមែងវិនិច្ឆ័យក្នុងសម្នាក់របស់សក្កទេវរាជ ព្រោះដូច្នោះ កាលសក្កៈកំពុងកំណត់ ទើបត្រាស់ថា មានករណីយកិច្ចនៃទេវតាទាំងឡាយជាន់តាវត្តិង្សទៀត ដូច្នេះ ។ ពិតហើយ ធីតា និងបុត្ររមែងកើតឡើងត្រង់ភ្លៅរបស់ទេវតាទាំងឡាយ ស្រីដែលជាបាទបរិចារិការមែងកើតឡើងក្នុងទីដេក គ្រឿងប្រដាប់តុបតែងរបស់ទេវតាទាំងនោះ ក៏កើតជុំវិញទីដេករបស់ទេពធីតា អ្នកជំនួយការទាំងឡាយ កើតឡើងខាងក្នុងវិមាន ទើបមិនមានក្ដីក្នុងវត្ថុទាំងនោះ តែមាតុគ្រាមវិញ រមែងកើតក្នុងព្រំដែន គេមិនអាចសម្រេចថា មាតុគ្រាមជាសម្បត្តិរបស់ខ្ញុំ ឬរបស់អ្នក កាលក្ដីកើតឡើង ទើបទូលសួរសក្កទេវរាជ ។ សក្កទេវរាជនោះ រមែងត្រាស់ថា វិមានរបស់អ្នកណានៅជិតជាង ជាសម្បត្តិរបស់អ្នកនោះ ។ បើវិមានទាំង ២ មានចម្ងាយស្មើគ្នា សក្កទេវរាជក៏ត្រាស់ថា អ្នកដែលកើតមកនោះ ឈរសម្លឹងមើលវិមានរបស់អ្នកណា ជាសម្បត្តិរបស់អ្នកនោះ ។ បើមិនសម្លឹងមើលសូម្បីតែវិមានមួយ ដើម្បីកាត់នូវវិវាទរបស់ទេវតាទាំងឡាយនោះ ក៏ធ្វើមាតុគ្រាមនោះ ឲ្យជាសម្បត្តិរបស់ព្រះអង្គឯង ។ សក្កទេវរាជត្រាស់ពាក្យថា មាន

ករណីយកិច្ចរបស់ទេវតាទាំងឡាយជាន់តាវត្តិង្ស ដូច្នេះ សំដៅយកពាក្យដែលពោលហើយនោះ ។ ម្យ៉ាងទៀត សូម្បីកិច្ច គឺការក្រសាលឧទ្យានបែបនេះ ក៏ជាករណីយកិច្ចរបស់សក្កទេវរាជដូចគ្នា ។

បទថា **យំ នោ ខិប្បមេវ អន្តរធាយតិ** សេចក្តីថា ពាក្យណាដែលខ្ញុំស្តាប់ហើយ ពាក្យនោះបាត់ទៅហើយឆាប់រហ័ស ដូចរូបដែលមិនប្រាកដក្នុងទីងងឹត គឺថា សក្កទេវរាជនោះ រមែងសម្តែងថា បពិត្រលោកដ៏ចម្រើន ខ្ញុំរមែងកំណត់មិនបានដល់ការស្រាយបញ្ហានោះ ដោយបទថា **យន្នោ ខិប្ប-មេវ អន្តរធាយតិ** នេះ ។ ព្រះថេរៈពិចារណាមើលថា ព្រោះហេតុអ្វីហ្ន៎ សក្កទេវរាជនេះ សម្តែងដល់ការដែលខ្លួនជាអ្នកធ្វើការកំណត់មិនបាន ក៏បានដឹងថា ដើម្បីរក្សាប្រយោជន៍ ដែលជាចំណែកខាងដើម ដែលឈ្មោះថា ពួកទេវតារមែងជាអ្នកភ្លេចស្មារតី ត្រូវអារម្មណ៍ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ គ្របសង្កត់ រមែងមិនដឹងនូវភាពដែលខ្លួនជាអ្នកបរិភោគហើយ ឬមិនទាន់បរិភោគ រមែងមិនដឹងនូវភាពដែលខ្លួនជាអ្នកផឹកហើយ ឬមិនទាន់បានផឹក និងភ្លេចកិច្ចដែលខ្លួនធ្វើហើយក្នុងទីនេះ ដូច្នេះ ។

អាចារ្យពួកខ្លះពោលថា ព្រះថេរៈជាអ្នកគួរគោរព គួរលើកតម្កើងរបស់សក្កទេវរាជ ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះ ដោយខ្លាចក្រែងព្រះថេរៈគប្បីគំរាមយ៉ាងនេះថា ឥឡូវនេះ សក្កទេវរាជសាកសួរបញ្ហាក្នុងសម្នាក់របស់អគ្គបុគ្គលក្នុងលោក មកហើយ ឥឡូវនេះ ក៏ចូលទៅកាន់ចំណោមស្រីបាំទាំងឡាយ ។ ឈ្មោះថា ការវង្វេងភ្លេចយ៉ាងនេះ រមែងមាន ។ ឈ្មោះថា

ការរវង្វេងភ្លេចបែបនេះរបស់ព្រះអរិយសាវក រមែងមិនមាន ។ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា សក្កទេវរាជនោះកំណត់មិនបាន ដោយភាពជាអ្នកភ្លេចស្មារតី សួរថា ព្រោះហេតុអ្វី ទើបក្នុងកាលខាងក្រោយកំណត់បាន ឆ្លើយថា ព្រោះថេរៈបានញ៉ាំងសោមនស្ស និងសេចក្តីសង្វេគឲ្យកើតដល់លោកហើយ នាំនូវការងងឹតចេញទៅ ទើបកំណត់បាន ។

ឥឡូវនេះ សក្កទេវរាជដើម្បីនឹងប្រាប់ហេតុដែលគួរភ្លេចភ្លាំងណាមួយរបស់ខ្លួន ក្នុងកាលមុនដល់ព្រះថេរៈ ទើបត្រាស់ថា **ភូតបុព្វំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **សមុបព្យុឡ្ហោ** ប្រែថា ប្រកៀកគ្នាហើយ គឺជាកងទ័ព ។ បទថា **អសុរាបរាយឹសុ** បានដល់ ពួកអសុរដល់នូវការបរាជ័យ ។ សួរថា ពួកអសុរទាំងនោះដល់នូវការបរាជ័យក្នុងកាលណា ឆ្លើយថា ក្នុងកាលដែលសក្កទេវរាជទ្រង់កើតឡើង ។

បានឮថា សក្កទេវរាជកើតជាមាណព ជាបណ្ឌិត ជាអ្នកមានប្រាជ្ញា ឈ្មោះថា មឃៈ ក្នុងស្រុកអចលគ្រាម ដែនមគធរដ្ឋ ក្នុងអត្តភាពបន្ទាប់អំពីព្រះឥន្ទ្រ ការប្រព្រឹត្តរបស់មឃមាណព ដូចគ្នានឹងការប្រព្រឹត្តរបស់ព្រះពោធិសត្វ ។ មឃមាណពនោះ នាំបុរស ៣៣ នាក់ ធ្វើសេចក្តីល្អ ។ ថ្ងៃមួយ គាត់ពិចារណាដោយបញ្ញារបស់ខ្លួនហើយ ជញ្ជូនសំរាមទាំងសងខាងក្នុងទីដែលមហាជនប្រជុំគ្នា ត្រង់កណ្តាលស្រុកចេញ បានធ្វើទីនោះឲ្យជារមណីយដ្ឋាន បានសាងមណ្ឌបក្នុងទីនោះឯង កាលកន្លងទៅទៀត ក៏បានសាងសាលា គាត់ចេញអំពីស្រុកត្រាច់ទៅ មួយអន្ទើដោយសម្លាញ់ទាំងនោះ

បានធ្វើទីដែលមិនស្មើ ឲ្យរាបស្មើ មានប្រមាណមួយគាវុតខ្លះ កន្លះយោជន៍ខ្លះ ៣ គាវុតខ្លះ មួយយោជន៍ខ្លះ ជនទាំងអស់នោះ មានឆន្ទៈតែមួយ ធ្វើស្ពានក្នុងទីដែលគួរធ្វើ សាងមណ្ឌបជាដើមក្នុងទីដែលគួរដល់មណ្ឌប សាលា ស្រះបោក្ខរណី និងដាំឈើផ្កា ឈើគុម្ពជាដើម បានធ្វើបុណ្យដ៏ច្រើន ។ មឃមាណពបានបំពេញវត្តបទ ៧ ប្រការ កាលអស់អាយុ រមែងទៅកើតក្នុងតាវត្តិង្សពិភព មួយអន្លើដោយសម្លាញ់ ក្នុងកាលនោះ ពួកអសុរនៅអាស្រ័យក្នុងតាវត្តិង្សទេវលោក ។ ពួកអសុរទាំងអស់នោះ មានអាយុ និងពណ៌សម្បុរដូចគ្នានឹងទេវតាទាំងឡាយ ពួកគាត់ឃើញសក្កៈ ព្រមទាំងបរិស័ទកំពុងកើតឡើង ទើបគិតថា ពួកទេវបុត្រថ្មីមកហើយ ទើបចាត់ចែងធ្វើមហាបានៈទទួល ។ សក្កទេវរាជបានឲ្យសញ្ញា គឺប្រាប់ឧបាយដល់ទេវបុត្រទាំង-ឡាយថា ពួកយើងធ្វើកុសល តែមិនបានធ្វើកុសលទូទៅ ជាមួយជនដទៃ ពួកអ្នកកុំផឹកទឹកគណ្ឌបាន ធ្វើត្រឹមតែផឹកប៉ុណ្ណោះ ដូច្នេះ ។ ពួកទេវបុត្របានធ្វើយ៉ាងនោះ ពួកអសុរល្ងង់នាំគ្នាផឹកគណ្ឌបានស្រវឹង ហើយដេកលក់ទៅ ។ សក្កទេវរាជឲ្យសញ្ញាដល់ពួកទេវតា នាំគ្នាចាប់ជើងពួកអាសុរគ្រវែងទៅកាន់ជើងភ្នំសិនេរុ ព្រោះថា ពិភពរបស់អសុរមាននៅក្នុងផ្ទៃខាងក្រោមនៃភ្នំសិនេរុ មានប្រមាណនប៉ុនតាវត្តិង្សទេវលោកដែរ ។ ពួកអសុរនៅក្នុងទីនោះ មានដើមឈើរបស់ពួកអសុរ ឈ្មោះ ចិត្តបាដលិប្រចាំភព ។ ពួកអសុរទាំងនោះរមែងដឹងបានក្នុងវេលាដែលផ្កាចិត្តបាដលិរីកថា ដើមឈើនេះមិនមែនដើមឈើប្រចាំភពតាវត្តិង្ស ពួកយើងត្រូវសក្កទេវរាជបោកបញ្ឆោតហើយ ។ ពួក

អសុរពោលថា ពួកអ្នកចូរចាប់សក្កទេវរាជនោះ ដូច្នេះហើយ គ្រប់គ្រងរក្សាក្នុំសិនេរុ កាលភ្លៀងធ្លាក់ហើយ ក៏នាំគ្នាឡើងទៅដូចកណ្ដៀរចេញទៅអំពីដំបូក ។ ក្នុងការច្បាំងគ្នានោះ ជួនកាលពួកទេវតាឈ្នះ ជួនកាលពួកអសុរឈ្នះ ។ កាលណា ពួកទេវតាឈ្នះ ក៏ដេញតាមពួកអសុរទៅ រហូតដល់សមុទ្រ ។ កាលណាពួកអសុរឈ្នះ ក៏ដេញតាមពួកទេវតាទៅ រហូតដល់ខាងក្រៅកំពែងក្រុង ។ តែការច្បាំងនោះ ពួកទេវតាជាអ្នកឈ្នះ ទើបពួកទេវតាដេញពួកអសុរទៅរហូតដល់មាត់សមុទ្រ ។ សក្កទេវរាជញ៉ាំងពួកអសុរឲ្យគេចទៅហើយ ទើបរៀបចំតាំងការរក្សាទុកក្នុងទី ៥ កន្លែង ។ បានឲ្យរក្សាយ៉ាងនេះ ទ្រង់តាំងរូបចម្លាក់ដែលមានទ្រង់ទ្រាយដូចព្រះឥន្ទ្រ មានដៃកាន់វជិរខាងក្រៅកំពែង ។ អាសុរទាំងឡាយ លើកគ្នាមកថ្មើរណា ក៏ឃើញរូបព្រះឥន្ទ្រនោះ ទើបនាំគ្នាបកក្រោយអំពីទីនោះឯង ដោយសម្គាល់ថា សក្កទេវរាជមិនប្រមាទ ប្រថាប់ឈរក្នុងទីនោះឯង ដូច្នេះ ។ បទថា **តតោ បដិនិវត្តិត្វា** បានដល់ ត្រឡប់ចាកទីដែលសក្កៈនោះឈ្នះហើយ ។ បទថា **បរិចារិកាយោ** ប្រែថា ទេពអប្សរទាំងឡាយ បានដល់ ទេពអប្សរដែលធ្វើកិច្ចទាំងឡាយ មានក្រងផ្កា និងគ្រឿងក្រអូបជាដើម ។

[ ៧៧ ] បទថា **វេស្សវណោ ច មហារាជា** សេចក្ដីថា បានឮថា ស្ដេចវេស្សវ័ណជាទីប្រោសប្រាណ ជាអ្នកស្និទ្ធស្នាលរបស់សក្កទេវរាជ ព្រោះដូច្នោះ ទើបបានទៅជាមួយសក្កទេវរាជ ។

បទថា **បុរក្ខត្វា** គឺធ្វើទុកខាងមុខ ។ បទថា **បរិសីសុ** សេចក្ដីថា ទេព

ធីតាដែលបម្រើសក្កទេវរាជទាំងនោះ ចូលទៅកាន់បន្ទប់ហើយ បិទទ្វារពាក់កណ្តាល ឈរសម្លឹងមើល ។ បទថា **ឥទម្បិ មារិស មោគ្គល្លាន បស្ស វេជយន្តបាសាទស្ស រាមណេយ្យកំ** សេចក្តីថា បពិត្រព្រះមោគ្គល្លានអ្នកនិទ៌ុក្ខ សូមលោកម្ចាស់មើលទីជាទីរីករាយនៃវេជយន្តប្រាសាទនេះ គឺសូមមើលសត្វសាហាវត្រង់សសរមាស សសរប្រាក់ សសរកែវមណី សសរកែវប្រពាល សសរកែវទទឹម សសរកែវមកិត សសរកែវមុក្តា សសររតនៈ ៧ ប្រការ ជាសសរសម្រេចហើយដោយមាសជាដើម នៃសសរទាំងឡាយនោះ ព្រោះដូច្នោះ កាលសក្កទេវរាជសម្តែងទីដែលគួររីករាយ ធ្វើជួរនៃសសរដោយអាការយ៉ាងនេះជាដើម ទើបត្រាស់យ៉ាងនោះ ។

បទថា **យថាតំ បុព្វេ កតបុញ្ញស្ស** អធិប្បាយថា ទីលំនៅរបស់បុគ្គលអ្នកមានបុណ្យធ្វើទុកក្នុងកាលមុន គប្បីរុងរឿងដោយការតាំងទុកនូវគ្រឿងឧបភោគ យ៉ាងណា របស់សក្កទេវរាជ ក៏រមែងរុងរឿងដូច្នោះដូចគ្នា ។ បទថា **អតិពាឡ្ហំ ខោ អយំ យក្ខោ បមត្តោ វិហរតិ** សេចក្តីថា សក្កៈនេះស្រវឹងក្រៃពេកដោយប្រាសាទ ដោយអ្នកបំរើជាបរិវារ ដោយសម្បត្តិ ដោយយសរបស់ខ្លួន ។ បទថា **ឥទ្ធាភិសង្ខារំ អភិសង្ខារេតិ** គឺបានធ្វើឫទ្ធិ ។ អធិប្បាយថា ព្រះមហាមោគ្គល្លានចូលអាបោកសិណ ហើយអធិដ្ឋានថា ចូរឱកាសដែលជាទីតាំងប្រាសាទ ទៅជាទឹក ហើយយកមេជើងសង្កត់ត្រង់ជហ្វាប្រាសាទ ។ ប្រាសាទនោះ ក៏រង្គើទៅមក ដូចបាត្រតាំងនៅលើទឹក យកដៃគោះត្រង់កណ្តាប់មាត់បាត្រ ក៏ឃ្លេងឃ្លោងទៅមក តាំងនៅមិនបាន ដូច្នោះ ។

វត្ថុទាំងឡាយ មានមេដំបូល ជហ្វា ផ្ទឹមជាដើម បញ្ចេញសំឡេង ក្រែះៗ ហាក់បីដូចផ្តើមនឹងធ្លាក់ទៅ ដោយហេតុនោះ ទើបលោកពោលថា **សង្កម្បេសិ សម្បកម្បេសិ សម្បវេធេសិ ។** បទថា **អច្ឆរិយព្ភុតចិត្តជាតា** បានដល់ មានសេចក្តីអស្ចារ្យដែលមិនធ្លាប់មាន កើតឡើងយ៉ាងនេះថា ឱហ្ន៎ គួរអស្ចារ្យពិត មិនធ្លាប់មានមក និងមានសេចក្តីត្រេកអរ គឺមានសោមនស្ស មានកម្លាំងកើតឡើងហើយ ។

[ ៧៨ ] បទថា **សំវិគ្គំ** បានដល់ តក់ស្លុតភ័យខ្លាចហើយ គឺញាប់ញ័រហើយ ។ បទថា **លោមហដ្ឋជាតំ** បានដល់ ព្រឺរោមព្រឺស្បែក គឺមានសរីរៈដេរដាសដោយរោមទាំងឡាយបះឡើងទៅខាងលើ ដូចតម្កក់សម្រាប់ព្យួរកែវមណី ដែលគេតាំងទុកត្រង់ជញ្ជាំងមាស ដូច្នោះ ម្យ៉ាងទៀត ឈ្មោះថា ព្រឺរោមនេះ រមែងកើតឡើងដោយសោមនស្សក៏មាន ដោយទោមនស្សក៏មាន ។ តែក្នុងទីនេះ កើតឡើងដោយសោមនស្ស ។ បានឮថា ព្រះថេរៈបានធ្វើបាដិហារ្យនោះ ដើម្បីឲ្យសក្កទេវរាជ កើតសេចក្តីសង្វេគដោយសោមនស្ស និងការតក់ស្លុត ព្រោះដូច្នោះ គប្បីជ្រាបអត្ថថា ព្រះមហាមោគ្គល្លាននោះដឹងថា សក្កទេវរាជតក់ស្លុត ព្រឺរោមហើយ ដោយសោមនស្ស និងសេចក្តីសង្វេគ ដូច្នេះ ។

បទថា **ឥធាហំ មារិស** សេចក្តីថា ឥឡូវនេះ ព្រះថេរៈញុំាងសោមនស្ស និងសង្វេគរបស់សក្កទេវរាជឲ្យកើតឡើង ទម្លាយនូវងងឹតបានហើយ ព្រោះដូច្នោះ កំណត់បានហើយ ទើបពោលយ៉ាងនេះ ។

បទថា **ឃសោ នុ តេ មារិស សោ ភគវា សត្ថា** សេចក្តីថា កាល ទេពអប្សរទូលសួរថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះអង្គស្តេចទៅណា សក្កៈ ត្រាស់ឆ្លើយថា ទៅកាន់សម្នាក់របស់ព្រះសាស្តានៃយើង ព្រះអង្គត្រាស់ យ៉ាងនេះ ហាក់ដូចទីនោះ តាំងនៅជាមួយគ្នានឹងទេវលោកនេះ ។ ទូលសួរ ទៀតថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះសមណៈនោះ ជាព្រះមានព្រះភាគ ជា សាស្តារបស់ព្រះអង្គឬហ្ន៎ ។ ក្នុងបទថា **សព្រហ្មចារី មេ ឃសោ** នេះ សេចក្តីថា ព្រះថេរៈជាបព្វជិត ជាអ្នកដល់ព្រមដោយអភិនីហារ ជាអគ្គសាវក តែសក្ក ទេវរាជជាអ្នកគ្រប់គ្រងផ្ទះក៏ពិត ទោះដូច្នោះ លោកទាំង ២ ក៏ជាព្រហ្មចារី ដោយអំណាចនៃមគ្គព្រហ្មចរិយៈ ព្រោះដូច្នោះ ទើបសក្កៈត្រាស់យ៉ាងនោះ ។ បទថា **អហោ នូន តេ សោ ភគវា សត្ថា** សេចក្តីថា សព្រហ្មចារីរបស់ ព្រះអង្គមានឫទ្ធិច្រើនដល់ម៉្លេះហ្ន៎ ។ ពួកនាងបរិចារិកាបានពោលដល់ការកើត ឡើងក្នុងការឃើញឥទ្ធិប្បាដិហារ្យនៃព្រះសាស្តា ទើបពោលយ៉ាងនេះថា ព្រះ ថេរៈជាព្រះមានព្រះភាគ ដែលជាសាស្តារបស់ព្រះអង្គ គួរមានឫទ្ធិច្រើនពិត ។

[ ៧៩ ] បទថា **ញាតញ្ញតរស្ស** សេចក្តីថា បុគ្គលណាមួយដែល ប្រាកដ ពិតហើយ បណ្តាបុគ្គលដែលមានឈ្មោះបោះសំឡេងទាំងឡាយ ក៏មាន សក្កទេវរាជម្នាក់ដែរ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ប្រាកដច្បាស់ហើយ ព្រះ មានព្រះភាគ ទ្រង់ញ៉ាំងទេសនាឲ្យចប់តាមអនុសន្ធិ ដូច្នេះឯង ៕

## ចូឡតណ្ហាសង្ខយសូត្រទី ៧ ចប់

# សុត្តន្តបិដក

## មហាតណ្ហាសង្ខយសូត្រទី ៨

[ ៨០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចសម្រាន្តព្រះឥរិយាបថ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុឈ្មោះសាតិ ជាកូននៃព្រានសំណាញ់ មានទិដ្ឋិអាក្រក់ កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅ មិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់ នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ យ៉ាងនោះដែរ ។ ពួកភិក្ខុជាច្រើនរូបបានឮដំណឹងថា សាតិភិក្ខុកេវដ្តបុត្រ មានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់ នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ យ៉ាងនោះដែរ ។ ទើបភិក្ខុទាំងនោះ ចូលទៅរកសាតិភិក្ខុកេវដ្តបុត្រ លុះចូលទៅដល់ហើយ បានសួរសាតិភិក្ខុកេវដ្តបុត្រដូច្នេះថា ម្នាលអាវុសោសាតិ បានឮថា អ្នកមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែនឬ ។ សាតិភិក្ខុកេវដ្តបុត្រឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ វិញ្ញាណរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃ យ៉ាងណា ខ្ញុំក៏បានដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសម្តែង

ហើយ យ៉ាងនោះដែរ ដូច្នេះមែន ។ គ្រានោះ ភិក្ខុទាំងនោះមានបំណងនឹងដោះសាតិភិក្ខុកេវដ្តបុត្រឲ្យរួចចាកទិដ្ឋិអាក្រក់នុ៎ះ ទើបនិយាយពន្យល់ដាស់តឿនក្រើនរំលឹកថា ម្នាលអាវុសោសាតិ អ្នកកុំនិយាយយ៉ាងនេះឡើយ អ្នកកុំនិយាយបង្កាច់ព្រះមានព្រះភាគ ព្រោះថា ការដែលពោលបង្កាច់ព្រះមានព្រះភាគ មិនប្រពៃទេ ដ្បិតព្រះមានព្រះភាគ ព្រះអង្គមិនមានបន្ទូលយ៉ាងនេះឡើយ ម្នាលអាវុសោសាតិ ព្រះមានព្រះភាគសម្តែងហើយ ដោយអនេកបរិយាយថា វិញ្ញាណកើតព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃវិញ្ញាណក៏មិនមាន ។ សាតិភិក្ខុកេវដ្តបុត្រ កាលបើពួកភិក្ខុទាំងនោះនិយាយពន្យល់ដាស់តឿន ក្រើនរំលឹកយ៉ាងនេះហើយ ក៏នៅតែចូលចិត្តប្រកាន់ទិដ្ឋិអាក្រក់នោះដដែល ហើយនិយាយប្រកែកតាមកម្លាំងដូច្នេះថា ម្នាលអាវុសោទាំងឡាយ វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា ខ្ញុំក៏បានដឹងនូវធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះឯង ។

[ ៨១ ] កាលដែលភិក្ខុទាំងនោះ មិនអាចនឹងដោះសាតិភិក្ខុកេវដ្តបុត្រឲ្យរួចចាកទិដ្ឋិអាក្រក់នុ៎ះបានហើយ ទើបភិក្ខុទាំងអម្បាលនោះ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំនូវព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សាតិភិក្ខុកេវដ្តបុត្រ មានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ

អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បាន ដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ក៏យ៉ាងនោះដែរ បពិត្រ ព្រះអង្គដ៏ចម្រើន គ្រានោះ យើងខ្ញុំព្រះអង្គបាននាំគ្នា ចូលទៅរកសាតិភិក្ខុ កេវដ្ដបុត្រ លុះចូលទៅដល់ហើយ បានសួរសាតិភិក្ខុកេវដ្ដបុត្រដូច្នេះថា ម្នាល អាវុសោសាតិ បានឮថា អ្នកមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណ នេះ រមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាង ណា អាត្មាអញក៏បានដឹងច្បាស់ នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ក៏យ៉ាងនោះ ដូច្នេះពិតមែនឬ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលយើងខ្ញុំព្រះ អង្គសួរយ៉ាងនេះហើយ សាតិភិក្ខុកេវដ្ដបុត្រ ក៏បាននិយាយតបមកនឹងយើងខ្ញុំ ព្រះអង្គដូច្នេះថា ម្នាលអាវុសោទាំងឡាយ វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោល ទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា ខ្ញុំក៏បានដឹងច្បាស់ នូវធម៌ ដែលព្រះមានព្រះភាគសម្តែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែន បពិត្រព្រះ អង្គដ៏ចម្រើន លំដាប់នោះ យើងខ្ញុំព្រះអង្គមានចំណង់នឹងដោះ សាតិភិក្ខុកេវដ្ដ បុត្រ ឲ្យរួចចាកទិដ្ឋិអាក្រក់នោះ ទើបនាំគ្នានិយាយពន្យល់ដាស់តឿន ក្រើន រំលឹកថា ម្នាលអាវុសោសាតិ អ្នកកុំនិយាយយ៉ាងនេះឡើយ អ្នកកុំនិយាយ បន្តាប់ព្រះមានព្រះភាគ ព្រោះការនិយាយបន្តាប់ព្រះមានព្រះភាគ មិនប្រពៃទេ ដ្បិតព្រះមានព្រះភាគ ទ្រង់មិនមានព្រះបន្ទូលយ៉ាងនេះឡើយ ម្នាលអាវុសោ សាតិ ព្រះមានព្រះភាគ ទ្រង់សម្តែងហើយដោយអនេកបរិយាយថា វិញ្ញាណ កើតឡើងព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃ

វិញ្ញាណក៏មិនមាន បពិត្រព្រះអង្គដ៏ចម្រើន សាតិភិក្ខុកេវដ្ដបុត្រនោះ កាលបើយើងខ្ញុំព្រះអង្គបាននិយាយពន្យល់ជាស់តឿនក្រើនរំលឹកយ៉ាងនេះហើយ ក៏នៅតែចូលចិត្តប្រកាន់ទិដ្ឋិអាក្រក់នោះដដែល ហើយនិយាយប្រកែកតាមកម្លាំងថា ម្នាលអាវុសោទាំងឡាយ វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយយ៉ាងណា ខ្ញុំបានដឹងច្បាស់ នូវធម៌ដែលព្រះមានព្រះភាគសម្ដែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែន បពិត្រព្រះអង្គដ៏ចម្រើន កាលដែលយើងខ្ញុំព្រះអង្គ មិនអាចនឹងដោះសាតិភិក្ខុកេវដ្ដបុត្រ ឲ្យរួចចាកទិដ្ឋិអាក្រក់នេះបានហើយ ទើបយើងខ្ញុំព្រះអង្គ យកសេចក្ដីនេះមកក្រាបបង្គំទូលព្រះមានព្រះភាគ ។

[ ៨២ ] គ្រានោះ ព្រះមានព្រះភាគត្រាស់ហៅនូវភិក្ខុ ១ រូបមកថា ម្នាលភិក្ខុ ចូរអ្នកមកអាយ ចូរអ្នកទៅហៅនូវសាតិភិក្ខុកេវដ្ដបុត្រតាមពាក្យនៃតថាគតថា ម្នាលអាវុសោសាតិ ព្រះសាស្ដាទ្រង់ត្រាស់ហៅលោក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ ដូច្នេះហើយក៏ចូលទៅរកសាតិភិក្ខុកេវដ្ដបុត្រ លុះចូលទៅដល់ហើយ បាននិយាយទៅនឹងសាតិភិក្ខុកេវដ្ដបុត្រដូច្នេះថា ម្នាលអាវុសោសាតិ ព្រះសាស្ដាត្រាស់ហៅលោក ។ សាតិភិក្ខុកេវដ្ដបុត្រ ទទួលពាក្យភិក្ខុនោះថា ករុណាអាវុសោ ដូច្នេះហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ កាលបើសាតិភិក្ខុកេវដ្ដបុត្រអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលសាតិ

បានឮថា អ្នកមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា ខ្ញុំបានដឹងច្បាស់ នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែនឬ ។ សាតិភិក្ខុកេវដ្តបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណនេះរមែង ស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជារបស់ដទៃឡើយ យ៉ាងណា ខ្ញុំ ព្រះអង្គបានដឹងច្បាស់ នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ក៏យ៉ាង នោះដែរ ដូច្នេះមែន ។ ព្រះអង្គត្រាស់សួរថា ម្នាលសាតិ វិញ្ញាណនោះ តើ ដូចម្តេច ។ សាតិភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន សភាវៈណា ដែលនិយាយបាន អាចទទួលអារម្មណ៍បាន បុគ្គលរមែងសោយវិបាកនៃកម្ម ទាំងឡាយ ល្អ និងអាក្រក់ ព្រោះសភាវៈនោះ សភាវៈនោះ ( ហៅថា វិញ្ញាណ ) ។ ព្រះអង្គត្រាស់ថា ម្នាលមោឃបុរស អ្នកដឹងច្បាស់នូវធម៌ ដែលតថាគតសម្តែងហើយ យ៉ាងណា អំពីសម្នាក់បុគ្គលណា ម្នាលមោឃ បុរស ក្រែងតថាគតបានសម្តែងហើយ ដោយអនេកបរិយាយថា វិញ្ញាណ កើតឡើងព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃ វិញ្ញាណក៏មិនមានដូច្នោះទេឬ ម្នាលមោឃបុរស ហេតុដូចម្តេច ក៏បានជាអ្នក ពោលបង្កាច់តថាគតដោយគំនិតដែលខ្លួនប្រកាន់ខុសវិញ អ្នកឈ្មោះថាគាស់ រម្លើងនូវខ្លួនផង ឈ្មោះថា សោយនូវអកុសលដ៏ច្រើនផង ម្នាលមោឃបុរស ព្រោះថា គំនិតដែលប្រកាន់ខុសរបស់អ្នកនោះ នឹងប្រព្រឹត្តទៅដើម្បីមិនជា ប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលយូរអង្វែង ។

[ ៨៣ ] គ្រានោះឯង ព្រះមានព្រះភាគត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច សាតិភិក្ខុកេវដ្តបុត្រនេះ ឈ្មោះថាធ្វើឲ្យកក់ក្តៅក្នុងធម្មវិន័យនោះបានឬទេ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធ្វើដូចម្តេចនឹងបាន បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះមិនមែនដូច្នោះទេ ។ កាលដែលពួកភិក្ខុនិយាយយ៉ាងនេះហើយ សាតិភិក្ខុកេវដ្តបុត្រក៏នៅស្ងៀម អៀនខ្មាស ឱនកចុះ សំយុងមុខចុះ អង្គុយសញ្ជប់សញ្ជឹងមិនមានប្រាជ្ញា ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសាតិភិក្ខុកេវដ្តបុត្រ នៅស្ងៀម អៀនខ្មាស ឱនកចុះ សំយុងមុខចុះ អង្គុយសញ្ជប់សញ្ជឹងមិនមានប្រាជ្ញាហើយ ទើបត្រាស់សួរសាតិភិក្ខុកេវដ្តបុត្រថា ម្នាលមោឃបុរស អ្នកប្រាកដជានៅតែប្រកាន់ខ្ជាប់ដោយទិដ្ឋិអាក្រក់របស់ខ្លួននេះតែម្យ៉ាងឬ តថាគតនឹងអាលសាកសួរពួកភិក្ខុដែលនៅក្នុងទីនេះ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ សាតិភិក្ខុកេវដ្តបុត្រនេះ ពោលបង្អាច់តថាគត ដោយគំនិតដែលខ្លួនប្រកាន់ខុសផង ឈ្មោះថាគាស់រម្លើងនូវខ្លួនផង ឈ្មោះថាទទួលនូវអកុសលដ៏ច្រើនផង យ៉ាងណា ចំណែកអ្នកទាំងឡាយ នឹងយល់ច្បាស់នូវធម៌ដែលតថាគតសម្តែងហើយយ៉ាងនោះដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គមិនបានយល់ដូច្នោះទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគ បានសម្តែងប្រោសយើងខ្ញុំព្រះអង្គដោយអនេកបរិយាយថា វិញ្ញាណកើតឡើងព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃ

វិញ្ញាណក៏មិនមាន ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យអ្នកទាំង-ឡាយនោះត្រូវពិតហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ច្បាស់នូវធម៌ដែលតថាគតសម្តែងហើយយ៉ាងនេះ ជាការប្រពៃពិត ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគតបានសម្តែងហើយ ដោយអនេកបរិយាយថា វិញ្ញាណកើតឡើង ព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃវិញ្ញាណក៏មិនមាន បើដូច្នោះ សាតិភិក្ខុកេវដ្តបុត្រនេះ ពិតជាពោលបង្កាច់តថាគតដោយគំនិតដែលខ្លួនប្រកាន់ខុសផង ឈ្មោះថាគាស់រម្លើងនូវខ្លួនផង ឈ្មោះថាទទួលនូវអកុសលដ៏ច្រើនផង ព្រោះថា ការប្រកាន់ខុសរបស់មោឃបុរសនោះ នឹងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរអង្វែង ។

[ ៨៤ ] ម្នាលភិក្ខុទាំងឡាយ វិញ្ញាណកើតឡើងព្រោះអាស្រ័យបច្ច័យណាៗ ក៏ដល់នូវកិរិយារាប់តាមបច្ច័យនោះៗ ដូចវិញ្ញាណកើតឡើង ព្រោះអាស្រ័យភ្នែក និងរូប ដល់នូវកិរិយារាប់ថាចក្ខុវិញ្ញាណ ( ការដឹងដោយសារភ្នែក ) វិញ្ញាណកើតឡើងព្រោះអាស្រ័យត្រចៀក និងសំឡេង ដល់នូវកិរិយារាប់ថា សោតវិញ្ញាណ ( ការដឹងដោយសារត្រចៀក ) វិញ្ញាណកើតឡើងព្រោះអាស្រ័យច្រមុះ និងក្លិន ដល់នូវកិរិយារាប់ថាឃានវិញ្ញាណ ( ការដឹងដោយសារច្រមុះ ) វិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាត និងរស ដល់នូវកិរិយារាប់ថា ជិវ្ហាវិញ្ញាណ ( ការដឹងដោយសារអណ្តាត ) វិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយ និងរបស់ដែលប៉ះនឹងកាយ ដល់នូវកិរិយារាប់ថាកាយវិញ្ញាណ ( ការដឹងដោយសារកាយ ) វិញ្ញាណកើតឡើង ព្រោះអាស្រ័យ

ចិត្ត និងធម្មារម្មណ៍ ដល់នូវកិរិយារាប់ថា មនោវិញ្ញាណ ( ការដឹងដោយសារចិត្ត ) ។ ម្នាលភិក្ខុទាំងឡាយ ដូចជាភ្លើងឆេះ អាស្រ័យនឹងវត្ថុណាៗ ក៏ដល់នូវកិរិយារាប់តាមវត្ថុនោះៗ ដូចជាភ្លើងឆេះ ព្រោះអាស្រ័យឧស ដល់នូវកិរិយារាប់ថា ភ្លើងឧស ភ្លើងឆេះ ព្រោះអាស្រ័យប្រឆេះ ឬបុ៉យ ដល់នូវកិរិយារាប់ថា ភ្លើងបុ៉យ ភ្លើងឆេះព្រោះអាស្រ័យស្មៅ ដល់នូវកិរិយារាប់ថា ភ្លើងស្មៅ ភ្លើងឆេះព្រោះអាស្រ័យអាចម៍គោ ដល់នូវកិរិយារាប់ថា ភ្លើងអាចម៍គោ ភ្លើងឆេះព្រោះអាស្រ័យអង្កាម ដល់នូវកិរិយារាប់ថា ភ្លើងអង្កាម ភ្លើងឆេះព្រោះអាស្រ័យសំរាម ដល់នូវកិរិយារាប់ថា ភ្លើងសំរាម យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណកើតឡើង ព្រោះអាស្រ័យនឹងបច្ច័យណាៗ ក៏ដល់នូវកិរិយារាប់តាមបច្ច័យនោះៗ ដូចជាវិញ្ញាណកើតឡើងព្រោះអាស្រ័យភ្នែក និងរូប ដល់នូវកិរិយារាប់ថា ចក្ខុវិញ្ញាណ វិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀក និងសំឡេង ដល់នូវកិរិយារាប់ថា សោតវិញ្ញាណ វិញ្ញាណកើតឡើងព្រោះអាស្រ័យច្រមុះ និងក្លិន ដល់នូវកិរិយារាប់ថា ឃានវិញ្ញាណ វិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាត និងរស ដល់នូវកិរិយារាប់ថា ជិវ្ហាវិញ្ញាណ វិញ្ញាណកើតឡើងព្រោះអាស្រ័យកាយ និងរបស់ដែលប៉ះដោយកាយ ដល់នូវកិរិយារាប់ថា កាយវិញ្ញាណ វិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្ត និងធម្មារម្មណ៍ ដល់នូវកិរិយារាប់ថា មនោវិញ្ញាណ យ៉ាងនោះដែរ ។

[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញនូវខន្ធបញ្ចកៈនេះ

ដែលកើតឡើងហើយឬទេ ។ ពួកភិក្ខុក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញថា ខន្ធបញ្ចកៈនោះ កើតឡើងព្រោះតែអាហារដូច្នោះឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយឃើញថា ខន្ធបញ្ចកៈនោះដែលកើតឡើងហើយ រមែងរលត់ទៅវិញជាធម្មតា ព្រោះរលត់អាហារនោះដែរឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ វិចិកិច្ឆាតែងកើតឡើង ព្រោះសេចក្តីសង្ស័យថា ខន្ធបញ្ចកៈនេះកើតហើយ ឬមិនកើតទេ ដូច្នេះដែរឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ វិចិកិច្ឆាកើតឡើង ព្រោះសេចក្តីសង្ស័យថា ខន្ធបញ្ចកៈតែងកើតឡើង ព្រោះអាហារនោះ ឬមិនមែនទេ ដូច្នេះដែរឬ ។ ព្រះករុណាព្រះអង្គ ។ វិចិកិច្ឆាកើតឡើងព្រោះសេចក្តីសង្ស័យថា ខន្ធបញ្ចកៈដែលកើតហើយ រលត់ទៅវិញជាធម្មតា ព្រោះតែរលត់អាហារនោះ ឬមិនមែន ដូច្នេះឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃតាមពិតថា ខន្ធបញ្ចកៈនេះកើតហើយដូច្នេះ បុគ្គលនោះ ឈ្មោះថាលះបង់វិចិកិច្ឆាបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គល ឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃតាមពិតថា ខន្ធបញ្ចកៈកើតឡើងព្រោះអាហារនោះ ដូច្នេះ បុគ្គលនោះ ឈ្មោះថា លះបង់វិចិកិច្ឆាបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃតាមពិតថា ខន្ធបញ្ចកៈដែលកើតហើយ រមែងរលត់ទៅវិញជាធម្មតា ព្រោះរលត់អាហារនោះ ដូច្នេះ បុគ្គលនោះ ឈ្មោះថា លះបង់វិចិកិច្ឆា

បានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនមានវិចិកិច្ឆាក្នុងខន្ធបញ្ចកៈនុ៎ះថា ខន្ធបញ្ចកៈនេះកើតហើយ ដូច្នេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនមានវិចិកិច្ឆា ក្នុងខន្ធបញ្ចកៈនោះថា ខន្ធបញ្ចកៈនោះ កើតឡើងព្រោះអាហារដូច្នេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនមានវិចិកិច្ឆា ក្នុងខន្ធបញ្ចកៈនុ៎ះថា ខន្ធបញ្ចកៈដែលកើតឡើង រមែងរលត់ទៅវិញជាធម្មតា ព្រោះរលត់អាហារនោះ ដូច្នេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ត្រូវដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតថា ខន្ធបញ្ចកៈនេះ កើតហើយដូច្នេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ឃើញត្រូវដោយបញ្ញាដ៏ល្អតាមពិតថា ខន្ធបញ្ចកៈកើតឡើងព្រោះអាហារដូច្នេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ឃើញត្រូវដោយប្រាជ្ញា ដ៏ប្រពៃតាមសេចក្តីពិតថា ខន្ធបញ្ចកៈដែលកើតហើយ រមែងរលត់ទៅវិញជាធម្មតា ព្រោះរលត់អាហារនោះដូច្នេះឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ ជាប់ជំពាក់ រីករាយ ក្តួចកាន់ រាប់អានទិដ្ឋិនេះថា បរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ដោយតណ្ហា និងទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយយល់ច្បាស់ នូវធម៌មានឧបមាដូចជាផែ ដែលតថាគតសំដែងហើយ ដើម្បីប្រយោជន៍ នឹងវេ្ចនចេញ ( ចាកឱឃៈទាំង ៤ ) មិនមែនដើម្បីប្រយោជន៍ នឹងប្រកាន់ ( ខន្ធបញ្ចកៈ ) ខ្លះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន

មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមិនជាប់ជំពាក់ មិនរីករាយ មិនក្តួចកាន់ មិនរាប់អានទិដ្ឋិនេះថា បរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ដោយអំណាចតណ្ហា និងទិដ្ឋិទេ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយយល់ច្បាស់ នូវធម៌មានឧបមាដូចជាផែ ដែលតថាគតសម្តែងហើយ ដើម្បីនឹងរើខ្លួនចេញ ( ចាកឱឃៈទាំង ៤ ) មិនមែនប្រយោជន៍នឹងប្រកាន់ (ខន្ធបញ្ចកៈ) ខ្លះឬទេ ។ ព្រះករុណាព្រះអង្គ ។

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ អាហារដែលប្រព្រឹត្តទៅដើម្បីតាំងនៅមាំរបស់ពួកសត្វដែលកើតហើយផង ប្រព្រឹត្តទៅដើម្បីអនុគ្រោះដល់ពួកសត្វដែលកំពុងកើតផង នេះមាន ៤ ប្រការ ។ អាហារទាំង ៤ ប្រការ តើដូចម្តេច ។ គឺ កវឡិង្ការាហារដែលគ្រោតគ្រាត ឬល្អិតជាទី១ ផស្សាហារជាទី២ មនោសញ្ចេតនាហារជាទី៣ វិញ្ញាណាហារជាទី៤ ម្នាលភិក្ខុទាំងឡាយ ចុះអាហារទាំង ៤ នេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ អាហារទាំង ៤ នេះ មានតណ្ហាជាហេតុ មានតណ្ហានាំឲ្យកើត មានតណ្ហាជាកំណើត មានតណ្ហាជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏តណ្ហានេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ តណ្ហាមានវេទនាជាហេតុ មានវេទនានាំឲ្យកើត មានវេទនាជាកំណើត មានវេទនាជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏វេទនានេះ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ វេទនាមានផស្សៈជាហេតុ មានផស្សៈនាំឲ្យកើត មានផស្សៈជាកំណើត មានផស្សៈជាដែន

កើត ។ ម្នាលភិក្ខុទាំងឡាយ ក៏ផស្សៈនេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ ផស្សៈមានសឡាយតនៈជាហេតុ មានសឡាយតនៈនាំឲ្យកើត មានសឡាយតនៈជាកំណើត មានសឡាយតនៈជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏សឡាយតនៈនេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ សឡាយតនៈមាននាមរូបជាហេតុ មាននាមរូបនាំឲ្យកើត មាននាមរូបជាកំណើត មាននាមរូបជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏នាមរូបនេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ នាមរូបមានវិញ្ញាណជាហេតុ មានវិញ្ញាណនាំឲ្យកើត មានវិញ្ញាណជាកំណើត មានវិញ្ញាណជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏វិញ្ញាណនេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ វិញ្ញាណមានសង្ខារជាហេតុ មានសង្ខារនាំឲ្យកើត មានសង្ខារជាកំណើត មានសង្ខារជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ ក៏សង្ខារទាំងឡាយនេះមានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត ។ សង្ខារទាំងឡាយមានអវិជ្ជាជាហេតុ មានអវិជ្ជានាំឲ្យកើត មានអវិជ្ជាជាកំណើត មានអវិជ្ជាជាដែនកើត ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមានព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យ នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមានព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមានព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ ឧបាទាន

កើតមានព្រោះតណ្ហាជាបច្ច័យ ភពកើតមានព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ សេចក្តីចាស់ស្លាប់ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ការសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងការចង្អៀតចង្អល់ទាំងឡាយ ក៏កើតមានព្រម ឯកិរិយាកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះ ដូច្នេះឯង ។

[ ៨៧ ] ពាក្យថា ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះជរាមរណៈ កើតមានព្រោះជាតិជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនោះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ជរាមរណៈកើតមានព្រោះជាតិជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះ យ៉ាងនេះថា ជរាមរណៈកើតមានព្រោះជាតិជាបច្ច័យដែរ ។ ពាក្យថា ជាតិកើតមាន ព្រោះភពជាបច្ច័យ ដូច្នេះនេះ តថាគតបានសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះជាតិកើតមានព្រោះភពជាបច្ច័យមិនមានក្នុងខន្ធបញ្ចកៈនោះទេ ឬដោយប្រការដូចម្តេច ។បពិត្រព្រះអង្គដ៏ចម្រើន ជាតិកើតមានព្រោះភពជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះ យ៉ាងនេះថា ជាតិកើតមានព្រោះភពជាបច្ច័យដែរ ។ ពាក្យថា ភពកើតមានព្រោះឧបាទានជាបច្ច័យដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះភពកើតមាន ព្រោះឧបាទានជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនោះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ភពកើតមានព្រោះឧបាទានជាបច្ច័យមែន

ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្ដីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះ យ៉ាងនេះថា ភពកើតមានព្រោះឧបាទានជាបច្ច័យដែរ ។ ពាក្យថា ឧបាទានកើតមានព្រោះតណ្ហាជាបច្ច័យដូច្នេះនេះ តថាគតបានសម្ដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះឧបាទានកើតមានព្រោះតណ្ហាជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្ដីយល់ឃើញក្នុងខន្ធបញ្ចកៈនោះយ៉ាងនេះថា ឧបាទានកើតមានព្រោះតណ្ហាជាបច្ច័យដែរ ។ ពាក្យថា តណ្ហាកើតមានព្រោះវេទនាជាបច្ច័យដូច្នេះនេះ តថាគតសម្ដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហាកើតមានព្រោះវេទនាជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើនតណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្ដីយល់ឃើញ ក្នុងខន្ធ-បញ្ចកៈនុ៎ះយ៉ាងនេះថា តណ្ហាកើតមានព្រោះវេទនាជាបច្ច័យដែរ ។ ពាក្យថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យដូច្នេះនេះ តថាគតសម្ដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះវេទនាកើតមានព្រោះផស្សៈជាបច្ច័យ មិនមានក្នុងខន្ធ-បញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន វេទនាកើតមានព្រោះផស្សៈជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្ដីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យដែរ ។ ពាក្យថា ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ ដូច្នេះនេះ តថាគតសម្ដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះផស្សៈកើតមានព្រោះសឡាយតនៈ

ជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ផស្សៈកើតមានព្រោះសឡាយតនៈជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា ផស្សៈកើតមានព្រោះសឡាយតនៈជាបច្ច័យដែរ ។ ពាក្យថាសឡាយតនៈកើតមានព្រោះនាមរូបជាបច្ច័យ ដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយចុះសឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យមិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សឡាយតនៈកើតមានព្រោះនាមរូបជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សឡាយតនៈកើតមានព្រោះនាមរូបជាបច្ច័យដែរ ។ ពាក្យថា នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យដូច្នេះនេះ តថាគតបានសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយចុះនាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យមិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះ យ៉ាងនេះថា នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យដែរ ។ ពាក្យថា វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យដូច្នេះនេះ តថាគតបានសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះវិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យមិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះ យ៉ាងនេះថា

វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យដែរ ។ ពាក្យថា សង្ខារកើតមានព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះនេះ តថាគតសំដែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សង្ខារកើតមានព្រោះអវិជ្ជាជាបច្ច័យ ដូច្នេះមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យដែរ ។

[ ៨៨ ] ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យនុ៎ះត្រូវល្អណាស់ហើយ ម្នាលភិក្ខុទាំងឡាយ ពួកអ្នកក៏និយាយយ៉ាងនេះ តថាគតក៏និយាយយ៉ាងនេះ ដូច្នេះដែរ កាលបើបច្ច័យមានអវិជ្ជាជាដើមនេះកើតហើយ ផលមានសង្ខារជាដើមនេះក៏កើតឡើង ផលមានសង្ខារជាដើមនេះកើតឡើង ព្រោះកើតឡើងនៃបច្ច័យមានអវិជ្ជាជាដើមនេះ ដ្បិតថា សង្ខារទាំងឡាយកើតមានព្រោះតែអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមានព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមានព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ ឧបាទានកើតមានព្រោះតណ្ហាជាបច្ច័យ ភពកើតមានព្រោះឧបាទានជាបច្ច័យ ជាតិកើតមានព្រោះភពជាបច្ច័យ សេចក្តីចាស់ស្លាប់ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ទាំងឡាយ ក៏កើតមាន ព្រោះជាតិជាបច្ច័យ កិរិយាកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះដូច្នេះឯង ។ មួយទៀត សេចក្តីរលត់

នៃសង្ខារ ព្រោះតែវិនាស និងរលត់មិនសល់នៃអវិជ្ជា សេចក្តីរលត់នៃវិញ្ញាណ ព្រោះរលត់សង្ខារ សេចក្តីរលត់នៃនាមរូបព្រោះរលត់វិញ្ញាណ សេចក្តីរលត់នៃសឡាយតនៈព្រោះរលត់នាមរូប សេចក្តីរលត់នៃផស្សៈព្រោះរលត់សឡាយតនៈ សេចក្តីរលត់នៃវេទនាព្រោះរលត់ផស្សៈ សេចក្តីរលត់នៃតណ្ហាព្រោះរលត់វេទនា សេចក្តីរលត់នៃឧបាទានព្រោះរលត់តណ្ហា សេចក្តីរលត់នៃភពព្រោះរលត់ឧបាទាន សេចក្តីរលត់នៃជាតិព្រោះរលត់ភព សេចក្តីចាស់ស្លាប់ ( រលត់ ) ព្រោះរលត់ជាតិ សោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ក៏សឹងតែរលត់ទៅ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះដូច្នេះឯង ។

[ ៨៩ ] ពាក្យថា សេចក្តីរលត់នៃជរាមរណៈ ព្រោះរលត់ជាតិដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់ជរាមរណៈ ព្រោះរលត់ជាតិ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់នៃជរាមរណៈព្រោះរលត់ជាតិមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះ យ៉ាងនេះថា សេចក្តីរលត់នៃជរាមរណៈព្រោះរលត់ជាតិ ។ ពាក្យថា សេចក្តីរលត់នៃជាតិព្រោះរលត់ភពដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់នៃជាតិ ព្រោះរលត់ភព មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់នៃជាតិ ព្រោះរលត់ភពមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះ

យ៉ាងនេះថា សេចក្តីរលត់នៃជាតិព្រោះរលត់ភពដែរ ។ ពាក្យថា សេចក្តីរលត់នៃភព ព្រោះរលត់ឧបាទាន ដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់ភពព្រោះរលត់ឧបាទាន មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់ភពព្រោះរលត់ឧបាទានមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់ភពព្រោះរលត់ឧបាទានដែរ ។ ពាក្យថា សេចក្តីរលត់ឧបាទានព្រោះរលត់តណ្ហា ដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់ឧបាទានព្រោះរលត់តណ្ហា មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់ឧបាទានព្រោះរលត់តណ្ហាមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់ឧបាទានព្រោះរលត់តណ្ហាដែរ ។ ពាក្យថា សេចក្តីរលត់តណ្ហា ព្រោះរលត់វេទនា ដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់តណ្ហា ព្រោះរលត់វេទនា មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់តណ្ហាព្រោះរលត់វេទនា ដូច្នេះមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះ យ៉ាងនេះថា សេចក្តីរលត់តណ្ហាព្រោះរលត់វេទនាដែរ ។ ពាក្យថា សេចក្តីរលត់វេទនាព្រោះរលត់ផស្សៈ ដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់វេទនា ព្រោះរលត់ផស្សៈ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូច

ម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់វេទនាព្រោះរលត់ផស្សៈមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះ យ៉ាងនេះថា សេចក្តីរលត់វេទនា ព្រោះរលត់ផស្សៈដែរ ។ ពាក្យថា សេចក្តីរលត់ផស្សៈ ព្រោះរលត់សឡាយតនៈ ដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំង-ឡាយ ចុះសេចក្តីរលត់ផស្សៈព្រោះរលត់សឡាយតនៈ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់ផស្សៈព្រោះរលត់សឡាយតនៈមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់ផស្សៈ ព្រោះរលត់សឡាយតនៈដែរ ។ ពាក្យថា សេចក្តីរលត់សឡាយតនៈ ព្រោះរលត់នាមរូប ដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់សឡាយតនៈព្រោះរលត់នាមរូប មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់សឡាយតនៈព្រោះរលត់នាមរូបមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះ យ៉ាងនេះថា សេចក្តីរលត់សឡាយតនៈព្រោះរលត់នាមរូបដែរ ។ ពាក្យថា សេចក្តីរលត់នាមរូបព្រោះរលត់វិញ្ញាណ ដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់នាមរូបព្រោះរលត់វិញ្ញាណ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់នាមរូប ព្រោះរលត់វិញ្ញាណមែន ទាំងយើងខ្ញុំព្រះអង្គក៏មានសេចក្តីយល់ឃើញក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់នាមរូបព្រោះរលត់វិញ្ញាណដែរ ។

ពាក្យថា សេចក្តីរលត់វិញ្ញាណ ព្រោះរលត់សង្ខារដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់វិញ្ញាណ ព្រោះរលត់សង្ខារ មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់វិញ្ញាណ ព្រោះរលត់សង្ខារមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់វិញ្ញាណព្រោះរលត់សង្ខារដែរ ។ ពាក្យថា សេចក្តីរលត់សង្ខារ ព្រោះរលត់អវិជ្ជាដូច្នេះនេះ តថាគតសម្តែងហើយមែន ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់សង្ខារព្រោះរលត់អវិជ្ជា មិនមានក្នុងខន្ធបញ្ចកៈនុ៎ះទេ ឬដោយប្រការដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីរលត់សង្ខារព្រោះរលត់អវិជ្ជាមែន ទាំងយើងខ្ញុំព្រះអង្គ ក៏មានសេចក្តីយល់ឃើញ ក្នុងខន្ធបញ្ចកៈនុ៎ះយ៉ាងនេះថា សេចក្តីរលត់សង្ខារព្រោះរលត់អវិជ្ជាដែរ ។

[ ៩០ ] ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យដែលអ្នកទាំងឡាយ និយាយនុ៎ះត្រូវល្អណាស់ហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយក៏និយាយយ៉ាងនេះ តថាគតក៏និយាយយ៉ាងនេះ ដូច្នេះដែរ កាលបើបច្ច័យមានអវិជ្ជាជាដើមនេះ មិនមានហើយ ផលមានសង្ខារជាដើមនេះ ក៏មិនមាន ផលមានសង្ខារជាដើមនេះ តែងរលត់ទៅមិនសល់ ព្រោះរលត់នៃបច្ច័យមានអវិជ្ជាជាដើមនេះ ដ្បិតថា សេចក្តីរលត់នៃសង្ខារ ព្រោះរលត់អវិជ្ជា សេចក្តីរលត់នៃវិញ្ញាណ ព្រោះរលត់សង្ខារ សេចក្តីរលត់នៃនាមរូប ព្រោះរលត់វិញ្ញាណ សេចក្តីរលត់នៃសឡាយតនៈ ព្រោះរលត់នាមរូប សេចក្តីរលត់នៃ

ផស្សៈ ព្រោះរលត់សឡាយតនៈ សេចក្តីរលត់នៃវេទនា ព្រោះរលត់ផស្សៈ សេចក្តីរលត់នៃតណ្ហា ព្រោះរលត់វេទនា សេចក្តីរលត់នៃឧបាទាន ព្រោះរលត់តណ្ហា សេចក្តីរលត់ភព ព្រោះរលត់ឧបាទាន សេចក្តីរលត់ជាតិ ព្រោះរលត់ភព សេចក្តីចាស់ស្លាប់ ( រលត់ ) ព្រោះរលត់ជាតិ ការយំសោក ការខ្សឹកខ្សួល ការលំបាកកាយ ការលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ទាំងឡាយ ក៏សឹងតែរលត់ទៅមិនសល់ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។

[ ៩១ ] ម្នាលភិក្ខុទាំងឡាយ ចុះកាលបើអ្នកទាំងឡាយ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ នឹងស្រាវជ្រាវនូវខន្ធ ធាតុ អាយតនៈ ជាចំណែកខាងដើម គឺអតីតកាលថា ក្នុងកាលកន្លងទៅហើយ យើងធ្លាប់បានកើតឬហ្ន៎ ឬក្នុងកាលកន្លងទៅហើយ យើងមិនធ្លាប់កើតទេ ក្នុងកាលកន្លងទៅហើយ យើងបានកើតជាជាតិអ្វីហ្ន៎ ក្នុងកាលកន្លងទៅហើយ យើងបានកើតជាមនុស្ស មានទ្រង់ទ្រាយដូចម្តេច ក្នុងកាលកន្លងទៅហើយ យើងកើតជាជាតិអ្វី បានជាអ្វីដូច្នេះបានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះ យើងខ្ញុំព្រះអង្គស្រាវជ្រាវរកមិនឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះកាលបើអ្នកទាំងឡាយ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ នឹងស្រាវជ្រាវរកខន្ធ ធាតុ អាយតនៈ ជាចំណែកខាងមុខ គឺអនាគតកាលថា ក្នុងកាលជាអនាគត យើងនឹងកើតឬហ្ន៎ ក្នុងកាលជាអនាគត យើងមិនកើតទៀតទេ ក្នុងកាលជាអនាគត យើងនឹងកើតជាអ្វីហ្ន៎ ក្នុងកាលជាអនាគត យើងនឹងកើតជាមនុស្សមានទ្រង់ទ្រាយ

ដូចម្តេចហ្ន៎ ក្នុងកាលជាអនាគត យើងនឹងកើតជាជាតិអ្វី បានជាអ្វីដូច្នេះ បានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះ យើងខ្ញុំព្រះអង្គស្រាវជ្រាវរកមិនឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះបើអ្នកទាំងឡាយដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ គប្បីសង្ស័យចំពោះខន្ធ ធាតុ អាយតនៈ ជាចំណែកខាងក្នុង ប្រារព្ធនូវកាលជាបច្ចុប្បន្នក្នុងកាលឥឡូវនេះថា អាត្មាអញកើតទៀតឬមិនកើតទេ អាត្មាអញកើតជាជាតិអ្វីហ្ន៎ អាត្មាអញកើតជាមនុស្សមានទ្រង់ទ្រាយដូចម្តេច សត្វនេះមកអំពីទីណា សត្វនោះនឹងទៅកើតក្នុងទីណាវិញ ដូច្នេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនោះ យើងខ្ញុំព្រះអង្គមិនបានសង្ស័យដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ គប្បីនិយាយយ៉ាងនេះថា ព្រះសាស្តាជាគ្រូយើង យើងត្រូវនិយាយយ៉ាងនេះ ដោយសេចក្តីគោរពចំពោះព្រះសាស្តាដូច្នេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ យើងខ្ញុំព្រះអង្គ មិនដែលនិយាយទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ គប្បីនិយាយយ៉ាងនេះថា សមណៈគឺព្រះពុទ្ធនិយាយយ៉ាងនេះ ចំណែកយើងទាំងឡាយជាសមណៈដែរ មិនត្រូវនិយាយយ៉ាងនេះ ដូច្នេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនោះយើងខ្ញុំព្រះអង្គ មិនដែលនិយាយទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ គប្បីឧទ្ទិសចំពោះសាស្តាឯទៀតដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គមិនបានឧទ្ទិសទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយដឹងយ៉ាង

នេះ ឃើញយ៉ាងនេះហើយ គប្បីប្រកាន់នូវវត្តសមាទាន សេចក្តីភ្ញាក់ផ្អើល ដោយទិដ្ឋិ និងទិដ្ឋមង្គល សុតមង្គល មុតមង្គលជារបស់ពួកតិរ្ថិយសមណៈ និងព្រាហ្មណសមណៈជាច្រើនដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គមិនបានប្រកាន់ទេ ។ ម្នាលភិក្ខុទាំងឡាយ ហេតុណាមួយ ដែលអ្នកទាំងឡាយស្គាល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯង អ្នកទាំងឡាយគប្បីនិយាយហេតុនោះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គនិយាយដែរ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យដែលអ្នកទាំងឡាយនិយាយនោះត្រូវល្អណាស់ហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ដែលតថាគតនាំចូលទៅ ( កាន់ព្រះនិព្វាន ) ដោយធម៌ដែលគួរឃើញច្បាស់ខ្លួនឯង ជាធម៌មិនរង់ចាំកាល ជាធម៌មានអាការដូចជាហៅបុគ្គលមកចង្អុលប្រាប់ ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តរបស់ខ្លួន ម្នាលភិក្ខុទាំងឡាយ ធម៌នេះជាធម៌គួរឃើញច្បាស់ខ្លួនឯង ជាធម៌មិនរង់ចាំកាល ជាធម៌មានអាការដូចជាហៅបុគ្គលមកប្រាប់ ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តរបស់ខ្លួន ហេតុដូច្នោះ បានជាតថាគតពោលសំដៅត្រង់ហេតុ ដែលអ្នកទាំងឡាយដឹងច្បាស់ដោយខ្លួនឯងនោះ ។

[ ៩២ ] ម្នាលភិក្ខុទាំងឡាយ កិរិយាចុះចាប់បដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃ ព្រោះប្រជុំហេតុ ៣ ប្រការ ។ ក្នុងសត្វលោកនេះ មាតាបិតាមក

ប្រជុំគ្នាហើយ តែមាតាជាស្រីមិនមានរដូវផង សត្វដែលគួរកើតក្នុងផ្ទៃនោះ ក៏មិនមានប្រាកដ ក្នុងឱកាសនោះផង កិរិយាចុះចាប់បដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃ ក៏មិនទាន់មាននៅឡើយ ។ ក្នុងសត្វលោកនេះ មាតាបិតាមកប្រជុំគ្នាហើយផង មាតាជាស្រីមានរដូវផង តែសត្វដែលគួរកើត ក៏មិនមានប្រាកដក្នុងឱកាសនោះ កិរិយាចុះចាប់បដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃ ក៏មិនទាន់មាននៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែកាលណា មាតាបិតាមកប្រជុំគ្នាផង មាតាជាស្រីមានរដូវផង សត្វដែលគួរកើតក៏មានប្រាកដក្នុងឱកាសនោះផង លុះប្រជុំហេតុទាំង ៣ ប្រការនេះឯង ទើបសត្វចុះចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាបាន ។ ម្នាលភិក្ខុទាំងឡាយ មាតាពគភ៌នោះដោយផ្ទៃ អស់ខែ ៩ ឬខែ ១០ ដោយសេចក្តីសង្ស័យ ( ក្នុងជីវិត ) ជាច្រើន ម្នាលភិក្ខុទាំងឡាយ លុះកន្លងខែ ៩ ឬខែ ១០ ទៅ មាតាក៏ប្រសូតគភ៌នោះ ដូចជាភារៈធ្ងន់ដោយសេចក្តីសង្ស័យជាច្រើន កាលបើគភ៌ដូចជាភារៈធ្ងន់នោះ ប្រសូតរួចហើយ ក៏ចិញ្ចឹមដោយឈាម ( គឺទឹកដោះ ) របស់ខ្លួន ។

[ ៩៣ ] ម្នាលភិក្ខុទាំងឡាយ ទឹកដោះរបស់មាតាណា ដែលតថាគតពោលហើយ ក្នុងអរិយវិន័យ ទឹកដោះនុ៎ះ គឺឈាមហ្នឹងឯង ។ ម្នាលភិក្ខុទាំង-ឡាយ កុមារនោះឯង អាស្រ័យនូវការចម្រើនធំឡើង អាស្រ័យនូវកិរិយាចាស់នៃឥន្ទ្រិយទាំងឡាយ ( គឺចាស់ខែឆ្នាំ ) ក៏លេងនូវល្បែងទាំងឡាយជាមួយនឹងពួកកុមារ គឺលេងកូនទន្គ័ល ហ៊ីង ដាំដូង កង្ហារ វាល់ដីខ្សាច់ កូនរទេះ កូនធ្នូ ។ ម្នាលភិក្ខុទាំងឡាយ កុមារនោះឯង អាស្រ័យនូវសេចក្តីចម្រើន

ធំឡើង អាស្រ័យនូវកិរិយាចាស់នៃឥន្ទ្រិយទាំងឡាយ ហើយក៏ឆ្អែតស្កប់ស្កល់ រីករាយសប្បាយ ត្រេកត្រអាលដោយកាមគុណទាំង ៥ គឺរូបដែលគប្បីស្គាល់ ដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួរឲ្យកើតតម្រេក និងគួរឲ្យស្រឡាញ់ សំឡេងដែលគប្បីដឹង ដោយត្រចៀក ... ក្លិនដែលគប្បីដឹងដោយច្រមុះ ... រសដែលគប្បីដឹងដោយ អណ្ដាត ... ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយជាទីប្រាថ្នា ជាទីត្រេកអរ ជាទី ពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួរឲ្យកើតតម្រេក និង គួរឲ្យស្រឡាញ់ ។ កុមារនោះ ឃើញរូបដោយភ្នែក ក៏កើតតម្រេកក្នុងរូប ដែលគួរស្រឡាញ់ កើតបដិឃៈក្នុងរូបដែលគួរស្អប់ មានសតិក្នុងកាយមិន បានតាំងមាំ មានចិត្តរំកើប ( ចិត្តជាអកុសល ) ផង ធម៌ទាំងឡាយជាអកុ- សលដ៏លាមករបស់កុមារនោះ រមែងរលត់ទៅមិនសល់ក្នុងផលសមាបត្តិណា ក៏មិនបានដឹងច្បាស់នូវផលសមាបត្តិ គឺ ចេតោវិមុត្តិ បញ្ញាវិមុត្តិនោះ តាម សេចក្ដីពិតផង ។ កុមារនោះ ដល់ព្រមដោយតម្រេក និងសេចក្ដីក្រេវក្រោធ យ៉ាងនេះហើយ រមែងសោយនូវវេទនាណាមួយ ជាសុខ ឬទុក្ខ ឬមិនទុក្ខ មិនសុខ ។ កុមារនោះ តែងត្រេកអរនិយាយសរសើរ ប្រកាន់វេទនានោះ ( ដោយអំណាចតណ្ហា ) ។ កាលបើកុមារនោះ ត្រេកអរនិយាយសរសើរ ប្រកាន់វេទនានោះហើយ ក៏កើតទៅជាតម្រេក កាលបើតម្រេកក្នុងវេទនាទាំង- ឡាយមានហើយ ឧបាទានក៏កើតឡើងដល់កុមារនោះ ព្រោះតម្រេកនោះ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ សេចក្ដី

ចាស់ស្លាប់កើតមាន ព្រោះជាតិជាបច្ច័យ ការសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ក៏កើតមានព្រម កិរិយាកើតឡើងនៃកង ទុក្ខទាំងអស់នេះ រមែងមានដោយហេតុយ៉ាងនេះឯង ។ កុមារនោះ ឮសំឡេង ដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ ត្រូវនូវផោដ្ឋព្វៈដោយកាយ ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ ក៏ កើតតម្រេកក្នុងធម្មារម្មណ៍ដែលគួរស្រឡាញ់ កើតបដិឃៈក្នុងធម្មារម្មណ៍ ដែលគួរស្អប់ផង សតិក្នុងកាយមិនតាំងខ្ជាប់ មានចិត្តជាអកុសលផង ធម៌ ទាំងឡាយជាអកុសល ដ៏លាមករបស់កុមារនោះ រមែងរលត់ទៅមិនសល់ ក្នុងផលសមាបត្តិណា ក៏មិនបានដឹងច្បាស់នូវផលសមាបត្តិ គឺ ចេតោវិមុត្តិ បញ្ញាវិមុត្តិនេះ តាមសេចក្តីពិតផង ។ កុមារនោះ ដល់ព្រមដោយតម្រេក និង សេចក្តីក្រេវក្រោធយ៉ាងនេះហើយ រមែងទទួលនូវវេទនាណាមួយ ជាសុខ ឬ ជាទុក្ខ ឬមិនទុក្ខមិនសុខ ។ កុមារនោះ តែងត្រេកអរ និយាយសរសើរ ប្រកាន់វេទនានោះ ។ កាលកុមារនោះ ត្រេកអរនិយាយសរសើរ ប្រកាន់ វេទនានោះហើយ តម្រេកក៏កើតឡើង កាលបើតម្រេកក្នុងវេទនាទាំងឡាយ មានហើយ ឧបាទានក៏កើតឡើងដល់កុមារនោះ ព្រោះតម្រេកនោះ ភពកើត មាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមានព្រោះភពជាបច្ច័យ សេចក្តីចាស់ ស្លាប់ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ការសោក ការខ្សឹកខ្សួល ការលំបាក កាយ ការលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏កើតព្រម កិរិយាកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានដោយប្រការដូច្នេះឯង ។

[ ៩៤ ] ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ មានដំណើរល្អទៅកាន់ព្រះនិព្វាន ជ្រាបច្បាស់នូវត្រៃលោក ជាបុគ្គលប្រសើរបំផុត ជាសារថីទូន្មាននូវបុរស ជាគ្រូនៃពួកទេវតា និងមនុស្ស ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ចធម៌ ផ្សែងត្រឡប់មកកាន់ត្រៃភពហើយ ព្រះអង្គកើតឡើងក្នុងលោកនេះ ទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញា ចំពោះព្រះអង្គនូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយប្រកាស ព្រះអង្គសម្តែងធម៌មានលម្អបទដើម មានលម្អបទកណ្តាល និងបទចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏បរិសុទ្ធបរិបូណ៌គ្រប់ទាំងអស់ ។ គហបតីក្តី កូនរបស់គហបតីក្តី មហាជនដែលកើតខាងក្រោយក្នុងត្រកូលណាមួយក្តី រមែងស្តាប់ធម៌នោះ ។ លុះគហបតីជាដើមនោះ ស្តាប់ធម៌នោះហើយ ក៏បាននូវសទ្ធា ( សេចក្តីជឿ ) ក្នុងតថាគត ។ លុះគហបតីជាដើមនោះ ប្រកបដោយការបាននូវសទ្ធានោះហើយ ក៏ពិចារណាដូច្នេះថា ឃរាវាសចង្អៀតចង្អល់ណាស់ ជាផ្លូវហូរមកនៃធូលី គឺកិលេស ឯបព្វជ្ជាមានពេលឱកាសច្រើន កាលបើអាត្មាអញនៅគ្រប់គ្រងផ្ទះនេះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ដោយចំណែកមួយ ឲ្យបរិសុទ្ធដោយចំណែកមួយ ឲ្យស្អាតដូចជាស័ង្ខដែលគេខាត់បានឡើយ បើដូច្នោះ មានតែអាត្មាអញកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ លុះ

ចំណេរមកខាងក្រោយ គហបតីជាដើមនោះ លះបង់នូវគំនរភោគសម្ប័ទ តិចក្តី លះបង់នូវគំនរភោគសម្ប័ទច្រើនក្តី លះបង់នូវញាតិវង្សតិចក្តី លះបង់នូវញាតិវង្សច្រើនក្តី ហើយកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។

[ ៩៥ ] កាលគហបតីជាដើមនោះ បួសយ៉ាងនេះហើយ ក៏បរិបូណ៌ដោយសិក្ខា និងសាជីវៈសម្រាប់ភិក្ខុទាំងឡាយ លះបង់នូវបាណាតិបាត ជាអ្នកវៀរស្រឡះចាកបាណាតិបាត មានអាជ្ញាដាក់ចុះ មានសស្ត្រាវុធដាក់ចុះ ជាអ្នកមានសេចក្តីខ្មាស មានសេចក្តីអាណិតអាសូរ អនុគ្រោះដោយប្រយោជន៍ចំពោះពួកសត្វដែលមានជីវិតទាំងអស់ ។ ជាអ្នកលះបង់នូវអទិន្នាទាន វៀរស្រះឡះចាកអទិន្នាទាន កាន់យកតែវត្ថុដែលគេឲ្យ ប្រាថ្នាតែរបស់ដែលគេឲ្យ មិនជាចោរ ជាអ្នកមានខ្លួនស្អាត ។ ជាអ្នកលះបង់នូវអព្រហ្មចរិយៈ ( ធម៌មិនប្រសើរ ) ប្រព្រឹត្តតែធម៌ដ៏ប្រសើរ វៀរឆ្ងាយ វៀរស្រឡះចាកមេថុនដែលជាធម៌របស់អ្នកស្រុក ។ ជាអ្នកលះបង់នូវមុសាវាទ វៀរស្រឡះចាកមុសាវាទ ជាអ្នកពោលពាក្យពិត តនូវពាក្យពិត ពោលតែពាក្យទៀងទាត់ និងពាក្យដែលគួរឲ្យជឿ ជាអ្នកមិនពោលបំភ្លាត់សត្វលោក ។ ជាអ្នកលះបង់នូវបិសុណ-វាចា វៀរស្រឡះចាកបិសុណវាចា គឺឮពាក្យអំពីសម្នាក់ជននេះហើយ មិនប្រាប់ជនឯណោះ ដើម្បីបំបែកជនទាំងពីរនេះឡើយ ឬ ឮពាក្យអំពីសម្នាក់ជនឯណោះហើយ មិនប្រាប់ដល់ជននេះ ដើម្បីបំបែកពួកជនឯណោះឡើយ ជាអ្នកសម្រួបសម្រួមពួកជនដែលបែកគ្នាហើយផង ជាអ្នកបន្ថែមកម្លាំងឲ្យពួក

ជនដែលព្រមព្រៀងគ្នាស្រាប់ហើយផង ជាអ្នកត្រេកអរក្នុងសេចក្តីព្រមព្រៀង ពេញចិត្តក្នុងសេចក្តីព្រមព្រៀង រីករាយក្នុងសេចក្តីព្រមព្រៀង ពោលតែវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀង ។ ជាអ្នកលះបង់នូវផរុសវាចា វៀរស្រឡះចាកផរុសវាចា បើវាចាណាឥតទោស សុខដល់ត្រចៀក គួរឲ្យស្រឡាញ់ គួរឲ្យតម្កល់ទុកក្នុងហឫទ័យ ជាវាចាអ្នកក្រុង ជាទីត្រេកអរដល់ជនច្រើន ជាទីពេញចិត្តដល់ជនច្រើន ជាអ្នកពោលតែវាចាមានសភាពដូច្នោះ ។ ជាអ្នកលះបង់នូវសម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកនិយាយតាមកាលគួរ និយាយពាក្យមែន និយាយពាក្យមានប្រយោជន៍ និយាយធម៌ និយាយវិន័យ និយាយវាចាដែលគួរឲ្យអ្នកផងយកទុកក្នុងហឫទ័យ ជាពាក្យប្រកបដោយទីអាងតាមកាល ជាវាចាមានទីបំផុតនិងប្រកបដោយប្រយោជន៍។ ជាអ្នកវៀរស្រឡះចាកកិរិយាផ្តិលផ្តាច់នូវពីជគាម និងភូតគាម ។ ជាអ្នកបរិ-ភោគភត្តតែ ១ ពេល ជាអ្នកវៀរចាកការបរិភោគក្នុងវេលាយប់ វៀរស្រឡះចាកកិរិយាបរិភោគក្នុងវេលាវិកាល ។ ជាអ្នកវៀរស្រឡះចាកការរាំច្រៀងប្រគំទាំងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ ។ ជាអ្នកវៀរស្រឡះចាកហេតុជាទីតាំងនៃកិរិយាទ្រទ្រង់ ប្រដាប់តាក់តែង ស្អិតស្អាង ( រាងកាយ ) ដោយផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។ ជាអ្នកវៀរស្រឡះចាកអាសនៈខ្ពស់ និងអាសនៈដ៏ប្រសើរ ។ ជាអ្នកវៀរស្រឡះ ចាកកិរិយាទទួលនូវប្រាក់ និងមាស ជាអ្នកវៀរស្រឡះចាកកិរិយាទទួលនូវធញ្ញជាតិឆៅ។ ជាអ្នកវៀរស្រឡះ ចាកកិរិយាទទួលនូវសាច់ឆៅ ។ ជាអ្នកវៀរស្រឡះ ចាក

កិរិយាទទួលនូវស្រី និងក្មេងស្រី ។ ជាអ្នកវៀរស្រឡះចាកកិរិយាទទួលនូវខ្ញុំស្រី និងខ្ញុំប្រុស ។ ជាអ្នកវៀរស្រឡះចាកកិរិយាទទួលនូវស្រែ និងចម្ការ ។ ជាអ្នកវៀរស្រឡះចាកកិរិយាទទួលនូវពពែ និងចៀម ។ ជាអ្នកវៀរស្រឡះចាកកិរិយាទទួលនូវមាន់ និងជ្រូក ។ ជាអ្នកវៀរស្រឡះចាកកិរិយាទទួលនូវដំរី គោ សេះ និងលា ។ ជាអ្នកវៀរស្រឡះចាកកិរិយាប្រកបក្នុងកិច្ចជាទូត នាំដំណឹងទៅមក ។ ជាអ្នកវៀរស្រឡះចាកការលក់ដូរ ។ ជាអ្នកវៀរស្រឡះចាកការបំបាត់ដោយជញ្ជីង ទាំងបន្ទំភាជន៍ដែលមិនមែនមាសថាជាមាស និងបំបាត់ដោយរង្វាស់ និងរង្វាល់ ។ ជាអ្នកវៀរស្រឡះចាកកិរិយាបង្កាច់ បោកប្រាស និងប្រកបក្នុងការបន្លំដោយរបស់ក្លែង ។ ជាអ្នកវៀរស្រឡះចាកកិរិយាកាត់នូវអវយវៈ សម្លាប់ចាប់ចង ធ្វើឲ្យវង្វេងផ្លូវ ប្លន់ធំ កំហែងយកទ្រព្យ ។ ភិក្ខុនោះជាអ្នកសន្តោសដោយចីវរ ជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ បើដើរចេញទៅទីណាៗ ក៏កាន់យក ( បរិក្ខារទាំងអស់ ) ដើរចេញទៅ ។ ដូចជាសត្វស្លាបដែលហើរទៅទីណាៗ ក៏ហើរទៅល្មមតែកម្លាំងស្លាបវាយ៉ាងណាមិញ ភិក្ខុជាអ្នកសន្តោសដោយចីវរ ជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ បើដើរចេញ ទៅទីណាៗ ក៏កាន់យក ( បរិក្ខារទាំងអស់ ) ដើរទៅដូច្នោះដែរ ។ ភិក្ខុនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះ ហើយទទួលចំពោះនូវសុខដែលមិនប្រកបដោយទោសក្នុងសន្តាន ។ ភិក្ខុនោះឃើញរូបដោយភ្នែកហើយ ក៏មិនកាន់នូវនិមិត្ត មិនកាន់នូវអនុព្យញ្ជនៈឡើយ ( មួយទៀត ) ធម៌ទាំងឡាយជាអកុសលដ៏លាមក គឺអភិជ្ឈា

និងទោមនស្ស រមែងជាប់តាមនូវភិក្ខុព្រោះហេតុ មិនសង្រួមឥន្ទ្រិយ គឺចក្ខុណា ភិក្ខុនោះក៏ប្រតិបត្តិដើម្បីសង្រួមឥន្ទ្រិយគឺចក្ខុនោះ រក្សានូវឥន្ទ្រិយ គឺចក្ខុដល់នូវសេចក្តីសង្រួមក្នុងឥន្ទ្រិយ គឺចក្ខុ ។ ភិក្ខុនោះឮ សំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ ក៏មិនក្តួចកាន់នូវនិមិត្ត មិនក្តួចកាន់នូវអនុព្យញ្ជនៈឡើយ ( មួយទៀត ) ធម៌ទាំងឡាយជាអកុសលដ៏លាមក គឺអភិជ្ឈា និងទោមនស្ស រមែងជាប់តាមនូវភិក្ខុ ព្រោះហេតុមិនសង្រួមឥន្ទ្រិយ គឺចិត្តណា ភិក្ខុនោះប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយ គឺចិត្តនោះ រក្សានូវឥន្ទ្រិយគឺចិត្ត ដល់នូវសេចក្តីសង្រួមក្នុងឥន្ទ្រិយ គឺចិត្ត ។ ភិក្ខុនោះប្រកបដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះ ក៏ទទួលចំពោះនូវសេចក្តីសុខ ដែលមិនច្រឡំដោយកិលេសក្នុងសន្តាន ។ ភិក្ខុនោះធ្វើនូវសេចក្តីដឹងខ្លួនក្នុងការឈានទៅមុខ និងការឈានថយក្រោយ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាក្រឡេកមើលទៅមុខ និងក្រឡេកមើលមកខាងក្រោយ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាបត់អវយវៈ និងលាតនូវអវយវៈ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាទ្រទ្រង់សង្ឃាដិ បាត្រ ចីវរ ជាអ្នកធ្វើសេចក្តីដឹងខ្លួន ក្នុងការស៊ី ផឹក ទំពា ទទួលរស ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ជាអ្នកធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើងវិញ និយាយ ស្ងៀម ។

[ ៩៦ ] ភិក្ខុនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះផង ប្រកបដោយ

ឥន្ទ្រិយសំវរៈដ៏ប្រសើរនេះផង ប្រកបដោយសតិ និងសម្បជញ្ញៈដ៏ប្រសើរនេះផង ហើយចូលចិត្តសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ញក ឬប្រកភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល និងគំនរចំបើង ។ ភិក្ខុនោះត្រឡប់មកអំពីបិណ្ឌបាតវិញ វេលាក្រោយភត្តក៏អង្គុយពែនភ្នែន តម្រង់កាយឲ្យត្រង់ តាំងស្មារតីឆ្ពោះមុខទៅរកកម្មដ្ឋាន ។ ភិក្ខុនោះលះបង់នូវអភិជ្ឈាក្នុងលោកចេញ មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា ។ លះបង់នូវព្យាបាទ និងសេចក្តីប្រទូស្តចេញ មានចិត្តមិនព្យាបាទ អនុគ្រោះដោយប្រយោជន៍ចំពោះពួកសត្វមានជីវិតទាំងអស់ ជម្រះចិត្តចាកព្យាបាទនិងសេចក្តីប្រទូស្ត ។ លះបង់នូវថីនមិទ្ធៈចេញ ជាអ្នកប្រាសចាកថីនមិទ្ធៈ បាននូវអាលោកសញ្ញា គឺសេចក្តីភ្លឺស្វាង មានសតិ និងសម្បជញ្ញៈ ជម្រះចិត្តចាកថីនមិទ្ធៈ ។ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈចេញ ជាអ្នកមានចិត្តមិនរាយមាយ មានចិត្តស្ងប់រម្ងាប់ក្នុងសន្តាន ជម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ ។ លះបង់នូវវិចិកិច្ឆា ជាអ្នកឆ្លងចាកសេចក្តីសង្ស័យ មិនងឿងឆ្ងល់ក្នុងធម៌ទាំងឡាយជាកុសល ជម្រះចិត្តចាកវិចិកិច្ឆា ។

[ ៩៧ ] ភិក្ខុនោះ លុះលះបង់នូវនីវរណធម៌ទាំង ៥ ប្រការនេះ ដែលជាឧបក្កិលេសរបស់ចិត្ត ដែលជាធម្មជាតិធ្វើបញ្ញាឲ្យថយកម្លាំង ហើយស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយក៏ចូលកាន់បឋមជ្ឈានដែលមានវិតក្ក វិចារៈ មានបីតិ និងសុខដែលកើតមកអំពីវិវេក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះរម្ងាប់នូវវិតក្ក និងវិចារៈបាន ក៏ចូលកាន់ទុតិយជ្ឈាន ជាទីផូរផង់ ប្រព្រឹត្តទៅខាងក្នុង ញុំាងសមាធិចិត្តឲ្យកើត ឥត

មានវិតក្កៈនិងវិចារៈទេ មានតែបីតិ និងសុខដែលកើតអំពីសមាធិ ។បេ។ ចូលកាន់តតិយជ្ឈាន ... ចូលកាន់ចតុត្ថជ្ឈាន សម្រេចសម្រាន្តឥរិយាបថ ។

[ ៩៨ ] ភិក្ខុនោះ ឃើញរូបដោយភ្នែក ហើយមិនត្រេកអរនឹងរូបដែលគួរស្រឡាញ់ មិនមានបដិឃៈចំពោះរូបដែលមិនគួរស្រឡាញ់ ជាអ្នកមានសតិក្នុងកាយ តម្កល់នៅខ្ជាប់ផង មានចិត្តប្រកបដោយគុណប្រមាណពុំបានផង ធម៌ទាំងឡាយជាអកុសលដ៏លាមកនោះ របស់ភិក្ខុនោះ រមែងរលត់ទៅមិនសល់ក្នុងចេតោវិមុត្តិ បញ្ញាវិមុត្តិណា លោកក៏បានដឹងច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិនោះ តាមសេចក្តីពិតផង ។ ភិក្ខុនោះ លុះលះបង់នូវតម្រេក និងសេចក្តីក្រេវក្រោធយ៉ាងនេះហើយ រមែងទទួលវេទនាណាមួយ ជាសុខ ឬជាទុក្ខ ឬមិនទុក្ខមិនសុខ ។ ភិក្ខុនោះមិនត្រេកអរ មិននិយាយសរសើរ មិនប្រកាន់វេទនានោះឡើយ ។ កាលបើភិក្ខុនោះមិនត្រេកអរ មិននិយាយសរសើរ មិនប្រកាន់វេទនានោះទេ សេចក្តីត្រេកអរក្នុងវេទនាទាំងឡាយ ក៏នឹងរលត់ទៅមិនសល់ ។ ភិក្ខុនោះបានរលត់ឧបាទាន ព្រោះរលត់តម្រេក បានរលត់ភពព្រោះរលត់ឧបាទាន បានរលត់ជាតិព្រោះរលត់ភព សេចក្តីចាស់ស្លាប់ ( រលត់ ) ព្រោះរលត់ជាតិ ការសោក ការខ្សឹកខ្សួល ការលំបាកកាយ ការលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ ក៏សឹងតែរលត់ទៅមិនសល់ សេចក្តីរលត់កងទុក្ខទាំងអស់នេះ រមែងមានដោយប្រការដូច្នេះឯង ។ ភិក្ខុនោះ ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ ក៏មិនត្រេកអរនឹង

ធម្មារម្មណ៍ ដែលមានសភាពគួរស្រឡាញ់ មិនមានបដិឃៈចំពោះធម្មារម្មណ៍ ដែលមានសភាពមិនគួរស្រឡាញ់ ជាអ្នកមានសតិក្នុងកាយ តម្កល់នៅខ្ជាប់ផង មានចិត្តប្រកបដោយគុណប្រមាណពុំបានផង ធម៌ទាំងឡាយជាអកុសលដ៏លាមករបស់ភិក្ខុនោះ រមែងរលត់ទៅ មិនសល់ក្នុងចេតោវិមុត្តិ បញ្ញាវិមុត្តិណា ភិក្ខុនោះក៏បានដឹងច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិនោះតាមសេចក្ដីពិតផង ។ ភិក្ខុនោះ លះបង់នូវតម្រេក និងសេចក្ដីក្រេវក្រោធយ៉ាងនេះហើយ រមែងទទួលវេទនាណាមួយ ជាសុខ ឬជាទុក្ខ ឬមិនទុក្ខមិនសុខ ។ ភិក្ខុនោះ មិនត្រេកអរ មិននិយាយសរសើរ មិនប្រកាន់វេទនានោះឡើយ ។ កាលបើភិក្ខុនោះមិនត្រេកអរ មិននិយាយសរសើរ មិនប្រកាន់វេទនានោះហើយ សេចក្ដីត្រេកអរក្នុងវេទនាទាំងឡាយ ក៏នឹងរលត់ទៅមិនសល់ ។ ភិក្ខុនោះ បានរលត់ឧបាទាន ព្រោះរលត់តម្រេក បានរលត់ភព ព្រោះរលត់ឧបាទាន បានរលត់ជាតិ ព្រោះរលត់ភពសេចក្ដីចាស់ស្លាប់ ( រលត់ ) ព្រោះរលត់ជាតិ ការសោក ការខ្សឹកខ្សួល ការលំបាកកាយ ការលំបាកចិត្ត និងការចង្អៀតចង្អល់ទាំងឡាយ ក៏រលត់ទៅមិនសល់ សេចក្ដីរលត់កងទុក្ខទាំងអស់នេះ រមែងមានដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវឧបាយជាគ្រឿងបង្អោនចិត្តទៅក្នុងព្រះនិព្វានជាទីក្ស័យនៃតណ្ហានេះ ដោយសង្ខេបរបស់តថាគតនេះចុះ ហើយចូរចាំទុកនូវសាតិភិក្ខុកេវដ្តបុត្រនេះ ថាជាអ្នកចំពាក់ក្នុងសំណាញ់ ដ៏ចង្អៀតចង្អល់ គឺតណ្ហាធំនេះដូច្នេះឯង ។ លុះព្រះ

មានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្តត្រេកអរហើយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## មហាតណ្ហាសង្ខយសូត្រទី ៨ ចប់

# អដ្ឋកថា

## មហាតណ្ហាសង្ខយសូត្រទី ៨

[ ៨០ ] មហាតណ្ហាសង្ខយសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះ បទថា **ទិដ្ឋិគតំ** នេះ ក្នុងអលគទ្ទូបមសូត្រ ពោលបទថា ទិដ្ឋិ ថាជា លទ្ធិ ។ ក្នុងទីនេះ លោកពោលថាជាសស្សតទិដ្ឋិ ។ ភិក្ខុនោះ ជាអ្នកស្ដាប់ច្រើន តែភិក្ខុដែលស្ដាប់តិច ពោលជាតក ស្ដាប់ព្រះមានព្រះភាគ ត្រាស់ប្រជុំរឿងជាតកថា ម្នាលភិក្ខុទាំងឡាយកាលនោះតថាគត កើតជាវេស្សន្តរ កើតជាមហោសថ កើតជាវិធុរបណ្ឌិត កើតជាសេនកបណ្ឌិត កើតជាមហាជនក ដូច្នេះ ។ ពេលនោះ លោកកើតគំនិតថា រូប វេទនា សញ្ញា សង្ខារទាំងនេះ រមែងរត់ទៅក្នុងទីទាំងនោះឯងតែវិញ្ញាណរមែងអន្ទោលទៅ រមែងស្ទុះទៅអំពីលោកនេះ ទៅកាន់លោកដទៃអំពីលោកដទៃ មកកាន់លោកនេះ ដូច្នេះ ទើបកើតសស្សតទិដ្ឋិ ព្រោះហេតុនោះ ទើបពោលថា វិញ្ញាណនោះឯង រមែងអន្ទោលទៅ រមែងស្ទុះទៅ មិនមែនដទៃឡើយ ដូច្នេះ ។ ព្រះសម្មាសម្ពុទ្ធត្រាស់ថា កាលបច្ច័យមាន ទើបការកើតឡើងនៃវិញ្ញាណមាន វៀរចាកបច្ច័យ ការកើតឡើងនៃវិញ្ញាណ មិនមាន ដូច្នេះ ព្រោះដូច្នោះ ភិក្ខុនេះ ឈ្មោះថា រមែងពោលពាក្យដែលព្រះពុទ្ធមិនបានត្រាស់ រមែងឲ្យការប្រហារទូវចក្ររបស់ព្រះជិនស្រី រមែងជំទាស់ក្នុងវេសារជ្ជញាណ រមែងពោលទឹងជនដែលប្រាថ្នាដើម្បីនឹងស្ដាប់ឲ្យយល់ខុសទាំងរាំងក្នុងផ្លូវ ដែលនាំទៅកាន់ភាពជាព្រះអរិយៈ ជាអ្នកបដិបត្តិដើម្បីវិត្ថ

មិនមែនប្រយោជន៍ ដើម្បីភាពជាទុក្ខដល់មហាជន មហាចោរ កាលកើតក្នុងរាជសម្បត្តិរបស់ព្រះរាជា រមែងកើតឡើងដើម្បីវត្តមិនមែនប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់មហាជន យ៉ាងណា បណ្ឌិតគប្បីជ្រាបថា ចោរក្នុងសាសនារបស់ព្រះជិនស្រី កើតឡើងហើយ ដើម្បីវត្តមិនមែនប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់មហាជនយ៉ាងនោះ ។

បទថា **សម្ពហុលា ភិក្ខូ** បានដល់ ភិក្ខុដែលបិណ្ឌបាតជាវត្ត មានប្រក្រតីនៅក្នុងជនបទ ។ បទថា **តេនុបសង្កមឹសុ** សេចក្តីថា ភិក្ខុទាំងនោះគិតថា សាតិភិក្ខុនេះ បានបក្ខពួកហើយ គប្បីញ៉ាំងព្រះសាសនាឲ្យអន្តរធានទៅ លោកមិនទាន់បានបក្ខពួកដរាបណា ពួកយើងនឹងដោះលោកអំពីការឃើញខុសដរាបនោះ ដូច្នេះ ទើបមិនឈរ មិនអង្គុយ ចូលទៅរកអំពីទីដែលខ្លួនស្តាប់ហើយនោះឯង ។

[ ៨២ ] បទថា **យំ កតមន្តំ សាតិ វិញ្ញាណំ** សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា ម្នាលសាតិ អ្នកពោលសំដៅយកវិញ្ញាណណា វិញ្ញាណនោះដូចម្តេច ។ បទថា **យ្វាយំ ភន្តេ វទោ វេទេយ្យោ តត្រ តត្រ កល្យាណបាបកានំ កម្មានំ វិបាកំ បដិសំវេទេតិ** សេចក្តីថា សាតិភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សភាវៈណារមែងពោលបាន រមែងសោយអារម្មណ៍បាន សភាវៈនោះ រមែងសោយវិបាករបស់កុសលកម្ម និងអកុសលកម្មក្នុងទីទាំងនោះបាន ខ្ញុំព្រះអង្គពោលសំដៅដល់វិញ្ញាណឯណា បពិត្រព្រះអង្គ នេះជាវិញ្ញាណនោះ ដូច្នេះ ។ បទថា **កស្ស នុ ខោ ណាម**

សេចក្តីថា ដល់បុគ្គលណា គឺដល់ក្សត្រ ព្រាហ្មណ៍ ឬដល់វៃស្យៈ សូទ្រៈ គ្រហស្ថ បព្វជិត ទេវតា និងមនុស្សទាំងឡាយណាមួយ ។

[ ៨៣ ] បទថា **អថខោ ភគវា ភិក្ខូ អាមន្តេសិ** សួរថា ព្រោះហេតុអ្វី ទើបត្រាស់ហៅភិក្ខុទាំងឡាយ ឆ្លើយថា បានឮថា សាតិភិក្ខុមានគំនិតយ៉ាងនេះថា ព្រះសាស្តាហៅអញថា មោឃបុរស ដូច្នេះ មិនមានឧបនិស្ស័យនៃមគ្គ និងផលទាំងឡាយ ដោយគ្រាន់តែពាក្យដែលពោលហើយថា មោឃបុរសនេះប៉ុណ្ណោះក៏ទេ ព្រោះថា សូម្បីព្រះឧបសេនត្ថេរ ព្រះមានព្រះភាគក៏ត្រាស់យ៉ាងនេះថា ម្នាលមោឃបុរស អ្នកវិលមកដើម្បីភាពជាអ្នកប្រាថ្នាច្រើនរហ័សពេក ដូច្នេះ ខាងក្រោយតមក ធ្វើសេចក្តីព្យាយាម ក៏បានធ្វើឲ្យជាក់ច្បាស់នូវអភិញ្ញា ៦ សូម្បីអញផ្គងសេចក្តីព្យាយាមហើយ ក៏នឹងធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផលទាំងឡាយ ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគសម្តែងដល់លោកថា សាតិភិក្ខុនេះ មានបច្ច័យដាច់ហើយ ជាបុគ្គលមានធម៌ដែលមិនដុះដាលក្នុងសាសនានេះ ទើបត្រាស់ហៅភិក្ខុទាំងឡាយ ។ បទថា **ឧស្មីកតោ** ជាដើម បណ្ឌិតគប្បីជ្រាបអធិប្បាយតាមដែលបានពោលហើយខាងដើមនោះឯង ។

បទថា **អថខោ ភគវា** សេចក្តីថា អនុសន្ធិនេះជារបស់ចំពោះបុគ្គល ។ បានឮថា សាតិភិក្ខុមានការគិតថា ព្រះមានព្រះភាគត្រាស់ថា ធម៌ដែលជាឧបនិស្ស័យនៃមគ្គ និងផលទាំងឡាយរបស់អញមិនមាន ដូច្នេះ កាលធម៌ដែលជាឧបនិស្ស័យមិនមាន អញអាចដើម្បីកែខៃធម៌ដែលជាឧបនិស្ស័យបាន

ឬ ព្រោះថា ព្រះតថាគតទាំងឡាយ រមែងមិនសម្តែងធម៌ដល់បុគ្គលដែលមានឧបនិស្ស័យប៉ុណ្ណោះទេ បុគ្គលណាក៏សម្តែងនោះឯង អញបានឱវាទនៃព្រះសុគតអំពីសម្នាក់របស់ទ្រង់ហើយ នឹងធ្វើកុសលដើម្បីសគ្គសម្បត្តិ ដូច្នេះ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ដល់សាតិភិក្ខុនោះថា ម្នាលមោឃបុរស តថាគតមិនឲ្យឱវាទ ឬអនុសាសនីដល់អ្នក ដូច្នេះ កាលទ្រង់រម្ងាប់ឱវាទរបស់ព្រះអង្គ ទើបផ្តើមទេសនានេះ ។ អត្ថនៃព្រះតម្រាស់នោះ គប្បីជ្រាបដោយន័យដែលពោលហើយខាងដើមនោះឯង ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ជម្រះលទ្ធិក្នុងបរិស័ទ ទើបត្រាស់ពាក្យថា **ឥធាហំ ភិក្ខូ បដិបុច្ឆិស្សាមិ** ជាដើម ។ ពាក្យទាំងអស់ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលខាងដើមនោះឯង ។

## សាតិកណ្ឌ ចប់

[ ៨៤ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងនូវភាពដែលវិញ្ញាណមានបច្ច័យ ទើបត្រាស់ពាក្យថា **យញ្ញទេវ ភិក្ខវេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **មនញ្ច មដិច្ច ធម្មេ ច** បានដល់ វិញ្ញាណអាស្រ័យភវង្គចិត្ត ព្រមទាំងអាវជ្ជនៈ និងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **កដ្ឋញ្ច បដិច្ច** ជាដើម ព្រះមានព្រះភាគត្រាស់ហើយ ដើម្បីសម្តែងចន្លុលបង្ហាញដោយឧបមា ព្រះមានព្រះភាគ ទ្រង់សម្តែងដោយឧបមានោះ ។ ទ្រង់សម្តែងដល់ការមិនមានការពេញចិត្តក្នុងទ្វារ ។ ប្រៀបដូចភ្លើងអាស្រ័យឧសទើបឆេះ កាលបច្ច័យ គឺកំញមនៅមាននោះឯង ក៏នៅឆេះ កាលបច្ច័យ គឺ

កំញមមិនមាន ក៏រលត់ទៅក្នុងទីនោះឯង ព្រោះការខ្វះនូវបច្ច័យ រមែងមិនដល់នូវការរាប់ថា ភ្លើងកម្ទេចឈើជាដើម ព្រោះឈានកន្លងវត្ថុ មានកម្ទេចឈើជាដើម យ៉ាងណា វិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុ និងរូប ដូច្នោះដូចគ្នា កាលបច្ច័យ ពោល គឺចក្ខុបសាទ រូប អាលោក និងមនសិការក្នុងទ្វារនោះនៅមាន រមែងកើតឡើង កាលបច្ច័យនោះមិនមាន រមែងរលត់ទៅក្នុងទីនោះឯង ដោយការខ្វះនៃបច្ច័យ រមែងមិនដល់នូវការរាប់ថា សោតវិញ្ញាណជាដើម ព្រោះឈានកន្លងសោតបសាទជាដើម ។ ក្នុងវារៈទាំងពួង ក៏ន័យនេះឯង ។ ដោយហេតុនេះ ទើបព្រះមានព្រះភាគត្រាស់តិះដៀលសាតិភិក្ខុដោយព្រះតម្រាស់ថា តថាគតរមែងមិនពោលហេតុគ្រាន់តែការពេញចិត្តក្នុងទ្វារ ក្នុងការប្រព្រឹត្តទៅនៃវិញ្ញាណ ឯសាតិភិក្ខុមោឃបុរសនេះ រមែងពោលដល់ការពេញចិត្តក្នុងភព ដូច្នេះ ។

[ ៨៥ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពដែលវិញ្ញាណ មានបច្ច័យហើយ ឥឡូវនេះ កាលទ្រង់សម្តែងដល់ភាពដែលខន្ធទាំង ៥ មានបច្ច័យ ទើបត្រាស់ថា **ភូតមិទំ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ភូតមិទំ** នេះបានដល់ ខន្ធបញ្ចកៈដែលកើតហើយ បដិសន្ធិហើយ កើតឡើងហើយ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកឃើញថា ខន្ធបញ្ចកៈដែលកើតហើយឬ ។ បទថា **តទាហារសម្ភវំ** សេចក្តីថា ខន្ធបញ្ចកៈនោះៗកើតឡើងព្រោះអាហារ កើតឡើងព្រោះបច្ច័យ ព្រះមានព្រះភាគត្រាស់សួរថាពួកអ្នកឃើញយ៉ាងនេះថា កាលបច្ច័យមាន ខន្ធបញ្ចកៈ រមែងកើតឡើងឬ

ដូច្នេះ ។ បទថា **តទាហារនិរោធា** បានដល់ ព្រោះការរលត់នៃបច្ច័យនោះ ។ បទថា **ភូតមិទំ នោសុ** បានដល់ ខន្ធបញ្ចកៈនេះ កើតឡើងហើយ គឺកើតហើយ មានឬហ្ន៎ ។ បទថា **តទាហារសម្ភវំ នោសុ** សេចក្ដីថា ព្រះមានព្រះភាគត្រាស់សួរថា ខន្ធបញ្ចកៈដែលមានហើយនេះ កើតឡើងព្រោះបច្ច័យឬហ្ន៎ ។ បទថា **តទាហារនិរោធា** បានដល់ ព្រោះការរលត់នៃបច្ច័យនោះ ។ បទថា **និរោធធម្មំ នោសុ** សេចក្ដីថា ព្រះមានព្រះភាគសួរថា ខន្ធបញ្ចកៈមានការរលត់ទៅជាធម្មតាឬទេហ្ន៎ ។ បទថា **សម្មប្បញ្ញាយ បស្សតោ** សេចក្ដីថា កាលបុគ្គលឃើញដោយប្រពៃដោយវិបស្សនាបញ្ញា ដោយលក្ខណៈដែលមានរសតាមសេចក្ដីពិតថា ខន្ធបញ្ចកៈនេះកើតហើយ បដិសន្ធិហើយ កើតឡើងហើយ ដូច្នេះ ។ បទថា **បញ្ញាយ សុទិដ្ឋំ** បានដល់ ឃើញហើយដោយប្រពៃ ដោយវិបស្សនាបញ្ញា តាមន័យដែលពោលហើយនោះឯង ។ បុគ្គលពួកណាមួយ កំណត់សំណួរនោះ ដោយអាការយ៉ាងនេះ ព្រះមានព្រះភាគ កាលទ្រង់ទទួលប្ដេជ្ញារបស់បុគ្គលទាំងនោះ ក៏នឹងសម្ដែងដល់ភាពដែលខន្ធ ៥ មិនមានបច្ច័យ ដូច្នេះ ។

ឥឡូវនេះ ពួកភិក្ខុមានការឃើញខន្ធបញ្ចកៈនោះ មានបច្ច័យ និងមាននិរោធយ៉ាងល្អ ដោយបញ្ញាណា ព្រះមានព្រះភាគ កាលត្រាស់សួរដល់ភាពដែលខន្ធបញ្ចកៈនោះ មិនមានតណ្ហាក្នុងទីនោះ ទើបត្រាស់ពាក្យថា **ឥមំ ចេ តុម្ហេ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **ទិដ្ឋិ** បានដល់ វិបស្សនាសម្មាទិដ្ឋិ ។ ឈ្មោះថា បរិសុទ្ធ ព្រោះឃើញដោយសភាវៈ ឈ្មោះថា ផូរផង់

ព្រោះ ឃើញបច្ច័យ ។ បទថា **អល្លិយេថ** បានដល់ គប្បីជាប់ដោយតណ្ហា និងទិដ្ឋិទាំងឡាយ ។ បទថា **កេឡាយេថ** បានដល់ គប្បីត្រេកអរដោយតណ្ហា និងទិដ្ឋិ ។ បទថា **ធនេយ្យាថ** បានដល់ គប្បីដល់នូវការចង់បាន ដូចបុគ្គលប្រាថ្នាទ្រព្យ ។ បទថា **មមាយេថ** បានដល់ គប្បីញ៉ាំងហេតុត្រឹមតែតណ្ហា និងទិដ្ឋិឲ្យកើតឡើង ។ បទថា **និត្ថរណត្ថាយ នោ គហណត្ថាយ** សេចក្តីថា ព្រះមានព្រះភាគត្រាស់ថា ធម៌ណាប្រៀបដោយក្បូនដែលតថាគតសម្តែងហើយ ដើម្បីប្រយោជន៍ក្នុងការរលាស់ចេញចាកឱឃៈ ៤ ពួកអ្នកគប្បីដឹងធម៌នោះ មិនមែនដើម្បីប្រយោជន៍ក្នុងការកាន់យក ដោយអំណាចនៃសេចក្តីប្រាថ្នាខ្លះឬហ្ន៎ ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបធម៌ ដែលជាសុក្កបក្ខដោយផ្ទុយគ្នាក្នុងទីនេះ ។

[ ៨៦ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងបច្ច័យនៃខន្ធទាំងនោះ ទើបត្រាស់ពាក្យថា **ចត្តារោ មេ ភិក្ខវេ អាហារា** ជាដើម ពាក្យនោះមានអត្ថតាមដែលពោលហើយនោះឯង អធិប្បាយថា ធម៌ ១ ដែលព្រះមានព្រះភាគត្រាស់ថា ភិក្ខុរមែងដឹងធម៌នេះ គឺបុគ្គលកាលដឹងដោយអំណាចនៃបវេណី ដែលមកយ៉ាងនេះថា អញរមែងដឹងមាតារបស់បុគ្គលនេះតែម្យ៉ាងរមែងដឹងនូវមាតារបស់មាតា ដូច្នេះ ឈ្មោះថា រមែងដឹងយ៉ាងល្អ យ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះដូចគ្នា ទ្រង់ជ្រាបច្បាស់ត្រឹមតែខន្ធម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន ទ្រង់ជ្រាបការបន្តគ្នាមករៀយៗ នៃធម៌ដែលជាបច្ច័យទាំងពួង យ៉ាងនេះថា ទ្រង់រមែងជ្រាបច្បាស់ សូម្បីបច្ច័យនៃខន្ធទាំងឡាយ ទ្រង់តែងជ្រាប

នូវបច្ច័យនៃបច្ច័យទាំងនោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងកម្លាំងរបស់ព្រះពុទ្ធ ដើម្បីទ្រង់សម្តែងការបន្តគ្នាមករឿយៗ នៃបច្ច័យក្នុងឥឡូវនេះ ទើបត្រាស់ពាក្យថា **ឥមេ ច ភិក្ខវេ ចត្តារោ អាហារា** ជាដើម ។ សូម្បីពាក្យនោះ ក៏មានអត្ថដូចដែលពោលហើយ ។ កថាពោលដោយបដិច្ចសមុប្បាទ ក្នុងព្រះបាលីនេះថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមាន ព្រោះអវិជ្ជាជាបច្ច័យ ។បេ។ ដោយប្រការដូច្នេះឯង ការកើតឡើងនៃកងទុក្ខទាំងអស់នោះ រមែងមានយ៉ាងនេះដូច្នេះ គប្បីឲ្យពិស្តារ ឯកថានោះ បានពោលពិស្តារហើយ ក្នុងវិសុទ្ធិមគ្គ ។

[ ៨៨ ] បទថា **ឥមស្មឹ សតិ ឥទំ ហោតិ** បានដល់ កាលបច្ច័យមានអវិជ្ជាជាដើមនេះមាន ផល មានសង្ខារជាដើមនេះក៏មាន ។ បទថា **ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** បានដល់ ព្រោះបច្ច័យ មានអវិជ្ជាជាដើមនេះកើតឡើង ផល មានសង្ខារជាដើមនេះក៏កើតឡើង ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ព្រោះអវិជ្ជាជាបច្ច័យ ទើបសង្ខារទាំងឡាយមាន ។បេ។ ការកើតឡើងនៃកងទុក្ខទាំងឡាយនោះ រមែងមានបានយ៉ាងនេះ ដូច្នេះ ។

ព្រះមានព្រះភាគ លុះទ្រង់សម្តែងវដ្តៈយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងវិវដ្តៈ ទើបត្រាស់ថា **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អវិជ្ជាយ ត្វេវ** គឺអវិជ្ជានោះឯង ។ បទថា **អសេសវិរាគនិរោធា** ពាក្យនេះ ព្រះមានព្រះភាគត្រាស់ថា ព្រោះសង្ខាររលត់ទៅ ទើបវិញ្ញាណរលត់ដូច្នេះជាដើម ដើម្បីសម្តែងថា ព្រោះការរលត់

ទៅនៃសង្ខារទាំងឡាយដែលរលត់ទៅយ៉ាងនេះថា ព្រោះការរលត់ដោយមិនមានសេសសល់ដោយមគ្គ ពោល គឺវិរាគៈ ទើបការរលត់មិនកើតឡើងនៃសង្ខារមាន ដូច្នេះ វិញ្ញាណក៏រលត់ ព្រោះការរលត់នៃធម៌ទាំងឡាយ មានវិញ្ញាណជាដើម ឈ្មោះថា ធម៌ទាំងឡាយ មានរូបជាដើម ក៏រមែងរលត់ទៅដូចគ្នា ដូច្នេះហើយ ទើបត្រាស់ថា ការរលត់នៃកងទុក្ខទាំងអស់នោះ រមែងមានយ៉ាងនេះ ។ បណ្ដាបទទាំងនោះ បទថា **កេវលស្ស** បានដល់ ទាំងអស់ អធិប្បាយថា កងទុក្ខសុទ្ធៗ វៀរចាកភាពជាសត្វ ។ បទថា **ទុក្ខក្ខន្ធស្ស** ប្រែថា កងទុក្ខ ។ បទថា **និរោធោ ហោតិ** បានដល់ ការមិនកើតឡើង ។

[ ៩០ ] បទថា **ឥមស្មឹ អសតិ** ជាដើម បណ្ឌិតគប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយ ។

[ ៩១ ] ព្រះមានព្រះភាគ កាលត្រាស់បដិច្ចសមុប្បាទ ព្រមទាំងវដ្តៈ និងវិវដ្តៈ ដោយអាការយ៉ាងនេះហើយ ឥឡូវនេះ កាលត្រាស់សួរដល់ការមិនមាននៃការអន្ទោលទៅ ដែលបុគ្គលដឹងនូវការវិលវល់ទៅនៃបច្ច័យ ១២ នេះ ព្រមដោយមគ្គក្នុងវិបស្សនាញាណ ដែលលះបានហើយនោះ ទើបត្រាស់ពាក្យថា **អបិនុ តុម្ហេ ភិក្ខវេ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **ឯវំ ជានន្តា** បានដល់ ដឹងយ៉ាងនេះ ព្រមដោយវិបស្សនាមគ្គ ។ បទថា **ឯវំ បស្សន្តា** ជាវេវចនៈនៃពាក្យនោះឯង ។ បទថា **បុព្វន្តំ** អធិប្បាយថា ខន្ធ ធាតុ និងអាយតនៈទាំងឡាយក្នុងអតីត ។ បទថា **បដិធាវេយ្យាថ** គឺគប្បីស្ទុះទៅដោយអំណាចនៃតណ្ហា និងទិដ្ឋិ ។ ពាក្យដ៏សេសពិស្ដារហើយ ក្នុងសព្វា-

សាវសំវរសូត្រ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលត្រាស់សួរដល់ការមិនញាប់ញ័រនៃភិក្ខុទាំងនោះ ក្នុងទីនោះ ទើបត្រាស់ពាក្យថា **អបិនុ តុម្ហេ ភិក្ខវេ ឯវំ ជានន្តា ឯវំ បស្សន្តា ឯវំ វទេយ្យាថ សត្ថា នោ គរុ** ដូច្នេះជាដើម ប្រែថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកដឹងយ៉ាងនេះ ឃើញយ៉ាងនេះ គប្បីពោលយ៉ាងនេះថា ព្រះសាស្តាជាគ្រូយើង ។

បណ្តាបទទាំងនោះ បទថា **គរុ** បានដល់ អ្នកពេញទៅដោយភារៈ ជាអ្នកបណ្តោយតាមការប្រាថ្នាក៏ទេ ។ បទថា **សមណោ** បានដល់ សមណៈដែលត្រាស់ដឹងហើយ ។ បទថា **អញ្ញំ សត្ថារំ ឧទ្ទិសេយ្យាថ** សេចក្តីថា ពួកអ្នកគប្បីជាអ្នកសម្គាល់យ៉ាងនេះថា ព្រះសាស្តាមិនអាចញុំាងកិច្ចរបស់ពួកយើងឲ្យសម្រេច ដូច្នេះហើយ គប្បីសរសើរសាស្តាដទៃ គឺខាងក្រៅសាសនាខ្លះឬ ។ បទថា **បុថុសមណព្រាហ្មណានំ** គឺតិរ្ថិយសមណៈ និងព្រាហ្មណ៍ជាច្រើន ។ បទថា **វតកោតុហលមង្គលានិ** បានដល់ សមាទានបដិបទាណាមួយ ភ្ញាក់ផ្អើលក្នុងការឃើញណាមួយ និងទិដ្ឋមង្គល សុតមង្គល មុតមង្គលណាមួយ ។ បទថា **តានិ សារតោ បច្ចាគច្ឆេយ្យាថ** សេចក្តីថា គប្បីជាអ្នកសម្គាល់សេចក្តីនោះយ៉ាងនេះថាជាសារៈ ដូច្នេះហើយ ប្រកាន់មាំអធិប្បាយថា សូម្បីលះបង់ចេញហើយយ៉ាងនេះ ហើយប្រកាន់យកទៀត ។ បទថា **សាមំ ញាតំ** បានដល់ ដឹងបានឯងដោយញាណ ។ បទថា **សាមំ ទិដ្ឋំ** បានដល់ ឃើញបានឯងដោយបញ្ញាចក្ខុ ។ បទថា **សាមំ វិទិតំ** បាន

ដល់ ធ្វើឲ្យជាក់ច្បាស់ គឺធ្វើឲ្យប្រាកដបានឯង ។ បទថា **ឧបនីតា ខោ មេ តុម្ហេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកដែលតថាគតនាំទៅកាន់និព្វាន ដោយធម៌ដែលមានសភាវៈ គប្បីឃើញដោយខ្លួនឯងជាដើមនេះ។ អធិប្បាយថា ដែលតថាគតឲ្យដល់ហើយនូវអត្ថនៃធម៌ទាំងឡាយ មានសន្ទិដ្ឋិកោជាដើម សេចក្តីនេះពិស្តារហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **ឥទមេតំ បដិច្ច វុត្តំ** សេចក្តីថា ពាក្យនេះ យ៉ាងនេះ តថាគតពោលហើយ ព្រោះអាស្រ័យភាពដែលពួកអ្នកដឹងឯងជាដើម ។

[ ៩២ ] សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគផ្តើមពាក្យថា ម្នាលភិក្ខុទាំងឡាយ កិរិយាចុះចាប់បដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃព្រោះប្រជុំហេតុ ៣ ប្រការ ដូច្នេះ ។ ព្រះអង្គទ្រង់ញុំាងទេសនាឲ្យដល់ទីបំផុតហើយ ដោយអំណាចនៃវដ្តៈខាងដើមហើយមិនមែនឬ ឆ្លើយថា មែន ដល់ទីបំផុតហើយ តែអនុសន្ធិនេះ ជារបស់ចំពោះបុគ្គល ។ ពិតហើយ លោក-សន្និវាសនេះ វង្វេងហើយក្នុងបដិសន្ធិ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ទេសនានេះថា តថាគតនឹងកម្ចាត់ឋានៈ ដែលជាទីតាំងនៃការវង្វេងនៃលោកសន្និវាស ធ្វើឲ្យប្រាកដ ។ម្យ៉ាងទៀត អវិជ្ជាមានវដ្តៈជាមូល ការកើតឡើងនៃព្រះពុទ្ធ មានវិវដ្តៈជាមូល ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់សម្តែងអវិជ្ជាដែលមានវដ្តៈជាមូល និងពុទ្ធុប្បាទដែលមានវិវដ្តៈជាមូល ហើយទ្រង់ត្រិះរិះថា តថាគតនឹងញុំាងទេសនាឲ្យដល់ទីបំផុតម្តងទៀត ដោយអំណាចនៃវដ្តៈ និងវិវដ្តៈ ដូច្នេះ ទើបផ្តើមទេសនានេះ ។

បណ្ដាបទទាំងនោះ បទថា **សន្និបាតា** បានដល់ ព្រោះការប្រជុំ គឺព្រោះប្រមូលមក ។ បទថា **គព្ភស្ស** បានដល់ សត្វដែលកើតឡើងក្នុងគភ៌ បទថា **អវក្កន្តិ ហោតិ** បានដល់ ការកើតរមែងមាន ។ ពិតហើយ ក្នុងទីខ្លះ ផ្ទៃនៃមាតា លោកហៅថា គភ៌ ដូចព្រះតម្រាស់ថា

**យមេករត្តឹ បឋមំ គព្ភេ វសតិ មាណវោ**
**អព្ភុដ្ឋិតោវ សោ យាតិ ស គច្ឆំ ន និវត្តតិ ។**

ប្រែថា សត្វនៅក្នុងគភ៌ អស់រាត្រីណាមួយជាដំបូង សត្វនោះប្រព្រឹត្តទៅ ដូចជាពពក ដែលតាំងឡើង សត្វនោះ កាលទៅ រមែងមិនត្រឡប់វិញទេ ។

ក្នុងទីខ្លះ លោកហៅសត្វដែលកើតក្នុងគភ៌ថា **គព្ភ** ។ ដូចព្រះតម្រាស់ថា **យថា ខោ បនានន្ទ អញ្ញា ឥត្ថិកា នវ វា ទស វា មាសេ គព្ភំ កុច្ឆិនា បរិហរិត្វា វិជាយន្តិ** ប្រែថា ម្នាលអានន្ទ ពួកស្ត្រីឯទៀត ពគភ៌ដោយផ្ទៃ អស់ ៩ ខែខ្លះ ១០ ខ្លះ ទើបប្រសូត ។ ក្នុងទីនេះ លោកបំណងយកសត្វ ។ ពាក្យដែលព្រះមានព្រះភាគត្រាស់ថា **គព្ភស្ស អវក្កន្តិ ហោតិ** នេះ សំដៅដល់សត្វនោះ ។ បទថា **ឥធ** បានដល់ ក្នុងសត្វលោកនេះ ។ បទថា **មាតា ច ឧតុនី ហោតិ** នេះ ត្រាស់សំដៅយកពេលមានរដូវ ។ បានឮថា ទារករមែងកើតដល់មាតុគ្រាមក្នុងឱកាសណា ក្នុងឱកាសនោះ តំណក់លោហិតធំតាំងនៅហើយ បែកហូរទៅ ជាវត្ថុបរិសុទ្ធ កាលវត្ថុបរិសុទ្ធ មាតាបិតានៅរួមគ្នាសូម្បីតែម្ដង មានខេត្ត ៧ ថ្ងៃនោះឯង ក្នុងសម័យនោះ ទារករមែងកើត

ឡើងបាន សូម្បីដោយការស្ទាបអង្អែលអវយវៈ មានចាប់ដៃ និងផ្ទងសក់ ជាដើម ។ បទថា **គន្ធព្វោ** បានដល់ សត្វដែលចូលដល់ក្នុងទីនោះ ។ បទថា **បច្ចុប្បដ្ឋិតោ ហោតិ** នេះ អធិប្បាយថា ឈ្មោះថា សត្វដែលសម្លឹងមើលការនៅរួមរបស់មាតា និងបិតា ដែលឈរនៅក្នុងទីជិត រមែងមិនមាន តែសត្វមួយដែលកម្មបន្សាត់ទៅហើយ ដែលនឹងកើតឡើងក្នុងឱកាសនោះមានដូច្នេះ ។ បទថា **សំសយេន** សេចក្តីថា ដោយការសង្ស័យក្នុងជីវិតយ៉ាងធំយ៉ាងនេះថា អញ ឬកូនរបស់អញ នឹងប្រាសចាករោគឬទេហ្ន៎ ដូច្នេះ ។

[ ៩៣ ] បទថា **លោហិតញ្ហេតំ ភិក្ខវេ** សេចក្តីថា បានឮថា ក្នុងលោហិតរបស់មាតាក្នុងគ្រានោះ ដល់ព្រមហើយ នឹងដល់ព្រមហើយនូវឋានៈនោះ គឺតែងជារបស់ស ដោយការស្នេហាក្នុងបុត្រ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។ បទថា **វង្កំ** បានដល់ នង្គ័លតូចរបស់ទារកដែលលេងក្នុងស្រុក ។ កាលលេងវាយឈើខ្លីដោយឈើវែង លោកហៅថា **ឃដិកា** ( លេងហឹង ) បទថា **មោក្ខចិកំ** បានដល់ លេងវិលជារង្វង់ អធិប្បាយថា លេងចាប់កំណាត់ឈើក្នុងអាកាស ឬលេងយកក្បាលទល់នឹងផែនដី ហើយត្រឡប់ខ្នងទៅម្ខាងទៀត ។ ចក្រវិលទៅ ដោយការប៉ះខ្យល់ដែលធ្វើដោយវត្ថុទាំងឡាយ មានស្លឹកត្នោតជាដើម លោកហៅថា **ចិង្គុលិក** ( កង្ហារ ) ។ កន្ទោងធ្វើដោយស្លឹកឈើ លោកហៅថា **បត្តាឡ្ហក** បានដល់ការលេងវាល់វត្ថុទាំងឡាយ មានខ្សាច់ជាដើម ដោយនាឡិស្លឹកឈើនោះ ។ បទថា **រថកំ** បានដល់ រទេះតូច ។ សូម្បីធ្នូ ក៏បានដល់ ធ្នូតូចនោះឯង ។ បទ

ថា **សារជ្ជតិ** បានដល់ រមែងញ៉ាំងរាគៈឲ្យកើតឡើង ។ បទថា **ព្យាបជ្ជតិ** បានដល់ ញ៉ាំងនូវការព្យាបាទឲ្យកើតឡើង ។ បទថា **អនុបដ្ឋិតកាយស្សតិ** សេចក្តីថា សតិក្នុងកាយ ហៅថា កាយសតិ អធិប្បាយថា តាំងកាយសតិនោះ ។ បទថា **បរិត្តចេតសោ** បានដល់ អកុសលចិត្ត ។ បទថា **យត្ថស្ស តេ ធាបកា** សេចក្តីថា អកុសលធម៌ដ៏លាមកទាំងនោះ រមែងរលត់ទៅ ក្នុងផលសមាបត្តិណា រមែងមិនដឹង រមែងមិនសម្រេចសមាបត្តិនោះ ។ បទថា **អនុរោធវិរោធំ** បានដល់ រាគៈ និងទោសៈ ។ បទថា **អភិនន្ទតិ** បានដល់ រមែងត្រេកអរដោយអំណាចនៃតណ្ហា កាលបុគ្គលពោលដោយអំណាចនៃតណ្ហាថា ឱ ! សុខហ្ន៎ជាដើម ឈ្មោះថា រមែងកន្ទក់កន្ទេញ ។ បទថា **អជ្ឈោសាយ តិដ្ឋតិ** បានដល់ លេប គឺញ៉ាំងកិច្ចឲ្យសម្រេចហើយ កាន់យកដោយការជាប់ចិត្តក្នុងតណ្ហា អធិប្បាយថា ចូរត្រេកអរក្រៃលែងនូវសុខ ឬអទុក្ខមសុខ ឬរមែងត្រេកអរក្រៃលែងនូវទុក្ខដូចម្តេច ។ កាលបុគ្គលប្រកាន់ថា អញមានទុក្ខ ទុក្ខជារបស់អញដូច្នេះ ឈ្មោះថា រមែងត្រេកអរក្រៃលែងក្នុងទុក្ខ ។ បទថា **ឧប្បជ្ជតិ នន្ទិ** បានដល់ តណ្ហារមែងកើតឡើង ។ បទថា **តទុបាទានំ** សេចក្តីថា តណ្ហានោះឯង ឈ្មោះថា ឧបាទាន ព្រោះអត្ថថាប្រកាន់ ។ ឯបច្ចយាការដែលជាវដ្តៈ មានសន្ធិ ៣ និងសង្ខេបនេះថា **តស្ស ឧបាទានបច្ចយា ភវោ ។បេ។ សមុទយោ ហោតិ** ដូច្នេះ ព្រះមានព្រះភាគត្រាស់ម្តងទៀត ។

[ ៩៤ ] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងចំណែកវិវដ្តៈ

ទើបត្រាស់ថា **ឥធ ភិក្ខវេ តថាគតោ លោកេ ឧប្បជ្ជតិ** ជាដើម ។

[ ៩៨ ] បណ្តាបទទាំងនោះ បទថា **អប្បមាណចេតសោ** សេចក្តីថា ឈ្មោះថា មានចិត្តប្រមាណមិនបាន ព្រោះមានចិត្តជាលោកុត្តរដែលប្រមាណមិនបាន អធិប្បាយថា ជាបុគ្គលដល់ព្រមដោយមគ្គចិត្ត ។

បទថា **ឥមំ ខោ មេ តុម្ហេ ភិក្ខវេ សង្ខិត្តេន តណ្ហាសង្ខយវិមុត្តឹ ធារេថ** សេចក្តីថា ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរទ្រទ្រង់ចាំនូវទេសនាតណ្ហាសង្ខយវិមុត្តិរបស់តថាគត ដែលតថាគតសម្តែងដោយសង្ខេបនេះ អស់កាលជានិច្ចចុះ កុំបីភ្លេចភ្លាំងឡើយ ។ ពិតហើយ ទេសនាក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ថា វិមុត្តិ ព្រោះជាហេតុបានវិមុត្តិ ។

បទថា **មហាតណ្ហាជាលតណ្ហាសង្ឃាដប្បដិមុក្កំ** សេចក្តីថា តណ្ហា ព្រះមានព្រះភាគត្រាស់ហៅថា មហាសំណាញ់តណ្ហា ព្រោះអត្ថថា ចងរួបរឹត ត្រាស់ហៅថា **សង្ឃាដ** ព្រោះអត្ថថា ចាក់ទម្លុះ អធិប្បាយថា ពួកអ្នកចូរទ្រទ្រង់ចាំសាតិភិក្ខុ ដែលជាបុត្រនាងកេវដ្តៈនេះថា ជាបុគ្គលជាប់នៅក្នុងសំណាញ់នៃមហាតណ្ហា និងក្នុងស្នួកនៃតណ្ហានេះ គប្បីចាំទុកនូវភិក្ខុនោះថា ជាអ្នកចូលទៅហើយ តណ្ហានៅខាងក្នុង ដូច្នេះ ដោយប្រការយ៉ាងនេះ ។ ពាក្យដ៏សេសទាំងពួង ងាយយល់ហើយ ។

**មហាតណ្ហាសង្ខយសូត្រ ចប់**

**សូត្រទី ៨ ចប់**

# សុត្តន្តបិដក

## មហាអស្សបុរសូត្រទី ៩

[ ៥៩ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគមរបស់អ្នកដែនអង្គៈ ឈ្មោះអស្សបុរៈ ទៀបដែនអង្គៈ ។ ក្នុងកាលនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទូលតបព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកផងតែងស្គាល់ច្បាស់នូវអ្នកទាំងឡាយ ថាជាសមណៈៗ ដូច្នេះ ឯអ្នកទាំងឡាយបើមានអ្នកផងសួរថា លោកទាំងឡាយជាអ្វី ក៏ចូរប្តេជ្ញាថា យើងទាំងឡាយជាសមណៈ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយនោះមានឈ្មោះយ៉ាងនេះ ប្តេជ្ញាយ៉ាងនេះហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរសិក្សាយ៉ាងនេះថា ធម៌ទាំងឡាយណាដែលធ្វើឲ្យជាសមណៈផង ធ្វើឲ្យជាព្រាហ្មណ៍ផង ពួកយើងនឹងសមាទានប្រព្រឹត្តធម៌ទាំងនោះ ឈ្មោះរបស់ពួកយើងនេះ ក៏នឹងពិតយ៉ាងនេះ ទាំងការប្តេជ្ញាក៏ប្រាកដយ៉ាងនេះ មួយវិញទៀត យើងទាំងឡាយបរិភោគនូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខាររបស់ជនទាំងឡាយណា សក្ការៈទាំងឡាយនោះដែលជនទាំងនោះ ( បូជា ) ដល់យើងទាំងឡាយ នឹងទៅជាសក្ការៈមានផលច្រើន មានអានិសង្សច្រើន ឯបព្វជ្ជារបស់ពួកយើង មិនមែនជាឥតអំពើទេ នឹងមានផល មានសេចក្តីចម្រើន ។

[ ១០០ ] ម្នាលភិក្ខុទាំងឡាយ ចុះពួកធម៌ដែលធ្វើឲ្យជាសមណៈ ទាំងធ្វើឲ្យជាព្រាហ្មណ៍ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា ពួកយើងនឹងជាអ្នកប្រកបដោយហិរិ និងឱត្តប្បៈ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិ និងឱត្តប្បៈហើយ កិច្ចដែលពួកយើងធ្វើហើយ ក៏ល្មមត្រឹមប៉ុណ្ណោះ ប្រយោជន៍របស់សមណៈ យើងទាំងឡាយក៏បានដល់ហើយត្រឹមប៉ុណ្ណោះ កិច្ចដែលត្រូវធ្វើតទៅទៀតតិចតួចមិនមានទេ លុះគិតដូច្នេះហើយ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីត្រេកអរដោយហេតុប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយត្រូវការនូវភាពជាសមណៈ កុំលះបង់ប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[ ១០១ ] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀតដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា កាយសមាចាររបស់ពួកយើង នឹងបរិសុទ្ធខ្ពង់ខ្ពស់ មិនរយីករយាក មិនធ្លុះធ្លាយ សង្រួមល្អប៉ុន្តែ ពួកយើងនឹងកុំលើកតម្កើងខ្លួនឯង កុំបន្តុះបង្អាប់អ្នកដទៃ ព្រោះកាយសមាចារបរិសុទ្ធនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ពួកយើងជាអ្នកប្រកបដោយហិរិ និងឱត្តប្បៈ កាយសមាចាររបស់ពួកយើងបរិសុទ្ធហើយ កិច្ចដែលពួកយើងត្រូវធ្វើ ក៏ល្មមត្រឹមប៉ុណ្ណោះហើយ ទាំងប្រយោជន៍របស់សមណៈ យើងទាំងឡាយ ក៏បាន

ដល់ហើយ ដោយហេតុត្រឹមប៉ុណ្ណោះ កិច្ចបន្តិចបន្តួចដែលត្រូវធ្វើតទៅទៀត របស់ពួកយើង មិនមានឡើយ លុះគិតដូច្នេះហើយ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីត្រេកអរ ដោយហេតុប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយត្រូវការដោយភាពជាសមណៈហើយ ត្រូវកុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[ ១០២ ] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា វចីសមាចាររបស់ពួកយើងនឹងបរិសុទ្ធខ្ពង់ខ្ពស់ មិនរាយមាយ មិនធ្លុះធ្លាយ សង្រួមល្អ ប៉ុន្តែ ពួកយើងកុំលើកតម្កើងខ្លួនឯង កុំបន្តុះបង្អាប់អ្នកដទៃ ព្រោះវចីសមាចារបរិសុទ្ធនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិ និងឱត្តប្បៈ កាយសមាចាររបស់ពួកយើងបរិសុទ្ធហើយ ទាំងវចីសមាចារក៏បរិសុទ្ធ កិច្ចដែលត្រូវធ្វើក៏ល្មមត្រឹមប៉ុណ្ណោះហើយ ប្រយោជន៍របស់សមណៈពួកយើងក៏បានដល់ហើយ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀត របស់ពួកយើងមិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីត្រេកអរដោយហេតុប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយត្រូវការដោយភាពជាសមណៈហើយ កុំលះបង់នូវប្រយោជន៍ជារបស់សមណៈ

ឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[ ១០៣ ] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា មនោសមាចាររបស់ពួកយើងនឹងបរិសុទ្ធខ្ពង់ខ្ពស់ មិនរាយមាយ មិនធ្លុះធ្លាយ សង្រួមល្អ ប៉ុន្តែ ពួកយើងកុំលើកតម្កើងខ្លួនឯង កុំបន្ទុះបង្អាប់អ្នកដទៃ ព្រោះមនោសមាចារបរិសុទ្ធនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិ និងឱត្តប្បៈ កាយសមាចាររបស់ពួកយើងបរិសុទ្ធហើយ វចីសមាចារបរិសុទ្ធហើយ មនោសមាចារបរិសុទ្ធហើយ កិច្ចដែលត្រូវធ្វើក៏ល្មមដោយហេតុត្រឹមប៉ុណ្ណោះហើយ ប្រយោជន៍របស់សមណៈ ពួកយើងក៏បានដល់ហើយ ដោយហេតុត្រឹមប៉ុណ្ណោះ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀត របស់ពួកយើងមិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីត្រេកអរ ដោយហេតុប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយ ត្រូវការដោយភាពជាសមណៈហើយ កុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[ ១០៤ ] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា អាជីវៈរបស់ពួកយើងនឹងបរិសុទ្ធស្អាត មិនរាយមាយ មិនធ្លុះធ្លាយ សង្រួមល្អ ប៉ុន្តែ

ពួកយើង កុំលើកតម្កើងខ្លួនឯង កុំបន្តុះបង្អាប់អ្នកដទៃ ព្រោះអាជីវៈបរិសុទ្ធនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិ និងឱត្តប្បៈ កាយសមាចាររបស់ពួកយើងបរិសុទ្ធហើយ វចីសមាចារបរិសុទ្ធហើយ មនោសមាចារបរិសុទ្ធហើយ អាជីវៈបរិសុទ្ធហើយ កិច្ចដែលត្រូវធ្វើ ក៏ល្មមដោយហេតុត្រឹមប៉ុណ្ណោះហើយ ប្រយោជន៍របស់សមណៈ ពួកយើងក៏បានដល់ហើយ ដោយហេតុត្រឹមប៉ុណ្ណោះ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀត របស់ពួកយើងមិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីត្រេកអរដោយហេតុមានប្រមាណប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយត្រូវការដោយភាពជាសមណៈហើយ អ្នកកុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[ ១០៥ ] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា ពួកយើងនឹងមានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំងឡាយ គឺបើឃើញរូបដោយចក្ខុ ក៏មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមនូវបុគ្គលព្រោះហេតុមិនសង្រួមឥន្ទ្រិយ គឺចក្ខុណា ពួកយើងនឹងប្រតិបត្តិ ដើម្បីសង្រួមនូវឥន្ទ្រិយគឺចក្ខុនោះ រក្សានូវឥន្ទ្រិយ គឺចក្ខុ ដល់នូវកិរិយាសង្រួមក្នុងឥន្ទ្រិយ គឺចក្ខុ ។ ឮសំឡេង

ដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយ ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ ក៏មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស រមែងជាប់តាមនូវបុគ្គល ព្រោះហេតុមិនសង្រួមឥន្ទ្រិយ គឺចិត្តណា ពួកយើងនឹងប្រតិបត្តិ ដើម្បីសង្រួមនូវឥន្ទ្រិយ គឺចិត្តនោះ រក្សានូវឥន្ទ្រិយ គឺចិត្ត ដល់នូវកិរិយាសង្រួមក្នុងឥន្ទ្រិយ គឺចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិ និងឱត្តប្បៈ កាយសមាចាររបស់ពួកយើងបរិសុទ្ធហើយ វចីសមាចារបរិសុទ្ធហើយ មនោសមាចារបរិសុទ្ធហើយ អាជីវៈបរិសុទ្ធហើយ យើងមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយហើយ កិច្ចដែលត្រូវធ្វើល្មមដោយហេតុត្រឹមប៉ុណ្ណោះហើយ ប្រយោជន៍របស់សមណៈពួកយើងក៏បានដល់ដោយហេតុត្រឹមប៉ុណ្ណោះហើយ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀត របស់ពួកយើង មិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីត្រេកអរ ដោយហេតុប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយ ត្រូវការដោយភាពជាសមណៈហើយ អ្នកទាំងឡាយកុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[ ១០៦ ] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា ពួកយើង

នឹងជាអ្នកដឹងប្រមាណក្នុងភោជន ពិចារណាដោយឧបាយនៃប្រាជ្ញា ហើយទើបបរិភោគនូវអាហារ នឹងបរិភោគដើម្បីលេង ( ដូចក្មេងអ្នកស្រុក ) ក៏ទេ ដើម្បីនឹងឲ្យកើតបុរិសមានះស្រវឹង ( ដូចអ្នកប្រដាល់ ) ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយ ( ដូចស្ត្រីក្នុងបុរី ) ក៏ទេ ដើម្បីនឹងធ្វើឲ្យផូរផង់សម្បុរ ( ដូចអ្នកលេងរបាំ )ក៏ទេ បរិភោគគ្រាន់តែដើម្បីតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយៈ ពួកយើងនឹងបំបាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណមិនឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស គឺមិនប្រអូសកាយ មិនប្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយដោយឥរិយាបថទាំង ៤ ក្តី នឹងមានដល់ពួកយើង ( ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ ) ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិ និងឱត្តប្បៈ កាយសមាចាររបស់ពួកយើងបរិសុទ្ធហើយ វចីសមាចារបរិសុទ្ធហើយ មនោសមាចារបរិសុទ្ធហើយ អាជីវៈបរិសុទ្ធហើយ ពួកយើងមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយហើយ ជាអ្នកដឹងប្រមាណក្នុងភោជន កិច្ចដែលត្រូវធ្វើល្មមដោយហេតុត្រឹមប៉ុណ្ណោះហើយ ប្រយោជន៍របស់សមណៈ ពួកយើងក៏បានដល់ដោយហេតុត្រឹមប៉ុណ្ណោះហើយ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀត របស់ពួកយើងមិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីត្រេកអរដោយ

ហេតុប៉ុណ្ណេះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយ ត្រូវការដោយភាពជាសមណៈហើយ អ្នកទាំងឡាយកុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[ ១០៧ ] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា ពួកយើងនឹងជាអ្នកប្រកបរឿយៗ ក្នុងការភ្ញាក់រឭក នឹងជម្រះចិត្តចាកពួកធម៌ដែលជាគ្រឿងរារាំង ដោយការចង្ក្រម ឬអង្គុយក្នុងវេលាថ្ងៃ នឹងជម្រះចិត្តចាកពួកធម៌ដែលជាគ្រឿងរារាំងដោយការចង្ក្រម ឬអង្គុយអស់បឋមយាមនៃរាត្រី នឹងសម្រេចសីហសេយ្យាសដោយបង្អៀងខាងស្តាំ អស់មជ្ឈិមយាមនៃរាត្រី នឹងតម្រួតជើងឆ្វេងលើជើងស្តាំ មានសតិ និងសម្បជញ្ញៈ ធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា ( គឺចំណាំពេលក្រោក ) រួចក្រោកឡើងក្នុងបច្ឆិមយាមនៃរាត្រី ជម្រះចិត្តចាកពួកធម៌ដែលជាគ្រឿងរារាំង ដោយការចង្ក្រម ឬអង្គុយ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិ និងឱត្តប្បៈ កាយសមាចាររបស់យើងបរិសុទ្ធហើយ វចីសមាចារបរិសុទ្ធហើយ មនោសមាចារបរិសុទ្ធហើយ អាជីវៈបរិសុទ្ធហើយ ពួកយើងជាអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយហើយ ពួកយើងជាអ្នកដឹងប្រមាណក្នុងភោជន ជាអ្នកប្រកបរឿយៗ ក្នុងកិរិយាភ្ញាក់រឭក កិច្ចដែលត្រូវធ្វើល្មមដោយហេតុត្រឹមប៉ុណ្ណេះហើយ ប្រយោជន៍របស់

សមណៈ ពួកយើងក៏បានដល់ដោយហេតុត្រឹមប៉ុណ្ណោះហើយ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀត របស់ពួកយើងមិនមានឡើយ ដូច្នេះហើយ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីត្រេកអរ ដោយហេតុប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតបំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយ ត្រូវការដោយភាពជាសមណៈហើយ អ្នកទាំងឡាយ កុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះកិច្ចដែលត្រូវធ្វើតទៅនៅមានទៀត ។

[ ១០៨ ] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា ពួកយើងនឹងជាអ្នកប្រកបដោយសតិ និងសម្បជញ្ញៈ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាឈានទៅមុខ និងឈានថយក្រោយ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាក្រឡេកមើលទៅមុខ និងក្រឡេកមើលមកក្រោយ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងការបត់អវយវៈ និងលាតអវយវៈ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកិរិយាទ្រទ្រង់សង្ឃាដិ បាត្រ ចីវរ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាឆាន់ ផឹក ទំពា ទទួលរស ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាបន្ទោបង់នូវឧច្ចារៈ និងបស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិរិយាដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយស្តី នៅស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងជាអ្នកប្រកបដោយហិរិ និងឱត្តប្បៈ កាយសមាចាររបស់ពួកយើងបរិសុទ្ធហើយ វចីសមាចារបរិសុទ្ធហើយ មនោសមាចារបរិសុទ្ធហើយ អាជីវៈ

បរិសុទ្ធហើយ ពួកយើងជាអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ហើយ ជាអ្នកដឹងនូវប្រមាណក្នុងភោជន ជាអ្នកប្រកបរឿយៗ ក្នុងការភ្ញាក់រឭក ប្រកបដោយសតិ និងសម្បជញ្ញៈ កិច្ចដែលត្រូវធ្វើល្មមដោយហេតុត្រឹមប៉ុណ្ណោះ ទាំងប្រយោជន៍របស់សមណៈ ពួកយើងក៏បានដល់ដោយហេតុត្រឹមប៉ុណ្ណោះ ហើយ កិច្ចបន្តិចបន្តួចត្រូវធ្វើតទៅទៀត របស់ពួកយើងមិនមានឡើយ ដូច្នេះ ហើយ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីត្រេកអរ ដោយហេតុប៉ុណ្ណោះពុំខាន ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគត បំភ្លឺអ្នកទាំងឡាយ កាលបើអ្នកទាំងឡាយ ត្រូវការដោយភាពជាសមណៈ ហើយ អ្នកទាំងឡាយ កុំលះបង់នូវប្រយោជន៍ជារបស់សមណៈឡើយ ព្រោះ កិច្ចដែលត្រូវធ្វើតទៅ នៅមានទៀត ។

[ ១០៩ ] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើតទៅទៀត ដូចម្តេច ខ្លះ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អាស្រ័យនូវសេនាសនៈស្ងាត់ គឺព្រៃ ទីជិតដើមឈើ ភ្នំ ច្រក ឬញកគុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ។ ភិក្ខុនោះត្រឡប់មកពីបិណ្ឌបាតវិញ វេលាខាងក្រោយភត្ត ក៏ អង្គុយពែនភ្នែនតាំងកាយឲ្យត្រង់ តម្កល់សតិឲ្យបែរមុខឆ្ពោះ ( ទៅរកព្រះកម្ម- ដ្ឋាន ) ។ ភិក្ខុនោះលះបង់នូវអភិជ្ឈាក្នុងលោក ជាអ្នកមានចិត្តប្រាសចាក អភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា។ លះបង់នូវព្យាបាទ និងសេចក្តីប្រទូស្ត មាន ចិត្តមិនព្យាបាទ ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះពួកសត្វមានជីវិត ទាំងពួង ជម្រះចិត្តចាកព្យាបាទ និងសេចក្តីប្រទូស្ត ។ លះបង់នូវថីនមិទ្ធៈ គឺ

មានថីនមិទ្ធៈទៅប្រាសហើយ មានអាលោកសញ្ញា ( គឺជាអ្នកមានសេចក្តីសម្គាល់នូវពន្លឺ ) មានសតិ និងសម្បជញ្ញៈ ជម្រះចិត្តចាកថីនមិទ្ធៈ ។ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈ គឺមិនមានចិត្តរាយមាយ មានចិត្តស្ងប់រម្ងាប់ក្នុងសន្តាន ជម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ ។ លះបង់នូវវិចិកិច្ឆា គឺមានវិចិកិច្ឆាឆ្លងផុតហើយ មិនបានសង្ស័យក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តចាកវិចិកិច្ឆា ។

[ ១១០ ] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសខ្ចីបំណុលគេ យកមកប្រកបការងារ ការងារទាំងនោះរបស់បុរសនោះ ក៏សម្រេច ។ បុរសនោះ ដោះថ្លៃបំណុលចាស់រួចស្រេចហើយ ក៏សល់ទ្រព្យចំណេញ ទុកបម្រុងចិញ្ចឹមប្រពន្ធ ( កូន ) តទៅ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលមុនអាត្មាអញខ្ចីបំណុលគេ យកមកប្រកបការងារ ការងារទាំងនោះ របស់អាត្មាអញនោះ ក៏បានសម្រេចហើយ អាត្មាអញនោះ ដោះថ្លៃបំណុលចាស់រួចស្រេចហើយ អាត្មាអញក៏សល់ទ្រព្យបំណុលទុកបម្រុងចិញ្ចឹមប្រពន្ធ ( កូន ) តទៅ ។ បុរសនោះ គប្បីបាននូវសេចក្តីរីករាយ ដល់នូវសេចក្តីសោមនស្ស ព្រោះរួចចាកបំណុលនោះជាហេតុ ( យ៉ាងណាមិញ ) ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសមានអាពាធ ដល់នូវទុក្ខឈឺខ្លាំង មិនឃ្លានបាយ មិនមានកម្លាំងក្នុងកាយ ។ ក្នុងសម័យខាងក្រោយតមក បុរសនោះ ក៏ស្បើយចាកអាពាធនោះ ឃ្លានបាយមានកម្លាំងកាយឡើងវិញ ។ បុរសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលមុនអាត្មាអញមានអាពាធ ដល់នូវសេចក្តីទុក្ខឈឺខ្លាំង មិនឃ្លានបាយ មិនមានកម្លាំងកាយសោះ ឥឡូវនេះ អាត្មាអញនោះស្បើយចាក

អាពាធនោះ ហ្វាទបាយមានកម្លាំងកាយឡើងវិញហើយ ។ បុរសនោះបាននូវសេចក្ដីរីករាយ ដល់នូវសោមនស្ស ព្រោះស្បើយចាកអាពាធនោះជាហេតុ ( យ៉ាងណាមិញ ) ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសជាប់ក្នុងផ្ទះឃុំខាំង ។ ក្នុងសម័យខាងក្រោយតមក បុរសនោះក៏រួចអំពីផ្ទះឃុំខាំង ដោយសួស្ដី ឥតមានភ័យ ទាំងសេចក្ដីវិនាស ដាច់ខាតកោតៈតិចតួចរបស់បុរសនោះ ក៏មិនមានឡើយ ។ បុរសនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលមុនអាត្មាអញជាប់ក្នុងផ្ទះឃុំខាំង ឥឡូវនេះ អាត្មាអញរួចពីផ្ទះឃុំខាំង ដោយសួស្ដី ឥតមានភ័យទាំងសេចក្ដីវិនាស ដាច់ខាតកោតៈតិចតួចរបស់អាត្មាអញ មិនមានឡើយ ។ បុរសនោះបាននូវសេចក្ដីរីករាយ ដល់នូវសេចក្ដីសោមនស្ស ព្រោះរួចអំពីផ្ទះឃុំខាំងនោះជាហេតុ ( យ៉ាងណាមិញ ) ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសខ្ញុំគេ មិនមានអំណាច គឺធ្វើអ្វីមិនបានតាមគាប់ចិត្តរបស់ខ្លួន អាស្រ័យនៅក្នុងអំណាចរបស់ជនដទៃ គឺប្រព្រឹត្តទៅតាមសេចក្ដីពេញចិត្ត របស់ជនដទៃ ចង់ទៅទីណា មិនបានតាមទំនើងចិត្តឡើយ ។ ក្នុងសម័យខាងក្រោយតមក បុរសនោះរួចចាកភាពជាខ្ញុំគេនោះ មានអំណាចដោយខ្លួនឯង មិនអាស្រ័យនៅក្នុងអំណាចរបស់ជនដទៃ ទៅជាអ្នកជា ចង់ទៅទីណាតាមទំនើងចិត្តរបស់ខ្លួនបាន ។ បុរសនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញជាខ្ញុំគេ មិនមានអំណាចដោយខ្លួនឯង អាស្រ័យនៅក្នុងអំណាចរបស់ជនដទៃ ចង់ទៅទីណាមិនបានតាមទំនើងចិត្តរបស់ខ្លួនឡើយ ឥឡូវនេះ អាត្មាអញនោះ រួចចាកភាពជាខ្ញុំគេនោះហើយ មានអំណាចដោយខ្លួនឯង មិនអាស្រ័យនៅក្នុងអំណាច

របស់ជនដទៃ បានជាអ្នកជា ចង់ទៅទីណាតាមទំនើងចិត្តរបស់ខ្លួនបាន ។ បុរសនោះបាននូវសេចក្តីរីករាយ ដល់នូវសេចក្តីសោមនស្ស ព្រោះរួចចាកភាពជាខ្ញុំគេនោះជាហេតុ ( យ៉ាងណាមិញ ) ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសមានទ្រព្យ មានភោគសម្បត្តិ ដើរទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ។ សម័យខាងក្រោយតមក បុរសនោះ ធ្វងផុតអំពីផ្លូវឆ្ងាយដាច់ស្រយាលនោះ ដោយសួស្តីឥតមានភ័យ ទាំងសេចក្តីវិនាស ដាច់ខាតភោគសម្បត្តិតិចតួច របស់បុរសនោះ ក៏មិនមានឡើយ ។ បុរសនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុនអាត្មាអញ មានទ្រព្យ មានភោគសម្បត្តិដើរទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ឥឡូវនេះអាត្មាអញ ធ្វងផុតអំពីផ្លូវឆ្ងាយដាច់ស្រយាលនោះ ដោយសួស្តីឥតមានភ័យហើយ ទាំងការដាច់ខាតភោគសម្បត្តិតិចតួច របស់អាត្មាអញក៏មិនមានឡើយ ។ បុរសនោះ បាននូវសេចក្តីរីករាយ ដល់នូវសេចក្តីសោមនស្ស ព្រោះដល់នូវទីក្សេមក្សាន្តនោះជាហេតុ ( យ៉ាងណាមិញ ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវនីវរណៈទាំង ៥ ប្រការនោះ មាននៅក្នុងខ្លួន ដែលខ្លួនមិនទាន់លះបង់ហើយថា ទុកដូចជាបំណុល ដូចជារោគ ដូចជាផ្ទះឃុំខាំង ដូចភាពជាខ្ញុំគេ ដូចជាផ្លូវឆ្ងាយដាច់ស្រយាលយ៉ាងនោះៗដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញនូវនីវរណៈទាំង ៥ ប្រការនេះ មាននៅក្នុងខ្លួន ដែលលះបង់បានហើយថា ទុកដូចជាភាពនៃបុរសដែលរួចចាកបំណុល ដូចជាបុរសមិនមានរោគ ដូចជាបុរសរួចអំពីផ្ទះឃុំខាំង ដូចជាបុរសរួចជាអ្នកជា ដូចជាបុរសដល់នូវទីក្សេមក្សាន្តយ៉ាងនោះៗ

ដែរ ។

[ ១១១ ] ភិក្ខុនោះលះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេស របស់ចិត្ត ជាធម្មជាតធ្វើបញ្ញាឲ្យមានកម្លាំងថយ ក៏ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន មាន វិតក្ក វិចារៈ បីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ ។ ភិក្ខុនោះ ញុំាង ករជកាយនេះឯង ឲ្យជោក ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយ បីតិ និងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃករជកាយ ទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់នោះគ្មាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជានហា-បកជន ឬ កូនសិស្សរបស់នហាបកជនដែលជាអ្នកឈ្លាស រោយរាយនូវ លម្អិតសម្រាប់ងូតក្នុងផ្តិលសំរិទ្ធិ ហើយស្រោចស្រប់ប្រឡប់ដោយទឹក ឯដុំ លម្អិតសម្រាប់ងូតនោះ ក៏រលាយទៅដោយទឹក ជ្រួតជ្រាបទៅក្នុងទឹក ប្រឡូក ប្រឡាំទៅដោយទឹក ទាំងខាងក្នុង ខាងក្រៅ មិនបានខ្ចាត់ខ្ចាយពីគ្នាឡើយ ដូច ម្តេចមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញុំាងករជកាយនេះឯងឲ្យជោក ឲ្យស្កប់ ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយបីតិ និងសុខ ដែលកើតអំពី សេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយបីតិ និងសុខដែលកើតអំពីសេចក្តីស្ងប់ ស្ងាត់នោះ គ្មាន ដូច្នោះឯង ។

[ ១១២ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុបានរម្ងាប់វិតក្ក វិចារៈ

រូបហើយ ក៏បានដល់ទុតិយជ្ឈាន ជាទីជ្រះថ្លាក្នុងសន្តាន មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កវិចារៈទេ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិប៉ុណ្ណោះ ។ ភិក្ខុនោះញុំាងករជកាយនេះឯងឲ្យជោក ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយបីតិ និងសុខ ដែលកើតអំពីសមាធិ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយបីតិ និងសុខដែលកើតអំពីសមាធិនោះ គ្មាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាអន្លង់ទឹកដ៏ជ្រៅ មានទឹកជោរឡើង មុខទឹកក្នុងទិសខាងកើតនោះ មិនមានឡើយ ទាំងមុខទឹកក្នុងទិសខាងលិច ក៏មិនមាន មុខទឹកក្នុងទិសខាងជើងក៏មិនមាន មុខទឹកក្នុងទិសខាងត្បូងក៏មិនមាន កាលបើភ្លៀងបង្អុរធារទឹកស្រួលសព្វៗកាលទៅ ក៏ស្រោច់តែទឹកត្រជាក់ជោរឡើង អំពីអន្លង់ទឹកនោះ ហើយញុំាងអន្លង់ទឹកនោះឯង ឲ្យជោកជាំ ឲ្យពេញពោរ ឲ្យពេញប្រៀប ឲ្យហូរហៀរដោយទឹកត្រជាក់ ( នោះ ) ប្រទេសបន្តិចបន្តួចនៃអន្លង់ទឹកទាំងអស់នោះ ដែលឈ្មោះថា មិនហូរហៀរដោយទឹកត្រជាក់នោះ គ្មាន ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញុំាងករជកាយនេះឲ្យជោក ឲ្យស្កប់ស្កល់ ឲ្យពេញលេញឲ្យផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសមាធិ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយបីតិនិងសុខ ដែលកើតអំពីសមាធិនោះ គ្មាន ដូច្នោះដែរ ។

[ ១១៣ ] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ភិក្ខុព្រោះប្រាសចាកបីតិផង ប្រកបដោយឧបេក្ខាផង មានសតិ និងសម្បជញ្ញៈផង សោយទូវ

សេចក្តីសុខដោយនាមកាយផង បានដល់តតិយជ្ឈាន ដែលព្រះអរិយៈទាំង-ឡាយ តែងប្រាប់នូវភិក្ខុអ្នកបានតតិយជ្ឈាននោះ ថាជាអ្នកមានឧបេក្ខា មានសតិនៅជាសុខ ដូច្នេះ ។ ភិក្ខុនោះញ៉ាំងករជកាយនេះឯង ឲ្យជោក ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយសេចក្តីសុខ ដែលប្រាសចាកបីតិ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយ ដោយសុខដែលប្រាសចាកបីតិនោះ គ្មាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងគុម្ពព្រលិតក្តី ក្នុងគុម្ពឈូកក្រហមក្តី ក្នុងគុម្ពឈូកសក្តី តែងដុះក្នុងទឹក ចម្រើនក្នុងទឹក លូតលាស់តាមទឹក លិចនៅក្នុងទឹក ជោកជាំ ឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយដោយទឹកត្រជាក់ រហូតដល់ចុង រហូតដល់គល់ ប្រទេសបន្តិចបន្តួចនៃជលជាតិទាំងអស់ គឺព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយទឹកត្រជាក់នោះ គ្មាន ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញ៉ាំងករជកាយនេះឯង ឲ្យជោក ឲ្យឆ្អែតស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយសុខដែលមិនមានបីតិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយសុខ ដែលមិនមានបីតិនោះ គ្មាន ដូច្នោះឯង ។

[ ១១៨ ] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ភិក្ខុព្រោះលះបង់នូវសេចក្តីសុខផង លះបង់នូវសេចក្តីទុក្ខផង រម្ងត់នូវសោមនស្ស និងទោមនស្សទាំងឡាយក្នុងកាលមុនផង ហើយក៏ដល់នូវចតុត្ថជ្ឈាន មិនទុក្ខមិនសុខ មាន

សតិដ៏បរិសុទ្ធដោយឧបេក្ខា ។ ភិក្ខុនោះរមែងញ៉ាំងករជកាយនេះឯង ឲ្យផ្សព្វ-ផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់ អង្គុយនៅ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយចិត្ត ដ៏បរិសុទ្ធផូរផង់នោះ គ្មាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសយកសំពត់ស ដណ្តប់កាយព្រមទាំងក្បាលអង្គុយនៅ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់បុរសនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយសំពត់សនោះ គ្មាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយភិក្ខុញ៉ាំងករជកាយនេះឯង ឲ្យផ្សព្វផ្សាយដោយចិត្ត ដ៏ស្អាតផូរផង់អង្គុយនៅ ប្រទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់នោះ គ្មាន យ៉ាងនោះដែរ ។

[ ១១៥ ] កាលបើចិត្តខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេសប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់គួរដល់ការនៃកម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ ភិក្ខុនោះក៏រឭកឃើញនូវខន្ធ ដែលធ្លាប់អាស្រ័យនៅមកពីមុនជាច្រើនដូចម្តេច គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកនូវខន្ធដែលសត្វធ្លាប់អាស្រ័យនៅ អំពីមុនជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសចេញអំពីស្រុករបស់ខ្លួន ទៅកាន់ស្រុកដទៃ ចេញអំពីស្រុកនោះ ទៅកាន់ស្រុកដទៃទៀត ត្រឡប់ពីស្រុកនោះមកកាន់ស្រុករបស់ខ្លួនវិញ បុរសនោះក៏រឭក

ឃើញយ៉ាងនេះថា អាត្មាអញចេញពីស្រុករបស់ខ្លួន បានទៅកាន់ស្រុកឯណោះ ដែលទៅដល់ស្រុកនោះ អាត្មាអញបានឈរយ៉ាងនេះ អង្គុយយ៉ាងនេះ និយាយយ៉ាងនេះ នៅស្ងៀមយ៉ាងនេះ លុះអាត្មាអញចេញពីស្រុកនោះ បានទៅកាន់ស្រុកឯណោះទៀត ដែលទៅដល់ស្រុកនោះ អាត្មាអញបានឈរយ៉ាងនេះ អង្គុយយ៉ាងនេះ និយាយយ៉ាងនេះ នៅស្ងៀមយ៉ាងនេះ ឥឡូវនេះ អាត្មាអញនោះ ចេញពីស្រុកនោះ ត្រឡប់មកកាន់ស្រុករបស់ខ្លួនវិញហើយ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុរឭកបាននូវខន្ធដែលធ្លាប់អាស្រ័យនៅមកពីមុន ជាច្រើនដូចម្តេច គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកនូវខន្ធដែលធ្លាប់អាស្រ័យនៅអំពីមុនជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ យ៉ាងនោះឯង ។

[ ១១៦ ] កាលបើចិត្តខាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រដោយអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅ ដើម្បីសត្តចុតូបបាតញ្ញាណ ។ ភិក្ខុនោះ មានចក្ខុជាទិព្វ ដ៏បរិសុទ្ធកន្លងចក្ខុរបស់មនុស្សជាធម្មតា រមែងឃើញនូវសត្វទាំងឡាយកំពុងច្យុត កំពុងកើតឡើង ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។បេ។ ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាផ្ទះពីរខ្នង មានទ្វារទល់មុខគ្នា បុរសដែលមានចក្ខុឈរនៅត្រង់កណ្តាលផ្ទះនោះ រមែងឃើញនូវពួកមនុស្ស កំពុងចូលទៅកាន់

ផ្ទះខ្លះ ចេញពីផ្ទះខ្លះ ដើរទៅមកខ្លះ ដើរហែៗ គ្នាខ្លះ ដើរប្រទាក់គ្នាខ្លះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធកន្លងនូវចក្ខុជារបស់មនុស្សធម្មតា រមែងឃើញនូវសត្វទាំងឡាយ កំពុងច្យុត កំពុងកើតឡើង ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។បេ។ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន យ៉ាងនោះដែរ ។

[ ១១៧ ] កាលបើចិត្តខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេសប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រដោយអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ គឺប្រាជ្ញាដឹងនូវធម៌ជាគ្រឿងក្ស័យនៃអាសវៈទាំង-ឡាយ ។ ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាឧបាយដើម្បីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាផ្លូវសម្រាប់ដើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាឧបាយដើម្បីរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះជាផ្លូវសម្រាប់ដើរទៅកាន់ឧបាយដើម្បីរលត់អាសវៈ ។ កាលភិក្ខុនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈផង កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តរបស់អាត្មាអញផុតស្រឡះ

ហើយ ដឹងច្បាស់ថា កំណើតអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាន ប្រព្រឹត្តហើយ សោឡសកិច្ច អាត្មាអញក៏បានធ្វើស្រេចហើយ កិច្ចដទៃប្រព្រឹត្ត ទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូច ជាអន្លង់ទឹកលើកំពូលភ្នំ ដែលថ្លាស្អាត ឥតមានកករល្អក់ បុរសម្នាក់មានចក្ខុ ឈរទៀបឆ្នេរ គប្បីមើលឃើញនូវខ្យង និងគ្រំខ្លះ ដុំក្រួស និងដុំថ្មខ្លះ នូវហ្វូង ត្រីដែលកំពុងសំកាំងខ្លះ ហែលទៅមកខ្លះ ក្នុងអន្លង់ទឹកនោះ ។ បុរសនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អន្លង់ទឹកនេះឯងថ្លាស្អាត ឥតមានកករល្អក់ ខ្យង និងគ្រំទាំងនេះក្តី ដុំក្រួស និងដុំថ្មទាំងនេះក្តី ហ្វូងត្រីទាំងនេះ កំពុងសំកាំង ខ្លះ ហែលទៅមកខ្លះក្តី ក្នុងអន្លង់ទឹកនោះយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។បេ។ ដឹងច្បាស់ថា កិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៅទៀតមិនមាន ក៏យ៉ាងនោះដែរ ។

[ ១១៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគតហៅថា សមណៈក៏បាន ថាព្រាហ្មណ៍ក៏បាន ថានហាតកៈក៏បាន ថាវេទគូក៏បាន ថាសោត្ថិយៈក៏បាន ថាអរិយៈក៏បាន ថាអរហន្តក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា សមណៈតើដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តី សៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រកបដោយសេចក្តីក្រវល់ ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុង ខាងមុខ ភិក្ខុនោះបានរម្ងាប់ហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថា សមណៈ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា ព្រាហ្មណ៍

តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ភិក្ខុនោះបានបន្សាត់ចោលហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថា ព្រាហ្មណ៍ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា នហាតកៈ តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រព្រឹត្តទៅ មួយអន្លើដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ភិក្ខុនោះបានជម្រះចេញហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថា នហាតកៈ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថាវេទគូ តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រព្រឹត្តទៅ មួយអន្លើដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ភិក្ខុនោះបានដឹងច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថាវេទគូ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថា សោត្ថិយៈ តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រព្រឹត្តទៅមួយអន្លើដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ

ប្រព្រឹត្តទៅក្នុងខាងមុខ ភិក្ខុនោះមិនបានទទឹកហើយ ( ដោយចិត្ត ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថាសោត្ថិយៈ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុដែលឈ្មោះថាអរិយៈ តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រព្រឹត្តទៅ មួយអន្លើដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ជាកិលេសឆ្ងាយអំពីភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថាអរិយៈ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថាអរហន្ត តើដោយប្រការដូចម្តេច ។ អកុសលធម៌ទាំងឡាយដ៏លាមក ប្រកបដោយសេចក្តីសៅហ្មង ធ្វើសត្វឲ្យកើតក្នុងភពថ្មីទៀត ជាធម៌ប្រព្រឹត្តទៅមួយអន្លើដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាវិបាក ប្រកបដោយជាតិ ជរា មរណៈ ប្រព្រឹត្តទៅក្នុងខាងមុខ ជាកិលេសឆ្ងាយអំពីភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលឈ្មោះថាអរហន្ត ដោយប្រការដូច្នេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរហើយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

មហាអស្សបុរសូត្រទី ៩ ចប់

# អដ្ឋកថា

## មហាអស្សបុរសូត្រ

[ ៩៩ ] មហាអស្សបុរសូត្រ មានបទផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងមហាអស្សបុរសូត្រនោះ បទថា **អង្គេសុ** បានដល់ ពួកអ្នកដែនជនបទ ឈ្មោះអង្គៈ ។ ទីនៅប្រថាប់នៃស្តេចអង្គៈទាំងនោះ សូម្បីជាជនបទមួយ ក៏ហៅថា អង្គា ដូច្នេះ, ព្រោះ សព្ទ ពង្រីកសេចក្តីដល់ក្នុងអង្គជនបទនោះ ។ បទថា **អស្សបុរំ នាម អង្គានំ និគមោ** សេចក្តីថា និគមមួយនៃអង្គជនបទ មានវោហារដែលបានហើយ ដោយឈ្មោះក្រុងថា **អស្សបុរៈ** អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់ធ្វើនិគមនោះឲ្យជាគោចរគ្រាមហើយប្រថាប់នៅ ។ បទថា **ភគវា ឯតទវោច** សេចក្តីថា ព្រះមានព្រះភាគ បានត្រាស់ពុទ្ធវចនៈថា ម្នាលភិក្ខុទាំងឡាយ អ្នកផងតែងស្គាល់ច្បាស់នូវអ្នកទាំងឡាយ ថាជាសមណៈៗ ដូច្នេះជាដើម ។

ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។ បានឮថា ក្នុងនិគមនោះ មនុស្សទាំងឡាយមានសទ្ធាជ្រះថ្លា មានការរាប់អានព្រះពុទ្ធថា ជារបស់អញ រាប់អានព្រះធម៌ថា ជារបស់អញ រាប់អានព្រះសង្ឃថា ជារបស់អញ សូម្បីឃើញសាមណេរដែលបួសក្នុងថ្ងៃនោះ ក៏ធ្វើឲ្យដូចជាព្រះថេរៈមានវស្សារាប់រយ ។ ពួកអ្នកស្រុកទាំងនោះ ឃើញភិក្ខុសង្ឃចូលទៅបិណ្ឌ-បាតក្នុងវេលាព្រឹក សូម្បីកាន់ពូជ និងនង្គ័លជាដើមទៅកាន់ស្រែ កាន់វត្ថុ មានពូថៅជាដើមចូលទៅកាន់ព្រៃ ក៏ដាក់ឧបករណ៍ទាំងនោះ ហើយបោសសម្អាតទី

សម្រាប់គន់របស់ភិក្ខុសង្ឃ ឬអាសនៈសាលា មណ្ឌប គល់ឈើ ហើយក្រាលអាសនៈទាំងឡាយ រៀបជើងបាត្រ និងទឹកផឹក ហើយនិមន្តឲ្យភិក្ខុសង្ឃគង់ ប្រគេនបបរ និងខាទនីយៈជាដើម បញ្ចូនភិក្ខុសង្ឃដែលធ្វើភត្តកិច្ចស្រេចហើយទៅ ទើបកាន់ឧបករណ៍ទាំងឡាយនោះ អំពីទីនោះ ទៅកាន់ស្រែ ឬព្រៃធ្វើការងារទាំងឡាយរបស់ខ្លួន ។ ក្នុងទីធ្វើការងារ ពួកគាត់ក៏មិននិយាយគ្នាដទៃ ពួកគាត់ទាំងនោះ រមែងពោលគុណរបស់ភិក្ខុសង្ឃនោះឯង ។ ដោយពាក្យថា បុគ្គល ៨ គឺបុគ្គលតាំងនៅក្នុងមគ្គ ៤ ឈ្មោះថា អរិយសង្ឃ ព្រះអរិយសង្ឃទាំងនោះ ប្រកបដោយសីលយ៉ាងនេះ ដោយអាចារបែបនេះ ដោយបដិបត្តិបែបនេះ ជាអ្នកខ្មាស ជាអ្នកមានសីលជាទីស្រឡាញ់ ជាអ្នកមានគុណដ៏ឧត្តមយ៉ាងនេះ មកអំពីទីធ្វើការហើយ បរិភោគអាហារល្ងាចហើយអង្គុយត្រង់ទ្វារផ្ទះក្តី ចូលទៅបន្ទប់ដេក អង្គុយហើយក្តី រមែងពោលគុណរបស់ភិក្ខុសង្ឃនោះឯង ។ ព្រះមានព្រះភាគ ទ្រង់ឃើញការរាប់អានរបស់ពួកមនុស្សទាំងនោះហើយ ទ្រង់ប្រកបភិក្ខុសង្ឃទុកក្នុងការគោរពក្នុងបិណ្ឌ-បាត ទើបបានត្រាស់ព្រះតម្រាស់នោះ ។

បទថា **យេ ធម្មា សមណករណា ច ព្រាហ្មណករណា ច** សេចក្តីថា ធម៌ឯណាដែលបុគ្គលសមាទានឲ្យបរិបូណ៌ហើយ រមែងធ្វើឲ្យជាសមណៈមានបាបស្ងប់ហើយ និងឲ្យជាព្រាហ្មណ៍មានបាបបន្សាត់ហើយ ដូច្នេះ ព្រះមានព្រះភាគត្រាស់ធម៌ដែលសមណៈគួរធ្វើក្នុងសេចក្តីនេះថា ម្នាលភិក្ខុទាំង-ឡាយ កិច្ចនៃសមណៈដែលសមណៈគប្បីធ្វើទាំងនេះ មាន ៣ យ៉ាង កិច្ច ៣

យ៉ាងនោះដូចម្តេច គឺការសមាទានអធិសីលសិក្ខា ១ ការសមាទានអធិចិត្ត-សិក្ខា ១ ការសមាទានអធិប្បញ្ញាសិក្ខា ១ ដូច្នេះ ។ សូម្បីធម៌ទាំងនោះ ក៏ឈ្មោះថា ជាធម៌ធ្វើឲ្យជាសមណៈដូចគ្នា ។ តែក្នុងទីនេះ ព្រះមានព្រះភាគឲ្យទេសនាពិស្តារហើយ ដោយអំណាចហិរិ និងឱត្តប្បៈជាដើម ។

ក្នុងបទថា **ឯវំ នោ អយំ អម្ហាកំ** នេះ បទថា **នោ** ត្រឹមជានិបាត អធិប្បាយថា ធម៌នេះ នឹងមានដល់ពួកយើងដោយអាការយ៉ាងនេះ ។ សូម្បីបទទាំង ២ គឺ **មហាប្ផលា** និង **មហានិសំសា** ពោលដោយអត្ថដូចគ្នាតែមួយ ។ បទថា **អវញ្ឈា** បានដល់ មិនជាមោឃៈ ។ បទថា **សផលា** សេចក្តីនេះ មានអត្ថដូចគ្នានឹងអមោឃៈនោះឯង ។ ពិតហើយ ផលនៃការមិនប្រកបព្យាយាមមិនមានផលនោះ ឈ្មោះថា មានទោស ។ បទថា **សឧទ្រយា** ប្រែថា មានកម្រៃ ពាក្យនេះជាវេវចនៈគ្នា ព្រោះមានផល ។ បទថា **ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ** ប្រែថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកគប្បីសិក្សាយ៉ាងនេះ ។

[ ១០០ ] ព្រះមានព្រះភាគត្រាស់សរសើរធម៌ មានហិរិ និងឱត្តប្បៈជាដើមដោយឋានៈមានប្រមាណប៉ុណ្ណេះ ដោយប្រការដូច្នេះ ។ ព្រោះហេតុអ្វី ព្រោះដើម្បីកាត់គន្លងនៃវាចា ។ ពិតហើយ បើបុគ្គលណាមួយ បួសមិនយូរជាភិក្ខុល្ងង់ គប្បីពោលយ៉ាងនេះថា ព្រះមានព្រះភាគត្រាស់ថា ពួកអ្នកសមាទានធម៌ មានហិរិ និងឱត្តប្បៈជាដើម ហើយប្រព្រឹត្តដូច្នេះ អ្វីហ្ន៎ជាអានិសង្សក្នុងការសមាទានធម៌ទាំងនោះ ប្រព្រឹត្តដើម្បីកាត់គន្លងនៃវាទៈរបស់

ភិក្ខុនោះ ។ ទើបព្រះមានព្រះភាគទ្រង់សរសើរថា ធម៌ទាំងនេះ បុគ្គលសមាទាន ធ្វើឲ្យបរិបូណ៌ហើយ រមែងធ្វើឲ្យមានឈ្មោះថាសមណៈ ដែលមានបាបស្ងប់ហើយ ឲ្យមានឈ្មោះថាព្រាហ្មណ៍ ដែលបន្សាត់បាបហើយ ទាំងឲ្យកើតលាភ គឺបច្ច័យ ៤ រមែងញុំាងការមានផលច្រើន ឲ្យដល់ព្រមដល់បុគ្គលដែលឲ្យបច្ច័យ រមែងធ្វើបព្វជ្ជាមិនឲ្យសោះសូន្យ ឲ្យមានផល ឲ្យមានកម្រៃ នេះជាអានិសង្សនេះ ។ គប្បីជ្រាបអត្ថដោយសង្ខេបក្នុងទីនេះត្រឹមប៉ុណ្ណោះ តែដោយពិស្តារ គប្បីជ្រាបការពោលសរសើរដោយន័យដែលពោលក្នុងសតិប្បដ្ឋាន ។

បទថា **ហិរោត្តប្បេន** បានដល់ ដោយហិរិ និងឱត្តប្បៈ ដែលលោកពន្រឹកចេញទៅយ៉ាងនេះថា វត្ថុណាដែលបុគ្គលគួរខ្មាស រមែងខ្មាស វត្ថុណាដែលបុគ្គលគួរខ្លាច រមែងខ្លាច ដូច្នេះ ម្យ៉ាងទៀត ក្នុងសេចក្ដីនេះ ហិរិមានវត្ថុខាងក្នុងជាសមុដ្ឋាន ឱត្តប្បៈមានវត្ថុខាងក្រៅជាសមុដ្ឋាន ហិរិជាអត្តាធិបតេយ្យ ឱត្តប្បៈជាលោកាធិប្បតេយ្យ ។ ហិរិតាំងនៅក្នុងសភាពនៃការខ្មាស ឱត្តប្បៈតាំងនៅក្នុងសភាពខ្លាច ។ កថាពិស្ដារក្នុងធម៌ទាំង ២ នេះ បានពោលហើយ ក្នុងវិសុទ្ធិមគ្គដោយអាការទាំងពួង ។

ម្យ៉ាងទៀត ធម៌ទាំង ២ នេះ ព្រះមានព្រះភាគត្រាស់ថា ឈ្មោះថា ធម៌ជាគ្រឿងគ្រប់គ្រងលោក ព្រោះរក្សាលោក ។ ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សុខធម៌ទាំង ២ នេះ រមែងគ្រប់គ្រងលោក សុខធម៌ ២ យ៉ាងដូចម្ដេច គឺហិរិ និងឱត្តប្បៈ ម្នាលភិក្ខុទាំងឡាយ ( បើ ) ធម៌សទាំងឡាយ ២ ប្រការនេះ មិនរក្សាទុកនូវសត្វលោកទេ ត្រង់ពាក្យថា មាតា

ក្តី ថាម្តាយមីងក្តី ថាម្តាយធំក្តី ថាភរិយារបស់អាចារ្យក្តី ថាប្រពន្ធរបស់គ្រូក្តី មិនប្រាកដក្នុងលោកនេះឡើយ សត្វលោកនឹងដល់នូវការច្រឡូកច្រឡំដូចសត្វពពែ ចៀម មាន់ ជ្រូក សុនខ និងចចកទាំងឡាយ ។ ធម៌ទាំងនេះឯងព្រះមានព្រះភាគ ត្រាស់ទុកក្នុងជាតកថា ជាទេវធម៌ ដូចព្រះតម្រាស់ថា

**ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា**
**សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ ។**

ប្រែថា ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយហិរិ និងឱត្តប្បៈ តាំងមាំហើយក្នុងធម៌ស លោកពោលថាមានទេវធម៌ក្នុងលោក ដូច្នេះ ។

ហិរិ និងឱត្តប្បៈ ធម៌ទាំងនេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ព្រះមហាចុន្ទត្ថេរថា ជាបដិបទាគ្រឿងជុសខាត់កិលេស ។ ដូចដែលត្រាស់ថា ពួកអ្នកត្រូវធ្វើនូវសេចក្តីជួរផង់យ៉ាងនេះថា ជនទាំងឡាយដទៃ នឹងមិនខ្មាសបាបក្នុងវត្ថុណា ពួកយើងនឹងមានចិត្តខ្មាសបាបក្នុងវត្ថុនោះ ដូច្នេះ ។ ឯធម៌គឺហិរិ និងឱត្តប្បៈទាំងនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងសម្រាប់ធ្វើឲ្យជាឱវាទូបសម្បទា ពិតហើយ ព្រះមានព្រះភាគត្រាស់ថា ម្នាលកស្សប ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា ហិរិ និងឱត្តប្បៈដ៏ក្លៀវក្លា អាត្មាអញបានតម្កល់ទុកក្នុងភិក្ខុចាស់ទាំងឡាយ ក្នុងភិក្ខុថ្មីទាំងឡាយ ក្នុងភិក្ខុកណ្តាលទាំងឡាយ ម្នាលកស្សប អ្នកគួរសិក្សាយ៉ាងនេះឯង ។ តែក្នុងទីនេះ ព្រះមានព្រះភាគទ្រង់សម្តែងធម៌ គឺហិរិ និងឱត្តប្បៈទាំងនេះថា

ឈ្មោះថា ជាសមណធម៌ ។ ព្រោះប្រយោជន៍នៃភាពជាសមណៈ រមែងមិនដល់នូវទីបំផុត ដោយធម៌មានប្រមាណប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះមានព្រះភាគដើម្បីសម្តែងធម៌ដែលធ្វើភាពជាសមណៈដទៃៗ ទៀត ទើបត្រាស់ពាក្យថា **សិយា ខោ បន ភិក្ខវេ តុម្ហាកំ** ជាដើម ។ បណ្តាបទទាំងនោះ ក្នុងបទថា **សាមញ្ញត្ថោ** ជាបឋម ក្នុងគម្ពីរសំយុត្តនិកាយ ទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ចុះសាមញ្ញគុណ តើដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ នេះឯង ។ គឺអ្វីខ្លះ ។ សេចក្តីឃើញត្រូវ ១ ។បេ។ សេចក្តីតាំងចិត្តត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សាមញ្ញគុណ ។ ម្នាលភិក្ខុទាំងឡាយ ចុះប្រយោជន៍នៃសាមញ្ញគុណ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ សភាវៈឯណាជាទីអស់ទៅនៃរាគៈ ជាទីអស់ទៅនៃទោសៈ ជាទីអស់ទៅនៃមោហៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ប្រយោជន៍នៃសាមញ្ញគុណ ។ មគ្គ លោកហៅថា សាមញ្ញ, ផល និងនិព្វាន លោកហៅថា ប្រយោជន៍នៃសាមញ្ញ ។ តែក្នុងទីនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ថា ប្រយោជន៍នៃសាមញ្ញ ព្រោះរួមទាំងមគ្គ និងផលចូលជាមួយគ្នា ។

[ ១០១ ] បទថា **អារោចយាមិ** ប្រែថា រមែងប្រាប់ ។ បទថា **បដិវេទយាមិ** បានដល់ ដាស់តឿនឲ្យដឹង ។

[ ១០២ ] ក្នុងបទថា **បរិសុទ្ធោ នោ កាយសមាចារោ** នេះ បាដល់កាយសមាចារ ២ យ៉ាង គឺបរិសុទ្ធ និងមិនបរិសុទ្ធ ។ ពិតហើយ ភិក្ខុណាសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាម កាយ-

សមាចារនៃភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធ ។ កាយសមាចារនេះ លោកហាមដោយភាពជាកម្មបថ ។ ភិក្ខុណារមែងវាយ រមែងបៀតបៀនអ្នកដទៃដោយបាតដៃ ដុំដី កំណាត់ឈើ ឬដោយសស្ត្រា កាយសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធ ។ កាយសមាចារនេះ លោកហាមទុកដោយទាក់ទងនឹងសិក្ខាបទនោះឯង ក្នុងសូត្រនេះ ព្រះមានព្រះភាគ មិនត្រាស់សេចក្ដីទាំង ២ ត្រាស់ត្រឹមតែឈ្មោះថា ជាធម៌ដុសខាត់យ៉ាងក្រៃលែង ។

ពិតហើយ ភិក្ខុណាងាទូវដុំដី ឬដំបង ដោយដេញក្អែកទាំងឡាយដែលផឹកទឹកក្នុងក្អម ឬចឹកស៊ីបាយក្នុងបាត្រ កាយសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធ ។ ផ្ទុយគ្នាដូចដែលពោលមកនេះ ឈ្មោះថា សមាចារបរិសុទ្ធ ។

[ ១០៣ ] បទថា **ឧត្តានោ** បានដល់ ឡើងទៅហើយ គឺប្រាកដហើយ ។ បទថា **វិវដោ** បានដល់ បើកផ្ការ គឺមិនបិទបាំង រមែងសម្ដែងសេចក្ដីបរិសុទ្ធដោយធម៌ទាំង ២ នោះឯង ។ បទថា **ន ច ឆិទ្ទវា** បានដល់ ដូចគ្នាក្នុងកាលគ្រប់កាល គឺមិនមានឱកាសក្នុងចន្លោះៗ ។ បទថា **សំវុតោ** បានដល់ បិទហើយដោយគ្រឿងបិទកិលេសទាំងឡាយ មិនមែនបិទបាំងទោស ។

ក្នុងវចីសមាចារ ភិក្ខុណាពោលកុហក ពោលញុះញង់ ពោលពាក្យគ្រោតគ្រាត ពោលពាក្យផ្ដេសផ្ដាស វចីសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធ ។ វចីសមាចារនេះ លោកហាមដោយកម្មបថហើយ ។ ភិក្ខុណាកាលពោលមើលងាយដោយពាក្យទាំងឡាយ មានពាក្យថា គហបតី ឬថា

ទាសៈ ឬអ្នកបម្រើជាដើម វចីសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធ ។ វចីសមាចារនេះ លោកហាមទាក់ទងដោយសិក្ខាបទ ក្នុងសូត្រនេះ ព្រះមានព្រះភាគ មិនត្រាស់វចីសមាចារទាំង ២ នោះទេ ត្រាស់តែឈ្មោះជាធម៌ដុសខាត់យ៉ាងក្រៃលែង ។

កាលភិក្ខុកំលោះ ឬសាមណេរពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយឃើញឧបជ្ឈាយ៍របស់ខ្ញុំដែរឬ ដូច្នេះ ភិក្ខុណា ទោះជាមានបំណងដើម្បីសើចលេង ពោលពាក្យបែបនេះ ដោយន័យជាដើមថា នែអាវុសោ ភិក្ខុនីច្រើនរូបនៅក្នុងទីនេះ ព្រះឧបជ្ឈាយ៍របស់ពួកលោកបានទៅជួយលើកកញ្ចប់ដាក់បន្ទែលក់ ដូច្នេះ វចីសមាចាររបស់ភិក្ខុនោះ មិនបរិសុទ្ធ ។ វចីសមាចារដែលផ្ទុយគ្នាដូចពោលមកនេះ ឈ្មោះថា បរិសុទ្ធ ។

ក្នុងមនោសមាចារ ភិក្ខុណាជាអ្នកមានអភិជ្ឈា មានចិត្តព្យាបាទ ជាអ្នកមានការយល់ខុស មនោសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធ ។ មនោសមាចារនេះ លោកហាមហើយក្នុងកម្មបថ ។ ភិក្ខុណា ត្រេកអរនូវមាស និងប្រាក់ដែលគេទុកដាក់ដើម្បីខ្លួន មនោសមាចាររបស់ភិក្ខុនោះឈ្មោះថា មិនបរិសុទ្ធ ។ មនោសមាចារនេះ ក៏ហាមហើយក្នុងសិក្ខាបទ ក្នុងសូត្រនេះ មិនត្រាស់ដល់មនោសមាចារទាំង ២ នោះទេ ដោយត្រាស់តែធម៌ដែលដុសខាត់យ៉ាងក្រៃលែង ។ ភិក្ខុណា ត្រិះរិះដល់កាមវិតក្កៈ ព្យាបាទវិតក្កៈ វិហិង្សាវិតក្កៈ មនោសមាចាររបស់ភិក្ខុនោះ ឈ្មោះថា មិនបរិសុទ្ធ ។ មនោសមាចារដែលផ្ទុយគ្នា ឈ្មោះថា បរិសុទ្ធ ។

ក្នុងអាជីវៈ ភិក្ខុណា ព្រោះអាជីវៈជាហេតុ ចិញ្ចឹមជីវិតដោយអំណាចអនេសនា ២១ ដូចជាធ្វើវេជ្ជកម្ម ទទួលវះបូស ឲ្យប្រេងលាបជើង ស្លប្រេងជាដើម ឬភិក្ខុណា ធ្វើវិញ្ញត្តិបរិភោគ អាជីវៈរបស់ភិក្ខុនោះ ឈ្មោះថាមិនបរិសុទ្ធ ។ អាជីវៈដែលមិនបរិសុទ្ធនេះ លោកហាមទាក់ទងដោយសិក្ខាបទ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ មិនត្រាស់ដល់អាជីវៈដែលមិនបរិសុទ្ធទាំង ២ ត្រាស់តែធម៌ដែលជុសខាត់កិលេសក្រៃលែង ។

ពិតហើយ ភិក្ខុណាបានសប្បិ ទធិ ប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើមហើយគិតថា នឹងឆាន់ថ្ងៃស្អែក ឬក្នុងថ្ងៃខានស្អែក ហើយឆាន់វត្ថុដែលសន្សំទុកក្ដីភិក្ខុណាឃើញបាច់ស្ពៅជាដើមហើយ ពោលនឹងពួកសាមណេរថា ពួកអ្នកចូរទំពាស៊ីបាច់ស្ពៅដូច្នេះក្ដី ។ ពួកសាមណេរគិតថា ព្រះថេរៈប្រហែលជាចង់បរិភោគ ទើបធ្វើឲ្យជាកប្បិយ ហើយប្រគេន ។ ភិក្ខុពោលនឹងភិក្ខុកំលោះ ឬសាមណេរថា នែអាវុសោ ពួកអ្នកចូរផឹកទឹកដូច្នេះ ។ ភិក្ខុកំលោះ ឬសាមណេរទាំងនោះគិតថា ព្រះថេរៈត្រូវការផឹកទឹក ទើបធ្វើទឹកនោះឲ្យស្អាតហើយប្រគេន ។ អាជីវៈរបស់ភិក្ខុដែលបរិភោគទឹកនោះជាដើមឈ្មោះថា មិនបរិសុទ្ធ ។ អាជីវៈដែលផុយគ្នានឹងពោលមកហើយ ឈ្មោះថា បរិសុទ្ធ ។

[ ១០៦ ] បទថា **មត្តញ្ញូ** បានដល់ ជាអ្នកស្គាល់ប្រមាណ ស្គាល់សមគួរ ស្គាល់ល្មមក្នុងការស្វែងរក ការទទួល និងការបរិភោគ ។

[ ១០៧ ] បទថា **ជាគរិយមនុយុត្តា** បានដល់ ធ្វើការចែកពេលយប់និងពេលថ្ងៃឲ្យជា ៦ ចំណែក ហើយធ្វើឱកាសដើម្បីនិទ្រាមួយចំណែក ប្រកប

ការខ្វល់ខ្វាយហើយក្នុងធម៌ជាគ្រឿងភ្ញាក់រឭក ៥ ចំណែក ។ ក្នុងបទថា **សីហសេយ្យំ** នេះ បានដល់ ការដេក ៤ យ៉ាងគឺ **កាមភោគិសេយ្យា បេតសេយ្យា សីហសេយ្យា តថាគតសេយ្យា** ។ ក្នុងបណ្ដាការដេកទាំងនោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកបរិភោគកាមច្រើនតែដេកផ្អៀងទៅខាងឆ្វេង ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណេកអ្នកបរិភោគកាម ពិតហើយ ក្នុងបណ្ដាសត្វដែលបរិភោគកាមទាំងនោះ ដោយច្រើន មិនដេកផ្អៀងទៅស្ដាំឡើយ ។ ម្នាលភិក្ខុទាំងឡាយ មនុស្សស្លាប់ ( ប្រេត ) ច្រើនតែដេកផ្ងារ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណេកមនុស្សស្លាប់ ។ ពិតហើយ ព្រោះមានសាច់ និងឈាមតិច ប្រេតមានសរីរៈមានឆ្អឹងរគាម មិនអាចដេកផ្អៀងខាងណាមួយបាន ទើបដេកផ្ងារប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ សម្រេចការដេកដោយខាងៗ ស្ដាំ យកជើងតម្រួតលើជើង ស៊កកន្ទុយក្នុងចន្លោះភ្លៅ សីហមិគរាជនោះ លុះភ្ញាក់ឡើងងើបកាយខាងមុខ គឺងើបក្បាល សម្លឹងមើលកាយខាងក្រោម ម្នាលភិក្ខុទាំងឡាយ បើសីហមិគរាជឃើញសេចក្ដីភ្លាំងភ្លាត់ ឬការឃ្លៀងឃ្លាតកាយណាមួយសោត ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ រមែងតូចចិត្តព្រោះការភ្លាំងភ្លាត់ និងឃ្លៀងឃ្លាតនៃកាយនោះ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសីហ-មិគរាជ មិនឃើញសេចក្ដីភ្លាំងភ្លាត់ ឬឃ្លៀងឃ្លាតនៃកាយណាមួយទេ ម្នាលភិក្ខុទាំងឡាយ សីហមិគរាជ រមែងត្រេកអរ ដោយការមិនភ្លាំងភ្លាត់ និងឃ្លៀងឃ្លាតនៃកាយនេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណេកសីហៈ ។

ពិតហើយ សីហមិគរាជ ព្រោះច្រើនដោយអំណាចដាក់ជើងខាងមុខទាំង ២ ក្នុងទីមួយកន្លែង ដាក់ជើងក្រោយទាំង ២ មួយកន្លែង យកកន្ទុយស៊កចូលទៅក្នុងចន្លោះភ្លៅ កំណត់ឱកាសនៃទីដែលតាំងនៅរបស់ជើងមុខជើងក្រោយនិងកន្ទុយហើយ ដេកដាក់ក្បាលលើជើងមុខទាំង ២ លក់ទៅ សូម្បីអស់មួយថ្ងៃ កាលភ្ញាក់ឡើង ក៏មិនមានការភ្ញាក់ផ្អើល អើតក្បាលឡើងហើយ កំណត់មើលឱកាសដែលតាំងនៅនៃជើងមុខជាដើម បើឋានៈណាមួយ ដែលខ្លួនតាំងទុកហើយ ខុសប្រក្រតីទៅ ក៏អាក់អន់ចិត្តថា ឋានៈនេះ មិនសមគួរដល់ជាតិ និងភាពជាអ្នកអង់អាចរបស់អញ ដូច្នេះ ក៏ដេកក្នុងទីនោះឯង មិនចេញទៅរកអាហារឡើយ ។ តែកាលឋានៈដែលខ្លួនតាំងទុកមិនខុសប្រក្រតី ក៏រីករាយ ពេញចិត្ត គិតថា ឋានៈនេះ សមគួរដល់ជាតិ និងដល់ភាពក្លាហានរបស់អញ ដូច្នេះ ក្រោកឡើងហើយ ក៏ពត់ខ្លួន រលាស់កេសរ បន្លឺសីហនាទ ៣ ដងហើយ ទើបចេញទៅរកអាហារ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ម្នាលភិក្ខុទាំងឡាយ នេះហៅថា ដំណេកព្រះតថាគត ។ ការដេកដោយឈានទាំង ៤ ព្រះមានព្រះភាគ ត្រាស់ហៅថា ដំណេកព្រះតថាគត ។ បណ្តាការដេក ៤ យ៉ាងនោះ ការដេកដូចសីហៈ មកហើយក្នុងទីនេះ ព្រោះថា ការដេកនេះឈ្មោះថា ការដេកយ៉ាងប្រសើរ ព្រោះជាឥរិយាបថរបស់អ្នកច្រើនដោយអំណាច ។

បទថា **ឆាទេន ឆាទំ** បានដល់ យកជើងឆ្វេងដាក់លើជើងស្តាំ ។ បទ

ថា **ឧច្ចារធាយ** បានដល់ ដាក់ត្រួតវែងជាងគ្នាបន្តិច ព្រោះថា កជើងសន្កត់ត្រង់កជើង ជង្គង់សង្កត់ជង្គង់ វេទនារមែងកើតរឿយៗ ចិត្តរមែងមិនស្ងប់ ការដេកក៏មិនមានផាសុក បើ-កជើង និងកជើង ជង្គង់ និងជង្គង់មិនសង្កត់គ្នាដោយប្រការណា កាលដាក់ឲ្យលយហួសដោយប្រការនោះ វេទនាតែងមិនកើតឡើង ចិត្តរមែងស្ងប់ ការដេកក៏ជាផាសុក ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។

[ ១០៩ ] បទថា **អភិជ្ឈំ លោកេ** ជាដើម បានពោលពិស្តារហើយក្នុងចូឡហត្ថិបទោបមសូត្រ ។

[ ១១០ ] បទថា **សេយ្យថាបិ ភិក្ខវេ** ជាឧបមា ។ បណ្ដាបទទាំងនោះបទថា **ឥណមាទាយ** បានដល់ កាន់យកទ្រព្យដោយចងការ ។ បទថា **ព្យន្តីករេយ្យ** បានដល់ គប្បីធ្វើឲ្យអស់ទៅ អធិប្បាយថា គប្បីសងទាំងអស់ ។ បទថា **តតោ និទានំ** បានដល់ ហេតុនៃការមិនមានបំណុល ពិតហើយ បុរសនោះ កាលរឭកថា អញជាអ្នកមិនមានបំណុល ដូច្នេះ ក៏នឹងបាននូវបាមោជ្ជ ដល់នូវសោមនស្ស ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បុគ្គលនោះគប្បីបាននូវបាមោជ្ជ គប្បីដល់នូវសោមនស្ស ដូច្នេះ ។ ឈ្មោះថា អាពាធ ព្រោះកើតវេទនាដែលជាសត្រូវ ព្រោះកាត់នូវឥរិយាបថ ដូចកាត់ដោយរណារបៀតបៀន អាពាធនោះ មានដល់បុគ្គលនោះ ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកមានអាពាធ ។ ឈ្មោះថា មានទុក្ខ ព្រោះទុក្ខដែលមានអាពាធនោះជាសមុដ្ឋាន ។ ឈ្មោះថា ឈឺធ្ងន់ ព្រោះជំងឺ មាន

ប្រមាណក្រៃលែង ។ បទថា **ឆម្ភាទេយ្យុ** បានដល់ មិនគប្បីពេញចិត្ត ព្រោះមានព្យាធិធ្ងន់ជាខាងមុខ ។ បទថា **ពលមត្តា** បានដល់ កម្លាំងនោះឯង អធិប្បាយថា បុគ្គលគប្បីមានកម្លាំងកាយ ។ បទថា **តតោ និទានំ** បានដល់ ហេតុ គឺការមិនមានរោគ ។ ពិតហើយ កាលបុគ្គលរឭកថា អញជាអ្នកមិនមានរោគ ដូច្នេះ ហេតុទាំង ២ នោះ រមែងកើតឡើង ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា **លភេថ ចាមោជ្ជំ អធិគច្ឆេយ្យ សោមនស្សំ** ដូច្នេះ ។ បទថា **ន ចស្ស កិញ្ចិ ភោគានំ វយោ** សេចក្តីថា មិនគប្បីវិនាសភោគៈទាំងឡាយ សូម្បីត្រឹមតែមួយកាកណិក[១] ។ បទថា **តតោ និទានំ** បានដល់ ហេតុផុតចាកការឃុំខាំង ។ ពាក្យដ៏សេសក្នុងបទទាំងពួងគប្បីប្រកបដោយន័យដែលពោលហើយ ។ បទថា **អនត្តាធីនោ** បានដល់ ខ្លួនឯងមិនបានជាធំ គឺរមែងធ្វើអ្វីមួយ មិនបានតាមការពេញចិត្តរបស់ខ្លួន ។ បទថា **បរាធីនោ** បានដល់ អ្នកដទៃជាធំ គឺប្រព្រឹត្តទៅតាមការពេញចិត្តរបស់អ្នកដទៃ ។ បទថា **ន យេនកាមង្គមោ** សេចក្តីថា បុគ្គលនោះប្រាថ្នានឹងទៅ ត្រូវទៅដោយចំណែកនៃទិសណា តែងមិនបានដោយទិសាភាគនោះ ។ បទថា **ទាសព្យា** បានដល់ ភាពជាទាសៈ ។ បទថា **ភុជិស្សោ** បានដល់ ជាអ្នកជាដល់ខ្លួន ។ បទថា **តតោ និទានំ** បានដល់ ហេតុភាពជាអ្នកជា ។ បទថា **កន្តារទ្ធានមគ្គំ** បានដល់ ផ្លូវកន្តារ អធិប្បាយថា ផ្លូវឆ្ងាយ ប្រាសចាកទឹក ។ បទថា **តតោ និទានំ** បានដល់ ហេតុ គឺដែនក៏ក្សេម ។

---

១- ១ កាកណិក គឺតម្លៃដែលអាចទិញសាច់ ល្មមក្អែកមួយបរិភោគឆ្អែតបាន ។

[ ១១១ ] ក្នុងបទថា **ឥមេ បញ្ច នីវរណេ អប្បហីនេ** នេះ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងកាមច្ឆន្ទនីវរណៈដែលមិនទាន់លះបាន ដូចគ្នានឹងការជំពាក់បំណុល នីវរណៈដ៏សេស ដូចរោគជាដើម ។ ក្នុងសេចក្តីនោះ គប្បីជ្រាបភាពដូចគ្នាដូចតទៅនេះ

ពិតហើយ បុគ្គលណាខ្ចីបំណុលទៅហើយ មិនបានសង បុគ្គលនោះត្រូវម្ចាស់បំណុលតឹងទារថា ឯងចូរសងបំណុល ដូច្នេះក្តី ត្រូវគេគំរាមដោយពាក្យគ្រោតគ្រាតក្តី ត្រូវគេចាប់ទៅក្តី ត្រូវគេប្រហារ គឺវាយតប់ក្តី មិនអាចតតាំងអ្វីបាន រមែងអត់ធន់គ្រប់យ៉ាង ព្រោះថា បំណុលនោះ មានការអត់ធន់ជាហេតុ យ៉ាងណា បុគ្គលណារមែងត្រេកអរនូវវត្ថុណាដោយកាមច្ឆន្ទៈ រមែងកាន់យកនូវវត្ថុនោះ ដោយការប្រកាន់ គឺតណ្ហាដូច្នោះដូចគ្នា បុគ្គលនោះត្រូវគេពោលពាក្យគ្រោតគ្រាតក្តី ត្រូវគេចាប់ទៅក្តី ត្រូវគេប្រហារ គឺវាយតប់ក្តី រមែងអត់ធន់គ្រប់យ៉ាង ព្រោះថា កាមច្ឆន្ទៈនោះ មានកាអត់ធន់ជាហេតុ ដូចការពេញចិត្តក្នុងកាយរបស់ស្រីទាំងឡាយ ដែលប្តីក្នុងផ្ទះសម្លាប់ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបកាមច្ឆន្ទៈ ប្រៀបដូចការជំពាក់បំណុល ដូច្នេះ ។

ឧបមាដូចបុគ្គលរសាប់រសល់ ព្រោះរោគប្រមាត់ កាលបុគ្គលណាមួយឲ្យវត្ថុទាំងឡាយ មានទឹកឃ្មុំ និងស្ករផែនជាដើម ក៏រមែងមិនបានរសនៃវត្ថុទាំងនោះ ព្រោះភាពដែលខ្លួនរសាប់រសល់ ដោយរោគប្រមាត់ រមែងក្អួតចេញនោះឯង ដោយសម្គាល់ថា រសល្វីងៗ ដូច្នេះ យ៉ាងណា បុគ្គលមានចិត្តព្យាបាទក៏ដូច្នោះដូចគ្នា កាលត្រូវអាចារ្យ ឬឧបជ្ឈាយ៍ដែលប្រាថ្នាប្រយោជន៍

ពោលទូន្មានត្រឹមតែបន្តិចបន្តួច ក៏មិនទទួលឱវាទ នឹងពោលថា ពួកលោក រមែងទាស់ចិត្តក្នុងខ្ញុំពេកណាស់ ហើយក៏សឹកចេញទៅ បុគ្គលនោះ រមែង មិនជួបនូវរសនៃព្រះសាសនា ដែលពោរពេញដោយសេចក្ដីសុខក្នុងឈាន ជាដើម ព្រោះសោប់សោល់ដោយសេចក្ដីក្រោធ បុគ្គលនោះដែលមិនជួបនូវ រសទឹកឃ្មុំ និងស្ករផែនជាដើម ព្រោះការសោប់សោល់ដោយរោគប្រមាត់ ។ បណ្ឌិតគប្បីឃើញព្យាបាទ ដូចរោគយ៉ាងនេះ ។

ភិក្ខុត្រូវថីនមិទ្ធៈគ្រប់សង្កត់ហើយ កាលធម្មស្សវនៈ គឺការស្ដាប់ធម៌ សូម្បីមានន័យដ៏វិចិត្រកំពុងប្រព្រឹត្តទៅ រមែងមិនដឹងខាងដើម កណ្ដាល និង ខាងចុងនៃធម្មស្សវនៈនោះ ដូចបុរសដែលត្រូវចងក្នុងគុក ក្នុងថ្ងៃនក្ខត្តឫក្ស រមែងមិនឃើញខាងដើម កណ្ដាល និងទីបំផុត នៃបុណ្យនក្ខត្តឫក្ស បុគ្គល នោះ រួចអំពីគុកក្នុងថ្ងៃទី ២ ហើយ បានស្ដាប់ពាក្យថា ឱ ! កាលពីម្សិល មិញ មានបុណ្យនក្ខត្តឫក្សយ៉ាងសប្បាយ មានរបាំចម្រៀងជាដើម ក៏មិន ពោលឆ្លើយ ។ ព្រោះហេតុអ្វី ព្រោះខ្លួនមិនបានជួបបុណ្យនក្ខត្តឫក្ស ដូច្នោះ ភិក្ខុនោះ កាលធម្មស្សវនៈតាំងឡើងហើយ សូម្បីស្ដាប់អ្នកដទៃពោលសរសើរ ធម្មស្សវនៈថា ឱ ! ស្ដាប់ធម៌ ឱ ! ការណៈ ឱ ! ឧបមាជាដើម ក៏មិនបាន ចម្លើយ ។ ព្រោះហេតុអ្វី ព្រោះខ្លួនមិនជួបធម្មកថា ដោយអំណាចនៃថីនមិទ្ធៈ ។ ថីនមិទ្ធៈ បណ្ឌិតគប្បីជ្រាបដូចគុកយ៉ាងនេះ ។

ឧបមាដូចទាសៈ សូម្បីកំពុងលេងនក្ខត្តឫក្ស ត្រូវចៅហ្វាយប្រាប់ថា ឈ្មោះថា ករណីចាំបាច់នេះនៅមាន ឯងចូរទៅក្នុងទីនោះភ្លាម បើឯងមិនទៅ

អញ្ជទឹងកាត់ដៃ-ជើង ត្រចៀក ឬច្រមុះរបស់ឯង ដូច្នេះ បុគ្គលនោះរមែង ប្រញាប់ទៅនោះឯង មិនបានជួបខាងដើម កណ្តាល និងខាងចុងរបស់បុណ្យ នក្ខត្តឫក្ស ។ ព្រោះអ្វី ព្រោះខ្លួនមានអ្នកដទៃជាធំ យ៉ាងណា ភិក្ខុមិនដឹង បដិបទាក្នុងព្រះវិន័យ ទោះចូលទៅកាន់ទីដទៃ ដោយវិវេកកថា កាលមាន ការសម្គាល់ក្នុងអកប្បិយណាមួយកើតឡើងហើយ ដោយហោច សូម្បីក្នុង កប្បិយមំសៈ ក៏លះវិវេកទៅក្នុងសម្នាក់ព្រះវិនយធរដើម្បីជម្រះសីល ព្រោះ ដូច្នោះ លោករមែងមិនបានសោយនូវសេចក្តីសុខ ដែលកើតអំពីវិវេក ។ ព្រោះហេតុអ្វី ព្រោះត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ ដូច្នោះ បណ្ឌិតគប្បីជ្រាប ឧទ្ធច្ចកុក្កុច្ចៈ ដូចទាសៈយ៉ាងនេះ ។

ឧបមាដូចបុរសដើរផ្លូវកន្តារ ឃើញឱកាសដែលពួកមនុស្សត្រូវចោរប្លន់ ហើយ សង្ស័យថា ពួកចោរមកហើយ ដោយសំឡេងនៃដំបងខ្លះ ដោយ សំឡេងរបស់ព្រានបក្សីខ្លះ ដូច្នេះ រមែងដើរទៅខ្លះ ឈប់ខ្លះ រមែងត្រឡប់ ខ្លះ ទីដែលមកច្រើនជាងទីទៅ បុគ្គលនោះរមែងទៅដល់ទីដែលជាដែនក្សេម បានដោយក្រ បានដោយលំបាក ឬមិនដល់ យ៉ាងណា វិចិកិច្ឆា គឺ ការ សង្ស័យនៃបុគ្គលណា ក្នុងឋានៈ ៨ យ៉ាង កើតឡើងហើយ ក៏ដូច្នោះដូចគ្នា បុគ្គលកាលសង្ស័យថា **ពុទ្ធោ នុ ខោ ន នុ ខោ ពុទ្ធោ** ជាព្រះពុទ្ធ ឬមិន មែនព្រះពុទ្ធហ្ន៎ជាដើម មិនអាចបង្អោនដើម្បីទឹងកាន់យកដោយសទ្ធា កាល មិនអាច ក៏មិនសម្រេចមគ្គផល ។ កាលបុគ្គលញ៉ាំងសេចក្តីរារែកសង្ស័យ ការមិនជឿមាំ ជាអ្នកញ៉ាំងការភ្ញាក់ផ្អើលឲ្យកើតឡើងដល់ចិត្តរឿយៗ ថា ពួក

ចោរមាននៅក្នុងផ្លូវកន្ដារ ឬក៏អត់ឃ្លាំ ដូច្នេះ រមែងធ្វើអន្តរាយដល់ការដែលដល់ទីផុតភ័យ យ៉ាងណា សូម្បីវិចិកិច្ឆា ក៏ដូច្នោះ ញ៉ាំងនូវការសង្ស័យ ការមិនជឿមាំ ការភ្ញាក់ផ្អើលឲ្យកើតដល់ចិត្តរឿយៗ ដោយន័យថា **ពុទ្ធោ** ជាដើម រមែងធ្វើអន្តរាយដល់ការសម្រេចអរិយមគ្គ បណ្ឌិតគប្បីជ្រាប ដូចបុគ្គលដែលធ្វើដំណើរផ្លូវកន្ដារ ។

ឥឡូវនេះ ក្នុងបទថា **សេយ្យថាបិ ភិក្ខវេ អាណណ្យំ** នេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងនូវកាមច្ឆន្ទៈដែលលះបានហើយ ឲ្យដូចគ្នានឹងការមិនមានបំណុល និងនូវនីវរណៈដ៏សេស ដែលភិក្ខុលះបានហើយ ឲ្យដូចជាការមិនមានរោគជាដើម ។ ក្នុងសេចក្ដីនេះថា ភាពតែមួយគប្បីជ្រាបដូចតទៅនេះថា

ឧបមាដូចបុរសជំពាក់បំណុល ប្រកបការងារ រួចការងារហើយ គិតថា ឈ្មោះថា បំណុល រមែងជាហេតុឲ្យកង្វល់ចិត្ត ដូច្នេះ ទើបសងបំណុលមួយអន្លើនឹងចុងការ ហែកសំបុត្រចោល ។ ពេលនោះ ក៏មិនមានបុគ្គលណាមួយ មកទារបំណុល ឬបញ្ជូនសំបុត្រមកទារ ចាប់តាំងពីកាលនោះ ។ បុរសនោះឃើញម្ចាស់បំណុលហើយ ទោះអង្គុយ ឬក្រោកឡើងអំពីទីអង្គុយក្ដី មិនប្រាថ្នាអង្គុយ មិនត្រូវការក្រោកឡើងក៏បាន ព្រោះហេតុអ្វី ព្រោះគាត់អស់បំណុលហើយ មិនទាក់ទងដោយម្ចាស់បំណុលនោះ យ៉ាងណា ភិក្ខុនេះគិតថា ឈ្មោះថា កាមច្ឆន្ទៈ មានការកង្វល់ចិត្តជាហេតុ ដូច្នេះហើយ ចម្រើនធម៌ទាំង ៦ យ៉ាង ដោយន័យដែលពោលក្នុងសតិប្បដ្ឋានហើយ លះកាមច្ឆន្ទនីវរណៈយ៉ាងនោះដូចគ្នា ។ ការខ្វាច ការតក់ស្លុត មិនមានដល់បុរស

ដែលអស់បំណុលហើយ ព្រោះឃើញម្ចាស់បំណុលយ៉ាងណា ការជាប់ ការជំពាក់របស់ភិក្ខុដែលមានកាមច្ឆន្ទៈលះបានហើយ រមែងមិនមានក្នុងវត្ថុដទៃយ៉ាងនោះដូចគ្នា ។ កាលឃើញរូបទាំងឡាយសូម្បីជាទិព្វ កិលេសក៏មិនផ្សាយឡើង ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ត្រាស់ការលះកាមច្ឆន្ទៈដូចអ្នកអស់បំណុល ។

ឧបមាថា បុរសអ្នកសោប់សោល់ដោយរោគប្រមាត់នោះ ធ្វើរោគនោះឲ្យជាសះស្បើយទៅ ដោយការធ្វើភេសជ្ជៈ ចាប់តាំងអំពីនោះ រមែងដឹងរសនៃស្ករផែនជាដើម យ៉ាងណា ភិក្ខុនោះក៏ដូច្នោះដូចគ្នា គិតថា ដែលឈ្មោះថាព្យាបាទនេះ ធ្វើនូវការវិនាស មិនមែនប្រយោជន៍ ដូច្នេះហើយ ចម្រើនធម៌ ៦ យ៉ាង លះព្យាបាទនីវរណៈបាន ។ ភិក្ខុនោះឈ្មោះថា លះនូវការព្យាបាទបានយ៉ាងនេះ ។ បុរសអ្នកជារោគប្រមាត់ ចូលចិត្តបរិភោគបង្អែម មានស្ករផែនជាដើម យ៉ាងណា ភិក្ខុនោះ ដែលអាចារ្យឲ្យសិក្សានូវអាចារ និងព្រះវិនយប្បញ្ញត្តិជាដើម ទទួលដោយសិរសា ចូលចិត្តក្នុងការសិក្សា ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ការលះព្យាបាទ ដូចការមិនមានរោគ ។

បុរសដែលត្រូវចាប់បញ្ចូលទៅក្នុងគុក ក្នុងថ្ងៃនក្ខត្តឫក្ស សូម្បីក្នុងថ្ងៃនក្ខត្តឫក្សដទៃទៀត បុរសនោះគិតថា អញធ្លាប់ជាប់គុក ដោយទោសនៃការប្រមាទ ទើបមិនបានលេងបុណ្យនក្ខត្តឫក្ស ព្រោះទោសនោះ ឥឡូវនេះ អញជាអ្នកមិនប្រមាទ ដូច្នេះ យ៉ាងណា សត្រូវនៃបុគ្គលនោះ មិនបានឱកាសបុគ្គលនោះជាអ្នកមិនប្រមាទ ទើបបានលេងបុណ្យនក្ខត្តឫក្ស ក៏បន្លឺឧទានថា

ឱ ! ថ្ងៃនក្ខត្តឫក្ស ដូច្នេះ យ៉ាងណា ភិក្ខុក៏ដូច្នោះដូចគ្នា គិតថា ដែលឈ្មោះថា ថីនមិទ្ធៈនេះ ធ្វើនូវសេចក្ដីវិនាសធំ ដូច្នេះ ទើបចម្រើនធម៌ ៦ យ៉ាង លះថីនមិទ្ធៈបាន ភិក្ខុនោះឈ្មោះថា លះថីនមិទ្ធៈហើយយ៉ាងនេះ បុរសដែលរួចផុតចាកគុក លេងបុណ្យនក្ខត្តឫក្សអស់កាលខាងដើម កណ្ដាល និងខាងចុងអស់ ៧ ថ្ងៃ ក៏សោយសុខទាំងខាងដើម កណ្ដាល និងខាងចុងអស់នៃធម្មនក្ខត្ត យ៉ាងណា សម្រេចអរហត្ត ព្រមទាំងបដិសម្ភិទាដូច្នោះដូចគ្នា ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ការលះថីនមិទ្ធៈ ដូចការផុតចាកអំពីគុក ។

ឧបមាថា ទាសៈចូលទៅអាស្រ័យមិត្រណាម្នាក់ ឲ្យទ្រព្យចៅហ្វាយ ធ្វើខ្លួនឲ្យជាអ្នកជាបានហើយ ចាប់តាំងអំពីនោះមក គប្បីធ្វើវត្ថុដែលខ្លួនប្រាថ្នាបាន យ៉ាងណា ភិក្ខុក៏ដូច្នោះដូចគ្នា គិតថា ឈ្មោះថា ឧទ្ធច្ចកុក្កុច្ចៈ ធ្វើនូវការវិនាសធំ ដូច្នេះ ទើបចម្រើនធម៌ ៦ យ៉ាង ហើយលះឧទ្ធច្ចកុក្កុច្ចៈបាន ។ ភិក្ខុនោះឈ្មោះថា លះឧទ្ធច្ចកុក្កុច្ចៈដោយអាការយ៉ាងនេះ បុរសដែលជាអ្នកជាប្រាថ្នាធ្វើវត្ថុណា ក៏ធ្វើវត្ថុនោះបាន បុគ្គលណាម្នាក់ មិនអាចបញ្ឈឲ្យបុគ្គលនោះធ្វើដោយកម្លាំងបាន យ៉ាងណា ភិក្ខុបដិបត្តិនេក្ខម្មបដិបទាតាមសប្បាយដូច្នោះដូចគ្នា ឧទ្ធច្ចកុក្កុច្ចៈ បុគ្គលណាម្នាក់ មិនអាចឲ្យលោកត្រឡប់អំពីនេក្ខម្មបដិបទានោះ មកកាន់ឧទ្ធច្ចកុក្កុច្ចៈដោយកម្លាំងបានឡើយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ការលះឧទ្ធច្ចកុក្កុច្ចៈបាន ដូចភាពជាអ្នកជា ។

ឧបមាថា បុរសមានកម្លាំងកាន់យកនូវស្បៀងក្រៀមក្រោះ ត្រៀមអាវុធ

មួយអន្ទើដោយបរិវារ ធ្វើដំណើរឆ្លងកាត់ផ្លូវកន្តារ ពួកចោរឃើញបុរសនោះអំពីចម្ងាយ គប្បីគេចទៅ បុរសនោះ ក៏ឆ្លងកន្តារនោះទៅដល់ទីផុតភ័យបានដោយសួស្តី គប្បីជាអ្នកត្រេកអររីករាយហើយ យ៉ាងណា ភិក្ខុក៏ដូច្នោះដូចគ្នា លោកគិតថា ឈ្មោះថាវិចិកិច្ឆានេះ រមែងធ្វើនូវការវិនាស មិនមែនប្រយោជន៍ ដូច្នេះ ទើបចម្រើនធម៌ ៦ យ៉ាងហើយ លះនូវវិចិកិច្ឆាបាន ភិក្ខុនោះឈ្មោះថា លះវិចិកិច្ឆាហើយ ដោយអាការយ៉ាងនេះ បុរសអ្នកមានកម្លាំង មានអាវុធត្រៀមទុកហើយ មួយអន្ទើដោយបរិវារ ឃើញចោរហើយ មិនខ្លាច មិនញញើតពួកចោរ សូម្បីប៉ុនចម្រៀកស្មៅ ចេញទៅដល់ទីស្ថានដែលផុតភ័យដោយសួស្តី យ៉ាងណា ភិក្ខុក៏ដូច្នោះដូចគ្នា ឆ្លងផុតផ្លូវកន្តារ គឺទុច្ចរិតហើយ ដល់នូវអមតនិព្វានដ៏ក្សេមក្សាន្ត ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ការលះវិចិកិច្ឆា ដូចបុគ្គលដែលដល់នូវទីផុតភ័យ ។

បទថា **ឥមមេវ កាយំ** បានដល់ ករជកាយនេះ ។ បទថា **អភិសន្ទេតិ** បានដល់ ធ្វើឲ្យជោក ធ្វើឲ្យស្មេហា គឺរមែងធ្វើបីតិ និងសុខ ឲ្យប្រព្រឹត្តទៅក្នុងករជកាយទាំងពួង ។ បទថា **បរិសន្ទេតិ** បានដល់ រមែងស្កប់ស្កល់ដោយជុំវិញ ។ បទថា **បរិបូរេតិ** បានដល់ រមែងពេញដូចខ្យល់ក្នុងស្នប់ ។ បទថា **បរិប្ផរតិ** បានដល់ រមែងពាល់ត្រូវដោយជុំវិញ ។ បទថា **សព្វាវតោ កាយស្ស** សេចក្តីថា ទីសូម្បីតិចតួចតាមស្បែក សាច់ ឈាម ក្នុងទីបន្តប្រព្រឹត្តទៅរបស់ឧបាទិន្នករូបណាមួយនៃកាយគ្រប់ចំណែករបស់ភិក្ខុនោះ ឈ្មោះថា មិនពាល់ត្រូវដោយសេចក្តីសុខក្នុងបឋមជ្ឈាន មិនមាន ។ បទថា **ទក្ខោ**

បានដល់ អ្នកឈ្មួសប្រតិពលដើម្បីធ្វើ ដើម្បីប្រកប ដើម្បីផ្សំនូវលម្អិតសម្រាប់ងូត ។ បទថា **កំសថាលេ** បានដល់ ភាជនៈដែលធ្វើដោយលោហៈណាមួយ ។ ឯភាជនៈដែលធ្វើដោយដីឥដ្ឋ ជាភាជនៈមិនមាំទាំ កាលបុគ្គលវាយ រមែងបែកបាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគមិនសម្តែងភាជនៈដែលធ្វើដោយដីឥដ្ឋនោះ ។ បទថា **បរិប្ផោសកំ បរិប្ផោសកំ** ប្រែថា ស្រោចស្រព ។ បទថា **សន្នេយ្យ** សេចក្តីថា កាន់ថាសសរីទ្ធដោយដៃច្រើន ស្រោចស្រពហើយ ស្រោចស្រពទៀតនូវទឹកល្មមប្រមាណដោយដៃស្តាំហើយ ពូតធ្វើឲ្យជាដុំ ។ បទថា **សិនេហានុគ្គតា** បានដល់ ជាប់គ្នាដោយជ័រស្អិត គឺទឹក ។ បទថា **សិនេហាបរេតា** បានដល់ សើមទៅដោយជ័រ គឺទឹក ។ បទថា **សន្តរពាហិរា** សេចក្តីថា ព្រមទាំងចំណែកខាងក្នុង ខាងក្រៅ ។ រមែងពាល់ត្រូវចំណែកទាំងអស់នោះឯង ដោយជ័រ គឺទឹក ។ បទថា **ន ច បគ្ឃរណី** សេចក្តីថា ទឹករមែងមិនហូរទៅជាតំណក់ៗ អធិប្បាយថា អាចដើម្បីកាន់យកដោយដៃ ដោយម្រាមត្រឹមតែ ២ ដើម្បីធ្វើឲ្យវិលបាន ។

[ ១១២ ] គប្បីជ្រាបឧបមាសេចក្តីសុខ ក្នុងទុតិយជ្ឈានដូចតទៅនេះ បទថា **ឧព្ភិតោទកោ** បានដល់ ទឹកដែលមិនហូរទៅ គឺមិនហូរទៅខាងក្រោម មិនហូរទៅខាងលើ អធិប្បាយថា ជាទឹកកើតនៅខាងក្នុងនោះឯង ។ បទថា **អាយមុខំ** បានដល់ ផ្លូវមក ។ បទថា **ទេវោ** បានដល់ ពពក ។ បទថា **កាលេន កាលំ** បានដល់ រៀងរាល់កន្លះខែ ឬ ១០ ថ្ងៃ ។ បទថា **ធារំ** ប្រែថា ភ្លៀង ។ បទថា **អានុបវេច្ឆេយ្យ** បានដល់ មិនគប្បីចូលទៅ គឺមិនគប្បី

ធ្លាក់ចុះទៅ អធិប្បាយថា ធ្លារទឹកត្រជាក់ដែលខ្ពុរឡើង គឺធ្វើអន្លង់ទឹកត្រជាក់ដែលនៅដក់ ឲ្យពេញហើយ ។ ពិតហើយ ទឹកដែលខ្ពុរឡើងអំពីខាងក្រោម ធ្វើទឹកដែលខ្ពុរឡើងមិនឲ្យបែកព្រួចចេញទៅ ទឹកដែលហូរចូលទៅដោយទិសទាំង ៤ រមែងធ្វើព្រួចស្លឹកឈើ ស្មៅ សំរាម កំណាត់ឈើជាដើម ទឹករមែងព្រួច ព្រោះពពុះនៃភ្លៀង ឬធ្លារទឹកដែលស្រក់ចុះមក តែទឹកស្ងប់នឹងកើតឡើង រមែងផ្សាយទៅកាន់ប្រទេសនេះ រមែងមិនផ្សាយទៅកាន់ប្រទេសនេះ ដូចនិម្មិតដោយឫទ្ធិ ព្រោះដូច្នោះ ឱកាសដែលទឹកនោះមិនពាល់ត្រូវហើយមិនមាន ។ ក្នុងសេចក្តីនោះ ករជកាយ ប្រៀបដូចអន្លង់ទឹក សេចក្តីសុខក្នុងទុតិយជ្ឈានដូចទឹក ។ ពាក្យដ៏សេស បណ្ឌិតគប្បីជ្រាបដោយន័យមុន ។

គប្បីជ្រាបឧបមាក្នុងសេចក្តីសុខនៃតតិយជ្ឈាន ផ្កាព្រលិតទាំងឡាយមាននៅក្នុងទីនោះ ព្រោះដូច្នេះ ទើបឈ្មោះថា គុម្ពឧប្បល ។ ពីរបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនេះថា បណ្តាផ្កាឧប្បល មានពណ៌ស ក្រហម ខៀវ ឧប្បលណាមួយ ក៏ចាត់ជាឧប្បលទាំងអស់ ផ្កាឧប្បលដែលមានត្របក ៩៩ ហៅថា បុណ្ឌរិក មានត្របក ១០០ ហៅថា បទុម ម្យ៉ាងទៀត ផ្កាឧប្បលពណ៌សមិនកំណត់ត្របក ហៅថា បទុម ផ្កាឧប្បលពណ៌ក្រហម ហៅថា បុណ្ឌរិក ។

[ ១១៣ ] បទថា **ឧទកានុគ្គតានិ** បានដល់ មិនផុសអំពីទឹក ។ បទថា **អន្តោនិមុគ្គបោសិតានិ** សេចក្តីថា លិចនៅខាងក្នុងទឹកប៉ុណ្ណោះតែងពាល់ត្រូវ គឺរមែងចម្រើន ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យមុននោះឯង ។

[ ១១៤ ] គប្បីជ្រាបឧបមាដោយសេចក្ដីសុខ ក្នុងចតុត្ថជ្ឈានតទៅ ក្នុងបទថា **បរិសុទ្ធេន ចេតសា បរិយោទាតេន** នេះ គប្បីជ្រាបឈ្មោះថា បរិសុទ្ធហើយ ព្រោះអត្ថថា អស់ឧបក្កិលេស ឈ្មោះថា ផូរផង់ហើយ ព្រោះអត្ថថា បកស្សរ ។ បទថា **ឱទាតេន វត្ថេន** នេះ លោកពោលដើម្បីការផ្សាយទៅនៃឱកាស គប្បីជ្រាបសេចក្ដីក្នុងពាក្យនេះ យ៉ាងនេះថា សំពត់ដែលសៅហ្មង ការកក់ក្ដៅ រមែងផ្សាយទៅ ។ កាលណាត់សំពត់សដែលបោកបរិសុទ្ធស្អាត រមែងកក់ក្ដៅ រមែងមានកម្លាំងផ្សាយទៅ ។ ពិតហើយ សម្រាប់ឧបមានេះ ករជកាយប្រៀបដូចសំពត់ សេចក្ដីសុខក្នុងចតុត្ថជ្ឈាន ប្រៀបដូចការផ្សាយទៅនៃឱកាស ព្រោះដូច្នោះ កាលបុរសងូតទឹកជម្រះល្អហើយ អង្គុយដណ្ដប់សំពត់ស ទទូរក្បាល ឧតុអំពីសរីរៈ រមែងផ្សាយទូទៅពេញសំពត់នោះឯង ឱកាសណាមួយ ដែលមិនជាឱកាសពាល់ត្រូវសំពត់មិនមាន យ៉ាងណា ឱកាសណាមួយ ដែលសេចក្ដីសុខក្នុងចតុត្ថ-ជ្ឈានមិនពាល់ត្រូវករជកាយនៃភិក្ខុ រមែងមិនមាន ដូច្នោះ ។ ម្យ៉ាងទៀត ចិត្តក្នុងចតុត្ថជ្ឈាននោះឯង ប្រៀបដូចសំពត់ដែលដណ្ដប់ហើយ រូបដែលមានចិត្តនោះជាសមុដ្ឋាន ប្រៀបដូចការផ្សាយទៅនៃឱកាស ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងទីនេះយ៉ាងនេះថា ប្រៀបដូចសំពត់សក្នុងទីខ្លះ សូម្បីមិនពាល់ត្រូវកាយ កាយក៏ជាឱកាសដែលមានកាយនោះជាសមុដ្ឋាន ពាល់ត្រូវទាំងអស់ហើយដូចគ្នា យ៉ាងណា កាយរបស់ភិក្ខុដែលសុខុមរូប ដែលចតុត្ថជ្ឈានឲ្យកើតឡើង ពាល់ត្រូវទូទៅទាំងអស់ ក៏ដូច្នោះ ។

[ ១១៥ ] គប្បីជ្រាបឧបមាក្នុងបុព្វេនិវាសញ្ញាណដូចតទៅនេះ កិរិយាដែលភិក្ខុនោះធ្វើហើយ ក្នុងថ្ងៃនោះ រមែងប្រាកដច្បាស់ ព្រោះដូច្នោះ ក្នុងថ្ងៃនោះ លោកកាន់យកផ្ទះ ៣ ខ្នង ក្នុងសេចក្ដីនោះ បណ្ឌិតគប្បីជ្រាបថា ភិក្ខុដែលបានបុព្វេនិវាសញ្ញាណ ដូចបុរសទៅកាន់ផ្ទះ ៣ ខ្នង ។ ភព ៣ បណ្ឌិតគប្បីឃើញដូចផ្ទះ ៣ ខ្នង ។ ការជាក់ច្បាស់នៃកិរិយាដែលភិក្ខុចចិត្តទៅក្នុងបុព្វេនិវាសញ្ញាណ អន្វយធ្វើហើយក្នុងភព ៣ បណ្ឌិតគប្បីជ្រាបដូចការជាក់ច្បាស់នៃកិរិយាដែលបុរសធ្វើហើយក្នុងថ្ងៃនោះ ក្នុងផ្ទះ ៣ ខ្នង ។

[ ១១៦ ] គប្បីជ្រាបឧបមាក្នុងទិព្វចក្ខុដូចតទៅនេះ បទថា **ទ្វេ អគារា** បានដល់ ផ្ទះ ២ ខ្នង ។ បទថា **សទ្វារា** បានដល់ មានទ្វារខាងមុខ ។ បទថា **អនុចង្កមន្តេ** បានដល់ ដើរទៅមក ។ បទថា **អនុវិចរន្តេ** បានដល់ ត្រាច់ទៅខាងនោះ ខាងនេះ អធិប្បាយថា គប្បីជ្រាបដោយអំណាចនៃការចេញចាកផ្ទះនេះ ហើយចូលទៅកាន់ផ្ទះនោះ ឬចេញអំពីផ្ទះនោះហើយ ចូលមកកាន់ផ្ទះនេះ ។

ក្នុងសេចក្ដីនោះ ចុតិ និងបដិសន្ធិប្រៀបដូចផ្ទះ ២ ខ្នង មានទ្វាររួមគ្នា ភិក្ខុបានទិព្វចក្ខុញាណ ប្រៀបដូចបុរសមានចក្ខុ កាលដែលសត្វកំពុងចុតិ និងបដិសន្ធិ ប្រាកដដល់ភិក្ខុដែលបានទិព្វចក្ខុ ដែលចម្រើនអាលោកកសិណសម្លឹងមើល ប្រៀបដូចវេលាដែលបុរសដើរចូល និងដើរចេញទៅមក ក្នុងផ្ទះទាំង ២ ប្រាកដដល់បុរសដែលមានភ្នែក កំពុងឈរសម្លឹងមើលក្នុងចន្លោះផ្ទះទាំង ២ ។ សួរថា កាលទាំងនោះប្រាកដដល់ញាណ ឬដល់បុគ្គល ឆ្លើយ

ថា ដល់ញាណ ។ តែព្រោះប្រាកដដល់ញាណនោះ ទើបប្រាកដដល់បុគ្គល ដូចគ្នា ។

[ ១១៧ ] គប្បីជ្រាបឧបមានៃអាសវក្ខយញ្ញាណដូច្នេះ បទថា **បព្វត-សង្ខេបេ** បានដល់ កំពូលភ្នំ ។ បទថា **អនាវិលោ** បានដល់ មិនមានភក់ ។ ខ្យងផង គ្រំផង ឈ្មោះថា ខ្យង និងគ្រំ ។ ដុំក្រួសផង ដុំថ្មផង ឈ្មោះថា ដុំក្រួស និងដុំថ្ម ។ ឈ្មោះថា ហ្វូងត្រី ព្រោះត្រីហែលជាក្រុម ជាហ្វូង ។ ក្នុងបទថា **តិដ្ឋន្តំបិ ចរន្តំបិ** នេះ បានដល់ ដុំក្រួស និងដុំថ្ម តែរបស់ក្រៅអំពីនេះ មានខ្យងជាដើម វារទៅខ្លះ ឈប់នៅខ្លះ ។ ឧបមាដូចមេគោឈរខ្លះ ឱនខ្លះ ដេកខ្លះ ក្នុងចន្លោះៗ ហ្វូងគោទាំងនោះ រមែងត្រាច់ទៅ ព្រះមានព្រះភាគ ទ្រង់សំដៅយកគោត្រាច់ទៅ ទើបត្រាស់ថា គោក្រៅអំពីនេះ រមែងត្រាច់ទៅ យ៉ាងណា ព្រះមានព្រះភាគទ្រង់សំដៅយកដុំថ្មនោះឯង ទើបត្រាស់ថា ២ ពួកក្រៅអំពីនេះឈប់ ។ ទ្រង់សំដៅយកសត្វ ២ ពួកនេះចរទៅ ទើបត្រាស់ថា សូម្បីដុំក្រួស និងដុំថ្មក៏ត្រាច់ទៅ ដូច្នេះ ។ ក្នុងសេចក្ដីនោះ គប្បីជ្រាបកាលដែលសច្ចៈ ៤ ជាក់ច្បាស់ហើយដល់ភិក្ខុដែលអង្គុយបង្អោនចិត្តទៅ ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ ដូចកាលដែលខ្យង និងគ្រំជាដើម ជាក់ច្បាស់ហើយដល់បុរសដែលមានភ្នែកឈរមើលត្រង់ច្រាំង ដូច្នោះ ។

[ ១១៨ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់កាន់យកឈ្មោះព្រះខីណាស្រព ទាំងភេទ ទាំងគុណ ដោយអាការ ៧ យ៉ាង ទើបត្រាស់បទថា **អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សមណោ ឥបិតិ** ជាដើម ។ គប្បីជ្រាបវិនិច្ឆ័យ

ក្នុងបទទាំងនោះដូចតទៅនេះ បទថា **ឯវំ ខោ ភិក្ខវេ ភិក្ខុ សមណោ ហោតិ** ជាដើម អធិប្បាយថា ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះថា សមណៈ ព្រោះមានបាបស្ងប់ហើយ ដោយអាការយ៉ាងនេះ ។ ឈ្មោះថា ព្រាហ្មណ៍ ព្រោះមានបាបបន្សាត់ហើយ ។ ឈ្មោះថា **នហាតក** គឺអ្នកងូត ព្រោះមានកិលេសលាងចេញហើយ គឺមានកិលេសកម្ចាត់ចេញហើយ ។ ឈ្មោះថា **វេទគូ** ព្រោះអកុសលធម៌ទាំងឡាយទៅហើយដោយវេទទាំងឡាយ គឺមគ្គញ្ញាណ ៤ អធិប្បាយថា ព្រោះដឹងហើយ ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា **វិទិតស្ស ហោន្តិ** ជាដើម ។ ឈ្មោះថា **សោត្តិយ** ព្រោះកិលេសទាំងឡាយនិទ្រាទៅហើយ គឺព្រោះកិលេសទាំងឡាយមិនហូរចេញទៅមក ។ ឈ្មោះថា **អរិយ** ព្រោះឆ្ងាយចាកកិលេសទាំងឡាយ អធិប្បាយថា ព្រោះកិលេសទាំងឡាយត្រូវកម្ចាត់ហើយ ។ ឈ្មោះថា **អរហន្ត** ព្រោះឆ្ងាយ គឺជាអ្នកឆ្ងាយហើយ ។ ពាក្យដ៏សេស ក្នុងទីទាំងពួងប្រាកដជាក់ច្បាស់ហើយ ៕

**មហាអស្សបុរសូត្រ ចប់**

**សូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ចូឡអស្សបុរសូត្រទី ១០

[ ១១៩ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងនិគមឈ្មោះ អស្សបុរៈ របស់អ្នកស្រុកអង្គៈទាំងឡាយ ក្នុងដែន អង្គៈ ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ មកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះក៏ទទួលស្តាប់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះថា ម្នាល ភិក្ខុទាំងឡាយ អ្នកផងតែងស្គាល់ច្បាស់នូវអ្នកទាំងឡាយថាជា សមណៈៗ ដូច្នេះ ចំណែកអ្នកទាំងឡាយ បើមានគេសួរថា លោកជាអ្វី តែងប្តេជ្ញាខ្លួនថា ពួកយើងជាសមណៈ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយនោះ មាន ឈ្មោះយ៉ាងនេះហើយ ប្តេជ្ញាខ្លួនយ៉ាងនេះហើយ ម្នាលភិក្ខុទាំងឡាយ អ្នក ទាំងឡាយគប្បីសិក្សាយ៉ាងនេះថា បដិបទាសមគួរដល់សមណៈណា យើង ទាំងឡាយនឹងប្រតិបត្តិនូវបដិបទានោះ នេះជាឈ្មោះ ពិតផង ជាសេចក្តីប្តេជ្ញា ពិតផង របស់យើងទាំងឡាយយ៉ាងនេះ មួយទៀតយើងទាំងឡាយបរិភោគ នូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខាររបស់ជនទាំង-ឡាយណា សក្ការៈទាំងឡាយនោះដែលជនទាំងនោះបាន ( បូជា ) ចំពោះយើង ទាំងឡាយ នឹងជាសក្ការៈមានផលច្រើន មានអានិសង្សច្រើន ទាំងបព្វជ្ជា របស់ពួកយើងនេះសោតក៏នឹងមិនទទេ គង់នឹងមានផលមានសេចក្តីចម្រើន ។

[ ១២០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិនូវបដិបទា ដ៏សមគួរ

( ដល់សមណៈ ) តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយមាន អភិជ្ឈាច្រើន ជាអ្នកមិនលះបង់អភិជ្ឈាចេញ មានចិត្តព្យាបាទ ជាអ្នកមិន លះបង់ព្យាបាទចេញ មានសេចក្ដីក្រោធ ជាអ្នកមិនលះបង់សេចក្ដីក្រោធចេញ មានសេចក្ដីគំនុំ ជាអ្នកមិនលះបង់សេចក្ដីគំនុំចេញ មានសេចក្ដីលុបគុណគេ ជាអ្នកមិនលះបង់សេចក្ដីលុបគុណគេចេញ មានសេចក្ដីលើកខ្លួន ជាអ្នកមិន លះបង់សេចក្ដីលើកខ្លួនចេញ មានសេចក្ដីប្រណែន ជាអ្នកមិនលះបង់សេចក្ដី ប្រណែនចេញ មានសេចក្ដីកំណាញ់ ជាអ្នកមិនលះបង់សេចក្ដីកំណាញ់ចេញ មានសេចក្ដីអួតអាង ជាអ្នកមិនលះបង់អំនួតចេញ មានសេចក្ដីលាក់ពុត ជា អ្នកមិនលះបង់សេចក្ដីលាក់ពុតចេញ មានសេចក្ដីប្រាថ្នាលាមក ជាអ្នកមិន លះបង់សេចក្ដីប្រាថ្នាលាមកចេញ មានសេចក្ដីយល់ខុស ជាអ្នកមិនលះបង់ សេចក្ដីយល់ខុសចេញ ។ ម្នាលភិក្ខុទាំងឡាយ ការមិនលះបង់នូវមន្ទិលរបស់ សមណៈ នូវទោសរបស់សមណៈ និងធម៌ជាអម្ចត់របស់សមណៈ ដែលជា ហេតុញុំាងសមណៈឲ្យកើតក្នុងអបាយ និងបច្ច័យឲ្យរងនូវវិបាកជាទុក្ខ ក្នុង ទុគ្គតិភូមិទាំងនេះចោលចេញហើយ តថាគតមិនទាន់ហៅថា អ្នកប្រតិបត្តិនូវ បដិបទាដ៏សមគួរដល់សមណៈទេ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាអាវុធឈ្មោះ មតជៈ មានមុខទាំងសងខាង ដែលបុគ្គលធ្វើឲ្យជោកនឹងទឹកហើយសំលៀង ( លើថ្ម ) ( រួចស៊ក ) អាវុធនោះ ទុកក្នុងស្រោម ហើយស្រែះព័ទ្ធព័ន្ធជុំ វិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបព្វជ្ជារបស់ភិក្ខុនេះថា មាន ឧបមេយ្យ ដូចអាវុធឈ្មោះ មតជៈ នោះដែរ ។

[ ១២១ ] ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលមានសង្ឃាដិថាជាសមណៈ ដោយគ្រាន់តែទ្រទ្រង់សង្ឃាដិប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកឥតសំពត់ ថាជាសមណៈ ដោយគ្រាន់តែឥតសំពត់ប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកសៅហ្មងដោយធូលី និងភក់្លលថាជាសមណៈ ដោយគ្រាន់តែសៅហ្មងដោយធូលី និងភក់្លលប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកចុះត្រាំទឹកថាជាសមណៈ ដោយគ្រាន់តែចុះត្រាំទឹកប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកអាស្រ័យនៅក្បែរគល់ឈើ ថាជាសមណៈ ដោយគ្រាន់តែអាស្រ័យនៅក្បែរគល់ឈើប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកអាស្រ័យនៅក្នុងទីវាល ថាជាសមណៈ ដោយគ្រាន់តែអាស្រ័យនៅក្នុងទីវាលប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នកប្រកាន់ការអេប់កាយ ( ដោយគិតថានឹងរម្ងាប់នូវកិលេស ) ថាជាសមណៈ ដោយគ្រាន់តែប្រកាន់ការអេប់កាយ ( ដោយគិតថានឹងរម្ងាប់កិលេស ) ប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលដែលបរិភោគភត្ត ១ ដង ១ កាល ថាជាសមណៈ ដោយគ្រាន់តែបរិភោគភត្ត ១ ដង ១ កាលប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលអ្នករៀនមន្ត ថាជាសមណៈ ដោយគ្រាន់តែរៀនមន្តប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវភាពនៃបុគ្គលដែល

ទុកផ្នួងសក់ ថាជាសមណៈ ដោយគ្រាន់តែទុកផ្នួងសក់ប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលមានសង្ឃាដិ មានអភិជ្ឈាច្រើនដោយអាងថា ទ្រទ្រង់សង្ឃាដិ ត្រូវលះបង់អភិជ្ឈាចេញ បើមានចិត្តប្រកបដោយព្យាបាទ ត្រូវលះបង់ព្យាបាទចេញ មានសេចក្តីក្រោធត្រូវលះបង់សេចក្តីក្រោធចេញ មានការចងគំនុំ ត្រូវលះបង់ការចងគំនុំចេញ មានសេចក្តីលុបគុណគេ ត្រូវលះបង់សេចក្តីលុបគុណគេចេញ មានសេចក្តីលើកខ្លួន ត្រូវលះបង់សេចក្តីលើកខ្លួនចេញ មានសេចក្តីប្រណែន ត្រូវលះបង់សេចក្តីប្រណែនចេញ មានសេចក្តីកំណាញ់ ត្រូវលះបង់សេចក្តីកំណាញ់ចេញ មានសេចក្តីអួតអាង ត្រូវលះបង់អំនួតចេញ មានសេចក្តីលាក់ពុត ត្រូវលះបង់សេចក្តីលាក់ពុតចេញ មានសេចក្តីប្រាថ្នាលាមក ត្រូវលះបង់សេចក្តីប្រាថ្នាលាមកចេញ មានគំនិតយល់ខុស ត្រូវលះបង់គំនិតយល់ខុសចេញ មិត្តអមាត្យញាតិសាលោហិត គប្បីធ្វើបុគ្គលអ្នកអាងមានសង្ឃាដិនោះ ឲ្យជាអ្នកទ្រទ្រង់សង្ឃាដិក្នុងថ្ងៃនោះឯង ពន្យល់នូវភាពនៃបុគ្គលអ្នកទ្រទ្រង់សង្ឃាដិថា នែលោក មានមុខស្រស់បស់លោកចូរមកនេះ លោកចូរជាអ្នកទ្រទ្រង់សង្ឃាដិចុះ កាលបើលោកមានសង្ឃាដិហើយ តែនៅមានអភិជ្ឈាច្រើន ដោយអាងទ្រទ្រង់សង្ឃាដិ លោកគួរលះបង់អភិជ្ឈាចេញ មានចិត្តប្រកបដោយព្យាបាទ គួរលះបង់ព្យាបាទចេញ មានសេចក្តីក្រោធ គួរលះបង់សេចក្តីក្រោធចេញ មានការចងគំនុំ គួរលះបង់ការចងគំនុំចេញ មានសេចក្តីលុបគុណគេ គួរលះបង់សេចក្តីលុបគុណគេចេញ មានសេចក្តីលើកខ្លួន គួរលះបង់សេចក្តីលើកខ្លួនចេញ មាន

សេចក្តីប្រណែន គួរលះបង់សេចក្តីប្រណែនចេញ មានសេចក្តីកំណាញ់ គួរលះបង់សេចក្តីកំណាញ់ចេញ មានសេចក្តីអួតអាង គួរលះបង់អំនួតចេញ មានសេចក្តីលាក់ពុត គួរលះបង់សេចក្តីលាក់ពុតចេញ មានសេចក្តីប្រាថ្នាលាមក គួរលះបង់សេចក្តីប្រាថ្នាលាមកចេញ មានគំនិតយល់ខុស គួរលះបង់គំនិតយល់ខុសចេញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញច្បាស់នូវបុគ្គលពួកមួយក្នុងលោកនេះ សូម្បីជាអ្នកមានសង្ឃាដិហើយ តែនៅមានអភិជ្ឈាច្រើន មានចិត្តប្រកបដោយព្យាបាទ មានសេចក្តីក្រោធ មានការចងគំនុំ មានសេចក្តីលុបគុណគេ មានសេចក្តីលើកខ្លួន មានសេចក្តីប្រណែន មានសេចក្តីកំណាញ់ មានសេចក្តីអួតអាង មានសេចក្តីលាក់ពុត មានសេចក្តីប្រាថ្នាលាមក មានគំនិតយល់ខុសនៅឡើយ ព្រោះហេតុណា ហេតុនោះ បានជាតថាគតមិនទាន់ហៅនូវភាពនៃបុគ្គលមានសង្ឃាដិ ថាជាសមណៈ ដោយគ្រាន់តែទ្រទ្រង់សង្ឃាដិប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលមិនមានសំពត់ ។បេ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលសៅហ្មងដោយធូលីនិងភក្អែល ... ម្នាលភិក្ខុទាំងឡាយ បើបុគ្គលចុះត្រាំទឹក ... ម្នាលភិក្ខុទាំងឡាយ បើបុគ្គលអាស្រ័យនៅក្បែរគល់ឈើ ... ម្នាលភិក្ខុទាំងឡាយ បើបុគ្គលអាស្រ័យនៅក្នុងទីវាល ... ម្នាលភិក្ខុទាំងឡាយ បើបុគ្គលប្រកាន់ការអេប់កាយ ... ម្នាលភិក្ខុទាំងឡាយ បើបុគ្គលបរិភោគភត្ត ១ ដង ១ កាល ... ម្នាលភិក្ខុទាំង-ឡាយ បើបុគ្គលរៀនមន្ត ... ម្នាលភិក្ខុទាំងឡាយ បើបុគ្គលទុកផ្នួងសក់មែន តែនៅមានអភិជ្ឈាច្រើន ដោយអាងថា ទុកផ្នួងសក់ប៉ុណ្ណោះ បុគ្គលនោះត្រូវ

លះអភិជ្ឈាចេញ មានចិត្តប្រកបដោយព្យាបាទ ត្រូវលះព្យាបាទចេញ មានសេចក្តីក្រោធ ត្រូវលះបង់សេចក្តីក្រោធចេញ មានការចងគំនុំ ត្រូវលះបង់ការចងគំនុំចេញ មានសេចក្តីលុបគុណគេ ត្រូវលះបង់សេចក្តីលុបគុណគេចេញ មានសេចក្តីលើកខ្លួន ត្រូវលះបង់សេចក្តីលើកខ្លួនចេញ មានសេចក្តីប្រណែន ត្រូវលះបង់សេចក្តីប្រណែនចេញ មានសេចក្តីកំណាញ់ ត្រូវលះបង់សេចក្តីកំណាញ់ចេញ មានសេចក្តីអួតអាង ត្រូវលះបង់អំនួតចេញ មានសេចក្តីលាក់ពុត ត្រូវលះបង់សេចក្តីលាក់ពុតចេញ មានសេចក្តីប្រាថ្នាលាមក ត្រូវលះបង់សេចក្តីប្រាថ្នាលាមកចេញ មានគំនិតយល់ខុស ត្រូវលះបង់គំនិតយល់ខុសចេញ មិត្តអមាត្យ ញាតិសាលោហិត គប្បីធ្វើបុគ្គលដែលទុកផ្នួងសក់នោះ ឲ្យជាអ្នកទុកផ្នួងសក់ក្នុងថ្ងៃនោះឯង ហើយពន្យល់នូវកាពនៃបុគ្គលអ្នកទ្រទ្រង់ផ្នួងសក់ថា នែលោកមានមុខស្រស់បស់ លោកចូរមកនេះ លោកចូរជាអ្នកទុកផ្នួងសក់ចុះ កាលបើលោកទុកផ្នួងសក់ហើយ តែនៅមានអភិជ្ឈាច្រើនដោយអាងថា ទុកផ្នួងសក់នោះប៉ុណ្ណោះ លោកគួរលះបង់អភិជ្ឈាចេញ មានចិត្តប្រកបដោយព្យាបាទ គួរលះបង់ព្យាបាទចេញ មានសេចក្តីក្រោធ គួរលះបង់សេចក្តីក្រោធចេញ មានការចងគំនុំ គួរលះបង់ការចងគំនុំចេញ មានសេចក្តីលុបគុណគេ គួរលះបង់សេចក្តីលុបគុណចេញ មានសេចក្តីលើកខ្លួន គួរលះបង់សេចក្តីលើកខ្លួនចេញ មានសេចក្តីប្រណែន គួរលះបង់សេចក្តីប្រណែនចេញ មានសេចក្តីកំណាញ់ គួរលះបង់សេចក្តីកំណាញ់ចេញ មានសេចក្តីអួតអាង គួរលះបង់អំនួតចេញ មានសេចក្តីលាក់ពុត គួរលះបង់

សេចក្តីលាក់ពុតចេញ មានសេចក្តីប្រាថ្នាលាមក គួរលះបង់សេចក្តីប្រាថ្នាលាមកចេញ មានគំនិតយល់ខុស គួរលះបង់គំនិតយល់ខុសចេញ ។ ម្នាលភិក្ខុទាំងឡាយ តថាគតឃើញច្បាស់នូវបុគ្គលពួកមួយក្នុងលោកនេះ សូម្បីទុកផ្នួងសក់ តែនៅមានអភិជ្ឈាច្រើន មានចិត្តប្រកបដោយព្យាបាទ មានសេចក្តីក្រោធ មានការចងគំនុំ មានសេចក្តីលុបគុណគេ មានសេចក្តីលើកខ្លួន មានសេចក្តីប្រណែន មានសេចក្តីកំណាញ់ មានសេចក្តីអួតអាង មានសេចក្តីលាក់ពុត មានសេចក្តីប្រាថ្នាលាមក មានគំនិតយល់ខុសនៅឡើយ ព្រោះហេតុណា ហេតុនោះ បានជាតថាគតមិនហៅបុគ្គលដែលទុកផ្នួងសក់ថាជាសមណៈ ដោយត្រឹមតែទុកផ្នួងសក់ប៉ុណ្ណោះទេ ។

[ ១២២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិនូវបដិបទាដ៏សមគួរដល់សមណៈតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយ មានអភិជ្ឈាច្រើន ជាអ្នកលះបង់អភិជ្ឈាចេញ មានចិត្តប្រកបដោយព្យាបាទ ជាអ្នកលះបង់ព្យាបាទចេញ មានសេចក្តីក្រោធ ជាអ្នកលះបង់សេចក្តីក្រោធចេញ មានការចងគំនុំ ជាអ្នកលះបង់ការចងគំនុំចេញ មានសេចក្តីលុបគុណគេ ជាអ្នកលះបង់សេចក្តីលុបគុណគេចេញ មានសេចក្តីលើកខ្លួន ជាអ្នកលះបង់សេចក្តីលើកខ្លួនចេញ មានសេចក្តីប្រណែន ជាអ្នកលះបង់សេចក្តីប្រណែនចេញ មានសេចក្តីកំណាញ់ ជាអ្នកលះបង់សេចក្តីកំណាញ់ចេញ មានសេចក្តីអួតអាង ជាអ្នកលះបង់អំនួតចេញ មានសេចក្តីលាក់ពុត ជាអ្នកលះបង់សេចក្តីលាក់ពុតចេញ មានសេចក្តីប្រាថ្នាលាមក ជាអ្នកលះបង់សេចក្តីប្រាថ្នាលាមក

ចេញ មានគំនិតយល់ខុស ជាអ្នកលះបង់គំនិតយល់ខុសចេញ ។ ម្នាលភិក្ខុទាំងឡាយ ការលះបង់នូវមន្ទិលរបស់សមណៈ នូវទោសរបស់សមណៈ នូវធម៌ជាគ្រឿងអម្ចត់របស់សមណៈ ដែលជាហេតុញ៉ាំងសមណៈឲ្យកើតក្នុងអបាយ ទាំងជាបច្ច័យឲ្យទទួលនូវវិបាកជាទុក្ខ ក្នុងទុគ្គតិភូមិ ទាំងនេះចេញហើយ ទើបតថាគតហៅថា ជាអ្នកប្រតិបត្តិនូវបដិបទាដ៏សមគួរដល់សមណៈមែន ។ ភិក្ខុនោះ ឃើញច្បាស់នូវខ្លួនថា បរិសុទ្ធ ឃើញច្បាស់នូវខ្លួនថារួចហើយចាកពួកអកុសលធម៌ដ៏លាមក ទាំងអស់នេះ ។ កាលបើភិក្ខុនោះឃើញច្បាស់នូវខ្លួនថាបរិសុទ្ធ ឃើញច្បាស់នូវខ្លួនថារួចចាកពួកអកុសលធម៌ដ៏លាមកទាំងអស់នេះហើយ បាមោជ្ជ គឺសេចក្ដីត្រេកអរទន់ក៏កើតឡើង កាលបើភិក្ខុមានបាមោជ្ជហើយ បីតិក៏កើតឡើង កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់ស្ងាត់ កាលបើភិក្ខុមានកាយស្ងប់ស្ងាត់ហើយ រមែងទទួលនូវសុខ ភិក្ខុដែលមានចិត្តទទួលសុខហើយ ចិត្តក៏នឹងជឹងល្អ ។ ភិក្ខុនោះមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទាំងទិសខាងលើ និងទិសខាងក្រោម ទិសទទឹងគឺទិសជុំវិញ ក៏ដូចគ្នា ទាំងមានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ គឺយកសត្វជាអនេកមកជាអារម្មណ៍ ជាចិត្តប្រកបដោយមហគ្គតភូមិ ឥតមានប្រមាណ គឺបានចម្រើនហើយ ជាចិត្តមិនមានពៀរ គឺមិនមានទោស មិនមានព្យាបាទ គឺ មិនមានទុក្ខ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះយកខ្លួនប្រៀបនឹងសត្វទាំងអស់គ្រប់ទិស ។ ភិក្ខុមានចិត្តប្រកបដោយករុណា ... មាន

ចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទាំងទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺ ទិសជុំវិញ ក៏ដូចគ្នា ទាំងមានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រកបក្នុងមហគ្គតភូមិ ឥតមានប្រមាណ ជាចិត្តមិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះយកខ្លួនប្រៀបនឹងសត្វទាំងអស់គ្រប់ទិស ។ ម្នាលភិក្ខុទាំងឡាយ ដូចជាស្រះបោក្ខរណីដែលមានទឹកថ្លាឆ្វង់ មានទឹកឆ្ងាញ់ មានទឹកត្រជាក់ មានទឹកថ្លាស្អាត ( មិនមានកករ ) មានកំពង់ល្អ គួរជាទីរីករាយ ។ ទោះបីបុរសមកអំពីទិសខាងកើត មានខ្លួនក្តៅក្រហាយ ដោកដាំដោយចំហាយកម្តៅ មានកាយនឿយព្រួយ តក់ស្លុត ស្រេក ។ បុរសនោះ មកដល់ស្រះបោក្ខរណីនោះហើយ ក៏បន្ទោបង់នូវសេចក្តីស្រេកទឹក ទាំងបន្ទោបង់នូវសេចក្តីក្តៅក្រហាយដោយចំហាយកម្តៅចេញបាន ។ ទោះបីបុរសមកពីទិសខាងលិច ... ទោះបីបុរសមកពីទិសខាងជើង ... ទោះបីបុរសមកពីទិសខាងត្បូង ... ទោះបីបុរសមកអំពីទិសណាៗ មានខ្លួនក្តៅក្រហាយដោកដាំ ដោយចំហាយកម្តៅ មានកាយនឿយព្រួយ តក់ស្លុត មានសេចក្តីស្រេក ។ បុរសនោះ មកដល់ស្រះបោក្ខរណីនោះហើយ ក៏បន្ទោបង់សេចក្តីស្រេកទឹក ទាំងបន្ទោបង់នូវសេចក្តីក្តៅក្រហាយ ដោយចំហាយកម្តៅចេញបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ទោះបីបុគ្គលចេញចាកខត្តិយត្រកូល ចេញចាកគេហដ្ឋានចូលទៅកាន់ផ្នួសក៏យ៉ាងនោះដែរ ។ ក៏បព្វជិតនោះ អាស្រ័យនូវធម៌វិន័យ ដែល

តថាគតត្រាស់សម្តែងហើយ បានចម្រើននូវមេត្តា ករុណា មុទិតា ឧបេក្ខា យ៉ាងនេះ តថាគត ហៅបព្វជិតនោះថា ជាអ្នកប្រតិបត្តិនូវបដិបទាដ៏សមគួរ ដល់សមណៈ ដ៏ស្ងប់រម្ងាប់ ប្រព្រឹត្តទៅក្នុងសន្តានមែន ។ ទោះបីបុគ្គល ចេញចាកព្រាហ្មណត្រកូល ... ទោះបីបុគ្គលចេញចាកវេស្សត្រកូល ... ទោះ បីបុគ្គលចេញចាកសុទ្ទត្រកូល ... ទោះបីបុគ្គលចេញចាកត្រកូលណាៗ ចេញ ចាកគេហដ្ឋានណាៗ ចូលទៅកាន់ផ្នួស ។ ក៏បព្វជិតនោះអាស្រ័យនូវធម៌វិន័យ ដែលតថាគតសម្តែងហើយ បានចម្រើននូវមេត្តា ករុណា មុទិតា ឧបេក្ខា យ៉ាងនេះ តថាគត ហៅបព្វជិតនោះថា ជាអ្នកប្រតិបត្តិនូវបដិបទាដ៏សមគួរ ដល់សមណៈ ដ៏ស្ងប់រម្ងាប់ប្រព្រឹត្តទៅក្នុងសន្តានមែន ។ ទោះបីបុគ្គលចេញ ចាកខត្តិយត្រកូល ចេញចាកគេហដ្ឋានចូលទៅកាន់ផ្នួស ។ ក៏បព្វជិតនោះ ធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយខ្លួនឯងក្នុងបច្ចុប្បន្ន តថាគតហៅ បព្វជិតនោះថាជាសមណៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ទោះបី បុគ្គលចេញចាកព្រាហ្មណត្រកូល ... ទោះបីបុគ្គលចេញចាកវេស្សត្រកូល ... ទោះបីបុគ្គលចេញចាកសុទ្ទត្រកូល ... ទោះបីបុគ្គលចេញចាកត្រកូលណាៗ ចេញចាកគេហដ្ឋានណាៗ ចូលទៅកាន់ផ្នួស ។ ក៏បព្វជិតនោះធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅ នៃអាសវៈទាំងឡាយដោយខ្លួនឯងក្នុងបច្ចុប្បន្ន តថាគតហៅបព្វជិតនោះថាជា សមណៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ លុះព្រះមានព្រះភាគ ទ្រង់

ត្រាស់នូវសុភាសិតនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរហើយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចូឡអស្សបុរសូត្រទី ១០ ចប់
មហាយមកវគ្គទី ៤ ចប់

## ឧទ្ទាននៃមហាយមកវគ្គ

ឧទ្ទានគឺបញ្ជីរឿងនៃមហាយមកវគ្គទី ៤ នោះគឺ និយាយពីព្រះមានព្រះភាគគង់ក្នុងរោងដែលកដោយឥដ្ឋ ក្នុងព្រៃគោសិង្គសាលវ័ន ( មានក្នុងចូឡ-គោសិង្គសាលសូត្រ និងមហាគោសិង្គសាលសូត្រ ) ១ និយាយពីធម៌ប្រៀបដោយគោបាល គួររក្សាគោបាននិងមិនបាន ( មានក្នុងមហាគោបាលសូត្រ ) ១ និយាយពីគោបាលមានប្រាជ្ញាម្តងទៀត ( មានក្នុងចូឡគោបាលសូត្រ ) ១ និយាយពីព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងវេសាលី ( មានក្នុងចូឡសច្ចកសូត្រ ) ១ និយាយពីព្រះមានព្រះភាគ មានព្រះភក្ត្រជ្រះថ្លាជាដើម ( មានក្នុងមហាសច្ចកសូត្រ ) ១ ។ និយាយពីព្រះឥន្ទ្រាធិរាជ ប្រកបដោយតណ្ហា ( មានក្នុងចូឡតណ្ហាសង្ខយសូត្រ ) ១ និយាយពីសាតិភិក្ខុកេវដ្តបុត្រ ( មានក្នុងមហាតណ្ហាសង្ខយសូត្រ ) ១ និយាយពីពាក្យថាសមណៈ មានក្នុងមហាអស្សបុរសូត្រ ១ និយាយពីសមណៈទុកផ្លូវសក់ មានក្នុងចូឡអស្សបុរសូត្រ ១ ។

# អដ្ឋកថា

## ចូឡអស្សបុរសូត្រទី ១០

[ ១១៩ ] ចូឡអស្សបុរសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ហេតុនៃការសម្ដែងព្រះសូត្រនេះ ដូចគ្នានឹងសូត្រមុននោះឯង ។ បទថា **សមណសាមីចិប្បដិបទា** បានដល់ បដិបទាដែលសមគួរដល់សមណៈទាំងឡាយ គឺបដិបទាដែលឧបការៈដល់សមណៈទាំងឡាយ ។

[ ១២០ ] ក្នុងបទថា **សមណមលានំ** ជាដើម សេចក្ដីថា ធម៌ទាំងឡាយនេះ កាលកើតឡើង រមែងធ្វើសមណៈទាំងឡាយឲ្យមានមន្ទិល គឺមន្ទិលចាប់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ជាមន្ទិលរបស់សមណៈ ។ សមណៈទាំងឡាយ រមែងវិនាស រមែងប្រទូស្ដដោយមន្ទិលទាំងនោះ ព្រោះដូច្នោះ ទើបត្រាស់ថា ជាទោសរបស់សមណៈ ។ ធម៌ទាំងនេះ កើតឡើងហើយ រមែងធ្វើសមណៈទាំងឡាយឲ្យដូចជាសំរាម អស់នូវឱជៈ ឲ្យក្រៀមស្ងួត ព្រោះដូច្នោះ ទើបត្រាស់ថា ដូចទឹកអម្ចត់របស់សមណៈ ដូច្នេះ ។ បទថា **អបាយិកានំ ឋានានំ** សេចក្ដីថា ហេតុឲ្យកើតក្នុងអបាយ ។ បទថា **ទុគ្គតិវេទនីយានំ** សេចក្ដីថា ជាបច្ច័យនៃការសោយវិបាកក្នុងទុគ្គតិ ។

បទថា **មតជន្នាម** សេចក្ដីថា ពួកមនុស្សកោសដែករឹងដោយដែក ហើយប្រឡប់កម្ទេចដែកនោះជាមួយសាច់ឲ្យសត្វក្រៀលស៊ី សត្វក្រៀលទាំងនោះ មិនអាចបន្ទោបង់ឧច្ចារៈក៏ស្លាប់ បើមិនស្លាប់ ក៏វាយឲ្យស្លាប់ ។ កាលបើដូច្នោះ ក៏វះពោះរបស់សត្វក្រៀលទាំងនោះ យកទឹកលាងកម្ទេចដែកទាំង

នោះ កាន់យកម្ចេចដែកទាំងនោះ លាយជាមួយសាច់ ឲ្យក្រៀលទាំងឡាយស៊ី ធ្វើយ៉ាងនោះរហូត ៧ ដង ហើយធ្វើអាវុធដោយកម្ទេចដែកដែលកាន់យកហើយ ជាងដែកដែលសិក្សាល្អហើយ បានមូលហេតុហត្ថកម្មដ៏ច្រើន រមែងធ្វើអាវុធនោះ ទើបគេហៅអាវុធនោះថា **មគជ** ព្រោះកើតអំពីបក្សីដែលស្លាប់ហើយ ។ អាវុធនោះ ជាអាវុធមុតថ្លាក្រៃពេក ។ បទថា **បីតិនិសិត្តំ** បានដល់ ផ្សើមដោយទឹក និងសំលៀងដោយថ្ម ។ បទថា **សង្ឃាដិយា** បានដល់ស្រោម ។ បទថា **សម្បារុតំ** បានដល់ រុំហើយ ។ បទថា **សម្បលិវេមិតំ** បានដល់ ព័ទ្ធព័ន្ធដោយជុំវិញ ។

[ ១២១ ] បទថា **រជោជល្លិកស្ស** បានដល់ បុគ្គលប្រឡាក់ដោយធូលី ។ បទថា **ឧទកោរោហកស្ស** បានដល់ ចុះងូតទឹកមួយថ្ងៃ ៣ ដង ។ បទថា **រុក្ខមូលិកស្ស** បានដល់ នៅត្រង់គល់ឈើ ។ បទថា **អព្ភោកាសិកស្ស** បានដល់ នៅកណ្តាលវាល ។ បទថា **ឧព្ភដ្ឋកស្ស** បានដល់ ការអប់កាយ ។ បទថា **បរិយាយភត្តិកស្ស** បានដល់ ការបរិភោគអាហារមួយខែម្តង ឬកន្លះខែម្តង ពាក្យទាំងអស់នោះ ត្រាស់ដល់លទ្ធិខាងក្រៅ ។ ព្រោះក្នុងសាសនានេះ ភិក្ខុដែលទ្រទ្រង់ចីវរ មិនហៅថា គ្រងសង្ឃាដី ។ ម្យ៉ាងទៀត វត្ត មានការប្រឡាក់ដោយធូលីជាដើម ក្នុងសាសនានេះក៏មិនមាន ព្រះតម្រាស់របស់ព្រះសម្ពុទ្ធប៉ុណ្ណោះ ជាឈ្មោះនៃព្រះពុទ្ធវចនៈ មិនមែនមន្ត ព្រោះដូច្នោះ បទថា **រុក្ខមូលិកោ អព្ភោកាសិកោ** រមែងបានត្រឹមនេះប៉ុណ្ណោះ ។ ពាក្យដែលពោលហើយនោះ ត្រាស់ដោយលទ្ធិខាងក្រៅ ។ បទថា **ជាតមេវ ធំ** បានដល់

គ្រាន់តែកើតហើយក្នុងថ្ងៃនោះឯង ។ បទថា **សង្ឃាដិកំ ករេយ្យំ** សេចក្តីថា ស្លៀកហើយ ដណ្តប់ហើយ នូវសំពត់សង្ឃាដី គប្បីធ្វើឲ្យជាសង្ឃាដី ។ ក្នុងពាក្យទាំងពួងក៏ន័យនេះ ។

[ ១២២ ] បទថា **វិសុទ្ធមត្តានំ សមនុបស្សតិ** សេចក្តីថា ភិក្ខុនោះរមែងឃើញ ខ្លួនថាបរិសុទ្ធ ។ តែបទថា បរិសុទ្ធដូច្នេះ មិនគប្បីពោលមុន ។ បទថា **បាមោជ្ជំ ជាយតិ** បានដល់ អាការនៃសេចក្តីត្រេកអររមែងកើតឡើង អធិប្បាយថា បីតិដែលញុំាងសរីរៈទាំងមូលឲ្យសោមនស្សហើយ ត្រេកអរហើយដោយបីតិ ឲ្យញាប់ញ័រកើតឡើង ។ បទថា **បីតិមនស្ស កាយោ** បានដល់ នាមកាយរបស់បុគ្គលដែលប្រកបហើយដោយបីតិ ។ បទថា **បស្សម្ភតិ** បានដល់ ប្រាសចាកការក្រវល់ក្រវាយ ។ បទថា **សុខំ វេទេតិ** សេចក្តីថា រមែងសោយសេចក្តីសុខតាមផ្លូវកាយខ្លះ ផ្លូវចិត្តខ្លះ ។ បទថា **ចិត្តំ សមាធិយតិ** សេចក្តីថា ចិត្តរបស់បុគ្គលដែលមានសេចក្តីសុខ ដោយនេក្ខម្មសុខនេះ រមែងតាំងមាំ រមែងហាក់ដូចចាក់ឫសដល់អប្បនា ។ បទថា **សោ មេត្តាសហគតេន ចេតសា** សេចក្តីថា ទេសនាដែលព្រះមានព្រះភាគទ្រង់ផ្តើមហើយ ដោយអំណាចនៃកិលេសខាងដើម ឈមចុះហើយកាន់ការចម្រើនព្រហ្មវិហារតាមអនុសន្ធិ ដូចភ្លៀងដែលធ្លាក់ហើយធ្លាក់ទៀតលើភ្នំ ហូរចុះកាន់ស្ទឹង ដូច្នោះ ។ បណ្តាពាក្យទាំងនោះ ពាក្យដែលគួរពោលទាំងអស់បានពោលហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **សេយ្យថាបិ ភិក្ខវេ បោក្ខរណី** នេះ គប្បីជ្រាបក្នុងមហាសីហនាទសូត្រ ។ មគ្គ ព្រះមានព្រះភាគ ប្រៀប

*ដោយស្រះបោក្ខរណីធំ ព្រះសាស្តាទ្រង់ប្រៀបធៀបក្នុងទីនេះ ។ បទថា* **អាសវានំ ខយា សមណោ ហោតិ** *សេចក្តីថា ឈ្មោះថា ជាសមណៈយ៉ាងក្រៃលែង ព្រោះកិលេសទាំងអស់ស្ងប់ហើយ ។ ពាក្យដ៏សេស ក្នុងទីទាំងពួងមានអត្ថងាយយល់ហើយនោះឯង ។*

**ចូឡអស្សបុរសូត្រ ចប់**

**សូត្រទី ១០ ចប់**

**វគ្គទី ៤ ចប់**

# សុត្តន្តបិដក

## ចូឡយមកវគ្គ

## សាលេយ្យកសូត្រទី ១

[ ១២៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ទីចារិក ក្នុងកោសលជនបទ ជាមួយនឹងព្រះភិក្ខុសង្ឃច្រើនរូប បានស្តេចទៅដល់ស្រុកព្រាហ្មណ៍ ឈ្មោះសាលៈ ជាខេត្តរបស់កោសលជនបទ ។ ពួកព្រាហ្មណ៍ និងគហបតិ អ្នកស្រុកសាលៈ បានឮ ( ដំណឹង ) ហើយ ក៏ប្រកាសពាក្យនេះថា ម្នាលគ្នាយើង ឮថា ព្រះសមណគោតមជាសក្យបុត្រ ចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ទ្រង់ស្តេចទៅកាន់ទីចារិក ក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃច្រើនរូប ឥឡូវស្តេចមកដល់សាលគ្រាមហើយ ។ កិត្តិសព្ទដ៏ល្អរបស់ព្រះគោតមដ៏មានព្រះភាគនោះ ល្បីឮខ្ទរខ្ទាយយ៉ាងនេះថា ព្រះមានព្រះភាគ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឯង បរិបូណ៌ដោយវិជ្ជា និងចរណៈ គឺសេចក្តីដឹង និងកិរិយាដែលបុគ្គលគប្បីប្រព្រឹត្ត មានដំណើរទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ចធម៌ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះអង្គទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញា ចំពោះព្រះអង្គឯង នូវលោកនេះ ព្រមទាំងទេវលោក មារលោក

ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយទ្រង់ប្រកាស ព្រះអង្គទ្រង់សំដែងធម៌ មានពីរោះបទដើម មានពីរោះបទកណ្ដាល មានពីរោះបទចុងប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញនូវព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងហ្នឹង ជាការប្រពៃពេក ។ គ្រានោះ ពួកព្រាហ្មណ៍ និងគហបតិ អ្នកស្រុកសាលគ្រាម នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយពួកខ្លះ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ អង្គុយក្នុងទីដ៏សមគួរ ប្រណម្យអញ្ជលីឆ្ពោះទៅព្រះមានព្រះភាគ ពួកខ្លះប្រកាសនូវនាម និងគោត្រក្នុងទីជិតព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ អង្គុយស្ងៀមក្នុងទីដ៏សមគួរ ។ កាលព្រាហ្មណ៍ និងគហបតិ អ្នកស្រុកសាលៈអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសួរពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្ដេច បច្ច័យដូចម្ដេច បានជាសត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈទៅកើតក្នុងអបាយ ( ទីមិនមានសេចក្ដីចម្រើន គឺតិរច្ឆានកំណើត ) ទុគ្គតិ ( ដំណើរដែលផ្អែកនឹងទុក្ខ គឺអសុរកាយ ) វិនិបាត ( ទីសម្រាប់ទម្លាក់នូវបុគ្គលធ្វើអំពើអាក្រក់ គឺប្រេតវិស័យ ) និរយៈ ( ទីមិនមាន

សេចក្តីសប្បាយ គឺនរក ) បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាសត្វទាំងឡាយ ពួកខ្លះក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងមនុស្ស សុគតិ សួគ៌ ទេវលោក ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតីទាំងឡាយ សត្វទាំងឡាយពួកខ្លះក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយទុគ្គតិ វិនិបាត នរក ព្រោះហេតុតែកិរិយា ប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តតាមធម៌យ៉ាងនេះឯង ម្នាលគហបតីទាំងឡាយ សត្វទាំងឡាយ ពួកខ្លះក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺមនុស្ស សុគតិ ឋានសួគ៌ ព្រោះហេតុតែកិរិយាប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌យ៉ាងនេះឯង ។ ព្រាហ្មណ៍ និងគហបតិ ក្រាបបង្គំទូលថា កាលបើព្រះគោតមដ៏ចម្រើននេះ សម្តែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារហើយ យើងទាំងឡាយមិនអាចនឹងដឹងសេចក្តីដោយពិស្តារទៅបានទេ កាលបើព្រះគោតមដ៏ចម្រើននេះ សម្តែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារទេ តែថា យើងទាំងឡាយ អាចនឹងដឹងសេចក្តីដោយពិស្តារទៅបានដោយប្រការយ៉ាងណា សូមព្រះគោតមដ៏ចម្រើន ទ្រង់ព្រះមេត្តាប្រោសសម្តែងធម៌ដល់យើងខ្ញុំទាំងឡាយ ដោយប្រការយ៉ាងនោះឲ្យទាន ។ ព្រះអង្គត្រាស់ថា ម្នាលគហបតិទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ ពួកព្រាហ្មណ៍ និងគហបតិអ្នកស្រុកសាលៈ ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា

ព្រះអង្គ ។

[ ១២៤ ] ព្រះមានព្រះភាគត្រាស់ភាសិតនេះថា ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តតាមធម៌ដោយកាយមាន ៣ ប្រការ កិរិយាប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តតាមធម៌ដោយវាចាមាន ៤ ប្រការ កិរិយាប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តតាមធម៌ដោយចិត្តមាន ៣ ប្រការ ។ ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលគហបតិទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាមនុស្សអាក្រក់ មានបាតដៃប្រឡាក់ដោយឈាម មានចិត្តបោះជាប់ក្នុងការសម្លាប់សត្វ ជាអ្នកមិនមានសេចក្តីអៀនខ្មាស មានចិត្តមិនអាសូរចំពោះពួកសត្វទាំងអស់ ។ មួយទៀត ជាអ្នកកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដូចជាគ្រឿងឧបករណ៍ គឺសម្បត្តិនៃបុគ្គលដទៃណា ដែលគេទុកក្នុងស្រុកក្តី ទុកក្នុងព្រៃក្តី ជាអ្នកកាន់យកគ្រឿងឧបករណ៍ដែលគេមិនបានឲ្យនោះ ដោយចំណែកនៃចិត្តលួច ។ មួយទៀត ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ដូចជាស្ត្រីទាំងឡាយណា គឺស្ត្រីដែលមាតារក្សា ដែលបិតារក្សា ដែលមាតាបិតារក្សា ដែលបងប្អូនប្រុសរក្សា ដែលបងប្អូនស្រីរក្សា ដែលញាតិរក្សា ដែលមានស្វាមី ដែលប្រកបដោយអាជ្ញា ដោយហោចទៅសូម្បីតែស្ត្រីដែលបុរសបំពាក់កម្រងផ្កាឲ្យ ជាអ្នកដល់នូវការប្រព្រឹត្តកន្លងក្នុងស្ត្រីទាំងឡាយ មានសភាពដូច្នោះ ។ ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តតាមធម៌ ដោយកាយមាន ៣ ប្រការ

យ៉ាងនេះឯង ។ ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តតាមធម៌ ដោយវាចាមាន ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលគហបតិទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកពោលពាក្យកុហក ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិស័ទក្តី ឋិតនៅក្នុងកណ្តាលញាតិក្តី ឋិតនៅកណ្តាលសេនិយក្តី ឋិតនៅកណ្តាលរាជត្រកូលក្តី គេនាំទៅធ្វើជាសាក្សី ហើយសួរថា នៃបុរសដ៏ចម្រើន ចូរអ្នកមកនេះ បើអ្នកដឹងហេតុណា ចូរនិយាយហេតុនោះ ។ បុរសនោះ កាលមិនដឹង និយាយថា ខ្ញុំដឹង ឬកាលដឹង និយាយថា ខ្ញុំមិនដឹង កាលមិនឃើញ និយាយថា ខ្ញុំឃើញ ឬកាលឃើញ និយាយថា ខ្ញុំមិនឃើញ ។ ជាអ្នកពោលពាក្យកុហកទាំងដឹងខ្លួន ព្រោះហេតុតែខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុសំណូក គឺអាមិសបន្តិចបន្តួចក្តី ។ មួយទៀត ជាអ្នកពោលនូវពាក្យញុះញង់ គឺឮពាក្យអំពីសំណាក់ជននេះហើយ នាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះ ឮពាក្យអំពីជនឯណោះហើយ នាំយកមកប្រាប់ជននេះ ដើម្បីបំបែកជនឯណោះ ជាអ្នកបំបែកនូវពួកជនដែលព្រមព្រៀងគ្នាផង ជាអ្នកជម្រុលពួកជន ដែលបែកគ្នាហើយផង ជាអ្នកត្រេកអរតែក្នុងពួក មានតម្រេកក្នុងពួក ជាអ្នករីករាយតែក្នុងពួក ជាអ្នកពោលនូវវាចា ដែលធ្វើឲ្យប្រកាន់ពួក ដូច្នេះឯង ។ មួយទៀត ជាអ្នកពោលពាក្យអាក្រក់ គឺវាចាណា ទ្រគោះ ខ្នោះខ្នួរ រោលរាល ស្ទាក់ដំណើរជនដទៃ ជាវាចាជិតនឹងសេចក្តីក្រោធ មិនប្រព្រឹត្តទៅដើម្បីសមាធិបាន ហើយជាអ្នកពោលនូវវាចា មានសភាព ដូច្នោះ ។ មួយវិញទៀត ជាអ្នកពោលនូវពាក្យ

មិនមានប្រយោជន៍ ពោលពាក្យខុសកាល ពោលនូវពាក្យមិនពិត ពោលពាក្យមិនមែនជាអត្ថ ពោលពាក្យមិនមែនជាធម៌ ពោលពាក្យមិនមែនជាវិន័យ ពោលពាក្យដែលមិនគួរ តាំងទុកក្នុងហឫទ័យខុសកាល ប្រាសចាកគ្រឿងអាង ជាពាក្យមិនមានទីបំផុត មិនប្រកបដោយប្រយោជន៍ ។ ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តតាមធម៌ ដោយវាចាមាន ៤ ប្រការដូច្នេះឯង ។ ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តតាមធម៌ ដោយចិត្តមាន ៣ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ច្រើនដោយអភិជ្ឈា គយគន់នូវគ្រឿងឧបករណ៍ ដែលជាសម្បត្តិនៃបុគ្គលដទៃ ដោយគិតថា ឱហ្ន៎ ! គ្រឿងឧបករណ៍ដែលជាសម្បត្តិនៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមកអាត្មាអញ ។ មួយទៀត ជាអ្នកមានចិត្តព្យាបាទ មានតម្រិះក្នុងចិត្តដែលទោសប្រទូស្តហើយថា សត្វទាំងឡាយ ចូរលំបាកខ្លះ ចូរស្លាប់ខ្លះ ចូរវិនាសសាបសូន្យទៅខ្លះ ដែលថា មិនវិនាស កុំឲ្យមានឡើយ ។ មួយវិញទៀត ជាអ្នកមានគំនិតយល់ខុស ឃើញនូវសេចក្តីវិបរិតថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំ មិនមានផល ការបូជាតូចក៏មិនមានផល ផលវិបាកនៃកុសលាកុសលកម្ម ដែលសត្វធ្វើល្អ និងអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ សត្វទាំងឡាយជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយខ្លួនឯង នូវ

លោកនេះ និងលោកខាងមុខ ហើយសម្តែងក៏មិនមាន ។ ម្នាលគហបតិទាំង-ឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តតាមធម៌ដោយចិត្តមាន ៣ ប្រការយ៉ាងនេះឯង ។ ម្នាលគហបតិទាំងឡាយ សត្វទាំងឡាយពួកខ្លះក្នុងលោកនេះ លុះបែកធ្លាយរាងកាយខាងមុខ បន្ទាប់អំពីមរណៈ ចូលទៅកាន់អបាយ ទុគ្គតិ វិនិបាត នរកយ៉ាងនេះ ព្រោះហេតុតែកិរិយាប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តតាមធម៌យ៉ាងនេះឯង ។

[ ១២៥ ] ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ដោយកាយមាន ៣ ប្រការ ។ កិរិយាប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ដោយវាចាមាន ៤ ប្រការ ។ កិរិយាប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ដោយចិត្តមាន ៣ ប្រការ ។ ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ដោយកាយមាន ៣ ប្រការ តើដូចម្តេច ។ ម្នាលគហបតិទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញា ដាក់ចុះនូវសាស្ត្រាវុធ ប្រកបដោយសេចក្តីខ្មាសដល់នូវមេត្តាចិត្ត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះពួកសត្វទាំងអស់ ។ ជាអ្នកលះបង់នូវអទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ដូចជាគ្រឿងឧបករណ៍ គឺសម្បត្តិនៃបុគ្គលណា ដែលគេទុកក្នុង ស្រុកក្តី ទុកក្នុងព្រៃក្តី ក៏ជាអ្នកមិនកាន់យកនូវវត្ថុដែលគេមិនបានឲ្យនោះ ដោយចំណែកនៃចិត្តលួចឡើយ ។ ជាអ្នកលះបង់នូវកាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេ-សុមិច្ឆាចារ ទោះបីស្ត្រីណាដែលមាតារក្សា បិតារក្សា មាតាបិតារក្សា បងប្អូន

ប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា មានស្វាមី ប្រកបដោយអាជ្ញា ដោយហោចទៅសូម្បីស្ត្រី ដែលបុរសបំពាក់កម្រងផ្កាឲ្យ ក៏ជាអ្នកមិនដល់នូវការប្រព្រឹត្តកន្លងក្នុងស្ត្រីទាំងឡាយ មានសភាពដូច្នោះឡើយ ។ ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ដោយកាយ មាន ៣ ប្រការដូច្នោះឯង ។ ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្ត តាមធម៌ដោយវាចាមាន ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលគហបតិទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ លះបង់នូវមុសាវាទ វៀរស្រឡះចាកមុសាវាទ ទោះបីឋិតនៅក្នុងរោងក្តី ឋិតនៅក្នុងបរិស័ទក្តី ឋិតនៅកណ្តាលញាតិក្តី ឋិតនៅកណ្តាលសេនិយក្តី ឋិតនៅកណ្តាល រាជត្រកូលក្តី គេនាំទៅធ្វើជាសាក្សីហើយសួរថា នែបុរសដ៏ចម្រើន ចូរអ្នកមកនេះ បើអ្នកដឹងហេតុណា ចូរនិយាយប្រាប់ហេតុនោះដូច្នេះក្តី ។ បុរសនោះ កាលមិនដឹង និយាយថា ខ្ញុំមិនដឹង ឬកាលដឹង ក៏និយាយថា ខ្ញុំដឹង កាលមិនឃើញ និយាយថា ខ្ញុំមិនឃើញ ឬកាលឃើញ ក៏និយាយថា ខ្ញុំឃើញ ។ ជាអ្នកមិនពោលនូវពាក្យកុហកទាំងដឹងខ្លួនដូច្នេះ ព្រោះហេតុខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុតែសំណូក គឺអាមិសៈបន្តិចបន្តួចក្តី ។ មួយវិញទៀត ជាអ្នកលះបង់នូវបិសុណ-វាចា វៀរស្រឡះចាកបិសុណវាចា គឺឮពាក្យអំពីជននេះ ហើយមិននាំទៅប្រាប់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងនេះផង ឮពាក្យអំពីជនឯណោះហើយមិននាំមកប្រាប់ជនទាំងនេះ ដើម្បីនឹងបំបែកជនឯណោះផង ជាអ្នកផ្សះផ្សានូវពួកជនដែលបែកគ្នាផង ជាអ្នកទំនុកបម្រុងនូវពួកជន ដែលព្រមព្រៀងគ្នា

ស្រាប់ហើយផង ជាអ្នកត្រេកអរតែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នកមានតម្រេកតែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នករីករាយក្នុងសេចក្តីព្រមព្រៀងគ្នា ពោលនូវវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀងដោយប្រការដូច្នេះ ។ ជាអ្នកលះបង់នូវផរុសវាចា វៀរស្រឡះចាកផរុសវាចា គឺវាចាណាមិនមានទោស ជាសុខដល់ត្រចៀក គួរឲ្យកើតសេចក្តីស្រឡាញ់ ចូលទៅកាន់ហឫទ័យ ជាវាចាអ្នកបុរី ជាទីស្រឡាញ់ដល់ជនច្រើន ជាទីពេញចិត្តដល់ជនច្រើន ជាអ្នកពោលនូវវាចាមានសភាព ដូច្នោះ ។ ជាអ្នកលះបង់នូវសម្ផប្បលាបៈ វៀរស្រឡះចាកសម្ផប្បលាបៈ ពោលពាក្យត្រូវតាមកាល ពោលពាក្យពិត ពោលពាក្យដែលជាអត្ថ ពោលពាក្យដែលជាធម៌ ពោលពាក្យជាវិន័យ ពោលពាក្យដែលគួរឲ្យតាំងទុកក្នុងហឫទ័យ ត្រូវតាមកាល ប្រកបដោយគ្រឿងអាង ជាវាចាមានទីបំផុត ប្រកបដោយប្រយោជន៍ ។ ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ ដោយវាចាមាន ៤ ប្រការយ៉ាងនេះឯង ។ ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោលគឺប្រព្រឹត្តតាមធម៌ ដោយចិត្តមាន ៣ ប្រការដូចម្តេចខ្លះ ។ ម្នាលគហបតិទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ មិនច្រើនដោយអភិជ្ឈា គ្រឿងឧបករណ៍ដែលជាសម្បត្តិនៃបុគ្គលដទៃណា ក៏មិនគយគន់នូវគ្រឿងឧបករណ៍នោះថា ឱហ្ន៎ គ្រឿងឧបករណ៍ដែលជាសម្បត្តិនៃបុគ្គលដទៃណា គ្រឿងឧបករណ៍នោះ គប្បីបានមកអាត្មាអញដូច្នេះឡើយ ។ មួយទៀត ជាអ្នកមានចិត្តមិនព្យាបាទ មានតម្រិះក្នុងចិត្តដែលទោសមិនប្រទូស្តហើយថា សត្វទាំងឡាយនេះ ចូរកុំមានពៀរ កុំ

មានព្យាបាទ កុំមានទុក្ខ រក្សាខ្លួនឲ្យបានសេចក្តីសុខចុះ ។ មួយវិញទៀតជាអ្នកមានគំនិតយល់ត្រូវ ឃើញនូវសេចក្តីមិនវិបរិតថា ទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាកនៃកុសលាកុលសកម្ម ដែលសត្វធ្វើល្អ និងធ្វើអាក្រក់មាន លោកនេះមាន លោកខាងមុខមាន មាតាមានគុណ បិតាមានគុណ សត្វដែលជាឱបបាតិកកំណើតមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកព្រមព្រៀង ប្រតិបត្តិដោយត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាចំពោះខ្លួនឯងនូវលោកនេះ និងលោកខាងមុខ ហើយប្រកាសក៏មាន ។ ម្នាលគហបតិទាំងឡាយ កិរិយាប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ ដោយចិត្តមាន ៣ ប្រការយ៉ាងនេះឯង ។ ម្នាលគហបតិទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ បែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ចូលទៅកាន់សុគតិ សួគ៌ ទេវលោកយ៉ាងនេះ ព្រោះហេតុតែកិរិយាប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្ត តាមធម៌យ៉ាងនេះឯង ។

[ ១២៦ ] ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱខ្លួនអាត្មាអញ លុះទម្លាយរាងកាយខាងមុខ បន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកខត្តិយមហាសាល ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកខត្តិយមហាសាលមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គល

នោះជាអ្នកប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱខ្លួនអាត្មាអញ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកព្រាហ្មណមហាសាល ។បេ។ កើតជាមួយនឹងគហតិមហាសាល ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកគហបតិមហាសាលមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱខ្លួនអាត្មាអញ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកទេវតា ក្នុងជាន់ចាតុម្មហារាជិកា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ លុះបែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតា ក្នុងជាន់ចាតុម្មហារាជិកាមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតិទាំង-ឡាយ បុគ្គលប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱខ្លួនអាត្មាអញ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកទេវតា ក្នុងជាន់តាវត្តិង្ស ។បេ។ ពួកទេវតាជាន់យាមៈ ... ពួកទេវតាជាន់តុសិត ... ពួកទេវតាជាន់និម្មានរតី ... ពួកទេវតាជាន់បរនិម្មិត-

វសវត្តី ... ពួកទេវតាជាន់ព្រហ្មកាយិកា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ លុះបែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតាជាន់ព្រហ្មកាយិកាមែន សេចក្តីនោះព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱខ្លួនអាត្មាអញ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកទេវតាជាន់អាភា ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ លុះបែកធ្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតាជាន់អាភាមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះជាអ្នកប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱខ្លួនអាត្មាអញ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ សូមឲ្យបានទៅកើតជាមួយនឹងពួកទេវតាជាន់បរិត្តាភា ។បេ។ នឹងពួកទេវតាជាន់អប្បមាណាភា ... ពួកទេវតាជាន់អាភស្សរា ... ពួកទេវតាជាន់បរិត្តសុភា ... ពួកទេវតាជាន់អប្បមាណសុភា ... ពួកទេវតាជាន់សុភកិណ្ហា ... ពួកទេវតាជាន់វេហប្ផលា ... ពួកទេវតាជាន់អវិហា ... ពួកទេវតាជាន់អតប្បា ... ពួកទេវតាជាន់សុទស្សា ... ពួកទេវតាជាន់សុទស្សី ... ពួកទេវតាជាន់អកនិដ្ឋកា ... ពួកទេវតាដែលកើតក្នុងអាកាសានញ្ចាយតនៈ ... ពួកទេវតាដែលកើតក្នុង

វិញ្ញាណញ្ចាយតនៈ ... ពួកទេវតាដែលកើតក្នុងជាន់អាកិញ្ចញ្ញាយតនៈ ... នឹងពួកទេវតាដែលកើតក្នុងជាន់នេវសញ្ញានាសញ្ញាយតនៈ ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងពួកទេវតា ដែលកើតក្នុងជាន់នេវសញ្ញានាសញ្ញាយតនៈមែន សេចក្តីនោះ ព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ ។ ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ បើប្រាថ្នាថា ឱខ្លួនអាត្មាអញ សូមឲ្យអស់អាសវៈទាំងឡាយ ហើយធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ដោយប្រាជ្ញាចំពោះខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ការណ៍ដែលបុគ្គលប្រាថ្នាបែបនេះ ក៏នឹងបានសម្រេច ព្រោះថា បុគ្គលនោះ នឹងអស់អសវៈទាំងឡាយ ហើយធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ដោយប្រាជ្ញាចំពោះខ្លួនឯង ក្នុងបច្ចុប្បន្នមែន សេចក្តីនោះព្រោះហេតុដូចម្តេច ព្រោះហេតុថា បុគ្គលនោះ ជាអ្នកប្រព្រឹត្តស្មើ ពោល គឺប្រព្រឹត្តតាមធម៌ ។

[១២៧] កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ពួកព្រាហ្មណ៍ និងគហបតិ អ្នកនៅក្នុងស្រុកសាលៈ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើនប្រកាសហើយ ដោយ

អនេកបរិយាយនេះឯង ( ភ្លឺច្បាស់ណាស់ ) ដូចជាបុគ្គលផ្ងាររបស់ដែលផ្កាប់ ឬដូចជាបុគ្គលបើកបង្ហាញនូវរបស់ដែលកំបាំង ពុំនោះ ដូចជាបុគ្គលប្រាប់ផ្លូវ ដល់មនុស្សវង្វេងទិស ពុំនោះសោត ដូចគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែក មើលឃើញរូបទាំងឡាយបាន យើងទាំងឡាយនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹង ទីរឭកតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើនទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយ ថាជាឧបាសក អ្នកដល់នូវទីពឹង ស្មើដោយជីវិត ។

## សាលេយ្យកសូត្រទី ១ ចប់

# អដ្ឋកថា

## ចូឡយមកវគ្គ

## សាលេយ្យកសូត្រទី ១

[ ១២៣ ] *សាលេយ្យកសូត្រ មានពាក្យផ្ដើមថា* **ឯវម្មេ សុតំ** *ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា* **កោសលេសុ** *សេចក្ដីថា ក្នុងដែននៃអ្នកកោសលទាំងឡាយ គឺពួកអ្នកក្រុង ឬរាជកុមារ ឈ្មោះកោសល ដែនដែលជាទីអាស្រ័យនៃជនទាំងនោះ សូម្បីត្រឹមតែខេត្តមួយ ឬហៅដោយសំឡេងរត់មាត់ថា កោសលទាំងឡាយបាន ។ ព្រះមានព្រះភាគ គង់ក្នុងខេត្តរបស់ពួកអ្នកកោសលនោះ ។ ឯបុរាណាចារ្យពោលថា ព្រោះកាលមុន ព្រះរាជាទ្រង់បានឮថា មហាបនាទរាជកុមារទតកំប្លែងផ្សេងៗ សូម្បីតែញញឹម ក៏មិនញញឹម ទើបត្រាស់ថា អ្នកណាធ្វើឲ្យកូនយើងសើចបាន យើងនឹងយកគ្រឿងសម្អាងគ្រប់យ៉ាង មកតាក់តែងឲ្យបុគ្គលនោះ ។ កាលមហាជន បោលនង្គ័លមកប្រជុំគ្នា ពួកមនុស្សនាំគ្នាសម្ដែងល្បែងរបាំផ្សេងៗ អស់ ៧ ឆ្នាំថ្វាយ ក៏មិនអាចធ្វើឲ្យព្រះរាជកុមារនោះ ទ្រង់ញញឹមបាន ។ គ្រានោះ ព្រះឥន្ទ្រទ្រង់បញ្ជូនទេវតាកំប្លែងទៅ ទេវតាអង្គនោះសម្ដែងអាកប្បកិរិយាបែបទិព្វ រហូតធ្វើឲ្យព្រះរាជបុត្រសើចបាន ។ លំដាប់នោះ មនុស្សទាំងនោះ ក៏នាំគ្នាបែរមុខចៀសទៅកាន់ទឹកដីរៀងៗខ្លួន កាលជួបមិត្តភក្តិក្នុង ចំណែកផ្លូវដែលមក ជនទាំងនោះក៏ប្រាស្រ័យរាក់ទាក់ថា* **កច្ចិ ភោ កុសលំ កច្ចិ ភោ កុសលំ** *ដូច្នោះ ព្រោះអាស្រ័យពាក្យថា* **កុសលំ កុសលំ** *ទើបប្រទេសនោះ ហៅថា*

កោសល ។

បទថា **ចារិកញ្ចរមានោ** គឺទ្រង់កំពុងចារិកដោយមិនប្រញាប់ប្រញាល់ ។ បទថា **មហតា ភិក្ខុសង្ឃេន សទ្ធឹ** គឺជាមួយពួកភិក្ខុចំនួនច្រើន ដែលមិនបានកំណត់យ៉ាងនេះថា ប៉ុណ្ណោះរយ ប៉ុណ្ណោះពាន់ ឬប៉ុណ្ណោះសែន ។ បទថា **ព្រាហ្មណគ្គាមោ** បានដល់ ស្រុកជាទីប្រជុំជនរបស់ពួកព្រាហ្មណ៍ ហៅថាស្រុករបស់ព្រាហ្មណ៍ ។ សូម្បីភូមិភោគៈរបស់ពួកព្រាហ្មណ៍ ក៏ជាភូមិប្រជុំជនក្នុងទីនេះ មិនមែនបំណងយកភូមិសម្រាប់នៅនៃពួកព្រាហ្មណ៍ទេ ។ បទថា **តទវសរិ** គឺវេពួកទៅក្នុងទីនោះ សំដៅដល់ការព្រមហើយ ។ ឯវិហារមិនបានកំណត់ឲ្យពិតប្រាកដក្នុងទីនេះ ដូច្នោះ ទើបជាដងព្រៃមួយ ដែលសមគួរដល់ព្រះពុទ្ធទាំងឡាយ ដែលនៅក្បែរៗ ស្រុករបស់ពួកព្រាហ្មណ៍នោះ ។ គប្បីជ្រាបថា ព្រះសាស្តាបានពុទ្ធដំណើរទៅដល់ព្រៃនោះ ។ បទថា **អស្សោសុំ** ប្រែថា ស្តាប់ហើយ គឺចូលទៅបាន បានដល់ ជ្រាបដោយទំនងសំឡេងកងរំពងនៃពាក្យដែលដល់សោតទ្វារ ។ បទថា **ខោ** ជានិបាត ចុះក្នុងអត្ថអវធារណៈ គឺគ្រាន់តែធ្វើបទឲ្យពេញ ។ គប្បីជ្រាបអធិប្បាយក្នុងពាក្យយ៉ាងនេះថា បានស្តាប់ហើយដោយអវធារណៈ អត្ថក្នុងទីនេះប៉ុណ្ណោះ អន្តរាយនៃការស្តាប់ណាមួយ មិនមានដល់ពួកគេ ។ ដោយការធ្វើបទឲ្យពេញ ក៏ត្រឹមតែឲ្យព្យញ្ជនៈពីរោះរណ្តំប៉ុណ្ណោះ ។

ឥឡូវនេះ កាលប្រកាសអត្ថដែលបានស្តាប់នោះ ទើបលោកពោលថា **សមណោ ខលុ ភោ គោតមោ** ដូច្នេះជាដើម ។ គប្បីជ្រាបថា ឈ្មោះថា

សមណៈ ព្រោះស្ងប់នូវបាប ។ ក្នុងបទទាំងនោះ បទថា **ខលុ** ជានិបាត ចុះក្នុងអត្ថថា ស្តាប់តាម ។ បទថា **ភោ** ជាពាក្យហៅគ្នានិងគ្នារបស់ពួកនោះ បទថា **គោតមោ** ជាពាក្យសម្តែងដោយគោត្ររបស់ព្រះមានព្រះភាគ ដូច្នោះ ក្នុងពាក្យទាំងនេះថា **សមណោ ខលុ ភោ គោតមោ** គប្បីឃើញអត្ថយ៉ាងនេះថា នៃលោក បានឮថា ព្រះសមណៈ ជាគោតមគោត្រ ឯពាក្យថា **សក្យបុត្តោ** នេះ ជាពាក្យសម្តែងត្រកូលដ៏ខ្ពង់ខ្ពស់នៃព្រះមានព្រះភាគ ។ បទថា **សក្យកុលា បព្វជិតោ** ជាពាក្យសម្តែងភាពជាអ្នកបួសដោយសទ្ធា មានពាក្យពោលថា បុគ្គលដែលមិនត្រូវសេចក្តីវិនាសឯណានីមួយគ្របសង្កត់ លះបង់ត្រកូលដែលមិនទាន់សាបសូន្យមកបួស ឈ្មោះថា បួសដោយសទ្ធា ។ ពាក្យតអំពីនោះទៅ មានអត្ថដូចពោលហើយនោះឯង ។ បទថា **តំ ខោ បន** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថប្រាប់ឥត្ថម្ភូត មានអត្ថថា សូមព្រះគោតមដ៏ចម្រើន ។ បទថា **កល្យាណោ** បានដល់ ប្រកបដោយព្រះគុណដែលស្អាត អធិប្បាយថា ជាអ្នកប្រសើរបំផុត ។ កិត្តិសព្ទនោះឯង ឬសំឡេងដែលសរសើរ ឈ្មោះថា **កិត្តិសទ្ទោ** ។ បទថា **អព្ភុគ្គតោ** គឺផ្សាយឡើងពេញមនុស្សលោក ព្រមទាំងទេវលោក ។ សេចក្តីនេះដូចម្តេច គឺផ្សាយឡើងថា ព្រះមានព្រះភាគអង្គនោះ ។បេ។ ទ្រង់ជាអ្នកភ្ញាក់ ( ជាអ្នកដាស់ ជាអ្នករីកដោយព្រះគុណ ) ទ្រង់ជាអ្នកមានជោគល្អ ទ្រង់មានចំណែកនៃការចែកធម៌ ទ្រង់ជាអ្នកចែកនូវធម៌ ។

តទៅនេះ គប្បីជ្រាបការទាក់ទងនៃបទក្នុងពាក្យទាំងនោះថា ព្រះមានព្រះភាគ ទ្រង់ជាអរហន្ត ព្រោះហេតុនេះ ទ្រង់ជាអ្នកត្រាស់ដឹងឯងដោយប្រពៃ

ព្រោះហេតុនេះ ។បេ។ ទ្រង់ជាអ្នកមានដោគល្អ ព្រោះហេតុនេះ ។ អធិប្បាយថា ព្រោះហេតុនេះ និងហេតុនេះ ។ បទទាំងអស់នេះឯង ដែលលោកលើកឡើងជាមាតិកា ដោយទំនងជាដើមថា គប្បីយល់ថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាព្រះអរហន្តដោយហេតុទាំងនេះ គឺទ្រង់ឆ្ងាយចាកសត្រូវ ព្រោះទ្រង់កាច់បំបាក់នូវកាំ គឺកង់នៃភព ព្រោះគួរដល់បច្ច័យជាដើម ព្រោះមិនមានការធ្វើបាបក្នុងទីស្ងាត់ សេចក្ដីនេះបានឲ្យពិស្ដារហើយ ក្នុងពុទ្ធានុស្សតិនិទ្ទេស នៃគម្ពីរវិសុទ្ធិមគ្គ ។ គប្បីកាន់យកសេចក្ដីពិស្ដារនៃបទទាំងនោះអំពីទីនោះចុះ ។

បទថា **សាធុ ខោ បន** គឺពាក្យថា **ខោ** ជាពាក្យស្អាត អធិប្បាយថា ជាការនាំយកប្រយោជន៍មកឲ្យ ជាការនាំយកសេចក្ដីសុខមកឲ្យ ។ បទថា **តថារូបានំ អរហតំ** គឺព្រះអរហន្តទាំងឡាយ ជាអ្នកបាននូវសទ្ធាថា បុគ្គលដែលជាអរហន្តទាំងឡាយក្នុងលោក ព្រោះសម្រេចគុណវិសេសតាមសេចក្ដីពិតនៃពួកព្រះអរហន្ត ដែលឃើញបានលំបាក ដោយសែនកោដិកប្ប មិនមែនតិច មានរាងកាយជាទីត្រេកអរ ដេរដាសដោយរស្មីនៃមហាបុរិសលក្ខណៈ ៣២ ប្រការ ប្រដាប់ដោយកែវ គឺ អនុព្យញ្ជនៈ ៨០ ធៀលធ្វាត់ដោយរស្មីមួយព្យាម មានការឃើញមិនក្ដៅក្រហាយ មានសំឡេងនៃធម៌ដ៏ពីរោះក្រៃលែង ដូចព្រះគោតមដ៏ចម្រើននោះ មាន ។ បទថា **ទស្សនំ ហោតិ** គឺធ្វើអជ្ឈាស្រ័យយ៉ាងនេះថា ការបើកភ្នែក មានបសាទរីកឡើងហើយ មើលឃើញក៏ជាការល្អ គឺញុំាំងប្រយោជន៍ឲ្យសម្រេច កាលបើលោកកំពុងសម្ដែង

ធម៌ ដោយសំឡេងដូចសំឡេងព្រហ្ម ដែលប្រកបព្រមដោយអង្គ ៨ បាន ស្តាប់សូម្បីបទមួយ ក៏ជាការល្អដែរ ។ បទថា **យេន ភគវា តេនុប-សង្កមឹសុ** បានដល់ លះបង់កិច្ចគ្រប់យ៉ាង មានចិត្តត្រេកអរមកហើយ ។ បទ ថា **ឯតទវោច** បានដល់ ការសួរមាន ២ យ៉ាង គឺសួរតាមបែបអ្នកស្រុក ១ សួរតាមបែបអ្នកបួស ១ ក្នុងការសួរ ២ យ៉ាងនោះ ការសួរតាមបែប អ្នកស្រុក មកហើយយ៉ាងនេះថា លោកម្ចាស់ អ្វីជាកុសល អ្វីជាអកុសល ការសួរបែបអ្នកបួសមកហើយយ៉ាងនេះថា បពិត្រលោកម្ចាស់ ទាំងនោះឬហ្ន៎ ជាឧបាទានក្ខន្ធ ៥ ឯព្រាហ្មណ៍ និងគហបតីទាំងនេះ កាលនឹងទូលសួរតាម បែបការសាកសួររបស់អ្នកស្រុក ដែលសមគួរដល់ខ្លួន ទើបពោលពាក្យ ជាដើមថា បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ចំពោះ ព្រះមានព្រះភាគអង្គនោះ ។ ព្រះមានព្រះភាគ កាលទ្រង់ដោះស្រាយបញ្ហា ដោយសង្ខេបពិតៗ ដល់ពួកជនទាំងនោះ ដែលពួកគេមិនទាន់អាចកំណត់បាន ទើបត្រាស់ពាក្យជាដើមថា ម្នាលគហបតីទាំងឡាយ កិរិយាប្រព្រឹត្តមិនស្មើ ពោល គឺមិនប្រព្រឹត្តិតាមធម៌ សួរថា ហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់ ឆ្លើយតាមបែបដែលពួកជនទាំងនោះមិនអាចកំណត់បាន ឆ្លើយថា មានបុគ្គល ពោលថា ព្រោះជនទាំងនោះ ប្រកាន់ខ្លួនថាជា បណ្ឌិត រមែងតាំងមាតិកា ហើយកំណត់អំពីដើមនោះឯង ដោយប្រការណា កាលព្រះអង្គទ្រង់ពង្រីកឲ្យ ពិស្តារដោយប្រការនោះ ក៏នាំគ្នាសម្គាល់ទេសនាថា រាក់ៗ និងនាំគ្នាពោល មើលងាយថា កាលពួកយើងនឹងពោល ក៏គប្បីពោលយ៉ាងនេះដូចគ្នា ព្រោះ

ហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ដោះស្រាយបញ្ហាសង្ខេបៗ ប្រភេទដែលជនទាំងនោះមិនអាចកំណត់បាន ។ បន្ទាប់អំពីនោះ កាលទ្រង់ត្រូវពួកជនដែលមិនអាចកំណត់បាននោះ អារាធនាសូមឲ្យសម្ដែងពិស្ដារ កាលទ្រង់សម្ដែងឲ្យពិស្ដារ ទើបត្រាស់ពាក្យថា ម្នាលគហបតីទាំងឡាយ បើដូច្នោះអ្នកទាំងឡាយ ។

ក្នុងបទទាំងនោះ បទថា **តេនហិ** ជានិបាត ចុះក្នុងហេតុ ដោយអត្ថថា ព្រោះហេតុដែលពួកអ្នកអារាធនាតថាគត ។

[ ១២៤-១២៥ ] បទថា **តិវិធំ** គឺ ៣ ចំណែក ។ បទថា **កាយេន** គឺដោយកាយទ្វារ ។ បទថា **អធម្មចរិយា វិសមចរិយា** គឺការប្រព្រឹត្តមិនសមគួរ បានដល់ ការប្រព្រឹត្តមិនត្រឹមត្រូវ ។ តទៅនេះ ជាអត្ថនៃបទក្នុងពាក្យទាំងនេះ ។

ការប្រព្រឹត្តអធម៌ ឈ្មោះថា **អធម្មចរិយា** ដោយអត្ថថា ការធ្វើដែលមិនជាធម៌ ឈ្មោះថា **វិសមចរិយា** ព្រោះប្រព្រឹត្តមិនស្មើ ឬប្រព្រឹត្តទាបខ្ពស់ៗ ការប្រព្រឹត្តមិនជាធម៌ និងការប្រព្រឹត្តមិនស្មើនោះ ព្រោះដូច្នោះ ទើបឈ្មោះថា ការប្រព្រឹត្តមិនជាធម៌ និងការប្រព្រឹត្តមិនស្មើ គប្បីជ្រាបអត្ថក្នុងកាឡបក្ខនិងសុក្កបក្ខគ្រប់បទ ដោយឧបាយនេះ ។

បទថា **ទារុណោ** បានដល់ គ្រោតគ្រាត កាចសាហាវ ឃោរឃៅយង់ឃ្នង ។ បទថា **លោហិតបាណី** បានដល់ ប្រឡាក់ដោយឈាមត្រង់ដៃនៃបុគ្គលដែលកំពុងធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះ សូម្បីមិនប្រឡាក់ មនុស្ស

បែបនោះ លោកក៏ហៅថា មានដៃប្រឡាក់ឈាមដែរ ។ បទថា **ហតប្បហតេ និវិដ្ឋោ** បានដល់ តាំងនៅក្នុងការសម្លាប់ ការឲ្យប្រហារសត្វដទៃ និងការសម្លាប់ដោយដៃ គឺការធ្វើសត្វដទៃឲ្យស្លាប់ ។ បទថា **អទយាបន្នោ** គឺមកដល់ភាពជាអ្នកមិនមានការអាណិតអាសូរ ។ បទថា **យំ តំ បរស្ស** គឺវត្ថុដែលមាននៃអ្នកដទៃនោះ ។ បទថា **បរវិត្តូបករណំ** បានដល់ ឧបករណ៍ជាគ្រឿងត្រេកអរនៃចិត្តរបស់អ្នកដទៃនោះឯង គឺគ្រឿងបរិក្ខារដែលញ៉ាំងឲ្យកើតការត្រេកអរដល់អ្នកដទៃនោះ ។ បទថា **គាមគតំ វា** គឺដែលតាំងនៅខាងក្នុងស្រុកក្តី ។ បទថា **អរញ្ញគតំ វា** គឺតាំងទុកនៅក្នុងព្រៃ ឬលើដើមឈើ ឬកំពូលភ្នំជាដើម ។ បទថា **អទិន្នំ** គឺពួកបុគ្គលនោះ មិនបានឲ្យដោយកាយ ឬដោយវាចា ។ បុគ្គលលួច ឈ្មោះថា ភាពជាចោរ ។ ពាក្យនេះជាឈ្មោះនៃចិត្តគិតនឹងលួច ។ បទថា **សង្ខាតំ** នេះ ជាឈ្មោះនៃចំណែកមួយដោយអត្ថ ។ ដូចក្នុងពាក្យជាដើមថា **សញ្ញានិទានា ហិ បបញ្ចសង្ខា** ប្រែថា ចំណែកនៃធម៌ជាគ្រឿងយឺតយូរ ដែលមានសញ្ញាជាមូលចំណែកនោះផង ភាពជាចោរផង ហេតុនោះ ឈ្មោះថា ចំណែកនៃភាពជាចោរ ដោយអត្ថថា ចំណែកនៃចិត្តមួយ ពោលគឺ ចិត្តគិតនឹងលួច ។ ពាក្យថា ចំណែកនៃភាពជាចោរនេះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ ដូច្នោះទើបគួរឃើញដោយសេចក្តីថា ចំណែកនៃភាពជាចោរ ដូច្នេះ ។

បទថា **មាតុរក្ខិតា** ជាដើម អធិប្បាយថា កាលឪពុកបាត់ ឬស្លាប់ទៅហើយ ម្តាយមើលថែរក្សាដោយអាហារ និងសម្លៀកបំពាក់ជាដើម គិត

ថា នឹងឲ្យមានក្រុមគ្រួសារ កាលធំហើយ រមែងគ្រប់គ្រងកូនស្រីណា កូននេះ ឈ្មោះថា ម្តាយរក្សា ។ សូម្បីស្រីដែលជាបិតុរក្ខិតាជាដើម ក៏គប្បីជ្រាប ដោយឧបាយនេះ ។ ឯត្រកូលដែលពេញចិត្តគ្នា ធ្វើកតិកាគ្នា តាំងអំពីកូន នៅក្នុងផ្ទៃថា បើកូនខ្ញុំជាកូនប្រុស ចំណែកអ្នកជាកូនស្រី ទៅទីដទៃមិនបាន ត្រូវតែជារបស់កូនប្រុសខ្ញុំប៉ុណ្ណោះ ស្រីដែលនាវទុកតាំងអំពីនៅក្នុងពោះយ៉ាង នោះ ឈ្មោះថា **សស្សាមិកា** គឺស្ត្រីមានប្តី ។ ឯស្រីដែលគេឧទ្ទិសចំពោះ ស្រុក ផ្ទះ ឬផ្លូវហើយ ដាក់ទោសយ៉ាងនេះថា អ្នកណាទៅរកស្រីនេះ នឹង ត្រូវទទួលទោសយ៉ាងនេះ ឈ្មោះថា **សបរិទណ្ឌា** គឺស្ត្រីមានទណ្ឌៈដោយ ជុំវិញ ។ បទថា **អន្តមសោ មាលាគុឡបរិក្ខិត្តាបិ** គឺដោយកំណត់យ៉ាង ទាបបំផុតជាងគេទាំងអស់ ស្រីដែលបុរសណាមួយកំពុងបោះកម្រងផ្កាទៅ លើនាង ដោយសម្គាល់ថា ស្រីនេះជាភរិយារបស់អញ ហើយក៏ត្រូវយក កម្រងផ្កាប៉ុណ្ណោះនាំទៅ ។ បទថា **តថារូបាសុ ចារិត្តំ អាបជ្ជិតា ហោតិ** បានដល់ ជាអ្នកធ្វើការឈានកន្លងក្នុងស្រីបែបនោះ ដោយអំណាចលក្ខណៈ នៃការប្រព្រឹត្តខុស ដែលពោលហើយក្នុងសម្មាទិដ្ឋិសូត្រ ។

បទថា **សភាគតោ** គឺឈរនៅក្នុងទីប្រជុំ គឺសភា ។ បទថា **បរិ-សាគតោ** គឺ ឈរនៅក្នុងបរិស័ទ ។ បទថា **ញាតិមជ្ឈគតោ** គឺ នៅក្នុង កណ្តាលពួកទាយាទ ។ បទថា **បូគមជ្ឈគតោ** គឺនៅត្រង់កណ្តាលកង ទាហាន ។ បទថា **រាជកុលមជ្ឈគតោ** គឺនៅក្នុងព្រះមន្ទីរធំកណ្តាលរាជ-ត្រកូល ។ បទថា **អភិនីតោ** គឺត្រូវនាំទៅដើម្បីសាកសួរ ។ បទថា **សក្ខិ-**

បុដ្ឋោ គឺត្រូវធ្វើជាសាក្សី ហើយសួរ ។ បទថា **ឯហម្ភោ បុរិស** នេះ ជាពាក្យសម្រាប់ហៅ ។ បទថា **អត្តហេតុ វា បរហេតុ វា** គឺព្រោះហេតុនៃដៃ និងជើងជាដើមរបស់ខ្លួន ឬអ្នកដទៃ ឬព្រោះហេតុនៃទ្រព្យ ។ បទថា **អាមិសំ** លោកបំណងយកអាមិស ក្នុងបទថា **អាមិសកិញ្ចិក្ខហេតុ វា** ប្រែថា ព្រោះឃើញដល់អាមិសតិចតួចជាហេតុនេះ ព្រោះដូច្នោះ បទថា **កិញ្ចិក្ខ** ទើបសំដៅដល់របស់មិនសំខាន់គឺតិចតួច អធិប្បាយថា ដោយហោច ព្រោះហេតុនៃសំណូកដែលមានត្រឹមតែសត្វទទា សត្វក្រួច សប្បិ និងនវនីតជាដើម ។

បទថា **សម្បជានមុសា ភាសិតា ហោតិ** គឺទាំងដែលដឹងខ្លួនពិតៗ ក៏នៅជាបុគ្គលពោលនូវពាក្យកុហក ។ បទថា **ឥមេសំ ភេទាយ** គឺបានឮក្នុងសម្នាក់របស់បុគ្គលពួកណា ដែលលោកហៅថា គឺជនខាងនេះ ដើម្បីបំបែកជនឯណោះ ។ បទថា **អមូសំ ភេទាយ** គឺបានស្តាប់ពាក្យរបស់ពួកណា គឺជនខាងណោះ ដើម្បីបំបែកជនខាងនេះ ។ បទថា **ឥតិ សមគ្គានំ វា ភេត្តា** បានដល់ ជាអ្នកធ្វើឲ្យសម្លាញ់ទាំងពីរចំណែក ដែលសាមគ្គីគ្នា បែកគ្នាហើយយ៉ាងនេះ ។ បទថា **ភិន្នានំ វា អនុប្បទាតា** គឺជាអ្នកជំរុញឲ្យអ្នកដែលបែកគ្នាហើយ ជួបជុំគ្នាទៀតមិនបាន យ៉ាងនេះថា អ្នកធ្វើត្រឹមត្រូវហើយដែលលះបង់គេបាន ២-៣ ថ្ងៃទៀតប៉ុណ្ណោះ គេនឹងធ្វើឲ្យអ្នកវិនាសធំ អធិប្បាយថា ជាអ្នកចង្អុលហេតុឲ្យ ។ បក្ខពួកជាទីត្រេកអរ គឺជាទីតាំងនៃការត្រេកអរក្រៃលែងរបស់បុគ្គលនោះ ហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **វគ្គារាមោ** គឺមានពួកជាទីត្រេកអរ ។ បទថា **វគ្គរតោ** គឺត្រេកអរហើយក្នុងពួកទាំង-

ឡាយ ។ ឈ្មោះថា ត្រេកអរក្នុងពួក ព្រោះឃើញ ឬបានឮថា ពួក ក៏រមែងត្រេកអរ ។ បទថា **វគ្គករណឹ វាចំ** គឺវាចាណាធ្វើសត្វឲ្យជាពួក គឺ ទម្លាយសត្វដែលព្រមព្រៀងគ្នាហើយ ជាអ្នកពោលវាចាដែលញុំាងឲ្យកើតនូវជម្លោះនោះ ។

បទថា **អណ្ហកា** គឺឈ្មោះថា ទ្រគោះ ដោយពាក្យសម្មុត និងពាក្យគំរាមជាដើម ព្រោះជាវាចាដែលមានទោស ដូចពកដែលតាំងឡើងត្រង់ដើមឈើ មានទោស គឺខូចដូច្នោះ ។ បទថា **កក្កសា** គឺខ្មោះខ្នរ ជាវាចាដែលគ្រោតគ្រាត ដូចដើមឈើដែលស្អុយ ជាដើមឈើដែលមានអាចម៍ខ្ទុតហូរចេញ ដូច្នោះ ។ វាចានោះ ហាក់ដូចជាចាក់ត្រចៀកចូលទៅ ដូច្នោះ ទើបលោកហៅថា ខ្មោះខ្នរ ។ បទថា **បរកដុកា** ជាវាចាដែលក្តៅក្រហាយ មិនគួរត្រេកអរនៃជនដទៃ ជាវាចាដែលញុំាងទោសឲ្យកើតឡើង ។ បទថា **បរាភិសជ្ជនិ** គឺបានដល់វាចាដែលចាក់ដោតទៅក្នុងរបស់ជាទីស្រឡាញ់ ដូចមែកឈើកោង មានបន្លា ចាក់ដោតអ្នកដទៃ ធ្វើឲ្យកើតការស្អុតស្អាញ ព្រោះមិនឲ្យទៅដល់អ្នកដែលចង់ទៅ ។ បទថា **កោធសាមន្តា** គឺជិតចំពោះសេចក្តីក្រោធ ។ បទថា **អសមាធិសំវត្តនិកា** គឺជាវាចាដែលមិនប្រព្រឹត្តទៅដើម្បីអប្បនាសមាធិ ឬឧបចារសមាធិ ។ វាចាដូចពោលមកទាំងអស់នេះ សុទ្ធតែជាពាក្យប្រើជំនួសវាចាដែលមានទោសទាំងអស់នោះឯង ។

បទថា **អកាលវាទី** គឺជាអ្នកពោលមិនស្គាល់កាល ។ បទថា **អភូតវាទី** គឺជាអ្នកនិយាយវត្ថុដែលមិនមាន ។ បទថា **អនត្ថវាទី** គឺជាអ្នកនិយាយ

ពាក្យមិនអាស្រ័យហេតុ ។ បទថា **អធម្មវាទី** គឺជាអ្នកពោលមិនជាសភាវៈ ។ បទថា **អវិនយវាទី** គឺជាអ្នកពោលពាក្យមិនប្រកបដោយសំវរវិន័យជាដើម ។ បទថា **អនិធានវតី វាចំ** គឺរមែងជាអ្នកពោលវាចា ដែលមិនសមគួររក្សាទុកក្នុងហិប គឺហទយៈ ។ បទថា **អកាលេន** គឺរមែងជាអ្នកពោលក្នុងកាលដែលមិនសមគួរមុន ឬក្រោយកាលដែលត្រូវពោល ។ បទថា **អនបទេសំ** គឺវៀរចាកទីអាង ទីអាស្រ័យ គឺសូត្រ ។ បទថា **អបរិយន្តវតី** គឺលើកយកព្រះសូត្រ ឬជាតកដែលមិនមានវគ្គមកហើយ ទាញយករឿងដែលល្មមនឹងចូលគ្នាជាមួយព្រះសូត្រ ឬជាតកនោះ បាននូវការប្រៀបធៀប ឬវត្ថុមកហើយ ត្រឡប់ទៅពោលវាចាក្រៅរឿងទាំងអស់ ។ ពាក្យដែលលើកមកហើយគ្រាន់តែលើកឡើងមកប៉ុណ្ណោះឯង ។ បុគ្គលនោះ រមែងជាអ្នកដល់នូវភាពដែលអ្នកដទៃគប្បីតវាថា លោកពោលសូត្រ ឬជាតកហ្ន៎ ពួកយើងមិនឃើញការចប់ ឬទីបំផុតនៃសូត្រ ឬជាតកនោះ បុគ្គលនេះក៏រមែងឈ្មោះថា ជាធម្មកថិកពួរជ្រៃ រមែងធ្វើបទដែលលើកឡើងមកតាំង ឲ្យគ្រាន់តែថា លើកមកតាំងទុកប៉ុណ្ណោះ ហើយពោលរឿយៗ ទៅ បញ្ជិតៗ អមៗ យ៉ាងនោះឯង ដូចឫសពួរនៃដើមជ្រៃសំយុងទៅក្នុងទីដែលទៅហើយ ក៏ដល់នូវទីសំយុងចុះហើយ រមែងចម្រើនទៀតនោះឯង ជ្រៃនោះ ទៅបានបែបនេះឯង រហូតកន្ទះយោជន៍ខ្វះ មួយយោជន៍ខ្វះ តាំងនៅជាជួរនោះឯង ដូច្នោះ ។ ឯបុគ្គលណាសូម្បីពោលច្រើន ក៏គង់អាចដើម្បីឲ្យទាញយកមក ហើយដឹងបានថា លោកពោលពាក្យនេះ ដើម្បីវត្ថុនេះ បុគ្គលនោះ ទោះពោលក៏គួរ ។ បទថា **អនត្ថ-**

**សញ្ញិតំ** គឺរកប្រយោជន៍ដោយប្រយោជន៍មិនបាន ។

បទថា **អភិជ្ឈាតា ហោតិ** បានដល់ រមែងជាអ្នកសម្លឹងដោយការសម្លឹងរំពៃ ។ បទថា **អហោ វត** ជានិបាត ចុះក្នុងអត្ថថា ប្រាថ្នា ។ ក្នុងសេចក្តីនេះ ដោយអាការត្រឹមតែសម្លឹងមើល ដោយការសម្លឹងប៉ុណ្ណោះ ការបែកកម្មបថមិនទាន់មាន លុះកាលណាបង្អោនមកជារបស់ខ្លួនថា ធ្វើម្តេចហ្ន៎វត្ថុនេះ ទើបបានមកជារបស់អញ អញគប្បីដាក់អំណាចឲ្យប្រព្រឹត្តទៅក្នុងរបស់នេះ ដូច្នេះ កម្មបថរមែងបែក ។ លោកសំដៅយកការសម្លឹងរំពៃបែបនេះ ក្នុងទីនេះ ។

បទថា **ព្យាបន្នចិត្តោ** គឺមានចិត្តកខ្វក់ បានដល់ មានចិត្តស្អុយ ។ បទថា **បទុដ្ឋមនសង្កប្បោ** បានដល់ មានការត្រិះរិះដោយចិត្តដែលត្រូវទោសៈប្រទូស្ត ។ បទថា **ហញ្ញន្តុ** គឺចូរធ្វើឲ្យស្លាប់ ។ បទថា **វជ្ឈន្តុ** គឺចូរដល់នូវការសម្លាប់ ។ បទថា **មា វា អហេសុំ** គឺសូម្បីតែសត្វណាមួយដែលមិនវិនាសកុំបីមានឡើយ ។ ក្នុងពាក្យនេះ ដោយហេតុត្រឹមតែធ្វើចិត្តឲ្យកម្រើកកម្មបថក៏មិនបែក តែកាលគិតថា ធ្វើម្តេចសត្វនេះត្រូវស្លាប់ហ្ន៎ កម្មបថក៏បែក ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។

បទថា **មិច្ឆាទិដ្ឋិកោ** គឺមានការយល់ឃើញជាអកុសល ។ បទថា **វិបរីតទស្សនោ** គឺការឃើញក្នុងចិត្តវិបរិតទៅ ។ បទថា **នត្ថិ ទិន្នំ** គឺព្រះមានព្រះភាគ ត្រាស់សំដៅយកការមិនមានផលនៃទានដែលឲ្យហើយ ។ ការបូជាធំ លោកហៅថា **យិដ្ឋំ** សក្ការៈត្រឹមតែល្មម ទ្រង់ហៅថា **ហុតំ** គឺការ

បួងសួងបុគ្គលនោះ សំដៅយកការមិនមានផលប៉ុណ្ណោះ ទើបហាមវត្ថុទាំង ២ នោះ ។ បទថា **សុកដទុក្កដានំ** សំដៅយកកុសល និងអកុសលដែលធ្វើល្អ និងធ្វើអាក្រក់ ។ បទថា **ផលំ វិបាកោ** នោះ ហៅថា ផល ឬហៅថា វិបាក ក៏បាន ។ បុគ្គលនោះពោលថា ផល ឬវិបាកនោះមិនមាន ។ ក្នុងបទថា **នត្ថិ អយំ លោកោ** គឺមិនមានលោកនេះ សម្រាប់បុគ្គលដែលតាំងនៅក្នុងលោកដទៃ ។ បទថា **នត្ថិ បរោ លោកោ** គឺមិនមានលោកដទៃសម្រាប់បុគ្គលដែលតាំងនៅក្នុងលោកនេះ ។ បុគ្គលនោះ អះអាងថា អ្វីទាំងអស់រមែងដាច់សូន្យក្នុងទីនោះឯង ។ បទថា **នត្ថិ មាតា នត្ថិ បិតា** សំដៅដល់បុគ្គលនោះរមែងពោលដោយអំណាចការមិនមានផលក្នុងកិច្ចបដិបត្តិត្រូវ និងបដិបត្តិខុសក្នុងជនទាំងនោះ ។ បទថា **នត្ថិ សត្តា ឱបបាតិកា** នោះ គឺបុគ្គលនោះពោលថា សត្វដែលឈ្មោះថា ចុតិ ហើយកើត មិនមាន ។ បទថា **សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ** គឺបុគ្គលនោះសម្តែងដល់ការមិនមាននៃព្រះសព្វញ្ញុពុទ្ធទាំងឡាយថា បុគ្គលដែលធ្វើឲ្យជាក់ច្បាស់ឯង ដោយបញ្ញាដ៏វិសេសក្រៃលែងហើយ ប្រកាសលោកនេះ និងលោកខាងមុខនោះ មិនមានដូច្នេះ ។

ដោយពាក្យមានប្រមាណប៉ុណ្ណោះ ការយល់ឃើញខុសដែលមានទីតាំង ១០ យ៉ាង ព្រះមានព្រះភាគបានត្រាស់ហើយ ។ កម្មបថ ៧ ខាងដើមមានការវៀរចាកសម្លាប់សត្វជាដើម ក៏បានពោលឲ្យពិស្តារហើយ ក្នុងចូឡហត្ថិបទោបមសូត្រ ។ អនភិជ្ឈាជាដើម មានអត្ថងាយយល់ហើយនោះឯង ។

[ ១២៦ ] បទថា **សហាព្យតំ ឧបបជ្ជេយ្យំ** គឺសូមឲ្យអាត្មាអញចូលដល់សហភាព គឺជាសម្លាញ់តែមួយ ។ បទថា **ព្រហ្មកាយិកានំ ទេវានំ** បានដល់ នៃពួកទេវតាជាន់បឋមជ្ឈាន ។ បទថា **អាភានំ ទេវានំ** គឺឈ្មោះអាភាដែលជាផ្នែកមួយដោយឡែកមិនមាន ពាក្យនេះ ជាឈ្មោះនៃពួកទេវតាជាន់បរិត្តាភា អប្បមាណាភា និងអាភស្សរានោះឯង ។ តែបទថា **បរិត្តាភា** ជាដើម ជាការមិនកាន់យករួមគ្នា តែកាន់យកដោយការចែកពួកទេវតាទាំងនោះឯង ។ ក្នុងបទថា **បរិត្តសុភានំ** ជាដើម ក៏ទំនងដូចគ្នានេះឯង ។

ព្រះមានព្រះភាគ ទ្រង់សម្តែងការអស់អាសវៈ ដោយប្រការដូច្នេះហើយ ទ្រង់បញ្ចប់ទេសនាដោយកំពូល គឺ អរហត្តផល ។

សម្រាប់ក្នុងទីនេះ គួរសង្គ្រោះយកទេវលោកមកតាំងទុកផង គឺព្រហ្មលោកចែកជា ១៨ ជាន់ក៏បាន ២០ ជាន់ក៏បាន ។ ព្រហ្មលោក ១៨ ជាន់ គឺព្រហ្មលោកដោយអំណាចឈានភូមិ ៣ គឺឈានទីមួយៗ មាន ៣ ជាន់ ទើបត្រូវជា ៩ យកសុទ្ធាវាស ៥ និងអរូបភូមិ ៤ ទៀតមករាប់បញ្ចូល រួមជា ១៨ ។ ព្រហ្មលោកមាន ២០ ជាន់នោះ គឺព្រហ្មលោកដែលរាប់រួចមកហើយ ១៨ ថែមវេហប្ផលា ១ និងអសញ្ញីភព ១ រួមជា ២០ ។ បើរួមទេវលោកទាំងអស់មាន ២៦ ជាន់ គឺព្រហ្មលោកដែលរៀបរាប់រួចមកហើយ និងទេវតាជាន់កាមាវចរ ៦ ជាន់ទៀត រួមជា ២៦ ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងការកើតនៃពួកទេវតាទាំងអស់នោះដោយកុសលកម្មបថ ១០ ប្រការ ។ ក្នុងទេវលោក ២៦ ជាន់នោះ ការកើតក្នុង

កាមាវចរ ៦ ជាន់ រមែងមានដោយវិបាកនៃសុចរិតទាំង ៣ យ៉ាងនោះឯង ។ ឯកម្មបថទាំងនេះ ត្រាស់ដោយអំណាចជាឧបនិស្ស័យនៃទេវលោកជាន់លើ ។ ពិតហើយ កុសលកម្មបថទាំង ១០ គឺ សីលនោះឯង កិច្ចបរិកម្មកសិណ រមែងសម្រេចដល់អ្នកមានសីលប៉ុណ្ណោះ ដូច្នោះ កាលតាំងនៅក្នុងសីល ហើយធ្វើបរិកម្មកសិណ កាលញុំាងបឋមជ្ឈានឲ្យកើតហើយ រមែងកើតក្នុងបឋមជ្ឈានភូមិ ។ អប់រំទុតិយជ្ឈានជាដើមហើយ ក៏រមែងកើតក្នុងទុតិយជ្ឈានភូមិជាដើម កាលធ្វើរូបាវចរជ្ឈានឲ្យជាបាទ ហើយចម្រើនវិបស្សនា តាំងនៅក្នុងអនាគាមិផលហើយ ក៏រមែងកើតក្នុងសុទ្ធាវាសភូមិ ៥ ជាន់ កាលបានធ្វើរូបាវចរជ្ឈានឲ្យជាបាទហើយ ញុំាងអរូបាវចរសម្បត្តិឲ្យកើតឡើង ក៏រមែងកើតក្នុងអរូបភព ៤ ជាន់ កាលធ្វើរូបជ្ឈាន និងអរូបជ្ឈានឲ្យជាបាទហើយ ចម្រើនវិបស្សនា រមែងសម្រេចអរហត្តផល ឯអសញ្ញសត្តភព ពួកតាបស និងបរិព្វាជកខាងក្រៅ ក៏អាចសម្រេចបាន ដូច្នោះ ទើបទ្រង់មិនសម្ដែងក្នុងទីនេះ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ ងាយយល់ទាំងអស់ហើយ ៕

## សាលេយ្យកសូត្រ ចប់

## សូត្រទី ១ ចប់

# សុត្តបិដក

## វេរញ្ជកសូត្រទី ២

[ ១២៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏សម័យនោះឯង ពួកព្រាហ្មណ៍ និងគហបតិ អ្នកស្រុកវេរញ្ជា នៅអាស្រ័យក្នុងក្រុងសាវត្ថី ដោយកិច្ចនីមួយ ។ ពួកព្រាហ្មណ៍ និងគហបតិ អ្នកស្រុកវេរញ្ជា បានឮដំណឹងថា ព្រះសមណគោតមជាសក្យបុត្រ ចេញចាកសក្យត្រកូលទៅបួស ប្រថាប់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ កិត្តិសព្ទដ៏ល្អនៃព្រះគោតមដ៏ចម្រើននោះ ល្បីឮខ្ចរខ្ចាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរបំផុត ព្រះអង្គជាសារថី ទូន្មាននូវបុរស ព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ជាព្រះពុទ្ធទ្រង់ចែកនូវធម៌ទាំងពួង ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាចំពោះព្រះអង្គ នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយប្រកាស ទ្រង់សម្តែងធម៌ មានលម្អបទដើម បទកណ្តាល បទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថទាំងព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានជួបប្រទះនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនេះ ជាការប្រពៃពេក ។ គ្រានោះ

ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកវេរញ្ជា នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះគ្រាន់តែនិយាយពាក្យសំណេះសំណាលទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះអង្គុយប្រណមអញ្ជលី ចំពោះព្រះមានព្រះភាគក្នុងទីដ៏សមគួរ ពួកខ្លះគ្រាន់តែប្រកាសនាម និងគោត្រ ក្នុងសម្នាក់ព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះអង្គុយនៅស្ងៀមក្នុងទីដ៏សមគួរ លុះពួកព្រាហ្មណ៍ និងគហបតិ អ្នកស្រុកវេរញ្ជា អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកសត្វខ្លះ ក្នុងលោកនេះ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ ទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេត-វិស័យ អសុរកាយ នរក បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត អ្វីជាហេតុ អ្វីជាបច្ច័យដែលនាំឲ្យពួកសត្វក្នុងលោកនេះ លុះបែកធ្លាយរាងកាយខាងមុខ អំពីសេចក្តីស្លាប់ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលគហបតីទាំងឡាយ ព្រោះហេតុតែការប្រព្រឹត្តមិនស្មើ គឺប្រព្រឹត្តមិនត្រូវធម៌នុ៎ះឯង បានជាពួកសត្វខ្លះក្នុងលោកនេះ ដល់បែកធ្លាយរាងកាយខាងមុខ អំពីសេចក្តីស្លាប់ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរ-កាយ នរកយ៉ាងនេះ ម្នាលគហបតីទាំងឡាយ ព្រោះហេតុតែសេចក្តីប្រព្រឹត្តស្មើ គឺប្រព្រឹត្តត្រូវតន្ទងធម៌ ដែលនាំឲ្យពួកសត្វខ្លះក្នុងលោកនេះ លុះបែក

ធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក យ៉ាងនេះ ។ ធម៌នេះ ព្រះគោតមដ៏ចម្រើន បានសម្តែងដោយសេចក្តីបង្រួញ មិនទាន់ចែករម្លែកសេចក្តីដោយពិស្តារទេ យើងខ្ញុំមិនទាន់ដឹងសេចក្តីដោយពិស្តារឡើយ សូមទ្រង់ព្រះមេត្តាប្រោស ព្រះគោតមជាម្ចាស់សម្តែងធម៌ដែលព្រះគោតមជាម្ចាស់ សម្តែងដោយសេចក្តីសង្ខេប មិនទាន់ចែករម្លែកសេចក្តីពិស្តារនៅឡើយនេះ ឲ្យយើងខ្ញុំបានយល់សេចក្តីច្បាស់លាស់ដោយពិស្តារឲ្យទាន ។ ម្នាលគហបតិទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយប្រុងចាំស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ពួកព្រាហ្មណ៍ និងគហបតិអ្នកស្រុកវេរញ្ជាទទួលតបព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ១២៩ ] ព្រះមានព្រះភាគ បានត្រាស់យ៉ាងនេះថា ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងកាយ ៣ ចំណែក បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងវាចា ៤ ចំណែក បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងចិត្ត ៣ ចំណែក ។ ម្នាលគហ-បតីទាំងឡាយ ចុះបុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងកាយ ៣ ចំណែកតើដូចម្តេច ។ ម្នាលគហបតិទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ប្រព្រឹត្តអាក្រក់ មានដៃប្រឡាក់ឈាម ជាអ្នកស្និទ្ធចិត្តក្នុងការសម្លាប់សត្វ ឥតមានសេចក្តីអៀនខ្មាស ឥតមានមេត្តាត្រាប្រណីចំពោះពួកសត្វដែលមានជីវិតទាំងអស់ ។ ជាអ្នកកាន់យកទ្រព្យ ដែលគេមិន

បានឲ្យ ជាអ្នកកាន់យកទ្រព្យដែលជាគ្រឿងប្រើប្រាស់របស់បុគ្គលដទៃ ដែលគេមិនបានឲ្យ ជាចំណែកនៃថេយ្យចិត្ត ។ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំង-ឡាយ ពួកស្ត្រីណាដែលមាតាគ្រប់គ្រងរក្សា ។បេ។ ជាអ្នកដល់នូវការប្រព្រឹត្តល្មើស ចំពោះស្ត្រីដែលមានសភាពយ៉ាងនោះ ។ ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងកាយ ៣ ចំណែក យ៉ាងនេះឯង ។ ម្នាលគហបតិទាំងឡាយ ចុះបុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងវាចា ៤ ចំណែកតើដូចម្តេច ។ ម្នាលគហបតិទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកនិយាយពាក្យកុហក ។បេ។ និយាយកុហកទាំងដឹងខ្លួន ។ ជាអ្នកមានសម្តីញុះញង់ គឺឮដំណឹងអំពីទីនេះ ទៅប្រាប់ក្នុងទីឯណោះ ។បេ។ ជាអ្នកនិយាយពាក្យដែលធ្វើឲ្យគេបែកគ្នាជាពួក ។ ជាអ្នកមានសម្តីអាក្រក់ វាចាណាដែលកន្លួលចិត្តទាំងរបើងរើងរូស ។បេ។ ជាអ្នកនិយាយពាក្យមានសភាពដូច្នោះ ។ ជាអ្នកមានសម្តីឥតប្រយោជន៍ និយាយពាក្យក្នុងកាលមិនគួរ និយាយពាក្យមិនពិត ។បេ។ និយាយពាក្យឥតមានកំណត់មិនប្រកបដោយប្រយោជន៍ ។ ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងវាចា ៤ ចំណែក យ៉ាងនេះឯង ។ ម្នាលគហបតិទាំងឡាយ ចុះបុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងចិត្ត ៣ ចំណែក តើដូចម្តេច ។ ម្នាលគហបតិទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានចិត្តសម្លឹងរំពៃ ។បេ។ ដោយការបង្អោនចិត្តទៅថា វត្ថុនោះគប្បីបានមកជារបស់អញ ។ បុគ្គលមានចិត្តព្យាបាទ ជាអ្នកមានសេចក្តីត្រិះរិះ

ដោយចិត្តដែលទោសប្រទូស្តហើយថា សត្វទាំងនេះ ចូរវិនាសទៅឬ ។បេ។ ដែលមិនវិនាស កុំបីមានឡើយ ។ បុគ្គលជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់ឃើញវិបរិតថា ទានដែលបុគ្គលឲ្យមិនមានផល បូជាធំមិនមានផល បូជាតូចមិនមានផល ។បេ។ ប្រកាសឲ្យជាក់ច្បាស់ ។ ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនស្មើខាងចិត្ត ៣ ចំណែកយ៉ាងនេះឯង ។ ម្នាលគហបតិទាំងឡាយ ព្រោះហេតុតែការប្រព្រឹត្តមិនស្មើ គឺប្រព្រឹត្តមិនត្រូវគន្លងធម៌ បានជាពួកសត្វខ្លះក្នុងលោកនេះ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ និងនរកយ៉ាងនេះ ។

[ ១៣០ ] ម្នាលគហបតិទាំងឡាយ ចំណែកខាងបុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាងកាយ ៣ ចំណែក បុគ្គលអ្នកប្រព្រឹត្តធម៌ប្រព្រឹត្តស្មើខាងវាចា ៤ ចំណែក បុគ្គលអ្នកប្រព្រឹត្តធម៌ប្រព្រឹត្តស្មើខាងចិត្ត ៣ ចំណែកដូចគ្នាដែរ ។ ម្នាលគហបតីទាំងឡាយ ចុះបុគ្គលប្រព្រឹត្តធម៌ប្រព្រឹត្តស្មើខាងកាយ ៣ ចំណែកតើដូចម្តេច ។ ម្នាលគហបតិទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត មានអាជ្ញាដាក់ចោលហើយ មានគ្រឿងសស្ត្រាដាក់ចោលហើយ ។បេ។ ជាអ្នកអនុគ្រោះដោយប្រយោជន៍ចំពោះសត្វដែលមានជីវិតទាំងអស់ ។ លះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន មិនបានកាន់យកទ្រព្យ ដែលជាគ្រឿងប្រើប្រាស់របស់ជនឯទៀតដែលគេមិនបានឲ្យ ជាចំណែកនៃថេយ្យចិត្ត ។ លះបង់កាមេសុមិច្ឆាចារ ។បេ។ ជាអ្នកមិនដល់នូវការប្រព្រឹត្តចំពោះពួកស្ត្រីដែលមានសភាពយ៉ាងនោះ ។

ម្នាលគហបតិទាំងឡាយ បុគ្គលដែលប្រព្រឹត្តធម៌ប្រព្រឹត្តស្មើខាងកាយ ៣ ចំណែកយ៉ាងនេះឯង ។ ម្នាលគហបតិទាំងឡាយ ចុះបុគ្គលប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាងវាចា ៤ ចំណែក តើដូចម្តេច ។ ម្នាលគហបតិទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ លះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ទោះ ឋិតនៅក្នុងរោងប្រជុំក្តី ។បេ។ មិននិយាយកុហកទាំងដឹងខ្លួន ។ លះបង់ពាក្យ ញុះញង់ វៀរស្រឡះចាកពាក្យញុះញង់ ។បេ។ និយាយតែពាក្យដែលធ្វើឲ្យ គេព្រមព្រៀងគ្នា ។ លះបង់ពាក្យអាក្រក់ ។បេ។ និយាយតែពាក្យមាន សភាពដូច្នោះ ។ លះបង់ពាក្យរោយរាយឥតប្រយោជន៍ ។បេ។ ប្រកប ដោយគ្រឿងអាង ពាក្យមានកំណត់ ពាក្យប្រកបដោយប្រយោជន៍ ដោយ កាលគួរ ។ ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាង វាចា ៤ ចំណែក យ៉ាងនេះឯង ។ ម្នាលគហបតិទាំងឡាយ បុគ្គលប្រព្រឹត្ត ធម៌ ប្រព្រឹត្តស្មើខាងចិត្ត ៣ ចំណែក តើដូចម្តេច ។ ម្នាលគហបតិទាំង- ឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនរំពេចង់បានទ្រព្យគេ មិនសម្លឹង ចង់បានទ្រព្យរបស់ដែលជាគ្រឿងប្រើប្រាស់របស់គេ ដោយគិតថា ធ្វើដូច ម្តេចហ្ន៎ ទ្រព្យរបស់អ្នកដទៃនោះ គប្បីបានមកជារបស់អញដូច្នេះ ។ ជាអ្នក មានចិត្តមិនបានព្យាបាទ មានសេចក្តីត្រិះរិះដោយចិត្ត ដែលទោសមិនប្រទូស្ត ហើយថា សូមឲ្យសត្វទាំងនេះកុំមានពៀរ កុំបៀតបៀនគ្នា កុំមានទុក្ខ ចូរ រក្សាខ្លួនប្រាណឲ្យបានសេចក្តីសុខចុះ ។ ជាអ្នកសម្មាទិដ្ឋិ មានសេចក្តីយល់ មិនវិបរិតថា ទានដែលបុគ្គលឲ្យហើយមានផល បូជាធំក៏មានផល ។បេ។ ធ្វើ

ឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែង ដោយខ្លួនឯង ។ ម្នាលគហបតិទាំង-ឡាយ បុគ្គលប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើខាងចិត្ត ៣ ចំណែក យ៉ាងនេះឯង ។ ម្នាលគហបតិទាំងឡាយ ព្រោះសេចក្តីប្រព្រឹត្តស្មើ គឺប្រព្រឹត្តធម៌ជាហេតុយ៉ាង នេះឯង បានជាពួកសត្វខ្លះក្នុងលោកនេះ ដល់បែកធ្លាយរាងកាយខាងមុខអំពី សេចក្តីស្លាប់ ទៅកើតក្នុងសុគតិសួគ៌ទេវលោកយ៉ាងនេះ ។

[ ១៣១ ] ម្នាលគហបតិទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រសិនបើប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ សូមឲ្យអាត្មាអញបានទៅកើតជាមួយនឹងពួកខត្តិយមហាសាលដូច្នេះ ហេតុនុ៎ះ ឯងរមែងមាន បុគ្គលនោះ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួកខត្តិយមហាសាលបានមែន ដំណើរ នុ៎ះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយ ពិត ។ ម្នាលគហបតិទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ បើ ប្រសិនជាប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ សូមឲ្យអាត្មាអញបានទៅកើតជាមួយនឹងពួកព្រាហ្មណមហាសាល ។បេ។ ពួក គហបតិមហាសាល ដូច្នេះ ហេតុនុ៎ះឯងរមែងមាន បុគ្គលនោះ លុះបែកធ្លាយ រាងកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួក គហបតិមហាសាលបានមែន ដំណើរនុ៎ះតើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះ ឯងជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយពិត ។ ម្នាលគហបតិទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ បើប្រសិនជាប្រាថ្នាថា ឱហ្ន៎លុះបែកធ្លាយ

រាងកាយខាងមុខអំពីសេចក្ដីស្លាប់ សូមឲ្យអាត្មាអញបានទៅកើតជាមួយនឹងទេវតាជាន់ចាតុម្មហារាជិកៈដូច្នេះ ហេតុនុ៎ះឯងរមែងមាន ដ្បិតបុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកៈបានមែន ដំណើរនុ៎ះតើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយពិត ។ ម្នាលគហបតិទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ប្រព្រឹត្តស្មើ បើប្រសិនជាប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ទៅ សូមឲ្យអាត្មាអញបានទៅកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។បេ។ ពួកទេវតាជាន់យាមៈ ... ពួកទេវតាជាន់តុសិត ... ពួកទេវតាជាន់និម្មានរតី ... ពួកទេវតាជាន់បរនិម្មិតវសវត្តី ... ពួកទេវតាដែលរាប់ចូលក្នុងព្រហ្មដូច្នេះ ហេតុនុ៎ះឯងរមែងមាន ដ្បិតបុគ្គលនោះ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួកទេវតា ដែលរាប់ចូលក្នុងពួកព្រហ្មបានមែន ដំណើរនុ៎ះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ដោយពិត ។ ម្នាលគហបតិទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ បើប្រសិនជាប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ទៅ សូមឲ្យអាត្មាអញបានទៅកើតជាមួយនឹងពួកទេវតាជាន់អាភា ដូច្នេះ ហេតុនុ៎ះឯងរមែងមាន ដ្បិតបុគ្គលនោះ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួកទេវតាជាន់អាភាបានមែន ដំណើរនុ៎ះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះ ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ

ដោយពិត ។ ម្នាលគហបតិទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ បើប្រសិនជាប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ទៅ សូមឲ្យអាត្មាអញ បានទៅកើតជាមួយនឹងពួកទេវតាជាន់បរិត្តាភៈ ។បេ។ ពួកទេវតាជាន់អប្បមាណាភៈ ... ពួកទេវតាជាន់អាភស្សរៈ ... ពួកទេវតាជាន់បរិត្តសុភៈ ... ពួកទេវតាជាន់អប្បមាណសុភៈ ... ពួកទេវតាជាន់សុភកិណ្ហកៈ ... ពួកទេវតាជាន់វេហប្ផលៈ ... ពួកទេវតាជាន់អវិហៈ ... ពួកទេវតាជាន់អតប្បៈ ... ពួកទេវតាជាន់សុទស្សៈ ... ពួកទេវតាជាន់សុទស្សី ... ពួកទេវតាជាន់អកនិដ្ឋកៈ ... ពួកទេវតា ជាអ្នកទៅកើតក្នុងអាកាសានញ្ចាយតនភព ... ពួកទេវតាជាអ្នកទៅកើតក្នុងវិញ្ញាណញ្ចាយតនភព ... ពួកទេវតាជាអ្នកទៅកើតក្នុងអាកិញ្ចញ្ញាយតនភព ... ពួកទេវតាជាអ្នកទៅកើតក្នុងនេវសញ្ញានាសញ្ញាយតនភពដូច្នេះ ហេតុនុ៎ះឯងរមែងមាន ដ្បិតបុគ្គលនោះ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ទៅ នឹងបានទៅកើតជាមួយនឹងពួកទេវតាជាន់នេវសញ្ញានាសញ្ញាយតនភពបានមែន ដំណើរនុ៎ះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយពិត ។ ម្នាលគហបតិទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ បើប្រសិនជាប្រាថ្នាថា ឱហ្ន៎ អាត្មាគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញារបស់ខ្លួន ចំពោះចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថ ៤ ដូច្នេះ ហេតុនុ៎ះឯងរមែងមាន ដ្បិតបុគ្គលនោះ គប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញា របស់

ខ្លួន ចំពោះចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ បានមែន ដំណើរនុ៎ះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះ ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយពិត ។

[ ១៣២ ] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ពួកព្រាហ្មណ៍ និងគហបតិទាំងឡាយ អ្នកស្រុកវេរញ្ជា ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ភាសិតដែលព្រះអង្គសម្តែងហើយ ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតដែលព្រះអង្គសម្តែងហើយ ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ( ភ្លឺច្បាស់ណាស់ ) ដូចបុគ្គលចាប់ផ្ងាររបស់ដែលផ្កាប់ ឬក៏ដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចបុគ្គលប្រាប់ផ្លូវដល់មនុស្សវង្វេងទិស ពុំនោះសោត ដូចជាបុគ្គលទ្រោលប្រទីបក្នុងទីងងឹតដោយ គិតថា ពួកមនុស្សមានភ្នែកភ្លឺឃើញរូបបានយ៉ាងនោះឯង ពួកខ្ញុំព្រះអង្គ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីរឭក សូមព្រះគោតមចាំទុកនូវពួកខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់នូវសរណៈ ស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះជាដើមទៅ ។

## វេរញ្ជកសូត្រទី ២ ចប់

# អដ្ឋកថា

## វេរញ្ជកសូត្រទី ២

[ ១២៨ ] វេរញ្ជកសូត្រ មានពាក្យផ្ដើមថា **ឯកំ សមយំ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **វេរញ្ជកា** បានដល់ បុគ្គលអ្នកនៅក្នុងក្រុងវេរញ្ជា ។ បទថា **កេនចិទេវ ករណីយេន** បានដល់ ដោយករណីយកិច្ចដែលមិនកំណត់ឲ្យពិតប្រាកដនោះឯង ។ ពាក្យដ៏សេសទាំងអស់ គប្បីជ្រាបតាមបែបដែលពោលហើយក្នុងសូត្រមុន ។ ឯក្នុងសូត្រនេះ ព្រះមានព្រះភាគទ្រង់បានធ្វើការសម្ដែងដោយលើកយកបុគ្គលមកជាទីតាំងយ៉ាងនេះថា បុគ្គលមានប្រក្រតីប្រព្រឹត្តជាធម៌ មានប្រក្រតីមិនវៀបរយ តែក្នុងព្រះសូត្រមុន ជាព្រះសូត្រដែលលើកយកធម៌មកជាទីតាំងប៉ុណ្ណោះ ។ សេចក្ដីប្លែកគ្នាមានប្រមាណប៉ុណ្ណេះ ។ ពាក្យដ៏សេសដូចគ្នាទាំងអស់ ៕

វេរញ្ជកសូត្រ ចប់

សូត្រទី ២ ចប់

# សុត្តន្តបិដក

## មហាវេទល្លសូត្រទី ៣

[ ១៣៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមហាកោដ្ឋិតៈមានអាយុ ចេញអំពីផលសមាបត្តិក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះសារីបុត្រមានអាយុ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យរាក់ទាក់ សំណេះសំណាលទៅរកព្រះសារីបុត្រមានអាយុ លុះបញ្ចប់ពាក្យសំណេះសំណាល និងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។

[ ១៣៤ ] លុះព្រះមហាកោដ្ឋិតៈមានអាយុ គង់ក្នុងទីដ៏សមគួរហើយ ទើបសួរព្រះសារីបុត្រមានអាយុយ៉ាងនេះថា ម្នាលអាវុសោ គេតែងនិយាយថា បុគ្គលគ្មានប្រាជ្ញាៗ ម្នាលអាវុសោ បុគ្គលដែលហៅថា អ្នកគ្មានប្រាជ្ញា តើដោយហេតុដូចម្តេច ។ ព្រះសារីបុត្រតបថា ម្នាលអាវុសោ បុគ្គលដែលមិនចេះមិនដឹងច្បាស់ហ្នឹងឯង ហៅថា អ្នកគ្មានប្រាជ្ញា ចុះបុគ្គលនោះមិនដឹងច្បាស់នូវអ្វី មិនដឹងច្បាស់ថា នេះទុក្ខ មិនដឹងច្បាស់ថា នេះហេតុឲ្យកើតទុក្ខ មិនដឹងច្បាស់ថា នេះជាគ្រឿងរម្ងត់ទុក្ខ មិនដឹងច្បាស់ថា នេះជាសេចក្តីប្រតិបត្តិ ដែលជាដំណើរទៅកាន់ទីរម្ងត់ទុក្ខ ម្នាលអាវុសោ ព្រោះតែបុគ្គលនោះមិនចេះមិនដឹងដូច្នេះឯង ទើបហៅថា អ្នកគ្មានប្រាជ្ញា ។ ព្រះមហាកោដ្ឋិតៈមានអាយុ ក៏ត្រេកអរអនុមោទនាចំពោះភាសិតរបស់ព្រះសារីបុត្រមានអាយុថា

ម្នាលអាវុសោ ពីរោះណាស់ លុះអនុមោទនាហើយ ទើបសួរប្រស្នានឹងព្រះសារីបុត្រមានអាយុតទៅទៀតថា ម្នាលអាវុសោ គេតែងនិយាយថា អ្នកមានប្រាជ្ញាៗ ម្នាលអាវុសោ ចុះបុគ្គលដែលហៅថា អ្នកមានប្រាជ្ញា តើដោយហេតុដូចម្តេចខ្លះ ។ ព្រះសារីបុត្រតបថា ម្នាលអាវុសោ បុគ្គលដែលចេះដឹងច្បាស់ហ្នឹងឯងដែលហៅថា អ្នកមានប្រាជ្ញា ចុះបុគ្គលនោះដឹងច្បាស់នូវអ្វី ដឹងច្បាស់ថា នេះទុក្ខ ដឹងច្បាស់ថា នេះជាហេតុឲ្យកើតទុក្ខ ដឹងច្បាស់ថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់ថា នេះជាសេចក្តីប្រតិបត្តិ ដែលជាដំណើរទៅកាន់ទីរលត់ទុក្ខ ម្នាលអាវុសោ ព្រោះតែបុគ្គលនោះដឹងច្បាស់ដូច្នេះឯង ទើបហៅថា អ្នកមានប្រាជ្ញា ។ ម្នាលអាវុសោ គេតែងហៅថា វិញ្ញាណ វិញ្ញាណ ម្នាលអាវុសោ ចុះធម្មជាតដែលគេហៅថា វិញ្ញាណ តើដូចម្តេច ។ ម្នាលអាវុសោ ធម្មជាតដែលស្គាល់ច្បាស់ ដឹងច្បាស់នុ៎ះឯងដែលគេហៅថា វិញ្ញាណ ចុះវិញ្ញាណនោះស្គាល់អ្វីខ្លះ ស្គាល់ថា សុខខ្លះ ស្គាល់ថា ទុក្ខខ្លះ ស្គាល់ថា មិនមែនទុក្ខមិនមែនសុខខ្លះ ម្នាលអាវុសោ ព្រោះតែធម្មជាតនោះ ស្គាល់ច្បាស់ ដឹងច្បាស់ដូច្នេះឯង ទើបហៅថា វិញ្ញាណ ។ ម្នាលអាវុសោ ចុះប្រាជ្ញា និងវិញ្ញាណ ធម៌ ( ទាំងពីរ ) នេះ តើដូចគ្នា ឬផ្សេងគ្នា មួយទៀតបុគ្គលចែករំលែកធម៌ ( ទាំងពីរ ) នេះ បញ្ញត្តឲ្យផ្សេងៗគ្នា បានឬទេ ។ ម្នាលអាវុសោ ប្រាជ្ញា និងវិញ្ញាណ ធម៌ ( ទាំងពីរ ) នេះ ជាធម៌ដូចគ្នា មិនមែនផ្សេងគ្នាទេ ទាំងបុគ្គលនឹងចែករំលែក បញ្ញត្តធម៌ទាំងពីរនេះឲ្យផ្សេងគ្នាមិនបានទេ ម្នាលអាវុសោ ប្រាជ្ញាដឹងច្បាស់នូវវត្ថុណា វិញ្ញាណក៏ដឹងច្បាស់

នូវវត្ថុនោះដែរ វិញ្ញាណស្គាល់ច្បាស់នូវវត្ថុណា ប្រាជ្ញាក៏ដឹងច្បាស់នូវវត្ថុនោះដែរ ព្រោះហេតុនោះ បានជាធម៌ ( ទាំងពីរ ) នេះ ជាធម៌ដូចគ្នា មិនមែនផ្សេងគ្នាទេ ទាំងបុគ្គលនឹងចែករំលែក បញ្ញត្តធម៌ទាំងពីរនេះ ឲ្យផ្សេងគ្នាមិនបានឡើយ ។ ម្នាលអាវុសោ បើប្រាជ្ញា និងវិញ្ញាណ ធម៌ ( ទាំងពីរ ) នេះ ដូចគ្នា មិនមែនផ្សេងគ្នាទេ ចុះសេចក្តីប្លែកគ្នាត្រង់ណា ។ ម្នាលអាវុសោ ប្រាជ្ញា និងវិញ្ញាណ ធម៌ ( ទាំងពីរ ) នេះ ជាធម៌ដូចគ្នា មិនមែនផ្សេងគ្នាទេ តែប្រាជ្ញាបុគ្គលគួរចម្រើន វិញ្ញាណបុគ្គលគួរកំណត់ដឹង នេះជាសេចក្តីប្លែកគ្នានៃធម៌ ( ទាំងពីរ ) នោះ ។

[ ១៣៥ ] ម្នាលអាវុសោ គេតែងហៅថា វេទនា វេទនា ម្នាលអាវុសោ គេហៅថា វេទនា ដោយហេតុដូចម្តេច ។ ម្នាលអាវុសោ ធម្មជាតទទួលដឹងនូវអារម្មណ៍ហ្នឹងឯង ដែលគេហៅថា វេទនា វេទនានោះ ដឹងអ្វីខ្លះ ដឹងសុខខ្លះ ដឹងទុក្ខខ្លះ ដឹងមិនមែនទុក្ខមិនមែនសុខខ្លះ ម្នាលអាវុសោ ព្រោះតែធម្មជាតនោះ ទទួលដឹងអារម្មណ៍ដូច្នេះឯង ទើបហៅថា វេទនា ។ ម្នាលអាវុសោ គេតែងហៅថា សញ្ញា សញ្ញា ម្នាលអាវុសោ ដែលគេហៅថា សញ្ញាដោយហេតុដូចម្តេច ។ ម្នាលអាវុសោ ព្រោះតែធម្មជាតនោះកត់សម្គាល់ចំណាំ ទើបហៅថា សញ្ញា សញ្ញានោះ តែងសម្គាល់អ្វីខ្លះ សញ្ញានោះតែងសម្គាល់ពណ៌ខៀវខ្លះ សម្គាល់ពណ៌លឿងខ្លះ សម្គាល់ពណ៌ក្រហមខ្លះ សម្គាល់ពណ៌សខ្លះ ម្នាលអាវុសោ ព្រោះតែធម្មជាតនោះ កត់សម្គាល់ហ្នឹងឯង ទើបហៅថា សញ្ញា ។ ម្នាលអាវុសោ វេទនា សញ្ញា និងវិញ្ញាណ ធម៌ទាំងនេះ

ជាធម៌ប្រឡូកគ្នា ឬមិនប្រឡូកគ្នាទេ មួយទៀត បុគ្គលនឹងចែករំលែកធម៌ទាំងនេះ ហើយ បញ្ញត្តកុំឲ្យប្រឡូកគ្នាបានឬទេ ។ ម្នាលអាវុសោ វេទនា សញ្ញា និង វិញ្ញាណ ធម៌ទាំងនេះប្រឡូកគ្នា មិនមែនផ្សេងគ្នាទេ ហើយបុគ្គលចែករំលែក ធម៌ទាំងនេះ បញ្ញត្តឲ្យផ្សេងគ្នាមិនបានទេ ម្នាលអាវុសោ វេទនាទទួលអារម្មណ៍ ណា សញ្ញាក៏សម្គាល់អារម្មណ៍នោះដែរ សញ្ញាសម្គាល់នូវអារម្មណ៍ណា វិញ្ញាណក៏ដឹងច្បាស់នូវអារម្មណ៍នោះដែរ ព្រោះហេតុនោះ ធម៌ទាំងនេះជាធម៌ ដូចគ្នា មិនមែនផ្សេងគ្នាទេ បុគ្គលនឹងចែករំលែកធម៌ទាំងនេះ ហើយបញ្ញត្ត ឲ្យផ្សេងគ្នាមិនបានទេ ។

[ ១៣៦ ] ម្នាលអាវុសោ ធម្មជាតអ្វី ដែលគេគប្បីដឹងដោយមនោ-វិញ្ញាណដ៏បរិសុទ្ធ ប្រាសចាកឥន្ទ្រិយទាំង ៥ ប្រការ ។ ម្នាលអាវុសោ អាកាសានញ្ចាយតនជ្ឈាន ដែលបរិកម្មថា អាកាសមិនមានទីបំផុត ដូច្នេះ គប្បីដឹងដោយមនោវិញ្ញាណ ដ៏បរិសុទ្ធប្រាសចាកឥន្ទ្រិយទាំង ៥ ប្រការ វិញ្ញាណញ្ចាយតនជ្ឈាន ដែលបរិកម្មថា វិញ្ញាណមិនមានទីបំផុត និង អាកិញ្ចញ្ញាយតនៈ ដែលបរិកម្មថា អ្វីតិចតួចមិនមាន ដូច្នេះ គប្បីដឹងបាន ដោយមនោវិញ្ញាណ ដ៏បរិសុទ្ធប្រាសចាកឥន្ទ្រិយទាំង ៥ ប្រការ ។ ម្នាល អាវុសោ ធម៌ដែលគេគប្បីដឹង តើគេតែងដឹងបានដោយអ្វី ។ ម្នាលអាវុសោ ធម៌ដែលគេគប្បីដឹងនោះឯង គេតែងដឹងដោយបញ្ញាចក្ខុ ។ ម្នាលអាវុសោ ប្រាជ្ញាមានសេចក្តីថា ដូចម្តេចខ្លះ ម្នាលអាវុសោ ប្រាជ្ញាមានសេចក្តីថា ដឹង ប្រាកដ មានសេចក្តីថា ដឹងសព្វ មានសេចក្តីថា លះបង់ ។

[ ១៣៧ ] ម្នាលអាវុសោ បច្ច័យដែលឲ្យសម្មាទិដ្ឋិកើតឡើង មានប៉ុន្មាន ។ ម្នាលអាវុសោ បច្ច័យដែលឲ្យសម្មាទិដ្ឋិកើតឡើង មាន ២ គឺ ការលាន់ឮអំពីសម្នាក់ជនដទៃ ១ ការយកចិត្តទុកដាក់ដោយឧបាយប្រាជ្ញា ( ខ្លួនឯង ) ១ ម្នាលអាវុសោ បច្ច័យដែលឲ្យសម្មាទិដ្ឋិកើតឡើង មាន ២ នេះឯង ។ ម្នាលអាវុសោ សម្មាទិដ្ឋិដែលមានចេតោវិមុត្តិជាផលផង មានផល គឺ ចេតោវិមុត្តិជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានផល គឺបញ្ញាវិមុត្តិជាអានិសង្សផង មានអង្គប៉ុន្មានទំនុកបម្រុង ។ ម្នាលអាវុសោ សម្មាទិដ្ឋិដែលមានចេតោ-វិមុត្តិជាផលផង មានផល គឺចេតោវិមុត្តិជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានផល គឺបញ្ញាវិមុត្តិជាអានិសង្សផង មានអង្គ ៥ ជួយទំនុកបម្រុង ម្នាលអាវុសោ សម្មាទិដ្ឋិក្នុងទីនេះ មានសីលជួយទំនុកបម្រុង ១ មានសុតៈជួយទំនុកបម្រុង ១ មានសាកច្ឆាជួយទំនុកបម្រុង ១ មានសមថៈជួយទំនុកបម្រុង ១ មានវិបស្សនាជួយទំនុកបម្រុង ១ ម្នាលអាវុសោ សម្មា-ទិដ្ឋិដែលមានចេតោវិមុត្តិជាផលផង មានផលគឺចេតោវិមុត្តិ ជាអានិសង្សផង មានបញ្ញាវិមុត្តិជាផលផង មានផល គឺបញ្ញាវិមុត្តិ ជាអានិសង្សផង មានអង្គ ៥ នេះឯង ជួយទំនុកបម្រុង ។

[ ១៣៨ ] ម្នាលអាវុសោ ភព តើមានប៉ុន្មាន ។ ម្នាលអាវុសោ ភពនេះមាន ៣ គឺ កាមភព១ រូបភព១ អរូបភព១ ។ ម្នាលអាវុសោ ការកើតក្នុងភពថ្មីតទៅទៀតព្រោះហេតុដូចម្តេច ។ ម្នាលអាវុសោ ព្រោះសេចក្តីត្រេកអរក្នុងភពនោះៗ របស់ពួកសត្វ ដែលមានអវិជ្ជាជានីវរណៈ មានតណ្ហា ជា

សំយោជនៈ ការកើតក្នុងភពថ្មីតទៅទៀត យ៉ាងនេះឯង ។ ម្នាលអាវុសោ ការមិនកើតក្នុងភពថ្មីតទៅទៀត ព្រោះហេតុដូចម្ដេច ។ ម្នាលអាវុសោ ព្រោះប្រាសចាកអវិជ្ជា ព្រោះវិជ្ជាកើតឡើង ព្រោះការរលត់នៃតណ្ហា ការមិនកើតក្នុងភពថ្មីតទៅទៀត យ៉ាងនេះឯង ។

[ ១៣៩ ] ម្នាលអាវុសោ បឋមជ្ឈានដូចម្ដេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិ និងសុខដែលកើតអំពីវិវេក ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលអាវុសោ នេះហៅថា បឋមជ្ឈាន ។ ម្នាលអាវុសោ បឋមជ្ឈានមានអង្គប៉ុន្មាន ។ ម្នាលអាវុសោ បឋមជ្ឈានមានអង្គ ៥ ម្នាលអាវុសោ កាលភិក្ខុក្នុងសាសនានេះ ចូលកាន់បឋមជ្ឈានមានអង្គ ៥ វិតក្កៈ វិចារៈ បីតិ សុខ និងចិត្តេកគ្គតា រមែងប្រព្រឹត្តទៅ ម្នាលអាវុសោ បឋមជ្ឈានមានអង្គ ៥ យ៉ាងនេះឯង ។ ម្នាលអាវុសោ បឋមជ្ឈានលះអង្គប៉ុន្មាន ប្រកបដោយអង្គប៉ុន្មាន ។ ម្នាលអាវុសោ បឋមជ្ឈានលះអង្គ ៥ ប្រកបដោយអង្គ ៥ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ កាលចូលកាន់បឋមជ្ឈាន ជាអ្នកលះបង់កាមច្ឆន្ទៈ លះបង់ព្យាបាទ លះបង់ថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ចំណែកខាងវិតក្កៈ វិចារៈ បីតិ សុខ និងចិត្តេកគ្គតាក៏ប្រព្រឹត្តទៅ ម្នាលអាវុសោ បឋមជ្ឈានលះអង្គ ៥ ប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។

[ ១៤០ ] ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ ប្រការនេះ មានវិស័យផ្សេងៗ

គ្នា មានអារម្មណ៍ផ្សេងៗគ្នា ទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាមិនបានទេ ឥន្ទ្រិយទាំង ៥ គឺអ្វីខ្លះ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ម្នាលអាវុសោ កាលបើឥន្ទ្រិយទាំង ៥ ប្រការនេះមានវិស័យផ្សេងៗគ្នា មានអារម្មណ៍ផ្សេងៗគ្នា មិនទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាបានទេ ចុះមានអ្វីជាទីពឹង មួយទៀត សភាពអ្វីទទួលវិស័យដែលកើតជាអារម្មណ៍របស់ឥន្ទ្រិយទាំង ៥ ប្រការនោះ ៗ ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ ប្រការនេះ មានវិស័យផ្សេងៗគ្នា មានអារម្មណ៍ផ្សេងៗគ្នា មិនទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាបានទេ ឥន្ទ្រិយទាំង ៥ គឺអ្វីខ្លះ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ម្នាលអាវុសោ កាលបើឥន្ទ្រិយទាំង ៥ ប្រការនេះឯង មានវិស័យផ្សេងៗ គ្នា មានអារម្មណ៍ផ្សេងៗ គ្នា មិនទទួលវិស័យដែលកើតជាអារម្មណ៍ជំនួសគ្នាបានទេ មានចិត្តជាទីពឹង មានចិត្តទទួលវិស័យដែលកើតជាអារម្មណ៍របស់ឥន្ទ្រិយទាំង ៥ នោះ ៗ

[ ១៤១ ] ម្នាលអាវុសោ ឥន្ទ្រិយ ៥ ប្រការនេះ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ នេះឯង អាស្រ័យនឹងអ្វី ទើបតាំងនៅបាន ៗ ម្នាលអាវុសោ ឥន្ទ្រិយ ៥ នេះ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ម្នាលអាវុសោ ឥន្ទ្រិយទាំង ៥ នេះឯង អាស្រ័យនឹងអាយុ ទើបតាំងនៅបាន ៗ ម្នាលអាវុសោ ចុះអាយុលុះតែអាស្រ័យនឹងអ្វីទើបតាំង

នៅបាន ។ អាយុលុះតែអាស្រ័យចំហាយធាតុភ្លើង ទើបតាំងនៅបាន ។ ម្នាលអាវុសោ ចំហាយធាតុភ្លើងអាស្រ័យនឹងអ្វី ទើបតាំងនៅបាន ។ ចំហាយធាតុភ្លើង លុះតែអាស្រ័យនឹងអាយុ ទើបតាំងនៅបាន ។ អម្បាញ់មិញនេះឯង ខ្ញុំដឹងច្បាស់ភាសិតរបស់ព្រះសារីបុត្រមានអាយុយ៉ាងនេះថា អាយុលុះតែអាស្រ័យចំហាយធាតុភ្លើង ទើបតាំងនៅបាន ឥឡូវនេះ ខ្ញុំដឹងច្បាស់ភាសិតរបស់ព្រះសារីបុត្រមានអាយុយ៉ាងនេះថា ភ្លើងធាតុលុះតែអាស្រ័យនឹងអាយុ ទើបតាំងនៅបានដូច្នេះវិញ ។ ម្នាលអាវុសោ បើដូច្នេះ ខ្ញុំត្រូវយល់សេចក្តីនៃភាសិតនេះដូចម្តេច ។ ម្នាលអាវុសោ បើដូច្នោះ ខ្ញុំនឹងធ្វើសេចក្តីឧបមាប្រគេនលោក ដ្បិតជនជាអ្នកចេះដឹងពួកខ្លះក្នុងលោកនេះ គង់យល់សេចក្តីនៃភាសិតដោយពាក្យឧបមាបានដែរ ម្នាលអាវុសោ ដូចប្រទីបប្រេងកាលឆេះ មានពន្លឺប្រាកដឡើងព្រោះអាស្រ័យអណ្តាត អណ្តាតប្រាកដឡើងព្រោះអាស្រ័យពន្លឺ សេចក្តីនេះ យ៉ាងណាមិញ អាយុតាំងនៅបាន ក៏ព្រោះអាស្រ័យចំហាយធាតុភ្លើង ចំហាយធាតុភ្លើងតាំងនៅបានព្រោះអាស្រ័យអាយុ ក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ អាយុសង្ខារទាំងនោះ ជាវេទនីយធម៌នោះ ឬថា អាយុសង្ខារផ្សេង វេទនីយធម៌ផ្សេង ។ ម្នាលអាវុសោ មិនមែនអាយុសង្ខារទាំងនោះ ជាវេទនីយ-ធម៌នោះទេ ម្នាលអាវុសោ ប្រសិនបើអាយុសង្ខារទាំងនោះ ជាវេទនីយធម៌នោះហើយ ភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធនេះ ចេញចាកសមាបត្តិមកវិញមិនកើតទេ គឺអាយុសង្ខារផ្សេង វេទនីយធម៌ផ្សេង ហេតុនោះបានជាភិក្ខុចូលកាន់សញ្ញាវេទយិតនិរោធ ចេញចាកសមាបត្តិមកវិញបាន ។

[ ១៤២ ] ម្នាលអាវុសោ ធម៌ប៉ុន្មានដែលលះបង់កាយនេះ ក្នុងកាលណាហើយ កាយនេះគេចោលរាត់រាយ ដេកស្តូកស្តឹងដូចជាកំណាត់ឈើដែលគ្មានចេតនា ។ ម្នាលអាវុសោ ធម៌ ៣ ប្រការ គឺអាយុ ១ ចំហាយធាតុភ្លើង ១ វិញ្ញាណ ១ លះបង់កាយនេះក្នុងកាលឯណាហើយ កាយនេះ គេចោលរាត់រាយ ដេកស្តូកស្តឹង ដូចកំណាត់ឈើដែលគ្មានចេតនា ។ ម្នាលអាវុសោ បុគ្គលដែលធ្វើកាលកិរិយាក្ស័យ១ ភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ១ បុគ្គលទាំង ២ ពួកនេះ មានសេចក្តីប្លែកគ្នាដូចម្តេច ។ ម្នាលអាវុសោ បុគ្គលដែលធ្វើកាលកិរិយាក្ស័យ បុគ្គលនោះ កាយសង្ខារ គឺខ្យល់ដង្ហើមចេញចូលរលត់សូន្យឈឹង វចីសង្ខារ គឺវិតក្ក និងវិចារៈរលត់សូន្យឈឹង ចិត្តសង្ខារ គឺសញ្ញា និងវេទនា រលត់សូន្យឈឹង អាយុក៏អស់ ចំហាយធាតុភ្លើងក៏រលត់សូន្យឈឹង ឥន្ទ្រិយក៏បែកធ្លាយ ឯភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ ភិក្ខុនោះមានកាយសង្ខាររលត់សូន្យឈឹង វចីសង្ខាររលត់សូន្យឈឹង ចិត្តសង្ខាររលត់សូន្យឈឹងដែរ តែអាយុមិនអស់ ចំហាយធាតុភ្លើងមិនរលត់សូន្យទេ ឥន្ទ្រិយនៅថ្លាល្អ ម្នាលអាវុសោ បុគ្គលដែលធ្វើមរណកាលក្ស័យ និងភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ បុគ្គលទាំង ២ ពួកនេះ មានសេចក្តីផ្សេងគ្នា យ៉ាងនេះឯង ។

[ ១៤៣ ] ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិ មានបច្ច័យប៉ុន្មាន ។ ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ៤ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសេចក្តីសុខ ១ ព្រោះ

លះបង់នូវសេចក្ដីទុក្ខ ១ ព្រោះរម្ងត់នូវសោមនស្ស និងទោមនស្សក្នុងកាលមុន ១ ចូលកាន់ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំងបួន ១ ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ៤ នេះឯង ។ ម្នាលអាវុសោ អនិមិត្តចេតោវិមុត្តិសមាបត្តិ មានបច្ច័យប៉ុន្មាន ។ ម្នាលអាវុសោ អនិមិត្ត-ចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ២ គឺការមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុ ដែលប្រាសចាកអារម្មណ៍ ១ ម្នាលអាវុសោ អនិមិត្តចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ២ នេះឯង ។ ម្នាលអាវុសោ បច្ច័យដែលឲ្យអនិមិត្តចេតោវិមុត្តិតាំងនៅបានយូរ តើមានប៉ុន្មាន ។ ម្នាលអាវុសោ បច្ច័យដែលឲ្យអនិមិត្តចេតោវិមុត្តិតាំងនៅបានយូរ មាន ៣ ប្រការ គឺការមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុដែលប្រាសចាកអារម្មណ៍ ១ ការបានតាក់តែងទុកពីខាងដើម ១ ម្នាលអាវុសោ បច្ច័យដែលឲ្យអនិមិត្តចេតោវិមុត្តិតាំងនៅបានយូរ មាន ៣ ប្រការ នេះឯង ។ ម្នាលអាវុសោ បច្ច័យនៃការចេញចាកអនិមិត្តចេតោវិមុត្តិមានប៉ុន្មាន ។ ម្នាលអាវុសោ បច្ច័យនៃការចេញចាកអនិមិត្តចេតោវិមុត្តិ មាន ២ ប្រការ គឺការយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ១ ការមិនយកចិត្តទុកដាក់ចំពោះនិព្វានធាតុ ដែលមិនមានអារម្មណ៍ ១ ម្នាលអាវុសោ បច្ច័យនៃការចេញចាកអនិមិត្តចេតោវិមុត្តិមាន ២ ប្រការនេះឯង ។

[ ១៨៤ ] ម្នាលអាវុសោ អប្បមាណចេតោវិមុត្តិ អាកិញ្ចញ្ញចេតោវិមុត្តិ សុញ្ញតចេតោវិមុត្តិ និងអនិមិត្តចេតោវិមុត្តិ ធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ឬមានសេចក្តីដូចគ្នា គ្រាន់តែព្យញ្ជនៈផ្សេងគ្នាប៉ុណ្ណោះទេ ។ ម្នាលអាវុសោ អប្បមាណចេតោវិមុត្តិណា អាកិញ្ចញ្ញចេតោ-វិមុត្តិណា សុញ្ញតចេតោវិមុត្តិណា និងអនិមិត្តចេតោវិមុត្តិណា ម្នាលអាវុសោ មានបរិយាយដែលធម៌ទាំងនេះ អាស្រ័យហើយ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ម្នាលអាវុសោ មួយទៀត មានបរិយាយដែលធម៌ទាំងនេះ អាស្រ័យហើយ ក៏បែរជាមានសេចក្តីដូចគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ ម្នាលអាវុសោ ចុះបរិយាយដូចម្តេច ដែលធម៌ទាំងនេះ អាស្រ័យហើយ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តាធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសកណ្តាល ព្រោះយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ។ មានចិត្តប្រកបដោយករុណា ... ប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិស ទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម

ទិសទទឹង ព្រោះបង្អោនខ្លួនទៅប្រៀបធៀបនឹងសត្វទាំងពួង ក្នុងទីទាំងពួង ម្នាលអាវុសោ នេះហៅថា អប្បមាណាចេតោវិមុត្តិ ។ ម្នាលអាវុសោ អាកិញ្ចញ្ញាចេតោវិមុត្តិ តើដូចម្តេច ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ កន្លងបង់នូវវិញ្ញាណញ្ចាយតនៈដោយសព្វអន្លើ ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា អ្វីបន្តិចបន្តួចមិនមានដូច្នេះ ម្នាលអាវុសោ នេះហៅថា អាកិញ្ចញ្ញាចេតោវិមុត្តិ ។ ម្នាលអាវុសោ សុញ្ញតចេតោវិមុត្តិ តើដូចម្តេច ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងសុញ្ញាគារស្ថានក្តី រមែងពិចារណាយ៉ាងនេះថា របស់នេះតែងសាបសូន្យចាកអត្តភាព ឬចាកវត្ថុសម្រាប់ទំនុកបម្រុងខ្លួន មានចីវរជាដើម ម្នាលអាវុសោ នេះលោកហៅថា សុញ្ញតចេតោវិមុត្តិ ។ ម្នាលអាវុសោ អនិមិត្តចេតោវិមុត្តិ តើដូចម្តេច ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ចូលកាន់ចេតោសមាធិដែលមិនមាននិមិត្ត ព្រោះមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង នេះហៅថា អនិមិត្តចេតោវិមុត្តិ ។ ម្នាលអាវុសោ នេះឯងជាបរិយាយដែលធម៌ទាំងនេះអាស្រ័យហើយ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ។ ម្នាលអាវុសោ ចុះបរិយាយដូចម្តេច ដែលពួកធម៌ទាំងនេះអាស្រ័យហើយ បែរជាមានសេចក្តីដូចគ្នា តែមានព្យញ្ជនៈផ្សេងគ្នា ម្នាលអាវុសោ រាគៈ ជាកិលេសធ្វើនូវប្រមាណ ទោសៈ ជាកិលេសធ្វើនូវប្រមាណ មោហៈ ជាកិលេសធ្វើនូវប្រមាណ កិលេសទាំងនោះ ភិក្ខុដែលជាខីណាស្រព បានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យកើតតទៅទៀត ដូច

ដើមត្នោតដែលគេក្របែលមិនឲ្យដុះតទៅទៀត ធ្វើមិនឲ្យមានបែបភាពតទៅទៀត ជាធម៌មិនកើតតទៅទៀត ។ ម្នាលអាវុសោ បណ្ដាអប្បមាណចេតោវិមុត្តិទាំងប៉ុន្មាន មានអកុប្បចេតោវិមុត្តិ ប្រសើរជាងវិមុត្តិទាំងនោះ ព្រោះអកុប្បចេតោវិមុត្តិនោះ សូន្យរាគៈ សូន្យទោសៈ សូន្យមោហៈ ។ ម្នាលអាវុសោ រាគៈជាគ្រឿងកង្វល់ ទោសៈជាគ្រឿងកង្វល់ មោហៈក៏ជាគ្រឿងកង្វល់ កិលេសទាំងនោះ ភិក្ខុជាខីណាស្រព បានលះបង់ហើយ បានផ្ដាច់ផ្ដិលឫសគល់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង ដូចដើមត្នោតដែលគេកាប់ក្របែល ធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅទៀតហើយ ។ ម្នាលអាវុសោ អាកិញ្ចញ្ញចេតោវិមុត្តិទាំងប៉ុន្មាន មានអកុប្បចេតោវិមុត្តិប្រសើរជាងវិមុត្តិទាំងនោះ ព្រោះអកុប្បចេតោវិមុត្តិនោះ សូន្យរាគៈ សូន្យទោសៈ សូន្យមោហៈ ។ ម្នាលអាវុសោ រាគៈជាកិលេសធ្វើនិមិត្ត ទោសៈជាកិលេសធ្វើនិមិត្ត មោហៈជាកិលេសធ្វើនិមិត្ត ពួកកិលេសធ្វើនិមិត្តទាំងនោះ ភិក្ខុជាព្រះខីណាស្រព បានលះបង់ហើយ បានផ្ដាច់ផ្ដិលឫសគល់ហើយ ធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង ដូចដើមត្នោតដែលគេក្របែលចោលហើយ ធ្វើឲ្យលែងមានបែបភាពតទៅទៀត ជាធម៌លែងមានកំណើតតទៅទៀតហើយ ។ ម្នាលអាវុសោ និមិត្តចេតោវិមុត្តិទាំងប៉ុន្មាន មានអកុប្បចេតោវិមុត្តិ ប្រសើរជាងវិមុត្តិទាំងនោះ ព្រោះអកុប្បចេតោវិមុត្តិនោះ សូន្យរាគៈ សូន្យទោសៈ សូន្យមោហៈ ។ ម្នាលអាវុសោ នេះឯងជាបរិយាយដែលធម៌ទាំងនេះអាស្រ័យហើយ មានសេចក្ដី

ដូចគ្នា តែមានព្យញ្ជនៈផ្សេងគ្នា ។ លុះព្រះសារីបុត្រមានអាយុ បានពោល ពាក្យនេះហើយ ព្រះមហាកោដ្ឋិតត្ថេរមានអាយុ ក៏មានចិត្តរីករាយត្រេកអរ ហើយ ចំពោះភាសិតរបស់ព្រះសារីបុត្រ មានអាយុ ។

## មហាវេទល្លសូត្រទី ៣ ចប់

# អដ្ឋកថា

## មហាវេទល្លសូត្រទី ៣

[ ១៣៣ ] មហាវេទល្លសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អាយស្មា** នេះ ជាពាក្យសម្តែងការគោរព និងកោតក្រែង ។ បទថា **មហាកោដ្ឋិតោ** ជាឈ្មោះរបស់ព្រះថេរៈនោះ ។ បទថា **បដិសល្លានា វុដ្ឋិតោ** គឺចេញចាកផលសមាបត្តិ ។

[ ១៣៤ ] ក្នុងបទថា **ទុប្បញ្ញោ** នេះ គឺដែលឈ្មោះថា បញ្ញាអាក្រក់ មិនសំដៅយកមិនមានបញ្ញា គឺឥតបញ្ញាទេ ។ បទថា **កិត្តាវតា នុ ខោ** គឺពាក្យសួរកំណត់ហេតុ ដោយសេចក្តីថា ហៅយ៉ាងនោះ ដោយហេតុប៉ុន្មានហ្ន៎ ឈ្មោះថា ការសួរនេះមាន ៥ យ៉ាង គឺសួរដើម្បីបញ្ជាក់វត្ថុដែលមិនទាន់ឃើញ ១ សួរដើម្បីប្រៀបធៀបវត្ថុដែលឃើញហើយ ១ សួរដើម្បីកាត់សេចក្តីសង្ស័យ ១ សួរដើម្បីបញ្ជាក់ឲ្យយល់ គឺឲ្យព្រមទទួល ឲ្យអនុមតិ ១ សួរដើម្បីត្រូវការសម្តែង គឺសួរឯង ឆ្លើយឯង ១ ។ តទៅនេះ ជាហេតុធ្វើឲ្យការសួរទាំងនោះប្លែកផ្សេងគ្នាចេញទៅ ។ ការសួរធ្វើឲ្យភ្លឺនូវវត្ថុដែលមិនទាន់ឃើញ តើដូចម្តេច ដោយប្រក្រតីបុគ្គលដែលមិនទាន់យល់ មិនទាន់ឃើញ មិនទាន់ថ្លឹងថ្លែង មិនទាន់ត្រិះរិះ មិនទាន់ជាក់ច្បាស់ មិនទាន់អប់រំលក្ខណៈ ក៏សួរបញ្ហាដើម្បីយល់ ដើម្បីឃើញ ដើម្បីថ្លឹងថ្លែង ដើម្បីត្រិះរិះ ដើម្បីឲ្យជាក់ច្បាស់ ដើម្បីអប់រំលក្ខណៈនោះ គឺសួរដើម្បីធ្វើឲ្យភ្លឺដល់វត្ថុដែលមិនទាន់ឃើញ ។

ការសួរដើម្បីប្រៀបធៀបវត្ថុដែលឃើញហើយ តើដូចម្តេច ។ ដោយ

ប្រក្រតី បុគ្គលដែលយល់ បានឃើញ បានថ្លឹងថ្លែង បានពិចារណា បានជ្រាប បានជាក់ច្បាស់ បានអប់រំលក្ខណៈទុកហើយ ក៏សួរបញ្ហាដើម្បីផ្ទៀងផ្ទាត់ ជាមួយពួកអ្នកប្រាជ្ញពួកដទៃ នេះគឺ ការសួរដើម្បីប្រៀបធៀប ។

ការសួរដើម្បីកាត់សេចក្តីសង្ស័យតើដូចម្តេច ។ ដោយប្រក្រតី បុគ្គលដែលស្ទុះទៅក្នុងសេចក្តីសង្ស័យ ស្ទុះទៅក្នុងភាពស្ទាក់ស្ទើរ កើតការគិត ២ យ៉ាង ក្នុងចិត្តថា យ៉ាងនេះ ឬមិនមែនហ្ន៎ យ៉ាងណាអើចេះហ្ន៎ ក៏សួរបញ្ហាដើម្បីកាត់សេចក្តីសង្ស័យ នេះគឺ សួរដើម្បីកាត់សេចក្តីសង្ស័យ ។

ឯការកាន់យកសេចក្តី រមែងដឹងហើយសួរ ក្នុងវេលាសម្តែងធម៌យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកយល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ដូច្នេះជាដើម ឈ្មោះថា សួរដើម្បីបញ្ជាក់ការយល់ ។

ការសួររបស់ព្រះមានព្រះភាគ ដែលទ្រង់សួរភិក្ខុសង្ឃ ដោយព្រះអង្គឯងពិត ហើយទ្រង់ឆ្លើយដោយព្រះអង្គឯង យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានមាន ៤ យ៉ាង ៤ យ៉ាង តើដូចម្តេច ដូច្នេះជាដើម ឈ្មោះថា ការសួរដើម្បីឆ្លើយ ។ ក្នុងការសួរ ៥ យ៉ាងនោះ ក្នុងទីនេះ បំណងយកការសួរដើម្បីប្រៀបធៀបវត្ថុដែលឃើញហើយ ។

ពិតហើយ ព្រះថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃរបស់ខ្លួនហើយ តាំងបញ្ហាឡើងឯង កាលនឹងសម្រេចខ្លួនឯង ក៏ធ្វើសូត្រនេះ តាំងអំពីផ្តើមឲ្យចប់បាន ឯបុគ្គលខ្លះ អាចតាំងប្រស្នាឡើងបាន តែកាត់សម្រេចមិនបាន បុគ្គល

ខ្លះកាត់សម្រេចបាន តែតាំងប្រស្នាឡើងមិនបាន បុគ្គលខ្លះមិនបានទាំង ២ យ៉ាង បុគ្គលខ្លះក៏បានទាំង ២ យ៉ាង ក្នុងបុគ្គលទាំងនោះ ព្រះថេរៈបានទាំង ២ យ៉ាងនោះឯង ព្រោះហេតុអ្វី ព្រោះមានបញ្ញាច្រើន ព្រោះអាស្រ័យបញ្ញាច្រើន ទើបមានព្រះថេរៈច្រើនរូបដែលសម្រេចឋានៈពិសេសក្នុងសាសនានេះ គឺព្រះសារីបុត្រ ព្រះមហាកច្ចានៈ ព្រះបុណ្ណៈ ព្រះកុមារកស្សប ព្រះអានន្ទត្ថេរ និងព្រះថេរៈអង្គនេះឯង ។

ពិតហើយ ភិក្ខុដែលមានបញ្ញាតិច អាចដល់ទីបំផុតសាវកបារមីញាណមិនបាន តែបុគ្គលអ្នកមានបញ្ញាច្រើនអាចដល់បាន ព្រោះការមានបញ្ញាច្រើនដូចពោលមកនេះ ទើបព្រះសារីបុត្របានសម្រេចតំណែងនោះ បុគ្គលមានបញ្ញាដូចព្រះថេរៈមិនមានឡើយ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់តាំងលោកទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រសើរជាងពួកភិក្ខុដែលមានបញ្ញាច្រើន ដែលជាសាវករបស់តថាគតនោះ គឺ សារីបុត្រ ។

ភិក្ខុដែលមានបញ្ញាតិចក៏បែបនោះ មិនអាចសង្គ្រោះយកមកប្រៀបធៀបនឹងសព្វញ្ញុតញ្ញាណ ហើយចែកអត្ថនៃព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ទុកដោយសង្ខេបឲ្យពិស្តារបានឡើយ តែបុគ្គលមានបញ្ញាច្រើនអាចធ្វើបាន ព្រោះភាពជាអ្នកមានបញ្ញាច្រើន ដូចដែលពោលមកនេះ ទើបព្រះមហាកច្ចាយនៈ ជាអ្នកអាចក្នុងរឿងនោះ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគ តាំងលោកទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែល

ជាកំពូលលើសពួកភិក្ខុដែលចែកអត្ថ នៃពាក្យដែលតថាគតពោលដោយសង្ខេប ឲ្យពិស្តារបាន ដែលជាសាវករបស់តថាគតនោះ គឺ មហាកច្ចាយនត្ថេរ ។

ភិក្ខុដែលមានបញ្ញាតិចក៏បែបនោះ នឹងពោលធម្មកថាប្រារព្ធរឿង ដែលគប្បីពោល ១០ ប្រការ ហើយចែកវិសុទ្ធិ ៧ ប្រការ មិនអាចពោលធម្មកថាបាន តែអ្នកមានបញ្ញាច្រើនធ្វើបាន ព្រោះជាអ្នកមានបញ្ញាច្រើនដូចពោលមកនេះ ទើបព្រះបុណ្ណត្ថេរសម្តែងលីលាដូចព្រះចន្ទពេញវង់ អង្គុយចាប់ផ្ចិតដ៏វិចិត្រលើអាសនៈ សម្តែងធម៌ដែលតាក់តែងហើយ ពោលធម្មកថាកណ្តាលបរិស័ទ ៤ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគទ្រង់តាំងលោកទុកដោយតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រសើរជាងពួកភិក្ខុ ជាអ្នកសម្តែងធម៌ដែលជាសាវករបស់តថាគតនោះ គឺ បុណ្ណៈ កូនប្រុសមន្តានីព្រាហ្មណី ។

ភិក្ខុដែលមានបញ្ញាតិចក៏បែបនោះ កាលពោលធម្មកថា ក៏ប្រព្រឹត្តទៅរតាក់រតុប ដូចមនុស្សខ្វាក់ កាន់ឈើច្រត់ដើរទើមៗ និងដូចមនុស្សស្ទួស្តានឈើដែលដើរទៅបានត្រឹមម្នាក់ ។ តែបុគ្គលមានបញ្ញាច្រើន លើកយកតែគាថា ៤ បាទ មកតាំងហើយ ទាញយកគោលប្រៀបធៀប និងហេតុផលមកបន្ថែមបន្ថែម ធ្វើឲ្យព្រះត្រៃបិដក ដែលជាព្រះពុទ្ធតម្រាស់មានទាំងបែបទាប និងបែបខ្ពស់សម្តែង ។ ព្រោះភាពជាអ្នកមានបញ្ញាច្រើន ទើបព្រះកុមារកស្សបលើកយកគាថា ត្រឹមតែ ៤ បាទមកតាំង ហើយនាំយកគោលប្រៀបធៀប និងហេតុផលមកប្រកបចូលជាមួយបទទាំងនោះ ធ្វើឲ្យព្រះត្រៃ

បិដកដែលជាព្រះពុទ្ធតម្រាស់ មានទាំងបែបទាប និងបែបខ្ពស់ ហើយសម្តែងដូចធ្វើផ្កាដែលមានពណ៌ ៥ រីកនៅក្នុងស្រះធម្មជាតិ ឬដូចអុជចង្កៀងប្រេងធ្វើប្រេះឲ្យឆេះទ្រលោមលើកំពូលភ្នំសិនេរុ ដូច្នោះ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគ ទ្រង់តាំងលោកទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុដែលជាកំពូលជាងភិក្ខុអ្នកសម្តែងធម៌ដ៏វិចិត្រ ដែលជាសាវកនៃតថាគតនោះ គឺ កុមារកស្សប ។

ភិក្ខុដែលមានបញ្ញាតិចក៏បែបនោះ សូម្បីប្រើវេលាអស់ ៤ ខែ ក៏មិនអាចរៀនគាថាត្រឹមតែ ៤ បាទបាន ។ ឯអ្នកមានបញ្ញាច្រើន ដើរតែមួយជំហានក៏រៀនបានរាប់រយរាប់ពាន់បាទ ព្រះអានន្ទត្ថេរ លោកដើរមួយជំហានទាំងដែលកំពុងលើកជើងម្ខាង ស្តាប់តែម្តងប៉ុណ្ណោះ មិនសួរដដែលទៀត ក៏ទទួលយកបាន សូម្បី ៦ ម៉ឺនបាទ និង ១៥០០០ គាថា ក្នុងខណៈមួយនោះឯង ដូចយកវល្លិមកជោតផ្កាទុក ហើយអ្វីដែលលោកបានរៀនមកហើយក៏តាំងនៅដោយអាការដែលបានទទួល ដូចស្នាមគំនូសលើថ្ម និងដូចខ្លាញ់រាជសីហ៍ដែលដាក់ក្នុងភាជនៈមាស ព្រោះហេតុដែលលោកមានបញ្ញាច្រើន ។ហេតុនោះឯង ទើបព្រះមានព្រះភាគ ទ្រង់តាំងលោកទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលជាកំពូលលើសភិក្ខុ ដែលមានគតិ ជាសាវករបស់តថាគតនោះ គឺអានន្ទ ជាអ្នកមានសតិ ជាអ្នកមានធិតិ គឺបញ្ញាជាគ្រឿងចងចាំ ជាអ្នកបានស្តាប់ច្រើន ជាឧបដ្ឋាកនោះ គឺ អានន្ទ ។

ភិក្ខុដែលមានបញ្ញាតិច មិនអាចដល់នូវកំពូលបដិសម្ភិទាទាំង ៤ បាន

ឡើយ ទាល់តែបុគ្គលជាអ្នកមានបញ្ញាច្រើន ទើបអាច ។ ព្រោះភាពជាអ្នកមានបញ្ញាច្រើន ដូចពោលមកនេះ ទើបព្រះមហាកោដ្ឋិតៈ ដល់នូវបញ្ញាដែលជាបដិសម្ភិទា ដែលក្រាស់ទៅដោយអនន្តន័យ ដោយអំណាចការប្រកបទុកក្នុងខាងដើម ដោយការសម្រេចការសាកសួរ និងការស្តាប់ ។ ហេតុនោះឯង ទើបព្រះមានព្រះភាគតាំងលោកទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ តំណែងដ៏កំពូលនៃពួកភិក្ខុដែលសម្រេចបញ្ញាបែកធ្លាយ ដែលជាសាវករបស់តថាគតនោះ គឺ មហាកោដ្ឋិតៈ ដូច្នេះ ។

ដោយភាពជាអ្នកមានបញ្ញាច្រើន ដូចពោលមកនេះ ទើបព្រះថេរៈតាំងបញ្ហាឡើងក៏បាន កាត់សម្រេចក៏បាន ទាំង ២ យ៉ាងក៏បាន ។ ខណៈដែលលោកអង្គុយក្នុងទីសម្រាកពេលថ្ងៃ លោកបានតាំងបញ្ហាគ្រប់ប្រស្នាឡើងមកហើយ លោកអាចវិនិច្ឆ័យព្រះសូត្រនេះ តាំងអំពីដើមដល់ចប់ក៏បាន តែគិតថា ធម្មទេសនានេះ មានលម្អពន់ពេក អញនឹងផ្ទៀងផ្ទាត់ជាមួយលោកមេទ័ពធម៌ដែលជាបងប្រុសច្បង បន្ទាប់អំពីនោះ ព្រះធម្មទេសនាដែលអាត្មាអញទាំងពីរនាក់ប្រើមតិតែមួយ ប្រើអធ្យាស្រ័យតែមួយ តាំងទុកនេះ នឹងក្លាយជាធម្មទេសនាដែលធ្ងន់ ប្រៀបដូចម្លប់នៃឆត្រថ្ម និងក្លាយជាធម្មទេសនាដែលមានឧបការៈច្រើន ដូចទូកដែលចតនៅត្រង់កំពង់សម្រាប់បុគ្គលដែលត្រូវការឆ្លងអន្លង់ទាំង ៤ និងដូចរថដែលទឹមដោយសេះអាជានេយ្យ ១០០០ សម្រាប់អ្នកត្រូវការទៅស្ថានសួគ៌ ។ ដូច្នេះហើយ ទើបសួរបញ្ហាដើម្បីផ្ទៀងផ្ទាត់វត្ថុដែលឃើញហើយ ។ ហេតុនោះ ក្នុងបណ្តាការសួរទាំងនោះ ក្នុងទីនេះសំដៅ

យកការសួរដើម្បីប្រៀបធៀបវត្ថុដែលឃើញហើយ ។

ក្នុងបទថា **ឆប្បជាឆាតិ** មានអត្ថថា បុគ្គលដែលត្រូវហៅថា មិនមានបញ្ញា ព្រោះមិនយល់ជាក់ច្បាស់ ។ ក្នុងទីគ្រប់អន្លើក៏មានន័យនេះ ។ បទថា **ឥធំ ឧក្ខន្តិ ឆប្បជាឆាតិ** គឺមិនយល់ជាក់ច្បាស់តាមសេចក្ដីពិត ទាក់ទងនឹងទុក្ខថា នេះជាទុក្ខ ទុក្ខមានប្រមាណប៉ុណ្ណេះ មិនមានទុក្ខដទៃក្រៅអំពីនេះ ដោយលក្ខណៈ កិច្ចតាមសេចក្ដីពិត ។ បទថា **អយំ ឧក្ខសមុឧយោ** គឺមិនយល់ជាក់ច្បាស់ដោយលក្ខណៈ ព្រមទាំងកិច្ចតាមការពិតថា ការប្រាថ្នាជាហេតុធ្វើឲ្យកើតមានទុក្ខ ដែលប្រព្រឹត្តទៅថា ទុក្ខរមែងកើតមកអំពីការប្រាថ្នានេះ ជាសេចក្ដីពិតទាក់ទងនឹងហេតុកើតឡើង ។ បទថា **អយំ ឧក្ខ-ណិរោធោ** គឺមិនដឹងច្បាស់ដោយលក្ខណៈ កិច្ចតាមការពិតថា សេចក្ដីពិតទាក់ទងនឹងការរលត់ដោយមិនមានសេសសល់ គឺការរលត់ទុក្ខ និងហេតុកើតឡើងនៃទុក្ខទាំង ២ ប្រព្រឹត្តទៅថា នេះទុក្ខ នេះហេតុធ្វើឲ្យកើតទុក្ខ កាលដល់តំណែងនេះហើយ រមែងរលត់ទៅ ដោយមិនមានសេសសល់ ។ បទថា **អយំ ឧក្ខណិរោធគាមិនី បដិបទា** គឺមិនដឹងជាក់ច្បាស់តាមការពិត ដែលទាក់ទងនឹងផ្លូវថា បដិបទានេះ រមែងទៅដល់ការរលត់ទុក្ខដោយមិនមានសេសសល់បាន ដោយលក្ខណៈ ព្រមទាំងកិច្ចតាមការពិត ។ សូម្បីក្នុងអនន្តរវារៈ គឺវារៈនៃអនន្តរប្បច្ច័យ ក៏គប្បីជ្រាបអត្ថដោយន័យនេះ សម្រាប់ក្នុងទីនេះ គប្បីជ្រាបថា លោកពោលដល់បុគ្គលដែលធ្វើកម្មដ្ឋាន ប្រកាន់យកសេចក្ដីពិត ៤ យ៉ាង មកជាអារម្មណ៍ដោយសង្ខេប ។

ពិតហើយ បុគ្គលនេះរៀនសច្ចៈ ៤ ប្រការ ក្នុងសម្នាក់អាចារ្យ ដោយការស្តាប់ កាលរៀនស្រេចហើយ ក៏ប្រកាន់យ៉ាងនេះថា វៀរតណ្ហាចេញហើយ វត្ថុដែលទាក់ទងនឹងភូមិ ៣ ឈ្មោះថា ទុក្ខសច្ច ដែលឈ្មោះថា ទុក្ខសមុទយសច្ច គឺតណ្ហា ការរលត់ គឺការមិនប្រព្រឹត្តទៅនៃទុក្ខ និងហេតុកើតឡើងនៃទុក្ខ ឈ្មោះថា និរោធសច្ច ។ កាលកំណត់ដឹង ទុក្ខសច្ច និងសមុទយសច្ច ក៏នាំឲ្យសម្រេចទុក្ខនិរោធគាមិនីបដិបទា ឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទា ក្នុងសច្ចៈទាំង ៤ ប្រការនោះ សច្ចៈ ២ ដំបូងជាវដ្តៈ ២ ប្រការ ខាងក្រោយជាវិវដ្តៈ ការប្រកាន់មាំក្នុងវដ្តៈក៏មាន មិនមែនការប្រកាន់មាំក្នុងវដ្តៈក៏មាន ។ ដូច្នោះ កាលប្រកាន់មាំ ក៏ឈ្មោះថា ប្រកាន់មាំក្នុងទុក្ខសច្ច ដោយប្រការដូច្នេះ ។ ដែលឈ្មោះថា ទុក្ខសច្ច គឺខន្ធ ៥ មានរូបជាដើម ។ កាលកំណត់ខន្ធ ៥ នោះ ក៏ឈោងចុះដោយអំណាចកម្មដ្ឋានដែលមានធាតុ ៤ ជាអារម្មណ៍ហើយ ទើបកំណត់មហាភូតរូប ៤ និងឧបាទាយរូបថា រូប ។ កាលកំណត់យ៉ាងនេះថា វេទនា សញ្ញា សង្ខារ វិញ្ញាណដែលមានធាតុ ៤ នោះ ជាអារម្មណ៍ ជានាម ទើបឈ្មោះថា កំណត់ថា វត្ថុ ២ នេះឯង គឺនាម និងរូប ដូចគ្នានឹងគូនៃគ្រាប់ត្នោត កាលបានកំណត់បច្ច័យនិងវត្ថុដែលដែលកើតឡើងព្រោះបច្ច័យថា វត្ថុនេះមិនមែនមិនមានហេតុ វាមានហេតុ មានបច្ច័យ អ្វីជាបច្ច័យ វត្ថុទាំងឡាយ មានអវិជ្ជាជាដើម ជាបច្ច័យយ៉ាងនេះហើយ ក៏លើកឡើងកាន់អនិច្ចលក្ខណៈថា វត្ថុទាំងអស់នេះជារបស់មិនទៀង ព្រោះអត្ថថា មិនមាន ។ បន្ទាប់អំពីនោះ ក៏លើកឡើងកាន់

លក្ខណៈ ៣ យ៉ាងថា ជាទុក្ខ ព្រោះអាការកើតឡើង សូន្យទៅ និងបៀតបៀន ។ ថាជា អនត្តា ព្រោះអាការមិនប្រព្រឹត្តទៅក្នុងអំណាច ហើយពិចារណាតាមលំដាប់វិបស្សនា ក៏រមែងសម្រេចលោកុត្តរបាន ក្នុងខណៈនៃផ្លូវ គឺ មគ្គក្ខណៈ ក៏រមែងចាក់ធ្លុះសច្ចៈទាំង ៤ ប្រការ ដោយការចាក់ធ្លុះត្រឹមតែម្តង ។ រមែងត្រាស់ដឹងដោយការត្រាស់ដឹងត្រឹមតែម្តង រមែងចាក់ធ្លុះនូវទុក្ខ ដោយអំណាចការកំណត់ដឹង រមែងចាក់ធ្លុះនូវសមុទយៈ ដោយការចាក់ធ្លុះ គឺ ការលះ រមែងចាក់ធ្លុះនូវនិរោធដោយការធ្វើឲ្យជាក់ច្បាស់ រមែងចាក់ធ្លុះនូវមគ្គដោយការនា ។ រមែងត្រាស់ដឹងទុក្ខដោយការកំណត់ដឹង រមែងត្រាស់ដឹងសមុទយៈដោយការលះ រមែងត្រាស់ដឹងនូវនិរោធដោយធ្វើឲ្យជាក់ច្បាស់ រមែងត្រាស់ដឹងនូវទុក្ខនិរោធគាមិនីបដិបទា ដោយការនា ។ បុគ្គលនោះចាក់ធ្លុះនូវសេចក្តីពិតទាំង ៣ យ៉ាង ដោយកិច្ច ចាក់ធ្លុះនូវនិរោធ ដោយអារម្មណ៍ ។ ឯក្នុងខណៈនៃផលរបស់បុគ្គលនោះ មិនត្រូវមានការចងចិត្ត ការបង្រួបបង្រួមចិត្ត ការយកចិត្តទុកដាក់ និងការពិចារណាថា អញកំណត់ដឹងទុក្ខ កំពុងលះហេតុឲ្យកើតទុក្ខ កំពុងធ្វើឲ្យជាក់ច្បាស់ ដោយមិនសេសសល់ កំពុងអប់រំចម្រើនមគ្គ ។ តែសម្រាប់បុគ្គលដែលកំពុងកំណត់កាន់យកនោះ ផ្លូវរបស់បុគ្គលដែលកំពុងកំណត់នោះឯង ធ្វើកិច្ច មានការកំណត់ដឹងជាដើម ក្នុងសេចក្តីពិត ៣ ប្រការ ឲ្យសម្រេចនោះឯង ចាក់ធ្លុះនូវនិរោធដោយអារម្មណ៍ ។

ក្នុងបទថា **តស្មា បញ្ញាវាតិ វុច្ចតិ** នេះ ដោយទាប ព្រះសោតាបន្ន

ដោយខ្ពស់ ព្រះទីណាស្រេព លោកសម្ដែងថា ជាអ្នកមានបញ្ញា ឯបុគ្គលដែលរៀនពាក្យរបស់ព្រះពុទ្ធចប់បិដកទាំង ៣ ដោយបាលីក្ដី ដោយអដ្ឋកថាក្ដី ដោយអនុសន្ធិក្ដី ដោយមុនក្រោយក្ដី ហើយត្រាច់ធ្វើឲ្យជាជាន់ទាប និងជាន់ខ្ពស់ តែមិនមានសូម្បីតែការកំណត់យក ដោយអនិច្ចំ ទុក្ខំ និងអនត្តាទេនោះ មិនបានឈ្មោះថា ជាអ្នកមានបញ្ញាឡើយ ក៏គង់បានឈ្មោះថា មិនមានបញ្ញាដដែល ពោលទៅថ្វីដល់បុគ្គលដែលកាន់យកតែការដឹងច្បាស់ គឺវិញ្ញាណចរិតនោះថា ជាអ្នកមានបញ្ញាឡើយ ។ គ្រានេះ បុគ្គលដែលបានលើកឡើងកាន់ត្រៃលក្ខណ៍ ហើយពិចារណាតាមលំដាប់វិបស្សនា គិតថា ថ្ងៃនេះ ថ្ងៃនេះឯង អរហត្តនេះ ឈ្មោះថា ជាអ្នកមានបញ្ញា មិនមែនមិនមានបញ្ញាទេ ។ បុគ្គលមានបញ្ញា កាលបុគ្គលណាឲ្យជួបក៏ជួបអ្នកមានបញ្ញាដូចគ្នា ឯក្នុងព្រះសូត្រ លោកពោលតែការចាក់ចុះប៉ុណ្ណោះ ។ ក្នុងបទថា **វិញ្ញាណំ វិញ្ញា-ណាតិ** នេះ ព្រះមហាកោដ្ឋិតៈសួរដល់អ្វី បុគ្គលដែលយកការដឹងច្បាស់ឯណាមកពិចារណាសង្ខារនោះ ក៏ជាអ្នកមានបញ្ញា ទើបព្រះមហាកោដ្ឋិតៈសួរថា ខ្ញុំសូមសួរវិបស្សនាដែលត្រូវមក ការដឹងច្បាស់ និងចិត្ត ដែលធ្វើការរបស់ការពិចារណាសង្ខារនោះជាមួយលោកម្ចាស់ ។ ពាក្យថា **សុខន្តិបិ ជានាតិ** គឺរមែងដឹងច្បាស់នូវសុខវេទនាខ្លះ ។ សូម្បី ២ បទខាងលើ ក៏ទំនងដូចគ្នានោះឯង ។ ដោយបទថា រមែងដឹងច្បាស់នូវសុខវេទនាខ្លះ នេះសម្ដែងដល់កម្មដ្ឋានដែលមិនបានប្រើរូបជាអារម្មណ៍ ដោយអំណាចការសោយ ដែលមកដោយន័យជាដើមថា កាលអាត្មាអញសោយនូវវេទនាជាសុខ ក៏ដឹងច្បាស់ថា

សោយនូវវេទនាជាសុខ គួរជ្រាបអត្ថនៃបទនោះតាមន័យដែលពោលទុកក្នុងសតិប្បដ្ឋានសូត្រនោះឯង ។

បទថា **សំសដ្ឋា** គឺព្រះថេរៈរមែងសួរថា ដែលឈ្មោះថា លាយឡំគ្នា ព្រោះអត្ថថា ប្រកបព្រមដោយលក្ខណៈ មានការកើតឡើងព្រមគ្នាជាដើម ឬបែកចេញអំពីគ្នា សម្រាប់សេចក្តីនេះ មិនគប្បីយល់ថា ព្រះថេរៈយកធម៌ដែលជាលោកិយ និងលោកុត្តរទាំង ២ គឺបញ្ញាក្នុងមគ្គ និងបញ្ញាក្នុងវិបស្សនាទាំងនេះមកប្របល់គ្នា ហើយទម្លាយនូវចន្លោះ ហើយសួរបែបបុគ្គលដែលមិនស្គាល់សម័យ តែគប្បីជ្រាបថា លោកសួរដល់ការលាយគ្នា ព្រមគ្នានឹងការដឹងច្បាស់នូវមគ្គ ក្នុងការដឹងច្បាស់មគ្គ និងការដឹងច្បាស់នូវវិបស្សនា ក្នុងការដឹងច្បាស់វិបស្សនាប៉ុណ្ណោះ ព្រះថេរៈកាលនឹងឆ្លើយអត្ថដល់ព្រះមហាកោដ្ឋិតៈក៏ពោលពាក្យជាដើមថា វត្ថុទាំងនេះលាយឡំគ្នា ។ បទថា **ន ច លព្ភា ឥមេសំ ធម្មានំ** បុគ្គលមិនគប្បីបានវត្ថុទាំងនេះ គឺនៃវត្ថុ ២ យ៉ាង ដែលកើតឡើងព្រមគ្នា ទាំងក្នុងខណៈលោកិយមគ្គ ទាំងក្នុងខណៈលោកុត្តរមគ្គទាំងនេះ ។ បទថា **វិនិព្ភុជិត្វា វិនិព្ភុជិត្វា** ដោយអត្ថថា មិនមានបុគ្គលណាអាចដើម្បីចែកជាផ្នែក ជាស្រទាប់ សម្តែងឲ្យឃើញដល់ការផ្សេងគ្នា ដោយអារម្មណ៍ ដោយទីតាំង ដោយការកើតឡើង ឬដោយការរលត់បានឡើយ ។

ធម្មតាអារម្មណ៍នៃវត្ថុនោះៗ មាន ។ ពិតហើយ កាលសម្រេចវត្ថុដែលជាលោកិយ ចិត្តរមែងជាធំ ជាប្រធាន កាលសម្រេចលោកុត្តរ បញ្ញារមែងជាធំ ជាប្រធាន ។ ពិតហើយ សូម្បីព្រះសម្មាសម្ពុទ្ធ កាលត្រាស់សួរដល់

វត្ថុដែលជាលោកិយ ក៏មិនត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុ អ្នកសម្រេចបញ្ញាប្រភេទណា ជាបញ្ញាក្នុងមគ្គខាងដើម ឬជាបញ្ញាក្នុងមគ្គទី ២-៣ និងទី ៤ តែត្រាស់សួរដោយអំណាចចិត្តថា ម្នាលភិក្ខុ អ្នកមានចិត្តអ្វី និងមិនត្រាស់សួរថា ម្នាលភិក្ខុ អ្នកមានផស្សៈដូចម្តេច មានវេទនាដូចម្តេច មានសញ្ញាដូចម្តេច មានចេតនាដូចម្តេច កាលទ្រង់បញ្ញត្តកុសល និងអកុសល ក៏ទ្រង់បញ្ញត្តដោយអំណាចចិត្តយ៉ាងនេះថា ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចដោយចិត្ត និងបញ្ញត្តថា ធម៌ដែលជាកុសលដូចម្តេច ក្នុងសម័យណា ចិត្តជាកុសលដែលត្រាច់ទៅក្នុងកាមាវចរ រមែងជារបស់កើតឡើងហើយ តែកាលទ្រង់សួរដល់លោកុត្តរ ទ្រង់មិនសួរថា ម្នាលភិក្ខុ អ្នកមានធម៌ដែលមានកិច្ចប៉ះខ្ទប់ដូចម្តេច មានការសោយអារម្មណ៍ដូចម្តេច មានការចាំដូចម្តេច មានការតាក់តែងចិត្តដូចម្តេច ។ ទ្រង់សួរដោយអំណាចបញ្ញាយ៉ាងនេះថា ម្នាលភិក្ខុ បញ្ញាដែលអ្នកសម្រេចហើយដូចម្តេច ជាបញ្ញាក្នុងមគ្គខាងដើម ឬជា បញ្ញាក្នុងមគ្គទី ២-៣ និងទី ៤ ។ ក្នុងឥន្ទ្រិយសំយុត្ត ក៏ត្រាស់តែលោកិយធម៌ និងលោកុត្តរធម៌ក្នុងអារម្មណ៍ប៉ុណ្ណោះ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ប្រការ ឥន្ទ្រិយ ៥ ប្រការ ដូចម្តេចខ្លះ គឺសទ្ធិន្ទ្រិយ ១ ។បេ។ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសទ្ធិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងទីដូចម្តេច បណ្តាឥន្ទ្រិយទាំង ៥ នោះ សទ្ធិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះវីរិយិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងទីដូចម្តេច បណ្តាឥន្ទ្រិយទាំងនោះ វីរិយិន្ទ្រិយ

បណ្ឌិតគប្បីឃើញក្នុងសម្មប្បធានទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះសតិន្ទ្រិយ បណ្ឌិតគប្បីឃើញក្នុងទីដូចម្ដេច បណ្ដាឥន្ទ្រិយទាំងនោះ សតិន្ទ្រិយ បណ្ឌិតគប្បីឃើញក្នុងសតិប្បដ្ឋានទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះសមាធិន្ទ្រិយ បណ្ឌិតគប្បីឃើញក្នុងទីដូចម្ដេច បណ្ដាឥន្ទ្រិយទាំងនោះ សមាធិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងឈានទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះបញ្ញិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងទីដូចម្ដេច បណ្ដាឥន្ទ្រិយទាំងនោះ បញ្ញិន្ទ្រិយបណ្ឌិតគប្បីឃើញក្នុងអរិយសច្ចទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយមាន ៥ ប្រការ ដូច្នេះឯង ។

ឧបមាដូចសម្លាញ់ ៥ នាក់ ដែលមានព្រះរាជាជាគម្រប់ ៥ គឺកូនសេដ្ឋី និងព្រះរាជាមួយអង្គ គិតថា ពួកយើងនឹងលេងនក្ខត្តឫក្ស ហើយនាំគ្នាដើរទៅតាមវិថី កាលដល់ផ្ទះរបស់កូនសេដ្ឋីម្នាក់ បួននាក់ទៀតក៏នាំគ្នាអង្គុយស្ងៀម ។ ម្ចាស់ផ្ទះប៉ុណ្ណោះ ដែលជាអ្នកខ្នះខ្នែងថា ពួកអ្នកចូរឲ្យខាទនីយៈ និងភោជ-នីយាហារ ដល់ពួកសម្លាញ់យើងនេះ ចូរឲ្យគ្រឿងក្រអូប កម្រងផ្កា និងគ្រឿងសម្អាងជាដើមដល់សម្លាញ់របស់យើង កាលទៅដល់ផ្ទះអ្នកទី ២ ... ទី ៣ ... ទី ៤ ... បុគ្គល ៤ នាក់ទៀត ក៏អង្គុយស្ងៀម ម្ចាស់ផ្ទះប៉ុណ្ណោះដែលជាអ្នកខ្នះខ្នែងថា ពួកអ្នកចូរឲ្យរបស់ទំពា របស់ស៊ីដល់សម្លាញ់យើងនេះ ចូរឲ្យគ្រឿងក្រអូប កម្រងផ្កា និងគ្រឿងសម្អាងជាដើម ដល់សម្លាញ់របស់យើងនេះ ។ ក្រោយគេបង្អស់ ក៏ទៅដល់ព្រះរាជវាំង ព្រះរាជាប៉ុណ្ណោះទ្រង់ជាធំក្នុងទីទាំងពួងក៏ពិត សូម្បីយ៉ាងនោះ ក្នុងវេននៃព្រះរាជានេះ ក៏ទ្រង់ខ្នះខ្នែង បញ្ជាថា ពួកអ្នក ចូរឲ្យរបស់ទំពា របស់ស៊ីដល់សម្លាញ់យើងនេះ ចូរឲ្យគ្រឿងក្រអូប កម្រង

ផ្កា និងគ្រឿងសម្ភារជាដើម ដល់សម្លាញ់របស់យើងនេះ ។ ដូច្នោះនោះឯង កាលឥន្ទ្រិយ មានបញ្ញិន្ទ្រិយជាគម្រប់ ៥ កំពុងកើតឡើងក្នុងអារម្មណ៍តែមួយ ដូចសម្លាញ់ទាំងនោះ ចុះកាន់វិថីតែមួយក្នុងផ្ទះដំបូង ៤ នាក់ទៀតអង្គុយស្ងៀម ម្ចាស់ផ្ទះប៉ុណ្ណោះ ជាអ្នកចាត់ចែងការ យ៉ាងណា ឥន្ទ្រិយទាំងនេះក៏ដូចគ្នា កាលអង្គសម្រាប់ដល់នូវក្រសែ គឺសោតៈ សទ្ធិន្ទ្រិយដែលមានលក្ខណៈកាត់សម្រេចអារម្មណ៍ប៉ុណ្ណោះ រមែងជាធំ ជាប្រធាន ឥន្ទ្រិយដ៏សេសក៏ស្របទៅតាមសទ្ធិន្ទ្រិយនោះ ។ កាលដល់សម្មប្បធាន វិរិយិន្ទ្រិយដែលមានការផ្គងជាលក្ខណៈប៉ុណ្ណោះ ជាធំ ជាប្រធាន ឥន្ទ្រិយដ៏សេសក៏អនុលោមតាមវិរិយិន្ទ្រិយនោះ ដូចក្នុងផ្ទះរបស់បុគ្គលទី ២ ឯ ៤ នាក់ទៀតក្រៅពីនេះ ក៏អង្គុយស្ងៀមទុកឲ្យម្ចាស់ផ្ទះប៉ុណ្ណោះជាអ្នកចាត់ការ ដូច្នោះ ។

កាលដល់គោលដែលគួរឭក សតិន្ទ្រិយដែលមានការប្រាកដជាលក្ខណៈប៉ុណ្ណោះជាធំ ជាប្រធាន ឥន្ទ្រិយដ៏សេសក៏ស្របទៅតាមសតិន្ទ្រិយនោះ ដូចក្នុងផ្ទះរបស់បុគ្គលទី ៣ បួននាក់ទៀតអង្គុយស្ងៀម ទុកឲ្យម្ចាស់ផ្ទះប៉ុណ្ណោះជាធុរៈក្នុងការចាត់ចែងការងារនោះ ។

កាលដល់វេនៃការរួបផុត ដោយអំណាចឈាន សមាធិន្ទ្រិយដែលមានការមិនរាយមាយជាលក្ខណៈប៉ុណ្ណោះជាធំ ជាប្រធាន ឥន្ទ្រិយដ៏សេសក៏ស្របទៅតាមសមាធិន្ទ្រិយនោះ ដូចក្នុងផ្ទះរបស់បុគ្គលទី ៤ ឯ ៤ នាក់ទៀតអង្គុយស្ងៀម ទុកឲ្យម្ចាស់ផ្ទះប៉ុណ្ណោះ ជាធុរៈក្នុងការចាត់ចែងការងារនោះ ។

កាលមកដល់អរិយសច្ច បញ្ញិន្ទ្រិយ ដែលមានការដឹងច្បាស់ជាលក្ខណៈ

ប៉ុណ្ណោះជាធំ ជាប្រធាន ឥន្ទ្រិយដ៏សេសក៏ស្របទៅតាមបញ្ញិន្ទ្រិយនោះ ដូចកាលទៅដល់ព្រះរាជវាំង ដែលជាវេនក្រោយគេ ៤ នាក់ទៀតក៏អង្គុយស្មៀមព្រះរាជាប៉ុណ្ណោះ ទ្រង់ជាអ្នកចាត់ចែងការងារក្នុងព្រះរាជវាំង ដូច្នេះ ។

ព្រះមហាកោដ្ឋិតត្ថេរ ជាអ្នកបានទទួលតំណែងឯតទគ្គៈនៃភិក្ខុជាសាវ័ក ជាអ្នកបាននូវបដិសម្ភិទា កាលនឹងសួររឿងដែលជាលោកិយ ក៏ធ្វើចិត្តឲ្យជាធំ ជាប្រធាន ហើយទើបសួរ កាលសួរដល់រឿងដែលជាលោកុត្តរ ក៏លើកយកបញ្ញាជាធំ ជាប្រធាន ហើយទើបសួរ ។ ឯព្រះសារីបុត្រដែលជាធម្មសេនាបតី ក៏ឆ្លើយយ៉ាងនោះដូចគ្នា ដោយប្រការដូច្នេះឯង ។

បទថា **យញ្ចាវុសោ បជានាតិ** គឺមគ្គប្បញ្ញារមែងដឹងច្បាស់នូវអរិយសច្ច ៤ ប្រការណា ដោយទំនងជាដើមថា នេះទុក្ខ ។ បទថា **តំ វិជានាតិ** គឺមគ្គវិញ្ញាណក៏រមែងដឹងច្បាស់យ៉ាងនោះដូចគ្នា ។ បទថា **យំ វិជានាតិ** គឺវិញ្ញាណក្នុងវិបស្សនាដោយទំនងជាដើមថា ធម៌ណា មានបច្ច័យប្រជុំតាក់តែង ធម៌នោះ មិនទៀង ។ បទថា **តំ បជានាតិ** គឺវិបស្សនាបញ្ញា ក៏ដឹងច្បាស់នូវធម៌នោះយ៉ាងនោះដូចគ្នា ។ បទថា **តស្មា ឥមេ ធម្មា** គឺព្រោះហេតុនោះ ធម៌ទាំងនេះ ។ បទថា **សំសដ្ឋា** គឺលាយឡំគ្នា ព្រោះកើតព្រមគ្នា រលត់ព្រមគ្នា មានវត្ថុដូចគ្នា និងមានអារម្មណ៍ជាមួយគ្នា ។ បទថា **បញ្ញា ភាវេតព្វា** នេះ លោកសំដៅយកមគ្គប្បញ្ញា ឯវិញ្ញាណដែលប្រកបព្រមដោយការដឹងច្បាស់នោះ ក៏ត្រូវចម្រើនឲ្យព្រមគ្នានឹងការដឹងច្បាស់នោះដែរ ។ បទថា **វិញ្ញាណំ បរិញ្ញេយ្យំ** នេះ លោកពោលសំដៅយកវិបស្សនាវិញ្ញាណ ឯ

បញ្ញាដែលប្រកបនឹងការដឹងច្បាស់ក្នុងវិបស្សនា ក៏គប្បីកំណត់ទៅព្រមជាមួយនឹងការដឹងច្បាស់នោះផង ។ ហេតុអ្វី ទើបលោកសួរថា វេទនា វេទនាកាលបើដូច្នេះ ក៏ត្រូវកំណត់ថា លោកសំដៅយកតែវេទនាដែលសម្រាប់ប្រើក្នុងការត្រិះរិះពិចារណា ប្រព្រឹត្តទៅក្នុងភូមិ ៣ ប៉ុណ្ណោះ ។

[ ១៣៥ ] បទថា **សុខម្បិ វេទេតិ** គឺរមែងតាមសោយអារម្មណ៍ ដែលជាសុខ ។ ទំនងដូចគ្នានេះឯង រមែងប្រើបានក្នុងពីរបទខាងមុខផងដែរ ។

ពិតហើយ លោកពោលដល់អារម្មណ៍ដែលជាសុខ និងអទុក្ខមសុខ ក្នុងទីនេះ តាមមហាលិសូត្រថា ម្នាលមហាលិ រូបនេះ មានទុក្ខតែម្យ៉ាង មានទុក្ខជាប់តាម មានទុក្ខគ្របសង្កត់ មិនទាន់មានសេចក្ដីសុខ មកគ្របដណ្ដប់នៅឡើយ ជារូបដែលពួកសត្វមិនគួរត្រេកអរទេ ។ ម្នាលមហាលិ តែរូបនេះជាសុខ មានសុខជាប់តាម មានសុខគ្របដណ្ដប់ មិនទាន់មានទុក្ខគ្របសង្កត់នៅឡើយ ព្រោះហេតុណា ព្រោះហេតុនោះ ពួកសត្វរមែងត្រេកអរក្នុងរូប ព្រោះតែមានសេចក្ដីត្រេកអរ បានជាជាប់ជំពាក់ ព្រោះមានការជាប់ជំពាក់បានជាសៅហ្មង ។ ម្នាលមហាលិ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយសៅហ្មង ។ ម្នាលមហាលិ វេទនានេះ ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ ម្នាលមហាលិ វិញ្ញាណនេះ ។បេ។ ម្នាលមហាលិ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យសត្វទាំងឡាយសៅហ្មង ដូច្នេះ ។

ម្យ៉ាងទៀត គួរជ្រាបអត្ថក្នុងរឿងវេទនានេះ យ៉ាងនេះថា សុខវេទនា

មួយទៀត ក៏រមែងធ្វើសុខវេទនាមុនឲ្យជាអារម្មណ៍ហើយ ទើបសោយ ។ ទុក្ខវេទនាក្រោយ ក៏រមែងធ្វើទុក្ខវេទនាមុនឲ្យមកជាអារម្មណ៍ ទើបសោយ ។ អទុក្ខមសុខវេទនាក្រោយ ក៏រមែងធ្វើអទុក្ខមសុខវេទនាមុន ឲ្យជាអារម្មណ៍ហើយ ទើបសោយ ។ មានពាក្យដែលលោកពោលយ៉ាងនេះថា វេទនានោះឯងរមែងសោយ មិនមានបុគ្គលណាដទៃជាអ្នកសោយឡើយ ។

ព្រះមហាកោដ្ឋិតត្ថេរសួរដល់អ្វី ក្នុងបទនេះថា **សញ្ញា សញ្ញា** ពាក្យថា លក្ខណៈនៃសញ្ញាក្តី ពាក្យថា លក្ខណៈនៃសញ្ញាក្នុងទីគ្រប់ស្ថានសព្វកាលក្តី នៃបញ្ហាថា អ្វីជាលក្ខណៈនៃសញ្ញា អ្វីជាលក្ខណៈនៃសញ្ញាក្នុងទីគ្រប់ស្ថានគ្រប់កាល នេះតែមួយដូចគ្នានោះឯង ។ កាលបើដូច្នេះ គប្បីកំណត់ថា លោកសំដៅយកតែវិចារសញ្ញា ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ប៉ុណ្ណោះ ។ បទថា **នីលកម្បិ សញ្ជានាតិ** គឺជាបរិកម្មក្នុងផ្កាពណ៌ខៀវ ឬក្នុងសំពត់ ហើយដល់ឧបចារៈ ឬអប្បនា ឈ្មោះថា សញ្ញា ក្នុងអត្ថនេះ ប្រើបានទាំងសញ្ញាក្នុងបរិកម្ម និងសញ្ញាក្នុងឧបចារៈ និងសញ្ញាក្នុងអប្បនា ដល់នូវការចាំដែលកើតឡើងក្នុងពណ៌ខៀវថា ពណ៌ខៀវ ក៏ប្រើបានដូចគ្នា ។ ក្នុងពណ៌លឿងជាដើម ក៏ទំនងនេះឯង ។ ហេតុអ្វី ទើបលោកមិនកាន់យកបញ្ញា តែកាន់យកធម៌ទាំង ៣ នេះ គឺវេទនា សញ្ញា វិញ្ញាណ ក្នុងបទទាំងនេះថា **យា ចាវុសោ វេទនា** ទៅវិញ ឆ្លើយថា ព្រោះមិនមែនជាការរួបរួមយកមកទាំងអស់ទេ ពិតហើយ កាលកាន់យកដោយបញ្ញា វេទនាជាដើម ដែលប្រកបដោយបញ្ញា ទើបមាន ដែលមិនប្រកបមិនមាន ។ តែកាលមិនកាន់យកបញ្ញានោះ កាលវត្ថុទាំងនោះ

បានទទួលការកាន់យកហើយ វេទនាជាដើម ដែលសម្បយុត្តដោយបញ្ញាក្តី មិនសម្បយុត្តក្តី ដោយហោច សុម្បីទ្វិបញ្ចវិញ្ញាណទាំង ១០ ដួង ក៏ឈ្មោះថា បានផងដែរ ។ ប្រៀបដូចបុរស ៣ នាក់ ពោលថា អំបោះៗ បុរសទី ៤ ពោលថា អំបោះកម្រងរតនៈ ក្នុងមនុស្សទាំងនោះ ៣ នាក់ដំបូង បានការដៅស្មានខ្លះ ការគិតគ្នេរជាដើមខ្លះ ហើយបានអំបោះចំនួនច្រើនណាមួយ ដោយហោច ក៏ត្រឹមតែសរសៃពីងពាង ។ ឯការស្វែងរកអំបោះកម្រងរតនៈ ក៏រមែងបានតិចតួច យ៉ាងណា គប្បីជ្រាបការប្រៀបធៀប ដូច្នោះ ។ ម្យ៉ាងទៀត អ្នកខ្លះពោលថា លោកឆ្លើយហើយ ព្រោះបានការប្រកបទៅព្រមៗ គ្នាជាមួយនឹងបញ្ញា និងវិញ្ញាណ មកអំពីខាងក្រោមហើយ ព្រោះដូច្នោះ ទើបមិនបានចាត់ចូលក្នុងទីនេះ ព្រោះលោកបានដោះស្រាយហើយ ។ បទថា **យញ្ចាវុសោ វេទេតិ** គឺវេទនា រមែងសោយអារម្មណ៍ណា សុម្បីសញ្ញាក៏រមែងចាំអារម្មណ៍នោះដូចគ្នា ។ បទថា **យំ សញ្ជានាតិ** ដោយអត្ថថា សញ្ញាចាំអារម្មណ៍ណា វិញ្ញាណក៏ដឹងច្បាស់នូវអារម្មណ៍នោះដូចគ្នា ។

គ្រានេះ គប្បីជ្រាបការផ្សេងគ្នា និងការមិនផ្សេងគ្នាក្នុងពាក្យទាំងនេះ គឺ សញ្ញា វិញ្ញាណ បញ្ញា ក្នុងពាក្យទាំង ៣ នោះ ផ្សេងគ្នាត្រឹមតែពាក្យនាំមុខប៉ុណ្ណោះ ។ ចំណែកពាក្យថា ដឹង មិនមានការផ្សេងគ្នាឡើយ ។ ក្នុងអត្ថថា ដឹងនៃបទនោះ ក៏គប្បីជ្រាបការប្លែកផ្សេងគ្នាដូច្នេះថា ពិតហើយ សញ្ញាត្រឹមតែចាំអារម្មណ៍ ដោយអំណាចពណ៌ខៀវជាដើមប៉ុណ្ណោះ មិនអាចឲ្យដល់ការចាក់ធ្លុះត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ និងអនត្តាបានឡើយ វិញ្ញាណ ដឹងច្បាស់

នូវអារម្មណ៍ ដោយអំណាចពណ៌ទៀវជាដើម និងឲ្យដល់នូវការចាក់ធ្លុះនូវលក្ខណៈ មានអនិច្ចំជាដើមក៏បាន តែឲ្យខ្វល់ខ្វាយ ហើយដល់នូវការប្រាកដរបស់មគ្គមិនបានឡើយ ។ បញ្ញារមែងចាំអារម្មណ៍ដោយអំណាចពណ៌ទៀវជាដើមក៏បាន ឲ្យដល់នូវការចាក់ធ្លុះលក្ខណៈ ដោយអំណាចការមិនទៀងជាដើមក៏បាន និងខ្វល់ខ្វាយហើយ អាចឲ្យសម្រេចការប្រាកដនៃមគ្គបានទៀតផង ។ ប្រៀបដូចយើងយកកហាបណៈ មកដាក់គរលើបន្ទះក្តាររបស់ហិរញ្ញិកបុរស កាលជន ៣ នាក់ គឺកុមារដែលមិនទាន់ដឹងក្តី អ្នកស្រុក និងហិរញ្ញិកបុរសមកឈរមើល កុមារដែលមិនទាន់ដឹងក្តី ដឹងបានត្រឹមតែការវិចិត្រ ស្អាត និងប្រភេទ ៤ ជ្រុង ឬមូលនៃកហាបណៈប៉ុណ្ណោះ មិនដឹងថារបស់នោះ គេទទួលស្គាល់ថា ជាកែវ ជាគ្រឿងឧបភោគបរិភោគរបស់មនុស្សទាំងឡាយឡើយ ។ បុរសអ្នកស្រុក រមែងដឹងដល់ការវិចិត្រជាដើមផង ដឹងដល់ភាពដែលគេទទួលស្គាល់ថាជាកែវសម្រាប់ប្រើប្រាស់ ជាគ្រឿងឧបភោគបរិភោគរបស់មនុស្សទាំងឡាយផង តែមិនដឹងថា កហាបណៈនេះក្លែងក្លាយ នេះមិនក្លែងក្លាយ នេះមិនគ្រោតគ្រាត នេះល្អិត ឯហិរញ្ញិកបុរសដឹងដល់ការវិចិត្រជាដើមផង ដឹងដល់ភាពដែលគេទទួលស្គាល់ថាជារតនៈផង ដឹងដល់ការក្លែងក្លាយ ឬសុទ្ធជាដើមផង ។ កាលកំពុងដឹង ក៏មើលរូបនោះខ្លះ ស្តាប់សំឡេងខ្លះ ហិតក្លិនខ្លះ លិទ្ធរសខ្លះ យកដៃស្ទាបពិនិត្យមើលទម្ងន់ និងការស្រាលខ្លះ ហើយក៏ដឹងថា កហាបណៈនេះធ្វើនៅស្រុកនោះខ្លះ ធ្វើនៅខេត្តនោះខ្លះ ក្នុងក្រុងនោះ ជិតស្រះជម្ជាតិនោះ ក្រោមភ្នំនោះ ត្រង់ប្រាំង

ស៊ីននោះ ធ្វើដោយអាចារ្យឈ្មោះនោះខ្វះ យ៉ាងណា សញ្ញាក៏ដូចកុមារដែលមិនមានការដឹងមើលនូវកហាបណៈ ចាំតែអារម្មណ៍ ដោយអំណាចពណ៌ខៀវជាដើមប៉ុណ្ណោះ ។ ឯវិញ្ញាណក៏ដូចបុរសអ្នកស្រុកមើលកហាបណៈ ចាំអារម្មណ៍ដោយអំណាចពណ៌ខៀវជាដើមផង ឲ្យដល់នូវការចាក់ធ្លុះនូវលក្ខណៈ ដោយអំណាចអនិច្ចំជាដើមផង ។ វិញ្ញាណក៏ដូចហិរញ្ញិកបុរស មើលកហាបណៈ ដឹងអារម្មណ៍ដោយអំណាចពណ៌ខៀវជាដើមផង ឲ្យដល់នូវការចាក់ធ្លុះនូវលក្ខណៈដោយអំណាចអនិច្ចំជាដើមផង ឲ្យខ្វល់ខ្វាយ ដល់ការប្រកបដនៃមគ្គផងដូច្នោះឯង ។ ឯការផ្សេងគ្នានៃវត្ថុទាំងនោះ ចាក់ធ្លុះ គឺដឹងបានលំបាក ។

ព្រោះដូច្នោះ ទើបព្រះនាគសេនពោលថា មហាបពិត្រ ព្រះមានព្រះភាគទ្រង់ធ្វើវត្ថុដែលធ្វើបានលំបាក ។ ព្រះបាទមិលិន្ទត្រាស់ថា ព្រះនាគសេនដ៏ចម្រើន វត្ថុដែលធ្វើបានលំបាកដូចម្ដេចដែលព្រះមានព្រះភាគ ទ្រង់បានធ្វើហើយ ។ ព្រះនាគសេនតបថា មហាបពិត្រ វត្ថុដែលធ្វើបានលំបាក ដែលព្រះមានព្រះភាគទ្រង់បានធ្វើហើយ គឺការដែលទ្រង់ប្រាប់ការកំណត់ធម៌ដែលជាចិត្ត និងចេតសិក ដែលមិនមានរូប ប្រព្រឹត្តទៅក្នុងអារម្មណ៍ជាមួយគ្នាថា នេះ គឺធម៌ដែលធ្វើការប៉ះខ្ទប់ នេះ គឺធម៌ធ្វើកិច្ចសោយអារម្មណ៍ នេះ គឺធម៌ធ្វើកិច្ចចាំអារម្មណ៍ នេះ គឺធម៌ដែលធ្វើកិច្ចតាក់តែង នេះ គឺធម៌ដែលធ្វើកិច្ចគិត ។ ប្រៀបដូចបុរសដែលនាំយកប្រេង ៥ ប្រភេទ គឺប្រេងល្ង ប្រេងស្ពៃ ប្រេងស្រគំ ប្រេងល្ហុងខ្វង និងខ្លាញ់ភាវ មកដាក់ក្នុងកាជនៈតែមួយ ហើយយកឈើកូរអស់មួយថ្ងៃ ហើយក៏ដួសចែកអំពីគ្នាម្យ៉ាងៗ ថា នេះប្រេងល្ង

នេះប្រេងស្នែ នេះក៏ឈ្មោះថា ធ្វើបានលំបាកហើយ តែការធ្វើបានលំបាកជាង នោះទៅទៀត ព្រោះព្រះមានព្រះភាគទ្រង់ជាព្រះធម្មរាជា ជាធម្មិស្សរៈ ព្រោះទ្រង់ដល់នូវសព្វញ្ញុតញ្ញាណដោយល្អហើយ ត្រាស់ប្រាប់ការកំណត់នូវវត្ថុដែលមិនមានរូបរាងបាន ដែលកំពុងប្រព្រឹត្តទៅក្នុងអារម្មណ៍ជាមួយគ្នាទាំងនេះ ។ គប្បីជ្រាបសេចក្តីនេះថា ដូចគ្នានឹងជនទឹកមកចែកជាចំណែកៗ យ៉ាងនេះថា នេះជាទឹករបស់ស្ទឹងគង្គា នេះជាទឹកស្ទឹងយមុនា ក្នុងទីដែលស្ទឹងធំទាំង ៥ ខ្សែហូរទៅកាន់សមុទ្រហើយ ដូច្នោះ ។

[១៣៦] បទថា **និស្សដ្ឋេន** គឺរលាស់ចេញទៅហើយ ឬដែលត្រូវរលាស់ទៅហើយ ។ ក្នុងកាលពាក្យថា **និស្សដ្ឋេន** ទាំង ៥ នោះ កាលមានអត្ថថា ដែលត្រូវរលាស់ទៅហើយ ក៏គប្បីជ្រាបថា ជាតតិយាវិភត្តិ ។ មានពាក្យដែលលោកអធិប្បាយថា វិញ្ញាណដែលរលាស់ចេញទៅអំពីឥន្ទ្រិយទាំង ៥ ហើយប្រព្រឹត្តទៅក្នុងមនោទ្វារ ឬត្រូវឥន្ទ្រិយទាំង ៥ រលាស់ចោលទៅហើយ ព្រោះវិញ្ញាណនោះមិនចូលដល់ភាពជាវត្ថុបាន ។ បទថា **បរិសុទ្ធេន** គឺមិនមានអ្វីចូលទៅធ្វើឲ្យប្រឡាក់ ។ បទថា **មនោវិញ្ញាណេន** គឺដោយរូបាវចរចតុត្ថជ្ឈានជាអារម្មណ៍ ។ បទថា **កឹ ញេយ្យំ** គឺគប្បីដឹងអ្វី ព្រោះវត្ថុដែលគប្បីដឹងក្នុងពាក្យជាដើមថា ធម្មតា ធម៌ណាមួយដែលគប្បីដឹកនាំមាន ។ លោកហៅថា **ញេយ្យ** គឺគប្បីដឹកនាំ គប្បីដឹង ។ គប្បីដឹងអាកាសានញ្ចាយតនៈ ដូចម្តេច អរូបាវចរសមាបត្តិ បុគ្គលគប្បីដឹងបានដោយរូបាវចរចតុត្ថជ្ឈានជាអារម្មណ៍ ព្រោះដូច្នោះ បុគ្គលដែលនៅក្នុងរូបាវចរចតុត្ថជ្ឈាន រមែងអាចធ្វើ

ឲ្យអរូបាវចរសមាបត្តិកើតឡើងបាន ។ ព្រោះអរូបាវចរសមាបត្តិ សម្រេចដល់បុគ្គលដែលនៅក្នុងរូបាវចរចតុត្ថជ្ឈានបាន ព្រោះដូច្នោះ ទើបព្រះសារីបុត្តឆ្លើយថា គប្បីដឹងនូវអាកាសានញ្ចាយតនៈ ដូច្នេះ ។ កាលបើយ៉ាងនោះ ហេតុអ្វី ទើបមិនពោលដល់នេវសញ្ញានាសញ្ញាយតនៈផង ព្រោះមិនមានការប្រកាន់ទុកជាផ្នែកមួយទៀត ក្នុងនេវសញ្ញានាសញ្ញាយតនៈនោះ បុគ្គលទោះពិចារណាដោយពួកៗ និងដោយជាន័យៗ ក៏បាន ។ ការកាន់យកជាផ្នែកៗ រមែងមិនកើតដល់ភិក្ខុអម្បាលព្រះធម្មសេនាបតីឡើយ ព្រោះដូច្នោះ សូម្បីព្រះថេរៈក៏ពិចារណាដោយភាពជាពួកៗ និងដោយភាពជាន័យៗ ហើយ ក៏ឆ្លើយថា បានឮមកថា វត្ថុទាំងនេះមិនមានហើយ រមែងមានព្រម មានហើយ រមែងវិនាសទៅយ៉ាងនេះ ដោយប្រការដូច្នេះ ។ ឯព្រះមានព្រះភាគ ព្រោះសព្វញ្ញុតញ្ញាណនៅក្នុងដៃ ទ្រង់លើកធម៌ច្រើនជាង ១០ យ៉ាង ក្នុងនេវសញ្ញានាសញ្ញាយតនៈ ដោយការលើកឡើងជាអង្គ រៀបចំឲ្យជាផ្នែកៗ ហើយត្រាស់ថា ការសម្រេចអរហត្តផល ស្មើនឹងការចូលសញ្ញាសមាបត្តិ ដូច្នេះ ។

បទថា **បញ្ញាចក្ខុនា បជានាតិ** ដឹងដោយភ្នែក គឺបញ្ញា ព្រោះអត្ថថាជាទស្សនបរិនាយក ។ ក្នុងពាក្យថា ដឹងច្បាស់ដោយភ្នែក គឺបញ្ញានោះ បញ្ញាមាន ២ យ៉ាង គឺ បញ្ញាក្នុងសមាធិ និងបញ្ញាក្នុងវិបស្សនា ។ រមែងដឹងច្បាស់ដោយកិច្ចផង ដោយការមិនវង្វេងផង ដោយបញ្ញាក្នុងសមាធិផង ។ លោកពោលការដឹងដោយអារម្មណ៍ ដោយការចាក់ធ្លុះលក្ខណៈបាន ចាក់ធ្លុះដោយបញ្ញាក្នុងវិបស្សនា ។ បទថា **កិមត្ថិយា** ជាសេចក្តីត្រូវការរបស់បញ្ញា

នេះ ។ ក្នុងបទថា **អភិញ្ញត្ថ** ជាដើម គឺឈ្មោះថា មានការដឹងក្រៃលែង ដែលជាសេចក្តីត្រូវការ ព្រោះដឹងក្រៃលែងនូវវត្ថុដែលគប្បីដឹងយ៉ាងក្រៃលែង ។ ដែលឈ្មោះថា **បរិញ្ញត្ថ** ព្រោះកំណត់ដឹងនូវវត្ថុដែលត្រូវកំណត់ឲ្យដឹង ។ ឈ្មោះថា **បហានត្ថ** ព្រោះលះវត្ថុដែលត្រូវលះ ។ បញ្ញានេះ សូម្បីជាបញ្ញាដែលជាលោកិយ ក៏មានការដឹងក្រៃលែងជាទីត្រូវការ មានការកំណត់ដឹងជាបំណង មានការលះដោយការសង្កត់ជាទីសម្គាល់ ។ ដែលជាលោកុត្តរ មានការដឹងក្រៃលែងជាទីត្រូវការ មានការកំណត់ដឹងជាគោលបំណង និងមានការលះដោយសមុច្ឆេទជាគ្រឿងចំណាំ ។ ក្នុងបញ្ញាទាំង ២ នោះ លោកិយ-ប្បញ្ញារមែងដឹងច្បាស់ដោយកិច្ចផង ដោយការមិនវង្វេងផង លោកុត្តរប្បញ្ញារមែងដឹងច្បាស់ដោយការមិនវង្វេង ។

[ ១៣៧ ] បទថា **សម្មាទិដ្ឋិយា ឧបាទាយ** គឺអាស្រ័យវិបស្សនា-សម្មាទិដ្ឋិ និងមគ្គសម្មាទិដ្ឋិ ។ បទថា **បរតោ ច ឃោសោ** គឺការស្តាប់ធម៌ដែលជាទីសប្បាយ ។ បទថា **យោនិសោ ច មនសិការោ** គឺយកចិត្តទុកដាក់ក្នុងឧបាយរបស់ខ្លួន ។ ក្នុងសាវកទាំងនោះសោត បច្ច័យទាំង ២ រមែងគួរ បានដល់ ព្រះធម្មសេនាបតីប៉ុណ្ណោះ ។ ព្រោះព្រះថេរៈសូម្បីបំពេញបារមីមកមួយអសង្ខេយ្យ និងមួយសែនកប្ប ក៏មិនអាចលះកិលេសតិចតួចដោយធម្មតារបស់ខ្លួនបានឡើយ លុះកណាតែបានស្តាប់គាថាអំពីព្រះអស្សជិ ដែលលោកសម្តែងថា ធម៌ទាំងឡាយ មានហេតុជាដែនកើត គឺកើតអំពីហេតុ ទើបបានសម្រេច ។ សម្រាប់ព្រះបច្ចេកពុទ្ធទាំងឡាយ និងព្រះសព្វញ្ញុពុទ្ធទាំង-

ឡាយ មិនមានកិច្ចទាក់ទងដោយបរតោឃោសៈឡើយ ។ លោកតាំងនៅក្នុងយោនិសោមនសិការប៉ុណ្ណោះ ក៏នាំឲ្យកើតបច្ចេកពោធិញ្ញាណ និងសព្វញ្ញុគុណទាំងឡាយបាន ។ បទថា **អនុគ្គហិត** គឺបានទទួលការអនុគ្រោះ គឺឧបការៈហើយ ។ បទថា **សម្មាទិដ្ឋិ** គឺអរហត្តមគ្គសម្មាទិដ្ឋិ ។ ដែលឈ្មោះថា **ចេតោវិមុត្តិផលា** ព្រោះចិត្តជាផល ព្រោះការរួចផុត ព្រោះបដិបត្តិផ្លូវចិត្តជាផលរបស់លោក ។ ដែលឈ្មោះថា អានិសង្ស គឺវត្ថុដែលហូរជូនមកអំពីចេតោវិមុត្តិ ព្រោះអានិសង្ស ពោលគឺ ចេតោវិមុត្តិរបស់លោកមាន ។ ក្នុងបទទី ២ ក៏ទំនងដូចគ្នានេះឯង ។ គប្បីជ្រាបថា ក្នុងផលនេះ ផលទី ៤ ឈ្មោះថា បញ្ញាវិមុត្តិ វត្ថុដ៏សេសជាចេតោវិមុត្តិ ។ ក្នុងបទថា **សីលា-នុគ្គហិតា** ជាដើម ដែលសីលអនុគ្រោះហើយ គឺ ចតុប្បារិសុទ្ធិសីល ៤ ឈ្មោះថា សីល ។ បទថា **សុតំ** គឺការស្តាប់ធម៌ដែលជាទីសប្បាយ ។ បទថា **សាកច្ឆា** បានដល់ ពាក្យដែលកាត់នូវការខុសក្លាំងក្លាត់ក្នុងកម្មដ្ឋាន ។ បទថា **សមថោ** គឺការស្ងប់ បានដល់ សមាបត្តិ ៨ ដែលមានវិបស្សនាជាបាទ ។ បទថា **វិបស្សនា** គឺការតាមឃើញដោយអនុបស្សនា ៧ យ៉ាង ។

ឯអរហត្តមគ្គ តែងកើតឡើងហើយក្នុងផលដល់បុគ្គលដែលកំពុងបំពេញចតុប្បារិសុទ្ធិសីល ស្តាប់ធម៌ដែលជាទីសប្បាយ កាត់នូវការខុសក្លាំងក្លាត់ក្នុងកម្មដ្ឋាន ធ្វើនូវសមាបត្តិ ៨ ដែលមានវិបស្សនាជាបាទ ហើយចម្រើននូវអនុបស្សនា ៧ ។ គប្បីជ្រាបការប្រៀបធៀប ដូចគ្នានឹងបុរសដែលចង់បរិភោគផ្លែស្វាយទុំ តម្កល់ទឹកដោយជុំវិញដើមស្វាយនោះយ៉ាងមាំទាំ កាន់ក្អម

ទឹក ស្រោចម្តងម្កាល លើកទំនប់ព័ទ្ធជុំវិញការពារទឹក មិនឲ្យហូរចេញយ៉ាង មាំទាំ បោចវល្លិដែលនៅក្បែរៗ យកកំណាត់ឈើស្ងួត សម្បកស្រមោច ឬសម្បកពីងពាងចេញទៅ យកចបទៅជ្រោយជុំវិញគល់ក្នុងកាលខ្លះ កាល បុគ្គលនោះថែរក្សាដោយហេតុ ៥ យ៉ាង ដូចពោលមកនេះ ស្វាយក៏ចម្រើន ហើយឲ្យផល ។

គប្បីឃើញចតុប្បារិសុទ្ធិសីល ដូចការព័ទ្ធរបងជុំវិញដើមឈើ ការស្តាប់ធម៌ ដូចការស្រោចទឹកម្តងម្កាល សមថៈដូចការធ្វើឲ្យមាំទាំដោយទំនប់ ការកាត់នូវការខុសភ្លាំងភ្លាត់ក្នុងកម្មដ្ឋាន ដូចការបោចវល្លិដែលនៅក្នុងទីជិតៗចេញ ការចម្រើនអនុបស្សនា ៧ ដូចការយកចបមកជ្រួយដីក្នុងកាលខ្លះ គប្បីជ្រាប ការឲ្យផល គឺភាពជាព្រះអរហន្ត ព្រោះសម្មាទិដ្ឋិក្នុងវត្ថុ ៥ យ៉ាងរបស់ភិក្ខុនេះ តាមដែលអនុគ្រោះហើយ ដូចវេលាដើមស្វាយ ដែលហេតុទាំង ៥ យ៉ាងតាមអនុគ្រោះហើយ ឲ្យផលផ្អែមឆ្ងាញ់ ដូច្នោះ ។

[ ១៣៨ ] ព្រះមហាកោដ្ឋិតៈ សួរដល់អ្វីក្នុងបទនេះថា **កតិ បនាវុសោ ភវា** ព្រះថេរៈសួរថា ការបន្តទៅដល់ឬសគល់នោះឯង បុគ្គលល្ងង់ខ្លៅ មិនឡើងចាកភពទាំងឡាយណា ខ្ញុំសួរដល់ភពទាំងនោះ ។ ក្នុងភពទាំងនោះ បទថា **កាមភវោ** ព្រោះព្រះថេរៈលោកសង្គ្រោះយកវត្ថុទាំង ២ គឺការធ្វើដែលចូលដល់កាមភព និងខន្ធដែលតណ្ហា មានះ និងទិដ្ឋិប្រកាន់ទុក ដែលកើតឡើងមក ព្រោះការធ្វើតែមួយ ហើយទើបពោលថា កាមភព ទោះរូបភព និងអរូបភពក៏មានទំនងដូចគ្នានេះឯង ។ បទថា **អាយតឹ** បានដល់ ក្នុង

អនាគត ។ ការកើតឡើងក្នុងភពថ្មីទៀត ឈ្មោះថា **បុនព្ភវាភិនិព្វត្តិ** ក្នុងទីនេះ លោកសួរដល់ការវិលវល់ស្លាប់កើត ។ ការត្រេកអរក្រៃលែងក្នុងវត្ថុនោះៗ យ៉ាងនេះ គឺ ការត្រេកអរយ៉ាងក្រៃលែងក្នុងរូប ការត្រេកអរយ៉ាងក្រៃលែងក្នុងសំឡេងជាដើម ឈ្មោះថា **តត្រតត្រាភិនន្ទនា** ពាក្យនេះជាបឋមាវិភត្តិ ចុះក្នុងតតិយាវិភត្តិនោះឯង ទើបអធិប្បាយថា ការកើតឡើងក្នុងភពថ្មីទៀតមាន ព្រោះការត្រេកអរក្រៃលែងក្នុងវត្ថុនោះៗ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ក៏ឈ្មោះថា ព្រះថេរៈធ្វើវដ្តៈឲ្យដល់ទីបំផុត ហើយសម្តែងថា ការទៅមាន ការមកក៏មាន ការទៅ និងការមកក៏មាន វដ្តៈរមែងវិលទៅដូច្នេះ ។

ឥឡូវនេះ ដើម្បីសួរដល់វិវដ្តៈ ទើបព្រះមហាកោដ្ឋិតៈពោលពាក្យថា **កថំ បនាវុសោ** ជាដើម ក្នុងការឆ្លើយនោះ គប្បីជ្រាបដូច្នេះ

បទថា **អវិជ្ជាវិរាគា** បានដល់ ព្រោះការអស់ទៅ និងប្រាសចាកការមិនដឹង ។ បទថា **វិជ្ជុប្បាទា** បានដល់ ព្រោះវិជ្ជាកើតឡើងក្នុងអរហត្តមគ្គ ។ មិនគប្បីសួរពាក្យទាំង ២ នេះថា អវិជ្ជារលត់មុន ឬវិជ្ជាកើតមុន ព្រោះការកើតឡើងនៃវិជ្ជា ទើបអវិជ្ជាឈ្មោះថា រលត់ទៅដោយពិត ដូចការងងឹតវិនាសទៅព្រោះពន្លឺនៃចង្កៀង ដូច្នោះ ។ បទថា **តណ្ហានិរោធា** បានដល់ការរលត់ទៅដោយមិនមានសេសសល់នៃតណ្ហា ។ បទថា **បុនព្ភវាភិនិព្វត្តិ ន ហោតិ** គឺការកើតឡើងនៃភពថ្មីតទៅទៀតមិនមាន ការទៅ ការមក ការទៅក្តី ការមកក្តី ក៏មិនមាន ។ វដ្តៈ ក៏ឈប់វិលទៅ ដោយប្រការដូច្នេះ ។

ឈ្មោះថា ព្រះថេរៈធ្វើឲ្យវដ្តៈដល់ទីបំផុត ហើយសម្តែង ។

ព្រះថេរៈសួរដល់អ្វី ក្នុងបទនេះថា **កតមំ បញ្ចាវុសោ** ភិក្ខុរបផុតទាំង ២ ចំណែក គឺទាំងចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ចូលនិរោធម្តងម្កាល ។ ព្រះថេរៈសួរថា ខ្ញុំសូមសួរបឋមជ្ឈាន ដែលមាននិរោធជាបាទរបស់ភិក្ខុនោះ ។

[ ១៣៩ ] ក្នុងបទនេះថា **បឋមំ ឈានំ** នេះ ព្រះថេរៈសួរដល់អ្វី ធម្មតាភិក្ខុដែលចូលនិរោធ ត្រូវយល់ដល់ព្រំដែន ដែលជាចំណែកកំណត់អង្គថា ឈាននេះមានអង្គ ៥ មានអង្គ ៤ មានអង្គ ៣ ឈាននេះមានអង្គ ២ ។ ទើបព្រះថេរៈសួរថា ខ្ញុំសូមសួរដល់ព្រំដែនសម្រាប់កំណត់អង្គ ។ ក្នុងអង្គថា វិតក្កជាដើមនេះ វិតក្ក មានការលើកចិត្តឡើងជាលក្ខណៈ វិចារៈ មានការបោសអង្អែលអារម្មណ៍ជាលក្ខណៈ បីតិ មានការផ្សាយទៅជាលក្ខណៈ ។ សុខ មានការសប្បាយចិត្តជាលក្ខណៈ ។ ឯកគ្គតា មានការមិនរាយមាយជាលក្ខណៈ ធម៌ទាំង ៥ យ៉ាងនេះ ប្រព្រឹត្តទៅដោយប្រការដូច្នេះ ។

ក្នុងបទថា **កតង្គិវិប្បហីនំ** នេះ ព្រះថេរៈសួរដល់អ្វី លោកសួរថា ធម្មតាភិក្ខុដែលចូលនិរោធ ត្រូវយល់អង្គដែលជាឧបការៈ និងដែលមិនជាឧបការៈ ខ្ញុំសូមសួរនូវអង្គទាំងនោះ ។ សម្រាប់ចម្លើយក្នុងសំណួរនេះ ប្រាកដច្បាស់ហើយ ។ ដោយប្រការដូច្នេះ ឈ្មោះថា លោកបានកាន់យកឈានទី ១ ដែលមាននិរោធជាទីទទួល ទុកក្នុងខាងក្រោមហើយ ទើបព្រះថេរៈសួរការចូលនេវសញ្ញានាសញ្ញាយតនៈ ដែលជាអនន្តរប្បច្ច័យនៃឈានទី ១ នោះខាងលើ ។ ឯសមាបត្តិ ៦ ក្នុងចន្លោះនៃនេវសញ្ញានាសញ្ញាយតនៈនោះ គប្បី

ជ្រាបថា លោកបានសង្ខេប ឬចង្អុលន័យដោះស្រាយហើយ ។

[ ១៤០ ] ឥឡូវនេះ កាលនឹងសួរបសាទទាំង ៥ ដែលអាស្រ័យវិញ្ញាណ ទើបព្រះមហាកោដ្ឋិតៈពោលថា **បញ្ចិមានិ អាវុសោ** នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **គោចរវិសយំ** គឺ វិស័យដែលជាគោចរ ។ បទថា **អញ្ញមញ្ញស្ស** បានដល់ មិនសោយចំពោះគោចរវិស័យនៃគ្នានិងគ្នាយ៉ាងនេះ គឺត្រចៀកទទួលអារម្មណ៍របស់ភ្នែកផង របស់ត្រចៀកផង ឬទទួលអារម្មណ៍របស់ភ្នែកតែម្យ៉ាង ។ បើរួមយកអារម្មណ៍ដែលជារូប មានពណ៌ខៀវជាដើម ហើយបង្អោនឲ្យទៅក្នុងឥន្ទ្រិយ គឺ ត្រចៀក ហើយពោលថា អើ ឯងកំណត់វាសិនចុះ ឬថា ឯងធ្វើឲ្យជាក់ច្បាស់ចុះថា វាជាអារម្មណ៍អ្វី ។ សូម្បីចក្ខុ-វិញ្ញាណ បើដកមាត់ចេញហើយ វាក៏គប្បីពោលធម្មតារបស់ខ្លួន យ៉ាងនេះថា ឱ ! អាខ្វាក់ល្ងង់ខ្លៅ ទោះបីឯងអង្វរអញរាប់រយឆ្នាំ ពាន់ឆ្នាំ ក្រៅអំពីអញហើយ ឯងមិនបានដឹងវត្ថុនេះឡើយ យកវាមកបង្អោនដាក់ក្នុងចក្ខុបសាទអញនឹងដឹងអារម្មណ៍នោះ ទោះវាខៀវ ឬលឿង វាមិនមែនវិស័យនៃអ្នកដទៃឡើយ វាជាវិស័យរបស់អញប៉ុណ្ណោះ ។ ក្នុងទ្វារដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ យ៉ាងនេះ ឈ្មោះថា ឥន្ទ្រិយទាំងនេះ មិនព្រមទទួលសោយគោចរវិស័យនៃគ្នានិងគ្នាឡើយ ។ បទថា **កឹ បដិសរណំ** បានដល់ លោកសួរថា អ្វីជាទីអាស្រ័យនៃឥន្ទ្រិយទាំងនេះ គឺ ឥន្ទ្រិយទាំងនេះ អាស្រ័យអ្វី ។ បទថា **មនោបដិសរណំ** បានដល់ មានចិត្តជាទីស្ទុះទៅ គឺសេពអារម្មណ៍ ឬធ្វើកម្ម ជាទីពឹងអាស្រ័យ ។ បទថា **មនោ ច នេសំ** បានដល់ ចិត្តដែល

ស្ទុះទៅតាមមនោទ្វារក្តី ចិត្តដែលស្ទុះទៅតាមបញ្ចទ្វារក្តី រមែងសោយគោចរ-វិស័យនៃឥន្ទ្រិយទាំងនោះ ដោយអំណាចសេចក្តីត្រេកអរជាដើម ។ ពិតហើយ ការដឹងច្បាស់តាមផ្លូវភ្នែក គ្រាន់តែជាការឃើញរូបប៉ុណ្ណោះ មិនត្រេកអរ មិនប្រទូស្ត ឬវង្វេងក្នុងការឃើញរូបជាដើម តែចិត្តដែលស្ទុះទៅក្នុងទ្វារនេះ រមែងត្រេកអរ ប្រទូស្ត ឬ វង្វេង ។ សូម្បីក្នុងសោតវិញ្ញាណជាដើម ក៏មានទំនងដូចគ្នានេះឯង ។

បន្ទាប់អំពីនេះទៅ ជាការប្រៀបធៀបក្នុងរឿងឥន្ទ្រិយទាំងនោះ គឺ មានរឿងមកថា មេស្រុកក្រីក្រ ៥ នាក់ នាំគ្នាសេពគប់ព្រះរាជា ហើយក៏បានសួយបន្តិចបន្តួច ក្នុងស្រុក ៥ ត្រកូលមួយកន្លែង ដោយការលំបាក ។ របស់ត្រឹមប៉ុណ្ណោះ គឺត្រីមួយចំណែក សាច់មួយចំណែក កហាបណៈល្មមទិញខ្សែបានមួយចង្វាយ កហាបណៈល្មមទិញខ្សែមួយសរសៃ សម្រាប់ចងដំរី ៤ កហាបណៈ ៨ កហាបណៈ ១៦ កហាបណៈ ៣២ កហាបណៈ ឬ ៦៤ កហាបណៈ ក្នុងស្រុកនោះ រមែងមានដល់ពួកមេស្រុកទាំងនោះ ។ ព្រះរាជាប៉ុណ្ណោះ ទ្រង់ទទួលពលីធំ ជារបស់ ១ រយ ៥ រយ ១ ពាន់ ។

គប្បីជ្រាបបសាទទាំង ៥ ដូចស្រុក ៥ ត្រកូលក្នុងទីនោះ ។ វិញ្ញាណទាំង ៥ ដូចមេស្រុកទុព្វល ៥ នាក់ ជវនដូចព្រះរាជា ទស្សនកិច្ចជាដើមនៃចក្ខុវិញ្ញាណ ដូចមេស្រុកទុព្វលបានទទួលរង្វាន់បន្តិចបន្តួច ។ ឯតម្រេកជាដើម មិនមានក្នុងបសាទទាំងនេះ ។ គប្បីជ្រាប តម្រេកជាដើមនៃចិត្តដែលធ្វើជវនក្នុងទ្វារទាំងនោះ ដូចការទទួលពលីដ៏ច្រើនរបស់ព្រះរាជា ។

[ ១៤១ ] ក្នុងបទថា **បញ្ចិមានិ អាវុសោ** នេះ ព្រះថេរៈសួរដល់អ្វី លោកសួរដល់បសាទទាំង ៥ ខាងក្នុងនិរោធថា សម្រាប់អរូបធម៌នោះ កាល ការប្រព្រឹត្តទៅដែលសម្រេចអំពីកិរិយាចិត្ត កំពុងប្រព្រឹត្តទៅ ក៏នឹងជាបច្ច័យ ដ៏មានកម្លាំងដល់បសាទទាំងឡាយ បុគ្គលណារម្ងត់បសាទដែលប្រព្រឹត្តទៅ ហើយនោះ ហើយចូលនិរោធសមាបត្តិ បសាទទាំង ៥ ខាងក្នុងនិរោធរបស់ បុគ្គលនោះអាស្រ័យអ្វី ទើបតាំងនៅបាន ខ្ញុំសូមសួរវត្ថុនេះ ដោយប្រការ ដូច្នេះ ។ បទថា **អាយុំ បដិច្ច** បានដល់ អាស្រ័យធម្មជាតដែលជាធំក្នុងកិច្ច រស់នៅ គឺជីវិតិន្ទ្រិយតាំងនៅ ។ បទថា **ឧស្មំ បដិច្ច** បានដល់ វត្ថុដែលជាធំ ក្នុងការរស់នៅ អាស្រ័យភ្លើងដែលកើតអំពីកម្មតាំងនៅ ។ ព្រោះភ្លើងដែល កើតអំពីកម្ម វៀរជីវិតិន្ទ្រិយ តាំងនៅមិនបាន ដូច្នោះ ទើបលោកពោលថា ឧស្មាតាំងនៅអាស្រ័យអាយុ ។ បទថា **ឈាយតោ** បានដល់ កំពុងឆេះ ។ បទថា **អច្ចឹ បដិច្ច** បានដល់ អាស្រ័យអណ្តាត ។ បទថា **អាភា បញ្ញាយតិ** បានដល់ ពន្លឺប្រាកដ ។ បទថា **អាភំ បដិច្ច អច្ចឹ** បានដល់ អណ្តាត ភ្លើងអាស្រ័យពន្លឺ ទើបប្រាកដ ។ ក្នុងបទថា **ឯវមេវ ខោ អាវុសោ អាយុ ឧស្មំ បដិច្ច តិដ្ឋតិ** នេះ គឺភ្លើងដែលកើតអំពីកម្ម ដូចអណ្តាតភ្លើង ជីវិតិន្ទ្រិយ ដូចពន្លឺ ។ ពិតហើយ អណ្តាតភ្លើង កាលកើត ក៏កាន់យកពន្លឺនោះឯងកើត ឡើង ។ អណ្តាតភ្លើងនោះឯង ក៏ប្រាកដជារបស់តូចធំ វែង ខ្លី តាមពន្លឺដែល ខ្លួនកើតនោះឯង ការប្រើជីវិតិន្ទ្រិយ ដែលកើតព្រមនឹងកម្មជមហាភូតរូប អាស្រ័យភ្លើងធាតុតាមរក្សាភ្លើងធាតុ ដូចការប្រាកដនៃការប្រព្រឹត្តទៅរបស់

អណ្តាតភ្លើងនោះឯង ព្រោះពន្លឺដែលការប្រព្រឹត្តទៅនៃអណ្តាតភ្លើងនោះឲ្យកើត ពិតហើយ ជីវិតិន្ទ្រិយរក្សាភ្លើងធាតុ ដែលកើតអំពីកម្ម ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ។បេ។ ១០០ ឆ្នាំខ្លះ ។ ដោយប្រការដូច្នេះ ទើបមហាភូតរូបជាបច្ច័យដោយអំណាចនិស្សយប្បច្ច័យនៃឧបាទាយរូប ដូច្នោះ ទើបឈ្មោះថា អាយុអាស្រ័យភ្លើងធាតុតាំងនៅ ។ ជីវិតិន្ទ្រិយ រក្សាមហាភូតរូបទាំងឡាយដោយហេតុនោះ ទើបគួរយល់ថា ភ្លើងធាតុតាំងនៅបានអាស្រ័យអាយុ ។ បទថា **អាយុសង្ខារា** គឺអាយុនោះឯង ។ បទថា **វេទនិយា ធម្មា** គឺធម៌ដែលជាគ្រឿងសោយ ។ បទថា **វុដ្ឋានំ បញ្ញាយតិ** គឺការចេញអំពីសមាបត្តិក៏ប្រាកដ ។ ពិតហើយ ភិក្ខុណាកើតនូវការពេញចិត្តក្នុងអរូប ដែលប្រព្រឹត្តទៅហើយ ទើបរលត់សញ្ញា និងវេទនា ហើយចូលកាន់និរោធ អរូបធម៌ដែលមានរូបជីវិតិន្ទ្រិយជាបច្ច័យ ក៏កើតដល់ភិក្ខុនោះ តាមអំណាចពេលវេលាដែលបានកំណត់ ឯរូបធម៌ និងអរូបធម៌ ប្រព្រឹត្តទៅហើយយ៉ាងនោះ ក៏គង់ប្រព្រឹត្តទៅ ។ សេចក្តីនេះដូចម្តេច ដូចបុរសម្នាក់កើតការក្តៅក្រហាយ ព្រោះអណ្តាតភ្លើង ដែលប្រព្រឹត្តទៅ ទើបយកទឹកស្រោច ធ្វើឲ្យភ្លើងរលត់ទៅ យកផេះមកលុបរងើក ហើយក៏អង្គុយស្ងៀម ។ កាលចង់ឲ្យមានអណ្តាតទៀត ក៏កាយផេះចេញ ហើយត្រឡប់រងើកឡើង បន្ថែមឧស ហើយផ្លុំដោយមាត់ ឬបក់ដោយស្លឹកត្នោត ពេលនោះ អណ្តាតភ្លើងប្រព្រឹត្តទៅទៀត យ៉ាងណា សេចក្តីនោះក៏ដូចគ្នា អរូបធម៌ ក៏ដូចគ្នានឹងអណ្តាតភ្លើងដែលប្រព្រឹត្តទៅ ។ កាលភិក្ខុកើតការក្តៅក្រហាយចិត្តឡើង ព្រោះអរូបដែលប្រព្រឹត្តទៅហើយ ទើប

រម្ងាប់សញ្ញា និងវេទនា ចូលនិរោធ ដូចការដែលបុគ្គលកើតនូវការរំខាន ព្រោះអណ្ដាតភ្លើងដែលប្រព្រឹត្តទៅហើយ ទើបយកទឹកមកស្រោច ធ្វើឲ្យអណ្ដាតភ្លើងឈប់ប្រព្រឹត្តទៅ យកផេះមកលុបរងើក ហើយអង្គុយស្ងៀម ។ រូបជីវិតិន្ទ្រិយ និងភ្លើងធាតុដែលកើតអំពីកម្ម ក៏នៅប្រព្រឹត្តទៅ ដូចគ្នានឹងរងើកភ្លើងដែលកប់ក្នុងផេះ ការប្រព្រឹត្តទៅតាមវេលាដែលភិក្ខុបានកំណត់ ដូចគ្នានឹងបុរសត្រូវការអណ្ដាតភ្លើងទៀត កាយផេះជាដើមចេញ ការប្រព្រឹត្តិទៅនៃរូបធម៌ និងអរូបធម៌ ក្នុងកាលអរូបធម៌កើតឡើងទៀត គប្បីជ្រាបថា ដូចការប្រព្រឹត្តទៅរបស់អណ្ដាតភ្លើង ។

[ ១៤២ ] បទថា **អាយុ ឧស្មា ច វិញ្ញាណំ** សំដៅយកវត្ថុទាំង ៣ យ៉ាងនេះ គឺរូបជីវិតិន្ទ្រិយ ១ ភ្លើងធាតុដែលកើតអំពីកម្ម ១ ចិត្ត ១ លះបង់រូបកាយនេះក្នុងកាលណា កាលនោះ ក៏ត្រូវគេបោះចោល ឲ្យដេកលើផែនដី ដូចកំណាត់ឈើ ដែលមិនមានចិត្ត ដូច្នោះ ។ សមដូចពាក្យដែលលោកពោលយ៉ាងនេះថា

**អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ**
**អបវិទ្ធោ តទា សេតិ បរភត្តំ អចេតនំ ។**

អាយុក្ដី ភ្លើងធាតុក្ដី វិញ្ញាណក្ដី តែងលះបង់នូវកាយនេះ ដែលជាចំណីនៃសត្វដទៃ មិនមានចេតនា ក្នុងកាលណាហើយ កាយដែលគេចោលហើយ រមែងដេកលើផែនដី ក្នុងកាលនោះ ។

ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឈ្មោះថា កាយសង្ខារ វិតក្កៈ និង

វិចារៈ ឈ្មោះថា វចីសង្ខារ សញ្ញា និងវេទនា ឈ្មោះថា ចិត្តសង្ខារ រូបជីវិតិន្ទ្រិយ ឈ្មោះថា អាយុ ។ ពាក្យថា បែកធ្លាយទៅដោយជុំវិញ បាន ដល់ ត្រូវកម្ចាត់វិនាសហើយ ។ ក្នុងរឿងរបស់និរោធនោះ អាចារ្យខ្លះពោល ថា ចិត្តមិនទាន់រលត់ ព្រោះបាលីថា ចិត្តសង្ខាររបស់បុគ្គលចូលនិរោធប៉ុណ្ណោះ ដែលរលត់ទៅ ដូច្នោះ ទើបជាការចូលដល់កាយ ព្រមទាំងចិត្ត គប្បីពោល ជំទាស់ អាចារ្យទាំងនោះថា ពាក្យពោលក៏មិនរលត់ ព្រោះពាក្យបាលីថា សូម្បីវចីសង្ខាររបស់លោកក៏រលត់ទៅដែរ ដូច្នោះ អ្នកចូលនិរោធសមាបត្តិ គប្បីអង្គុយពោលធម៌ក៏បាន គប្បីអង្គុយធ្វើការសូធ្យគម្ពីរក៏បាន ហើយចិត្ត របស់បុគ្គលដែលធ្វើកាលកិរិយាទៅហើយ ក៏មិនរលត់ ព្រោះបាលីថា សូម្បី ចិត្តសង្ខាររបស់បុគ្គលនោះ ក៏រលត់ទៅហើយ ដូច្នោះ អ្នកដែលដុតឪពុក ម្ដាយ ឬព្រះអរហន្តដែលស្លាប់ទៅហើយ ក៏គប្បីជាអ្នកធ្វើអនន្តរិយកម្មទៅ ហើយ ... ព្រោះដូច្នោះ មិនគប្បីធ្វើការប្រកាន់មាំក្នុងព្យញ្ជនៈឡើយ គប្បី តាំងនៅក្នុងបែបផែន គឺ ន័យ ហើយពិចារណាអត្ថឲ្យសព្វគ្រប់ ពិតហើយ អត្ថជាគោលដែលគប្បីអាស្រ័យ មិនមែនព្យញ្ជនៈទេ ។ បទថា **ឥន្ទ្រិយានិ វិប្បសន្នានិ** សេចក្ដីថា ពិតហើយ ការប្រព្រឹត្តទៅដែលសម្រេចមកអំពី កិរិយាចិត្ត កំពុងប្រព្រឹត្តទៅ កាលអារម្មណ៍ខាងក្រៅ កំពុងប៉ះខ្ទប់បសាទ ឥន្ទ្រិយទាំងឡាយ រមែងលំបាក ដូចគ្នានឹងត្រូវប៉ះខ្ទប់ ដូចគ្នានឹងកញ្ចក់ដែល តាំងនៅក្នុងផ្លូវបែកជា ៤ ត្រូវល្អងធូលីដែលហុយឡើងជាដើមធ្វើឲ្យប្រឡាក់ ដូច្នោះ ។ បសាទរូប ៥ ដែលនៅខាងក្នុងនិរោធនៃភិក្ខុដែលចូលនិរោធ រុង

រឿងហួសពណ៌នា ដូចកញ្ចក់ដែលថ្លាដាក់ក្នុងស្រោម ហើយតាំងទុកក្នុងប្រអប់ជាដើម រុងរឿងនៅខាងក្នុងនោះឯង យ៉ាងណា សេចក្ដីនេះ ក៏យ៉ាងនោះ ព្រោះដូច្នោះ ទើបព្រះសារីបុត្រពោលថា ឥន្ទ្រិយនៅថ្លាល្អ ។

[ ១៤៣ ] ក្នុងបទថា **កតិ បនាវុសោ បច្ចយា** ព្រះមហាកោដ្ឋិតត្ថេរសួរដល់អ្វី លោកសួរថា ខ្ញុំសូមសួរដល់នេវសញ្ញានាសញ្ញាយតនៈដែលជាអនន្តរប្បច្ច័យរបស់និរោធ ។ សម្រាប់ក្នុងការឆ្លើយប្រស្នានោះ ព្រះសារីបុត្របានពោលដល់បច្ច័យដែលទៅប្រាស ៤ យ៉ាងថា **សុខស្ស ច** ជាដើម ។

ក្នុងបទថា **អនិមិត្តាយ** នេះ លោកសួរដល់អ្វី លោកសួរថា ខ្ញុំសូមសួរដល់ផលសមាបត្តិរបស់អ្នកចេញអំពីនិរោធ ។ ឯការចេញអំពីសមាបត្តិដ៏សេស មានព្រោះភវង្គ ។ ឯការចេញអំពីនិរោធ មានព្រោះផលសមាបត្តិដែលហូរមកអំពីវិបស្សនា ដូច្នោះ ទើបព្រះថេរៈសួរដល់ការចេញអំពីនិរោធនោះឯង ។ បទថា **សព្វនិមិត្តានំ** បានដល់ អារម្មណ៍ទាំងអស់ មានរូបជាដើម ។ បទថា **អនិមិត្តាយ ច ធាតុយា មនសិការោ** បានដល់ ការដាក់ចិត្តក្នុងនិព្វានធាតុដែលមិនមាននិមិត្តគ្រប់យ៉ាង ។ ព្រះថេរៈពោលសំដៅយកការដាក់ចិត្តដែលកើតព្រមនឹងផលសមាបត្តិ ដោយប្រការដូច្នេះ ។ ឈ្មោះថាលោកកាន់យកបឋមជ្ឈាន ដែលមាននិរោធជាបាទខាងក្រោមហើយ នេវ-សញ្ញានាសញ្ញាយតនៈ ដែលជាអនន្តរប្បច្ច័យនៃនិរោធ លោកក៏កាន់យកហើយ ។ ផលសមាបត្តិរបស់បុគ្គលដែលចេញអំពីនិរោធ លោកក៏កាន់យកក្នុងបទនេះឯងហើយដែរ ។ ក្នុងទីនេះគប្បីពោលដល់និរោធកថា ឯនិរោធ-

កថានេះ មកហើយក្នុងបដិសម្ភិទាមគ្គយ៉ាងនេះថា បញ្ញាដែលមានភាពស្ទាត់ជំនាញ ព្រោះហេតុប្រកបដោយកម្លាំងសមថៈ និងវិបស្សនាទាំង ២ ផង ព្រោះការរម្ងាប់នូវសង្ខារទាំង ៣ ផង ព្រោះញាណចរិយា ១៦ ផង ព្រោះសមាធិចរិយា ៩ ផង ឈ្មោះថា និរោធសមាបត្តិញ្ញាណ ដូច្នេះ ។ ឯពាក្យវិនិច្ឆ័យគ្រប់ជ្រុងជ្រោយនៃនិរោធកថានោះ លោកក៏បានពោលហើយ ក្នុងវិសុទ្ធិមគ្គ ។

ឥឡូវនេះ កាលទឹងសួរដល់សមាបត្តិសម្រាប់ប្រើប្រាស់ ទើបព្រះថេរៈពោលថា **កតិ បនាវុសោ បច្ចយា** ជាដើម ធម្មតាការតាំងនៅនៃផលសមាបត្តិរបស់បុគ្គលចេញចាកនិរោធមិនមាន ។ ការតាំងនៅ ប្រព្រឹត្តទៅ ១-២ វារៈចិត្តប៉ុណ្ណោះ ហើយក៏ធ្លាក់ចុះកាន់ភវង្គ សម្រាប់ភិក្ខុដែលអង្គុយរម្ងត់អរូបធម៌ដែលប្រព្រឹត្តទៅហើយ អស់ ៧ ថ្ងៃនេះ និងតាំងនៅក្នុងផលសមាបត្តិរបស់អ្នកចេញអំពីនិរោធមិនបានយូរ ។ តែក្នុងសមាបត្តិសម្រាប់ប្រើប្រាស់ ការកំណត់វេលាជារឿងសំខាន់ ។ ដូច្នោះ ឈ្មោះថា ការតាំងនៅនោះ មាន ព្រោះហេតុនោះ ទើបព្រះមហាកោដ្ឋិតៈពោលថា ម្នាលអាវុសោ បច្ច័យដែលឲ្យអនិមិត្តាចេតោវិមុត្តិតាំងនៅបានយូរ តើមានប៉ុន្មាន សេចក្តីថា បច្ច័យដើម្បីការតាំងនៅបានយូរនៃផលសមាបត្តិនោះ មានប៉ុន្មាន ។ ឯក្នុងការឆ្លើយប្រស្នានោះ លោកពោលដល់ការកំណត់វេលាថា ការបានតាក់តែងទុកពីខាងដើម ដូច្នេះ ។ ព្រះមហាកោដ្ឋិតៈសួរដល់ការចេញអំពីភវង្គ ក្នុងពាក្យថា **វុដ្ឋានាយ** នេះ ។ ក្នុងការឆ្លើយបញ្ហានោះ ព្រះសារីបុត្រក៏បានពោល

ដល់ការដាក់ចិត្ត ដែលកើតឡើងព្រមនឹងកវគ្គដោយនិមិត្ត មានរូបជាដើមថា ការយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង ។

[ ១៤៤ ] ក្នុងបទថា **យា ចាយំ អាវុសោ** នេះ ដូច្នេះ ព្រះមហាកោដ្ឋិតៈ សួរដល់អ្វី លោកសួរថា ក្នុងទីនេះ មិនមានពាក្យដទៃ ខ្ញុំនឹងសូមយកវត្ថុ ដែលពោលស្រេចហើយខាងដើមនោះឯង មកបញ្ចូលគ្នាតែមួយ ហើយទើបសួរ ។ ឯវត្ថុទាំងនេះ លោកពោលទីណា លោកពោលចេតោវិមុត្តិ ដែលមិនមានព្រំដែន កំណត់ក្នុងទីនេះថា ចាំនូវពណ៌ខៀវក៏បាន ពណ៌លឿង ពណ៌ក្រហម ពណ៌សក៏បាន ។ លោកពោលដល់ភាពជារបស់ទទេក្នុងសូត្រនេះថា ដឹងច្បាស់នូវអាកិញ្ចញ្ញា ។ ក្នុងទីនេះថា គប្បីដឹងអាកិញ្ចញ្ញាយតនៈ ដែលបរិកម្មថា អ្វីតិចតួចមិនមាន អ្វីតិចតួចមិនមាន ដោយភ្នែក គឺ បញ្ញា ។ ព្រះកោដ្ឋិតត្ថេរពោលដល់អនិមិត្តចេតោវិមុត្តិក្នុងព្រះសូត្រនេះថា ម្នាលអាវុសោ បច្ច័យនៃការចេញអំពីអនិមិត្តាចេតោវិមុត្តិមានប៉ុន្មាន លោកយកវត្ថុដែលពោលស្រេចហើយខាងដើមនោះឯង មកសង្គ្រោះចូលជាមួយគ្នាក្នុងទីនេះ រួចទើបសួរយ៉ាងនេះ ។ ព្រោះពោលថា លោកដាក់ការរួចផុតនោះហើយ ទើបសម្តែងការរួចផុតនេះក្នុងទីនោះៗ ឬ ទើបនៅមានវត្ថុដទៃទៀត ៤ យ៉ាង ដែលមានឈ្មោះតែមួយ ។ វត្ថុតែមួយ មានឈ្មោះ ៤ យ៉ាង ក៏មាន ។ ទើបលោកសួរដើម្បីឲ្យអ្នកឆ្លើយធ្វើវត្ថុមួយឲ្យជាក់ច្បាស់ ហើយប្រាប់ក្នុងទីនេះ ។ ក្នុងអដ្ឋកថា លោកធ្វើការសម្រេចចិត្ត ដូច្នេះ ។ ពាក្យក្នុងការឆ្លើយសំណួរនោះថា ម្នាលអាវុសោ អប្បមាណចេតោវិមុត្តិនេះ ឈ្មោះថា អប្បមាណ-

ចេតោវិមុត្តិ ព្រោះមិនមានប្រមាណនៃការផ្សាយទៅ ។ ពិតហើយ អប្បមាណាចេតោវិមុត្តិនេះ រមែងផ្សាយទៅក្នុងសត្វមិនមានកំណត់ចំនួន ឬផ្សាយទៅក្នុងសត្វមួយ រហូតដល់មិនមានសត្វសេសសល់ ។

បទថា **អយំ វុច្ចតាវុសោ អាកិញ្ចញ្ញា** គឺដែលឈ្មោះថា អាកិញ្ចញ្ញា ព្រោះមិនមានកង្វល់ក្នុងអារម្មណ៍ ។ បទថា **អត្តេន វា** គឺ អំពីខ្លួន ពោលគឺអត្តភាពបុរស និងបុគ្គលជាដើម ។ បទថា **អត្តនិយេន វា** បានដល់ ទទេចាករបស់ខ្លួន ពោលគឺ បរិក្ខារ មានចីវរជាដើម ។ បទថា **អនិមិត្តា** បានដល់ ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមានរាគនិមិត្តជាដើម ។ ព្រះថេរៈពោលសំដៅយកការចូលដល់អរហត្តផល ។ បទថា **នានត្ថា ចេវ នានាព្យញ្ជនា ច** បានដល់ ព្យញ្ជនៈក្តី អត្ថក្តី នៃធម៌ទាំងនោះផ្សេងគ្នា ។ ក្នុងការផ្សេងគ្នាទាំងនោះ ការផ្សេងគ្នានៃព្យញ្ជនៈជាក់ច្បាស់ហើយ ។ ឯអត្ថ គឺអប្បមាណាចេតោវិមុត្តិ ជាមហគ្គតៈ ។ ជារូបាវចរដោយភូមិ តែដោយអារម្មណ៍ មានសត្វបញ្ញត្តិជាអារម្មណ៍ ។ អាកិញ្ចញ្ញាដោយភូមិ ជាអរូបាវចរ ដោយអារម្មណ៍ មានអារម្មណ៍ដែលមិនគប្បីពោល ។ សុញ្ញតាដោយភូមិជា កាមាវចរ ដោយអារម្មណ៍ មានសង្ខារជាអារម្មណ៍ ។ សម្រាប់ក្នុងទីនេះ លោកសំដៅយកវិបស្សនាថា ភាពជារបស់ទទេ ។ អនិមិត្តា ដោយភូមិ ជាលោកុត្តរ ដោយអារម្មណ៍ មានព្រះនិព្វានជាអារម្មណ៍ ។ ក្នុងបទថា **រាគោ ខោ អាវុសោ បមាណករណោ** ជាដើម លោកពោលដល់វត្ថុដែលធ្វើការប្រមាណថា ប្រៀបដូចជើងភ្នំ មានទឹកស្អុយ ១៥ ប្រភេទ ជាទឹកមានពណ៌

ខ្មៅប្រាកដហាក់បីដូចមានជម្រៅរាប់រយព្យាម ដល់បុគ្គលដែលសម្លឹងមើល តែមិនមានទឹកត្រឹមតែលិចខ្នងជើង របស់បុគ្គលដែលយកឈើប្រត់ ឬខ្សែវាស់មើលឡើយ យ៉ាងណា សេចក្តីនោះក៏ដូចគ្នា កិលេស មានរាគៈជាដើម មិនទាន់កើតឡើងដរាបណា ដរាបនោះ ក៏មិនមាននរណាអាចនឹងស្គាល់បុគ្គលបាន ប្រាកដដូចព្រះសោតាបន្ន ដូចព្រះសកទាគាមី ដូចព្រះអនាគាមី ។ ល្គឹកណា រាគៈជាដើមកើតឡើងដល់បុគ្គលនោះ ទើបប្រាកដចេញមកថា ជាអ្នកតម្រេក ជាអ្នកខឹង ជាអ្នកវង្វេង ។ កាលតម្រេកជាដើមនោះ កើតឡើងសម្តែងប្រមាណនៃបុគ្គលថា បុគ្គលនេះ លំដាប់នេះ ដូចពោលមកនេះ ។

បទថា **យាវតា ខោ អាវុសោ អប្បមាណា ចេតោវិមុត្តិយោ** គឺ អប្បមាណចេតោវិមុត្ត មានប្រមាណត្រឹមណា ។ ឯអប្បមាណចេតោវិមុត្តិទាំងនោះមានប៉ុន្មាន មាន ១២ យ៉ាង គឺព្រហ្មវិហារ ៤ មគ្គ ៤ ផល ៤ ។ ទាំង ១២ យ៉ាងនោះ ព្រហ្មវិហារ ឈ្មោះថា អប្បមាណ ព្រោះការផ្សាយទៅមិនមានប្រមាណ ធម៌ដ៏សេស ឈ្មោះថា អប្បមាណ ព្រោះមិនមានកិលេសជាគ្រឿងធ្វើនូវប្រមាណ ។ ព្រះនិព្វានក៏ប្រមាណមិនបានដូចគ្នា ។ ឯចេតោ-វិមុត្តិ មិនមានក្នុងព្រះនិព្វាននោះ ដូច្នោះ ទើបលោកមិនរាប់ចូល ។ បទថា **អកុប្បា** គឺមិនកម្រើក សំដៅដល់ អរហត្តផលចេតោវិមុត្តិ ។ ឯអរហត្ត-ផលចេតោវិមុត្តនោះ ជាធំជាងធម៌ទាំងអស់ ដូច្នោះ ទើបលោកពោលថា ជាអគ្គធម៌ ។ បទថា **រាគោ ខោ អាវុសោ កិញ្ចនោ** គឺ រាគៈ កាលកើតឡើងហើយ រមែងបៀតបៀន ញាំញី រុករានបុគ្គល ដូច្នោះ ទើបលោក

ពោលថា ជាតួបៀតបៀន គឺនាំឲ្យកើតកង្វល់ ស្មុគស្មាញ ។ បានឮមកថា ពួកមនុស្សក្រំពុងនាំគ្នាយកគោបញ្ជាន់ស្រូវ តែងនាំគ្នាពោលថា អាខ្មៅចូល អាក្រហមចូល គប្បីជ្រាបអត្ថថា ញាំញី អត្ថថា បៀតបៀនដូចដែលពោលមកនេះ ។ តែក្នុងការប្រទូស្ត និងការវង្វេង ក៏មានទំនងដូចគ្នានេះឯង ។ ធម៌ ៩ យ៉ាង គឺ អាកិញ្ចញ្ញាយតនៈ ១ មគ្គ និងផលនីមួយៗ ៤ ឈ្មោះថា អាកិញ្ចញ្ញាចេតោវិមុត្តិ ។ ក្នុងធម៌ ៩ យ៉ាងនោះ អាកិញ្ចញ្ញាយតនៈ ឈ្មោះថា អាកិញ្ចញ្ញា ព្រោះមិនមានអារម្មណ៍នាំឲ្យកើតកង្វល់ គឺការបៀតបៀន ញាំញី រុករាន ស្មុគស្មាញណាមួយដល់ចិត្តឡើយ ។ មគ្គ និងផល ឈ្មោះថា អាកិញ្ចញ្ញា ព្រោះមិនមានការបៀតបៀន គឺព្រោះមិនមានកិលេស ជាគ្រឿងញាំញី និងជាគ្រឿងនាំឲ្យកើតនូវកង្វល់ ព្រះនិព្វានក៏ជាអាកិញ្ចញ្ញាដែរ ។ តែមិនមានការរួបផុតនៃចិត្ត គឺព្រោះចិត្តមិនមានក្នុងព្រះនិព្វាន ព្រះនិព្វានមិនមានចិត្ត ព្រោះដូច្នោះ ទើបមិនចាត់ចូល ។ ក្នុងបទថា **រាគោ ខោ អាវុសោ និមិត្តករណោ** ជាដើម សេចក្តីថា កាលតម្រេកមិនទាន់កើតដរាបណា ដរាបនោះ មិនមានអ្នកអាចដឹងបានថា ជាអរិយៈ ឬ បុថុជ្ជនឡើយ ។ ឯតម្រេកកាលកើតឡើង ក៏កើតឡើងហាក់ដូចកំពុងធ្វើនិមិត្ត សម្គាល់បានថា បុគ្គលនេះ ឈ្មោះថា ជាអ្នកមានតម្រេក ព្រោះដូច្នោះ ទើបលោកពោលថា

ជានិមិត្ត ដូចកូនគោ ២ ក្បាល ដែលមានរូបរាងដូចគ្នា ក្នុងត្រកូល ២ ដរាបណា មិនទាន់ធ្វើគ្រឿងសម្គាល់ដល់កូនគោទាំង ២ ក្បាលនោះ ក៏មិនមាននរណាដែលអាចដឹងបានថា នេះជាកូនគោរបស់ត្រកូលនោះ នេះរបស់ត្រកូលនេះ តែកាលណាយកដែកស្រួច មានចុងលំពែងជាដើម មកធ្វើគ្រឿងសម្គាល់ណាមួយ ក៏មានបុគ្គលអាចស្គាល់បាន យ៉ាងណា សេចក្ដីនេះ ក៏ដូចគ្នា ។ ក្នុងការប្រទូស្ត និងការវាង្វេង ក៏មានទំនងតែមួយដូចគ្នា ។

វិបស្សនា ១ អរូប ៤ មគ្គ ៤ និងផល ៤ រួមជា ១៣ ធម៌នេះ ឈ្មោះថា អនិមិត្តចេតោវិមុត្តិ ក្នុងធម៌ ១៣ នោះ វិបស្សនា ឈ្មោះថា មិនមាននិមិត្ត ព្រោះកើចកន្ទ្រាក់នូវនិច្ចនិមិត្ត សុខនិមិត្ត និងអត្តនិមិត្តបានហើយ ។ អរូប ៤ ឈ្មោះថា អនិមិត្ត ព្រោះមិនមានរូបនិមិត្ត ។ មគ្គ ផល ឈ្មោះថា អនិមិត្ត ព្រោះមិនមានកិលេសនិមិត្ត ។ ព្រះនិព្វានក៏មិនមានអ្វីជានិមិត្តដូចគ្នា ។ តែព្រះនិព្វាននោះ មិនមែនជាចេតោវិមុត្តិ ព្រោះដូច្នោះ ទើបលោកមិនសង្គ្រោះចូល ។ ហេតុអ្វី ទើបមិនចាត់ចេតោវិមុត្តិដែលជាសុញ្ញតផងចេតោវិមុត្តិដែលជាសុញ្ញតនោះ ឈ្មោះថា មិនចូលទៅក្នុងកិលេសគ្រប់ប្រភេទឡើយ ព្រោះពាក្យបាលីជាដើមថា ទទេចាករាគៈ ព្រោះដូច្នោះ ទើបមិនចាត់ចូលមួយផ្នែកដោយឡែក ។ បទថា **ឯកត្ថា** បានដល់ ដោយអំណាច

អារម្មណ៍ដែលមានអត្ថដូចគ្នាតែមួយ ។ ឯពាក្យទាំងអស់នេះ គឺ **អប្បមាណំ អាកិញ្ចញ្ញំ សុញ្ញតំ អនិមិត្តំ** ជាឈ្មោះរបស់ព្រះនិព្វានទាំងអស់ ។

ទើបសរុបបានថា តាមបែបនេះ អប្បមាណាក្នុងទីដទៃ អាកិញ្ចញ្ញាក្នុងទីដទៃ សុញ្ញតាក្នុងទីដទៃ អនិមិត្តាក្នុងទីដទៃ ទាំងអស់នេះ មានអត្ថតែមួយ ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ។

ព្រះថេរៈបញ្ចប់ទេសនាតាមអនុសន្ធិ ដូចដែលបានសម្ដែងមក ដោយប្រការដូច្នេះឯង ៕៚

## មហាវេទល្លសូត្រ ចប់

## សូត្រទី ៣ ចប់

# សុត្តន្តបិដក

## ចូឡវេទល្លសូត្រទី ៤

[ ១៤៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ឧបាសកឈ្មោះវិសាខ បានចូលទៅរកធម្មទិន្នាភិក្ខុនី លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំធម្មទិន្នាភិក្ខុនី ហើយក៏អង្គុយក្នុងទីដ៏សមគួរ ។

[ ១៤៦ ] លុះវិសាខឧបាសក អង្គុយក្នុងទីដ៏សមគួរហើយ ទើបទូលសួរធម្មទិន្នាភិក្ខុនី យ៉ាងនេះថា បពិត្រព្រះនាងជាម្ចាស់ ព្រះមានព្រះភាគតែងត្រាស់ថា សក្កាយៈ សក្កាយៈ បពិត្រព្រះនាងជាម្ចាស់ ធម៌ដូចម្តេចខ្លះ ដែលព្រះមានព្រះភាគត្រាស់ថា សក្កាយៈ ។ ធម្មទិន្នាភិក្ខុនីតបថា ម្នាលអាវុសោវិសាខ ឧបាទានក្ខន្ធ ៥ ប្រការ នេះឯង ដែលព្រះមានព្រះភាគត្រាស់ថា សក្កាយៈ ឧបាទានក្ខន្ធ ៥ គឺ រូបូបាទានក្ខន្ធ១ វេទនូបាទានក្ខន្ធ១ សញ្ញូ-បាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ១ ម្នាលអាវុសោវិសាខ ឧបាទានក្ខន្ធទាំង ៥ ប្រការ នេះឯងដែលព្រះមានព្រះភាគត្រាស់ថាសក្កាយៈ។ វិសាខឧបាសកក៏ត្រេកអរនឹងភាសិតរបស់ធម្មទិន្នាភិក្ខុនីថា ពីរោះណាស់ ព្រះនាងជាម្ចាស់ ហើយក៏បានសួរប្រស្នានឹងធម្មទិន្នាភិក្ខុនីតទៅទៀតថា បពិត្រព្រះនាងជាម្ចាស់ព្រះមានព្រះភាគទ្រង់តែងត្រាស់ថា ហេតុដែលនាំឲ្យកើតសក្កាយៈ ហេតុដែលនាំឲ្យកើតសក្កាយៈ បពិត្រព្រះនាងជាម្ចាស់ ធម៌ដូចម្តេចហ្ន៎ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាហេតុនាំឲ្យកើតសក្កាយៈ ។ ធម្មទិន្នាភិក្ខុនី

តបថា ម្នាលអាវុសោវិសាខ តណ្ហាដែលនាំឲ្យសត្វកើតក្នុងភពថ្មីទៀត ប្រកប ដោយនន្ទិរាគៈ មានសេចក្តីត្រេកអរក្នុងភពនោះៗ តណ្ហានោះ គឺកាមតណ្ហា១ ភវតណ្ហា១ វិភវតណ្ហា១ ម្នាលអាវុសោវិសាខ នេះឯងហើយ ដែលព្រះ មានព្រះភាគត្រាស់ថា ហេតុនាំឲ្យកើតសក្កាយៈ ។ បពិត្រព្រះនាងជាម្ចាស់ ព្រះមានព្រះភាគត្រាស់ថា ការរម្ងត់សក្កាយៈ ការរម្ងត់សក្កាយៈ បពិត្រព្រះ នាងជាម្ចាស់ ធម៌ដូចម្តេចហ្ន៎ ដែលព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងរម្ងត់ សក្កាយៈ ។ ម្នាលអាវុសោវិសាខ សេចក្តីនឿយណាយ និងការរម្ងត់ដោយ មិនសល់ ការលះបង់ ការជម្រុះចោល ការរួចស្រឡះ ការលែងអាឡោះ អាល័យចំពោះតណ្ហានោះឯង ម្នាលអាវុសោវិសាខ នេះឯងហើយ ដែលព្រះ មានព្រះភាគត្រាស់ថា ការរម្ងត់សក្កាយៈ ។ បពិត្រព្រះនាងជាម្ចាស់ ព្រះ មានព្រះភាគទ្រង់ត្រាស់ថា បដិបទា ជាដំណើរទៅកាន់ការរម្ងត់សក្កាយៈ បដិបទាជាដំណើរទៅកាន់ការរម្ងត់សក្កាយៈ បពិត្រព្រះនាងជាម្ចាស់ ធម្មជាត ដូចម្តេចហ្ន៎ ដែលព្រះមានព្រះភាគត្រាស់ថា បដិបទា ជាដំណើរទៅកាន់ សេចក្តីរម្ងត់សក្កាយៈ ។ ម្នាលអាវុសោវិសាខ មគ្គប្រកបដោយអង្គ ៨ ដ៏ ប្រសើរនេះឯង ដែលព្រះមានព្រះភាគត្រាស់ថា បដិបទាជាដំណើរទៅកាន់ សេចក្តីរម្ងត់សក្កាយៈ មគ្គដែលប្រកបដោយអង្គ ៨ នោះ គឺ សេចក្តីយល់ ត្រូវ ១ ការត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ ស្មារតីត្រូវ ១ ការតម្កល់ចិត្តនឹងត្រូវ ១ ។ បពិត្រព្រះនាងជាម្ចាស់ ឧបាទាននោះ គឺឧបាទានក្ខន្ធទាំង ៥ នោះឯង ឬក៏

ឧបាទានដោយឡែកអំពីឧបាទានក្ខន្ធទាំង ៥ ( នោះ ) ទេ ។ ម្នាលអាវុសោវិសាខ ឧបាទាននោះឯង មិនមែនជាឧបាទានក្ខន្ធទាំង ៥ នោះទេ ឯឧបាទាន ( នោះ ) សោត ក៏មិនមែនដោយឡែកអំពីឧបាទានក្ខន្ធទាំង ៥ ដែរ ម្នាលអាវុសោវិសាខ ឧបាទាននោះឯង មិនមែនជាឧបាទានក្ខន្ធទាំង ៥ នោះទេ តែឧបាទាននឹងញែកចេញអំពីឧបាទានក្ខន្ធ មិនបានដែរ ម្នាលអាវុសោវិសាខ សេចក្តីត្រេកត្រអាល ក្នុងឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា ឧបាទាន ក្នុងឧបាទានក្ខន្ធនោះ ។

[ ១៤៧ ] បពិត្រព្រះនាងជាម្ចាស់ ចុះសក្កាយទិដ្ឋិដូចម្តេច ។ ម្នាលអាវុសោវិសាខ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានជួបប្រទះនឹងពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌ព្រះអរិយៈ មិនបានហាត់ខ្លួនក្នុងធម៌របស់ព្រះអរិយៈ ទាំងមិនបានឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនបានហាត់ចិត្តក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូបថាខ្លួនខ្លះ ពិចារណាឃើញនូវខ្លួនថាមានរូបខ្លះ ពិចារណាឃើញរូបក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួនក្នុងរូបខ្លះ ពិចារណាឃើញវេទនា ... សញ្ញា ... សង្ខារទាំងឡាយ ... ពិចារណាឃើញវិញ្ញាណថាខ្លួនខ្លះ ពិចារណាឃើញខ្លួនជាមានវិញ្ញាណខ្លះ ពិចារណាឃើញវិញ្ញាណក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួនក្នុងវិញ្ញាណខ្លះ ម្នាលអាវុសោវិសាខ យ៉ាងនេះឯងហើយ ដែលហៅថាសក្កាយទិដ្ឋិ ។ បពិត្រព្រះនាងជាម្ចាស់ ដែលហៅថា មិនមានសក្កាយទិដ្ឋិដូចម្តេច ។ ម្នាលអាវុសោវិសាខ អរិយសាវកក្នុងលោកនេះ ជាអ្នកចេះដឹង បាន

ឃើញពួកព្រះអរិយៈ ឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ បានហាត់ចិត្តល្អក្នុងធម៌ព្រះអរិយៈ ទាំងបានជួបប្រទះនឹងពួកសប្បុរស ឈ្លាសវៃក្នុងធម៌របស់សប្បុរស បានហាត់ចិត្តដោយល្អក្នុងធម៌របស់សប្បុរស មិនបានពិចារណាឃើញនូវរូបថាខ្លួនខ្លះ មិនបានពិចារណាឃើញ នូវខ្លួនថាមានរូបខ្លះ មិនពិចារណាឃើញរូបក្នុងខ្លួនខ្លះ មិនពិចារណាឃើញខ្លួនក្នុងរូបខ្លះ មិនបានពិចារណាឃើញវេទនា .... សញ្ញា ... សង្ខារទាំងឡាយ ... មិនបានពិចារណាឃើញវិញ្ញាណថាខ្លួនខ្លះ មិនបានពិចារណាឃើញខ្លួនថាមានវិញ្ញាណខ្លះ មិនបានពិចារណាឃើញ វិញ្ញាណក្នុងខ្លួនខ្លះ និងមិនពិចារណាឃើញ ខ្លួនក្នុងវិញ្ញាណខ្លះ ម្នាលអាវុសោវិសាខ យ៉ាងនេះឯងហើយ ដែលហៅថា មិនមានសក្កាយទិដ្ឋិ ។

[ ១៤៨ ] បពិត្រព្រះនាងជាម្ចាស់ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្តេច ។ ម្នាលអាវុសោវិសាខ មគ្គដែលប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរនេះឯង គឺសេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ វាចាត្រូវ ១ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ស្មារតីត្រូវ ១ការតម្កល់ចិត្តនឹងត្រូវ ១ ។ បពិត្រព្រះនាងជាម្ចាស់ ចុះអដ្ឋង្គិកមគ្គដ៏ប្រសើរនោះ ជាសង្ខតធម៌ ឬជាអសង្ខតធម៌ ។ ម្នាលអាវុសោវិសាខ អដ្ឋង្គិកមគ្គដ៏ប្រសើរជាសង្ខតធម៌ ។ បពិត្រព្រះនាងជាម្ចាស់ ខន្ធទាំង ៣ ប្រការ លោកសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គដ៏ប្រសើរ ឬអដ្ឋង្គិកមគ្គដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង ៣ ប្រការវិញ ម្នាលអាវុសោវិសាខ ខន្ធទាំង ៣ ប្រការ

លោកមិនបានសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គដ៏ប្រសើរទេ ម្នាលអាវុសោវិសាខ តែអដ្ឋង្គិកមគ្គទាំង ៨ ប្រការ ដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង ៣ ប្រការវិញ ម្នាលអាវុសោវិសាខ សម្មាវាចា១ សម្មាកម្មន្តៈ១ សម្មាអាជីវៈ១ ធម៌ទាំង ( ៣ ) នេះ លោកសង្គ្រោះចូលក្នុងសីលក្ខន្ធ សម្មាវាយាមៈ១ សម្មាសតិ១ សម្មាសមាធិ១ ធម៌ទាំង( ៣ ) នេះ លោកសង្គ្រោះចូលក្នុងសមាធិក្ខន្ធ សម្មាទិដ្ឋិ១ សម្មាសង្កប្បៈ១ ធម៌ទាំង ( ២ ) នេះ លោកសង្គ្រោះចូលក្នុងបញ្ញាខន្ធ ។ បពិត្រព្រះនាងជាម្ចាស់ សមាធិដូចម្ដេច ពួកធម៌ជាសមាធិនិមិត្តដូចម្ដេច ពួកធម៌ជាសមាធិបរិក្ខារដូចម្ដេច សមាធិភាវនាដូចម្ដេច ។ ម្នាលអាវុសោវិសាខ សភាវៈដែលធ្វើចិត្តឲ្យនឹងនៅក្នុងអារម្មណ៍តែមួយហៅថា សមាធិ សតិប្បដ្ឋានទាំង៤ ហៅថា សមាធិនិមិត្ត សម្មប្បធាន ៤ ហៅថា សមាធិបរិក្ខារ ការធ្វើចិត្តឲ្យតម្កល់នឹង ការចម្រើន និងការធ្វើឲ្យច្រើន ចំពោះធម៌ទាំងនោះឯង ហៅថា សមាធិភាវនា ។

[ ១៤៩ ] បពិត្រព្រះនាងជាម្ចាស់ ចុះសង្ខារទាំងឡាយមានប៉ុន្មាន ។ ម្នាលអាវុសោវិសាខ សង្ខារទាំងឡាយនេះមាន ៣ គឺ កាយសង្ខារ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ។ បពិត្រព្រះនាងជាម្ចាស់ កាយសង្ខារតើដូចម្ដេច វចីសង្ខារដូចម្ដេច ចិត្តសង្ខារដូចម្ដេច ។ ម្នាលអាវុសោវិសាខ ខ្យល់ដង្ហើមចេញចូលហ្នឹងឯង ហៅថា កាយសង្ខារ វិតក្កៈ និងវិចារៈ ហៅថា វចីសង្ខារ សញ្ញា និងវេទនា ហៅថា ចិត្តសង្ខារ ។ បពិត្រព្រះនាងជាម្ចាស់ ព្រោះហេតុអ្វីបានជាខ្យល់ដង្ហើមចេញចូលហៅថា កាយសង្ខារ ព្រោះហេតុអ្វីបានជាវិតក្កៈ និង

វិចារៈហៅថាវចីសង្ខារ ព្រោះហេតុអ្វីបានជាសញ្ញា និងវេទនាហៅថាចិត្តសង្ខារ ។ ម្នាលអាវុសោវិសាខ ការដកដង្ហើមចេញចូលហ្នឹងឯង ជាធម៌ប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនុ៎ះជាធម៌ជាប់ទាក់ទងនឹងកាយ ព្រោះហេតុនោះបានជាខ្យល់ដកដង្ហើមចេញចូល ហៅថា កាយសង្ខារ ម្នាលអាវុសោវិសាខ បុគ្គលត្រិះរិះពិចារណាមុនសិន ទើបបញ្ចេញវាចា ( ក្រោយ ) ព្រោះហេតុនោះបានជាវិតក្ក និងវិចារៈ ហៅថា វចីសង្ខារ ឯសញ្ញា និងវេទនាជាធម៌ប្រព្រឹត្តទៅក្នុងចិត្ត ធម៌ទាំងនុ៎ះ ជាធម៌ជាប់ទាក់ទងនឹងចិត្ត ព្រោះហេតុនោះ បានជាសញ្ញា និងវេទនា ហៅថា ចិត្តសង្ខារ ។

[ ១៥០ ] បពិត្រព្រះនាងជាម្ចាស់ ចុះសញ្ញាវេទយិតនិរោធសមាបត្តិដូចម្តេច ។ ម្នាលអាវុសោវិសាខ ភិក្ខុដែលកំពុងចូលសញ្ញាវេទយិតនិរោធ ( នោះ ) មិនមានគំនិតយ៉ាងនេះថា អាត្មាអញនឹងចូលសញ្ញាវេទយិតនិរោធ ឬថា អាត្មាអញកំពុងចូលសញ្ញាវេទយិតនិរោធ ឬក៏ថាអាត្មាអញចូលសញ្ញាវេទយិតនិរោធហើយដូច្នេះឡើយ តែថាមុននឹងដល់និរោធសមាបត្តិនោះ ភិក្ខុនោះបានចម្រើនចិត្តយ៉ាងនោះ បានជាបង្អោនទៅដើម្បីជាបុគ្គលរលត់ចិត្តសង្ខារ ។ បពិត្រព្រះនាងជាម្ចាស់ ចុះភិក្ខុដែលចូលសញ្ញាវេទយិតនិរោធ ពួកធម៌ណារលត់មុន កាយសង្ខារ ឬវចីសង្ខារ ឬក៏ចិត្តសង្ខារ ( រលត់មុន ) ។ ម្នាលអាវុសោវិសាខ ភិក្ខុដែលចូលសញ្ញាវេទយិតនិរោធនោះ វចីសង្ខាររលត់មុនតមក ទើបកាយសង្ខារ ( រលត់ ) តពីនោះមកទៀត ទើបចិត្តសង្ខារ ( រលត់ )។ បពិត្រព្រះនាងជាម្ចាស់ ការចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិមកវិញ

ដោយប្រការដូចម្តេច ។ ម្នាលអាវុសោវិសាខ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ( នោះ ) មិនមានគំនិតយ៉ាងនេះថា អាត្មាអញនឹងចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ឬថា អាត្មាអញចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិឥឡូវនេះ ឬក៏ថា អាត្មាអញចេញហើយអំពីសញ្ញាវេទយិតនិរោធសមាបត្តិដូច្នេះឡើយ តែថា មុននឹងចេញអំពីនិរោធសមាបត្តិនោះ ភិក្ខុនោះចម្រើនចិត្តយ៉ាងនេះ បានជាបង្អោនចិត្តទៅ ដើម្បីជាបុគ្គលមានចិត្តសង្ខារឡើងវិញ ។ បពិត្រព្រះនាងជាម្ចាស់ ចុះភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធ ពួកធម៌ណាកើតមុន កាយសង្ខារ ឬវចីសង្ខារ ឬក៏ចិត្តសង្ខារ ( កើតមុន ) ។ ម្នាលអាវុសោវិសាខ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ( នោះ ) ចិត្តសង្ខារកើតមុន តមក ទើបកាយសង្ខារ ( កើត ) តអំពីនោះមកទៀត ទើបវចីសង្ខារ ( កើត ) ។ បពិត្រព្រះនាងជាម្ចាស់ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិមកវិញ មានផស្សៈប៉ុន្មានពាល់ត្រូវ ។ ម្នាលអាវុសោវិសាខ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិមកវិញ មានផស្សៈ ៣ ប្រការ ពាល់ត្រូវ គឺសុញ្ញតផស្សៈ ១ អនិមិត្តផស្សៈ ១ អប្បណិហិតផស្សៈ ១ ។ បពិត្រព្រះនាងជាម្ចាស់ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ចិត្ត (លោក) បង្អោនទៅរកអ្វី ទោរទន់ទៅរកអ្វី ឈមទៅរកអ្វី ។ ម្នាលអាវុសោវិសាខ ភិក្ខុដែលចេញអំពីសញ្ញាវេទយិតនិរោធសមាបត្តិ ចិត្តលោកបង្អោនទៅរកវិវេក ទោរទន់ទៅរកវិវេក ឈមទៅរកវិវេក ។

[ ១៥១ ] បពិត្រព្រះនាងជាម្ចាស់ វេទនា តើមានប៉ុន្មាន ។ ម្នាលអាវុសោវិសាខ វេទនានេះមាន ៣ ប្រការ គឺ សុខវេទនា១ ទុក្ខវេទនា១ អទុក្ខមសុខវេទនា១ ។ បពិត្រព្រះនាងជាម្ចាស់ ចុះសុខវេទនា តើដូចម្តេច ទុក្ខវេទនាដូចម្តេច អទុក្ខមសុខវេទនាដូចម្តេច ។ ម្នាលអាវុសោវិសាខ ធម្មជាតដែលទទួលអារម្មណ៍ ជាសុខដ៏ធ្ញាញ់ ប្រព្រឹត្តទៅក្នុងកាយ ឬប្រព្រឹត្តទៅក្នុងចិត្ត នេះហៅថា សុខវេទនា ម្នាលអាវុសោវិសាខ ធម្មជាតដែលទទួលអារម្មណ៍ជាទុក្ខមិនធ្ញាញ់ប្រព្រឹត្តទៅក្នុងកាយ ឬប្រព្រឹត្តទៅក្នុងចិត្ត នេះហៅថា ទុក្ខវេទនា ម្នាលអាវុសោវិសាខ ធម្មជាតដែលទទួលអារម្មណ៍ដែលធ្ញាញ់ ក៏មិនមែន មិនធ្ញាញ់ក៏មិនមែន ប្រព្រឹត្តទៅក្នុងកាយ ឬប្រព្រឹត្តទៅក្នុងចិត្ត នេះហៅថា អទុក្ខមសុខវេទនា ។ បពិត្រព្រះនាងជាម្ចាស់ ចុះសុខ-វេទនា មានអ្វីជាសុខ មានអ្វីជាទុក្ខ ។ ម្នាលអាវុសោវិសាខ សុខវេទនា មានកិរិយាឋិតនៅដដែលដែលជាសុខ មានការប្រែប្រួលទៅវិញជាទុក្ខ ទុក្ខ-វេទនាមានកិរិយាឋិតនៅជាទុក្ខ មានកិរិយាប្រែប្រួលទៅវិញជាសុខ ឯអទុក្ខ-មសុខវេទនា មានការដឹងច្បាស់ជាសុខ មានការមិនដឹងជាទុក្ខ ។ បពិត្រព្រះនាងជាម្ចាស់ ចុះអនុស័យអ្វីដេកសម្ងំនៅក្នុងសុខវេទនា អនុស័យអ្វីដេកសម្ងំនៅក្នុងទុក្ខវេទនា អនុស័យអ្វីដេកសម្ងំនៅក្នុងអទុក្ខមសុខវេទនា ។ ម្នាលអាវុសោវិសាខ រាគានុស័យដេកសម្ងំនៅក្នុងសុខវេទនា បដិឃានុស័យដេកសម្ងំនៅក្នុងទុក្ខវេទនា អវិជ្ជានុស័យដេកសម្ងំនៅក្នុងអទុក្ខមសុខវេទនា ។ បពិត្រព្រះនាងជាម្ចាស់ រាគានុស័យ សុទ្ធតែដេកសម្ងំនៅក្នុងសុខវេទនាទាំង

អស់ បដិឃានុស័យ សុទ្ធតែដេកសម្ងំនៅក្នុងទុក្ខវេទនាទាំងអស់ អវិជ្ជានុ-ស័យ សុទ្ធដេកសម្ងំនៅក្នុងអទុក្ខមសុខវេទនាទាំងអស់ ឬដូចម្តេច ។ ម្នាលអាវុសោវិសាខ រាគានុស័យ មិនសុទ្ធតែដេកសម្ងំនៅខាងក្នុងសុខវេទនាទាំងអស់ទេ បដិឃានុស័យ មិនសុទ្ធតែដេកសម្ងំនៅខាងក្នុងទុក្ខវេទនាទាំងអស់ទេ អវិជ្ជានុស័យ មិនសុទ្ធតែដេកសម្ងំនៅខាងក្នុងអទុក្ខមសុខវេទនាទាំងអស់ទេ ។ បពិត្រព្រះនាងជាម្ចាស់ ចុះអ្វីដែលបុគ្គលត្រូវលះបង់ដោយសុខវេទនា អ្វីដែលត្រូវលះបង់ដោយទុក្ខវេទនា អ្វីដែលត្រូវលះបង់ដោយអទុក្ខមសុខវេទនា ។ ម្នាលអាវុសោវិសាខ រាគានុស័យ ត្រូវលះបង់ដោយសុខវេទនា បដិឃា-នុស័យ ត្រូវលះបង់ដោយទុក្ខវេទនា អវិជ្ជានុស័យ ត្រូវលះបង់ដោយអទុក្ខមសុខវេទនា ។ បពិត្រព្រះនាងជាម្ចាស់ រាគានុស័យ ត្រូវលះបង់ដោយសុខវេទនាទាំងអស់ បដិឃានុស័យ ត្រូវលះបង់ដោយទុក្ខវេទនាទាំងអស់ អវិជ្ជានុស័យ ត្រូវលះបង់ដោយអទុក្ខមសុខវេទនាទាំងអស់ឬ ។ ម្នាលអាវុសោវិសាខ រាគានុស័យ មិនត្រូវលះបង់ដោយសុខវេទនាទាំងអស់ទេ បដិឃានុស័យ មិនត្រូវលះបង់ដោយទុក្ខវេទនាទាំងអស់ទេ អវិជ្ជានុស័យ មិនត្រូវលះបង់ដោយអទុក្ខមសុខវេទនាទាំងអស់ទេ ។ ម្នាលអាវុសោវិសាខ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងប់ស្ងាត់ចាកកាម ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំង-ឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារៈ មានបីតិ និងសុខដែលកើតអំពីវិវេក លោកលះបង់រាគៈ ដោយបឋមជ្ឈាននោះ ឯរាគានុស័យ ដេកសម្ងំនៅក្នុងបឋមជ្ឈាននោះមិនបានទេ ម្នាលអាវុសោ

វិសាខ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញដូច្នេះថា កាលណាហ្ន៎ អាត្មាអញនឹងបានចូលកាន់អាយតនៈ គឺអរហត្តដែលពួកព្រះអរិយៈ តែងចូលក្នុងកាលឥឡូវនេះ កាលបើភិក្ខុតាំងនូវសេចក្តីប្រាថ្នា ចំពោះពួកវិមោក្ខដ៏ប្រសើរដូច្នេះហើយ ទោមនស្សរមែងកើតឡើង ព្រោះសេចក្តីប្រាថ្នាជាបច្ច័យ ភិក្ខុនោះ រមែងលះបង់នូវបដិឃៈដោយទោមនស្ស ឯបដិឃានុស័យ ក៏ដេកសម្ងំនៅក្នុងទោមនស្សនោះមិនបានទេ ម្នាលអាវុសោវិសាខ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់សេចក្តីសុខផង លះបង់សេចក្តីទុក្ខផង រម្ងាត់សោមនស្ស និងទោមនស្សក្នុងកាលមុនផង ក៏ចូលកាន់ចតុត្ថជ្ឈាន ដែលឥតសុខ ឥតទុក្ខ មានតែសតិដ៏បរិសុទ្ធដោយឧបេក្ខា សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ភិក្ខុនោះ រមែងលះបង់អវិជ្ជាដោយចតុត្ថជ្ឈាននោះ អវិជ្ជានុស័យ ដេកសម្ងំនៅក្នុងចតុត្ថជ្ឈាននោះ មិនបានឡើយ ។

[ ១៥២ ] បពិត្រព្រះនាងជាម្ចាស់ ចុះសុខវេទនាមានអ្វីជាគ្រឿងប្រៀបធៀបឲ្យប្រហែលគ្នា ។ ម្នាលអាវុសោវិសាខ សុខវេទនាមានរាគៈជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ ចុះទុក្ខវេទនាមានអ្វីជាគ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខ ទុក្ខវេទនាមានបដិឃៈជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ ចុះអទុក្ខមសុខវេទនាមានអ្វីជាគ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខ អទុក្ខមសុខវេទនា មានអវិជ្ជាជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ ចុះអវិជ្ជាមានអ្វីជាគ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខ អវិជ្ជាមានវិជ្ជាជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ វិជ្ជា

មានអ្វីជាគ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខ វិជ្ជាមានវិមុត្តិជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ ចុះវិមុត្តិមានអ្វីជាគ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខ វិមុត្តិមានព្រះនិព្វានជាគ្រឿងប្រៀបធៀប ។ បពិត្រព្រះនាងជាម្ចាស់ ចុះនិព្វានមានអ្វីជាគ្រឿងប្រៀបធៀប ។ ម្នាលអាវុសោវិសាខ អ្នកសួរជ្រុលហួសពេកហើយ អ្នកណាក៏មិនអាចនឹងកាន់យកទីបំផុត របស់ប្រស្នាទាំងឡាយ ( នេះ ) បានទេ ម្នាលអាវុសោវិសាខ ព្រោះព្រហ្មចរិយធម៌ឈមទៅកាន់ព្រះនិព្វាន មានព្រះនិព្វានជាទីប្រព្រឹត្តទៅខាងមុខ មានព្រះនិព្វានជាទីបំផុត ម្នាលអាវុសោវិសាខ បើអ្នកត្រូវការគប្បីចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលសួរសេចក្តីនេះចុះ បើព្រះមានព្រះភាគទ្រង់ព្យាករដល់អ្នកយ៉ាងណា ត្រូវអ្នកចាំទុកនូវសេចក្តីនោះយ៉ាងនោះចុះ ។

[ ១៥៣ ] លំដាប់នោះឯង វិសាខឧបាសក បានត្រេកអររីករាយនឹងភាសិតរបស់ធម្មទិន្នាភិក្ខុនី ហើយក្រោកចាកអាសនៈ ថ្វាយបង្គំធម្មទិន្នាភិក្ខុនី ធ្វើប្រទក្សិណហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានបុញ្ញរាសី ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះវិសាខឧបាសកអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលពាក្យ ដែលខ្លួនបានចរចានឹងធម្មទិន្នាភិក្ខុនីទាំងប៉ុន្មាន ចំពោះព្រះមានព្រះភាគ ដោយសព្វគ្រប់ ។ លុះវិសាខឧបាសកក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងវិសាខឧបាសកយ៉ាងនេះថា ម្នាលវិសាខ ធម្មទិន្នាភិក្ខុនីជាបណ្ឌិត ម្នាលវិសាខ ធម្មទិន្នាភិក្ខុនីជាស្ត្រីមានប្រាជ្ញាច្រើន ម្នាលវិសាខ បើទុកជាអ្នកត្រឡប់សួរ

សេចក្តីនុ៎ះនឹងតថាគតវិញ តថាគតក៏ត្រូវព្យាករសេចក្តីនុ៎ះ ដូចសេចក្តីដែលនាងធម្មទិន្នាភិក្ខុនីព្យាករហើយ យ៉ាងនោះដែរ សេចក្តីនៃប្រស្នានោះ យ៉ាងហ្នឹងហើយ ចូរអ្នកចាំទុកនូវប្រស្នានុ៎ះយ៉ាងនេះចុះ ។ លុះព្រះមានព្រះភាគត្រាស់ភាសិតនេះហើយ វិសាខឧបាសកក៏ត្រេកអរនឹងភាសិតរបស់ ព្រះមានព្រះភាគ ។

## ចូឡវេទល្លសូត្រទី ៤ ចប់

# អដ្ឋកថា

## ចូឡវេទល្លសូត្រ

[ ១៤៥ ] ចូឡវេទល្លសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ជាដើម ។ ក្នុងបទទាំងនោះ បទថា **វិសាខោ ឧបាសកោ** បានដល់ ឧបាសក មានឈ្មោះយ៉ាងនេះថា វិសាខ ។ បទថា **យេន ធម្មទិន្នា** គឺចូលទៅរក ដល់ទីដែលភិក្ខុនី ឈ្មោះ ធម្មទិន្នានៅ ។

វិសាខនេះ គឺជានរណា នាងធម្មទិន្នាជានរណា ហេតុអ្វី ទើបចូលទៅ រក ។ កាលនាងធម្មទិន្នានៅជាគ្រហស្ថ វិសាខជាម្ចាស់នៃផ្ទះ គឺជាស្វាមី ។ កាលព្រះមានព្រះភាគអង្គនោះ បានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ហើយ ទ្រង់បង្វិលនូវធម្មចក្រដ៏ប្រសើរ ទ្រង់បានដឹកនាំកុលបុត្រ មានយសកុលបុត្រ ជាដើម ទ្រង់យាងដល់តំបន់ឧរុវេលា ។ ក្នុងទីនោះ ទ្រង់បានទូន្មានជដិល មួយពាន់នាក់ ហើយធ្វើពុទ្ធដំណើរទៅកាន់ក្រុងរាជគ្រឹះ ជាមួយបុរាណជដិល-ភិក្ខុ ដែលជាខីណាស្រព ហើយទ្រង់សម្ដែងធម៌ថ្វាយព្រះបាទពិម្ពិសារមហារាជ ដែលទ្រង់យាងមក មួយអន្លើនឹងបរិស័ទមួយសែនពីរម៉ឺននាក់ ដើម្បីគាល់ ព្រះសម្ពុទ្ធ ។ ក្នុងមួយសែនពីរម៉ឺននាក់ ដែលមកជាមួយព្រះរាជាក្នុងកាល នោះ ១ ម៉ឺននាក់ ប្រកាសខ្លួនជាឧបាសក ។ ១ សែន ១ ម៉ឺននាក់ មួយ អន្លើដោយព្រះបាទពិម្ពិសារតាំងនៅក្នុងសោតាបត្តិផល ។ ឧបាសកនេះ ជា មនុស្សម្នាក់ ក្នុងចំនួនបុគ្គលដែលតាំងនៅក្នុងសោតាបត្តិផលនោះ ក្នុងកាល គាល់គ្រាដំបូងនោះឯង ។ ក្នុងថ្ងៃមួយ ក៏បានស្ដាប់ធម៌សម្រេចសកទាគាមិ-

ផល ថ្ងៃក្រោយមកទៀត បានស្តាប់ធម៌ ទើបបានតាំងនៅក្នុងអនាគាមិផល កាលបានជាព្រះអនាគាមីហើយ មកកាន់ផ្ទះ មិនបានមកដូចថ្ងៃដទៃ ដែលសម្លឹងមើលនោះ មើលនេះ សើចញញឹមញញែម ដើរចូលមក តែរទៅជាមនុស្សស្ងប់ឥន្ទ្រិយ មានចិត្តស្ងប់ ដើរសង្រួមចូលទៅ ។

នាងធម្មទិន្នាបើកបង្អួចបណ្តើរ សម្លឹងមើលទៅត្រង់ផ្លូវបណ្តើរ ឃើញហេតុការណ៍ក្នុងការមកនៃឧបាសកហើយ ក៏គិតថា មានរឿងអ្វីហ្ន៎ កាលឈរត្រង់ក្បាលជណ្តើរ បានធ្វើការស្វាគមន៍បណ្តើរ ក៏លាដៃចេញទៅ ។ ឧបាសកដកដៃរបស់ខ្លួនចេញ ។ នាងគិតថា អញនឹងដឹងក្នុងពេលបរិភោគអាហារពេលព្រឹក ។ អំពីមុនមក ឧបាសក រមែងទទួលទានជាមួយនាង តែថ្ងៃនោះមិនព្រមសម្លឹងមើលនាង ធ្វើហាក់បីដូចយោគាវចរភិក្ខុ បរិភោគម្នាក់ឯងប៉ុណ្ណោះ ។ នាងគិតថា ពេលដេកអញនឹងដឹង ឧបាសកមិនចូលបន្ទប់ដែលមានសិរីនោះ ប្រើឲ្យរៀបចំបន្ទប់ដទៃ ឲ្យរៀបចំគ្រែតូច ដ៏សមគួរហើយដេក ។

ឧបាសិកាគិតថា មានរឿងអ្វីហ្ន៎ បុរសនេះ មានការប្រាថ្នាខាងក្រៅ ឬត្រូវបុគ្គលជាទីស្រឡាញ់ណាមួយញុះញង់ឲ្យបែកគ្នា ឬអាត្មាអញនេះឯងមានកំហុសណាមួយ ហើយក៏ទោមនស្សយ៉ាងខ្លាំងក្លា សម្រេចចិត្តថា អស់កាល ១ ថ្ងៃ ២ ថ្ងៃ ដែលបុរសនេះនៅនេះឯង នឹងត្រូវដឹងគ្នាឲ្យបាន ហើយទើបចូលទៅកាន់ទីបម្រើ ថ្វាយបង្គំហើយ ក៏ឈរនៅក្នុងចំណែកម្ខាង ឧបាសកសួរថា ធម្មទិន្នា ហេតុអ្វី ទើបនាងមកខុសកាលដូច្នេះ ។ នាងធម្មទិន្នាពោលថា បពិត្រអយ្យបុត្រ ខ្ញុំមក លោកមិនដូចមនុស្សពីមុន ខ្ញុំសូមសួរលោក

បន្តិចចុះថា លោកមានការប្រាថ្នាខាងក្រៅឬ ។ ឧបាសកពោលថា ធម្មទិន្នា ខ្ញុំមិនមានប្រាថ្នាខាងក្រៅទេ ។ នាងធម្មទិន្នាពោលថា មានអ្នកដទៃជាអ្នកញុះញង់ឬ ឧបាសកពោលថា សេចក្តីនេះក៏មិនមាន ។ នាងធម្មទិន្នាពោលថា បើដូច្នោះ ខ្ញុំនេះឯង មានកំហុសអ្វីមួយឬ ឧបាសកពោលថា សូម្បីនាងក៏មិនមានកំហុស ។ នាងធម្មទិន្នាពោលថា ចុះហេតុអ្វី គ្រាន់តែធ្វើការនិយាយចរចា ប្រាស្រ័យតាមប្រក្រតីជាមួយខ្ញុំ មិនបាន ។

ឧបាសកគិតថា ឈ្មោះថា លោកុត្តរធម៌នេះ ជាការៈធ្ងន់ មិនគប្បីបើកបង្ហាញ តែបើអាត្មាអញមិនប្រាប់ ធម្មទិន្នានេះនឹងបែកហឫទ័យ ស្លាប់ក្នុងទីនេះឯង ដើម្បីអនុគ្រោះនាង ទើបប្រាប់ថា ធម្មទិន្នា ខ្ញុំស្តាប់ធម្មទេសនារបស់ព្រះសាស្តា ហើយបានសម្រេចលោកុត្តរធម៌ អ្នកបានសម្រេចលោកុត្តរធម៌នោះហើយ មិនអាចធ្វើតាមបែបលោកិយជនយ៉ាងនេះបានឡើយ បើនាងត្រូវការទ្រព្យចំណែករបស់នាង ៤ រយលាន ចំណែករបស់ខ្ញុំ ៤ រយលាន រួមគ្នាហើយ មានដល់ ៨០ កោដិ នាងជាអ្នកជំក្នុងទីនេះ ហើយចូរតាំងនៅក្នុងតំណែងជាមេផ្ទះ ឬតំណែងជាប្អូនស្រីរបស់ខ្ញុំក៏បាន ខ្ញុំនឹងសូមចិញ្ចឹមជីវិតដោយត្រឹមតែដុំបាយដែលនាងឲ្យ បើនាងមិនធ្វើដូចដែលខ្ញុំនិយាយមក ក៏ចូរយកភោគៈទាំងនេះ ទៅកាន់ត្រកូលក៏បាន ហើយបើនាងមានសេចក្តីត្រូវការបុរសខាងក្រៅ ខ្ញុំក៏តាំងនាងទុកក្នុងតំណែងប្អូនស្រី ឬតំណែងកូនស្រី ហើយចិញ្ចឹមរក្សា ។

នាងគិតថា បុរសធម្មតាមិនមានអ្នកណានិយាយយ៉ាងនេះ បុរសនេះគង់

ចាក់ដុះលោកុត្តរធម៌ដោយពិត បុរសប៉ុណ្ណោះឬដែលគប្បីចាក់ដុះធម៌នោះបាន ឬស្ត្រីតែស្រីក៏អាចចាក់ដុះបានដែរ ទើបនិយាយជាមួយវិសាខថា ធម៌នោះ បុរសប៉ុណ្ណោះឬហ្ន៎ដែលគប្បីបាន ឬមួយក៏ស្រីអាចបានដែរ ឧបាសកពោល ថា ធម្មទិន្នា នាងនិយាយអ្វី បុគ្គលដែលជាអ្នកបដិបត្តិនោះ រមែងជាទាយាទ របស់ធម៌នោះ អ្នកដែលមានឧបនិស្ស័យក៏រមែងបានទទួលធម៌នោះ ។ ធម្ម-ទិន្នាពោលថា បើដូច្នោះ សូមលោកយល់ព្រមឲ្យខ្ញុំបួសចុះ ឧបាសកពោល ថា សាធុ ប្រពៃហើយនាង ខ្ញុំក៏ចង់ដឹកនាំនាងក្នុងផ្លូវនេះដូចគ្នា តែមិនទាន់ ដឹងចិត្តនាង ទើបមិននិយាយ ។ ហើយក៏ទៅគាល់ព្រះបាទពិម្ពិសារក្នុងខណៈ នោះឯង ថ្វាយបង្គំហើយ ក៏បានឈរនៅក្នុងចំណែកម្ខាង ព្រះរាជាត្រាស់សួរ ថា គហបតី ហេតុអ្វីមកខុសកាល ដូច្នេះ វិសាខពោលថា បពិត្រសម្មតិទេព នាងធម្មទិន្នាពោលថា ខ្ញុំនឹងបួស ។ ព្រះរាជាពោលថា នាងសមគួរបានអ្វីហ្ន៎ វិសាខពោលថា មិនមានអ្វីដទៃទេ បានត្រឹមវិមាស និងប្រាប់ឲ្យតាក់តែងព្រះ នគរ ក៏សមគួរណាស់ទៅហើយ ។

ព្រះរាជាប្រទានវិមាស ហើយបញ្ជាឲ្យរៀបចំតុបតែងព្រះនគរ ។ វិសាខ ឲ្យនាងធម្មទិន្នាងូតទឹកក្រអូប ប្រដាប់ខ្លួនដោយគ្រឿងសម្អាងគ្រប់យ៉ាង ឲ្យ អង្គុយលើវិមាស ហែហមដោយពួកញាតិ បូជាដោយផ្កាក្រអូបជាដើម បណ្តើរៗ ដូចធ្វើដល់ពួកអ្នកក្រុង ទៅកាន់សម្នាក់ពួកភិក្ខុនី ហើយពិតថេរីវាចា ថា បពិត្រអ្នកនាងម្ចាស់ សូមបំបួសធម្មទិន្នាផងចុះ ពួកភិក្ខុនីពោលថា នែ គហបតី ខុសម្តង ឬពីរដង ក៏គួរអត់ឱនគ្នា ។ វិសាខឧបាសកប្រាប់ថា បពិត្រ

អ្នកនាងម្ចាស់ មិនមានកំហុសអ្វីទេ នាងបួសដោយសទ្ធាទេតើ ។ គ្រានោះ ទើបភិក្ខុនីអ្នកប្រតិពលមួយរូបប្រាប់តចបញ្ចកកម្មដ្ឋាន ឲ្យកោរសក់ ហើយឲ្យបួស ។ វិសាខពោលថា បពិត្រអ្នកនាងម្ចាស់ ព្រះមានព្រះភាគត្រាស់ព្រះធម៌ល្អហើយ សូមនាងត្រេកអរចុះ ថ្វាយបង្គំហើយ ចៀសចេញទៅ ។

តាំងអំពីថ្ងៃដែលនាងបួសហើយ លាភសក្ការៈក៏កើតឡើង ព្រោះហេតុនោះ ទើបនាងរវល់រហូតរកឱកាសធ្វើសមណធម៌មិនបាន ។ ពេលនោះ ទើបព្រះថេរីដែលជាអាចារ្យ និងឧបជ្ឈាយ៍នាំនាងទៅកាន់ស្រុកក្រៅ ហើយក៏ឲ្យរៀនកម្មដ្ឋានតាមគាប់ចិត្ត ក្នុងអារម្មណ៍ ៣៨ យ៉ាង ផ្តើមធ្វើសមណធម៌សម្រាប់នាងលំបាកមិនយូរ ព្រោះមានអភិនីហារបរិបូណ៌ ។

សេចក្តីសង្ខេបមានដូច្នេះថា ក្នុងកប្បទី ១ សែន រាប់អំពីកប្បនេះទៅព្រះសាស្តាព្រះនាមថាបទុមុត្តរៈ ទ្រង់កើតឡើងក្នុងលោក ។ គ្រានោះ នាងធម្មទិន្នានេះ ជាស្រីបម្រើក្នុងត្រកូលមួយ លក់សក់របស់ខ្លួនហើយ ថ្វាយទានដល់ព្រះអគ្គសាវក ឈ្មោះសុជាតត្ថេរ ហើយបានធ្វើនូវសេចក្តីប្រាថ្នា ។ ព្រោះដល់ព្រមដោយអភិនីហារនៃការប្រាថ្នានោះ ទើបនាងមិនលំបាកច្រើន ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចជាព្រះអរហន្ត ហើយគិតថា អាត្មាអញបួសក្នុងសាសនាព្រោះប្រយោជន៍ណា ប្រយោជន៍នោះអញដល់ទីបំផុតហើយ អញនៅស្រុកក្រៅ នឹងមានប្រយោជន៍អ្វី ពួកញាតិរបស់អញនឹងធ្វើបុណ្យ ។ សូម្បីភិក្ខុនីសង្ឃ ក៏មិនលំបាកដោយបច្ច័យ អញនឹងទៅកាន់ក្រុងរាជគ្រឹះ ហើយក៏បាននាំភិក្ខុនីសង្ឃទៅកាន់ក្រុងរាជគ្រឹះនោះឯង ។

វិសាខបានឮដំណឹងថា នាងធម្មទិន្នាមកហើយ ទើបគិតថា នាងបួស ហើយទៅស្រុកក្រៅ មិនបានប៉ុន្មានផង ក៏ត្រឡប់មក តើមានរឿងអ្វីហ្ន៎ ។ ហើយក៏បានទៅកាន់សម្នាក់ភិក្ខុនីជាលើកទី ២ ។ ព្រោះហេតុនោះ ទើបព្រះអានន្ទពោលថា គ្រានោះឯង ឧបាសកឈ្មោះវិសាខ បានចូលទៅរកធម្មទិន្នាភិក្ខុនីដល់លំនៅ ដូច្នេះ ។

[ ១៤៦ ] បទថា **ឯតទវោច** គឺបានពោលពាក្យជាដើមថា សក្កាយៈ នេះ ។ ហេតុអ្វី ទើបពោលយ៉ាងនេះ បានឮថា ឧបាសកគិតយ៉ាងនេះថា បើសួរយ៉ាងនេះថា បពិត្រអ្នកនាងម្ចាស់ អ្នកនាងនៅត្រេកអរឬ ឬមិនត្រេកអរទេ មិនមែនជាកិច្ចរបស់បណ្ឌិត អញនឹងបង្អោនទៅក្នុងឧបាទានក្ខន្ធ ៥ ហើយសួរបញ្ហា ដោយការដោះស្រាយបញ្ហានោះឯង អញនឹងដឹងថា នាងនៅមានការត្រេកអរ ឬមិនត្រេកអរ ទើបពោលដូច្នោះ ។ លុះនាងធម្មទិន្នាបានស្តាប់ពាក្យនោះ ក៏មិនពោលថា នែវិសាខ ខ្ញុំទើបតែបួសមកមិនយូរ នឹងដឹងកាយខ្លួន ឬកាយអ្នកដទៃអំពីណា ឬក៏ពោលថា សូមអ្នកទៅរកសាកសួរព្រះថេរីដទៃចុះ កាលតាំងនៅក្នុងវិស័យនៃបដិភាណ ក៏ឆ្លើយនូវបញ្ហា ដូចទទួលរបស់ដែលគេផ្ញើ ដូចស្រាយនូវអន្ទាក់ ដូចក្ការផ្លូវដរីក្នុងទីស្មុក ដូចក្ដិះសត្វរពីងដោយចុងដាវ ទើបពោលថា ម្នាលអាវុសោវិសាខ ឧបាទានក្ខន្ធទាំង ៥ នេះឯង ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បញ្ច** ជាពាក្យកំណត់ក្នុងការរាប់ ។ បទថា **ឧបាទានក្ខន្ធា** បានដល់ គប្បីធ្វើឲ្យអដ្ឋកថាឧបាទានក្ខន្ធពិស្តារ ហើយពោល

ក្នុងទីនេះ ដោយន័យជាដើមយ៉ាងនេះថា ខន្ធដែលមានឧបាទានជាបច្ច័យ ឯ អដ្ឋកថានៃឧបាទានក្ខន្ធនោះ លោកបានពង្រីកយ៉ាងពិស្តារ ក្នុងវិសុទ្ធិមគ្គនោះឯង ព្រោះដូច្នោះ គប្បីជ្រាបដោយន័យ ដែលលោកធ្វើឲ្យពិស្តារ សម្រេចហើយ ក្នុងវិសុទ្ធិមគ្គនោះចុះ ។ ពាក្យដែលគប្បីពោលក្នុងសក្កាយសមុទយៈជាដើមនោះ ក៏បានពោលស្រេចហើយក្នុងទីនោះ ខាងដើមដូចគ្នា ។ កាលវិសាខបានស្តាប់ការបកស្រាយសច្ចៈ ៤ នេះហើយ ក៏ជ្រាបថា ព្រះថេរីត្រេកអរហើយ ព្រោះថា បុគ្គលដែលអផ្សុកមិនត្រេកអរក្នុងព្រះពុទ្ធសាសនានោះ មិនអាចឆ្លើយបញ្ហាដែលសួរហើយសួរទៀតបានឡើយ ដូចយកចន្ទាសមកដកសក់ស្កូវមួយសរសៃៗ ដូចជញ្ជូនខ្សាច់ចេញអំពីជើងភ្នំសិនេរុ ។ ព្រោះសច្ចៈ ៤ យ៉ាងនេះ ប្រាកដហើយក្នុងព្រះពុទ្ធសាសនា ដូចព្រះចន្ទ និងព្រះអាទិត្យប្រាកដក្នុងលោក ព្រោះថា បុគ្គល មានព្រះមានព្រះភាគក្តី ព្រះមហាថេរៈទាំងឡាយក្តី ដែលនៅកណ្តាលបរិស័ទ រមែងប្រកាសតែសច្ចៈប៉ុណ្ណោះ ភិក្ខុសង្ឃក៏ឲ្យពួកកុលបុត្ររៀនប្រស្នាថា អ្វីឈ្មោះថា ៤ គឺអរិយ-សច្ច ៤ តាំងអំពីថ្ងៃដែលបួសទៅ ។ វិសាខគិតថា នាងធម្មទិន្នានេះ ក៏ជាបណ្ឌិតអ្នកឈ្លាស តាំងនៅក្នុងភាពជាអ្នកឈ្លាសក្នុងឧបាយ បាននាំយកន័យមកហើយ ក៏អាចពោលដោយគន្លងដែលបានស្តាប់មកហើយ ដូច្នោះ ទើបបុគ្គលណាម្នាក់ មិនអាចនឹងដឹងនូវការចាក់ធ្លុះអរិយសច្ចរបស់នាង ដោយហេតុមានប្រមាណប៉ុណ្ណេះ ឯអាត្មាអញ ក៏អាចដឹងបានដោយការឆ្លើយប្រស្នាដែលទាក់ទងនឹងការចែកសច្ចៈ កាលនឹងត្រឡប់ទៅកាន់សច្ចៈទាំង ២ ដែល

ពោលខាងដើម ធ្វើឲ្យជាកំបាំង ហើយសួរថា ខ្ញុំនឹងសួរបញ្ហាដែលមានកំណួច ទើបពោលពាក្យថា បពិត្រព្រះនាងជាម្ចាស់ ឧបាទាននោះ ដូច្នេះជាដើម ។

ក្នុងការឆ្លើយបញ្ហានោះ ព្រះថេរីឆ្លើយថា នែវិសាខ ទុំះឯង មិនមែនឧបាទានឡើយ មានពាក្យអធិប្បាយថា ទុំះមិនមែនឧបាទានឡើយ តែជាខន្ធដោយឡែក ព្រោះជាសភាវៈដែលជាឯកទេសបាកកងសង្ខារនៃឧបាទាន ហើយឧបាទានក៏មិនមែនអ្វីដទៃ ក្រៅអំពីឧបាទានក្ខន្ធទាំង ៥ ។ ព្រោះបើវត្ថុនោះឯងគប្បីជាឧបាទានសោត សភាវៈ មានរូបជាដើម ក៏គប្បីជាឧបាទានផងដែរ ។ បើឧបាទានគប្បីផុតទៅអំពីរូបជាដើមសោត ក៏នឹងជាខន្ធវិមុត្តិ ដូចគ្នានឹងអនុស័យ បញ្ញត្តិ និងព្រះនិព្វាន ដែលមិនប្រកបជាមួយចិត្តក្នុងសម័យដទៃ ឬបើមិនដូច្នោះទេ ក៏ត្រូវបញ្ញត្តខន្ធទី ៦ បន្ថែមទៀត ព្រោះដូច្នោះ ទើបនាងធម្មទិន្នាថេរីឆ្លើយយ៉ាងនេះ ។

កាលបានស្តាប់ពាក្យរបស់នាង វិសាខក៏ដល់នូវការប្រាកដក្នុងចិត្តថា ព្រះថេរីនេះបានត្រាស់ដឹងហើយ ហើយគិតថា បុគ្គលដែលមិនមែនព្រះខីណាស្រព មិនដឹង មិនឃើញ និងធ្វើឲ្យពិស្តារ ប្រៀបដូចអង្រួនប្រទីប ១ ពាន់ដួងឲ្យញាប់ញ័រ មិនអាចដោះស្រាយប្រស្នាដែលកំបាំង និងត្រៃលក្ខណ៍នាំមកនូវភាពជ្រាលជ្រៅបែបនេះបានឡើយ ។ តែនាងធម្មទិន្នានេះដល់ទីបំផុត គឺព្រះនិព្វាន បាននូវទីពឹងក្នុងសាសនា សម្រេចបដិសម្ភិទា ដល់នូវភាពក្លាហាន កម្ចាត់នូវកត ជាមហាខីណាស្រព អាចដោះស្រាយប្រស្នាដែលអាត្មាអញសាកសួរ ទើបគិតថា ឥឡូវនេះ អញនឹងសួរបញ្ហាដ៏កំបាំងនឹងនាង

ទៀត កាលសួរបញ្ហា ទើបពោលពាក្យថា **កថំ បនយ្យេ** ដូច្នេះជាដើម ។

[ ១៤៧ ] ក្នុងការឆ្លើយបញ្ហានោះ បទថា **អស្សុតវា** ជាដើម គឺបុគ្គលមិនបានស្តាប់ហើយ លោកបានពោលឲ្យពិស្តារហើយ ក្នុងមូលបរិយាយសូត្រនោះឯង ។ បទថា **រូបំ អត្តតោ សមនុបស្សតិ** គឺបុគ្គលខ្លះក្នុងលោកនេះពិចារណាឃើញរូបដោយភាពជាខ្លួន ពិចារណាឃើញរូប និងខ្លួនជាវត្ថុមិនមែន ២ ថា រូបយ៉ាងណា ខ្លួនក៏យ៉ាងនោះ ខ្លួនយ៉ាងណា រូបក៏យ៉ាងនោះ ។ ប្រៀបដូចចង្កៀងកំពុងឆេះ អណ្តាតភ្លើងយ៉ាងណា ពន្លឺក៏យ៉ាងនោះ ពន្លឺយ៉ាងណា អណ្តាតភ្លើងក៏យ៉ាងនោះ សេចក្តីនេះយ៉ាងណា បុគ្គលខ្លះក្នុងលោកនេះពិចារណាឃើញរូប ដោយភាពជាខ្លួន ពិចារណាឃើញ ... មិនមែន ២ យ៉ាង ដូច្នេះ ទើបឈ្មោះថា រមែងឃើញដោយវិបស្សនាក្នុងទិដ្ឋិថា រូបជាតួខ្លួនយ៉ាងនេះ ។ ឬពិចារណាឃើញថា ខ្លួនមានរូប ទើបកាន់យកអរូបថាជាខ្លួនហើយពិចារណាឃើញខ្លួនមានរូប ដូចឃើញដើមឈើមានម្លប់ ឬ ឃើញថារូបក្នុងខ្លួន ទើបកាន់យកអរូបនោះឯងថាជាខ្លួន ទើបឈ្មោះថា រមែងពិចារណាឃើញរូបក្នុងខ្លួន ដូចហិតក្លិនក្នុងផ្កា ឬឃើញថា ខ្លួនក្នុងរូប ទើបកាន់យកអរូបនោះឯងថាជាខ្លួន ទើបឈ្មោះថា រមែងពិចារណាឃើញ ខ្លួននោះក្នុងរូបដូចឃើញកែវមណីក្នុងជប សូម្បីក្នុងការពិចារណាថា វេទនាជាខ្លួនជាដើមក៏មានទំនងដូចគ្នានោះឯង ។ ក្នុងបទទាំងនោះ បទថា **រូបំ អត្តតោ សមនុបស្សតិ** លោកពោលដល់រូបសុទ្ធៗ ប៉ុណ្ណោះ ថាជាខ្លួន ។ លោកពោលដល់អរូបថាជាខ្លួនក្នុងទី ៧ អន្លើទាំងនេះ គឺរមែងពិចារណាឃើញខ្លួនមានរូប

រូបមានក្នុងខ្លួន ខ្លួនមានក្នុងរូប វេទនាដោយភាពជាខ្លួន សញ្ញា សង្ខារ វិញ្ញាណ ដោយភាពជាខ្លួន លោកពោលដល់រូប និងអរូប ដែលលាយឡំគ្នា ជាជាខ្លួន មាន ១២ អន្ទើ ដោយអំណាចនៃខន្ធទាំង ៣ ក្នុងចំនួនខន្ធ ៤ យ៉ាងនេះ គឺខ្លួនមានវេទនា វេទនាមានក្នុងខ្លួន ខ្លួនមានក្នុងវេទនា ដូច្នេះ ។

ក្នុងពាក្យថា រមែងពិចារណាឃើញរូបដោយភាពជាខ្លួន រមែងពិចារណាឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយភាពជាខ្លួននោះ លោកសម្តែងឧច្ឆេទទិដ្ឋិក្នុងឋាន: ៥ ក្នុងឋាន:ដ៏សេស លោកសម្តែងសស្សតទិដ្ឋិ ។ ដោយប្រការដូច្នេះ ក្នុងទីនេះ ទើបមានភវទិដ្ឋិ ១៥ វិភវទិដ្ឋិ ៥ យ៉ាង ។ ក្នុងបទថា **ឩ រូបំ អត្តតោ** បានដល់ រមែងពិចារណាថា មិនទៀង ជាទុក្ខ ជាអនត្តា ដោយអាការគ្រប់យ៉ាង គឺ រមែងមិនពិចារណាឃើញ ៥ យ៉ាងទាំងនេះ ដោយបែបឯណាមួយ បានដល់ មិនពិចារណាឃើញរូបថាជាខ្លួន តែពិចារណាឃើញថា មិនទៀងជាទុក្ខ ជាអនត្តា មិនពិចារណាឃើញខ្លួនថាមានរូប ។បេ។ មិនពិចារណាឃើញខ្លួនថានៅក្នុងវិញ្ញាណ ដូច្នេះ ។ កាលព្រះថេរីឆ្លើយបញ្ហាដំបូងយ៉ាងនេះថា ម្នាលអាវុសោវិសាខ យ៉ាងនេះឯងហើយ ដែលហៅថា មិនមានសក្កាយទិដ្ឋិ ដូច្នេះ ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ពាក្យថា ដោយហេតុមានប្រមាណប៉ុណ្ណេះ ការទៅក៏មាន ការមកក៏មាន ការទៅ និងការមកក៏មាន វដ្ដ:ក៏រមែងវិលទៅ ក៏ឈ្មោះថា នាងបានធ្វើវដ្ដ:ឲ្យដល់ទីបំផុត ហើយសម្តែង ។ ការឆ្លើយបញ្ហាខាងក្រោយថា ម្នាលអាវុសោវិសាខ យ៉ាងនេះឯងហើយដែលហៅថា មិនមានសក្កាយទិដ្ឋិ ដូច្នេះ ។

ពាក្យថា ដោយហេតុមានប្រមាណប៉ុណ្ណេះ ការទៅក៏មិនមាន ការមកក៏មិនមាន ការទៅ និងការមក ក៏មិនមាន វដ្តៈក៏ឈប់វិល ឈ្មោះថា នាងបានធ្វើវិវដ្តៈឲ្យដល់ទីបំផុត សម្តែងហើយ ។

[ ១៤៨ ] ប្រស្នាថា បពិត្រព្រះនាងជាម្ចាស់ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ តើដូចម្តេច ឈ្មោះថា ព្រះថេរីគប្បីសួរត្រឡប់ ហើយទើបឆ្លើយថា ឧបាសក អ្នកសួរដល់ផ្លូវខាងក្រោមហើយ ហេតុអ្វី ក្នុងទីនេះ ទើបសួរក្នុងផ្លូវទៀត ព្រះថេរីនោះ កំណត់បំណងរបស់ឧបាសកនោះបាន ក៏ព្រោះភាពដែលខ្លួនជាអ្នកឈ្លាស ជាបណ្ឌិត ។ នាងគិតថា ឧបាសកនេះ គង់នឹងសួរផ្លូវខាងក្រោមដោយអំណាចបដិបត្តិ តែក្នុងទីនេះ គង់ចង់សួរដល់ផ្លូវនោះនៃសង្ខតៈ អសង្ខតៈ លោកិយ លោកុត្តរ ដែលលោកសង្គ្រោះ និងមិនសង្គ្រោះ ដូច្នោះ ឧបាសកសួរដល់ប្រស្នាណាមួយ ទោះច្រើន ក៏ឆ្លើយប្រស្នានោះៗ ដោយមិនសួរត្រឡប់វិញឡើយ ។

ក្នុងបទទាំងនោះ បទថា **សង្ខតោ** សេចក្តីថា ត្រូវគិត ត្រូវលើក ចិត្តឡើងកាន់អារម្មណ៍ ត្រូវចិត្តឲ្យត្រាច់ទៅក្នុងអារម្មណ៍ ត្រូវបង្រួបបង្រួមទុក ត្រូវឲ្យកើត ជាអ្នកចូលដល់ គប្បីចូលដល់ ។ ក្នុងបទថា **តីហិ ច ខោ អាវុសោ វិសាខ ខន្ធេហិ អរិយោ អដ្ឋង្គិកោ មគ្គោ សង្គហិតោ** មានពាក្យអធិប្បាយថា ព្រោះមគ្គមានបទេស ខន្ធ ៣ មិនមានបទេស ដូច្នោះ ទើបលោកយកមគ្គនេះ មកសង្គ្រោះដោយខន្ធ ៣ ដែលមិនមានបទេស ដូចយកក្រុងមកសង្គ្រោះចូលនឹងរាជធានី ព្រោះភាពដែលមគ្គមានបទេស ។ ក្នុងអង្គ

មគ្គទាំងនោះ អង្គមគ្គ ៣ មានសម្មាវាចាជាដើម ជាសីលពិត ដូច្នោះ ទើបលើកយកអង្គមគ្គទាំងនោះមកសង្គ្រោះក្នុងសីលក្ខន្ធ ព្រោះមានជាតិស្មើគ្នា ។ សូម្បីក្នុងបាលី លោកលើកយកមកសម្តែង ធ្វើដូចសត្តមីវិភត្តិថា ក្នុងសីលក្ខន្ធ ដូច្នេះក៏ពិត តែទោះជាដូច្នោះ ក៏គប្បីជ្រាបអត្ថដោយអំណាចតតិយាវិភត្តិ ឯសមាធិក្នុងអង្គមគ្គ ៣ ទៀត មានការព្យាយាមត្រូវជាដើម ដោយធម្មតារបស់ខ្លួនហើយ រមែងមិនអាចនឹងចុះស៊ប់បាន ព្រោះជាសភាវៈដ៏លើសក្នុងអារម្មណ៍ តែកាលសេចក្តីព្យាយាមកំពុងនាំមុខ ដែលមានការផ្គងឲ្យសម្រេច ការរឭកដែលកំពុងធ្វើកិច្ចរឭកឲ្យសម្រេច សមាធិក្លាយជាធម្មជាត ដែលបានឧបការៈ ទើបអាចចុះស៊ប់បាន ។

ក្នុងរឿងអង្គមគ្គនោះ ពាក្យប្រៀបធៀបមានដូចតទៅនេះ ឧបមាដូចសម្លាញ់ ៣ នាក់ បបួលគ្នាទៅកាន់ឧទ្យាន ដោយតាំងចិត្តថា ពួកយើងនឹងលេងបុណ្យនក្ខត្តឫក្ស បុគ្គលម្នាក់ជួបផ្កាចម្ប៉ា មានផ្ការីកល្អ ឈោងដៃទៅក៏មិនអាចបេះបាន ពេលនោះ ទើបសម្លាញ់ម្នាក់មកបញ្ឈិះក សូម្បីបានជិះកសម្លាញ់ទី ២ នោះ ក៏នៅតែបេះមិនបាន ពេលនោះ សម្លាញ់ម្នាក់ទៀត ក៏មកឲ្យសម្លាញ់ទី ២ ឈរត្រង់ចង្កួយស្មា ។ សម្លាញ់ទី ១ ឈរជិះកសម្លាញ់ទី ២ សម្លាញ់ទី ២ ឈរលើចង្កួយស្មាសម្លាញ់ទី ៣ បេះយកផ្កាមកប្រដាប់តាមពេញចិត្ត ហើយលេងបុណ្យនក្ខត្តឫក្ស យ៉ាងណា គប្បីឃើញពាក្យដែលនាំមកប្រៀបធៀបនេះ ដូច្នោះ គឺ ធម៌ទាំង ៣ មានសម្មាវាយាមៈជាដើមដែលកើតរួមគ្នា ដូចសម្លាញ់ទាំង ៣ ដែលចូលឧទ្យានជាមួយគ្នា

អារម្មណ៍ដូចដើមចម្ប៉ាមានផ្ការីកស្គុសស្គាយ សមាធិដែលមិនអាចដល់ឈាន បាន ដោយភាវៈជាឯកគ្គតាដោយទំនើងខ្លួនឯង ដូចបុរសដែលលើកដៃឡើង ហើយក៏មិនអាចបេះបាន សម្មាវាយាមៈ ដូចសម្លាញ់ ទី ២ ដែលបញ្ចិះក សតិដូចសម្លាញ់ទី ៣ ដែលឲ្យសម្លាញ់ទី ២ ឈរលើស្មា សមាធិ កាល វិរិយៈកំពុងធ្វើកិច្ចផ្គងឲ្យសម្រេច សតិកំពុងធ្វើកិច្ចរឭក ឲ្យសម្រេចយ៉ាងនេះ បានឧបការៈហើយ ក៏អាចសម្រេចឈានបាន ព្រោះជាភាវៈដែលមាន អារម្មណ៍តែមួយ ដូចបុគ្គលទី ១ ជិះកបុគ្គលទី ២ បុគ្គលទី ២ ឈរលើស្មា បុគ្គលទី ៣ ទើបអាចបេះផ្កាបានតាមពេញចិត្ត យ៉ាងណា សេចក្តីនេះ ក៏ ដូច្នោះ ព្រោះហេតុនោះ ទើបលោកយកសមាធិមកបញ្ចូលក្នុងសមាធិក្ខន្ធតាម ជាតិរបស់ខ្លួន ឯសម្មាវាយាមៈ និងសម្មាសតិ លោកក៏យកមករួមចូលនឹង កិរិយា ។

បញ្ញាក្នុងសម្មាទិដ្ឋិ និងសម្មាសង្កប្ប ក៏មិនអាចកាត់សម្រេចអារម្មណ៍ ថាមិនទៀង ជាទុក្ខ មិនមែនជាខ្លួនតាមទំនើងខ្លួនឯងបាន ។ តែកាលវិតក្ក អាកោដេត្វារឿយៗ ប៉ះខ្ទប់ហើយ ប្រគល់មកឲ្យក៏អាច សេចក្តីនេះដូចអ្វី ប្រៀបដូចក្អាក់ងាររហិរញ្ញិកយកកហាបណៈមកដាក់លើដៃ សូម្បីចង់ពិនិត្យ មើលឲ្យគ្រប់ចំណែក ក៏មិនអាចពិនិត្យដោយភ្នែកបានឡើយ លុះកាលណា ប្រើម្រាមដៃត្រឡប់ចុះឡើងហើយ ទើបអាចពិនិត្យមើលបានគ្រប់ចំណែក យ៉ាងណា បញ្ញាក៏ដូច្នោះដូចគ្នា មិនអាចកាត់សម្រេចអារម្មណ៍ដោយអំណាច ការមិនទៀងជាដើម តាមទំនើងរបស់ខ្លួនឯងបាន តែអាចកាត់សម្រេចត្រឹមតែ

អារម្មណ៍ដែលវិតក្ក មានការលើកឡើងជាលក្ខណៈ មានការទល់ទ្រ និងចាប់អារម្មណ៍ជាកិច្ច ដូចកំពុងវាយ កំពុងចាប់ប្រមៀល ហើយបញ្ជូនមកឲ្យប៉ុណ្ណោះ ព្រោះដូច្នោះ ទើបលោកលើកយកតែសម្មាទិដ្ឋិប៉ុណ្ណោះមកសង្គ្រោះទុកនឹងបញ្ញាខន្ធ ព្រោះមានជាតិស្មើគ្នាក្នុងទីនេះ ។ ឯសម្មាសង្កប្បក៏ត្រូវលើកយកមកសង្គ្រោះចូល ព្រោះការធ្វើ ។ មគ្គរមែងដល់នូវការសង្គ្រោះចូលជាមួយរបស់ទាំង ៣ នេះ ដោយប្រការដូច្នេះ ព្រោះដូច្នោះ ទើបនាងធម្មទិន្នាពោលថា ម្នាលអាវុសោវិសាខ តែអដ្ឋង្គិកមគ្គទាំង ៨ ប្រការ ដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង ៣ ដូច្នេះ ។

ឥឡូវនេះ កាលសួរដល់សមាធិក្នុងមគ្គដែលប្រព្រឹត្តទៅត្រឹមតែខណៈចិត្តមួយ ប្រកបដោយនិមិត្ត និងបរិក្ខារ ទើបពោលពាក្យជាដើមថា **កតមោ បនយ្យេ** ។

ក្នុងការឆ្លើយប្រស្នានោះ លោកពោលថា សតិប្បដ្ឋាន ៤ គឺសម្មាសតិកើតឡើងហើយ ដោយអំណាចញ៉ាំងកិច្ច ៤ យ៉ាងក្នុងមគ្គខណៈឲ្យសម្រេច ។ សម្មាសតិនោះ ក្លាយជានិមិត្ត ព្រោះអត្ថថា ជាបច្ច័យនៃសម្មាសមាធិ ។ សម្មប្បធាន ៤ គឺវីរិយៈកើតឡើងហើយ ដោយអំណាចការធ្វើកិច្ច ៤ យ៉ាងឲ្យសម្រេច វីរិយៈនោះក្លាយជាបរិក្ខារ ព្រោះអត្ថថា ហែហម ។ បទថា **តេសំ យេវ ធម្មានំ** គឺនៃធម៌ដែលប្រកបដោយមគ្គទាំងនោះ ។ ក្នុងបទថា **អាសេវនា** ជាដើម គឺលោកពោលការសេពដែលប្រព្រឹត្តទៅត្រឹមតែមួយខណៈចិត្ត ចំណែកវិតណ្ឌវាទី គឺអ្នកចូលចិត្តនិយាយលេង ក៏ពោលថា ឈ្មោះថា មគ្គដែល

ប្រព្រឹត្តទៅត្រឹមមួយខណៈចិត្តមិនមាន ។ បើគប្បីទៅជាដូច្នោះ ទោះមានការចម្រើនមគ្គអស់ ៧ ឆ្នាំ ព្រោះពាក្យថា ៧ ឆ្នាំ ឯពួកកិលេសកាលនឹងដាច់ក៏រមែងដាច់ទៅដោយញាណទាំង ៧ ដោយឆាប់រួសរាន់ ។ គប្បីពោលនឹងវិតណ្ឌវាទីនោះថា នាំព្រះសូត្រមកអានចុះ ពិតហើយ កាលបុគ្គលនោះមើលមិនឃើញផ្លូវដទៃ ក៏នឹងនាំអត្ថមកថា ការសេព ការចម្រើន ការធ្វើឲ្យច្រើនធម៌ទាំងនោះឯងឯណា នេះឯងមកពោលថា រមែងសេពដោយចិត្តដួងដទៃចម្រើនដោយចិត្តដួងដទៃ ធ្វើឲ្យច្រើនដោយចិត្តដួងដទៃ ។ បន្ទាប់អំពីនោះ អ្នកនោះគប្បីត្រូវពោលថា ឯសូត្រនេះមានអត្ថគប្បីដឹង មានអត្ថនាំទៅដូចម្តេចបុគ្គលនោះក៏នឹងពោលតទៅទៀតថា សូត្រមានអត្ថដូចដែលនាំទៅនោះឯងយ៉ាងច្រើននៃបុគ្គលនោះ ក៏មានប្រមាណប៉ុណ្ណោះ ។ កាលបើយ៉ាងនេះ នឹងមានតែការសេពប៉ុណ្ណោះ សូម្បីអស់មួយថ្ងៃយ៉ាងនេះ គឺចិត្ត ១ ដួងកើត សេពហើយ ចិត្ត ១ ដួងទៀតកើត សេពហើយ សូម្បីចិត្ត ១ ដួងទៀត ក៏កើតសេពហើយ នឹងមានការចម្រើនអំពីណា នឹងមានការធ្វើឲ្យច្រើនអំពីណា ឬកាល ១ ដួងក៏កើត ចម្រើនហើយ ១ ដួងទៀតក៏កើតចម្រើនហើយ ១ ដួងទៀតក៏កើត ចម្រើនហើយ ដូច្នេះ បែបនេះអស់មួយថ្ងៃ ក៏មានតែការចម្រើនប៉ុណ្ណោះ ។ ការសេពនឹងមានអំពីណា ការធ្វើឲ្យច្រើននឹងមានអំពីណា ឬ ១ ដួងក៏កើត ធ្វើឲ្យច្រើនហើយ ១ ដួងទៀតក៏កើត ធ្វើឲ្យច្រើនហើយ ១ ដួងទៀតក៏កើតធ្វើឲ្យច្រើនឡើងហើយ ដូច្នេះ បែបនេះអស់មួយថ្ងៃ ក៏នឹងមានតែការធ្វើឲ្យច្រើនប៉ុណ្ណោះ នឹងមានការសេពអំពីណា នឹងមានការចម្រើនអំពី

ណា ម្យ៉ាងទៀត បុគ្គលអាចពោលយ៉ាងនេះថា រមែងសេពដោយចិត្តដួងមួយ រមែងចម្រើនដោយចិត្ត ២ ដួង រមែងធ្វើឲ្យច្រើនដោយចិត្ត ៣ ដួង ឬរមែងសេពដោយចិត្ត ២ ដួង រមែងចម្រើនដោយចិត្ត ៣ ដួង រមែងធ្វើឲ្យច្រើនដោយចិត្ត ១ ដួង ឬរមែងសេពដោយចិត្ត ៣ ដួង រមែងចម្រើនដោយចិត្ត ១ ដួង រមែងធ្វើឲ្យច្រើនដោយចិត្ត ២ ដួង ។ បុគ្គលគប្បីពោលថា លោកកុំពោលឡេះឡោះថា ខ្ញុំក៏មានសូត្រអាង ធម្មតាអ្នកឆ្លើយបញ្ហា ត្រូវនៅក្នុងសម្នាក់អាចារ្យ រៀនសូធ្យព្រះពុទ្ធវចនៈឲ្យដឹងអត្ថរសហើយ សឹមពោលការសេពនេះ ប្រកបដោយចិត្ត ១ ខណៈ ការចម្រើនក៏ប្រកបដោយចិត្ត ១ ខណៈ ការធ្វើឲ្យច្រើន ក៏ប្រកបដោយចិត្ត ១ ខណៈ ធម្មតាលោកុត្តរមគ្គដែលឲ្យដល់នូវការអស់ទៅ ដែលមានច្រើនខណៈចិត្តមិនមាន មានតែប្រកបដោយខណៈចិត្ត ១ ប៉ុណ្ណោះ គប្បីធ្វើឲ្យបុគ្គលនោះព្រមទទួលដូចពោលមកនេះ បើវិតណ្ឌានោះព្រមទទួល ក៏ព្រមទទួលទៅ បើមិនព្រមទទួល ក៏គប្បីបញ្ជូនទៅថា ចូលទៅវិហារអំពីព្រលឹម ហើយឆាន់បបរចុះ ។

[ ១៤៩ ] ក្នុងបទថា **កតិ បនយ្យេ សង្ខារា** នេះ វិសាខសួរដល់អ្វី សួរថា បុគ្គលរម្ងត់សង្ខារពួកណាហើយ ទើបចូលនិរោធ ខ្ញុំសូមសួរសង្ខារទាំងនោះ កាលព្រះថេរីបានជ្រាបបំណងរបស់ឧបាសក ដោយប្រការនោះឯងប្រាប់កាយសង្ខារជាដើមក្នុងសង្ខារជាច្រើន មានបុញ្ញាភិសង្ខារជាដើមដែលមាន ទើបពោលពាក្យជាដើមថា សង្ខារទាំងឡាយនេះមាន ៣ ។

ក្នុងសង្ខារទាំងនោះ ឈ្មោះថា កាយសង្ខារ ព្រោះកាយតាក់តែង គឺឲ្យ

កើត ព្រោះជាសភាវៈដែលទាក់ទងនឹងកាយ ឈ្មោះថា វចីសង្ខារ ព្រោះត្រូវតាក់តែង គឺត្រូវឲ្យកើតដោយវាចា ព្រោះជាវត្ថុដែលទាក់ទងនឹងវាចា ឈ្មោះថា ចិត្តសង្ខារ ព្រោះត្រូវតាក់តែង គឺត្រូវឲ្យកើតដោយចិត្ត ព្រោះជាវត្ថុដែលទាក់ទងនឹងចិត្ត ។ វិសាខសួរដល់អ្វី ក្នុងបទថា **កតមោ បនយ្យេ** នេះ ឧបាសកសួរថា សង្ខារទាំងនេះលាយឡំគ្នានិងគ្នា អាប់អួ មិនជាក់ច្បាស់ ប្រាប់បានដោយលំបាក ។ ពិតហើយ ដែលហៅថា ចេតនា ២០ ដែលជាកុសល អកុសលទាំងនេះ គឺចេតនាក្នុងកាមាវចរកុសល ៨ ចេតនាក្នុងអកុសល ១២ ដែលញុំាងបុគ្គលឲ្យដល់នូវការប្រកាន់ ការកាន់យក ការរួបផុត ការរលាស់ក្នុងកាយទ្វារខ្លះ ខ្យល់ដង្ហើមចេញ-ចូលខ្លះថា ជាកាយ-សង្ខារ ។ លោកហៅចេតនា ២០ មានប្រការដែលបានពោលហើយ ដែលញុំាងការកម្រើកនៃចង្កាឲ្យដល់នូវវចីភេទ ក្នុងវចីទ្វារខ្លះ វិតក្ក វិចារៈខ្លះថាជាវចីសង្ខារ លោកហៅចេតនា ២០ នោះ កុសល និងអកុសល ដែលកើតដល់បុគ្គលដែលមិនកម្រើកកាយ និងវាចា ហើយអង្គុយគិតក្នុងទីស្ងាត់ ធម៌ ២ យ៉ាង គឺសញ្ញា និងវេទនាខ្លះ ថាជាចិត្តសង្ខារនោះឯង ធម៌ទាំងនេះលាយឡំគ្នា ស្រអាប់ មិនទាន់ជាក់ច្បាស់ ប្រាប់បានលំបាក ខ្ញុំសូមឲ្យធម៌ទាំងនោះជាក់ច្បាស់ ហើយប្រាប់ ។

ក្នុងបទថា **កស្មា បនយ្យេ** នេះ វិសាខសួរដល់អត្ថរបស់បទនៃឈ្មោះកាយសង្ខារជាដើម ។ ក្នុងការឆ្លើយប្រស្នានោះ អ្នកសិក្សាគប្បីជ្រាបអត្ថនេះថា កាយសង្ខារ ឈ្មោះថា អាស្រ័យកាយ ព្រោះទាក់ទងនឹងកាយ កាល

មានកាយ ក៏មានកាយសង្ខារ កាលកាយមិនមាន កាយសង្ខារក៏មិនមាន ចិត្តសង្ខារ ឈ្មោះថា អាស្រ័យចិត្ត ព្រោះទាក់ទងនឹងចិត្ត កាលចិត្តមាន ចិត្តសង្ខារក៏មាន កាលចិត្តមិនមាន ចិត្តសង្ខារក៏មិនមាន ។

[ ១៥០ ] ឥឡូវនេះ កាលវិសាខសួរដើម្បីការដឹងថា សមាបត្តិនេះ ប្រើសញ្ញាវេទយិតនិរោធឬហ្ន៎ ឬមិនប្រើ ឬជាអ្នកសន្សំវសីក្នុងសញ្ញាវេទយិត-និរោធប៉ុណ្ណោះឬហ្ន៎ ឬមិនមែន ឬជាអ្នកសន្សំវសីក្នុងសញ្ញាវេទយិតនិរោធនោះ ឬមិនត្រូវជាអ្នកសន្សំនូវវសី ទើបពោលពាក្យជាដើមថា បពិត្រព្រះនាងម្ចាស់ ចុះសញ្ញាវេទយិតនិរោធសមាបត្តិដូចម្តេចជាដើម ។ ក្នុងការឆ្លើយបញ្ហានោះ ដោយសេចក្តីថា លោកបានពោលដល់វេលានៃនេវសញ្ញានា-សញ្ញាយតនសមាបត្តិ ដោយបទទាំង ២ ថា អញនឹងចូលក្តី អញកំពុងចូលក្តី លោកពោលនិរោធខាងក្នុងដោយពាក្យថា ចូលហើយ ។ វេលាដែលមានចិត្ត លោកក៏ពោលដោយបទទាំង ២ មុនដូចគ្នា វេលាដែលមិនមានចិត្ត លោកពោលដោយបទក្រោយ ។ បទថា **បុព្វេវ តថា ចិត្តំ ភាវិតំ ហោតិ** បានដល់ ចិត្តដែលមានកាលវេលាជាគ្រឿងកំណត់ ដែលបានចម្រើនហើយថា កំណត់វេលាប៉ុណ្ណោះ អញនឹងជាអ្នកមិនមានចិត្ត ក្នុងកាលមានរយៈវេលាជាគ្រឿង កំណត់មុននិរោធសមាបត្តិ ។ បទថា **យំ តំ តថត្តាយ ឧបនេតិ** គឺបង្អោនបុគ្គលដែលចម្រើនចិត្តហើយយ៉ាងនេះ ចូលទៅដើម្បីភាពជាយ៉ាងនោះ បានដល់ ដើម្បីភាពជាអ្នកមិនមានចិត្ត ។ បទថា **បឋមំ និរុជ្ឈតិ វចីសង្ខារោ** គឺវចីសង្ខាររលត់ចាកសង្ខារដ៏សេស ក្នុងទុតិយជ្ឈាន ។ បទថា **តតោ**

**កាយសង្ខារោ** គឺបន្ទាប់អំពីនោះ កាយសង្ខារក៏រលត់ទៅ ក្នុងចតុត្ថជ្ឈាន ។ បទថា **តតោ ចិត្តសង្ខារោ** គឺបន្ទាប់អំពីនោះ ទើបចិត្តសង្ខាររលត់ខាងក្នុងនិរោធ ។ លោកពោលវេលាខាងក្នុងនិរោធដោយ ២ បទថា **វុដ្ឋ ហិស្សន្តិ វា វុដ្ឋ ហាមីតិ វា** វេលានៃផលសមាបត្តិ លោកពោលដោយបទថា **វុដ្ឋិតោ** វេលាជាអ្នកមិនមានចិត្ត លោកពោលដោយ ២ បទ ដូចគ្នាអំពីមុននោះ ។ ដោយបទក្រោយ លោកពោលវេលាដែលមានចិត្ត ។ បទថា **បុព្វេ តថា ចិត្តំ ភាវិតំ ហោតិ** គឺចិត្តដែលមានវេលាជាគ្រឿងកំណត់ ឈ្មោះថា បានចម្រើនហើយថា អស់កាលវេលាប៉ុណ្ណេះ អញនឹងជាបុគ្គលមិនមានចិត្ត ក្នុងកាលដែលមានរយៈពេលជាគ្រឿងកំណត់ចូលដល់និរោធសមាបត្តិហើយ បន្ទ អំពីនោះ ទើបជាអ្នកមានចិត្ត ។ បទថា **យំ តំ តថត្តាយ ឧបនេតិ** គឺបង្អោនបុគ្គលដែលចម្រើនចិត្តហើយយ៉ាងនេះ ចូលទៅដើម្បីភាពជាយ៉ាងនោះ គឺដើម្បីភាពជាអ្នកមានចិត្ត ។ វេលានៃការចូលនិរោធ លោកពោលខាងដើមក្នុងទីនេះ លោកពោលវេលានៃការចេញអំពីនិរោធ ដោយប្រការដូច្នេះ ។

ឥឡូវនេះ ជាវារៈពោលនូវនិរោធកថា ដូច្នោះ ទើបនិរោធកថា ជារឿងដែលត្រូវពោល ។

និរោធកថានោះ លោកបានតាំងមាតិកា បានពោលក្នុងវិសុទ្ធិមគ្គ គ្រប់ចំណុច គ្រប់ជ្រុងថា បញ្ញាដែលវសីចម្រើន ដោយការរម្ងាប់សង្ខារ ៣ ព្រោះភាពជាអ្នកប្រកបដោយកម្លាំង ២ ដោយការប្រព្រឹត្តក្នុងញាណ ១៦ ដោយការប្រព្រឹត្តក្នុងសមាធិ ៩ បញ្ញាដែលវសីអប់រំហើយ និងញាណក្នុងការចូល

ដល់និរោធ ព្រោះដូច្នោះ បុគ្គលត្រូវការចេះដឹង គប្បីកាន់យកតាមបែបដែលពោលក្នុងវិសុទ្ធិមគ្គនោះចុះ ។ ដែលឈ្មោះថា និរោធនេះ បានដល់អ្វី ឆ្លើយថា បានដល់ ការមិនប្រព្រឹត្តទៅនៃការពិចារណាខន្ធទាំង ៤ បើមានការសួរថា កាលបើដូច្នោះ ចូលសមាបត្តិដើម្បីអ្វី ឆ្លើយថា ចូលសមាបត្តិដើម្បីនេះ គឺអាត្មាអញធុញទ្រាន់ក្នុងការប្រព្រឹត្តទៅហើយក្នុងសង្ខារ នឹងជាអ្នកមិនមានចិត្ត ៧ ថ្ងៃ នឹងសប្បាយ និរោធនេះ ឈ្មោះថា និព្វានក្នុងបច្ចុប្បន្ន ។ បទថា **បឋមំ ឧប្បជ្ជតិ ចិត្តសង្ខារោ** ពិតហើយ កាលចេញអំពីនិរោធ ចិត្តក្នុងផលសមាបត្តិ រមែងកើត ។ លោកពោលសំដៅយកសញ្ញា និងវេទនាដែលប្រកបដោយផលសមាបត្តិនោះ ទើបពោលថា ចិត្តសង្ខារកើតឡើង ។ បទថា **តតោ កាយសង្ខារោ** បន្ទាប់អំពីចិត្តសង្ខារនោះទៅ កាយសង្ខារកើតឡើងក្នុងសម័យនៃភវង្គ ។ សួរថា ផលសមាបត្តិមិនញុំាងខ្យល់ដង្ហើមចេញ-ចូលឲ្យតាំងឡើងឬ ឆ្លើយថា ឲ្យតាំងឡើង ។ តែផលសមាបត្តិនៃបុគ្គលនេះ ប្រកបដោយចតុត្ថជ្ឈាន ទើបផលសមាបត្តិនោះ ធ្វើឲ្យខ្យល់ដង្ហើមចេញ-ចូល តាំងឡើងមិនបាន ។ ព្រោះហេតុនេះឬ ផលសមាបត្តិទោះប្រកបដោយឈានទី ១ ក្តី ប្រកបដោយឈានទី ២ ក្តី ទី ៣-៤ ក្តី ក៏ដោយចុះ ខ្យល់ដង្ហើមចេញ-ចូលរបស់ ភិក្ខុដែលចេញចាកសមាបត្តិដ៏ស្ងប់ រមែងជាវត្ថុដែលពោលមិនបាន គឺមានដូចមិនមានឬ ការដែលខ្យល់ដង្ហើមចេញចូលនោះ ជាវត្ថុដែលពោលមិនបាន គប្បីជ្រាបដោយរឿងព្រះសញ្ជីវត្ថេរ ។

មានសេចក្តីសង្ខេបថា កាលព្រះសញ្ជីវត្ថេរចេញអំពីសមាបត្តិហើយ ក៏

ដើរលុយទៅលើរងើកភ្លើង ដែលខ្ចាត់ខ្ចាយដូចផ្កាចារ សូម្បីជាយចីវរក៏មិន ឆេះ ត្រឹមតែអាការក្តៅក៏មិនមាន ។ ពួកមនុស្សក៏ពោលថា នេះឯងជាផល នៃសមាបត្តិ ។ ខ្យល់ដង្ហើមចេញ-ចូលរបស់ភិក្ខុដែលចេញអំពីសមាបត្តិដែល ស្ងប់ ជាវត្ថុដែលពោលមិនបាន ដូចពោលមកនេះឯង ដូច្នោះ គប្បីជ្រាបថា ពាក្យនេះ លោកពោលដោយសម័យនៃភវង្គប៉ុណ្ណោះ ។

បទថា **តតោ វចីសង្ខារោ** គឺបន្ទាប់អំពីកាយសង្ខារនោះមក វចីសង្ខារ ក៏កើតឡើងក្នុងវេលានៃការប្រើ ដែលសម្រេចអំពីកិរិយាចិត្តប្រព្រឹត្តទៅ សួរ ថា ភវង្គឲ្យវិតក្កវិចារៈតាំងឡើងមិនបានឬ ឆ្លើយថា ឲ្យតាំងឡើងបាន តែវិតក្ក និងវិចារៈដែលប្រកបដោយភវង្គនោះ តាក់តែងវាចាមិនបាន ព្រោះដូច្នោះ ពាក្យនោះ លោកពោលតាមវេលាប្រើ ដែលសម្រេចមកអំពីកិរិយាចិត្ត ដែល ប្រព្រឹត្តទៅហើយប៉ុណ្ណោះ ។ សមាបត្តិជាដើមថា ផស្សៈជារបស់សុញ្ញ គប្បី ពោលដោយផស្សៈដែលមានគុណ និងដោយអារម្មណ៍ ។ ផលសមាបត្តិ ឈ្មោះថា ជារបស់សុញ្ញដោយផស្សៈ ដែលមានគុណមុន ព្រោះលោក បំណងយកផស្សៈដែលកើតព្រមនឹងសុញ្ញតៈ ទើបផលសមាបត្តិនោះ លោក ពោលថា ផស្សៈជារបស់សុញ្ញ សូម្បីក្នុងអនិមិត្តផលសមាបត្តិ និងអប្ប- ណិហិតផលសមាបត្តិ ក៏ទំនងដូចគ្នានេះឯង ដោយអារម្មណ៍ ព្រះនិព្វាន ក៏ ឈ្មោះថា សុញ្ញ ព្រោះសុញ្ញចាករាគៈជាដើម ។ ឈ្មោះថា អនិមិត្ត ព្រោះ មិនមានគ្រឿងសម្គាល់នៃរាគៈជាដើម ព្រោះមិនមានទីតាំងនៃរាគៈជាដើម ទើប ឈ្មោះថា មិនមានទីតាំង ។ ផស្សៈក្នុងផលសមាបត្តិ ដែលធ្វើសុញ្ញតនិព្វាន

ឲ្យកើតជាអារម្មណ៍ ឈ្មោះថា ជារបស់សូន្យ ។ សូម្បីក្នុងអនិមិត្តផល-សមាបត្តិ និងអប្បណិហិតផលសមាបត្តិ ក៏មានទំនងដូចគ្នានេះឯង ។ នៅមានពាក្យដែលគប្បីពោលបន្ថែមដទៃទៀត គឺសូម្បីវិបស្សនា លោកក៏ហៅថា សុញ្ញតា អនិមិត្តា អប្បណិហិតា ក្នុងប្រការទាំងនោះ ភិក្ខុណាកំណត់សង្ខារដោយអនិច្ចំ ឃើញដោយការមិនទៀងហើយ ចេញដោយការមិនទៀង ។ វិបស្សនាដែលនាំទៅដល់ការចេញនៃភិក្ខុនោះ ឈ្មោះថា អនិមិត្តាវិបស្សនា ។ ភិក្ខុណាកំណត់សង្ខារដោយភាពជាទុក្ខ ឃើញដោយភាពជាទុក្ខហើយ ចេញដោយភាពជាទុក្ខ វិបស្សនាដែលនាំទៅដល់ការចេញរបស់ភិក្ខុនោះ ឈ្មោះថា អប្បណិហិតាវិបស្សនា ។ ភិក្ខុណាកំណត់សង្ខារដោយភាពជាអនត្តា ឃើញដោយភាពជារបស់មិនមែនខ្លួនហើយ ចេញដោយភាពជារបស់មិនមែនខ្លួន វិបស្សនាដែលនាំទៅដល់ការចេញនៃភិក្ខុនោះ ឈ្មោះថា សុញ្ញតាវិបស្សនា ។ មគ្គក្នុងអនិមិត្តវិបស្សនារបស់ភិក្ខុនោះ ឈ្មោះថា អនិមិត្តមគ្គ ។ ផលរបស់អនិមិត្តមគ្គ ឈ្មោះថា អនិមិត្តផល កាលពាល់ត្រូវផស្សៈដែលកើតព្រមនឹងនិមិត្តផលសមាបត្តិ ក៏ហៅថា អនិមិត្ត រមែងពាល់ត្រូវក្នុង អប្បណិហិតៈ និងសុញ្ញតៈក៏មានទំនងដូចគ្នានេះដូចគ្នា ។ ដោយពាក្យដែលត្រូវបន្ថែម ដែលបានពោលហើយ ផស្សៈក៏គប្បីមកដល់ការជ្រើសរើសយកឯណាមួយថា សុញ្ញតផស្សៈក៏បាន អនិមិត្តផស្សៈក៏បាន ឬអប្បណិហិតផស្សៈក៏បាន ព្រោះដូច្នោះ ទើបគួរពោលសមាបត្តិជាដើម ដោយផស្សៈដែលមានគុណ និងដោយអារម្មណ៍ ។ ព្រោះកាលពោលយ៉ាងនេះ ពាក្យក៏នឹងចូលគ្នាបានថា ផស្សៈ

៣ ពាល់ត្រូវ ។ ព្រះនិព្វាន ឈ្មោះថា វិវេក ក្នុងបទថា **វិវេកនិន្នំ** ជាដើម ដែលជាបង្អោនទៅក្នុងវិវេក ព្រោះបង្អោន គឺឱនទៅក្នុងវិវេកនោះ ។ ដែលឈ្មោះថា ឈមទៅក្នុងវិវេក ។ ក្នុងបទថា **វិវេកបោណំ** ក៏ព្រោះមកអំពីទីដទៃហើយ ក៏តាំងនៅ ហាក់ដូចជាចូលទៅរកវិវេកនោះ ។ ដែលឈ្មោះថា **វិវេកបព្ភារំ** ក៏ព្រោះថា តាំងនៅហាក់ដូចជាធ្លាក់ទៅរកវិវេកនោះ ។

[ ១៥១ ] ឥឡូវនេះ កាលវិសាខសួរថា ខ្ញុំសូមសួរវេទនាដែលភិក្ខុរម្ងាត់បានហើយ ទើបចូលនិរោធសមាបត្តិបាន ទើបពោលពាក្យថា **កតិ បនយ្យេ វេទនា** ជាដើម ។

សេចក្តីសុខដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ ក្នុងបទថា **កាយិកំ វា** ជាដើម ឈ្មោះថា កាយិកសុខ ដែលប្រព្រឹត្តទៅក្នុងមនោទ្វារ គប្បីជ្រាបថា ឈ្មោះថា ចេតសិកសុខ ។ ក្នុងរឿងរបស់វេទនានោះ បទថា **សុខំ** ជាពាក្យបង្អួលបង្ហាញសភាវៈ ។ បទថា **សាតំ** ជាពាក្យសម្រាប់ប្រើជំនួស សម្តែងដល់ការត្រេកអរនៃសុខនោះឯង ។ បទថា **វេទយិតំ** ជាពាក្យទូទៅដល់វេទនាគ្រប់យ៉ាង ដែលសម្តែងការកើត គឺការសោយ ក្នុងបទដ៏សេសក៏មានទំនងដូចគ្នានេះឯង ។ ក្នុងបទថា **ឋិតិសុខា វិបរិណាមទុក្ខា** ជាដើម សេចក្តីថា ការមាននៃសុខវេទនា ឈ្មោះថា សុខ ការមិនមាន ឈ្មោះថា ជាទុក្ខ ការមាននៃទុក្ខវេទនា ឈ្មោះថា ទុក្ខ ការមិនមាន ឈ្មោះថា សុខ ការដឹងអទុក្ខ-សុខវេទនា ឈ្មោះថា សុខ ការមិនដឹង ឈ្មោះថា ទុក្ខ ។ ក្នុងបទថា **កឹ អនុសយោ អនុសេតិ** នេះ វិសាខសួរដល់អនុស័យថា អនុស័យដូចម្តេច

តែងដេកត្រាំ គឺប្រៀបដូចជាបុគ្គលដេក ព្រោះអត្ថថា មិនទាន់លះបាន ។ បទថា **ន ខោ អាវុសោ វិសាខ សព្វាយ សុខាយ វេទនាយ រាគានុសយោ អនុសេតិ** សេចក្ដីថា រាគានុស័យ មិនមែនដេកត្រាំក្នុងសុខវេទនាទាំងអស់ទេ រាគានុស័យនោះ ដែលមិនទាន់លះបានក្នុងសុខវេទនាគ្រប់យ៉ាង ក៏រមែងមិនប្រារព្ធសុខវេទនាគ្រប់ប្រភេទ ហើយកើតឡើង ។ ក្នុងទីគ្រប់អន្លើ ក៏មានទំនងដូចគ្នានេះ ។ បទថា **កឹ បហាតព្វំ** នេះ ជាពាក្យសួរដល់ការលះ ធម្មទិន្នាថេរីឆ្លើយសំណួរ ២ ប្រការ ដោយចម្លើយនេះឯង ក្នុងបទថា លះរាគៈដោយបឋមជ្ឈាននោះ ។ កិច្ចក្នុងធម្មវិន័យនេះ សង្កត់កាមរាគានុស័យបានហើយ ចូលដល់ឈានទី ១ ធ្វើរាគានុស័យ ដែលឈានសង្កត់ទុកហើយ ឲ្យជាការសង្កត់ទុកហើយយ៉ាងនោះឯង ហើយចម្រើនវិបស្សនា ទើបដកបានជាសមុច្ឆេទ ដោយអនាគាមិមគ្គ ។ រាគានុស័យនោះ សូម្បីដកបានដោយអនាគាមិមគ្គហើយ ក៏នៅតែឈ្មោះថា ដេកត្រាំជាមួយឈានទី ១ ព្រោះអនុស័យនេះ ត្រូវបឋមជ្ឈាននោះសង្កត់ទុកយ៉ាងនោះ ព្រោះដូច្នោះ ទើបធម្មទិន្នាថេរីពោលថា រាគានុស័យរមែងមិនដេកត្រាំក្នុងសុខវេទនានោះ ។

បទថា **តទាយតនំ** កាត់បទជា **តំ អាយតនំ** សេចក្ដីថា អរហត្តផលឈ្មោះថា ជាទីពឹង ព្រោះជាទីក្សេមយ៉ាងក្រៃលែង ។ បទថា **ឥតិ អនុត្តរេសុ** គឺបុគ្គលតាំងសេចក្ដីប្រាថ្នាក្នុងអរហត្តផល ដែលបានឈ្មោះថា វិមោក្ខដ៏កំពូល ដោយប្រការដូច្នេះ ។ បទថា **ឧប្បជ្ជតិ បីហាប្បច្ចយា ទោមនស្សំ** គឺរមែងកើតទោមនស្សដែលជាមូលឲ្យការប្រាថ្នាតាំងឡើង តែទោមនស្សដែលជា

មូលឲ្យការប្រាថ្នាតាំងឡើងនោះ មិនកើតឡើងឡើយ តែលោកពោលថា ទោមនស្សដែលមានការមិនបានជាមូល កាលនឹងកើតដល់បុគ្គលប្រាថ្នាហើយមិនបាន រមែងកើតឡើង ព្រោះការប្រាថ្នាជាបច្ច័យ ។ អាចារ្យពួកខ្លះពោលថា ឈ្មោះថា ទោមនស្សក្នុងការប្រាថ្នា តែមិនបាននោះ ជាអកុសលដោយចំណែកមួយក៏ពិត តែគប្បីសេពទោមនស្សនេះ ទោមនស្សនេះគួរពិតហើយ ពួកយោគីរមែងទទួលយកបដិបទា ៣ ខែខ្លះ ៦ ខែខ្លះ ៩ ខែខ្លះ ។ ក្នុងយោគីទាំងនោះ បុគ្គលដែលទទួលយកបដិបទាទាំងនោះទៅហើយ ក៏បន្តព្យាយាម ដោយគិតថា ខាងក្នុងវេលាដែលបានកំណត់នេះឯង អញគង់នឹងបានអរហត្តផល តែក៏មិនអាចសម្រេចតាមដែលបានកំណត់ ទើបកើតនូវទោមនស្សដ៏ខ្លាំងក្លា ទឹកភ្នែកក៏ហូរ ដូចព្រះមហាបុស្សត្ថេរអ្នកចុងដែន ។

មានរឿងតំណាលមកថា ព្រះថេរៈបំពេញវត្តដើរទៅ ដើរមក អស់ ១៩ ឆ្នាំ កាលលោកដាក់ចិត្តថា ពេលនេះ អញនឹងកាន់យកអរហត្តផលឲ្យបាន និងថា គ្រានេះ អញនឹងបវារណា ប្រភេទវិសុទ្ធិបវារណា ហើយធ្វើសមណធម៌នោះឯង ១៩ ឆ្នាំកន្លងទៅ កាលមកដល់ថ្ងៃបវារណា ក៏មិនមានថ្ងៃរបស់បុគ្គលរួចផុត ព្រោះទឹកភ្នែករបស់ព្រះថេរៈ តែក្នុងឆ្នាំទី ២០ ទើបបានសម្រេចអរហត្តផល ។

ក្នុងបទថា **បដិយំ តេន បជហាតិ** សេចក្តីថា យកទោមនស្សទៅលះបដិយៈមិនបាន យកបដិយៈនោះឯង ទៅលះបដិយៈក៏មិនបាន ឬយកទោមនស្សទៅលះទោមនស្សក៏មិនបាន ។ តែភិក្ខុនេះ ទទួលយកបដិបទាណាមួយ

ក្នុងបដិបទាមានរយៈ ៣ ខែជាដើម ហើយពិចារណាយ៉ាងនេះថា ភិក្ខុមើល ចុះ បុគ្គលមានឋានៈអាក្រក់ដោយសីល ដោយវីរិយៈ ឬដោយបញ្ញា សីលរបស់អ្នកបរិសុទ្ធហើយមិនមែនឬ អ្នកផ្គងវីរិយៈហើយមិនមែនឬ បញ្ញាជាធម្មជាតបាស់ក្លា រមែងនាំទៅមិនមែនឬ កាលលោកពិចារណាយ៉ាងនេះ ក៏ឃើញថា ឥឡូវនេះ អាត្មាអញមិនព្រមឲ្យទោមនស្សកើតឡើងទៀត ទើបធ្វើសេចក្ដីព្យាយាមឲ្យខ្លាំងក្លាខាងក្នុង ៣ ខែ ខាងក្នុង ៦ ខែ ឬខាងក្នុង ៩ ខែ ក៏ដកបដិឃៈដោយអនាគាមិមគ្គបានជាសមុច្ឆេទ ការធ្វើយ៉ាងនេះ ឈ្មោះថា លោកប្រើបដិឃៈនោះឯង ដើម្បីលះបដិឃៈ ប្រើទោមនស្សនោះឯង ដើម្បីលះទោមនស្ស ។ ក្នុងបទថា **ន តត្ថ បដិឃានុសយោ អនុសេតិ** នោះសេចក្ដីថា ទោមនស្សបែបនោះ បដិឃានុស័យមិនដេកត្រាំ បដិឃានុស័យក៏មិនប្រារព្ធទោមនស្សនោះកើតឡើង បដិឃានុស័យ ឈ្មោះថា ត្រូវលះបានក្នុងទោមនស្សនោះ ។ បទថា **អវិជ្ជំ តេន បជហាតិ** គឺភិក្ខុក្នុងធម្មវិន័យនេះសង្កត់អវិជ្ជានុស័យបានហើយ ក៏ចូលកាន់ចតុត្ថជ្ឈាន ធ្វើអវិជ្ជានុស័យដែលត្រូវឈានសង្កត់ទុកហើយ ឲ្យជាការសង្កត់ទុកយ៉ាងនោះ ហើយទើបចម្រើនវិបស្សនា ដកបានជាសមុច្ឆេទដោយអរហត្តមគ្គ ។ សូម្បីអវិជ្ជានុស័យនោះត្រូវអរហត្តមគ្គលះបានហើយក៏ដោយ ក៏នៅឈ្មោះថា ដេកត្រាំដោយឈានទី ៤ ព្រោះត្រូវឈានទី ៤ នោះសង្កត់បានហើយ ព្រោះដូច្នោះ ទើបធម្មទិន្នាថេរីពោលថា អវិជ្ជានុស័យ ដេកសម្ងំនៅក្នុងអរហត្តមគ្គនោះមិនបានឡើយ ដូច្នេះ ។

[ ១៥២ ] ឥឡូវនេះ កាលទីងសួរសំណួរដែលជាបដិភាគ ទើបវិសាខ ពោលថា **សុខាយ បនយ្យេ** ជាដើម ក្នុងការឆ្លើយបញ្ហានោះ គប្បីជ្រាបដូចតទៅនេះ ព្រោះទុក្ខជាសត្រូវចំពោះសុខ សុខក៏ជាសត្រូវចំពោះទុក្ខ ដូច្នោះ ទើបលោកពោលវិសភាគបដិភាគទុកក្នុងវេទនាទាំង ២ ឯឧបេក្ខាជាធម្មជាតិដែលត្រូវងងឹតគ្របសង្កត់ លំបាកនឹងចង្អុលបង្ហាញ ព្រោះដូច្នោះ ទើបលោកពោលទាំងសភាគ និងបដិភាគ ក្នុងទីនេះថា សូម្បីអវិជ្ជាក៏ដូច្នោះពិត ។ បុគ្គលរមែងធ្វើនូវការងងឹត គឺអវិជ្ជា ក្នុងទីមានប្រមាណប៉ុនណា ក៏រមែងបន្ទោបង់នូវងងឹត គឺអវិជ្ជាក្នុងទីមានប្រមាណប៉ុណ្ណោះ ដូច្នោះ ទើបពោលទាំងវិសភាគនិងបដិភាគក្នុងទីនេះ ។ ក្នុងបទថា **អវិជ្ជាយ ខោ អាវុសោ** នេះ គឺលោកពោលទាំងសភាគ និងបដិភាគថា ធម៌ទាំង ២ នេះ មិនមានអាសវៈជាលោកុត្តរៈ លោកពោលទាំងសភាគ និងបដិភាគ ព្រោះអត្ថថា មិនមានអាសវៈ ព្រោះអត្ថថា ជាលោកុត្តរៈ និងព្រោះអត្ថថា ជាអព្យាកតៈ ក្នុងបទនេះថា **វិមុត្តិយា ខោ អាវុសោ** ។ ក្នុងបទថា **អច្ចយាសិ** នេះ សេចក្តីថា អ្នកជាបុគ្គលសួរជ្រុលហួសពេកហើយ ។ បទថា **នាសក្ខិ បញ្ហានំ បរិយន្តំ គហេតុំ** សេចក្តីថា អ្នកមិនអាចកាន់យកប្រមាណនៃការកំណត់បញ្ហាបាន ទើបសួរបដិភាគនៃអប្បដិភាគធម៌ ព្រះនិព្វាននេះ ជាអប្បដិភាគធម៌ដែលមិនមានបុគ្គលណាអាចនឹងធ្វើបដិភាគ គឺ ការប្រៀបធៀបនឹងធម៌ចំណែកខ្វះ គឺ ខៀវ លឿង ឬក្រហម ហើយសម្តែងបាន អ្នកក៏រមែងសួរព្រះនិព្វាននោះ ដោយបំណងនេះ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ឧបាសកសួរបដិភាគនៃ

អប្បដិភាគធម៌នេះ បុគ្គលគប្បីជ្រាបថា រមែងជាអ្នកផ្ដើមខុសក្នុងសំណួរ ដែលមានចំណែកកាត់សម្រេចគ្រប់ប្រការ ដូចភិក្ខុដែលបានសលាកកត្តក្នុងផ្ទះទី ៧ ហើយដើរហួសទៅ ផ្ទះទី ៧ ឈរនៅត្រង់ទ្វារផ្ទះទី ៨ ផ្ដើមខុសទៅទាំង ៧ ខ្នង មិនដឹងឡើយ យ៉ាងណា សេចក្ដីនេះក៏ដូច្នោះ ។ បទថា **និព្វានោគធំ** គឺចូលទៅខាងក្នុងព្រះនិព្វាន គឺទៅតាមព្រះនិព្វាន ។ បទថា **និព្វាន-បរាយនំ** គឺមានព្រះនិព្វាន ជាទីត្រាច់ទៅខាងមុខ គឺជាទីទៅខាងមុខនៃបុគ្គលនោះ អធិប្បាយថា បុគ្គលមិនទៅទីដទៃ ក្រៅអំពីព្រះនិព្វានឡើយ ។ ឈ្មោះថា **និព្វានបរិយន្តំ** ព្រោះព្រះនិព្វានជាទីបំផុតនៃបុគ្គលនោះ ។ បុគ្គលដែលដល់ព្រមដោយភាពជាបណ្ឌិត ឈ្មោះថា **បណ្ឌិតា** ដោយអត្ថថា ជាអ្នកឈ្លាសក្នុងធាតុ ក្នុងអាយតនៈ ក្នុងបដិច្ចសមុប្បាទ ក្នុងឋានៈ និងអឋានៈ ។ បទថា **មហាបញ្ញា** បានដល់ បុគ្គលដែលដល់ព្រមដោយបញ្ញាដែលអាចកំណត់កាន់យកនូវអត្ថដ៏ធំក្រៃលែង ធម៌ដ៏ធំក្រៃលែង និរុត្តិដ៏ធំក្រៃលែង បដិភាណដ៏ធំក្រៃលែង ។ បទថា **យថា តំ ធម្មទិន្នាយ** គឺសូម្បីតថាគតក៏គប្បីព្យាករដូច ដែលធម្មទិន្នាភិក្ខុនី ព្យាករហើយដូចគ្នានោះឯង ។

ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណោះ ព្រះសូត្រនេះ ក៏ក្លាយជាភាសិតរបស់ព្រះជិនស្រី ។ មិនមែនភាសិតរបស់សាវក ឧបមាដូចលិខិតដែលរាជ-លេខានុការ ( ស្មៀន ) សរសេរហើយ មិនទាន់ឈ្មោះថា ជាព្រះរាជសាស្ត្រ ល្គឹកណាមិនទាន់ប្រថាប់ព្រះរាជលញ្ឆករ គឺត្រារបស់ព្រះរាជាហើយ លិខិត

នោះក៏ឈ្មោះថា ជាព្រះរាជសាស្ត្រ យ៉ាងណា សូត្រនេះបានក្លាយជាភាសិតរបស់ព្រះជិនស្រី ដោយការទទួលស្គាល់ ដោយព្រះតម្រាស់ ព្រោះត្រា គឺព្រះតម្រាស់របស់ព្រះជិនស្រីនេះ បានប្រថាប់ហើយថា សូម្បីតថាគតក៏ព្យាករយ៉ាងនោះដូចគ្នា ដូច្នេះ ។ ពាក្យដ៏សេសគ្រប់អន្ទើ ងាយយល់ហើយ ដោយប្រការយ៉ាងនេះ ។៚

## ចូឡវេទល្លសូត្រ ចប់
## សូត្រទី ៤ ចប់

# សុត្តន្តបិដក

## ចូឡធម្មសមាទានសូត្រទី ៥

[ ១៥៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ១៥៥ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានទាំងឡាយនេះមាន ៤ យ៉ាង ធម្មសមាទាន ៤ យ៉ាង តើដូចម្តេចខ្លះ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានមានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានទុក្ខជាវិបាកតទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានមានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ១ ។

[ ១៥៦ ] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានដែលមានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកខ្លះ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយមិនមាន បានជាអ្នកទាំងនោះដល់នូវសេចក្តីស្រួលចិត្តក្នុង

កាមទាំងឡាយ ។ សមណព្រាហ្មណ៍ទាំងនោះ ក៏ឲ្យនាងបរិព្វាជិកាទាំងឡាយ ដែលមានផ្នួងសក់បួងហើយបម្រើខ្លួន អ្នកទាំងនោះពោលយ៉ាងនេះថា ចុះហេតុអ្វី បានជាសមណព្រាហ្មណ៍ដ៏ចម្រើនអម្បាលនោះ ពិចារណាឃើញអនាគត-ភ័យក្នុងកាមទាំងឡាយ ហើយពោលនូវការលះបង់នូវកាមទាំងឡាយ បញ្ញត្តនូវការកន្លងកាមទាំងឡាយ ដ្បិតថា សម្ផស្សក្រំក្នួនដៃរបស់នាងបរិព្វាជិកាជំទង់ប្រកបដោយរោមទន់នេះជាសុខម្ល៉េះ សមណព្រាហ្មណ៍ទាំងនោះ ក៏ដល់នូវសេចក្ដីស្រួលចិត្តក្នុងកាមទាំងឡាយ ។ សមណព្រាហ្មណ៍ទាំងនោះ ដល់នូវសេចក្ដីស្រួលចិត្តក្នុងកាមទាំងឡាយ លុះទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ សមណព្រាហ្មណ៍ទាំងនោះរងនូវទុក្ខវេទនាដ៏ក្លាខ្លាំង ខ្លោចផ្សាក្នុងអបាយនោះ ទើបអ្នកទាំងនោះពោលយ៉ាងនេះថា ឱនេះហើយតើ បានជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះពិចារណាឃើញអនាគតភ័យក្នុងកាមទាំងឡាយ ហើយពោលនូវការលះបង់នូវកាមទាំងឡាយ បញ្ញត្តនូវការកន្លងកាមទាំងឡាយ ឥឡូវយើងទាំងនេះក៏រងទុក្ខវេទនាដ៏ក្លាខ្លាំង ខ្លោចផ្សា ព្រោះមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផលមែន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាផ្លែជ្រៃទុំ បែកក្នុងខែជាទីបំផុតនៃគិម្ហរដូវទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពូជជ្រៃនោះ ក៏ជ្រុះចុះទៀបគល់រាំងភ្នំមួយដើម ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទេវតាណាដែលអាស្រ័យនៅលើដើមរាំងភ្នំនោះ ទេវតានោះ ក៏ភិតភ័យភ្ញាក់ផ្អើល ដល់នូវសេចក្ដីតក់ស្លុត ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង អារាមទេវតា វន-

ទេវតា រុក្ខទេវតា និងទេវតាដែលអាស្រ័យលើដើមឈើជាថ្នាំ និងស្មៅ និងដើមឈើជាធំក្នុងព្រៃទាំងឡាយ ជាមិត្ត ជាអាមាត្យជាញាតិសាលោហិតរបស់ទេវតាដែលអាស្រ័យនៅលើដើមរាំងភ្នំនោះ មកប្រជុំព្រមគ្នាលួងលោមយ៉ាងនេះថា អ្នកដ៏ចម្រើនកុំខ្លាចឡើយ អ្នកដ៏ចម្រើនកុំខ្លាចឡើយ ធ្វើម្ដេចឲ្យតែក្ងោកចឹកលេប ម្រឹគទំពាស៊ី ភ្លើងព្រៃឆេះ អ្នកធ្វើការងារក្នុងព្រៃបោចរោច ឬកណ្ដៀរពូនលុបនូវពូជជ្រៃនោះ ពុំនោះសោត ធ្វើម្ដេចឲ្យតែមិនមានពូជក៏បាន ។ ម្នាលភិក្ខុទាំងឡាយ ក្ងោកក៏មិនចឹកលេប ម្រឹគមិនទំពាស៊ី ភ្លើងព្រៃមិនឆេះ អ្នកធ្វើការងារក្នុងព្រៃមិនបោចរោច កណ្ដៀរមិនពូនលុបនូវពូជជ្រៃនុ៎ះ ពូជក៏នៅតែមាន ។ លុះមេឃមានភ្លៀងបង្អុរចុះមក ពូជជ្រៃនោះក៏ដុះលូតលាស់ឡើង ។ ពូជជ្រៃនោះខ្ចីទន់មានព្រុយសំយុងចុះ ។ ពូជជ្រៃនោះ ក៏រួបរឹតដើមរាំងភ្នំនោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ទេវតាដែលអាស្រ័យលើដើមរាំងភ្នំនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ហេតុអ្វីបានជាអារាមទេវតា វនទេវតា រុក្ខទេវតា និងទេវតាដែលអាស្រ័យនៅលើដើមឈើជាថ្នាំ និងស្មៅ និងឈើជាធំក្នុងព្រៃទាំងឡាយ ជាមិត្ត ជាអាមាត្យ ជាញាតិសាលោហិត ពិចារណាឃើញនូវអនាគតភ័យក្នុងពូជជ្រៃទាំងឡាយហើយ ប្រជុំព្រមគ្នាលួងលោមយ៉ាងនេះថា អ្នកដ៏ចម្រើនកុំខ្លាចឡើយ អ្នកដ៏ចម្រើនកុំខ្លាចឡើយ ធ្វើម្ដេចឲ្យតែក្ងោកចឹកលេប ម្រឹគទំពាស៊ី ភ្លើងព្រៃឆេះ អ្នកធ្វើការងារក្នុងព្រៃបោចរោច កណ្ដៀរពូនលុបនូវពូជជ្រៃនោះ ពុំនោះសោត ធ្វើម្ដេចឲ្យតែមិនមានពូជដូច្នេះ ( បើ ) សម្ផស្សរបស់ពួរជ្រៃនោះខ្ចីទន់ មានព្រុយសំយុងចុះ

ស្រួលម៉្លេះ ។ ( លុះកាលតមក ) ពួរជ្រៃនោះ ក៏រួបរឹតដើមរាំងភ្នំនោះ ។ លុះពួរជ្រៃនោះ រួបរឹតដើមរាំងភ្នំនោះហើយ ក៏ធ្វើជាប្រគាបស៊ុមទ្រុមខាងលើ សំយុងចុះចាប់ផែនដី ទម្លាយនូវដើមរាំងភ្នំធំៗ នោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ទេវតាដែលអាស្រ័យនៅដើមរាំងភ្នំនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱនេះហើយ បានជាអារាមទេវតា វនទេវតា រុក្ខទេវតា និងទេវតាដែលអាស្រ័យលើដើមឈើជាថ្នាំ និងស្មៅ និងដើមឈើធំក្នុងព្រៃទាំងឡាយ ជាមិត្ត ជាអាមាត្យ ជាញាតិសាលោហិត ពិចារណាឃើញអនាគតភ័យក្នុងពូជជ្រៃ ហើយមកប្រជុំ ព្រមគ្នាលួងលោមយ៉ាងនេះថា អ្នកដ៏ចម្រើនកុំខ្លាចឡើយ អ្នកដ៏ចម្រើនកុំខ្លាចឡើយ ធ្វើម្តេចឲ្យតែក្ងោកចឹកលេប ម្រឹគទំពាស៊ី ភ្លើងព្រៃឆេះ អ្នកធ្វើការងារក្នុងព្រៃបោចរោច កណ្តៀរពូនលុបនូវពូជជ្រៃនុ៎ះ ពុំនោះសោត ធ្វើម្តេចឲ្យតែមិនមានពូជ ឥឡូវអញក៏បានរងទុក្ខវេទនាដ៏ក្លាខ្លាំង ខ្លោចផ្សាព្រោះហេតុតែ ពូជជ្រៃ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចជាសមណព្រាហ្មណ៍ពួកខ្លះ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយមិនមាន បានជាអ្នកទាំងនោះ ដល់នូវសេចក្តីស្រួលចិត្តក្នុងកាមទាំងឡាយ ។ សមណព្រាហ្មណ៍ទាំងនោះ ក៏ឲ្យពួកនាងបរិញ្វាជិកាដែលមានផ្នួងសក់បួងហើយបម្រើខ្លួន អ្នកទាំងនោះពោលយ៉ាងនេះថា ចុះហេតុអ្វីបានជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ពិចារណាឃើញនូវអនាគតភ័យក្នុងកាមទាំងឡាយ ហើយពោលនូវការលះបង់នូវកាមទាំងឡាយ បញ្ញត្តនូវការកន្លងកាមទាំងឡាយ ដ្បិតថា សម្ផស្សកំភួន

ដៃរបស់នាងបរិញ្វជិកាជំទង់ ប្រកបដោយរោមទន់នេះ ជាសុខម្ល៉េះ សមណព្រាហ្មណ៍ទាំងនោះ ក៏ដល់នូវសេចក្ដីស្រួលចិត្តក្នុងកាមទាំងឡាយ ។ លុះសមណព្រាហ្មណ៍ទាំងនោះ ដល់នូវសេចក្ដីស្រួលចិត្តក្នុងកាមទាំងឡាយហើយ ទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ សមណព្រាហ្មណ៍ទាំងនោះ រងនូវទុក្ខវេទនាដ៏ក្លាខ្លាំង ខ្លោចផ្សាក្នុងអបាយនោះ ទើបសមណព្រាហ្មណ៍ទាំងនោះពោលយ៉ាងនេះ ក្នុងទីនោះថា ឱនេះហើយតើ បានជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ពិចារណាឃើញអនាគតភ័យក្នុងកាមទាំងឡាយ ហើយពោលនូវការលះបង់នូវកាមទាំងឡាយ បញ្ញត្តនូវការកន្លងកាមទាំងឡាយ ឥឡូវយើងទាំងនេះក៏រងទុក្ខវេទនាដ៏ក្លាខ្លាំង ខ្លោចផ្សា ព្រោះមានកាមជាហេតុ មានកាមជាគ្រឿងប្រគល់ឲ្យនូវផល ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតពោលថា មានសេចក្ដីសុខក្នុងបច្ចុប្បន្ន តែមានសេចក្ដីទុក្ខជាវិបាកតទៅ ។

[ ១៥៧ ] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានដែលមានសេចក្ដីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីទុក្ខជាវិបាកតទៅ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអចេលក៍ ( អ្នកប្រព្រឹត្តអាក្រាត ) លះបង់មារយាទល្អ បរិភោគលិទ្ធដៃ គេអញ្ជើញថា ចូរមក មិនចូល គេឃាត់ថា ឈប់ មិនឈប់ មិនត្រេកអរនឹងភត្តដែលគេនាំមកចំពោះ មិនត្រេកអរនឹងភត្តដែលគេធ្វើចំពោះខ្លួន មិនត្រេកអរនឹងការនិមន្ត ។ អចេលក៍នោះ មិនទទួលភត្តដែលគេដួសអំពីមាត់ឆ្នាំង មិនទទួលភត្តអំពីមាត់ចង្អេរ

កឡោបី មិនទទួលភត្តដែលគេឲ្យត្រង់ចន្លោះធរណីទ្វារ មិនទទួលភត្តដែលគេឲ្យត្រង់ចន្លោះអង្រែ មិនទទួលភត្តដែលគេឲ្យត្រង់ចន្លោះកំណាត់ឈើ មិនទទួលភត្តដែលជនពីរនាក់កំពុងបរិភោគនាំមកឲ្យ មិនទទួលភត្តរបស់ស្រីមានគភ៌ មិនទទួលភត្តរបស់ស្រីកំពុងបំបៅកូន មិនទទួលភត្តរបស់ស្រីនៅក្នុងចន្លោះបុរស មិនទទួលភត្តក្នុងកាលដែលពួកគ្នាឯងធ្វើអង្គាសបាន មិនទទួលភត្តក្នុងទីមានឆ្កែចាំ មិនទទួលភត្តក្នុងទីមានរុយរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកត្រាំថ្នាំ ។ អចេលក៍នោះ ទទួលភត្តចំពោះតែផ្ទះមួយខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយមួយពំនូតខ្លះ ទទួលភត្តចំពោះតែផ្ទះពីរខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយពីរពំនូតខ្លះ ។បេ។ ទទួលភត្តចំពោះតែផ្ទះ ៧ ខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយ ៧ ពំនូតខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភត្តក្នុងភាជន៍មួយខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ពីរខ្លះ ។បេ។ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ ៧ ខ្លះ បរិភោគអាហាររំលង ១ ថ្ងៃខ្លះ បរិភោគអាហាររំលង ៧ ថ្ងៃខ្លះ អចេលក៍នោះប្រកបនូវភត្តភោជនដោយការផ្លាស់ប្តូរគ្នាអស់កន្លះខែ មានសភាពយ៉ាងនេះ ដោយប្រការដូច្នេះឯង ។ អចេលក៍នោះមានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្កួយជាអាហារខ្លះ មានចំនៀរស្បែកជាអាហារខ្លះ មានសារាយជាអាហារខ្លះ មានកុណ្ឌកជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានកំញានជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមផ្លែឈើក្នុង

ព្រៃជាអាហារ និងផ្លែឈើដែលជ្រុះចុះឯងជាភោជនខ្លះ ។ អចេលក៍នោះ ប្រើប្រាស់សំពត់សម្បកធ្មៃខ្លះ ប្រើប្រាស់សំពត់ដែលត្បាញលាយគ្នាខ្លះ ប្រើប្រាស់សំពត់ស្មប់ខ្លះ ប្រើប្រាស់សំពត់បង្សុកូលខ្លះ ប្រើប្រាស់សំពត់សម្បកឈើខ្លះ ប្រើប្រាស់ស្បែកខ្លាខ្លះ ប្រើប្រាស់ស្បែកខ្លាទាំងក្រចកខ្លះ ប្រើប្រាស់សំពត់ដែលក្រងដោយស្បូវក្លាំងខ្លះ ប្រើប្រាស់សំពត់ ដែលធ្វើដោយបន្ទះឈើខ្លះ ប្រើប្រាស់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ ប្រើប្រាស់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ជាអ្នកដកសក់ និងពុកមាត់ខ្លះ ប្រកបរឿយៗ នូវការដកសក់ និងពុកមាត់ខ្លះ ជាអ្នកឈរសម្រឹងខាងលើខ្លះ ហាមឃាត់អាសនៈខ្លះ អង្គុយប្រហោងខ្លះ ជាអ្នកប្រកបរឿយៗ នូវការព្យាយាមក្នុងការអង្គុយប្រហោងខ្លះ ដេកលើបន្លាខ្លះ សម្រេចការដេកលើបន្លាខ្លះ ប្រកបរឿយៗ ក្នុងការព្យាយាមចុះត្រាំទឹកគម្រប់ ៣ ដង ទាំងវេលាល្ងាចខ្លះ អចេលក៍នោះ ជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើកាយឲ្យក្តៅក្រហាយច្រើនយ៉ាង មានសភាពយ៉ាងនេះ ដោយប្រការដូច្នេះឯង ។ អចេលក៍នោះ លុះទម្លាយកាយបន្ទាប់អំពីមរណៈទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតពោលថា មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន និងមានសេចក្តីទុក្ខជាវិបាកតទៅ ។

[ ១៥៨ ] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានដែលមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកមានជាតិប្រកបដោយរាគៈ ដ៏

ក្តៅក្លាតាមប្រក្រតី បុគ្គលនោះតែងរងសេចក្តីទុក្ខ ទោមនស្សដែលកើតអំពីរាគៈរឿយៗ ។ ជាអ្នកមានជាតិប្រកបដោយទោសៈដ៏ក្តៅក្លា តាមប្រក្រតី បុគ្គលនោះតែងរងសេចក្តីទុក្ខទោមនស្ស ដែលកើតអំពីទោសៈរឿយៗ ។ ជាអ្នកមានជាតិប្រកបដោយមោហៈដ៏ក្តៅក្លា តាមប្រក្រតី បុគ្គលនោះ តែងរងសេចក្តីទុក្ខទោមនស្សដែលកើតអំពីមោហៈរឿយៗ ។ បុគ្គលនោះ ទោះបីសេចក្តីទុក្ខពាល់ត្រូវក្តី ទោះបីទោមនស្សពាល់ត្រូវក្តី ទោះបីមានមុខទទឹកដោយទឹកភ្នែកទួញយំក្តី ក៏គង់តែប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធបាន ។ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតហៅថា មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ។

[ ១៥៩ ] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានដែលមានសេចក្តីសុខក្នុងបច្ចុប្បន្នទាំងមានសេចក្តីសុខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ មិនជាអ្នកមានជាតិប្រកបដោយរាគៈដ៏ក្តៅក្លា តាមប្រក្រតី បុគ្គលនោះមិនរងទុក្ខទោមនស្ស ដែលកើតអំពីរាគៈរឿយៗ ។ មិនជាអ្នកមានជាតិប្រកបដោយទោសៈដ៏ក្តៅក្លាតាមប្រក្រតី បុគ្គលនោះមិនរងទុក្ខទោមនស្ស ដែលកើតអំពីទោសៈរឿយៗ ។ មិនជាអ្នកមានជាតិប្រកបដោយមោហៈដ៏ក្តៅក្លា តាមប្រក្រតី បុគ្គលនោះមិនរងទុក្ខទោមនស្ស ដែលកើតអំពីមោហៈរឿយៗ ។ បុគ្គលនោះ ជាអ្នកស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈាន ដែលប្រកប

ដោយវិតក្ក វិចារៈ មានបីតិ និងសុខកើតអំពីសេចក្ដីស្ងប់ស្ងាត់ ។ លុះបុគ្គល នោះ បានរម្ងាប់វិតក្ក វិចារៈហើយ ក៏ចូលកាន់ទុតិយជ្ឈានដែលមានក្នុងខ្លួន ជាទីជ្រះថ្លា មានភាពនៃចិត្តដ៏ខ្ពស់ឯក គ្មានវិតក្ក គ្មានវិចារៈ មានតែបីតិ និង សុខកើតអំពីសមាធិ ... ចូលកាន់តតិយជ្ឈាន ... ចូលកាន់ចតុត្ថជ្ឈាន ។ បុគ្គលនោះលុះទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ តែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតហៅថា មានសេចក្ដីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីសុខជាវិបាកតទៅ ។ ម្នាលភិក្ខុ ទាំងឡាយ នេះឯងជាធម្មសមាទានមាន ៤ ប្រការ ។ លុះព្រះមានព្រះភាគ សម្ដែងភាសិតនេះចប់ហើយ ភិក្ខុទាំងនោះក៏មានចិត្តត្រេកអរ រីករាយហើយ នឹងភាសិតរបស់ព្រះមានព្រះភាគ ។

## ចូឡធម្មសមាទានសូត្រទី ៥ ចប់

# អដ្ឋកថា

## ចូឡធម្មសមាទានសូត្រទី ៩

[ ១៥៤ ] ចូឡធម្មសមាទានសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ១៥៥ ] បណ្ដាបទទាំងនោះ បទថា **ធម្មសមាទានានិ** បានដល់ការកាន់យក ដែលលោកកាន់យកដោយបទថា **ធម្ម** ដូច្នេះ ។ បទថា **បច្ចុប្បន្នសុខំ** បានដល់ សេចក្ដីសុខដែលកើតក្នុងបច្ចុប្បន្ន ។ សេចក្ដីសុខក្នុងការប្រមូលមកធ្វើបានងាយ គឺអាចឲ្យពេញបានដោយងាយ ។ បទថា **អាយតឹ ទុក្ខវិបាកំ** បានដល់ ផលដែលជាទុក្ខក្នុងអនាគតកាល ។ គប្បីជ្រាបអធិប្បាយក្នុងបទទាំងពួងដោយឧបាយនេះ ។ បទថា **នត្ថិ កាមេសុ ទោសោ** សេចក្ដីថា មិនមានទោសក្នុងវត្ថុកាមខ្លះ កិលេសកាមខ្លះ ។

បទថា **បាតព្យតំ អាបជ្ជន្តិ** សេចក្ដីថា សមណព្រាហ្មណ៍ទាំងនោះដល់នូវការឆ្អែតស្កប់ស្កល់ គឺភាពជាវត្ថុដែលខ្លួនគប្បីផឹក បានដល់ ភាពជាវត្ថុ ដែលខ្លួនគប្បីបរិភោគតាមពេញចិត្ត ដោយកិលេសកាមក្នុងវត្ថុកាម ។

បទថា **មោលិពទ្ធាហិ** បានដល់ ពួកតាបស និងបរិព្វាជកដែលចងសក់ធ្វើជាកំប៉ោយ ។ បទថា **បរិព្វាជិកាហិ** បានដល់ អ្នកបួសជាតាបសិនី ។ បទថា **ឯវមាហំសុ** គឺរមែងពោលយ៉ាងនេះ ។ បទថា **បរិញ្ញំ បញ្ញបេន្តិ** បានដល់ រមែងបញ្ញត្តការលះ គឺការឈានកន្លង ។ បទថា **មាលុវាសិបា–ដិកា** បានដល់ ចង្កោមផ្លែជ្រៃដែលទុំហើយ មានសណ្ឋានវែង ។ បទថា

**ផលេយ្យ** សេចក្តីថា ស្ងួតដោយកម្តៅ ហើយបែក ។ បទថា **សាលមូលេ** បានដល់ ក្បែរដើមរាំងភ្នំ ។ បទថា **សន្តាសំ អាបជ្ជេយ្យ** សេចក្តីថា រមែងដល់នូវការតក់ស្លុត ព្រោះហេតុអ្វី ព្រោះខ្លាចការវិនាសទៅនៃទីលំនៅ ព្រោះថា ផ្លែជ្រៃដែលធ្លាក់ទៅត្រង់ដើមឈើ កើតឡើងហើយអំពីពូជ រមែងវារឡើងដើមឈើ ។ បើឫសជ្រៃនោះមានស្លឹកធំ និងក្រាស់ ប្រកបដោយស្លឹកដូចគ្នានឹងស្លឹករលួសផ្អុង លំដាប់នោះ ពួរនៃជ្រៃកម្ចាត់ដើមឈើនោះ តាំងអំពីគល់ទៅរហូតដល់ប្រគាបទាំងពួង ឲ្យកើតទម្ងន់យ៉ាងច្រើន តាំងនៅ វល្លិជ្រៃនោះ កាលខ្យល់បក់មក ឬកាលភ្លៀងធ្លាក់ ធ្វើនូវកម្រាស់ កាច់បំបាក់មែកធំតូចទាំងពួងនៃដើមឈើនោះ ឲ្យធ្លាក់ទៅលើផែនដី បន្ទាប់អំពីនោះ កាលដើមឈើនោះដួលទៅ វិមានរមែងបាក់បែកវិនាសទៅ ទេវតានោះ ដល់នូវការភ័យខ្លាច ព្រោះខ្លាចការវិនាសទៅនៃវិមាន ដោយប្រការដូច្នេះ ។

បទថា **អារាមទេវតា** សេចក្តីថា ទេវតាដែលនៅអាស្រ័យក្នុងសួនផ្កា និងសួនផ្លែឈើនោះៗ ។

បទថា **វនទេវតា** បានដល់ ទេវតាដែលអាស្រ័យនៅក្នុងព្រៃអន្លង់ និងសុកគវនជាដើម ។ បទថា **រុក្ខទេវតា** បានដល់ ទេវតានៅអាស្រ័យត្រង់ដើមស្តៅជាដើម ដែលហួងហែង ។

បទថា **ឱសធិតិណវនប្បតីសុ** សេចក្តីថា ទេវតាបានអាស្រ័យហើយត្រង់ដើមឈើដែលជាឱសថ មានដើមសម៉ និងដើមកន្ទួតព្រៃជាដើម ត្រង់ដើមស្មៅ មានត្នោត និងដូងជាដើម និងដើមឈើម្ចាស់ព្រៃ ដែលជាឈើធំ

បំផុតក្នុងព្រៃ ។ បទថា **វនកម្មិក** សេចក្តីថា ពួកមនុស្សដែលធ្វើការងារណាមួយ មានក្ជួរ ប្រួត ដីកឧស និងឃ្វាលគោជាដើមក្នុងព្រៃ ។ បទថា **ឧឌ្ឌហេយ្យុំ** បានដល់ គប្បីទំពាស៊ី ។ បទថា **វិលម្ពិនិ** បានដល់ សំយុងចុះដូចកង់សម្រាប់លេងក្នុងទីដែលត្រូវខ្យល់បក់ ។ បទថា **សុខោ ឥមិស្សា** សេចក្តីថា ពួរជ្រៃយ៉ាងនេះ សូម្បីពាល់ត្រូវក៏ជាសុខ សូម្បីសម្លឹងមើលក៏កើតសេចក្តីសុខ រមែងឲ្យកើតការពេញចិត្តក្នុងការមើល និងការពាល់ត្រូវ បើពួកកូនរបស់យើងនឹងមានរោងផឹក នឹងមានទីលេង យើងបានវិមានទី ២ ហើយ ព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះ ។ បទថា **វិដភឹ ការេយ្យ** សេចក្តីថា គប្បីតាំងនៅដោយអាការដូចឆត្រ ខាងលើមែកឈើទាំងឡាយ ។

បទថា **ឱយនំ ជនេយ្យ** សេចក្តីថា ធ្វើឲ្យកើតម្លប់ខាងក្រោម ។ ពួរជ្រៃនោះ កាលវារឡើងខាងលើ ក៏រុំដើមឈើទាំងមូលទុកខាងក្រោមទៀត ។ បទថា **បនាលេយ្យ** សេចក្តីថា ធ្វើឲ្យក្រាស់យ៉ាងនេះ បន្ទាប់អំពីនោះ ដើមជ្រៃនេះក៏វារឡើងទៅតាំងអំពីគល់តាមមែក ដែលដុះឡើងទៅហើយ រុំព័ទ្ធមែកគ្រប់មែក កាលដល់ចុងហើយ ក៏សំយុងចុះដោយទំនងនោះឯងទៀត និងវារឡើងទៅរួបរឹតដើមឈើទាំងអស់ ឲ្យមែកទាំងអស់នៅខាងក្រោម ខ្លួនឯងនៅខាងលើ កាលខ្យល់បក់ ឬភ្លៀងធ្លាក់ ក៏នឹងបែកធ្លាយខ្ទាត់ខ្ទាយទៅ វិមាននោះ គប្បីតាំងនៅត្រឹមតែគ្រឹះប៉ុណ្ណោះ ត្រង់គល់ដើមឈើនោះ តែងមានវិមានដែលនៅលើមែកឈើ កាលមែកឈើបាក់ បានទម្លាយត្រង់មែកនោះៗ កាលមែកទាំងអស់បាក់អស់ វិមានទាំងពួងក៏វិនាស វិមានដែលតាំង

នៅលើដើមឈើ ក៏នឹងតាំងនៅត្រឹមតែគល់ដើមឈើ ដរាបមិនទាន់វិនាស នេះជាវិមានដែលនៅលើមែកឈើ ព្រោះដូច្នោះ កាលមែកទាំងអស់បាក់អស់ហើយ ទេវតាបានពរកូនតូច ឈរត្រង់ជង្គត់ឈើ ហើយក៏កន្ទក់កន្ទេញ ។

[ ១៥៨ ] បទថា **តិព្វរាគជាតិកោ** បានដល់ បុគ្គលមានរាគៈក្រាស់ជាសភាវៈ ។

បទថា **រាគជំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ** សេចក្ដីថា ព្រោះភាពជាអ្នកមានជាតិរាគៈខ្លាំងក្លា រមែងកាន់យកនិមិត្តក្នុងអារម្មណ៍ដែលឃើញហើយ ។ កាលនោះ ពួកអាចារ្យ និងឧបជ្ឈាយ៍របស់លោក បញ្ជាឲ្យដាក់ទណ្ឌកម្ម កាលធ្វើទណ្ឌកម្មរឿយៗ រមែងសោយទុក្ខទោមនស្ស ទើបមិនធ្វើការឈានកន្ទុំទៀតនោះឯង ។ សម្រាប់បុគ្គលមានជាតិប្រកបដោយទោសៈខ្លាំងក្លា រមែងកម្រើកដោយហេតុត្រឹមតែតិចតួចប៉ុណ្ណោះ កាលបុគ្គលនោះ ចាប់ដៃជាដើម ជជែកជាមួយភិក្ខុកំលោះ និងសាមណេរទាំងឡាយ ក៏រមែងសោយទុក្ខទោមនស្ស ព្រោះទណ្ឌកម្មជាបច្ច័យ ។

ឯបុគ្គលមានជាតិជាមោហៈ មិនកំណត់កិច្ចដែលធ្វើហើយ ថាធ្វើហើយ ឬកិច្ចដែលមិនទាន់បានធ្វើ ថាមិនទាន់បានធ្វើក្នុងសាសនានេះ រមែងឲ្យកិច្ចឃ្លៀងឃ្លាត សូម្បីបុគ្គលនោះ ក៏រមែងសោយទុក្ខទោមនស្ស ព្រោះទណ្ឌកម្មជាបច្ច័យ ។

[ ១៥៩ ] បទថា **ន តិព្វរាគជាតិកោ** គប្បីជ្រាបតាមន័យដែលផ្ទុយគ្នានឹងពោលហើយ ។

សួរថា ព្រោះហេតុអ្វី ក្នុងលោកនេះ បុគ្គលខ្លះជាអ្នកមានរាគៈជាដើមខ្លាំងក្លា បុគ្គលខ្លះមានរាគៈជាដើមមិនខ្លាំងក្លា ឆ្លើយថា ព្រោះថា ក្នុងខណៈសន្សំកម្មតាមទំនៀមរបស់កម្ម លោភៈនៃបុគ្គលណាមានកម្លាំង អលោភៈខ្សោយកម្លាំង អទោសៈ និងអមោហៈមានកម្លាំង ទោសៈ និងមោហៈខ្សោយ កម្លាំង អលោភៈនៃបុគ្គលនោះខ្សោយកម្លាំង មិនអាចគ្របសង្កត់លោភៈបាន ។ ឯអទោសៈ និងអមោហៈមានកម្លាំង អាចគ្របសង្កត់ទោសៈនិងមោហៈបាន ព្រោះដូច្នោះ បុគ្គលនោះកើតហើយ ដោយអំណាចបដិសន្ធិដែលកម្មនោះឲ្យផលហើយ រមែងជាបុគ្គលលោភលន់ មានប្រក្រតីជាសុខមិនក្រោធ មានបញ្ញា មានបញ្ញាប្រៀបដូចពេជ្រ ។ ក្នុងខណៈសន្សំកម្មលោភៈ និងទោសៈ នៃបុគ្គលណាមានកម្លាំង អលោភៈ និងអទោសៈខ្សោយកម្លាំង អមោហៈមានកម្លាំង មោហៈខ្សោយកម្លាំង បុគ្គលនោះរមែងជាអ្នកលោភលន់ ជាអ្នកក្រោធខឹង តាមន័យមុននោះឯង ជាអ្នកមានបញ្ញា មានបញ្ញាដូចពេជ្រ ដូចព្រះទត្តាភយត្ថេរ ដូច្នោះ ។ ឯខណៈសន្សំកម្ម លោភៈទោសៈ មោហៈនៃបុគ្គលណាមានកម្លាំង កិលេសក្រៅពីនេះខ្សោយកម្លាំងបុគ្គលនោះ រមែងជាអ្នកលោភ និងល្ងង់ខ្លៅ តាមន័យមុននោះឯង ជាអ្នកមានប្រក្រតីជាសុខ មិនក្រោធ ។

សេចក្តីនេះដែរ ក្នុងខណៈសន្សំកម្ម លោភៈ ទោសៈ និងមោហៈ ទាំង ៣ របស់បុគ្គលណាមានកម្លាំង អលោភៈជាដើមខ្សោយកម្លាំង បុគ្គលនោះរមែងលោភ ប្រទូស្ត និងវង្វេង តាមន័យមុននោះឯង ។ តែក្នុងខណៈសន្សំ

កម្ម អលោភៈ ទោសៈ និងមោហៈនៃបុគ្គលណាមានកម្លាំង កិលេសក្រៅអំពីនេះខ្សោយកម្លាំង បុគ្គលនោះរមែងជាអ្នកមានកិលេសតិច កាលឃើញអារម្មណ៍ជាទិព្វ ក៏មិនញាប់ញ័រ តាមន័យមុននោះឯង តែជាអ្នកប្រទូស្ត និងមានបញ្ញាខ្សោយ ។ ក្នុងខណៈសន្សំកម្ម អលោភៈ អទោសៈ និងមោហៈនៃបុគ្គលណាមានកម្លាំង កិលេសក្រៅអំពីនេះ ខ្សោយកម្លាំង បុគ្គលនោះរមែងជាអ្នកមិនលោភ មានប្រក្រតីជាសុខ មិនក្រោធ តែជាអ្នកល្ងង់ខ្លៅតាមន័យដែលពោលមុននោះឯង ។ ដូចគ្នានេះដែរ ក្នុងខណៈសន្សំកម្ម អលោភៈ ទោសៈ អមោហៈនៃបុគ្គលណាមានកម្លាំង កិលេសក្រៅពីនេះខ្សោយកម្លាំង បុគ្គលនោះ រមែងជាអ្នកមិនលោភ មានបញ្ញា តែជាអ្នកប្រទូស្ត និងច្រើនដោយសេចក្តីក្រោធតាមន័យមុននោះឯង ។ តែក្នុងខណៈសន្សំកម្ម កិលេសទាំង ៣ មានអលោភៈជាដើមនៃបុគ្គលណាមានកម្លាំង កាលលោភៈជាដើមមានកម្លាំងខ្សោយ បុគ្គលនោះរមែងជាអ្នកមិនលោភ មិនប្រទូស្ត និងមានបញ្ញា ដូចព្រះមហាសង្ឃរក្ខិតត្ថេរ ដូច្នោះ ។ អត្ថក្នុងបទដ៏សេសទាំងពួងងាយយល់ហើយនោះឯង ៕

**ចូឡធម្មសមាទានសូត្រ ចប់**

**សូត្រទី ៥ ចប់**

# សុត្តន្តបិដក

## មហាធម្មសមាទានសូត្រទី ៦

[ ១៦០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំង-ឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ១៦១ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយច្រើនតែមានសេចក្តីប្រាថ្នាយ៉ាងនេះ មានអធ្យាស្រ័យយ៉ាងនេះ មានបំណងយ៉ាងនេះថា ធ្វើម្តេចហ្ន៎ អារម្មណ៍ទាំងឡាយមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត គប្បីសាបសូន្យទៅ អារម្មណ៍ទាំងឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត គប្បីចម្រើនឡើង ម្នាលភិក្ខុទាំង-ឡាយ កាលសត្វអម្បាលនោះ មានសេចក្តីប្រាថ្នាយ៉ាងនេះ មានអធ្យាស្រ័យយ៉ាងនេះ មានបំណងយ៉ាងនេះ អារម្មណ៍មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងចម្រើនឡើង អារម្មណ៍ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងសាបសូន្យទៅ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយពិចារណាឃើញនូវដំណើរនោះដូចម្តេច ក្នុងអារម្មណ៍ទាំងនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ពួកខ្ញុំព្រះអង្គ មានព្រះមានព្រះភាគជាមូល មានព្រះមានព្រះភាគ ជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹង បពិត្រព្រះ

អង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់បំភ្លឺនូវអត្ថនៃភាសិតនុ៎ះ ភិក្ខុទាំងឡាយ បើបានស្តាប់ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគហើយនឹងចងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរស្តាប់ ចូរធ្វើមនសិការដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ១៦២ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះជាអ្នកមិនដែលបានស្តាប់ មិនដែលបានឃើញព្រះអរិយៈទាំងឡាយ មិនឈ្លាសក្នុងអរិយធម៌ មិនទូន្មានខ្លួនក្នុងអរិយធម៌ មិនឃើញសប្បុរសទាំងឡាយ មិនឈ្លាសក្នុងធម៌របស់សប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស មិនស្គាល់ធម៌ ដែលគួរសេព មិនស្គាល់ធម៌ដែលមិនគួរសេព មិនស្គាល់ធម៌ដែលគួរគប់ មិនស្គាល់ធម៌ដែលមិនគួរគប់ ។ កាលបុថុជ្ជននោះ មិនស្គាល់ធម៌ដែលគួរសេព មិនស្គាល់ធម៌ដែលមិនគួរសេព មិនស្គាល់ធម៌ដែលគួរគប់ មិនស្គាល់ធម៌ដែលមិនគួរគប់ តែងសេពនូវធម៌ដែលមិនគួរសេព មិនសេពនូវធម៌ដែលគួរសេព គប់នូវធម៌ដែលមិនគួរគប់ មិនគប់នូវធម៌ដែលគួរគប់ ។ កាលបើបុថុជ្ជននោះ សេពនូវធម៌ដែលមិនគួរសេព មិនសេពនូវធម៌ដែលគួរសេព គប់នូវធម៌ដែលមិនគួរគប់ មិនគប់នូវធម៌ដែលគួរគប់ អារម្មណ៍ទាំងឡាយមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តតែងចម្រើនឡើង អារម្មណ៍ទាំងឡាយជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តក៏សាបសូន្យទៅ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ

ព្រោះបុថុជ្ជនអន្ធពាល មិនដឹងតាមពិត ក៏រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចំណែកខាងអរិយសាវកដែលបានស្តាប់ បានឃើញព្រះអរិយៈទាំង-ឡាយ ជាអ្នកឈ្លាសក្នុងអរិយធម៌ ទូន្មានខ្លួនល្អក្នុងសប្បុរិសធម៌ ស្គាល់ធម៌ដែលគួរសេព ស្គាល់ធម៌ដែលមិនគួរសេព ស្គាល់ធម៌ដែលគួរគប់ ស្គាល់ធម៌ដែលមិនគួរគប់ ។ កាលអរិយសាវកនោះ ស្គាល់ធម៌ដែលគួរសេព ស្គាល់ធម៌ដែលមិនគួរសេព ស្គាល់ធម៌ដែលគួរគប់ ស្គាល់ធម៌ដែលមិនគួរគប់ ទើបមិនសេពធម៌ដែលមិនគួរសេព សេពតែធម៌ដែលគួរសេព មិនគប់ធម៌ដែលមិនគួរគប់ គប់តែធម៌ដែលគួរគប់ ។ កាលបើអរិយសាវកនោះ មិនសេពធម៌ដែលមិនគួរសេព សេពតែធម៌ដែលគួរសេព មិនគប់ធម៌ដែលមិនគួរគប់ គប់តែធម៌ដែលគួរគប់ អារម្មណ៍ទាំងឡាយមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងសាបសូន្យទៅ អារម្មណ៍ទាំងឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត តែងចម្រើនឡើង ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះអរិយសាវក ជាអ្នកដឹងតាមពិត ក៏រមែងដូច្នោះឯង ។

[ ១៦៣ ] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានទាំងឡាយនេះ មាន ៤ យ៉ាង ធម្មសមាទានទាំង ៤ យ៉ាង តើដូចម្តេចខ្លះ ម្នាលភិក្ខុទាំងឡាយ ធម្ម-សមាទាន ដែលមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីទុក្ខជាវិបាកតទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានមានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានមានសេចក្តី

ទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ១ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានមានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ១ ។

[ ១៦៤ ] ម្នាលភិក្ខុទាំងឡាយ បណ្តាធម្មសមាទានអម្បាលនោះ ធម្មសមាទានណា មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីទុក្ខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិតថា ធម្មសមាទាននេះឯង មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីទុក្ខជាវិបាកតទៅ ។ កាលបើភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិត ក៏រមែងសេពនូវធម្មសមាទាននោះ មិនវៀរចាកនូវធម្មសមាទាននោះឡើយ ។ កាលបើភិក្ខុនោះ សេពនូវធម្មសមាទាននោះ មិនវៀរធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងចម្រើនឡើង អារម្មណ៍ទាំងឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងសាបសូន្យទៅ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះបុថុជ្ជនមិនដឹងតាមពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម្មសមាទានទាំងនោះ ធម្មសមាទានណា ដែលមានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិតថា ធម្មសមាទាននេះឯង មានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ ។ កាលភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិត ក៏រមែងសេពនូវធម្ម-

សមាទាននោះ មិនវៀរចាកធម្មសមាទាននោះឡើយ ។ កាលបើភិក្ខុនោះ សេពនូវធម្មសមាទាននោះ មិនវៀរចាកធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងចម្រើនឡើង អារម្មណ៍ទាំងឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត រមែងសាបសូន្យទៅ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះបុថុជ្ជនមិនដឹងតាមពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម្មសមាទានទាំងនោះ ធម្មសមាទានណា ដែលមានសេចក្ដីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្ដីសុខជាវិបាកតទៅ ភិក្ខុមិនដឹងនូវធម្មសមាទាននោះ ជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្ដីពិតថា ធម្មសមាទាននេះឯង មានសេចក្ដីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្ដីសុខជាវិបាកតទៅ ។ កាលភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្ដីពិត ក៏រមែងសេពនូវធម្មសមាទាននោះ មិនវៀរចាកធម្មសមាទាននោះឡើយ ។ កាលបើភិក្ខុនោះ សេពនូវធម្មសមាទាននោះ មិនវៀរចាកធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងចម្រើនឡើង អារម្មណ៍ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងសាបសូន្យទៅ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះបុថុជ្ជនមិនដឹងតាមពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម្មសមាទាននោះ ធម្មសមាទានណា ដែលមានសេចក្ដីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្ដីសុខជាវិបាកតទៅ ភិក្ខុជា

អ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិត ថា ធម្មសមាទាននេះឯង មានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ។ កាលភិក្ខុជាអ្នកប្រកបដោយអវិជ្ជា មិនដឹងនូវធម្មសមាទាននោះ មិនស្គាល់តាមសេចក្តីពិត ក៏រមែងសេពនូវធម្មសមាទាននោះ មិនវៀរបាកធម្មសមាទាននោះឡើយ ។ កាលបើភិក្ខុនោះ សេពនូវធម្មសមាទាននោះ មិនវៀរចាកធម្មសមាទាននោះ អារម្មណ៍ទាំងឡាយមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងចម្រើនឡើង អារម្មណ៍ទាំងឡាយជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងសាបសូន្យទៅ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះបុថុជ្ជនមិនដឹងតាមពិត រមែងដូច្នោះឯង។

[ ១៦៥ ] ម្នាលភិក្ខុទាំងឡាយ បណ្តាធម្មសមាទាននោះ ធម្មសមាទានណា ដែលមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីទុក្ខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្តីពិតថា ធម្មសមាទាននេះឯង មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីទុក្ខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយវិជ្ជាដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្តីពិត រមែងមិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះ ។ កាលបើភិក្ខុនោះមិនសេព នូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងសាបសូន្យទៅ អារម្មណ៍ទាំងឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងចម្រើនឡើង ចុះដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំង-

ឡាយ ដំណើរនុ៎ះ ព្រោះភិក្ខុជាអ្នកដឹងតាមពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម្មសមាទានទាំងនោះ ធម្មសមាទានណា ដែលមានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយវិជ្ជាដឹងធម្មសមាទាននោះ ស្គាល់តាមសេចក្តីពិតថា ធម្មសមាទាននេះឯង មានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ ។ កាលភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្តីពិត រមែងមិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះហើយ ។ កាលបើភិក្ខុនោះមិនសេព នូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះ អារម្មណ៍ទាំងឡាយមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងសាបសូន្យទៅ អារម្មណ៍ទាំងឡាយជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងចម្រើនឡើង ចុះដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះភិក្ខុជាអ្នកដឹងតាមពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម្មសមាទានទាំងនោះ ធម្មសមាទានណា ដែលមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយវិជ្ជាដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្តីពិតថា ធម្មសមាទាននេះឯង មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ។ ភិក្ខុជាអ្នកប្រកបដោយវិជ្ជាដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្តីពិត រមែងមិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះ ។ កាលបើភិក្ខុនោះ មិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែល

មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងសាបសូន្យទៅ អារម្មណ៍ទាំងឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងចម្រើនឡើង ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះភិក្ខុជាអ្នកដឹងតាមសេចក្តីពិត រមែងដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម្មសមាទានទាំងនោះ ធម្មសមាទានណា ដែលមានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្តីពិតថា ធម្មសមាទាននេះឯង មានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ។ កាលភិក្ខុជាអ្នកប្រកបដោយវិជ្ជា ដឹងនូវធម្មសមាទាននោះ ស្គាល់តាមសេចក្តីពិត រមែងមិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះ ។ កាលបើភិក្ខុនោះ មិនសេពនូវធម្មសមាទាននោះ វៀរចាកធម្មសមាទាននោះហើយ អារម្មណ៍ទាំងឡាយដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត រមែងសាបសូន្យទៅ អារម្មណ៍ទាំងឡាយជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត តែងចម្រើនឡើង ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ព្រោះភិក្ខុជាអ្នកដឹងតាមសេចក្តីពិត រមែងដូច្នោះឯង ។

[ ១៦៦ ] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានដែលមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីទុក្ខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះបាណាតិបាតជាបច្ច័យ ។

ជាអ្នកកាន់យកវត្ថុដែលគេមិនបានឲ្យ ( ដោយកាយឬវាចា ) ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះអទិន្នាទានជាបច្ច័យ ។ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ទាំងសេចក្តីទុក្ខទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះកាមេសុមិច្ឆាចារជាបច្ច័យ ។ ជាអ្នកពោលនូវពាក្យកុហក ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះមុសាវាទជាបច្ច័យ ។ ជាអ្នកពោលពាក្យញុះញង់ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះបិសុណវាចាជាបច្ច័យ ។ ជាអ្នកមានវាចាអាក្រក់ ទាំងសេចក្តីទុក្ខទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះផរុសវាចាជាបច្ច័យ ។ ជាអ្នកពោលពាក្យរោយរាយឥតប្រយោជន៍ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះសម្ផប្បលាបៈជាបច្ច័យ ។ ជាអ្នកមានអភិជ្ឈាច្រើន ទាំងសេចក្តីទុក្ខទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះអភិជ្ឈាជាបច្ច័យ ។ ជាអ្នកមានចិត្តព្យាបាទ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះព្យាបាទជាបច្ច័យ ។ ជាអ្នកយល់ខុស ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ ។ បុគ្គលនោះលុះទម្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះតថាគតហៅថា មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីទុក្ខជាវិបាក

តទៅ ។

[ ១៦៧ ] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានមានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ទាំងសេចក្តីសុខទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខនិងសោមនស្ស ព្រោះបាណាតិបាតជាបច្ច័យ ។ ជាអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ ( ដោយកាយឬវាចា ) ទាំងសេចក្តីសុខទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះអទិន្នាទានជាបច្ច័យ ។ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះកាមេសុមិច្ឆាចារជាបច្ច័យ ។ ជាអ្នកពោលពាក្យកុហក ទាំងសេចក្តីសុខទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះមុសាវាទជាបច្ច័យ ។ ជាអ្នកមានវាចាញុះញង់ ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះបិសុណវាចាជាបច្ច័យ ។ ជាអ្នកមានវាចាអាក្រក់ ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខនិងសោមនស្ស ព្រោះផរុសវាចាជាបច្ច័យ ។ ជាអ្នកពោលពាក្យឥតប្រយោជន៍ ទាំងសេចក្តីសុខទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះសម្ផប្បលាបៈជាបច្ច័យ ។ ជាអ្នកមានអភិជ្ឈាច្រើន ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះអភិជ្ឈាជាបច្ច័យ ។ ជាអ្នកមានចិត្តព្យាបាទ ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តី

សុខ និងសោមនស្ស ព្រោះព្យាបាទជាបច្ច័យ ។ ជាអ្នកយល់ខុស ទាំងសេចក្តីសុខ ទាំងសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ ។ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់ពីមរណៈទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតហៅថា មានសេចក្តីសុខក្នុងបច្ចុប្បន្ន តែមានសេចក្តីទុក្ខ ជាវិបាកតទៅ ។

[ ១៦៨ ] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានដែលមានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះវៀរចាកបាណាតិបាតជាបច្ច័យ ។ ជាអ្នកវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះវៀរចាកអទិន្នាទានជាបច្ច័យ ។ ជាអ្នកវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ទាំងសេចក្តីទុក្ខទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះវៀរចាកកាមេសុមិច្ឆាចារជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យកុហក ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះវៀរចាកមុសាវាទជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យញុះញង់ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះវៀរចាកបិសុណវាចាជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យអាក្រក់ ទាំង

សេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះវៀរចាកផរុស វាចាជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យឥតប្រយោជន៍ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះវៀរចាកសម្ផប្បលាបៈជាបច្ច័យ ។ ជាអ្នកមិនមានអភិជ្ឈាច្រើន ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះការមិនមានអភិជ្ឈាជាបច្ច័យ ។ ជាអ្នកមិនមានព្យាបាទ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងសេចក្តីទុក្ខ និងទោមនស្ស ព្រោះមិនមានព្យាបាទជាបច្ច័យ ។ ជាអ្នកយល់ត្រូវ ទាំងសេចក្តីទុក្ខ ទាំងទោមនស្ស ក៏រមែងរងនូវសេចក្តីទុក្ខ និងទោមនស្ស ព្រោះសម្មាទិដ្ឋិជាបច្ច័យ ។ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ ក៏រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះ តថាគតហៅថា មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ។

[ ១៦៩ ] ម្នាលភិក្ខុទាំងឡាយ ធម្មសមាទានមានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះវៀរចាកបាណាតិបាតជាបច្ច័យ ។ ជាអ្នកវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះវៀរចាកអទិន្នាទានជាបច្ច័យ ។ ជាអ្នក

វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះវៀរចាកកាមេសុមិច្ឆាចារជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យកុហក ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះវៀរចាកមុសាវាទជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យញុះញង់ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះវៀរចាកបិសុណវាចាជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យអាក្រក់ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបាននូវសេចក្តីសុខ និងសោមនស្ស ព្រោះវៀរចាកផរុសវាចាជាបច្ច័យ ។ ជាអ្នកវៀរចាកការពោលពាក្យឥតប្រយោជន៍ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះវៀរចាកសម្ផប្បលាបៈជាបច្ច័យ ។ ជាអ្នកមិនមានអភិជ្ឈាច្រើន ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះមិនមានអភិជ្ឈាជាបច្ច័យ ។ ជាអ្នកមិនមានចិត្តព្យាបាទ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះមិនមានចិត្តព្យាបាទជាបច្ច័យ ។ ជាអ្នកយល់ត្រូវ ព្រមដោយសេចក្តីសុខ ព្រមដោយសោមនស្ស ក៏រមែងបានសេចក្តីសុខ និងសោមនស្ស ព្រោះសម្មាទិដ្ឋិជាបច្ច័យ ។ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ ក៏រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ ធម្ម-

សមាទាននេះ តថាគតហៅថា មានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាធម្មសមាទាន មាន ៤ ប្រការ ។

[ ១៧០ ] ម្នាលភិក្ខុទាំងឡាយ ដូចជានទោងព្រៃ[១] លាយដោយថ្នាំពិស ។ គ្រានោះ បុរសមានប្រាថ្នាដើម្បីរស់នៅ មិនប្រាថ្នាដើម្បីស្លាប់ ប្រាថ្នាសេចក្តីសុខខ្ពើមសេចក្តីទុក្ខបានមកដល់ ។ ពួកជននិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន នទោងព្រៃនេះលាយដោយថ្នាំពិស បើអ្នកត្រូវការ ចូរផឹកចុះ កាលបើបុរសផឹកនូវនទោងព្រៃនោះ ក៏នទោងព្រៃនោះមិនគាប់ចិត្តដោយពណ៌ផងដោយក្លិនផង ដោយរសផង លុះផឹកហើយក៏ដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ ។ បើបុរសនោះមិនបានពិចារណានូវនទោងព្រៃនោះ មុខជាផឹក មិនលះបង់ទេ កាលបុរសនោះផឹកនូវនទោងព្រៃហើយមិនគាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយក៏ដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខស្មើរតែនឹងស្លាប់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតហៅធម្មសមាទាននេះថា មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីទុក្ខជាវិបាកតទៅ ក៏មានឧបមេយ្យដូច្នោះឯង ។

[ ១៧១ ] ម្នាលភិក្ខុទាំងឡាយ ដូចជាភាជន៍សំរិទ្ធពេញដោយទឹកផ្អែម

---

១- ប្រែថា ត្រសក់ក្អែក ឬពុលអែក ក៏បាន ។

បរិបូណ៌ដោយពណ៌ បរិបូណ៌ដោយក្លិន បរិបូណ៌ដោយរស តែភាជន៍សំរឹទ្ធ ពេញដោយទឹកផ្អែមនោះឯងលាយដោយថ្នាំពិស ។ គ្រានោះ បុរសមានប្រាថ្នា ដើម្បីរស់នៅ មិនប្រាថ្នាដើម្បីស្លាប់ ប្រាថ្នាសេចក្ដីសុខ ខ្ពើមសេចក្ដីទុក្ខ បាន មកដល់ ។ ពួកជននិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ភាជន៍សំរឹទ្ធពេញដោយទឹកផ្អែម បរិបូណ៌ដោយពណ៌ បរិបូណ៌ដោយក្លិន បរិបូណ៌ដោយរស តែភាជន៍សំរឹទ្ធពេញដោយទឹកផ្អែមនោះឯង លាយទៅ ដោយថ្នាំពិស បើអ្នកត្រូវការ ចូរផឹកចុះ កាលបើបុរសនោះផឹកទឹកនោះហើយ ក៏គាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹក ហើយក៏ ដល់នូវសេចក្ដីស្លាប់ ឬដល់នូវសេចក្ដីទុក្ខស្មើរតែនឹងស្លាប់ ។ បើបុរសនោះ មិនបានពិចារណានូវភាជន៍សំរឹទ្ធ ដែលពេញដោយទឹកផ្អែមនោះហើយ មុខជា ផឹកមិនលះបង់ទេ កាលបុរសនោះផឹកនូវទឹកនោះ ក៏គាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយក៏ដល់នូវសេចក្ដីស្លាប់ ឬដល់នូវ សេចក្ដីទុក្ខស្មើរតែនឹងស្លាប់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគត ហៅធម្មសមាទាននេះថា មានសេចក្ដីសុខក្នុងបច្ចុប្បន្ន តែមានសេចក្ដីទុក្ខជា វិបាកតទៅ ក៏មានឧបមេយ្យដូច្នោះឯង ។

[ ១៧២ ] ម្នាលភិក្ខុទាំងឡាយ ដូចជាទឹកមូត្រស្អុយ លាយដោយ ភេសជ្ជៈទាំងឡាយផ្សេងៗ ។ គ្រានោះ បុរសមានរោគលឿងបានមកដល់ ។ ពួកជននិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ទឹកមូត្រស្អុយ នេះ លាយដោយភេសជ្ជៈទាំងឡាយផ្សេងៗ បើអ្នកត្រូវការ ចូរផឹកចុះ កាល

បើបុរសនោះផឹកទឹកមូត្រស្អុយនោះ ក៏មិនគាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយ ក៏ជាអ្នកបានសេចក្តីសុខ ។ បើបុរសនោះបានពិចារណាទឹកមូត្រស្អុយនោះហើយ ក៏មុខជាផឹកមិនលះបង់ទេ កាលបើបុរសនោះផឹកទឹកមូត្រស្អុយនោះ ក៏មិនគាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយ ក៏ជាអ្នកបានសេចក្តីសុខ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតហៅធម្មសមាទាននេះថា មានសេចក្តីទុក្ខក្នុងបច្ចុប្បន្ន តែមានសេចក្តីសុខជាវិបាកតទៅ ក៏មានឧបមេយ្យដូច្នោះឯង ។

[ ១៧៣ ] ម្នាលភិក្ខុទាំងឡាយ ដូចជាទឹកដោះជូរក្តី ទឹកឃ្មុំក្តី ទឹកដោះថ្លាក្តី ទឹកអំពៅក្តី លាយច្រឡំជាមួយគ្នា ។ គ្រានោះ បុរសមានរោគចុះឈាមបានមកដល់ ។ ពួកជននិយាយនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន ទឹកដោះជូរក្តី ទឹកឃ្មុំក្តី ទឹកដោះថ្លាក្តី ទឹកអំពៅក្តី ទាំងនេះ លាយច្រឡំជាមួយគ្នា បើអ្នកត្រូវការ ចូរផឹកចុះ កាលបើបុរសនោះ ផឹកទឹកអម្បាលនោះ ក៏គាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយជាអ្នកបានសេចក្តីសុខ ។ បើបុរសនោះ បានពិចារណាទឹកនោះហើយ ក៏មុខជាផឹកមិនលះបង់ទេ កាលបុរសនោះផឹកទឹកនោះហើយ ក៏គាប់ចិត្តដោយពណ៌ផង ដោយក្លិនផង ដោយរសផង លុះផឹកហើយ ជាអ្នកបានសេចក្តីសុខ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតហៅធម្មសមាទាននេះថា មានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ។

[ ១៧៤ ] ម្នាលភិក្ខុទាំងឡាយ ដូចជាព្រះអាទិត្យ កាលអាកាសរាំង

ភ្លៀងឃ្លាតទៅចាកពពកហើយ ក្នុងសរទសម័យនាខែជាទីបំផុតនៃវស្សានរដូវទាំងឡាយ ក៏រះឡើងកាន់ផ្ទៃមេឃ កម្ចាត់បង់នូវងងឹត ដែលមានព្ធដ៏អាកាសទាំងអស់ ភ្លឺផង ក្តៅផង រុងរឿងផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ធម្មសមាទាននេះមានសេចក្តីសុខក្នុងបច្ចុប្បន្ន ទាំងមានសេចក្តីសុខជាវិបាកតទៅ ធម្មសមាទាននោះអាចគ្របសង្កត់នូវពាក្យបរប្បវាទរបស់ពួកសមណព្រាហ្មណ៍ដទៃផង ភ្លឺផង ក្តៅផង រុងរឿងផង ក៏មានឧបមេយ្យដូច្នោះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ភិក្ខុទាំងនោះក៏ពេញចិត្តរីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

## មហាធម្មសមាទានសូត្រទី ៦ ចប់

# អដ្ឋកថា

## មហាធម្មសមាទានសុត្តទី ៦

[ ១៦០ ] មហាធម្មសមាទានសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ១៦១ ] ក្នុងបទទាំងនោះ បទថា **ឯវំ កាមា** គឺមានសេចក្ដីត្រូវការយ៉ាងនេះ ។ បទថា **ឯវំ ឆន្ទា** គឺមានការបង្អោនទៅយ៉ាងនេះ ។ បទថា **ឯវំ អធិប្បាយា** គឺមានលទ្ធិយ៉ាងនេះ ។ បទថា **តត្រ** គឺ ក្នុងការចម្រើននៃអារម្មណ៍ដែលមិនគួរពេញចិត្ត និងក្នុងការវិនាសទៅនៃអារម្មណ៍ដែលគួរពេញចិត្តនោះ ។ បទថា **ភគវំមូលកា** គឺឈ្មោះថា មានព្រះមានព្រះភាគជាមូល ព្រោះព្រះមានព្រះភាគទ្រង់ជាមូលនៃវត្ថុទាំងនេះ ។ មានពាក្យដែលពោលថា បពិត្រព្រះអង្គ វត្ថុទាំងឡាយនេះរបស់ពួកខ្ញុំព្រះអង្គ គ្រាដំបូង ព្រះកស្សបសម្ពុទ្ធ ទ្រង់បានឲ្យកើតឡើង កាលព្រះអង្គទ្រង់បរិនិព្វានហើយ មិនមានសមណៈ ឬ ព្រាហ្មណ៍ដែលបានឈ្មោះថា ជាអ្នកអាចឲ្យធម៌ទាំងនេះកើតឡើងទៀតទេ អស់មួយពុទ្ធន្តរ តែព្រះមានព្រះភាគ ទ្រង់បានឲ្យធម៌ទាំងនេះនៃពួកខ្ញុំព្រះអង្គកើតឡើងហើយ ពួកខ្ញុំព្រះអង្គបានអាស្រ័យព្រះមានព្រះភាគដោយពិត ទើបយល់ទូទៅ គឺដឹងចំពោះធម៌ពួកនេះបាន ព្រោះហេតុនេះ ធម៌របស់ពួកខ្ញុំព្រះអង្គ ឈ្មោះថា មានព្រះមានព្រះភាគជាមូល ដោយប្រការដូច្នេះ ។ បទថា **ភគវំនេត្តិកា** គឺព្រះមានព្រះភាគ ទ្រង់ជាអ្នកដឹកនាំ ទ្រង់ដឹកនាំទាក់ទងនឹងរឿងរបស់ធម៌ដោយពិត ។ ធម៌ទាំងឡាយ ដែលទ្រង់តាំង

ឈ្មោះជាពួកៗ តាមសេចក្តីពិត ទើបឈ្មោះថា ព្រះមានព្រះភាគទ្រង់ជាអ្នកដឹកនាំ ។ បទថា **ភគវំបដិសរណា** បានដល់ ធម៌ទាំង ៤ ថ្នាក់ មកកាន់គន្លងព្រះសព្វញ្ញុតញ្ញាណ រមែងប្រជុំចុះ ព្រមព្រៀងក្នុងព្រះមានព្រះភាគម្យ៉ាងទៀត ក្នុងកាលដែលព្រះមានព្រះភាគប្រថាប់គង់ត្រង់មណ្ឌលពោធិព្រឹក្សកាលទ្រង់កាន់យកឈ្មោះជាពួកៗ តាមសេចក្តីពិតនៃធម៌ទាំង ៤ ជាន់ យ៉ាងនេះ គឺផស្សៈ មកដោយអំណាចបដិវេធ អាត្មាអញជាអ្នកបែកធម៌ឈ្មោះអ្វីហើយទ្រង់តាំង ឈ្មោះថា ឈ្មោះ ផស្សៈ ព្រោះអត្ថថា ពាល់ត្រូវ ។ វេទនា ( សញ្ញា ) សង្ខារ វិញ្ញាណ ក៏ទ្រង់គិតថា អញនឹងបែកធម៌ទាំងនេះឈ្មោះអ្វី ហើយទ្រង់ក៏តាំងឈ្មោះថា វេទនា ( សញ្ញា ) សង្ខារ ព្រោះអត្ថថាសោយអារម្មណ៍ ... ចាំអារម្មណ៍ ... តាក់តែងអារម្មណ៍ និងឈ្មោះថាវិញ្ញាណ ព្រោះអត្ថថា ដឹងច្បាស់ ។ ព្រះមានព្រះភាគ ទ្រង់យកធម៌មកសង្គ្រោះជាក្រុម ព្រោះដូច្នោះ ទើបធម៌ទាំងនោះ ឈ្មោះថា មានព្រះមានព្រះភាគជាទីពឹងអាស្រ័យ ។ បទថា **ភគវន្តំ យេវ បដិភាតុ** បានដល់សូមឲ្យអត្ថរបស់ភាសិតនេះប្រាកដដល់ព្រះមានព្រះភាគ ប៉ុណ្ណោះចុះ គឺសូមព្រះអង្គនោះឯង ទ្រង់មេត្តាសម្តែងប្រទានដល់ពួកខ្ញុំព្រះអង្គផងចុះ ។

[ ១៦២ ] បទថា **សោវិតញ្ញេ** គឺគប្បីអាស្រ័យ ។ បទថា **ភជិតញ្ញេ** គឺគប្បីចូលជិត ។ បទថា **យថាតំ អវិទ្ធសុនោ** គឺដូច អន្ធបុថុជ្ជន ។ បទថា **យថាតំ វិទ្ធសុនោ** គឺដូចបណ្ឌិតដែលជាអ្នកប្រាជ្ញ ។ ព្រះមានព្រះភាគ ទ្រង់តាំងមាតិកា តាមបែបជាលំដាប់ខ្ពស់ឡើងទៅក្នុងសូត្រមុនថា **អត្ថិ ភិក្ខវេ**

**ធម្មសមាទានំ** តែក្នុងព្រះសូត្រនេះ ព្រះសាស្តាទ្រង់តាំងមាតិកាតាមរសនៃធម៌ប៉ុណ្ណោះ ។

[ ១៦៣ ] ក្នុងបទទាំងនោះ បទថា **ធម្មសមាទានំ** បានដល់ ការសមាទានធម៌ មានការសម្លាប់ជាដើម ។

[ ១៦៤ ] បទថា **អវិជ្ជាគតោ** បានដល់ បុគ្គលប្រកបព្រមដោយការមិនដឹង ។

[ ១៦៥ ] បទថា **វិជ្ជាគតោ** បានដល់ បុគ្គលប្រកបព្រមដោយវិជ្ជា គឺបុគ្គលមានបញ្ញា ។

[ ១៦៦ ] ធម៌ទាំង ៣ នេះ គឺ មិច្ឆាចារ អភិជ្ឈា មិច្ឆាទិដ្ឋិ ក្នុងពាក្យទាំងនេះ គឺព្រមដោយទុក្ខក៏មាន ជាទុក្ខវេទនា ដោយអំណាចចេតនាទាំង ២ គឺបុព្វចេតនា និងអបរចេតនា ។ ឯ **សន្និដ្ឋាបកចេតនា** គឺឯចេតនាដែលឲ្យសម្រេចរៀបរយ ជាចេតនាដែលប្រកបដោយសុខ ឬប្រកបដោយឧបេក្ខា ។ ឯចេតនាដ៏សេស មានការសម្លាប់សត្វជាដើម ៧ ទៀត ជាទុក្ខវេទនា ដោយអំណាចវេទនាគ្រប់ទាំង ៣ ព្រះមានព្រះភាគ ទ្រង់សំដៅយកសេចក្តីនេះ ទើបត្រាស់ពាក្យថា ព្រមនឹងទុក្ខខ្លះ ព្រមនឹងទោមនស្សខ្លះ ដូច្នេះ ។ ទោមនស្សក្នុងពុទ្ធតម្រាស់នេះ គប្បីយល់ថា ជាទុក្ខ ។ កាលបុគ្គលមកដល់ការស្វែងរកសូម្បីទុក្ខផ្លូវកាយ ក៏រមែងពាល់ត្រូវទាំងចំណែកខាងដើម និងខាងចុងដោយពិត ។ ធម៌ ៣ គឺការសម្លាប់សត្វ ការពោលពាក្យទ្រគោះបោះបោក ព្យាបាទក្នុងបទនេះ គឺប្រកបដោយសុខក៏មាន ជាសុខវេទនា ដោយអំណាចចេតនា

២ យ៉ាង គឺបុព្វចេតនា និងអបរចេតនា ឯសន្និដ្ឋាបកចេតនា ជាចេតនាដែលប្រកបដោយទុក្ខ កម្មបថដ៏សេស ៧ ទៀត រមែងជាសុខវេទនា ដោយអំណាចចេតនាគ្រប់ទាំង ៣ ។ សោមនស្សនោះឯង ក៏គប្បីយល់ថា ជាសុខក្នុងទីនេះ ។ ឬសម្រាប់បុគ្គលដែលដល់ព្រមដោយផោដ្ឋព្វារម្មណ៍គួរពេញចិត្តសូម្បីសុខតាមផ្លូវកាយ ក៏រមែងត្រូវក្នុងចំណែកខាងដើម និងចំណែកចុងដោយពិត ។ ក្នុងការប្រកាន់ធម៌ទាំង ៣ នេះឯង បុគ្គលខ្លះក្នុងលោកនេះជាអ្នកនេសាទក្តី ជាព្រានម្រឹគក្តី អាស្រ័យការសម្លាប់ប៉ុណ្ណោះចិញ្ចឹមជីវិតភិក្ខុដែលនៅក្នុងតំណែងជាទីគោរពនៃបុគ្គលនោះ សម្តែងទោសនៃការសម្លាប់សត្វ និងអានិសង្សនៃការវៀរចាកការសម្លាប់សត្វ ហើយឲ្យសិក្ខាបទដល់បុគ្គលនោះ អ្នកនោះមិនត្រូវការឡើយ បើទទួលក៏ទទួលទាំងទុក្ខទោមនស្សនោះឯង ។ ក្រោយមក កាលកន្លងទៅ ២-៣ ថ្ងៃ កាលបុគ្គលនោះមិនអាចរក្សាបាន ក៏កើតទុក្ខទៀត បុព្វចេតនា និងអបរចេតនានៃបុគ្គលនោះ រមែងជាគូគ្នាដោយទុក្ខនោះឯង ។ ឯសន្និដ្ឋាបកចេតនា ទៅជាមួយសុខខ្លះ ទៅជាមួយឧបេក្ខាខ្លះ ។ ក្នុងទីគ្រប់អន្លើគប្បីយល់អត្ថ ដូច្នេះ ។ ព្រះមានព្រះភាគទ្រង់សំដៅយកចេតនាដែលជាខាងដើម និងខាងចុងនេះឯង ដោយប្រការដូច្នេះហើយ ទើបត្រាស់ថា ប្រកបព្រមដោយទុក្ខក៏មាន ប្រកបព្រមដោយទោមនស្សក៏មាន ដូច្នេះ ។ គប្បីជ្រាបថា ទោមនស្សនោះឯងជាទុក្ខ ។ ក្នុងការកាន់យកធម៌ទី ៤ បុព្វចេតនា មុញ្ចនចេតនា អបរចេតនា និងសន្និដ្ឋាបកចេតនា ទាំង ៣ ក្នុងបទគ្រប់ទាំង ១០ រមែងប្រកបដោយសុខពិត ព្រះ

មានព្រះភាគទ្រង់សំដៅយកសេចក្ដីនោះ ទើបត្រាស់ថា ប្រកបដោយសុខខ្លះ ប្រកបដោយសោមនស្សខ្លះ ឯសោមនស្សនោះឯង ក៏គប្បីជ្រាបថា សុខក្នុងទីនេះ ។

[ ១៧០ ] បទថា **តិត្តកាលាពុ** ប្រែថា ននោងព្រៃ ។ បទថា **វិសេន សំសដ្ឋោ** បានដល់ លាយឡំដោយថ្នាំពិស ដែលមានពិសដ៏ពន្លឹក ។ បទថា **ន ឆាទេស្សតិ** គឺមិនពេញចិត្ត មិនធ្វើសេចក្ដីត្រេកអរ ។ បទថា **និគច្ឆសិ** គឺនឹងសម្រេច ។ បទថា **អប្បដិសង្ខាយ បិវេយ្យ** គឺគប្បីផឹកដោយមិនពិចារណា ។

[ ១៧១ ] បទថា **អចានីយកំសោ** គឺកាជនៈពេញប្រៀបទៅដោយគ្រឿងផឹកឆ្ងាញ់គួរផឹក ។ បទថា **វណ្ណសម្បន្នោ** គឺជាកាជនៈដល់ព្រមដោយពណ៌នៃគ្រឿងផឹកជាដើម ដែលមនុស្សពោលយ៉ាងនេះថា កាជនៈបរិបូណ៌ដោយគ្រឿងផ្សំហើយ ។ បទថា **ឆាទេស្សតិ** បានដល់ ឯថ្នាំពិសខ្លាំងក្លានោះឈ្មោះថា ដាក់ហើយក្នុងគ្រឿងផឹកណាមួយ រមែងឲ្យរសនៃគ្រឿងផឹកនោះៗឯង ព្រោះហេតុនោះ ទើបពោលពាក្យជាដើមថា ពេញចិត្ត ។

[ ១៧២ ] បទថា **បូតិមុត្តំ** គឺទឹកមូត្រនោះឯង ។ ប្រៀបដូចរាងកាយរបស់មនុស្សយើង ទោះបីមានពណ៌ដូចមាស ក៏នៅតែហៅថា កាយស្អុយនោះឯង ដូចវល្លិ៍ខ្លី ដែលទើបតែកើតឡើងក្នុងថ្ងៃនោះ នៅតែហៅថា វល្លិ៍ខ្លីនោះឯង យ៉ាងណា ទឹកមូត្រថ្មីៗ ដែលត្រងទុកក្ដាមៗ ក៏នៅតែហៅថា ទឹកមូត្រស្អុយនោះឯង ដូច្នោះ ។ បទថា **នានាភេសជ្ជេហិ** គឺដោយថ្នាំច្រើន

ប្រភេទ មានសម្ព័ និងកន្ទួតព្រៃជាដើម ។ បទថា **សុខី អស្សុ** គឺចូរជាអ្នកមានសេចក្ដីសុខ ប្រាសចាករោគ មានពណ៌ដូចមាស ។

[ ១៧៣ ] បទថា **ទធិ ច មធុ ច** គឺទធិដែលបរិសុទ្ធ និងទឹកឃ្មុំដែលផ្អែមឆ្ងាញ់ ។ បទថា **ឯកជ្ឈំ សំសដ្ឋំ** បានដល់ លាយចូលគ្នាតែមួយ ។ បទថា **តស្ស តំ** គឺគប្បីពេញចិត្តដល់បុគ្គលដែលបរិភោគភេសជ្ជៈ ដែលប្រកបដោយមធុរស ៤ យ៉ាងឯណា ដែលលាយច្រឡំជាមួយគ្នានេះ គប្បីធ្វើឲ្យរោគចុះឈាមជាសះស្បើយបាន ព្រោះថ្នាំនោះ ធ្វើឲ្យអាហាររឹង បន្ទោបង់មិនចេញ ឯឈាមដែលលាយដោយប្រមាត់ ថ្នាំនោះក៏បន្ទោបង់ចេញមកខាងក្រៅបាន ធ្វើឲ្យរាងកាយត្រជាក់ ។

[ ១៧៤ ] បទថា **វិទេ្ឋ** គឺអណ្ដែតខ្ពស់ឡើង គឺមិនមានពពក ដោយអត្ថថា ពពកនៅឆ្ងាយ ។ បទថា **វិគតវលាហកេ** គឺ ជុំពពកចៀសទៅហើយ ។ បទថា **ទេវេ** បានដល់ កាលអាកាស ។ បទថា **អាកាសគតំ តមគតំ** គឺការងងឹតក្នុងអាកាស ។ បទថា **បុថុសមណព្រាហ្មណបរប្បវាទេ** បានដល់ វាទៈរបស់បុគ្គលដទៃ បានដល់ សមណព្រាហ្មណ៍ជាធំ ។ បទថា **អភិវិហច្ច** បានដល់ បៀតបៀនក្រៃលែង គឺ សម្លាប់ ។ បទថា **ភាសតេ ច តបតេ ច វិរោចតេ ច** បានដល់ ពេលថ្ងៃក្នុងសរទរដូវ ព្រះអាទិត្យរមែងបញ្ចេញពន្លឺ គឺបញ្ចេញពន្លឺល្អ រុងរឿងល្អ ។ ឯសូត្រនេះ ពួកទេវតាស្រឡាញ់ពេញចិត្តពន់ពេក ដូចមានរឿងតទៅនេះ

បានឮថា នាទិសខាងត្បូង ក្នុងដែនហត្ថិភោគៈ ក្នុងមន្ទុរវិហារ ត្រង់ទ្វារ

នៃរោងកត្តរបស់វត្តនោះ មានទេវតានៅអាស្រ័យត្រង់ដើមមន្ទ័រ ពេលយប់ បានស្ដាប់ភិក្ខុកំលោះមួយរូប កំពុងសរុបព្រះសូត្រនេះដោយបទសរកញ្ញ ទើបឲ្យសាធុការ ។ ភិក្ខុកំលោះសួរថា នរណាហ្នឹ៎ ទេវតាឆ្លើយថា ខ្ញុំជាទេវតានៅអាស្រ័យត្រង់ដើមឈើនេះ ភិក្ខុកំលោះសួរថា នែទេវតា អ្នកជ្រះថ្លាក្នុងអ្វីក្នុងសំឡេង ឬក្នុងព្រះសូត្រ ទេវតាឆ្លើយថា បពិត្រលោកម្ចាស់ អ្នកណាក៏មានសំឡេងដែរ ខ្ញុំជ្រះថ្លាក្នុងសូត្រ ក្នុងថ្ងៃដែលព្រះសាស្ដាទ្រង់គង់ក្នុងវត្តជេតពន ហើយក្នុងថ្ងៃនេះ មិនមានការប្លែកផ្សេងគ្នា សូម្បីតែមួយព្យញ្ជនៈ ភិក្ខុកំលោះសួរថា នែទេវតា ក្នុងថ្ងៃដែលព្រះសាស្ដាត្រាស់សូត្រនេះ នាងបានឮឬ ទេវតាពោលថា ពិតហើយលោកម្ចាស់ ។ ភិក្ខុកំលោះសួរថា នាងឈរស្ដាប់ក្នុងទីណា ទេវតាពោលថា បពិត្រលោកម្ចាស់ ខ្ញុំទៅវត្តជេតពន តែកាលពួកទេវតាជាអ្នកមានសក្តិធំនាំគ្នាមក ខ្ញុំអស់ឱកាស ទើបឈរស្ដាប់ក្នុងទីនេះឯង ។ ភិក្ខុកំលោះសួរថា នាងឈរក្នុងទីនេះ ហើយបានឮសំឡេងព្រះសាស្ដាឬ ទេវតាពោលថា បពិត្រលោកម្ចាស់ សំឡេងរបស់ខ្ញុំ លោកម្ចាស់បានឮទេ ភិក្ខុកំលោះពោលថា អាត្មាឮ ទេវតាពោលថា ដូចគ្នានោះឯង ខ្ញុំបានឮច្បាស់ដូចគ្នា ។ ភិក្ខុកំលោះសួរថា នែទេវតា ចុះនាងបានឃើញរូបព្រះសាស្ដាឬទេ ទេវតាឆ្លើយថា ខ្ញុំយល់ថា ព្រះសាស្ដា ទតមើលតែខ្ញុំប៉ុណ្ណោះឯង រហូតដល់ទប់ខ្លួនមិនបាន ។ ភិក្ខុកំលោះសួរថា ចុះអ្នកមាន

គុណវិសេសកើតឡើងខ្លះទេ ។ ទេវតាក៏បាត់ទៅក្នុងទីនោះឯង បានឮថា ថ្ងៃនោះ ទេវតាអង្គនេះ តាំងនៅក្នុងសោតាបត្តិផល ។ ទេវតាទាំងឡាយស្រឡាញ់ពេញចិត្តព្រះសូត្រនេះ ដូចពោលមកនេះ ។ ពាក្យដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ហើយ ៕៚

## មហាធម្មសមាទានសូត្រ ចប់

## សូត្រទី ៦ ចប់

# សុត្តន្តបិដក

## វីមំសកសូត្រទី ៧

[ ១៧៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។

[ ១៧៦ ] ព្រះមានព្រះភាគ បានត្រាស់ភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកពិចារណា កាលមិនដឹងវារៈចិត្តរបស់បុគ្គលដទៃទេ ត្រូវធ្វើការស្វែងរកក្នុងព្រះតថាគតដើម្បីឲ្យដឹងថា ព្រះសម្មាសម្ពុទ្ធ ឬមិនមែន ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ មានព្រះមានព្រះភាគជាមូល មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹងចំពោះរបស់យើងទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ព្រះមេត្តាប្រោសសម្តែងនូវអត្ថនៃភាសិតនេះ ភិក្ខុទាំងឡាយបានស្តាប់ភាសិតព្រះមានព្រះភាគហើយ នឹងបានចាំទុក ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះអ្នកទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងឥឡូវនេះ ។ ភិក្ខុទាំងឡាយនោះ បានទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ១៧៧ ] ព្រះមានព្រះភាគ បានត្រាស់នូវភាសិតនេះថា ម្នាលភិក្ខុ

ទាំងឡាយ ភិក្ខុអ្នកពិចារណា កាលមិនដឹងនូវវារៈចិត្តរបស់បុគ្គលដទៃទេ ត្រូវស្វែងរកព្រះតថាគតក្នុងធម៌ពីរប្រការ គឺ ធម៌ដែលគប្បីដឹងបានដោយចក្ខុ ១ ដឹងបានដោយសោតៈ ១ ថា ធម៌ទាំងឡាយដ៏សៅហ្មង ដែលគប្បីដឹងបានដោយចក្ខុ និងសោតៈនៃព្រះតថាគតមាន ឬមិនមានទេ ។ កាលភិក្ខុស្វែងរកនូវហេតុនោះហើយ ក៏គង់ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏សៅហ្មង ដែលគប្បីដឹងបានដោយចក្ខុ និងសោតៈនៃព្រះតថាគត មិនមានទេ ។ កាលណាភិក្ខុស្វែងរកហេតុនោះហើយ ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏សៅហ្មងដែលគប្បីដឹងបានដោយចក្ខុ និងសោតៈនៃព្រះតថាគតមិនមានទេ តពីនោះទៅទើបស្វែងរកហេតុនោះទៀតថា ធម៌ទាំងឡាយដ៏ប្រឡូកប្រឡំ ដែលគប្បីដឹងដោយចក្ខុ និងសោតៈនៃព្រះតថាគត មាន ឬមិនមានទេ ។ កាលភិក្ខុស្វែងរកនូវហេតុនោះហើយ ក៏គង់ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏ប្រឡូកប្រឡំ ដែលគប្បីដឹងដោយចក្ខុ និងសោតៈនៃព្រះតថាគត មិនមានទេ ។ កាលណាភិក្ខុស្វែងរកហេតុនោះហើយ ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏ប្រឡូកប្រឡំ ដែលគប្បីដឹងដោយចក្ខុ និងសោតៈនៃព្រះតថាគត មិនមានទេ តពីនោះទៅ ទើបស្វែងរកហេតុនោះថា ធម៌ទាំងឡាយដ៏ផូរផង់ ដែលគប្បីដឹងដោយចក្ខុ និងសោតៈនៃព្រះតថាគត មាន ឬមិនមានទេ ។ កាលភិក្ខុស្វែងរកនូវហេតុនោះហើយ ក៏គង់ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏ផូរផង់ ដែលគប្បីដឹងដោយចក្ខុ និងសោតៈនៃព្រះតថាគត មានពិត ។ កាលណាភិក្ខុស្វែងរកហេតុនោះហើយ ដឹងយ៉ាងនេះថា ធម៌ទាំងឡាយដ៏ផូរផង់ដែលគប្បីដឹងដោយចក្ខុ និងសោតៈ

នៃព្រះតថាគតមានពិតហើយ តទៅ ទើបស្វែងរកនូវហេតុនោះទៀតថា លោកមានអាយុនេះ បានសមាទានកុសលនេះ អស់កាលយូរអង្វែងហើយ ឬទើបនឹងសមាទានទេ ។ កាលភិក្ខុស្វែងរកហេតុនោះហើយ ក៏គង់ដឹងយ៉ាងនេះថា លោកមានអាយុនេះបានសមាទានកុសលធម៌នេះ អស់កាលជាយូរអង្វែងមកហើយ លោកមានអាយុនេះ មិនមែនទើបតែនឹងសមាទានឥឡូវនេះទេ ។ កាលភិក្ខុស្វែងរកហេតុនោះហើយ ដឹងយ៉ាងនេះថា លោកមានអាយុនេះបានសមាទានកុសលធម៌នេះអស់កាលជាយូរអង្វែងណាស់មកហើយ លោកមានអាយុមិនមែនទើបតែនឹងសមាទានឥឡូវនេះទេ តទៅ ទើបស្វែងរកនូវហេតុនោះទៀតថា ភិក្ខុមានអាយុនេះ មានកិត្តិសព្ទបរិបូណ៌ មានយសសក្តិបរិបូណ៌ហើយ តើទោសចំពូកខ្លះក្នុងលោកនេះនៃភិក្ខុនោះមានដែរឬទេ ។ ម្នាលភិក្ខុទាំងឡាយ ( តាមធម្មតា ) ភិក្ខុមិនទាន់មានកិត្តិសព្ទបរិបូណ៌ មិនទាន់មានយសបរិបូណ៌ ដរាបណា ទោសទាំងឡាយចំពូកខ្លះ ភិក្ខុក៏មិនទាន់មានដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានកិត្តិសព្ទបរិបូណ៌ មានយសបរិបូណ៌ក្នុងកាលណាហើយ ទោសទាំងឡាយចំពូកខ្លះក្នុងលោកនេះ នៃភិក្ខុនោះ ក៏មានក្នុងកាលនោះ ។ កាលភិក្ខុស្វែងរកហេតុនោះហើយ ក៏គង់ដឹងយ៉ាងនេះថា ភិក្ខុមានអាយុនេះ មានកិត្តិសព្ទបរិបូណ៌ មានយសបរិបូណ៌ហើយ ទោសទាំងឡាយចំពូកខ្លះក្នុងលោកនេះនៃភិក្ខុនោះក៏មិនមាន ។ កាលភិក្ខុស្វែងរកហេតុនោះហើយ ដឹងយ៉ាងនេះថា ភិក្ខុមានអាយុនេះមានកិត្តិសព្ទបរិបូណ៌ មានយសបរិបូណ៌ ទោសទាំងឡាយចំពូកខ្លះក្នុងលោកនេះ នៃភិក្ខុ

នោះមិនមានឡើយ តទៅ ទើបស្វែងរកហេតុនោះទៀតថា លោកមានអាយុនេះមិនវិនាសដោយភ័យ ឬលោកមានអាយុនេះ ដែលមិនវិនាសដោយភ័យហើយ មិនសេពកាមទាំងឡាយទេ ព្រោះលោកប្រាសចាករាគៈហើយ ព្រោះអស់រាគៈហើយ ។ ភិក្ខុនោះ កាលស្វែងរកហេតុនោះហើយ ដឹងយ៉ាងនេះថា លោកមានអាយុនេះ មិនវិនាសដោយភ័យ លោកមានអាយុនេះ ដែលមិនវិនាសដោយភ័យហើយ មិនសេពនូវកាមទាំងឡាយទេ ព្រោះលោកប្រាសចាករាគៈហើយ ព្រោះអស់រាគៈហើយ ម្នាលភិក្ខុទាំងឡាយ បើពួកជនឯទៀតសួរហេតុនោះនឹងភិក្ខុ យ៉ាងនេះថា ចុះអាការរបស់លោកមានអាយុដូចម្តេច សេចក្តីត្រាស់ដឹងដូចម្តេច បានជាលោកមានអាយុ ពោលយ៉ាងនេះថា លោកមានអាយុនេះ មិនវិនាសដោយភ័យ លោកមានអាយុនេះ ដែលមិនវិនាសដោយភ័យហើយ មិនសេពនូវកាមទាំងឡាយទេ ព្រោះលោកប្រាសចាករាគៈហើយ ព្រោះអស់រាគៈហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលនឹងព្យាករឲ្យត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា លោកមានអាយុនេះ ទុកជានៅកណ្តាលជំនុំសង្ឃក្តី នៅតែម្នាក់ឯងក្តី លោកមានអាយុនេះមិនមើលងាយនូវពួកជន ដែលប្រតិបត្តិត្រូវក្នុងទីនោះផង នូវពួកជនដែលប្រតិបត្តិខុសក្នុងទីនោះផង នូវពួកជនដែលប្រៀនប្រដៅគណៈក្នុងទីនោះផង នូវពួកជនខ្លះក្នុងលោកនេះ ដែលសម្លឹងអាមិសៈផង នូវពួកជនខ្លះក្នុងលោកនេះ ដែលមិនជាប់ចិត្តដោយអាមិសៈផង ដោយសេចក្តីប្រតិបត្តិ ( របស់ជនទាំងនោះ ) ឡើយ ។ ពាក្យនេះខ្ញុំបានស្តាប់មក អំពីទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ខ្ញុំ

បានបេះបាំមកអំពីទីចំពោះព្រះភក្ត្រព្រះមានព្រះភាគថា ខ្ញុំជាបុគ្គលមិនវិនាស ដោយភ័យ លុះខ្ញុំមិនវិនាសដោយភ័យហើយ ក៏មិនសេពនូវកាមទាំងឡាយ ព្រោះប្រាសចាករាគៈហើយ ព្រោះអស់រាគៈហើយ ។

[ ១៧៨ ] ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកពិចារណានូវធម៌ទាំងពីរនោះ គួរឲ្យភិក្ខុអ្នកពិចារណាធម៌មួយរូប សាកសួរតថាគតតទៅទៀតថា ធម៌ទាំងឡាយដ៏សៅហ្មង ដែលគប្បីដឹងដោយចក្ខុនិងសោតៈនៃព្រះតថាគត មាន ឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតកាលនឹងព្យាករ គប្បីព្យាករយ៉ាងនេះថា ធម៌ទាំងឡាយដ៏សៅហ្មងដែលគប្បីដឹងដោយចក្ខុ និងសោតៈនៃព្រះតថាគតមិនមានទេ ។ ធម៌ទាំងឡាយដ៏ប្រឡូកប្រឡំ ដែលគប្បីដឹងដោយចក្ខុ និងសោតៈនៃព្រះតថាគត មាន ឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតកាលនឹងព្យាករ គប្បីព្យាករយ៉ាងនេះថា ធម៌ទាំងឡាយដ៏ប្រឡូកប្រឡំ ដែលគប្បីដឹងដោយចក្ខុ និងសោតៈនៃព្រះតថាគតមិនមានទេ ។ ធម៌ទាំងឡាយដ៏ផូរផង់ដែលគប្បីដឹងដោយចក្ខុ និងសោតៈនៃព្រះតថាគតមាន ឬមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតកាលនឹងព្យាករដោយត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា ធម៌ទាំងឡាយដ៏ផូរផង់ដែលគប្បីដឹងដោយចក្ខុ និងសោតៈនៃព្រះតថាគតមានពិត តថាគតមានគន្លងបែបនេះ មានអារម្មណ៍ជាទីគោចរបែបនេះ មិនប្រកបដោយតណ្ហា ព្រោះសីលដ៏បរិសុទ្ធនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ សាវកគួរចូលទៅរកសាស្តាដែលមានវាទៈយ៉ាងនេះ ដើម្បីនឹងបានស្តាប់នូវធម្មទេសនា សាស្តាសម្តែងធម៌ដ៏ប្រសើរក្រៃលែង ដ៏ឧត្តមក្រៃលែង មាន

ចំណែកប្រៀបស្មើដោយធម៌ខ្មៅ និងធម៌ស ដល់សាវកនោះ ម្នាលភិក្ខុទាំង-ឡាយ សាស្តាតែងសំដែងធម៌ដ៏ប្រសើរក្រៃលែង ដ៏ឧត្តមក្រៃលែង មានចំណែកប្រៀបស្មើដោយធម៌ខ្មៅ និងធម៌ស ដល់ភិក្ខុដោយប្រការណាៗ ភិក្ខុនោះបានដឹងច្បាស់នូវបដិវេធធម៌ចំពូកខ្លះ ក្នុងសាសនានេះ ក្នុងធម៌ដែលព្រះមានព្រះភាគសំដែងហើយនោះ ហើយដល់នូវសេចក្តីចូលចិត្តក្នុងទេសនាធម៌ទាំងឡាយ ជ្រះថ្លាក្នុងព្រះសាស្តាថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ធម៌ព្រះមានព្រះភាគ ទ្រង់សំដែងហើយដោយប្រពៃ ព្រះសង្ឃប្រតិបត្តិប្រពៃហើយ ដូច្នេះ ដោយប្រការនោះៗ ។ ម្នាលភិក្ខុទាំងឡាយ បើពួកជនសួរសេចក្តីនោះនឹងភិក្ខុយ៉ាងនេះទៀតថា ចុះអាការរបស់លោកមានអាយុដូចម្តេច សេចក្តីត្រាស់ដឹងដូចម្តេច បានជាលោកមានអាយុពោលយ៉ាងនេះថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ធម៌ព្រះមានព្រះភាគ ទ្រង់សំដែងហើយដោយប្រពៃ ព្រះសង្ឃប្រតិបត្តិប្រពៃហើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលនឹងព្យាករឲ្យត្រឹមត្រូវ គប្បីព្យាករយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគក្នុងទីនេះដើម្បីស្តាប់ធម៌ ព្រះមានព្រះភាគក៏ទ្រង់សំដែងធម៌ដ៏ប្រសើរក្រៃលែង ដ៏ឧត្តមក្រៃលែង មានចំណែកប្រៀបស្មើដោយធម៌ខ្មៅ និងធម៌សដល់ខ្ញុំ ម្នាលអាវុសោ ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ដ៏ប្រសើរក្រៃលែង ដ៏ឧត្តមក្រៃលែង មានចំណែកប្រៀបស្មើដោយធម៌ខ្មៅ និងធម៌សដល់ខ្ញុំនោះ ដោយប្រការណាៗ ខ្ញុំក៏ដឹងច្បាស់នូវបដិវេធធម៌ចំពូកខ្លះ ក្នុងសាសនានេះ ក្នុងធម៌ដែលព្រះមានព្រះភាគសំដែងហើយនោះ ហើយដល់នូវ

សេចក្ដីចូលចិត្តក្នុងទេសនាធម៌ទាំងឡាយ ជ្រះថ្លាក្នុងព្រះសាស្ដាថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ព្រះមានព្រះភាគ ទ្រង់សម្ដែងប្រពៃហើយ ព្រះសង្ឃប្រតិបត្តប្រពៃហើយ ដូច្នេះ ដោយប្រការនោះៗ ។

[ ១៧៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ មានសទ្ធាមិនកម្រើកចាក់ឫសខ្ជាប់ តម្កល់ស៊ប់ក្នុងព្រះតថាគត ដោយអាការទាំងឡាយនេះ ដោយបទទាំងឡាយនេះ ដោយព្យញ្ជនៈទាំងឡាយនេះហើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ ទើបតថាគតហៅថា អ្នកមានសទ្ធាប្រកបដោយហេតុ មានសោតាបត្តិមគ្គជាមូលដ៏មាំមួន ឥតមានសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្មក្ដី អ្នកណាមួយក្នុងលោកក្ដី ដឹកនាំទៅបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរកធម៌ក្នុងព្រះតថាគតយ៉ាងនេះ ចំណែកខាងព្រះតថាគត ( ត្រូវតែ ) បុគ្គលស្ទះស្វែងរកតាមធម្មតាយ៉ាងនេះដែរ ។ លុះព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ពួកភិក្ខុទាំងនោះ មានសេចក្ដីពេញចិត្តត្រេកអរនឹងភាសិតរបស់ព្រះមានព្រះភាគ ។

## វីមំសកសូត្រទី ៧ ចប់

# អដ្ឋកថា

## វីមំសកសូត្រទី ៧

[ ១៧៥ ] វីមំសកសូត្រ មានពាក្យផ្ដើមថា **ឯវំមេ សុតំ** ដូច្នេះជាដើម ។

[ ១៧៦ ] បណ្ដាបទទាំងនោះ បទថា **វីមំសកេន** សេចក្ដីថា ពិចារណាមាន ៣ គឺអ្នកពិចារណាក្នុងអត្ថ ១ អ្នកពិចារណាក្នុងសង្ខារ ១ អ្នកពិចារណាក្នុងព្រះសាស្ដា ១ ។ ក្នុងអ្នកពិចារណាទាំងនោះ បុគ្គលពិចារណាអត្ថ មកហើយក្នុងបទនេះថា អាវុសោ មនុស្សទាំងឡាយដែលជាអ្នកប្រាជ្ញរមែងពិចារណា ។ បុគ្គលពិចារណាក្នុងសង្ខារ មកហើយក្នុងបទនេះថា ម្នាលអានន្ទ ភិក្ខុជាអ្នកឈ្លាសក្នុងធាតុផង ឈ្លាសក្នុងអាយតនៈផង ឈ្លាសក្នុងបដិច្ចសមុប្បាទផង ឈ្លាសក្នុងហេតុគួរ និងហេតុមិនគួរផង ដោយហេតុណា ម្នាលអានន្ទ ការណ៍ដែលគួរហៅថាភិក្ខុជាបណ្ឌិត អ្នកចេះពិចារណា ដោយហេតុប៉ុណ្ណោះឯង ។ ឯអ្នកឈ្លាសក្នុងព្រះសាស្ដា លោកបំណងយកក្នុងព្រះសូត្រនេះ ។ បទថា **ចេតោបរិយាយំ** សេចក្ដីថា វារៈនៃចិត្ត គឺការកំណត់ចិត្ត ។ បទថា **សមន្នេសេន** សេចក្ដីថា ស្វែងរក គឺស្ទុះស្វែង បានដល់ពិចារណារក ។

បទថា **ឥតិ វិញ្ញាណាយ** សេចក្ដីថា ដើម្បីប្រយោជន៍ដល់ការដឹងយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងការចូលទៅអាស្រ័យនឹងកល្យាណមិត្រ ក្នុងពាក្យនេះថា ភិក្ខុគប្បីស្វែងរកព្រះតថាគតក្នុងហេតុទាំង ២ ព្រោះថា ព្រះ

តថាគតនេះ ឈ្មោះថា ជាទីពឹង គឺជាកល្យាណមិត្រធំ គប្បីជ្រាបភាពដែលព្រះតថាគតជាកល្យាណមិត្រធំយ៉ាងនេះ ។

សម័យមួយ ព្រះអានន្ទគិតថា ព្រហ្មចរិយៈពាក់កណ្ដាល មានព្រោះអានុភាពរបស់ខ្លួន ពាក់កណ្ដាលមានព្រោះអានុភាពកល្យាណមិត្រ ហើយមិនអាចវិនិច្ឆ័យតាមធម្មតារបស់ខ្លួនបាន ទើបចូលទៅគាល់ព្រះមានព្រះភាគទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន គុណជាតិឯណា គឺការមានមិត្រល្អ ការមានសម្លាញ់ល្អ និងការមានក្លើល្អ គុណជាតិនេះ ចាត់ជាពាក់កណ្ដាលនៃព្រហ្មចរិយធម៌ ។ ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលអានន្ទ គុណជាតិឯណា គឺការមានមិត្រល្អ ការមានសម្លាញ់ល្អ និងការមានក្លើល្អ គុណជាតិនេះឯង ចាត់ជាព្រហ្មចរិយធម៌ទាំងមូល ។ ម្នាលអានន្ទ ព្រហ្មចរិយធម៌នេះឯង ប្រាកដដល់ភិក្ខុមានមិត្រល្អ មានសម្លាញ់ល្អ មានក្លើល្អ នឹងចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នឹងធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ម្នាលអានន្ទ ចុះភិក្ខុមានមិត្រល្អ មានសម្លាញ់ល្អ មានក្លើល្អ ចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ តើដូចម្ដេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសម្មាទិដ្ឋិដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្ដីនឿយណាយ អាស្រ័យនូវសេចក្ដីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ចម្រើននូវសម្មាសង្កប្ប ដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ ។បេ។ ចម្រើននូវសម្មាវាចា ។បេ។ ចម្រើននូវ

សម្មាកម្មន្ត: ។បេ។ ចម្រើននូវសម្មាអាជីវៈ ។បេ។ ចម្រើននូវសម្មាវាយាមៈ ។បេ។ ចម្រើននូវសម្មាសតិ ។បេ។ ចម្រើននូវសម្មាសមាធិ ដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្ដីនឿយណាយ អាស្រ័យនូវសេចក្ដីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ។ ម្នាលអានន្ទ ភិក្ខុមានមិត្រល្អ មានសម្លាញ់ល្អ មានក្លើល្អ ចម្រើននូវមគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ ធ្វើឲ្យច្រើននូវមគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ យ៉ាងនេះឯង ។ ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្ដីនោះដោយបរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្រល្អ ការមានសម្លាញ់ល្អ និងការមានក្លើល្អ ។ ម្នាលអានន្ទ ព្រោះអាស្រ័យតថាគតដែលជាមិត្រល្អ បានជាពួកសត្វដែលមានជាតិជាធម្មតា រួចស្រឡះចាកជាតិទៅបាន ពួកសត្វដែលមានជរាជាធម្មតា រួចស្រឡះចាកជរាទៅបាន ពួកសត្វដែលមានមរណៈជាធម្មតា រួចស្រឡះចាកមរណៈទៅបាន ពួកសត្វដែលមានសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្តជាធម្មតា រួចស្រឡះចាកសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្ដីចង្អៀតចង្អល់ចិត្តទៅបាន ។ ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្ដីនោះ ដោយបរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្រល្អ ការមានសម្លាញ់ល្អ និងការមានក្លើល្អ ដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់ការដល់ព្រមដោយអង្គខាងក្រៅដល់ភិក្ខុទាំងឡាយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ច្រើន ដូច

ការមានកល្យាណមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការមានកល្យាណមិត្រ ទើបប្រព្រឹត្តទៅដើម្បីប្រយោជន៍ច្រើន ។ កាលត្រាស់សល្លេខប្បដិបទារបស់ព្រះមហាចុន្ទ ទើបត្រាស់ថា ពួកអ្នកត្រូវធ្វើនូវសេចក្ដីផូរផង់យ៉ាងនេះថា ជនទាំងឡាយដទៃនឹងមានមិត្តអាក្រក់ក្នុងវត្ថុណា ពួកយើងនឹងមានមិត្រល្អក្នុងវត្ថុនោះ ។

កាលត្រាស់ធម៌សម្រាប់អប់រំវិមុត្តិដល់ព្រះមេឃិយត្ថេរ ទើបត្រាស់ថា ម្នាលមេឃិយៈ ធម៌ ៥ យ៉ាង ប្រព្រឹត្តទៅដើម្បីធ្វើចេតោវិមុត្តិ ដែលមិនទាន់ចាស់ក្លា ឲ្យចាស់ក្លាបាន ធម៌ ៥ យ៉ាង តើដូចម្ដេច ម្នាលមេឃិយៈ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្រល្អ បែរទៅរកមិត្រល្អ ... ។

កាលនឹងប្រទានឱវាទជាគ្រឿងពិចារណារឿយៗ ដល់ព្រះរាហុល ដែលជាបិយបុត្រ ទើបត្រាស់ធម៌ជាគ្រឿងចូលទៅអាស្រ័យកល្យាណមិត្រនោះឯងមុនធម៌ទាំងពួងថា

អ្នកចូរគប់រកនូវកល្យាណមិត្រ និងទីដេក ទីអង្គុយដ៏ឆ្ងាយ ស្ងប់ស្ងាត់ មិនមានសំឡេងគឹកកង ចូរជាអ្នកស្គាល់ប្រមាណក្នុងភោជន ។

ឈ្មោះថា ធម៌ជាគ្រឿងចូលទៅអាស្រ័យកល្យាណមិត្រនេះ ជាធម៌មានគុណច្រើនយ៉ាងនេះ ។ កាលទ្រង់សម្ដែងធម៌ក្នុងព្រះសូត្រនេះ ទើបព្រះមានព្រះភាគ ទ្រង់ប្រារព្ធទេសនាថា ត្រូវស្វែងរកព្រះតថាគតក្នុងធម៌ពីរប្រការ ។ អធិប្បាយថា ភិក្ខុអ្នកឈ្លាស ចូរស្ទះស្ទែង គឺស្វែងរកតថាគតក្នុងធម៌ទាំង ២ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់បន្លឺសីហនាទថា កិច្ចដោយការគិត

យ៉ាងនេះថា ព្រះពុទ្ធនេះមានជាតិធំ ដល់ព្រមដោយលក្ខណៈ រូបស្អាតគួរសរសើរ មានឈ្មោះបោះសំឡេង ដែលបុគ្គលប្រកាន់ថា សំខាន់យ៉ាងក្រៃលែង ឬអញអាស្រ័យបុគ្គលនេះហើយ នឹងបានបច្ច័យ មានចីវរជាដើម ហើយនៅអាស្រ័យតថាគតមិនមាន ឯបុគ្គលណាកំណត់យ៉ាងនេះថា ព្រះពុទ្ធនេះ ល្មមជាសាស្តា ដែលធ្វើនាទីជាសាស្តាឲ្យសម្រេចដល់អញបាន បុគ្គលនោះ ចូរសេពគប់នឹងតថាគតចុះ ។ ឈ្មោះថា ការបន្លឺសីហនាទនៃព្រះពុទ្ធទាំងឡាយជាព្រះសូត្រ ។

ឥឡូវនេះ កាលទ្រង់សម្តែងធម៌ទាំង ២ នោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ដែលគប្បីដឹងបានដោយចក្ខុ ១ ដឹងបានដោយសោតៈ ១ មារយាទដែលប្រព្រឹត្តទៅតាមផ្លូវកាយរបស់ព្រះសាស្តា ឈ្មោះថា ជាធម៌គប្បីដឹងដោយភ្នែករបស់បុគ្គលពិចារណា ។ មារយាទដែលប្រព្រឹត្តទៅផ្លូវវាចា ឈ្មោះថា ជាធម៌គប្បីដឹងដោយត្រចៀក ។ ឥឡូវនេះ កាលទ្រង់សម្តែងអាការដែលគប្បីពិចារណាក្នុងធម៌ទាំងនោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម៌ទាំងឡាយដ៏សៅហ្មងជាដើម ។

[ ១៧៧ ] បណ្តាបទទាំងនោះ បទថា **សង្កិលិដ្ឋា** បានដល់ ប្រកបកិលេស ហើយវត្ថុទាំងនោះ គប្បីដឹងច្បាស់ដោយភ្នែក និងត្រចៀកមិនបាន ដូចទឹកខ្ទុរពពុះឡើង បុគ្គលរមែងដឹងថា ខាងក្នុងមានត្រី យ៉ាងណា បុគ្គលបានឃើញ ឬបានឮមារយាទផ្លូវកាយ និងផ្លូវវាចារបស់បុគ្គលដែលជាអ្នកសម្លាប់សត្វ ឬពោលកុហកជាដើម ក៏រមែងដឹងថា ចិត្តដែលឲ្យអកុសលធម៌

មានការសម្លាប់ជាដើមតាំងឡើង សៅហ្មងព្រមហើយ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះថា បុគ្គលកាលមានចិត្តសៅហ្មងហើយ សូម្បីកាយសមាចារ និងវចីសមាចារ ក៏ឈ្មោះថា សៅហ្មងទៅដែរ ។ បទថា **ន តេ តថាគតស្ស សំវិជ្ជន្តិ** សេចក្តីថា បុគ្គលរមែងដឹងយ៉ាងនេះថា ធម៌ទាំងនោះនៃព្រះតថាគតមិនមាន គឺឥតអង្គឹមានឡើយ ។ ព្រោះភាពដែលវត្ថុទាំងនោះមិនមាននោះឯង គឺព្រោះមិនបានបិទបាំង ទើបមិនមានធម៌ទាំងនោះ ។ ពិតហើយ ព្រះមានព្រះភាគ កាលទ្រង់បវារណាពួកភិក្ខុ ក្នុងធម៌ពួកទាំងនេះក្នុងថ្ងៃមួយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះតថាគតបវារណាដល់អ្នកទាំងឡាយ អ្នកទាំងឡាយមិនតិះដៀលនូវកម្មតិចតួច ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វាររបស់តថាគតទេឬ ។ កាលព្រះមានព្រះភាគត្រាស់ យ៉ាងនេះហើយ ព្រះសារីបុត្រមានអាយុ ក៏ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៀងស្មាម្ខាង ប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គ មិនបានតិះដៀលនូវកម្មតិចតួច ដែលប្រព្រឹត្តទៅក្នុងកាយទ្វារ ឬវចីទ្វាររបស់ព្រះមានព្រះភាគទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើត ឲ្យស្គាល់ផ្លូវដែលមិនទាន់ស្គាល់ ប្រាប់ផ្លូវដែលមិនទាន់ប្រាប់ ទ្រង់ដឹងនូវផ្លូវ ជ្រាបច្បាស់នូវផ្លូវ ឈ្លាសវៃក្នុងផ្លូវ បពិត្រព្រះអង្គដ៏ចម្រើន ពួកសាវកក្នុងកាលឥឡូវនេះ តែងដើរទៅតាមផ្លូវ ដើរតាមក្រោយ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់មានកាយសមាចារ និងវចី-

សមាចារបរិសុទ្ធយ៉ាងនេះ ។

បានឮថា សូម្បីឧត្តរមាណពគិតថា អញនឹងឃើញទោសណាមួយដែលមិនគួរត្រេកអរក្នុងកាយទ្វារ និងវចីទ្វាររបស់ព្រះតថាគត ហើយដើរតាម ៧ ខែ ក៏មិនបានឃើញសូម្បីប៉ុនសុច កុំថាឡើយ ឧត្តរមាណពនេះជាមនុស្សឃើញណាមួយដែលមិនគួរត្រេកអរ ក្នុងកាយទ្វារ និងវចីទ្វាររបស់ព្រះមានព្រះភាគដ៏ជា ពុទ្ធ សូម្បីទេវបុត្តមារ ក៏ជាប់តាមតាំងអំពីព្រះមានព្រះភាគនៅជាព្រះពោធិសត្វ ទ្រង់ចេញមហាភិនេស្រ្កម៍ ចាំចាប់ទោសអស់ ៦ ឆ្នាំ ក៏មិនឃើញទោសណាមួយ ដែលមិនគួរត្រេកអរ ដោយហោច សូម្បីត្រឹមតែការគិតដោយផ្លូវចិត្ត ។ មារគិតហើយថា បើអញឃើញអកុសល ត្រឹមតែហេតុដែលព្រះពោធិសត្វនោះត្រិះរិះសោត ព្រោះទោសនោះឯង អញនឹងវាយព្រះពោធិសត្វនោះត្រង់ក្បាល ហើយចៀសទៅ ។ មារនោះមិនបានឃើញហើយអស់ ៦ ឆ្នាំ ហើយក៏ជាប់តាមព្រះពោធិសត្វដែលបានត្រាស់ជាព្រះពុទ្ធហើយមួយឆ្នាំទៀត ក៏មិនបានឃើញទោសណាមួយ ទើបថ្វាយបង្គំ ក្នុងវេលាជាទីទៅ ទើបពោលគាថានេះថា

**មហាវីរ មហាបញ្ញ ឥទ្ធិយា យសសា ជល**
**សព្វវេរ ភយាតីត ចាទេ វន្ទាមិ ចក្ខុម ។**

បពិត្រព្រះអង្គអ្នកមានព្យាយាមធំ មានប្រាជ្ញាច្រើន រុងរឿងដោយឫទ្ធិនិងយស កន្លងបង់នូវពៀរ និងភ័យគ្រប់ប្រការ ទ្រង់មានចក្ខុ ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំព្រះបាទា ដូច្នេះហើយ ចៀសចេញទៅ ។ បទថា **វីតិ-**

**មិស្សា** សេចក្តីថា លាយឡំគ្នាយ៉ាងនេះ គឺជួនកាលខ្មៅ ជួនកាលក៏ស ។ បទថា **អោធាតា** បានដល់ បរិសុទ្ធមិនមានកិលេស ។ បទថា **សំវិជ្ជន្តិ** សេចក្តីថា ធម៌ដែលផ្ទុយផង់ហើយមាន គឺរកបាន ។ ពិតហើយ ព្រះតថាគត រមែងមានកាយសមាចារជាដើមបរិសុទ្ធ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ហេតុទាំងឡាយ ៤ យ៉ាងនេះ តថាគតមិន បាច់រក្សាផង មិនមានការតិះដៀលដោយហេតុ ៣ យ៉ាងផង ។ ហេតុទាំង ៤ យ៉ាងដែលតថាគតមិនបាច់រក្សា តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ តថាគតមាន កាយសមាចារបរិសុទ្ធហើយ កាយទុច្ចរិតរបស់តថាគតមិនមានទេ ដែល តថាគតគួររក្សាថា កុំឲ្យបុគ្គលដទៃដឹងនូវកាយទុច្ចរិតនេះ របស់តថាគត ឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានវចីសមាចារបរិសុទ្ធហើយ ម្នាល ភិក្ខុទាំងឡាយ តថាគតមានមនោសមាចារបរិសុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ តថាគតមានការចិញ្ចឹមជីវិតបរិសុទ្ធហើយ ការចិញ្ចឹមជីវិតខុស របស់តថាគត មិនមានទេ ដែលតថាគតគួររក្សាថា កុំឲ្យបុគ្គលដទៃដឹងនូវការចិញ្ចឹមជីវិត ខុសនេះ របស់តថាគតឡើយ ដូច្នេះ ។

បទថា **ឥមំ កុសលំ ធម្មំ** បានដល់ សីលមានអាជីវៈជាគម្រប់ ៨ ។ អធិប្បាយថា អាវុសោនេះ ចូរស្វែងរកយ៉ាងនេះថា ព្រះសាស្តាទ្រង់ចូល អស់កាលដ៏យូរ ទ្រង់បរិបូណ៌ដោយសីលនេះ តាំងអំពីកាលដ៏យូរក្រៃលែង ឬថា ទ្រង់ចូលវេលាតិចតួច ទើបទ្រង់ចូលម្សិលមិញ ស្អែកនេះ ឬខានស្អែក នេះ ។ ព្រោះថា បុគ្គលពួកខ្លះដែលនៅក្នុងទីមួយ បានធ្វើកម្មជាគ្រឿងចិញ្ចឹម

ជីវិតខុសយ៉ាងច្រើន កម្មនោះ រមែងប្រាកដក្នុងការកន្ទងកាលនោះ រមែងប្រាកដហើយ លោកកាលទៅកាន់ស្រុកជាយដែន ឬប្រាំងមហាសមុទ្រណាមួយ ហើយធ្វើបណ្ណសាលា នៅដូចអ្នកព្រៃ ពួកមនុស្សកើតស្ញើចសរសើរហើយប្រគេនបច្ច័យដល់លោក ។ ពួកភិក្ខុដែនក្រៅឃើញការរស់នៅរបស់លោក ទើបកំណត់ថា លោកម្ចាស់អង្គនេះ ក្បៀវក្លាពន់ពេក ជានរណាហ្ន៎ ។ បានដឹងហើយថា ពួកភិក្ខុអ្នកធ្វើមិច្ឆាជីវៈឈ្មោះនោះ ក្នុងទីនោះ ចៀសទៅហើយអង្គុយប្រឹក្សាគ្នាថា ពួកយើងមិនអាចធ្វើឧបោសថ ឬបវារណារួមជាមួយភិក្ខុនេះបានឡើយ ទើបធ្វើកម្មឯណាមួយ ក្នុងបណ្ដាកម្ម មានឧក្ខេបនីយ-កម្មជាដើមតាមធម៌ ។ ព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះ ដើម្បីទ្រង់ឲ្យភិក្ខុទាំងនោះពិចារណាដល់បដិបទាដែលបិទបាំងបែបនោះ ថាមាន ឬមិនមាន ។

បទថា **ឯវំ ជានាតិ** សេចក្ដីថា ដឹងថា ទ្រង់ចូលអស់កាលយូរ មិនមែនទ្រង់ចូលអស់កាលតិចតួច ។ ឯអាជីវដ្ឋមកសីលរបស់ព្រះតថាគតដែលទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណក្នុងឥឡូវនេះ គប្បីបរិសុទ្ធអស់កាលយូរនេះមិនគួរអស្ចារ្យទេ សូម្បីក្នុងវេលាជាព្រះពោធិសត្វ សីលរបស់ព្រះអង្គ ក៏ដូច្នេះដែរ ។

បានឮថា ក្នុងអតីតកាល ព្រះរាជា ២ អង្គ គឺព្រះរាជាក្នុងដែនគន្ធារៈនិងព្រះរាជាក្នុងដែនវិទេហៈ ទ្រង់ជាសម្លាញ់នឹងគ្នា ទ្រង់ឃើញទោសក្នុងកាមទាំងឡាយ ទើបប្រគល់រាជសម្បត្តិដល់ឱរស ទ្រង់បួសជាឥសី ហើយត្រាច់បិណ្ឌបាតក្នុងស្រុកមួយ ។ ក្នុងជាយដែនរកអំបិលបានដោយលំបាក ឥសី

ទាំង ២ នោះ បានបបរ មិនបានដាក់អំបិល ហើយអង្គុយហុតលើសាលាមួយ ។ ពួកមនុស្សក្នុងចន្លោះៗ បានធ្វើអំបិលមកប្រគេន ។ ថ្ងៃមួយ បុរសម្នាក់បានដាក់អំបិលលើស្លឹកឈើ ឲ្យដល់វិទេហឥសី ។ វិទេហឥសីទទួលហើយ រំលែកទុកក្នុងសម្នាក់របស់គន្ធារឥសីពាក់កណ្ដាល សម្នាក់របស់ខ្លួនពាក់កណ្ដាល ។ បន្ទាប់អំពីនោះ ឥសីនោះឃើញអំបិលបន្តិចបន្តួចដែលសល់អំពីការបរិភោគ ទើបពោលថា អំបិលនេះ កុំវិនាសឡើយ ហើយយកស្លឹកឈើខ្ចប់ទុកក្នុងគុម្ពស្មៅ ។ ថ្ងៃមួយ ក្នុងវេលាឆាន់បបរ វិទេហឥសីរឭកបានកាលមើលទៅក៏ឃើញអំបិលនោះ ទើបចូលទៅរកគន្ធារឥសីពោលថា បពិត្រលោកអាចារ្យ សូមលោកអាចារ្យយកបន្តិចអំពីចំណែកនេះចុះ គន្ធារឥសីពោលថា នែ វិទេហឥសី លោកបានអំបិលនេះមកអំពីណា វិទេហឥសីពោលថា អំបិលដែលសល់អំពីការបរិភោគក្នុងថ្ងៃនោះ ខ្ញុំក៏រក្សាទុក ដោយគិតថា កុំវិនាសទៅឡើយ ។ គន្ធារឥសីមិនប្រាថ្នានឹងទទួល បានហុតបបរមិនមានអំបិលនោះឯង ហើយពោលនឹងវិទេហឥសីនោះថា លោកលះបង់ស្រុកចំណុះ ១ ពាន់ និងឃ្លាំង ១៦ ដ៏ពេញបរិបូណ៌ ( ដោយទ្រព្យ ) ធ្វើនូវការសន្សំក្នុងកាលឥឡូវនេះ ។ វិទេហឥសីបានពោលថា លោកម្ចាស់លះរាជសម្បត្តិ បួសហើយ ឥឡូវនេះ ព្រោះហេតុអ្វី ទើបមិនធ្វើកម្មដែលសមគួរដល់ការបួស ( លោកចេញមិនផុតអំពីពាក្យប្រៀនប្រដៅ ) ព្រោះប្រៀនប្រដៅខ្ញុំ ដោយហេតុត្រឹមតែសន្សំអំបិលឬ ។ គន្ធារឥសីពោលថា នែ វិទេហៈ ខ្ញុំបានធ្វើអ្វីខុស ។ គ្រានោះ ទើបវិទេហឥសីពោលនឹងគន្ធារឥសី

ថា លោកលះបង់នូវដែនគន្ធារៈ ដែលជាដែនសម្បូរដោយទ្រព្យ និងទឹក ហើយចេញផុតអំពីទីជាទីឲ្យនូវពាក្យប្រៀនប្រដៅ ( ដូចខ្ញុំដែរ ) ឥឡូវនេះ ( ហេតុអ្វីក៏មក ) ប្រៀនប្រដៅ ( ខ្ញុំ ) ក្នុងព្រៃនេះ ។ គន្ធារឥសីពោលថា ម្នាលវិទេហៈ ខ្ញុំនិយាយចំពោះតែធម៌ សភាវៈមិនមែនជាធម៌ មិនគាប់ចិត្ត ខ្ញុំទេ កាលបើខ្ញុំនិយាយធម៌ បាបឥតប្រឡាក់បានទេ ។ វិទេហតាបសពោល ថា បុគ្គលដទៃបាននូវសេចក្ដីក្រោធ ព្រោះពាក្យណានីមួយ បណ្ឌិតមិនគប្បី ពោលនូវពាក្យនោះឡើយ បើទុកជាពាក្យមានប្រយោជន៍ដ៏ធំក៏ដោយ ។ គន្ធារ តាបសពោលថា បុគ្គលទោះខឹងក៏ដោយ មិនខឹងក៏ដោយ ទោះរោយរាយដូច អង្កាមក៏ដោយ កាលបើខ្ញុំនិយាយធម៌ បាបមិនប្រឡាក់បានទេ ។ លំដាប់ នោះ វិទេហឥសីគិតថា បុគ្គលណាមិនមានការដឹងសូម្បីរបស់ខ្លួន មិនសិក្សា របៀបបែបផែនក្នុងសម្នាក់អាចារ្យ បុគ្គលនោះរមែងត្រាច់ទៅ ដូចក្របីខ្វាក់ ត្រាច់ទៅក្នុងព្រៃ ។ ហើយពោលថា បើប្រាជ្ញារបស់ខ្លួនក្ដី វិន័យដែលសិក្សា ល្អក្ដី មិនមានទេ ជនច្រើនគ្នា តែងប្រព្រឹត្តដូចជាក្របីខ្វាក់ក្នុងព្រៃ ។ មួយ ទៀត ពួកជនខ្លះក្នុងលោកនេះ បានសិក្សាល្អក្នុងអាចារប្បញ្ញត្តិ ព្រោះហេតុ នោះ ( ធីរជន ) អ្នកមានវិន័យទូន្មានហើយ រមែងមានចិត្តតាំងមាំល្អ ។ កាលពោលយ៉ាងនេះហើយ ទើបវិទេហឥសីពោលថា ហេតុនេះ ខ្ញុំមិនដឹង បានធ្វើហើយ ។ ក៏ឲ្យគន្ធារឥសីអត់ទោស ។ ឥសីទាំង ២ ប្រព្រឹត្តតបៈ ហើយទៅកាន់ព្រហ្មលោក ។ ក្នុងកាលដែលព្រះតថាគត ជាព្រះពោធិសត្វ អាជីវដ្ឋមកសីលក៏បានបរិសុទ្ធ អស់កាលយូរយ៉ាងនេះ ។

បទថា **ញត្តជ្ឈាបន្នោ អយមាយស្មា ភិក្ខុ យសបត្តោ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងថា ភិក្ខុនេះជាគ្រូរបស់អញ ដល់នូវភាពជាបុគ្គលដែលគេដឹងហើយ មានឈ្មោះបោះសំឡេង បានដល់ ប្រាកដហើយ ខ្លួនឯង សម្រេចបរិវារសម្បត្តិឬហ្ន៎ ព្រោះហេតុនោះ អ្នកចូរពិចារណាយ៉ាងនេះថា ទោសពួកខ្លះនឹងប្រាកដ ដោយភាពដែលខ្លួនប្រាកដឈ្មោះបោះសំឡេង និងដោយភាពដែលខ្លួនអាស្រ័យយស ឬមិនប្រាកដ ។

បទថា **ន តាវ ភិក្ខវេ** សេចក្តីថា ដរាបណាភិក្ខុ ជាអ្នកដល់នូវភាពជាបុគ្គល មានឈ្មោះបោះសំឡេងក្នុងព្រះរាជា និងអមាត្យរបស់ព្រះរាជាជាដើម ឬនូវបរិវារសម្បត្តិ ទោសឯណានីមួយ មានមានះ និងអស្មិមានះជាដើម តែងមិនមាន លោកហាក់ដូចជាបុគ្គលចូលទៅស្ងប់រម្ងាប់ហើយ ដូចព្រះសោតា-បន្ន និងដូចព្រះសកទាគាមី លោកជាបុគ្គលដែលបុគ្គលណា មិនអាចដើម្បីនឹងចង្អុលបង្ហាញថា លោកជាព្រះអរិយៈ ឬបុថុជ្ជនហ្ន៎ ។

បទថា **យតោ ច ខោ ភិក្ខវេ** សេចក្តីថា ក្នុងកាលណា ភិក្ខុពួកខ្លះក្នុងសាសនានេះ ជាអ្នកប្រាកដឈ្មោះបោះសំឡេងហើយ ឬជាអ្នកសម្បូរដោយបរិវារ កាលនោះ លោកកាលនឹងបៀតបៀនភិក្ខុដទៃក្នុងទីទាំងនោះ ដូចគោកាចបោលយកស្នែងដែលស្រួច វែធហ្វូងគោ និងដូចខ្លាដំបង ញាំញីហ្វូងម្រឹគដែលជាអ្នកមិនមានសេចក្តីគោរព មានការប្រព្រឹត្តមិនសមរម្យប្រកបត្រាច់ទៅ ដូចយកក្រចកជើងឆ្កឹះផែនដី ។

កុលបុត្រពួកខ្លះ ជាអ្នកប្រាកដឈ្មោះបោះសំឡេង មានយស ដោយ

ប្រការណាមួយ ឪនចុះដោយល្អ ដូចកួរស្រូវសាលីដែលពេញដោយគ្រាប់ ដោយប្រការនោះៗ កាលព្រះរាជា និងមហាមាត្យរបស់ព្រះរាជាជាដើមចូលទៅរក លោករមែងពិចារណាឃើញការមិនមានកិលេសជាតិ ជាគ្រឿងកន្ទល់ចូលទៅតាំងសមណសញ្ញាទុក ជាអ្នកស្ងប់រម្ងាប់ មិនក្រអឺតក្រទម មានចិត្តដាក់ចុះ ដូចគោឧសភដែលបាក់ស្នែង និងដូចក្មេងចណ្ឌាល បដិបត្តិហើយ ដើម្បីប្រយោជន៍ និងសេចក្ដីសុខដល់ភិក្ខុសង្ឃ និងដល់សត្វលោក ព្រមទាំងទេវលោក ព្រះមានព្រះភាគ ទ្រង់សំដៅយកបដិបទាបែបនេះ ទើបត្រាស់ថា ទោសឯណានីមួយក្នុងលោកនេះ មិនមានដល់អ្នក ។

ព្រះតថាគត ទ្រង់ជាតាទិបុគ្គល គឺមិនញាប់ញ័រក្នុងលោកធម៌ ៨ ព្រោះព្រះអង្គជាបុគ្គលមិនញាប់ញ័រក្នុងលាភខ្លះ ក្នុងការមិនមានលាភខ្លះ ក្នុងយសខ្លះ ក្នុងអយសខ្លះ ក្នុងនិន្ទាខ្លះ ក្នុងសរសើរខ្លះ ក្នុងសុខខ្លះ ទុក្ខខ្លះ ដូច្នោះ ទើបទោសទាំងឡាយណាមួយ ក្នុងលោកនេះ មិនមានដល់ព្រះអង្គ ដោយប្រការទាំងពួងនោះឯង ។

បទថា **អភយូបរតោ** សេចក្ដីថា ជាអ្នកមិនមានភ័យចូលទៅត្រេកអរហើយ អធិប្បាយថា ជាអ្នកចូលទៅត្រេកអរហើយ ដោយចំណែកមួយ គឺជាអ្នកចូលទៅត្រេកអរជាប់ជានិច្ច ។

ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកមិនមានភ័យចូលទៅត្រេកអរហើយ ព្រោះមិនជាអ្នកចូលទៅត្រេកអរដោយភ័យ ដូច្នេះក៏បាន ។ ភ័យមាន ៤ យ៉ាង គឺកិលេសភ័យ ១ វដ្តភ័យ ១ ទុគ្គតិភ័យ ១ ឧបវាទភ័យ គឺភ័យដែលកើត

អំពីការតិះដៀល ១ បុថុជ្ជនរមែងខ្លាចក្នុងភ័យ ៤ ប្រការ សេក្ខបុគ្គលទាំង-ឡាយរមែងខ្លាចក្នុងភ័យ ៣ ប្រការ ព្រោះសេក្ខបុគ្គលទាំងនោះ លះភ័យដែលកើតក្នុងទុគ្គតិបាន ព្រះសេក្ខបុគ្គល ៧ ពួក ជាអ្នកផុតភ័យដូច្នេះឯង ។ ព្រះខីណាស្រព ឈ្មោះថា ជាអ្នកផុតភ័យ ភ័យឯណាមួយ រមែងមិនមាន ភ័យដែលកើតអំពីការតិះដៀលរបស់អ្នកដទៃក៏មិនមាន លោករមែងអាស្រ័យការអាណិតអាសូរអ្នកដទៃ ហើយរក្សាការចូលទៅតិះដៀលអ្នកដទៃថា សត្វទាំងឡាយ អាស្រ័យព្រះខីណាស្រពដូចអាត្មាអញ កុំបីវិនាសឡើយ ដូចព្រះថេរៈនៅក្នុងមុលុប្បលវាបិវិហារ ដូច្នោះ ។

បានឮថា ព្រះថេរៈចូលទៅកាន់ស្រុកមុលុប្បលវាបិ ដើម្បីបិណ្ឌបាត ។ លំដាប់នោះ មនុស្សទាំងឡាយ ទទួលបាត្ររបស់លោកដែលនិមន្តដល់ទ្វារត្រកូលឧបដ្ឋាក ហើយក្រាលអាសនៈ ដាក់កៅអីបង្អែក ចំណែកធីតារបស់អមាត្យ អាស្រ័យកៅអីនោះឯង ឲ្យក្រាលអាសនៈទាប ក្នុងចំណែកម្ខាង ហើយអង្គុយ ។ ភិក្ខុម្ចាស់អាវាសមួយរូប ចូលទៅបិណ្ឌបាតខាងក្រោយ ឈរមើលត្រង់ទ្វារស្រុកនោះហើយ កំណត់ថា ព្រះថេរៈអង្គុយលើគ្រែតែមួយជាមួយកូនស្រីអមាត្យ ទើបគិតថា ភិក្ខុអ្នកទ្រទ្រង់សំពត់បង្សុកូលនេះ នៅក្នុងវិហារ ធ្វើដូចជាស្ងប់ស្ងាត់ តែមកអង្គុយលើគ្រែតែមួយជាមួយនឹងធីតាអមាត្យដែលជាឧបដ្ឋាកខាងក្នុងស្រុក សម្លឹងមើលម្តងហើយម្តងទៀត ពោលថា ហេតុអ្វីហ្ន៎ អញឃើញភិក្ខុគម្រក់នេះ ជាអ្នកសម្គាល់យ៉ាងនេះ ហើយចៀសចេញទៅ ។ ឯព្រះថេរៈឆាន់ស្រេចហើយ ទៅកាន់វិហារ ចូល

ក្នុងលំនៅរបស់ខ្លួន បិទទ្វារអង្គុយហើយ ។ ឯភិក្ខុម្ចាស់អាវាស ឆាន់ស្រេចហើយ ក៏ទៅវិហារគិតថា អញនឹងព្រមានលោក ហើយបណ្ដេញភិក្ខុ ដែលទ្រទ្រង់សំពត់បង្សុកូលនេះចេញអំពីវត្ត ហើយទៅត្រង់លំនៅរបស់ព្រះថេរៈដោយទំនងនៃការត្រាច់ទៅ ដោយមិនសង្រួម ហើយយកត្រឡោកដងទឹកសម្រាប់ឆាន់ ធ្វើសំឡេងខ្លាំង លាងជើងហើយ ។ ព្រះថេរៈពិចារណាថា បុគ្គលនេះជានរណាហ្ន៎ ជាអ្នកដើរមកមិនសង្រួមហើយ ដឹងរឿងទាំងអស់ហើយ គិតថា បុគ្គលនេះ កុំបានជាអ្នកមានចិត្តប្រទូស្តក្នុងអញ ហើយចូលដល់អបាយឡើយ ក៏ហោះឡើងទៅអង្គុយពត់ភ្នែន ក្បែរមណ្ឌលដំបូល ។ ភិក្ខុចៅអាវាស លើកក្អមដោយអាការប្រទូស្ត បានបើក ទ្វារចូលទៅខាងក្នុង មិនឃើញព្រះថេរៈ គិតថា ព្រះថេរៈប្រហែលជាចូលទៅក្រោមគ្រែ ទើបពិនិត្យមើល ក៏មិនជួបព្រះថេរៈក្នុងទីនោះទៀត ក៏គិតនឹងចេញទៅវិញ ។ ទើបព្រះថេរៈគ្រហែមឡើង ភិក្ខុចៅអាវាសនោះក៏ងើយឡើងទៅខាងលើ ឃើញហើយ មិនអាចនឹងអត់ធន់បាន ទើបពោលយ៉ាងនេះថា អាវុសោអ្នកទ្រទ្រង់សំពត់បង្សុកូល ការអង្គុយលើគ្រែជាមួយកូនអមាត្យដែលជាឧបដ្ឋាក សមគួរដល់លោកដែលដល់ព្រមហើយ ដោយអានុភាពយ៉ាងនេះឬ លោកដ៏ចម្រើនឈ្មោះថា បព្វជិតទាំងឡាយ អង្គុយលើគ្រែជាមួយមាតុគ្រាមមិនបាន ហេតុនេះ លោកឃើញថា មិនល្អឬ ព្រះខីណាស្រពទាំងឡាយ រមែងរក្សានូវឧបវាទ គឺការតិះដៀលរបស់អ្នកដទៃយ៉ាងនេះ ។

បទថា **១យា រាគស្ស** សេចក្ដីថា ព្រោះការអស់ទៅនៃរាគៈនោះឯង

រមែងមិនសេពកាមទាំងឡាយ ព្រោះប្រាសចាករាគៈ អធិប្បាយថា ហាមហើយ សេពដោយការពិចារណាក៏ទេ ។ បទថា **តញ្ចេ** សេចក្តីថា មនុស្សដទៃគប្បីសួរយ៉ាងនេះនឹងភិក្ខុដែលពិចារណានោះ ដែលជាអ្នកដឹងការលះកិលេសរបស់ព្រះតថាគតយ៉ាងនេះ ហើយអង្គុយលើធម្មាសនៈដែលតាក់តែងហើយ កណ្តាលបរិស័ទ ៤ សូម្បីក្នុងវេលាឈរ និងអង្គុយជាដើមនោះ ពោលសរសើរការលះកិលេសរបស់តថាគតយ៉ាងនេះថា ព្រោះយ៉ាងនេះ ព្រះសាស្តាទ្រង់ជាអ្នកប្រាសចាករាគៈ ទោសៈ មោហៈ ខ្ជាក់ចោលនូវកិលេសលះមន្ទិលបាន ទ្រង់បរិសុទ្ធដោយប្រពៃ ដូចព្រះចន្ទផុតចាកពពក ដូច្នោះ ។ បទថា **អាការា** បានដល់ ហេតុ ។ បទថា **អន្វយា** បានដល់ ដឹងតាម ។ បទថា **សង្ឃេ វា វិហរន្តោ** សេចក្តីថា ជួនកាលនៅត្រង់កណ្តាលភិក្ខុដែលកំណត់រាប់មិនបាន ។ បទថា **ឯកោ វា វិហរន្តោ** សេចក្តីថា ម្នាក់ឯងប្រថាប់នៅក្នុងទីសម្ងំ និងក្នុងព្រៃស្ដុក ឈ្មោះបាលិលេយ្យកៈយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដើម្បីនឹងពួនសម្ងំកន្លះខែ ឬ ៣ ខែ ។

បទថា **សុគតា** សេចក្តីថា ជាអ្នកទៅល្អហើយ គឺជាអ្នកបដិបត្តិល្អបានដល់ ជាអ្នកប្រកបសមគួរដល់ហេតុ ។ ភិក្ខុពួកខ្លះដែលមានសភាពបែបនេះក៏មាន ។ បទថា **ទុគ្គតា** សេចក្តីថា ឈ្មោះថា ជាអ្នកជាប់ជំពាក់ ព្រោះជាប់ជំពាក់ខ្លាំង លះបង់នូវកម្មដ្ឋាន ភិក្ខុរបខ្លះមានសភាពបែបនេះក៏មាន ។ បទថា **គណាមនុសាសន្តិ** សេចក្តីថា ឈ្មោះថា ជាអ្នកជាប់ជំពាក់ដោយគណៈ ជាអ្នកត្រេកអរក្នុងគណៈ ច្រើនក្នុងគណៈ បរិហារគណៈ ។ ភិក្ខុរប

ខ្លះមានសភាពបែបនេះក៏មាន ។ ភិក្ខុទាំងនោះជាបដិបក្ខចំពោះភិក្ខុពួកនោះ ជាអ្នករសាត់ចេញ រលាស់ចេញចាកគណៈ មិនប្រកបក៏មាន ។

បទថា **អាមិសេសុ សន្និស្សន្តិ** សេចក្តីថា ពួកភិក្ខុដែលប្រាថ្នាក្នុងអាមិសទាំងឡាយ ជាអ្នកល្មោភក្នុងអាមិស មានភ្នែកសម្លឹងតែអាមិស ត្រាច់ទៅដើម្បីអាមិស គឺបច្ច័យ ៤ ប៉ុណ្ណោះក៏មាន ។ ភិក្ខុទាំងឡាយត្រូវអាមិសលាបលន តែមានចិត្តផូរផង់ចាកបច្ច័យ ៤ ដូចព្រះចន្ទដែលផុតចាកពពកក៏មាន ។

បទថា **ឆាយមាយស្មា តំ តេន អវជានាតិ** សេចក្តីថា ការលើកឡើងដោយអំណាចអាស្រ័យផ្ទះ រមែងមិនមានដល់លោកយ៉ាងនេះថា អ្នកមានអាយុនេះជាគ្រូ រមែងមិនមើលងាយបុគ្គលនោះៗ តាមបដិបទានោះៗ អ្នកនេះជាបុគ្គលបដិបត្តិល្អ នេះឈ្មោះថា ជាអ្នកបន្សាត់ចេញ រលាស់ចេញចាកគណៈ បុគ្គលនេះជាអ្នកមានអាមិសមិនលាបលន ជាអ្នកមានចិត្តផូរផង់ចាកបច្ច័យទាំងឡាយ ដូចព្រះចន្ទផុតចាកពពក ដូច្នោះ ដូច្នេះក៏មាន ។ ការសម្គាល់គំរាមដោយអំណាចគេហសិតៈ រមែងមិនមានដល់លោកយ៉ាងនេះថា បុគ្គលនេះជាអ្នកបដិបត្តិមិនល្អ មិនមែនអ្នកបដិបត្តិ ជាអ្នកមានកាយធ្ងន់ លះកម្មដ្ឋាន បុគ្គលនេះជាអ្នកជាប់ជំពាក់ដល់ពួកគណៈ ល្មោភក្នុងអាមិស ជាអ្នកឡេះឡោះ មានចក្ខុសម្លឹងតែអាមិសដូច្នេះក៏មាន ។ សួរថា ពាក្យណាដែលភិក្ខុនោះពោល ឆ្លើយថា លោក រមែងជាអ្នកពោលភាពជាអ្នកមិនញាប់ញ័រ ក្នុងសត្វទាំងឡាយរបស់ព្រះតថាគត ។

ព្រះមានព្រះភាគដ៏ជាមុនីនេះ មានព្រះទ័យស្មើចំពោះសត្វទាំងឡាយ គឺ

ចំពោះទេវទត្តភិក្ខុ នាយខ្មាន់ធ្នូ ចោរអង្គុលិមាល ដីរ៉ធនបាល និងក្នុងព្រះរាហុល ។

[ ១៧៨ ] បទថា **តត្រ ភិក្ខវេ** សេចក្ដីថា ក្នុងបណ្ដាភិក្ខុដែលពិចារណាទាំង ២ នោះ ភិក្ខុនេះបានមកដល់ហើយ ព្រោះការសួរថា អ្វីជាអាការរបស់លោក នេះឈ្មោះថា បុគ្គលពិចារណាគណ្ឋិ ។ ម្យ៉ាងទៀត បុគ្គលណាមកហើយ ដោយគិតថា បុគ្គលនេះជាអ្នកមិនមានភ័យ ចូលទៅត្រេកអរហើយ ឈ្មោះថា អ្នកពិចារណាមូល ។ ក្នុងបុគ្គលទាំង ៣ បុគ្គលពិចារណាទាំងនេះ អ្នកពិចារណាមូល គប្បីត្រឡប់សួរព្រះតថាគតឲ្យធ្ងន់ឡើងទៅទៀតនោះឯង ។ អធិប្បាយថា ដំបូងលោកក៏នឹងដល់នូវការសម្រេចចិត្ត ដោយពាក្យរបស់អ្នកដទៃ ដែលឈ្មោះថា អ្នកដទៃ កាលដឹងខ្លះ មិនដឹងខ្លះ ក៏គប្បីពោលពាក្យសម្ដីរបស់លោក ជាពាក្យពិតខ្លះ មិនពិតខ្លះយ៉ាងនេះ ព្រោះដូច្នោះ លោកមិនដល់នូវការសម្រេចចិត្តក្នុងពាក្យរបស់អ្នកដទៃនោះឯង គប្បីសួរព្រះតថាគតឲ្យក្រៃលែងឡើងជាងនោះទៀត ។ ក្នុងបទថា **ព្យាករមានោ** នេះ ព្រោះដែលឈ្មោះថា ព្រះតថាគតមិនព្យាករខុស ដូច្នោះ ទើបព្រះមានព្រះភាគមិនត្រាស់ថា ត្រូវ ខុស តែត្រាស់ថា ទ្រង់ព្យាករ ។

បទថា **ឯតំ បថោហមស្មិ ឯតំ គោចរោ** សេចក្ដីថា តថាគតជាអ្នកមានអាជីវដ្ឋមកសីលបរិសុទ្ធថា នេះជាផ្លូវរបស់តថាគត នេះជាគោចររបស់តថាគត បាលីថា **ឯតាបថោ** ដូច្នេះក៏មាន ។ បទថា **ឯតាបថោ** នោះមានអធិប្បាយថា តថាគតជាបុគ្គលមានអាជីវដ្ឋមកសីលបរិសុទ្ធ តថាគត

នោះ ឈ្មោះថា ជាអ្នកមានអាជីវដ្ឋមកសីលជាផ្លូវដោយមុខ គឺញាណរបស់ភិក្ខុដែលឈ្មោះថា ជាអ្នកពិចារណានោះ ព្រោះភាពជាបុគ្គលបរិសុទ្ធ មានពាក្យអធិប្បាយថា តថាគតប្រាកដខ្លួនជាបុគ្គល មានសភាពយ៉ាងនេះ ។

ដោយបទថា **សោ ច តេន តម្មយោ** ព្រះមានព្រះភាគ ទ្រង់សម្ដែងថា តថាគតជាអ្នកសម្រេចហើយដោយអាជីវដ្ឋមកសីលនោះ ដោយសីលដែលបរិសុទ្ធនោះក៏ទេ ជាអ្នកមិនមានតណ្ហា ឈ្មោះថា ជាអ្នកអស់តណ្ហា ព្រោះភាពជាបុគ្គលមានសីលបរិសុទ្ធនោះឯង ។ បទថា **ឧត្តរុត្តរឹ បណីតប្បណីតំ** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់សម្ដែងឲ្យក្រៃលែងឡើង និងឲ្យប្រណីតក្រៃលែងឡើង ។ បទថា **កណ្ហសុក្កសប្បដិភាគំ** សេចក្ដីថា ទាំងខ្មៅ និងស ។ ព្រះមានព្រះភាគ ទ្រង់ធ្វើធម៌ចំណែកខ្មៅ និងធម៌ចំណែកសនោះឲ្យមានចំណែកប្រៀបធៀបគ្នា ឲ្យមានវិបាកប៉ុនគ្នា ហើយទ្រង់ហាមធម៌ចំណែកខ្មៅ ទ្រង់សម្ដែងទាំងធម៌ចំណែកខ្មៅ និងស ឲ្យមានចំណែកប្រៀបធៀបគ្នាយ៉ាងនេះថា ស ព្រោះទ្រង់ហាមចំណែកដែលស ហើយសម្ដែងទាំងចំណែកខ្មៅ និងចំណែកស ឲ្យមានចំណែកប្រៀបធៀបយ៉ាងនេះថា ខ្មៅ ដូច្នេះ ។ កាលទ្រង់សម្ដែងចំណែកដែលខ្មៅ ក៏ទ្រង់សម្ដែងព្រមដោយឧស្សាហៈ និងវិបាក ។ កាលទ្រង់សម្ដែងចំណែកដែលស ក៏រមែងទ្រង់សម្ដែងទាំងការឧស្សាហៈ និងវិបាក ។ បទថា **អភិញ្ញាយ ឯកេកច្ចំ ធម្មំ ធម្មេសុ និដ្ឋំ គច្ឆតិ** សេចក្ដីថា ដល់នូវការដាក់ចិត្តក្នុងព្រះធម្មទេសនាដោយធម៌ គឺការចាក់ធ្លុះដ៏ក្រៃលែងហើយនោះ ដោយការដឹងក្រៃលែងនូវធម៌ឯណាមួយ ក្នុង

ធម៌ដែលទ្រង់សម្តែងហើយនោះ ។

បទថា **សត្ថរិ បសីទតិ** សេចក្តីថា ដល់នូវការសម្រេចចិត្ត ក្នុងធម៌យ៉ាងនេះហើយ ជ្រះថ្លាក្នុងព្រះសាស្តា ដោយប្រមាណក្រៃលែងថា ព្រះមានព្រះភាគត្រាស់ដឹងឯងដោយប្រពៃ រមែងជ្រះថ្លាក្នុងព្រះធម៌ សូម្បីក្នុងព្រះសង្ឃក៏យ៉ាងនេះថា ព្រះធម៌ណាដែលព្រះមានព្រះភាគត្រាស់ថា ព្រះធម៌នោះឈ្មោះថា ព្រះមានព្រះភាគត្រាស់ល្អហើយ ព្រោះជាគ្រឿងនាំចេញ ។ ព្រះសង្ឃណាបដិបត្តិធម៌នោះ របស់ព្រះមានព្រះភាគអង្គនោះ ព្រះសង្ឃនោះឈ្មោះថា បដិបត្តិល្អហើយ ព្រោះបដិបត្តិបដិបទាដែលវៀរចាកទោស មានការវៀចវេរជាដើម ។ បទថា **តញ្ច** សេចក្តីថា នូវកិច្ចនោះ ដែលជ្រះថ្លាហើយយ៉ាងនេះ ពោលសរសើរគុណព្រះរតនត្រ័យក្នុងទីទាំងនោះ ។

[ ១៧៩ ] បទថា **ឥមេហិ អាការេហិ** សេចក្តីថា ដោយហេតុជាគ្រឿងពិចារណា ព្រះសាស្តាទាំងនេះ ។ បទថា **ឥមេហិ បទេហិ** បានដល់បទជាគ្រឿងរួបរួមអក្ខរៈទាំងនេះ ។ បទថា **ឥមេហិ ព្យញ្ជនេហិ** បានដល់បទជាគ្រឿងរួបរួមព្យញ្ជនៈទាំងនេះ ។ បទថា **សទ្ធា និវិដ្ឋា** បានដល់ ការចុះស៊ប់តាំងមាំហើយ គឺមានការជឿមាំ ។ បទថា **មូលជាតា** បានដល់ មានមូលកើតព្រមដោយអំណាចសោតាបត្តិមគ្គ ។ ឯសោតាបត្តិមគ្គ ឈ្មោះថាជាមូលនៃសទ្ធា ។ បទថា **អាការវតិ** បានដល់ ឈ្មោះថា មានហេតុព្រោះលោកស្វែងរកហេតុហើយ ទើបកាន់យក ។ បទថា **ទស្សនមូលិកា** បានដល់ ជាមូលនៃសោតាបត្តិមគ្គ ។ សោតាបត្តិមគ្គ លោកហៅថា

ទស្សន: ។ បទថា **ឧទ្ធរា** បានដល់ ស្ថិតស្ថេរ មាំមួន ។ បទថា **អសំហារិយ** បានដល់ ដែលបុគ្គលណាម្នាក់ មិនអាចនាំទៅបាន ។ បទថា **សមណេន វា** បានដល់ ទោះជាសមណៈដែលមានបាបស្ងប់ហើយក្តី ។ បទថា **ព្រាហ្មណេន វា** បានដល់ ទោះព្រាហ្មណ៍ដែលជាអ្នកបន្សាត់បាបហើយក្តី ។ បទថា **ទេវេន វា** បានដល់ ឧបបត្តិទេពក្តី ។ បទថា **មារេន វា** បានដល់ ស្តេចវសវត្តីមារក្តី ។ ឯការជឿរបស់ព្រះសោតាបន្ននោះ ជាសភាវៈដែលទេវតា សូម្បីវសវត្តីមារក៏លួចទៅមិនបាន ដូចសទ្ធារបស់នាយសូរអម្ពដ្ឋៈដូច្នោះ ។

បានឮថា សូរអម្ពដ្ឋៈនោះ ស្តាប់ធម៌របស់ព្រះសាស្តាហើយ បានជាព្រះសោតាបន្ន ហើយត្រឡប់ទៅផ្ទះ ។ លំដាប់នោះ មារនិម្មិតជាព្រះសម្មាសម្ពុទ្ធប្រដាប់ដោយលក្ខណៈ ៣២ ប្រការ ហើយឈរនៅត្រង់ផ្ទះរបស់សូរឧបាសក បញ្ជូនដំណឹងទៅថា ព្រះសាស្តាយាងមកហើយ ។ ឧបាសកគិតហើយថា អញស្តាប់ធម៌អំពីសម្នាក់របស់ព្រះសាស្តាអម្បាញ់មិញនេះឯង តើមានហេតុអ្វីហ្ន៎ ទើបទៅគាល់ ហើយឈរផ្គងអញ្ជលីដោយសម្គាល់ថា ជាព្រះសាស្តា ។ មារពោលថា ម្នាលសូរអម្ពដ្ឋៈ ពាក្យណាដែលតថាគតពោលហើយជាមួយអ្នកថា រូបមិនទៀង ។បេ។ វិញ្ញាណមិនទៀង ពាក្យនោះតថាគតពោលច្រឡំ តថាគតមិនបានពិចារណា ទើបពោលយ៉ាងនេះ ដូច្នោះ ចូរអ្នកកាន់យកថា រូបទៀង ។បេ។ វិញ្ញាណទៀង ។

សូរឧបាសកគិតថា ព្រះពុទ្ធទាំងឡាយ ទ្រង់មិនពិចារណាហើយ ត្រាស់នូវពាក្យណា មិនឲ្យជាក់ច្បាស់ហើយនោះ មិនជាឋានៈឡើយ បុគ្គលនេះជា

មារ មកដើម្បីឲ្យអញយល់ខុសពិត ។ លំដាប់នោះ ទើបពោលនឹងមារនោះ ថា អ្នកជាមារឬ មារនោះមិនអាចពោលកុហកបាន ទើបទទួលថា អើ ... យើងជាមារ ។ សូរឧបាសកពោលថា ចុះអ្នកមកព្រោះហេតុអ្វី មារពោល ថា មកដើម្បីឲ្យសទ្ធារបស់អ្នកឃ្លាតចាកទី ។

ទើបសូរឧបាសក ផ្ទាត់ម្រាមដៃឲ្យដឹងថា មារខ្លៅមានចិត្តបាប អ្នកឯង ចូរឈប់សិន មារដូចជាអ្នករាប់រយ រាប់ពាន់ ក៏មិនអាចឲ្យសទ្ធារបស់ខ្ញុំ ញាប់ញ័របានដែរ ឈ្មោះថា សទ្ធាដែលមកហើយដោយមគ្គ រមែងមិនកម្រើក ដូចភ្នំសិនេរុដែលតាំងនៅលើសិលាបឋវី អ្នកឯងនៅក្នុងទីនេះធ្វើអ្វី ។ មារ នោះមិនអាចតាំងនៅក្នុងទីនោះបាន ក៏អន្តរធានទៅក្នុងទីនោះឯង ។

បទថា **ព្រហ្មុនា វា** សេចក្ដីថា ឬបណ្ដាព្រហ្ម មានព្រហ្មកាយិកជាដើម ណាមួយក្ដី ។ បទថា **កេនចិ វា លោកស្មឹ** សេចក្ដីថា វៀរសមណៈ ទាំងនេះជាដើម ទោះបីបុគ្គលណាមួយដទៃក្នុងលោក ក៏មិនអាចនាំទៅបាន ។ ការពិចារណាការៈនៃខ្លួន ឈ្មោះថា ការពិចារណាធម៌ ។ បទថា **ធម្មតា-សុសមន្និដ្ឋោ** បានដល់ តាំងនៅក្នុងការពិចារណាចំណែកយ៉ាងល្អដោយ ធម្មតា អធិប្បាយថា ជាអ្នកពិចារណាហើយយ៉ាងល្អ តាមការៈនៃខ្លួននោះ ឯង ។ ពាក្យដ៏សេសគ្រប់បទ ងាយយល់ទាំងអស់ហើយ ៕

**វីមំសកសូត្រ ចប់**

**សូត្រទី ៧ ចប់**

# សុត្តន្តបិដក

## កោសម្ពិយសូត្រទី ៨

[ ១៨០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ ក៏សម័យនោះឯង ពួកភិក្ខុក្នុងក្រុងកោសម្ពីបង្កហេតុឈ្លោះទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នាដោយលំពែង គឺមាត់ ពួកភិក្ខុទាំងនោះ មិនញ៉ាំងគ្នានិងគ្នាឲ្យសុខចិត្តផង មិនប្រាថ្នានូវសេចក្តីសុខចិត្តផង មិនញ៉ាំងគ្នានិងគ្នាឲ្យយល់ព្រមផង មិនប្រាថ្នានូវសេចក្តីយល់ព្រមផង ។ គ្រានោះ ភិក្ខុ ១ រូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុក្នុងនគរកោសម្ពីនេះ បង្កហេតុឈ្លោះទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នាដោយលំពែង គឺ មាត់ ភិក្ខុទាំងនោះមិនញ៉ាំងគ្នានិងគ្នាឲ្យសុខចិត្តផង មិនប្រាថ្នានូវសេចក្តីសុខចិត្តផង មិនញ៉ាំងគ្នានិងគ្នាឲ្យយល់ព្រមផង មិនប្រាថ្នានូវសេចក្តីយល់ព្រមផង ។ គ្រានោះព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុមួយរូបមកថា ម្នាលភិក្ខុ អ្នកចូរមកនេះ អ្នកចូរហៅភិក្ខុទាំងឡាយនោះ តាមពាក្យតថាគតថា ព្រះសាស្តាត្រាស់ហៅលោកមានអាយុទាំងឡាយ ។ ភិក្ខុនោះ បានទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅរកពួកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងភិក្ខុទាំងនោះ ដូច្នេះថា ព្រះសាស្តាទ្រង់

ត្រាស់ហៅលោកមានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ពាក្យភិក្ខុនោះថា ករុណាអាវុសោ ដូច្នេះហើយ ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចទើបអង្គុយក្នុងទីដ៏សមគួរ ។

[ ១៨១ ] លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគបានត្រាស់ភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយបង្កហេតុ ឈ្លោះទាស់ទែងគ្នា ចាក់ដោតគ្នានឹងគ្នាដោយលំពែង គឺមាត់ អ្នកទាំងឡាយនោះ មិនញ៉ាំងគ្នានិងគ្នាឲ្យសុខចិត្តផង មិនប្រាថ្នានូវសេចក្តីសុខចិត្តផង មិនញ៉ាំងគ្នានិងគ្នាឲ្យយល់ព្រមផង មិនប្រាថ្នានូវសេចក្តីយល់ព្រមផង ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះដូចម្តេច សម័យណាដែលអ្នកទាំងឡាយបង្កហេតុ ឈ្លោះទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នាដោយលំពែង គឺមាត់ សម័យនោះអ្នកទាំងឡាយបានតាំងកាយកម្ម ប្រកបដោយមេត្តា ចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ក្នុងទីចំពោះមុខ និងទីកំបាំងមុខ ឬបានតាំងវចីកម្ម ប្រកបដោយមេត្តា ចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ក្នុងទីចំពោះមុខ និងទីកំបាំងមុខ ឬបានតាំងមនោកម្មប្រកបដោយមេត្តា ចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ក្នុងទីចំពោះមុខ និងទីកំបាំងមុខដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនបានតាំងយ៉ាងនោះទេ ។ ម្នាលភិក្ខុទាំងឡាយ បានឮដូច្នេះថា សម័យណា ដែលអ្នកទាំង-

ឡាយ បង្កហេតុឈ្លោះទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នាដោយលំពែង គឺមាត់ សម័យនោះ អ្នកទាំងឡាយ មិនបានតាំងកាយកម្មប្រកបដោយមេត្តា ចំពោះពួកសព្រហ្មចារីបុគ្គល ក្នុងទីចំពោះមុខ និងទីកំបាំងមុខផង មិនបានតាំងវចីកម្មប្រកបដោយមេត្តា ចំពោះពួកសព្រហ្មចារីបុគ្គលក្នុងទីចំពោះមុខ និងទីកំបាំមុខផង មិនបានតាំងមនោកម្មប្រកបដោយមេត្តា ចំពោះពួកសព្រហ្មចារី-បុគ្គលក្នុងទីចំពោះមុខ និងទីកំបាំងមុខផង ម្នាលមោឃបុរសទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយ ដឹងដូចម្តេច ឃើញដូចម្តេច បានជាបង្កហេតុឈ្លោះទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នាដោយលំពែង គឺមាត់ អ្នកទាំងឡាយនោះ មិនញុំាងគ្នានិងគ្នាឲ្យសុខចិត្តផង មិនប្រាថ្នានូវសេចក្តីសុខចិត្តផង មិនញុំាងគ្នានិងគ្នាឲ្យយល់ព្រមផង មិនប្រាថ្នានូវសេចក្តីយល់ព្រមផង ម្នាលមោឃបុរសទាំងឡាយ ហេតុនោះនឹងប្រព្រឹត្តទៅដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីទុក្ខដល់អ្នកទាំងឡាយ អស់កាលជាយូរអង្វែង ។

[ ១៨២ ] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៦ ប្រការនេះ ជាទីរឭក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ។ ធម៌ទាំងឡាយ ៦ ប្រការ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ គួរតាំងកាយកម្មប្រកបដោយមេត្តា ចំពោះពួកសព្រហ្មចារីបុគ្គលក្នុងទីចំពោះមុខ និងទីកំបាំងមុខផង នេះឯងជាធម៌គួរឲ្យរឭក ជាទីធ្វើឲ្យកើត

សេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ភិក្ខុគួរតាំងវចីកម្មប្រកបដោយមេត្តា ចំពោះពួកសព្រហ្មចារីបុគ្គល ក្នុងទីចំពោះមុខ និងទីកំបាំងមុខផង នេះឯងជាធម៌គួរឲ្យរឭក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ភិក្ខុគួរតាំងមនោកម្មប្រកបដោយមេត្តា ចំពោះពួកសព្រហ្មចារីបុគ្គល ក្នុងទីចំពោះមុខ និងទីកំបាំងមុខផង នេះឯងជាធម៌គួរឲ្យរឭក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត លាភណាដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅសូម្បីតែវត្ថុដែលរាប់ចូលក្នុងបាត្រ ភិក្ខុជាអ្នកបរិភោគមិនចែករំលែកលាភទាំងឡាយ មានសភាពដូច្នោះទេ គឺជាអ្នកបរិភោគសាធារណ៍ ដោយពួកសព្រហ្មចារីបុគ្គលដែលមានសីល នេះឯងជាធម៌គួរឲ្យរឭក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត សីលណាមិនដាច់ មិនធ្លុះធ្លាយ មិនពពាល មិនពព្រុស ជាសីលល្អដែលវិញ្ញូជនតែង

សរសើរ មិនប៉ះពាល់ដោយតណ្ហា និងទិដ្ឋិ ប្រព្រឹត្តទៅដើម្បីសមាធិ ភិក្ខុជាអ្នកមានសីលស្មើគ្នានឹងពួកសព្រហ្មចារីបុគ្គល ក្នុងសីលទាំងឡាយមានសភាពដូច្នោះ ទាំងក្នុងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះឯងជាធម៌គួរឲ្យរឭក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយវិញទៀត ទិដ្ឋិណាដ៏ប្រសើរ ជាទីស្រោចស្រង់សត្វ រមែងដឹកនាំសត្វដែលធ្វើតាម ឲ្យអស់ទៅនៃសេចក្តីទុក្ខបានដោយប្រពៃ ភិក្ខុប្រកបដោយទិដ្ឋិស្មើគ្នានឹងពួកសព្រហ្មចារីបុគ្គល ក្នុងទិដ្ឋិមានសភាពដូច្នោះ ទាំងក្នុងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះឯងជាធម៌គួរឲ្យរឭក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ទាំង ៦ ប្រការនេះឯង ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសារាណីយធម៌ទាំង ៦ ប្រការនេះ មានតែទិដ្ឋិដ៏ប្រសើរ ជាទីស្រោចស្រង់នេះឯង ដែលជាច្បង ជាទីរួបរួម ជាទីប្រជុំចុះ ( នៃធម៌ទាំង ៥ នោះ ) អាចដឹកនាំសត្វដែលប្រតិបត្តិតាម ឲ្យអស់ទៅនៃទុក្ខដោយប្រពៃបាន ។ ម្នាលភិក្ខុទាំងឡាយ កំពូលនៃផ្ទះមាន កំពូលជាច្បង ជាទីរួបរួម ជាទីប្រជុំចុះ យ៉ាង

ណា ម្នាលភិក្ខុទាំងឡាយ បណ្តាសារាណីយធម៌ទាំង ៦ ប្រការនេះ មានតែទិដ្ឋិដ៏ប្រសើរ ជាទីស្រោចស្រង់នេះឯងដែលជាច្បង ជាទីរួបរួម ជាទីប្រជុំចុះ (នៃធម៌ទាំង ៥ នោះ) អាចដឹកនាំសត្វដែលប្រតិបត្តិតាម ឲ្យអស់ទុក្ខដោយប្រពៃបាន យ៉ាងនោះដែរ ។

[ ១៨៣ ] ម្នាលភិក្ខុទាំងឡាយ ទិដ្ឋិដ៏ប្រសើរ ដែលជាទីស្រោចស្រង់ ដឹកនាំសត្វដែលប្រតិបត្តិតាម ឲ្យអស់សេចក្តីទុក្ខបានដោយប្រពៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងសុញ្ញាគារស្ទានក្តី រមែងពិចារណាដូច្នេះថា អាត្មាអញមានចិត្តដែលបរិយុដ្ឋានកិលេសណា គ្របសង្កត់ហើយ មិនដឹងច្បាស់ មិនឃើញច្បាស់តាមសភាវៈពិត បរិយុដ្ឋានកិលេសនោះ តាំងនៅក្នុងសន្តាន អាត្មាអញមិនទាន់លះបង់បាន មានដែរឬទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានកាមរាគៈគ្របសង្កត់ហើយ ក៏ឈ្មោះថាជាអ្នកមានចិត្តដែលបរិយុដ្ឋានកិលេសគ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានព្យាបាទគ្របសង្កត់ហើយ ក៏ឈ្មោះថាជាអ្នកមានចិត្ត ដែលបរិយុដ្ឋានកិលេសគ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានថីនមិទ្ធៈគ្របសង្កត់ហើយ ក៏ឈ្មោះថាជាអ្នកមានចិត្ត ដែលបរិយុដ្ឋានកិលេសគ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមានឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ហើយ ក៏ឈ្មោះថាជាអ្នកមានចិត្ត ដែលបរិយុដ្ឋានកិលេសគ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានវិចិកិច្ឆាគ្របសង្កត់ហើយ ក៏ឈ្មោះថាជាអ្នកមានចិត្ត ដែលបរិយុដ្ឋានកិសេលគ្របសង្កត់

ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុខ្វល់ខ្វាយដោយការគិតនូវលោកនេះហើយ ឈ្មោះថាជាអ្នកមានចិត្តដែលបរិយុដ្ឋានកិលេសគ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុមានសេចក្តីខ្វល់ខ្វាយដោយការគិតនូវលោកខាងមុខហើយ ឈ្មោះថាជាអ្នកមានចិត្តដែលបរិយុដ្ឋានកិលេស គ្របសង្កត់ពិត ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុបង្កហេតុ ឈ្លោះទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នាដោយលំពែង គឺមាត់ហើយ ឈ្មោះថាជាអ្នកមានចិត្ត ដែលបរិយុដ្ឋានកិលេសគ្របសង្កត់ពិត ភិក្ខុនោះរមែងដឹងយ៉ាងនេះថា អាត្មាអញមានចិត្តដែលបរិយុដ្ឋានកិលេសណាគ្របសង្កត់ហើយ មិនបានដឹងច្បាស់ មិនបានឃើញច្បាស់ តាមសភាវៈពិត បរិយុដ្ឋានកិលេសដែលតាំងនៅក្នុងសន្តាននោះ ដែលថាអាត្មាអញមិនទាន់លះបង់បាន មិនមានឡើយ ចិត្តរបស់អាត្មាអញបានតម្កល់ទុកប្រពៃហើយ ដើម្បីត្រាស់ដឹងនូវអរិយសច្ចធម៌ទាំង-ឡាយ ។ នេះជាញាណទី ១ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[ ១៨៤ ] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត អរិយសាវករមែងពិចារណាដូច្នេះថា អាត្មាអញកាលសេព កាលចម្រើន កាលធ្វើរឿយៗ នូវទិដ្ឋិនេះឯង តើបាននូវសេចក្តីស្ងប់រម្ងាប់ក្នុងចិត្តរបស់ខ្លួន បាននូវការរម្ងត់កិលេសក្នុងចិត្តរបស់ខ្លួនឬហ្ន៎ ។ អរិយសាវកនោះ រមែងដឹងយ៉ាងនេះថា អាត្មាអញកាលសេព កាលចម្រើន កាលធ្វើរឿយៗ នូវទិដ្ឋិនេះឯងតែងបាននូវសេចក្តីស្ងប់រម្ងាប់ក្នុងចិត្តរបស់ខ្លួន បាននូវការរម្ងត់កិលេសក្នុងចិត្តរបស់

ខ្លួន ។ នេះជាញាណទី ២ ដែលភិក្ខុនោះ បានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[ ១៨៥ ] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត អរិយសាវករមែងពិចារណាដូច្នេះថា អាត្មាអញប្រកបដោយទិដ្ឋិ មានសភាពយ៉ាងណា សមណៈ និងព្រាហ្មណ៍ដទៃក្រៅអំពីនេះ ដែលប្រកបដោយទិដ្ឋិ មានសភាពយ៉ាងនោះដែរ តើមានឬហ្ន៎ ។ អរិយសាវកនោះ ក៏ដឹងយ៉ាងនេះថា អាត្មាអញប្រកបដោយទិដ្ឋិមានសភាពយ៉ាងណា សមណៈ និងព្រាហ្មណ៍ដទៃ ក្រៅអំពីនេះ ដែលប្រកបដោយទិដ្ឋិមានសភាពយ៉ាងនោះ មិនមានទេ ។ នេះជាញាណទី ៣ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[ ១៨៦ ] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត អរិយសាវករមែងពិចារណាដូច្នេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមធម្មតា មានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមធម្មតា មានសភាពយ៉ាងនោះដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមធម្មតា មានសភាពដូចម្តេច ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គឺការចេញចាកអាបត្តិមានសភាពយ៉ាងណា ភិក្ខុក៏គង់ត្រូវអាបត្តិមានសភាពយ៉ាងនោះខ្លះដែរ តែថា ភិក្ខុនោះរមែងសម្តែងបើក ធ្វើឲ្យច្បាស់ឡើងនូវអាបត្តិនោះក្នុងសំណាក់សាស្តា ឬក្នុងពួកសព្រហ្មចារីបុគ្គល ជាអ្នកប្រាជ្ញដោយឆាប់រហ័ស លុះសម្តែងបើកធ្វើឲ្យច្បាស់ឡើង

ហើយ ក៏ដល់នូវការសង្រួមតទៅ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាកុមារក្មេង ជាកូនខ្ចី នៅដេកផ្ងារនៅឡើយ ប៉ះពាល់រងើកភ្លើងដោយដៃក្តី ដោយជើងក្តី ក៏ដកមកវិញជាប្រញាប់ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គល ដែលប្រកបដោយទិដ្ឋិ គឺការចេញចាកអាបត្តិមានសភាពយ៉ាងណា ភិក្ខុក៏គង់ត្រូវអាបត្តិមានសភាពយ៉ាងនោះខ្លះដែរ តែថាភិក្ខុនោះសម្តែង បើក ធ្វើឲ្យច្បាស់ឡើងនូវអាបត្តិនោះ ក្នុងសំណាក់សាស្តា ឬក្នុងពួកសព្រហ្មចារីបុគ្គល ជាអ្នកប្រាជ្ញដោយឆាប់រហ័ស លុះសម្តែង បើក ធ្វើឲ្យច្បាស់ឡើងហើយ ក៏ដល់នូវកិរិយាសង្រួមតទៅ យ៉ាងនោះដែរ ។ ភិក្ខុនោះ ក៏ដឹងយ៉ាងនេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិ តាមធម្មតាមានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមធម្មតា មានសភាពយ៉ាងនោះដែរ ។ នេះជាញាណទី ៤ ដែលភិក្ខុនោះ បានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[ ១៨៧ ] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត អរិយសាវករមែងពិចារណាដូច្នេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមធម្មតា មានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមធម្មតា មានសភាពយ៉ាងនោះដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមធម្មតា មានសភាពដូចម្តេច ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិនេះ គង់មានសេចក្តីខ្វល់ខ្វាយ ធ្វើការងារអ្វីៗ ខ្ពស់ និងទាប របស់ពួកសព្រហ្មចារីបុគ្គលខ្លះដែរ តែថាគេមានសេចក្តីប្រាថ្នា

ក្លៀវក្លា ក្នុងអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ ម្នាលភិក្ខុទាំង-ឡាយ ដូចជាមេគោមានកូនខ្ចី ទំព្រឹងស៊ីស្មៅផង ថ្មិតថ្មមកូនផង យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិនេះ គង់មាន សេចក្តីខ្វល់ខ្វាយ ធ្វើការងារអ្វីៗ ខ្ពស់ និងទាប របស់ពួកសព្រហ្មចារីបុគ្គល ខ្លះដែរ តែជាគេមានសេចក្តីប្រាថ្នាដ៏ក្លៀវក្លា ក្នុងអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ក៏យ៉ាងនោះដែរ ។ ភិក្ខុនោះ រមែងដឹងយ៉ាងនេះថា បុគ្គល ដែល បរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមធម្មតា មានសភាពយ៉ាងណា អាត្មាអញ ក៏ប្រកបដោយទិដ្ឋិតាមធម្មតា មានសភាពយ៉ាងនោះដែរ ។ នេះជា ញាណទី ៥ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជា លោកុត្តរ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[ ១៨៨ ] ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត អរិយសាវករមែង ពិចារណាដូច្នេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាព យ៉ាងនោះដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភាពនៃ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិមានកម្លាំងនុ៎ះ តែងត្រូវការយកចិត្តទុកដាក់ចំពោះ អ្នកសម្តែងធម៌វិន័យ ដែលតថាគតបានសម្តែងទុកមកហើយ ប្រមូលចិត្ត មកឲ្យមូល ផ្ទៀងត្រចៀកប្រុងស្តាប់ធម៌ ( នោះ ) ។ ភិក្ខុនោះរមែងដឹងយ៉ាង នេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាព

យ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពយ៉ាងនោះដែរ ។ នេះជាញាណទី ៦ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[ ១៨៩ ] ម្នាលភិក្ខុទាំងឡាយ ប្រការមួយវិញទៀត អរិយសាវករមែងពិចារណាដូច្នេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពយ៉ាងនោះដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភាពនៃបុគ្គលដែលបរិបូណ៌ដោយទិដ្ឋិមានកម្លាំងនោះ រមែងបានអត្ថវេទ បានធម្មវេទ និងបាមោជ្ជ ដែលប្រកបដោយធម៌ ចំពោះអ្នកសម្តែងធម្មវិន័យ ដែលតថាគតបានសម្តែងទុកមក ។ ភិក្ខុនោះរមែងដឹងយ៉ាងនេះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពយ៉ាងណា អាត្មាអញក៏ប្រកបដោយទិដ្ឋិតាមកម្លាំង មានសភាពដូច្នោះដែរ ។ នេះជាញាណទី ៧ ដែលភិក្ខុនោះបានត្រាស់ដឹងហើយ ជាញាណដ៏ប្រសើរ ជាលោកុត្តរ មិនសាធារណ៍ដល់ពួកបុថុជ្ជនឡើយ ។

[ ១៩០ ] ម្នាលភិក្ខុទាំងឡាយ ធម្មតានៃអរិយសាវកដែលប្រកបដោយអង្គទាំង ៧ ប្រការយ៉ាងនេះ សម្រេចល្អហើយ ក្នុងការធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកដែលប្រកបដោយអង្គទាំង ៧ ប្រការយ៉ាងនេះ ឈ្មោះថា ជាអ្នកប្រកបដោយសោតាបត្តិផល ។

លុះព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ពួកភិក្ខុទាំងនោះក៏មានសេចក្តីពេញចិត្ត ត្រេកអរនឹងភាសិតរបស់ព្រះមានព្រះភាគ ។

## កោសម្ពិយសូត្រទី ៨ ចប់

# អដ្ឋកថា
# កោសម្ពិយសូត្រទី ៨

[ ១៨០ ] កោសម្ពិយសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **កោសម្ពិយំ** សេចក្ដីថា ជិតព្រះនគរមានឈ្មោះយ៉ាងនេះ ។ បានឮថា មានដើមក្រចកស្មាំងយ៉ាងក្រាស់ក្នុងទីមានសួននិងស្រះបោក្ខរណីនោះៗ នៃព្រះនគរនោះ ព្រោះដូច្នោះ ព្រះនគរនោះ បានដល់នូវការរាប់ថា កោសម្ពី ។ អាចារ្យពួកខ្លះពោលថា ឈ្មោះថា **កោសម្ពី** ព្រោះឥសីឈ្មោះ **កុសម្ពៈ** ឲ្យសាងមិនឆ្ងាយអំពីអាស្រម ។ បទថា **ឃោសិតារាមេ** បានដល់ អារាមដែលឃោសិតសេដ្ឋី ឲ្យសាង ។

បានឮថា ក្នុងកាលមុនមានដែនឈ្មោះថា **អទិលៈ** លំដាប់នោះ មនុស្សក្រីក្រម្នាក់ឈ្មោះ **កោតុហាលិកៈ** ព្រោះកើតធាតកភ័យ ទើបនាំបុត្រ និងភរិយាទៅកាន់ដែនដែលកំណត់តាមភ្លឺស្រែ កាលមិនអាចនាំកូនទៅបាន ទើបចោលហើយទៅ ។ ស្ត្រីជាម្ដាយត្រឡប់មកពរកូននោះទៅ ។ ទាំង ២ នាក់នោះ ចូលទៅកាន់ផ្ទះអ្នកចិញ្ចឹមគោមួយខ្នង ។ ក្នុងកាលនោះ មនុស្សទាំងឡាយបានចាត់ចែងមធុបាយាសយ៉ាងច្រើន ដើម្បីឲ្យគោទាំងឡាយ ប្ដីប្រពន្ធទាំង ២ នាក់នោះ បានមធុបាយាសអំពីផ្ទះនោះបរិភោគហើយ ។ ខណៈនោះ កាលបុរសនោះបរិភោគមធុបាយាសច្រើន មិនអាចឲ្យរលួយបាន ស្លាប់កណ្ដាលយប់ បដិសន្ធិជាកូនឆ្កែក្នុងពោះរបស់មេឆ្កែ ក្នុងផ្ទះនោះ ។ កូនឆ្កែនោះបានជា

ទីស្រឡាញ់ ជាទីប្រោសប្រាណរបស់ម្ចាស់ ។ អ្នកចិញ្ចឹមគោបានទំនុកបម្រុងព្រះបច្ចេកពុទ្ធមួយអង្គ ។ ព្រះបច្ចេកពុទ្ធកាលឆាន់ហើយ ក៏ឲ្យដុំបាយមួយដុំដល់កូនឆ្កែនោះ ។ កូនឆ្កែធ្វើសេចក្ដីស្រឡាញ់ឲ្យកើតក្នុងព្រះបច្ចេកពុទ្ធទៅបណ្ណសាលាជាមួយអ្នកចិញ្ចឹមគោ ។ កាលអ្នកចិញ្ចឹមគោមិនបានត្រៀមខ្លួន កូនឆ្កែនោះក៏ទៅក្នុងវេលាឆាន់ដោយខ្លួនឯង ហើយព្រុសត្រង់ទ្វារបណ្ណ-សាលា ដើម្បីប្រាប់កត្តកាល កាលឃើញម្រឹគកាចក្នុងចន្លោះផ្លូវ ក៏ព្រុសឲ្យគេចទៅ ។ កូនឆ្កែនោះមានចិត្តទន់ភ្លន់ក្នុងព្រះបច្ចេកពុទ្ធ ស្លាប់ហើយកើតក្នុងទេវលោក ។ កាលនោះ ទេវបុត្រនោះ មានឈ្មោះថា **ឃោសកទេវបុត្រ** ។ កាលឃ្លាតចាកទេវលោក បានកើតក្នុងត្រកូលមួយ ក្នុងក្រុងកោសម្ពី ។ សេដ្ឋីជាអ្នកមិនមានបុត្រ ឲ្យទ្រព្យដល់ឪពុកម្ដាយរបស់ក្មេងនោះ នាំមកជាកូន ។

លំដាប់នោះ កាលកូនរបស់ខ្លួនកើត សេដ្ឋីនោះបានព្យាយាមដើម្បីសម្លាប់ដល់ទៅ ៧ ដង ។ កុមារនោះ ព្រោះខ្លួនមានបុណ្យ មិនដល់នូវការស្លាប់ក្នុងទី ៧ កន្លែង ចុងក្រោយ មានជីវិតព្រោះការឈ្លាសរបស់ធីតាសេដ្ឋីម្នាក់បន្ទាប់មក កាលបិតាអនិច្ចកម្មទៅ ទើបបានតំណែងជាសេដ្ឋី ឈ្មោះ ឃោសិតសេដ្ឋី ។ ក្នុងក្រុងកោសម្ពី មានសេដ្ឋីដទៃ ២ នាក់ទៀត គឺកុក្កុដសេដ្ឋី ១ បាវារិកសេដ្ឋី ១ និងឃោសិតសេដ្ឋី ១ ទើបជា ៣ នាក់ ។

កាលនោះ ពួកសេដ្ឋីដែលជាសម្លាញ់គ្នានោះ មានឥសី ៥០០ ជាជីតុននៅត្រង់ជើងភ្នំ ។ ជួនកាលពួកឥសីទាំងនោះ មកកាន់ទីកដីរបស់មនុស្សដើម្បីសេពរសប្រៃ និងរសជូរ ។ គ្រាមួយ ក្នុងរដូវក្ដៅ កាលទៅកាន់ទីកដី

មនុស្ស ដើរឆ្លងកន្តារយ៉ាងលំបាក រកទឹកមិនបាន កាលផុតផ្លូវកន្តារហើយ ឃើញដើមជ្រៃធំមួយដើម គិតគ្នាថា ក្នុងដើមជ្រៃនេះ គួរតែមានទេវតាមានសក្តិធំអាស្រ័យនៅដោយពិត ជាការល្អហ្ន៎ បើទេវតានោះឲ្យទឹក និងភោជនីយាហារដល់ពួកយើង ។ ទេវតាដឹងអធ្យាស្រ័យរបស់ពួកឥសីនោះ ទើបគិតថា អញនឹងសង្គ្រោះពួកឥសីនេះ ដោយអានុភាពខ្លួន ទើបបណ្តាលឲ្យផ្ការទឹកប្រមាណប៉ុនចុងដងនង្គ័ល ហូរចេញអំពីចន្លោះប្រគាបឈើ ឥសីឃើញផ្ការទឹកដូចខ្សែប្រាក់ ទើបយកភាជនៈរបស់ខ្លួនដងទឹកបរិភោគ នាំគ្នាគិតថា ពួកយើងទេវតាឲ្យទឹកផឹក ឯព្រៃធំនេះ មិនមានភូមិស្រុក បើទេវតាឲ្យអាហារដល់ពួកយើង គប្បីជាការល្អហ្ន៎ ។ ទើបទេវតាឲ្យបបរ និងខាទនីយជាដើម ដែលជាទិព្វ ឲ្យឆ្អែតស្កប់ស្កល់ហើយ ដោយអំណាចការចូលទៅសម្រេចដល់ពួកឥសី ។ ពួកឥសីនាំគ្នាគិតថា ពួកយើងទេវតាឲ្យរបស់គ្រប់យ៉ាង មិនថាទឹកផឹក និងអាហារ បើទេវតាគប្បីបង្ហាញខ្លួនដល់ពួកយើង ក៏ជាការល្អហ្ន៎ ទើបពួកឥសីនោះពោលថា លោកទេវតា សម្បត្តិរបស់លោកច្រើន លោកធ្វើកម្មអ្វី ទើបសម្រេចផលបែបនេះ ទេវតាពោលថា បពិត្រលោកម្ចាស់ ខ្ញុំធ្វើកម្មតិចតួច មិនធំដុំអ្វីឡើយ ខ្ញុំអាស្រ័យឧបោសថកម្មពាក់កណ្តាល ( គឺរក្សាបានមួយយប់ ) ទើបបានសម្បត្តិនេះ ។

បានឮថា ក្នុងកាលនោះ ទេវបុត្រនេះ បានជាកម្មករក្នុងផ្ទះរបស់អនាថបិណ្ឌិក ។ ក្នុងផ្ទះសេដ្ឋី រាល់ថ្ងៃឧបោសថ មនុស្សទាំងអស់ ដោយហោចទាសៈ និងកម្មករ សុទ្ធសឹងតែជាអ្នករក្សាឧបោសថ ។ ថ្ងៃមួយ កម្មករនេះ

ម្នាក់ឯងប៉ុណ្ណោះ ក្រោកឡើងអំពីព្រលឹម ទៅធ្វើការ ។ មហាសេដ្ឋី កាល បានកំណត់មនុស្សដែលគួរនឹងបានអាហារទាំងឡាយ បានដឹងថា កម្មករនោះ ម្នាក់ឯងប៉ុណ្ណោះ ទៅព្រៃហើយ ទើបបានរៀបចំអាហារដើម្បីពេលល្ងាច ។ ស្រីបម្រើដែលជាចុងភៅ ចម្អិនបាយដើម្បីគេម្នាក់ប៉ុណ្ណោះ កាលគាត់មកអំពី ព្រៃ ទើបលើកបាយទៅឲ្យ ។ កម្មករនោះពោលថា ក្នុងវេលាថ្ងៃដទៃៗ ក្នុង ផ្ទះ មានសំឡេងតែម្យ៉ាង ថ្ងៃនេះស្ងប់ស្ងាត់ពន់ពេក នេះព្រោះហេតុអ្វីហ្ន៎ ។ ចុងភៅនោះប្រាប់ដល់បុរសនោះថា ថ្ងៃនេះ ក្នុងផ្ទះនេះ មនុស្សទាំងអស់ ជា អ្នករក្សាឧបោសថ មហាសេដ្ឋីបានឲ្យរៀបចំអាហារដល់អ្នកតែម្នាក់ប៉ុណ្ណោះ កម្មករនោះពោលថា ពិតឬអ្នក ចុងភៅពោលថា ពិតមែន កម្មករពោលថា បុគ្គលសមាទានឧបោសថក្នុងពេលនេះ នឹងទៅជាឧបោសថកម្មឬទេ សូម អ្នកសួរមហាសេដ្ឋីយ៉ាងនេះឲ្យខ្ញុំផងចុះ ។

មហាសេដ្ឋីកាលស្រីបម្រើចូលទៅសួរ ទើបពោលថា មិនជាឧបោសថ ទាំងអស់ទេ តែជាឧបោសថពាក់កណ្តាល ចូរអ្នករក្សាឧបោសថចុះ ។ ទើប កម្មករនោះមិនបរិភោគអាហារ ខ្ពុរមាត់ រក្សាឧបោសថ ទៅកាន់លំនៅរបស់ ខ្លួន ហើយដេក ។ កាលបុរសនោះមានរាងកាយអត់អាហារ ខ្យល់បានកម្រើក ហើយកណ្តាលយប់ ស្លាប់វេលាព្រឹក កើតជាទេវបុត្រត្រង់ដើមជ្រៃធំក្នុងព្រៃ ព្រោះផលជាគ្រឿងហូរជូនទៅនៃឧបោសថកម្មពាក់កណ្តាល ទេវតាប្រាប់ការ ប្រព្រឹត្តទៅនោះដល់ពួកឥសី ។

ឥសីពោលថា លោកប្រកាសប្រាប់វត្ថុដែលខ្ញុំមិនធ្លាប់បានឮថា ព្រះពុទ្ធ

ព្រះធម៌ និងព្រះសង្ឃ ឲ្យខ្ញុំបានឮថា ព្រះពុទ្ធទ្រង់កើតឡើងក្នុងលោកហើយ ឬហ្ន៎ ទេវបុត្រពោលថា បពិត្រលោកម្ចាស់ ទ្រង់កើតឡើងហើយ ឥសីពោលថា ឥឡូវនេះ ទ្រង់ប្រថាប់នៅទីណា ទេវបុត្រពោលថា ទ្រង់អាស្រ័យក្នុងក្រុងសាវត្ថី នៅប្រថាប់ក្នុងវត្តជេតពន ឥសីពោលថា សូមលោកស្ងៀមប៉ុណ្ណឹងសិនចុះ ពួកខ្ញុំនឹងចូលគាល់ព្រះសាស្តា នាំគ្នាត្រេកអររីករាយចេញទៅដល់នគរកោសម្ពីដោយលំដាប់ ។ ពួកមហាសេដ្ឋីឮថា ឥសីទាំងឡាយមកហើយ ទើបធ្វើបដិសណ្ឋារៈ ហើយពោលថា បពិត្រលោកម្ចាស់ ស្អែកនេះ សូមទទួលកិច្ចាររបស់ពួកខ្ញុំ កាលដល់ថ្ងៃស្អែកឡើង ក៏បានថ្វាយមហាទានដល់ឥសីគណៈ ពួកឥសីឆាន់ហើយ ទើបសួរគ្នាថា ពួកយើងទៅណាទៀតហ្ន៎ ។ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ ក្នុងកាលដទៃ ក៏ស្នាក់នៅ ១ ខែខ្លះ ២ ខែខ្លះ ៣-៤ ខែខ្លះ ទើបទៅ តែពេលនេះ ទើបតែមកពីម្សិលសោះ បែរជាពោលថា ពួកយើងនឹងទៅថ្ងៃនេះពិតៗ តើព្រោះហេតុអ្វីហ្ន៎ ។ ឥសីពោលថា ពិតហើយ លោកគហបតី ព្រះពុទ្ធទ្រង់កើតឡើងក្នុងលោកហើយ អាត្មាមិនអាចដឹងនូវអន្តរាយនៃជីវិតបាន ព្រោះហេតុនោះ ទើបពួកអាត្មាប្រញាប់ទៅ ។ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ ពួកខ្ញុំក៏ទៅដែរ សូមលោកម្ចាស់ទៅរួមគ្នាជាមួយពួកខ្ញុំចុះ ។ ឥសីពោលថា ឈ្មោះថា ជាមហាជន ជាអ្នកគ្រប់គ្រងផ្ទះ ចូរឈប់បន្តិចសិនចុះ ពួកអាត្មាទៅមុនដូច្នេះ ក៏នាំគ្នាចេញទៅ មិនសម្រាក ១-២ ថ្ងៃ ទៅដោយប្រញាប់នោះឯងកាន់យកក្រុងសាវត្ថីហើយ ទើបមកកាន់សម្នាក់ព្រះសាស្តា ក្នុងជេតពនមហា

វិហារ ។ ឥសីទាំងនោះ ស្តាប់ធម្មកថាដ៏ពីរោះក្នុងទីនោះ បួសហើយ បាន សម្រេចជាព្រះអរហន្ត ។

ឯសេដ្ឋីទាំង ៣ បររទេះទៅម្នាក់ ៥០០ ដឹកសប្បិ ទឹកឃ្មុំ ទឹកអំពៅ និង សំពត់សម្បកឈើជាដើម ចេញអំពីក្រុងកោសម្ពី ដល់ក្រុងសាវត្ថីដោយ លំដាប់ បោះជំរំក្បែរវត្តជេតពន នាំគ្នាទៅសម្នាក់ព្រះសាស្តា ថ្វាយបង្គំ ធ្វើ បដិសណ្ឋារៈហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ព្រះសាស្តាបានត្រាស់ ធម្មកថាយ៉ាងពីរោះដល់សម្មាញ់ទាំង ៣ ។ ពួកសេដ្ឋីទាំងនោះ កើតសោម-នស្សដ៏ខ្លាំងក្លា និមន្តព្រះសាស្តា ថ្ងៃស្អែកឡើង បានថ្វាយមហាទាន ។ ពួក សេដ្ឋីថ្វាយហើយរៀងរាល់ថ្ងៃ សរុបសេចក្តីមក បានថ្វាយយ៉ាងនេះអស់ កាលកន្លះខែនោះឯង ក្រាបទៀបបាទា ក្រាបទូលថា សូមព្រះអង្គប្រទាន បដិញ្ញាដើម្បីយាងមកជនបទរបស់ខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាល គហបតីទាំងឡាយ ព្រះតថាគតទាំងឡាយ រមែងត្រេកអរក្រៃលែង ក្នុងផ្ទះ ស្ងាត់ ។ ពួកគហបតីនាំគ្នាកំណត់ថា ហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ព្រះមានព្រះភាគ បានប្រទានបដិញ្ញាហើយ ហើយគិតថា ព្រះមានព្រះភាគ ទ្រង់ប្រទានបដិញ្ញាដល់ពួកយើងហើយ ថ្វាយបង្គំព្រះទសពល ចេញទៅ ឲ្យ សាងវិហារគ្រប់ៗ កន្លះយោជន៍ ក្នុងចន្លោះផ្លូវដល់ក្រុងកោសម្ពីដោយលំដាប់ នាំគ្នាពោលថា ព្រះពុទ្ធកើតឡើងក្នុងលោកហើយ ។ ឯសេដ្ឋីទាំង ៣ បរិច្ចាគ ទ្រព្យដ៏ច្រើនក្នុងអារាមរបស់ខ្លួន រៀងៗ ខ្លួន ឲ្យសាងវិហារសម្រាប់ជាទីគង់ ប្រថាប់របស់ព្រះមានព្រះភាគ ។ សេដ្ឋីទាំង ៣ នោះ កុក្កុដសេដ្ឋីឲ្យសាង

កុក្កុដារាម បាវារិកសេដ្ឋីឲ្យសាងបាវារិកម្ពវ័នក្នុងព្រៃស្វាយ ឃោសិតសេដ្ឋីឲ្យសាងឃោសិតារាម ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកឃោសិតារាមនោះ ទើបត្រាស់ថា ក្នុងអារាមដែលឃោសិតសេដ្ឋីឲ្យសាង ។

ក្នុងបទជាដើមថា **ភណ្ឌនជាតា** គួរធ្វើវិគ្គហៈថា ខាងដើមនៃជម្លោះឈ្មោះថា ការទាស់ទែង ការទាស់ទែងនោះ កើតដល់ភិក្ខុទាំងនោះ ហេតុនោះ ឈ្មោះថា ការទាស់ទែងកើត ។ ជម្លោះដែលដល់ទីបំផុត ដោយអំណាចការវាយតប់ជាដើមកើតដល់ភិក្ខុទាំងនោះ ហេតុនោះ ទើបឈ្មោះថា បុគ្គលមានជម្លោះកើតហើយ ។

ពីរបទថា **វិវាទាបន្នា** សេចក្តីថា ភិក្ខុទាំងនោះ ដល់នូវវិវាទនោះ ហេតុនោះ ឈ្មោះថា ដល់នូវការពោលផ្សេងគ្នា ។ បទថា **មុខសត្តីហិ** បាន ដល់ ដោយលំពែង គឺវាចាទាំងឡាយ ។ បទថា **វិតុទន្តា** គឺ ចាក់ទម្លុះ ។ ព្រើនបទថា **តេ ន ចេវ អញ្ញមញ្ញំ សញ្ញាបេន្តិ ន ច សញ្ញត្តឹ ឧបេន្តិ** សេចក្តីថា ភិក្ខុទាំងនោះបង្ហាញហេតុផលហើយ មិនយល់ព្រមដល់គ្នានិងគ្នា អធិប្បាយថា បើប្រាថ្នាឲ្យគ្នានិងគ្នាយល់ព្រមសោត ។ ពួកលោកក៏មិនចូលដល់ការយល់ព្រមយ៉ាងនោះ ទាំងមិនប្រាថ្នាដើម្បីស្រុះស្រួល សូម្បីបទថា **និជ្ឈត្តឹ** ក៏ន័យនេះ ។ បទថា **និជ្ឈត្តឹ** ជាវេវចនៈរបស់បទថា ពាក្យថា **សញ្ញត្តឹ** ។

បានឮថា ភិក្ខុ ២ រូប គឺព្រះវិនយធរ និងភិក្ខុទ្រទ្រង់ព្រះសូត្រ នៅក្នុងវត្តតែមួយ ។ ថ្ងៃមួយ ភិក្ខុទ្រទ្រង់ព្រះសូត្រចូលវច្ចកុដិ បន្សល់ទឹកសម្រាប់

លាងក្នុងភាជនៈ ហើយចេញទៅ ភិក្ខុដែលទ្រទ្រង់វិន័យចូលទៅខាងក្រោយ ឃើញទឹកនោះ ចេញមកហើយ សួរភិក្ខុនោះថា នែលោកម្ចាស់ ទឹកនេះលោកបន្សល់ឬ ភិក្ខុទ្រទ្រង់ព្រះសូត្រឆ្លើយថា ពិតមែនហើយលោកម្ចាស់ ភិក្ខុទ្រទ្រង់វិន័យសួរថា លោកម្ចាស់មិនដឹងថា ត្រូវអាបត្តិព្រោះហេតុនោះឬ ភិក្ខុទ្រទ្រង់ព្រះសូត្រពោលថា អើ ខ្ញុំមិនដឹង ភិក្ខុទ្រទ្រង់វិន័យពោលថា នែលោកម្ចាស់ លោកម្ចាស់ត្រូវអាបត្តិក្នុងសេចក្តីនេះ ភិក្ខុទ្រទ្រង់ព្រះសូត្រពោលថា បើមានអាបត្តិ ខ្ញុំនឹងសម្តែង ភិក្ខុជាវិនយធរពោលថា នែលោកម្ចាស់ បើលោកម្ចាស់មិនមានចិត្តក្លែង ព្រោះមិនមានស្មារតី លោកម្ចាស់ក៏មិនត្រូវអាបត្តិ ។

ភិក្ខុទ្រទ្រង់ព្រះសូត្រ បានជាអ្នកយល់ឃើញថា មិនជាអាបត្តិក្នុងវត្ថុដែលជាអាបត្តិ ។ ទើបភិក្ខុទ្រទ្រង់វិន័យ ប្រាប់ដល់ពួកនិស្សិតរបស់ខ្លួនថា លោកម្ចាស់ទ្រទ្រង់ព្រះសូត្រនេះ សូម្បីត្រូវអាបត្តិក៏មិនដឹង ។ ពួកភិក្ខុដែលជានិស្សិតរបស់ព្រះវិនយធរឃើញពួកនិស្សិត របស់ភិក្ខុអ្នកទ្រទ្រង់ព្រះសូត្រ ទើបពោលថា ឧបជ្ឈាយ៍របស់ពួកលោកម្ចាស់ សូម្បីត្រូវអាបត្តិហើយ ក៏មិនដឹងថាត្រូវអាបត្តិ ។ ភិក្ខុដែលជានិស្សិតរបស់ភិក្ខុអ្នកទ្រង់ព្រះសូត្រទាំងនោះទៅប្រាប់ដល់ឧបជ្ឈាយ៍របស់ខ្លួន ។ ទើបភិក្ខុអ្នកទ្រទ្រង់ព្រះសូត្រពោលយ៉ាងនេះថា ព្រះវិនយធរនេះ កាលមុនពោលថា មិនត្រូវអាបត្តិ ឥឡូវនេះ ពោលថា ត្រូវអាបត្តិ វិនយធរនោះ ជាមនុស្សមុសាវាទ ។ ពួកនិស្សិតរបស់ភិក្ខុដែលទ្រទ្រង់ព្រះសូត្រ ទើបទៅពោលថា ឧបជ្ឈាយ៍របស់ពួកលោកពោលកុហក ដូច្នេះ ផ្សាយនូវជម្លោះទៅកាន់គ្នានិងគ្នា ។ ព្រះមានព្រះភាគ ទ្រង់

សំដៅយកនូវការឈ្លោះទាស់ទែងនោះ ទើបត្រាស់ពាក្យនេះ ។

បទថា **ភគវន្តំ ឯតទវោច** សេចក្តីថា បានក្រាបទូលពាក្យខាងដើមនោះថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គសូមប្រទានឱកាស ពួកភិក្ខុក្នុងក្រុងកោសម្ពីកើតវិវាទដល់គ្នានិងគ្នាហើយ ។ ភិក្ខុនោះ មិនបានពោលពាក្យនោះ ព្រោះបំណងជាទីស្រឡាញ់ផង មិនបានពោលព្រោះត្រូវការបែកបាក់គ្នាផង ដោយពិត ត្រូវការប្រយោជន៍ និងការអនុគ្រោះ ។

បានឮថា ភិក្ខុនេះជាអ្នកធ្វើឲ្យកើតសាមគ្គីដល់គ្នានិងគ្នា ដូច្នោះ ទើបមានការគិតយ៉ាងនេះថា ភិក្ខុទាំងនេះប្រារព្ធនូវជម្លោះ និងវិវាទ សូម្បីអញនិងភិក្ខុដទៃ ក៏មិនអាចធ្វើឲ្យព្រមព្រៀងគ្នាបាន ឯព្រះមានព្រះភាគ ទ្រង់មិនមានបុគ្គលប្រៀបក្នុងលោក ព្រមទាំងទេវលោក ទ្រង់យាងទៅឯង ឬត្រាស់ឲ្យហៅមកកាន់សម្នាក់របស់ព្រះអង្គ ត្រាស់ធម្មទេសនា ជាហេតុឲ្យរឭកដល់គ្នានិងគ្នា ប្រកបដោយខន្តី និងមេត្តាដល់ភិក្ខុទាំងនោះ ប្រហែលជាអាចធ្វើឲ្យព្រមព្រៀងគ្នាបាន ទើបទៅក្រាបទូល ព្រោះប្រាថ្នាប្រយោជន៍ និងសេចក្តីអនុគ្រោះ ។

[ ១៨២ ] បទថា **ឆយិមេ ភិក្ខវេ ធម្មា សារាណីយា** សេចក្តីថា ប្រារព្ធទេសនា ដោយអំណាចការឈ្លោះ និងការទាស់ទែងខាងដើម ។ ពាក្យថា ធម៌ជាទីតាំងនៃការរឭកដល់ ៦ មកហើយក្នុងឋានៈនេះ សេចក្តីថា កោសម្ពិយសូត្រនេះ មកហើយតាមអនុសន្ធិយ៉ាងនេះថា

ក្នុងបទនេះថា **សារាណីយា** សេចក្តីថា កាលកន្លងទៅយូរ មិនគួរ

ក្មេង ព្រោះប្រកបដោយធម៌ដែលគួររឭកដល់ បុគ្គលណាបំពេញធម៌ទាំង នោះ ធម៌ទាំងនោះរមែងធ្វើបុគ្គលនោះ ឲ្យជាទីស្រឡាញ់ របស់សព្រហ្មចារី រួមគ្នា ហេតុនោះ ឈ្មោះថា ធម៌ជាគ្រឿងធ្វើឲ្យជាទីស្រឡាញ់ ។ ឈ្មោះថា ធម៌ជាគ្រឿងធ្វើសេចក្តីគោរព ព្រោះធ្វើនូវសេចក្តីគោរព ។

បទថា **សង្គហាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់ការសង្គ្រោះ ។ បទ ថា **អវិវាទាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការមិនវិវាទ ។ បទថា **សាមគ្គិយា** បានដល់ ដើម្បីប្រយោជន៍ដល់ការព្រមព្រៀងគ្នា ។ បទថា **ឯកីភាវាយ** សេចក្តីថា ដើម្បីប្រយោជន៍នៃឯកីភាព គឺដើម្បីមិនធ្វើឲ្យផ្សេងគ្នា ។ បទថា **សំវត្តន្តិ** បានដល់ ប្រព្រឹត្តទៅព្រម គឺមាន ។ បទថា **មេត្តំ កាយកម្មំ** បាន ដល់ កាយកម្ម គប្បីធ្វើដោយចិត្ត ប្រកបដោយមេត្តា ។ សូម្បីក្នុងវចីកម្ម និងមនោកម្មក៏មានន័យដូច្នេះ ។ មេត្តាចិត្តទាំងនេះមកហើយ ដោយអំណាច ភិក្ខុទាំងឡាយ រមែងរកបានសូម្បីក្នុងពួកគ្រហស្ថ ។ មេត្តាជាគ្រឿងបំពេញ អភិសមាចារិកធម៌ ដោយចិត្តប្រកបដោយមេត្តានៃភិក្ខុទាំងឡាយ ឈ្មោះថា **កាយកម្ម** ។ កម្មជាដើមយ៉ាងនេះ គឺការទៅដើម្បីប្រយោជន៍ថ្វាយបង្គំចេតិយ ១ ថ្វាយបង្គំពោធិព្រឹក្ស ១ និមន្តព្រះសង្ឃ ១ ការឃើញភិក្ខុទាំងឡាយ ដែលចូលទៅកាន់គោចរគ្រាមដើម្បីបិណ្ឌបាត ហើយទទួល ១ ការទទួល បាត្រ ១ ការក្រាលអាសនៈ ១ ការតាមបញ្ជូន ១ របស់ពួកគ្រហស្ថ ឈ្មោះថា **មេត្តាកាយកម្ម** ។ ឈ្មោះថា មេត្តាវចីកម្ម គឺការប្រាប់សិក្ខាបទ គឺ បញ្ញត្តិដែលទាក់ទងនឹងមារយាទ ការប្រាប់កម្មដ្ឋាន ការសម្តែងធម៌ ការប្រាប់

ពុទ្ធវចនៈ គឺព្រះត្រៃបិដក ដោយមេត្តាចិត្តរបស់ភិក្ខុទាំងឡាយ ។ មួយវិញទៀត កម្មក្នុងកាលជាទីពោលជាដើមថា អញនឹងទៅថ្វាយបង្គំព្រះចេតិយ ១ ថ្វាយបង្គំពោធិព្រឹក្ស ១ និងឲ្យធ្វើការស្តាប់ធម៌ ១ និងបូជាដោយប្រទីប កម្រងផ្កា ១ និងប្រព្រឹត្តសមាទានសុចរិតបី ១ ប្រគេនសលាកភត្តជាដើម ១ ប្រគេនសំពត់ចំណាំវស្សា ១ ប្រគេនបច្ច័យ ៤ ដល់សង្ឃក្នុងថ្ងៃនេះ ១ ពួកអ្នកចូរនិមន្តព្រះសង្ឃ ហើយចាត់ចែងខាទនីយ និងភោជនីយាហារជាដើម ១ ចូរក្រាលអាសនៈ ១ ចូរតាំងទឹកផឹក ១ ចូរក្រោកទទួល ហើយនាំសង្ឃមកដោយខ្លួនឯង ១ ចូរនិមន្តព្រះសង្ឃ ឲ្យគង់លើអាសនៈដែលក្រាលហើយ កើតនូវការពេញចិត្ត ប្រកបដោយឧស្សាហ៍ ហើយចូរធ្វើនូវការខ្នះខ្នែងដូច្នេះ របស់ពួកគ្រហស្ថ ឈ្មោះថា **មេត្តាវចីកម្ម** ។ ការក្រោកឡើងអំពីព្រលឹម ហើយបដិបត្តិរាងកាយ ធ្វើចេតិយវត្ត និងគណៈជាដើម អង្គុយលើអាសនៈដ៏ស្ងាត់ គិតក្នុងចិត្តថា សូមពួកភិក្ខុក្នុងវិហារនេះ មានសេចក្តីសុខ មិនមានពៀរ មិនមានព្យាបាទនឹងគ្នាចុះ ឈ្មោះថា **មេត្តាមនោកម្ម**។

បទថា **អាវិ ចេវ រហោ ច** សេចក្តីថា ចំពោះមុខផង កំបាំងមុខផង ។ បណ្តាកម្មនោះ ការដល់នូវភាពជាសម្លាញ់ ក្នុងវចីកម្មជាដើមរបស់នវកភិក្ខុទាំងឡាយ ឈ្មោះថា **មេត្តាកាយកម្មចំពោះមុខ**។

មួយវិញទៀត សាមីចិកម្មទាំងឡាយ មានការលាងជើង បក់ផ្លិតឲ្យជាដើម របស់ព្រះថេរៈ ឈ្មោះថា **កាយកម្មចំពោះមុខ** ។ ការមិនធ្វើនូវការប្រហែសធ្វេសក្នុងគ្រឿងឈើជាដើម ដែលទាំង ២ ចំណែកទុកដាក់មិនល្អ ហើយរក្សា

ឲ្យដូចជារបស់ខ្លួន ដែលទុកដាក់មិនល្អ ឈ្មោះថា មេត្តាកាយកម្មកំបាំងមុខ ។ ការពោលសរសើរយ៉ាងនេះថា ព្រះទេវត្ថេរ ព្រះតិស្សត្ថេរ ... ឈ្មោះថា **មេត្តាវចីកម្មចំពោះមុខ** ។ ដែលបុគ្គលសួរចំពោះភិក្ខុដែលមិននៅក្នុងវិហារ ពោលអាងថា ជារបស់ខ្លួនយ៉ាងនេះថា ព្រះទេវត្ថេររបស់ពួកយើងទៅណា មកវិញក្នុងកាលណាហ្ន៎ ព្រះតិស្សត្ថេររបស់ពួកយើងទៅណា មកវិញក្នុងវេលាណាហ្ន៎ ដូច្នេះ ឈ្មោះថា **មេត្តាវចីកម្មកំបាំងមុខ**។

ម្យ៉ាងទៀត ការធ្មេចភ្នែកជិតដោយសេចក្តីស្រឡាញ់ ប្រកបដោយមេត្តា ហើយមើលដោយទឹកមុខផូរផង់ល្អ ឈ្មោះថា **មេត្តាមនោកម្មចំពោះមុខ** ។ ការប្រមូលមកថា សូមព្រះទេវត្ថេរ ព្រះតិស្សត្ថេរ មិនមានរោគ មានអាពាធតិច ឈ្មោះថា **មេត្តាមនោកម្មកំបាំងមុខ** ។ បទថា **លាភា** បានដល់បច្ច័យដែលបាន មានចីវរជាដើម ។ បទថា **ធម្មិកា** សេចក្តីថា បច្ច័យដែលកើតឡើងដោយវត្ត គឺការវៀរចាកមិច្ឆាជីព មានការកុហកជាដើម រួចត្រាច់ទៅដើម្បីអាហារ ដោយធម៌ ដោយស្មើ ។

បទថា **អន្តមសោ បត្តបរិយាបន្នមត្តម្បិ** សេចក្តីថា ដោយហោចសូម្បីអាហារ ២-៣ វែក ដែលដាក់ចូលក្នុងបាត្រ គឺនៅខាងក្នុងបាត្រ ។

ក្នុងបទថា **អប្បដិវិភត្តភោគី** ឈ្មោះថា ជាអ្នកមានអាហារចែកចាយហើយ មាន ២ គឺ ចែកចាយអាមិស ១ ចែកចាយបុគ្គល ១ ។

ក្នុងការបែងចែកទាំង ២ នោះ ការចែករំលែកដោយចិត្តយ៉ាងនេះថា អញនឹងឲ្យប៉ុណ្ណេះ នឹងមិនឲ្យប៉ុណ្ណេះ ឈ្មោះថា **ចែករំលែកដោយអាមិស**។

ការចែករំលែកដោយចិត្តយ៉ាងនេះថា អញនឹងឲ្យដល់បុគ្គលនោះ មិនឲ្យដល់បុគ្គលនោះ ឈ្មោះថា **ចែករំលែកបុគ្គល** ។

ការដែលបុគ្គលមិនធ្វើទាំង ២ យ៉ាងនោះ ហើយបរិភោគអាហារដែលមិនបានចែករំលែកនេះ ឈ្មោះថា **ជាអ្នកមានប្រក្រតីបរិភោគអាហារដែលមិនទាន់បានចែករំលែក** ។

ក្នុងបទថា **សីលវន្តេហិ សព្រហ្មចារីហិ សាធារណភោគី** អធិប្បាយថា ភិក្ខុមានប្រក្រតីបរិភោគជាសាធារណៈ មានលក្ខណៈដូច្នេះ គឺលោកបានវត្ថុណាមួយប្រណីត ក៏មិនឲ្យវត្ថុនោះៗ ដោយលាភ លោកនឹងឲ្យលាភដល់គ្រហស្ថទាំងឡាយ ក៏ដោយបំណងស្វែងរក ទាំងខ្លួនក៏មិនបរិភោគ កាលទទួលក៏ទទួលយក ដោយគិតថា ចូរជារបស់ទូទៅដល់សង្ឃ វាយជួងហើយសម្លឹងមើលដូចរបស់សង្ឃដែលគួរបរិភោគ ។

សួរថា បុគ្គលណាបំពេញនូវសារាណីយធម៌ បុគ្គលណាមិនបំពេញ ឆ្លើយថា ជាបឋម បុគ្គលទ្រុស្តសីលមិនបំពេញ ព្រោះថា បុគ្គលមានសីលទាំងឡាយ រមែងមិនកាន់យកវត្ថុដែលជារបស់បុគ្គលនោះ ។ ឯបុគ្គលមានសីលបរិសុទ្ធ មិនធ្វើវត្តឲ្យដាច់ ឲ្យពេញ ។ ក្នុងសេចក្តីនោះ មានទំនៀមនេះជាឧទាហរណ៍ ។

បុគ្គលដែលធ្វើចំពោះហើយ ឲ្យដល់មាតាបិតា អាចារ្យ និងឧបជ្ឈាយ៍ជាដើមនោះ ឲ្យវត្ថុដែលគួរឲ្យ ។ បុគ្គលនោះរមែងមិនមានសារាណីយធម៌ដល់គ្នានិងគ្នា ។ មានតែការរក្សានូវកង្វល់ ព្រោះថា បុគ្គលផុតចាកបលិពោធ

ប៉ុណ្ណោះ ទើបសមគួរនឹងសារាណីយធម៌ ។ បុគ្គលនោះ កាលឲ្យចោះចំពោះ គួរឲ្យដល់ភិក្ខុដែលមានជំងឺ ភិក្ខុអ្នកថែភិក្ខុឈឺ អាគន្តុកភិក្ខុ គមិកភិក្ខុ នវកភិក្ខុ ដែលមិនដឹងវត្ត សម្រាប់ទទួលសង្ឃាដី និងបាត្រ កាលឲ្យដល់ភិក្ខុទាំងនោះ តាំងអំពីថេរាសនៈចុះមក មិនគួរប្រគេនឲ្យសល់តិចតួច ប្រគេនប៉ុនដែលលោកកាន់យកនោះ កាលមិនសល់មិនមាន ក៏គួរត្រាច់ទៅបិណ្ឌបាតហើយ ប្រគេនរបស់ដែលប្រណីតៗ នោះ តាំងពីអាសនៈព្រះថេរៈចុះមក ហើយឆាន់របស់ដែលសល់ ។

ព្រោះពោលយ៉ាងនេះថា អ្នកមានសីល ដូច្នេះ ដល់នូវការមិនឲ្យដល់អ្នកមិនមានសីលក៏គួរ ។ ព្រោះថា ធម៌ជាទីតាំងនៃការរឭកដល់គ្នានេះ ឈ្មោះថា បរិស័ទដែលមិនបានសិក្សា មិនបំពេញហើយ ព្រោះថា កាលបរិស័ទបានសិក្សាហើយ បុគ្គលដែលបានអំពីបុគ្គលដទៃនោះ រមែងមិនកាន់យក កាលមិនបានអំពីអ្នកដទៃ ក៏កាន់យកល្មមប្រមាណប៉ុណ្ណោះ មិនកាន់យកហួសប្រមាណ ។ ឯសារាណីយធម៌នេះ ភិក្ខុកាលឲ្យវត្តដែលខ្លួនត្រាច់ទៅបិណ្ឌបាតដដែលហើយដដែលទៀត ប្រព្រឹត្តឲ្យពេញ ១២ ឆ្នាំ មិនតិចជាងនោះ ។ បើភិក្ខុបំពេញសារាណីយធម៌ដល់គ្នានិងគ្នា ដាក់បាត្រដែលពេញដោយចង្ហាន់ត្រង់រោងកត្ត ហើយទៅងូតទឹក ។ ព្រះសង្ឃត្ថេរសួរថា នេះបាត្រអ្នកណា កាលភិក្ខុទាំងឡាយពោលថា របស់ភិក្ខុអ្នកបំពេញសារាណីយធម៌ ទើបពោលថា ពួកលោកចូរនាំបាត្រនោះមក ហើយចាត់ចែងបិណ្ឌបាតគ្រប់យ៉ាង ឆាន់ហើយ ទុកដាក់បាត្រទទេ ។

ភិក្ខុនោះ កើតទោមនស្សថា ភិក្ខុទាំងឡាយឆាន់ភត្តរបស់អញហើយ ទុកបន្សល់តែបាត្រទទេ ។ សារាណីយធម៌រមែងបែកធ្លាយដល់លោក ដែលត្រូវបំពេញ ១២ ឆ្នាំទៀត សារាណីយធម៌នេះ ដូចគ្នានឹងតិត្ថិយបរិវាស កាលដាច់ម្តងហើយ ក៏គប្បីប្រព្រឹត្តសាដើមទៀត ។ ភិក្ខុណាកើតសោមនស្សថា ការដែលភិក្ខុអ្នកប្រព្រឹត្តព្រហ្មចរិយៈរួមជាមួយអញ មិនសាកសួរដោយអើពើដល់អាហារដែលនៅក្នុងបាត្រ ហើយឆាន់ ទុំះជាលាភរបស់អញ អញបានល្អហើយហ្ន៎ ។ ភិក្ខុនោះឈ្មោះថា មានសារាណីយធម៌ពេញហើយ ។ ឯការប្រណែន និងការកំណាញ់ មិនមានដល់ភិក្ខុដែលបំពេញសារាណីយធម៌យ៉ាងនេះពិតប្រាកដ ។ លោកជាទីស្រឡាញ់របស់ពួកមនុស្ស សូម្បីបច្ច័យ ក៏រកបានងាយ សូម្បីវត្ថុដែលនៅក្នុងបាត្រ ដែលទាយកប្រគេនដល់លោក ក៏មិនអស់ទៅ ។ រមែងបានវត្ថុដ៏លើសក្នុងចំណែកវត្ថុដែលគប្បីចែករំលែក កាលដល់ នូវការភ័យខ្លាច ឬការស្រេកឃ្លាន ពួកទេវតារមែងខ្នះខ្នែង ។

ក្នុងសេចក្តីនោះ មានរឿងនេះជាឧទាហរណ៍ ។

## រឿង ព្រះសេលាគិរីវងវាសីតិស្សត្ថេរ

បានឮមកថា ព្រះតិស្សត្ថេរ ជាអ្នកនៅក្នុងសេលាគិរីវិហារ អាស្រ័យស្រុកមហាគិរី នៅអាស្រ័យ កាលព្រះមហាថេរៈ ៥០ រូប កំពុងទៅកាន់កោះនាគ ដើម្បីថ្វាយបង្គំព្រះចេតិយ ត្រាច់បិណ្ឌបាតក្នុងស្រុកគិរី មិនបានអ្វីសោះ ចេញទៅហើយ ។ កាលព្រះថេរៈចូលទៅឃើញព្រះមហាថេរៈទាំងនោះ សួរថា លោកម្ចាស់បានអ្វីតិចតួចឬ ព្រះថេរៈទាំងនោះប្រាប់ថា លោក

ម្ចាស់ ពួកខ្ញុំបានត្រាច់ទៅហើយ ។ ព្រះថេរៈនោះដឹងថា ព្រះមហាថេរៈទាំងនោះមិនបានអ្វី ទើបពោលថា សូមលោកម្ចាស់ទាំងឡាយ បង្អង់នៅក្នុងទីនេះសិន ទម្រាំខ្ញុំមកវិញ ។ ព្រះមហាថេរៈទាំងនោះពោលថា លោកម្ចាស់ ពួកខ្ញុំ ៥០ អង្គមិនបានសូម្បីតែសើមបាត្រ ។ ព្រះតិស្សៈពោលថា លោកម្ចាស់ធម្មតាអ្នកនៅប្រចាំជាអ្នកអាច ទោះបីមិនបាន ក៏គង់ដឹងសភាវៈប្រមាណក្នុងភិក្ខាចារ ។ ពួកព្រះថេរៈមកហើយ ។ ទើបព្រះថេរៈចូលទៅកាន់ស្រុក ។ មហាឧបាសិកា ក្នុងផ្ទះឃើញអំពីចម្ងាយ បានចាត់ចែងទឹកដោះ និងបាយរង់ចាំមើលព្រះថេរៈ កាលព្រះថេរៈដល់មាត់ទ្វារប៉ុណ្ណោះ ក៏បានធ្វើបាត្រឲ្យពេញប្រគេនហើយ ។ ព្រះថេរៈកាន់បាត្រនោះ ទៅកាន់សម្នាក់ព្រះថេរៈទាំងឡាយ ពោលនឹងព្រះសង្ឃត្ថេរថា សូមលោកម្ចាស់ទទួលចុះ ។ ព្រះថេរៈសម្លឹងមើលមុខព្រះថេរៈដ៏សេសបណ្តើរ គិតថា ពួកយើងមានប្រមាណប៉ុណ្ណោះ មិនបានអ្វីសោះ ភិក្ខុនេះកាន់យកមកហើយរហ័សនោះឯង តើនេះដូចម្តេចហ្ន៎ ។

ព្រះថេរៈជ្រាបដោយការសម្លឹងមើល ទើបពោលថា បិណ្ឌបាតខ្ញុំបានមកដោយធម៌ សូមលោកម្ចាស់អស់នូវសេចក្តីរង្កៀស ទទួលយកចុះ ហើយបានឲ្យដល់ព្រះថេរៈទាំងអស់អង្គ តាមដែលត្រូវការ តាំងអំពីដើមរហូតដល់ចុង សូម្បីខ្លួនលោកក៏ឆាន់តាមត្រូវការ កាលឆាន់ស្រេច ទើបព្រះថេរៈសួរលោកថា លោកម្ចាស់សម្រេចលោកុត្តរធម៌តាំងអំពីកាលណា ព្រះតិស្សត្ថេរប្រាប់ថា ខ្ញុំមិនទាន់មានលោកុត្តរធម៌ទេ ព្រះថេរៈទាំងឡាយពោលថា លោក

ម្ចាស់បានឈានឬ ព្រះថេរៈពោលថា ឈានក៏មិនបានដែរលោកម្ចាស់ ព្រះថេរៈទាំងឡាយពោលថា ចុះលោកម្ចាស់បានបាដិហារ្យមិនមែនឬ ព្រះថេរៈពោលថា ខ្ញុំបំពេញសារាណីយធម៌តាំងអំពីខ្ញុំបំពេញសារាណីយធម៌មក ទោះជាមានភិក្ខុមួយពាន់រូប ក៏អាហារក្នុងបាត្រមិនអស់ដែរ ។ ព្រះថេរៈទាំងឡាយ ពោលថា សាធុ សាធុ សប្បុរស កម្មនេះសមគួរដល់លោកហើយ ។ ក្នុងពាក្យថា អាហារក្នុងបាត្ររបស់លោកមិនអស់នេះ មានរឿងដូច្នេះ

ព្រះថេរៈអង្គនេះឯង បានទៅកាន់ទីថ្វាយទានក្នុងទីបូជាធំនៃគិរីកណ្ឌវិហារត្រង់ចេតិយបព៌ត សួរថា ទាននេះមានអ្វីជារបស់ល្អ ។ សំពត់ ២ ផ្ទាំងលោកម្ចាស់ ។ សំពត់ ២ ផ្ទាំងនោះនឹងដល់អាត្មា ។ អមាត្យស្ដាប់ពាក្យនោះទើបក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ ភិក្ខុកំលោះពោលយ៉ាងនេះ ។

ព្រះរាជាគិតថា ការគិតរបស់ភិក្ខុកំលោះសមគួរនោះឯង តែព្រះថេរៈទាំងឡាយក៏សមគួរដល់សំពត់សាច់ល្អនេះ ហើយទ្រង់ព្រះតម្រិះថា អញនឹងប្រគេនព្រះមហាថេរៈទាំងឡាយ ។ កាលភិក្ខុឈរតាមលំដាប់ សំពត់ ២ ផ្ទាំងក៏អណ្ដែតទៅលើព្រះសិរសៈរបស់ព្រះរាជាដែលកំពុងប្រគេន មិនចុះមកកាន់ព្រះហស្តរបស់ព្រះរាជាឡើយ សំពត់ដទៃៗប៉ុណ្ណោះដែលចុះមក តែដល់វេលាប្រគេនភិក្ខុកំលោះ សំពត់ទាំង ២ ផ្ទាំង ក៏ចុះមកកាន់ព្រះហស្ត ។ ព្រះរាជាទ្រង់ដាក់លើដៃភិក្ខុកំលោះនោះ មើលមុខអមាត្យ ទ្រង់ឲ្យភិក្ខុកំលោះនោះគង់ ហើយថ្វាយទាន ទ្រង់លះព្រះសង្ឃ មកប្រថាប់ជិតភិក្ខុកំលោះត្រាស់ថា បពិត្រលោកម្ចាស់ ធម៌នេះ លោកម្ចាស់ចាក់ធ្លុះអំពីអង្កាល់ កាលមិនពោល

បែបអមៗ ទើបថ្វាយព្រះពរថា បពិត្រមហារាជ អាត្មាមិនមានលោកុត្តរធម៌ទេ ព្រះរាជាពោលថា លោកម្ចាស់បានពោលមុនមិនមែនឬ ព្រះថេរៈពោលថា ថ្វាយព្រះពរមហាបពិត្រ អាត្មាភាពបំពេញសារាណីយធម៌ តាំងអំពីពេលដែលអាត្មាភាពបំពេញធម៌នោះមក ក៏បានវត្ថុដែលល្អជាងគេ ក្នុងទីដែលគប្បីចែក ព្រះរាជាពោលថា សាធុ សាធុ លោកម្ចាស់ សារាណីយធម៌នេះគួរដល់លោកម្ចាស់ហើយ ទ្រង់ថ្វាយបង្គំហើយចៀសចេញទៅ ។ ក្នុងពាក្យថា បាននូវរបស់ល្អលើសក្នុងទីដែលគប្បីចែកនេះ មានរឿងនេះជាឧទាហរណ៍ថា

ភិក្ខុទាំងឡាយ មានប្រក្រតីនៅក្នុងស្រុកកាតរៈ ក្នុងចណ្ឌាលតិស្សរកយ-វិហារ មិនប្រាប់ព្រះថេរីឈ្មោះនាគា ចៀសចេញទៅហើយ ។ ព្រះថេរីពោលនឹងពួកភិក្ខុនីក្រមុំ ក្នុងវេលាព្រហាមថា ភូមិនេះស្ងាត់ពន់ពេក ពួកនាងម្ចាស់ចូរពិនិត្យមើលសិនចុះ ។ ភិក្ខុនីក្រមុំទាំងនោះទៅ ដឹងថា ភិក្ខុទាំងឡាយទៅអស់ហើយ ទើបត្រឡប់មកប្រាប់ព្រះថេរី ។ ព្រះថេរីនោះបានស្តាប់ហើយពោលថា ពួកនាងកុំគិតថា ភិក្ខុទាំងនោះទៅឡើយ ចូរធ្វើសេចក្តីព្យាយាមក្នុងការរៀនបាលី សាកសួរ និងការដាក់ចិត្តដោយឧបាយចុះ កាលដល់វេលាត្រាច់បិណ្ឌបាត ទើបដណ្តប់សំពត់ បានគ្នា ១២ រូប ឈរត្រង់គល់ជ្រៃក្បែរមាត់ព្រៃ ។ ទេវតាដែលស្ថិតនៅត្រង់ដើមឈើ ក៏បានប្រគេនបិណ្ឌបាតដល់ភិក្ខុនី ១២ រូប ដោយពោលថា បពិត្រអ្នកនាងម្ចាស់ សូមកុំទៅទីដទៃឡើយ សូមមកទីនេះជាប្រចាំចុះ ។ ព្រះថេរីមានប្អូនប្រុសពៅ ឈ្មោះនាគត្ថេរ ។ ព្រះនាគត្ថេរគិតថា អញមិនអាចឲ្យភ័យធំដែលប្រព្រឹត្តទៅក្នុងទី

នេះ ពួកអញទឹងទៅកាន់ត្រើយដទៃ មានគ្នា ១២ នាក់នោះឯង ចេញអំពីលំនៅរបស់ខ្លួន មកកាន់កាតរគ្រាម ដោយគិតថា អញទឹងសួរសុខទុក្ខព្រះថេរី ហើយសឹមទៅ ។

ព្រះថេរីបានឮថា ពួកព្រះថេរះមក ទើបទៅកាន់សម្នាក់ព្រះថេរះទាំងនោះ សួរថា លោកម្ចាស់និមន្តមកធ្វើអ្វី ទើបលោកប្រាប់ការប្រព្រឹត្តទៅនោះ ព្រះថេរីនោះពោលថា ថ្ងៃនេះ សូមលោកម្ចាស់ស្នាក់ក្នុងវិហារសិនចុះ ស្អែកសឹមទៅចុះ ។ ពួកព្រះថេរះក៏មកកាន់វិហារ ។ ស្អែកឡើងព្រះថេរីបិណ្ឌបាតត្រង់គល់ឈើ ហើយចូលទៅរកព្រះថេរះ ពោលថា សូមលោកម្ចាស់ទាំងឡាយឆាន់បិណ្ឌបាតនេះចុះ ។ ព្រះថេរះពោលថា នែព្រះថេរី ការណ៍នេះសមគួរឬ ទើបបានឈរស្ងៀម ។ ព្រះថេរីពោលថា លោកម្ចាស់ បិណ្ឌបាតនេះបានមកដោយធម៌ សូមលោកម្ចាស់ទាំងឡាយកុំរង្កៀស ឆាន់ចុះ ។ ព្រះថេរះពោលថា នែព្រះថេរី ការណ៍នេះសមគួរឬ ។ ព្រះថេរីចាប់បាត្រ ហើយបោះទៅលើអាកាស បាត្របានអណ្តែតទៅក្នុងអាកាស ព្រះថេរះពោលថា អាហាររបស់ភិក្ខុនីអណ្តែតទៅប្រមាណ ៧ ជួរដើមត្នោត កាលពោលថា កាលឈ្មោះថា ភ័យ មិនមានគ្រប់វេលា ភ័យស្ងប់ហើយ កាលពោលអរិយវង្សក៏នឹងពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ឆាន់អាហាររបស់ភិក្ខុនីដែលបានអំពីបិណ្ឌបាត ហើយបណ្តោយឲ្យវេលាកន្លងទៅ ដូច្នេះ កាលប្រព្រឹត្តទៅតាមការគិត ក៏មិនអាចឧបការៈបាន នែព្រះថេរី ពួកនាង ចូរទៅមិនប្រមាទចុះ ។ ហើយចុះកាន់ផ្លូវ ឯរុក្ខទេវតាឈរគិតថា បើព្រះថេរះបរិភោគ

បិណ្ឌបាតអំពីដៃព្រះថេរី អញក៏នឹងឲ្យលោកត្រឡប់ ។ ទេវតានោះ ឃើញព្រះថេរៈដើរទៅ ក៏ចុះអំពីដើមឈើ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យបាត្រ ឲ្យហើយ ទទួលបាត្រ នាំព្រះថេរៈមកត្រង់គល់ឈើនោះឯង ក្រាលអាសនៈ ប្រគេនបិណ្ឌបាត ឲ្យព្រះថេរៈឆាន់ហើយ ធ្វើប្ដេជ្ញារូបទំនុកបម្រុងភិក្ខុនី ១២ រូប ភិក្ខុ ១២ រូប អស់កាល ៧ ឆ្នាំ ។ ក្នុងពាក្យថា ទេវតាខ្វល់ខ្វាយ មានរឿងនេះជាឧទាហរណ៍ ។ ឯក្នុងរឿងនេះ ព្រះថេរីបានជាអ្នកបំពេញសារាណីយធម៌ ។

ក្នុងបទថា **អក្ខណ្ឌានិ** ជាដើម អធិប្បាយថា ភិក្ខុណាមានសិក្ខាបទទម្លាយខាងដើម និងទីបំផុត ក្នុងកងអាបត្តិទាំង ៧ ភិក្ខុនោះ ឈ្មោះថាមានសីលដាច់ ដូចសំពត់ដាច់ជុំវិញជាយ ដូច្នោះ ។ មួយវិញទៀត ភិក្ខុណាមានសិក្ខាបទបែកធ្លាយត្រង់កណ្ដាល ភិក្ខុនោះ ឈ្មោះថា មានសីលធ្លុះ ដូចសំពត់ធ្លុះត្រង់កណ្ដាល ។ ភិក្ខុណាទម្លាយសិក្ខាបទ ២-៣ ជាប់គ្នាតាមលំដាប់ ភិក្ខុនោះ ឈ្មោះថា មានសីលពពាល ដូចមេគោដែលមានពណ៌ខ្មៅឬក្រហមជាដើមណាមួយ ដោយពណ៌ដែលឆ្លាសគ្នាតាំងលើខ្នង ឬពោះ ។ ភិក្ខុណាមានសិក្ខាបទបែកធ្លាយចន្លោះៗ ភិក្ខុនោះ ឈ្មោះថា សីលពព្រុសដូចមេគោដែលមានស្នាមចុចៗ ពេញរាងកាយ ។ ឯភិក្ខុណាមានសិក្ខាបទមិនបែកធ្លាយទាំងអស់ ភិក្ខុនោះ ឈ្មោះថា មានសីលមិនដាច់ មិនធ្លុះ មិនពព្រុស មិនពពាល ។ សិក្ខាបទទាំងនេះ ឈ្មោះថា ជាអ្នកជា ព្រោះផុតចាកភាពជាទាសៈនៃតណ្ហា ហើយធ្វើឲ្យជាឥស្សរៈ ឈ្មោះថា វិញ្ញូជនសរសើរ

ព្រោះវិញ្ញូជនទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរហើយ ឈ្មោះថា ធម្ម-ជាតអ្វីមួយស្ទាបអង្អែលមិនបាន ព្រោះតណ្ហាជាដើម ស្ទាបអង្អែលមិនបាន និងព្រោះកិលេសណាមួយ មិនអាចស្ទាបអង្អែលថា លោកធ្លាប់ត្រូវអាបត្តិក្នុងសិក្ខាបទឈ្មោះនេះ រមែងប្រព្រឹត្តទៅដើម្បីសមាធិយ៉ាងមាំទាំ ឬអប្បនា-សមាធិ ដូច្នោះ ទើបលោកហៅថា ប្រព្រឹត្តទៅដើម្បីការតាំងមាំ ។

បទថា **សីលសាមញ្ញគតោ** សេចក្តីថា ជាអ្នកមានសីលចូលដល់ភាពស្មើគ្នាជាមួយភិក្ខុទាំងឡាយ ដែលនៅក្នុងចំណែកនៃទិសទាំងនោះ ព្រោះថា សីលរបស់ព្រះសោតាបន្នជាដើម ស្មើគ្នាដោយសីលរបស់ព្រះសោតាបន្នជាដើមពួកដទៃ ។ លំនៅចន្លោះសមុទ្រក្តី ទេវលោកក្តី មិនមានការផ្សេងគ្នាដោយមគ្គ និងសីល ព្រះមានព្រះភាគទ្រង់សំដៅយកសីលនោះ ទើបត្រាស់ពាក្យនេះ ។

បទថា **យាយំ ទិដ្ឋិ** សេចក្តីថា សម្មាទិដ្ឋិដែលប្រកបព្រមដោយមគ្គ ។ បទថា **អរិយា** បានដល់ មិនមានទោស ។ បទថា **និយ្យា** គឺនាំចេញទៅ ។ បទថា **តក្ករស្ស** បានដល់ បុគ្គលណា ជាអ្នកធ្វើយ៉ាងនោះ ។ បទថា **ទុក្ខក្ខយាយ** បានដល់ ដើម្បីការអស់ទុក្ខទាំងពួង ។ បទថា **ទិដ្ឋិសាមញ្ញ-គតោ** សេចក្តីថា ជាអ្នកចូលដល់ភាពជាអ្នកមានទិដ្ឋិស្មើគ្នា ។ បទថា **អគ្គន្តំ** បានដល់ ចម្រើនបំផុត ។ បទថា **សង្ឃាដនិកំ** បានដល់ ទាញល្អ អធិប្បាយថា ធ្វើបង្អង់ឲ្យទល់គ្នា ហេតុនោះ ឈ្មោះថា ឲ្យតៗ គ្នា ។

បទថា **យទិទំ កូដំ** សេចក្តីថា ទីតផ្ទះកំពូលជាប់នឹងជហ្វា ហេតុនោះ

ឈ្មោះថា កំពូល ។ ប្រាសាទ ៥ ជាន់ជាដើមត្រង់កំពូលនោះ ដោតនោះឯង ទើបតាំងនៅបាន កាលកំពូលនោះបែកទៅ ប្រាសាទទាំងអស់ ចាប់តាំងអំពីដីស្អិតក៏ធ្លាក់ទៅ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។

បទថា **ឯវមេវ ខោ** សេចក្តីថា ការឃើញដ៏ប្រសើរ និងដ៏លើសនៃសារាណីយធម៌ទាំងនេះ គប្បីឃើញថា ជាតួបង្រួបបង្រួម និងជាតួក្ជាប់ ដូចកំពូលនៃផ្ទះកំពូល ដូច្នោះ ។

[ ១៨៣ ] ក្នុងបទថា **កថញ្ច ភិក្ខវេ យាយំ ទិដ្ឋិ** អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ទិដ្ឋិក្នុងសោតាបត្តិមគ្គ លោកពោលថា ឆ្ងាយអំពីសត្រូវ គឺសភាពនាំចេញ រមែងនាំចេញទៅ ដើម្បីការអស់នូវទុក្ខដោយប្រពៃរបស់អ្នកបដិបត្តិ ។ ទិដ្ឋិនោះនាំចេញដូចម្តេច នាំចេញព្រោះហេតុអ្វី ។

បទថា **បរិយុដ្ឋិតចិត្តោវ ហោតិ** សេចក្តីថា ឈ្មោះថា ជាអ្នកមានចិត្តត្រូវចោមរោមហើយ ដោយហេតុមានប្រមាណប៉ុណ្ណោះ ។ ក្នុងបទទាំងពួងក៏ន័យនេះ ។ បទថា **សុបណិហិតំ មេ មានសំ** សេចក្តីថា ចិត្តរបស់អញតាំងទុកល្អហើយ ។ បទថា **សច្ចានំ ពោធាយ** បានដល់ ដើម្បីប្រយោជន៍ក្នុងការត្រាស់ដឹងសច្ចៈ ៤ ។

ក្នុងបទជាដើមថា **អរិយំ** មានអធិប្បាយថា ព្រោះញាណនោះ រមែងមានដល់ព្រះអរិយបុគ្គល មិនមានដល់បុថុជ្ជនឡើយ ដូច្នោះ ទើបលោកហៅថា **អរិយៈ** ។ ឯលោកុត្តរធម៌នៃបុគ្គលពួកណាមាន ក៏ជារបស់បុគ្គលពួកនោះប៉ុណ្ណោះ មិនមានដល់ពួកដទៃឡើយ ដូច្នោះ ទើបលោកពោលថា **លោកុត្តរំ**

មានពាក្យអធិប្បាយថា ឈ្មោះថា មិនទូទៅដល់បុថុជ្ជនទាំងឡាយ ព្រោះមិនមានដល់បុថុជ្ជន ។ ក្នុងវារៈទាំងពួងក៏ន័យនេះ ។

[ ១៨៤ ] បទថា **លភាមិ បច្ចត្តំ សមថំ** សេចក្តីថា អញបាននូវការស្ងប់ក្នុងចិត្តនៃខ្លួន ។ សូម្បីក្នុងការរលត់ក៏ន័យនេះ ។ ក្នុងបទថា **សមថោ** រមែងបានទាំងការស្ងប់ ទាំងឯកគ្គតារម្មណ៍ ។ បទថា **និព្វុតិ** បានដល់ចូលទៅស្ងប់កិលេស ។

[ ១៨៥ ] បទថា **យថារូបាយ ទិដ្ឋិយា** បានដល់ សោតាបត្តិមគ្គទិដ្ឋិបែបនោះ ។

[ ១៨៦ ] បទថា **ធម្មតាយ** គឺដោយសភាវៈ ។ សភាវៈនេះ ឈ្មោះថា ធម្មតា នេះ ។ បទថា **វុដ្ឋានំ បញ្ញាយតិ** សេចក្តីថា ការតាំងឡើងដោយអំណាចសង្ឃកម្មក្តី ទេសនាក្តី រមែងប្រាកដ ។ ពិតហើយ អរិយ-សាវកកាលត្រូវអាបត្តិ ក៏ត្រូវអាបត្តិអចិត្តក ដូចជាការសាងកុដិ ក្នុងគរុកាបត្តិ និងដូចត្រូវអាបត្តិក្នុងការដេករួមក្នុងទីប្រក់ទីបាំងតែមួយជាដើម ក្នុងលហុកាបត្តិ ពិតហើយ ព្រះអរិយសាវកនោះ មិនក្លែង គឺមិនមានចិត្តត្រូវអាបត្តិនោះ ត្រូវហើយក៏មិនបិទបាំង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **អថខោ នំ ខិប្បមេវ** ជាដើម ។

បទថា **ទហរោ** បានដល់ នៅទន់ខ្ចី គឺកំលោះ ។ បទថា **កុមារោ** បានដល់ មិនមែនមនុស្សចាស់ ។ បទថា **មន្ទោ** គឺឈ្មោះថា មន្ទៈ ព្រោះភ្លេក និងត្រចៀកមិនទាន់ដឹងសេចក្តី ។ បទថា **ឧត្តានសេយ្យកោ** សេចក្តី

ថា ឈ្មោះថា ជាអ្នកដេកផ្ងារ ព្រោះទន់ខ្ចីពន់ពេក មិនអាចដេកផ្អៀងស្តាំ ឬផ្អៀងឆ្វេងបាន ។ បទថា **អង្គានំ អក្កមិត្វា** សេចក្តីថា យកដៃ ឬជើង សណ្តូកទៅខាងនេះ ខាងនោះ ត្រូវហើយ កាលពួកមនុស្សពាល់ត្រូវភ្លើង ហើយយ៉ាងនេះ ដៃនឹងដកចេញយ៉ាងរហ័ស ធ្វើឲ្យឃើតមិនបាន មនុស្ស ទាំងឡាយ យកដៃខាងណាមួយចាប់រងើកភ្លើងត្រឡប់ទៅត្រឡប់មក រមែង ទៅបានឆ្ងាយ តែដៃ និងជើងរបស់ទារកនៅទន់ខ្ចីពេកណាស់ ។ ទារកនោះ គប្បីត្រូវភ្លើងរលាកប៉ុណ្ណោះ ក៏នឹងត្រូវស្រែកយំ បោះបោល ដោយរហ័ស ដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងកូនខ្ចីក្នុងទីនេះឯង ។ មនុស្សចាស់ កាលត្រូវភ្លើងឆេះ រមែងអត់ធន់បាន តែកូនខ្ចីនេះ អត់ធន់មិនបានឡើយ ។ ព្រោះដូច្នោះ ទើបទ្រង់សម្តែងកូនខ្ចីនោះឯង ។

បទថា **ទេសេតិ** សេចក្តីថា កាលសភាគបុគ្គល ជាអ្នកទទួលអាបត្តិ ក៏ មិនរង់ចាំថា ពេលថ្ងៃ ឬពេលយប់ ក្នុងលំនៅរបស់ភិក្ខុដែលសភាគគ្នានោះ សូម្បីក្នុងពេលយប់ប្រកបដោយអង្គ ៤ ក៏សម្តែង ។

[ ១៨៧ ] បទថា **ឧច្ចាវចានិ** បានដល់ ខ្ពស់ និងទាប ។ កិច្ចដែលគួរ ពោលយ៉ាងនេះថា អញធ្វើយ៉ាងណា ហើយធ្វើ ឈ្មោះថា **កឹករណីយា** នេះ ។ ក្នុងកិច្ចទាំងនោះ កិច្ចជាដើមយ៉ាងនេះ គឺការធ្វើ ឬជ្រលក់ចីវរ ១ ការងារត្រង់ចេតិយ ១ ការងារដែលគួរធ្វើត្រង់រោងឧបោសថ ១ ខឿនព្រះ ចេតិយ ១ ខឿនព្រះពោធិព្រឹក្ស ១ ឈ្មោះថា ការងារយ៉ាងឧត្តម ។ ការងារ តូចតាច មានការលាង និងលាបជើងជាដើម ឈ្មោះថា ការងារយ៉ាងទាប ។

ម្យ៉ាងទៀត ការងារ មានបូកបាយអជាដើមត្រង់ចេតិយ ឈ្មោះថា ការងារខ្ពង់ខ្ពស់ ។ ក្នុងការងារទាំងនោះ ការបោកសំពត់កាសាវៈ ១ ការដងទឹកមក ១ ការធ្វើស្ពាបព្រោះបូកបាយអ ១ ការពាក់ដណ្តើរ ១ ឈ្មោះថា ការងារយ៉ាងទាប ។

បទថា **ឧស្សុក្កមាបន្នោ ហោតិ** សេចក្តីថា ជាអ្នកបដិបត្តិ ការខ្វល់ខ្វាយដែលគួរធ្វើ ។ បទថា **តិព្វាបេក្ខោ ហោតិ** សេចក្តីថា ជាអ្នកមានការប្រាថ្នាយ៉ាងខ្លាំងក្លា ។ បទថា **ថម្ភញ្ច អាលុម្បតិ** បានដល់ ខិតខំស៊ីស្មៅ ។ បទថា **វច្ឆកញ្ច អបចិនាតិ** បានដល់ មើលថែកូនគោផង ។ ប្រៀបដូចមេគោកូនខ្ចីមិនបោះបង់កូនគោដែលរួមគ្នាមកព្រៃ ហើយដេកក្នុងទីមួយទៅឆ្ងាយ មេគោនោះនឹងត្រាច់ទៅក្នុងទីជិតៗ កូនគោ និងពន្លកស្មៅ ហើយក៏អើតកឡើង ផ្ទៀងផ្អងមើលកូនគោបណ្តើរផងនោះឯង ។ ព្រះសោតាបន្នក៏ដូច្នោះដូចគ្នា ធ្វើកិច្ចដែលគួរធ្វើទាំងខ្ពស់ និងទាប បង្អោនទៅក្នុងកិច្ចនោះ ជាអ្នកបំពេញមិនធូរថយ មានការពេញចិត្តយ៉ាងក្លៀវក្លា ជាអ្នកមានការប្រាថ្នាយ៉ាងមាំទាំ ហើយធ្វើ ។ ក្នុងសេចក្តីនោះ មានរឿងជាឧទាហរណ៍ថា

បានឮថា កាលកំពុងបូកលាបបាយអ ត្រង់មហាចេតិយ ព្រះអរិយសាវ័កមួយរូប មានដៃម្ខាងកាន់កាជនៈដាក់បាយអ ដៃម្ខាងកាន់ស្ពាបព្រាបាយអ គិតថា នឹងបូកបាយអ ហើយឡើងកាន់បល្ល័ង្កចេតិយ ភិក្ខុមួយរូបកាយមានទម្ងន់ច្រើន បានទៅឈរក្បែរព្រះថេរៈដែលជាព្រះអរិយបុគ្គលនោះ ព្រះថេរៈក្នុងទីដទៃជាអ្នកឃើញយូរពន់ពេក ព្រោះហេតុនោះ ទើបអំពីទីនោះ

ទៅទីដទៃ ។ សូម្បីភិក្ខុនោះក៏បានទៅទីនោះឯង ។ ព្រះថេរៈក៏បានទៅទីដទៃទៀត ដូច្នេះ ។ ព្រះថេរៈបានពោលនឹងភិក្ខុដែលមកក្នុងទី ២-៣ កន្លែងយ៉ាងនេះថា នៃសប្បុរស ទួលព្រះចេតិយធំ លោកម្ចាស់មិនបានឱកាសក្នុងទីដទៃឬ ។ ព្រះថេរៈក៏មិនព្រមចៀសចេញទៅ ។

[ ១៨៨ ] បទថា **ពលតាយ សមន្នាគតោ** បានដល់ ប្រកបដោយកម្លាំង ។ បទថា **អត្ថិ កត្វា** សេចក្ដីថា ធ្វើភាពជាអ្នកមានប្រយោជន៍ គឺជាអ្នកមានប្រយោជន៍ ។ បទថា **មនសិកត្វា** សេចក្ដីថា ធ្វើទុកក្នុងចិត្ត ។ បទថា **សព្វចេតសា សមន្នាហរិត្វា** គឺមិនធ្វើនូវការរាយមាយត្រឹមតែបន្តិចបន្តួច រួបរួមមកដោយចិត្តទាំងមូល ។

បទថា **ឱហិតសោតោ** សេចក្ដីថា មានសោតៈ គឺត្រចៀកតាំងទុកហើយ ។ ព្រះអរិយសាវកទាំងឡាយ ជាអ្នកស្រឡាញ់ក្នុងការស្ដាប់ធម៌ កាលនឹងទៅស្ដាប់ធម៌ ក៏មិនអង្គុយនិទ្រា សន្ទនាជាមួយនឹងបុគ្គលណាមួយ ឬមានចិត្តរាយមាយឡើយ ។ ពិតហើយ លោកជាអ្នកមិនឆ្អែតក្នុងការស្ដាប់ធម៌ ដូចបរិភោគទឹកអម្រឹត រហូតដល់អរុណរះក្នុងការស្ដាប់ធម៌ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។

[ ១៩០ ] បទថា **ធម្មតា សុសមន្និដ្ឋា ហោតិ** សេចក្ដីថា សភាវៈឈ្មោះថា លោកស្វែងរកល្អហើយ ។ បទថា **សោតាបត្តិផលសច្ឆិកិរិយាយ** នេះជាពាក្យពោលដល់ហេតុ អធិប្បាយថា ព្រោះញាណដែលធ្វើឲ្យជាក់ច្បាស់ហើយ ដោយសោតាបត្តិផល ។

បទថា **ឯវំ សត្តង្គសមន្នាគតោ** សេចក្តីថា ប្រកបដោយមហាបច្ចវេក្ខ-ណញ្ញាណទាំងនេះ យ៉ាងនេះ ។ អាចារ្យទាំងឡាយមានពាក្យសម្តីដែលស្មើគ្នានេះ ។ ឯលោកុត្តរមគ្គ ដែលឈ្មោះថា មានខណៈចិត្តច្រើន មិនមាន ។

ឯអាចារ្យដែលជាវិតណ្ឌវាទ រមែងពោលថា មគ្គដែលឈ្មោះថា មានខណៈចិត្តមួយមិនមាន ការចម្រើនមគ្គមានអស់កាល ៧ ឆ្នាំ ឯកិលេសទាំង-ឡាយ កាលនឹងដាច់សូន្យដោយរហ័ស រមែងដាច់សូន្យដោយញាណទាំង ៧ ព្រោះពាក្យថា គប្បីឲ្យចម្រើនអស់កាល ៧ ឆ្នាំ ។ អាចារ្យនោះ ត្រូវគេពោលថា សូមនាំព្រះសូត្រមកអាង ។ កាលមិនឃើញសូត្រដទៃ អាចារ្យនោះ ក៏នាំសូត្រនេះមកសម្តែងយ៉ាងពិតប្រាកដថា ញាណដែលអាត្មាអញសម្រេចនេះ ជាទីមួយនៃព្រះសូត្រនោះ ញាណដែលអញសម្រេចហើយនេះជាទីពីរនៃព្រះសូត្រនោះ ។បេ។ ញាណដែលអញសម្រេចហើយនេះជាទី ៧ នៃព្រះសូត្រនោះ ។ លំដាប់នោះ អាចារ្យនោះ ក៏នឹងត្រូវពោលថា ព្រះសូត្រនេះមានអត្ថដែលគប្បីនាំទៅ មានអត្ថដែលនាំទៅហើយឬ ។ បន្ទាប់អំពីនោះ ក៏នឹងពោលថា មានអត្ថដែលនាំទៅហើយ ។ ព្រះសូត្រយ៉ាងណា អត្ថក៏ដូច្នោះ ។

អាចារ្យនោះគប្បីត្រូវពោលថា ភាពជាធម៌ក៏នឹងតាំងមាំដោយល្អ ប្រ-យោជន៍មានប្រមាណប៉ុណ្ណោះ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ អាចារ្យនោះរមែងពោលថា ប្រយោជន៍នៃការធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិ-ផល មានពិតប្រាកដ ។ បន្ទាប់អំពីនោះ ក៏នឹងត្រូវសួរថា បុគ្គលដល់ព្រម

ដោយមគ្គ រមែងធ្វើផលឲ្យជាក់ច្បាស់ ហើយក្លាយជាបុគ្គលដល់ព្រមដោយផលឬ ។ កាលដឹងក៏ឆ្លើយថា បុគ្គលដល់ព្រមដោយមគ្គ រមែងធ្វើឲ្យជាក់ច្បាស់នូវផល ក្លាយជាដល់ព្រមនូវផល ។ បន្ទាប់អំពីនោះ ត្រូវញាំញីម្តងទៀតថា ព្រោះលោកមិនចម្រើនមគ្គ ក្នុងព្រះពុទ្ធតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ អរិយសាវកដែលប្រកបដោយអង្គ ៧ យ៉ាងនេះ ជាអ្នកប្រកបដោយសោតាបត្តិផល ។ ទើបលោកទៅពោលផ្ដេសផ្ដាសថា ខ្ញុំមិនទាន់បានព្រះសូត្រថា អរិយសាវកនឹងទាញយកផលឲ្យបាន ធម្មតាភិក្ខុដែលនឹងស្រាយបញ្ហា គួរនៅក្នុងសម្នាក់អាចារ្យ រៀនយកព្រះពុទ្ធវចនៈ ជ្រាបអត្ថរស ហើយពោលពាក្យសម្ដី ។

ញាណទាំង ៧ នេះ ចាត់ជាបច្ចវេក្ខណញ្ញាណរបស់ព្រះអរិយសាវកនោះឯង ។ លោកុត្តរមគ្គ ដែលឈ្មោះថា មានខណៈចិត្តច្រើនរមែងមិនមានគប្បីឲ្យព្រមទទួលថា មានខណៈចិត្តមួយប៉ុណ្ណោះ បើបុគ្គលនោះដឹង ក៏គួរដឹង បើមិនដឹង ក៏ចូរបញ្ជូនទៅថា សូមលោកចូលទៅកាន់វិហារអំពីព្រលឹមហើយធាន់បបរចុះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ហើយ ។

**កោសម្ពិយសូត្រ ចប់**

**សូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ព្រហ្មនិមន្តនិកសូត្រទី ៩

[ ១៩១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។

[ ១៩២ ] ព្រះមានព្រះភាគបានត្រាស់ភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគតនៅក្នុងសុភគវ័ននេះ ទៀបគល់សាលរាជព្រឹក្ស នាដែនឧក្កដ្ឋា ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង ទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះ កើតឡើងដល់ព្រហ្មឈ្មោះពកៈថា ឋានព្រហ្មនេះជារបស់ទៀង ជារបស់ឋិតថេរ ជារបស់មាននៅគ្រប់កាល ជារបស់មិនធ្លុះធ្លាយ ជារបស់មិនឃ្លៀងឃ្លាត ព្រោះថា ឋានព្រហ្មនេះ មិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនកើតឡើងឯឋានដទៃ ជាទីរលាស់ខ្លួនចេញចាកទុក្ខ ឲ្យក្រៃលែងជាងឋានព្រហ្មនេះ មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ តថាគតបានដឹងនូវសេចក្តីត្រិះរិះ ក្នុងចិត្តរបស់ពកព្រហ្ម ដោយចិត្តរបស់តថាគត ហើយក៏បាត់អំពីសុភគវ័ន ទៀបគល់សាលរាជព្រឹក្ស ក្នុងក្រុងឧក្កដ្ឋា ទៅប្រាកដក្នុងព្រហ្មលោកនោះ ដូចជាបុរសមានកម្លាំង លាដៃដែលបត់ចូល ឬបត់ដៃដែលលាចេញ ដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ពកព្រហ្មបានឃើញតថាគត កំពុង

មកអំពីចម្ងាយ លុះឃើញហើយ ទើបក្រាបបង្គំទូលតថាគត យ៉ាងនេះថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ សូមព្រះអង្គទ្រង់ស្តេចចូលមក បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ដំណើរដែលព្រះអង្គស្តេចមកនេះ ប្រពៃហើយ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ព្រះអង្គខានធ្វើដំណើរនិមន្តមកក្នុងទីនេះ អស់កាលជាយូរអង្វែងណាស់ហើយ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ធម្មតាឋានព្រហ្មនេះ ជាទីទៀង ជាទីឋិតថេរ មាននៅសព្វកាល មិនធ្លុះធ្លាយ មិនឃ្លៀងឃ្លាត ព្រោះថា ឋានព្រហ្មនេះ រមែងមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនកើតឡើងទៀតទេ ឯឋានដទៃ ជាទីរលាស់ខ្លួនចេញចាកទុក្ខ ឲ្យក្រៃលែងជាងឋានព្រហ្មនេះ មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលពកព្រហ្មពោលយ៉ាងនេះហើយ តថាគតបានពោលនឹងពកព្រហ្មយ៉ាងនេះថា អើហ្ន៎ ពកព្រហ្មប្រកបដោយអវិជ្ជាទេតើ អើហ្ន៎ ពកព្រហ្ម ប្រកបដោយអវិជ្ជាទេតើ បានជាពោលនូវរបស់ដែលមិនទៀងទាត់ ថាជារបស់ទៀងទាត់វិញ ពោលរបស់ដែលមិនឋិតថេរ ថាជារបស់ឋិតថេរវិញ ពោលរបស់គ្មាននៅគ្រប់កាល ថាជារបស់មាននៅគ្រប់កាលវិញ ពោលរបស់ដែលធ្លុះធ្លាយ ថាជារបស់មិនធ្លុះធ្លាយវិញ ពោលរបស់ដែលឃ្លៀងឃ្លាត ថាជារបស់មិនឃ្លៀងឃ្លាតវិញ មួយទៀត ពកព្រហ្ម ពោលចំពោះឋានព្រហ្ម ដែលនៅកើតនៅចាស់ នៅស្លាប់ នៅច្យុត នៅកើតទៀតថា ឋានព្រហ្មនេះមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនកើតឡើងវិញ ឯឋានដទៃ ជាទីរលាស់ខ្លួនចេញចាកទុក្ខឲ្យក្រៃលែងជាងឋានព្រហ្មនេះ មិនមានឡើយ ។

[ ១៩៣ ] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មារមានចិត្តបាបចូលជ្រែក ព្រហ្មមួយរូប ឈ្មោះបរិសជ្ជៈ ហើយពោលពាក្យនេះនឹងតថាគតថា ម្នាលភិក្ខុ ភិក្ខុកុំបណ្តេញព្រហ្មនេះឡើយ ភិក្ខុកុំបណ្តេញព្រហ្មនេះឡើយ ម្នាលភិក្ខុ ព្រោះព្រហ្មនេះជាមហាព្រហ្ម ជាច្បងឥតមានអ្នកដទៃគ្របសង្កត់បាន ជាអ្នកឃើញហេតុពិត ជាអ្នកធ្វើជនទាំងអស់ ឲ្យលុះក្នុងអំណាចខ្លួនបាន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក និម្មិតលោក ជាអ្នកប្រសើរ ជាអ្នកចាត់ចែងលោក ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់ពួកសត្វដែលកើតហើយ និងសត្វដែលនៅក្នុងគភ៌ ។ ម្នាលភិក្ខុ ក្នុងកាលមុនអំពីខ្លួនលោក មានពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកតិះដៀលផែនដី ខ្ពើមផែនដី តិះដៀលទឹក ខ្ពើមទឹក តិះដៀលភ្លើង ខ្ពើមភ្លើង តិះដៀលខ្យល់ ខ្ពើមខ្យល់ តិះដៀលពួកសត្វ ខ្ពើមពួកសត្វ តិះដៀលទេវតា ខ្ពើមទេវតា តិះដៀលបជាបតិទេវរាជ ខ្ពើមបជាបតិទេវរាជ តិះដៀលព្រហ្ម ខ្ពើមព្រហ្ម ពួកសមណព្រាហ្មណ៍ទាំងនោះ លុះទម្លាយកាយផ្តាច់បង់ជីវិតទៅ ក៏កើតក្នុងពួកដ៏ថោកទាប គឺអបាយភូមិ ៤ ។ ម្នាលភិក្ខុមួយវិញទៀត ក្នុងកាលមុនអំពីខ្លួនលោក មានពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកសរសើរផែនដី ត្រេកអរនឹងផែនដី សរសើរទឹក ត្រេកអរនឹងទឹក សរសើរភ្លើង ត្រេកអរនឹងភ្លើង សរសើរខ្យល់ ត្រេកអរនឹងខ្យល់ សរសើរពួកសត្វ ត្រេកអរនឹងពួកសត្វ សរសើរទេវតា ត្រេកអរនឹងទេវតា សរសើរបជាបតិទេវរាជ ត្រេកអរនឹងបជាបតិទេវរាជ សរសើរព្រហ្ម ត្រេកអរនឹងព្រហ្ម ពួកសមណព្រាហ្មណ៍ទាំងនោះ លុះទម្លាយកាយផ្តាច់បង់ជីវិតទៅ ក៏

កើតក្នុងពួកដ៏ប្រសើរ គឺព្រហ្មលោក ។ ម្នាលភិក្ខុ ព្រោះហេតុនោះ ខ្ញុំសូម និយាយនឹងលោកយ៉ាងនេះ បពិត្រលោកអ្នកនិទ្ទុក្ខ ខ្ញុំសូមជាស់តឿនលោក ចូរលោកធ្វើតាមពាក្យព្រហ្ម ដែលបាននិយាយហើយដល់លោក លោកកុំកន្លងពាក្យរបស់ព្រហ្មឡើយ ម្នាលភិក្ខុ ប្រសិនបើលោកកន្លងពាក្យរបស់ព្រហ្មហើយ ។ ដូចជាបុរសយកដំបង វាយបណ្តេញនូវសិរី ដែលកំពុងមកដល់ យ៉ាងណា ម្នាលភិក្ខុ ពុំនោះសោត ដូចជាបុរសធ្លាក់ក្នុងអណ្តូងជំជ្រៅ មិនអាចនឹងចាប់ផែនដី ដោយដៃ និងជើងទាំងឡាយបាន យ៉ាងណា ម្នាលភិក្ខុ សេចក្តីឧបមេយ្យនេះ នឹងមានដល់លោក ក៏យ៉ាងនោះដែរ ។ បពិត្រលោកអ្នកនិទ្ទុក្ខ ខ្ញុំសូមជាស់តឿនលោក ចូរលោកធ្វើតាមពាក្យព្រហ្ម ដែលបាននិយាយហើយដល់លោក ចូរលោកកុំកន្លងពាក្យរបស់ព្រហ្មឡើយ ម្នាលភិក្ខុ ក្រែងលោកឃើញព្រហ្មបរិស័ទ កំពុងប្រជុំគ្នាដែរឬទេ ។ ម្នាលភិក្ខុទាំងឡាយ មារមានចិត្តបាប បានបង្អោនតថាគត ឲ្យដូចជាព្រហ្មបរិស័ទ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលមារនិយាយយ៉ាងនេះហើយ តថាគតបានពោលនឹងមារមានចិត្តបាប យ៉ាងនេះវិញថា ម្នាលមារមានចិត្តបាប តថាគតស្គាល់អ្នកច្បាស់ហើយ អ្នកកុំមើលងាយថា ឥតមានអ្នកណាមួយស្គាល់អញដូច្នេះឡើយ ម្នាលមារមានចិត្តបាប អ្នកហ្នឹងហើយជាមារ ម្នាលមារមានចិត្តបាប ព្រហ្មណាក៏ដោយ ព្រហ្មបរិស័ទណាក៏ដោយ ព្រហ្មបារិសជ្ជាណាក៏ដោយ អ្នកទាំងអស់នោះ សុទ្ធតែលុះក្នុងកណ្តាប់ដៃរបស់អ្នក អ្នកទាំងអស់នោះសុទ្ធតែលុះក្នុងអំណាចរបស់អ្នក ម្នាលមារមានចិត្តបាប ព្រោះហេតុនោះ បានជា

អ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះសមណគោតម គប្បីលុះក្នុងកណ្តាប់ដៃរបស់អញ ព្រះសមណគោតម គប្បីលុះក្នុងអំណាចរបស់អញ ម្នាលមារមានចិត្តបាប ឯតថាគតមិនលុះក្នុងកណ្តាប់ដៃរបស់អ្នកទេ មិនលុះក្នុងអំណាចរបស់អ្នកទេ ។

[ ១៩៤ ] ម្នាលភិក្ខុទាំងឡាយ កាលតថាគតពោលយ៉ាងនេះហើយ ពកព្រហ្មបានពោលនូវពាក្យនេះថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ខ្ញុំព្រះអង្គពោលរបស់ដែលទៀង ថាជារបស់ទៀងពិត ពោលរបស់ដែលឋិតថេរ ថាជារបស់ឋិតថេរពិត ពោលរបស់ដែលមាននៅសព្វកាល ថាជារបស់មាននៅសព្វកាលពិត ពោលរបស់ដែលដាច់ដុះដាយ ថាជារបស់ដាច់ដុះដាយពិត ពោលរបស់ដែលមិនឃ្លៀងឃ្លាត ថាជារបស់មិនឃ្លៀងឃ្លាតពិត ។ មួយវិញទៀត ទីណាមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនកើតឡើង ខ្ញុំព្រះអង្គ ពោលទីនោះឯង ថាទីនេះមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនកើតឡើង មួយវិញទៀត ឋានដទៃជាទីរលាស់ខ្លួនចេញចាកទុក្ខឲ្យក្រៃលែងមិនមាន បានជាខ្ញុំព្រះអង្គពោលថា ឋានដទៃជាទីរលាស់ខ្លួនចេញចាកទុក្ខ ឲ្យក្រៃលែងមិនមាន ។ ម្នាលភិក្ខុ កាលមុនខ្លួនអ្នកទៅទៀត មានពួកសមណព្រាហ្មណ៍ក្នុងលោក មានតបកម្មប្រហែលនឹងអាយុទាំងអស់របស់អ្នក ។ ពួកសមណព្រាហ្មណ៍នោះ ដឹងយ៉ាងនេះថា ឋានដទៃជាទីរលាស់ខ្លួនចេញចាកទុក្ខ តទៅទៀតមាន ឋានដទៃជាទីរលាស់ខ្លួនចេញចាកទុក្ខ តទៅទៀតមាន ថាឋានដទៃជាទីរលាស់ខ្លួនចេញចាកទុក្ខ តទៅទៀតមិនមាន ឋានដទៃជាទីរលាស់ខ្លួន

ចេញចាកទុក្ខ តទៅទៀតមិនមាន ។ ម្នាលភិក្ខុ ព្រោះហេតុនោះ បានជាខ្ញុំនិយាយនឹងលោកយ៉ាងនេះ លោកមិនឃើញនូវឋានដទៃ ជាទីរលាស់ខ្លួនចេញចាកទុក្ខ តទៅទៀតទេ លោកជាអ្នកមានចំណែកនៃសេចក្តីលំបាក និងសេចក្តីចង្អៀតចង្អល់តែមួយយ៉ាង ។ ម្នាលភិក្ខុ ប្រសិនបើលោកប្រកាន់ផែនដី ឈ្មោះថាដេកនៅក្បែរខ្ញុំ ឈ្មោះថាដេកត្រាំនៅក្នុងវត្ថុរបស់ខ្ញុំ ខ្ញុំនឹងធ្វើលោកតាមសេចក្តីប្រាថ្នារបស់ខ្ញុំ ឲ្យលោកជាមនុស្សថោកទាបក៏បាន ។ មួយវិញទៀត ប្រសិនបើលោកប្រកាន់ទឹក ភ្លើង ខ្យល់ ពពួកសត្វ ទេវតា បជា-បតិទេវរាជ ព្រហ្ម ឈ្មោះថាដេកនៅក្បែរខ្ញុំ ឈ្មោះថាដេកត្រាំក្នុងវត្ថុរបស់ខ្ញុំ ខ្ញុំនឹងធ្វើលោកតាមសេចក្តីប្រាថ្នារបស់ខ្ញុំ ឲ្យលោកជាមនុស្សថោកទាបក៏បាន ។ ម្នាលព្រហ្ម តថាគតក៏ដឹងហេតុនេះដែរ ។ ប្រសិនបើតថាគតប្រកាន់ផែនដី ឈ្មោះថាដេកនៅក្បែរអ្នក ឈ្មោះថាដេកត្រាំក្នុងវត្ថុរបស់អ្នក អ្នកគួរនឹងធ្វើតថាគតតាមសេចក្តីប្រាថ្នារបស់អ្នក ឲ្យតថាគតជាមនុស្សថោកទាបបានមែន ។ មួយវិញទៀត ប្រសិនបើតថាគតប្រកាន់ទឹក ភ្លើង ខ្យល់ ពួកសត្វ ពួកទេវតា បជាបតិទេវរាជ ព្រហ្ម ឈ្មោះថាដេកនៅក្បែរអ្នក ឈ្មោះថាដេកត្រាំក្នុងវត្ថុរបស់អ្នក អ្នកគួរនឹងធ្វើតថាគតតាមសេចក្តីប្រាថ្នា ឲ្យតថាគតជាមនុស្សថោកទាបបានមែន ។ ម្នាលព្រហ្ម ប៉ុន្តែតថាគតស្គាល់គតិរបស់អ្នក ស្គាល់អានុភាពរបស់អ្នកហើយថា ពកព្រហ្មមានឫទ្ធិច្រើនយ៉ាងនេះ ពកព្រហ្មមានអានុភាពច្រើនយ៉ាងនេះ ពកព្រហ្មមានសក្តិធំយ៉ាងនេះ ។ ពកព្រហ្មទូលសួរថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ចុះព្រះអង្គស្គាល់គតិរបស់ខ្ញុំ ស្គាល់អានុភាពរបស់ខ្ញុំថា

ពកព្រហ្មមានឫទ្ធិច្រើនយ៉ាងនេះ ពកព្រហ្មមានអានុភាពច្រើនយ៉ាងនេះ ពកព្រហ្មមានសក្តិធំយ៉ាងនេះ តើដោយប្រការដូចម្តេច ។

( ព្រះអង្គត្រាស់ថា ) ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយ
ដើរបំភ្លឺទិសទាំងឡាយ ឲ្យភ្លឺបានត្រឹមណា លោក គឺចក្រ-
វាលទាំងមួយពាន់ ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នក
ប្រព្រឹត្តទៅ បានតែត្រឹមចក្រវាលមួយពាន់នុ៎ះ មួយទៀត
អ្នកស្គាល់ពួកសត្វថោកទាប និងពួកសត្វខ្ពង់ខ្ពស់ សត្វ
ដែលប្រកបដោយរាគៈ និងសត្វដែលប្រាសចាករាគៈ
ស្គាល់ចក្រវាលនេះ ចក្រវាលដទៃ ស្គាល់ដំណើរមក និង
ដំណើរទៅរបស់សត្វទាំងឡាយ ។

ម្នាលព្រហ្ម តថាគតស្គាល់គតិ ស្គាល់អានុភាពរបស់អ្នកយ៉ាងនេះថា ពកព្រហ្មមានឫទ្ធិច្រើនយ៉ាងនេះ ពកព្រហ្មមានអានុភាពច្រើនយ៉ាងនេះ ពកព្រហ្មមានសក្តិធំយ៉ាងនេះ ។ ម្នាលព្រហ្ម នៅមានព្រហ្ម ៣ ពួកដទៃទៀត អ្នកមិនដឹងមិនឃើញ ព្រហ្មទាំង ៣ ពួកនោះទេ តថាគតទើបដឹង ទើបឃើញព្រហ្មទាំង ៣ ពួកនោះបាន ។ ម្នាលព្រហ្ម មានពួកព្រហ្មមួយ ឈ្មោះអាភស្សរៈ ។ ខ្លួនអ្នកច្យុតអំពីទីនោះ បានមកកើតក្នុងទីនេះ ស្មារតីរបស់អ្នកនោះក៏ភ្លេចបាត់ទៅ ដោយសារនៅក្នុងទីនេះយូរពេក ព្រោះហេតុនោះ បានជាអ្នកមិនដឹង មិនឃើញ អាភស្សរព្រហ្មនោះ តថាគតទើបដឹង ទើបឃើញព្រហ្មនោះបាន ។ ម្នាលព្រហ្មយ៉ាងនេះឯង តថាគតមិនមែនស្មើនឹងអ្នកទេ តថាគត

ដឹងច្បាស់ហើយ នឹងឲ្យថោកទាបជាងអ្នកដូចម្តេចបាន តថាគតត្រូវតែប្រសើរជាងអ្នកដោយពិត ។ ម្នាលព្រហ្ម នៅមានពួកព្រហ្មឈ្មោះសុភកិណ្ហ និងពួកព្រហ្មឈ្មោះវេហប្ផលៈ អ្នកមិនដឹង មិនឃើញពួកព្រហ្មទាំងនោះទេ តថាគតទើបដឹង ទើបឃើញពួកព្រហ្មនោះបាន ។ ម្នាលព្រហ្ម យ៉ាងនេះឯង តថាគតមិនមែនស្មើនឹងអ្នកទេ តថាគតដឹងហើយ នឹងឲ្យថោកទាបជាងអ្នកដូចម្តេចបាន តថាគតត្រូវតែប្រសើរជាងអ្នកដោយពិត ។ ម្នាលព្រហ្ម តថាគត ដឹងច្បាស់នូវផែនដី ថាជាផែនដីពិត ដឹងច្បាស់នូវព្រះនិព្វានដែលសត្វមិនធ្លាប់ដល់ដោយសភាពនៃផែនដីពិត បានជាតថាគតមិនប្រកាន់នូវផែនដី មិនប្រកាន់ក្នុងផែនដី មិនប្រកាន់អំពីផែនដី មិនប្រកាន់ថាផែនដីរបស់តថាគត មិនប្រកាសផែនដី ។ ម្នាលព្រហ្ម កាលបើយ៉ាងនេះ តថាគតមិនមែនជាបុគ្គលស្មើនឹងអ្នកទេ តថាគតត្រាស់ដឹងហើយនឹងឲ្យថោកទាបជាងអ្នកដូចម្តេចបាន តថាគតត្រូវតែប្រសើរជាងអ្នកដោយពិត ។ ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវទឹក ។បេ។ ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវភ្លើង ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវខ្យល់ ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវពួកសត្វ ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវពួកទេវតា ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវបជាបតិទេវរាជ ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវព្រហ្ម ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវពួកព្រហ្មឈ្មោះអាភស្សរៈ ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវព្រហ្មឈ្មោះ សុភកិណ្ហៈ ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវព្រហ្មឈ្មោះវេហប្ផលៈ ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវព្រហ្ម

ជាច្បងគេ... ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវវត្ថុទាំងពួងថាជាវត្ថុទាំងពួងពិត ដឹងច្បាស់នូវព្រះនិព្វាន ដែលសត្វមិនធ្លាប់ដល់ ដោយសភាពនៃវត្ថុទាំងពួង បានជាតថាគតមិនប្រកាន់វត្ថុទាំងពួង មិនប្រកាន់ក្នុងវត្ថុទាំងពួង មិនប្រកាន់អំពីវត្ថុទាំងពួង មិនប្រកាន់វត្ថុទាំងពួងថាជារបស់តថាគត មិនប្រកាសនូវវត្ថុទាំងពួង ។ ម្នាលព្រហ្ម កាលបើយ៉ាងនេះ តថាគតមិនមែនស្មើនឹងអ្នកទេ តថាគតត្រាស់ដឹងហើយ នឹងឲ្យថោកទាបជាងអ្នកដូចម្តេចបាន តថាគតត្រូវតែប្រសើរជាងអ្នកដោយពិត ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ បើព្រះអង្គដឹងនូវព្រះនិព្វានដែលសត្វមិនធ្លាប់ដល់ដោយសភាពនៃវត្ថុទាំងពួងហើយ សូមកុំឲ្យពាក្យរបស់ព្រះអង្គ សោះសូន្យទទេ ឥតអំពើឡើយ ។ វិញ្ញាណឈ្មោះអនិទស្សនៈ ឈ្មោះអនន្តៈ មានពន្លឺភ្លឺជាងធម្មជាតទាំងអស់ ដែលសត្វមិនធ្លាប់បានដល់ដោយសភាពនៃផែនដី មិនធ្លាប់បានដល់ដោយសភាពនៃទឹក មិនធ្លាប់បានដល់ដោយសភាពនៃភ្លើង មិនធ្លាប់បានដល់ដោយសភាពនៃខ្យល់ មិនធ្លាប់បានដល់ដោយសភាពជាពួកសត្វ មិនធ្លាប់បានដល់ដោយសភាពជាទេវតា មិនធ្លាប់បានដល់ដោយសភាពជាបជាបតិទេវរាជ មិនធ្លាប់បានដល់ដោយសភាពជាព្រហ្ម មិនធ្លាប់បានដល់ដោយសភាពជាអាភស្សរព្រហ្ម មិនធ្លាប់បានដល់ដោយសភាពជាសុភកិណ្ហព្រហ្ម មិនធ្លាប់បានដល់ដោយសភាពជាវេប្ផលព្រហ្ម មិនធ្លាប់បានដល់ដោយសភាពនៃព្រហ្មជាច្បង មិនធ្លាប់បានដល់ដោយសភាពនៃវត្ថុទាំងពួង ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ណ្ហើយចុះ ខ្ញុំនឹងបំបាត់ខ្លួនអំពីព្រះអង្គឥឡូវនេះ ។ ម្នាលព្រហ្ម អើ បើអ្នកអាច ក៏ចូរបំបាត់

ខ្លួនអំពីតថាគតឥឡូវនេះមើល ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ពកព្រហ្មគិតថា អាត្មាអញនឹងបំបាត់ខ្លួនអំពីព្រះសមណគោតម អាត្មានឹងបំបាត់ខ្លួនអំពីព្រះសមណគោតម ហើយក៏មិនអាចនឹងបំបាត់ខ្លួនអំពីតថាគតបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពកព្រហ្មពោលយ៉ាងនេះហើយ តថាគតក៏បានពោលនឹងពកព្រហ្មយ៉ាងនេះវិញថា ម្នាលព្រហ្ម បើដូច្នោះ តថាគតនឹងបំបាត់ខ្លួនអំពីអ្នកវិញ ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ បើព្រះអង្គអាចក៏ចូរបំបាត់ខ្លួនអំពីខ្ញុំទៅមើល ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតនិម្មិតនូវឥទ្ធាភិសង្ខារ មានសភាពដូច្នោះថា ព្រហ្ម និងព្រហ្មបរិស័ទ ព្រមទាំងព្រហ្មបារិសជ្ជា ឲ្យឮតែសំឡេងរបស់តថាគតប៉ុណ្ណោះ តែមិនបានឃើញតថាគតឡើយ ។ កាលតថាគតបំបាត់ខ្លួនទៅហើយ ក៏ពោលនូវព្រះគាថានេះថា

តថាគតឃើញភ័យក្នុងភពផង ឃើញនូវពួកសត្វដែលកំពុងស្វែងរកនូវភពផង ហើយមិនបានពោលសរសើរ គឺមិនស្វែងរកភពណាមួយ ទាំងមិនប្រកាន់នូវសេចក្តីត្រេកអរ ( ក្នុងភព ) ឡើយ ។

[ ១៩៥ ] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រហ្ម និងព្រហ្មបរិស័ទ ព្រមទាំងព្រហ្មបារិសជ្ជាក៏កើតសេចក្តីអស្ចារ្យក្នុងចិត្តថា អើហេតុនេះជាអស្ចារ្យណាស់ហ្ន៎ អើហេតុនេះមិនដែលមានទេហ្ន៎ ព្រះសមណគោតមពេញជាមានឫទ្ធិច្រើន ពេញជាមានអានុភាពច្រើនមែន មួយទៀត មុនអំពីកាលនេះ យើងទាំងឡាយមិនដែលបានឃើញ មិនដែលបានឮថា មានសមណៈ ឬព្រាហ្មណ៍ដទៃមានឫទ្ធិច្រើន មានអានុភាពច្រើនឲ្យដូចជាព្រះសមណគោតមដែលចេញ

បាកសក្យត្រកូល មកបួសនេះឡើយ អើហ្ន៎ ព្រះសមណគោតម បេះផ្តិល ផ្តាច់នូវភព ព្រមទាំងឫសគល់របស់ពួកសត្វដែលរីករាយក្នុងភព ត្រេកអរក្នុងភព ពេញចិត្តក្នុងភពបាន ។

[ ១៩៦ ] ម្នាលភិក្ខុទាំងឡាយ គ្រានោះ មារមានចិត្តបាបបានចូលជ្រែកសរីរៈនៃព្រហ្មបារិសជ្ជាមួយរូប ហើយបានពោលនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ប្រសិនបើព្រះអង្គជ្រាបច្បាស់យ៉ាងនេះ ប្រសិនបើត្រាស់ដឹង ( សច្ចៈ ) យ៉ាងនេះហើយ សូមព្រះអង្គកុំពន្យល់ពួកសាវក កុំពន្យល់ពួកបព្វជិត កុំសម្តែងធម៌ដល់ពួកសាវក កុំសម្តែងធម៌ដល់ពួកបព្វជិតឡើយ កុំធ្វើសេចក្តីប្រាថ្នាក្នុងពួកសាវក កុំធ្វើសេចក្តីប្រាថ្នាក្នុងពួកបព្វជិតឡើយ ។ ម្នាលភិក្ខុ ក្នុងកាលមុនខ្ញុំនលោក ( ទៅទៀត ) មានពួកសមណ-ព្រាហ្មណ៍ជាអរហន្តសម្មាសម្ពុទ្ធ ជាអ្នកបេះដឹងក្នុងលោក ពួកសមណព្រាហ្មណ៍ទាំងនោះបានពន្យល់ពួកសាវក និងពួកបព្វជិត បានសម្តែងធម៌ដល់ពួកសាវក និងពួកបព្វជិត បានធ្វើសេចក្តីប្រាថ្នាក្នុងពួកសាវក និងពួកបព្វជិត លុះពន្យល់ពួកសាវក និងពួកបព្វជិត សម្តែងធម៌ដល់ពួកសាវក និងពួកបព្វជិត មានចិត្តប្រាថ្នា ក្នុងពួកសាវក និងពួកបព្វជិតហើយ លុះទម្លាយកាយផ្តាច់ជីវិតបាត់ទៅ កើតក្នុងពួកដ៏ថោកទាប ( គឺអបាយភូមិទាំង ៤ ) ។ ម្នាលភិក្ខុមួយទៀត ក្នុងកាលមុនខ្ញុំនលោក ( ទៅទៀត ) មានសមណព្រាហ្មណ៍ ជាអរហន្តសម្មាសម្ពុទ្ធ ជាអ្នកបេះដឹងក្នុងលោក ពួកសមណព្រាហ្មណ៍ទាំងនោះមិនបានពន្យល់ពួកសាវក មិនបានពន្យល់ពួកបព្វជិត មិនសម្តែងធម៌ដល់ពួក

សាវក មិនសម្តែងធម៌ដល់ពួកបព្វជិត មិនធ្វើសេចក្តីប្រាថ្នាក្នុងពួកសាវក មិនធ្វើសេចក្តីប្រាថ្នាក្នុងពួកបព្វជិត ពួកសមណព្រាហ្មណ៍ទាំងនោះ លុះមិនបានពន្យល់ពួកសាវក មិនបានពន្យល់ពួកបព្វជិត មិនបានសម្តែងធម៌ដល់ពួកសាវក មិនបានសម្តែងធម៌ដល់ពួកបព្វជិត មិនមានចិត្តប្រាថ្នាក្នុងពួកសាវក មិនមានចិត្តប្រាថ្នាក្នុងពួកបព្វជិតហើយ លុះទម្លាយកាយផ្តាច់បង់ជីវិត ក៏បានមកកើតក្នុងទីដ៏ខ្ពង់ខ្ពស់ ( ព្រហ្មលោក ) ។ ម្នាលភិក្ខុ ព្រោះហេតុនោះ បានជាខ្ញុំនិយាយនឹងលោកយ៉ាងនេះថា ម្នាលអ្នកនិទ្ទុក្ខ ខ្ញុំសូមរម្ងឹក កុំឲ្យលោកមានសេចក្តីខ្វល់ខ្វាយពេក សូមប្រកបរឿយៗ នូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នចុះ ព្រោះថា ការដែលមិនសម្តែង ( ធម៌ ) ប្រាប់ជនដទៃជាការប្រពៃ ម្នាលអ្នកនិទ្ទុក្ខ សូមលោកកុំទូន្មានអ្នកដទៃឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើមារពោលយ៉ាងនេះហើយ ទើបតថាគតបានពោលពាក្យនេះនឹងមារមានចិត្តបាបវិញថា ម្នាលមារមានចិត្តបាប តថាគតស្គាល់អ្នកច្បាស់ហើយ អ្នកកុំមើលងាយថា ឥតអ្នកណាមួយស្គាល់អាត្មាអញដូច្នេះឡើយ ម្នាលមារមានចិត្តបាប អ្នកហ្នឹងហើយ ជាមារ ម្នាលមារមានចិត្តបាប អ្នកជាអ្នកមិនអនុគ្រោះតថាគតដោយប្រយោជន៍ទេ បានជានិយាយយ៉ាងនេះ ម្នាលមារមានចិត្តបាប អ្នកអនុគ្រោះតថាគត ដោយអំពើឥតប្រយោជន៍ បានជានិយាយយ៉ាងនេះ ។ ម្នាលមារមានចិត្តបាប ព្រោះអ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា សមណគោតមសម្តែងធម៌ដល់ពួកជនណា ពួកជននោះ នឹងកន្លងផុតវិស័យរបស់អាត្មាអញ ។ ម្នាលមារមានចិត្តបាប ឯពួកសមណព្រាហ្មណ៍

ទាំងនោះ មិនមែនជាសម្មាសម្ពុទ្ធទេ តែប្តេជ្ញាថា យើងជាសម្មាសម្ពុទ្ធ ម្នាលមារមានចិត្តបាប តថាគតជាសម្មាសម្ពុទ្ធពិត ទើបប្តេជ្ញាថា សម្មាសម្ពុទ្ធ ។ ម្នាលមារមានចិត្តបាប ទោះបីតថាគតសម្តែងធម៌ដល់ពួកសាវកក្តី ក៏នៅជាតថាគតដដែល ម្នាលមារមានចិត្តបាប ទោះបីតថាគតមិនសម្តែងធម៌ដល់ពួកសាវកក្តី ក៏នៅជាតថាគតដដែល ម្នាលមារមានចិត្តបាប ទោះបីតថាគតពន្យល់ពួកសាវកក្តី ក៏នៅជាតថាគតដដែល ម្នាលមារមានចិត្តបាប ទោះបីតថាគតមិនពន្យល់ពួកសាវកក្តី ក៏នៅជាតថាគតដដែល ដំណើរនោះ ព្រោះហេតុអ្វី ម្នាលមារមានចិត្តបាប ព្រោះតថាគតបានលះបង់នូវអាសវៈ ដែលជាសង្កិ-លេសធម៌ ជាធម៌តាក់តែងភពថ្មី ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល មានជាតិ ជរា និងមរណៈតទៅខាងមុខបាន ទាំងផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចជាដើមត្នោតដែលគេគាស់ក្របែល រម្លើងឲ្យលែងដុះទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ ម្នាលមារមានចិត្តបាប ដូចជាដើមត្នោតដែលមានចុងកំបុតហើយ មិនគួរនឹងដុះឡើងវិញបាន យ៉ាងណា ម្នាលមារមានចិត្តបាប តថាគតបានលះបង់នូវអាសវៈទាំងឡាយ ជាសង្កិលេស ជាធម៌តាក់តែងភពថ្មីទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខជាផល មានជាតិ ជរា និងមរណៈតទៅខាងមុខ បានទាំងផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីងដូចជាដើមត្នោត ដែលគេក្របែលគាស់រម្លើងឲ្យលែងដុះតទៅទៀត

ហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅទៀតហើយ ក៏យ៉ាងនោះដែរ ព្រោះការចរចាមិនកើតការនៃមារផង ព្រោះការនិមន្តន៍ចំពោះនៃព្រហ្មផង ហេតុដូច្នោះ បានជាវេយ្យាករណ៍នេះ មាននាមថា ព្រហ្មនិមន្តនិកៈ ដោយប្រការដូច្នេះឯង ។

ព្រហ្មនិមន្តនិកសូត្រទី ៩ ចប់

# អដ្ឋកថា

## ព្រហ្មនិមន្តនិកសូត្រទី ៩

[ ១៩១ ] ព្រហ្មនិមន្តនិកសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ១៩២ ] បណ្ដាបទទាំងនោះ បទថា **ចាបកំ ទិដ្ឋិគតំ** បានដល់ការយល់ឃើញថាទៀងដ៏លាមក ។ បទថា **ឥទំ និច្ចំ** គឺពោលថា ឋាននៃព្រហ្ម ព្រមគ្នានឹងឱកាសដែលជារបស់មិនទៀងនេះថាទៀង ។ បទថា **ធុវា-ទីនិ** ជាដើម ជាពាក្យប្រើជំនួសពាក្យថាទៀងនោះឯង ។ ក្នុងបទទាំងនោះ បទថា **ធុវំ** គឺមាំទាំ ។ បទថា **សស្សតំ** គឺមានគ្រប់កាល ។ បទថា **កេវលំ** គឺទាំងអស់ មិនមានកំណត់ ។ បទថា **អចវនធម្មំ** គឺមានសភាព មិនរំកិលទៅ ។ សូម្បីឋានៈក្នុងបទថា **ឥទំ ហិ ន ជាយតិ** ជាដើមនេះ គឺពោលសំដៅយកអ្នកកើត អ្នកចាស់ អ្នកស្លាប់ អ្នកច្យុត អ្នកឧប្បត្តិ មិនមាន ។ បទថា **ឥតោ ច បនញ្ញំ** គឺការឃើញថា ការទៀងយ៉ាងមាំទាំ រមែងជារបស់ដែលកើតឡើងហើយ ដល់ព្រហ្មនោះយ៉ាងនេះថា ឈ្មោះថា ហេតុនៃការចេញទៅដទៃ ក្រៅអំពីឋាននៃព្រហ្ម ព្រមទាំងឱកាសនេះ មិនមាន ។ ឯបុគ្គលកាលពោលដូច្នេះ រមែងការពារគ្រប់យ៉ាង គឺលំដាប់របស់ឈានខាងលើ ៣ មគ្គ ៤ ផល ៤ និព្វាន ១ ។ បទថា **អវិជ្ជាគតោ** សេចក្ដីថា បុគ្គលទៅ គឺប្រកបក្នុងការមិនដឹង ឈ្មោះថា ជាអ្នកមិនដឹង គឺជាបុគ្គលខ្វាក់ ។ បទថា **យត្រ ហិ នាម** គឺឈ្មោះណា ។

[ ១៩៣ ] បទថា **មារោ** ក្នុងបទទាំងឡាយថា **អថខោ ភិក្ខវេ មារោ បាបិម** នេះ តើមារបានឃើញព្រះមានព្រះភាគដូចម្តេច ។

បានឮមកថា មារនោះ ជញ្ជឹងគិតដល់ព្រះសាស្តាក្នុងកាលខ្លួនឯង សព្វវេលាថា ថ្ងៃនេះ ព្រះគោតមសមណៈ នៅស្រុកណា និគមណា ក្នុងពេលដែលកំពុងជញ្ជឹងគិតនេះ បានដឹងថា កំពុងអាស្រ័យក្នុងក្រុងឧក្កដ្ឋៈ ត្រង់ព្រៃសុភគៈ ទើបពិចារណាមើលថា តើទ្រង់ទៅណាទៀតហ្ន៎ ក៏ឃើញថា កំពុងទៅព្រហ្មលោក ទើបគិតថា ព្រះសមណគោតមកំពុងទៅព្រហ្មលោក អញនឹងធ្វើឲ្យពេញចិត្តក្នុងធម្មទេសនាក្នុងធម៌ខុស អស់កាលដែលមារពោលធម្មកថាក្នុងទីនោះហើយ នឹងមិនធ្វើឲ្យគណៈព្រហ្ម ឈានកន្លងផុតវិស័យរបស់អញ ទើបដើរតាមក្រោយព្រះសាស្តា ហើយមកឈរកំបាំងខ្លួន ក្នុងចន្លោះពួកព្រហ្ម មារដឹងថា ពួកព្រហ្មត្រូវព្រះសាស្តាបណ្តេញ ទើបបានឈរធ្វើខ្លួនជាអ្នកគាំទ្រព្រហ្ម ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មារមានចិត្តបាប ដូច្នេះ ។ បទថា **ព្រហ្មបារិសជ្ជំ អន្វាវិសិត្វា** គឺមារចូលសណ្ឋិតក្នុងរាងកាយរបស់ព្រហ្មបារិសជ្ជមួយអង្គ ក៏មិនទាន់អាចចូលជ្រែកមហាព្រហ្ម ឬពួកព្រហ្មបុរោហិតបាន ។ បទថា **មេតមាសទោ** គឺកុំបណ្តេញពួកព្រហ្មនេះ ។ បទថា **អភិភូ** គឺជាអ្នកគ្របសង្កត់តាំងនៅ គឺចម្រើនបំផុត ។ បទថា **អនភិភូតោ** គឺអ្នកដទៃគ្របសង្កត់មិនបាន ។ បទថា **អញ្ញទត្ថុ** ត្រឹមតែជានិបាត ចុះក្នុងពាក្យដែលប្រារព្ធចំណែកមួយ ទ្រង់សម្តែងថា ជាអ្នកឃើញដោយអំណាចការឃើញ រមែងឃើញវត្ថុគ្រប់យ៉ាង ។

បទថា **វសវត្តិ** គឺរមែងញុំាងជនទាំងអស់ឲ្យប្រព្រឹត្តទៅក្នុងអំណាច ។ បទថា **ឥស្សរោ** គឺជាធំក្នុងលោក ។ បទថា **កត្តា និម្មាតា** គឺជាអ្នកធ្វើ និងជាអ្នកនិម្មិតលោក លោកសម្តែងថា ផែនដី ភ្នំហិមពាន្ត ភ្នំសិនេរុ ចក្រវាលមហាសមុទ្រ ព្រះចន្ទ និងព្រះអាទិត្យ មហាព្រហ្មអង្គនេះ ជាអ្នកនិម្មិត ។ បទថា **សេដ្ឋោ សជ្ជិត** គឺមហាព្រហ្មអង្គនេះ ជាអ្នកប្រសើរបំផុត ជាអ្នកចាត់ចែង លោកសម្តែងថា មហាព្រហ្មអង្គនេះ បានចាត់ចែងពួកសត្វយ៉ាងនេះថា ឯងជាក្សត្រ ឯងជាព្រាហ្មណ៍ ជាវេស្សៈ ជាសូទ្រៈ ជាឃរាវាស ជាអ្នកបួស ជាអូដ្ឋ ជាគោ លោកពោលថា មហាព្រហ្មអង្គនេះ ឈ្មោះថា ជាអ្នកមានអំណាច ព្រោះសន្សំអំណាច ។ មហាព្រហ្មអង្គនេះ ជាបិតារបស់ពួកកូត និងពួកភព្យ ក្នុងបទថា **វសី បិតា ភូតភព្យានំ** ។ ក្នុងពាក្យថា ពួកកូត និងភព្យនោះ ពួកសត្វដែលជាអណ្ឌជកំណើត និងជលាពុជកំណើត ខណៈនៅក្នុងស៊ុត ឬនៅក្នុងស្បូន ឈ្មោះថា ភព្យ តាំងអំពីកាលចេញមកខាងក្រៅហើយ ឈ្មោះថា កូត ។ ពួកសត្វដែលជាសំសេទជកំណើត ក្នុងខណៈចិត្តដំបូង ហៅថា ភព្យ តាំងអំពីខណៈចិត្តទី ២ ទៅ ឈ្មោះថា កូត ។ ពួកសត្វដែលជាឱបបាតិក ក្នុងឥរិយាបថដំបូង ឈ្មោះថា ភព្យ តាំងអំពីឥរិយាបថទី ២ ទៅ គប្បីជ្រាបថា ជាកូត ។ ព្រះមានព្រះភាគត្រាស់ថា ជាព្រះបិតារបស់ពួកកូត និងភព្យ ដោយទ្រង់សម្គាល់ថា ពួកសត្វទាំងអស់នោះជាកូនរបស់មហាព្រហ្មអង្គនេះ ។ ដោយបទថា **បឋវិគរហកា** នេះ ព្រះមានព្រះភាគទ្រង់សម្តែងថា ពួកបុគ្គលបានជាអ្នកតិះដៀលនូវផែនដីមកហើយ ដូច

ដែលអ្នកកំពុងតិះដៀល ស្អប់ខ្ពើមនូវផែនដីថា មិនទៀង ជាទុក្ខ ជាអនត្តា ក្នុងឥឡូវនេះ នឹងមិនមែនតែអ្នកប៉ុណ្ណោះទេ ។ ក្នុងបទថា **អាបោគរហកា** ជាដើម ក៏ទំនងដូចគ្នានេះឯង ។ បទថា **ហីនេ កាយេ បតិដ្ឋិតា** បានដល់ កើតក្នុងអបាយទាំង ៤ ។ ដោយបទថា **បឋវីបសំសកា** នេះ ព្រះមានព្រះភាគត្រាស់ថា ពួកបុគ្គលនោះ ជាអ្នកសរសើរនូវផែនដី គឺជាអ្នកពោលសរសើរគុណផែនដីមកហើយយ៉ាងនេះ គឺបុគ្គលមិនតិះដៀល តែសរសើរថា ផែនដីទៀងពិត ស្ថិតស្ថេរចីរកាល មិនដាច់ មិនអស់ទៅ ដូចអ្នកកំពុងតិះដៀល ។ បទថា **បឋវាភិនន្ទិនោ** បានដល់ ជាអ្នកមានការត្រេកអរក្នុងផែនដី ដោយអំណាចតណ្ហា និងទិដ្ឋិ ក្នុងបទដ៏សេសទាំងឡាយ ក៏ទំនងដូចគ្នានេះឯង ។ បទថា **បណីតេ កាយេ បតិដ្ឋិតា** បានដល់ កើតក្នុងព្រហ្មលោក ។ បទថា **តំតាហំ** គឺព្រោះហេតុនោះ តថាគត ... និងអ្នក ។ បទថា **ឥង្ឃ** ជានិបាត ចុះក្នុងអត្ថថា ដាស់តឿន ។ បទថា **ឧច្ចាតិវត្តិដ្ឋោ** គឺឈានកន្លង បាឋៈថា **ឧច្ចាតិវត្តិតោ** ប្រែថា ចូលទៅប្រព្រឹត្តកន្លងដូច្នេះក៏មាន ។ ឯអត្ថក៏ដូចគ្នានោះឯង ។ បទថា **ទណ្ឌេន បដិប្បនាមេយ្យ** គឺយកដំបងវែង ៤ ហត្ថវាយឲ្យគេចទៅ ។ បទថា **នរកប្បបាតេ** គឺអណ្តូងធំ ជម្រៅ ១០០ ជួរបុរស ។ បទថា **វិរាធេយ្យ** បានដល់ មិនអាចដើម្បីនឹងធ្វើជាទីប្រកាន់ដែលជាន់ក្នុងទីដែលល្មមនឹងយកដៃចាប់ ឬល្មមនឹងយកជើងជាន់បាន ។ ដោយបទថា **ននុ ត្វំ ភិក្ខុ បស្សសិ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងឥទ្ធានុភាពនៃបុគ្គលដែលតាំងនៅក្នុងឱវាទរបស់ព្រហ្មថា ភិក្ខុ លោកក៏រមែងឃើញព្រហ្ម-

បរិស័ទដែលប្រជុំគ្នា ក្លីស្វាងរុងរឿង សន្ធោសន្ធៅនេះ មិនមែនឬ ។ បទថា **ឥតិ ខោ មំ ភិក្ខវេ មារោ បាបិមា ព្រហ្មបរិសំ ឧបនេសិ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ មារមានចិត្តបាបពោលយ៉ាងនេះថា ភិក្ខុ អ្នកក៏រមែងឃើញព្រហ្មបរិស័ទដែលរុងរឿងដោយយស ដោយសិរីមិនមែនឬ ណ្ហើយចុះ បើនឹងឈានកន្លងពាក្យមហាព្រហ្ម ធ្វើតាមដែលព្រហ្មពោលនឹងអ្នកហើយ អ្នកក៏នឹងត្រូវរុងរឿងដោយយស និងសិរីបែបនេះដូចគ្នា ក៏បង្អោន គឺនាំយកព្រហ្មបរិស័ទមកកាន់តថាគត ។ បទថា **មា ត្វំ មញ្ញិត្ថោ** គឺមារមានចិត្តបាបអ្នកកុំសម្គាល់ដូច្នោះឡើយ ។ បទថា **មារោ ត្វមសិ បាបិម** គឺមារ ខ្ញុំស្គាល់អ្នកថា អ្នកឯងឈ្មោះថា មារ ព្រោះសម្លាប់មហាជន អ្នកឯងឈ្មោះថា ស្មោកគ្រោក ព្រោះធ្វើព្រមដោយដែកដ៏ស្មោកគ្រោក គឺលាមកដល់មហាជន ។

[ ១៩៤ ] បទថា **កសិណំ អាយុំ** គឺអាយុទាំងអស់ ។ បទថា **តេ ខោ ឯវំ ជានេយ្យុំ** គឺព្រហ្មមកហើយ ពោលបន្តទៅថា ពួកបុគ្គលនោះ ដល់ព្រមដោយការធ្វើតបៈយ៉ាងធំក្រៃលែងយ៉ាងនេះ ឯអ្នកទើបតែកើតមកម្សិលមិញនេះ នឹងដឹងអ្វី ។ ក្នុងថ្ងៃនេះ ក្នុងមាត់របស់អ្នកនៅមានក្លិនទឹកដោះនៅឡើយ ។ បទថា **បឋវី អជ្ឈោសិស្សសិ** គឺនឹងទំពាស៊ីនូវផែនដីអស់រលីងហើយកាន់យកដោយតណ្ហា មានះ និងទិដ្ឋិ ។ បទថា **ឱបសាយិកោ មេ ភវិស្សសិ** គឺអ្នកនឹងជាប់តាមខ្ញុំ ដោយអត្ថថា កាលខ្ញុំដើរ អ្នកក៏ដើរតាម កាលខ្ញុំឈរ អ្នកក៏ឈរក្បែរ ខ្ញុំអង្គុយ អ្នកក៏អង្គុយក្បែរ ខ្ញុំដេក អ្នកក៏

ដេកក្បែរ ។ បទថា **វត្ថុសាយិកោ** គឺជាអ្នកដេកក្នុងផ្ទះរបស់ខ្ញុំ ។ បទថា **យថាកាមករណីយោ ពាហិតេយ្យោ** សេចក្ដីថា អ្នកជាបុគ្គលត្រូវវត្ថុដែលខ្ញុំត្រូវការតាមការពេញចិត្តរបស់ខ្លួនខ្ញុំ និងកាលជញ្ជូនមក អ្នកក៏នឹងជាបុគ្គលដែលត្រូវធ្វើឲ្យទាបជាង ខ្ពីជាង សូម្បីតែដើមម្រះ ។ ព្រហ្មរមែងពោលបៀតបៀនព្រះមានព្រះភាគយ៉ាងនេះ ដោយពាក្យនេះ ឈ្មោះថា រមែងចាក់ដោតគឺព្រហ្ម ឈ្មោះថា ពោលបៀតបៀនយ៉ាងនេះថា ភិក្ខុ បើអ្នកទំពាស៊ីផែនដីនោះដោយតណ្ហាជាដើម អ្នកក៏នឹងជាអ្នកដេកក្បែរខ្ញុំ កាលខ្ញុំដើរ អ្នកក៏ដើរ ខ្ញុំឈរ អ្នកក៏ឈរ ខ្ញុំអង្គុយ អ្នកក៏អង្គុយ ខ្ញុំដេក អ្នកក៏ដេក ខ្ញុំនឹងរាប់អានអ្នក ហើយធ្វើឲ្យអ្នកជាមនុស្សជិតស្និទ្ធ ជាមនុស្សខាងក្នុង ។ ឯបទដ៏សេសឈ្មោះថា រមែងរុករាន ។ ក្នុងបទទាំងនេះ មានអធិប្បាយដូចតទៅនេះ ព្រហ្មឈ្មោះថា រមែងបៀតបៀនយ៉ាងនេះថា បើអ្នកទំពាស៊ីផែនដី អ្នកក៏នឹងក្លាយជាបុគ្គលដែល ដេកក្នុងផ្ទះខ្ញុំ កាលខ្ញុំដើរជាដើមហើយ សឹមអ្នកដើរឈរអង្គុយ ឬដេក នឹងកាន់យកនូវការរក្សាខ្ញុំក្នុងផ្ទះខ្ញុំ ខ្ញុំនឹងធ្វើអ្នកតាមសេចក្ដីប្រាថ្នា នឹងធ្វើអ្នកឲ្យជញ្ជូនវត្ថុណាមួយទៅ ធ្វើឲ្យទាបជាងគុម្ពនៃដើមម្រះ ។ តែព្រហ្មនេះអាស្រ័យការប្រកាន់ខ្លួន ដូច្នោះ ក្នុងទីនេះ ទើបសំដៅយកត្រឹមតែការរុករានប៉ុណ្ណោះ ក្នុងរឿងទឹកជាដើមក៏ទំនងនេះដូចគ្នា ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលត្រាស់ពាក្យជាដើមថា **អបិច តេ អហំ ព្រហ្មេ** ហើយទ្រង់គិតថា ព្រហ្មនេះអាស្រ័យការប្រកាន់ខ្លួន ទើបសម្គាល់ថា ខ្លួនរមែងដឹង ជាអ្នកត្រូវសន្មតដោយយសរបស់ខ្លួនឯង ទើបមិន

ឃើញអ្វីតិចតួចដែលអាចពាល់ត្រូវរាងកាយបាន គួរសង្កត់សង្កិនបន្តិចទៀត ទើបទ្រង់ផ្តើមទេសនានេះ ។

ក្នុងបទទាំងនោះ បទថា **គតិញ្ច បជានាមិ** សេចក្តីថា តថាគតរមែងដឹងច្បាស់នូវការសម្រេចផង ។ បទថា **ជុតិញ្ច** គឺតថាគតរមែងដឹងច្បាស់នូវអានុភាពផង ។ បទថា **ឯវំ មហេសក្ខោ** គឺជាអ្នកមានយសធំ មានបរិវារច្រើន ។ បទថា **យាវតា ចន្ទិមសុរិយា បរិហរន្តិ** គឺព្រះចន្ទ និងព្រះអាទិត្យគោចរទៅក្នុងទីមានប្រមាណប៉ុនណា ។ បទថា **ទិសា ភន្តិ វិរោចនា** គឺចាំងចែងនូវពន្លឺរុងរឿងក្នុងទិសទាំងឡាយ ឬទិសទាំងឡាយរមែងភ្លឺស្វាងរុងរឿង ព្រោះព្រះចន្ទ និងព្រះអាទិត្យទាំងនោះ ។ បទថា **តាវ សហស្សធា លោកោ** គឺលោកធាតុ ១ ពាន់ ដោយប្រមាណប៉ុណ្ណោះ អធិប្បាយថា ១ ពាន់ចក្រវាល រួមទាំងចក្រវាលនេះផង ។ បទថា **ឯត្ថ តេ វត្តតី វសោ** គឺអំណាចរបស់អ្នករមែងប្រព្រឹត្តទៅក្នុងចក្រវាល ១ ពាន់នេះ ។ បទថា **បរោបរញ្ច ជានាសិ** គឺអ្នករមែងស្គាល់សត្វដែលមានលំដាប់ផ្សេងគ្នា គឺខ្ពស់ ទាប អាក្រក់ ប្រណីត ក្នុង ១ ពាន់ចក្រវាឡនេះ ។ បទថា **អថោ រាគវិរាគិនំ** គឺមិនមែនស្គាល់តែសត្វដែលផ្សេងគ្នាថា បុគ្គលនេះជាធំក្រៃលែង បុគ្គលនេះជាមនុស្សប្រក្រតីដូច្នេះប៉ុណ្ណោះ តែនៅដឹងបុគ្គលដែលនៅមានរាគៈ និងប្រាសចាករាគៈ យ៉ាងនេះថា បុគ្គលនេះនៅមានរាគៈ បុគ្គលនេះប្រាសចាករាគៈហើយ ។ បទថា **ឥត្ថភាវញ្ញថាភាវំ** គឺចក្រវាលនេះ ហៅថា ភាពជាយ៉ាងនេះ ចក្រវាល ៩៩៩ ដ៏សេសអំពីនេះ ហៅថា ភាពជាយ៉ាងដទៃ ។

បទថា **សត្តានំ អាគតឹ គតឹ** គឺលោកដឹងច្បាស់នូវការមករបស់ពួកសត្វ ដោយអំណាចបដិសន្ធិ គតិ ដោយអំណាចចុតិក្នុងចក្រវាល ១ ពាន់នេះ ។ ព្រះមានព្រះភាគទ្រង់សង្កត់សង្កិនថា ការសម្គាល់តថាគតជាបុគ្គលធំក្រៃលែងជាងអ្នក អ្នកត្រឹមតែជាព្រហ្មក្នុងចក្រវាល ១ ពាន់ ចំណែកព្រហ្មដទៃមានអានុភាពច្រើនជាងអ្នក ២ ពាន់ ៣ ពាន់ ៤ ពាន់ ៥ ពាន់ ១ ម៉ឺន ១ សែន និងប្រមាណមិនបាន បែរជាមកធ្វើការសម្គាល់ថា អញធំ ដូចព្យាយាមយកសំពត់តូចតាច ៤ ហត្ថមកធ្វើជាខ្នាតសំពត់ ។ បទថា **ឥទ្ធូបបន្នោ** គឺបុគ្គលនោះដល់នូវជាន់នៃឈានទី ១ នេះ ។ បទថា **តេន តំ ត្វំ ន ជានាសិ** គឺព្រោះហេតុនោះ ទើបអ្នកមិនស្គាល់កាយនោះ ។ បទថា **នេវ តេ សម-សមោ** គឺបុគ្គលដែលដល់នូវឋានៈដែលគប្បីដឹងស្មើគ្នានឹងអ្នក ក៏មិនមែនជាតថាគត ។ បទថា **អភិញ្ញាយ** គឺដឹងក្រៃលែងទូទៅ ។ បទថា **កុតោនីចេយ្យំ** គឺភាពជាបុគ្គលទាបជាងអ្នកនឹងមានដល់តថាគតអំពីណា បានឮថា ព្រហ្មអង្គនេះ កើតខាងដើម គឺកាលមិនទាន់មានការកើតឡើងនៃព្រះពុទ្ធ បានបួសជាឥសី ធ្វើបរិកម្មកសិណ ឲ្យកើតសមាបត្តិ មិនសូន្យចាកឈាន ស្លាប់ហើយ ក៏កើត គឺបដិសន្ធិក្នុងព្រហ្មលោកជាន់វេហប្ផលា មានអាយុ ៥០០ កប្ប ក្នុងឈានទី ៤ កាលតាំងនៅក្នុងទីនោះ ក៏ធ្វើក្នុងកំណើតក្រោយ អប់រំក្នុងឈានទី ៣ យ៉ាងប្រណីត ទើបកើតកាន់យកអាយុ ៦៤ កប្ប ក្នុងព្រហ្មលោកជាន់សុភកិណ្ហា អប់រំឈានទី ២ ក្នុងឈាននោះ កើតកាន់យកអាយុ ៨ កប្ប ក្នុងជាន់អាភស្សរ ។ ក្នុងជាន់នោះ បានអប់រំឈានទី ១

ហើយ កើតជាបុគ្គលមានអាយុ ១ កប្ប ក្នុងឈានជាន់ទី ១ ។ ក្នុងកាលដំបូងឡើយ ព្រហ្មនេះ ដឹងបានសព្វគ្រប់ ទាំងកម្មដែលបានសាង ទាំងទីកន្លែងដែលកើត តែកាលវេលាកន្លងទៅ ព្រហ្មនេះភ្លេចអស់ទាំង ២ យ៉ាង ទើបកើតទិដ្ឋិឃើញថាទៀងមក ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់នឹងព្រហ្មនោះថា ម្នាលព្រហ្ម យ៉ាងនេះឯង តថាគតមិនមែនស្មើនឹងអ្នកទេ តថាគតដឹងច្បាស់ហើយ នឹងឲ្យថោកទាបជាងអ្នកដូចម្ដេចបាន តថាគតត្រូវតែប្រសើរជាងអ្នកដោយពិត ។

ពេលនោះ ព្រហ្មគិតថា ព្រះគោតមជាសមណៈ ដឹងទាំងអាយុ ទីកើត និងកម្មដែលសាងក្នុងកាលមុនរបស់អញ ណ្ហើយចុះ អញនឹងសួរដល់កម្មដែលសាងក្នុងកាលមុនជាមួយលោក ដូច្នេះហើយ ទើបទូលសួរបុព្វកម្មរបស់ខ្លួននឹងព្រះសាស្ដា ។ ទើបព្រះសាស្ដាត្រាស់ថា

បានឮថា ក្នុងកាលមុន ព្រហ្មនេះបានកើតក្នុងផ្ទះនៃត្រកូល ឃើញទោសក្នុងកាមទាំងឡាយហើយ ទើបគិតថា អញនឹងធ្វើទីបំផុតនៃការកើត ការចាស់ និងការស្លាប់ ហើយចេញទៅបួសជាឥសី ញ៉ាំងសមាបត្តិឲ្យកើតឡើង ហើយ ជាអ្នកបានឈាន មានអភិញ្ញាជាបាទ សាងបណ្ណសាលាក្បែរច្រាំងទន្លេគង្គា សម្រាប់ពេលវេលាដោយការត្រេកអរក្នុងឈាន ។

ក្នុងកាលនោះ មានពួកឈ្មួញរទេះ បររទេះ ៥០០ ឆ្លងសមុទ្រខ្សាច់មក ។ ក្នុងសមុទ្រខ្សាច់នោះ ពេលថ្ងៃទៅមិនបាន ទៅបានតែពេលយប់ ។ គ្រានោះ គោដែលទឹមក្នុងនឹមនៃរទេះទី ១ ដើរទៅហើយ ក៏ត្រឡប់បក

ក្រោយ តាមផ្លូវដដែលវិញ រទេះបន្ទាប់ៗ មក ក៏ត្រឡប់ទៅតាមគ្នា លុះដល់អរុណរះ ទើបដឹងថា រទេះបកក្រោយ ។ កាលនោះ ជាថ្ងៃធ្វងសមុទ្រខ្សាច់របស់ពួកបុគ្គលនោះ ពួកគេគិតថា ឧស និងទឹកអស់រលីង ព្រោះដូច្នោះ ពួកយើងនឹងស្លាប់ពិត ហើយក៏យកគោចងត្រង់កង់រទេះ ពួកមនុស្សនាំគ្នាចូលទៅដេកត្រង់ម្លប់រទេះ ។

ឯតាបសព្រឹកឡើង ចេញមកអំពីសាលាស្លឹក អង្គុយមើលទឹកស្ទឹងគង្គាត្រង់មាត់ទ្វារសាលានោះឯង បានឃើញពួកឈ្មួញហើយ កាលបានឃើញស្ទឹងគង្គា មានជំនន់ទឹកជំពេញ ហូរមក ដូចផ្ទារកែវមណី ទើបគិតថា ក្នុងលោកនេះ មានបុគ្គលណាហ្ន៎ ពួកសត្វណាហ្ន៎ ដែលកំពុងលំបាក ព្រោះមិនបានទឹកផ្ចាញ់បែបនេះ កាលលោកពិចារណាយ៉ាងនេះ ក៏បានឃើញក្រុមរទេះនោះក្នុងសមុទ្រខ្សាច់ ទើបគិតថា ចូរសត្វទាំងនោះ កុំវិនាសឡើយ ហើយអធិដ្ឋានដោយអភិញ្ញាចិត្តថា ចូរឲ្យផ្ទារទឹកធំ ហូរអំពីទីនេះតម្រង់ទៅរកក្រុមរទេះក្នុងសមុទ្រខ្សាច់ចុះ ។ ព្រមគ្នានឹងការគិត ទឹកក៏ហូរទៅកាន់សមុទ្រខ្សាច់នោះ ហាក់បីដូចឡើងមកតាមប្រឡាយ ។ ពួកមនុស្សនាំគ្នាក្រោកឡើងព្រោះសំឡេងទឹក បានជួបទឹក នាំគ្នាត្រេកអររីករាយ បានងូត បានផឹក ហើយឲ្យពួកគោផឹកទឹកស្រេច នាំគ្នាទៅកាន់ទីដែលខ្លួនត្រូវការដោយសួស្តី ។

ព្រះសាស្តា កាលទ្រង់សម្តែងបុព្វកម្មនោះរបស់ព្រហ្ម ទើបត្រាស់គាថានេះថា

អ្នកបានញុំាងពួកមនុស្សច្រើនដែលស្រេកទឹក លំបាកដោយកម្តៅថ្ងៃ

ឲ្យផឹកហើយ នុ៎ះឯងជាវត្តសមាទាន និងសីលវត្តរបស់អ្នកពីដើម តថាគត រឭកឃើញដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

ក្នុងសម័យដទៃទៀត តាបសធ្វើបណ្ណសាលា នៅអាស្រ័យត្រង់ស្រុកអ្នកព្រៃ ។ សម័យនោះឯង ពួកចោរប្លន់ស្រុកនោះ កាន់យករបស់មានតម្លៃជាប់ដៃ ហើយកៀងគោ និងចាប់អ្នកស្រុកធ្វើជាឈ្លើយទៅ ទាំងគោ ទាំងឆ្កែ ទាំងមនុស្សក៏នាំគ្នាស្រែករំពង តាបសបានឮសំឡេងនោះ ក៏ពិចារណាថា នេះសំឡេងអ្វីហ្ន៎ ក៏ដឹងថា ភ័យកើតឡើងដល់ពួកមនុស្ស ទើបគិតថា កាលអាត្មាអញឃើញ ចូរសត្វទាំងនេះកុំបីវិនាសឡើយ ហើយក៏ចូលឈានដែលមានអភិញ្ញាជាបាទ ចេញហើយ ក៏និម្មិតជាកងទ័ពដែលប្រកបដោយអង្គ ៤ ត្រៀមចាំ និងកំពុងដើរមក តាមផ្លូវដែលពួកចោរដើរទៅ ដោយអភិញ្ញាចិត្ត ។ ពួកចោរបានឃើញនាំគ្នាយល់ថា ជាព្រះរាជា ទើបចោលរបស់របរ ចៀសចេញទៅ តាបសអធិដ្ឋានថា ទ្រព្យណាជារបស់អ្នកណា ទ្រព្យនោះក៏ចូរជារបស់អ្នកនោះចុះ ។ របស់នោះក៏បានទៅជាយ៉ាងនោះឯង ។ មហាជន ក៏ដល់នូវសួស្តី ។ ព្រះសាស្តា កាលទ្រង់ចង្អុលបុព្វកម្មនេះរបស់ព្រហ្មនោះ ទើបត្រាស់គាថានេះថា

អ្នកបានដោះលែងនូវពួកជនឈ្លើយ ដែលចោរចាប់ នាំយកទៅ ទៀបឆ្នេរនៃស្ទឹងឈ្មោះឯណី នុ៎ះឯងជាវត្តសមាទាន និងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញដូចជាបុគ្គល ដេកលក់ហើយភ្ញាក់ឡើង ។

ពាក្យថា ឯណី ក្នុងទីនេះ សំដៅដល់ច្រាំងនៃស្ទឹងគង្គា ។

សម័យដទៃទៀត ត្រកូលដែលនៅតាមដងស្ទឹងគង្គាខាងលើ ធ្វើសន្ថវ-មេត្រីស្ថិតស្ថេរជាមួយត្រកូល ដែលនៅខាងក្រោមក្រសែទឹក នាំគ្នាចងក្បូនទូកឲ្យជាប់គ្នា ហើយនាំគ្នាដឹកជញ្ជូនយកចំណីអាហារ និងអណ្តាប់ គ្រឿងក្រអូបជាច្រើនមកដាក់ ហើយក៏មកតាមក្រសែទឹកក្នុងស្ទឹងគង្គានោះ ។ ពួកមនុស្សក៏នាំគ្នាបរិភោគ ច្រៀងរាំ ធ្វើភ្លេងយ៉ាងសុខសប្បាយ ដូចគ្នានឹងទេវវិមាន ។ នាគដែលកើតក្នុងស្ទឹងគង្គា ក៏ក្តៅក្រហាយថា មនុស្សទាំងនេះ មិនធ្វើសូម្បីតែសញ្ញាក្នុងអញ ឥឡូវនេះ អញនឹងឲ្យពួកវាទៅដល់សមុទ្រឲ្យបាន ។ រួចក៏និម្មិតរាងកាយធំ ញែកទឹកចេញជា ២ ចំណែក ផុសឡើងមក បើកពពារបញ្ចេញសំឡេងហ្វូៗ ។ មហាជនបានឃើញក៏ខ្លាច បន្លឺសំឡេងទ្រហឹង អឺងកង ។ តាបសអង្គុយត្រង់បណ្ណសាលា បានឮសំឡេងមនុស្សទាំងនោះ ក៏ពិចារណាថា មនុស្សទាំងនេះច្រៀងរាំ ដល់នូវសេចក្តីសុខ តែឥឡូវនេះ បែរជាស្រែកដូចជាខ្លាចស្លាប់ សេចក្តីនេះម្តេចហ្ន៎ បានឃើញស្តេចនាគ ទើបគិតថា អ្វីដែលអញឃើញ ចូរសត្វទាំងឡាយកុំវិនាសឡើយ ហើយក៏ចូលឈាន មានអភិញ្ញាជាបាទ លះសរីរៈដើម កាឡាភេទជាគ្រុឌ ហើយបង្ហាញចំពោះស្តេចនាគៗ ខ្លាច បិទពពារ មុជទៅក្នុងទឹក ។ មហាជនក៏ដល់នូវសួស្តី ។ កាលព្រះសាស្តាទ្រង់បង្អុលបុព្វកម្មនោះ ទើបត្រាស់គាថានេះថា

អ្នកបានគំរាមដោយកម្លាំងហើយដោះលែងនូវទូក ដែលនាគរាជ
អាក្រក់ បម្រុងនឹងពន្លិចបោលក្នុងខ្សែនៃទឹកស្ទឹង ព្រោះវាចង់ធ្វើ

មនុស្សឲ្យវិនាស នុ៎ះឯងជាវត្តសមាទាន និងសីលវត្តរបស់អ្នក
ពីដើម តថាគតរឭកឃើញដូចជាបុគ្គលដេកលក់ ហើយ
ភ្ញាក់ឡើង ។

សម័យឯទៀត ព្រហ្មអង្គនេះ បួសជាឥសី ឈ្មោះ កេសវៈ ។ កាលនោះឯង ព្រះពោធិសត្វនៃយើង ជាមាណពឈ្មោះកប្បៈ ជាកូនសិស្សជំនិតជាប់តាមកេសវៈ ទទួលធ្វើកិច្ចការងារទាំងពួង ជាអ្នកប្រព្រឹត្តត្រូវចិត្ត ដល់ព្រមដោយប្រាជ្ញា ជាអ្នកប្រព្រឹត្តប្រយោជន៍ ។ វៀរនាយកប្បៈហើយ កេសវៈក៏មិនអាចប្រព្រឹត្តទៅបាន ។ ព្រោះបានអាស្រ័យនាយកប្បៈនោះឯង ទើបកេសវៈចិញ្ចឹមជីវិតទៅបាន ។ ព្រះសាស្ដា កាលទ្រង់សម្ដែងបុព្វកម្មនេះរបស់ព្រហ្មនោះ ទើបត្រាស់ព្រះគាថានេះថា

តថាគតឈ្មោះ កប្បៈ ធ្លាប់ជាកូនសិស្សរបស់អ្នក តថាគតបាន
សម្គាល់ថា អ្នកជាបុគ្គលមានប្រាជ្ញា មានវត្តប្រតិបត្តិ នុ៎ះឯងជាវត្ត
សមាទាន និងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញ ដូច
ជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

ព្រះសាស្ដា ទ្រង់បានប្រកាសកម្មដែលធ្វើហើយ ក្នុងអត្តភាពផ្សេងៗរបស់ព្រហ្ម ដូចពោលមកនេះ ។ ខណៈដែលព្រះសាស្ដាកំពុងត្រាស់នោះឯង ព្រហ្មក៏កំណត់ហើយ ។ កម្មគ្រប់យ៉ាងរបស់ព្រហ្មនោះ ប្រាកដដូចរូបដែលប្រាកដ កាលប្រទីប ១០០០ ឆេះឡើង ដូច្នោះ ។ ព្រហ្មនោះមានចិត្តជ្រះថ្លាពោលគាថានេះថា

ព្រះអង្គជ្រាបច្បាស់នូវអាយុរបស់ខ្ញុំនុ៎ះដោយពិតផង ជ្រាបច្បាស់នូវហេតុដទៃផង ព្រះអង្គជាព្រះពុទ្ធមែន នេះជាអនុភាពដ៏រុងរឿងរបស់ព្រះអង្គ ដែលញុំាងព្រហ្មលោកឲ្យភ្លឺរុងរឿង ។

លំដាប់នោះ ទ្រង់ប្រកាសភាពជាអប្បមេយ្យបុគ្គលឲ្យក្រៃលែងឡើងដល់ព្រហ្មអង្គនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បឋវី ខោ អហំ ព្រហ្មេ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **បឋវិយា បឋវត្តេន អននុភូតំ** សេចក្ដីថា មិនប្រព្រឹត្តទៅតាម បានដល់ មិនដល់ព្រោះភាពជាផែនដីនៃផែនដី ។ សួរថា នុ៎ះបានដល់អ្វី ឆ្លើយថា បានដល់ ព្រះនិព្វាន ។ ព្រះនិព្វាននោះ ឈ្មោះថា មិនដល់ដោយភាពជាផែនដី ព្រោះព្រះនិព្វាននោះ ផុតចាកសភាវៈដែលត្រូវបច្ច័យគ្រប់យ៉ាងតាក់តែង ។ បទថា **តទភិញ្ញាយ** សេចក្ដីថា ដឹង គឺធ្វើព្រះនិព្វាននោះឲ្យជាក់ច្បាស់ហើយ ។ បទថា **បឋវី នាបហោសឹ** សេចក្ដីថា តថាគតមិនប្រកាន់ផែនដី ដោយការកាន់យកដោយអំណាចតណ្ហា ទិដ្ឋិ និងមានះ ។ សូម្បីក្នុងទឹកជាដើម ក៏មានទំនងដូចគ្នានេះឯង ។ ឯសេចក្ដីពិស្ដារ គប្បីជ្រាបតាមបែបដែលពោលហើយ ក្នុងមូលបរិយាយសូត្រនោះឯង ។ ព្រហ្មនេះសម្ដែងអក្ខរៈថា ទាំងអស់ ព្រោះភាពដែលខ្លួនជាអ្នកពោលពាក្យនេះថា ណ្ហើយចុះ បពិត្រព្រះអង្គអ្នកនិទ៌ុក ទាំងអស់ ព្រោះអត្ថថា ទាំងអស់ ហើយយកការខុសក្នុងអក្ខរៈមកពោល ។ តែព្រះសាស្ដាទ្រង់ជាអ្នកអាច ទើបទ្រង់សំដៅយកវត្ថុណា មកត្រាស់ថា **សព្វំ** ។ ទើបព្រហ្មពោលថា ព្រះអង្គសំដៅយកពាក្យថា **សព្វំ** មកពោល

ទាំងអស់ ព្រះអង្គពោលថា មិនប្រព្រឹត្តទៅតាម ព្រោះអត្ថថា ទាំងអស់ បើវត្ថុមិនប្រព្រឹត្តទៅតាមទាំងអស់មិនមាន វត្ថុដែលមិនប្រព្រឹត្តទៅតាមវត្ថុនោះក៏មាន សូមឲ្យពាក្យរបស់ព្រះអង្គ កុំជាពាក្យសោះសូន្យប៉ុណ្ណោះឡើយ កុំជាពាក្យទទេៗ ប៉ុណ្ណោះឡើយ ហើយក៏សង្កត់សង្កិនព្រះសាស្តា ដោយមុសាវាទថា សូមកុំឲ្យពាក្យរបស់ព្រះអង្គសោះសូន្យទទេ ឥតអំពើឡើយ ដូច្នេះ ។

ឯព្រះសាស្តា ទ្រង់ជាអ្នកពោលក្រៃលែងជាងព្រហ្មនេះរាប់រយរាប់ពាន់ដង ដូច្នោះ កាលទ្រង់នាំយកហេតុមកដើម្បីញាំញីពាក្យរបស់ព្រហ្មនោះថា តថាគតនឹងពោលដល់សភាវៈទាំងអស់ តថាគតនឹងពោលសភាវៈដែលមិនមានអ្វីប្រព្រឹត្តទៅតាម ចូរស្តាប់តថាគត ទើបត្រាស់ថា **វិញ្ញាណំ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **វិញ្ញាណំ** សេចក្តីថា គប្បីដឹងជាក់ច្បាស់ ។ បទថា **អនិទស្សនំ** សេចក្តីថា ឈ្មោះថា ឃើញមិនបាន ព្រោះមិនចូលកាន់គន្លងនៃចក្ខុវិញ្ញាណ ។ ដោយបទទាំង ២ នេះ ព្រះមានព្រះភាគត្រាស់ដល់ព្រះនិព្វាននោះឯង ។ បទថា **អនន្តំ** សេចក្តីថា ឈ្មោះថា មិនមានទីបំផុត ព្រោះព្រះនិព្វាននេះ វៀរចាកចន្លោះនៃការកើត និងការវិនាស ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា

សត្វទាំងឡាយ មានទីបំផុត ព្រះនិព្វានដែលមិនកើត មិនមានទីបំផុត សត្វទាំងឡាយ មិនប្រាកដក្នុងទីបំផុត តថាគតបានប្រកាសទីបំផុតក្នុងសត្វហើយ ។

បទថា **សព្វតោបភំ** បានដល់ សម្បូរដោយពន្លឺដោយប្រការទាំងពួង ពិតហើយ ក្រៅអំពីព្រះនិព្វានហើយ មិនមានធម៌ដទៃដែលមានពន្លឺជាង មានឱកាសជាង មានទីបំផុតដែលបរិសុទ្ធជាង ឬសជាងឡើយ ម្យ៉ាងទៀត ព្រះនិព្វានជាដែនកើតចាកទីទាំងពួងនោះឯង ក្នុងទីឯណានីមួយមិនមែនមិនមានឡើយ ព្រោះដូច្នោះ ទើបឈ្មោះថា ជាដែនកើតដោយប្រការទាំងពួង ពិតហើយ ក្នុងទិសខាងកើតជាដើម ឈ្មោះថា ក្នុងទិសនោះមិនគប្បីពោលថា មិនមានព្រះនិព្វាន ។ ម្យ៉ាងទៀត បទថា **បភំ** ជាឈ្មោះរបស់កំពង់ ។ ឈ្មោះថា មានកំពង់គ្រប់កន្លែង ព្រោះគ្រប់កន្លែងមានកំពង់ ( សម្រាប់ចុះ )។ បុគ្គលពោលទាក់ទងនឹងព្រះនិព្វានថា បុគ្គលចង់ចុះមហាសមុទ្រ ដោយទីណាៗ ទីនោះៗ ហើយ រមែងជាកំពង់ ឈ្មោះថា ដែលមិនមែនកំពង់ រមែងមិនមាន យ៉ាងណា ក្នុងកម្មដ្ឋាន ៣៨ បុគ្គលបំណងនឹងចូលទៅព្រះនិព្វានដោយកម្មដ្ឋានសំខាន់ណាមួយ កម្មដ្ឋាននោះឯង រមែងជាកំពង់ មិនមានកម្មដ្ឋានដែលឈ្មោះថា មិនមែនជាកំពង់របស់ព្រះនិព្វានឡើយ ដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **សព្វតោបភំ** ។ បទថា **តំ បឋវិយា បឋវត្តេន** ព្រោះអត្ថថា ផែនដី សេចក្តីថា ព្រះនិព្វាននោះ ជាសភាវៈមិនប្រព្រឹត្តទៅតាមផែនដី ព្រោះអត្ថថា ផែនដីនឹងមិនប្រព្រឹត្តទៅតាមទឹកជាដើម ដទៃអំពីផែនដីនោះ ព្រោះសភាពនៃទឹកជាដើម ។ ព្រះមានព្រះភាគទ្រង់តាំងព្រះតម្រាស់ថា ធម្មជាតដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ជាវិស័យនៃបុគ្គលដូចជាអ្នកឯណា ធម្មជាតនោះ ជាធម្មជាតដែលគប្បីដឹងច្បាស់

ឃើញមិនបាន មិនមានទីបំផុត កំពង់គ្រប់កន្លែង ជាធម្មជាតដែលមិនប្រព្រឹត្ត ទៅតាមអ្វីមួយឡើយ ព្រោះអត្ថថា ទាំងអស់នៃធម្មជាតទាំងអស់នោះ ដូច្នេះ ។

លំដាប់នោះ ព្រហ្ម ត្រូវព្រះសាស្តាទូន្មានឲ្យលះបង់នូវវត្ថុដែលប្រកាន់ ហើយ កាលសម្លឹងមិនឃើញធម៌ណាមួយ ដែលគប្បីកាន់យក ក៏ប្រាថ្នានឹង ធ្វើលទ្ធិ ទើបពោលថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ណ្ហើយចុះ ខ្ញុំនឹងបំបាត់ខ្លួន អំពីព្រះអង្គឥឡូវនេះ ។ ក្នុងបទទាំងនោះ បទថា **អន្តរធាយាមិ** សេចក្តីថា ព្រហ្មពោលថា ខ្ញុំនឹង ធ្វើបាដិហារ្យមិនឲ្យអ្នកណាឃើញ ។ បទថា **សចេ វិសហសិ** សេចក្តីថា បើអ្នកអាច ក៏ចូរធ្វើបាដិហារ្យដែលបាត់ខ្លួនបានពិតៗ ដើម្បីការបាត់ខ្លួនដល់តថាគតចុះ ។ បទថា **នេវស្សុ មេ សក្កោតិ អន្តរ-ធាយិតុំ** សេចក្តីថា អ្នកមិនអាចដើម្បីកំបាំងខ្លួនដល់តថាគតបានទេ ។ សួរ ថា ព្រហ្មនេះជាអ្នកប្រាថ្នានឹងធ្វើអ្វី ឆ្លើយថា ជាអ្នកប្រាថ្នាដើម្បីទៅបដិសន្ធិ ដូចដើម ។ ពិតហើយ អត្តភាពដែលបានអំពីបដិសន្ធិដូចដើមរបស់ពួកព្រហ្ម ជាវត្ថុល្អិត ជាទីពឹងដល់អ្នកដទៃមិនបាន រមែងតាំងនៅដោយកាយដែលត្រូវ សាងក្រៃលែងនោះឯង ។ ព្រះសាស្តាមិនប្រទានដើម្បីទៅកាន់បដិសន្ធិដូចដើម ដល់ព្រហ្មនោះ ។ កាលមិនទៅបដិសន្ធិដូចដើម ព្រហ្មគប្បីធ្វើខ្លួនឲ្យបាត់ទៅ ហើយជាអ្នកមិនមានអ្នកណាមើលឃើញដោយការងងឹតណា ព្រះសាស្តាក៏ ទ្រង់បន្ទោបង់នូវងងឹតនោះចេញហើយ ព្រោះដូច្នោះ ទើបព្រហ្មមិនអាចបាត់ ខ្លួនបាន កាលព្រហ្មមិនអាចលាក់ខ្លួនក្នុងវិមាន ទើបពួនត្រង់ដើមកប្បព្រឹក្ស អង្គុយប្រហោង ។ ពួកព្រហ្មក៏ធ្វើការចំអកថា ពកព្រហ្មនេះ ពួនក្នុងវិមាន

ពួនត្រង់ដើមកប្បព្រឹក្ស អន្តយប្រហោង ។ ព្រហ្មអ្នកឈ្មោះថា រមែងញុំាង ឲ្យកើតសញ្ញាថា អ្នកបំបាំងខ្លួន ត្រូវពួកព្រហ្មចំអក ក៏សែនខ្មាសអៀន ។

បទថា **ឯវំ វុត្តេ អហំ ភិក្ខវេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កាល ព្រហ្មនោះពោលយ៉ាងនោះថា ណ្ហើយចុះ បើយ៉ាងនោះ ខ្ញុំនឹងបំបាំងខ្លួន តថាគតមើលឃើញថា ព្រហ្មនោះមិនអាចបាត់ខ្លួនបាន ទើបបានពោលពាក្យ នេះ ។ បទថា **ឥមំ គាថមភាសឹ** សេចក្តីថា សួរថា ហេតុអ្វី ទើបព្រះ មានព្រះភាគបានត្រាស់គាថា ឆ្លើយថា ព្រះមានព្រះភាគទ្រង់គិតថា ពួកព្រហ្ម ចូរកុំមានឱកាស ពោលយ៉ាងនេះថា អ្នកណាអាចជ្រាបបានយ៉ាងណាថា ក្នុង ទីនេះ មានព្រះគោតមជាសមណៈ ឬមិនមាន ទើបត្រាស់ព្រះគាថា ហើយ ទ្រង់បាត់ព្រះកាយទៅ ។

ក្នុងបទទាំងនោះ បាទព្រះគាថាថា **ភវេវាហំ ភយំ ទិស្វា** សេចក្តីថា តថាគតបានមើលឃើញភ័យក្នុងភពដោយពិត ។ បាទព្រះគាថាថា **ភវញ្ច វិភវេសិនំ** សេចក្តីថា ឃើញភពរបស់សត្វទាំង ៣ យ៉ាង មានកាមភព ជាដើមនេះ ឃើញអ្នកស្វែងរកភព គឺកំពុងស្វែងរក បានដល់ ស្វះស្វែងរក នូវភព និងឃើញភ័យក្នុងភពនោះឯងរឿយៗ ។ បទថា **ភវំ នាភិវទឹ** សេចក្តីថា មិនកន្ទក់កន្ទេញ គឺមិនស្វែងរកភពណាមួយ ដោយអំណាចតណ្ហា និងទិដ្ឋិ ។ បាទគាថាថា **នន្ទិញ្ច ន ឧបាទិយឹ** សេចក្តីថា មិនចូលដល់ គឺមិន បានកាន់យកតណ្ហាក្នុងភព ។ ព្រះសាស្តាទ្រង់ប្រកាសអរិយសច្ច ៤ ទ្រង់ សម្តែងធម៌ ដោយប្រការដូច្នេះ ។

កាលទ្រង់បញ្ចប់ធម្មទេសនា ព្រហ្មប្រមាណមួយម៉ឺនអង្គ ញ៉ាំងវិបស្សនាឲ្យកាន់យកគតិ តាមគន្លងនៃទេសនា ហើយក៏ផឹកនូវទឹកអម្រឹត គឺមគ្គ និងផល ។

[ ១៩៥ ] បទថា **អច្ឆរិយព្ភុតចិត្តជាតា** សេចក្តីថា ជាអ្នកកើតសេចក្តីអស្ចារ្យចម្លែកក្នុងចិត្ត និងកើតសេចក្តីត្រេកអរហើយ ។ បាទព្រះគាថាថា **សម្ពលំ ភវំ ឧឧព្ពហិ** សេចក្តីថា ទ្រង់ដក គឺទ្រង់ភើចកន្ទ្រាក់ បានដល់ទ្រង់ដកឡើងនូវភព ព្រមទាំងឫសគល់របស់ទេវតា និងមនុស្សដ៏ច្រើន ពួកដទៃដោយទេសនានោះៗ របស់ព្រះអង្គត្រង់មណ្ឌលពោធិព្រឹក្ស ។

ក្នុងសម័យនោះ មារមានចិត្តបាប ត្រូវសេចក្តីក្រោធគ្របសង្កត់ហើយគិតថា កាលអញកំពុងអន្ទោលទៅនោះឯង ព្រហ្មប្រមាណមួយម៉ឺនអង្គប្រព្រឹត្តទៅ កន្លងអំណាចអញបាន ព្រោះព្រះសមណគោតម សម្តែងនូវធម៌ក៏ចូលសណ្ឋិតក្នុងរាងកាយរបស់ព្រហ្មបារិសជ្ជៈមួយអង្គ ព្រោះភាពជាអ្នកមានសេចក្តីក្រោធគ្របសង្កត់ហើយ ដើម្បីទ្រង់សម្តែងមារនោះ ទើបត្រាស់ថា **អជេវា ភិក្ខុវេ** ដូច្នេះជាដើម ។

[ ១៩៦ ] បណ្តាបទទាំងនោះ បទថា **សចេ ត្វំ ឯវំ អនុពុទ្ធោ** សេចក្តីថា បើបុគ្គលនោះ មកតាមត្រាស់ដឹងនូវអរិយសច្ច ៤ ដោយខ្លួនយ៉ាងនេះ ។ បទថា **មា សាវកេ ឧបនេសិ** សេចក្តីថា កុំបង្អោនយកធម៌នោះ ចូលទៅក្នុងសាវកដែលជាគ្រហស្ថ ឬសាវកដែលជាបព្វជិត ។ បទថា **ហីនេ កាយេ បតិដ្ឋិតា** សេចក្តីថា តាំងនៅក្នុងអបាយទាំង ៤ ។ បទថា **បណីតេ កាយេ**

**បតិដ្ឋិតា** សេចក្តីថា តាំងនៅក្នុងព្រហ្មលោក ។ ព្រះមានព្រះភាគត្រាស់ពាក្យនេះ សំដៅយកសត្វពួកណា ត្រាស់សំដៅយកពួកតាបស និងបរិព្វាជកដែលជាអ្នកបួសក្នុងលទ្ធិខាងក្រៅ ។ មានសេចក្តីពិតថា កាលមិនទាន់កើតយុគនៃការកើតរបស់ព្រះពុទ្ធ ពួកកុលបុត្របួសជាតាបស មិនជ្រើសរើសវត្ថុណាមួយ ត្រាច់ទៅតែម្នាក់ឯង ញ៉ាំងសមាបត្តិឲ្យកើត ហើយចូលដល់ព្រហ្មលោក ។ ព្រះមានព្រះភាគត្រាស់សំដៅយកបុគ្គលទាំងនោះ ។ បាទគាថាថា **អនក្ខាតំ កុសលញ្ហិ មារិសា** សេចក្តីថា អ្នកនិទ៌ុក្ខ អ្នកមិនបានអាស្រ័យដល់កុសល មិនប្រៀនប្រដៅ មិនពោលធម្មកថាដល់អ្នកដទៃសេចក្តីនោះជាការល្អ ។ បទថា **មា បរំ ឱវទាហិ** សេចក្តីថា លោកកុំខាតពេលត្រាច់ទៅស្វែងរកមនុស្សលោក ទេវលោក ព្រហ្មលោក នាគលោកឡើយ ចូរអន្តុយសម្រាប់ពេលវេលា ដោយភាពជាសុខក្នុងឈាន ក្នុងមគ្គនិងក្នុងផល ក្នុងទីនេះឯង ។ បទថា **អនាលបនតាយ** សេចក្តីថា ព្រោះភាពជាអ្នកបរបោមិនកើតការ ព្រោះភាពជាអ្នកមិនចរចាវែកញែក ។ បទថា **ព្រហ្មុនោ ច អភិនិមន្តនតាយ** សេចក្តីថា ព្រោះពាក្យអារាធនារបស់ពកព្រហ្ម ដោយតំណែងនៃព្រហ្មដែលមានឱកាស ព្រមដោយន័យជាដើមថាបពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ធម្មតាស្ថានព្រហ្មនេះ ជាទីទៀង ។ បទថា **តស្មា** ប្រែថា ព្រោះហេតុនោះ ។ បទថា **ព្រហ្មនិមន្តនិក** នោះឯង ជាឈ្មោះជាពាក្យសម្រាប់រាប់ ជាពាក្យដែលដឹងព្រមគ្នា ជាពាក្យតែងតាំងកើតហើយ

តែជាពាក្យកម្រេងកែវនេះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ឆាយយល់ទាំងអស់ហើយ ដូច្នេះ ។

## ព្រហ្មនិមន្តនិកសូត្រ ចប់
## សូត្រទី ៩ ចប់

# សុត្តន្តបិដក

## មារតជ្ជនីយសូត្រទី ១០

[ ១៩៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងឈ្មោះ សុំសុមារគិរៈ ក្នុងភគ្គជនបទ ។ គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ ចង្ក្រមក្នុងទីវាល ។ សម័យនោះ មារមានចិត្តបាប បានចូលទៅនៅក្នុងផ្ទៃ សម្ងំក្នុងពោះវៀនរបស់ព្រះមហាមោគ្គល្លានមានអាយុ ។ លំដាប់នោះ ព្រះ មហាមោគ្គល្លានមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ដូចម្តេចហ្ន៎ បានជា ផ្ទៃរបស់អាត្មាអញ ធ្ងន់ៗ ហាក់ដូចជាសណ្តែករាជមាសទទឹក ដូច្នេះ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានមានអាយុ ចុះមកអំពីចង្ក្រមចូលទៅកាន់ វិហារហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលប្រគេន ។ លុះព្រះមហា មោគ្គល្លានមានអាយុអង្គុយហើយ ទើបពិចារណាឃើញនូវមារមានចិត្តបាប ដោយឧបាយចិត្តជារបស់ខ្លួន ។

[ ១៩៨ ] ព្រះមហាមោគ្គល្លានមានអាយុ បានឃើញមារដែលមានចិត្ត បាបនោះ ចូលក្នុងផ្ទៃសម្ងំនៅក្នុងពោះវៀន លុះឃើញហើយ ក៏បាននិយាយ នឹងមារមានចិត្តបាបដូច្នេះថា ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ ម្នាល មារមានចិត្តបាប អ្នកចូរចេញទៅ អ្នកកុំបៀតបៀនព្រះតថាគត កុំបៀតបៀន សាវ័កព្រះតថាគតឡើយ ការបៀតបៀនដែលប្រព្រឹត្តទៅដើម្បីសេចក្តីមិន ចម្រើន ដើម្បីសេចក្តីទុក្ខអស់កាលជាអង្វែង កុំមានដល់អ្នកឡើយ ។ គ្រា

នោះ មារមានចិត្តបាប មានសេចក្តីត្រិះរិះយ៉ាងនេះថា សមណៈមិនដឹង មិនស្គាល់អញទេ បានជានិយាយយ៉ាងនេះថា ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ អ្នកកុំបៀតបៀនព្រះតថាគត កុំបៀតបៀនសាវកព្រះតថាគតឡើយ ការបៀតបៀនដែលប្រព្រឹត្តទៅដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីទុក្ខអស់កាលជាអង្វែង កុំមានដល់អ្នកឡើយ សូម្បីគ្រូនៃសាវកនោះ ក៏មិនគប្បីស្គាល់អាត្មាអញបានដោយឆាប់រហ័ស ចំណង់បើសាវកនេះនឹងស្គាល់អាត្មាអញដូចម្តេចបាន ។ លំដាប់នោះ ព្រះមហាមោគ្គល្លានមានអាយុ បាននិយាយនឹងមារមានចិត្តបាប យ៉ាងនេះថា ម្នាលមារមានចិត្តបាប អាត្មាស្គាល់អ្នកច្បាស់ហើយ អ្នកកុំមើលងាយថា ឥតមានអ្នកណាស្គាល់អញយ៉ាងនេះដូច្នេះ ម្នាលមារមានចិត្តបាប អ្នកហ្នឹងហើយជាមារ ម្នាលមារមានចិត្តបាប ឯអ្នកតែងមានសេចក្តីត្រិះរិះយ៉ាងនេះថា សមណៈនេះមិនស្គាល់អញ មិនឃើញអញទេ បានជានិយាយយ៉ាងនេះថា ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ អ្នកកុំបៀតបៀនព្រះតថាគត កុំបៀតបៀនសាវកព្រះតថាគតឡើយ ការបៀតបៀនដែលប្រព្រឹត្តទៅដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីទុក្ខអស់កាលជាយូរអង្វែង កុំមានដល់អ្នកឡើយ សូម្បីគ្រូនៃសាវកនោះ ក៏មិនគប្បីស្គាល់អាត្មាអញបានដោយឆាប់រហ័ស ចំណង់បើសាវកនេះនឹងស្គាល់អាត្មាអញដូចម្តេចបាន ។ លំដាប់នោះ មារមានចិត្តបាប មានសេចក្តីត្រិះរិះយ៉ាងនេះថា សមណៈនេះស្គាល់ ឃើញអាត្មាអញមែន បានជានិយាយយ៉ាងនេះ

ថា ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ អ្នកកុំបៀតបៀនព្រះតថាគត កុំបៀតបៀនសាវករបស់ព្រះតថាគតឡើយ ការបៀតបៀនដែលប្រព្រឹត្តទៅដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីទុក្ខអស់កាលជាអង្វែង កុំមានដល់អ្នកឡើយ ។ គ្រានោះ មារមានចិត្តបាបឡើងមកតាមមាត់នៃព្រះមហាមោគ្គល្លានមានអាយុ មកឋិតនៅត្រង់សន្ទះទ្វារ ។

[ ១៩៩ ] ព្រះមហាមោគ្គល្លានមានអាយុ បានឃើញមារមានចិត្តបាបនោះ មកឋិតនៅត្រង់សន្ទះទ្វារ លុះឃើញហើយ ទើបនិយាយនឹងមារមានចិត្តបាបយ៉ាងនេះថា ម្នាលមារមានចិត្តបាប អាត្មាឃើញអ្នកក្នុងទីនេះដែរ អ្នកកុំមើលងាយថា មិនមានអ្នកណាឃើញអាត្មាអញដូច្នេះឡើយ ម្នាលមារមានចិត្តបាប អ្នកទុំឋិតនៅត្រង់សន្ទះទ្វារ ។ ម្នាលមារមានចិត្តបាប កាលពីដើមមក អាត្មាបានកើតជាមារឈ្មោះ ទូសី ប្អូនស្រីរបស់អាត្មានោះ ឈ្មោះនាងកាឡី ឯនអ្នកជាកូនប្រុសរបស់ប្អូនស្រីនោះ អ្នកនោះត្រូវជាក្មួយរបស់អាត្មា ។ ក៏សម័យនោះ ព្រះមានព្រះភាគទ្រង់ព្រះនាមកកុសន្ធៈ ជាអរហន្តសម្មាសម្ពុទ្ធត្រាស់ឡើងក្នុងលោក ។ ម្នាលមារមានចិត្តបាប ព្រះមានព្រះភាគ ទ្រង់ព្រះនាមកកុសន្ធៈ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់មានគូមហាសាវក ឈ្មោះ វិធុរៈ ១ ឈ្មោះ សញ្ជីវៈ ជាគូដ៏ប្រសើរ ដ៏ចម្រើន ។ ម្នាលមារមានចិត្តបាប ពួកសាវករបស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមកកុសន្ធៈ ជាអរហន្តសម្មាសម្ពុទ្ធក្នុងសាសនានេះ មិនមានសាវកណាមួយស្មើនឹងវិធុរៈមានអាយុ ក្នុងការសម្តែងធម៌ឡើយ ។ ម្នាលមារមានចិត្តបាប ដោយហេតុនេះ វិធុរៈមានអាយុ

មានឈ្មោះថា វិធុរៈ វិធុរៈដូច្នេះកើតប្រាកដឡើង ។ ម្នាលមារមានចិត្តបាប ចំណែកខាងសញ្ជីវៈមានអាយុនៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងតែចូលសញ្ញាវេទយិតនិរោធ ដោយសេចក្តីលំបាកតិច ។ ម្នាលមារមានចិត្តបាប កាលពីដើមមក សញ្ជីវៈមានអាយុ អង្គុយចូលសញ្ញាវេទ-យិតនិរោធក្រោមម្លប់ឈើមួយដើម ។ ម្នាលមារមានចិត្តបាប ពួកអ្នករក្សាគោ ពួកអ្នករក្សាពពែ ពួកអ្នកភ្ជួររាស់ និងពួកអ្នកដំណើរបានឃើញសញ្ជីវៈមានអាយុ កំពុងអង្គុយចូលសញ្ញាវេទយិតនិរោធ ក្រោមម្លប់ឈើមួយដើម លុះឃើញហើយ ពួកជនទាំងនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អើ នេះអស្ចារ្យណាស់ហ្ន៎ អើ មិនដែលមានទេហ្ន៎ សមណៈនេះអង្គុយធ្វើមរណ-កាលទៅហើយ បើដូច្នោះ យើងនឹងនាំគ្នាបូជាសពលោក ។ ម្នាលមារមានចិត្តបាប គ្រានោះ ពួកអ្នករក្សាគោ ពួកអ្នករក្សាពពែ ពួកអ្នកភ្ជួររាស់ និងពួកអ្នកដំណើរនោះ ប្រមូលនូវស្មៅ ឧស និងអាចម៍គោ មករុំកាយព្រះសញ្ជីវៈមានអាយុហើយ ក៏ដុតភ្លើង ហើយចៀសចេញទៅ ។ ម្នាលមារមានចិត្តបាប គ្រានោះ ព្រះសញ្ជីវៈមានអាយុ លុះកន្លងរាត្រីនោះទៅ ទើបចេញអំពីសមាបត្តិនោះ ក៏រលាស់ចីវរ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរចូលទៅកាន់ស្រុកដើម្បី បិណ្ឌបាតក្នុងវេលាព្រឹកព្រហាម ។ ម្នាលមារមានចិត្តបាប ពួកអ្នករក្សាគោ ពួកអ្នករក្សាពពែ ពួកអ្នកភ្ជួររាស់ និងពួកអ្នកដំណើរទាំងនោះ បានឃើញព្រះសញ្ជីវៈមានអាយុ កំពុងត្រាច់ទៅបិណ្ឌបាតហើយ ពួកជនទាំងនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អើ អស្ចារ្យណាស់ហ្ន៎ អើ

មិនដែលមានទេហ្ន៎ សមណៈនេះ អន្តិយធ្វើមរណកាលទៅហើយ ឥឡូវ សមណៈនេះ ត្រឡប់មានសញ្ញាឋិតនៅវិញ ។ ម្នាលមារមានចិត្តបាប ដោយហេតុនេះ ព្រះសញ្ជីវៈមានអាយុ មានឈ្មោះថា សញ្ជីវៈ សញ្ជីវៈ កើតឡើងយ៉ាងនេះឯង ។

[ ២០០ ] ម្នាលមារមានចិត្តបាប គ្រានោះ ទូសីមារមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញមិនបានដឹងដំណើរមក និងដំណើរទៅរបស់ពួកភិក្ខុដែលមានសីល មានកល្យាណធម៌ទាំងនេះសោះឡើយ បើដូច្នោះ គួរតែអាត្មាអញចូលជ្រែកសរីរៈពួកព្រាហ្មណ៍ និងគហបតីថា អ្នកទាំងឡាយ ចូរមក ចូរជេរ គំរាម ប្រទូស្ត បៀតបៀនពួកភិក្ខុដែលមានសីល មានធម៌ជាកុសល គិតដូចម្តេចនឹងធ្វើចិត្តរបស់ពួកភិក្ខុ ដែលពួកអ្នកជេរ គំរាម ប្រទូស្ត បៀតបៀនហើយនោះ ឲ្យរាយមាយ ល្មមឲ្យទូសីមារបានឱកាសនោះ ។ ម្នាលមារមានចិត្តបាប គ្រានោះ ទូសីមារ បានចូលជ្រែកសរីរៈពួកព្រាហ្មណ៍ និងគហបតីថា អ្នកទាំងឡាយចូរមក ចូរជេរ គំរាម ប្រទូស្ត បៀតបៀនពួកភិក្ខុដែលមានសីល មានធម៌ជាកុសល គិតដូចម្តេចនឹងធ្វើចិត្តរបស់ពួកភិក្ខុ ដែលពួកអ្នកជេរ គំរាម ប្រទូស្ត បៀតបៀនហើយនោះ ឲ្យរាយមាយ ល្មមឲ្យទូសីមារបានឱកាសនោះ ។ ម្នាលមារមានចិត្តបាប ពួកព្រាហ្មណ៍ និងគហបតីនោះ ដែលទូសីមារចូលជ្រែកសរីរៈហើយ ទើបនាំគ្នាជេរ គំរាម ប្រទូស្ត បៀតបៀនពួកភិក្ខុដែលមានសីល មានធម៌ជាកុសលថា ពួកសមណៈមានក្បាលរលីងទាំងនេះ ជាគហបតី ជាកណ្ហគោត្រ កើតអំពីបាទាព្រហ្ម

មានកឱនចុះ មានមុខសំយុងចុះ មានអាការដូចជាមធុរកជាតិ គឺជាតិអ្នកខ្ជិលច្រអូស តែងសញ្ជប់សញ្ជឹងសំកុកជ្រប់នៅ ដោយគិតថា យើងទាំងឡាយជាអ្នកមានឈាន យើងទាំងឡាយជាអ្នកមានឈាន ដូច្នេះ ។ ដូចជាសត្វមៀមស្វែងរកកណ្តុរលើមែកឈើ តែងសញ្ជប់សញ្ជឹង សំកុកជ្រប់នៅ យ៉ាងណា ពួកសមណៈមានក្បាលរលីង ជាគហបតី ជាកណ្ហគោត្រ ជាអ្នកកើតអំពីបាទាព្រហ្មនេះ មានកឱនចុះ មានមុខសំយុងចុះ មានអាការដូចមធុរកជាតិ តែងសញ្ជប់សញ្ជឹងសំកុកជ្រប់នៅ ដោយគិតថា យើងទាំងឡាយជាអ្នកមានឈាន យើងទាំងឡាយជាអ្នកមានឈាន ដូច្នេះ ក៏យ៉ាងនោះ ។ ឬដូចជាសត្វចចកស្វែងរកត្រីក្បែរច្រាំងស្ទឹង តែងសញ្ជប់សញ្ជឹងសំកុកជ្រប់នៅយ៉ាងណា ពួកសមណៈមានក្បាលរលីងទាំងនេះ ជាគហបតី ជាកណ្ហគោត្រ ជាអ្នកកើតអំពីបាទាព្រហ្ម មានកឱនចុះ មានមុខសំយុងចុះ មានអាការដូចមធុរកជាតិ តែងសញ្ជប់សញ្ជឹងសំកុកជ្រប់នៅ ដោយគិតថា យើងទាំង-ឡាយជាអ្នកមានឈាន យើងទាំងឡាយជាអ្នកមានឈាន ដូច្នេះ ក៏យ៉ាងនោះដែរ ។ ឬក៏ដូចជាសត្វឆ្មា ស្វែងរកកណ្តុរទៀបជញ្ជាំងផ្ទះ និងទសម្រាប់បង្ហូរទឹកសម្អុយ និងគំនរសំរាម តែងសញ្ជប់សញ្ជឹង សំកុកជ្រប់នៅយ៉ាងណា ពួកសមណៈមានក្បាលរលីងទាំងនេះ ជាគហបតី ជាកណ្ហគោត្រ កើតអំពីបាទាព្រហ្ម មានកសំយុងចុះ មានមុខឱនចុះ មានអាការដូចមធុរកជាតិ តែងសញ្ជប់សញ្ជឹង សំកុកជ្រប់នៅ ដោយគិតថា យើងទាំងឡាយ ជាអ្នកមានឈាន យើងទាំងឡាយ ជាអ្នកមានឈានដូច្នេះ ក៏យ៉ាងនោះដែរ ។

ពុំនោះ ដូចជាសត្វលាដែលអស់សន្ទុះ ( អស់ជើង ) ហើយ តែងសញ្ជប់ សញ្ជឹង សំកុកជ្រប់នៅទៀបជញ្ជាំងផ្ទះ នឹងទីសម្រាប់បង្ហូរទឹកសម្អុយ និង គំនរសំរាម យ៉ាងណា ពួកសមណៈ មានក្បាលរលីងទាំងនេះ ជាគហបតី ជាកណ្ហគោត្រ ជាអ្នកកើតអំពីបាទាព្រហ្ម មានកន្ទិនចុះ មានមុខសំយុងចុះ មានអាការដូចមធុរកជាតិ តែងសញ្ជប់សញ្ជឹង សំកុកជ្រប់នៅ ដោយគិតថា យើងទាំងឡាយជាអ្នកមានឈាន យើងទាំងឡាយជាអ្នកមានឈាន ដូច្នេះ ក៏យ៉ាងនោះដែរ ។ ម្នាលមារមានចិត្តបាប ក៏ឯពួកមនុស្សណា ដែលធ្វើ មរណកាលក្នុងសម័យនោះ ពួកមនុស្សទាំងនោះ លុះទម្លាយកាយបន្ទាប់ អំពីមរណៈ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ និងនរក ដោយច្រើន ។

[ ២០១ ] ម្នាលមារមានចិត្តបាប គ្រានោះ ព្រះមានព្រះភាគទ្រង់ព្រះ នាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធ បានត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាល ភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍ និងគហបតី ដែលទូសីមារចូលជ្រែកសរីរៈ ហើយថា អ្នកទាំងឡាយចូរមក ចូរជេរ គំរាម ប្រទូស្ត បៀតបៀនភិក្ខុ ទាំងឡាយដែលមានសីល មានធម៌ជាកុសល គិតដូចម្តេចនឹងធ្វើចិត្តរបស់ ពួកភិក្ខុដែលពួកអ្នកជេរ គំរាម ប្រទូស្ត បៀតបៀនហើយនោះ ល្មមឲ្យ រាយមាយ ឲ្យទូសីមារបានឱកាសនោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរមានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តា

ដ៏ធំទូលាយ ជារូបាវចរ និងអរូបាវចរ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វទាំងអស់ ដោយយកខ្លួនឯងប្រៀបនឹងសត្វទាំងអស់ ក្នុងទីទាំងពួង គឺទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសជុំវិញ ដោយប្រការដូច្នេះ ។ អ្នកទាំងឡាយ ចូរមានចិត្តប្រកបដោយករុណា ... មានចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ... ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ចូរមានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ជារូបាវចរ និងអរូបាវចរ មានប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វទាំងអស់ដោយយកខ្លួនឯង ប្រៀបនឹងសត្វទាំងអស់ ក្នុងទីទាំងពួង គឺទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសជុំវិញ ដោយប្រការដូច្នេះ ។ ម្នាលមារមានចិត្តបាប កាលព្រះមានព្រះភាគទ្រង់ព្រះនាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះហើយ ទើបពួកភិក្ខុទាំងនោះទៅនៅក្នុងព្រៃខ្លះ ទៅនៅក្រោមម្លប់ឈើខ្លះ ទៅនៅក្នុងសុញ្ញាគារដ្ឋានខ្លះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ជារូបាវចរ និងអរូបាវចរ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វទាំងអស់ ដោយយកខ្លួនឯងប្រៀបនឹងសត្វទាំងអស់ ក្នុងទីទាំងពួង គឺទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសជុំវិញ ដោយប្រការ

ដូច្នេះ ។ ពួកភិក្ខុទាំងនោះ មានចិត្តប្រកបដោយករុណា ... មានចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ ជារូបាវចរ និងអរូបាវចរ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វទាំងអស់ ដោយយកខ្លួនឯងប្រៀបនឹងសត្វទាំងអស់ក្នុងទីទាំងពួង គឺទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទីជុំវិញ ដោយប្រការដូច្នេះ ។

[ ២០២ ] ម្នាលមារមានចិត្តបាប គ្រានោះ ទូសីមារមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើអាត្មាអញធ្វើយ៉ាងនេះ មិនបានដឹងដំណើរមក និងដំណើរទៅរបស់ពួកភិក្ខុដែលមានសីល មានធម៌ជាកុសលទាំងនេះឡើយ បើដូច្នោះ គួរតែអាត្មាអញ ចូលជ្រែកសរីរៈពួកព្រាហ្មណ៍ និងគហបតីថា អ្នកទាំងឡាយ ចូរមកធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជា ពួកភិក្ខុដែលមានសីល មានធម៌ជាកុសល គិតដូចម្តេចនឹងធ្វើចិត្តពួកភិក្ខុ ដែលពួកអ្នកធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជាឲ្យរាយមាយ ល្មមឲ្យទូសីមារបានឱកាសនោះ ។ ម្នាលមារមានចិត្តបាប គ្រានោះ ទូសីមារចូលជ្រែកសរីរៈពួកព្រាហ្មណ៍ និងគហបតីទាំងនោះថា អ្នកទាំងឡាយ ចូរមកធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជា ពួកភិក្ខុដែលមានសីល មានធម៌ជាកុសល គិតដូចម្តេច នឹងធ្វើចិត្តពួកភិក្ខុ ដែលពួកអ្នកធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជា ឲ្យរាយមាយ ល្មមឲ្យទូសីមារបានឱកាសនោះ ។ ម្នាលមារ

មានចិត្តបាប ពួកព្រាហ្មណ៍ និងគហបតីដែលទូសីមារចូលជ្រែកសរីរៈហើយ នោះ ទើបនាំគ្នាធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជាពួកភិក្ខុដែលមានសីល មានធម៌ជាកុសល ។ ម្នាលមារមានចិត្តបាប ក៏ពួកមនុស្សណាធ្វើមរណកាលក្នុងសម័យនោះ ពួកមនុស្សទាំងនោះ លុះទម្លាយកាយខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកាន់សុគតិ សួគ៌ ទេវលោក ។

[ ២០៣ ] ម្នាលមារមានចិត្តបាប ព្រះមានព្រះភាគ ទ្រង់ព្រះនាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍ និងគហបតី ដែលទូសីមារចូលជ្រែកសរីរៈថា អ្នកទាំងឡាយចូរមកធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជាពួកភិក្ខុដែលមានសីលមានធម៌ជាកុសល គិតដូចម្តេចនឹងធ្វើចិត្តរបស់ពួកភិក្ខុ ដែលពួកអ្នកធ្វើសក្ការៈធ្វើសេចក្តីគោរព រាប់អាន បូជាឲ្យរាយមាយ ល្មមឲ្យទូសីមារបានឱកាសនោះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមក ចូរពិចារណារឿយៗ នូវរបស់មិនស្អាតក្នុងកាយ មានសេចក្តីសម្គាល់គួរខ្ពើមរអើមក្នុងអាហារ មានសេចក្តីសម្គាល់នូវរបស់មិនជាទីត្រេកអរ ក្នុងលោកទាំងអស់ ពិចារណាឃើញថា មិនទៀង ក្នុងសង្ខារទាំងអស់ ។ ម្នាលមារមានចិត្តបាប គ្រានោះពួកភិក្ខុទាំងនោះ កាលបើព្រះមានព្រះភាគ ព្រះនាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះហើយ ទោះបីទៅនៅក្នុងព្រៃក្តី ទៅនៅក្រោមម្លប់ឈើក្តី ទៅនៅក្នុងផ្ទះស្ងាត់ក្តី ជាអ្នកពិចារណាឃើញរឿយៗ នូវរបស់មិនស្អាតក្នុងកាយ មានសេចក្តីសម្គាល់ថាគួរខ្ពើមរអើមក្នុង

អាហារ មានសេចក្តីសម្គាល់នូវរបស់មិនជាទីត្រេកអរ ក្នុងលោកទាំងអស់ ជាអ្នកពិចារណាថា មិនទៀង ក្នុងសង្ខារទាំងអស់ ។

[ ២០៤ ] ម្នាលមារមានចិត្តបាប គ្រានោះ ព្រះមានព្រះភាគ ព្រះនាមកកុសន្ធៈអរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងវេលាបុព្វណ្ហសម័យ មានព្រះវិធុរៈមានអាយុជាបច្ឆាសមណៈ ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ម្នាលមារមានចិត្តបាប គ្រានោះ ទូសីមារបានចូលជ្រែកសរីរៈកូនក្មេងម្នាក់ កាន់យកក្រួសចោលត្រង់សីសៈព្រះវិធុរៈមានអាយុ សីសៈរបស់លោកក៏បែក ។ ម្នាលមារមានចិត្តបាប គ្រានោះ ព្រះវិធុរៈមានអាយុ មានសីសៈបែកចេញឈាម ហូរហោមដើរតាមក្រោយៗ ព្រះមានព្រះភាគព្រះនាមកកុសន្ធៈអរហន្តសម្មសម្ពុទ្ធ ។ ម្នាលមារមានចិត្តបាប គ្រានោះ ព្រះមានព្រះភាគព្រះនាមកកុសន្ធៈ អរហន្តសម្មសម្ពុទ្ធ ទ្រង់ងាកមើល ដូចជាងាកមើលនៃដំរីថា ទូសីមារនេះមិនបានដឹងប្រមាណទេ ។ ម្នាលមារមានចិត្តបាប ក៏ឯទូសីមារច្យុតចាកទីនោះ ទៅកើតក្នុងមហានរក ព្រមដោយការងាកទត ( របស់ព្រះកកុសន្ធៈ ) ។

[ ២០៥ ] ម្នាលមារមានចិត្តបាប ក៏ឯមហានរកនោះឯងមានឈ្មោះ ៣ យ៉ាង គឺឆផស្សាយតនិកៈ ១ សង្កុសមាហតៈ ១ បច្ចត្តវេទនីយៈ ១ ។ ម្នាលមារមានចិត្តបាប គ្រានោះ ពួកនាយនិរយបាល បានចូលទៅរកអាត្មា ហើយនិយាយយ៉ាងនេះថា បពិត្រលោកអ្នកនិទុក្ខ កាលណាដែកស្រួចមកប្រជុំជាមួយនឹងដែកស្រួច ត្រង់ហឫទ័យរបស់អ្នកហើយ ទើបអ្នកដឹងនូវហេតុ

នោះថា អាត្មាអញឆេះក្នុងនរកអស់មួយពាន់ឆ្នាំហើយ ។ ម្នាលមារមានចិត្តបាប អាត្មានោះ បានឆេះក្នុងមហានរកនោះ អស់ឆ្នាំជាច្រើន អស់រយឆ្នាំជាច្រើន អស់ពាន់ឆ្នាំជាច្រើន បានឆេះក្នុងឧស្សុទនរក របស់មហានរកនោះឯង ទទួលទុក្ខវេទនា ដែលកើតមកអំពីវិបាក អស់មួយហ្មឺនឆ្នាំ ។ ម្នាលមារមានចិត្តបាប ឯកាយរបស់អាត្មានោះ មានសភាពដូចជាក្បាលមនុស្សពុំនោះសោត មានសភាពដូចជាក្បាលត្រី ។

[ ២០៦ ] ទូសីមារ ដែលបៀតបៀនព្រះវិធុរសាវ័ក និងព្រះកកុសន្ធៈ ជាព្រាហ្មណជាត ហើយឆេះក្នុងនរកដូចម្ដេចទៅ ទូសីមារដែលបៀតបៀនព្រះវិធុរសាវ័ក និងព្រះកកុសន្ធៈ ជាព្រាហ្មណជាត ហើយឆេះក្នុងនរក ដែលមានដែកស្រួចច្រើន មានសុទ្ធតែពួកសត្វទទួលទុក្ខវេទនាចំពោះខ្លួនឯង អ្នកឯងបៀតបៀនភិក្ខុជាពុទ្ធសាវ័ក ដែលលោកដឹងច្បាស់នូវវិមានវត្ថុនុ៎ះហើយ នឹងបាននូវសេចក្ដីទុក្ខដ៏ខ្លៅ វិមានទាំងឡាយដែលឋិតនៅអស់មួយកប្ប មានពណ៌ដូចជាកែវពៃទូរ្យដ៏រុងរឿង ហាក់ដូចជាអណ្ដាតភ្លើង មានពន្លឺភ្លឺផ្លេក ឋិតនៅត្រង់កណ្ដាលសមុទ្រ មានទាំងពួកស្រីអប្សរជាច្រើន មានខ្លួន និងសម្បុរផ្សេងគ្នា តែងរាំលើវិមាននោះ អ្នកឯងបៀតបៀនភិក្ខុជាពុទ្ធសាវ័ក ដែលលោកដឹងច្បាស់នូវវិមានវត្ថុនុ៎ះហើយ រមែងបាននូវសេចក្ដីទុក្ខដ៏ខ្លៅ

ភិក្ខុណាមួយដែលព្រះពុទ្ធជាម្ចាស់ ដាស់តឿនហើយ ធ្វើមិគារមាតុប្រាសាទរបស់ភិក្ខុសង្ឃ ដែលកំពុងសំឡឹងមើលឲ្យញាប់ញ័រដោយចុងម្រាមជើងបាន អ្នកឯងបៀតបៀនភិក្ខុជាពុទ្ធសាវក ដែលលោកដឹងច្បាស់នូវវិមានវត្ថុនុ៎ះហើយ រមែងបាននូវសេចក្តីទុក្ខដ៏ខ្លាំ ភិក្ខុណាបានធ្វើវេជយន្តប្រាសាទឲ្យញាប់ញ័រ ដោយចុងម្រាមជើងបាន ជាអ្នកមាំមួនដោយកម្លាំងឫទ្ធិ អាចធ្វើទេវតាទាំងឡាយឲ្យសង្វេគបាន អ្នកឯងបៀតបៀន ភិក្ខុជាពុទ្ធសាវក ដែលលោកដឹងច្បាស់នូវវេជយន្តប្រាសាទនុ៎ះហើយ រមែងបាននូវសេក្តីទុក្ខដ៏ខ្លាំ ភិក្ខុណាសាកសួរប្រស្នានឹងព្រះឥន្ទ្រ លើវេជយន្តប្រាសាទថា ម្នាលអាវុសោ អ្នកស្គាល់តណ្ហក្ខយវិមុត្តិឬទេ ព្រះឥន្ទ្រដែលភិក្ខុនោះសួរប្រស្នាហើយ ក៏ដោះស្រាយតាមដំណើរពាក្យរបស់ភិក្ខុនោះ អ្នកឯងបៀតបៀននូវភិក្ខុ ជាពុទ្ធសាវក ដែលដឹងច្បាស់នូវហេតុនុ៎ះហើយ រមែងបាននូវសេចក្តីទុក្ខដ៏ខ្លាំ ភិក្ខុណាសាកសួរប្រស្នានឹងព្រហ្ម ជិតសាលាឈ្មោះសុធម្មាថា ម្នាលអាវុសោ សព្វថ្ងៃនេះ អ្នកឯងនៅមានទិដ្ឋិ ដូចជាពីថ្ងៃមុនដែរឬ អ្នកបានឃើញពន្លឺ ( ព្រះមានព្រះភាគ ) ដែលភ្លឺផ្លេក កន្លងសត្វក្នុងព្រហ្មលោកដែរឬទេ ព្រហ្មក៏បានដោះស្រាយតាម

លំដាប់ពាក្យរបស់ភិក្ខុនោះថា បពិត្រលោកអ្នកនិទ៌ុក ខ្ញុំមិនមានទិដ្ឋិដូចពីថ្ងៃមុនទេ ខ្ញុំបានឃើញពន្លឺ ( ព្រះមានព្រះភាគ ) ដែលភ្លឺផ្ទេក កន្លងសត្វក្នុងព្រហ្មលោកដែរ ថ្ងៃនេះខ្ញុំបានពោលពាក្យថា ខ្ញុំជាបុគ្គលទៀងទាត់ ឥតប្រែប្រួលឡើយ អ្នកឯងបៀតបៀននូវភិក្ខុ ជាពុទ្ធសាវក ដែលលោកដឹងច្បាស់នូវហេតុនុ៎ះហើយ រមែងបាននូវសេចក្ដីទុក្ខដ៏ខ្មៅ ភិក្ខុណា បានប៉ះពាល់កំពូលភ្នំមហាសិនេរុ ប៉ះពាល់នូវជម្ពូទ្វីប បុព្វវិទេហទ្វីប និងពួកជនដែលដេកលើផែនដី ដោយឈានវិមោក្ខ អ្នកឯងបៀតបៀននូវភិក្ខុ ជាពុទ្ធសាវក ដែលលោកដឹងច្បាស់នូវហេតុនុ៎ះហើយ រមែងបាននូវសេចក្ដីទុក្ខដ៏ខ្មៅ ប្រៀបដូចជាភ្លើង មិនដែលគិតថាអាត្មាអញនឹងឆេះមនុស្សពាលម្ដងឡើយ តែមនុស្សពាលចេះតែមកប៉ះពាល់ភ្លើង ដែលកំពុងឆេះសន្ធោ ភ្លើងនោះក៏ឆេះទៅ ( យ៉ាងណា ) ម្នាលមារ អ្នកឯងបៀតបៀនព្រះតថាគ គង់នឹងឆេះខ្លួនដោយខ្លួនឯង ដូចជាបុគ្គលពាលប៉ះពាល់ភ្លើង យ៉ាងនោះដែរ មារបើបៀតបៀនព្រះតថាគតហើយ គង់នឹងបានបាបពុំខាន ម្នាលមារមានចិត្តបាប អ្នកឯងស្មានថា បាប មិនឲ្យផលដល់អាត្មាអញ ឬដូចម្ដេចបាបពិតជាឲ្យផលដល់អ្នកធ្វើបាប ឯបុគ្គលបាបរមែងកន្ទុក់

កន្ទេញអស់កាលយូរអង្វែង ម្នាលមារ អ្នកឯងគេចចេញពីព្រះពុទ្ធទៅ កុំនៅបៀតបៀនពួកភិក្ខុឡើយ ភិក្ខុ គឺមហាមោគ្គល្លាន បានគំរាមមារ ក្នុងព្រៃភេសកឡាវ័ន ដូចបានរៀបរាប់មកនេះឯង លំដាប់នោះ យក្ស គឺ មារ នោះឯងក៏មានចិត្តអាក់អន់ហើយ ស្រាប់តែបាត់ពីទីនោះទៅ មួយរំពេច ។

មារតជ្ជនីយសូត្រទី ១០ ចប់

ចូឡយមកវគ្គទី ៥ ចប់

## ឧទ្ទាន គឺបញ្ជីរឿងនៃចូឡយមកវគ្គនោះ ដូច្នេះគឺ

សាលេយ្យកសូត្រ ១ វេរញ្ជកសូត្រ ១ ចូឡវេទល្លសូត្រ ១ មហាវេទល្លសូត្រ ១ ចូឡធម្មសមាទានសូត្រ ១ មហាធម្មមហាសមាទានសូត្រ ១ វីមំសកសូត្រ ១ កោសម្ពិយសូត្រ ១ ព្រហ្មនិមន្តនិកសូត្រ ១ មារតជ្ជនីយសូត្រ ១ ចប់វវគ្គជាគម្រប់ ៥ ។

មូលបណ្ណាសកៈ ចប់

# អដ្ឋកថា

## មារតជ្ជនីយសូត្រទី ១០

[ ១៩៧ ] មារតជ្ជនីយសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **កោដ្ឋមនុបវិដ្ឋោ** សេចក្ដីថា ចូលពោះទៅហើយ ចូលទៅតាមលំដាប់ខាងក្នុងពោះវៀនធំ អន្ទុយត្រង់ក្រពះ ។ បទថា **គរុគរោ វិយ** សេចក្ដីថា រឹងធ្ងន់ ដូចគ្នានឹងដុំថ្ម អធិប្បាយថា អាហារដែលធ្វើដោយសណ្ដែក និងដូចសណ្ដែកដែលសើមដោយប្រេង ដូចពោះដែលមនុស្សបរិភោគបាយហើយ ដូចថង់ដែលពេញដោយសណ្ដែក និងដូចសណ្ដែកដែលសើមហើយ ។

បទថា **វិហារំ បវិសិត្វា** សេចក្ដីថា បើនេះជាការធ្ងន់ ព្រោះទោសនៃអាហារ ការចង្ក្រមក្នុងទីវាល ក៏មិនជាការសប្បាយ ។ ដូច្នោះ ទើបព្រះថេរៈចុះអំពីទីចង្ក្រម ចូលទៅកាន់បណ្ណសាលា អង្គុយលើអាសនៈដែលក្រាលតាមប្រក្រតី ។

បទថា **បច្ចត្តំ យោនិសោ មនសាកាសិ** សេចក្ដីថា កាលពិចារណាថា នេះអ្វីហ្ន៎ ទើបព្រះថេរៈដាក់ចិត្តដោយឧបាយរបស់ខ្លួននោះឯង ។ បើព្រះថេរៈរឭកដល់សីល យកដៃស្ទាបពោះ ពិចារណាថា អាហារដែលអញបរិភោគម្សិលមិញ ម្សិលម្ង៉ៃ ឬម្សិលម្ង៉ៃមួយនោះ មិនរលាយ ឬថា ទោសដែលកើតអំពីអាហារដែលមិនត្រូវចំណែកគ្នាដទៃមាន អាហារទាំងអស់នោះ ចូរវិនាសទៅ ផាសុកចូរកើតមាន ។ មារមានចិត្តបាបក៏បានខ្មាស បាត់ទៅ ។ ព្រះថេរៈមិនធ្វើយ៉ាងនោះឡើយ គ្រាន់តែដាក់ចិត្តដោយឧបាយ ។

[ ១៩៨ ] បទថា **មា តថា គតំ វិហោសេសិ** សេចក្តីថា ប្រៀបដូចកូនៗ ត្រូវបៀតបៀន មាតាបិតា ក៏ឈ្មោះថា ត្រូវបៀតបៀនផង កាលសិទ្ធិ-វិហារិក និងអន្តេវាសិកត្រូវបៀតបៀនឧបជ្ឈាយ៍ និងអាចារ្យ ក៏ឈ្មោះថា ត្រូវបៀតបៀនផង កាលអ្នកជនបទត្រូវបៀតបៀន ព្រះរាជាក៏ឈ្មោះថា ត្រូវបៀតបៀនផង យ៉ាងណា កាលសាវ័ករបស់ព្រះតថាគតត្រូវបៀតបៀន ព្រះតថាគតក៏ឈ្មោះថា ត្រូវបៀតបៀនដែរ ដូច្នោះ ព្រោះដូច្នោះ ទើបព្រះមហាមោគ្គល្លានពោលថា អ្នកកុំបៀតបៀនព្រះតថាគតឡើយ ។

បទថា **បច្ចគ្គឡេ អដ្ឋាសិ** សេចក្តីថា បានដល់ ឈរត្រង់សន្ទះទ្វារ សន្ទះទ្វារលោកហៅថា **អគ្គឡ** មារបានអណ្តែតចេញទៅតាមមាត់ ទៅអំពីបណ្ណសាលាហើយ ឈរផ្អែកទ្វារបណ្ណសាលា ព្រោះហេតុអ្វី ទើបព្រះថេរៈប្រារព្ធទេសនានេះថា ម្នាលមារមានចិត្តបាប កាលពីដើមមក ។

បានឮថា ព្រះថេរៈគិតថា ក្លិនរបស់ពួកមនុស្ស រមែងបៀតបៀនពួកអាកាសទេវតា រាប់រយយោជន៍ ។ ពាក្យនោះ ព្រះថេរៈពោលថា រាជញ្ញៈក្លិនពួកមនុស្សរមែងបៀតបៀន ពួកទេវតារាប់រយយោជន៍ ព្រោះហេតុនោះមារនេះ ជាអ្នកក្រង មានបរិវាររក្សា ដល់ព្រមដោយអានុភាព ជាស្តេចនៃពួកទេវតា ចូលទៅក្នុងពោះរបស់អញ អង្គុយក្នុងក្រពះ ខាងក្នុងពោះវៀនទារុណពន់ពេក ។ កាលព្រះថេរៈពោលថា បុគ្គលដទៃណាមានមុខ ដែលអាចនឹងចូលក្នុងឱកាសដែលគួររង្កៀស គួរតិះដៀលបែបនេះ មិនខ្មាសនូវគុណាមួយ អ្នកមិនមែនញាតិរបស់ខ្ញុំទេ ។ ព្រះថេរៈគិតថា ដែលឈ្មោះថា

បុគ្គលដែលមិនដល់នូវការទន់ភ្លន់ រមែងមិនមាន ណ្ហើយចុះ អញនឹងចាក់ខាងខ្នងញាតិរបស់មារនេះ ហើយលែងលោកដោយឧបាយដែលសុភាពនោះឯង ទើបប្រាថ្នាការសម្ដែងនេះ ។

[ ១៩៩ ] បទថា **សោ មេ ត្វំ ភាគិនេយ្យោ ហោសិ** សេចក្ដីថា អ្នកធ្លាប់ជាក្មួយរបស់អាត្មាក្នុងវេលានោះ ។ ព្រះថេរៈពោលពាក្យនេះ ដោយអំណាចទំនៀម ។ ឈ្មោះថា ពួកញាតិរបស់បិតាដែលជាខ្សែស្រឡាយនៃជីតាគ្រងរាជ្យ មិនមានក្នុងទេវលោក ។ បិតារបស់មារនោះ កើតជាព្រះរាជានៃទេវតាក្នុងទេវលោក ដោយអំណាចនៃបុណ្យ តាំងនៅមួយជួរអាយុ ហើយចុតិ ទេវតាដទៃម្នាក់ទៀត ដែលកើតជាធំក្នុងទីនោះ ដោយកម្មដែលខ្លួនធ្វើហើយ ។ មារនោះ ក៏គប្បីជ្រាបថា វេលានោះ ឃាតចាកអត្តភាពនោះ ធ្វើកុសលទៀត កើតក្នុងតំណែងអធិបតីពេលនេះ ដូច្នេះ ។

បទថា **វិធុរោ** គឺប្រាសចាកធុរៈ អធិប្បាយថា មិនដូចមនុស្សពួកដទៃៗ ។ បទថា **អប្បកសិរេន** គឺលំបាកតិច ។ បទថា **បសុបាលកា** គឺអ្នកចិញ្ចឹមពពែ និងចៀម ។ បទថា **បថាវិនោ** គឺជាអ្នកដើរទៅតាមផ្លូវ ។ បទថា **កាយេ ឧបចិនិត្វា** សេចក្ដីថា ចងជើងថ្ករជុំវិញ ។ បទថា **អគ្គឹ ទត្វា បក្កមឹសុ** សេចក្ដីថា អ្នកស្រែទាំងឡាយកំណត់ទំហំនៃជើងថ្ករថា ជើងថ្ករប៉ុណ្ណេះ រាងកាយនឹងកាន់យកជុំវិញ ហើយដុតភ្លើងឡើងទាំង ៤ ទិស ចៀសចេញទៅហើយ ។ ជើងថ្ករក៏បានឆេះឡើង ដូចអណ្ដាតប្រទីប ហើយបាន ហាក់ដូចជាវេលាដែលព្រះថេរៈចូលគុហាមានទឹក ហើយអង្គុយចុះ ។

បទថា **ចីវរានិ បច្ចោដេត្វា** សេចក្តីថា ព្រះថេរៈកាលចេញអំពីសមាបត្តិ ជាន់រងើកភ្លើងដែលមានអណ្តាត មានពណ៌ដូចផ្កាចារ បានរលាស់ចីវរហើយ ត្រឹមតែកម្តៅក៏មិនមានក្នុងរាងកាយរបស់លោក ។ កម្តៅក៏មិនឆេះចីវរ ។ នេះឈ្មោះថា ជាផលរបស់សមាបត្តិ ។

[ ២០០ ] បទថា **អក្កោសថ** សេចក្តីថា ពួកអ្នកចូរជេរ ដោយវត្ថុសម្រាប់ជេរ ១០ យ៉ាង ។ បទថា **បរិភាសថ** បានដល់ ប្រទេចដោយវាចា ។ បទថា **រោសេថ** បានដល់ ចូរទ្រគោះបោះបោក ។ បទថា **វិហេសេថ** បានដល់ ឲ្យដល់នូវសេចក្តីទុក្ខ ។ ពាក្យទាំងអស់នេះ ជាឈ្មោះរបស់ការទ្រគោះបោះបោកផ្លូវវាចា ។ បទថា **យថា តំ ទូសី មារោ** សេចក្តីថា ដូចមារឈ្មោះទូសីបានឱកាសរបស់ពួកព្រាហ្មណ៍ និងគហបតីទាំងនោះ ។ បទថា **លភេថ ឱតារំ** សេចក្តីថា ពួកអ្នកចូរបានដីង គឺគប្បីបានអារម្មណ៍ ដែលជាបច្ច័យនៃការកើតឡើងរបស់កិលេស ។

ក្នុងបទថា **មុណ្ឌកា** ដូច្នេះជាដើម ពួកព្រាហ្មណ៍ និងពួកគហបតីពោលថា មារគប្បីសមគួរពោលនឹងបុគ្គលមានក្បាលត្រងោលថា ត្រងោល និងជាមួយពួកសមណៈថា សមណៈ ឯពួកសមណៈត្រងោលទាំងនេះ មើលងាយ ។ បទថា **ឥព្ភា** បានដល់ គហបតី គឺម្ចាស់ផ្ទះ ។ បទថា **កិណ្ហា** ប្រែថា ខ្មៅ បានដល់ ងងឹត ។

ព្រហ្ម លោកបំណងយកថា ញាតិ ក្នុងបទនេះថា ជាពូជនៃមហាព្រហ្ម ពួកព្រាហ្មណ៍រមែងហៅព្រហ្មនោះថា ជីតា អធិប្បាយថា ពូជពង្សរបស់

បុគ្គលដែលកើតអំពីជើងទាំងឡាយ ឈ្មោះថា ខ្សែស្រឡាយពួកដែលកើតអំពីជើង គឺពួកដែលកើតអំពីខ្នងជើងរបស់ព្រហ្ម ។

បានឮថា ពួកព្រាហ្មណ៍នោះ មានលទ្ធិយ៉ាងនេះថា ពួកព្រាហ្មណ៍កើតអំពីមាត់ព្រហ្ម ក្សត្រកើតអំពីទ្រូង អ្នកជំនួញកើតអំពីផ្ចិត ពួកសូទ្រៈកើតអំពីស្មង ពួកសមណៈកើតអំពីខ្នងជើង ។ បទថា **ឈាយិនោស្មា ឈាយិ-នោស្មា** សេចក្តីថា ពួកយើងជាអ្នកសម្ងំ ពួកយើងជាអ្នកសម្ងំ ។ បទថា **មធុរកជាតា** បានដល់ មានជាតិជាអ្នកខ្ជិលច្រអូស ។ បទថា **ឈាយន្តិ** បានដល់គិត ។ បទថា **បជ្ឈាយន្តិ** ជាដើម លោកពង្រីកដោយអំណាចឧបសគ្គ ។ បទថា **មូសិកំ មគ្គយមានោ** សេចក្តីថា ស្វែងរកកណ្តុរលើមែកឈើ កណ្តុរណាដែលចេញអំពីដើមឈើដែលមានប្រហោងដើម្បីរកអាហារពេលល្ងាច ។ បានឮថា មៀមនោះឈរស្ងៀម ហាក់ដូចស្ងប់ស្ងាត់ហើយ និងចឹកកណ្តុរយ៉ាងរហ័ស ក្នុងវេលាដែលជួបប្រទះ ។

បទថា **កុត្ថោ** បានដល់ ឆ្កែចចក អាចារ្យទាំងឡាយពោលថា ជាស្មាំងក៏មាន ។ បទថា **សន្ធិសមលសង្កដិរេ** សេចក្តីថា ទីជញ្ជាំងផ្ទះផង ទសម្រាប់បង្ហូរទឹកជ្រាំផង គំនរសំរាមផង ។ ក្នុងទីទាំងនោះ ទីតនៃផ្ទះ ឈ្មោះថា ជញ្ជាំងផ្ទះ ទបង្ហូរទឹកស្អុយ ជាទីចោលលាមក ឈ្មោះថា ទសម្រាប់បង្ហូរទឹកស្អុយ ទីចោលកាកសំណល់ ឈ្មោះថា គំនរសំរាម ។ បទថា **វិហាច្ចិន្នោ** សេចក្តីថា កាលចេញចាកទីកន្ទារ មានសន្ទុះដាច់ហើយ ។ បទថា **សន្ធិ-សមលសង្កដិរេ** បានដល់ ទីតផ្ទះ អណ្តូងទឹកជ្រាំ ឬគំនរសំរាម ឯលានោះ

កាលដុត ក៏មិនកម្រើក ហាក់ដូចជារឹង ។

បទថា **និរយំ ឧបបជ្ជន្តិ** សេចក្ដីថា បើមារចូលសណ្ឋិតក្នុងសរីរៈរបស់ពួកមនុស្ស ពួកមនុស្សមិនគប្បីមានអកុសលកម្ម គប្បីមានដល់មារប៉ុណ្ណោះ តែមារមិនបានសណ្ឋិតក្នុងរាងកាយ ហើយសម្ដែងវត្ថុដែលមិនត្រូវចំណែកគ្នា និងអារម្មណ៍ដែលឲ្យកើតការក្ដៅក្រហាយ បានឮថា កាលណោះ មារនោះ សម្ដែងភិក្ខុទាំងឡាយ ធ្វើឲ្យដូចជាអ្នកចាប់ត្រី ក៏ចាប់ដោយរហ័ស ១ ធ្វើឲ្យឃើញដូចជាបុគ្គលកាន់សំណាញ់ ហើយបង់ត្រី ១ ឲ្យឃើញដូចជាបុគ្គលវាយលប់ហើយ ចងបក្សី ១ ឃើញដូចបុគ្គលត្រាច់កៀងម្រឹគក្នុងព្រៃជាមួយឆ្កែ ១ ឃើញដូចបុគ្គលនាំស្រីមកអង្គុយក្នុងទីផឹកស៊ី ១ ឃើញដូចបុគ្គលរាំ ១ ឃើញដូចបុគ្គលប្រគំ ១ ឃើញដូចពួកមនុស្ស ដែលមិនត្រូវគ្នាអង្គុយ និងឈរក្នុងទីសម្រាកពេលយប់ និងពេលថ្ងៃរបស់ភិក្ខុទាំងឡាយ ១ ។

មនុស្សទាំងឡាយទៅព្រៃស្រោងខ្លះ ទៅព្រៃក្រាស់ខ្លះ ទៅវត្តខ្លះ ឃើញអារម្មណ៍ដែលធ្វើឲ្យក្ដៅក្រហាយ ហើយមកពោលដល់គ្នីគ្នាថា ពួកសមណៈធ្វើកិច្ចដែលមិនសមគួរដល់សមណៈ មិនសមគួរបែបនេះ កាលពួកយើងបានថ្វាយទានដល់សមណៈពួកនោះ ធ្វើម្ដេចនឹងបានបុណ្យកុសល ពួកអ្នកកុំឲ្យវត្ថុណាមួយដល់សមណៈទាំងនោះ ។ មនុស្សទាំងនោះ ជេរភិក្ខុអ្នកមានសីលទាំងឡាយក្នុងទីដែលខ្លួនឃើញហើយ បានជួបនូវបាបដែលជាទីញ៉ាំងអបាយឲ្យពេញ ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា **និរយំ ឧបបជ្ជន្តិ** ។

[ ២០១ ] បទថា **អន្វាវិដ្ឋា** បានដល់ ត្រូវមារបង្ខិលទូទៅ ។ បទថា

**ឋវិត្វា វិហរឹសុ** បានដល់ ផ្សាយទៅហើយតែម្យ៉ាងក៏ទេ បុគ្គលដែលតាំងនៅក្នុងឱវាទនៃព្រះមានព្រះភាគកកុសន្ធៈ ឲ្យនូវព្រហ្មវិហារ ៤ កើតហើយ ចម្រើនវិបស្សនា ដែលមានឈានជាបាទ បានតាំងនៅក្នុងព្រះអរហត្ត ។

[ ២០២ ] បទថា **អាគតឹ វា គតឹ វា** សេចក្តីថា ខ្ញុំមិនដឹងទីមកដោយអំណាចបដិសន្ធិ ឬដែលជាទីទៅដោយអំណាចគតិ ។ បទថា **សិយា ចិត្តស្ស អញ្ញថត្តំ** សេចក្តីថា គប្បីមានការប្រព្រឹត្តទៅដោយប្រការដទៃ ដោយអំណាចការពេញចិត្ត ។ ក្នុងបទនេះថា **សត្តំ លោកំ ឧប្បជ្ជន្តិ** គប្បីជ្រាបអត្ថតាមន័យមុននោះឯង ។ ប្រៀបដូចមារសម្តែងអារម្មណ៍ដែលធ្វើឲ្យក្តៅក្រហាយក្នុងកាលមុន យ៉ាងណា ក្នុងឥឡូវនេះ ក៏ដូច្នោះ សម្តែងអារម្មណ៍ ធ្វើឲ្យជ្រះថ្លាបាន ។

បានឮថា កាលណោះ មារនោះ បានសម្តែងភិក្ខុទាំងឡាយក្នុងទីដែលប្រាកដដល់មនុស្សទាំងឡាយ ធ្វើឲ្យដូចទៅក្នុងអាកាស ឈរក្នុងអាកាស អង្គុយពត់ភ្នែន ដេរសំពត់ ប្រាប់គម្ពីរ រលាស់ចីវរ ឲ្យកាយទទួលរដូវ ដូចដើរទៅ ដូចសាមណេរកំលោះឈរបេះផ្កា សុទ្ធតែលើអាកាសទាំងអស់ ។ ពួកមនុស្សទៅព្រៃស្បាតខ្លះ ព្រៃក្រាស់ខ្លះ ទៅវត្តខ្លះ ឃើញកិច្ចបដិបត្តិនោះរបស់ពួកបព្វជិត រមែងមកប្រាប់ដល់ពួកមនុស្សដទៃថា ក្នុងពួកភិក្ខុ ដោយហោចសូម្បីសាមណេរ ក៏មានឫទ្ធិច្រើន មានអានុភាពច្រើនយ៉ាងនេះ ទានដែលថ្វាយដល់បុគ្គលទាំងនេះ ឈ្មោះថា មានផលច្រើន ពួកអ្នកចូរឲ្យ ចូរធ្វើសក្ការៈដល់ពួកលោកទាំងនោះចុះ ។ គ្រានោះ ពួកមនុស្សបានធ្វើសក្ការៈ

ដល់ភិក្ខុសង្ឃដោយបច្ច័យ ៤ ធ្វើបុណ្យច្រើន ជាអ្នកញ៉ាំងសួគ៌ឲ្យពេញ ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា **សគ្គំ លោកំ ឧបប្បជ្ជន្តិ** ។

[ ២០៣ ] បទថា **ឯថ តុម្ហេ ភិក្ខវេ អសុភានុបស្សិនោ កាយេ វិហរថ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ត្រាច់ទៅពេញសកលជម្ពូទ្វីប ដោយហោចទ្រង់ក៏បានយាងទៅកាន់លំនៅរបស់ភិក្ខុ ២ រូបខ្លះ ៣ រូបខ្លះ ទ្រង់សម្តែងអានិសង្សយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្វរ បែរចេញចាកការជួបប្រសព្វដោយមេថុនធម្ម មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំអាហារេបដិកូលសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្វរ បែរចេញចាករសតណ្ហា មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើងព្រម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំ សព្វលោកេអនភិរតិសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្វរ បែរចេញចាកលោកសន្និវាស មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំអនិច្ចសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្វរ បែរចេញចាកលាភសក្ការៈ និងសេចក្តីសរសើរ មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង ។ ហើយទ្រង់ត្រាស់កម្មដ្ឋានទាំង ៤ នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមក ចូរពិចារណារឿយៗ នូវរបស់មិនស្អាតក្នុងកាយ មានសេចក្តីសម្គាល់គួរខ្ពើមរអើម

ក្នុងអាហារ មានសេចក្តីសម្គាល់នូវរបស់មិនជាទីត្រេកអរក្នុងលោកទាំងអស់ ពិចារណាឃើញថា មិនទៀងក្នុងសង្ខារទាំងអស់ ។

ភិក្ខុទាំងនោះ ធ្វើកម្មក្នុងកម្មដ្ឋានទាំង ៤ នេះ ឲ្យអាសវៈទាំងពួងអស់ទៅ តាំងនៅក្នុងភាពជាព្រះអរហន្ត ។ កម្មដ្ឋាន ៤ នេះ ឲ្យរាគៈ ទោសៈ និងមោហៈស្ងប់ កម្ចាត់រាគៈ ទោសៈ និងមោហៈដោយពិតប្រាកដ ដូច្នេះ ។

[ ២០៤ ] បទថា **សក្ខរំ គហេត្វា** សេចក្តីថា កាន់យកដុំថ្មប្រមាណប៉ុនក្តាប់ដៃ ។ មារនេះបានឲ្យពួកព្រាហ្មណ៍ និងគហបតីជេរភិក្ខុខ្លះ បណ្តាលឲ្យភិក្ខុសង្ឃកើតលាភ និងសក្ការៈ ដោយអំណាចព្រាហ្មណ៍ និងគហបតីខ្លះ កាលមិនបានឱកាស ឥឡូវនេះ មានបំណងដើម្បីព្យាយាមដោយដៃរបស់ខ្លួន ទើបចូលសណ្ឋិតក្នុងរាងកាយរបស់កុមារម្នាក់ ហើយបានកាន់យកដុំថ្មនោះ ។ ព្រះថេរៈសំដៅយកក្មេងនោះ ទើបពោលថា **សក្ខរំ គហេត្វា** ។

បទថា **សីសំ វោ ភិន្ទិ** សេចក្តីថា ទម្លាយសីសៈរបស់លោក គឺបំបែកនូវសីសៈ ។ សាច់ និងស្បែកបែកទៅជា ២ ចំណែក ។ ដុំថ្មមិនទម្លាយលលាដ៍ ទល់គ្នានឹងឆ្អឹងហើយឈប់នោះឯង ។ បទថា **នាគាបលោកិតំ អបលោកេសិ** ប្រែថា ទ្រង់បែរមើលហើយ ដូចដំរីបែរក្រោយ បានដល់ឰសំឡេងខ្លាំង ។

ដំរីដ៏ប្រសើរ កាលបំណងនឹងងាកទៅខាងនេះ ឬខាងនោះ នឹងមិនងាកតែក រមែងបែររាងកាយទាំងមូលសម្លឹងមើលនោះឯង យ៉ាងណា ព្រះសម្មាសម្ពុទ្ធ ព្រះនាមថា កកុសន្ធៈក៏ដូច្នោះ ទ្រង់បានបង្វិលរាងកាយទាំងមូល

សម្លឹងមើលហើយ ។ ធ្មឹងទាំងឡាយរបស់មហាជនខាងចុងទល់គ្នាតាំងនៅរបស់ព្រះបច្ចេកពុទ្ធ ត្រង់ចុងជាថ្នាំង តែរបស់ព្រះពុទ្ធទាំងឡាយ មិនដូច្នោះឡើយ ស្រឡូនដូចគ្នាតាំងនៅ ដូចបំពង់ដែក ព្រោះដូច្នោះ វេលាទ្រង់មើលខាងក្រោយ ព្រះពុទ្ធទាំងឡាយ មិនអាចងាកទៅបាន ដ៏រីដ៏ប្រសើរ កាលបំណងនឹងមើលខាងក្រោយ ទើបបង្វិលរាងកាយទាំងមូលនោះឯង ព្រះពុទ្ធក៏គប្បីវិលទៅ ដូច្នោះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់បង្វិលព្រះសរីរៈទាំងមូលសម្លឹងមើល ដូចព្រះបដិមាមាសដែលបង្វិលទៅដោយគ្រឿងយន្ត ព្រះសម្មាសម្ពុទ្ធបានប្រថាប់ឈរសម្លឹងមើលត្រាស់ថា ឱ ! ទូសីមារនេះ មិនស្គាល់ប្រមាណខ្លួនឯងហ្ន៎ ។ ពាក្យនោះ មានសេចក្តីថា ទូសីមារនេះធ្វើបាប មិនដឹងប្រមាណនោះឯង បានធ្វើការឈានកន្លងប្រមាណហើយ ។ បទថា **សហាបលោកនាយ** សេចក្តីថា ខណៈនោះឯង ព្រមគ្នានឹងការមើលរបស់ព្រះមានព្រះភាគ ព្រះនាមថា កកុសន្ធៈ ។ បទថា **តម្ហា ច ឋានា ចវិ** សេចក្តីថា ចុតិចាកទីក្នុងទេវលោកនោះ ចូលដល់មហានរកហើយ ។

មារកាលនឹងចុតិ ទោះឈរក្នុងទីមួយ ក៏ចុតិ ព្រោះដូច្នោះ ទើបមារនោះមិនមកទេវលោកជាន់វសវត្តីវិញ ចុតិហើយ ។ មារនោះមិនដឹងថា ចុតិព្រោះព្រះមានព្រះភាគ ។ មារនោះមិនបានពោលលា ព្រោះពាក្យថា ដំណាលគ្នាក្នុងការក្រឡេកមើល ។ ពាក្យនេះត្រឹមតែជាការសម្តែងវេលាចុតិប៉ុណ្ណោះ ។ អាយុរបស់មារនោះ គប្បីជ្រាបថា ដាច់ទៅហើយក្នុងទេវលោកជាន់វសវត្តីនោះឯង ដូចការប្រហារដោយពូថៅ ព្រោះបានធ្វើខុសក្នុងព្រះមហាសាវក ។

[ ២០៥ ] បទថា **តយោ ឆាមចេយ្យា ហោន្តិ** បានដល់ មានឈ្មោះ ៣ ។ បទថា **ឆឥស្សាយតនិកោ** សេចក្តីថា ក្នុងផស្សាយតនៈ ៦ វេទនារមែងមានបច្ច័យ ។ បទថា **សង្កុសមាហតោ** សេចក្តីថា នាំចូលទៅព្រមដោយកន្លៀវដែក ។ បទថា **បច្ចត្តវេទនិយោ** បានដល់ ខ្លួនឯងនោះឯងឲ្យកើតវេទនា ។ បទថា **សង្កុនា សង្កុ ហទយេ សមាគច្ឆេយ្យ** សេចក្តីថា កន្លៀវដែក និងដែកស្រួចមកប្រជុំគ្នាត្រង់បេះដូង ។

បានឮថា កាលសត្វទាំងនោះកើតក្នុងនរកនោះ មានអត្តភាព ៣ គាវុត រាងកាយមារក៏ដូច្នោះដែរ កាលនោះ ពួកនាយនិរយបាល កាន់លំពែងដែកប្រមាណប៉ុនដើមត្នោត ដែលឆេះសន្ធោសន្ធៅ ពោលថា ឯងនេះ គិតហើយទើបធ្វើកម្មអាក្រក់ត្រង់ទីនេះ ហើយចាក់ត្រង់កណ្តាលបេះដូង ដូចគេជំនំក្នុងស្នូកនំ ធ្វើមនុស្ស ៥០ នាក់ឲ្យមានមុខនៅត្រង់ជើង ៥០ នាក់ឲ្យមានមុខនៅលើក្បាល កាលលំពែងដែកប្រព្រឹត្តទៅយ៉ាងនេះ អស់ ៥០០ ឆ្នាំ ហើយលំពែងត្រឡប់មកវិញអស់ ៥០០ ឆ្នាំ ក៏ប្រជុំគ្នាត្រង់បេះដូង ព្រះថេរៈសំដៅយកលំពែងនោះ ទើបពោលពាក្យនេះ ។

បទថា **វុដ្ឋានិមំ** សេចក្តីថា វេទនាដែលតាំងឡើងអំពីវិបាក បានឮថា ការសោយអារម្មណ៍នោះ មានទុក្ខច្រើនជាងការសោយផលក្នុងនរក ។ អាចារ្យទាំងឡាយពោលថា ដូចការរក្សាអស់ ៧ ថ្ងៃ លំបាកជាងការផឹក ការជាប់ជំពាក់អស់ ៧ ថ្ងៃ យ៉ាងណា ការសោយអារម្មណ៍ដែលតាំងឡើងនៃវិបាកក្នុងតណ្ហាដែលផ្សាយឡើង មានទុក្ខច្រើនជាងទុក្ខក្នុងមហានរក ។

បទថា **សេយ្យាថាបិ គច្ឆស្ស** សេចក្តីថា ក្បាលរបស់មនុស្សមូល កាលបុគ្គលប្រហារដោយលំពែង ការប្រហាររមែងមិនត្រង់ រមែងផ្ចាតបញ្ចិត ទៅ ក្បាលរបស់ត្រីវែង ការប្រហាររមែងត្រង់ ការប្រហារ ឈ្មោះថា ធ្វើទុក ល្អ ព្រោះធ្វើកម្មមិនខុស ។ ដូច្នោះ ទើបក្បាលមានសភាពដូច្នេះ ។

[ ២០៦ ] បទថា **វិធុរំ សាវកមាសជ្ជ** សេចក្តីថា ចំព្រះសាវកឈ្មោះ ថា វិធុរៈ ។ បទថា **បច្ចត្តវេទនា** សេចក្តីថា ឲ្យកើតការសោយអារម្មណ៍ ណាទីមួយចំពោះខ្លួនឯង ។ បទថា **ឦទិសោ និរយោ អាសិ** សេចក្តីថា គប្បីសម្តែងនរកដោយទេវទូតសូត្រក្នុងទីនេះ ។ បទថា **កណ្ហា ទុក្ខំ និគច្ឆសិ** សេចក្តីថា គឺជួបនូវទុក្ខដែលកើតអំពីមារ ស្លាប់ហើយ ។ បទថា **មជ្ឈេ សរស្ស** បានដល់ បានឮថា វិមានដែលធ្វើឲ្យទឹកជាទីទ្រ ហើយកើតកណ្តាល មហាសមុទ្រ តាំងនៅអស់មួយកប្ប ។ វិមានទាំងនោះ មានពណ៌ដូចកែវ ពៃទូរ្យ មានពន្លឺទ្រលោម ដូចគំនរភ្លើងដែលឆេះដើមបបុស សន្ធោសន្ធៅលើ កំពូលភ្នំ មានរស្មីផ្សាយទៅ ។ សម្បូរដោយរស្មីក្នុងវិមានទាំងនោះ មាន នាងទេពអប្សរ មានពណ៌ផ្សេងៗ ច្រៀងរាំ ។ បទថា **យោ ឯតមភិ-ជានាតិ** សេចក្តីថា បុគ្គលណាដឹងរឿងវិមានវត្ថុនេះ ។

ក្នុងរឿងនេះ ក៏គួរសម្តែងអត្ថដោយរឿងវិមានវត្ថុ និងបេតវត្ថុដូចគ្នា ។

បទនេះថា **ចាទំគុដ្ឋេន កម្បយិ** គួរសម្តែងដោយបាសាទកម្បនសូត្រ គឺសូត្រដែលធ្វើប្រាសាទឲ្យញាប់ញ័រចុះ ។ បទនេះថា **យោ វេជយន្តំ-ចាសាទំ** គួរសម្តែងដោយចូឡតណ្ហាសង្ខយសូត្រ និងវិមុត្តិសូត្រ ។ ពាក្យ

នេះថា **សក្កំ សោ បរិបុច្ឆតិ** ក៏គួរសម្តែងដោយចូឡតណ្ហាសង្ខយសូត្រ និង វិមុត្តិសូត្រនោះដូចគ្នា ។ បទថា **សុធម្មាយាភិតោ សភំ** សេចក្តីថា ក្បែរទីប្រជុំឈ្មោះ សុធម្មា ។ ឯសុធម្មសភានេះ នៅក្នុងព្រហ្មលោក មិនមែនក្នុងជាន់តាវត្តិង្ស ដែលឈ្មោះថា ទេវលោក វៀរចាកសុធម្មសភាមិនមាន ។

បទថា **ព្រហ្មលោកេ បភស្សរំ** សេចក្តីថា ពន្លឺរបស់ព្រះមានព្រះភាគ ដែលយាងទៅជាមួយពួកសាវក មានព្រះសារីបុត្រ ព្រះមោគ្គល្លាន និង ព្រះមហាកស្សបជាដើម ក្នុងព្រហ្មលោក ហើយអង្គុយចូលតេជោធាតុ ។ ព្រោះថា សម័យមួយ ព្រះមានព្រះភាគ ទ្រង់ជ្រាបចិត្តរបស់ពួកព្រហ្មដែលអង្គុយប្រជុំក្នុងសុធម្មទេវសភាក្នុងព្រហ្មលោក គិតថា មានឬហ្ន៎ សមណៈ ឬព្រាហ្មណ៍ណាម្នាក់ដែលមានឫទ្ធិច្រើនយ៉ាងនេះ អាចមកក្នុងទីនេះ ទើបទ្រង់យាងទៅទីនោះ ប្រថាប់គង់ត្រង់ទីបំផុតគណៈនៃព្រហ្ម ទ្រង់ចូលតេជោធាតុ ទ្រង់បានត្រិះរិះដល់ការមករបស់ព្រះមហាមោគ្គល្លានជាដើម ។

សាវកទាំងនោះ បានទៅថ្វាយបង្គំព្រះសាស្តា ហើយទៅអង្គុយចូលតេជោធាតុក្នុងទិសមួយ ១ អង្គ ។ ទើបព្រហ្មលោកទាំងមូលមានពន្លឺតែមួយ ។ ព្រះសាស្តា ទ្រង់បានសម្តែងធម៌ ប្រកាសសច្ចៈ ៤ ។ វេលាចប់ទេសនា ព្រហ្មច្រើនពាន់ តាំងនៅក្នុងមគ្គ និងផល ។ ព្រះថេរៈសំដៅយកធម៌នេះ ទើបពោលគាថានេះ ។ ឯអត្ថនោះ គួរសម្តែងដោយពកព្រហ្មសូត្រ ។ បទថា **វិមោក្ខេន អផស្សយិ** បានដល់ ពាល់ត្រូវដោយការរួចផុត គឺឈាននោះឯង ។ បទថា **វនំ** បានដល់ ជម្ពូទ្វីប ។ បទថា **បុព្វវិទេហានំ** បានដល់

ទ្វីបដែលមានឈ្មោះថា បុព្វវិទេហផងដែរ ។ បទថា **យេ ច ភូមិសយា ឆរា** សេចក្ដីថា ពួកអមរគោយានទ្វីប និងអ្នកឧត្តរកុរុទ្វីប ឈ្មោះថា ពួកនរៈដេកលើផែនដី មានពាក្យអធិប្បាយថា ពាល់ត្រូវមនុស្សទាំងអស់នោះ ។ សេចក្ដីនេះ គួរសម្ដែងដោយការទូន្មាននន្ទោបនន្ទនាគរាជ រឿងនេះលោកឲ្យពិស្ដារហើយ ដោយឫទ្ធិកថា ក្នុងបករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ ។ បទថា **អបុញ្ញំ បសវិ** បានដល់ បានចំពោះនូវវត្ថុដែលមិនមែនបុណ្យ ។ បទថា **អាសំ មាកាសិ ភិក្ខុសុ** សេចក្ដីថា កុំបានធ្វើការសង្ឃឹមនេះថា អញនឹងឲ្យភិក្ខុនេះវិនាស អញនឹងបៀតបៀនភិក្ខុ ។ ពាក្យដ៏សេស ក្នុងបទទាំងពួងងាយយល់ទាំងអស់ហើយ ។៙

មារតជ្ជនីយសូត្រ ចប់

សូត្រទី ១០ ចប់

ចូឡយមកវគ្គទី ៥ ចប់

ការពន្យល់សេចក្ដីព្រះសូត្រ មូលបណ្ណាសកៈនៃអដ្ឋកថាមជ្ឈិមនិកាយ

ឈ្មោះបបញ្ចសូទនី ចប់ហើយដោយប្រការដូច្នេះ

អដ្ឋកថា ដែលរួមសូត្រក្នុងគម្ពីរបណ្ណាសក

ដែលប្រដាប់ដោយវគ្គ ៥ ចប់ហើយ

# សុត្តន្តបិដក

## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក

## ចតុត្ថភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

## គហបតិវគ្គ

## កន្ទរកសូត្រទី ១

[ ១ ] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅជិតឆ្នេរស្រះគគ្គរា ក្បែរក្រុងចម្ប៉ា ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ។ សម័យនោះឯង បេស្សបុត្តាពោហបុត្រ និងកន្ទរកបរិព្វាជក នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបបេស្សបុត្តាពោហបុត្រថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ឯកន្ទរកបរិព្វាជកនិយាយរាក់ទាក់ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់និងពាក្យដែលគួររឭកហើយ ឋិតនៅក្នុងទីដ៏សមគួរ ។ លុះកន្ទរកបរិព្វាជកឋិតនៅក្នុងទីដ៏សមគួរហើយ ក្រឡេកមៀងមើលភិក្ខុសង្ឃ ដែលគង់នៅស្ងៀមស្ងាត់ហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់ ព្រោះព្រះគោតមដ៏ចម្រើន បានប្រដៅភិក្ខុសង្ឃមានប្រមាណប៉ុណ្ណេះ ឲ្យប្រតិបត្តិដោយល្អ បពិត្រព្រះគោតមដ៏ចម្រើន ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា*

មានហើយក្នុងអតីតកាល តើព្រះអរហន្តសម្មាសម្ពុទ្ធមានព្រះភាគទាំងឡាយនោះ ប្រដៅភិក្ខុសង្ឃដោយល្អ អស់កំណត់ត្រឹមប៉ុណ្ណោះ ដូចជាភិក្ខុសង្ឃដែលព្រះគោតមដ៏ចម្រើនប្រដៅដោយល្អ ក្នុងកាលឥឡូវនេះដែរឬ បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា នឹងមានក្នុងអនាគតកាល តើព្រះអរហន្តសម្មាសម្ពុទ្ធមានព្រះភាគទាំងឡាយនោះ នឹងប្រដៅភិក្ខុសង្ឃដោយល្អ អស់កំណត់ត្រឹមប៉ុណ្ណោះ ដូចជាភិក្ខុសង្ឃ ដែលព្រះគោតមដ៏ចម្រើនប្រដៅដោយល្អក្នុងកាលឥឡូវនេះដែរឬ ។

[ ២ ] ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ម្នាលកន្ទរកៈ ដំណើរនុ៎ះយ៉ាងនេះហើយ ម្នាលកន្ទរកៈ ដំណើរនោះយ៉ាងនេះហើយ ម្នាលកន្ទរកៈ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា មានហើយក្នុងអតីតកាល ព្រះអរហន្តសម្មាសម្ពុទ្ធ មានព្រះភាគទាំងឡាយនោះ ក៏បានប្រដៅភិក្ខុសង្ឃដោយល្អ អស់កំណត់ត្រឹមប៉ុណ្ណោះឯង ដូចជាភិក្ខុសង្ឃ ដែលតថាគតប្រដៅដោយល្អ ក្នុងកាលឥឡូវនេះដែរ ម្នាលកន្ទរកៈ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា នឹងមានក្នុងអនាគតកាល ព្រះអរហន្តសម្មាសម្ពុទ្ធមានព្រះភាគទាំងឡាយនោះ ក៏នឹងប្រដៅភិក្ខុសង្ឃដោយល្អ អស់កំណត់ត្រឹមប៉ុណ្ណោះឯង ដូចជាភិក្ខុសង្ឃ ដែលតថាគតប្រដៅដោយល្អ ក្នុងកាលឥឡូវនេះដែរ ម្នាលកន្ទរកៈ ព្រោះក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុខ្លះ ជាអរហន្តខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយៈរួចហើយ បានធ្វើសោឡសកិច្ចរួចស្រេច បានដាក់ភារៈចុះហើយ ធ្វើប្រយោជន៍របស់ខ្លួនឲ្យស្រេចហើយ អស់សំយោជនៈក្នុងភពហើយ មានចិត្តផុតស្រឡះ

ហើយ ព្រោះត្រាស់ដឹងដោយប្រពៃ ម្នាលកន្ទរកៈ មួយទៀត ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុខ្លះ ជាសេក្ខបុគ្គល រក្សាសីលជាប់ជានិច្ច ប្រព្រឹត្តនៅក្នុងសីលជាប់ជានិច្ច មានបញ្ញាខ្ជាប់ខ្ជួន ប្រព្រឹត្តនៅក្នុងបញ្ញាខ្ជាប់ខ្ជួន ពួកភិក្ខុទាំងនោះ តម្កល់ចិត្តស៊ប់ក្នុងសតិប្បដ្ឋាន ៤ ឯសតិប្បដ្ឋាន ៤ នោះ តើដូចម្តេចខ្លះ ម្នាលកន្ទរកៈ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ ដោយប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈ និងស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក គឺ កាយ ។ ពិចារណានូវវេទនាក្នុងវេទនា ដោយប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈ និងស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ពិចារណានូវចិត្តក្នុងចិត្ត ដោយប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈ និងស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ពិចារណានូវធម៌ក្នុងធម៌ ដោយប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈ និងស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។

[ ៣ ] កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ បេស្សហត្ថារោហបុត្រ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ ព្រោះសតិប្បដ្ឋានទាំង ៤ ដែលព្រះអង្គទ្រង់បញ្ញត្តិហើយដោយល្អនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធដល់ពួកសត្វ ដើម្បីកន្លងបង់នូវសេចក្តីសោក ខ្សឹកខ្សួល ដើម្បីធ្វើទុក្ខ

និងទោមនស្សឲ្យអស់ទៅ ដើម្បីបាននូវអរិយមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានជាប្រាកដ បពិត្រព្រះអង្គដ៏ចម្រើន ឯពួកខ្ញុំព្រះអង្គជាគ្រហស្ថស្លៀកពាក់ស តែងមានចិត្តតាំងល្អ ក្នុងសតិប្បដ្ឋានទាំង ៤ នេះ មួយជង់ មួយកាល បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គ ជាអ្នកពិចារណានូវកាយក្នុងកាយនេះ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈ និងស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ពួកខ្ញុំព្រះអង្គ តែងពិចារណានូវវេទនាក្នុងវេទនា មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈ និងស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ពួកខ្ញុំព្រះអង្គ តែងពិចារណានូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈ និងស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ពួកខ្ញុំព្រះអង្គ តែងពិចារណានូវធម៌ក្នុងធម៌ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានសម្បជញ្ញៈ និងស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា កាលបើមនុស្សមានចិត្តសាំញ៉ាំយ៉ាងនេះ កាលបើមនុស្សមានចិត្តស្រកាក មិនបរិសុទ្ធយ៉ាងនេះ កាលបើមនុស្សមានកិច្ចកល ប្រព្រឹត្តទៅយ៉ាងនេះ ព្រះមានព្រះភាគគង់ជ្រាបនូវសេចក្តីប្រតិបត្តិ ដែលជាប្រយោជន៍ និងមិនមែនជាប្រយោជន៍ របស់សត្វទាំងឡាយបានប្រាកដ បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សមានចិត្តសាំញ៉ាំ បពិត្រព្រះអង្គដ៏ចម្រើន ពួកសត្វចិញ្ចឹម មានចិត្តឲ្យងាយយល់

បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខាងខ្ញុំព្រះអង្គ អាចទូន្មានដំរីដែលល្មមទូន្មានបាន ក្នុងខណៈដែលទូន្មានដំរីមួយរំពេចនោះ នឹងដើរទៅដើរមកកាន់នគរចម្ប៉ាបាន ( តែលុះយូរទៅ ) ដំរីនឹងធ្វើកិច្ចកលគ្រប់យ៉ាង គឺក្រអឺតក្រអោង កោងកាច វៀចវេរ គ្រលែងខ្លួន ឲ្យប្រាកដឡើង បពិត្រព្រះអង្គដ៏ចម្រើន ចំណែកពួកជនជាខ្ញុំកំដរក្តី អ្នកបម្រើក្តី អ្នកស៊ីឈ្នួលក្តី របស់ខ្ញុំព្រះអង្គ តែងប្រព្រឹត្តទៅដោយកាយផ្សេង ដោយវាចាផ្សេង ទាំងចិត្តរបស់វាក៏ផ្សេង បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា កាលបើមនុស្សមានចិត្តសាំញ៉ាំយ៉ាងនេះ កាលបើមនុស្សមានចិត្តស្រកាក មិនបរិសុទ្ធយ៉ាងនេះ កាលបើមនុស្សមានកិច្ចកល ប្រព្រឹត្តទៅយ៉ាងនេះ ព្រះមានព្រះភាគ គង់ជ្រាបនូវសេចក្តីប្រតិបត្តិជាប្រយោជន៍ និងមិនជាប្រយោជន៍ ( របស់សត្វទាំងនោះ ) ជាប្រាកដ បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សមានចិត្តសាំញ៉ាំ បពិត្រព្រះអង្គដ៏ចម្រើន ពួកសត្វចិញ្ចឹម មានចិត្តងាយយល់ ។

[ ៤ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលបេស្សៈ ដំណើរនុ៎ះយ៉ាងនេះហើយ ម្នាលបេស្សៈ ដំណើរនុ៎ះយ៉ាងនេះហើយ ម្នាលបេស្សៈ ពួកមនុស្សមានចិត្តសាំញ៉ាំ ម្នាលបេស្សៈ ពួកសត្វចិញ្ចឹមមានចិត្តឲ្យងាយយល់ ម្នាលបេស្សៈ បុគ្គល ៤ ពួកនេះ តែងមានក្នុងលោក បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ម្នាលបេស្សៈ ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាអ្នកដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួន ១ ម្នាលបេស្សៈ ក្នុងលោកនេះ បុគ្គល

ពួកខ្លះ ជាអ្នកដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាមដើម្បីដុតកម្តៅអ្នកដទៃ ១ ម្នាលបេស្ស: ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាអ្នកដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯងផង ជាអ្នកដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាមដើម្បីដុតកម្តៅអ្នកដទៃផង ១ ម្នាលបេស្ស: ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាអ្នកមិនដុតកម្តៅខ្លួនឯង មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ជាអ្នកមិនដុតកម្តៅអ្នកដទៃ មិនប្រកបសេចក្តីព្យា-យាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលជាអ្នកមិនដុតកម្តៅខ្លួនឯង ទាំងមិនដុតកម្តៅអ្នកដទៃនោះ ជាអ្នកអស់សេចក្តីស្រេកឃ្លានក្នុងបច្ចុប្បន្ននេះ ជាអ្នករលត់ទុក្ខ មានសេចក្តីត្រជាក់ ទទួលនូវសេចក្តីសុខ រមែងមានខ្លួនដ៏ប្រសើរ ១ ម្នាលបេស្ស: បណ្តាបុគ្គលទាំង ៤ ពួកនេះ តើបុគ្គលពួកណា ធ្វើចិត្តអ្នកឲ្យត្រេកអរបាន ។

[ ៥ ] បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង បុគ្គលនេះ មិនធ្វើចិត្តខ្ញុំព្រះអង្គឲ្យត្រេកអរទេ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលនេះ ក៏ធ្វើចិត្តរបស់ខ្ញុំព្រះអង្គ ឲ្យត្រេកអរមិនបានដែរ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯងផង ជាអ្នកដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃផង បុគ្គលនេះ ក៏ធ្វើចិត្តរបស់ខ្ញុំព្រះអង្គ ឲ្យត្រេកអរមិនបានដែរ បពិត្រព្រះអង្គដ៏ចម្រើន

លុះតែបុគ្គលណា មិនដុតកម្តៅខ្លួនឯង មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ជាអ្នកមិនដុតកម្តៅអ្នកដទៃ មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលជាអ្នកមិនដុតកម្តៅខ្លួនឯង ទាំងមិនដុតកម្តៅអ្នកដទៃនោះ ជាអ្នកអស់សេចក្តីស្រេកឃ្លាន ក្នុងបច្ចុប្បន្ននេះ ជាអ្នករលត់ទុក្ខ មានសេចក្តីត្រជាក់ ទទួលសេចក្តីសុខ ជាអ្នកមានខ្លួនប្រសើរ បុគ្គលនេះ ទើបធ្វើចិត្តរបស់ខ្ញុំព្រះអង្គឲ្យត្រេកអរបាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលបេស្ស: ចុះបុគ្គល ៣ ពួកនេះ ធ្វើចិត្តរបស់អ្នក ឲ្យត្រេកអរមិនមានកើតដោយហេតុអ្វី ។

[ ៦ ] បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង បុគ្គលនោះឈ្មោះថាធ្វើខ្លួនឯង ដែលប្រាថ្នាសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខ ឲ្យក្តៅក្រហាយអន្ទះអន្ទែង ដោយហេតុនេះឯង បានជាបុគ្គលនេះ ធ្វើចិត្តរបស់ខ្ញុំព្រះអង្គឲ្យត្រេកអរមិនបាន បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលនោះឈ្មោះថាធ្វើអ្នកដទៃដែលប្រាថ្នាសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខ ឲ្យក្តៅក្រហាយអន្ទះអន្ទែង ដោយហេតុនេះឯង បានជាបុគ្គលនេះ ធ្វើចិត្តរបស់ខ្ញុំព្រះអង្គឲ្យត្រេកអរមិនបាន បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ដែលដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯងផង ជាអ្នកដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃផង បុគ្គលនោះឈ្មោះថាធ្វើខ្លួនឯង និងអ្នកដទៃ ដែល

ប្រាថ្នាសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខ ឲ្យក្តៅក្រហាយក្រហល់អន្ទះអន្ទែង ដោយហេតុនេះឯង បានជាបុគ្គលនេះធ្វើចិត្តរបស់ខ្ញុំព្រះអង្គឲ្យត្រេកអរមិនបាន បពិត្រព្រះអង្គដ៏ចម្រើន លុះតែបុគ្គលណា មិនដុតកម្តៅខ្លួនឯង មិនប្រកបសេចក្តីព្យាយាមដើម្បីដុតកម្តៅខ្លួនឯង ជាអ្នកមិនដុតកម្តៅអ្នកដទៃ មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលជាអ្នកមិនដុតកម្តៅខ្លួនឯង មិនដុតកម្តៅអ្នកដទៃនោះ ជាអ្នកអស់សេចក្តីស្រេកឃ្លានក្នុងបច្ចុប្បន្ន ជាអ្នករលត់ទុក្ខ មានសេចក្តីត្រជាក់ ទទួលសេចក្តីសុខ ជាអ្នកមានខ្លួនប្រសើរ បុគ្គលនេះទើបធ្វើចិត្តរបស់ខ្ញុំព្រះអង្គ ឲ្យជ្រះថ្លា ឲ្យត្រេកអរបាន ដោយហេតុនេះឯង បពិត្រព្រះអង្គដ៏ចម្រើន ក៏ឥឡូវនេះខ្ញុំព្រះអង្គនឹងលាទៅ ព្រោះខ្ញុំព្រះអង្គមានកិច្ចច្រើន មានអំពើដែលត្រូវធ្វើច្រើន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលបេស្សៈ អ្នកចូរដឹងកាលនៃដំណើរទៅរបស់អ្នក ក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ បេស្សហត្ថារោហបុត្រ ត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ក្រោកអំពីអាសនៈ រួចថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ក៏ដើរចេញទៅ ។

[ ៧ ] កាលដែលបេស្សហត្ថារោហបុត្រ ចេញទៅមិនទាន់បានយូរប៉ុន្មានខាងក្រោយនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ទៅនឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ បេស្សហត្ថារោហបុត្រ ជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ បេស្សហត្ថារោហបុត្រ ជាអ្នកមានបញ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបេស្សហត្ថារោហបុត្រ អង្គុយនៅមួយស្របក់ទៀត ទម្រាំតថាគតនឹងចែកនូវបុគ្គល

ទាំង ៤ ពួកនេះដោយពិស្តារសិន គាត់មុខជានឹងបានសម្រេចប្រយោជន៍ច្រើន ( ដល់សោតាបត្តិផល ) ម្នាលភិក្ខុទាំងឡាយ តែបើទុកជាដូច្នោះ បេស្សហត្ថារោហបុត្រ ក៏គង់តែបានប្រកបដោយប្រយោជន៍ច្រើន ត្រឹមហេតុប៉ុណ្ណោះដែរ ។ ពួកភិក្ខុក្រាបបង្គំទូលថា ព្រះមានព្រះភាគ គប្បីចែកបុគ្គល ៤ ពួកនេះ ដោយសេចក្តីពិស្តារ ដោយភាសិតណា បពិត្រព្រះមានព្រះភាគ នេះជាកាលគួរដល់ភាសិតនុ៎ះ បពិត្រព្រះសុគត នេះជាកាលគួរដល់ភាសិតនុ៎ះ ពួកភិក្ខុបើបានស្តាប់ភាសិត របស់ព្រះមានព្រះភាគដោយពិស្តារហើយ នឹងចងចាំបាន ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរប្រុងចាំស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែងឥឡូវនេះ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ ។

[ ៨ ] ព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាអ្នកមានកាយអាក្រាត លះបង់មារយាទល្អ ជាអ្នកប្រព្រឹត្តហត្ថាវលេខនៈ ជាអ្នកមិនទទួលភត្តដែលគេនិមន្តថា សូមលោកដ៏ចម្រើនចូលមក ជាអ្នកមិនទទួលភត្តដែលគេនិមន្តថា សូមលោកដ៏ចម្រើនរង់ចាំសិន មិនត្រេកអរនឹងភិក្ខាដែលគេនាំមកចាំមុន មិនត្រេកអរនឹងភិក្ខាដែលគេធ្វើចំពោះខ្លួន មិនត្រេកអរនឹងការនិមន្តន៍ បុគ្គលនោះមិនទទួលភិក្ខាអំពីមាត់ឆ្នាំង មិនទទួលភិក្ខាអំពីមាត់កូនល្អី មិនទទួលភិក្ខាក្នុងចន្លោះធរណីទ្វារ មិនទទួលភិក្ខាក្នុងចន្លោះកំណាត់ឈើ មិនទទួលភិក្ខាក្នុង

ចន្លោះអង្រ្គែ មិនទទួលភិក្ខារបស់ជនពីរនាក់ ដែលកំពុងបរិភោគ មិនទទួលភិក្ខារបស់ស្រ្តីមានគភ៌ មិនទទួលភិក្ខារបស់ស្រ្តីដែលកំពុងបំបៅកូន មិនទទួលភិក្ខារបស់ស្រ្តីដែលកំពុងនៅក្នុងចន្លោះបុរស មិនទទួលភិក្ខាដែលគេអង្គាសគ្នាធ្វើ មិនទទួលភិក្ខាក្នុងទីដែលមានសុនខនៅចាំ មិនទទួលភិក្ខាដែលរុយរោម មិនបរិភោគត្រី មិនបរិភោគសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកថ្នាំត្រាំ ។ បុគ្គលនោះ ទទួលភិក្ខាចំពោះតែក្នុងផ្ទះមួយ ឬទទួលបាយតែមួយពំនូត ទទួលភិក្ខាចំពោះតែក្នុងផ្ទះពីរ ឬទទួលបាយតែពីរពំនូត ។បេ។ ទទួលភិក្ខាចំពោះតែក្នុងផ្ទះ ៧ ឬទទួលបាយតែ ៧ ពំនូត ចិញ្ចឹមអត្តភាពដោយភិក្ខាក្នុងភាជន៍តូចមួយក៏មាន ចិញ្ចឹមអត្តភាពដោយភិក្ខាក្នុងភាជន៍ពីរក៏មាន ។បេ។ ចិញ្ចឹមអត្តភាពដោយភិក្ខាក្នុងភាជន៍ ៧ ក៏មាន បរិភោគអាហាររំលង ១ ថ្ងៃក៏មាន បរិភោគអាហាររំលងពីរថ្ងៃក៏មាន ។បេ។ បរិភោគអាហាររំលង ៧ ថ្ងៃក៏មាន ប្រកបរឿយៗ នូវព្យាយាមក្នុងកិរិយាបរិភោគនូវភត្ត ដោយការផ្លាស់ប្តូរគ្នា កន្លះខែដូច្នេះឯង ។ បុគ្គលនោះ បរិភោគបន្លែស្រស់ក៏មាន បរិភោគស្កួយក៏មាន បរិភោគគ្រាប់ស្មៅគែលលកក៏មាន បរិភោគចំនៀរស្បែកក៏មាន បរិភោគសារាយក៏មាន បរិភោគកុណ្ឌកក៏មាន បរិភោគបាយក្តាំងក៏មាន បរិភោគម្សៅក៏មាន បរិភោគស្មៅក៏មាន បរិភោគអាចម៍គោក៏មាន បរិភោគមើម និងផ្លែក្នុងព្រៃក៏មាន បរិភោគផ្លែដែលជ្រុះចុះឯងក៏មាន ។ បុគ្គលនោះប្រើប្រាស់សំពត់ ដែលត្បាញដោយសម្បកធ្មៃក៏មាន ប្រើប្រាស់សំពត់ដែលត្បាញលាយគ្នាក៏មាន ប្រើប្រាស់សំពត់ដែលគេរុំសពក៏មាន ប្រើ

ប្រាស់សំពត់បន្ទុក្កូលក៏មាន ប្រើប្រាស់សំពត់សម្បកឈើក៏មាន ប្រើប្រាស់ស្បែកខ្លាក៏មាន ប្រើប្រាស់ស្បែកខ្លាទាំងក្រចកក៏មាន ប្រើប្រាស់ស្បូវក្រងក៏មាន ប្រើប្រាស់សំពត់ដែលត្បាញដោយសម្បកក្រចៅក៏មាន ប្រើប្រាស់សំពត់ដែលត្បាញដោយសម្បកផ្លៃឈើក៏មាន ប្រើប្រាស់សំពត់កម្ពល ដែលត្បាញដោយសក់ក៏មាន ប្រើប្រាស់សំពត់កម្ពលត្បាញដោយរោមសត្វក៏មាន ប្រើប្រាស់សំពត់ដែលត្បាញដោយស្លាបមៀមក៏មាន ជាអ្នកទុកសក់ និងពុកមាត់ ពុកចង្កា ប្រកបព្យាយាមក្នុងការទុកសក់ និងពុកមាត់ ពុកចង្កាក៏មាន ជាអ្នកប្រព្រឹត្តឈរ ហាមនូវការអង្គុយក៏មាន ជាអ្នកអង្គុយច្រហោង ប្រកបព្យាយាមអង្គុយច្រហោងក៏មាន ជាអ្នកដេកលើបន្លា សម្រេចនូវការដេកលើបន្លាក៏មាន ប្រកបព្យាយាមក្នុងការចុះត្រាំទឹកក្នុង ១ ថ្ងៃ ៣ ដងក៏មាន ខ្វល់ខ្វាយព្យាយាម ដើម្បីធ្វើកាយឲ្យក្តៅរោលរាលច្រើនប្រការ មានសភាពយ៉ាងនេះ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ តថាគតហៅថា អ្នកដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ។

[ ៩ ] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាអ្នកសម្លាប់ចៀម សម្លាប់ជ្រូក សម្លាប់សត្វស្លាប សម្លាប់ម្រឹគ ជាអ្នកនេសាទត្រី ជាចោរ ជាអ្នកពិឃាតចោរ ជាអ្នកគ្រប់គ្រងគុក ពុំនោះសោត ពួកជនណាមួយក្រៅពីនេះ ជាអ្នកមានអំពើអាក្រក់ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះតថាគតហៅថា អ្នកដុតកម្តៅអ្នកដទៃ ប្រកប

សេចក្តីព្យាយាមដើម្បីដុតកម្តៅអ្នកដទៃ ។

[ ១០ ] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯងផង ជាអ្នកដុតកម្តៅបុគ្គលដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃផង តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ក្នុងលោកនេះ បុគ្គលពួកខ្លះ ជាស្តេច ជាក្សត្រ ដែលបានមុទ្ធាភិសេកក្តី ជាព្រាហ្មណមហាសាលក្តី ស្តេចនោះឲ្យគេសង់សណ្ឋាគារសាលាថ្មី ១ ក្នុងទិសខាងកើតនៃព្រះនគរ ហើយកោរសក់ និងពុកមាត់ពុកចង្កា ស្លៀកពាក់ស្បែកខ្លាទាំងក្រចក លាបកាយដោយទឹកដោះថ្លា និងប្រេង ហើយអេះខ្នងដោយស្នែងម្រឹគ ចូលទៅកាន់សណ្ឋាគារសាលា ជាមួយនឹងមហេសីផង ព្រាហ្មណបុរោហិតផង ស្តេចនោះ សម្រេចទីក្រឡាព្រះបន្ទំលើផែនដី ដែលប្រកបដោយវត្ថុមានពណ៌ខៀវ ដែលមិនស្អាតក្នុងរោងនោះ ស្តេចនោះសោយទឹកដោះស្រស់ចំពោះដោះមួយរបស់មេគោមួយ ដែលមានកូនមានរូបស្រដៀងនឹងមេ មហេសីសោយទឹកដោះស្រស់ចំពោះដោះទី ២ ព្រាហ្មណបុរោហិតផឹកទឹកដោះស្រស់ចំពោះដោះទី ៣ បូជាភ្លើង ដោយទឹកដោះស្រស់ ចំពោះដោះទី ៤ ឯទឹកដោះសេសសល់ពីនោះ ទើបឲ្យកូនគោបៅ ស្តេចនោះ ទ្រង់ត្រាស់បង្គាប់យ៉ាងនេះថា ចូរអ្នកទាំងឡាយសម្លាប់គោឧសភប្រមាណប៉ុណ្ណោះ ដើម្បីប្រយោជន៍ដល់ការបូជា ចូរសម្លាប់កូនគោឈ្មោលតូចប្រមាណប៉ុណ្ណោះ ដើម្បីប្រយោជន៍ដល់ការបូជា ចូរសម្លាប់កូនគោញីតូច ប្រមាណប៉ុណ្ណោះ ដើម្បីប្រយោជន៍ដល់ការបូជា ចូរសម្លាប់ពពែប្រមាណប៉ុណ្ណោះ ដើម្បីប្រ-

យោជន៍ដល់ការបូជា ចូរសម្លាប់ចៀមប្រមាណប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់ការបូជា ចូរសម្លាប់សេះប្រមាណប៉ុណ្ណេះ ដើម្បីប្រយោជន៍ដល់ការបូជា ចូរកាប់ឈើប្រមាណប៉ុណ្ណេះ ដើម្បីធ្វើប្រាសាទ ចូរអារកាត់គ្រឿងឈើប្រមាណប៉ុណ្ណេះ ដើម្បីធ្វើរបង និងកម្រាលដូច្នេះ ពួកជនណាជាខ្ញុំកំដរក្តី ជាអ្នកបម្រើក្តី ជាអ្នកធ្វើការស៊ីឈ្នួលក្តី របស់ស្តេចនោះ ពួកជនទាំងនោះឯង កាលបើត្រូវអាជ្ញាគំរាមហើយ ត្រូវភ័យគំរាមហើយ ក៏មានមុខទទឹកដោយទឹកភ្នែក ទ្រហោយំ ធ្វើនូវការបន់ស្រន់បួងសួង ( កុំឲ្យស្លាប់ ) ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះ តថាគតហៅថា អ្នកដុតកម្តៅខ្លួនឯង ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯងផង ជាអ្នកដុតកម្តៅអ្នកដទៃ ប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃផង ។

[ ១១ ] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលមិនដុតកម្តៅខ្លួនឯង មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ជាអ្នកមិនដុតកម្តៅអ្នកដទៃ មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលនោះ ឈ្មោះថា អ្នកមិនដុតកម្តៅខ្លួនឯង មិនដុតកម្តៅអ្នកដទៃ ជាអ្នកអស់សេចក្តីស្រេកឃ្លាន ក្នុងបច្ចុប្បន្ននេះ ជាអ្នករលត់ទុក្ខ មានសេចក្តីត្រជាក់ ទទួលសេចក្តីសុខ ជាអ្នកប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតកើតឡើងក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជា និងចរណៈ មានដំណើរល្អទៅកាន់ព្រះនិព្វាន ដឹងច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ជាសារថីអ្នកទូន្មានបុរស ដែលគួរទូន្មានបាន ជាគ្រូនៃទេវតា

និងមនុស្សទាំងឡាយ បានត្រាស់ដឹងសច្ចធម៌ លែងត្រឡប់មកកាន់ភពថ្មីទៀត ព្រះតថាគតនោះ បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញារបស់ខ្លួន នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយប្រកាស ព្រះតថាគតនោះ សម្តែងធម៌មានលម្អបទដើម បទកណ្តាល និងបទចុង ព្រះតថាគតប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ។ គហបតី ឬកូននៃគហបតី ឬជនអ្នកកើតក្នុងត្រកូលណាមួយ ក្នុងកាលជាខាងក្រោយ រមែងបានស្តាប់ធម៌នោះ លុះគេស្តាប់ធម៌នោះហើយ ក៏បាននូវសទ្ធាក្នុងព្រះតថាគត លុះគេប្រកបដោយសទ្ធានោះ រមែងពិចារណាដូច្នេះថា ឃរាវាស ចង្អៀតណាស់ ជាផ្លូវនៃធូលី បព្វជ្ជាទើបមានឱកាសល្អ កាលបើអាត្មាអញ នៅជាគ្រហស្ថគ្រប់គ្រងផ្ទះ ក៏មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌តែមួយយ៉ាង ឲ្យបរិសុទ្ធតែមួយយ៉ាង ដូចជាស័ង្ខដែលគេខាត់ហើយនោះទេ បើដូច្នោះ គួរតែអាត្មាអញ កោរសក់ និងពុកមាត់ ពុកចង្កា រួចស្លៀកដណ្តប់សំពត់ជ្រលក់ទឹកចត់ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ លុះសម័យខាងក្រោយមក ជននោះក៏លះបង់គំនរទ្រព្យតិចក្តី លះគំនរទ្រព្យច្រើនក្តី លះបង់ញាតិវង្សតិចក្តី លះបង់ញាតិវង្សច្រើនក្តី ហើយកោរសក់ និងពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់ជ្រលក់ទឹកចត់ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។

[ ១២ ] លុះជននោះបួសយ៉ាងនេះហើយ ដល់ព្រមដោយសិក្ខា និង

សាជីវៈសម្រាប់ភិក្ខុទាំងឡាយ ហើយលះបាណាតិបាត ជាអ្នកវៀរចាក បាណាតិបាត ដាក់ចុះនូវអាជ្ញា ដាក់ចុះនូវគ្រឿងសស្ត្រា មានសេចក្ដីអៀនខ្មាស ប្រកបដោយសេចក្ដីអាណិតអាសូរ ជាអ្នកមានសេចក្ដីអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ជាអ្នកលះអទិន្នាទាន វៀរចាកអទិន្នាទាន កាន់ យកតែទ្រព្យដែលគេឲ្យ ប្រាថ្នាតែទ្រព្យ ដែលគេឲ្យ មានខ្លួនស្អាត មិនមែន ជាអ្នកលួច ជាអ្នកលះអព្រហ្មចរិយធម៌ ប្រព្រឹត្តព្រហ្មចរិយធម៌ ប្រព្រឹត្តឆ្ងាយ វៀរចាកមេថុន ជាធម៌សម្រាប់អ្នកស្រុក ជាអ្នកលះមុសាវាទ វៀរចាក មុសាវាទ ពោលតែពាក្យពិត តតែពាក្យពិត មានសម្ដីខ្ជាប់ខ្ជួន គួរឲ្យអ្នកផង ជឿបាន មិនពោលពាក្យឲ្យខុសចំពោះសត្វលោក ជាអ្នកលះបិសុណាវាចា វៀរចាកបិសុណាវាចា ឮអំពីទីនេះ មិននាំយកទៅប្រាប់ទីនោះ ដើម្បីបំបែក ពួកជននេះ ឬឮក្នុងទីឯណោះ មិននាំមកប្រាប់ដល់ពួកជននេះ ដើម្បីបំបែកពួក ជនឯណោះ ជាអ្នកពោលពាក្យផ្សះផ្សាជនដែលបែកគ្នាហើយ ឬជួយជ្រោម ជ្រែងជនដែលព្រមព្រៀងគ្នាស្រាប់ហើយ មានសេចក្ដីព្រមព្រៀង ជាទីត្រេកអរ ត្រេកអរក្នុងសេចក្ដីព្រមព្រៀង ពេញចិត្តក្នុងសេចក្ដីព្រមព្រៀង ពោល តែសម្ដីជាទីធ្វើនូវសេចក្ដីព្រមព្រៀង ជាអ្នកលះផរុសវាចា វៀរចាកផរុសវាចា វាចាណាមិនមានទោស សុខដល់ត្រចៀក គួរជាទីស្រឡាញ់ គួរយកទុកក្នុង ហឫទ័យ ជាពាក្យរបស់អ្នកក្រុង ជាទីប្រាថ្នារបស់ជនច្រើន ជាទីគាប់ចិត្តរបស់ ជនច្រើន ក៏ពោលតែវាចាមានសភាពដូច្នោះ ជាអ្នកលះសម្ផប្បលាបៈ វៀរ ចាកសម្ផប្បលាបៈ ពោលតែក្នុងកាលដែលគួរ ពោលតែពាក្យដែលពិត

ប្រាកដ ពោលតែអត្ថ ពោលតែធម៌ ពោលតែវិន័យ ពោលតែវាចាដែលគួរតម្កល់ទុកក្នុងហឫទ័យ ជាវាចាមានគ្រឿងអាងតាមកាលគួរ មានកំណត់ប្រកបដោយប្រយោជន៍ ។ ភិក្ខុនោះវៀរចាកការផ្តាច់ផ្តិលពីជគាម និងកូតគាមជាអ្នកបរិភោគភត្តតែមួយពេល វៀរចាកការបរិភោគក្នុងវេលារាត្រី វៀរចាកការបរិភោគក្នុងកាលខុស វៀរចាកការរាំ ច្រៀង ប្រគំ និងការមើលល្បែងផ្សេងៗ វៀរចាកការទ្រទ្រង់ប្រដាប់តាក់តែង និងការស្អិតស្អាង ( រាងកាយ ) ដោយផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ វៀរចាកការដេក ឬអង្គុយលើអាសនៈដ៏ខ្ពស់ និងអាសនៈដ៏ប្រសើរ វៀរចាកការទទួលមាសនិងប្រាក់ វៀរចាកការទទួលស្រូវស្រស់ វៀរចាកការទទួលសាច់ឆៅ វៀរចាកការទទួលស្ត្រី និងក្មេងស្ត្រី វៀរចាកការទទួលខ្ញុំស្រី និងខ្ញុំប្រុស វៀរចាកការទទួលពពែ និងចៀម វៀរចាកការទទួលមាន់ និងជ្រូក វៀរចាកការទទួលដំរី គោ សេះឈ្មោល និងសេះញី វៀរចាកការទទួលស្រែ និងចម្ការ វៀរចាកការប្រកបក្នុងកិច្ចជាទូត និងការនាំសំបុត្រទៅមក វៀរចាកការលក់ដូរ វៀរចាកការបោកដោយជញ្ជីង ឆបោកដោយភាជន៍មាស ទាំងឆបោកដោយរង្វាស់រង្វាល់ វៀរចាកការសេរីរី បញ្ឆោត បន្លំ កោងកាច វៀរចាកការកាប់សម្លាប់ ចងបំភាន់ ប្លន់ កំហែង ។ បុគ្គលនោះជាអ្នកសន្តោសដោយចីវរសម្រាប់រក្សាកាយ ដោយបិណ្ឌបាតសម្រាប់រក្សាផ្ទៃ ត្រាច់ទៅក្នុងទីណាៗ ក៏កាន់យក ( ត្រឹមតែគ្រឿងបរិក្ខារ ) ប៉ុណ្ណោះទៅ ។ សត្វបក្សីហើរទៅក្នុងទីណាៗ ក៏ទៅត្រឹមតែស្លាបរបស់ខ្លួនប៉ុណ្ណោះ យ៉ាងណាមិញ ភិក្ខុ

ជាអ្នកសន្ដោសដោយចីវរសម្រាប់រក្សាកាយ ដោយបិណ្ឌបាតសម្រាប់រក្សាផ្ទៃ ត្រាច់ទៅក្នុងទីណាៗ ក៏កាន់យក ( ត្រឹមតែគ្រឿងបរិក្ខារ ) ប៉ុណ្ណោះទៅក៏យ៉ាងនោះដែរ ។ ភិក្ខុនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះហើយ បានទទួលនូវសេចក្ដីសុខ ដែលមិនមានទោសក្នុងសន្ដាន ។ ភិក្ខុនោះឃើញរូបដោយភ្នែក ក៏មិនក្ដោបកាន់និមិត្ត មិនក្ដោបកាន់អនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមបុគ្គល ដែលមិនសង្រួមនូវចក្ខុន្ទ្រិយ ព្រោះហេតុមិនសង្រួម ចក្ខុន្ទ្រិយណា លោកក៏ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវសេចក្ដីសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្ដាត ... ពាល់ត្រូវផ្សព្វដោយកាយ ... ដឹងធម្មារម្មណ៍ដោយចិត្ត ក៏មិនក្ដោបកាន់និមិត្ត ទាំងមិនក្ដោបកាន់អនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមនូវបុគ្គលនុ៎ះ ដែលមិនសង្រួមមនិន្ទ្រិយ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា លោកក៏ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវសេចក្ដីសង្រួមក្នុងមនិន្ទ្រិយ ។ ភិក្ខុនោះ ប្រកបដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះ តែងទទួលសេចក្ដីសុខ ឥតសៅហ្មងខាងក្នុងសន្ដាន ។ ភិក្ខុនោះជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលឈានទៅមុខ និងឈានថយក្រោយ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលក្រឡេកមើលទៅមុខ ឬក្រឡេកមើលទៅទិសផ្សេងៗ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលបត់អវយវៈចូល និងលាចេញ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលប្រើប្រាស់សង្ឃាដីបាត្រ និង

ចីវរ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលស៊ី ផឹក ទំពា ទទួលរស ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលធ្វើឧច្ចារៈ និងបស្សាវៈ ជាអ្នកធ្វើនូវការដឹងខ្លួន ក្នុងវេលាដែលដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ រឭក និយាយស្តី នៅស្ងៀម ។

[ ១៣ ] ភិក្ខុនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះផង ប្រកបដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះផង ប្រកបដោយសតិ និងសម្បជញ្ញៈដ៏ប្រសើរនេះផង គប់រកនូវសេនាសនៈស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ប្រកភ្នំ គុហាលើភ្នំ ព្រៃស្មសាន ព្រៃស្រោង ទីវាល គំនរចំបើង ។ ភិក្ខុនោះ ត្រឡប់មកពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្តហើយ ក៏អង្គុយផ្គត់ភ្នែនតាំងកាយឲ្យត្រង់ តម្កល់សតិឆ្ពោះមុខទៅរកកម្មដ្ឋាន ។ ភិក្ខុនោះ លះអភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា ជាអ្នកលះសេចក្តីប្រទូស្ត ព្រោះព្យាបាទ មានចិត្តប្រាសចាកព្យាបាទ ជាអ្នកអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ជម្រះចិត្តឲ្យស្អាតចាកសេចក្តីប្រទូស្ត ព្រោះព្យាបាទ ជាអ្នកលះថីនមិទ្ធៈ ប្រាសចាកថីនមិទ្ធៈ សម្គាល់នូវអាលោកកសិណ មានសតិ និងសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ ជាអ្នកលះឧទ្ធច្ចកុក្កុច្ចៈ មិនរាយមាយ មានចិត្តស្ងប់ស្ងាត់ខាងក្នុងសន្តាន ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ ជាអ្នកលះវិចិកិច្ឆា ឆ្លងផុតចាកវិចិកិច្ឆា មិនមានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។

[ ១៤ ] ភិក្ខុនោះ លុះលះនីវរណៈទាំង ៥ ដែលជាឧបក្កិលេសរបស់

ចិត្ត ដែលធ្វើបញ្ញាឲ្យមានកម្លាំងថយនេះរួចហើយ លោកក៏ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានដែលប្រកបដោយវិតក្ក និងវិចារៈ មានបីតិសុខដែលកើតអំពីវិវេក ព្រោះរម្ងាប់វិតក្ក និងវិចារៈរួចហើយ ចូលកាន់ទុតិយជ្ឈាន ជាទីផូរផង់ខាងក្នុងសន្តាន មានភាវៈនៃចិត្តដ៏ប្រសើរ មិនមានវិតក្កវិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ ព្រោះលះបង់បីតិចេញហើយ ជាបុគ្គលព្រងើយផង មានសតិ និងសម្បជញ្ញៈផង ទទួលសេចក្តីសុខដោយនាមកាយផង ចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយតែងសរសើរថា បុគ្គលដែលបានតតិយជ្ឈានហើយ តែងមានចិត្តព្រងើយ ជាអ្នកមានស្មារតីនៅជាសុខ ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះរលត់នូវសោមនស្ស និងទោមនស្សអំពីកាលមុនផង លោកក៏ចូលកាន់ចតុត្ថជ្ឈាន ឥតទុក្ខ ឥតសុខ មានសតិដែលកើតអំពីឧបេក្ខា ។

[ ១៥ ] កាលដែលចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ភ្លន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅរកបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះ ក៏រឭកឃើញជាតិដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើនជាតិ គឺរឭកឃើញបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១០០០ ជាតិ មួយសែនជាតិក៏បានខ្លះ រឭកឃើញបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ដូច្នេះថា អាត្មាអញនៅក្នុងភពឯណោះ

មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ មាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ លុះច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ។ ភិក្ខុនោះរឭកឃើញនូវជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលមុន បានច្រើនជាតិ ព្រមទាំងអាការទាំងឧទ្ទេស ។

[ ១៦ ] កាលដែលចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ភ្លន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅដើម្បីញាណជាគ្រឿងដឹងនូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ភិក្ខុនោះក៏ឃើញសត្វទាំងឡាយដែលច្យុតចាប់បដិសន្ធិ មានការៈទាបថោក និងឧត្ដម មានវណ្ណៈល្អ និងវណ្ណៈអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដោយចក្ខុដ៏ជាទិព្វ ដ៏បរិសុទ្ធក្រៃលែង ជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ និយាយតិះដៀលព្រះអរិយបុគ្គលទាំងឡាយ សត្វទាំងនោះ លុះរំលាងខន្ធបន្ទាប់អំពីមរណៈក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក អើហ្ន៎ ចំណែកឯ

សត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសម្មាទិដ្ឋិ កាន់មាំនូវកម្មជាសម្មាទិដ្ឋិ មិនតិះដៀលពួកព្រះអរិយបុគ្គល សត្វទាំងនោះ លុះដល់រំលាងខន្ធបន្ទាប់អំពីមរណៈក៏ទៅកើតឯឋានសុគតិ សួគ៌ ទេវលោក ។ ភិក្ខុនោះ ឃើញសត្វទាំងឡាយ ដែលច្យុតដែលចាប់បដិសន្ធិ មានភាវៈទាបថោក និងឧត្តម មានវណ្ណៈល្អ និងវណ្ណៈអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។

[ ១៧ ] កាលដែលចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ភ្លន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅរកអាសវក្ខយញ្ញាណ លោកក៏ដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា ធម៌ប៉ុណ្ណោះជាអាសវៈ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់អាសវៈ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរលត់អាសវៈ ។ កាលដែលភិក្ខុនោះ ដឹងយ៉ាងនេះ ពិចារណាឃើញយ៉ាងនេះ ចិត្តក៏ផុតចាកកាមាសវៈផងផុតចាកភវាសវៈផង ផុតចាកអវិជ្ជាសវៈផង កាលបើចិត្តផុតស្រឡះហើយ

ញាណក៏កើតប្រាកដថា អាត្មាអញផុតស្រឡះចាកអាសវៈហើយ ដឹងច្បាស់ថា កំណើតរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញក៏បានធ្វើស្រេចហើយ កិច្ចដទៃក្រៅពីសោឡសកិច្ច តទៅទៀតមិនមានឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឯង ដែលតថាគតហៅថា អ្នកមិនដុតកម្តៅខ្លួនឯង មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ជាអ្នកមិនដុតកម្តៅអ្នកដទៃ មិនប្រកបសេចក្តីព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលដែលមិនដុតកម្តៅខ្លួនឯង មិនដុតកម្តៅអ្នកដទៃនោះ ជាអ្នកអស់សេចក្តីស្រេកឃ្លានក្នុងបច្ចុប្បន្ននេះ ជាអ្នករលត់ទុក្ខ មានសេចក្តីត្រជាក់ ទទួលសេចក្តីសុខ ជាអ្នកប្រសើរ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ មានចិត្តត្រេកអររីករាយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

**កន្ទរកសូត្រទី ១ ចប់**

# មជ្ឈិមនិកាយ
# បបញ្ចសូទនី អដ្ឋកថា
# មជ្ឈិមបណ្ណាសក
# គហបតិវគ្គ

## កន្ទរកសូត្រទី ១

[ ១ ] *កន្ទរកសូត្រ មានពាក្យផ្ដើមថា* **ឯវម្មេ សុតំ** *ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា* **ចម្បាយំ** *គឺក្នុងនគរមានឈ្មោះយ៉ាងនេះ ។ ព្រោះនគរនោះ មានដើមចម្ប៉ា ដុះសន្ធឹកសន្ធាប់ក្នុងទីនោះ មានសួន និងស្រះបោក្ខរណីជាដើម ដូច្នោះ ទើបបានឈ្មោះថា នគរចម្ប៉ា ។ បទថា* **គគ្គរាយ បោក្ខរណិយា តីរេ** *ត្រង់ច្រាំងស្រះបោក្ខរណីឈ្មោះគគ្គរា គឺក្នុងទីមិនឆ្ងាយអំពីនគរចម្ប៉ានោះ មានស្រះបោក្ខរណី ឈ្មោះគគ្គរា ព្រោះព្រះរាជមហេសីព្រះនាមថាគគ្គរាជីក ។ ត្រង់ច្រាំងស្រះបោក្ខរណីនោះ មានសួនចម្ប៉ាដ៏ធំប្រដាប់ដោយផ្កាមាន ៥ ពណ៌ មានពណ៌ខៀវដោយជុំវិញជាដើម ។*

*ព្រះមានព្រះភាគប្រថាប់នៅត្រង់សួនចម្ប៉ា ដែលមានក្លិនផ្កាក្រអូបនោះ ។ ព្រះអាចារ្យទាំងឡាយ សំដៅដល់សួនចម្ប៉ានោះ ទើបពោលពាក្យថា* **គគ្គរាយ បោក្ខរណិយា តីរេ** *ដូច្នេះ ។*

បទថា **មហតា ភិក្ខុសង្ឃេន សទ្ធឹ** គឺព្រមដោយភិក្ខុសង្ឃជាច្រើន មិនមានកំណត់ចំនួនទុក ។ បទថា **បេស្សោ** ជាឈ្មោះរបស់កូននាយហត្ថាចារ្យនោះ ។ បទថា **ហត្ថារោហបុត្តោ** គឺកូននៃនាយហត្ថាចារ្យជាអ្នកបង្ហាត់ដំរី ។ បទថា **កន្ទរកោ បរិព្វាជកោ** គឺបរិព្វាជកអ្នកស្លៀកសំពត់ ទើបមានឈ្មោះយ៉ាងនេះថា **កន្ទរក** ។ បទថា **អភិវាទេត្វា** គឺជាអ្នកចូលទៅក្នុងរវាងព្រះពុទ្ធរស្មីដ៏ក្រាស់ ប្រកបដោយពណ៌ ៦ ហើយមុជចុះក្នុងទឹកថ្លាស្អាត ឬហាក់ដូចបន្ទះសំពត់ដែលមានពណ៌ដូចមាសគ្របចុះលើក្បាល ឬជួតក្បាលដោយគ្រឿងប្រដាប់ ធ្វើដោយផ្កាចម្ប៉ាដែលដល់ព្រមដោយពណ៌ និងក្លិន ឬដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មីដែលគោចរទៅកាន់ជើងភ្នំសិនេរុ ដូច្នោះហើយ ថ្វាយបង្គំព្រះបាទារបស់ព្រះមានព្រះភាគ ដែលប្រកបដោយព្រះសិរី ដូចផ្កាចម្ប៉ាស្រស់កំពុងរីក ដែលប្រដាប់ដោយចក្កលក្ខណៈ ។ បទថា **ឯកមន្តំ និសីទិ** គឺអង្គុយក្នុងឱកាសដែលវៀរចាកទោស ៦ ប្រការ ។

បទថា **តុណ្ហីភូតំ តុណ្ហីភូតំ** គឺសម្លឹងមើលភិក្ខុសង្ឃដែលកំពុងអង្គុយស្ងៀមស្ងាត់ ។ ព្រោះក្នុងទីនោះ ភិក្ខុសូម្បីមួយរូប ក៏មិនមានការរំខានដោយដៃ និងជើង ។ ភិក្ខុគ្រប់រូបមិនបានជជែកគ្នា ដោយការគោរពដល់ព្រះមានព្រះភាគ និងព្រោះខ្លួនបានទទួលការសិក្សាហើយយ៉ាងល្អ ដោយហោច មិនធ្វើសំឡេងក្អក សូម្បីកាយក៏មិនកម្រើក សូម្បីចិត្តក៏មិនរាយមាយ ដូចសសរខឿនកប់យ៉ាងល្អ ដូចទឹកក្នុងមហាសមុទ្រ ស្ងប់ក្នុងទីដែលមិនមានខ្យល់ អង្គុយជុំវិញព្រះមានព្រះភាគ ដូចរត្តវលាហកៈព័ទ្ធជុំវិញកំពូលភ្នំសិនេរុដូច្នោះ

បីតិ និងសោមនស្សដ៏ក្រៃលែង បានកើតដល់បរិព្វាជក ព្រោះឃើញបរិស័ទស្ងប់ស្ងៀមយ៉ាងនោះ ។ ឯបរិព្វាជកមិនអាចស្ងប់បីតិសោមនស្សដែលកើតហើយខាងក្នុងហឫទ័យឲ្យស្ងៀមបាន ទើបបន្លឺវាចាដែលគួរស្រឡាញ់ថា **អច្ឆរិយំ ភោ គោតម** ជាដើម ។ ឈ្មោះថា **អច្ឆរិយ** ព្រោះមិនមានជានិច្ចដូចមនុស្សខ្វាក់ឡើងភ្នំបាន ដូច្នោះ គប្បីជ្រាបថា នេះជាតន្តិន័យ គឺបែបផែនបវេណី ។

ឯអដ្ឋកថាន័យ គប្បីជ្រាបដូចតទៅនេះថា ឈ្មោះថា **អច្ឆរិយំ** ព្រោះប្រកបដល់ម្រាមដៃ អធិប្បាយថា គួរប្រកបការផ្ទាត់ម្រាមដៃ ។ ឈ្មោះថា **អព្ភុតំ** ព្រោះមិនធ្លាប់កើតអំពីមុន ។ សូម្បីបទទាំង ២ ក៏ដូចគ្នា ។ បទថា **អព្ភុតំ** នេះ ជាឈ្មោះរបស់ការនាំមកនូវភាពស្ញប់ស្ញែង ។ ឯបទថា **អច្ឆរិយំ** នេះ មានន័យ ២ យ៉ាង គឺ **គរហាអច្ឆរិយ** គឺអស្ចារ្យក្នុងការតិះដៀល ១ **បសំសាអច្ឆរិយ** គឺអស្ចារ្យក្នុងការសរសើរ ១ ។

ក្នុងអច្ឆរិយៈទាំង ២ នោះ ព្រះពុទ្ធត្រាស់ថា **អច្ឆរិយំ មោគ្គល្លាន អព្ភុតំ មោគ្គល្លាន យាវ ពាហាគហណាបិ ណាម សោ មោឃបុរិសោ អាគមិស្សតិ** ម្នាលមោគ្គល្លាន មោឃបុរសនោះ មិនសមបើនឹងមកដរាបតែគេចាប់ទាញដៃបណ្តេញដូច្នេះសោះ នេះឈ្មោះថា **គរហាអច្ឆរិយ** ។ ព្រះពុទ្ធត្រាស់ថា **អច្ឆរិយំ នន្ទមាតេ អព្ភុតំ នន្ទមាតេ យត្រ ហិ ណាម ចិត្តុប្បាទមត្តម្បិ បរិសោធេស្សសិ** ម្នាលនាងនន្ទមាតា អស្ចារ្យណាស់ ម្នាលនាងនន្ទមាតា ចម្លែកណាស់ កោតតែនាងជម្រះនូវហេតុត្រឹមតែការកើតឡើង

នៃចិត្តបាន នេះឈ្មោះថា **បសំសាអច្ឆរិយ** ។ ក្នុងទីនេះ លោកបំណងយក **បសំសាអច្ឆិយ** នេះឯង ។ ព្រោះបរិព្វាជកនេះ កាលសរសើរ ទើបពោលយ៉ាងនេះ ។ បទថា **ឥធំ** ក្នុងបទថា **យាវញ្ចិធំ** នេះ ត្រឹមតែជានិបាត ។ បទថា **យាវ** គឺទ្រង់ឲ្យភិក្ខុសង្ឃបដិបត្តិប្រពៃយ៉ាងក្រៃលែង ។ លោកអធិប្បាយថា មិនអាចនឹងពណ៌នាដល់ប្រមាណ ដែលឲ្យភិក្ខុសង្ឃបដិបត្តិប្រពៃ នេះទើបគួរអស្ចារ្យ នេះទើបមិនធ្លាប់មានដោយពិត ។

បទថា **ឯតបរមំយេវ** ឈ្មោះថា **ឯតបរមោ** ព្រោះឲ្យភិក្ខុសង្ឃនោះបដិបត្តិប្រពៃយ៉ាងនោះ នេះជាការក្រៃលែងរបស់ភិក្ខុនោះ ។ ឈ្មោះថាបដិបត្តិយ៉ាងក្រៃលែងមានប្រមាណប៉ុណ្ណោះ អធិប្បាយថា ព្រះសម្មាសម្ពុទ្ធទាំងឡាយ ធ្លាប់ឲ្យភិក្ខុសង្ឃបដិបត្តិ យ៉ាងណា ក៏ធ្វើឲ្យភិក្ខុសង្ឃនេះបដិបត្តិដូចគ្នាដូច្នោះ មិនក្រៃលែងជាងនេះ ។ ក្នុងន័យទី ២ គប្បីប្រកបសេចក្ដីថា ព្រះសម្មាសម្ពុទ្ធឲ្យភិក្ខុសង្ឃបដិបត្តិយ៉ាងនេះ មិនឲ្យក្រៃលែងជាងនេះ ។

ក្នុងបទទាំងនោះ បទថា **បដិបាទិតោ** គឺឲ្យប្រកបក្នុងបដិបទាដែលមិនជាសត្រូវដោយប្រពៃ ព្រោះធ្វើអភិសមាចារិកវត្តឲ្យជាខាងដើម ។ សួរថា បើដូច្នោះ ព្រោះហេតុអ្វី ទើបបរិព្វាជកនេះអាងដល់ព្រះសម្ពុទ្ធទាំងឡាយក្នុងអតីត និងអនាគតទៅវិញ បរិព្វាជកនោះ មានញាណកំណត់ដឹងក្នុងកាលទាំង ៣ ឬ ឆ្លើយថា មិនមានសូម្បីក្នុងការកាន់យកន័យ ។

[ ២ ] បទថា **និបកា** មានបញ្ញាមុតស្រួច គឺភិក្ខុទាំងឡាយ មានបញ្ញាប្រកបដោយការពណ្ឍាស មានបញ្ញាចិញ្ចឹមជីវិតដោយបញ្ញា សម្រេចការ

ចិញ្ចឹមជីវិត ព្រោះតាំងនៅក្នុងបញ្ញា ដូចភិក្ខុរូបខ្លះ សូម្បីបួសក្នុងសាសនា ត្រាច់ទៅក្នុងអគោចរ ៦ ព្រោះហេតុនៃជីវិត ត្រាច់ទៅរកស្រីពេស្យា ត្រាច់ទៅរកស្រីមេម៉ាយ ក្រមុំចាស់ ខ្ទើយ រោងសុរា និងលំនៅរបស់ភិក្ខុនី ប្រឡូកប្រឡំជាមួយព្រះរាជា មហាមាត្យនៃព្រះរាជា តិរ្ថិយ សាវករបស់តិរ្ថិយ ប្រឡូកប្រឡំជាមួយគ្រហស្ថ ដែលមិនសមគួរ សម្រេចការចិញ្ចឹមជីវិតដោយអនេសនៈ ២១ គឺធ្វើពេទ្យ ធ្វើទូតកម្ម ធ្វើការនាំដំណឹង វះបូស ឲ្យថ្នាំបន្ទាត់បូស ឲ្យថ្នាំបញ្ចុះដ៏ខ្វាំងក្លា ឲ្យថ្នាំបញ្ចុះយ៉ាងទន់ខ្សោយ ចម្រាញ់ប្រេងសម្រាប់នត្ថុ ( ឆ្លង ឬប្រកតាមច្រមុះ ) ចម្រាញ់ប្រេងសម្រាប់ផឹក ឲ្យឫស្សីឲ្យស្លឹក ឈើ ឲ្យផ្កាឈើ ឲ្យផ្លែឈើ ឲ្យទឹកងូត ឲ្យឈើស្ទន់ ឲ្យទឹកខ្ពុរមាត់ឲ្យលម្អិតសម្រាប់ជុសខ្លួន និយាយឲ្យគេស្រឡាញ់ និយាយលាយលេងលាយមែន ជួយចិញ្ចឹមក្មេង ជួយបញ្ជូនដំណឹង ឈ្មោះថា មិនចិញ្ចឹមជីវិតដោយបញ្ញាដ៏ឈ្លាស គឺសម្រេចការចិញ្ចឹមជីវិត ព្រោះមិនតាំងនៅដោយបញ្ញា ។

បន្ទាប់អំពីនោះ កាលធ្វើកាលកិរិយាហើយ ក៏នឹងកើតជាសមណយក្សសោយទុក្ខធំ ដោយន័យដូចពោលថា សូម្បីសង្ឃាដីរបស់ភិក្ខុនោះ ក៏ក្តៅសន្ធោសន្ធៅ ភិក្ខុមិនជាយ៉ាងនេះ មិនកន្លងសិក្ខាបទ ព្រោះហេតុនៃជីវិត តាំងនៅក្នុងចតុប្បារិសុទ្ធិសីល សិក្សាព្រះពុទ្ធវចនៈតាមកម្លាំង បំពេញអរិយ-បដិបទាទាំងនេះ គឺរថវិនីតប្បដិបទា មហាគោសិង្គប្បដិបទា មហាសុញ្ញតា-បដិបទា អនង្គណប្បដិបទា ធម្មទាយាទប្បដិបទា នាលកប្បដិបទា តុវដ្ដ-កប្បដិបទា ចន្ទោបមប្បដិបទា ជាកាយសក្ខី ក្នុងអរិយវង្សប្បដិបទា គឺមាន

ការសន្ទោសដោយបច្ច័យ ៤ និងមានការត្រេកអរតាមមានតាមបានរបស់ខ្លួន ជាបុគ្គលម្នាក់ឯង ក្នុងការត្រាច់ទៅជាដើម ដូចដំរីផុតចាកសត្រូវ ដូចសីហៈ លះបង់ហ្វូង ដូចមហានាវា មិនមានទូកជាប់តាមទៅអំពីក្រោយ ផ្តើមបំពេញ វិបស្សនា តាំងនូវឧស្សាហ៍ថា អញនឹងសម្រេចអរហត្តក្នុងថ្ងៃនេះឲ្យបាន ។

បទថា **សុបតិដ្ឋិតចិត្តា** គឺជាអ្នកមានចិត្តតាំងមាំល្អក្នុងសតិប្បដ្ឋាន ៤ ។ សតិប្បដ្ឋានកថាដ៏សេស ពោលពិស្តារហើយខាងដើម ឯក្នុងទីនេះ លោក ពោលដល់សតិប្បដ្ឋានលាយឡំគ្នា ជាលោកិយផង លោកុត្តរផង ។ ដោយ ហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា លោកពោលដល់ហេតុ ដែលភិក្ខុសង្ឃ ចូលទៅស្ងប់ហើយ ។

[ ៣ ] បទថា **យាវ សុប្បញ្ញត្តា** គឺសតិប្បដ្ឋាន ៤ ព្រះអង្គទ្រង់តាំង ដោយល្អហើយ គឺទ្រង់សម្តែងល្អហើយ ។ ដោយបទថា **មយំបិ ហិ ភន្តេ** នេះ បេស្សៈកូនហ្មដំរីនោះសម្តែងដល់ការដែលខ្លួនជាអ្នកធ្វើការងារ និងលើក ភិក្ខុសង្ឃឡើង ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅនេះថា បពិត្រព្រះ អង្គដ៏ចម្រើន ដែលពិត សូម្បីពួកខ្ញុំព្រះអង្គជាគ្រហស្ថ ស្លៀកសំពត់ស ។បេ។ ជាអ្នកមានចិត្តតាំងមាំល្អហើយ ។ ការភ្ជួរ ពូជ នឹម នង្គ័ល និងផាល នេះ មិនមានដល់ភិក្ខុសង្ឃ ព្រោះដូច្នោះ ទើបភិក្ខុសង្ឃប្រាថ្នាចំពោះសតិប្បដ្ឋាន សព្វកាល ។ ឯពួកខ្ញុំព្រះអង្គបានឱកាសតាមកាលតាមសមគួរហើយ ទើប ធ្វើមនសិការនេះ ។ សូម្បីពួកខ្ញុំព្រះអង្គ ជាអ្នកធ្វើការងារ ក៏មិនលះកម្មដ្ឋាន ដោយប្រការទាំងពួង ។

បទថា **មនុស្សគហនេ** មនុស្សស្មុគស្មាញ ព្រោះកាន់យកការស្មុគស្មាញរបស់អធ្យាស្រ័យនៃមនុស្សទាំងឡាយ ។ គប្បីជ្រាបថា ការដែលកាន់យកអធ្យាស្រ័យរបស់មនុស្សទាំងនោះ ដោយការស្មុគស្មាញនៃកិលេស ។ សូម្បីក្នុងអធ្យាស្រ័យប្រឡាក់ប្រឡូស និងអធ្យាស្រ័យអួតអាង ក៏មានន័យដូចគ្នា ។ ក្នុងអធ្យាស្រ័យទាំងនោះ គប្បីជ្រាបអធ្យាស្រ័យ ឈ្មោះថា ស្រកាក ព្រោះអត្ថថា មិនបរិសុទ្ធ ។ អធ្យាស្រ័យ ឈ្មោះថា អួតអាង ព្រោះអត្ថថា បោកបញ្ឆោត ។

បទថា **សត្តានំ ហិតាហិតំ ជានាតិ** ព្រះមានព្រះភាគ ទ្រង់រមែងដឹងប្រយោជន៍ និងមិនមែនប្រយោជន៍របស់សត្វទាំងឡាយ គឺព្រះមានព្រះភាគទ្រង់ជ្រាបប្រយោជន៍ និងមិនមែនប្រយោជន៍នៃមនុស្សទាំងឡាយដោយល្អ ដូចទ្រង់ជ្រាបភាពស្មុគស្មាញ ប្រឡាក់ប្រឡូស និងបោកបញ្ឆោតរបស់មនុស្សដូច្នោះ ។ ក្នុងបទថា **យទិទំ បសវោ** នេះ លោកបំណងយកសត្វជើង ២ ទាំងអស់ ។

បទថា **បហោមិ** គឺអាច ។ បទថា **យាវត្តកេន អន្តរេន** ដោយរវាងប្រមាណប៉ុន្មាន គឺដោយខណៈប៉ុន្មាន ។ បទថា **ចម្បំ គតាគតំ ករិស្សតិ** នឹងធ្វើនគរចម្ប៉ាឲ្យជាទីទៅមក គឺនឹងធ្វើការទៅ និងការមកតាំងអំពីរោងសេះរហូតដល់ទ្វារនគរចម្ប៉ា ។ បទថា **សាឋេយ្យានិ** គឺភាពជាអ្នកក្រអើតក្រអោង ។ បទថា **កូដេយ្យានិ** គឺភាពជាអ្នកកោងកាច ។ បទថា **វង្កេយ្យានិ** គឺភាពជាអ្នកវៀចវេរ ។ បទថា **ជិម្ហេយ្យានិ** គឺភាពជាអ្នកគ្រលែងខ្លួន ។ បទ

ថា **ចាតុក្កាវិស្សតិ** នឹងធ្វើឲ្យប្រាកដ គឺនឹងប្រកាស នឹងសម្ដែង ។ ព្រោះមិនអាចសម្ដែងការអួតអាងទាំងនោះជាដើម ដោយរវាងប្រមាណប៉ុណ្ណេះបាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការក្រអឺតក្រអោងដូចតទៅនេះ កាលភិក្ខុសង្ឃឈរនៅក្នុងទីណា ទោះជាទីមិនមានភ័យចំពោះមុខរបស់មនុស្ស គិតថា អញនឹងទៅខាងមុខ ហើយឈរបញ្ឆោត ទើបទៅឈរធ្វើជាមិនកម្រើក ដូចសសរដែលកប់ក្នុងទីបំណាងនឹងតាំងទុក ភិក្ខុនេះឈ្មោះថា ក្រអឺតក្រអោង កាលភិក្ខុសង្ឃរាកាំងក្នុងទីណាមួយ ហើយឱនខ្លួនទទឹង ទោះជាទីមិនមានភ័យចំពោះមុខរបស់មនុស្សទាំងឡាយ គិតថា អញនឹងទៅខាងមុខ ហើយឱនបញ្ឆោត ទើបឱនខ្លួនបញ្ឆោតក្នុងទីនោះ ភិក្ខុនេះឈ្មោះថា កោងកាច ។ កាលភិក្ខុបំណាងនឹងចៀសចាកផ្លូវក្នុងទីណាមួយ ហើយត្រឡប់ដើរបញ្ច្រាសផ្លូវ ទោះជាទីមិនមានភ័យចំពោះមុខរបស់មនុស្សទាំងឡាយ គិតថា អញនឹងទៅខាងមុខ ហើយបញ្ឆោតធ្វើយ៉ាងនេះ ទើបចៀសចេញអំពីផ្លូវក្នុងទីនោះ ហើយត្រឡប់ដើរមកតាមក្រោយ ភិក្ខុនេះឈ្មោះថា វៀចវេរ ។ កាលភិក្ខុបំណាងនឹងទៅតាមផ្លូវត្រង់តាមវេលា ផ្លូវឆ្វេងតាមវេលា ផ្លូវស្ដាំតាមវេលា ទោះមិនមានភ័យចំពោះមុខរបស់មនុស្សទាំងឡាយ គិតថា អញនឹងដើរទៅខាងមុខ ហើយធ្វើយ៉ាងនេះ ទើបទៅផ្លូវត្រង់តាមវេលា អំពីឆ្វេងតាមវេលា អំពីស្ដាំតាមវេលា ក្នុងទីនោះ ។ ម្យ៉ាងទៀត ទីណាដែលគេបោសរាបស្មើអ៊ូអរដោយមនុស្ស គួររីករាយ មិនគួរធ្វើកម្មបែបនេះក្នុងទីនេះ រមែងមិនមានដល់ភិក្ខុ ដែលបំណាងនឹងបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ដោយគិតថា

អញ្ចេនឹងទៅខាងមុខ ហើយធ្វើដូចបន្ទោបង់ក្នុងទីដែលបិទបាំង ទើបមកធ្វើក្នុងទីនោះ ភិក្ខុនេះឈ្មោះថា គ្រលែងខ្លួន ។ លោកពោលដូច្នេះ សំដៅដល់កិរិយា ៤ យ៉ាងនេះ ដោយប្រការដូច្នេះ ។

ដំរីនោះនឹងធ្វើការក្រអឺតក្រអោង កោងកាច វៀចវេរ និងគ្រលែងខ្លួនទាំងអស់នោះឲ្យប្រាកដបាន ។ សណ្ឋានជាដើមនោះ សូម្បីកំពុងធ្វើយ៉ាងនេះក៏ឈ្មោះថា រមែងធ្វើនូវការអួតអាងជាដើមនោះឲ្យប្រាកដ ។

កាលនាយ បេស្ស: បុត្រហត្ថាចារ្យ សម្តែងភាពដែលសត្វចិញ្ចឹមទាំងឡាយ ជាវត្ថុងាយយល់ ឥឡូវនេះ កាលនឹងសម្តែងភាពដែលមនុស្សទាំងឡាយ ជាវត្ថុដែលសាំញ៉ាំ ទើបក្រាបទូលថា **អម្ហាកំ បន ភន្តេ** ។

ក្នុងបទទាំងនោះ បទថា **ទាសា** បានដល់ ទាសៈកើតខាងក្នុង ទាសៈដែលលោះមកដោយទ្រព្យ ទាសៈដែលជាឈ្លើយ ឬដល់ភាពជាទាសៈទទួលបម្រើ ។ បទថា **បេស្សា** គឺអ្នកបម្រើ ។ បទថា **កម្មករា** គឺអ្នកចិញ្ចឹមជីវិតដោយអាហារ និងថ្លៃឈ្នួល ។ បទថា **អញ្ញថា ច កាយេន** ដោយកាយម្យ៉ាង លោកសម្តែងថា ទាសៈជាដើមរមែងប្រព្រឹត្តដោយកាយដោយអាការម្យ៉ាង ដោយវាចា ដោយអាការម្យ៉ាង និងចិត្តរបស់ទាសៈជាដើមនោះ រមែងតាំងនៅដោយអាការម្យ៉ាង ។ ក្នុងទាសៈទាំងនោះ ទាសៈណាឃើញចៅហ្វាយចំពោះមុខហើយ ក្រោកឡើងទទួល ទទួលរបស់អំពីដៃលែងរបស់នេះ កាន់យករបស់នេះ ធ្វើកិច្ចទាំងអស់ដ៏សេស មានក្រាលអាសនៈ បក់ផ្លិត និងលាងជើងជាដើម តែលុះកំបាំង សូម្បីប្រេងហូរ ក៏មិន

មើលថៃ ការងារសូម្បីខាតរាប់រយរាប់ពាន់ ក៏មិនប្រាថ្នានឹងត្រឡប់មកមើលថៃ ទោសៈនេះឈ្មោះថា ប្រព្រឹត្តដោយកាយផ្សេង ។ ម្យ៉ាងទៀត ទោសៈពួកណាចំពោះមុខពោលសរសើរ មានពាក្យថា គាត់ជាចៅហ្វាយរបស់ខ្ញុំជាដើម លុះកំបាំងមុខ ពាក្យដែលពោលមិនបានមិនមានឡើយ រមែងពោលពាក្យដែលត្រូវការពោល ទោសៈនេះឈ្មោះថា ប្រព្រឹត្តដោយវាចាផ្សេង ។

[ ៤-៥ ] បទថា **ចត្តារោមេ បេស្ស បុគ្គលា** ប្រែថា បុគ្គល ៤ ពួកនេះតែងមាន សេចក្តីថា បុគ្គលនេះក៏ជាការបន្ទចំពោះខ្លួន ។ បេស្សៈនេះក្រាបទូលថា បពិត្រព្រះអង្គ ព្រះអង្គទ្រង់រមែងជ្រាបប្រយោជន៍ និងមិនមែនប្រយោជន៍របស់សត្វទាំងឡាយ ក្នុងកាលមនុស្សសាំញ៉ាំប្រព្រឹត្តទៅយ៉ាងនេះ ក្នុងកាលមនុស្សមានចិត្តស្រេកាកប្រព្រឹត្តទៅយ៉ាងនេះ ក្នុងកាលមនុស្សអួតអាង ប្រព្រឹត្តទៅយ៉ាងនេះ ។

បុគ្គល ៣ ពួកខាងដើម ជាអ្នកបដិបត្តិបដិបទាមិនជាប្រយោជន៍ បុគ្គលពួកទី ៤ ជាអ្នកបដិបត្តិជាប្រយោជន៍ ព្រះមានព្រះភាគ កាលទ្រង់សម្តែងថាតថាគតដឹងប្រយោជន៍ និងមិនមែនប្រយោជន៍របស់សត្វទាំងឡាយយ៉ាងនេះ ទើបទ្រង់ប្រារព្ធទេសនានេះ ។ សូម្បីការប្រកបជាមួយពាក្យសម្តីរបស់កន្ទរកបរិព្វាជកខាងដើមក៏គួរ ដោយហេតុនេះ ទើបកន្ទរកបរិព្វាជកពោលថា ព្រះគោតមដ៏ចម្រើន បានប្រដៅភិក្ខុសង្ឃមានប្រមាណប៉ុណ្ណោះ ឲ្យប្រតិបត្តិដោយល្អ ដូច្នេះ ។

លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់នាយបេស្សៈនោះ

ថា តថាគតវៀរបុគ្គល ៣ ពួកសិន ហើយឲ្យបុគ្គលពួកទី ៤ ខាងលើ បដិបត្តិក្នុងបដិបទាជាប្រយោជន៍នោះឯង ទើបទ្រង់ប្រារព្ធទេសនានេះ ។

បទថា **សន្តោ** នេះ ជាវេវចនៈនៃបទថា **សំវិជ្ជមានា** ប្រែថា មានហើយ ។ ពិតហើយ សព្ទថា **សន្តោ** មានអត្ថថា រលត់ ដូចក្នុងប្រយោគជាដើមថា **សន្តា ហោន្តិ សមិតា វូបសន្តា** ( អភិជ្ឈានេះ ) ជាធម្មជាតស្ងប់រម្ងាប់លោក ដូច្នេះ ។ មកក្នុងអត្ថថា រលត់ហើយដូចក្នុងប្រយោគជាដើមថា **សន្តា ឯតេ វិហារា អរិយស្ស វិនយេ វុច្ចន្តិ** ( គ្រាន់តែឲ្យឈ្មោះ ) ធម៌ទាំងនោះ ថាជាគ្រឿងនៅដ៏ស្ងប់រម្ងាប់ ក្នុងអរិយវិន័យប៉ុណ្ណោះ ដូច្នេះ ។ មកក្នុងអត្ថថា បណ្ឌិត ដូចក្នុងប្រយោគជាដើមថា **សន្តោ ហវេ សព្ភិ បវេទយំ** ពួកសប្បុរសរមែងចរចាដោយពួកសប្បុរស ។ បណ្ឌិតទាំងឡាយ មាននៅក្នុងលោកនេះ អធិប្បាយថា ល្មមរកបាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អត្តន្តបោ** ជាដើម ឈ្មោះថា **អត្តន្តបោ** ព្រោះធ្វើខ្លួនឲ្យក្តៅក្រហាយ ឲ្យដល់នូវទុក្ខ ។ ការប្រកបសេចក្តីខ្វល់ខ្វាយក្នុងការធ្វើខ្លួនឲ្យក្តៅក្រហាយ ឈ្មោះថា **អត្តបរិតាបនានុយោគំ** ។ ឈ្មោះថា **បរន្តបោ** ព្រោះធ្វើអ្នកដទៃឲ្យក្តៅក្រហាយ ឲ្យដល់នូវទុក្ខ ។ ការប្រកបសេចក្តីខ្វល់ខ្វាយក្នុងការធ្វើអ្នកដទៃឲ្យក្តៅក្រហាយ ឈ្មោះថា **បរបរិតាបនានុយោគំ** ។ បទថា **ទិដ្ឋេវ ធម្មេ** គឺក្នុងអត្តភាពនេះឯង ។ បទថា **និច្ឆាតោ** មិនមានការឃ្លាន តណ្ហា លោកហៅថា **ឆាត** ។ ឈ្មោះថា **និច្ឆាតោ** ព្រោះមិនមានការឃ្លានបាន ។ ឈ្មោះថា **និព្វុតោ** ព្រោះរម្ងាប់

កិលេសបានទាំងអស់ ។ ឈ្មោះថា **សីតិភូតោ** ព្រោះជាអ្នកត្រជាក់ ព្រោះមិនមានកិលេសដែលធ្វើឲ្យក្ដៅក្រហាយជាខាងក្នុង ។ ឈ្មោះថា **សុខប្បដិ-សំវេទី** ព្រោះសោយសុខកើតអំពីឈាន មគ្គ ផល និងនិព្វាន ។ បទថា **ព្រហ្មភូតេន អត្តនា** គឺមានខ្លួនប្រសើរ ។ បទថា **ចិត្តំ អារាធេតិ** គឺញ៉ាំងចិត្តឲ្យដល់ព្រម ឲ្យបរិបូណ៌ អធិប្បាយថា ឲ្យជ្រះថ្លា ។

[ ៦ ] បទថា **ទុក្ខប្បដិក្កូលំ** គឺទុក្ខជាវត្ថុគួរខ្ពើម តាំងនៅក្នុងភាពជាសត្រូវ អធិប្បាយថា មិនប្រាថ្នាទុក្ខ ។

[ ៧ ] ក្នុងបទថា **បណ្ឌិតោ** នេះ មិនគួរពោលថា ជាបណ្ឌិតដោយហេតុ ៤ ប្រការ ។ តែគួរពោលថា ជាបណ្ឌិត ព្រោះធ្វើកម្មក្នុងសតិប្បដ្ឋាន សូម្បីបទនេះថា **មហាបញ្ញោ** ក៏មិនគួរពោលដោយលក្ខណៈរបស់មហាបញ្ញា ដោយបទជាដើមថា **មហន្តេ អត្ថេ បរិគណ្ហាតិ** ប្រែថា កាន់យកប្រយោជន៍ធំ ។ តែគួរពោលថា ជាអ្នកមានបញ្ញាច្រើន ព្រោះប្រកបដោយបញ្ញា កំណត់កាន់យកសតិប្បដ្ឋាន ។ បទថា **មហតា អត្ថេន សំយុត្តោ អភវិស្ស** គឺគប្បីជាអ្នកប្រកប ជាបុគ្គលដល់ដោយប្រយោជន៍ធំ សេចក្ដីថា គប្បីសម្រេចសោតាបត្តិផល ។

សួរថា សូម្បីកាលតាំងនៅចំពោះព្រះកក្រព្រះពុទ្ធទាំងឡាយ នឹងមានអន្តរាយដល់មគ្គផលឬ ឆ្លើយថា មានអន្តរាយពិត ។ តែមិនមានព្រោះអាស្រ័យព្រះពុទ្ធទាំងឡាយ ។ ដោយពិត រមែងមានព្រោះការវិនាសរបស់កិរិយា ឬព្រោះបាបមិត្រ ។ ក្នុងអន្តរាយទាំង ២ នោះ ឈ្មោះថា រមែងមាន

ព្រោះការវិនាសនៃកិរិយាដូចតទៅនេះ

បើព្រះធម្មសេនាបតី ដឹងអធ្យាស្រ័យធនញ្ជានិយព្រាហ្មណ៍ ហើយបាន សម្តែងធម៌ ព្រាហ្មណ៍នោះនឹងបានជាព្រះសោតាបន្ន ។ យ៉ាងនេះឈ្មោះថា រមែងមានព្រោះការវិនាសនៃកិរិយា ។ ឈ្មោះថា រមែងមានព្រោះបាបមិត្រ មានអធិប្បាយដូច្នេះ បើព្រះបាទអជាតសត្តុជឿពាក្យរបស់ទេវទត្ត ហើយមិន ធ្វើបិតុឃាត ។ ព្រះបាទអជាតសត្តុនឹងបានជាព្រះសោតាបន្ន ក្នុងថ្ងៃដែលព្រះ មានព្រះភាគត្រាស់សាមញ្ញផលសូត្រនោះឯង ។ តែព្រោះព្រះបាទអជាត សត្តុជឿពាក្យរបស់ទេវទត្តនោះ ហើយធ្វើបិតុឃាត ទើបមិនបានជាសោតា- បន្ន ។ យ៉ាងនេះឈ្មោះថា អន្តរាយមានព្រោះបាបមិត្រ ។ ការវិនាសនៃ កិរិយាកើតដល់ឧបាសកនេះ កាលទេសនាមិនទាន់ចប់ ព្រាហ្មណ៍ក្រោក ចៀសចេញទៅ ។

បទថា **អបិច ភិក្ខវេ ឯត្តាវតាបិ បេស្សោ ហត្ថារោហបុត្តោ មហតា អត្ថេន សំយុត្តោ** ម្យ៉ាងទៀត ម្នាលភិក្ខុទាំងឡាយ សូម្បីដោយការស្តាប់ ដោយសង្ខេបមានប្រមាណប៉ុណ្ណោះ នាយបេស្សៈ កូនហត្ថាចារ្យគង់ប្រកប ដោយប្រយោជន៍ធំ ។ សួរថា ដោយប្រយោជន៍ធំដូចម្តេច ឆ្លើយថា គឺ ដោយអានិសង្ស ២ ប្រការ ។ បានឮថា ឧបាសកជ្រះថ្លាក្នុងព្រះសង្ឃ និង ន័យថ្មីក្រៃលែងកើតដល់ឧបាសកនោះ ដើម្បីកំណត់កាន់យកសតិប្បដ្ឋាន ដោយ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **មហតា អត្ថេន សំយុត្តោ** ។ កន្ទរកបរិព្វាជកបាននូវការជ្រះថ្លាក្នុងព្រះសង្ឃប៉ុណ្ណោះ ។ បទថា **ឯតស្ស**

**ភគវា កាលោ** សេចក្ដីថា នេះជាកាលនៃការពោលធម៌ ឬនៃការចែកបុគ្គល ៤ ពួក ។

[ ៩ ] គប្បីជ្រាបអត្ថក្នុងបទថា **ឱរព្ភិកោ** ជាដើម ដូចតទៅនេះ

ពពែលោកហៅថា **ឧរព្ភ** ឈ្មោះថា **ឱរព្ភិកោ** ព្រោះសម្លាប់ពពែ ។ ក្នុងបទថា **សូករិកោ** ជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា **លុទ្ទោ** គឺទារុណពន់ពេក ។ បទថា **មច្ឆឃាតកោ** គឺព្រានអ្នកចងសន្ទូចយកត្រី ។ បទថា **ពន្ធនាគារិកោ** គឺអ្នកគ្រប់គ្រងគុក ។ បទថា **កុរូរកម្មន្តា** គឺអ្នកមានការងារអាក្រក់ ។

[ ១០ ] បទថា **មុទ្ធាវសិត្តោ** គឺព្រះរាជាបានទទួលមុទ្ធាភិសេក ដោយការអភិសេកជាក្សត្រ ។ បទថា **បុរត្ថិមេន នគរស្ស** គឺទិសបូព៌ានៃព្រះនគរ ។ បទថា **សន្ថាគារំ** គឺរោងបូជាយញ្ញ ។ បទថា **ខរាជិនំ និវាសេត្វា** គឺទ្រង់ស្លៀកស្បែកខ្លាទាំងក្រចក ។ បទថា **សប្បិតេលេន** ដោយសប្បិ និងប្រេង ។ ប្រេងឯណាទីមួយដ៏សេស វៀរសប្បិ លោកហៅថា **តេលំ** ។ បទថា **កណ្ឌុវមានោ** ទ្រង់អេះ គឺ ទ្រង់អេះដោយស្នែង ក្នុងវេលាដែលត្រូវការអេះ ព្រោះមិនមានក្រចក ។ បទថា **អនន្តរហិតាយ** គឺមិនបានក្រាលដោយកម្រាល ។ បទថា **សរូបវច្ឆាយ** នៃគោដែលមានរូបដូចគ្នានឹងមេគោ បើមេគោស កូនគោក៏សដែរ បើមេគោពពាល ឬក្រហម កូនគោក៏ដូច្នោះដែរ ព្រោះហេតុនោះ ទើបឈ្មោះថា **សរូបវច្ឆា** ដោយប្រការដូច្នេះ ។ បទថា **សោ ឯវមាហ** ព្រះរាជាទាំងនោះត្រាស់យ៉ាងនេះ ។ បទថា **វច្ឆតរា**

កូនគោមានកម្លាំង ដែលដល់នូវភាពមានកម្លាំងជាងភាពជាកូនគោជំទង់ ក្នុងបទថា **វច្ឆតរី** កូនគោញីក៏មានន័យនេះដូចគ្នា ។ បទថា **ពរិហិសត្ថាយ** ដើម្បីក្រាលដី គឺដើម្បីត្រូវការធ្វើគ្រឿងពន្ធ និងដើម្បីត្រូវការក្រាលដីបូជាយញ្ញ ។ បទដ៏សេស ងាយយល់ទាំងអស់ហើយ ព្រោះបានពោលពិស្តារហើយ ក្នុងបទទាំងនោះខាងដើម ។ល។

## កន្ទរកសូត្រ ចប់

## សូត្រទី ១ ចប់

# សុត្តន្តបិដក

## អដ្ឋកនាគរសូត្រទី ២

[ ១៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះអានន្ទមានអាយុ គង់នៅក្នុងវេឡុវគ្រាម ជិតក្រុងវេសាលី ។ សម័យនោះឯង ទសមគហបតី អ្នកក្រុងអដ្ឋកៈ បានទៅដល់ក្រុងបាតលិបុត្ត ដោយកិច្ចការនីមួយ ។ គ្រានោះ ទសមគហបតីអ្នកក្រុងអដ្ឋកៈ ចូលទៅរកភិក្ខុ ១ រូប ដែលនៅក្នុងកុក្កុដារាម លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំភិក្ខុនោះ ហើយអង្គុយក្នុងទីសមគួរ ។ លុះទសមគហបតីអ្នកក្រុងអដ្ឋកៈ អង្គុយក្នុងទីសមគួរហើយ បានសួរភិក្ខុនោះ យ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ ព្រះអានន្ទមានអាយុគង់ នៅក្នុងទីណា ព្រោះយើងខ្ញុំចង់ឃើញព្រះអានន្ទនោះ ។ ភិក្ខុនោះប្រាប់ថា ម្នាលគហបតី ព្រះអានន្ទមានអាយុនុ៎ះ លោកគង់នៅក្នុងវេឡុវគ្រាម ជិតក្រុង វេសាលី ។ ទើបទសមគហបតីអ្នកក្រុងអដ្ឋកៈ ត្រួតត្រាកិច្ចការដែលខ្លួនត្រូវ ធ្វើក្នុងក្រុងបាតលិបុត្តនោះរួចហើយ ក៏ចូលទៅរកព្រះអានន្ទមានអាយុ ក្នុង វេឡុវគ្រាម ទៀបក្រុងវេសាលីនោះ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះ អានន្ទមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។

[ ១៩ ] លុះទសមគហបតីអ្នកក្រុងអដ្ឋកៈ អង្គុយក្នុងទីសមគួរហើយ ទើបទូលសួរព្រះអានន្ទមានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ភិក្ខុជា អ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះ និព្វាន ចិត្តដែលមិនទាន់រួចស្រឡះ ( ចាកអាសវៈ ) ក៏រួចស្រឡះបានផង

អាសវធម៌ទាំងឡាយ ដែលមិនទាន់អស់ទៅ ក៏អស់រលីងបានផង ទាំងបាន ដល់ធម៌ក្សេមចាកយោគៈដ៏ប្រសើរ ដែលខ្លួនមិនទាន់បានដល់ផង ព្រោះធម៌ ឯកណា ធម៌ឯកនោះ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គបានសម្តែងហើយ តើមានដែរឬ ។ ព្រះ អានន្ទត្រាស់តបថា ម្នាលគហបតី ភិក្ខុជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅ កិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ចិត្តដែលមិនទាន់រួចស្រឡះ ក៏រួច ស្រឡះបានផង អាសវធម៌ទាំងឡាយ ដែលមិនទាន់អស់ទៅ ក៏អស់រលីង បានផង ទាំងបានដល់នូវធម៌ក្សេមចាកយោគៈដ៏ប្រសើរ ដែលខ្លួនមិនទាន់បាន ដល់ផង ព្រោះធម៌ឯកណា ធម៌ឯកនោះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គបានសម្តែងហើយ រមែង មានប្រាកដ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ភិក្ខុជាអ្នកមិនប្រមាទ មានព្យាយាម ដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ចិត្តដែលមិនទាន់រួចស្រឡះ ក៏រួចស្រឡះបានផង អាសវធម៌ទាំងឡាយ ដែលមិនទាន់អស់ទៅ ក៏អស់ រលីងបានផង ទាំងបានដល់ធម៌ក្សេមចាកយោគៈដ៏ប្រសើរ ដែលខ្លួនមិនទាន់ បានដល់ផង ព្រោះធម៌ឯកណា ធម៌ឯកនោះ ព្រះមានព្រះភាគអរហន្តសម្មា-សម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គបានសម្តែងហើយ តើដូចម្តេចខ្លះ ។

[ ២០ ] ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ស្ងាត់ ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានដែលប្រកបដោយវិតក្កៈ និង

វិចារៈ មានបីតិ និងសុខដែលកើតអំពីវិវេក ភិក្ខុនោះពិចារណាដឹងច្បាស់ដូច្នេះថា បឋមជ្ឈាននេះឯង អាត្មាអញបានតាក់តែងហើយ បានបង្កើតហើយ ក៏បឋមជ្ឈានតិចតួច ដែលអាត្មាអញបានតាក់តែង បានបង្កើតហើយនោះ ជាធម្មជាតមិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះ ក៏ឋិតនៅក្នុងធម៌នោះ ហើយក៏ដល់នូវការអស់ទៅនៃអាសវៈ បើមិនទាន់ដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់នឹងទៅកើតជាឱបបាតិកៈ ព្រោះការអស់ទៅនៃសំយោជនធម៌ទាំង ៥ ប្រការ ជាចំណែកខាងក្រោម ដោយសេចក្តីត្រេកអរក្នុងធម៌នោះ និងសេចក្តីរីករាយក្នុងធម៌នោះ ហើយនឹងបរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់មក អំពីព្រហ្មលោកនោះវិញឡើយ ម្នាលគហបតី ភិក្ខុជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ចិត្តដែលមិនទាន់រួចស្រឡះ ក៏រួចស្រឡះបានផង អាសវៈទាំងឡាយដែលមិនទាន់អស់ទៅ ក៏អស់រលីងបានផង ទាំងដល់នូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ដែលខ្លួនមិនទាន់បានដល់ផង ព្រោះធម៌ឯកណា នេះឯង ជាធម៌ឯក ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ព្រះអង្គបានសម្តែងហើយ ។ ម្នាលគហបតី មួយទៀត ភិក្ខុព្រោះរម្ងាប់វិតក្កនិងវិចារៈ ។បេ។ ក៏ចូលកាន់ទុតិយជ្ឈាន ទើបភិក្ខុនោះពិចារណាដឹងច្បាស់ដូច្នេះថា ទុតិយជ្ឈាននេះឯង អាត្មាអញបានតាក់តែងហើយ បានបង្កើតហើយ ។បេ។ ទាំងដល់ធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។ ម្នាលគហបតី មួយទៀត ភិក្ខុព្រោះប្រាសចាកបីតិ ។បេ។ ចូលកាន់តតិយជ្ឈាន ទើបភិក្ខុនោះពិចារណា

ដឹងច្បាស់ដូច្នេះថា តតិយជ្ឈានទេះឯង អាត្មាអញបានតាក់តែងហើយ បានបង្កើតហើយ ។បេ។ ទាំងដល់នូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។ ម្នាលគហបតី មួយទៀត ភិក្ខុព្រោះលះបង់សុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ទើបភិក្ខុនោះពិចារណាដឹងច្បាស់ដូច្នេះថា ចតុត្ថជ្ឈានទេះឯង អាត្មាអញបានតាក់តែងហើយ បានបង្កើតហើយ ។បេ។ ទាំងដល់នូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។

[ ២១ ] ម្នាលគហបតី មួយទៀត ភិក្ខុមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទាំងមានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដោយយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទិសទាំងពួង ដោយប្រការដូច្នេះ ទើបភិក្ខុនោះពិចារណា ដឹងច្បាស់ដូច្នេះថា មេត្តាចេតោវិមុត្តិនេះឯង អាត្មាអញបានតាក់តែងហើយ បានបង្កើតហើយ ប៉ុន្តែធម្មជាតតិចតួចណា ដែលតាក់តែងហើយ បានបង្កើតហើយ ធម្មជាតទាំងនោះ ជារបស់មិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះក៏ឋិតនៅក្នុងធម៌នោះ ។បេ។ ទាំងដល់ធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។ ម្នាលគហបតី មួយទៀត ភិក្ខុមានចិត្តប្រកបដោយករុណា ។បេ។ មានចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទាំងមានចិត្តប្រកបដោយឧបេក្ខាដ៏ធំ

ទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងអស់ ក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ដោយយកខ្លួនឯងទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទិសទាំងពួង ដោយប្រការដូច្នេះ ទើបភិក្ខុនោះពិចារណា ដឹងច្បាស់ដូច្នេះថា ឧបេក្ខាចេតោវិមុត្តិនេះឯង អាត្មាអញបានតាក់តែងហើយ បានបង្កើតហើយ ប៉ុន្តែធម្មជាតតិចតួចណា ដែលតាក់តែងហើយ បានបង្កើតហើយ ធម្មជាតនោះឯង ជារបស់មិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះ ក៏ឋិតនៅក្នុងធម៌នោះ ។បេ។ ទាំងដល់ធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។

[ ២២ ] ម្នាលគហបតី មួយទៀត ភិក្ខុព្រោះកន្លងនូវពួករូបសញ្ញា ដោយអាការសព្វគ្រប់ រលត់នូវបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ហើយក៏ចូលអាកាសានញ្ចាយតនសមាបត្តិ ដោយបរិកម្មថា អាកាសមិនមានទីបំផុត ដូច្នេះ ទើបភិក្ខុនោះពិចារណា ដឹងច្បាស់ដូច្នេះថា អាកាសានញ្ចាយតនសមាបត្តិនេះឯង អាត្មាអញបានតាក់តែង បានបង្កើតហើយ ប៉ុន្តែធម្មជាតតិចតួចណា ដែលតាក់តែងហើយ បានបង្កើតហើយ ធម្មជាតនោះឯងជារបស់មិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះក៏ឋិតនៅក្នុងធម៌នោះ ។បេ។ ទាំងដល់នូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។ ម្នាលគហបតី មួយទៀត ភិក្ខុកន្លងនូវអាកាសានញ្ចាយតនសមាបត្តិ ដោយអាការសព្វគ្រប់ ហើយក៏ចូលវិញ្ញាណញ្ចាយតនសមាបត្តិ ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ ភិក្ខុនោះពិចារណាដឹងច្បាស់ដូច្នេះថា វិញ្ញាណញ្ចាយតនសមាបត្តិ

នេះឯង អាត្មាអញបានតាក់តែងហើយ បានបង្កើតហើយ ប៉ុន្តែធម្មជាតតិចតួចណា ដែលតាក់តែងហើយ បានបង្កើតហើយ ធម្មជាតនោះឯង ជារបស់មិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះ ក៏ឋិតនៅក្នុងធម៌នោះ ។បេ។ ទាំងដល់នូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ។ ម្នាលគហបតី មួយវិញទៀត ភិក្ខុកន្លងវិញ្ញាណញ្ចាយតនសមាបត្តិ ដោយអាការសព្វគ្រប់ ហើយក៏ចូលអាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា របស់បន្តិចបន្តួចមិនមាន ដូច្នេះ ទើបភិក្ខុនោះពិចារណា ដឹងច្បាស់ដូច្នេះថា អាកិញ្ចញ្ញាយតនសមាបត្តិនេះឯង អាត្មាអញបានតាក់តែងហើយ បានបង្កើតហើយ ប៉ុន្តែធម្មជាតតិចតួចណា ដែលតាក់តែងហើយ បានបង្កើតហើយ ធម្មជាតនោះឯង ជារបស់មិនទៀង តែងរលត់ទៅវិញជាធម្មតា ភិក្ខុនោះក៏ឋិតនៅក្នុងធម៌នោះ ហើយក៏បានដល់នូវការអស់ទៅនៃអាសវៈ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់ទៅកើតជាឱបបាតិកៈ ព្រោះអស់ទៅនៃសំយោជនធម៌ទាំង ៥ ប្រការ ជាចំណែកខាងក្រោម ដោយសេចក្តីត្រេកអរ ក្នុងធម៌នោះ និងសេចក្តីរីករាយក្នុងធម៌នោះ ហើយបរិនិព្វានក្នុងជាន់សុទ្ធាវាសនោះ មានសភាពមិនត្រឡប់ចាកព្រហ្មលោកនោះជាធម្មតា ម្នាលគហបតី ភិក្ខុជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ចិត្តដែលមិនទាន់រួចស្រឡះ ក៏រួចស្រឡះបានផង អាសវធម៌ទាំងឡាយ ដែលមិនទាន់អស់ទៅ ក៏អស់រលីងបានផង ទាំងដល់ធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ដែលមិនទាន់បានដល់ ព្រោះធម៌ឯកណា នេះឯង ជាធម៌ឯក ដែលព្រះ

មានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ព្រះអង្គបានសម្តែងហើយ ។

[ ២៣ ] កាលដែលព្រះអានន្ទត្ថេរ សម្តែងយ៉ាងនេះហើយ ទសមគហបតីអ្នកក្រុងអដ្ឋកៈ បាននិយាយនឹងព្រះអានន្ទមានអាយុយ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចម្រើន បុរសកាលស្វែងរកកំណប់តែ ១ ស្រាប់តែបានកំណប់ទាំង ១១ ដោយព្យាយាមតែម្តង មានឧបមាយ៉ាងណាមិញ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំព្រះករុណាកាលស្វែងរកទ្វារព្រះនិព្វានតែ ១ សោះ ស្រាប់តែបានទ្វារព្រះនិព្វានទាំង ១១ ដោយការស្តាប់តែម្តង ក៏មានឧបមេយ្យយ៉ាងនោះដែរ បពិត្រព្រះអានន្ទដ៏ចម្រើន មួយយ៉ាងទៀត ផ្ទះរបស់បុរសមានទ្វារ ១១ កាលភ្លើងឆេះផ្ទះនោះហើយ បុរសម្ចាស់ផ្ទះនោះ អាចនឹងធ្វើខ្លួនឲ្យមានសួស្តី ដោយទ្វារតែមួយៗ ក៏បាន មានឧបមាដូចម្តេចមិញ បពិត្រព្រះអានន្ទដ៏ចម្រើន បណ្តាទ្វារព្រះនិព្វានទាំង ១១ នេះ ខ្ញុំព្រះករុណានឹងអាចធ្វើខ្លួនឲ្យមានសួស្តី ដោយទ្វារព្រះនិព្វានតែមួយៗ បាន ក៏មានឧបមេយ្យដូច្នោះឯង បពិត្រព្រះអានន្ទដ៏ចម្រើន តាមទំនៀមពួកតិរ្ថិយទាំងនេះ ( កាលបើរៀនសិល្បសាស្រ្តក្នុងសម្នាក់អាចារ្យណា ) តែងស្វែងរកវង្វាន់អាចារ្យ ដើម្បីអាចារ្យ ( នោះ ) ចំណង់បើរូបខ្ញុំព្រះករុណា នឹងខានធ្វើការបូជាដល់ព្រះអានន្ទមានអាយុដូចម្តេចបាន ។ ទើបទសមគហបតី អ្នកក្រុងអដ្ឋកៈ បានប្រជុំភិក្ខុសង្ឃដែលគង់នៅក្នុងក្រុងបាតលិបុត្ត និងក្រុងវេសាលី ហើយអង្គាសដោយខាទនីយភោជនីយាហារដ៏ផ្ចាញ់ពិសា ដោយខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ ត្រា

តែលោកប្រកែកលែងទទួលទៀត ហើយនិមន្តភិក្ខុមួយរូបៗ ឲ្យស្លៀកដណ្តប់ ដោយសំពត់ ១ គូ ១ អង្គ រួចនិមន្តព្រះអានន្ទមានអាយុ ឲ្យស្លៀកដណ្តប់ ដោយចីវរ ៣ ហើយកសាងទីនៅគួរដល់ថ្លៃ ៥០០ ( កហាបណៈ ) ប្រគេន ព្រះអានន្ទមានអាយុ ។

## អដ្ឋកនាគរសូត្រទី ២ ចប់

# អដ្ឋកថា

## អដ្ឋកនាគរសូត្រទី ២

[ ១៨ ] អដ្ឋកនាគរសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **វេឡុវគ្គាមកេ** សេចក្តីថា មានស្រុកឈ្មោះវេឡុវគ្រាម មិនឆ្ងាយក្នុងទិសខាងត្បូងនៃក្រុងវេសាលី ព្រះអានន្ទធ្វើវេឡុវគ្រាមនោះ ឲ្យជាគោចរគាម ។ បទថា **ទសមោ** សេចក្តីថា គហបតីនោះរាប់ចូលក្នុងឋានៈទី ១០ ដោយជាតិ និងត្រកូល និងដោយការរាប់ត្រកូលដែលដល់នូវភាពជាត្រកូលមហាសាល ដោយហេតុនោះ ទើបគហបតីនោះឈ្មោះថា **ទសម** ។ បទថា **អដ្ឋកនាគរោ** ប្រែថា អ្នកអដ្ឋកនគរ ។ បទថា **កុក្កុដារាមោ** ប្រែថា អារាមដែលកុក្កុដសេដ្ឋីសាង ។

[ ១៩ ] ក្នុងបាលីនេះថា **តេន ភគវតា ។បេ។ អក្ខាតោ** មានសេចក្តីសង្ខេបដូច្នេះ ព្រះមានព្រះភាគអង្គនោះ ទ្រង់បំពេញបារមី ៣០ ទ្រង់កាច់បំបាក់កិលេសទាំងពួង ត្រាស់ដឹងអនុត្តរសម្មាធិញ្ញាណ ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់ដឹងអធ្យាស្រ័យ និងអនុស័យរបស់សត្វនោះ ទ្រង់ឃើញញេយ្យធម៌ទាំងពួងនោះ ដូចផ្លែកន្ទួតព្រៃដែលដាក់លើបាតដៃ ។ ម្យ៉ាងទៀត ទ្រង់ដឹងដោយបុព្វេនិវាសញ្ញាណជាដើម ទ្រង់ឃើញដោយទិព្វចក្ខុ ឬទ្រង់ដឹងដោយវិជ្ជា ៣ អភិញ្ញា ៦ ទ្រង់ឃើញដោយសមន្តចក្ខុ ដែលធម្មជាតណាមួយមិនរារាំងក្នុងធម៌ទាំងពួង ។ ទ្រង់ដឹងដោយបញ្ញាដែលអាចដឹងធម៌ទាំងពួង ។ ទ្រង់ឃើញសត្វទាំងឡាយដែលកន្លងបង់នូវចក្ខុវិស័យនៃសត្វទាំងពួង ឬត្រង់

លំនៅ ឬដែលនៅក្រោមជញ្ជាំងផ្ទះជាដើម ដោយមំសចក្ខុដ៏បរិសុទ្ធក្រៃលែង ។ ទ្រង់ដឹងដោយបញ្ញា ដែលឲ្យសម្រេចប្រយោជន៍ចំពោះព្រះអង្គ ទ្រង់ឃើញដោយទេសនាបញ្ញា ដែលមានករុណាជាបទដ្ឋាន ឲ្យសម្រេចប្រយោជន៍ដល់អ្នកដទៃ ។ ឈ្មោះថា **ព្រះអរហន្ត** ព្រោះទ្រង់កម្ចាត់សត្រូវចេញបាន និងព្រោះគួរដល់សក្ការៈ មានបច្ច័យជាដើម ។ ឯឈ្មោះថា **សម្មាសម្ពុទ្ធ** ព្រោះត្រាស់ដឹងសច្ចៈ ៤ ដោយប្រពៃ និងដោយព្រះអង្គឯង ។ ម្យ៉ាងទៀត ទ្រង់ដឹងអន្តរាយិកធម៌ ទ្រង់ឃើញនិយ្យានិកធម៌ ជាព្រះអរហន្ត ព្រោះកម្ចាត់សត្រូវ គឺកិលេស ជាព្រះសម្មាសម្ពុទ្ធ ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយព្រះអង្គឯង សរុបសេចក្តីថា ព្រះអង្គត្រូវលើកសរសើរដោយហេតុ ៤ គឺវេសារជ្ជធម៌ ៤ យ៉ាងនេះហើយ ទើបត្រាស់ថា **ឯកោធម្មោ អក្ខាតោ** ។

[ ២០ ] បទថា **អភិសង្ខតំ** សេចក្តីថា ដែលបច្ច័យធ្វើហើយ ឲ្យកើតហើយ ។ បទថា **អភិសញ្ចេតយិតំ** សេចក្តីថា ញុំាងឲ្យសម្រេចហើយ ។ បទថា **សោ តត្ថ ឋិតោ** សេចក្តីថា គហបតីនោះ តាំងនៅហើយក្នុងធម៌ គឺសមថៈ និងវិបស្សនានោះ ។ ដោយពីរបទថា **ធម្មរាគេន ធម្មនន្ទិយា** សេចក្តីថា ព្រះអង្គត្រាស់ឆន្ទរាគៈក្នុងសមថៈ និងវិបស្សនា ។ ពិតហើយ បុគ្គលកាលអាចគ្របសង្កត់ឆន្ទរាគៈដោយប្រការទាំងពួង ក្នុងសមថៈ និងវិបស្សនា រមែងជាព្រះអរហន្ត កាលមិនអាច ក៏នឹងជាព្រះអនាគាមី លោករមែងកើតក្នុងសុទ្ធាវាសព្រហ្ម ដោយចេតនាដែលសម្បយុត្តដោយចតុត្ថជ្ឈាន ព្រោះមិនទាន់លះឆន្ទរាគៈក្នុងសមថៈ និងវិបស្សនាបាន ។ នេះ

ជាកថាសម្រាប់អាចារ្យទាំងឡាយ ។ ឯវិតណ្ឌវាទីពោលថា ព្រះអនាគាមីកើតក្នុងសុទ្ធាវាសព្រោះអកុសល តាមព្រះបាលីថា **តេនេវ ធម្មរាគេន** បុគ្គលនោះគប្បីពោលថា ចូរទាញព្រះសូត្រមក បុគ្គលនោះ កាលមិនឃើញបាលីដទៃ ក៏នឹងនាំបាលីនេះឯងមកដោយពិត ដូច្នោះ បុគ្គលនោះ គប្បីត្រូវបន្តថា ព្រះសូត្រនេះ មានអត្ថដែលគួរអធិប្បាយ មានអត្ថដែលអធិប្បាយមកហើយ ឬ ។ បុគ្គលនោះ ក៏នឹងពោលថា មានអត្ថដែលលោកអធិប្បាយហើយដោយពិត បន្ទាប់អំពីនោះ បុគ្គលនោះគប្បីពោលបន្តថា កាលបើដូច្នោះ ការគិតដោយអំណាចការពេញចិត្តក្នុងសមថៈ និងវិបស្សនា ក៏នឹងជាកិលេសដែលត្រូវការអនាគាមិផលគប្បីធ្វើ កាលធ្វើឲ្យកើតឆន្ទរាគៈឡើង ក៏នឹងចាក់ចុះអនាគាមិផល ។ អ្នកកុំសម្ដែងលំៗ ថា ខ្ញុំបានសូត្រមកហើយ អ្នកឆ្លើយបញ្ហា គួររៀនក្នុងសម្នាក់របស់ព្រះអរិយៈជាអ្នកដឹងនូវអត្ថរសេ ហើយសឹមដោះស្រាយបញ្ហា ព្រោះថា ឈ្មោះថា បដិសន្ធិក្នុងសួគ៌ដោយអកុសល ឬថា ក្នុងអបាយ ដោយកុសលមិនមាន សមដូចព្រះពុទ្ធតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ពួកទេវតាក្ដី ពួកមនុស្សក្ដី ឬសុគតិឯណាមួយឯទៀត មិនមែនបានប្រាកដមកអំពីកម្មដែលកើតអំពីលោភៈ កម្មដែលកើតអំពីទោសៈ កម្មដែលកើតអំពីមោហៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ នរកក្ដី កំណើតតិរច្ឆានក្ដី ប្រេតវិស័យក្ដី ឬក៏ទុគ្គតិណាមួយឯទៀត រមែងកើតប្រាកដមកអំពីកម្ម ដែលកើតអំពីលោភៈ កម្មដែលកើតអំពីទោសៈ កម្មដែលកើតអំពីមោហៈ ជាប្រាកដ ។

បុគ្គលនោះ ក៏គប្បីត្រូវធ្វើឲ្យយល់យ៉ាងនេះថា បើលោកយល់បាន ក៏ចូរយល់ទៅចុះ បើមិនយល់ ក៏ត្រូវបញ្ជូនត្រឡប់ទៅកាន់វិហារ ឲ្យធាន់បបរអំពីព្រលឹម ។ លោកពោលសមថៈ និងវិបស្សនាក្នុងមហាមាលុង្ក្យោវាទសូត្រក៏មាន មហាសតិប្បដ្ឋានសូត្រក៏មាន កាយគតាសតិសូត្រក៏មាន ដូចក្នុងសូត្រនេះឯង ។

ក្នុងបណ្តាព្រះសូត្រទាំងនោះ ក្នុងព្រះសូត្រនេះ ព្រះអង្គត្រាស់សំដៅដល់ធុរៈ គឺវិបស្សនាធុរៈប៉ុណ្ណោះ សម្រាប់ភិក្ខុដែលប្រព្រឹត្តទៅដោយអំណាចនៃសមថធុរៈ និងប្រព្រឹត្តទៅដោយអំណាចនៃវិបស្សនាធុរៈ ។ ក្នុងមហាមាលុង្ក្យោវាទសូត្រ ព្រះមានព្រះភាគត្រាស់សំដៅដល់វិបស្សនាធុរៈ ឯក្នុងមហាសតិប្បដ្ឋានសូត្រ ព្រះអង្គត្រាស់សំដៅដល់ធុរៈ គឺ វិបស្សនាធុរៈដ៏ប្រសើរ ក្នុងកាយគតាសតិសូត្រ ព្រះមានព្រះភាគត្រាស់សំដៅដល់សមថធុរៈដ៏ប្រសើរ ។

ធម៌ទាំង ១១ យ៉ាង ឈ្មោះថា ជាធម៌ឯក ព្រោះជាការសួរដល់ធម៌ឯកថា **អយំ ខោ គហបតិ ។បេ។ ឯកធម្មោ អក្ខាតោ** ទើបសម្តែងជាបុច្ឆាយ៉ាងនេះថា នេះក៏ចាត់ជាធម៌ឯក ពិតហើយ ក្នុងមហាសកុលុទាយិសូត្រ មានបុច្ឆាដល់ទៅ ១៩ បុច្ឆា ទាំងអស់ក៏ចាត់ជាធម៌ឯកដោយបដិបទា ។ ធម៌ ១១ យ៉ាង ក្នុងទីនេះ មកជាធម៌ឯកដោយបុច្ឆា ។ ម្យ៉ាងទៀត គួរនឹងពោលថា ទាំងអស់ ក៏ឈ្មោះថា ធម៌ឯក ដោយអត្ថថា ធ្វើឲ្យកើតអមតធម៌ ។

[ ២៣ ] បទថា **និធិមុខំ គវេសន្តោ** ប្រែថា ស្វែងរកកំណាប់ទ្រព្យ ។ បទថា **សកិទេវ** ប្រែថា ដោយការប្រកបម្ដងប៉ុណ្ណោះ ។ សួរថា កាលបានកំណាប់ទ្រព្យ ១១ យ៉ាង ដោយការប្រកបម្ដងមានដូចម្ដេច ឆ្លើយថា បុគ្គលក្នុងលោកនេះ ស្វែងរកកំណាប់ទ្រព្យក្នុងព្រៃ អ្នកស្វែងរកទ្រព្យម្នាក់ទៀត ជួបបុគ្គលនោះហើយ សួរថា នែអ្នកដ៏ចម្រើន អ្នកទៅធ្វើអ្វី បុរសនោះឆ្លើយថា ខ្ញុំស្វែងរកទ្រព្យជាគ្រឿងចិញ្ចឹមជីវិត ម្នាក់ទៀតប្រាប់ថា សម្លាញ់ បើដូច្នោះមក ទៅប្រមៀលថ្មមួយដុំនោះ បុរសប្រមៀលថ្មមួយដុំនោះហើយ ជួបក្អមទ្រព្យ ១១ ក្អម ដែលដាក់ត្រួតៗ គ្នា ឬដែលដាក់រៀងគ្នា ។ កាលបានកំណាប់ទ្រព្យ ១១ ដោយការប្រកបម្ដង មានយ៉ាងនេះ ។ បទថា **អាចរិយធនំ បរិយេសិស្សន្តិ** សេចក្ដីថា អន្យតិរ្ថិយទាំងឡាយរៀនសិប្បៈ ក្នុងសម្នាក់នៃអាចារ្យណា នាំទ្រព្យមកអំពីផ្ទះ ប្រគល់ឲ្យអាចារ្យនោះមុន ក្រោយ ឬរវាងការរៀនសិល្បសាស្ត្រ ។ បុគ្គលដែលមិនមានទ្រព្យក្នុងផ្ទះ រមែងស្វែងរកទ្រព្យអំពីញាតិ ឬអំពីបុគ្គលដែលរាប់អានគ្នា កាលមិនបានយ៉ាងនោះ ក៏ត្រូវសូមគេឲ្យ លោកសំដៅយកទ្រព្យនោះ ទើបពោលពាក្យនេះ ។ បទថា **កិមង្គំ បនាហំ** សេចក្ដីថា ជាបឋម បុគ្គលខាងក្រៅសាសនា ស្វែងរកទ្រព្យដើម្បីអាចារ្យដែលឲ្យត្រឹមតែសិប្បៈ ក្នុងសាសនាដែលមិនមែនជានិយ្យានិកធម៌ ហេតុអ្វី យើងមិនធ្វើការបូជាអាចារ្យ អ្នកសម្ដែងបដិបទាឲ្យកើតអមតធម៌ ១១ យ៉ាង ក្នុងសាសនាដែលជានិយ្យានិកធម៌នោះ ។ ទើបបុគ្គលនោះពោល ខ្ញុំនឹងធ្វើការបូជានោះឯង ។ បទថា **បច្ចេកំ ឧស្សយុគេន**

**អច្ឆាទេសិ** សេចក្ដីថា យើងបានថ្វាយគូសំពត់ដល់ភិក្ខុមួយអង្គមួយគូៗ ក្នុងទីនេះ ពាក្យដែលបន្ទឹទ្បើង ក៏យ៉ាងនោះ ព្រោះដូច្នោះ ទើបលោកពោលថា **អច្ឆាទេសិ** ។ បទថា **បញ្ចសតំ វិហារំ** សេចក្ដីថា បានធ្វើបណ្ណសាលាតម្លៃ ៥០០ ពាក្យដ៏សេសក្នុងបទទាំងអស់ ងាយយល់ហើយ ៕

## អដ្ឋកនាគរសូត្រ ចប់

## សូត្រទី ២ ចប់

# សុត្តន្តបិដក

## សេក្ខប្បដិបទាសូត្រទី ៣

[ ២៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលវត្ថុ ក្នុងដែនសក្កៈ ។ សម័យនោះឯង ពួកសក្យៈ អ្នកក្រុងកបិលវត្ថុ បានសាងសន្ថាគារសាលាថ្មីមួយ ទើបនឹងហើយថ្មីៗ មិនទាន់មានសមណៈ ឬព្រាហ្មណ៍ ឬអ្នកណាមួយ ដែលជាជាតិមនុស្ស ចូលទៅនៅអាស្រ័យនៅឡើយ ។ លំដាប់នោះ ពួកសក្យៈ អ្នកក្រុងកបិលវត្ថុ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះពួកសក្យៈអ្នកក្រុងកបិលវត្ថុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកសក្យៈអ្នកក្រុងកបិលវត្ថុ បានកសាងសន្ថាគារសាលាថ្មី ១ ទើបនឹងហើយថ្មីៗ មិនទាន់មានសមណៈ ឬព្រាហ្មណ៍ ឬអ្នកណាមួយ ដែលជាជាតិមនុស្ស ចូលទៅអាស្រ័យនៅឡើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ប្រើប្រាស់សន្ថាគារសាលានោះជាមុន លុះព្រះមានព្រះភាគ ទ្រង់ប្រើប្រាស់ជាមុនរួចហើយ ទើបពួកសក្យៈ អ្នកក្រុងកបិលវត្ថុ នឹងប្រើប្រាស់ជាខាងក្រោយ ការប្រើប្រាស់នោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខ យូរអង្វែង ដល់ពួកសក្យៈ អ្នកក្រុងកបិលវត្ថុ ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តន៍ដោយអាការស្ងៀម ។ ចំណែកខាងពួកសក្យៈអ្នកក្រុងកបិលវត្ថុដឹងថា ព្រះមានព្រះភាគទទួលនិមន្តន៍

ហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចហើយ នាំគ្នាចូលទៅកាន់សន្ថាគារសាលាថ្មី លុះចូលទៅដល់ហើយ បាន នាំគ្នាចាត់ចែងសន្ថាគារសាលា ឲ្យមានកម្រាលគ្រប់អន្លើ ហើយក្រាល អាសនៈទាំងឡាយ រួចតម្កល់ក្អមទឹកទុក អុជប្រទីបប្រេង រួចហើយ នាំគ្នា ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមាន ព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះពួកសក្យៈ អ្នកក្រុងកបិលវត្ថុ ឋិតនៅក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គបានចាត់ចែងនូវសន្ថាគារសាលាឲ្យមាន កម្រាលគ្រប់អន្លើ បានក្រាលអាសនៈទាំងឡាយ បានតម្កល់ក្អមទឹកទុក និង អុជប្រទីបប្រេងទុករួចស្រេចហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះ ភាគ ទ្រង់សម្គាល់នូវកាលនៃពុទ្ធដំណើរ ក្នុងកាលឥឡូវនេះចុះ ។

[ ២៥ ] គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ព្រមទាំងភិក្ខុសង្ឃ ទ្រង់និមន្តចូលទៅកាន់សន្ថាគារសាលា លុះចូលទៅដល់ ហើយ ទ្រង់ឲ្យលាងព្រះបាទា រួចហើយ យាងចូលទៅកាន់សន្ថាគារសាលា គង់ផ្អែកនឹងសសរកណ្តាល បែរព្រះភក្ត្រទៅទិសខាងកើត ។ ឯភិក្ខុសង្ឃក៏ឲ្យ លាងជើង រួចហើយ ចូលទៅកាន់សន្ថាគារសាលា អង្គុយផ្អែកនឹងជញ្ជាំង ខាងលិច បែរមុខទៅទិសខាងកើត ព្រះមានព្រះភាគគង់នៅខាងមុខ ។ ឯពួក សក្យៈអ្នកក្រុងកបិលវត្ថុ ក៏លាងជើង រួចហើយចូលទៅកាន់សន្ថាគារសាលា អង្គុយផ្អែកនឹងជញ្ជាំងខាងកើត បែរមុខទៅទិសខាងលិច មានព្រះមានព្រះភាគ

គង់នៅខាងមុខ ។ លំដាប់នោះ ព្រះមានព្រះភាគពន្យល់ណែនាំពួកសក្យៈអ្នកក្រុងកបិលវត្ថុ ឲ្យយល់ប្រយោជន៍ ( ក្នុងបច្ចុប្បន្ន និងបរលោក ) ឲ្យជឿជាក់ ( ក្នុងកុសលធម៌ ) ឲ្យខ្មីឃ្មាតសង្វាត ឲ្យរីករាយ ដោយធម្មីកថា ច្រើនរាត្រី ( ពេញមួយយប់ ) ហើយត្រាស់ទៅនឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកសម្តែងសេក្ខប្បដិបទា ដល់ពួកសក្យៈ អ្នកក្រុងកបិលវត្ថុចុះ ដ្បិតតថាគតរួយខ្នងណាស់ តថាគតនឹងសម្រាកខ្នងបន្តិច ។ ព្រះអានន្ទមានអាយុទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះព្រះមានព្រះភាគ ទ្រង់ក្រាលសង្ឃាដីឲ្យជា ៤ ជាន់ ហើយសម្រេចនូវសីហសេយ្យាផ្អៀងខាងស្តាំ គងព្រះបាទដោយព្រះបាទ មានសតិ និងសម្បជញ្ញៈកំណត់ទុកក្នុងហឫទ័យនូវឧដ្ឋានសញ្ញាគឺសេចក្តីសម្គាល់នូវការក្រោកឡើងវិញ ។

[ ២៦ ] គ្រានោះ ព្រះអានន្ទមានអាយុ សម្តែងចំពោះមហានាមសក្យៈថា បពិត្រមហានាម អរិយសាវក ក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសីល ជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកស្គាល់ប្រមាណក្នុងភោជន ជាអ្នកប្រកបនូវការភ្ញាក់រឭក ជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការ ជាអ្នកបានដូចប្រាថ្នានូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លាជាហេតុនៃកិរិយានៅជាសុខក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយ ។

[ ២៧ ] បពិត្រមហានាម ចុះអរិយសាវក ជាអ្នកបរិបូណ៌ដោយសីលតើដូចម្តេច ។ បពិត្រមហានាម អរិយសាវក ក្នុងសាសនានេះ ជាអ្នកមាន

សីល សង្រួមល្អក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារ និងគោចរ ឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ បពិត្រមហានាម អរិយសាវ័កដែលជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះឯង ។

[ ២៨ ] បពិត្រមហានាម ចុះអរិយសាវ័ក ជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្រ្ទិយទាំងឡាយ តើដូចម្តេច ។ បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ ឃើញរូបារម្មណ៍ដោយចក្ខុ មិនក្តោបកាន់និមិត្ត មិនក្តោបកាន់អនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមបុគ្គលដែលមិនសង្រួមនូវចក្ខុន្រ្ទិយ ព្រោះហេតុមិនសង្រួមចក្ខុន្រ្ទិយណា លោកប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្រ្ទិយនោះ រក្សាចក្ខុន្រ្ទិយ ដល់នូវសេចក្តីសង្រួម ក្នុងចក្ខុន្រ្ទិយ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយ ... ដឹងធម្មារម្មណ៍ដោយចិត្ត ហើយជាអ្នកមិនក្តោបកាន់និមិត្ត មិនក្តោបកាន់អនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមបុគ្គលដែលមិនសង្រួមនូវមនិន្រ្ទិយ ព្រោះហេតុមិនសង្រួមមនិន្រ្ទិយណា លោកប្រតិបត្តិដើម្បីសង្រួមនូវមនិន្រ្ទិយនោះ រក្សាមនិន្រ្ទិយ ដល់នូវសេចក្តីសង្រួមក្នុងមនិន្រ្ទិយ បពិត្រមហានាម អរិយសាវ័កដែលជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្រ្ទិយទាំងឡាយ យ៉ាងនេះឯង ។

[ ២៩ ] បពិត្រមហានាម ចុះអរិយសាវ័ក ជាអ្នកស្គាល់ប្រមាណក្នុងភោជន តើដូចម្តេច ។ បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ ពិចារណា

ដោយឧបាយ ទើបបរិភោគអាហារដោយគិតថា អាត្មាអញបរិភោគអាហារ ដើម្បីលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីស្រវឹងក៏ទេ ដើម្បីប្រដាប់តាក់តែងរាងកាយក៏ទេ ដើម្បីធ្វើឲ្យផូរផង់ពណ៌សម្បុរក៏ទេ ( បរិភោគ ) ដើម្បីនឹងឲ្យតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់លំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយធម៌ អាត្មាអញនឹងកម្ចាត់បង់វេទនាចាស់ គឺសេចក្ដីឃ្លាន ដែលមានហើយផង នឹងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្ដី សេចក្ដីមិនមានទោសមានមិនប្រអូសចិត្តជាដើមក្ដី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្ដី នឹងមានដល់អាត្មាអញ ដោយបានបរិភោគអាហារនេះ បពិត្រមហានាម អរិយសាវកក្នុងសាសនានេះ ដែលជាអ្នកស្គាល់ប្រមាណក្នុងភោជន យ៉ាងនេះឯង ។

[ ៣០ ] បពិត្រមហានាម ចុះអរិយសាវក ជាអ្នកប្រកបនូវសេចក្ដីភ្ញាក់រឭក តើដូចម្ដេច ។ បពិត្រមហានាម អរិយសាវកក្នុងសាសនានេះ បើក្នុងវេលាថ្ងៃ ( លោក ) រមែងជម្រះចិត្តចាកនីវរណធម៌ទាំងឡាយ ដោយការចង្ក្រម និងអង្គុយ បើវេលារាត្រីបឋមយាម ( លោក ) រមែងជម្រះចិត្តចាកនីវរណធម៌ទាំងឡាយ ដោយការចង្ក្រម និងអង្គុយ លុះដល់វេលារាត្រីមជ្ឈិមយាម លោករមែងសម្រេចសីហសេយ្យាផ្ទៀងខាងស្ដាំ យកជើងគងលើជើង មានសតិ និងសម្បជញ្ញៈ ធ្វើមនសិការនូវឧដ្ឋានសញ្ញា លុះដល់វេលារាត្រីបច្ឆិមយាម ( លោក ) រមែងក្រោកឡើង ហើយជម្រះចិត្តចាក

នីវរណធម៌ទាំងឡាយដោយការចង្ក្រម និងអង្គុយ បពិត្រមហានាម អរិយសាវ័ក ដែលជា អ្នកប្រកបនូវការភ្ញាក់រឭក យ៉ាងនេះឯង ។

[ ៣១ ] បពិត្រមហានាម ចុះអរិយសាវ័ក ជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការ តើដូចម្តេច ។ បពិត្រមហានាម អរិយសាវ័កក្នុងសាសនានេះ ជាអ្នកមានសទ្ធា រមែងជឿចំពោះពោធិញ្ញាណរបស់ព្រះតថាគត ថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគតជ្រាបច្បាស់នូវលោក ព្រះអង្គប្រសើរបំផុត ដោយសីលាទិគុណ ព្រះអង្គជាសារថីទូន្មានបុរស ព្រះអង្គជាសាស្តារបស់ពួកទេវតា និងមនុស្ស ព្រះអង្គត្រាស់ដឹងសច្ចធម៌ ព្រះអង្គបំបាត់បង់ត្រៃភព ដូច្នេះ ១ ជាអ្នកមានសេចក្តីខ្មាស រមែងអៀនខ្មាសចំពោះកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត រមែងអៀនខ្មាសចំពោះការជួបប្រសព្វអកុសលធម៌ដ៏លាមក ១ ជាអ្នកមានសេចក្តីតក់ស្លុត រមែងតក់ស្លុតចំពោះកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត រមែងតក់ស្លុតចំពោះការជួបប្រសព្វអកុសលធម៌ដ៏លាមក ១ ជាពហុស្សូត ទ្រទ្រង់នូវចំណេះ សន្សំទុកនូវចំណេះ ធម៌ទាំងឡាយណាមានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកបដោយអត្ថនិងព្យញ្ជនៈរមែងប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ លោកបានស្តាប់ច្រើន បានទ្រទ្រង់ទុក បានចាំស្ទាត់រត់មាត់ បានចូលចិត្តច្បាស់លាស់ បានយល់ច្បាស់ដោយទិដ្ឋិគឺបញ្ញា ១ ជាអ្នកផ្តួចផ្តើមសេចក្តីព្យាយាម ដើម្បីលះអកុសលធម៌ ដើម្បីបំពេញនូវកុសលធម៌ ជាអ្នក

មានកម្លាំងព្យាយាម ខ្មីឃ្មាតមុតមាំ មិនដាក់ធុរៈចោលចំពោះកុសលធម៌ទាំង-ឡាយ ១ ជាអ្នកមានសតិ ប្រកបព្រមដោយសតិ និងបញ្ញាដ៏ឧត្តម ជាអ្នកនឹករឭកចាំបាននូវអំពើដែលខ្លួនធ្វើយូរហើយ និងសម្តីដែលខ្លួននិយាយយូរហើយ ១ ជាអ្នកមានប្រាជ្ញា រមែងប្រកបដោយប្រាជ្ញា ជាគ្រឿងដឹងច្បាស់នូវការកើតឡើង និងសូន្យទៅ ( នៃខន្ធ ៥ ) និងបញ្ញាសម្រាប់ទម្លាយបង់នូវគំនរ លោភៈ ទោសៈ មោហៈដ៏ប្រសើរ ទាំងជាគ្រឿងដឹងនូវការអស់ទៅនៃកងទុក្ខដោយប្រពៃ ១ បពិត្រមហានាម អរិយសាវកដែលជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការ យ៉ាងនេះឯង ។

[ ៣២ ] បពិត្រមហានាម ចុះអរិយសាវក ជាអ្នកបានដូចប្រាថ្នានូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ថ្លៃថ្លា ជាហេតុនៃការនៅជាសុខក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយ តើដូចម្តេច ។ បពិត្រមហានាម អរិយសាវកក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈានដែលប្រកបដោយវិតក្ក និងវិចារៈ មានបីតិ និងសុខដែលកើតអំពីវិវេក ព្រោះរម្ងាប់វិតក្ក និងវិចារៈ ក៏ចូលកាន់ទុតិយ-ជ្ឈាន ជាទីផូរផង់ប្រព្រឹត្តទៅក្នុងសន្តាន មានភាវៈនៃចិត្តដ៏ប្រសើរ គ្មានវិតក្ក និងវិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ ព្រោះលះបង់បីតិចេញ ជាបុគ្គលព្រងើយផង មានសតិ និងសម្បជញ្ញៈផង ទទួលសេចក្តីសុខដោយនាមកាយផង ចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយសរសើរថា បុគ្គលដែលបានតតិយជ្ឈានហើយ តែងមានចិត្តព្រងើយ ជាអ្នកមានស្មារតី

មានប្រក្រតីនៅជាសុខ ព្រោះលះបង់នូវសេចក្តីសុខផង លះបង់សេចក្តីទុក្ខផង ព្រោះរលត់សោមនស្ស និងទោមនស្សអំពីមុនផង លោកក៏បានចូលកាន់ចតុត្ថជ្ឈាន ឥតទុក្ខឥតសុខ មានសតិ ដែលកើតអំពីឧបេក្ខាដ៏បរិសុទ្ធ ។ បពិត្រមហានាម អរិយសាវកជាអ្នកបានដូចប្រាថ្នានូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ថ្លៃថ្លា ជាហេតុនៃការនៅជាសុខក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយ យ៉ាងនេះឯង ។

[ ៣៣ ] បពិត្រមហានាម កាលណាអរិយសាវកជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះ ជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយយ៉ាងនេះ ជាអ្នកស្គាល់ប្រមាណក្នុងភោជនយ៉ាងនេះ ជាអ្នកប្រកបដោយការភ្ញាក់រឭកយ៉ាងនេះ ជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការយ៉ាងនេះ ជាអ្នកបានដូចប្រាថ្នានូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ថ្លៃថ្លា ជាហេតុនៃការនៅជាសុខក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយយ៉ាងនេះ បពិត្រមហានាម អរិយសាវកនេះ ព្រះបរមគ្រូសម្តែងថា អ្នកមានសេចក្តីប្រតិបត្តិជាសេក្ខៈ ប្រកបដោយសេចក្តីប្រតិបត្តិ ដូចជាពងមាន់មិនស្អុយ ជាបុគ្គលគួរដើម្បីបែកធ្លាយនូវញាណ គួរត្រាស់ដឹង គួរបាននូវព្រះនិព្វាន ជាដែនក្សេមចាកយោគៈដ៏ប្រសើរ ។ បពិត្រមហានាម ប្រៀបដូចពងមាន់ ៨ ក្តី ១០ ក្តី ១២ ក្តី ពងមាន់ទាំងនោះ មេមាន់បានក្រាបល្អហើយ ធ្វើឲ្យកក់ក្តៅដោយប្រពៃហើយ អប់រំកម្តៅដោយល្អហើយ ចំណែកខាងមេមាន់នោះ មិនមានបំណងយ៉ាងនេះថា ធ្វើម្តេចហ្ន៎ កូនមាន់ទាំងនេះ គប្បីទម្លាយសំបកពង ដោយចុង

ក្រចកឬដោយចុងចំពុះ ហើយញាស់ចេញមកដោយសួស្តីដូច្នេះទេ មានឧបមាយ៉ាងណាមិញ បពិត្រមហានាម កាលណាបើអរិយសាវក ជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះ ជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយយ៉ាងនេះ ជាអ្នកស្គាល់ប្រមាណក្នុងភោជនយ៉ាងនេះ ជាអ្នកប្រកបការភ្ញាក់រឭកយ៉ាងនេះ ជាអ្នកប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការយ៉ាងនេះ ជាអ្នកបានដូចសេចក្តីប៉ុនប៉ងនូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ថ្លៃថ្លា ជាហេតុនៃការនៅជាសុខក្នុងបច្ចុប្បន្ន ជាអ្នកបានដោយមិនលំបាក បានដោយងាយយ៉ាងនេះ បពិត្រមហានាម អរិយសាវកនេះ ព្រះបរមសាស្តាចារ្យសម្តែងថា អ្នកមានសេចក្តីប្រតិបត្តិជាសេក្ខៈ ប្រកបដោយសេចក្តីប្រតិបត្តិដូចជាពងមាន់មិនស្អុយ ជាបុគ្គលគួរដើម្បីបែកធ្លាយនូវញាណ គួរត្រាស់ដឹង គួរបាននូវព្រះនិព្វានជាដែនក្សេមចាកយោគៈ ដ៏ប្រសើរ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បពិត្រមហានាម អរិយសាវកនោះឯង អាស្រ័យសតិដ៏បរិសុទ្ធដោយឧបេក្ខាដ៏ប្រសើរនេះឯង ទើបរឭកបាននូវជាតិដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលមុន បានច្រើនជាតិ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកបាននូវជាតិដែលខ្លួនធ្លាប់អាស្រ័យនៅអំពីមុនបានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះឯង នេះឈ្មោះថាការបែកធ្លាយនៃប្រាជ្ញាទី ១ គឺបុព្វេនិវាសញ្ញាណរបស់អរិយសាវកនោះ ដូចពងមាន់ដែលញាស់ចេញចាកសំបកពង ។ បពិត្រមហានាម អរិយសាវកនេះឯង អាស្រ័យសតិដ៏បរិសុទ្ធដោយឧបេក្ខាដ៏ប្រសើរនេះឯង ទើបលោកមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្ស

ធម្មតា ។បេ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម នេះឈ្មោះថា ការបែកធ្លាយនៃប្រាជ្ញាទី ២ គឺទិព្វចក្ខុញ្ញាណរបស់អរិយសាវក នោះ ដូចកូនមាន់ដែលញាស់ចេញចាកសំបកពង ។ បពិត្រមហានាម អរិយសាវកនោះឯង អាស្រ័យសតិដ៏បរិសុទ្ធដោយឧបេក្ខាដ៏ប្រសើរនេះឯង ទើបធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវធម៌ទាំងឡាយ ដោយប្រាជ្ញារបស់ខ្លួនក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅដោយឥរិយាបថ នេះឈ្មោះថា ការបែកធ្លាយនៃប្រាជ្ញាទី ៣ គឺអាសវក្ខយញ្ញាណរបស់អរិយសាវកនោះ ដូចកូនមាន់ដែលញាស់ចេញចាកសំបកពង ។

[ ៣៤ ] បពិត្រមហានាម ត្រង់អរិយសាវក លោកបានបរិបូណ៌ដោយសីល នេះឯងជាចរណៈរបស់អរិយសាវកនោះ បពិត្រមហានាម ត្រង់អរិយសាវក បានគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយនេះឯង ជាចរណៈរបស់អរិយសាវកនោះ បពិត្រមហានាម ត្រង់អរិយសាវកស្គាល់ប្រមាណក្នុងភោជន នេះឯងជាចរណៈរបស់អរិយសាវកនោះ បពិត្រមហានាម ត្រង់អរិយសាវកប្រកបការភ្ញាក់រឭក នេះឯងជាចរណៈរបស់អរិយសាវកនោះ បពិត្រមហានាម ត្រង់អរិយសាវកបានប្រកបដោយសប្បុរិសធម៌ទាំង ៧ ប្រការ នេះឯងជាចរណៈរបស់អរិយសាវកនោះ បពិត្រមហានាម ត្រង់អរិយសាវកបានដូចសេចក្តីប៉ុនប៉ង នូវឈានទាំង ៤ ប្រការ ដែលអាស្រ័យចិត្តដ៏ថ្លៃថ្លា ជាហេតុនៃការនៅជាសុខក្នុងបច្ចុប្បន្ន បានដោយមិនលំបាក បានដោយងាយ នេះឯង

ជាចរណៈរបស់អរិយសាវកនោះ បពិត្រមហានាម ត្រង់អរិយសាវកបានរឭក ឃើញជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅអំពីមុន បានច្រើនជាតិ គឺ រឭកបាន ១ជាតិខ្លះ ២ជាតិខ្លះ ។ បេ ។ រឭកជាតិដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាល អំពីមុន បានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ នេះឯង ជាវិជ្ជារបស់អរិយសាវកនោះ បពិត្រមហានាម ត្រង់អរិយសាវកមានចក្ខុដូច ជាទិព្វដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សធម្មតា ។បេ។ លោកដឹងច្បាស់នូវ សត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម នេះឯងជាវិជ្ជារបស់អរិយសាវក នោះ បពិត្រមហានាម ត្រង់អរិយសាវកធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និង បញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវធម៌ទាំងឡាយ ដោយ ប្រាជ្ញានៃខ្លួនក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តដោយឥរិយាបថ នេះឯងជា វិជ្ជារបស់អរិយសាវកនោះ បពិត្រមហានាម អរិយសាវកនេះ ព្រះបរមគ្រូ ទ្រង់សម្តែងថា ជាអ្នកបរិបូណ៌ដោយវិជ្ជាដូច្នេះក៏បាន បរិបូណ៌ដោយចរណៈ ដូច្នេះក៏បាន បរិបូណ៌ដោយវិជ្ជា និងចរណៈដូច្នេះក៏បាន ។ បពិត្រមហានាម ទាំងព្រហ្មឈ្មោះ សនង្កុមារ ក៏បានពោលគាថានេះថា

ក្សត្រប្រសើរបំផុត ក្នុងពួកជនដែលប្រកាន់គោត្រ អ្នក
ណាបរិបូណ៌ដោយវិជ្ជា និងចរណៈ អ្នកនោះ ឈ្មោះ
ថា ប្រសើរបំផុត ក្នុងពួកទេវតា និងមនុស្ស ។

[ ៣៥ ] បពិត្រមហានាម គាថានេះឯង ព្រហ្មឈ្មោះសនង្កុមារ ច្រៀង ពីរោះហើយ មិនមែនច្រៀងមិនពីរោះទេ ពោលពីរោះហើយ មិនមែនពោល

មិនពីរោះទេ ជាគាថាប្រកបដោយប្រយោជន៍ មិនមែនឥតប្រយោជន៍ទេ ទាំងព្រះមានព្រះភាគ ក៏ទ្រង់យល់ព្រមហើយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ក្រោកឡើងហើយត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ពីរោះណាស់ៗ ម្នាលអានន្ទ អ្នកសម្តែងនូវសេក្ខប្បដិបទាដល់ពួកសក្យៈអ្នកក្រុងកបិលវត្ថុ ពេញហៅពីរោះ ។ លុះព្រះអានន្ទមានអាយុ បានសម្តែងសេចក្តីនេះចប់ហើយ ព្រះបរមគ្រូក៏មានហឫទ័យត្រេកអរ ពួកសក្យៈអ្នកក្រុងកបិលវត្ថុ ក៏មានចិត្តរីករាយ ត្រេកអរហើយ ចំពោះភាសិតនៃព្រះអានន្ទមានអាយុ ។

## សេក្ខប្បដិបទាសូត្រទី ៣ ចប់

# អដ្ឋកថា

## សេក្ខប្បដិបទាសូត្រទី ៣

[ ២៤ ] *សេក្ខសូត្រ មានពាក្យផ្ដើមថា* **ឯវម្មេ សុតំ** *ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា* **នវំ សន្ថាគារំ** *គឺសណ្ឋាគារដែលសាងស្រេចមកមិនយូរ អធិប្បាយថា សាលាធំមួយខ្នង ។ ពិតហើយ ក្នុងវេលារៀបចំក្បួនទទួលព្រះរាជាជាដើម គេចាត់របៀបការពារខេត្តយ៉ាងនេះ គឺពួកក្អាក់ងារដែលនៅក្នុងទីនោះនៅខាងមុខប៉ុណ្ណោះ នៅខាងក្រោយប៉ុណ្ណោះចំហៀងៗ ជិះដំរីប៉ុណ្ណោះ ជិះសេះប៉ុណ្ណោះ ឈរលើរថប៉ុណ្ណោះ ព្រោះដូច្នោះ ទើបទីនោះ គេហៅថា សណ្ឋាគារ ។ម្យ៉ាងទៀត មនុស្សទាំងឡាយ មកអំពីទទួលព្រះរាជា ធ្វើការបូកលាបដោយអាចម៍គោស្រស់ជាដើម ត្រង់ផ្ទះទាំងឡាយដរាបណា ពួកស្ដេចទាំងនោះ ក៏អនុគ្រោះនៅក្នុងទីនោះ ២-៣ ថ្ងៃដរាបនោះ ព្រោះដូច្នោះ ទើបទីនោះឈ្មោះថា សណ្ឋាគារ អាគារជាទីបញ្ជូការដោយខ្លួនឯងរបស់ស្ដេចទាំងនោះ ព្រោះដូច្នោះ ទើបអាគារនោះ ឈ្មោះថា សណ្ឋាគារ ពិតហើយ មនុស្សទាំងនោះជារាជាគណៈ ព្រោះដូច្នោះ កិច្ចដែលកើតឡើងទើបដាច់ខាតដោយអំណាចព្រះរាជាមួយអង្គ គួរនឹងបានឆន្ទៈ ពេញចិត្តរបស់ស្ដេចទាំងអស់ ព្រោះដូច្នោះ ទើបស្ដេចគ្រប់អង្គប្រជុំរៀបចំកិច្ចការក្នុងទីនោះ ដោយហេតុនោះ ទើបពោលថា អាគារជាទីចាត់ចែងការដោយខ្លួនឯង ព្រោះហេតុនោះ ទើបអាគារនោះ ឈ្មោះថា សណ្ឋាគារ តែស្ដេចទាំងនោះប្រជុំគ្នាក្នុងទីនោះ រមែងប្រឹក្សាគ្នាដល់កិច្ចការខាងឃរាវាស ដោយន័យជាដើមយ៉ាង*

នេះថា ពេលនេះ គួរភ្ជួរ ពេលនេះ គួរព្រោះ ព្រោះដូច្នោះ ស្តេចទាំងឡាយរៀបចំកិច្ចការយកវាសជាចំណែកតូចៗ ក្នុងទីនោះ ព្រោះហេតុនោះ ទើបឈ្មោះថា សណ្ឋាគារ ។ បទថា **អចិរការិតំ ហោតិ** គឺធ្វើស្រេចមិនយូរប្រៀបដូចទេពវិមានដែលតាក់តែងល្អហើយ ដោយការឆ្លាក់ឈើ ការឆ្លាក់ថ្មនិងការឆ្លាក់ចិត្រកម្មជាដើម ។ ក្នុងបទថា **សមណេន វា** ជាដើម ព្រោះហេតុដែលក្នុងវេលាកំណត់ទីលានដែលធ្វើផ្ទះ ទេវតាទាំងឡាយរមែងប្រកាន់ថា ជាទីលំនៅរបស់ខ្លួន ដូច្នោះ ទើបពួកស្តេចសក្យៈមិនពោលថា ទេវតាឬ តែពោលថា មិនទាន់មានសមណៈ ឬព្រាហ្មណ៍ ឬអ្នកណាមួយដែលជាជាតិមនុស្ស ចូលទៅនៅអាស្រ័យនៅឡើយ ។

បទថា **យេន ភគវា តេនុបសង្កមឹសុ** សេចក្តីថា សក្យរាជបានដំណឹងថា សណ្ឋាគារធ្វើស្រេចហើយ ក៏ប្រាថ្នានឹងទៅមើលសណ្ឋាគារនោះ ទើបទៅមើលទាំងអស់ តាំងអំពីខ្លោងទ្វារ ក៏គិតថា សណ្ឋាគារនេះ គួរត្រេកអរក្រៃលែង មានសិរីសួស្តី ដូចទេវវិមាន នរណាប្រើមុន ទើបជាប្រយោជន៍សុខដល់យើងអស់កាលដ៏យូរ ទើបប្រឹក្សាសម្រេចគ្នាថា សណ្ឋាគារនេះសមគួរដល់ព្រះសាស្តាប៉ុណ្ណោះ ក្នុងកាលយើងថ្វាយជាបឋមដល់ព្រះញាតិដ៏ប្រសើរបំផុតរបស់យើង សមដល់ព្រះសាស្តាប៉ុណ្ណោះ ក្នុងកាលយើងថ្វាយដោយអំណាចដែលព្រះអង្គ ទ្រង់ជាទក្ខិណេយ្យបុគ្គល ព្រោះដូច្នោះយើងនឹងអារាធនាព្រះសាស្តា ឲ្យទ្រង់ប្រើប្រាស់ជាបឋមឫក្ស និងអារាធនាភិក្ខុសង្ឃមក កាលភិក្ខុសង្ឃមក ក៏ស្មើគ្នានឹងព្រះត្រៃបិដកពុទ្ធវចនៈមកដែរ

យើងនឹងអារាធនាព្រះសាស្តាឲ្យត្រាស់ធម្មកថា ប្រៀនប្រដៅពួកយើង អស់យាមទាំង ៣ នៃរាត្រី ដូច្នោះ សណ្ឋាគារនេះ ឈ្មោះថា ព្រះរតនត្រ័យប្រើប្រាស់ហើយ យើងនឹងប្រើប្រាស់ក្នុងកាលជាក្រោយយ៉ាងនេះ ក៏នឹងជាប្រយោជន៍សុខដល់ពួកយើងអស់កាលដ៏យូរ ហើយនាំគ្នាចូលទៅគាល់ ។ ពាក្យថា **យេន សណ្ឋាគារំ តេនុបសង្កមឹសុ** សេចក្តីថា បានឮថា ថ្ងៃនោះសណ្ឋាគារបានតាក់តែងចាត់ចែង ដើម្បីឲ្យពួករាជត្រកូលទតក៏ពិត តែមិនបានរៀបចំឲ្យសមគួរដល់ព្រះពុទ្ធអង្គ ព្រោះជាធម្មតា ព្រះពុទ្ធទាំងឡាយមានអធ្យាស្រ័យនៅក្នុងព្រៃ ត្រេកអរតែក្នុងព្រៃ និងប្រថាប់នៅខាងក្នុងស្រុកឬអត់ហ្ន៎ ព្រោះដូច្នោះ ទើបពួកសក្យរាជគិតថា នឹងដឹងព្រះអធ្យាស្រ័យរបស់ព្រះមានព្រះភាគមុនហើយ សឹមក្រាល ព្រោះដូច្នោះ ទើបនាំគ្នាទៅគាល់ព្រះមានព្រះភាគ ដល់ទីប្រថាប់ ។

តែឥឡូវនេះ ពួកស្តេចសក្យៈជ្រាបព្រះអធ្យាស្រ័យ ហើយទ្រង់បំណងនឹងក្រាល ទើបនាំគ្នាទៅកាន់សណ្ឋាគារ ។ បទថា **សព្វសន្ថរិំ សន្ថាគារំ សន្ថរិត្វា** សេចក្តីថា ឲ្យក្រាលសន្ថតគ្រប់កន្លែង ។ ជាដំបូង ពួកសក្យៈឲ្យបូកលាបដោយគោម័យប៉ុណ្ណោះ ព្រោះគោម័យ រមែងគួរក្នុងមង្គលទាំង-ឡាយ សេចក្តីថា ពួកស្តេចសក្យៈឲ្យយកគោម័យស្រស់បូកសង្កត់អំពីលើសូម្បីបូកដោយបាយអហើយ ដឹងថា បរិសុទ្ធហើយ ក៏ប្រោះព្រំដោយគន្ធជាតិ ៤ ប្រភេទ មិនឲ្យស្នាមព្រះបាទប្រាកដក្នុងទីដែលទ្រង់ជាន់ ក្រាលកន្ទេលផែងមានពណ៌ផ្សេងៗ ខាងលើ ឲ្យក្រាលបិទប្រហោងគ្រប់កន្លែងដែល

គួរក្រាលដោយកម្រាលទាំងឡាយ មានពណ៌ផ្សេងៗ គ្នា ដូចជាគ្រឿងកម្រាលរូបដំរី រូបសេះ រូបរាជសីហ៍ រូបខ្លា រូបព្រះចន្ទ រូបព្រះអាទិត្យ រូបចិត្រកម្មជាដើម តាំងអំពីសំពត់កោជវៈមួយផ្ទាំងធំ ខាងលើកន្ទេលផែនទាំងនោះ ព្រោះហេតុនោះ ទើបលោកពោលថា **សព្វសន្ថរិសន្ថតំ សន្ថាគារំ សន្ថរាបេត្វា** ដូច្នេះ ។ បទថា **អាសនានិ បញ្ញាបេត្វា** សេចក្តីថា ក្រាលពុទ្ធាសនៈដែលមានតម្លៃច្រើនជាប់នឹងសសរមង្គល ត្រង់កណ្តាលមុនហើយ ក្រាលបច្ចត្ថរណៈដ៏ទន់ គួររីករាយលើពុទ្ធាសនៈនោះ ដាក់ខ្នើយដែលគួរគាប់ភ្នែក មានពណ៌ក្រហមសងខាង ប៉ាំងពិតានដ៏វិចិត្រដោយផ្កាយមាស ផ្កាយប្រាក់ខាងលើ ប្រដាប់កម្រងគ្រឿងក្រអូប កម្រងផ្កា និងកម្រងមុក្តាជាដើម ធ្វើសំណាញ់ដោយផ្កាឈើ ក្នុងទី ១២ ហត្ថដោយជុំវិញ យករាំងនន ព័ទ្ធត្រង់រ៉ាវ ៣០ ហត្ថ តម្កល់តាំងបល្ល័ង្ក តាំងបង្អែក និងតាំងត្រងោល ក្រាលបច្ចត្ថរណៈពណ៌សខាងលើ សម្រាប់ភិក្ខុសង្ឃផ្អែកខ្នង ក្រាលសំពត់កោជវៈមួយផ្ទាំងធំ ដាក់ខ្នើយដែលញាត់ដោយរោមហង្សជាដើម សម្រាប់ផ្អែកខ្នង ដោយត្រិះរិះថា ពួកយើងមិនលំបាកនឹងស្តាប់ធម៌បានអស់មួយរាត្រី យ៉ាងនេះ ។ លោកសំដៅយកសេចក្តីនេះ ទើបពោលថា **អាសនានិ បញ្ញាបេត្វា** ដូច្នេះ ។ បទថា **ឧទកមណិកំ** បានដល់ ក្អមទឹកដែលមានក្អេងធំ ។ បទថា **បតិដ្ឋបេត្វា** សេចក្តីថា ពួកស្តេចសក្យៈគិតថា ព្រះមានព្រះភាគ និងភិក្ខុសង្ឃ នឹងលាងព្រះហស្ត ឬព្រះបាទ ឬខ្ពុរព្រះឱស្ឋតាមពេញចិត្តយ៉ាងនេះ ទើបដាក់ក្អមពេញដោយទឹកថ្លា ពណ៌ដូចកែវមណី ដាក់ផ្កាផ្សេងៗ និងលម្អិត

អប់ទឹក ដើម្បីប្រយោជន៍អប់ទឹកឲ្យក្រអូប បិទដោយសាជីស្លឹកចេក តាំងទុកក្នុងទីនោះៗ លោកសំដៅយកសេចក្ដីនេះ ទើបពោលថា **បតិដ្ឋបេត្វា** ។ បទថា **តេលប្បទីបំ អារោបេត្វា** សេចក្ដីថា អុជប្រទីបប្រេងត្រង់ចង្កៀង ដែលមានដងធ្វើដោយប្រាក់ និងមាសជាដើម និងត្រង់ភាជនៈដែលធ្វើដោយមាសនិងប្រាក់ជាដើម ដែលគេតាំងក្នុងដៃនៃរូបអ្នកយោនកៈ និងរូបកិន្នរជាដើម ។

ក្នុងបាលីថា **យេន ភគវា តេនុបសង្កមឹសុ** គប្បីជ្រាបដូច្នេះ ពួកស្ដេចសក្យៈទាំងនោះឲ្យរៀបចំតុបតែងសណ្ឋាគារប៉ុណ្ណោះក៏ទេ ដោយពិតនោះ ឲ្យវាយស្គរ ស្រែកប្រកាសថា អ្នកទាំងឡាយ ចូរបោសផ្លូវជុំវិញក្រុងកបិលកសួមួយយោជន៍ ចូរលើកទង់ តាំងក្អមទឹក និងដើមចេកត្រង់ទ្វារផ្ទះ ពេញព្រះនគរ បីដូចដួងតារា ដេរដាសដោយប្រទីបផ្កាលាជាដើម ឲ្យទារកដែលនៅបៅដោះ បៅឲ្យឆ្អែត ឲ្យក្មេងតូចៗ ប្រញាប់ស៊ីបាយ ហើយឲ្យដេក កុំធ្វើសំឡេងខ្លាំង ថ្ងៃនេះ ព្រះសាស្ដានឹងប្រថាប់នៅខាងក្នុងស្រុកអស់មួយរាត្រីដោយធម្មតា ព្រះពុទ្ធទាំងឡាយ ត្រូវការស្ងប់ស្ងាត់ ហើយខ្លួនឯង ក៏កាន់ប្រទីបមានដង ចូលគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។

[ ២៥ ] ព្រះបាលីថា **អថខោ ភគវា និវាសេត្វា បត្តចីវរំ អាទាយ សទ្ធឹ ភិក្ខុ សង្ឃេន យេន នវំ សន្ថាគារំ តេនុបសង្កមិ** គប្បីជ្រាបសេចក្ដីដូច្នេះថា កាលពួកស្ដេចសក្យៈក្រាបទូលកាលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ជ្រាបកាលដ៏គួរក្នុងឥឡូវនេះ ព្រះមានព្រះភាគទ្រង់ដាក់សំពត់ក្រហម ពណ៌ដូចផ្ការលួសផ្អុង ដែលជ្រលក់ដោយទឹកចត់

ប្រៀបដូចកាត់ផ្កាឈូកដោយកន្ត្រៃ ទ្រង់ស្លៀកស្បង់បិទបាំងមណ្ឌលទាំង ៣ ទ្រង់ចងវត្ថពន្ធ មានសិរីដូចផ្លេកបន្ទោរ ប្រៀបដូចរុំបាច់បទុមដោយសង្វារមាស ទ្រង់ដណ្តប់បង្សុកូលចីវរដ៏ប្រសើរពណ៌ក្រហម មានពណ៌ដូចត្រួយខ្ចីនៃដើមជ្រៃ ធ្វើឲ្យមហាប្រឹថពី ដែលប្រកបដោយស្តេចភ្នំសិនេរុ និងភ្នំយុគន្ធរនៃចក្រវាលឲ្យញាប់ញ័រ ហើយចាប់ទុក ប្រៀបដូចគ្របដណ្តប់ពោធដំរីដោយសំពត់កម្ពលក្រហម ប្រៀបដូចបាចសាចសំណាញ់កែវប្រពាលក្នុងទីកម្ពស់ ១០០ ហត្ថ ដែលមានតម្លៃដូចមាស ប្រៀបដូចដោះសំពត់កម្ពលពណ៌ក្រហម ត្រង់សុវណ្ណចេតិយ ប្រៀបដូចបិទមណ្ឌលព្រះចន្ទពេញវង់ដែលកំពុងគោចរដោយភ្លៀងពណ៌ក្រហម ប្រៀបដូចស្រោចទឹកល័ក្តដែលឆ្អិនល្អ លើកំពូលកញ្ចនបព៌ត ប្រៀបដូចព័ទ្ធកំពូលភ្នំចិត្រកូដដោយផ្លេកបន្ទោរ ទ្រង់ចេញអំពីព្រះគន្ធកុដិ ដូចរាជសីហ៍ចេញអំពីគុហាមាស និងដូចព្រះចន្ទពេញវង់ ផុសចេញអំពីកំពូលឧទយបព៌ត ។ កាលទ្រង់យាងចេញហើយ ក៏ប្រថាប់ឈរត្រង់មុខព្រះគន្ធកុដិ គ្រានោះ រស្មីដែលផ្សាយចេញអំពីព្រះកាយរបស់ព្រះមានព្រះភាគនោះ ប្រៀបដូចផ្លេកបន្ទោរចេញអំពីចន្លោះពពក ធ្វើឲ្យព្រឹក្សជាតិក្នុងអារាម ហាក់ដូចជាមានស្លឹក ផ្កា ផ្លែ និងប្រគាបលាបដោយទឹកមាស ដូច្នោះ ព្រមគ្នានោះ មហាភិក្ខុសង្ឃកាន់យកបាត្រ និងចីវររបស់ខ្លួនហែហមព្រះមានព្រះភាគ ។ ឯភិក្ខុទាំងឡាយ ដែលឈរជុំវិញព្រះមានព្រះភាគនោះ ជាអ្នកប្រាថ្នាតិច សន្តោស ជាអ្នកមានវិវេក មិនប្រឡូកប្រឡំដោយពួកគណៈ ជាអ្នកប្រារព្ធព្យាយាម មានវត្តអត់ធន់ កាន់យកពាក្យ

ទូន្មានដាស់តឿនគ្នានិងគ្នា តិះដៀលនូវបាបកម្ម ដល់ព្រមដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈបែបនេះ ព្រះមានព្រះភាគ ដែលភិក្ខុទាំងនោះចោមរោមហើយ ក៏រុងរឿងផូរផង់ ដូចដុំមាសដែលខ្ចប់ដោយសំពត់កម្ពលក្រហម ដូចនាវាមាសរសាត់ទៅកណ្តាលស្រះឈូកក្រហម និងដូចប្រាសាទមាសដែលព័ទ្ធដោយផ្ទះកែវប្រពាល សូម្បីព្រះមហាថេរៈទាំងឡាយមានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម ក៏ដណ្តប់បង្សុកូលចីវរ មានពណ៌ដូចពពក សុទ្ធសឹងជាអ្នកខ្ជាក់ចោលនូវរាគៈ ទម្លាយនូវកិលេស ធ្លាវនូវព្រៃស្មុកបានហើយ កាត់ចំណងហើយ មិនជាប់ក្នុងត្រកូល ឬគណៈ ឈរហែហមដូចដីរីធំ មានស្បែកដណ្តប់ដោយកែវមណី ព្រះមានព្រះភាគ ទ្រង់ក៏ប្រាសចាករាគៈ ដែលភិក្ខុប្រាសចាករាគៈហែហមហើយ ទ្រង់ប្រាសចាកទោសៈដែលភិក្ខុប្រាសចាកទោសៈហែហមហើយ ទ្រង់ប្រាសចាកមោហៈ ដែលភិក្ខុប្រាសចាកមោហៈហែហមហើយ ទ្រង់មិនមានតណ្ហា ដែលភិក្ខុមិនមានតណ្ហាហែហមហើយ ទ្រង់មិនមានកិលេស ដែលពួកភិក្ខុមិនមានកិលេសហែហមហើយ ជាអ្នកត្រាស់ដឹងឯង ដែលភិក្ខុអ្នកត្រាស់ដឹង ព្រោះជាពហុស្សូតហែហមហើយ និងដូចកេសរសីហរាជ ដែលហ្វូងម្រឹគហែហមហើយ ដូចផ្កាកណិការដែលកេសរហ៊ុមព័ទ្ធ ដូចស្តេចដំរីឈ្មោះឆទ្ទន្ត ដែលហ្វូងដំរី ៨០០០ហែហមហើយ ដូចស្តេចហង្សឈ្មោះធតរដ្ឋ ដែលហ្វូងហង្ស ៩ ម៉ឺនហែហមហើយ ដូចស្តេចចក្រពត្តិដែលសេនាង្គនិករហែហមហើយ ដូចសក្កទេវរាជដែលពួកទេវតាហែហមហើយ ដូចហារិតមហាព្រហ្ម ដែលពួកព្រហ្មហែហម

ហើយ ដូចព្រះចន្ទពេញវង់ ដែលហ្វូងតារាហែហមហើយ ទ្រង់យាងទៅកាន់ក្រុងកបិលពស្តុដោយភេទរបស់ព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ដោយរស្មីដ៏រុងរឿងរបស់ព្រះពុទ្ធ ដែលមិនមានប្រមាណ ដោយប្រការដូច្នេះ ។

គ្រានោះ ព្រះរស្មីដែលមានពណ៌ដូចមាស ផ្សាយចេញអំពីព្រះកាយខាងមុខរបស់ព្រះមានព្រះភាគនោះ ប្រមាណ ៨០ ហត្ថ ។ ព្រះរស្មីមានពណ៌ដូចមាសផ្សាយចេញអំពីព្រះកាយខាងក្រោយ ខាងស្តាំ ខាងឆ្វេង ក៏មានប្រមាណ ៨០ ហត្ថ ព្រះរស្មីដែលមានពណ៌ដូចអង្កាំកន្ទុយក្ងោក ផ្សាយចេញអំពីព្រះកេសាទាំងអស់ តាំងអំពីចុងព្រះកេសាខាងលើ ទៅក្នុងអាកាស ៨០ ហត្ថ ក្នុងផ្ទៃនៃអម្ពរ ព្រះរស្មីដែលមានពណ៌ដូចកែវប្រពាល ផ្សាយចេញអំពីផ្ទៃព្រះបាទទៅខាងក្រោម ៨០ ហត្ថ ក្នុងកម្រាស់នៃផែនដី ព្រះពុទ្ធរស្មីមានពណ៌ ៦ រុងរឿងផ្សាយទៅ ៨០ ហត្ថដោយជុំវិញ ដូចពន្លឺភ្លើងដែលផ្សាយចេញអំពីប្រទីប ឡើងទៅកាន់អាកាស ដូចផ្លេកបន្ទោរដែលដាលចេញអំពីមហាពពកទាំង ៤ ទិស ដោយប្រការដូច្នេះ ។

ព្រះពុទ្ធរស្មីផ្សាយទៅកាន់គ្រប់ចំណែកនៃទិស ប្រៀបដូចដេរដាសដោយផ្កាចម្ប៉ាមាស ប្រៀបដូចស្រោចដោយខ្សែទឹកមាសដែលចេញអំពីឆ្នាំងមាស ប្រៀបដូចព័ទ្ធទុកដោយដំបាមាស ដែលធ្វើល្អហើយ ប្រៀបដូចដេរដាសដោយលម្អងផ្កាចារ និងផ្កាកណិការដែលខ្យល់វេរម្ភាញ៉ាំងឲ្យកើតឡើង ។

ព្រះសរីរៈរបស់ព្រះមានព្រះភាគ ក៏រុងរឿងដោយវរលក្ខណៈ ៣២ ប្រដាប់ដោយអនុព្យញ្ជនៈ ៨០ និងរស្មីមួយព្យាម ល្អបីដូចផ្ទៃនភាកាស ដែល

មានដួងតារាព្រោងព្រាត បីដូចគុម្ពបទុមដែលរីកហើយ បីដូចបារិច្ឆត្តកព្រឹក្ស កម្ពស់ ១០០ យោជន៍ មានផ្ការីកស្គុសស្គាយ បីដូចយកសិរីគ្រប់សង្កត់សិរី របស់ព្រះចន្ទ ៣២ ព្រះអាទិត្យ ៣២ ស្តេចចក្រពត្តិ ៣២ អង្គ ស្តេចទេវតា ៣២ អង្គ មហាព្រហ្ម ៣២ អង្គ ដែលស្ថិតនៅតាមលំដាប់ ដូចទានដែល ទ្រង់ថ្វាយ សីលដែលទ្រង់រក្សា កល្យាណកម្មដែលទ្រង់ធ្វើ អស់ ៤ អសង្ខេយ្យ កម្រៃមួយសែនកប្ប ប្រដាប់ដោយទសបារមី ទសឧបបារមី រួមនឹងបរមត្ថបារមី ដែលទ្រង់បំពេញហើយដោយល្អ ក៏មកប្រជុំចុះក្នុងអត្ត-ភាពមួយ មិនបានឋានៈដែលនឹងឲ្យវិបាក ហាក់ដូចជាធ្លាក់ទៅក្នុងទីចង្អៀត ហាក់ដូចវេលាលើកទ្រព្យអំពីទូកមួយពាន់ដាក់ចូលក្នុងទូកមួយ ហាក់ដូចជា លើកទ្រព្យអំពីរទេះមួយពាន់ដាក់ក្នុងរទេះមួយ ហាក់បីដូចយកស្ទឹង ២៥ មក បញ្ចូលគ្នាជាស្ទឹងតែមួយ ត្រង់ទ្វាររួម គឺប្រជុំផ្លូវនៃឱឃៈ មនុស្សទាំងឡាយ លើកប្រទីបមានជងច្រើនពាន់ ដាក់ខាងមុខនៃព្រះមានព្រះភាគ ដែលកំពុង បញ្ចេញឱភាសដោយពុទ្ធសិរីនេះ ៗ ខាងក្រោយ ខាងឆ្វេង ខាងស្តាំ ក៏យ៉ាង នោះដូចគ្នា ភ្ញៀងទាំងឡាយដែលជ្រុះចាកពពកទាំង ៤ ទិស ផ្កាម្លិះរួត ផ្កា ចម្ប៉ា ផ្កាម្លិះលា ផ្កាឧប្បលក្រហម ឧប្បលស កំញាន និងជវសន្ទវារៈ មួយអន្ទើដោយផ្កាឈើដែលមានពណ៌ខៀវ ពណ៌លឿងជាដើម មានក្លិន ក្រអូប និងល្អិត ក៏រោយទៅ ដូចលម្អងទឹក សំឡេងរងំរបស់តន្ត្រីមានអង្គ ៥ និងសំឡេងនៃតន្ត្រីដែលប្រកបដោយគុណរបស់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ក៏តាមទៅគ្រប់ទិស កែវភ្នែករបស់ពួកទេវតា មនុស្ស នាគ គ្រុឌ គន្ធព្វ

យក្សជាដើមបានឃើញ ដូចផឹកទឹកអម្រឹត តែទោះនៅក្នុងឋានៈដែលពោលពណ៌នាការដែលទ្រង់ព្រះពុទ្ធដំណើរដោយស្លោក ១០០០ បទក៏គួរ ក្នុងសេចក្តីនេះ នឹងពោលល្មមបានជាគន្លង ដូច្នេះថា

ព្រះលោកនាយក បរិបូណ៌ដោយព្រះសព៌ាង្គយ៉ាងនេះ ទ្រង់ធ្វើមហាប្រឹថពីឲ្យញាប់ញ័រ ទ្រង់មិនបៀតបៀនសត្វ យាងទៅ ព្រះនរាសភៈដ៏ឧត្តមជាងសត្វជើង ២ លើកព្រះបាទស្តាំ ឈានជាដំបូង ទ្រង់ព្រះពុទ្ធដំណើរ ក៏សម្បូរដោយសិរីរុងរឿង កាលព្រះពុទ្ធដ៏ប្រសើរឧត្តម ស្តេចព្រះពុទ្ធដំណើរបាតជើងដ៏ទន់ប៉ះនឹងផែនដីដ៏រាប ក៏មិនប្រឡាក់ដោយល្អងធូលី កាលព្រះលោកនាយក ទ្រង់ព្រះពុទ្ធដំណើរត្រង់ដីដែលទាប ដីក៏ផុសឡើង ត្រង់ដីដែលទួល ដីក៏រាបស្មើ ផែនដីថ្ម ក្រួស អំបែង និងបន្លាគ្រប់យ៉ាង មិនមានចិត្ត ក៏ចៀសចេញអំពីផ្លូវថ្វាយ កាលព្រះលោកនាយក ទ្រង់ព្រះពុទ្ធដំណើរក៏មិនចាំបាច់លើកព្រះបាទឈានវែងក្នុងទីឆ្ងាយ មិនចាំបាច់លើកព្រះបាទឈានខ្លីក្នុងទីជិត ទ្រង់មិនចង្អៀតព្រះហឫទ័យយាងទៅ ព្រះមុនីដ៏មានចរណៈបរិបូណ៌ក៏មិនលើព្រះជានុទាំង ២ និងកព្រះបាទយាងទៅរហ័សពេកណាស់ ។ ព្រះតាទិ កាលទ្រង់ព្រះពុទ្ធដំណើរ ក៏មិនចាំបាច់យាងទៅយឺតពេក ព្រះអង្គទ្រង់មិនបានសម្លឹងមើលខាងលើ ខាងក្រោម ខាងទទឹង ទិសធំ ទិសតូចយ៉ាងនោះ យាងទៅ ទ្រង់ទតត្រឹមតែមួយជួរនឹម ព្រះជិនស្រីអង្គនោះ ទ្រង់មានអាចារគួរសរសើរ ដូចស្តេចដំរីដ៏រុងរឿង ក្នុងអាការទ្រង់ព្រះពុទ្ធដំណើរ ព្រះអគ្គលោក ទ្រង់ព្រះពុទ្ធដំណើរល្អពន់ពេក ទ្រង់ញុំាងមនុស្សលោក ព្រមទាំង

ទេវលោកឲ្យត្រេកអរ ដូចឧសភរាជ ដូចកេសរសីហៈដែលត្រាច់ទៅទាំង ៤ ទិស ទ្រង់ញ៉ាំងសត្វជាអនន្តឲ្យត្រេកអរ ទ្រង់យាងដល់បុរីដ៏ប្រសើរ ដូច្នេះ ។

បានឮថា វេលានេះ ជាវេលានៃវណ្ណនា ។ កម្រាំងប៉ុណ្ណេះជាគោលសម្គាល់សម្រាប់ព្រះធម្មកថិក ក្នុងកិច្ចពណ៌នាព្រះសរីរៈ ឬពណ៌នាព្រះគុណរបស់ព្រះពុទ្ធក្នុងកាលទាំងឡាយយ៉ាងនេះ ។ ហើយនៅអាចពណ៌នាដោយកម្រងកែវ ឬដោយកម្រងកាព្យបានប៉ុនណា ក៏គួរពោលប៉ុណ្ណោះ មិនគួរពោលថា ពោលលំបាក ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ មានព្រះគុណមិនមានប្រមាណ សូម្បីតែព្រះពុទ្ធដូចគ្នា ក៏មិនអាចពណ៌នាគុណរបស់ព្រះពុទ្ធទាំងនោះ ដោយមិនឲ្យសេសសល់បាន នឹងពោលថ្វីដល់ពួកសត្វក្រៅអំពីនេះ ។ ព្រះមានព្រះភាគ ទ្រង់ចូលកាន់ព្រះបូរីនៃសក្យរាជ ដែលប្រដាប់តាក់តែង ដោយសិរីវិលាសយ៉ាងនេះ ដែលជនមានចិត្តជ្រះថ្លា បូជាដោយគ្រឿងក្រអូប ផ្សែងក្រអូប និងលម្អិតជាដើម ទ្រង់យាងចូលកាន់សណ្ឋាគារ ព្រោះហេតុនោះ ទើបលោកពោលថា **អថ ខោ ភគវា និវាសេត្វា បត្តចីវរំ អាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន នវំ សណ្ឋាគារំ តេនុបសង្កមិ** ដូច្នេះ ។ បទថា **ភគវន្តំ យេវ បុរក្ខត្វា** សេចក្តីថា ធ្វើព្រះមានព្រះភាគទុកខាងមុខក្នុងសណ្ឋាគារនោះ ព្រះមានព្រះភាគប្រថាប់គង់ត្រង់កណ្តាលនៃភិក្ខុ និងពួកឧបាសក ទ្រង់រុងរោចន៍យ៉ាងក្រៃលែង ដូចបដិមាដែលធ្វើដោយមាស ដែលបុគ្គលប្រោះព្រំដោយទឹកក្រអូប ជូតសម្អាតដោយសំពត់ទុកូលពស្ត្រ រហូតស្ងួតហើយ លាបដោយលោហជាតិពណ៌ក្រហម តម្កល់លើតាំង ដែលគ្រប

ដោយសំពត់កម្ពលពណ៌ក្រហម ដូច្នោះ គន្ធនៃពណ៌នាគុណនៃបុរាណាចារ្យទាំងឡាយ ក្នុងសេចក្ដីនេះ មានដូច្នេះថា

ព្រះអគ្គបុគ្គលនៃលោក ទ្រង់មានចរណៈ គួរសរសើរ ដូចស្ដេចដំរីយាងទៅកាន់រោងមណ្ឌល បញ្ចេញព្រះរស្មី ប្រថាប់គង់លើពុទ្ធាសនៈ ដ៏ប្រសើរ ទ្រង់ជាសារថី ទូន្មានបុគ្គលដែលគួរទូន្មាន ជាទេវទេព មានព្រះ-បុញ្ញលក្ខណៈ ១០០ ប្រថាប់គង់ក្នុងទីនោះ ត្រង់កណ្ដាលពុទ្ធាសនៈ ទ្រង់ដូចជាដុំមាសដែលបុគ្គលដាក់ទុកលើសំពត់កម្ពលលឿង ដូច្នោះ ។

ព្រះវិតមលោ ទ្រង់រុងរឿង ដូចដុំនៃមាសជម្ពូនុទ ដែលគេដាក់ទុកលើសំពត់កម្ពលពណ៌លឿង ដូចកែវមណីដែលបញ្ចេញពន្លឺ ដូច្នោះ ទ្រង់រុងរឿងដូចដើមមហាសាលព្រឹក្ស បញ្ចេញនូវផ្ការីកស្គុសស្គាយ ដែលជាគ្រឿងប្រដាប់របស់ស្ដេចភ្នំសិនេរុ ដូច្នោះ ទ្រង់មានព្រះរស្មីដូចប្រាសាទមាស ដូចផ្កាបទុមកោកនុទ ដូចប្រទីបចែងចាំងពន្លឺ ដូចគំនរភ្លើងលើកំពូលភ្នំ ដូចបារិច្ឆត្តរបស់ស្ដេចទេវតា ដែលមានផ្ការីកស្គុសស្គាយ ដូច្នោះ ។

បកិណ្ណកកថា ដែលប្រកបដោយការអនុមោទនា ឆ្លងសណ្ឋាគារ គប្បីជ្រាបថា ឈ្មោះធម្មីកថា ក្នុងទីនេះថា **កាបិលវត្ថវេ សក្យេ ពហុទេវ រត្តឹ ធម្មិយា កថាយ** ។ ពិតហើយ ព្រះមានព្រះភាគ ត្រាស់បកិណ្ណកថាដែលនាំប្រយោជន៍មកឲ្យពួកស្ដេចសក្យៈ ក្រុងកបិលពស្ដុ ដូចទ្រង់ញ៉ាំងពួកស្ដេចសក្យៈឲ្យឆ្លងអាកាសគង្គា ដូចទ្រង់ផ្ដិតឱជៈនៃបឋវីមកឲ្យ ដូចទ្រង់ចាប់ដើមព្រីងធំអង្រួន ដូចទ្រង់បោសផ្ចិតឃ្មុំ ទំហំមួយយោជន៍ ដោយចក្កយន្ត ឲ្យពួក

ស្តេចសក្យៈ ផឹកទឹកឃ្មុំដូច្នោះថា មហាបពិត្រ ការថ្វាយលំនៅជាទានធំ លំនៅរបស់ពួកអ្នក តថាគតក៏ប្រើប្រាស់ហើយ ភិក្ខុសង្ឃក៏ប្រើប្រាស់ហើយ លំនៅដែលតថាគត និងភិក្ខុសង្ឃប្រើប្រាស់ហើយ ក៏ឈ្មោះថា ធម្មរតនៈប្រើប្រាស់ហើយដូចគ្នា ព្រោះដូច្នោះ ទើបឈ្មោះថា ព្រះរតនៈទាំង ៣ ប្រើប្រាស់ហើយ កាលពួកអ្នកថ្វាយអាវាសទានហើយ ទានទាំងពួង ក៏ឈ្មោះថា ពួកអ្នកថ្វាយហើយដូចគ្នា ធម្មតាអានិសង្សនៃបណ្ណសាលា ដែលតាំងនៅលើផែនដីក្តី មណ្ឌបដែលតាំងនៅលើមែកឈើក្តី បុគ្គលណាមួយ ក៏មិនអាចកំណត់បាន កាលត្រាស់ធម្មកថាដ៏ច្រើន មានន័យវិចិត្រច្រើនប្រការហើយ ក៏ត្រាស់ព្រះគាថា វិហារទានគាថា ដូច្នេះថា

( វិហារ គឺទីអាវាស ឬសេនាសនៈជាទីនៅនៃសង្ឃទាំងឡាយ ) រមែងការពាររងាផង ក្តៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូច និងពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំង-ឡាយផង ខ្យល់ និងកម្តៅថ្ងៃដ៏ក្លាខ្លាំងដែលកើតឡើងហើយ រមែងបាត់ទៅវិញ ព្រោះវិហារនោះៗ ។ វិហារទាន គឺការឲ្យលំនៅ ( ដែលបុគ្គលបានឲ្យហើយ ) ដល់សង្ឃដើម្បីជាទីជ្រកកោនផង ដើម្បីនៅជាសុខផង ដើម្បីដុតបាបធម៌ផង ដើម្បីចម្រើនវិបស្សនាផង ព្រះពុទ្ធទាំងឡាយតែងសរសើរ ថាជាទានដ៏ប្រសើរ ។ ព្រោះហេតុនោះឯង បុរស ( ស្ត្រី ) ជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ក៏គួរសាងព្រះវិហារ គឺអាវាសឬសេនាសនៈទាំងឡាយដ៏ជាទីគួររីករាយ ហើយគួរនិមន្តលោក ដែលជា

ពហុស្សុត គឺលោកអ្នកចេះដឹងច្រើនទាំងឡាយឲ្យនៅក្នុងទីនោះ ។ គួរមានចិត្តជ្រះថ្លាចំពោះលោកទាំងឡាយដែលមានចិត្តត្រង់ហើយប្រគេនបាយ ទឹក សំពត់ និងសេនាសនៈទាំងឡាយដល់លោកទាំងនោះចុះ ។ លោកទាំងនោះ រមែងសម្ដែងធម៌ជាគ្រឿងបន្ទោបង់ ឲ្យឃ្លាតចាកទុក្ខគ្រប់ប្រការដល់អ្នកនោះ លុះអ្នកនោះបានដឹងធម៌ណា ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ។

អានិសង្សក្នុងអាវាសទាននេះ ក៏មានដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគត្រាស់អានិសង្សរកថា ក្នុងអាវាសទានអស់រាត្រីជាច្រើន គឺ លើស ២ យាមកន្លះ ។ ក្នុងព្រះបាលីនោះ គាថាទាំងនេះប៉ុណ្ណោះ លោកលើកឡើងកាន់សង្គីតិ ឯបកិណ្ណកធម្មទេសនា មិនឡើងកាន់សង្គីតិឡើយ ។ បទថា **សន្ទស្សេសិ** ជាដើម មានអត្ថដូចពោលហើយនោះឯង ។ បទថា **អាយស្មន្តំ អានន្ទំ អាមន្តេសិ** សេចក្ដីថា ព្រះមានព្រះភាគ មានព្រះពុទ្ធបំណង នឹងឲ្យព្រះអានន្ទពោលធម្មកថា ទើបប្រាប់ឲ្យជ្រាប ។ សួរថា កាលព្រះមហាថេរៈដែលជាព្រះអសីតិមហាសាវក ដូចជាព្រះសារីបុត្រ ព្រះមហាមោគ្គល្លាន និងព្រះមហាកស្សបជាដើមក៏មាន ហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ប្រគល់ភារៈឲ្យព្រះអានន្ទទៅវិញ ឆ្លើយថា ព្រោះអំណាចអធ្យាស្រ័យរបស់បរិស័ទពិតហើយ ព្រះអានន្ទ មានឈ្មោះបោះសំឡេង ប្រាកដទៅក្នុងចំណែកស្ដេចសក្យៈថា ជាកំពូលនៃពួកភិក្ខុដែលជាពហុស្សុត អាចពោលធម្មកថាបានពីរោះ ដោយបទព្យញ្ជនៈដ៏ក្រអួនក្រអៅ ពួកស្ដេចសក្យៈសូម្បីយាងទៅព្រះ

វិហារ ក៏ធ្លាប់ស្តាប់ធម្មកថារបស់លោក ឯស្តេចសក្យៈទាំងនោះមិនបាន ឱកាសទៅកាន់វិហារបានតាមការពេញចិត្ត ទើបសក្យរាជទាំងនោះត្រិះរិះតែ ក្នុងចិត្តថា គួរតែព្រះមានព្រះភាគត្រាស់ធម្មកថា តែបន្តិចបន្តួច ហើយទ្រង់ ប្រគល់ភារៈឲ្យព្រះអានន្ទ ដែលជាព្រះញាតិដ៏ប្រសើររបស់យើង ។ ព្រោះ អំណាចអធ្យាស្រ័យនៃស្តេចសក្យៈទាំងនោះ ទើបព្រះមានព្រះភាគ ទ្រង់ ប្រគល់ភារៈឲ្យព្រះអានន្ទនោះតែមួយអង្គឯង ។ បទថា **សេក្ខោ បដិបន្នោ** បានដល់ ជាសេក្ខសមណៈដែលបដិបត្តិ ព្រះមានព្រះភាគអង្គនោះត្រាស់ថា សេក្ខប្បដិបទាចូរជាក់ច្បាស់ប្រាកដដល់អ្នក អ្នកចូរសម្តែងសេក្ខប្បដិបទា-សមណៈនោះ ទ្រង់កំណត់បុគ្គលសម្តែងដោយបដិបទា ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់កំណត់បដិបទានេះ ឆ្លើយថា ព្រោះហេតុច្រើនយ៉ាង ។

ជាបឋម សក្យរាជទាំងនេះ ប្រាថ្នាមង្គល ប្រាថ្នាសេចក្តីចម្រើនដល់ មង្គលសាលា ម្យ៉ាងទៀត សេក្ខប្បដិបទានេះ ជាមង្គលប្បដិបទា ជាបដិបទា របស់បុគ្គលចម្រើននៅក្នុងព្រះសាសនារបស់តថាគត ព្រោះហេតុនេះ ទើប ទ្រង់កំណត់បដិបទានេះ ម្យ៉ាងទៀត ព្រះសេក្ខបុគ្គលជាច្រើនអង្គុយនៅក្នុង បរិស័ទរបស់ព្រះអង្គ កាលព្រះអង្គត្រាស់ឋានៈដែលទ្រង់ចាក់ធ្លុះដោយព្រះអង្គ ឯងហើយ ព្រះសេក្ខបុគ្គលទាំងនោះ នឹងកំណត់បានដោយមិនលំបាកឡើយ ព្រោះហេតុនេះ ទើបទ្រង់កំណត់បដិបទានេះ ម្យ៉ាងទៀត ព្រះអានន្ទក៏សម្រេច សេក្ខប្បដិសម្ភិទា លោកពោលក្នុងឋានៈដែលប្រចក្ស ដែលលោកចាក់ធ្លុះ

ហើយដោយខ្លួនឯង ក៏មិនលំបាក នឹងអាចធ្វើអ្នកដទៃឲ្យយល់បាន ព្រោះហេតុនេះ ទើបទ្រង់កំណត់បដិបទានេះ ម្យ៉ាងទៀត សិក្ខាទាំង ៣ ក៏សង្គ្រោះចូលក្នុងសេក្ខប្បដិបទា ហើយក្នុងសិក្ខាទាំង ៣ នោះ កាលលោកពោលអធិសីលសិក្ខា វិនយបិដកទាំងអស់ ក៏ឈ្មោះថា លោកបានពោលហើយ កាលពោលអធិចិត្តសិក្ខា សុត្តន្តបិដកទាំងអស់ ក៏ឈ្មោះថា លោកបានពោលហើយ កាលពោលអធិប្បញ្ញាសិក្ខា អភិធម្មបិដកទាំងអស់ ក៏ឈ្មោះថា លោកបានពោលហើយ ។ ម្យ៉ាងទៀត ព្រះអានន្ទជាពហូសូត ទ្រទ្រង់ព្រះត្រៃបិដក លោកអាចនឹងពោលសិក្ខាទាំង ៣ ដោយបិដកទាំង ៣ បាន កាលលោកពោលយ៉ាងនេះ មង្គល និងសេចក្តីចម្រើនតែម្យ៉ាង នឹងមានដល់ស្តេចសក្យៈ ព្រោះហេតុនេះ ទើបទ្រង់កំណត់បដិបទានេះ ។

សួរថា ក្នុងព្រះបាលី ព្រះមានព្រះភាគពោលថា តថាគតរួយខ្នងណាស់ ហេតុអ្វី ទើបខ្នងមិនសប្បាយ ឆ្លើយថា ព្រោះកាលទ្រង់បំពេញព្យាយាម ៦ ឆ្នាំ ទុក្ខតាមផ្លូវព្រះវរកាយ ក៏មានច្រើន ខាងក្រោយមក កាលទ្រង់ព្រះជរា ខ្យល់ក្នុងខ្នងកើតដល់ព្រះអង្គ ។ បានឮថា សេចក្តីនោះមិនទាន់ជាហេតុ ព្រោះព្រះមានព្រះភាគនោះ ទ្រង់អាចដើម្បីនឹងសង្កត់វេទនាដែលកើតឡើង ប្រថាប់គង់ដោយឥរិយាបថមួយ បានដល់ ១ សប្តាហ៍ខ្លះ ២ សប្តាហ៍ខ្លះ តែមានព្រះពុទ្ធបំណងប្រើប្រាស់សណ្ឋាគារសាលា ដោយឥរិយាបថទាំង ៤ ទើបទ្រង់ពុទ្ធដំណើរ តាំងអំពីជម្រះព្រះហស្ត និងព្រះបាទ រហូតប្រថាប់គង់លើអាសនៈសម្តែងធម៌ ទ្រង់ព្រះពុទ្ធដំណើរក្នុងទីដូច្នេះ ដល់អាសនៈសម្តែងធម៌

រឿយៗ ប្រឋាប់ឈរ ហើយប្រឋាប់គន់ ប្រឋាប់គន់លើអាសនៈ សម្ដែងធម៌ អស់ ២ យាមកន្លះ ក្នុងទីដូច្នេះ សម្រេចការប្រឋាប់គន់ក្នុងទីដូច្នេះ ឥឡូវនេះ កាលទ្រង់ផ្ទំដោយបង្អៀងស្ដាំ ក៏សម្រេចការផ្ទំ ព្រះមានព្រះភាគ មានព្រះ បំណងនឹងប្រើដោយឥរិយាបថ ៤ ដូចពោលមក ដោយប្រការដូច្នេះ មិនគួរ ពោលថា ធម្មតាសរីរៈដែលមានវិញ្ញាណគ្រប់គ្រងរបស់តថាគត មិនសប្បាយ ដូច្នេះ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទ្រង់កាន់យកការមិនសប្បាយតិចតួច ដែលកើតអំពីការប្រឋាប់គន់យូរ ទើបត្រាស់យ៉ាងនេះ ។ បទថា **សង្ឃាដឹ បញ្ញាបេត្វា** សេចក្ដីថា ពួកសក្យៈទាំងនោះឲ្យបាំងវាំងននសំពត់នៅត្រង់ ចំណែកម្ខាងនៃសណ្ឋាគារ ឲ្យរៀបចំគ្រែដែលសមគួរ ហើយក្រាលដោយ កម្រាលដែលសមគួរ ហើយចងពិតាន ប្រដាប់ដោយផ្កាយមាស កម្រងផ្កា ក្រអូបខាងលើ ដុតប្រទីបប្រេងក្រអូប ដោយទ្រង់ត្រិះរិះថា ធ្វើម្ដេចហ្ន៎ ព្រះ សាស្ដានឹងទ្រង់ក្រោកឡើងចាកធម្មាសនៈ ហើយសម្រាកបន្ដិចហ្ន៎ និងទ្រង់ផ្ទំ ក្នុងទីនេះ កាលបើដូច្នេះ សណ្ឋាគារនេះឈ្មោះថា ព្រះសាស្ដាទ្រង់ប្រើប្រាស់ ហើយដោយឥរិយាបថ ៤ ក៏នឹងជាប្រយោជន៍សុខដល់ពួកយើងអស់កាល យូរ ។ សូម្បីព្រះសាស្ដាក៏ទ្រង់ជ្រាបអធ្យាស្រ័យនោះឯង ទើបទ្រង់ក្រាល សង្ឃាដី ផ្ទំក្នុងទីនោះ ។ បទថា **ឧដ្ឋានសញ្ញំ មនសិករិត្វា** សេចក្ដីថា ទ្រង់ តាំងឧដ្ឋានសញ្ញាក្នុងចិត្តថា កន្លងវេលាប៉ុណ្ណោះ តថាគតនឹងក្រោកឡើង ។

[ ២៦ ] បទថា **មហានាមំ សក្កំ អាមន្តេសិ** សេចក្ដីថា ក្នុងវេលា នោះ ព្រះបាទមហានាមសក្យៈ ជាប្រធានក្នុងបរិស័ទនោះ កាលព្រះអានន្ទ

សង្គ្រោះព្រះបាទមហានាមនោះហើយ ក៏ឈ្មោះថា សង្គ្រោះបរិស័ទដែលសល់ផងដែរ ព្រោះហេតុនោះ ទើបព្រះថេរៈហៅចំពោះ មហានាមសក្យៈនោះតែមួយអង្គ ។ បទថា **សីលសម្បន្នោ** ប្រែថា ដល់ព្រមដោយសីល ។ អធិប្បាយថា មានសីលសម្បូរ មានសីលបរិបូណ៌ ។ បទថា **សទ្ធម្មេហិ** ប្រែថា ដោយធម៌ដ៏ល្អ ឬដោយធម៌របស់មនុស្សល្អ គឺ សប្បុរស ។

[ ២៧ ] ដោយបទថា **កថំ ច មហានាម** នេះ ព្រះថេរៈបំណងនឹងតាំងមាតិកានៃសេក្ខប្បដិបទា ដោយឋានៈទាំងនេះ ហើយអធិប្បាយឲ្យពិស្តារដោយលំដាប់ ទើបពោលយ៉ាងនេះ ។ បទថា **សីលសម្បន្នោ** ជាដើម ដោយព្រះបាលីនោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលបានត្រាស់ហើយ ក្នុងអាកង្ខេយ្យសូត្រជាដើមថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាអ្នកមានសីលបរិបូណ៌ ដូច្នេះ ។

[ ៣១ ] ក្នុងបទថា **កាយទុច្ចរិតេន** ជាដើម ជាតតិយាវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ អធិប្បាយថា ខ្មាស ខ្ពើមនូវកាយទុច្ចរិតជាដើមដែលគួរខ្មាស ។ បទថា **កាយទុច្ចរិតេន** ជាតតិយាវិភត្តិ ចុះក្នុងអត្ថហេតុ ក្នុងនិទ្ទេសនៃឱត្តប្បៈ អធិប្បាយថា ខ្លាចអំពីកាយទុច្ចរិតជាដើម ដែលជាហេតុនៃឱត្តប្បៈ ។ បទថា **អារទ្ធវីរិយោ** គឺជាអ្នកមានសេចក្តីព្យាយាមដែលផ្គងមានចិត្តមិនរួញរា ។ បទថា **បហានាយ** គឺដើម្បីប្រយោជន៍ដល់ការលះ ។ បទថា **ឧបសម្បទាយ** គឺដើម្បីប្រយោជន៍ដល់ការត្រឡប់បាន ។ បទថា **ថាមវា** គឺជាអ្នកប្រកបដោយកម្លាំង គឺសេចក្តីព្យាយាម ។

បទថា **ឧឡារបរក្កមោ** គឺ ឈានទៅខាងមុខយ៉ាងមាំទាំ ។ បទថា **អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ** សេចក្តីថា មានធុរៈមិនដាក់ចុះ មានសេចក្តីព្យាយាម មិនធូរថយក្នុងកុសលធម៌ ។ បទថា **បរមេន** គឺ ឧត្តម ។ បទថា **សតិនេបក្កេន** គឺដោយសតិ និងភាពជាអ្នកមានបញ្ញារក្សាខ្លួន ។

សួរថា ព្រោះហេតុអ្វី ទើបបញ្ញាមកក្នុងបទភាជនីយរបស់សតិ ឆ្លើយថា ដើម្បីសម្តែងភាពដែលសតិមានកម្លាំង ។ ពិតហើយ សតិដែលប្រាសចាកបញ្ញា រមែងខ្សោយកម្លាំង សតិដែលប្រកបដោយបញ្ញា រមែងមានកម្លាំង ។ បទថា **ចិរកតំបិ** សេចក្តីថា ការបំពេញបដិបទា គឺមហាវត្ត ៨០ មានចេតិយង្គណវត្តជាដើម ដែលខ្លួនឯង និងអ្នកដទៃធ្វើដោយកាយមក អស់កាលដ៏យូរ ។ បទថា **ចិរភាសិតំបិ** សេចក្តីថា ពាក្យដែលខ្លួនឯង ឬអ្នកដទៃពោលដោយវាចាមក អស់កាលដ៏យូរ បានដល់ កថាដែលពោលដោយការឧទ្ទិសឯង ការឲ្យអ្នកដទៃឧទ្ទិស ការប្រជុំធម៌ ការសម្តែងធម៌ និងការស្តាប់ស្ទួន់ដោយការគោរព គឺវចីកម្មដែលប្រព្រឹត្តទៅដោយអំណាចវាចាដែលគួរអនុមោទនាជាដើម ។ បទថា **សរិតា អនុស្សរិតា** សេចក្តីថា កាលកាយកម្មនោះ ដែលធ្វើមកយូរដោយកាយ ឈ្មោះថា កាយជាកាយវិញ្ញត្តិ កាលវចីកម្មពោលមកយូរ ឈ្មោះថា វាចាជាវចីវិញ្ញត្តិ ទាំង ២ យ៉ាងនោះជារូប ចិត្ត និងចេតសិកដែលញ៉ាំងរូបនោះឲ្យតាំងឡើងជារូប រមែងរឭក និងតាមរឭកថា រូបធម៌ និងអរូបធម៌ទាំងនេះ កើតឡើងយ៉ាងនេះ រលត់ទៅយ៉ាងនេះ ដោយប្រការដូច្នេះ អធិប្បាយថា ញ៉ាំងសតិសម្ពោជ្ឈង្គឲ្យតាំង

ឡើង ពិតហើយ ក្នុងទីនេះ លោកបំណងយកសតិដែលញ៉ាំងពោជ្ឈង្គឲ្យតាំងឡើងដោយសតិនោះ អរិយសាវកនោះ គប្បីជ្រាបថា ឈ្មោះថា **សរិតា** ព្រោះរឭកបានម្តង ឈ្មោះថា **អនុស្សរិតា** ព្រោះរឭកបានរឿយៗ ។

បទថា **ឧទយត្ថគាមិយា** សេចក្តីថា ដល់នូវការកើត និងការវិនាស គឺអាចដើម្បីដឹងច្បាស់នូវការកើត និងការវិនាសនៃខន្ធទាំង ៥ ។ បទថា **អរិយាយ** សេចក្តីថា បរិសុទ្ធ ព្រោះតាំងនៅឆ្ងាយអំពីកិលេសទាំងឡាយ ដោយសង្កត់សង្កិន និងដោយកាត់បានជាសមុច្ឆេទ ។ បទថា **បញ្ញាយ សមន្នាគតោ** គឺជាអ្នកដល់ព្រមដោយវិបស្សនាបញ្ញា និងមគ្គបញ្ញា ។ ក្នុងបទថា **និព្វេធិកាយ** សេចក្តីថា វិបស្សនាបញ្ញា និងមគ្គបញ្ញានោះឯង លោកហៅថា **និព្វេធិកា** ព្រោះជាគ្រឿងចាក់ធ្លុះ អធិប្បាយថា ប្រកបដោយនិព្វេធិកបញ្ញានោះ ។ បណ្តាវិបស្សនាបញ្ញា និងមគ្គបញ្ញាទាំង ២ នោះ មគ្គបញ្ញា ឈ្មោះថា **និព្វេធិកា** ព្រោះអត្ថវិគ្គហៈថា ចោះទម្លុះ គឺទម្លាយគំនរលោភៈ គំនរទោសៈ គំនរមោហៈ ដែលមិនធ្លាប់ចោះទម្លុះ ដែលមិនធ្លាប់ទម្លាយចេញបាន ដោយកាត់ផ្តាច់បាន វិបស្សនាបញ្ញា ឈ្មោះថា **និព្វេធិកា** ព្រោះអត្ថវិគ្គហៈថា ចោះទម្លុះទម្លាយគំនរលោភៈជាដើមបាន ដោយចោះទម្លុះទម្លាយបាន មួយជួរខណៈ និងព្រោះប្រព្រឹត្តទៅ ដើម្បីបានមកនូវមគ្គបញ្ញា ដែលជាគ្រឿងចោះទម្លុះ ព្រោះដូច្នោះ វិបស្សនាបញ្ញា ទោះហៅថា **និព្វេធិកា** ក៏គួរ មគ្គបញ្ញាធ្វើសេចក្តីទុក្ខក្នុងវដ្តៈឲ្យអស់ទៅដោយប្រពៃ គឺដោយហេតុ ដោយន័យ ព្រោះហេតុនោះ ទើបឈ្មោះថា ជាបដិបទាឲ្យដល់

នូវការអស់ទៅនៃទុក្ខដោយប្រពៃ សូម្បីក្នុងបទថា **សម្មាទុក្ខក្ខយគាមិនិយា** វិបស្សនាក៏ធ្វើសេចក្ដីទុក្ខក្នុងវដ្ដៈ និងទុក្ខព្រោះកិលេសឲ្យអស់ទៅ ដោយអំណាចតទង្គប្បហាន ព្រោះហេតុនោះ ទើបឈ្មោះថា ជាបដិបទាឲ្យដល់នូវការអស់ទៅនៃទុក្ខ ម្យ៉ាងទៀត វិបស្សនា ក៏គប្បីជ្រាបថា ជាបដិបទាឲ្យដល់នូវការអស់ទៅនៃទុក្ខ ព្រោះប្រព្រឹត្តទៅដើម្បីបាននូវមគ្គប្បញ្ញា ដែលជាបដិបទា ឲ្យដល់នូវការអស់ទៅនៃទុក្ខ ។

[ ៣២ ] បទថា **អាភិចេតសិកានំ** សេចក្ដីថា ដែលអាស្រ័យចិត្តដ៏ក្រៃលែង ចិត្តដ៏ប្រសើរ ។ បទថា **ទិដ្ឋធម្មសុខវិហារានំ** សេចក្ដីថា ជាហេតុឲ្យបានមក នូវសេចក្ដីសុខក្នុងខណៈដែលឆ្អែតស្កប់ស្កល់ ។ បទថា **និកាមលាភី** សេចក្ដីថា ចូលសមាបត្តិក្នុងខណៈដែលត្រូវការ ។ បទថា **អកិច្ឆលាភី** គឺ បានមិនលំបាក ។ បទថា **អកសិរលាភី** គឺ បានដោយបរិបូណ៌ ។ ព្រះអរិយសាវកមួយរូប អាចចូលសមាបត្តិបានក្នុងខណៈដែលត្រូវការ ព្រោះជាអ្នកស្ទាត់ជំនាញ មួយរូបទៀតមិនលំបាក តែមិនអាចសង្កត់ធម៌ដែលជាអន្តរាយនៃសមាធិបាន លោកក៏ចេញអំពីសមាបត្តិទៅមួយរំពេច ព្រោះខ្លួនមិនប្រាថ្នា មិនអាចតាំងសមាបត្តិបាន ដោយកាលតាមដែលកំណត់ អរិយសាវកនេះ ឈ្មោះថា **កិច្ឆលាភី** គឺបានដោយលំបាកផង និង **កសិរ-លាភី** គឺបានដោយក្រផង ឯអរិយសាវកមួយរូបទៀត អាចចូលសមាបត្តិបានក្នុងខណៈដែលត្រូវការ ទាំងមិនលំបាកក្នុងធម៌ដែលមានសមាធិបរិសុទ្ធ ក៏សង្កត់ចិត្តបាន លោកអាចចេញចាកសមាបត្តិ ដោយកាលតាមដែលកំណត់

បាននអរិយសាវកនេះ ឈ្មោះថា **អភិច្ចលាភី** ផង **អកសិរលាភី** ផង ។

[ ៣៣ ] ដោយបទថា **អយំ វុច្ចតិ មហានាម អរិយសាវកោ សេក្ខោ ចាដិបទោ** នេះ ព្រះថេរៈសម្តែងថា មហាបពិត្រ អរិយសាវកដែលបដិបត្តិសេក្ខប្បដិបទា លោកហៅថា ជាអ្នកប្រកបដោយបដិបទាដែលប្រព្រឹត្តទៅដើម្បីបន្ទុបនៃវិបស្សនា ។ បទថា **អបុច្ចណ្ណតាយ** គឺព្រោះភាពជាសម្បកពងមិនខូច ។ បទថា **ភព្វោ អភិនិព្ភិទាយ** គឺគួរដើម្បីចោះចេញដោយអំណាចឈាន ។ បទថា **សម្ពោធាយ** គឺដើម្បីអរិយមគ្គ ។ ដោយបទថា **អនុត្តរស្ស យោគក្ខេមស្ស** នេះ ព្រះថេរៈសម្តែងថា អរហត្តឈ្មោះថា ជាធម៌ក្សេមចាកយោគៈដ៏កំពូល ជាបុគ្គលគួរដើម្បីសម្រេចធម៌នោះ ឧបមាដែលលោកនាំមកដើម្បីសម្តែងអត្ថក្នុងព្រះសូត្រនេះ បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលក្នុងចេតោខិលសូត្រនោះឯង ការប្រៀបធៀបឧបមាយ៉ាងណា មកក្នុងចេតោខិលសូត្រនោះ ដូចជាការព្យាយាមក្រៃលែងរបស់ភិក្ខុនេះ គឺភាពដែលភិក្ខុនេះជាអ្នកប្រកបដោយអង្គ ១៥ នោះ ក៏ដូចការធ្វើកិរិយា ៣ យ៉ាង ក្នុងសម្បកពងនៃមេមាន់ ដូច្នោះ ការប្រៀបធៀបឧបមានោះ បណ្ឌិតគប្បីប្រកបយ៉ាងនេះថា ការដែលភិក្ខុនេះ ព្រមព្រៀងដោយធម៌ ១៥ មានភាពជាអ្នកដល់ព្រមដោយសីលជាដើម ក៏ដូចការធ្វើកិរិយា ៣ យ៉ាង ក្នុងសម្បកពងរបស់មេមាន់នោះ ហើយគប្បីជ្រាបដូចគ្នា ព្រោះព្រះបាលីថា ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកដល់ព្រមដោយសីលយ៉ាងនេះជាដើម ពាក្យដ៏សេស ក៏ដូចគ្នានឹងពាក្យដែលលោកពោលក្នុងទីទាំងពួងនោះឯង ។ បទថា

**ឥមំយេវ អនុត្តរំ ឧបេក្ខា សតិចារិសុទ្ធឹ** សេចក្តីថា ដែលជាចតុត្ថជ្ឈានដ៏ឧត្តម មិនដូចគ្នានឹងបឋមជ្ឈានជាដើមនេះ ។ បទថា **បឋមាអភិនិព្ភិទា** គឺការទម្លាយដោយឈានដំបូង សូម្បីក្នុងគ្រាទី ២ ជាដើម ក៏ន័យនេះដូចគ្នា ឯកូនមាន់កើត ២ ដង គឺអំពីពោះមេម្តង ចេញអំពីសម្បកម្តង អរិយសាវកកើត ៣ ដង ដោយវិជ្ជា ៣ គឺបន្ទោបង់នូវងងឹតដែលបិទបាំងខន្ធ ដែលធ្លាប់អាស្រ័យក្នុងកាលមុន កើតលើកទី ១ ដោយបុព្វេនិវាសញ្ញាណ បន្ទោបង់នូវងងឹត ដែលបិទបាំងចុតិបដិសន្ធិរបស់សត្វទាំងឡាយ ហើយកើតលើកទី ២ ដោយទិព្វចក្ខុញ្ញាណ បន្ទោបង់ងងឹតដែលបិទបាំងសច្ចៈទាំង ៤ ហើយកើតលើកទី ៣ ដោយអាសវក្ខយញ្ញាណ ។

[ ៣៤ ] បទថា **ឥទំ បេស្ស ហោតិ ចរណាស្មឹ** សេចក្តីថា នេះក៏រមែងឈ្មោះថា ចរណៈនៃភិក្ខុអ្នកមានសីល ឈ្មោះថា ចរណៈមានច្រើន មិនមែនមានតែមួយ បានដល់ ធម៌ ១៥ មានសីលជាដើម អធិប្បាយថា ធម៌ ១៥ នោះ មានសីលនេះជាចរណៈមួយដែរ តែដោយអត្ថចំពោះ បុគ្គលណាត្រាច់គឺទៅកាន់ទិសដែលមិនធ្លាប់ទៅ ដោយគុណជាតិនេះ ហេតុនោះ គុណជាតិនោះ ឈ្មោះថា ចរណៈ គឺ គ្រឿងត្រាច់ទៅ ។ ក្នុងទីគ្រប់អន្លើ ក៏មានន័យនេះ ។ បទថា **ឥទំ បេស្ស ហោតិ វិជ្ជាយ** សេចក្តីថា បុព្វេនិវាសញ្ញាណនេះ ឈ្មោះថា វិជ្ជារបស់ភិក្ខុនោះ ។ ឈ្មោះថា វិជ្ជា មានច្រើន មិនមែនមានតែមួយ បានដល់ ញាណ ៨ មានវិបស្សនាញាណជាដើម អធិប្បាយថា ក្នុងញាណ ៨ នោះ សូម្បីញាណនេះ ក៏ឈ្មោះថា វិជ្ជាមួយដែរ តែ

ដោយអត្ថចំពោះ បុគ្គលណាដឹងច្បាស់ ចាក់ធ្លុះដោយគុណជាតិនេះ ហេតុនោះ គុណជាតិនេះ ឈ្មោះថា **វិជ្ជា ។** បទថា **វិជ្ជាសម្បន្នោ ឥតិបិ** សេចក្តីថា ដល់ព្រមដោយវិជ្ជា ៣ ហៅថា អ្នកបរិបូណ៌ដោយវិជ្ជាដូច្នេះក៏មាន ។ បទថា **ចរណសម្បន្នោ ឥតិបិ** សេចក្តីថា ដល់ព្រមដោយធម៌ ១៥ ហៅថា បរិបូណ៌ដោយចរណៈដូច្នេះក៏មាន ។ បទថា **វិជ្ជាចរណសម្បន្នោ ឥតិបិ** សេចក្តីថា ឯបុគ្គលដល់ព្រមទាំង ២ យ៉ាងនោះ ហៅថា ជាអ្នកបរិបូណ៌ដោយវិជ្ជា និងចរណៈដូច្នេះក៏មាន ។ បទថា **សនង្កុមារេន** គឺក្មេងបុរាណដែលឈ្មោះថា សនង្កុមារតាំងអំពីបុរាណ កាលនោះ បានឮថា ក្នុងទឹកដីមនុស្ស សនង្កុមារនោះ ធ្វើឈានឲ្យកើតតាំងអំពីនៅជាកុមារ ទុកដុក ៥ ឈានក៏មិនវិនាស ទៅកើតក្នុងព្រហ្មលោក អត្តភាពរបស់ព្រហ្មនោះ គួរស្រឡាញ់ គួរពេញចិត្ត ព្រោះដូច្នោះ ទើបព្រហ្មនោះត្រាច់ទៅដោយអត្តភាពដូច្នោះ ដោយហេតុនោះ ទើបមនុស្សទាំងឡាយ ឲ្យសម្មតិនាមព្រហ្មនោះថា សនង្កុមារ ។ បទថា **ជនេតស្មឹ** គឺក្នុងប្រជុំជន អធិប្បាយថា ក្នុងពួកប្រជាជន ។ បទថា **យេ គោត្តបដិសារិនោ** សេចក្តីថា ជនពួកណាបានកាន់យកគោត្រក្នុងជនពួកនោះថា អញជាគោតម អញជាកស្សប ក្នុងពួកបុគ្គលដែលប្រកាន់រឿងគោត្រនោះ ក្សត្រជាបុគ្គលប្រសើរបំផុតក្នុងលោក ។

[ ៣៥ ] បទថា **អនុមតា ភគវតា** សេចក្តីថា គាថានេះ តថាគតប្រៀបធៀបសម្តែងព្រមដោយបញ្ហាព្យាកររបស់តថាគត ។ ក្នុងអម្ពដ្ឋសូត្រ ព្រះមានព្រះភាគ កាលត្រាស់ថា ម្នាលអម្ពដ្ឋ: សូម្បីតថាគត ក៏ពោលយ៉ាង

នេះថា

ក្សត្រិជាមនុស្សប្រសើរបំផុត ក្នុងប្រជុំជនដែលពោលអាងគោត្រ បុគ្គលដែលបរិបូណ៌ដោយវិជ្ជា និងចរណៈ ជាមនុស្សប្រសើរបំផុត ក្នុងពួកទេវតានិងមនុស្ស ។

ព្រះសាស្តាទ្រង់អនុមតិ គឺទ្រង់អនុមោទនា ( ភាសិតរបស់ព្រះអានន្ទ ) យ៉ាងនេះ ។ តាមគាថានេះ បទថា **សាធុ សាធុ អានន្ទ** សេចក្តីថា បានឮថា ព្រះមានព្រះភាគ ទ្រង់មិនចូលកាន់និទ្រាតាំងអំពីដើម ទ្រង់ស្តាប់សូត្រនេះ ទ្រង់ជ្រាបថា អានន្ទនឹងទាញយកកំពូលសេក្ខប្បដិបទា ទើបទ្រង់ក្រោកឡើងប្រថាប់គង់ពត់ភ្នែន បានប្រទានសាធុការទទួលដូច្នោះ សូត្រនេះ ដោយព្រះវាចាមានប្រមាណប៉ុណ្ណោះ ទើបក្លាយទៅជាភាសិតរបស់ព្រះជិនស្រី ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើងាយយល់ទាំងអស់ហើយ ៕

**សេក្ខសូត្រ ចប់**

**សូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ចោតលិយសូត្រទី ៤

[ ៣៦ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអាបណនិគមរបស់ពួកអង្គុត្តរាបជនបទ ក្នុងអង្គុត្តរាបជនបទ ។ ក្នុងកាលនោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់ដោយបាត្រ និងចីវរ ហើយទ្រង់ចូលទៅកាន់អាបណនិគម ដើម្បីបិណ្ឌបាតក្នុងវេលាបុព្វណ្ហសម័យ ។ លុះទ្រង់ពុទ្ធដំណើរទៅដើម្បីបិណ្ឌបាត ក្នុងអាបណនិគម ហើយត្រឡប់អំពីបិណ្ឌបាតក្នុងវេលាបច្ឆាភត្ត ហើយទ្រង់យាងសំដៅទៅរកដងព្រៃមួយ លុះយាងទៅដល់ហើយ ក៏ទ្រង់ចូលទៅកាន់ដងព្រៃនោះ ដើម្បីសម្រាកព្រះអង្គក្នុងវេលាថ្ងៃ ទ្រង់គង់សម្រាកព្រះអង្គ ក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយ ។ ទើបបោតលិយគហបតីស្លៀកដណ្តប់សំពត់សមគួរ ប្រដាប់ឆត្រ និងស្បែកជើង ដើរត្រាច់ទៅរឿយៗ ដើម្បីសម្រួលស្មុង ហើយដើរសំដៅទៅដងព្រៃនោះ លុះដើរទៅដល់ហើយ ក៏ចូលទៅកាន់ដងព្រៃនោះ ហើយចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏ឋិតនៅក្នុងទីសមគួរ ។

[ ៣៧ ] លុះបោតលិយគហបតីឋិតនៅក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកាដូច្នេះថា ម្នាលគហបតី អាសនៈមានគ្រប់គ្រាន់ បើអ្នកត្រូវការ ចូរអង្គុយចុះ ។ កាលបើព្រះមានព្រះភាគទ្រង់មានព្រះ

ពុទ្ធដីកាយ៉ាងនេះហើយ ពោតលិយគហបតី ក៏នៅស្ងៀមដោយខឹងអន់ចិត្តថា ព្រះសមណគោតមហៅអញ ដោយពាក្យថា គហបតី ។ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងពោតលិយគហបតី ជាគម្រប់ពីរដងទៀតដូច្នេះថា ម្នាលគហបតី អាសនៈមានគ្រប់គ្រាន់ បើអ្នកត្រូវការ ចូរអង្គុយចុះ ។ ពោតលិយគហបតី ក៏នៅស្ងៀមជាគម្រប់ពីរដង ដោយខឹងអន់ចិត្តថា ព្រះសមណគោតមហៅអញ ដោយពាក្យថា គហបតី ។ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងពោតលិយគហបតីជាគម្រប់បីដងទៀតដូច្នេះថា ម្នាលគហបតី អាសនៈមានគ្រប់គ្រាន់ បើអ្នកត្រូវការ ចូរអង្គុយចុះ ។ កាលបើព្រះមានព្រះភាគទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ពោតលិយគហបតីក៏ខឹងអន់ចិត្តថា ព្រះសមណគោតមហៅអញ ដោយពាក្យថា គហបតី ហើយក៏ពោលពាក្យដូច្នេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គហៅខ្ញុំដោយពាក្យថា គហបតីណា ពាក្យនុ៎ះ មិនសមគួរឡើយ ពាក្យនុ៎ះ មិនសុភាពឡើយ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតី អាការ ភេទ និងនិមិត្តរបស់អ្នកនៅប្រាកដជារបស់គហបតីនៅឡើយទេតើ ។ ពោតលិយគហបតីតបថា បពិត្រព្រះគោតមដ៏ចម្រើន ដូច្នោះមែនហើយ តែថា ការងារគ្រប់ចំពូក ខ្ញុំព្រះអង្គឈប់ លែងធ្វើហើយ ជំនួញទាំងអស់ ខ្ញុំព្រះអង្គកាត់ចោលហើយ ។ ព្រះមានព្រះភាគទ្រង់សួរថា ម្នាលគហបតី ការងារគ្រប់ចំពូកដែលអ្នកឈប់លែងធ្វើហើយ ជំនួញទាំងអស់ដែលអ្នកកាត់ចោលហើយ តើដូចម្តេច ។ បពិត្រព្រះគោតមដ៏ចម្រើន មតិកណា គឺទ្រព្យសម្បត្តិ ស្រូវ អង្ករ ឬប្រាក់

មាស ដែលមានក្នុងលោកនេះ មតិកទាំងអស់នោះ ខ្ញុំព្រះអង្គប្រគល់ឲ្យកូនអស់ហើយ ខ្ញុំព្រះអង្គលែងទូន្មានជាស់តឿន លែងឃាត់ខាំងក្នុងការងារទាំងនោះហើយ នៅមានតែគ្រឿងស៊ី និងគ្រឿងស្លៀកដណ្តប់ប៉ុណ្ណោះ បពិត្រព្រះគោតមដ៏ចម្រើន ការងារគ្រប់ចំពូក ខ្ញុំព្រះអង្គឈប់លែងធ្វើហើយ ជំនួញទាំងអស់ ខ្ញុំព្រះអង្គកាត់ចោលហើយយ៉ាងនេះឯង ។ ម្នាលគហបតី អ្នកពោលផ្តាច់បង់ជំនួញដោយចំណែកផ្សេង ការផ្តាច់បង់ជំនួញក្នុងវិន័យរបស់ព្រះអរិយៈដោយចំណែកផ្សេង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការផ្តាច់បង់ជំនួញក្នុងវិន័យរបស់ព្រះអរិយៈ តើដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ការផ្តាច់បង់ជំនួញក្នុងវិន័យរបស់ព្រះអរិយៈ យ៉ាងណា សូមព្រះមានព្រះភាគទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គ យ៉ាងនោះឲ្យទាន ។ ម្នាលគហបតី បើដូច្នោះអ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។

បោតលិយគហបតីទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ៣៨ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី ធម៌ ៨ ប្រការនេះឯង រមែងប្រព្រឹត្តទៅដើម្បីផ្តាច់បង់ជំនួញ ក្នុងវិន័យរបស់ព្រះអរិយៈ ធម៌ ៨ ប្រការ តើដូចម្តេច បុគ្គលព្រោះអាស្រ័យនូវការមិនសម្លាប់សត្វ ទើបលះបង់នូវការសម្លាប់សត្វចេញបាន ព្រោះអាស្រ័យនូវការកាន់យកតែទ្រព្យដែលគេឲ្យ ទើបលះបង់នូវការកាន់យកទ្រព្យដែលគេមិនឲ្យចេញបាន ព្រោះអាស្រ័យនូវសច្ចវាចា ទើបលះបង់នូវមុសាវាទចេញបាន ព្រោះអាស្រ័យនូវ

ពាក្យមិនញុះញង់ ទើបលះបង់នូវពាក្យញុះញង់ចេញបាន ព្រោះអាស្រ័យនូវសេចក្តីមិនលោភលន់ ទើបលះបង់នូវសេចក្តីលោភលន់ចេញបាន ព្រោះអាស្រ័យនូវសេចក្តីមិនគ្នាន់ក្នាញ់គឺមិននិន្ទា ទើបលះបង់នូវសេចក្តីគ្នាន់ក្នាញ់គឺនិន្ទាចេញបាន ព្រោះអាស្រ័យនូវសេចក្តីមិនចង្អៀតចង្អល់ចិត្តគឺមិនក្រោធ ទើបលះបង់នូវសេចក្តីចង្អៀតចង្អល់ចិត្តគឺសេចក្តីក្រោធចេញបាន ព្រោះអាស្រ័យនូវសេចក្តីមិនមើលងាយគេ ទើបលះបង់នូវសេចក្តីមើលងាយគេចេញបាន ម្នាលគហបតី ធម៌ទាំង ៨ ប្រការនេះឯង តថាគតពោលហើយ ដោយបង្រួញ មិនទាន់ចែកដោយពិស្តារ រមែងប្រព្រឹត្តទៅដើម្បីផ្តាច់បង់ជំនួញ ក្នុងវិន័យរបស់ព្រះអរិយៈ ។ បពិត្រព្រះអង្គដ៏ចម្រើន ក៏ធម៌ទាំង ៨ ប្រការណាដែលព្រះមានព្រះភាគសម្តែងហើយ ដោយបង្រួញ មិនទាន់ចែកដោយពិស្តារ រមែងប្រព្រឹត្តទៅដើម្បីផ្តាច់បង់ជំនួញ ក្នុងវិន័យរបស់ព្រះអរិយៈ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគអាស្រ័យសេចក្តីអនុគ្រោះ ចែកនូវធម៌ ៨ ប្រការនេះ ដោយពិស្តារ ដល់ខ្ញុំព្រះអង្គឲ្យទាន ។ ម្នាលគហបតី បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែងឲ្យស្តាប់ ។ បោតលិយគហបតី ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ៣៩ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ត្រង់ពាក្យថា បុគ្គលព្រោះអាស្រ័យនូវការមិនសម្លាប់សត្វ ទើបលះបង់នូវការសម្លាប់សត្វចេញបាន ដូច្នេះនេះ តថាគតបានពោលហើយ ដោយប្រការដូច្នេះ ក៏ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី ព្រះអរិយ-

សាវកក្នុងសាសនានេះ តែងពិចារណាដូច្នេះថា អាត្មាអញជាអ្នកសម្លាប់សត្វ ព្រោះហេតុសំយោជនៈទាំងឡាយណា អាត្មាអញបានប្រតិបត្តិ ដើម្បីលះបង់ ដើម្បីផ្តាច់បង់សំយោជនៈទាំងនោះចេញហើយ មួយវិញទៀត បើអាត្មាអញជាអ្នកសម្លាប់សត្វហើយ សូម្បីខ្លួនឯងក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុសម្លាប់សត្វ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយៗ ក៏គប្បីតិះដៀលបាន ព្រោះហេតុតែសម្លាប់សត្វ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុសម្លាប់សត្វ ធម្មជាតនេះ ឈ្មោះថាសំយោជនៈ ធម្មជាតនេះ ឈ្មោះថានីវរណៈ គឺការសម្លាប់សត្វហ្នឹងឯង ម្យ៉ាងទៀត អាសវៈទាំងឡាយណា មានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុតែការសម្លាប់សត្វ អាសវៈដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះដែលវៀរចាកការសម្លាប់សត្វយ៉ាងនេះ ពាក្យណា ដែលតថាគតពោលហើយថា ព្រោះអាស្រ័យនូវការមិនសម្លាប់សត្វ ទើបលះបង់នូវការសម្លាប់សត្វចេញបាន ដូច្នេះ ពាក្យនេះ តថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

[ ៤០ ] ត្រង់ពាក្យថា បុគ្គលព្រោះអាស្រ័យនូវការកាន់យកតែទ្រព្យដែលគេឲ្យ ទើបលះបង់នូវការកាន់យកទ្រព្យដែលគេមិនឲ្យ ដូច្នេះនេះ តថាគតបានពោលហើយ ដោយប្រការដូច្នេះ ក៏ពាក្យនេះដែលតថាគតពោលហើយព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ តែងពិចារណាដូច្នេះថា អាត្មាអញកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ព្រោះហេតុ

សំយោជនៈណា អាត្មាអញបានប្រតិបត្តិ ដើម្បីលះបង់ ដើម្បីផ្តាច់បង់នូវសំយោជនៈនុ៎ះ ចេញហើយ មួយវិញទៀត បើអាត្មាអញជាអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យហើយ សូម្បីខ្លួនឯង គប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយៗហើយ ក៏គប្បីតិះដៀលបាន ព្រោះហេតុតែកាន់យកទ្រព្យដែលគេមិនបានឲ្យ លុះទម្លាយរាងកាយខាងមុខអំពីមរណៈទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុតែកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ធម្មជាតនេះ ឈ្មោះថា សំយោជនៈ ធម្មជាតនេះ ឈ្មោះថានីវរណៈ គឺការកាន់យកទ្រព្យដែលគេមិនបានឲ្យហ្នឹងឯងមួយយ៉ាងទៀត អាសវៈទាំងឡាយណា មានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុកាន់យកទ្រព្យដែលគេមិនបានឲ្យ អាសវៈដែលមានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលវៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យយ៉ាងនេះ ពាក្យណា ដែលតថាគតពោលហើយថា បុគ្គលគួរអាស្រ័យការកាន់យកតែទ្រព្យដែលគេឲ្យ ទើបលះបង់ការកាន់យកទ្រព្យ ដែលគេមិនបានឲ្យចេញ ដូច្នេះពាក្យនេះ តថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

[ ៤១ ] ត្រង់ពាក្យថា បុគ្គលគួរអាស្រ័យពាក្យពិត ទើបលះបង់ការកុហកចេញដូច្នេះនេះ តថាគតបានពោលហើយ ដោយប្រការដូច្នេះ ក៏ពាក្យនេះឯង ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតីអរិយសាវកក្នុងសាសនានេះ តែងពិចារណាដូច្នេះថា អាត្មាអញពោលពាក្យ

កុហក ព្រោះហេតុសំយោជនៈទាំងឡាយណា អាត្មាអញបានប្រតិបត្តិដើម្បីលះបង់ ដើម្បីផ្តាច់បង់សំយោជនៈទាំងនោះចេញហើយ មួយវិញទៀត បើអាត្មាអញ ជាអ្នកពោលពាក្យកុហកហើយ សូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុពោលពាក្យកុហក ទាំងអ្នកប្រាជ្ញ ដែលបានពិចារណារឿយៗ ហើយ ក៏គប្បីតិះដៀលបាន ព្រោះហេតុ ពោលពាក្យកុហក លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីមរណៈទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុ ពោលពាក្យកុហក ធម្មជាតនុ៎ះហៅថា សំយោជនៈ ធម្មជាតនុ៎ះ ហៅថានីវរណៈ គឺពាក្យកុហកហ្នឹងឯង មួយយ៉ាងទៀត អាសវៈទាំងឡាយណា មានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុ ពោលពាក្យកុហក អាសវៈដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលវៀរចាកពាក្យកុហកយ៉ាងនេះ ពាក្យណាដែលតថាគតពោលហើយថា បុគ្គលព្រោះអាស្រ័យពាក្យពិត ទើបលះបង់ការពោលពាក្យកុហកចេញ ដូច្នេះ ពាក្យនេះ តថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

[ ៤២ ] ត្រង់ពាក្យថា ព្រោះអាស្រ័យពាក្យមិនញុះញង់ ទើបលះបង់ពាក្យញុះញង់ចេញ ដូច្នេះនេះ តថាគតបានពោលហើយ ដោយប្រការដូច្នេះ ក៏ពាក្យនេះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ តែងពិចារណាដូច្នេះថា អាត្មាអញជាអ្នកមានពាក្យញុះញង់ ព្រោះហេតុសំយោជនៈទាំងឡាយណា អាត្មាអញបានប្រតិបត្តិ

ដើម្បីលះបង់ ដើម្បីផ្ដាច់បង់នូវសំយោជនៈទាំងនោះចេញហើយ ម្យ៉ាងទៀត បើអាត្មាអញនិយាយពាក្យញុះញង់ហើយ សូម្បីខ្លួនឯងក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុ ពាក្យញុះញង់ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយៗហើយ ក៏គប្បីតិះដៀលបាន ព្រោះហេតុ ពាក្យញុះញង់ លុះទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុ ពាក្យញុះញង់ ធម្មជាតនុ៎ះ ហៅថា សំយោជនៈ ធម្មជាតនុ៎ះ ហៅថា នីវរណៈ គឺ ពាក្យញុះញង់ហ្នឹងឯង ម្យ៉ាងទៀត អាសវៈទាំងឡាយណា មានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុ ពាក្យញុះញង់ អាសវៈដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលវៀរចាកពាក្យញុះញង់យ៉ាងនេះ ពាក្យណា ដែលតថាគតពោលហើយថា ព្រោះអាស្រ័យពាក្យមិនញុះញង់ ទើបលះបង់ពាក្យញុះញង់ចេញដូច្នេះ ពាក្យនេះ តថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនោះឯង ។

[ ៤៣ ] ត្រង់ពាក្យថា ព្រោះអាស្រ័យសេចក្ដីមិនលោភលន់ ទើបលះបង់សេចក្ដីលោភលន់ចេញដូច្នេះនេះ តថាគតបានពោលហើយ ដោយប្រការដូច្នេះ ក៏ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ រមែងពិចារណាដូច្នេះថា អាត្មាអញជាអ្នកមានសេចក្ដីលោភលន់ ព្រោះសំយោជនៈទាំងឡាយណា អាត្មាអញបានប្រតិបត្តិដើម្បីលះបង់ ដើម្បីផ្ដាច់បង់នូវសំយោជនៈនោះចេញហើយ ម្យ៉ាងទៀត បើអាត្មាអញជាអ្នកមានសេចក្ដីលោភលន់ហើយ សូម្បីខ្លួនឯងក៏គប្បី

តិះដៀលខ្លួនឯងបាន ព្រោះហេតុ សេចក្តីលោភលន់ ទាំងអ្នកប្រាជ្ញដែលបាន ពិចារណារឿយៗ ហើយ ក៏គប្បីតិះដៀលបាន ព្រោះហេតុ សេចក្តីលោភលន់ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុ សេចក្តីលោភលន់ ធម្មជាតនុ៎ះ ហៅថា សំយោជនៈ ធម្មជាតនុ៎ះ ហៅថានីវរណៈ គឺសេចក្តីលោភលន់ហ្នឹងឯង ម្យ៉ាងទៀត អាសវៈទាំងឡាយ ណា ដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយគប្បីកើតឡើង ព្រោះ ហេតុ សេចក្តីលោភលន់ អាសវៈដែលមានសភាពចង្អៀតចង្អល់ ក្រហល់ ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលមិនមានសេចក្តីលោភលន់ បានយ៉ាងនេះ ពាក្យណាដែលតថាគតពោលហើយថា ព្រោះអាស្រ័យសេចក្តី មិនលោភលន់ ទើបលះសេចក្តីលោភលន់ចេញដូច្នេះ ពាក្យនេះ តថាគតបាន ពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

[ ៤៤ ] ត្រង់ពាក្យថា ព្រោះអាស្រ័យសេចក្តីមិនគ្នាន់ក្នាញ់ គឺមិននិន្ទា ទើបលះបង់សេចក្តីគ្នាន់ក្នាញ់ គឺនិន្ទាចេញដូច្នេះនេះ តថាគតបានពោលហើយ ដោយប្រការដូច្នេះ ក៏ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យ ហេតុអ្វី ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ រមែងពិចារណាដូច្នេះថា អាត្មាអញជាអ្នកមានសេចក្តីគ្នាន់ក្នាញ់គឺនិន្ទា ព្រោះហេតុសំយោជនៈទាំងឡាយ ណា អាត្មាអញបានប្រតិបត្តិដើម្បីលះបង់ ដើម្បីផ្តាច់បង់នូវសំយោជនៈទាំង នោះចេញហើយ ម្យ៉ាងទៀត បើអាត្មាអញជាអ្នកមានសេចក្តីគ្នាន់ក្នាញ់ គឺ និន្ទាហើយ សូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុសេចក្តី

គ្មានក្នាញ់ គឺនិន្ទា ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយៗ ហើយ ក៏គប្បីតិះដៀលបាន ព្រោះហេតុសេចក្ដីគ្មានក្នាញ់ គឺនិន្ទា លុះទម្លាយរាងកាយ ខាងមុខ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុ សេចក្ដីគ្មានក្នាញ់ គឺ និន្ទា ធម្មជាតនុ៎ះ ហៅថា សំយោជនៈ ធម្មជាតនុ៎ះ ហៅថា នីវរណៈ គឺសេចក្ដីគ្មានក្នាញ់ គឺនិន្ទាហ្នឹងឯង ម្យ៉ាងទៀត អាសវៈទាំងឡាយណា ដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុ សេចក្ដីគ្មានក្នាញ់ គឺនិន្ទា អាសវៈដែលមានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលជាអ្នកមិនមានសេចក្ដីគ្មានក្នាញ់ គឺមិននិន្ទាយ៉ាងនេះ ពាក្យណា ដែលតថាគតពោលហើយថា ព្រោះអាស្រ័យសេចក្ដីមិនគ្មានក្នាញ់ គឺមិននិន្ទា ទើបលះបង់សេចក្ដីគ្មានក្នាញ់ គឺនិន្ទាចេញដូច្នេះ ពាក្យនេះ តថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

[ ៤៥ ] ត្រង់ពាក្យថា ព្រោះអាស្រ័យនូវសេចក្ដីមិនចង្អៀតចង្អល់ គឺមិនក្រោធ ទើបលះបង់សេចក្ដីចង្អៀតចង្អល់ គឺសេចក្ដីក្រោធចេញ ដូច្នេះនេះ តថាគតពោលហើយដោយប្រការដូច្នេះ ក៏ពាក្យនេះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ រមែងពិចារណាដូច្នេះថា អាត្មាអញជាអ្នកមានសេចក្ដីចង្អៀតចង្អល់គឺសេចក្ដីក្រោធ ព្រោះហេតុសំយោជនៈទាំងឡាយណា អាត្មាអញបានប្រតិបត្តិ ដើម្បីលះបង់ ដើម្បីផ្ដាច់បង់សំយោជនៈទាំងនោះចេញហើយ ម្យ៉ាងទៀត បើអាត្មាអញជា

អ្នកមានសេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធហើយ សូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះសេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយៗ ហើយ ក៏គប្បីតិះដៀលបាន ព្រោះសេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុ សេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធ ធម្មជាតនុ៎ះ ហៅថា សំយោជនៈ ធម្មជាតនុ៎ះ ហៅថា នីវរណៈ គឺសេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធហ្នឹងឯង ម្យ៉ាងទៀត អាសវៈទាំងឡាយណា ដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុសេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធ អាសវៈដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធយ៉ាងនេះ ពាក្យណា ដែលតថាគតពោលហើយថា ព្រោះអាស្រ័យនូវសេចក្តីមិនចង្អៀតចង្អល់ គឺសេចក្តីមិនក្រោធ ហើយលះបង់សេចក្តីចង្អៀតចង្អល់ គឺសេចក្តីក្រោធចេញដូច្នេះ ពាក្យនេះ តថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។

[ ៤៦ ] ត្រង់ពាក្យថា ព្រោះអាស្រ័យនូវសេចក្តីមិនមើលងាយគេ ទើបលះបង់សេចក្តីមើលងាយដូច្នេះនេះ តថាគតបានពោលហើយដោយប្រការដូច្នេះ ក៏ពាក្យនេះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុអ្វី ម្នាលគហបតី អរិយសាវកក្នុងសាសនានេះ រមែងពិចារណាដូច្នេះថា អាត្មាអញជាអ្នកមានសេចក្តីមើលងាយគេ ព្រោះហេតុសំយោជនៈទាំងឡាយណា អាត្មា

អញបានប្រតិបត្តិដើម្បីលះបង់ ដើម្បីផ្តាច់បង់សំយោជនៈទាំងនោះចេញហើយ ម្យ៉ាងទៀត បើអាត្មាអញជាអ្នកមានសេចក្តីមើលងាយគេហើយ សូម្បីខ្លួនឯងក៏គប្បីតិះដៀលខ្លួនឯងបាន ព្រោះហេតុសេចក្តីមើលងាយ ទាំងអ្នកប្រាជ្ញដែលបានពិចារណារឿយៗ ហើយ គប្បីតិះដៀលបាន ព្រោះហេតុសេចក្តីមើលងាយគេ លុះទម្លាយរាងកាយ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទុគ្គតិនឹងមានប្រាកដ ព្រោះហេតុសេចក្តីមើលងាយ ធម្មជាតនុ៎ះ ហៅថា សំយោជនៈ ធម្មជាតនុ៎ះ ហៅថានីវរណៈ គឺសេចក្តីមើលងាយហ្នឹងឯង ម្យ៉ាងទៀត អាសវៈទាំងឡាយណា ដែលមានសភាពចង្អៀតចង្អល់ ក្រហល់ក្រហាយ គប្បីកើតឡើង ព្រោះហេតុសេចក្តីមើលងាយគេ អាសវៈដែលមានសភាពចង្អៀតចង្អល់ក្រហល់ក្រហាយទាំងនោះ មិនមានដល់បុគ្គលនោះ ដែលជាអ្នកមិនមានសេចក្តីមើលងាយ យ៉ាងនេះ ពាក្យណា ដែលតថាគតពោលហើយថា ព្រោះអាស្រ័យនូវសេចក្តីមិនមើលងាយគេ ទើបលះបង់សេចក្តីមើលងាយគេចេញ ដូច្នេះ ពាក្យនេះ តថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនុ៎ះឯង ។ ម្នាលគហបតី ធម៌ទាំង ៨ ណា តែងប្រព្រឹត្តទៅដើម្បីលះបង់ ដើម្បីផ្តាច់បង់ជំនួញ ក្នុងអរិយវិន័យ ធម៌ទាំង ៨ នេះឯង តថាគតពោលហើយ ដោយបង្រួញ មិនបានចែកដោយពិស្តារទេ ម្នាលគហបតី ការផ្តាច់បង់ជំនួញសព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យ មិនមានត្រឹមប៉ុណ្ណោះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការផ្តាច់បង់ជំនួញសព្វគ្រប់ដោយប្រការទាំងពួង ក្នុងអរិយវិន័យនោះ តើដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ការផ្តាច់បង់ជំនួញ

សព្វគ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យយ៉ាងណា សូមព្រះមានព្រះភាគទ្រង់សម្តែងធម៌យ៉ាងនោះ ដល់ខ្ញុំព្រះអង្គឲ្យទាន ។ ម្នាលគហបតី បើដូច្នោះ អ្នកចូរស្តាប់ ចូរយកចិត្តទុកដាក់ដោយប្រពៃចុះ តថាគតនឹងសម្តែងឲ្យស្តាប់ ។ បោតលិយគហបតី ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ៤៧ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី ដូចសុនខដែលអស់កម្លាំង ព្រោះសេចក្តីឃ្លានគ្របសង្កត់ ក៏ដើរចូលទៅកាន់ទីសម្រាប់អារសាច់លក់របស់គោឃាតកៈ ឯគោឃាតកៈក្តី កូនឈ្នួលរបស់គោឃាតកៈក្តី ដែលឈ្លាស យករាងឆ្អឹងដែលពន្លះសាច់ចេញស្អាត ឥតមានសាច់ គ្រាន់តែប្រឡាក់ដោយឈាម បោះទៅឲ្យឆ្កែនោះ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះថា ដូចម្តេច ឆ្កែនោះកាលអង្អៀមនូវរាងឆ្អឹងឯណោះ ដែលគេពន្លះសាច់ចេញស្អាត ឥតមានសាច់ គ្រាន់តែប្រឡាក់ដោយឈាម នឹងបន្ទោបង់សេចក្តីអស់កម្លាំង ព្រោះការឃ្លានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ការបន្ទោបង់នូវសេចក្តីអស់កម្លាំង ព្រោះការឃ្លាននុ៎ះ មិនបានទេ ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថារាងឆ្អឹងឯណោះ ដែលគេពន្លះសាច់ចេញស្អាត ឥតមានសាច់ គ្រាន់តែប្រឡាក់ដោយឈាម ឯសុនខនោះ ជាសត្វគ្រាន់តែមានចំណែកនៃសេចក្តីលំបាកកាយលំបាកចិត្ត ប៉ុណ្ណោះឯង ។ ម្នាលគហបតី អរិយសាវកតែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដោយរាងឆ្អឹង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់

ច្រើន ទោសមានច្រើនប្រការក្នុងកាមទាំងនេះ យ៉ាងនោះឯង អរិយសាវក ឃើញសេចក្តីនេះ តាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះហើយ ក៏លះបង់នូវ ឧបេក្ខា ( ក្នុងបញ្ចកាមគុណ ) ដែលមានសភាពផ្សេងគ្នា អាស្រ័យនូវ អារម្មណ៍មានសភាពផ្សេងគ្នា ហើយចម្រើនឧបេក្ខា ដែលមានសភាពតែមួយ អាស្រ័យនូវអារម្មណ៍មានសភាពតែមួយ និងឧបេក្ខាជាទីរលត់នៃឧបាទានជា លោកាមិសៈ មិនមានសេសសល់ ដោយប្រការទាំងពួង ។

[ ៤៨ ] ម្នាលគហបតី ដូចជាសត្វត្មាត ខ្លែងក្រហម ឬខ្លែងខ្មៅពាំនាំ ដុំសាច់ហើរទៅ មានពួកត្មាតខ្លះ ពួកក្អែងក្រហមខ្លះ ពួកខ្លែងខ្មៅខ្លះ នាំគ្នាហើរ ដេញតាមសត្វត្មាតជាដើមនោះ ចឹកជញ្ជែងដណ្តើមយក ម្នាលគហបតី អ្នក សម្គាល់សេចក្តីនោះថាដូចម្តេច បើសត្វត្មាត ខ្លែងក្រហម ឬខ្លែងខ្មៅនោះ មិន លះចោលដុំសាច់នោះ ដោយឆាប់ទេ ក៏ត្មាតជាដើមនោះ នឹងដល់នូវសេចក្តី ស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះដុំសាច់នោះជាហេតុ មែនឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតី អរិយសាវក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដោយដុំ សាច់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការ ក្នុងកាមទាំងនេះយ៉ាងនោះឯង អរិយសាវកឃើញសេចក្តីនេះ តាមពិតដោយ ប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះហើយ ក៏លះបង់នូវឧបេក្ខាដែលមានសភាពផ្សេងគ្នា អាស្រ័យនូវអារម្មណ៍មានសភាពផ្សេងគ្នា ចម្រើននូវឧបេក្ខាដែលមានសភាព តែមួយ អាស្រ័យនូវអារម្មណ៍មានសភាពតែមួយ និងឧបេក្ខាជាទីរលត់នៃ

ឧបាទានជាលោកាមិសៈ មិនមានសេសសល់ ដោយប្រការទាំងពួង ។

[ ៤៩ ] ម្នាលគហបតី ដូចជាបុរសកាន់នូវគប់ស្មៅដែលភ្លើងឆេះដើរប្រាសខ្យល់ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច បើបុរសនោះមិនលះចោលគប់ស្មៅដែលភ្លើងឆេះនោះ ដោយឆាប់ទេ គប់ស្មៅដែលភ្លើងឆេះនោះ នឹងរោលរាលដៃ ឬកំភួនដៃ ឬរោលរាលអវយវៈតូចធំនីមួយ បុរសនោះនឹងដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះគប់ស្មៅដែលភ្លើងឆេះនោះ ជាហេតុមែនឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតី អរិយសាវ័កតែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដោយគប់ស្មៅ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការក្នុងកាមទាំងនេះ យ៉ាងនោះឯង អរិយ-សាវ័ក ឃើញសេចក្តីនេះតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះ ។បេ។ ក៏ចម្រើននូវឧបេក្ខានោះឯង ។

[ ៥០ ] ម្នាលគហបតី ដូចជារណ្តៅរងើកភ្លើង មានជម្រៅមួយជំហរបុរស ដ៏ពេញដោយរងើកភ្លើង ឥតមានអណ្តាត ឥតមានផ្សែង កាលនោះមានបុរសម្នាក់មានប្រាថ្នាដើម្បីរស់នៅ មិនប្រាថ្នាដើម្បីស្លាប់ ប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ ដើរមក ( កាន់រណ្តៅនោះ ) មានបុរសខ្លាំងពូកែពីរនាក់ ចាប់បុរសនោះ ត្រង់កំភួនដៃម្ខាងម្នាក់ ទាញទម្លាក់ទៅក្នុងរណ្តៅ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច តើបុរសនោះ គួរបង្អោនកាយ ( ទៅកាន់រណ្តៅ ) នោះដូច្នេះខ្លះ ដូច្នោះខ្លះដែរឬទេ ។ បពិត្រព្រះអង្គដ៏

ចម្រើន បុរសនោះ មិនគួរបង្អោនកាយទៅឡើយ ដំណើរនោះ ព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះបុរសនោះដឹងច្បាស់ថា បើអាត្មាអញនឹងធ្លាក់រណ្តៅរងើកភ្លើងនេះ អាត្មាអញនឹងដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតស្លាប់ ព្រោះរណ្តៅរងើកភ្លើងនោះ ជាហេតុ ។ ម្នាលគហបតី អរិយសាវក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដោយរណ្តៅរងើកភ្លើង មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការ ក្នុងកាមទាំងនេះ យ៉ាងនោះឯង អរិយសាវកឃើញសេចក្តីនេះតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ ។បេ។ ក៏ចម្រើននូវឧបេក្ខានោះឯង ។

[ ៥១ ] ម្នាលគហបតី ដូចជាបុរសយល់សប្តិឃើញអារាមជាទីសប្បាយ ព្រៃជាទីសប្បាយ ផែនដីជាទីសប្បាយ និងស្រះបោក្ខរណីជាទីសប្បាយ លុះបុរសនោះភ្ញាក់ឡើង មិនឃើញអ្វីមួយឡើយ ម្នាលគហបតី អរិយសាវក តែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដោយយល់សប្តិ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការ ក្នុងកាមទាំងនេះ យ៉ាងនោះឯង ។បេ។ ក៏ចម្រើននូវឧបេក្ខានោះឯង ។

[ ៥២ ] ម្នាលគហបតី ដូចជាបុរសខ្ចីទ្រព្យគេជារបស់បណ្តោះអាសន្ន គឺកែវមណី និងកុណ្ឌល ( គ្រឿងប្រដាប់ត្រចៀក ) ដ៏ប្រសើរ ហើយឡើងកាន់យាន បុរសនោះ បានប្រដាប់តាក់តែងដោយទ្រព្យជារបស់ខ្ចីគេបណ្តោះ

អាសន្នទាំងនោះ ដើរទៅកាន់រានផ្សារ អ្នកផងបានឃើញបុរសនោះហើយ ក៏និយាយយ៉ាងនេះថា អើហ្ន៎ បុរសនេះ មានភោគសម្បត្តិច្រើនណាស់ បានឮថា ពួកជនអ្នកមានភោគសម្បត្តិ រមែងបរិភោគសម្បត្តិយ៉ាងហ្នឹងតើ បើពួកជនជាម្ចាស់គប្បីឃើញបុរសនោះក្នុងទីណាៗ ក៏គប្បីយកទ្រព្យ ដែលជារបស់ខ្លួនក្នុងទីនោះទៅ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះ ថាដូចម្តេច បុរសនោះ គួរអាក់អន់ចិត្តឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះមិនគួរនឹងអាក់អន់ចិត្តទេ ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះពួកជនជាម្ចាស់ទ្រព្យ នាំយកទ្រព្យដែលជារបស់ខ្លួនទៅ ។ ម្នាលគហបតី អរិយសាវកតែងពិចារណាដូច្នេះថា ព្រះមានព្រះភាគទ្រង់សម្តែងហើយថា កាមទាំងឡាយ មានឧបមាដោយរបស់ខ្ចីគេ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការ ក្នុងកាមទាំងនេះ យ៉ាងនោះឯង ។បេ។ ក៏ចម្រើននូវឧបេក្ខានោះឯង ។

[ ៥៣ ] ម្នាលគហបតី ដូចជាដងព្រៃស្តុក នៅជិតស្រុក ឬនិគម មានដើមឈើក្នុងព្រៃនោះ ជាឈើមានផ្លែផ្អែមផង មានផ្លែដ៏ច្រើនផង សូម្បីផ្លែណាមួយ ក៏មិនជ្រុះចុះលើផែនដីឡើយ ទើបមានបុរសម្នាក់ជាអ្នកត្រូវការដោយផ្លែ ស្វែងរកផ្លែ ត្រាច់ទៅស្វែងរកផ្លែ ក៏ដើរមកដល់ បុរសនោះ ដើរចូលទៅកាន់ដងព្រៃនោះ ឃើញដើមឈើនោះ មានផ្លែផ្អែមផង មានផ្លែច្រើនផង ទើបបុរសនោះគិតយ៉ាងនេះថា ឈើនេះឯង មានផ្លែផ្អែមផង មានផ្លែច្រើនផង សូម្បីផ្លែណាមួយ ក៏មិនជ្រុះចុះលើផែនដីឡើយ ឯអាត្មាអញក៏ចេះ

ឡើងឈើដែរ បើដូច្នោះ មានតែអាត្មាអញឡើងកាន់ដើមឈើនេះ ហើយទំពាស៊ីត្រាតែឆ្អែតផង ដក់ថ្នក់ផង លុះបុរសនោះគិតហើយ ក៏ឡើងកាន់ដើមឈើនោះ ទំពាស៊ីត្រាតែឆ្អែតផង ដក់ថ្នក់ផង កាលនោះ មានបុរសជាគម្រប់ពីរ ជាអ្នកត្រូវការដោយផ្លែ ស្វែងរកផ្លែ ត្រាច់ទៅស្វែងរកផ្លែ ក៏កាន់យកដឹងដ៏មុតដើរមកដល់ បុរសនោះចូលទៅកាន់ដងព្រៃនោះ ហើយឃើញនូវដើមឈើនោះ មានផ្លែផ្អែមផង មានផ្លែច្រើនផង ទើបបុរសនោះគិតយ៉ាងនេះថា ឈើនេះឯង មានផ្លែផ្អែមផង មានផ្លែច្រើនផង សូម្បីផ្លែណាមួយ ក៏មិនជ្រុះចុះលើផែនដីឡើយ ឯអាត្មាអញមិនចេះឡើងដើមឈើឡើយ បើដូច្នោះ មានតែអាត្មាអញកាប់ដើមឈើនេះត្រង់គល់ ហើយទំពាស៊ីត្រាតែឆ្អែតផង ដក់ថ្នក់ផង លុះបុរសនោះគិតហើយ ក៏កាប់ដើមឈើនោះត្រង់គល់ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច បុរសដែលឡើងដើមឈើមុនគេនោះ បើមិនចុះមកដោយរហ័សទេ ដើមឈើនោះកាលរលំចុះ គប្បីបំបាក់ដៃ បំបាក់ជើង បំបាក់អវយវៈតូចធំណានីមួយរបស់បុរសនោះ បុរសនោះគប្បីដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះផ្លែឈើនោះជាហេតុ មែនឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតី អរិយសាវកតែងពិចារណាដូច្នេះថា ព្រះមានព្រះភាគ ទ្រង់សម្តែងហើយថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសមានច្រើនប្រការ ក្នុងកាមទាំងនេះ យ៉ាងនោះឯង អរិយសាវកឃើញសេចក្តីនេះតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះហើយ ក៏លះបង់ឧបេក្ខា ដែលមានសភាពផ្សេងគ្នា អាស្រ័យ

អារម្មណ៍មានសភាពផ្សេងគ្នា ហើយចម្រើនឧបេក្ខា ដែលមានសភាពតែមួយ អាស្រ័យអារម្មណ៍មានសភាពតែមួយ និងឧបេក្ខាជាទីរលត់ទៅនៃឧបាទានជាលោកាមិសៈ មិនមានសេសសល់ ដោយប្រការទាំងពួង ។

[ ៥៤ ] ម្នាលគហបតី អរិសាវកនោះឯង អាស្រ័យសេចក្តីបរិសុទ្ធនៃសតិ ដែលកើតអំពីឧបេក្ខាដ៏ប្រសើរនេះឯង ហើយរឭកនូវបុព្វេនិវាសច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ ម្នាលគហបតី អរិយសាវកនោះឯង អាស្រ័យសេចក្តីបរិសុទ្ធនៃសតិ ដែលកើតអំពីឧបេក្ខាដ៏ប្រសើរនេះឯង ហើយឃើញពួកសត្វដែលច្យុត កើតឡើង ជាសត្វថោកទាប ឧត្តម មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។បេ។ ក៏ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្ម ដោយទិព្វចក្ខុដ៏បរិសុទ្ធកន្លងហួសចក្ខុរបស់មនុស្សសាមញ្ញ ។ ម្នាលគហបតី អរិយសាវកនោះឯង អាស្រ័យនូវសេចក្តីបរិសុទ្ធនៃសតិដែលកើតអំពីឧបេក្ខាដ៏ប្រសើរនេះឯង ហើយធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នឹងបានដល់ចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។

[ ៥៥ ] ម្នាលគហបតី ការផ្តាច់បង់ជំនួញ ដោយសព្វគ្រប់ដោយប្រការទាំងពួង ក្នុងអរិយវិន័យ តែងមានដោយហេតុ មានប្រមាណប៉ុណ្ណេះ ម្នាលគហបតី អ្នកសម្គាល់សេចក្តីនោះដូចម្តេច ការផ្តាច់បង់ជំនួញដោយសព្វ

គ្រប់ ដោយប្រការទាំងពួង ក្នុងអរិយវិន័យ ដោយសភាពយ៉ាងណា អ្នកបាន ឃើញការផ្តាច់បង់ជំនួញ មានសភាពយ៉ាងនោះ ក្នុងខ្លួនដែរឬ ។ បពិត្រព្រះ អង្គដ៏ចម្រើន ខ្ញុំព្រះអង្គណាក្តី ការផ្តាច់បង់ជំនួញដោយសព្វគ្រប់ ដោយប្រការ ទាំងពួង ក្នុងអរិយវិន័យណាក្តី បពិត្រព្រះអង្គដ៏ចម្រើន បណ្តាសភាវៈទាំង ពីរនោះ ខ្ញុំព្រះអង្គឆ្ងាយចាកការផ្តាច់បង់ជំនួញដោយសព្វគ្រប់ ដោយប្រការ ទាំងពួង ក្នុងអរិយវិន័យនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាកាលពី ដើមខ្ញុំព្រះអង្គបានសម្គាល់នូវពួកបរិព្វាជក មានលទ្ធិផ្សេង ដែលមិនមែនជា បុរសអាជានេយ្យពិត ថាជាបុរសអាជានេយ្យ ញុំាងបុគ្គលដែលមិនមែនជា បុរសអាជានេយ្យពិត ឲ្យបរិភោគភោជន សម្រាប់បុរសអាជានេយ្យ តាំង បុគ្គលដែលមិនមែនជាបុរសអាជានេយ្យពិត ឲ្យតាំងនៅក្នុងទីជាបុរសអាជា-នេយ្យ បពិត្រព្រះអង្គដ៏ចម្រើន មួយយ៉ាងទៀត ខ្ញុំព្រះអង្គបានសម្គាល់ភិក្ខុ ទាំងឡាយដែលជាបុរសអាជានេយ្យពិត ថាមិនមែនជាបុរសអាជានេយ្យវិញ ញុំាងភិក្ខុដែលជាបុរសអាជានេយ្យពិត ឲ្យបរិភោគភោជន សម្រាប់បុរសមិន មែនជាអាជានេយ្យវិញ តាំងភិក្ខុដែលជាបុរសអាជានេយ្យពិត ក្នុងទីនៃបុរស មិនមែនជាអាជានេយ្យ បពិត្រព្រះអង្គដ៏ចម្រើន ក៏ឥឡូវនេះ ខ្ញុំព្រះអង្គស្គាល់ ពួកបរិព្វាជក មានលទ្ធិផ្សេងៗ ដែលមិនមែនជាបុរសអាជានេយ្យពិត ថាមិន មែនជាបុរសអាជានេយ្យ និងញុំាងបុគ្គលដែលមិនមែនជាបុរសអាជានេយ្យ ពិត ឲ្យបរិភោគភោជនសម្រាប់បុរសមិនមែនជាអាជានេយ្យ និងតាំងបុគ្គល ដែលមិនមែនជាបុរសអាជានេយ្យពិត ក្នុងទីនៃបុគ្គលមិនមែនជាបុរសអាជា-

នេយ្យ បពិត្រព្រះអង្គដ៏ចម្រើន មួយយ៉ាងទៀត ខ្ញុំព្រះអង្គស្គាល់ភិក្ខុទាំងឡាយដែលជាបុរសអាជានេយ្យពិត ថាជាបុរសអាជានេយ្យ និងញុំាងភិក្ខុដែលជាបុរសអាជានេយ្យពិត ឲ្យបរិភោគភោជន សម្រាប់បុរសអាជានេយ្យ និងតាំងភិក្ខុដែលជាបុរសអាជានេយ្យ ក្នុងទីនៃបុរសអាជានេយ្យ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់បានធ្វើសេចក្តីស្រឡាញ់ចំពោះពួកសមណៈ សេចក្តីជ្រះថ្លាចំពោះពួកសមណៈ សេចក្តីគោរពចំពោះពួកសមណៈ ឲ្យកើតដល់ខ្ញុំព្រះអង្គហើយហ្ន៎ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយដោយអនេកបរិយាយយ៉ាងនេះ ( ភ្លឺច្បាស់ណាស់ ) ដូចជាបុរសចាប់បើករបស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ឬដូចជាបុរសបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ឬក៏ដូចជាបុរសប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះដូចជាគេកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានចក្ខុមើលឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង ទីរឭក សូមព្រះមានព្រះភាគ ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសកដល់នូវសរណៈ ស្មើដោយជីវិត ក្នុងថ្ងៃនេះជាដើម ។

## បោតលិយសូត្រទី ៤ ចប់

# អដ្ឋកថា

## ចោតលិយសូត្រទី ៤

[ ៣៦ ] ចោតលិយសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **អង្គុត្តរាបេសុ** សេចក្ដីថា ជនបទដែលឈ្មោះថា អង្គុត្តរាបៈនោះ គឺ ដែនអង្គៈនោះឯង ល្អាងទឹកដែលនៅខាងលើស្ទឹងមហី ហៅថា អង្គុត្តរាបៈក៏មាន ព្រោះនៅមិនឆ្ងាយអំពីល្អាងទឹកនោះ ។

សួរថា ល្អាងទឹកនោះនៅទិសខាងជើងស្ទឹងមហីណា ឆ្លើយថា ស្ទឹងមហីដែលជាស្ទឹងធំ ក្នុងសេចក្ដីនេះ នឹងថ្លែងឲ្យជាក់ច្បាស់ ដូចតទៅនេះថា

បានឮថា ជម្ពូទ្វីបនេះ មានផ្ទៃដីប្រមាណ ១ ម៉ឺនយោជន៍ ក្នុង ១ ម៉ឺនយោជន៍នោះ ដីប្រមាណ ៤ ពាន់យោជន៍ គ្របដណ្ដប់ដោយទឹក រាប់បានថាជាសមុទ្រ មនុស្សអាស្រ័យនៅក្នុងផ្ទៃដីប្រមាណ ៣ ពាន់យោជន៍ ភ្នំហិមពាន្តតាំងនៅក្នុងផ្ទៃដីប្រមាណ ៣ ពាន់យោជន៍ កម្ពស់ ១០៥ យោជន៍ ប្រដាប់ដោយកំពូល ៨ ម៉ឺន ៤ ពាន់កំពូលដ៏ស្រស់ស្អាត លម្អដោយស្ទឹង ៥០០ ខ្សែ ហូរដោយជុំវិញ មានស្រះធំ ៧ គឺ អនោតត្តស្រះ កណ្ណមុណ្ឌស្រះ រថការស្រះ ឆទ្ទន្តស្រះ កុណាលស្រះ មន្ទាកិនីស្រះ ( ហង្សបបាតស្រះ ) សីហបបាតស្រះ បណ្ដោយ ទទឹង និងជម្រៅ ៥០ យោជន៍ បរិមាត្រ ១៥០ យោជន៍ ក្នុងស្រះទាំង ៧ នោះ អនោតត្តស្រះ ព័ទ្ធដោយភ្នំ ៥ ជាន់ គឺសុទស្សនកូដ ចិត្រកូដ កាលកូដ គន្ធមាទនកូដ កៃលាសកូដ ក្នុងភ្នំ ៥ នោះ សុទស្សនកូដជាភ្នំមាស កម្ពស់ ២០០ យោជន៍ ខាងក្នុងកោង

មានសណ្ឋានដូចចំពុះក្អែក បិទបាំងស្រះនោះឯង ចិត្រកូដជាភ្នំរតនៈទាំងអស់ កាលកូដ ជាភ្នំរ៉ៃពេជ្រ គន្ធមាទនកូដ ជាភ្នំដែលមានផ្ទៃដីរាប ដេរដាសទៅដោយគន្ធជាតិ គឺក្លិនប្រអូបទាំង ១០ គឺឈើឫសក្រអូប ឈើក្រមរក្រអូប ឈើសម្បកក្រអូប ឈើស្រាយក្រអូប ឈើរសក្រអូប ឈើស្លឹកប្រអូប ឈើផ្កាក្រអូប ឈើផ្លែក្រអូប ឈើដើមក្រអូប ដេរដាសដោយឱសថច្រើនប្រការ ថ្ងៃឧបោសថខាងរនោច នឹងមានពន្លឺដូចរងើកភ្លើង ៗ កៃលាសកូដជាភ្នំប្រាក់ ភ្នំទាំងអស់ មានចំណែកខ្ពស់ និងសណ្ឋានស្មើជាមួយនឹងសុទស្សនកូដ បិទបាំងស្រះនោះឯង ភ្នំទាំងអស់នោះ ស្ថិតនៅបានដោយអានុភាពរបស់ទេវតា និងនាគ ៗ សូម្បីទឹកទាំងឡាយ រមែងហូរទៅត្រង់ភ្នំទាំងនោះ ទឹកទាំងអស់នោះ ក៏ហូរទៅកាន់អនោតត្តស្រះតែមួយកន្លែង ៗ ព្រះចន្ទ និងព្រះអាទិត្យ គោចរទៅទិសខាងត្បូងខ្លះ ខាងជើងខ្លះ បាំងពន្លឺទៅត្រង់ស្រះនោះ ដោយវាំងភ្នំ មិនគោចរទៅត្រង់ៗ ដោយហេតុនោះឯង ទើបស្រះនោះឈ្មោះថា អនោតត្តៈ គឺមិនត្រូវពន្លឺថ្ងៃ ក្នុងអនោតត្តស្រះនោះ ធម្ម-ជាតិបានរៀបចំយ៉ាងល្អ មានជុំមនោសិលា និងហរតាល ប្រាសចាកអណ្តើក និងត្រី មានទឹកថ្លាឆ្វេង ដូចកែវផលិក មានកំពង់រាបស្មើ ដែលជាទីស្រពស្រង់របស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរហន្តខីណាស្រព និងពួកឥសីដែលមានឫទ្ធិ ទាំងពួកទេវតា និងយក្ខក៏មកលេងទឹកនោះដូចគ្នា ជុំវិញអនោតត្ត-ស្រះនោះ មានប្រកផ្លូវ ៤ គឺផ្លូវរាជសីហ៍ ផ្លូវដំរី ផ្លូវសេះ ផ្លូវគោឧសភៈ ដែលជាផ្លូវហូរនៃស្ទឹង ៤ ខ្សែ ៗ ហ្វូងរាជសីហ៍មានច្រើន នៅតាមមាត់

ប្រាំងស្ទឹងដែលហូរចេញអំពីផ្លូវរាជសីហ៍ មានហ្វូងដំរី ហ្វូងសេះ ហ្វូងគោច្រើន តាមមាត់ប្រាំងស្ទឹងដែលហូរចេញតាមផ្លូវដំរីជាដើម ។ ស្ទឹងដែលហូរចេញទៅកាន់ទិសខាងកើត ព័ទ្ធស្តាំជុំវិញអនោតត្តស្រះ ៣ ផ្ទត់ មិនជួបជាមួយស្ទឹងដទៃ ៣ ខ្សែ ហូរឆ្លងកាត់ទឹកដីអមនុស្ស តាមភ្នំហិមពាន្ត នាទិសខាងកើត ចុះកាន់មហាសមុទ្រ ។ ឯស្ទឹងដែលហូរចេញអំពីទិសខាងត្បូងបត់ខាងស្តាំអនោតត្តស្រះនោះ ៣ ផ្ទត់ ហូរត្រង់ទៅទិសខាងត្បូង ៦០ យោជន៍ខាងលើផ្ទាំងថ្មនោះឯង ទម្លុះភ្នំចេញមក មានក្រសែទឹកប្រមាណ ៣០ គាវុតព័ទ្ធ ឆ្លងអាកាសគង្គា ៦០ យោជន៍ ទៅធ្លាក់ចុះលើផែនថ្ម ឈ្មោះ តិយគ្គឡផែនថ្មក៏សឹកដោយកម្លាំងនៃក្រសែទឹក ទីដែលផែនថ្ម តិយគ្គឡសឹកនោះក៏កើតជាស្រះបោក្ខរណី ឈ្មោះតិយគ្គឡា ប្រមាណ ៥០ យោជន៍ ក្រសែទឹកទម្លុះប្រាំងស្រះបោក្ខរណី ទម្លុះថ្មទៅ ៦០ យោជន៍ បន្ទាប់អំពីនោះ ក៏ទម្លុះផែនដីទៅ ៦០ យោជន៍ ក្លាយជាឧមង្គ ទង្គិចនឹងតិរច្ឆានបព៌ត ឈ្មោះវិជ្ឈៈ ទៅជាក្រសែទឹក ៥ ខ្សែ ដូចគ្នានឹងម្រាមដៃទាំង ៥ ខ្សែទឹកនោះដែលហូរបត់ទៅស្តាំអនោតត្តស្រះ ៣ ផ្ទត់ ហៅថា អាវដ្តគង្គា ក្នុងទីដែលហូរត្រង់ទៅ ៦០ យោជន៍ លើខ្នងថ្ម ហៅថា កណ្ហគង្គា ក្នុងទីដែលហូរទៅ ៦០ យោជន៍ តាមអាកាស ហៅថា ទឹកជ្រោះ ទីដែលទឹកជ្រោះធ្លាក់ចុះលើថ្មឈ្មោះ តិយគ្គឡ ហៅថា តិយគ្គឡបោក្ខរណី ក្នុងទីដែលទម្លុះប្រាំងស្រះធ្លុះថ្មទៅ ៦០ យោជន៍ ហៅថា ពហលគង្គា ។ ក្នុងទីដែលហូរទៅ ៦០ យោជន៍តាមផ្លូវឧមង្គ ហៅថា ឧមង្គគង្គា ឯក្នុងទីដែលទង្គិចនឹងតិរច្ឆានបព៌ត

ឈ្មោះវិជ្ឈៈ បែកចេញជាក្រសែទឹក ៥ ខ្សែ ក្លាយជាស្ទឹង ៥ គឺគង្គា យមុនា អចិរវតី សរភូ មហី មហានទី ៥ ខ្សែនេះ មានប្រភពកើតមកអំពីហិមវន្ត-បពិត ដោយប្រការដូច្នេះ ។ ក្នុងមហានទី ៥ ខ្សែនោះ មហានទីខ្សែទី ៥ ឈ្មោះមហី លោកពោលសំដៅយកមហីមហានទីក្នុងទីនេះ ល្អាងទឹកណានៅទិសខាងជើង មហានទីឈ្មោះមហីនោះ ជនបទនោះគប្បីជ្រាបថា ឈ្មោះអង្គុត្តរាបៈ ព្រោះនៅជិតល្អាងទឹកនោះ ។ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងជនបទឈ្មោះអង្គុត្តរាបៈនោះ ។ បទថា **អាបណំ នាម** សេចក្ដីថា បានឮថា ក្នុងនិគមនោះ មានផ្សារដែលសំខាន់ៗ រាប់បាន ២ ម៉ឺនផ្សារ ព្រោះនិគមនោះមានផ្សារច្រើន ទើបបានឈ្មោះថា **អាបណា** ដែលប្រែថា ផ្សារ ។ ឯភូមិភាគដែលមានព្រៃក្រាស់ គួរជាទីរីករាយ នៅតាមមាត់ស្ទឹង មិនឆ្ងាយអំពីនិគមនោះ ជាដងព្រៃមហាវ័ន ព្រះមានព្រះភាគអាស្រ័យនៅក្នុងជួរព្រៃមហាវ័ននោះ ដោយហេតុនោះឯង គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់កំណត់ទីកន្លែង ក្នុងដងព្រៃមហាវ័ននោះ ។ បទថា **យេនញ្ញតរោ វនសណ្ឌោ តេនុបសង្កមិ** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់បញ្ជូនភិក្ខុសង្ឃ ទៅកាន់ស្ថានទីលំនៅ ទ្រង់យាងចូលទៅតែមួយព្រះអង្គឯង លោកសំដៅដល់ពោតលិយគហបតី ទើបពោលថា **ពោតលិយោបិ ខោ គហបតិ** គហបតីមានឈ្មោះយ៉ាងនេះថា ពោតលិយ ។ បទថា **សម្បន្ននិវាសនបារុបនោ** ប្រែថា មានសំពត់ស្លៀក សំពត់ដណ្ដប់បរិបូណ៌ អធិប្បាយថា សំពត់ស្លៀកជាយវែងមួយផ្ទាំង ដណ្ដប់មួយផ្ទាំង ។ បទថា **ឆត្តុបាហនាហិ** បានដល់

បាំងធ្មត្រ ពាក់ស្បែកជើង ។

[ ៣៧ ] បទថា **អាសនានិ** បានដល់ អាសនៈ មានតាំងធ្វើទុកជាបល្ល័ង្ក និងតាំងធ្វើដោយចំបើងជាដើម ។ ពិតហើយ ដោយហោច សូម្បីមែកឈើបាក់ៗ ក៏ហៅថា អាសនៈបានទាំងអស់ ។ បទថា **គហបតិវាទេន** ប្រែថា ដោយពាក្យនេះថា គហបតី ។ បទថា **សមុទាចរតិ** ប្រែថា ហៅ ។ បទថា **ភគវន្តំ ឯតទវោច** សេចក្តីថា បោតលិយគហបតីមិនអាចទទួលពាក្យថា គហបតីលើកទី ៣ បាន ទើបទូលព្រះមានព្រះភាគថា **តយិទំ ភោ គោតម** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **នច្ឆន្នំ** ប្រែថា មិនសម ។ បទថា **នប្បដិរូបំ** ប្រែថា មិនគួរ ។ បទថា **អាការា** ជាដើម ជាវេវចនៈនៃហេតុ ។ ពិតហើយ ការស្លៀកសំពត់ជាយវែង ការទុកសក់ ទុកពុកមាត់ ទុកក្រចក ឈ្មោះថា អាការ ព្រោះអត្ថវិគ្គហៈថា ភេទគ្រហស្ថទាំងអស់នោះឯង ធ្វើការៈគ្រហស្ថរបស់បោតលិយគហបតីឲ្យប្រាកដ អាការទាំងនោះ លោកហៅថា ភេទ ព្រោះតាំងនៅដោយទ្រង់ទ្រាយរបស់គ្រហស្ថ ហៅថា និមិត្ត ព្រោះជាគ្រឿងសម្គាល់ឲ្យយល់ដល់ការៈនៃគ្រហស្ថ ។ ដោយបទថា **យថាតំ គហបតិស្ស** ព្រះមានព្រះភាគ ទ្រង់វែងសម្តែងថា អាការ ភេទ និងនិមិត្ត គប្បីមានដល់គហបតី យ៉ាងណា អាការ ភេទ និងនិមិត្តទាំងនោះ ក៏មានដល់អ្នកដូច្នោះ ដោយហេតុនោះ ទើបតថាគត ហៅយ៉ាងនេះ ។ គ្រានោះបោតលិយគហបតីមិនព្រមទទួលពាក្យថា គហបតី ដោយហេតុណា កាលនឹងប្រកាសហេតុនោះ ទើបទូលថា **តថា ហិ បន មេ** ដូច្នេះជាដើម ។ បទ

ថា **និយ្យាតំ** ប្រែថា ទ្រព្យមត៌កដែលបានទទួល ។ បទថា **អនោវាទី** សេចក្ដីថា បុគ្គលដែលពោលប្រៀនប្រដៅដោយន័យជាដើមថា នែបា ពួកបា ចូរភ្ជួរ ចូរព្រោះ ចូរប្រកបដោយការលក់ដូរ ពួកបានឹងជាអ្នករស់នៅ ឬ ចិញ្ចឹមកូនប្រពន្ធបាន យ៉ាងណា ដូច្នេះ ឈ្មោះថា ជាអ្នកពោលថា ខ្ញុំមិនធ្វើ ទាំង ២ យ៉ាងនោះ ដោយហេតុនោះ ទើបបោតលិយគហបតីសម្ដែងថា ក្នុង រឿងនោះ ខ្ញុំព្រះអង្គមិនមែនពោលប្រៀនប្រដៅ មិនមែនជាអ្នកពោល ។ ដោយបទថា **ឃាសច្ឆាទនបរមោ វិហរាមិ** បោតលិយគហបតីសម្ដែងថា ខ្ញុំព្រះអង្គធ្វើការដើម្បីត្រឹមតែអាហារ និងត្រឹមតែគ្រឿងស្លៀកដណ្ដប់យ៉ាង ក្រៃលែងប៉ុណ្ណោះ មិនប្រាថ្នាអ្វីដទៃក្រៅអំពីនេះឡើយ ។

[ ៣៨ ] បទថា **គិទ្ធិលោភោ បហាតព្វោ** បានដល់ ការលោភដែលជាការជាប់ជំពាក់ គួរលះបង់ ។ បទថា **អនិន្ទារោសោ** បានដល់ ការមិនមាននិន្ទា ឬទ្រគោះបោះបោក ។ បទថា **និន្ទារោសោ** បានដល់ ការនិន្ទា និងការទ្រគោះបោះបោក ។ ការហៅឈ្មោះក្ដី បញ្ញត្តិក្ដី វាចាក្ដី ចេតនាក្ដី ឈ្មោះថា វោហារ ក្នុងបទថា **វោហារសមុច្ឆេទាយ** ។ បណ្ដាវោហារទាំងនោះ វោហារមកក្នុងការហៅឈ្មោះ ដូចក្នុងប្រយោគថា

**យោ ហិ កោចិ មនុស្សេសុ វោហារំ ឧបជីវតិ**
**ឯវំ វាសេដ្ឋ ជានាហិ វាណិជោ សោ ន ព្រាហ្មណោ ។**

មនុស្សណាមួយចិញ្ចឹមជីវិតដោយការជួញ ម្នាលវាសេដ្ឋ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះជាពាណិជ្ជ មិនមែនព្រាហ្មណ៍ទេ ដូច្នេះ ។

វោហារ មកក្នុងអត្ថថា បញ្ញត្តិ ដូចក្នុងប្រយោគនេះថា **សង្ខា សមញ្ញា បណ្ណត្តិ វោហារោ** ការរាប់ ការដឹងដោយប្រពៃ ការតាំងទុក ការនិយាយ ដូច្នេះ ។ វោហារ មកក្នុងអត្ថថា វាចា ដូចក្នុងប្រយោគនេះថា **តថា តថា វោហរតិ អបរាមាសំ** យ៉ាងនោះៗ ម្នាលភិក្ខុទាំងឡាយ ការមិនប្រកាន់នូវភាសា ( ក្នុងជនបទ ) និងការមិនប្រព្រឹត្តកន្លងនូវឈ្មោះយ៉ាងនេះឯង ដូច្នេះ ។ វោហារ មកក្នុងអត្ថថា ចេតនា ដូចក្នុងប្រយោគនេះថា **អដ្ឋ អរិយវោហារា អដ្ឋ អនរិយវោហារា** ម្នាលភិក្ខុទាំងឡាយ អរិយវោហារ ( វោហារដ៏ប្រសើរ ) នេះមាន ៨ យ៉ាង ... ម្នាលភិក្ខុទាំងឡាយ អនរិយវោហារ ( វោហារមិនប្រសើរ ) នេះ មាន ៨ យ៉ាង ដូច្នេះ ។ វោហារក្នុងទីនេះ លោកសំដៅយកចេតនានេះ ។ ម្យ៉ាងទៀត ចាប់តាំងអំពីពេលដែលបួសចេតនាថាជាគ្រហស្ថមិនមាន មានតែចេតនាដែលជាសមណៈ ពាក្យថា គ្រហស្ថមិនមាន ពាក្យថា សមណៈមាន បញ្ញត្តថា គ្រហស្ថមិនមាន បញ្ញត្តថា សមណៈមាន ការពោល ហៅថា គ្រហស្ថមិនមាន ការពោល ហៅថា សមណៈមាន ព្រោះដូច្នោះ ទើបបានវោហារទាំងអស់ ។

[ ៣៩-៤៦ ] ក្នុងបទថា **យេសំ ខោ អហំ សញ្ញោជនានំ ហេតុ បាណាតិបាតី** នេះ បាណាតិបាតប៉ុណ្ណោះ ឈ្មោះថា សំយោជនៈ ពិតហើយ បុគ្គលឈ្មោះថា ធ្វើបាណាតិបាត ក៏ព្រោះហេតុនៃបាណាតិបាតប៉ុណ្ណោះ គឺព្រោះមានបាណាតិបាតជាបច្ច័យ តែដែលត្រាស់ថា **យេសំ ខោ អហំ** ជាដើម ក៏ព្រោះបាណាតិបាតមានច្រើន ។ បទថា **តេសាហំ សំយោ–**

**ជឆានំ** ប្រែថា តថាគតបដិបត្តិដើម្បីលះ ដើម្បីកាត់ផ្តាច់នូវគ្រឿងជាប់ជំពាក់ គឺបាណាតិបាតទាំងនោះ ។ បទថា **បហានាយ សមុច្ឆេទាយ បដិបន្នោ** សេចក្តីថា តថាគតបដិបត្តិដើម្បីប្រយោជន៍ដល់ការលះ ដើម្បីប្រយោជន៍ដល់ការកាត់ផ្តាច់ ដោយសីលសំវរៈផ្លូវកាយ ពោល គឺមិនធ្វើបាណាតិបាតនេះ ។ បទថា **អត្តាបិ មំ ឧបវទេយ្យ** សេចក្តីថា សូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯង យ៉ាងនេះថា អញបួសក្នុងសាសនារបស់បុគ្គលដែលមិនផ្តាច់ផ្តិលជីវិតសត្វ សូម្បីតែស្រមោចខ្មៅ ស្រមោចក្រហម គង់មិនអាចវៀរ សូម្បីត្រឹមតែបាណាតិបាតបាន អញបួសធ្វើអ្វី ។ បទថា **អនុវិច្ចាបិ វិញ្ញូ គរហេយ្យុំ** សេចក្តីថា វិញ្ញូជន គឺបណ្ឌិតជទៃពិចារណា គឺពិនិត្យពិច័យហើយ ក៏គប្បីតិះដៀលយ៉ាងនេះថា បុគ្គលនោះបួសក្នុងសាសនាបែបនេះហើយ នៅតែមិនវៀរចាក សូម្បីត្រឹមតែបាណាតិបាត បុគ្គលនោះបួសធ្វើអ្វី ។

បទថា **ឯតេនេវ ខោ បន សញ្ញោជនំ ឯតំ នីវរណំ** នេះ សូម្បីមិនទាក់ទងក្នុងសំយោជនៈ ១០ នីវរណៈ ៥ តែក៏ត្រាស់ដោយអំណាចទេសនាថា ជាគ្រឿងរារាំង ៨ យ៉ាង គ្រឿងរារាំង ៨ យ៉ាងនោះ ត្រាស់ហៅថា សំយោជនៈខ្លះ នីវរណៈខ្លះ ព្រោះអត្ថថា ជាគ្រឿងចង និងព្រោះអត្ថថា បិទបាំងក្នុងវដ្តៈយ៉ាងនេះ ។ បទថា **អាសវា** គឺអវិជ្ជាសវៈតែម្យ៉ាង រមែងកើតព្រោះបាណាតិបាតជាហេតុ ។ បទថា **វិឃាតបរិឡាហា** ប្រែថា ការចង្អៀតចង្អល់ និងការក្តៅក្រហាយ ។ ក្នុងពាក្យនោះ ទ្រង់កាន់យកទុក្ខព្រោះកិលេស និងទុក្ខដែលជាវិបាក ដោយសព្ទថា **វិឃាត** ទ្រង់កាន់យកការក្តៅ

ក្រហាយដែលជាវិបាក ដោយសព្ទថា **បរិឡាហា** ។ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងទីគ្រប់អន្លើ ដោយឧបាយយ៉ាងនេះ ។ តែការប្រែកគ្នា មានដូច្នេះ គប្បីប្រកបសេចក្តីក្នុងវារៈទាំងអស់យ៉ាងនេះថា បដិបត្តិដើម្បីប្រយោជន៍ដល់ការលះ ដើម្បីប្រយោជន៍ដល់ការកាត់ផ្តាច់ ដោយសីលសំវរៈផ្លូវកាយ គឺ លះបង់អទិន្នាទាន ដោយសីលសំវរៈផ្លូវវាចា គឺ សច្ចវាចា ដោយសីលសំវរៈផ្លូវវាចា គឺ លះបង់បិសុណាវាចា ដោយសីលសំវរៈផ្លូវចិត្ត ពោលគឺ អគិទ្ធលោភៈ( មិនរង្វេង មិនល្មោភ ) ដោយសីលសំវរៈផ្លូវកាយ និងផ្លូវវាចា គឺ អនិន្ទារោសៈ( មិនគ្នាន់ក្នាញ់ គឺ មិននិន្ទា ) ដោយសីលសំវរៈផ្លូវចិត្ត ពោលគឺ ការមិនក្រោធ និងមិនចង្អៀតចង្អល់ចិត្ត ដោយសីលសំវរៈផ្លូវចិត្ត ពោលគឺ ការមិនមើលងាយ ។

ឯក្នុងបទទាំងនេះថា **អត្តាបិ មំ ឧបវទេយ្យ អនុវិច្ចាបិ វិញ្ញូ គរហេយ្យុំ** គប្បីប្រកបសេចក្តីគ្រប់វារៈយ៉ាងនេះថា សូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯងយ៉ាងនេះថា អញបួសក្នុងសាសនា ដែលប្រៀនប្រដៅមិនឲ្យកាន់យកទ្រព្យដែលគេមិនបានឲ្យ សូម្បីតែស្មៅមួយសរសៃ នៅមិនអាចវៀរចាកសូម្បីត្រឹមតែអទិន្នាទានបាន អញបួសធ្វើអ្វី ។ វិញ្ញូជនពិចារណាហើយ ក៏គប្បីតិះដៀលយ៉ាងនេះថា បុគ្គលដែលបួសក្នុងសាសនាបែបនេះហើយ នៅមិនអាចវៀរត្រឹមតែអទិន្នាទានបាន បុគ្គលនេះបួសធ្វើអ្វី សូម្បីខ្លួនឯង ក៏គប្បីតិះដៀលខ្លួនឯងយ៉ាងនេះថា អញបួសក្នុងសាសនាដែលទូន្មានមិនឲ្យធ្វើមុសាវាទ សូម្បីដោយបំណងឲ្យសើច ឬបំណងនឹងលេង បួសក្នុងសាសនា ដែលទូន្មានមិន

ឲ្យធ្វើការពោលញុះញង់ ដោយអាការទាំងពួង បួសក្នុងសាសនាដែលទូន្មាន មិនឲ្យធ្វើការលោភ ឬជាប់ជំពាក់ សូម្បីមានប្រមាណតិចតួច បួសក្នុងសាសនាដែលប្រៀនប្រដៅមិនឲ្យធ្វើការនិន្ទា និងពោលពាក្យទ្រគោះអ្នកដទៃ ក្នុងកាលដែលគេយករណារមកអារខ្លួន បួសក្នុងសាសនាដែលទូន្មានមិនឲ្យធ្វើសេចក្តីក្រោធ និងការចង្អៀតចង្អល់ សូម្បីកាលដង្គត់ និងបន្ទាមុតជាដើម បួសក្នុងសាសនាដែលទូន្មានមិនឲ្យប្រកាន់ខ្លួន សូម្បីត្រឹមតែសម្គាល់ខុស ក៏មិនអាចលះសូម្បីការសម្គាល់ខុសបាន អញបួសធ្វើអ្វី វិញ្ញូជនសូម្បីពិចារណា ក៏គប្បីតិះដៀលយ៉ាងនេះថា បុគ្គលនេះបួសក្នុងសាសនាបែបនេះហើយ នៅតែមិនអាចលះមុសាវាទ ... ការសម្គាល់ខុសបាន បុគ្គលនេះបួសធ្វើអ្វី ដូច្នេះ ។

ពីរបទថា **អាសវា** នេះ គប្បីជ្រាបការកើតនៃអាសវៈយ៉ាងនេះ គឺ កាមាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ រមែងកើតព្រោះអទិន្នាទានជាហេតុ កើតព្រោះមុសាវាទជាហេតុ និងបិសុណាវាចាជាហេតុ ក៏យ៉ាងនោះដូចគ្នា ។ ទិដ្ឋាសវៈ និងអវិជ្ជាសវៈ កើតព្រោះគិទ្ធិលោភៈជាហេតុ អវិជ្ជាតែម្យ៉ាង កើតព្រោះនិន្ទារោសៈជាហេតុ កើតព្រោះកោធៈ និងឧបាយាសៈជាហេតុ ក៏ដូចគ្នាយ៉ាងនោះ ។ អាសវៈ ២ គឺភវាសវៈ និងអវិជ្ជាសវៈ កើតព្រោះអតិមានៈជាហេតុ តែដើម្បីមិនឲ្យធ្លាក់ក្នុងវារៈទាំង ៨ នេះ វិនិច្ឆ័យសង្ខេបមានដូច្នេះ ។ គួរពោលថា អញមិនអាចវៀរក្នុងវារៈ៤ នេះមុន គួរពោលថា អញមិនអាចលះក្នុងវារៈខាងចុង ។ អវិជ្ជាសវៈ តែម្យ៉ាងប៉ុណ្ណោះ មានក្នុងបាណាតិបាត និន្ទារោសៈ កោធៈ និងឧបាយាសៈ ។ កាមាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ

មានក្នុងអទិន្នាទាន មុសាវាទ និងបិសុណាវាចា ។ ទិដ្ឋាសវៈ អវិជ្ជាសវៈ មានក្នុងគិទ្ធិលោភៈ ។ ភវាសវៈ អវិជ្ជាសវៈ មានក្នុងអតិមានៈ ។ អបាណាតិបាត អនទិន្នាទាន ជាសីលផ្លូវកាយ ។ អមុសាវាទ អបិសុណាវាចា ជាសីលផ្លូវវាចា ។ ៣ ដ៏សេស វៀរអនិន្ទារោសៈ ជាសីលផ្លូវចិត្ត ។ តែបុគ្គលរមែងបៀតបៀនគ្នាដោយកាយខ្លះ បៀតបៀនគ្នាដោយវាចាខ្លះ ព្រោះដូច្នោះ ទើបអនិន្ទារោសៈមានឋានៈ ២ គឺសីលផ្លូវកាយក៏មាន សីលផ្លូវវាចាក៏មាន ។

សួរថា សីលអ្វី ទើបលោកពោលដោយប្រមាណត្រឹមប៉ុណ្ណោះ ឆ្លើយថា បាតិមោក្ខសំវរសីល ។ ឯការកាត់ផ្តាច់ ការត្រាស់ដល់គ្រហស្ថដោយអំណាចការពិចារណា និងការលះ គប្បីជ្រាបថា ត្រាស់សម្រាប់ភិក្ខុដែលនៅក្នុងបាតិមោក្ខសំវរសីល ។

[ ៤៧ ] ទេសនាដោយពិស្តារ មានដូចតទៅនេះ បទថា **គោឃាតកោ** គប្បីជ្រាបសម្ពន្ធនឹងបទនេះថា **ឧបដ្ឋហេយ្យ** លោកអធិប្បាយថា អ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោ គប្បីបោះឆ្អឹងនោះទៅកាន់ឆ្កែ អធិប្បាយថា បោះទៅក្បែរឆ្កែនោះ ។ បទថា **អដ្ឋិកង្កលំ** សរីរៈឆ្អឹង គឺឆ្អឹងទ្រូង ឆ្អឹងខ្នង ឬឆ្អឹងក្បាល ពិតហើយ សរីរៈឆ្អឹងនោះ ហៅថា រាងឆ្អឹង ព្រោះមិនមានសាច់ ។ បទថា **សុនិក្កន្តំ និក្កន្តំ** គឺឆ្អឹងដែលពន្លះសាច់អស់ហើយ ។ អធិប្បាយថា សាច់ស្រស់ឯណាមានត្រង់ឆ្អឹងនោះ ក៏ភ្លូះសាច់នោះចេញអស់ មានត្រឹមតែឆ្អឹងប៉ុណ្ណោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ប្រាសចាក

សាច់ តែកាងឆ្អឹងនោះប្រឡាក់ឈាមនៅឡើយ ព្រោះហេតុនោះ ទើបត្រាស់ថា **លោហិតមក្ខិតំ** ប្រែថា នៅប្រឡាក់ឈាម ។ បទថា **ពហុទុក្ខា ពហុបាយាសា** សេចក្តីថា កាមទាំងឡាយឈ្មោះថា ទុក្ខច្រើន ក៏ព្រោះច្រើនដោយទុក្ខ ទាំងបច្ចុប្បន្នផង ខាងមុខផង ។ ឈ្មោះថា មានការចង្អៀតចង្អល់ច្រើន ក៏ព្រោះច្រើនដោយការសៅហ្មងដោយការចង្អៀតចង្អល់ ។ បទថា **យាយំ ឧបេក្ខា នានត្តា នានត្តសិតា** សេចក្តីថា ឧបេក្ខាក្នុងកាមគុណ ៥ នេះ ហៅថា មានសភាវៈផ្សេងៗ គ្នា ក៏ដោយអំណាចអារម្មណ៍ គឺកាមគុណ ៥ និងហៅថា **នានត្តសិតា** ក៏ព្រោះអាស្រ័យអារម្មណ៍ទាំងនោះឯង ។ ភិក្ខុវៀរចាកឧបេក្ខានោះចេញ ។ បទថា **ឯកត្តា ឯកត្តសិតា** បានដល់ ឧបេក្ខាក្នុងចតុត្ថជ្ឈាន ។ ពិតហើយ ឧបេក្ខាក្នុងចតុត្ថជ្ឈាននោះ ឈ្មោះថា មានសភាវៈដូចគ្នា ព្រោះកើតឡើងក្នុងអារម្មណ៍តែមួយ អស់មួយថ្ងៃ ឈ្មោះថា **ឯកត្តសិតា** ព្រោះអាស្រ័យអារម្មណ៍តែមួយនោះឯង ។ បទថា **យត្ថ សព្វសោ លោកាមិសុបាទានា អបរិសេសា និរុជ្ឈន្តិ** សេចក្តីថា អាមិស គឺកាមគុណ ៥ ពោល គឺលោកាមិសអាស្រ័យឧបេក្ខាណា រមែងរលត់ទៅអស់រលីងមិនមានសេសសល់ក្នុងឧបេក្ខាចតុត្ថជ្ឈានណា ។ បទថា **បញ្ចកាមគុណាមិសា** បានដល់ ការត្រេកត្រអាល ដោយអំណាចការពេញចិត្ត ក្នុងកាមគុណជាអារម្មណ៍ ។ ឯកាមគុណ ៥ នោះឯង លោកហៅថា ឧបាទានក៏មាន ព្រោះអត្ថថា ប្រកាន់ ។ បទថា **តមេវូបេក្ខំ ភាវេតិ** សេចក្តីថា រមែងចម្រើនក្នុងឧបេក្ខាចតុត្ថជ្ឈានដែលជាបដិបក្ខចំពោះឧបាទាន ដែលអាស្រ័យលោកាមិសៈ

នោះឯង ។

[ ៤៨ ] បទថា **ឧឌ្ឌយេយ្យ** ប្រែថា គប្បីលោតឡើងទៅ ។ បទថា **អនុបតិត្វា** ប្រែថា ជាប់តាម ។ បទថា **វិតច្ឆេយ្យុំ** គឺគប្បីចឹកដោយចំពុះ ។ បទថា **វិភាជេយ្យុំ** គឺខ្វាំចម្រៀកសាច់ ដោយក្រចកឲ្យធ្លាក់ទៅ ។

[ ៥២ ] បទថា **យានំ ឱរោបេយ្យ** គឺផ្ទុកយានដែលសមគួរដល់បុរស ។ បទថា **បវរមណិកុណ្ឌលំ** គឺកែវមណីមានតម្លៃខ្ពស់ និងកុណ្ឌលមានបែបផ្សេងៗ ។ បទថា **សានិ ហរន្តិ** គឺកាន់យកទ្រព្យនៃខ្លួន ។

[ ៥៣ ] បទថា **សម្បន្នផលំ** គឺមានផ្លែឆ្ងាញ់ ។ បទថា **ឧបន្នផលំ** គឺមានផ្លែច្រើន ។ បទថា **អនុត្តរា** គឺប្រសើរ មានពន្លឺ ប្រាសចាកឧបក្កិលេស ។

[ ៥៥ ] បទថា **អារកា អហំ ភន្តេ** សេចក្តីថា ខ្ញុំនៅឆ្ងាយក្រៃពេកដូចផែនដី និងផ្ទៃមេឃ និងដូចត្រើយសមុទ្រខាងអាយ និងខាងនាយ ។ បទថា **អនាជានីយេ** គឺបុគ្គលមិនដឹងហេតុនៃការកាត់ផ្តាច់វោហារនៃគ្រហស្ថ។ បទថា **អាជានីយភោជនំ** គឺភោជនដែលបុគ្គលអ្នកដឹងហេតុ គប្បីបរិភោគ។ បទថា **អនាជានីយភោជនំ** គឺភោជនដែលពួកបុគ្គលមិនដឹងហេតុ បរិភោគ ពាក្យក្រៅអំពីនោះ ក្នុងទីគ្រប់អន្លើ ងាយយល់ទាំងអស់ហើយ ។៙

**ពោតលិយសូត្រ ចប់**

**សូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ជីវកសូត្រទី ៥

[ ៥៦ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអម្ពវ័នរបស់ជីវកកោមារភច្ច ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ជីវកកោមារភច្ច ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះជីវកកោមារភច្ច អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឮមកដូច្នេះថា ពួកជនតែងសម្លាប់សត្វចំពោះព្រះសមណគោតម ព្រះសមណគោតម បើទុកជាជ្រាបហេតុនោះហើយ ក៏រមែងសោយសាច់ ដែលគេធ្វើចំពោះ គឺសាច់ដែលគេធ្វើអាស្រ័យនូវខ្លួន បពិត្រព្រះអង្គដ៏ចម្រើន ពួកជនណាពោលយ៉ាងនេះថា ពួកជនតែងសម្លាប់សត្វចំពោះព្រះសមណគោតម ព្រះសមណគោតម បើទុកជាជ្រាបហេតុនោះហើយ ក៏រមែងសោយសាច់ដែលគេធ្វើចំពោះ គឺសាច់ដែលគេធ្វើអាស្រ័យនូវខ្លួន បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងនោះនិយាយត្រូវតាមពាក្យ ដែលគេពោលចំពោះព្រះមានព្រះភាគ មិនមែននិយាយបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង និយាយនូវហេតុសមគួរដល់ហេតុផង ឬទេ មួយយ៉ាងទៀត វាទៈ និងអនុវាទៈ បន្តិចបន្តួចរបស់ព្រះអង្គ ដែលប្រកបដោយហេតុ មិនបានដល់នូវហេតុដែលគួរតិះដៀលឬទេ ។

[ ៥៧ ] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលជីវកៈ ពួកជនណានិយាយយ៉ាង

នេះថា ពួកជនសម្លាប់សត្វចំពោះព្រះសមណគោតម ព្រះសមណគោតម បើទុកជាជ្រាបហេតុនោះហើយ ក៏រមែងសោយសាច់ដែលគេធ្វើចំពោះ គឺសាច់ដែលគេធ្វើអាស្រ័យនូវខ្លួន ពួកជននោះ មិនមែននិយាយត្រូវតាមពាក្យដែលគេពោលចំពោះតថាគតឡើយ ពួកជននោះនិយាយបង្កាច់តថាគតដោយពាក្យមិនមែន មិនពិត ម្នាលជីវក: តថាគតពោលនូវសាច់ដែលមិនគួរបរិភោគ ដោយហេតុទាំង ៣ គឺ ឃើញ ឮ រង្កៀស ម្នាលជីវក: តថាគតពោលនូវសាច់ដែលមិនគួរបរិភោគ ដោយហេតុទាំង ៣ នេះឯង ម្នាលជីវក: តថាគតពោលនូវសាច់ដែលគួរបរិភោគ ដោយហេតុទាំង ៣ គឺមិនឃើញ មិនឮ មិនរង្កៀស ម្នាលជីវក: តថាគតពោលនូវសាច់ដែលគួរបរិភោគ ដោយហេតុទាំង ៣ នេះឯង ។

[ ៥៨ ] ម្នាលជីវក: ភិក្ខុក្នុងសាសនានេះ ចូលទៅនៅអាស្រ័យនឹងស្រុក ឬនិគមណាមួយ ។ ភិក្ខុនោះ មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយដល់នូវសភាពធំ ប្រមាណមិនបាន មិនមានវេរា មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ។ គហបតី ឬគហបតិបុត្តចូលទៅរកភិក្ខុនោះ ហើយនិមន្តដោយភត្តដើម្បីឆាន់ក្នុងថ្ងៃស្អែក ម្នាលជីវក: កាលបើភិក្ខុមានប្រាថ្នា ក៏ទទួលនិមន្តន៍ ។ លុះកន្លងរាត្រីនោះទៅ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រ និងចីវរក្នុងវេលាព្រឹក ក៏ចូលទៅកាន់ផ្ទះនៃគហបតី

ឬគហបតិបុត្តនោះ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាល ហើយ ។ ឯគហបតី ឬគហបតិបុត្តនោះ ក៏អង្គាសភិក្ខុនោះ ដោយបិណ្ឌបាតដ៏ផ្ចិតផ្ចង់ ។ ភិក្ខុនោះមិនមានសេចក្តីត្រិះរិះយ៉ាងនេះថា គហបតី ឬគហបតិបុត្តនេះអង្គាសអាត្មាអញដោយបិណ្ឌបាតដ៏ផ្ចិតផ្ចង់ ដោយប្រពៃណាស់ហ្ន៎ ធ្វើម្តេចហ្ន៎ គហបតី ឬគហបតិបុត្តនេះ គប្បីអង្គាសអាត្មាអញដោយបិណ្ឌបាតដ៏ផ្ចិតផ្ចង់មានសភាពយ៉ាងនេះតទៅទៀត ភិក្ខុនោះមិនមានសេចក្តីត្រិះរិះយ៉ាងនេះសោះ ។ ភិក្ខុនោះមិនផ្តេកផ្តួល មិនជ្រុលជ្រប់ មិនល្មោភ តែងឃើញទោស មានបញ្ញាជាគ្រឿងរលាស់ចេញចាកទុក្ខ បរិភោគបិណ្ឌបាតនោះ ។ ម្នាលជីវកៈ អ្នកសម្គាល់ហេតុនោះថាដូចម្តេច តើភិក្ខុនោះគិតដើម្បីបៀតបៀនខ្លួន ឬគិតដើម្បីបៀតបៀនអ្នកដទៃ ឬគិតដើម្បីបៀតបៀនអ្នកទាំងពីរ ក្នុងសម័យនោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលជីវកៈ ភិក្ខុនោះ ឈ្មោះថាឆាន់អាហារដែលមិនមានទោស ក្នុងសម័យនោះមែនឬទេ ។ ព្រះករុណាព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគ្រាន់តែឮមកយ៉ាងនេះថា ព្រហ្មមានកិរិយានៅដោយមេត្តា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនោះជាពាក្យរបស់ខ្ញុំព្រះអង្គ ឥឡូវនេះ ខ្ញុំព្រះអង្គបានឃើញព្រះមានព្រះភាគច្បាស់នឹងភ្នែករបស់ខ្លួនហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគ មានកិរិយានៅដោយមេត្តាពិត ។ ម្នាលជីវកៈ បុគ្គលមានព្យាបាទ ដោយរាគៈទោសៈមោហៈណា រាគៈទោសៈមោហៈនោះ តថាគតបានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជា

សភាវៈដល់នូវការសោបសូន្យ មានសភាវៈមិនកើតឡើងតទៅ ម្នាលជីវកៈ បើអ្នកនិយាយអាស្រ័យហេតុនេះ តថាគតក៏យល់ព្រម នូវពាក្យនេះរបស់អ្នកដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនិយាយអាស្រ័យហេតុហ្នឹងឯង ។

[ ៥៩ ] ម្នាលជីវកៈ ភិក្ខុក្នុងសាសនានេះ ចូលទៅនៅអាស្រ័យនឹងស្រុក ឬនិគមណាមួយ ។ ភិក្ខុនោះមានចិត្តប្រកបដោយករុណា ។បេ។ មានចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី១ ទិសទី២ ទិសទី៣ ទិសទី៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានវេរា មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង ។ គហបតី ឬគហបតិបុត្ត ក៏ចូលទៅរកភិក្ខុនោះ ហើយនិមន្តដោយភត្ត ដើម្បីឆាន់ក្នុងថ្ងៃស្អែក ម្នាលជីវកៈ កាលបើភិក្ខុមានប្រាថ្នា ក៏ទទួលនិមន្ត ។ លុះកន្លងរាត្រីនោះទៅ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងវេលាព្រឹក ក៏ចូលទៅកាន់ផ្ទះគហបតី ឬគហបតិបុត្តនោះ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលហើយ ។ ឯគហបតី ឬគហបតិបុត្តនោះ ក៏អង្គាសភិក្ខុនោះដោយបិណ្ឌបាតដ៏ផ្ចិតផ្ចង់ ។ ភិក្ខុនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា គហបតី ឬគហបតិបុត្តនេះ អង្គាសអាត្មាអញដោយបិណ្ឌបាតដ៏ផ្ចិតផ្ចង់ ដោយប្រពៃណាស់ហ្ន៎ ធ្វើម្តេចហ្ន៎ គហបតី ឬគហបតិបុត្តនេះ គប្បីអង្គាសអាត្មាអញដោយបិណ្ឌបាតដ៏ផ្ចិតផ្ចង់ មានសភាពយ៉ាងនេះតទៅទៀត ភិក្ខុនោះ

មិនមានសេចក្តីត្រិះរិះយ៉ាងនេះសោះ ។ ភិក្ខុនោះមិនផ្តេកផ្តួល មិនជ្រុលជ្រប់ មិនល្មោភ តែងឃើញទោស មានបញ្ញាជាគ្រឿងរលាស់ចេញចាកទុក្ខ បរិភោគបិណ្ឌបាតនោះ ។ ម្នាលជីវកៈ អ្នកសម្គាល់ហេតុនោះ ថាដូចម្តេច តើភិក្ខុនោះគិតដើម្បីបៀតបៀនខ្លួនឯង ឬគិតដើម្បីបៀតបៀនអ្នកដទៃ ឬក៏គិតដើម្បីបៀតបៀនអ្នកទាំងពីរ ក្នុងសម័យនោះ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ម្នាលជីវកៈ ភិក្ខុនោះឈ្មោះថា ឆាន់អាហារដែលមិនមានទោសនោះ ក្នុងសម័យនោះមែនឬទេ ។ ព្រះករុណាព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគ្រាន់តែឮមកយ៉ាងនេះថា ព្រហ្មមានកិរិយានៅដោយឧបេក្ខា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនោះ ជាពាក្យរបស់ខ្ញុំព្រះអង្គ ឥឡូវនេះ ខ្ញុំព្រះអង្គបានឃើញព្រះមានព្រះភាគ ច្បាស់នឹងភ្នែករបស់ខ្លួនហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាព្រះមានព្រះភាគមានកិរិយានៅដោយឧបេក្ខាពិត ។ ម្នាលជីវកៈ បុគ្គលមានសេចក្តីបៀតបៀន សេចក្តីអផ្សុក និងសេចក្តីចង្អៀតចង្អល់ដោយ រាគៈ ទោសៈ និងមោហៈណា រាគៈ ទោសៈ និងមោហៈនោះ តថាគតបានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការសាបសូន្យ មានសភាពមិនកើតឡើងតទៅ ម្នាលជីវកៈ បើអ្នកនិយាយអាស្រ័យហេតុនេះ តថាគតក៏យល់ព្រមនូវពាក្យនេះរបស់អ្នកដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនិយាយអាស្រ័យហេតុហ្នឹងឯង ។

[ ៦០ ] ម្នាលជីវកៈ បុគ្គលណាសម្លាប់សត្វចំពោះតថាគត ឬសាវក

របស់តថាគត បុគ្គលនោះតែងទទួលបាបច្រើន ដោយឋានៈ ៥ យ៉ាង បុគ្គលនោះនិយាយយ៉ាងនេះថា អ្នកទាំងឡាយចូរទៅនាំយកសត្វឯណោះមក ដោយឋានៈណា តែងទទួលនូវបាបច្រើន ដោយឋានៈនេះជាបឋម សត្វនោះ កាលដែលគេយកខ្សែទាក់កដឹកយកមក ក៏ទទួលទុក្ខទោមនស្ស ដោយឋានៈណា បុគ្គលនោះតែងទទួលបាបច្រើន ដោយឋានៈនេះជាគម្រប់ពីរ បុគ្គលនោះនិយាយយ៉ាងនេះថា អ្នកទាំងឡាយចូរទៅសម្លាប់សត្វនេះ ដោយឋានៈណា បុគ្គលនោះតែងទទួលនូវបាបច្រើន ដោយឋានៈនេះ ជាគម្រប់ ៣ សត្វនោះកាលដែលគេកំពុងសម្លាប់ក៏ទទួលនូវទុក្ខទោមនស្ស ដោយឋានៈណា បុគ្គលតែងទទួលបាបច្រើន ដោយឋានៈនេះជាគម្រប់ ៤ បុគ្គលនោះធ្វើឲ្យគេតិះដៀល តថាគត ឬសាវករបស់តថាគត ដោយអកប្បិយមំសៈ ( សាច់មិនសមគួរ ) ដោយឋានៈណា បុគ្គលនោះតែងទទួលបាបច្រើន ដោយឋានៈនេះជាគម្រប់ ៥ ម្នាលជីវកៈ បុគ្គលណាសម្លាប់សត្វចំពោះតថាគត ឬសាវករបស់តថាគត បុគ្គលនោះ តែងទទួលបាបច្រើន ដោយឋានៈទាំង ៥ យ៉ាងនេះឯង ។

[ ៦១ ] លុះព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ទើបជីវកកោមារភច្ច ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុឆាន់តែអាហារជាកប្បិយៈហ្ន៎ បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុឆាន់តែអាហារដែលមិនមានទោសហ្ន៎ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់

បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ( ភ្លឺច្បាស់ណាស់ ) ដូចជាបុរសចាប់បើករបស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ឬដូចជាបុរសបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះដូចជាបុរសប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាបុរសកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានចក្ខុ មើលឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះមានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណៈស្មើដោយជីវិត ក្នុងថ្ងៃនេះជាដើម ។

## ជីវកសូត្រទី ៥ ចប់

# អដ្ឋកថា

## ជីវកសូត្រទី ៥

[ ៥៦ ] ជីវកសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ ព្រះបាលីថា **ជីវកស្ស កោមារភច្ចស្ស អម្ពវនេ** ដែលឈ្មោះថា ជីវក ព្រោះមានជីវិតនៅឡើយ ។ ដែលឈ្មោះថា កោមារភច្ច ព្រោះព្រះរាជកុមារចិញ្ចឹម ដូចដែលលោកពោលថា ព្រះកុមារ គឺសំដៅដល់អភយរាជកុមារ ដែលត្រាស់សួរថា នែលោក នុ៎ះជាអ្វី ទើបហ្វូងក្អែកចោមរោមដេរដាស ។ ពួករាជបុរសទូលថា ទារកព្រះអង្គ ព្រះរាជាត្រាស់ថា នៅមានជីវិតឬ ឆ្លើយថា នៅមានជីវិតទេ ព្រះអង្គ ទើបត្រាស់ឲ្យនាំទារកចូលវាំង ប្រគល់ឲ្យមេដោះចិញ្ចឹម ។ ទើបមនុស្សទាំងឡាយតាំងឈ្មោះទារកនោះថា ជីវក ព្រោះនៅរស់នៅឡើយ និងតាំងរហ័សនាមថា កោមារភច្ច ព្រោះព្រះរាជកុមារចិញ្ចឹម ។ ក្នុងព្រះសូត្រនេះ មានសេចក្ដីសង្ខេបដូចពោលមកនេះ ឯរឿងដោយពិស្ដារ មកក្នុងជីវកវត្ថុក្ខន្ធកវិន័យ សូម្បីពាក្យវិនិច្ឆ័យរឿងពេទ្យជីវកកោមារភច្ចនោះ លោកក៏បានពោលហើយ ក្នុងអដ្ឋកថាព្រះវិន័យ ឈ្មោះ សមន្តបាសាទិកា ។ ទេព្យជីវកកោមារភច្ចនេះ ថ្វាយព្រះឱសថបញ្ចុះតិចៗ សម្រកព្រះកាយដែលច្រើនទៅដោយទោសរបស់ព្រះមានព្រះភាគ ហើយតាំងនៅក្នុងសោតាបត្តិផល ពេលចប់អនុមោទនា ថ្វាយគូសំពត់ដែលបានមកអំពីដែនសិវេយ្យ ។ ត្រិះរិះថា អញត្រូវទៅគាល់បម្រើព្រះពុទ្ធអង្គ មួយថ្ងៃ ២-៣ ដង តែវត្តវេឡុវ័ននេះនៅឆ្ងាយពេក ចម្ការ

ស្វាយរបស់អញនៅជិតជាង ណ្ហើយចុះ អញនឹងធ្វើវិហារថ្វាយព្រះមានព្រះភាគ ក្នុងចម្ការស្វាយរបស់អញនេះឯង ដូច្នោះ ទើបឲ្យសាងទីសម្ងំ កុដិ និងមណ្ឌបជាដើម សម្រាប់សម្រាកពេលយប់ និងពេលថ្ងៃ សាងព្រះគន្ធកុដិដែលសមគួរដល់ព្រះមានព្រះភាគ ក្នុងសួនអម្ពវ័ននោះ ធ្វើកំពែងពណ៌ស្ពឹកឈើក្រហម កម្ពស់ ១៨ ហត្ថ ព័ទ្ធសួនអម្ពវ័ន អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយភត្តាហារ និងចីវរហើយ ប្រួចទក្ខិណោទក ថ្វាយវិហារ លោកសំដៅយកសួនអម្ពវ័ននោះ ទើបពោលថា **ជីវកស្ស កោមារ-ភច្ចស្ស អម្ពវនេ** ដូច្នេះ ។

បទថា **អារភន្តិ** ប្រែថា សម្លាប់ ។ បទថា **ឧទ្ទិស្ស កតំ** ប្រែថា ធ្វើឧទ្ទិស ។ បទថា **បដិច្ច កម្មំ** ប្រែថា ធ្វើចំពោះខ្លួន ។ម្យ៉ាងទៀត បទថា **បដិច្ច កម្មំ** នេះ ជាឈ្មោះនៃនិមិត្តកម្ម ។ កម្មដែលអាស្រ័យខ្លួន ជាហេតុធ្វើ មាននៅក្នុងសាច់នោះ ហេតុនោះ ទើបលោកអធិប្បាយថា កម្ម មានចំពោះអាស្រ័យសាច់ ។ លទ្ធិ គឺការជឿរបស់អ្នកទាំងនោះ មានយ៉ាងនេះថា បុគ្គលណាបរិភោគសាច់យ៉ាងនោះ បុគ្គលនោះ ត្រូវជាអ្នកទទួលផល កម្មនោះផង បាណាឃាតកម្មផង ទើបមានដល់បុគ្គលនោះ ដូចសម្លាប់ឯងដែរ ។ បទថា **ធម្មស្ស ច អនុធម្មំ ព្យាករោន្តិ** សេចក្តីថា រមែងពោលហេតុតាមហេតុ ដែលព្រះមានព្រះភាគត្រាស់ក្នុងពាក្យនោះ ការបរិភោគសាច់ដោយចំណែក ៣ ឈ្មោះថា ហេតុ ការព្យាករយ៉ាងនោះ នៃមហាជន ឈ្មោះថាតាមហេតុ ។ តែព្រះមានព្រះភាគ មិនសោយសាច់ដែលគេធ្វើចំពោះ ។

ព្រោះដូច្នោះ សេចក្តីនោះ មិនឈ្មោះថា ហេតុ ។ ការធ្វើយ៉ាងនោះនៃពួកតិរ្ថិយ ក៏មិនឈ្មោះថា តាមហេតុ ។ បទថា **សហធម្មិកោ វាទានុវាទោ** សេចក្តីថា ការពោល ឬការពោលតាមនៃពួកលោកមានហេតុ ដោយហេតុដែលអ្នកដទៃពោលហើយ ជាហេតុដែលអ្នកប្រាជ្ញទាំងឡាយគប្បីតិះដៀលនូវវាទៈណាមួយ តិចតួចឬហ្ន៎ លោកអធិប្បាយថា ហេតុដែលគប្បីតិះដៀលក្នុងវាទៈនៃពួកលោក រមែងមិនមានដោយអាការទាំងអស់ឬ ។

[ ៥៧ ] បទថា **អព្ភាចិក្ខន្តិ** ប្រែថា ពោលសង្កត់សង្កិន គឺពោលបង្កាច់ ។ បទថា **ឋានេហិ** គឺដោយហេតុទាំងឡាយ ។

បណ្តាចំណែកទាំង ៣ មានចំណែកដែលឃើញហើយជាដើម ដែលគេសម្លាប់ម្រឹគ និងត្រី ហើយយកមកប្រគេនភិក្ខុទាំងឡាយ ឈ្មោះថា ចំណែកដែលឃើញហើយ ។ បានឮថា ឈ្មោះថា ចំណែកដែលសង្ស័យមាន ៣ យ៉ាង ចំណែកដែលសង្ស័យថា បានឃើញមក ចំណែកដែលសង្ស័យថា បានឮមក និងចំណែកដែលសង្ស័យក្រៅអំពីទាំង ២ យ៉ាងនោះ ។ ក្នុងចំណែកដែលសង្ស័យទាំង ៣ នោះ មានវិនិច្ឆ័យសរុបដូច្នេះថា

ភិក្ខុទាំងឡាយក្នុងសាសនានេះ ឃើញមនុស្សទាំងឡាយកាន់ជង់ និងសំណាញ់ជាដើម កំពុងចេញទៅអំពីស្រុក ឬកំពុងត្រាច់ទៅក្នុងព្រៃអំពីព្រឹក កាលភិក្ខុទាំងនោះ ចូលទៅបិណ្ឌបាតក្នុងស្រុកនោះ មនុស្សទាំងនោះ ក៏នាំបិណ្ឌបាតដែលមានសាច់ និងត្រីប្រគេន ភិក្ខុទាំងនោះក៏សង្ស័យ ដោយការឃើញនោះថា សាច់ និងត្រី គេធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយឬហ្ន៎

នេះឈ្មោះថា សង្ស័យដោយឃើញ ទទួលអាហារដែលសង្ស័យ ដោយការឃើញនោះ មិនគួរ ។ អាហារណា ភិក្ខុមិនបានសង្ស័យយ៉ាងនោះ ទទួលអាហារនោះ ក៏គួរ ។ បើទាយកទាំងនោះសួរថា បពិត្រលោកម្ចាស់ ហេតុអ្វីទើបលោកម្ចាស់មិនទទួល ស្តាប់ពាក្យរបស់ពួកភិក្ខុហើយ ក៏ពោលថា អាហារនេះ ពួកខ្ញុំមិនបានធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយទេ តែពួកខ្ញុំធ្វើដើម្បីប្រយោជន៍ដល់ខ្លួនឯង ឬដើម្បីប្រយោជន៍ដល់ពួករាជការជាដើមឯណោះទេ ទទួលអាហារនោះ ក៏គួរ ។

ភិក្ខុទាំងឡាយ មិនឃើញយ៉ាងនោះឡើយ តែបានឮថា មនុស្សទាំងឡាយកាន់ជង់ និងសំណាញ់ជាដើមចេញអំពីស្រុកទៅ ឬត្រាច់ទៅក្នុងព្រៃ ស្អែកឡើង កាលភិក្ខុទាំងនោះ ចូលទៅបិណ្ឌបាតក្នុងស្រុកនោះ មនុស្សទាំងនោះក៏នាំបិណ្ឌបាតដែលមានសាច់ និងត្រី មកប្រគេនភិក្ខុទាំងនោះ ភិក្ខុទាំងនោះក៏សង្ស័យដោយការបានឮនោះថា ជនទាំងនោះ ធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយឬហ្ន៎ នេះឈ្មោះថា សង្ស័យដោយបានឮមក ទទួលអាហារនោះមិនគួរ អាហារណាមិនបានសង្ស័យយ៉ាងនោះ ទទួលអាហារនោះ ក៏គួរ ។ តែបើមនុស្សទាំងនោះសួរថា បពិត្រលោកម្ចាស់ ហេតុអ្វី ទើបលោកម្ចាស់មិនទទួល ស្តាប់ចម្លើយរបស់ភិក្ខុទាំងនោះហើយ ក៏ពោលថា អាហារនេះ ពួកខ្ញុំមិនបានធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយទេ តែពួកខ្ញុំធ្វើដើម្បីប្រយោជន៍ដល់ខ្លួនឯង ឬដើម្បីប្រយោជន៍ដល់ពួកខ្ញុំរាជការជាដើមឯណោះទេតើ ទទួលអាហានោះ ក៏គួរ ។

ម្យ៉ាងទៀត ភិក្ខុមិនឃើញ មិនបានឮមក កាលភិក្ខុទាំងនោះចូលទៅបិណ្ឌបាតក្នុងស្រុកនោះ មនុស្សទាំងឡាយទទួលយកបាត្រទៅ រៀបចំបិណ្ឌ-បាត ដែលមានសាច់ និងត្រី នាំទៅប្រគេន ភិក្ខុទាំងនោះក៏សង្ស័យថា គេធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយឬហ្ន៎ នេះឈ្មោះថាសង្ស័យក្រៅអំពី ២ យ៉ាងនោះ ។ ទទួលអាហារនោះ ក៏មិនគួរ អាហារណាមិនបានសង្ស័យយ៉ាងនោះ ទទួលអាហារនោះ គួរ ។ បើមនុស្សទាំងនោះសួរថា បពិត្រលោកម្ចាស់ ហេតុអ្វី ទើបលោកម្ចាស់មិនទទួល ស្តាប់ចម្លើយរបស់ពួកភិក្ខុហើយក៏ពោលថា បពិត្រលោកម្ចាស់ អាហារនេះ ពួកខ្ញុំមិនបានធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយទេ ខ្ញុំធ្វើដើម្បីប្រយោជន៍ដល់ខ្លួនឯង ឬដើម្បីប្រយោជន៍ខ្ញុំរាជការឯណោះទេ ឬថា ពួកខ្ញុំបានបវត្តមំសៈ គឺសាច់ដែលបានស្រាប់ហើយ ជារបស់កប្បិយទាំងអស់ ទើបរៀបចំដើម្បីប្រយោជន៍ដល់ភិក្ខុទាំង-ឡាយ ទទួលអាហារនោះ គួរ ។ ក្នុងអាហារដែលគេធ្វើដើម្បីប្រយោជន៍ដល់បេតកិច្ច សម្រាប់អ្នកដែលស្លាប់ទៅហើយ ឬដើម្បីប្រយោជន៍ដល់មង្គលជាដើម ក៏ន័យនេះដូចគ្នា ។ ពិតហើយ អាហារណាមួយ គេមិនបានធ្វើដើម្បីភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក៏មិនបានសង្ស័យក្នុងអាហារណា ទទួលអាហារនោះ គ្រប់យ៉ាង ក៏គួរ ។ តែបើអាហារគេឧទ្ទិសភិក្ខុទាំងឡាយក្នុងវត្តមួយ ភិក្ខុទាំងនោះមិនដឹងថា គេធ្វើដើម្បីប្រយោជន៍ខ្លួន ភិក្ខុដទៃដឹង ភិក្ខុពួកណាដឹង អាហារនោះ ក៏មិនគួរដល់ភិក្ខុទាំងនោះ គួរដល់ភិក្ខុក្រៅអំពីនេះ ភិក្ខុពួកដទៃមិនដឹង ភិក្ខុពួកនោះប៉ុណ្ណោះដែលដឹង អាហារនោះក៏មិនគួរ

ដល់ភិក្ខុទាំងនោះ គួរដល់ភិក្ខុដទៃ សូម្បីភិក្ខុទាំងនោះដឹងថា គេធ្វើដើម្បីប្រយោជន៍ដល់ពួកយើង សូម្បីភិក្ខុពួកដទៃក៏ដឹងថា គេធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងនោះ អាហារនោះ ក៏មិនគួរដល់ភិក្ខុទាំងអស់ ភិក្ខុទាំងអស់ក៏មិនដឹង ក៏គួរដល់ភិក្ខុទាំងអស់នោះឯង ។

បណ្ដាសហធម្មិក ៥ រូប អាហារដែលគេធ្វើឧទ្ទិសដល់ភិក្ខុរូបណាមួយរមែងមិនសមគួរដល់សហធម្មិកគ្រប់រូប បើបុគ្គលសម្លាប់សត្វឧទ្ទិសចំពោះភិក្ខុមួយរូប ហើយដាក់ពេញបាត្រ ដោយសាច់សត្វនោះប្រគេន ភិក្ខុនោះក៏ដឹងថា គេធ្វើដើម្បីប្រយោជន៍ដល់ខ្លួន កាលទទួលហើយ ក៏ប្រគេនដល់ភិក្ខុអន្តដទៃ ភិក្ខុនោះក៏ឆាន់ដោយការជឿភិក្ខុនោះ សួរថា ភិក្ខុណាត្រូវអាបត្តិ ឆ្លើយថា មិនត្រូវអាបត្តិទាំង ២ រូប ព្រោះថា អាហារណាគេធ្វើចំពោះដល់លោក លោកក៏មិនត្រូវអាបត្តិ ព្រោះលោកមិនឆាន់អាហារនោះ ឯមួយរូបទៀតឆាន់ ក៏មិនត្រូវអាបត្តិ ព្រោះមិនដឹង ក្នុងការទទួលកប្បិយមំសៈ មិនជាអាបត្តិ ។ ភិក្ខុមិនដឹងថា ជាឧទ្ទិសមំសៈ ហើយដឹងជាខាងក្រោយ គឺ ឆាន់រួចហើយ ក៏មិនមានកិច្ចក្នុងការសម្ដែងអាបត្តិ ។ ឯភិក្ខុមិនដឹងថា ជាអកប្បិយ-មំសៈ មកដឹងឯក្រោយឆាន់ហើយ ត្រូវសម្ដែងអាបត្តិ ភិក្ខុដឹងថា ជាឧទ្ទិសមំសៈ ហើយឆាន់ ប្រព្រឹត្តជាអាបត្តិ សូម្បីភិក្ខុមិនដឹងថា ជាអកប្បិយមំសៈហើយឆាន់ ក៏ត្រូវអាបត្តិដូចគ្នាទាំងអស់ ព្រោះដូច្នោះ ភិក្ខុអ្នកខ្លាចអាបត្តិសូម្បីកំណត់រូបជាអារម្មណ៍ សួរហើយ សឹមទទួលមំសៈ ឬលោកទទួលដោយគិតថា នឹងសួរហើយឆាន់ ក្នុងវេលាឆាន់ សួរហើយសឹមឆាន់ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជារបស់ដែលជីនបានលំបាក ពិតហើយ សាច់ខ្លាឃ្មុំ ក៏ដូចគ្នានឹងសាច់ជ្រូក សូម្បីសាច់ខ្លាដំបងជាដើម ក៏ដូចគ្នានឹងសាច់ម្រឹគ ព្រោះដូច្នោះ ទើបអាចារ្យទាំងឡាយពោលថា សួរហើយសឹមទទួល ទើបគួរ ។ ពាក្យថា មិនឃើញ គឺមិនឃើញម្រឹគដែលគេសម្លាប់ហើយយកមកដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ ។ ពាក្យថា មិនបានឮ គឺមិនបានឮថា គេសម្លាប់ហើយ យកមកដើម្បីប្រយោជន៍ភិក្ខុទាំងឡាយ ។ ពាក្យថា មិនសង្ស័យ គឺមិនសង្ស័យដោយអំណាចឃើញជាដើម ។ បទថា **បរិភោគន្តិ វទាមិ** សេចក្តីថា សាច់ដែលបរិសុទ្ធដោយហេតុ ៣ ប្រការនេះ ឈ្មោះថា បរិសុទ្ធដោយចំណែក ៣ ពិតហើយ ការឆាន់មំសៈដែលបរិសុទ្ធដោយចំណែក ៣ នោះ ដូចគ្នានឹងការឆាន់សម្ល និងបន្លែត្រាំ ដែលកើតឯងក្នុងព្រៃ ភិក្ខុនៅដោយមេត្តា ឆាន់មំសៈដូច្នោះ រមែងមិនមានទោស ព្រោះដូច្នោះ ទើបតថាគតពោលថា មំសៈនោះគួរឆាន់បាន ។

[ ៥៨-៥៩ ] ឥឡូវនេះ ដើម្បីទ្រង់សម្តែងភាពដែលភិក្ខុនៅដោយមេត្តា មិនមានទោស ក្នុងការឆាន់មំសៈដែលមានសភាពបែបនោះ ទើបត្រាស់ថា **ឥធ ជីវក ភិក្ខុ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ សូម្បីព្រះមានព្រះភាគទ្រង់មិនបានកំណត់ ហើយត្រាស់ថា **ភិក្ខុ** ក៏ពិត ដែលពិតនោះ គប្បីជ្រាបថា ទ្រង់សំដៅដល់ព្រះអង្គនោះឯង ទើបត្រាស់យ៉ាងនេះ ពិតហើយ ព្រះមានព្រះភាគ ទ្រង់សំដៅដល់ព្រះអង្គប៉ុណ្ណោះ ក្នុង ៣ អាគតដ្ឋាន គឺមហាវច្ឆគោត្តសូត្រ ក្នុងចង្កីសូត្រ និងក្នុងសូត្រនេះ ។ ក្នុងអនង្គណសូត្រខាង

ដើម ត្រង់បទថា **បណីតេន បិណ្ឌបាតេន** លោកសំដៅយកបិណ្ឌបាតដែលមានតម្លៃច្រើន គ្រប់ប្រភេទ ឈ្មោះថា បិណ្ឌបាតដ៏ប្រណីត តែក្នុងសូត្រនេះសំដៅយកមំសៈដែលឆ្អិន ។ បទថា **អគធិតោ** គឺមិនល្មោភដោយការចង់បាន ។ បទថា **អមុច្ឆិតោ** គឺមិនវង្វេងដោយការវង្វេង ដោយការចង់បាន ។ បទថា **អនជ្ឈាបន្នោ** គឺមិនត្រូវការចង់បានគ្របសង្កត់ អធិប្បាយថា មិនដូចក្អែកដែលត្រូវការត្របាក់សាច់ទាំងអស់លេបចូលក្នុងក ដោយការចឹកតែម្តងប៉ុណ្ណោះ ។ បទថា **អាទីនវទស្សាវី** គឺឃើញទោស ដោយន័យជាដើមថា អាហារនេះនៅក្នុងពោះមួយយប់ ហើយក៏ចេញទៅតាមមុខដំបៅទាំង ៩ ។ បទថា **និស្សរណបញ្ញោ បរិភុញ្ជតិ** គឺកំណត់ដោយបញ្ញាថា ការបរិភោគអាហារក៏ដើម្បីប្រយោជន៍យ៉ាងនេះ ហើយបរិភោគ ។ បទថា **អត្តព្យាពាធាយ វា ចេតេតិ** គឺគិតដើម្បីធ្វើទុក្ខដល់ខ្លួន ។ បទថា **សុតំ មេ តំ** គឺរឿងនោះ ខ្ញុំព្រះអង្គបានឮមក ទើបជីវកពោលថា អំពីមុនរឿងនោះ ខ្ញុំត្រឹមតែបានឮមកប៉ុណ្ណោះ ។ បទថា **សចេ ខោ តេ ជីវក ឥទំ សន្ធាយ ភាសិតំ** សេចក្តីថា ម្នាលជីវក មហាព្រហ្មលះព្យាបាទជាដើម ដោយវិក្ខម្ភនប្បហាន លះដោយអំណាចការសង្កត់ ដោយហេតុនោះ ទើបមហាព្រហ្មនោះ ឈ្មោះថា នៅដោយមេត្តា បើអ្នកពោលសំដៅដល់សេចក្តីនេះ ដោយសមុច្ឆេទ-ប្បហានរបស់តថាគត កាលបើដូច្នេះ តថាគតក៏អនុមតិពាក្យនេះរបស់អ្នក ពេទ្យជីវកក៏ទទួល កាលនោះ ព្រះមានព្រះភាគ ទ្រង់ពណ៌នាឲ្យក្រៃលែងឡើងទៅ ដោយអំណាចព្រហ្មវិហារដ៏សេសដល់ទេព្យជីវកនោះ ទើបត្រាស់

ថា **ឥធ ជីវក ភិក្ខុ** ដូច្នេះជាដើម ពាក្យក្រៅអំពីនោះ មានអត្ថងាយយល់ទាំងអស់ហើយ ។

[ ៦០ ] អត្ថថា **យោ ខោ ជីវក** នេះ ជាអនុសន្ធិដែលចែកចេញដោយឡែក ពិតហើយ ក្នុងឋានៈនេះ ព្រះមានព្រះភាគទ្រង់បិទទ្វារ ទ្រង់សម្តែងការអោណិតអាសូរសត្វ បើមនុស្សទាំងឡាយប្រគេនបិណ្ឌបាត មានរសប្រណីតដល់ភិក្ខុណាមួយនោះ យ៉ាងនេះហើយ ត្រឡប់បានទូវសុគតិអស់សែនកប្បសោត បុគ្គលនោះ ក៏គប្បីធ្វើកម្មឯណាមួយ សូម្បីធ្វើអ្នកដទៃឲ្យស្លាប់ ហើយប្រគេនបិណ្ឌបាតមានរសបាន ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់បដិសេធសេចក្តីនោះ ទើបត្រាស់ថា **យោ ខោ ជីវក តថាគតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ឥមិនា បឋមេន ឋានេន** បានដល់ ដោយហេតុទី ១ ដែលត្រឹមតែជាពាក្យបញ្ជាប៉ុណ្ណោះនេះមុន ។ បទថា **គលប្បវេធកេន** បានដល់ សត្វដែលត្រូវខ្សែបង់កអូសមក ឬសត្វដែលមានកត្រូវចងអូសមក ។ បទថា **អារភិយមានោ** បានដល់ ត្រូវគេធ្វើឲ្យស្លាប់ ។ បទថា **អកប្បិយេន អសាទេតិ** សេចក្តីថា បុគ្គលដែលឲ្យភិក្ខុឆាន់សាច់ខ្លាឃ្មុំ ដោយសម្គាល់ថា សាច់ជ្រូក ឆាន់សាច់ខ្លាដំបង ដោយសម្គាល់ថា សាច់ម្រឹគ ក៏ពោលចាក់ដោតថា លោកម្ចាស់ ឈ្មោះថាសមណៈ ឬ លោកម្ចាស់ ឆាន់អកប្បិយមំសៈ ។ ឯមនុស្សពួកណាដឹងថា សាច់ខ្លាឃ្មុំ ដូចសាច់ជ្រូក សាច់ខ្លាដំបងដូចសាច់ម្រឹគ ក្នុងកាលដែលរកអាហារបានលំបាក ឬប្រើក្នុងការព្យាបាលជំងឺ ក៏បានពោលថា នេះសាច់ជ្រូក នេះសាច់

ម្រឹគ ឲ្យភិក្ខុធាន់ ដោយអធ្យាស្រ័យអនុគ្រោះ ព្រះមានព្រះភាគ ទ្រង់មិនបានសំដៅដល់មនុស្សទាំងនោះ ត្រាស់ពាក្យនេះ ព្រោះមនុស្សទាំងនោះ តែងបានបុណ្យច្រើន បុគ្គលនេះពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ថាជាសរណៈ ឈ្មោះថា ជាអរិយ-សាវក ជាអ្នកជួបនូវផល ជាអ្នកដឹងពាក្យទូន្មាន ជាអ្នកឃើញសច្ចៈហើយ ឯពេទ្យជីវកឈមចុះកាន់ធម្មទេសនានេះ កើតសេចក្ដីជ្រះថ្លា ធ្វើការសរសើរ គឺអនុមោទនាធម្មកថា ទើបពោលយ៉ាងនេះ ។ ពាក្យក្រៅអំពីនេះ ក្នុងទីគ្រប់អន្លើ ងាយយល់ទាំងអស់ហើយ ៕

**ជីវកសូត្រ ចប់**

**សូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ឧទាលិវាទសូត្រទី ៦

[ ៦២ ] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងបាវារិកម្ពវ័ន ជិតស្រុកនាលន្ទា ។ សម័យនោះឯង និគ្គន្ថនាដបុត្ត នៅអាស្រ័យក្នុងស្រុកនាលន្ទា ជាមួយនឹងនិគ្គន្ថបរិស័ទជាច្រើន ។ គ្រានោះ និគ្រន្ថឈ្មោះទីឃតបស្សី ត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងស្រុកនាលន្ទា លុះត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាបច្ឆាភត្តហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងបាវារិកម្ពវ័ននោះ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏ឋិតនៅក្នុងទីសមគួរ ។ លុះទីឃតបស្សីនិគ្រន្ថ ឋិតនៅក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា នែទីឃតបស្សី អាសនៈមានគ្រប់គ្រាន់ បើអ្នកត្រូវការ ចូរអង្គុយចុះ ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ទើបទីឃតបស្សីនិគ្រន្ថ កាន់យកអាសនៈទាបមួយ អង្គុយក្នុងទីសមគួរ ។

[ ៦៣ ] លុះទីឃតបស្សីនិគ្រន្ថអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលតបស្សី ចុះនិគ្គន្ថនាដបុត្ត បញ្ញត្តកម្មក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមានប៉ុន្មាន ។ ទីឃតបស្សីតបថា អាវុសោគោតម និគ្គន្ថនាដបុត្តមិនធ្លាប់បញ្ញត្តនូវកម្ម ថាកម្មដូច្នេះឡើយ អាវុសោគោតម និគ្គន្ថនាដបុត្តធ្លាប់បញ្ញត្តនូវទណ្ឌៈ ថាទណ្ឌៈ ប៉ុណ្ណោះឯង ។

ម្នាលតបស្សី ចុះនិគ្គន្ថនាដបុត្ត តែងបញ្ញត្តនូវទណ្ឌៈប៉ុន្មានយ៉ាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមានប៉ុន្មាន ។ អាវុសោគោតម និគ្គន្ថនាដបុត្តតែងបញ្ញត្តនូវទណ្ឌៈក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមាន ៣ យ៉ាង គឺកាយទណ្ឌៈ ១ វចីទណ្ឌៈ ១ មនោទណ្ឌៈ ១ ។ ម្នាលតបស្សី ចុះកាយទណ្ឌៈផ្សេង វចីទណ្ឌៈផ្សេង មនោទណ្ឌៈផ្សេង ឬក៏ដូចគ្នា ។ អាវុសោគោតម កាយទណ្ឌៈផ្សេង វចីទណ្ឌៈផ្សេង មនោទណ្ឌៈផ្សេង មិនដូចគ្នាទេ ។ ម្នាលតបស្សី បណ្ដាទណ្ឌៈទាំង ៣ នេះ ដែលអ្នកចែកហើយយ៉ាងនេះ ញែកហើយយ៉ាងនេះ និគ្គន្ថនាដបុត្តតែងបញ្ញត្តនូវទណ្ឌៈណា ដែលមានទោសធំជាងគេ ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម កាយទណ្ឌៈ ឬវចីទណ្ឌៈ ឬមនោទណ្ឌៈ ។ អាវុសោគោតម បណ្ដាទណ្ឌៈទាំង ៣ នេះ ដែលខ្ញុំព្រះអង្គចែកហើយយ៉ាងនេះ ញែកហើយយ៉ាងនេះ និគ្គន្ថនាដបុត្តតែងបញ្ញត្តនូវកាយទណ្ឌៈថា មានទោសធំជាងគេ ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម មិនបញ្ញត្តនូវវចីទណ្ឌៈ និងមនោទណ្ឌៈ ថាមានទោសធំដូច្នោះទេ ។ ម្នាលតបស្សី អ្នកនិយាយថា កាយទណ្ឌៈដូច្នេះឬ ។ អាវុសោគោតម ខ្ញុំព្រះអង្គនិយាយថា កាយទណ្ឌៈដូច្នេះ ។ ម្នាលតបស្សី អ្នកនិយាយថា កាយទណ្ឌៈ ដូច្នេះឬ ។ អាវុសោគោតម ខ្ញុំព្រះអង្គនិយាយថា កាយទណ្ឌៈ ដូច្នេះ ។ ម្នាលតបស្សី អ្នកនិយាយថា កាយទណ្ឌៈ ដូច្នេះឬ ។ អាវុសោគោតម ខ្ញុំព្រះអង្គនិយាយថា កាយទណ្ឌៈ ដូច្នេះ ។ ព្រះមានព្រះភាគទ្រង់ញ៉ាំងទីឃតបស្សីនិគ្រន្ថ ឲ្យឋិត

នៅទីឯក្នុងកថាវត្ថុនេះ ជាគម្រប់ ៣ ដង ដោយប្រការដូច្នេះ ។

[ ៦៤ ] កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ទីឃតបស្សីនិគ្រន្ថ ក៏និយាយពាក្យនេះនឹងព្រះមានព្រះភាគថា អាវុសោគោតម ព្រះអង្គទ្រង់បញ្ញត្តទណ្ឌៈ ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមានប៉ុន្មាន ។ ម្នាលតបស្សី តថាគតមិនធ្លាប់បញ្ញត្តនូវទណ្ឌៈ ថាទណ្ឌៈដូច្នេះទេ ម្នាលតបស្សី តថាគតធ្លាប់បញ្ញត្តតែកម្ម ថាកម្មប៉ុណ្ណោះឯង ។ អាវុសោគោតម ចុះព្រះអង្គទ្រង់បញ្ញត្តកម្មមានប៉ុន្មាន ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមានប៉ុន្មាន ។ ម្នាលតបស្សី តថាគតបញ្ញត្តនូវកម្ម ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ថាមាន ៣ យ៉ាង គឺកាយកម្ម ១ វចីកម្ម ១ មនោកម្ម ១ ។ អាវុសោគោតម ចុះកាយកម្មផ្សេង វចីកម្មផ្សេង មនោកម្មផ្សេង ឬអ្វី ។ ម្នាលតបស្សី កាយកម្មផ្សេង វចីកម្មផ្សេង មនោកម្មផ្សេង ។ អាវុសោគោតម បណ្តាកម្មទាំង ៣ នេះ ដែលព្រះអង្គចែកហើយយ៉ាងនេះ ញែកហើយយ៉ាងនេះ ព្រះអង្គទ្រង់បញ្ញត្តកម្មណាថា មានទោសធំជាងគេ ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម តើកាយកម្ម ឬវចីកម្ម ឬក៏មនោកម្ម ។ ម្នាលតបស្សី បណ្តាកម្មទាំង ៣ នេះ ដែលតថាគតចែកហើយយ៉ាងនេះ ញែកហើយយ៉ាងនេះ តថាគតបញ្ញត្តមនោកម្ម ថាមានទោសធំជាងគេ ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម មិនបញ្ញត្តកាយកម្ម និងវចីកម្ម ថាមានទោសធំទេ ។ អាវុសោគោតម ព្រះអង្គថាមនោកម្មឬ ។ ម្នាលតបស្សី តថាគតថា មនោកម្ម ។បេ។

អាវុសោគោតម ព្រះអង្គថាមនោកម្មឬ ។ ម្នាលតបស្សី តថាគតថាមនោកម្ម ។ ទីឃតបស្សីនិគ្រន្ថ ញុំាងព្រះមានព្រះភាគឲ្យស្ថិតនៅក្នុងកថាវត្ថុនេះដរាប ៣ ដង ដោយប្រការដូច្នេះហើយ ក្រោកចាកអាសនៈ ចូលទៅរកនិគន្ថនាដបុត្ត ។

[ ៦៥ ] សម័យនោះឯង និគន្ថនាដបុត្តកំពុងអង្គុយជាមួយនឹងគិហិបរិស័ទជាច្រើន អ្នកនៅក្នុងស្រុកពាលកៈ មានឧបាលិគហបតីជាប្រធាន ។ និគន្ថនាដបុត្ត បានឃើញទីឃតបស្សីនិគ្រន្ថ ដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏និយាយនឹងទីឃតបស្សីនិគ្រន្ថ ដោយពាក្យដូច្នេះថា តបស្សី ចុះអ្នកឯងទើបមកពីណាទាំងថ្ងៃម្ល៉េះ ។ ទីឃតបស្សីតបថា បពិត្រលោកដ៏ចម្រើន ខ្ញុំមកអំពីសម្នាក់ព្រះសមណគោតមឯណោះ ។ និគន្ថនាដបុត្តសួរថា នែតបស្សី ចុះអ្នកមានកថាសល្លាបៈបន្តិចបន្តួច ជាមួយនឹងព្រះសមណគោតមដែរឬ ។ បពិត្រលោកដ៏ចម្រើន ខ្ញុំមានកថាសល្លាបៈបន្តិចបន្តួចជាមួយនឹងព្រះសមណគោតមដែរ ។ នែតបស្សី អ្នកមានកថាសល្លាបៈបន្តិចបន្តួច ជាមួយនឹងព្រះសមណគោតម តើដូចម្តេច ។ ទើបទីឃតបស្សីនិគ្រន្ថ ក៏រៀបរាប់កថាសល្លាបៈ ជាមួយនឹងព្រះមានព្រះភាគទាំងអស់ដល់និគន្ថនាដបុត្ត ។ កាលបើទីឃតបស្សីនិគ្រន្ថនិយាយយ៉ាងនេះហើយ និគន្ថនាដបុត្តនិយាយនឹងទីឃតបស្សីនិគ្រន្ថដូច្នេះថា នែតបស្សី ពីរោះណាស់ៗ សាវ័កដែលជាអ្នកចេះដឹងអាចដឹងច្បាស់សាសនារបស់គ្រូដោយប្រពៃ ហើយព្យាករពាក្យនោះយ៉ាងណា ទីឃតបស្សីនិគ្រន្ថបានព្យាករចំពោះព្រះសមណគោតម ក៏យ៉ាងនោះឯង ក៏មនោទណ្ឌៈជាសភាវៈថោកថយ យកមកប្រៀបធៀបនឹងកាយទណ្ឌៈដ៏ថ្លៃថ្លា

នេះឲ្យវិសេសវិសាលជាងយ៉ាងនេះដូចម្តេចបាន គឺកាយទណ្ឌៈហ្នឹងឯង ជារបស់មានទោសធំជាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ឯវចីទណ្ឌៈ និងមនោទណ្ឌៈ នឹងមានទោសធំដូច្នោះក៏ទេ ។

[ ៦៦ ] កាលបើនិគ្គន្ថនាដបុត្តនិយាយយ៉ាងនេះហើយ ទើបឧបាលិគហបតីនិយាយនឹងនិគ្គន្ថនាដបុត្តដូច្នេះថា បពិត្រលោកដ៏ចម្រើន ទីឃតបស្សីនិយាយពាក្យនេះពីរោះណាស់ៗ សាវ័កដែលជាអ្នកចេះដឹង អាចដឹងច្បាស់នូវសាសនារបស់គ្រូដោយប្រពៃ ហើយព្យាករពាក្យនោះ យ៉ាងណា ទីឃតបស្សីដ៏ចម្រើន បានព្យាករចំពោះព្រះសមណគោតមយ៉ាងនោះឯង ក៏មនោទណ្ឌៈជារបស់ថោកថយ យកមកប្រៀបធៀបនឹងកាយទណ្ឌៈដ៏ថ្លៃថ្លានេះឲ្យវិសេសវិសាលជាងយ៉ាងនេះ ដូចម្តេចបាន គឺ កាយទណ្ឌៈហ្នឹងឯង ជាសភាវៈមានទោសធំជាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ឯវចីទណ្ឌៈ និងមនោទណ្ឌៈ នឹងមានទោសធំដូច្នោះក៏ទេ បពិត្រលោកដ៏ចម្រើន ណ្ហើយចុះ ខ្ញុំនឹងទៅលើកឡើងនូវវាទៈ របស់ព្រះសមណគោតម ក្នុងកថាវត្ថុនេះ បើសមណគោតម នឹងតាំងពាក្យឲ្យនៅនឹងដូចដែល ចំពោះខ្ញុំ ដូចកាលដែលតបស្សីដ៏ចម្រើនឲ្យតាំងនៅដូច្នោះ ខ្ញុំនឹងទាញកន្ត្រាក់គ្រវាត់គ្រវែងនូវវាទៈដោយវាទៈចំពោះសមណគោតម ដូចជាបុរសអ្នកមានកម្លាំង ចាប់សត្វចៀមដែលមានរោមវែង ត្រង់រោម ហើយទាញកន្ត្រាក់គ្រវាត់គ្រវែង ដូច្នោះឯងពុំនោះ ខ្ញុំនឹងទាញកន្ត្រាក់គ្រវាត់គ្រវែងនូវវាទៈ ដោយវាទៈ ចំពោះសមណ-គោតម ដូចជាបុរសអ្នកមានកម្លាំង ជាអ្នកធ្វើការងារក្នុងផ្ទះសុរា ដាក់ចុះនូវ

កន្ទេលសម្រាប់ដាក់នូវមេប្ញា ក្នុងផ្ទះធ្វើសុរា ក្នុងអន្លង់ទឹកជ្រៅ ហើយចាប់ត្រង់ជាយទាញកន្ទ្រាក់ គ្រវាត់គ្រវែងដូច្នោះឯង ពុំនោះ ខ្ញុំនឹងផ្តាប់ចុះផ្ងារឡើង បោះចោលនូវវាទៈដោយវាទៈ ចំពោះសមណគោតម ដូចជាបុរសមានកម្លាំងជាអ្នកលេងសុរាចាប់ថាសត្រង់កណ្តាប់មាត់ ផ្តាប់ចុះផ្ងារឡើង បោះចោលដូច្នោះឯង ពុំនោះសោត ខ្ញុំនឹងលេងនូវព្រះសមណគោតម ដូចគេលេងល្បែងលាងសម្បកធ្មៃ ដូចជាដំរីដែលមានអាយុ ៦០ ឆ្នាំ ចុះកាន់ស្រះដ៏ជ្រៅហើយលេងល្បែងលាងសម្បកធ្មៃដូច្នោះឯង បពិត្រលោកដ៏ចម្រើន ណ្ហើយចុះ ខ្ញុំនឹងទៅលើកឡើងនូវវាទៈរបស់ព្រះសមណគោតម ក្នុងកថាវត្ថុនេះ ។ ម្នាលគហបតី អ្នកចូរទៅលើកឡើងនូវវាទៈរបស់ព្រះសមណគោតម ក្នុងកថាវត្ថុនេះ ម្នាលគហបតី ឬអាត្មាគប្បីលើកឡើងនូវវាទៈរបស់សមណគោតមក៏បាន ទីឃតបស្សីនិគ្រន្ថក៏បាន អ្នកឯងក៏បានដែរ ។

[ ៦៧ ] កាលបើនិគ្គន្ថនាដបុត្តនិយាយយ៉ាងនេះហើយ ទើបទីឃតបស្សីនិគ្រន្ថនិយាយនឹងនិគ្គន្ថនាដបុត្តដូច្នេះថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតីគប្បីលើកឡើងនូវវាទៈរបស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះមិនពេញចិត្តខ្ញុំឡើយ បពិត្រលោកដ៏ចម្រើន ព្រោះថា ព្រះសមណគោតមជាអ្នកមានកិច្ចកល តែងដឹងនូវកិច្ចកលសម្រាប់បោកប្រាស តែងបោកប្រាសនូវពួកសាវករបស់អន្យតិ្ថយ ។ និគ្គន្ថនាដបុត្តនិយាយថា ម្នាលតបស្សី ឧបាលិគហបតីគប្បីចុះចូលជាសាវករបស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះ

ចូលជាសាវ័ករបស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនោះទើបជាទីតាំងមានមែន ម្នាលគហបតី អ្នកចូរទៅលើកឡើងនូវវាទៈរបស់ព្រះសមណគោតម ក្នុងកថាវត្ថុនោះចុះ ម្នាលគហបតី ឬអាត្មាគប្បីលើកឡើងនូវវាទៈរបស់ព្រះសមណគោតមក៏បាន ទីឃតបស្សីនិគ្រន្ថក៏បាន អ្នកឯងក៏បាន ។ ទីឃតបស្សីនិគ្រន្ថ និយាយនឹងនិគ្គន្ថនាដបុត្តដូច្នេះ ជាគម្រប់ពីរដងទៀតថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតី គប្បីលើកឡើងនូវវាទៈរបស់ព្រះសមណគោតមដោយហេតុណា ហេតុនោះមិនពេញចិត្តខ្ញុំទេ បពិត្រលោកដ៏ចម្រើន ព្រោះថា ព្រះសមណគោតម ជាអ្នកមានកិច្ចកល តែងដឹងនូវកិច្ចកលសម្រាប់បោកប្រាស តែងបោកប្រាសនូវពួកសាវ័កអន្យតិរ្ថិយ ។ ម្នាលតបស្សី ឧបាលិគហបតីគប្បីចុះចូលជាសាវ័ករបស់សមណគោតម ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះចូលជាសាវ័ករបស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនុ៎ះ ទើបជាទីតាំងមានមែន ម្នាលគហបតី អ្នកចូរទៅលើកឡើងនូវវាទៈរបស់ព្រះសមណគោតម ក្នុងកថាវត្ថុនេះចុះ ម្នាលគហបតី ឬអាត្មាគប្បីលើកឡើងនូវវាទៈរបស់ព្រះសមណគោតមក៏បាន ទីឃតបស្សីនិគ្រន្ថក៏បាន អ្នកឯងក៏បាន ។ ទីឃតបស្សីនិគ្រន្ថ និយាយនឹងនិគ្គន្ថនាដបុត្តដូច្នេះជាគម្រប់ ៣ ដងទៀតថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតី គប្បីលើកឡើងនូវវាទៈ របស់ព្រះសមណគោតមដោយហេតុណា ហេតុនុ៎ះមិនពេញចិត្តខ្ញុំទេ បពិត្រលោកដ៏ចម្រើន ព្រោះថា ព្រះសមណគោតមជាអ្នកមានកិច្ចកល តែងដឹងនូវកិច្ចកលសម្រាប់បោកប្រាស

តែងបោកប្រាសនូវពួកសាវ័ករបស់អន្យតិរ្ថិយ ។ ម្នាលតបស្សី ឧបាលិគហបតី គប្បីចុះចូលជាសាវ័ករបស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះចូលជាសាវ័ករបស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនុ៎ះ ទើបជាទីតាំងមានមែន ម្នាលគហបតី អ្នកចូរទៅលើកឡើងនូវវាទៈរបស់ព្រះសមណគោតម ក្នុងកថាវត្ថុនេះចុះ ម្នាលគហបតី ឬអាត្មាគប្បីលើកឡើងនូវវាទៈរបស់ព្រះសមណគោតមក៏បាន ទីឃតបស្សីនិគ្រន្ថក៏បាន អ្នកឯងក៏បាន ។

[ ៦៨ ] ឧបាលិគហបតី ទទួលពាក្យរបស់និគ្គន្ថនាដបុត្តថា អើលោកម្ចាស់ ហើយក្រោកអំពីទីអង្គុយ សំពះនិគ្គន្ថនាដបុត្តធ្វើប្រទក្សិណហើយ ចូលទៅរកព្រះមានព្រះភាគ ក្នុងបាវារិកម្ពវ័ន លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះឧបាលិគហបតី អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទីឃតបស្សីនិគ្រន្ថ បានមកក្នុងទីនេះឬទេ ។ ម្នាលគហបតី ទីឃតបស្សីនិគ្រន្ថ បានមកក្នុងទីនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គមានកថាសល្លាបៈបន្តិចបន្តួច ជាមួយនឹងទីឃតបស្សីនិគ្រន្ថដែរឬ ។ ម្នាលគហបតី តថាគតមានកថាសល្លាបៈបន្តិចបន្តួច ជាមួយនឹងទីឃតបស្សីនិគ្រន្ថដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គមានកថាសល្លាបៈបន្តិចបន្តួច ជាមួយនឹងទីឃតបស្សីនិគ្រន្ថ ដូចម្តេច ។ ទើបព្រះមានព្រះភាគ ទ្រង់រៀបរាប់កថាសល្លាបៈជាមួយនឹងទីឃតបស្សីនិគ្រន្ថ ទាំងអស់នោះ ប្រាប់ដល់ឧបាលិគហបតី ។

កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ទើបឧបាលិគហបតីក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ទីឃតបស្សីនិគ្រន្ថ និយាយពាក្យនេះពីរោះណាស់ៗ សាវ័កដែលជាអ្នកចេះដឹង អាចដឹងច្បាស់ នូវសាសនារបស់គ្រូដោយប្រពៃ ហើយព្យាករពាក្យនោះយ៉ាងណា ទីឃតបស្សីនិគ្រន្ថ ព្យាករចំពោះព្រះមានព្រះភាគ យ៉ាងនោះដែរ មនោទណ្ឌៈ ជាសភាវៈថោកថយ យកមកប្រៀបធៀបនឹងកាយទណ្ឌៈដ៏ថ្លៃថ្លានេះ ឲ្យវិសេសវិសាលជាងយ៉ាងនេះ ដូចម្ដេចបាន គឺកាយទណ្ឌៈហ្នឹងឯង ជាសភាវៈមានទោសធំជាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ឯវចីទណ្ឌៈ និងមនោទណ្ឌៈនឹងមានទោសធំដូច្នោះក៏ទេ ។ ម្នាលគហបតី បើអ្នកឯងគប្បីឋិតនៅក្នុងពាក្យសច្ចៈ ហើយប្រឹក្សាគ្នា កថាសល្លាបៈរបស់យើងគប្បីមានក្នុងហេតុនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងឋិតនៅក្នុងពាក្យសច្ចៈ ហើយប្រឹក្សាគ្នា កថាសល្លាបៈរបស់យើង ចូរមានក្នុងដំណើរនេះ ។

[ ៦៩ ] ម្នាលគហបតី អ្នកសម្គាល់នូវហេតុនោះ ថាដូចម្ដេច និគ្រន្ថក្នុងលោកនេះ មានអាពាធ មានទុក្ខ មានជំងឺធ្ងន់ ហាមបង់ទឹកត្រជាក់ ប្រើប្រាស់តែទឹកក្ដៅ កាលបើនិគ្រន្ថនោះ មិនបានទឹកត្រជាក់ ក៏ធ្វើមរណកាលទៅ ម្នាលគហបតី និគន្ថនាដបុត្តបញ្ញត្តនូវកំណើតរបស់និគ្រន្ថនេះ ក្នុងភពណា ។ បពិត្រព្រះអង្គដ៏ចម្រើន មានពួកទេវតាឈ្មោះមនោសត្ត ឯនិគ្រន្ថនោះ ក៏ទៅកើតក្នុងពួកទេវតានោះ សេចក្ដីនោះ ព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា និគ្រន្ថនោះ ជាអ្នកជាប់ចំពាក់ក្នុងចិត្តធ្វើមរណកាលទៅ ។ ម្នាល

គហបតី គហបតីអ្នកចូរធ្វើទុកក្នុងចិត្តចុះ ម្នាលគហបតី លុះអ្នកធ្វើទុកក្នុងចិត្ត ចូរព្យាករចុះ ( តែថា ) ពាក្យចុងរបស់អ្នកមិនតគ្នានឹងពាក្យដើម ឬពាក្យដើម មិនតគ្នានឹងពាក្យចុងសោះឡើយ ម្នាលគហបតី ពាក្យនេះដែលអ្នកនិយាយហើយជាពិតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងឋិតនៅក្នុងពាក្យសច្ចៈ ហើយប្រឹក្សាគ្នា កថាសល្លាបៈរបស់យើង ចូរមានក្នុងដំណើរនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះ ក៏ពិតមែន តែថា កាយទណ្ឌៈហ្នឹងឯង មានទោសធំជាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ឯវចីទណ្ឌៈ និងមនោទណ្ឌៈ នឹងមានទោសធំដូច្នោះក៏ទេ ។

[ ៧០ ] ម្នាលគហបតី អ្នកសម្គាល់ហេតុនោះថាដូចម្តេច និគ្រន្ថក្នុងលោកនេះ ជាអ្នកសង្រួមដោយការសង្រួម ៤ ចំណែក ហាមឃាត់ដោយការហាមឃាត់បាបទាំងអស់ ប្រកបដោយការហាមឃាត់បាបទាំងអស់ ជាអ្នកកម្ចាត់បាបដោយការហាមបាបទាំងអស់ ជាអ្នកប៉ះពាល់ដោយការហាមឃាត់បាបទាំងអស់ និគ្រន្ថនោះ កាលដែលដើរឈានទៅមុខ ឈានថយ ក៏ញុំាងសត្វតូចៗ ជាច្រើន ឲ្យដល់នូវសេចក្តីវិនាស ម្នាលគហបតី និគន្ថនាដបុត្តបញ្ញត្តនូវវិបាកនៃកម្មនេះ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន និគន្ថនាដបុត្តមិនបញ្ញត្តនូវកម្មដែលមិនមានចេតនា ថាមានទោសធំទេ ។ ម្នាលគហបតី ចុះបើបុគ្គលមានចេតនាវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន កម្មនោះមានទោសធំ ។ ម្នាលគហបតី ចុះនិគន្ថនាដបុត្តបញ្ញត្តនូវចេតនាក្នុងចំណែកណា ។ បពិត្រព្រះ

អន្តដ៏ចម្រើន ក្នុងមនោទណ្ឌៈ ។ ម្នាលគហបតី អ្នកចូរធ្វើទុកក្នុងចិត្តចុះ ម្នាលគហបតី លុះអ្នកធ្វើទុកក្នុងចិត្តហើយ ចូរព្យាករចុះ ( តែថា ) ពាក្យចុងរបស់អ្នកមិនតគ្នានឹងពាក្យដើម ឬពាក្យដើមមិនតគ្នានឹងពាក្យចុងសោះឡើយ ម្នាលគហបតី ពាក្យនេះ ដែលអ្នកនិយាយជាពិតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងឋិតនៅក្នុងពាក្យសច្ចៈប្រឹក្សាគ្នា កថាសល្លាបៈរបស់យើង ចូរមានក្នុងជំណើរនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះ ក៏ពិតមែនហើយ តែថា កាយទណ្ឌៈហ្នឹងឯង នៅតែមានទោសធំជាងក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ឯវចីទណ្ឌៈ និងមនោ-ទណ្ឌៈ នឹងមានទោសធំដូច្នោះក៏ទេ ។ ម្នាលគហបតី អ្នកសម្គាល់នូវហេតុនោះជាដូចម្ដេច ស្រុកនាលន្ទានេះ ស្តុកស្តម្ភមាំមួនផង ទូលាយផង មានជនច្រើន មានមនុស្សកុះករផង មែនឬទេ ។ ព្រះករុណាព្រះអង្គ ស្រុកនាលន្ទានេះ ស្តុកស្តម្ភមាំមួនផង ទូលាយផង មានជនច្រើន មានមនុស្សកុះករផងមែន ។ ម្នាលគហបតី អ្នកសម្គាល់នូវហេតុនោះជាដូចម្ដេច មានបុរសម្នាក់ ងាដាវដើរមកក្នុងស្រុកនាលន្ទានេះ បុរសនោះ និយាយយ៉ាងនេះថា សត្វទាំងឡាយក្នុងស្រុកនាលន្ទានេះមានចំនួនប៉ុន្មាន អាត្មាអញនឹងធ្វើសត្វទាំងនោះ ឲ្យជាលានៃសាច់តែមួយ ឲ្យជាគំនរនៃសាច់តែមួយ តែមួយរំពេច តែមួយស្របក់ប៉ុណ្ណោះ ។ ម្នាលគហបតី អ្នកសម្គាល់ហេតុនោះជាដូចម្ដេច បុរសនោះអាចនឹងធ្វើសត្វទាំងឡាយ ក្នុងក្រុងនាលន្ទានេះ ដែលមានចំនួនប៉ុន្មាននោះ ឲ្យជាលានៃសាច់តែមួយ ឲ្យជាគំនរនៃសាច់តែមួយ តែមួយរំពេច តែមួយស្របក់

ប៉ុណ្ណោះបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរស ១០ នាក់ក្តី ២០ នាក់ក្តី ៣០ នាក់ក្តី ៤០ នាក់ក្តី ៥០ នាក់ក្តី ក៏មិនអាចនឹងធ្វើសត្វ ក្នុងស្រុកនាលន្ទានេះ ទាំងអម្បាលម៉ាននោះ ឲ្យជាលានរៃនៃសាច់តែមួយ ឲ្យជាគំនរនៃសាច់តែមួយ តែមួយរំពេច តែមួយស្របក់បានឡើយ ចំណង់បើបុរសកម្សាយតែម្នាក់ នឹងអាចធ្វើឲ្យវិសេសវិសាល ដូចម្តេចបាន ។ ម្នាលគហបតី អ្នកសម្គាល់នូវហេតុនោះថា ដូចម្តេច បុគ្គលជាសមណៈ ឬព្រាហ្មណ៍ ជាអ្នកមានឫទ្ធិ ដល់នូវសេចក្តីស្ទាត់ជំនាញក្នុងចិត្ត ដើរមកក្នុងស្រុកនាលន្ទានេះ បុគ្គលនោះនិយាយយ៉ាងនេះថា អញនឹងធ្វើស្រុកនាលន្ទានេះ ឲ្យទៅជាផេះ ដោយចិត្តប្រទូស្តតែម្តង ។ ម្នាលគហបតី អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច បុគ្គលជាសមណៈ ឬព្រាហ្មណ៍ ជាអ្នកមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញក្នុងចិត្តនោះ អាចនឹងធ្វើស្រុកនាលន្ទានេះ ឲ្យទៅជាផេះ ដោយចិត្តប្រទូស្តតែម្តងបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ស្រុកនាលន្ទា ១០ ក្តី ស្រុកនាលន្ទា ២០ ក្តី ស្រុកនាលន្ទា ៣០ ក្តី ស្រុកនាលន្ទា ៤០ ក្តី ស្រុកនាលន្ទា ៥០ ក្តី ក៏បុគ្គលជាសមណៈ ឬព្រាហ្មណ៍ ជាអ្នកមានឫទ្ធិ ដល់នូវសេចក្តីស្ទាត់ក្នុងចិត្តនោះ អាចដើម្បីធ្វើស្រុកនាលន្ទានេះ ឲ្យទៅជាផេះ ដោយចិត្តប្រទូស្តតែម្តងបាន ជ្រៀតស្រុកនាលន្ទាតូចមួយ នឹងអាចទប់ទល់ដូចម្តេចបាន ។ ម្នាលគហបតីៗ អ្នកចូរធ្វើទុកក្នុងចិត្តចុះ ម្នាលគហបតី លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរព្យាករចុះ ពាក្យចុងរបស់អ្នកមិនតគ្នានឹងពាក្យដើម ឬពាក្យដើមមិនតគ្នានឹងពាក្យចុងសោះឡើយ ម្នាលគហបតី វាចានេះអ្នកបាននិយាយរួចហើយថា បពិត្រព្រះ

អង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងតាំងនៅក្នុងពាក្យសច្ចៈ ហើយប្រឹក្សាគ្នាថា កថាសល្លាបៈរបស់យើង សូមមានក្នុងដំណើរនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះពិតមែនហើយ តែថាកាយទណ្ឌៈហ្នឹងឯង ក៏នៅតែមានទោសធំជាង ក្នុងការធ្វើនូវបាបកម្ម ក្នុងការប្រព្រឹត្តទៅនៃបាបកម្ម ឯវចីទណ្ឌៈ និងមនោទណ្ឌៈ នឹងមានទោសធំដូច្នោះក៏ទេ ។ ម្នាលគហបតី អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច អ្នកបានឮថា ព្រៃទណ្ឌកី ព្រៃកាលិង្គៈ ព្រៃមេជ្ឈា និងព្រៃមាតង្គៈ ជាព្រៃកើតជាព្រៃឬទេ ។ ព្រះករុណាព្រះអង្គ ខ្ញុំព្រះអង្គបានឮថាព្រៃទណ្ឌកី ព្រៃកាលិង្គៈ ព្រៃមេជ្ឈា និងព្រៃមាតង្គៈ ជាព្រៃទទេ ជាព្រៃសុទ្ធ ។ ម្នាលគហបតី អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច អ្នកបានឮដូចម្តេច ព្រៃទណ្ឌកី ព្រៃកាលិង្គៈ ព្រៃមេជ្ឈា និងព្រៃមាតង្គៈនោះ ជាព្រៃទទេ ជាព្រៃសុទ្ធ ដោយហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គឮមកថា ព្រៃទណ្ឌកី ព្រៃកាលិង្គៈ ព្រៃមេជ្ឈា និងព្រៃមាតង្គៈនោះ ជាព្រៃ កើតទៅជាព្រៃសុទ្ធ ព្រោះចិត្តប្រទូស្តនឹងពួកឥសី ។ ម្នាលគហបតី អ្នកចូរធ្វើទុកក្នុងចិត្តចុះ ម្នាលគហបតី លុះអ្នកធ្វើទុកក្នុងចិត្តហើយ ចូរព្យាករចុះ ពាក្យចុងរបស់អ្នកមិនតគ្នានឹងពាក្យដើម ពាក្យដើមមិនតគ្នានឹងពាក្យចុងសោះឡើយ ម្នាលគហបតី វាចានេះ អ្នកបាននិយាយរួចហើយថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងតាំងនៅក្នុងពាក្យសច្ចៈប្រឹក្សាគ្នា កថាសល្លាបៈរបស់យើង ចូរមានក្នុងដំណើរនេះ ។

[ ៧១ ] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គត្រេកអរពីកកាយ ដោយ

ពាក្យឧបមាខាងដើមរបស់ព្រះមានព្រះភាគ តែថាខ្ញុំព្រះអង្គមានប្រាថ្នានឹងស្ដាប់នូវបញ្ហាព្យាករណ៍ដ៏វិចិត្រនេះ របស់ព្រះមានព្រះភាគ កាលពីដើម ខ្ញុំព្រះអង្គបានសម្គាល់នូវព្រះមានព្រះភាគ ថាជាបុគ្គលគួរធ្វើឲ្យជាសត្រូវយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគសម្ដែងហើយ ដោយអនេកបរិយាយ ភ្លឺច្បាស់ណាស់ ដូចជាបុរសបើករបស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ឬដូចជាបុរសបើកបង្ហាញរបស់ដែលលាក់បិទបាំង ពុំនោះដូចជាបុរសប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោតដូចជាបុរសកាន់ប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សមានចក្ខុតែងមើលរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះមានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវសរណគមន៍ស្មើដោយជីវិត ក្នុងថ្ងៃនេះជាដើម ។

[ ៧២ ] ម្នាលគហបតី អ្នកចូរធ្វើនូវការពិចារណាល្អិតល្អន់សិន ការពិចារណាល្អិតល្អន់ របស់ពួកមនុស្ស ដែលគេស្គាល់ ប្រាកដដូចជាខ្លួនអ្នកទើបជាការប្រពៃ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះនឹងខ្ញុំព្រះអង្គថា ម្នាលគហបតី អ្នកចូរធ្វើនូវការពិចារណាល្អិតល្អន់សិន ការពិចារណាល្អិតល្អន់របស់ពួកមនុស្ស ដែលគេស្គាល់ ប្រាកដដូចជាខ្លួនអ្នកទើបជាការប្រពៃ ដូច្នេះ ដោយពាក្យណា ខ្ញុំព្រះអង្គមានចិត្តត្រេកអររីករាយ

ហួសប្រមាណ ដោយពាក្យនេះ របស់ព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន បើពួកអន្យតិរ្ថិយបានខ្ញុំព្រះអង្គជាសាវកហើយ គប្បីលើកឡើងនូវទង់សំពត់ ក្នុងស្រុកនាលន្ទាទាំងអស់ ដោយអំណរថា ឧបាលិគហបតី ចុះចូលមកជាសាវករបស់ពួកយើងហើយ សមដូចព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះនឹងខ្ញុំព្រះអង្គថា ម្នាលគហបតី អ្នកចូរធ្វើនូវការពិចារណាល្អិតល្អន់សិន ដ្បិតការពិចារណាល្អិតល្អន់ របស់ពួកមនុស្សដែលគេស្គាល់ ប្រាកដដូចជាខ្លួនអ្នក ទើបជាការប្រពៃ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ក្នុងថ្ងៃនេះជាដើម ។

[ ៧៣ ] ម្នាលគហបតី អ្នកគប្បីសម្គាល់បិណ្ឌបាត ថាជារបស់គួរឲ្យដល់ពួកនិគ្រន្ថនោះ ដែលចូលមក ក្នុងត្រកូលណា ត្រកូលនោះ របស់អ្នក តាំងនៅដូចជាអណ្តូងនៃពួកនិគ្រន្ថ ជាយូរអង្វែងមកហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះនឹងខ្ញុំព្រះអង្គថា ម្នាលគហបតី អ្នកគប្បីសម្គាល់នូវបិណ្ឌបាត ថាជារបស់គួរឲ្យដល់ពួកនិគ្រន្ថនោះ ដែលចូលមក ក្នុងត្រកូលណា ត្រកូលនោះ របស់អ្នក តាំងនៅដូចជាអណ្តូងនៃពួកនិគ្រន្ថ ជាយូរអង្វែងមកហើយ ដោយពាក្យណា ខ្ញុំព្រះអង្គមានចិត្តត្រេកអររីករាយហួសប្រមាណ ដោយពាក្យនេះ របស់ព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឮពាក្យដូច្នេះថា ព្រះសមណគោតម សម្តែងយ៉ាងនេះថា

បុគ្គលគួរតែឲ្យទានដល់តថាគត មិនគួរឲ្យទានដល់ពួកជនដទៃឡើយ គួរតែឲ្យទានដល់ពួកសាវ័ករបស់តថាគត មិនគួរឲ្យទានដល់ពួកសាវ័ករបស់គ្រូដទៃឡើយ ទានដែលបុគ្គលឲ្យហើយដល់តថាគត ទើបមានផលច្រើន ទានដែលបុគ្គលឲ្យហើយដល់គ្រូដទៃ មិនមានផលច្រើនទេ ទានដែលបុគ្គលឲ្យដល់ពួកសាវ័ករបស់តថាគត ទើបមានផលច្រើន ទានដែលបុគ្គលឲ្យដល់ពួកសាវ័ករបស់គ្រូដទៃ មិនមានផលច្រើនទេ ក៏ប៉ុន្តែព្រះមានព្រះភាគទ្រង់ណែនាំខ្ញុំព្រះអង្គឲ្យធ្វើទានដល់ពួកនិគ្រន្ថដែរ បពិត្រព្រះអង្គដ៏ចម្រើន មួយយ៉ាងទៀត យើងនឹងដឹងនូវកាលគួរក្នុងដំណើរនេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭកជាគម្រប់ ៣ ដងផង សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវសរណគមន៍ ស្មើដោយជីវិត ក្នុងថ្ងៃនេះជាដើម ។

[ ៧៤ ] គ្រានោះ ព្រះមានព្រះភាគទ្រង់សម្តែងនូវអនុបុព្វីកថា គឺទ្រង់ប្រកាសនូវទានកថា សីលកថា សគ្គកថា និងទោសនៃកាមទាំងឡាយដែលជាទោសដ៏លាមកសៅហ្មង និងអានិសង្សក្នុងការចេញចាកកាមដល់ឧបាលិគហបតី ។ កាលដែលព្រះមានព្រះភាគ ទ្រង់ជ្រាបនូវឧបាលិគហបតីថា មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណៈ មានចិត្តខ្ពស់ឡើង មានចិត្តជ្រះថ្លាហើយ ទើបព្រះអង្គទ្រង់សម្តែងធម៌ទេសនា ដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង គឺទុក្ខសច្ច សមុទយសច្ច និរោធ-សច្ច មគ្គសច្ច ។ ធម្មតាសំពត់ស្អាត ប្រាសចាកវត្ថុមានពណ៌ខ្មៅ គួរទទួល

ទឹកជ្រលក់ដោយល្អបាន មានឧបមាដូចម្តេចមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់ឧបាលិគហបតី ក្នុងកន្លែងអង្គុយនោះឯងថា ធម្មជាតណានីមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ ក៏រលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ។ គ្រានោះ ឧបាលិគហបតីបានឃើញអរិយសច្ចធម៌ហើយ បានដល់នូវអរិយសច្ចធម៌ហើយ បានដឹងច្បាស់នូវអរិយសច្ចធម៌ហើយ បានឈានចុះកាន់អរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនជឿបុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្តា ទើបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ណ្ហើយចុះ ខ្ញុំព្រះអង្គនឹងទៅក្នុងកាលឥឡូវនេះ ព្រោះខ្ញុំព្រះអង្គមានកិច្ចច្រើន មានការងារច្រើន ។ ម្នាលគហបតី អ្នកសម្គាល់នូវកាលដ៏សមគួរនឹងទៅឥឡូវនេះចុះ ។

[ ៧៥ ] គ្រានោះ ឧបាលិគហបតីក៏ត្រេកអររីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ហើយក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគហើយធ្វើប្រទក្សិណ ដើរចូលទៅកាន់លំនៅរបស់ខ្លួន លុះចូលទៅដល់ហើយ ក៏ហៅអ្នករក្សាទ្វារមកប្រាប់ថា ម្នាលអ្នករក្សាទ្វារ ជាសម្លាញ់ ពីថ្ងៃនេះជាដើមរៀងទៅ ខ្ញុំបិទទ្វារចំពោះពួកនិគ្រន្ថប្រុស និងពួកនិគ្រន្ថស្រី មិនបានបិទទ្វារចំពោះពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជាសាវ័ករបស់ព្រះមានព្រះភាគទេ បើមាននិគ្រន្ថណាមួយមកដល់ អ្នកគប្បីនិយាយយ៉ាងនេះនឹងគេថា បពិត្រលោកដ៏ចម្រើន លោកចូរឈប់សិន កុំចូលទៅឡើយ ពីថ្ងៃនេះជាដើមរៀង

តទៅ ឧបាលិគហបតីចុះចូលជាសាវ័ក របស់ព្រះសមណគោតមហើយ បិទទ្វារចំពោះពួកនិគ្រន្ថប្រុស និងពួកនិគ្រន្ថស្រីហើយ ប៉ុន្តែមិនបិទទ្វារចំពោះពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជាសាវ័ករបស់ព្រះមានព្រះភាគទេ បពិត្រលោកដ៏ចម្រើន បើលោកត្រូវការដោយបិណ្ឌបាត សូមឈប់នៅទីនេះសិនចុះ ពួកជននឹងនាំមកឲ្យលោក ត្រឹមទីនេះឯង ។ អ្នករក្សាទ្វារ ក៏ទទួលពាក្យរបស់ឧបាលិគហបតី ដោយពាក្យថា បាទ អ្នកដ៏ចម្រើន ។

[ ៧៦ ] ទីឃតបស្សីនិគ្រន្ថ បានឮដំណឹងថា ឧបាលិគហបតីចុះចូលជាសាវ័ករបស់ព្រះសមណគោតមហើយ ។ ទើបទីឃតបស្សីនិគ្រន្ថចូលទៅរកនិគន្ថនាដបុត្ត លុះចូលទៅដល់ហើយ និយាយនឹងនិគន្ថនាដបុត្តដូច្នេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំបានឮដំណឹងដូច្នេះថា ឧបាលិគហបតីចុះចូលទៅជាសាវ័ករបស់ព្រះសមណគោតមហើយ ។ និគ្គន្ថនាដបុត្តតបថា នែតបស្សី ឧបាលិគហបតី គប្បីចុះចូលទៅជាសាវ័កនៃព្រះសមណគោតម ដោយហេតុណាហេតុនុ៎ះ មិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតមគប្បីចុះចូលមកជាសាវ័ករបស់ឧបាលិគហបតី ដោយហេតុណា ហេតុនុ៎ះទើបជាទីតាំង មានមែន ។ ទីឃតបស្សីនិគ្រន្ថ ក៏និយាយនឹងនិគ្គន្ថនាដបុត្តជាគម្រប់ពីរដងដូច្នេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំបានឮដំណឹងដូច្នេះថា ឧបាលិគហបតី ចុះចូលទៅជាសាវ័ករបស់ព្រះសមណគោតមហើយ ។ និគ្គន្ថនាដបុត្តតបថា នែតបស្សី ឧបាលិគហបតី គប្បីចុះចូលទៅជាសាវ័ករបស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះ មិនមែនជាទីតាំង មិនមែនជា

ឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះចូលមកជាសាវ័ករបស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនុ៎ះ ទើបជាទីតាំងមានមែន ។ ទីឃតបស្សីនិគ្រន្ថនិយាយនឹងនិគ្គន្ថនាដបុត្តជាគម្រប់ ៣ ដង ដូច្នេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំបានឮដំណឹងដូច្នេះថា ឧបាលិគហបតី ចុះចូលទៅជាសាវ័ករបស់ព្រះសមណគោតមហើយ ។ នែតបស្សី ឧបាលិគហបតី គប្បីចុះចូលទៅជាសាវ័ករបស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះ មិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះចូលមកជាសាវ័ករបស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនុ៎ះ ទើបជាទីតាំងមានមែន ។ បពិត្រលោកដ៏ចម្រើន ណ្ហើយចុះ ខ្ញុំនឹងទៅត្រាតែដឹងថា ឧបាលិគហបតី ចុះចូលទៅជាសាវ័ករបស់ព្រះសមណគោតមមែន ឬក៏មិនមែនទេ ។ ម្នាលតបស្សី អ្នកចូរទៅចុះ អ្នកចូរដឹងថា ឧបាលិគហបតី ចុះចូលទៅជាសាវ័ករបស់ព្រះសមណគោតមមែន ឬមិនមែនទេ ។

[ ៧៧ ] លំដាប់នោះ ទីឃតបស្សីនិគ្រន្ថ ក៏ចូលទៅកាន់ផ្ទះរបស់ឧបាលិគហបតី ។ អ្នករក្សាទ្វារ បានឃើញទីឃតបស្សីនិគ្រន្ថដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏និយាយនឹងទីឃតបស្សីនិគ្រន្ថដូច្នេះថា បពិត្រលោកដ៏ចម្រើន លោកចូរឈប់សិន កុំចូលទៅឡើយ ពីថ្ងៃនេះជាដើមរៀងទៅ ឧបាលិគហបតី ចុះចូលជាសាវ័ករបស់ព្រះសមណគោតមហើយ បិទទ្វារចំពោះពួកនិគ្រន្ថប្រុស និងពួកនិគ្រន្ថស្រី មិនបានបិទទ្វារដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជាសាវ័ករបស់ព្រះមានព្រះភាគឡើយ បពិត្រលោកដ៏ចម្រើន បើលោកត្រូវការ

ដោយបិណ្ឌបាត សូមឈប់នៅត្រឹមនេះសិនចុះ ពួកជននឹងនាំមកឲ្យលោកក្នុងទីនេះឯង ។ ទីឃតបស្សីនិយាយថា ម្នាលអាវុសោ យើងមិនត្រូវការដោយបិណ្ឌបាតទេ ហើយក៏ត្រឡប់មកអំពីទីនោះ ដើរចូលទៅរកនិគន្ថនាដបុត្ត លុះចូលទៅដល់ហើយ ទើបនិយាយនឹងនិគន្ថនាដបុត្តដូច្នេះថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតីចុះចូលជាសាវ័ក របស់ព្រះសមណគោតមមែនហើយ បពិត្រលោកដ៏ចម្រើន ខ្ញុំមិនបានចួបនឹងឧបាលិគហបតីនុ៎ះដើម្បីលោកទេ បពិត្រលោកដ៏ចម្រើន ឧបាលិគហបតីគប្បីលើកឡើងនូវវាទៈ របស់ព្រះសមណគោតមដោយហេតុណា ហេតុនុ៎ះ ខ្ញុំមិនពេញចិត្តទេ បពិត្រលោកដ៏ចម្រើន ព្រោះថាព្រះសមណគោតមជាអ្នកមានកិច្ចកល តែងដឹងនូវកិច្ចកលសម្រាប់បោកប្រាស តែងបោកប្រាសនូវសាវ័ករបស់ពួកអន្យតិរ្ថិយ បពិត្រលោកដ៏ចម្រើន ព្រះសមណគោតមបោកប្រាស នូវឧបាលិគហបតីរបស់លោក ដោយកិច្ចកលសម្រាប់បោកប្រាសបានទៅហើយ ។ និគ្គន្ថនាដបុត្ត និយាយតបថា ម្នាលទីឃតបស្សី ឧបាលិគហបតីគប្បីចុះចូលជាសាវ័ក របស់ព្រះសមណគោតមដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះចូលជាសាវ័ក របស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនុ៎ះទើបជាទីតាំងមានមែន ។ ទីឃតបស្សីនិគ្រន្ថនិយាយនឹងនិគ្គន្ថនាដបុត្តជាគម្រប់ពីរដងដូច្នេះថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតី ចុះចូលជាសាវ័ក របស់ព្រះសមណគោតមមែនហើយ បពិត្រលោកដ៏ចម្រើន ខ្ញុំមិនបានចួបនឹងឧបាលិគហបតិនុ៎ះ ដើម្បីលោកទេ បពិត្រលោកដ៏ចម្រើន

ឧបាលិគហបតីគប្បីលើកឡើងនូវវាទៈ របស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះមិនពេញចិត្តខ្ញុំទេ បពិត្រលោកដ៏ចម្រើន ព្រោះថាព្រះសមណគោតមជាអ្នកមានកិច្ចកល តែងដឹងកិច្ចកលសម្រាប់បោកប្រាស តែងបោកប្រាសសាវករបស់ពួកអន្យតិរ្ថិយ បពិត្រលោកដ៏ចម្រើន ព្រះសមណគោតមបោកប្រាសនូវឧបាលិគហបតីរបស់លោក ដោយកិច្ចកលសម្រាប់បោកប្រាសបានទៅហើយ ។ ម្នាលតបស្សី ឧបាលិគហបតី គប្បីចុះចូលជាសាវករបស់ព្រះសមណគោតម ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាសឡើយ ឯព្រះសមណគោតម គប្បីចុះចូលជាសាវក របស់ឧបាលិគហបតីវិញ ដោយហេតុណា ហេតុនុ៎ះទើបជាទីតាំងមានមែន ម្នាលតបស្សីណ្ហើយចុះ ខ្ញុំនឹងទៅត្រាតែដឹងដោយខ្លួនឯងថា ឧបាលិគហបតី ចុះចូលជាសាវករបស់ព្រះសមណគោតមមែន ឬក៏មិនមែនទេ ។

[ ៧៨ ] លំដាប់នោះ និគ្គន្ថនាដបុត្ត ជាមួយនឹងនិគ្គន្ថបរិស័ទជាច្រើនរូប ចូលទៅកាន់ផ្ទះរបស់ឧបាលិគហបតី ។ អ្នករក្សាទ្វារ បានឃើញនិគ្គន្ថនាដបុត្ត ដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏និយាយនឹងនិគ្គន្ថនាដបុត្ត ដូច្នេះថា បពិត្រលោកដ៏ចម្រើន សូមលោកឈប់សិន កុំចូលទៅឡើយ ពីថ្ងៃនេះជាដើមរៀងទៅ ឧបាលិគហបតីចុះចូលជាសាវករបស់ព្រះសមណគោតមហើយ បានបិទទ្វារចំពោះពួកនិគ្រន្ថប្រុស និងនិគ្រន្ថស្រី មិនបានបិទទ្វារចំពោះពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជាសាវករបស់ព្រះមានព្រះភាគឡើយ បពិត្រលោកដ៏ចម្រើន បើលោកត្រូវការដោយបិណ្ឌបាត សូមលោកឈប់នៅត្រឹមទី

នេះសិនចុះ ពួកជននឹងនាំមកឲ្យលោក ក្នុងទីនេះឯង ។ និគ្គន្ថនាដបុត្តនិយាយថា ម្នាលអ្នករក្សាទ្វារជាសម្លាញ់ បើដូច្នោះ សូមអ្នកចូលទៅរកឧបាលិគហបតី លុះចូលទៅដល់ហើយ ក៏និយាយនឹងឧបាលិគហបតីយ៉ាងនេះថា និគ្គន្ថនាដបុត្តជាមួយនឹងនិគ្គន្ថបរិស័ទជាច្រើនរូប មកឈរនៅខាងក្រៅខ្លោងទ្វារ និគ្គន្ថនាដបុត្តនោះចង់ជួបនឹងអ្នក ។ អ្នករក្សាទ្វារទទួលពាក្យរបស់និគ្គន្ថនាដបុត្តថា អើលោកម្ចាស់ ហើយចូលទៅរកឧបាលិគហបតី លុះចូលទៅដល់ហើយ ក៏និយាយនឹងឧបាលិគហបតីដូច្នេះថា បពិត្រអ្នកដ៏ចម្រើន និគ្គន្ថនាដបុត្តជាមួយនឹងនិគ្គន្ថបរិស័ទជាច្រើនរូប មកឈរនៅខាងក្រៅខ្លោងទ្វារ និគ្គន្ថនាដបុត្តនោះចង់ជួបនឹងអ្នក ។ ឧបាលិគហបតីក៏និយាយថា ម្នាលអ្នករក្សាទ្វារជាសម្លាញ់ បើដូច្នោះចូរអ្នកក្រាលអាសនៈ ត្រង់ខ្លោងទ្វារជាកណ្តាលចុះ ។ អ្នករក្សាទ្វារទទួលពាក្យឧបាលិគហបតីថា អើអ្នកដ៏ចម្រើន ក៏ក្រាលអាសនៈ ត្រង់ខ្លោងទ្វារ ជាកណ្តាលហើយត្រឡប់ចូលទៅរកឧបាលិគហបតីវិញ លុះចូលទៅដល់ហើយ ក៏និយាយប្រាប់ឧបាលិគហបតីដូច្នេះថា បពិត្រអ្នកដ៏ចម្រើន ខ្ញុំបានក្រាលអាសនៈ ត្រង់ខ្លោងទ្វារជាកណ្តាលរួចហើយ សូមអ្នកសម្គាល់នូវកាលដ៏សមគួរនឹងអញ្ជើញទៅឥឡូវនេះចុះ ។ ទើបឧបាលិគហបតី ដើរចូលទៅកាន់ខ្លោងទ្វារជាកណ្តាល លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈខ្ពស់ប្រសើរ ឧត្តម ថ្លៃថ្លា ដោយខ្លួនឯង ហើយប្រាប់អ្នករក្សាទ្វារថា ម្នាលអ្នករក្សាទ្វារជាសម្លាញ់ បើដូច្នោះ ត្រូវអ្នកចូលទៅរកនិគ្គន្ថនាដបុត្ត លុះចូលទៅដល់ហើយ និយាយនឹងនិគ្គន្ថនាដបុត្ត យ៉ាងនេះថា បពិត្រលោកដ៏ចម្រើន

ឧបាលិគហបតីបាននិយាយដូច្នេះថា បពិត្រលោកដ៏ចម្រើន បើលោកចង់ចូលទៅក៏ចូលទៅចុះ ។ អ្នករក្សាទ្វារ ក៏ទទួលពាក្យឧបាលិគហបតីថា អើអ្នកដ៏ចម្រើន ហើយក៏ចូលទៅរកនិគ្គន្ថនាដបុត្ត លុះចូលទៅដល់ហើយ ក៏និយាយនឹងនិគ្គន្ថនាដបុត្តដូច្នេះថា បពិត្រលោកដ៏ចម្រើន ឧបាលិគហបតីបាននិយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន បើលោកចង់ចូលទៅក៏ចូលទៅចុះ ។ លំដាប់នោះ និគ្គន្ថនាដបុត្តព្រមទាំងនិគ្គន្ថបរិស័ទច្រើនរូប ក៏ចូលទៅកាន់ខ្លោងទ្វារកណ្តាល ។

[ ៧៩ ] កាលពីដើម បើឧបាលិគហបតីបានឃើញនិគ្គន្ថនាដបុត្តមកអំពីចម្ងាយក្នុងកាលណា លុះឃើញហើយ ក៏ក្រោកទៅទទួលក្នុងកាលនោះ ហើយយកសំពត់បង់ក ជូតសម្អាតអាសនៈដ៏ខ្ពង់ខ្ពស់ប្រសើរ ឧត្តម ថ្លៃថ្លា ហើយគ្រាហ៍ឡើងទៅអង្គុយ តែពេលនេះ ឧបាលិគហបតីនោះ ត្រឡប់ទៅជាឡើងអង្គុយលើអាសនៈដ៏ខ្ពង់ខ្ពស់ប្រសើរ ឧត្តម ថ្លៃថ្លា ខ្លួនឯងវិញ ហើយក៏និយាយនឹងនិគ្គន្ថនាដបុត្តថា នែគហបតីដ៏ចម្រើន អាសនៈមានគ្រប់គ្រាន់ បើអ្នកត្រូវការចូរអង្គុយចុះ ។ កាលបើឧបាលិគហបតី និយាយយ៉ាងនេះហើយ និគ្គន្ថនាដបុត្តក៏និយាយនឹងឧបាលិគហបតីដូច្នេះវិញថា ម្នាលគហបតី អ្នកឆ្កួតទេឬ ម្នាលគហបតី អ្នកឯងលីលាទេឬ អ្នកនិយាយថា បពិត្រលោកដ៏ចម្រើន ខ្ញុំនឹងទៅលើកវាទៈរបស់ព្រះសមណគោតម លុះទៅហើយ ម្តេចឡើយក៏ត្រឡប់ជាពាក់ឃ្នាប គឺវាទៈដ៏ធំលើក្បាលមកវិញ ម្នាលគហបតី ដូចជាបុរសនាំអណ្តុះដើរទៅ ក៏ត្រឡប់នាំយកអណ្តុះដែលគេកាត់ចេញដើរមកវិញ

ម្នាលគហបតី ពុំនោះសោតដូចជាបុរសនាំយកក្អែកជាល្អដើរទៅ ត្រឡប់នាំយកក្អែកដែលគេធ្មៀលចេញដើរមកវិញ ម្នាលគហបតី អ្នកក៏យ៉ាងហ្នឹងដែរ និយាយថា បពិត្រលោកដ៏ចម្រើន ខ្ញុំនឹងទៅលើកវាទៈ របស់ព្រះសមណគោតម លុះទៅដល់ហើយ ម្ដេចឡើយក៏ត្រឡប់ជាពាក់ឃ្នាប គឺវាទៈដ៏ធំលើក្បាលដើរមកវិញ ម្នាលគហបតី អ្នកត្រូវព្រះសមណគោតមបោកប្រាសដោយកលជាគ្រឿងបោកប្រាសហើយ ។

[ ៨០ ] បពិត្រលោកដ៏ចម្រើន កលជាគ្រឿងបោកប្រាសស្រួលពេកណាស់ បពិត្រលោកដ៏ចម្រើន កលជាគ្រឿងបោកប្រាសល្អពេកណាស់ បពិត្រលោកដ៏ចម្រើន ញាតិសាលោហិតទាំងឡាយ ជាទីស្រឡាញ់របស់ខ្ញុំ គប្បីចាញ់បោកដោយកលជាគ្រឿងបោកនេះ ការចាញ់បោកនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលជាអង្វែងដល់ញាតិ និងសាលោហិត ដែលជាទីស្រឡាញ់របស់ខ្ញុំ បពិត្រលោកដ៏ចម្រើន ប្រសិនបើពួកក្សត្រទាំងអស់ គប្បីចាញ់បោកដោយកលជាគ្រឿងបោកនេះ ការចាញ់បោកនោះ នឹងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលជាអង្វែង ដល់ពួកក្សត្រទាំងអស់ បពិត្រលោកដ៏ចម្រើន ប្រសិនបើពួកព្រាហ្មណ៍ទាំងអស់ ។បេ។ ពួកវេស្សៈ ។បេ។ ពួកសុទ្ទៈគប្បីចាញ់បោកដោយកលជាគ្រឿងបោកនេះ ការចាញ់បោកនោះ នឹងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលជាអង្វែង ដល់ពួកសុទ្ទៈទាំងអស់ បពិត្រលោកដ៏ចម្រើន ប្រសិនបើលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក

ពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស គប្បីបាញ់បោកដោយកលជាគ្រឿងបោកនេះ ការបាញ់បោកនោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលជាអង្វែងដល់លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដល់សត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស បពិត្រលោកដ៏ចម្រើន ណ្ហើយចុះ ខ្ញុំនឹងធ្វើសេចក្តីឧបមាដល់លោក វិញ្ញូបុរសពួកមួយ ក្នុងលោកនេះ គន់ដឹងនូវសេចក្តីនៃភាសិត ដោយឧបមាខ្លះមិនខាន ។

[ ៨១ ] បពិត្រលោកដ៏ចម្រើន រឿងធ្លាប់មានមកហើយថា មានព្រាហ្មណ៍ម្នាក់ចាស់ព្រឹទ្ធា ជាធំដោយអាយុ បាននាងមាណវិកាក្រមុំ ជាប្រពន្ធមានផ្ទៃពោះជិតដល់កាលនឹងប្រសូត ។ បពិត្រលោកដ៏ចម្រើន គ្រានោះ នាងមាណវិកានោះ ក៏និយាយនឹងព្រាហ្មណ៍នោះដូច្នេះថា ម្នាលព្រាហ្មណ៍ អ្នកចូរទៅទិញកូនស្វាឈ្មោលពីផ្សារយកមក ដើម្បីឲ្យកុមាររបស់ខ្ញុំលេង ។ បពិត្រលោកដ៏ចម្រើន កាលដែលនាងមាណវិកានិយាយយ៉ាងនេះ ព្រាហ្មណ៍នោះក៏និយាយដូច្នេះនឹងនាងមាណវិកានោះថា ម្នាលនាងដ៏ចម្រើន នាងចូរបង្អង់ចាំទម្រាំនាងប្រសូតសិន ម្នាលនាងដ៏ចម្រើន បើនាងប្រសូតកុមារ សឹមអញទៅទិញកូនស្វាឈ្មោលពីផ្សារ យកមកឲ្យនាង ដើម្បីឲ្យកុមាររបស់នាងលេង ម្នាលនាងដ៏ចម្រើន តែប្រសិនបើនាងប្រសូតកុមារី អញនឹងទៅទិញកូនស្វាញីពីផ្សារ យកមកឲ្យនាង ដើម្បីឲ្យកុមារីរបស់នាងលេង ។ បពិត្រលោកដ៏

ចម្រើន នាងមាណវិកានោះនិយាយនឹងព្រាហ្មណ៍នោះដូច្នេះ ជាគម្រប់ពីរដង ទៀតថា ម្នាលព្រាហ្មណ៍ អ្នកចូរទៅទិញកូនស្វាឈ្មោលពីផ្សារយកមកដើម្បី ឲ្យកុមាររបស់ខ្ញុំលេង ។ បពិត្រលោកដ៏ចម្រើន ព្រាហ្មណ៍នោះនិយាយនឹង មាណវិកានោះដូច្នេះ ជាគម្រប់ពីរដងទៀតថា ម្នាលនាងដ៏ចម្រើន ចូរនាង បង្អង់ចាំទម្រាំនាងប្រសូតសិន ម្នាលនាងដ៏ចម្រើន បើនាងប្រសូតកុមារ សឹម អញទៅទិញកូនស្វាឈ្មោលពីផ្សារ យកមកឲ្យនាង ដើម្បីឲ្យកុមាររបស់នាង លេង ម្នាលនាងដ៏ចម្រើន តែប្រសិនបើនាងប្រសូតកុមារី អញនឹងទៅទិញ កូនស្វាញីពីផ្សារ យកមកឲ្យនាង ដើម្បីឲ្យកុមារីរបស់នាងលេង ។ បពិត្រ លោកដ៏ចម្រើន នាងមាណវិកានោះ និយាយនឹងព្រាហ្មណ៍នោះដូច្នេះ ជា គម្រប់បីដងទៀតថា ម្នាលព្រាហ្មណ៍ អ្នកចូរទៅទិញកូនស្វាឈ្មោលពីផ្សារ យកមក ដើម្បីឲ្យកុមាររបស់ខ្ញុំលេង ។ បពិត្រលោកដ៏ចម្រើន គ្រានោះ ព្រាហ្មណ៍នោះមានតម្រេក មានចិត្តប្រតិព័ទ្ធ ចំពោះនាងមាណវិកានោះ ក៏ទៅ ទិញកូនស្វាឈ្មោលពីផ្សារយកមក ហើយនិយាយដូច្នេះ នឹងនាងមាណវិកា នោះថា ម្នាលនាងដ៏ចម្រើន កូនស្វាឈ្មោលនេះ អញបានទៅទិញមកពីផ្សារ យកមកឲ្យនាងហើយ ដើម្បីឲ្យកុមាររបស់នាងលេង ។ បពិត្រលោកដ៏ចម្រើន កាលដែលព្រាហ្មណ៍និយាយយ៉ាងនេះហើយ នាងមាណវិកានោះ ក៏និយាយ ដូច្នេះនឹងព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍ ចូរអ្នកនាំយកកូនស្វាឈ្មោលនេះ ដើរចូលទៅរករជកបុត្រ ( កូនជាងជ្រលក់ ) ឈ្មោះរត្តបាណី លុះចូលទៅ ដល់ហើយ ចូរនិយាយនឹងរត្តបាណីរជកបុត្រយ៉ាងនេះថា ម្នាលរត្តបាណីជា

សម្លាញ់ ខ្ញុំចង់ឲ្យអ្នកយកវត្ថុជាគ្រឿងលាបមានពណ៌លឿង មកជ្រលក់កូនស្វាឈ្មោលនេះ បោកគក់ឲ្យសព្វ ធ្វើឲ្យមានសម្បុរស្អាតទាំងពីរខាង ។ បពិត្រលោកដ៏ចម្រើន គ្រានោះ ព្រាហ្មណ៍នោះ មានតម្រេកមានចិត្តប្រតិព័ទ្ធចំពោះនាងមាណវិកានោះ ក៏យកកូនស្វាឈ្មោល ចូលទៅរកវត្ថបាណី-រជកបុត្រ លុះចូលទៅដល់ហើយ ក៏និយាយដូច្នេះនឹងវត្ថបាណីរជកបុត្រថា ម្នាលវត្ថបាណីជាសម្លាញ់ ខ្ញុំចង់ឲ្យអ្នកយកវត្ថុជាគ្រឿងលាបមានពណ៌លឿង មកជ្រលក់កូនស្វាឈ្មោលនេះឲ្យសព្វ ធ្វើឲ្យមានសម្បុរស្អាតទាំងពីរខាង ។ បពិត្រលោកដ៏ចម្រើន កាលដែលព្រាហ្មណ៍និយាយយ៉ាងនេះហើយ វត្ថបា-ណីរជកបុត្រ ក៏និយាយដូច្នេះនឹងព្រាហ្មណ៍នោះថា នែអ្នកដ៏ចម្រើន កូនស្វាឈ្មោលរបស់អ្នកនេះគួរដល់គ្រឿងជ្រលក់ តែមិនគួរដល់ការបោកគក់ មិនគួរដល់ការដុសខាត់ឡើយ ។ បពិត្រលោកដ៏ចម្រើន វាទៈរបស់ពួកនិគ្រន្ថពាល គួរដល់គ្រឿងជ្រលក់របស់ពួកជនពាលបាន ប៉ុន្តែ មិនគួរដល់គ្រឿងជ្រលក់របស់ពួកបណ្ឌិត ទាំងមិនគួរដល់សេចក្តីព្យាយាម មិនគួរដល់ការដុសខាត់ចិត្តឡើយ យ៉ាងនោះឯង ។ បពិត្រលោកដ៏ចម្រើន គ្រានោះ ព្រាហ្មណ៍នោះ ក៏បានយកសំពត់ថ្មីមួយគូ ចូលទៅរកវត្ថបាណីរជកបុត្រក្នុងសម័យជាខាងក្រោយ លុះចូលទៅដល់ហើយ ក៏និយាយដូច្នេះនឹងវត្ថ-បាណីរជកបុត្រថា ម្នាលវត្ថបាណីជាសម្លាញ់ ខ្ញុំចង់ឲ្យអ្នកយកវត្ថុ ជាគ្រឿងលាបមានពណ៌លឿង មកជ្រលក់សំពត់ថ្មី ១ គូនេះ បោកគក់ឲ្យសព្វ ធ្វើឲ្យមានសម្បុរម៉ដ្ឋទាំងពីរខាង ។ បពិត្រលោកដ៏ចម្រើន កាលដែលព្រាហ្មណ៍

និយាយយ៉ាងនេះហើយ វត្តបាណិវជកបុត្រ ក៏និយាយដូច្នេះនឹងព្រាហ្មណ៍នោះថា នែអ្នកដ៏ចម្រើន សំពត់ថ្មី ១ គួរបស់អ្នកនេះ គួរដល់គ្រឿងជ្រលក់ផង គួរដល់ការបោកគក់ផង គួរដល់ការដុសខាត់ផង ។ បពិត្រលោកដ៏ចម្រើន វាទះរបស់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ គួរដល់គ្រឿងជ្រលក់របស់ពួកបណ្ឌិត គួរដល់សេចក្ដីព្យាយាមផង គួរដល់ការដុសខាត់ផង របស់បណ្ឌិត តែមិនគួរដល់ពួកជនពាលទេ យ៉ាងនេះឯង ។ និគ្គន្ថនាដបុត្ត និយាយថា ម្នាលគហបតី បរិស័ទព្រមទាំងស្ដេច តែងស្គាល់អ្នកយ៉ាងនេះថា ឧបាលិគហបតីជាសាវ័ក របស់និគ្គន្ថនាដបុត្ត ម្នាលគហបតី ឥឡូវយើងនឹងចាំបានថា អ្នកជាសាវ័ករបស់បុគ្គលណា ។

[ ៨២ ] កាលដែលនិគ្គន្ថនាដបុត្តពោលយ៉ាងនេះហើយ ឧបាលិគហបតី ក៏ក្រោកអំពីអាសនៈ ធ្វើសំពត់បង់កធៀងស្មាម្ខាង ប្រណម្យអញ្ជលីឆ្ពោះទៅរកព្រះមានព្រះភាគ ហើយនិយាយដូច្នេះនឹងនិគ្គន្ថនាដបុត្តថា បពិត្រលោកដ៏ចម្រើន បើដូច្នោះ លោកចូរស្ដាប់ ខ្ញុំជាសាវ័ករបស់ព្រះមានព្រះភាគណា ដែលមានប្រាជ្ញាខ្ជាប់ខ្ជួន មានមោហៈទៅប្រាសហើយ មានបង្គោលបាក់បែកហើយ បានឈ្នះមារហើយ ឥតមានសេចក្ដីទុក្ខ មានព្រះទ័យស្មើល្អ មានសីលដ៏ចម្រើន មានប្រាជ្ញាល្អ បានឆ្លងនូវវិសមធម៌ ប្រាសចាកមន្ទិល ខ្ញុំជាសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គឥតមានសេចក្ដីសង្ស័យ មានព្រះទ័យស្រស់ស្រាយ មានអាមិសៈក្នុងលោកខ្ជាក់ចោលហើយ មានព្រះទ័យរីករាយ មានសមណធម៌ធ្វើស្រេចហើយ ជាមនុស្ស

មានសរីរៈតាំងនៅក្នុងទីបំផុត ជានរៈ រកបុគ្គលប្រៀបគ្មាន ប្រាសចាកធូលី គឺកិលេស ខ្ញុំជាសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណាឥតមានសេចក្តីសង្ស័យ ជាអ្នកឈ្លាសវៃ ព្រះអង្គជាអ្នកដឹកនាំសត្វ ជាសារថីដ៏ប្រសើរ ជាបុគ្គលប្រសើររកអ្នកណាស្មើគ្មាន មានធម៌ដ៏រុងរឿង ឥតមានកង្ខា ជាអ្នកធ្វើពន្លឺ ផ្តាច់បង់នូវមានះហើយ មានព្យាយាម ខ្ញុំជាសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គប្រសើរ មានគុណប្រមាណមិនបាន ប្រកបដោយគុណដ៏ជ្រាលជ្រៅ ដល់នូវសេចក្តីដឹងធ្វើនូវសេចក្តីក្សេម ប្រកបដោយប្រាជ្ញា ទ្រង់ឋិតនៅក្នុងធម៌ ទ្រង់សង្រួមដោយប្រពៃ ទ្រង់កន្លងបង់នូវកិលេសជាគ្រឿងជាប់នៅ ទ្រង់រួចចាកគ្រឿងសៅហ្មង ខ្ញុំជាសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គប្រសើរ ទ្រង់មានសេនាសនៈស្ងាត់ មានសំយោជនៈអស់ហើយ មានព្រះទ័យរួចស្រឡះចាកកិលេស មានប្រាជ្ញាជាគ្រឿងប្រឹក្សា ទ្រង់ប្រកបដោយសេចក្តីដឹង មានទទង់ គឺមានះដាក់ចុះហើយ ប្រាសចាករាគៈហើយ ទ្រង់ទូន្មានឥន្ទ្រិយហើយ មិនមានធម៌ជាគ្រឿងធ្វើសត្វឲ្យយឺតយូរ ខ្ញុំជាសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គជាឥសីទី ៧ មិនកុហក មានត្រៃវិជ្ជា ជាសត្វដ៏ប្រសើរ ទ្រង់លាងកិលេសអស់ហើយ ឈ្លាសវៃក្នុងបទគាថា ទ្រង់រម្ងាប់សេចក្តីក្រវល់ក្រវាយហើយ ទ្រង់មានសេចក្តីដឹងដ៏វិសេស ទ្រង់ប្រទានធម៌មុនជនទាំងពួង ជាអ្នកអង់អាច ខ្ញុំជាសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គជា

ព្រះអរិយៈ មានព្រះទ័យចម្រើនហើយ ដល់នូវគុណដែលគួរដល់ ទ្រង់សម្តែងនូវសេចក្តីជាក់ច្បាស់ ទ្រង់មានព្រះស្មារតី ទ្រង់មានប្រាជ្ញាជាគ្រឿងឃើញច្បាស់ មានព្រះទ័យមិនបានទន់ទៅ មានព្រះទ័យមិនប្រព្រឹត្តទៅក្នុងកិលេស មានព្រះទ័យមិនញាប់ញ័រ ទ្រង់ដល់នូវការស្ទាត់ ខ្ញុំជាសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គជាអ្នកប្រព្រឹត្តដោយប្រពៃ ជាអ្នកមានឈាន មានព្រះសន្តានមិនប្រព្រឹត្តទៅតាមកិលេស មានព្រះទ័យស្អាត មិនជាប់ចំពាក់ ឥតមានសេចក្តីខ្លាច មានកាយ និងចិត្តស្ងាត់ហើយ ដល់នូវភាវៈជាបុគ្គលប្រសើរ ជាអ្នកឆ្លងចាកលោក ជាអ្នកចម្លងសត្វ ខ្ញុំជាសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ព្រះអង្គមានព្រះទ័យស្ងប់រម្ងាប់ហើយ មានប្រាជ្ញាដូចជាផែនដី មានប្រាជ្ញាច្រើន ប្រាសចាកលោភៈហើយ ព្រះអង្គមានដំណើរដូចព្រះសម្ពុទ្ធអំពីបុរាណ ទ្រង់មានដំណើរល្អ ឥតមានបុគ្គលប្រៀប ឥតមានអ្នកណាស្មើ ជាអ្នកក្លៀវក្លា មានប្រាជ្ញាល្អិត ខ្ញុំជាសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គណា ទ្រង់ផ្តាច់តណ្ហាហើយ ទ្រង់ត្រាស់ដឹងនូវសច្ចធម៌ហើយ ទ្រង់ប្រាសចាកផ្សែងហើយ មិនប្រឡាក់ដោយតណ្ហា និងទិដ្ឋិ គួរទទួលគ្រឿងបូជា ព្រះអង្គជាយក្ខ ជាបុគ្គលដ៏ឧត្តម ឥតមានអ្នកណាប្រឹងបាន ព្រះអង្គជាធំ ដល់នូវយសដ៏ប្រសើរ ខ្ញុំជាសាវ័ករបស់ព្រះមានព្រះភាគអង្គនោះ ។

[ ៨៣ ] និគ្គន្ថនាដបុត្តពោលថា ម្នាលគហបតី ចុះគុណរបស់សមណគោតមទាំងអម្បាលនេះ អ្នកប្រមូលមកអំពីកាលណា ។ ឧបាលិគហបតីថា

បពិត្រលោកដ៏ចម្រើន គំនរផ្កាធំនៃផ្កាផ្សេងៗ មាលាការក្តី កូនសិស្សរបស់មាលាការក្តី ដែលជាអ្នកប៉ិនប្រសប់ ក្រងផ្កានោះ ឲ្យជាកម្រងដ៏វិចិត្រ មានឧបមាយ៉ាងណា បពិត្រលោកដ៏ចម្រើន ព្រះមានព្រះភាគអង្គនោះ មានគុណច្រើន មានគុណជាច្រើនរយ មានឧបមេយ្យយ៉ាងនោះ បពិត្រលោកដ៏ចម្រើន អ្នកណានឹងអាចមិនធ្វើ នូវសេចក្តីសរសើរដល់ព្រះអង្គ ដែលមានគុណគួរសរសើរបាន ។ គ្រានោះឯង និគ្គន្ថនាដបុត្តអត់ទ្រាំនឹងសក្ការៈ របស់ព្រះមានព្រះភាគមិនបាន ក៏ក្អួតឈាមក្តៅៗ ចេញពីមាត់ក្នុងទីនោះឯង ។

ឧបាលិវាទសូត្រទី ៦ ចប់

# អដ្ឋកថា

## ឧបាលិវាទសូត្រទី ៦

[ ៦២ ] ឧបាលិវាទសូត្រ មានពាក្យផ្ដើមយ៉ាងនេះថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **នាឡន្ទាយំ** សេចក្ដីថា ក្នុងនគរមានឈ្មោះយ៉ាងនេះថា នាលន្ទា ព្រោះធ្វើនគរនោះឲ្យជាគោចរគ្រាម គឺស្រុកសម្រាប់គោចរ ។ បទថា **បាវារិកម្ពវនេ** ប្រែថា ចម្ការស្វាយរបស់ទុស្សបាវារិកសេដ្ឋី បានឮថា ចម្ការស្វាយនោះ ជាចម្ការរបស់បាវារិកសេដ្ឋីនោះ ។ សេដ្ឋីនោះ ស្ដាប់ធម្មទេសនារបស់ព្រះមានព្រះភាគហើយជ្រះថ្លា សាងវិហារដែលប្រដាប់ដោយកុដិ ទីសម្ងំ និងមណ្ឌបជាដើម ក្នុងចម្ការនោះ ហើយវេរថ្វាយដល់ព្រះមានព្រះភាគ ។ ទើបវិហារនោះបានឈ្មោះថា បាវា-រិកម្ពវន ដូចវិហារឈ្មោះជីវកម្ពវន ដូច្នោះ អធិប្បាយថា ព្រះមានព្រះភាគប្រថាប់នៅនាបាវារិកម្ពវននោះ ។ តិរ្ថិយដែលបានឈ្មោះយ៉ាងនេះថា ទីឃត-បស្សី ព្រោះជាអ្នកបំពេញតបៈមកយូរហើយ ។ បទថា **បិណ្ឌបាតប្ប-ដិក្កន្តោ** ប្រែថា ត្រឡប់អំពីបិណ្ឌបាត ។ ពិតហើយ វោហារថា **បិណ្ឌបាត** មិនមានក្នុងលទ្ធិខាងក្រៅ ដូចក្នុងព្រះពុទ្ធសាសនាឡើយ ។

[ ៦៣ ] បទថា **បញ្ញាបេតិ** ប្រែថា សម្ដែងតាំងទុក ។ ទីឃតបស្សីតិរ្ថិយសួរតាមលទ្ធិនិគ្រន្ថ ទើបពោលពាក្យនេះថា **ទណ្ឌានិ បញ្ញាបេតិ** ។ ក្នុងបទនេះថា **កាយទណ្ឌំ វចីទណ្ឌំ មនោទណ្ឌំ** ពួកនិគ្រន្ថបញ្ញត្តទណ្ឌ ២ ខាងដើមថា តូចតាច ថាមិនមានចិត្ត ដូចជាកាលខ្យល់បក់ មែកឈើក៏

កម្រើក ទឹកក៏រលក ព្រោះមែកឈើ និងទឹកនោះ មិនមានចិត្ត យ៉ាងណា សូម្បីកាយទណ្ឌ ក៏មិនមានចិត្ត ដូច្នោះ ។ម្យ៉ាងទៀត កាលខ្យល់បក់មែកឈើ មានជាងត្នោតជាដើម ទើបមានសំឡេង ទើបទឹកមានសំឡេង ព្រោះមែកឈើ និងទឹកនោះមិនមានចិត្ត យ៉ាងណា សូម្បីវចីទណ្ឌ ក៏មិនមានចិត្ត ដូច្នោះ ពួកនិគ្រន្ថបញ្ញត្តទណ្ឌទាំង ២ យ៉ាងនេះថា មិនមានចិត្ត ដូចពោលមក ដូច្នេះ ។ បញ្ញត្តថា តែចិត្តជាមនោទណ្ឌ ។ គ្រានោះ ព្រះមានព្រះភាគមានព្រះពុទ្ធបំណងនឹងឲ្យទីឃតបស្សីនិគ្រន្ថអះអាងពាក្យនោះទុក ទើបត្រាស់សួរថា **កឹ បន តបស្សិ** ជាដើម ក្នុងព្រះបាលីនោះ ពាក្យនោះឯង ឈ្មោះថាកថាវត្ថុ ក្នុងពាក្យដែលថា **កថាវត្ថុស្មឹ** អធិប្បាយថា ទ្រង់ឲ្យនិគ្រន្ថនោះតាំងនៅក្នុងវាចា ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ធ្វើយ៉ាងនេះ ឆ្លើយថា ព្រោះព្រះមានព្រះភាគ ទ្រង់ឃើញថា ទីឃតបស្សីនិគ្រន្ថនេះ នឹងយកពាក្យនេះទៅប្រាប់និគ្រន្ថធំ ដែលជាសាស្តារបស់ខ្លួន និងឧបាលិគហបតីដែលអង្គុយក្នុងបរិស័ទរបស់និគ្រន្ថនោះ ឧបាលិនោះស្តាប់ពាក្យនេះហើយ ក៏នឹងមកលើកវាទៈជាមួយតថាគតៗ នឹងសម្តែងធម៌ដល់ឧបាលិនោះ ឧបាលិនោះនឹងដល់នូវសរណៈ ៣ បន្ទាប់អំពីនោះ តថាគតនឹងប្រកាសសច្ចៈ ៤ ដោយអំណាចការប្រកាសសច្ចៈ ឧបាលិនោះនឹងតាំងនៅក្នុងសោតាបត្តិផល ។ ពិតហើយ តថាគតបំពេញបារមីទាំងឡាយ ក៏ដើម្បីសង្គ្រោះបុគ្គលដទៃៗប៉ុណ្ណោះ ព្រះមានព្រះភាគទ្រង់ឃើញប្រយោជន៍នេះ ទើបទ្រង់ធ្វើយ៉ាងនេះ ។

[ ៦៤ ] និគ្រន្ថសួរតាមលទ្ធិរបស់ព្រះពុទ្ធ ពោលពាក្យនេះថា **កម្មានិ**

**បញ្ញាបេសិ** ។ ក្នុងបទនេះថា **កាយកម្មំ វចីកម្មំ មនោកម្មំ** បានដល់ ចេតនា ២០ គឺចេតនាក្នុងកាមាវចរកុសល ៨ ចេតនាក្នុងអកុសល ១២ ដែលដល់នូវការប្រកាន់ការទទួល ការលែង និងការកម្រើកក្នុងកាយទ្វារ ឈ្មោះថា **កាយកម្ម** ។ ចេតនា ២០ នោះឯង ដែលមិនដល់នូវការប្រកាន់ជាដើមក្នុងកាយទ្វារ តែឲ្យដល់នូវការបន្ទឺវាចាកើតឡើងក្នុងវចីទ្វារ ឈ្មោះថា **វចីកម្ម** ។ ចេតនាក្នុងកុសល និងអកុសល ២៩ ដែលមិនដល់នូវការកម្រើកក្នុងទ្វារទាំង ២ ដែលកើតឡើងក្នុងមនោទ្វារ ឈ្មោះថា **មនោកម្ម** ។

ម្យ៉ាងទៀត កាលពោលដោយសង្ខេប កាយទុច្ចរិត ៣ ឈ្មោះថា **កាយកម្ម** វចីទុច្ចរិត ៤ ឈ្មោះថា **វចីកម្ម** មនោទុច្ចរិត ៣ ឈ្មោះថា **មនោកម្ម** ។ តែក្នុងព្រះសូត្រនេះ **កម្ម** ឈ្មោះថា **ទណ្ឌៈ** ។ ចេតនាដែលនឹងដល់ក្នុងព្រះសូត្រលំដាប់តទៅយ៉ាងនេះថា បុញ្ញកម្ម ៤ នេះ តថាគតនឹងធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ក្រៃលែងឯង ប្រកាសហើយ ឈ្មោះថា **ទណ្ឌៈ** ។ ចេតនាដែលប្រព្រឹត្តទៅក្នុងកម្មឯណាមួយក៏បាន មានប្រភេទដូចជា កម្មខ្មៅមានវិបាកខ្មៅជាដើម ។ ក្នុងនិទ្ទេសវារៈនៃកម្មនោះ លោកក៏ពោលចេតនានោះដោយន័យថា រមែងតាក់តែងកាយសង្ខារ ព្រមទាំងការបៀតបៀនដូច្នេះជាដើម ។ ក្នុងសូត្រនេះ ចេតនាដែលប្រព្រឹត្តទៅក្នុងកាយទ្វារ លោកសំដៅយកកាយកម្ម ចេតនាដែលប្រព្រឹត្តទៅក្នុងវចីទ្វារ ជាវចីកម្ម ចេតនាដែលប្រព្រឹត្តទៅក្នុងមនោទ្វារ ជាមនោកម្ម ។ ព្រោះហេតុនោះ ទើបពោលថា កម្មក្នុងព្រះសូត្រនេះ ឈ្មោះថា **ទណ្ឌៈ** ។ ចេតនាក្នុងព្រះសូត្រ ក្នុងលំដាប់តទៅ

ក៏ឈ្មោះថា **ធុរៈ** ។ ពិតហើយ ព្រះមានព្រះភាគទ្រង់បញ្ញត្តកម្មថា កម្ម ដូចគ្នានឹងចេតនាក្នុងព្រះសូត្រនេះឯង ក៏ឈ្មោះថា កម្ម ដូចគ្នា ។ សមដូចព្រះមានព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលចេតនាថា ជាតួកម្ម ព្រោះសត្វគិតហើយ ទើបធ្វើកម្ម ។

សួរថា ព្រោះហេតុអ្វី ទើបត្រាស់ហៅចេតនាថាជាតួកម្ម ឆ្លើយថា ព្រោះកម្ម មានចេតនាជាមូល ។

ក្នុងអកុសល និងកុសលទាំង ២ នោះ ព្រះមានព្រះភាគ កាលត្រាស់កាយកម្ម វចីកម្ម ដែលដល់អកុសលថាជាធំ ដូច្នេះ រមែងមិនលំបាក ត្រាស់មនោកម្មខាងកុសលថាជាធំ ដូច្នេះ ក៏មិនលំបាក ពិតហើយ បុគ្គលព្យាយាមដោយកាយតែម្យ៉ាង ធ្វើកម្ម ៤ មានមាតុឃាតជាដើម ក៏ដោយកាយប៉ុណ្ណោះ បុគ្គលធ្វើកម្ម គឺសង្ឃភេទ នឹងញុំាងផលឲ្យបុគ្គលតាំងនៅក្នុងនរកអស់មួយកប្ប ក៏ដោយវចីទ្វារ ដូច្នេះ ព្រះមានព្រះភាគត្រាស់កាយកម្ម វចីកម្មខាងអកុសលថាជាធំ ទើបឈ្មោះថា មិនលំបាក ។ ឯចេតនាក្នុងឈានតែម្យ៉ាង រមែងនាំសគ្គសម្បត្តិមកឲ្យ ដល់ទៅ ៨៤០០០ កប្ប ចេតនាក្នុងមគ្គតែម្យ៉ាង ដកនូវអកុសលគ្រប់យ៉ាង រមែងកាន់យកអរហត្តបាន ដូច្នោះ ព្រះមានព្រះភាគ កាលត្រាស់មនោកម្មខាងកុសលថាធំ ទើបមិនលំបាក ។ តែក្នុងទីនេះ ព្រះមានព្រះភាគ កាលត្រាស់មនោកម្មខាងអកុសលថាមានទោសច្រើន ទើបត្រាស់សំដៅដល់និយតមិច្ឆាទិដ្ឋិ ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលមានទោសធំយ៉ាងនេះ ដូចមិច្ឆាទិដ្ឋិនេះឡើយ ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយ មានតែមិច្ឆាទិដ្ឋិ ជាទោសក្រៃលែង ។

ឥឡូវនេះ និគ្រន្ថ កាលនឹងធ្វើដំណើរដែលព្រះសាស្ដា ទ្រង់ធ្វើដំណើរ សូម្បីមើលមិនឃើញការសម្រេចប្រយោជន៍ណាមួយ ក៏ទូលសួរថា **កឹ បនាវុសោ គោតម** ដូច្នេះជាដើម ។

[ ៦៥ ] បទថា **នាលន្ទិយា** សេចក្ដីថា ស្រុកឈ្មោះនាលន្ទា របស់ឧបាលិគហបតីមាន ។ មនុស្សទាំងឡាយ រាប់អាននិគ្រន្ថដែលមកអំពីស្រុកនោះ និគ្រន្ថនោះ ត្រូវបរិស័ទនោះហែហម ដោយគិតថា ពួកយើងនឹងសួរសុខទុក្ខនិគ្រន្ថធំ ដែលជាសាស្ដារបស់ពួកយើង នៅក្នុងភូមិនោះ ក៏ទៅឯនាលន្ទានោះ លោកសំដៅដល់នាលន្ទានោះ ទើបពោលថា **នាល-ន្ទិយា បរិសាយ** អធិប្បាយថា ដែលបរិស័ទអ្នកអាស្រ័យនៅក្នុងនាលន្ទា ។ បទថា **ឧបាលិប្បមុខាយ** ប្រែថា មានឧបាលិគហបតីជាប្រធាន ។ ម្យ៉ាងទៀត **នាលន្ទិយា** ប្រែថា បុគ្គលល្ងង់ខ្លៅ អធិប្បាយថា គ្រាស់ ។ បទថា **ឧបាលិប្បមុខាយ** សេចក្ដីថា ក្នុងបរិស័ទនោះ ឧបាលិគហបតីប៉ុណ្ណោះជាអ្នកមានបញ្ញាតិច ឧបាលិគហបតីនោះជាប្រមុខ គឺជាប្រធានរបស់មនុស្សទាំងនោះ ព្រោះហេតុនោះ ទើបលោកពោលថា **ឧបាលិប្បមុខាយ** ។ សព្ទថា **ហន្ទ** ជានិបាត ចុះក្នុងអត្ថថា ពោលអញ្ជើញ ។ សព្ទថា **ជយោ** ប្រែថា ជោគជ័យ ។ សព្ទថា **ឱឡារិកស្ស** ប្រែថា ធំ ។ សព្ទថា **ឧបនិធាយ**

ប្រែថា លើកឡើងមក លោកអធិប្បាយថា និគ្រន្ថសម្ដែងថា កាយទណ្ឌ ដែលលើកឡើងមក មើលឃើញបានយ៉ាងនេះថា កាយទណ្ឌនេះ ធំហ្ន៎ កាយទណ្ឌជាធំហ្ន៎ មនោទណ្ឌទាប នឹងស្អាតអ្វី នឹងល្អអំពីណា មិនល្អឡើយ សូម្បីគ្រាន់តែលើកឡើងមក ក៏មិនគ្រប់គ្រាន់ ។

[ ៦៦ ] បទថា **សាធុ សាធុ ភន្តេ តបស្សី** សេចក្ដីថា ឧបាលិ-គហបតី កាលឲ្យសាធុការដល់តបស្សីនិគ្រន្ថ ក៏ហៅសាស្ដានាជបុត្រថា **ភន្តេ** ។

[ ៦៧ ] បទថា **ន ខោ មេតំ ភន្តេ រុច្ចតិ** សេចក្ដីថា ទីឃតបស្សី-និគ្រន្ថជំទាស់ថា បពិត្រលោកម្ចាស់ សេចក្ដីនេះ នឹងឲ្យឧបាលិគហបតីទៅលើកវាទៈជាមួយព្រះសមណគោតមនោះ មិនពេញចិត្តដល់ខ្ញុំឡើយ ។ សព្ទថា **មាយាវី** ប្រែថា ធ្វើកលបញ្ឆោត ។ សព្ទថា **អាវដ្ដនិមាយំ** ប្រែថា មាយា គឺការត្រឡប់ចិត្ត ។ បទថា **អាវដ្ដេតិ** ប្រែថា កលព័ទ្ធចាប់ ។ បទថា **គច្ឆ ត្វំ គហបតិ** សេចក្ដីថា ហេតុអ្វី និគ្រន្ថធំបញ្ជូនឧបាលិគហបតីទៅដល់ទៅ ៣ ដង ឯទីឃតបស្សី និគ្រន្ថ ក៏ជំទាស់គ្រប់គ្រា ព្រោះថា និគ្រន្ថធំ ទោះអាស្រ័យនៅនគរមួយជាមួយព្រះមានព្រះភាគ ក៏មិនធ្លាប់ឃើញព្រះមានព្រះភាគ ព្រោះថា បុគ្គលណា ប្ដេជ្ញាខ្លួនដោយវាទៈថា ជាសាស្ដា បុគ្គលនោះមិនលះបង់ប្ដេជ្ញានោះ ក៏មិនគួរឃើញព្រះពុទ្ធ ព្រោះដូច្នោះ និគ្គណ្ឋនាជ-បុត្រនោះ មិនដឹងដល់សម្បត្តិ គឺការឃើញ និងភាវៈ គឺកថាដែលសម្ដែងនិយ្យានិកធម៌នៃព្រះទសពល ព្រោះមិនបានឃើញព្រះពុទ្ធ ទើបអះអាង

បញ្ជូនឧបាលិគហបតីទៅដល់ទៅ ៣ ដង ។ ឯទីឃតបស្សីនិគ្រន្ថ ជួនកាល ចូលគាល់ព្រះមានព្រះភាគ ឈរខ្លះ អង្គុយខ្លះ សួរបញ្ហាខ្លះ ដឹងដល់សម្បត្តិ គឺការឃើញខ្លះ ភាវៈ គឺកថាសម្តែងនិយ្យានិកធម៌ខ្លះ នៃព្រះតថាគត ។ គ្រានោះ ទើបគាត់គិតថា ឧបាលីនេះ ជាគហបតី ជាបណ្ឌិត ទៅកាន់សម្នាក់ព្រះគោតម ហើយក៏គប្បីជ្រះថ្លា ព្រោះឃើញខ្លះ ព្រោះស្តាប់កថាសម្តែងនិយ្យា-និកធម៌ខ្លះ ដូច្នោះ ឧបាលីក៏នឹងមិនត្រឡប់មកកាន់សម្នាក់របស់ពួកយើងទៀតឡើយ ។ ព្រោះដូច្នោះ ទើបគាត់ជំទាស់ដល់ទៅ ៣ ដងដូចគ្នា ។

[ ៦៨ ] សព្ទថា **អភិវាទេត្វា** ប្រែថា ថ្វាយបង្គំ ។ សេចក្តីពិត មនុស្សទាំងឡាយ ឃើញព្រះសាស្តាហើយ ទោះជាអ្នកជ្រះថ្លាក្តី មិនជ្រះថ្លាក្តី ដោយច្រើន ថ្វាយបង្គំទាំងអស់ អ្នកដែលមិនថ្វាយបង្គំ មានចំនួនតិច ព្រោះហេតុអ្វី ព្រោះមនុស្សដែលកើតក្នុងត្រកូលខ្ពង់ខ្ពស់ សូម្បីគ្រប់គ្រងផ្ទះ ក៏សំពះគ្នាទាំងអស់ ។ ឯគហបតីនេះថ្វាយបង្គំ ព្រោះជាអ្នកជ្រះថ្លា បានឮថាគ្រាន់តែឃើញប៉ុណ្ណោះ ក៏ជ្រះថ្លាហើយ ។ បទថា **អាគមា នុ ខ្វិធ** កាត់បទជា **អាគមា នុ ខោ ឥធ** ។ បទថា **សាធុ សាធុ ភន្តេ តបស្សី** សេចក្តីថា ឧបាលិគហបតី កាលនឹងឲ្យសាធុការដល់ទីឃតបស្សីនិគ្រន្ថ ក៏ហៅព្រះមានព្រះភាគ **ភន្តេ** ។ បទថា **សច្ចេ បតិដ្ឋាយ** សេចក្តីថា តាំងនៅក្នុងវចីសច្ចៈ មិនកម្រើក ដូចបង្គោលដែលបោះចុះក្នុងគំនរអង្កាម ។ បទថា **សិយា នោ** ប្រែថា គប្បីមានដល់ពួកយើង ។

[ ៦៩ ] សព្ទថា **ឥធ** ប្រែថា ក្នុងលោកនេះ ។ សព្ទថា **អស្ស** ប្រែ

ថា គប្បីមាន ។ បទថា **សីតោទកំ បដិក្ខិត្តោ** សេចក្តីថា និគ្រន្ថហាមទឹកត្រជាក់ ដោយយល់ថា មានសត្វ ។ ពាក្យនេះ លោកពោលសំដៅដល់ទឹកដែលមានសត្វ ។ បទថា **មនោសត្តា ឆាម ទេវា** សេចក្តីថា ទេវតាទាំងឡាយដែលជាអ្នកជាប់ អ្នកជំពាក់ អ្នកជាប់ស្អិតហើយក្នុងចិត្ត ។ បទថា **មនោបដិពទ្ធោ** សេចក្តីថា ឧបាលិគហបតីសម្តែងថា បុគ្គលដែលជាប់ជំពាក់នៅក្នុងចិត្ត តែងធ្វើកាលកិរិយា ព្រោះហេតុនោះ ទើបបុគ្គលនោះ កើតក្នុងទេវតាពពួកមនោសត្ត ( ពួកទេវតាដែលជាប់ជំពាក់នៅក្នុងចិត្ត ) ។ ពិតហើយ រោគដែលកើតអំពីចិត្ត នឹងមានដល់បុគ្គលនោះ ព្រោះហេតុនោះ ការផឹកទឹកក្តៅ ឬនាំទឹកក្តៅចូលទៅដើម្បីប្រយោជន៍ដល់ការលាងដៃ និងជើងជាដើម ឬដើម្បីប្រយោជន៍ដល់ការងូតខ្លួនឯង និងអ្នកដទៃ ទើបមិនគួរដល់បុគ្គលនោះ រោគនឹងកម្រើក ។ ទឹកត្រជាក់ទើបគួររម្ងាប់រោគបាន ។ និគ្រន្ថនេះសេពតែទឹកក្តៅប៉ុណ្ណោះ កាលមិនបានទឹកក្តៅ ក៏សេពតែទឹកបាយ និងទឹកជ្រក់ជំនួស និគ្រន្ថនោះត្រូវការផឹក និងត្រូវការបរិភោគទឹកត្រជាក់នោះសូម្បីដោយចិត្ត ព្រោះហេតុនោះ ទើបមនោទណ្ឌរបស់គេបែក ព្រោះមិនបានផឹក និងបរិភោគទឹកត្រជាក់នោះ បុគ្គលនោះមិនអាចនឹងពោលថា ខ្ញុំនឹងរក្សាកាយទណ្ឌ និងវចីទណ្ឌ ព្រោះហេតុនោះ ខ្ញុំត្រូវការផឹក ឬត្រូវការបរិភោគទឹកត្រជាក់ ចូរអ្នកឲ្យតែទឹកត្រជាក់ប៉ុណ្ណោះចុះ ។ កាយទណ្ឌ វចីទណ្ឌនៃបុគ្គលនោះ សូម្បីរក្សាទុកយ៉ាងនេះ ក៏មិនអាចនឹងទាញចុតិ និងបដិសន្ធិបាន ។ ឯមនោទណ្ឌសូម្បីបែកទៅហើយ ក៏គង់ទាញចុតិ និងបដិសន្ធិបាន

នោះឯង ដូច្នេះ ទើបព្រះមានព្រះភាគត្រាស់ជាមួយគេថា កាយទណ្ឌ និង វចីទណ្ឌ ទាប គ្រោតគ្រាត មានកម្លាំងខ្សោយ មនោទណ្ឌមានកម្លាំងធំ ឧបាសកនោះក៏រិតក្កថា គេកំណត់ដោយអំណាច ។ ពាក្យសួរថា អស្សាស: និងបស្សាស: របស់អសញ្ញីសត្វ រមែងប្រព្រឹត្តទៅមិនបានសូម្បីទាំង ៧ ថ្ងៃ តែអសញ្ញីសត្វទាំងនោះ គេមិនហៅថា ស្លាប់ ព្រោះមានត្រឹមតែការប្រព្រឹត្តទៅនៃសន្តតិនៃចិត្តប៉ុណ្ណោះ កាលណាចិត្តរបស់អសញ្ញីសត្វនោះ មិនប្រព្រឹត្តទៅ កាលនោះ ទើបស្លាប់ ។ ទោះបីភាពជាអ្នកដែលគេគួរពោលថា ចូរនាំសត្វទាំងនោះទៅដុតចុះ កាយទណ្ឌប្រាសចាកការទៅ មិនខ្វល់ខ្វាយ វចីទណ្ឌក៏ដូចគ្នា តែសត្វទាំងនោះគង់ចុតិខ្ល: បដិសន្ធិខ្ល: ក៏ដោយចិត្តតែមួយ ព្រោះហេតុនេះ ទើបមនោទណ្ឌធំ មនោទណ្ឌប៉ុណ្ណោះ ឈ្មោះថា ធំ ក៏ព្រោះចិត្តសូម្បីបែកទៅហើយ ក៏គង់ទាញចុតិ និងបដិសន្ធិបាន ឯពាក្យរបស់និគ្រន្ថធំ ដែលជាសាស្តារបស់ខ្ញុំ ជាពាក្យដែលមិននាំសត្វចេញចាកទុក្ខបានពិត ។ តែឧបាលិគហបតីនោះ ត្រូវការស្តាប់បញ្ហាបដិភាណដ៏វិចិត្រនៃព្រះមានព្រះភាគ ទើបមិនស្របតាមមុន ។ បទថា **ន ខោ តេ សន្ធិយតិ** ប្រែថា ពាក្យរបស់អ្នកមិនជាប់តគ្នា ។ បទថា **បុរិមេន វា បច្ឆិមំ** សេចក្តីថា ពាក្យថា មនោទណ្ឌធំក្នុង ឥឡូវនេះ និងពាក្យមុនដែលថា កាយទណ្ឌធំមិនជាប់តគ្នា ។ បទថា **បច្ឆិមេន វា បុរិមំ** សេចក្តីថា ពាក្យមុននោះ និងពាក្យក្រោយមិនជាប់តគ្នា ។

[ ៧០ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់នាំហេតុដទៃៗ មកដល់

ឧបាលិគហបតីនោះ ទើបត្រាស់សួរថា **តំ កឹ មញ្ញសិ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **ចតុយាមសំវរសំវុតោ** សេចក្ដីថា បុគ្គលសង្រួមហើយដោយការសង្រួម ៤ ចំណែក គឺការមិនសម្លាប់សត្វឯង មិនប្រើគេឲ្យសម្លាប់ មិនពេញចិត្តចំពោះការសម្លាប់ចំណែក ១ មិនលួចទ្រព្យឯង មិនប្រើឲ្យគេលួច មិនពេញចិត្តចំពោះអ្នកលួចចំណែក ១ មិននិយាយកុហកឯង មិនប្រើឲ្យអ្នកដទៃនិយាយកុហក មិនពេញចិត្តចំពោះបុគ្គលដែលពោលកុហកចំណែក ១ មិនប្រាថ្នាកាមគុណឯង មិនប្រើឲ្យអ្នកដទៃប្រាថ្នាក្នុងកាមគុណ មិនពេញចិត្តចំពោះអ្នកប្រាថ្នាកាមគុណចំណែក ១ ។ ក្នុងបទទាំងនោះ បទថា **ភាវិតំ** ដោយអត្ថថា កាមគុណ ៥ ។ បទថា **សព្វវារិវារិតោ** ប្រែថា ហាមទឹកទាំងអស់ អធិប្បាយថា ទឹកត្រជាក់ទាំងអស់ក៏ហាម ។ ពិតហើយ និគ្រន្ថនោះសម្គាល់ថា មានសត្វនៅក្នុងទឹកត្រជាក់ ព្រោះដូច្នោះ ទើបមិនប្រើទឹកត្រជាក់ ។ ម្យ៉ាងទៀត បទថា **សព្វវារិវារិតោ** ដោយអត្ថថា ហាមនូវបាបដោយការវៀរបាបទាំងអស់ ។ បទថា **សព្វវារិយុត្តោ** ដោយអត្ថថា ប្រកបដោយការហាមបាបទាំងអស់ ។ បទថា **សព្វវារិធុតោ** ដោយអត្ថថា កម្ចាត់បាប ដោយការវៀរបាបទាំងអស់ ។ បទថា **សព្វវារិផុដ្ឋោ** ដោយអត្ថថា ពាល់ត្រូវដោយការឃាត់នូវបាបទាំងអស់ ។ បទថា **ខុទ្ទកេ បាណេ សង្ឃាដំ អាបាទេតិ** សេចក្ដីថា ធ្វើសត្វតូចៗ ឲ្យដល់ឃាតៈ ( គឺស្លាប់ ) ។

បានឮថា និគ្រន្ថនោះ បញ្ញត្តសត្វមានឥន្ទ្រិយ ១ ថា បាណៈ បញ្ញត្តសត្វមានឥន្ទ្រិយ ២ ថា បាណៈ បញ្ញត្តស្ងឹកឈើស្ងួត ស្ងឹកឈើចាស់ៗ

ដុំក្រួស និងអំបែងថា បាណៈទាំងអស់ ។ ក្នុងបាណៈទាំងនោះ និគ្រន្ថទាំងនោះ សម្គាល់ថា តំណក់ទឹកតូចៗ ( ផ្គុំគ្នា ) ក៏ធំ ដុំថ្មតូចៗ ( ផ្គុំគ្នា ) ក៏ធំ ។ ពាក្យនោះ លោកពោលដល់សេចក្តីនោះ ។ បទថា **កិស្មឹ បញ្ញាបេតិ** សេចក្តីថា បញ្ញត្តត្រង់ចំណែកនោះ គឺចំណែកណា ។ **មនោទណ្ឌស្មឹ** គឺក្នុងចំណែកដែលជាមនោទណ្ឌ ។ ឧបាសកនេះកាលពោលថា **ភន្តេ** ក៏កំណត់ដឹងដោយខ្លួនឯងថា និគ្រន្ថជំរបស់អញ បញ្ញត្តកម្មដែលមិនដាក់ចិត្តធ្វើថាមានទោសតិច កម្មដែលដាក់ចិត្ត ថាមានទោសច្រើន ហើយបញ្ញត្តចេតនា ថាជាមនោទណ្ឌ ពាក្យរបស់គាត់ មិននាំសត្វចេញចាកទុក្ខពិត ឯព្រះមានព្រះភាគនាំសត្វចេញចាកទុក្ខបានពិត ។ បទថា **ឥទ្ធា** ប្រែថា មាំទាំ ។ បទថា **ផីតា** ប្រែថា ទូលាយ ដូចផ្កាឈើដែលរីកស្គុសស្គាយទាំងដើម ។ បទថា **អាកិណ្ណមនុស្សា** ប្រែថា ដេរដាសដោយមនុស្ស ។ បទថា **បាណា** បានដល់ សត្វតិរច្ឆាន មានដំរី សេះជាដើម និងមនុស្ស មានស្រី ប្រុស និងទារកជាដើម ។ បទថា **ឯកមំសខលំ** បានដល់ គំនរសាច់មួយពំនូក ។ បទថា **បុញ្ជំ** ជាវេវចនៈនៃពាក្យថា **ឯកមំសខលំ** នោះឯង ។ បទថា **ឥទ្ធិមា** គឺជាបុគ្គលដល់ព្រមដោយអានុភាព ។ បទថា **ចេតោវសិប្បត្តោ** គឺបុគ្គលដល់ការជំនាញក្នុងចិត្ត ។ បទថា **ភស្មំ ករិស្សាមិ** ប្រែថា នឹងធ្វើឲ្យជាផេះ ។ បទថា **កិញ្ហិ សោភតិ ឯកា ឆវា នាឡន្ទា** សេចក្តីថា គហបតីនោះ កាលពោលពាក្យនេះ កំណត់បានថា ដោយកាយប្បយោគ សូម្បីមនុស្ស ៥០ នាក់ ក៏ធ្វើក្រុងនាលន្ទាមួយឲ្យជាលានសាច់តែមួយបាន ឯអ្នកមានឫទ្ធិម្នាក់ក៏

អាចធ្វើក្រុងនាលន្ទាឲ្យជាផេះបាន ដោយការប្រទូស្តផ្លូវចិត្តតែមួយប៉ុណ្ណោះ ។ ពាក្យរបស់និគ្រន្ថធំរបស់អញ មិននាំសត្វចេញចាកទុក្ខ ពាក្យនៃព្រះមានព្រះភាគប៉ុណ្ណោះ នាំចេញចាកទុក្ខបានពិត ។ បទថា **អរញ្ញំ អរញ្ញភូតំ** សេចក្តីថា មិនឲ្យជាស្រុក គឺជាព្រៃនោះឯង ឈ្មោះថា កើតជាព្រៃ ។ បទថា **ឥសិនំ មនោបទោសេន** សេចក្តីថា ដោយការប្រទូស្តផ្លូវចិត្តនៃឥសីទាំងឡាយ ធ្វើឲ្យវិនាសហើយ រដ្ឋទាំងឡាយនោះ ទេវតាជាអ្នកអត់ទ្រាំមិនបាន ប្រទូស្តផ្លូវចិត្តនោះធ្វើឲ្យវិនាសហើយ ឯអ្នកស្រុកសម្គាល់ថា បុគ្គលមានចិត្តប្រទូស្តធ្វើឲ្យវិនាសហើយ ដើម្បីប្រយោជន៍ដល់ឥសីទាំងឡាយ ព្រោះដូច្នោះ គប្បីជ្រាបថា បុគ្គលនោះតាំងនៅក្នុងវាទៈរបស់លោកនេះ ទើបលើកវាទៈនេះឡើងធ្វើហើយ ។ ក្នុងសេចក្តីនោះ គប្បីជ្រាបថា ព្រៃទណ្ឌកីជាដើម ក្លាយជាព្រៃដូចតទៅនេះ

## រឿង ព្រៃទណ្ឌកី

កាលបរិស័ទរបស់សរភង្គតាបសពោធិសត្វ ចម្រើនបរិបូណ៌ហើយ តាបសឈ្មោះកីសវច្ឆៈ ជាសិស្សរបស់ព្រះពោធិសត្វ បំណងនៅដោយស្ងាត់ស្ងៀម ទើបលះពួកក្រុមទៅ អាស្រ័យនគរឈ្មោះកុម្ភបុរៈ នៃស្តេចទណ្ឌកីដែនកាលិង្គៈ ដែលបន្តអំពីស្ទឹងគោធាវារី ចម្រើនវិវេកនៅក្នុងព្រះរាជឧទ្យាន សេនាបតីរបស់ព្រះបាទទណ្ឌកីនោះជាឧបដ្ឋាក ។ គ្រានោះ នាងគណិកាម្នាក់ជិះរទេះ មានស្រី ៥០០ ជាបរិវារ ធ្វើនគរឲ្យល្អត្រាច់ទៅ ។ មហាជនសម្លឹងឃើញ ក៏ចោមរោមនាងត្រាច់តាមទៅ រហូតផ្លូវក្នុងព្រះនគរមិនគ្រប់គ្រាន់

ព្រះរាជាបើកបង្អួចប្រថាប់ឈរ ឃើញនាង ទើបត្រាស់សួរពួករាជបុរសថា ស្រីនោះជានរណា ពួករាជបុរសទូលថា បពិត្រព្រះអង្គ ស្រីនគរសោភិនី របស់ព្រះអង្គ ។ ព្រះរាជាកើតសេចក្តីប្រណែន ទ្រង់ព្រះតម្រិះថា នគរដែល ស្រីនេះធ្វើឲ្យស្អាត នឹងស្អាតបានដូចម្តេច ហើយត្រាស់ដកហ៊ានន្ទរសក្តិនោះ ចេញ តាំងអំពីនោះមក នាងគណិកានោះ ក៏ធ្វើសេចក្តីស្និទ្ធស្នាលជាមួយ មនុស្សនោះៗ ស្វែងរកហ៊ានន្ទរឿយៗ ទៅ ថ្ងៃមួយ ចូលទៅកាន់ព្រះរាជ-ឧទ្យាន ជួបតាបសអង្គុយលើដុំថ្ម ផ្អែកផ្ទាំងថ្មដែលលយចុះមក ក្បែរចុងទី ចង្រ្កម ទើបគិតថា តាបសនេះស្មោកគ្រោកពិតហ្ន៎ អង្គុយមិនកម្រើក ចង្កូម ចេញមកក្រោមាត់ ពុកមាត់ ពុកចង្កាបិទដើមទ្រូង រោមក្លៀកទាំងសងខាង ស្កូញស្កាញ គ្រានោះ នាងកើតទោមនស្សថា អញត្រាច់ទៅដោយកិច្ចឯណា នីមួយ ក៏មកជួបនឹងមនុស្សកាឡកណ្ណីនេះទៅវិញ អ្នកទាំងឡាយនាំគ្នាមក ឃើងនឹងលាងក្អែក ក៏ប្រើឲ្យគេយកទឹក និងឈើស្ទន់មកហើយ ក៏ទំពាឈើ ស្ទន់ខ្ពុរទឹកមាត់ជាដុំៗ ដាក់លើខ្លួនតាបសនោះ ហើយបោះឈើស្ទន់លើកំពូល ជដា ខ្ពុរមាត់ខ្លួនឯងហើយ យកទឹកស្រោចលើក្បាលតាបស គិតថា អញ លាងក្អែកដែលឃើញមនុស្សកាឡកណ្ណីហើយ ទោសរបស់អញក៏អណ្តែត ចេញហើយ ក៏ចេញទៅអំពីព្រះរាជឧទ្យាន ។ ក្នុងថ្ងៃនោះឯង ព្រះរាជាទ្រង់ រឭកបាន ក៏ត្រាស់សួរថា នែបាទាំងឡាយ ស្រីនគរសោភិនីនៅឯណា ។ រាជបុរសឆ្លើយថា បពិត្រព្រះអង្គ នៅក្នុងនគរនេះឯង ។ ទ្រង់ក៏ត្រាស់ថា ចូរពួកអ្នកឲ្យហ៊ានន្ទរជាប្រក្រតីដល់នាងដូចមុន ហើយទ្រង់បញ្ជាឲ្យប្រទាន

ឋានន្តរ ។ នាងអាស្រ័យបុញ្ញកម្មដែលធ្វើមកអំពីមុន ទើបបានឋានន្តរ តែនាងយល់ខុសទៅថា ព្រោះបានស្តោះទឹកមាត់ដាក់លើខ្លួនរបស់តាបស បន្ទាប់អំពីថ្ងៃនោះទៅ មិនបានប៉ុន្មាន ព្រះរាជាដកឋានន្តររបស់បុរោហិត ទើបបុរោហិតចូលទៅកាន់សម្នាក់នាងនគរសោភិនីនោះ សាកសួរថា នែប្អូនស្រីនាងធ្វើដូចម្តេច ទើបបានឋានន្តរវិញ នាងក៏ពោលថា លោកព្រាហ្មណ៍ មានទៅលំបាកអ្វី ជដិលកោងម្នាក់ ជាមនុស្សកាឡកណ្ណី អង្គុយមិនកម្រើក នៅក្នុងព្រះរាជឧទ្យាន សូមលោកទៅស្តោះទឹកមាត់ដាក់ខ្លួនតាបសនោះ ក៏នឹងបានឋានន្តរយ៉ាងនេះ ។ បុរោហិតនោះក៏ពោលថា អើ ប្អូនស្រី អញនឹងធ្វើយ៉ាងនោះ ហើយក៏ទៅឯព្រះរាជឧទ្យាននោះ ធ្វើដូចនាងប្រាប់គ្រប់ប្រការ ហើយក៏ចេញអំពីព្រះរាជឧទ្យានទៅ ក្នុងថ្ងៃនោះឯង ព្រះរាជាទ្រង់រឭកបាន ក៏ត្រាស់សួរថា នែបាទាំងឡាយ ព្រាហ្មណ៍នៅឯណា បានទូលថា បពិត្រព្រះអង្គនៅក្នុងព្រះនគរនេះឯង ព្រះរាជាទ្រង់មានព្រះតម្រាស់ថា យើងមិនពិចារណាជាមុន ហើយធ្វើ ពួកឯងចូរឲ្យឋានន្តរដល់គេវិញ ហើយទ្រង់ប្រទានឋានន្តរដល់ព្រាហ្មណ៍នោះ ។ សូម្បីព្រាហ្មណ៍នោះបានឋានន្តរ ក៏ព្រោះកម្លាំងបុណ្យអំពីមុន តែយល់ខុសថា បានឋានន្តរ ព្រោះស្តោះទឹកមាត់ដាក់សរីរៈរបស់តាបស ។ បន្ទាប់អំពីថ្ងៃនោះ មិនយូរប៉ុន្មានជនបទជាយដែនរបស់ព្រះរាជាក៏កើតការបះបោរ ។ ព្រះរាជាត្រាស់ថា អញនឹងទៅបង្ក្រាបសត្រូវឯជាយដែន ទើបយាងទៅ មួយអន្ទើដោយចតុរង្គសេនា ទើបបុរោហិត ទៅឈរចំពោះព្រះភក្ត្រនៃព្រះរាជា ថ្វាយព្រះពរថា **ជយតុ មហារាជា** សូមទ្រង់

មានជ័យជម្នះចុះ ហើយទូលសួរថា ព្រះអង្គយាងទៅដើម្បីជ័យជម្នះឬ ព្រះអង្គ ព្រះរាជាត្រាស់ថា អើ យ៉ាងនោះហើយព្រាហ្មណ៍ ។ ព្រាហ្មណ៍ទូលថា បើដូច្នោះ ជដិលកោងម្នាក់ ជាមនុស្សកាឡកណ្ណី អង្គុយមិនកម្រើក ស្នាក់ក្នុងព្រះរាជឧទ្យាន សូមទ្រង់ស្តោះព្រះខេលៈដាក់ជដិលនោះចុះ ។ ព្រះរាជាទ្រង់ទទួលពាក្យរបស់បុរោហិតនោះ ប្រាប់ឲ្យធ្វើដូចដែលស្រីគណិកា និងព្រាហ្មណ៍បុរោហិតនោះធ្វើគ្រប់យ៉ាង ហើយត្រាស់ឲ្យមេកង ស្តោះទឹកមាត់ត្រង់ខ្លួនជដិលកោងនោះ បន្ទាប់អំពីនោះ មេក្រុមក៏ធ្វើតាមយ៉ាងនោះដូចគ្នា ។

គ្រានោះ ព្រះរាជាទ្រង់ប្រើឲ្យតាំងកងរក្សាជិតទ្វារព្រះរាជឧទ្យាន រួចក៏បញ្ជាថា បុគ្គលតាមទ្រង់មិនស្តោះទឹកមាត់លើតាបសឲ្យទូទៅហើយ ចេញមិនបាន ។ គ្រានោះ នាយមេកងទាំងអស់ក៏នាំទឹកមាត់ ឈើស្ទន់ និងទឹកខ្ទុរមាត់ យកទៅដាក់លើខ្លួនតាបសដោយទំនងនោះឯង ។ ទឹកមាត់ និងឈើជម្រះធ្មេញក៏កប់លិចខ្លួនតាបស ។ សេនាបតីដែលជាអ្នកឧបដ្ឋាកដ៏ទៀងទៅក្រោយគេបង្អស់ ក៏គិតថា បានឮថា មនុស្សទាំងឡាយប្រទូស្តដល់សាស្តារបស់អញ ដែលជាស្រែបុណ្យ ជាជណ្តើរនៃស្ថានសួគ៌យ៉ាងនេះ បេះដូងក៏ក្តៅរំជួល ត្រូវដកដង្ហើមតាមមាត់ ទើបរួតរះទៅកាន់ព្រះរាជឧទ្យាន ឃើញឥសីជួបនូវសេចក្តីលំបាកយ៉ាងនោះ ក៏ស្មៀកចងក្បិន យកដៃទាំង ២ កៀរឈើជម្រះធ្មេញ លើកឡើងឲ្យអង្គុយ នាំទឹកមកងូត លាបដោយថ្នាំគ្រប់ប្រភេទ និងគន្ធជាតិ ៤ ប្រភេទ ជូតដោយសំពត់សាច់ម៉ដ្ឋ ឈរផ្គងអញ្ជលីនៅខាងមុខ ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ ពួកមនុស្ស ហេតុអ្វីធ្វើ

មិនសមគួរ តើអ្វីនឹងមានដល់ពួកគេ តាបសពោលថា នៃគហបតី ទេវតាបែកគ្នាជា ៣ ពួក មួយពួកពោលថា នឹងធ្វើព្រះរាជាមួយអង្គឲ្យវិនាស ពួកមួយពោលថា នឹងធ្វើព្រះរាជា មួយអន្លើដោយបរិស័ទឲ្យវិនាស មួយពួកពោលថា នឹងធ្វើដែនទាំងអស់របស់ព្រះរាជាឲ្យវិនាស កាលពោលដូច្នេះហើយ តាបសមិនបានសម្តែងអាការក្រោធ សូម្បីតែតិចតួច កាលនឹងប្រាប់ឧបាយដែលជាសន្តិនៃលោក ក៏ពោលថា កំហុសមាន តែបើដឹង សម្តែងទោសចេញ ហេតុការណ៍ក៏នឹងជាប្រក្រតីដូចដើម ។ សេនាបតីបានន័យហើយ ចូលទៅគាល់ព្រះរាជា ថ្វាយបង្គំព្រះរាជាហើយ ក្រាបទូលថា បពិត្រព្រះមហារាជ ព្រះអង្គធ្វើខុសក្នុងតាបសដែលមិនខុស ជាអ្នកមានឫទ្ធិច្រើន ទ្រង់ធ្វើកម្មធ្ងន់ពេកណាស់ ដ្បិតតាបសពោលថា ទេវតាបែកគ្នាជា ៣ ពួក និយាយគ្នាយ៉ាងនេះ ហើយទូលរឿងទាំងអស់ ក្រាបទូលថា បើព្រះអង្គទ្រង់សូមខមាទោស ដែនក៏នឹងជាប្រក្រតី សូមព្រះអង្គកុំធ្វើដែនឲ្យវិនាសឡើយ សូមមហារាជ សូមខមាទោសនឹងតាបសចុះ ។ សេនាបតីក្រាបទូល អស់វារៈ ៣ ដង ព្រះរាជាទ្រង់ក៏មិនប្រាថ្នានឹងសូមខមាទោស ទើបសេនាបតីក្រាបទូលថា បពិត្រមហារាជ ទូលបង្គំជ្រាបកម្លាំងរបស់តាបស តាបសនេះមិនមែនពោលមិនពិត ទាំងមិនជាអ្នកក្រោធ តែលោកពោលយ៉ាងនេះ ក៏ដោយសេចក្តីករុណា អនុគ្រោះសត្វ សូមព្រះអង្គខមាទោសតាបសនោះចុះ ។ ព្រះរាជាទ្រង់ប្រកែកថា យើងមិនសូមខមាទោសទេ ។ ទើបសេនាបតីក្រាបទូលថា បើដូច្នោះ សូមព្រះអង្គប្រទានតំណែងសេនាបតីដល់អ្នកដទៃចុះ ទូល

បន្តំមិននៅក្នុងអាណាចក្ររបស់ព្រះអង្គទេ ។ ព្រះរាជាត្រាស់ថា លោកទៅណាក៏ទៅចុះ យើងនឹងបានសេនាបតីថ្មី ។ បន្ទាប់អំពីនោះ សេនាបតីក៏ទៅកាន់សម្នាក់តាបស ថ្វាយបង្គំហើយ ក៏ពោលថា ខ្ញុំបដិបត្តិតាមពាក្យរបស់លោកម្ចាស់ហើយ ។ តាបសពោលថា សេនាបតី មនុស្សដែលជឿ ចូរនាំវត្ថុគ្រប់យ៉ាង និងបរិក្ខារ ទាំងទ្រព្យ សត្វទ្វេបាទ ចតុបាទចេញទៅខាងក្រៅរាជាណាចក្រ ក្នុងរយៈពេល ៧ ថ្ងៃ ទេវតាខឹងក្រោធពេកណាស់ នឹងបៀតបៀនដែនពិតប្រាកដ ។ សេនាបតីក៏ធ្វើតាម ។ ព្រះរាជាក៏ទ្រង់ក្តៅក្រហាយតែម្យ៉ាង ទ្រង់បង្ក្រាបសត្រូវ ធ្វើជនបទជាយដែនឲ្យស្ងប់ហើយ ក៏យាងមកសម្រាកត្រង់បន្ទាយជ័យ ទ្រង់ចាត់ការព្រះនគរនោះៗ ហើយ យាងចូលកាន់ព្រះរាជនិវេសន៍ ជាដំបូងនោះឯង ពួកទេវតាបណ្តាលភ្លៀងទឹកឲ្យធ្លាក់ចុះមក ។ មហាជនក៏សប្បាយចិត្តថា តាំងអំពីធ្វើខុសក្នុងជដិលកោងមក ព្រះរាជានៃយើង ក៏ចម្រើនតែម្យ៉ាង ទ្រង់បង្ក្រាបសត្រូវបាន ក្នុងថ្ងៃទ្រង់ត្រឡប់ភ្លៀងក៏ធ្លាក់ចុះមក ។ តមក ពួកទេវតា ក៏បណ្តាលភ្លៀងផ្កាម្ទិះធ្លាក់ចុះមក មហាជនក៏សប្បាយចិត្តក្រៃលែងឡើងទៀត បន្ទាប់មក ពួកទេវតាក៏បណ្តាលភ្លៀងមាសក ភ្លៀងកហាបណៈឲ្យធ្លាក់ចុះមក យល់ថា មនុស្សទាំងឡាយនឹងចេញមករើស ទើបបណ្តាលភ្លៀងគ្រឿងប្រដាប់ដៃ ប្រដាប់ជើង ប្រដាប់ចង្កេះជាដើមឲ្យធ្លាក់ចុះមក មហាជនក៏ចុះអំពីប្រាសាទ ៧ ជាន់ តាមទ្វារក្រោយនាំគ្នាប្រដាប់អាភរណៈ សប្បាយចិត្តថា ការស្តោះទឹកមាត់លើជដិលកោងសមគួរពិតហ្ន៎ តាំងអំពីស្តោះទឹកមាត់លើជដិលកោងនោះ ព្រះរាជានៃយើង

ក៏ចម្រើន ទ្រង់បន្ទ្រាបសត្រូវក៏សម្រេច ថ្ងៃទ្រង់ត្រឡប់ ភ្លៀងក៏ធ្លាក់ចុះមក បន្ទាប់អំពីនោះ ភ្លៀង ៤ យ៉ាង គឺភ្លៀងផ្កាម្ទិះ ភ្លៀងមាសក ភ្លៀងកហាបណៈ ភ្លៀងគ្រឿងប្រដាប់ចង្កេះក៏កើត បន្ទាប់ចាត្រេកអរយ៉ាងនេះហើយ ក៏សោមនស្សក្នុងកម្មដែលព្រះរាជាទ្រង់ធ្វើខុស ។ សម័យនោះ ពួកទេវតាក៏បណ្ដាលអាវុធផ្សេងៗ មានអាវុធមុខម្ខាង អាវុធមុខសងខាងជាដើម ឲ្យធ្លាក់ចុះមកប្រៀកសាច់មហាជនជាចម្រៀកៗ បន្តអំពីនោះ ក៏បណ្ដាលរងើកភ្លើងមានពណ៌ក្រហមដូចផ្កាចារ ប្រាសចាកផេះ និងផ្សែង បណ្ដាលដុំថ្មទំហំប៉ុនផ្ទះកំពូល បណ្ដាលដីខ្សាច់ល្អិតឲ្យធ្លាក់ចុះមក លិចព្រះនគរកម្ពស់ ៨០ ហត្ថ ។ ក្នុងដែនរបស់ព្រះរាជា មនុស្ស ៣ ពួក គឺកីសវច្ឆតាបស សេនាបតី និងអ្នកត្រេកអរក្នុងការចិញ្ចឹមមាតា ជាអ្នកមិនមានរោគ ។ ក្នុងអណ្ដូងទឹកផឹកក៏មិនមានទឹក ក្នុងវាលស្មៅក៏មិនមានស្មៅ សម្រាប់សត្វតិរច្ឆានដ៏សេស ជាអ្នកមិនបានរួមក្នុងកម្មនោះ ។ សត្វតិរច្ឆានទាំងនោះ ក៏ទៅកាន់អណ្ដូងដែលមានទឹក មានស្មៅ មុនពេល ៧ ថ្ងៃ ក៏នាំគ្នាទៅក្រៅព្រះរាជាណាចក្រ ។ ព្រោះហេតុនោះ ទើបសរភង្គពោធិសត្វពោលថា

**កីសញ្ហិ វច្ឆំ អវកិរិយ ទណ្ឌកី ឧច្ឆិន្នមូលោ សជនោ សរដ្ឋោ**
**កុក្កុលនាមេ និរយម្ហិ បច្ចតិ តស្ស ផុលិង្គានិ បតន្តិ កាយេ ។**

ព្រះបាទទណ្ឌកី ព្រមទាំងជន ទាំងអ្នកដែន បានស្ដោះដាក់តាបស
ឈ្មោះកីសវច្ឆៈ ព្រះអង្គមានមូលដាច់ហើយ ឆេះក្នុងនរកឈ្មោះ
កុក្កុល រងើកភ្លើងទាំងឡាយធ្លាក់មិនដាច់ លើកាយនៃព្រះអង្គ ។

គប្បីជ្រាបថា ព្រៃទណ្ឌកី ក្លាយជាព្រៃដូចពោលមក ដូច្នេះ ។

## រឿង ព្រៃកាលិង្គៈ

បានឮមកថា កាលព្រះបាទនាឡិកីរៈ ទ្រង់គ្រងរាជ្យក្នុងដែនកលិង្គៈ តាបស ៥០០ រូប ក្នុងព្រៃហិមពាន្ត ជាអ្នកមិនបានក្និនស្រី ទ្រទ្រង់ស្បែកខ្លា ចងជដា និងសំពត់សម្បកឈើ មានឫសឈើ ផ្លែឈើព្រៃជាអាហារមកជាយូរ បំណងនឹងបរិភោគអាហារមានរសជូរ ប្រៃ ក៏នាំគ្នាមកកាន់ដែនដីមនុស្ស មកដល់នគររបស់ព្រះបាទនាឡិកីរៈ ដែនកលិង្គៈតាមលំដាប់ តាបសទាំងនោះ ទ្រទ្រង់ជដាស្បែកខ្លាជំបង និងសំពត់សម្បកឈើ សម្តែងកិរិយាស្ងប់រម្ងាប់ សមគួរដល់ភេទអ្នកបួស ចូលទៅកាន់ព្រះនគរសូមអាហារ ។ កាលព្រះពុទ្ធមិនទាន់កើត មនុស្សទាំងឡាយឃើញតាបសអ្នកបួស ក៏ជ្រះថ្លា និងប្រាប់ទីអង្គុយ ទីឈរ មានដៃកាន់ភាជនៈដាក់អាហារ និមន្តឲ្យអង្គុយហើយរៀបចំអាហារប្រគេន ។ ពួកតាបសបរិភោគអាហារស្រេចហើយ ក៏អនុមោទនា មនុស្សទាំងឡាយស្តាប់ហើយ ក៏មានចិត្តជ្រះថ្លា សួរថា បពិត្រលោកម្ចាស់ទាំងឡាយៗ នឹងទៅទីណា តាបសឆ្លើយថា នឹងទៅតាមដែលមានផាសុក ។ មនុស្សទាំងនោះ ក៏ពោលនិមន្តថា លោកម្ចាស់មិនគួរទៅកាន់ទីដទៃ សូមនៅត្រង់ព្រះរាជឧទ្យានចុះ ពួកខ្ញុំបរិភោគអាហារព្រឹកហើយ នឹងមកស្តាប់ធម្មកថា ពួកតាបសក៏ទទួល ទៅកាន់ព្រះរាជឧទ្យាន ។ អ្នកស្រុកបរិភោគអាហារហើយ ក៏ស្លៀកសំពត់ស្អាត ដណ្តប់សំពត់ស្អាត បំណងនឹងស្តាប់ធម្មកថា បណ្តើរគ្នាទៅជាក្រុមៗ មានមុខទៅកាន់ព្រះរាជឧទ្យាន ។

ព្រះរាជាប្រថាប់ឈរលើប្រាសាទ ទតឃើញមនុស្សទាំងនោះ កំពុងដើរទៅ ទើបសួរអ្នកបម្រើថា នែលោក ហេតុអ្វី ទើបអ្នកស្រុកទាំងនេះស្លៀកសំពត់ស្អាត ដើរមុខទៅកាន់ឧទ្យាន ឯឧទ្យាននោះ មានការប្រជុំ ឬ សម្តែងរបាំឬ អ្នកបម្រើក្រាបទូលថា មិនមានទេព្រះអង្គ ពួកគេទៅស្តាប់ធម្មកថា ក្នុងសម្នាក់ពួកតាបស ។ ព្រះរាជាត្រាស់ថា បើយ៉ាងនោះយើងនឹងទៅដែរ ប្រាប់ឲ្យពួកគេទៅជាមួយយើង ។ បរិវារក៏ទៅប្រាប់ដល់មនុស្សទាំងនោះថា ព្រះរាជាក៏មានព្រះរាជបំណងយាងទៅដែរ ពួកអ្នកចូរដង្ហែព្រះរាជាជាមួយគ្នាចុះ ។ តាមប្រក្រតីពួកអ្នកស្រុកសប្បាយចិត្តស្រាប់ហើយ កាលស្តាប់ពាក្យនោះ ក៏រីងរឹតតែសប្បាយចិត្ត ពោលថា ព្រះរាជារបស់យើង មិនមានសទ្ធា មិនជ្រះថ្លា ជាអ្នកទ្រុស្តសីល ពួកតាបសមានធម៌ អាស្រ័យតាបសទាំងនោះ ព្រះរាជានឹងតាំងនៅក្នុងធម៌បាន ។ ព្រះរាជាយាងចេញ មានអ្នកស្រុកហែហមយាងទៅកាន់ឧទ្យាន ទ្រង់បដិសណ្ឋារៈជាមួយពួកតាបស ហើយប្រថាប់គង់ក្នុងទីសមគួរ នាចំណែកម្ខាង ។ ពួកតាបសឃើញព្រះរាជាពក់ទាក់ ឲ្យតាបសមួយរូបដែលជាអ្នកឈ្លាសពោលធម្មកថាថ្វាយព្រះរាជា ដោយពាក្យសម្តីពីរោះទន់ភ្លន់ តាបសសម្លឹងមើលពពួកមនុស្ស កាលនឹងពោលទោសក្នុងពៀរ ៥ និងអានិសង្សក្នុងសីល ៥ ទើបពោលទោសក្នុងពៀរ ៥ ថា មិនគួរសម្លាប់សត្វ មិនគួរលួចទ្រព្យ មិនគួរប្រព្រឹត្តខុសក្នុងកាម មិនគួរពោលកុហក មិនគួរផឹកទឹកស្រវឹង ឈ្មោះថា បាណាតិបាត រមែងបញ្ជូនផលឲ្យកើតក្នុងនរក ក្នុងកំណើតតិរច្ឆាន ក្នុងបេតវិស័យ អទិន្នាទានជាដើម

ក៏ដូចគ្នា កាលចេះក្នុងនរកហើយ មកកាន់មនុស្សលោក បាណាតិបាតក៏ឲ្យផលជាអ្នកមានអាយុខ្លី ដ៏សេសនៃវិបាក អទិន្នាទាន ក៏ឲ្យផលជាមនុស្សមានភោគទ្រព្យតិច មិច្ឆាចារ ក៏បញ្ជូនផលឲ្យជាអ្នកមានសត្រូវច្រើន មុសាវាទក៏ឲ្យផលជាបុគ្គលត្រូវគេពោលបង្កាច់ មជ្ជបាន ក៏ឲ្យផលជាមនុស្សឆ្កួត ។ សូម្បីដោយប្រក្រតី ព្រះរាជាក៏ជាអ្នកមិនមានការជឿ មិនជ្រះថ្លា ជាអ្នកទ្រុស្តសីល ធម្មតាសីលកថា ជាទុកថា គឺពាក្យអាក្រក់សម្រាប់អ្នកទ្រុស្តសីល ទើបហាក់ដូចជាលំពែងទម្លុះត្រចៀក ព្រោះដូច្នោះ ទើបទ្រង់ព្រះតម្រិះថា អញក៏បំណងនឹងលើកតម្កើងតាបសទាំងនេះ តែតាបសទាំងនេះ បែរជាពោលទ្រគោះបោះបោកចាក់ទម្លុះអញនេះឯង ក្នុងកណ្តាលបរិស័ទ តាំងអំពីអញមក អញធ្វើឲ្យសក្តិសមដល់តាបសទាំងនោះ ។ កាលចប់ធម្មកថា ព្រះរាជានិមន្តថា លោកអាចារ្យទាំងឡាយ ស្អែកនេះ សូមទទួលអាហារត្រង់ផ្ទះញោម ហើយទ្រង់យាងត្រឡប់ ។ ថ្ងៃស្អែកឡើង ទ្រង់ឲ្យនាំក្រឡជំៗ មកហើយដាក់លាមករហូតពេញហើយ យកស្លឹកចេកមកចងមាត់ក្រឡទាំងនោះ ឲ្យយកទៅតាំងទុកក្នុងទីនោះៗ ដាក់ទឹកឃ្មុំ ប្រេង ជ័រខ្ទឹង និងបន្ទារកាក្រាស់ៗ ជាដើម រហូតពេញឆ្នាំង ដាក់ត្រង់ក្បាលជណ្តើរ ហើយឲ្យអ្នកប្រដាល់មាឌធំៗ ចងខ្សែក្រវាត់ចង្កេះ កាន់ដំបងវង់ចាំក្នុងទីនោះឯង ប្រថាប់ឈរពោលថា ពួកតាបសកោងបៀតបៀនយើងពេកណាស់ តាំងអំពីតាបសទាំងនោះចុះចាកប្រាសាទ ពួកឯងចូរវាយឆ្នាំង ពង្រាយបន្ទារកាទៅត្រង់មាត់ជណ្តើរ យកដំបងវាយក្បាល ចាប់កបោះទៅត្រង់ជណ្តើរ ត្រង់ជើងជណ្តើរ

ត្រូវចន្កែកាចៗ ។

ឯពួកតាបសគិតថា ពួកយើងនឹងបរិភោគអាហារក្នុងវាំងស្ដេច ថ្ងៃស្អែកនេះ ក៏ទូន្មានគ្នានិងគ្នាថា រាជវាំងគួរសង្ស័យ គួរមានភ័យ ធម្មតាបព្វជិតគប្បីសង្រួមក្នុងទ្វារទាំង ៦ មិនគួរកាន់យកនិមិត្ត ក្នុងអារម្មណ៍ដែលឃើញហើយ គប្បីតាំងចំពោះការសង្រួមក្នុងចក្ខុទ្វារ ថ្ងៃស្អែកឡើង ពួកតាបសក៏កំណត់កត្តកាល ទើបស្លៀកសំពត់សម្បកឈើ ដណ្ដប់ស្បែកខ្លាធៀងស្មាម្ខាង រុំជដា កាន់យកភាជនៈដាក់អាហារ ឡើងកាន់ព្រះរាជនិវេសន៍តាមលំដាប់ ព្រះរាជាទ្រង់ជ្រាបថា តាបសឡើងមកហើយ ក៏ឲ្យនាំយកស្វឹកចេកចេញអំពីមាត់ក្រឡ ក្លិនស្អុយក៏ប៉ះដល់ច្រមុះរបស់តាបស ដល់នូវអាការហាក់ដូចជាខួរធ្លាក់ចូលទៅ ។ តាបសដែលជាប្រធានសម្លឹងព្រះរាជាៗ ត្រាស់ថា មកចុះលោកដ៏ចម្រើន សូមឆាន់ សូមនាំទៅតាមសេចក្ដីត្រូវការ នុ៎ះជារបស់សមគួរដល់ពួកលោក ម្សិលមិញ យើងមកបំណងនឹងលើកតម្កើងពួកលោក តែពួកលោកបែរជាពោលទ្រគោះយើងនោះឯង កណ្ដាលបរិស័ទ ពួកលោកចូរឆាន់របស់ដែលសមគួរដល់ពួកលោក ហើយបញ្ជាឲ្យយកត្រឡោកដួសលាមកទៅប្រគេនតាបសដែលជាប្រធាន តាបសក៏បានត្រឹមតែពោលថា ធិ ធិ ក៏ត្រឡប់ទៅ ព្រះរាជាត្រាស់ថា ពួកលោកត្រូវទៅតាមផ្លូវនេះ ហើយឲ្យសញ្ញាដល់មនុស្សទាំងឡាយ ឲ្យយកធ្នាំងបាចបន្ទារកាត្រង់មាត់ជណ្ដើរ ពួកអ្នកប្រដាល់ក៏យកដំបងវាយក្បាល ចាប់កបោះទៅខាងក្រោម តាបសមួយរូបក៏មិនអាចឈរត្រង់ជណ្ដើរបាន ។ តាបសទាំងឡាយក៏រមៀលចុះមកដល់

ជើងជណ្តើរ កាលដល់ជើងជណ្តើរហើយ ហ្វូងក្អែគិតថា ជាផ្ទាំងសំពត់ ក៏ចោមរោមខាំស៊ី បណ្តាតាបសទាំងនោះ តាបសរូបណាក្រោកឡើង គេចទៅបាន រូបនោះក៏ត្រូវធ្លាក់ទៅក្នុងរណ្តៅ ហ្វូងក្អែក៏តាមទៅខាំស៊ីតាបសនោះក្នុងរណ្តៅនោះឯង ដូច្នោះ សូម្បីតែរាងឆ្អឹងរបស់តាបសទាំងនោះ ក៏មិនមានសេសសល់ឡើយ ។ ព្រះរាជាទ្រង់ផ្តាច់ជីវិតតាបស ៥០០ ដែលសម្បូរដោយតបៈ ដោយរយៈពេលមួយប៉ុណ្ណោះ ។ គ្រានោះ ពួកទេវតាបណ្តាលភ្លៀង ៩ ប្រភេទ ឲ្យធ្លាក់ចុះមកទៀត ក្នុងដែនរបស់ព្រះរាជាអង្គនោះ ដោយន័យមុននោះឯង ។ ដែននៃព្រះរាជាអង្គនោះ ត្រូវលុបដោយគំនរខ្សាច់កម្ពស់ ៦០ យោជន៍ ព្រោះហេតុនោះ ទើបសរភង្គពោធិសត្វពោលថា

**យោ សញ្ញតេ បព្វជិតេ អហោឋយិ ធម្មំ ភណន្តេ សមណេ អទូសកេ**
**តំនាលិកីរំ សុនខា បរត្ថ សង្គម ខាទន្តិ វិបជន្ទមានំ ។**

ព្រះបាទនាលិកីរៈណា បានបៀតបៀនបព្វជិតទាំងឡាយ ជាអ្នកសង្រួម ជាអ្នករម្ងាប់បាប មិនប្រទូស្តកំពុងសម្តែងធម៌ ឆ្កែទាំងឡាយ ចោមខាំស៊ីនូវព្រះបាទនាលិកីរៈនោះ ឲ្យអន្ទះអន្ទែងក្នុងបរលោក ។ គប្បីជ្រាបថា ព្រៃកលិង្គៈ ក្លាយជាព្រៃដោយប្រការដូច្នេះ ។

## រឿង ព្រៃមាតង្គៈ

ក្នុងអតីតកាល នាទគរពារាណសី សេដ្ឋីម្នាក់មានទ្រព្យសម្បត្តិ ៤០ កោដិ មានធីតាម្នាក់ ឈ្មោះទិដ្ឋមង្គលិកា ស្រស់ស្អាតគួរស្រឡាញ់ នាងជាទី

ប្រាថ្នានៃមនុស្សដ៏ច្រើន ព្រោះនាងដល់ព្រមដោយរូបសម្បត្តិ ភោគសម្បត្តិ និងកុលសម្បត្តិ បុរសណាបញ្ជូនមនុស្សទៅសូមនាងៗ ឃើញបុរសនោះហើយ ក៏លើករឿងជាតិ បើមិនដូច្នោះ ក៏រឿងដៃ ជើងជាដើមណាមួយឡើង ដើម្បីតិះដៀល ពោលថា បុគ្គលនោះជានរណា កើតមិនល្អ ទ្រង់ទ្រាយមិនល្អ ដូច្នេះជាដើមហើយ ក៏ប្រាប់ឲ្យអញ្ជើញបុគ្គលនោះត្រឡប់ចេញទៅ ហើយពោលប្រាប់ថា បើអញបានមនុស្សដូច្នេះ ពួកឯងចូរយកទឹកមក អញនឹងលាងភ្នែក ហើយក៏លាងភ្នែក ។ ព្រោះហេតុដែលនាងមានអាការខុសប្រក្រតីដែលនាងឃើញនរណាៗ ហើយ ប្រើឲ្យបញ្ជូនបុរសនោះទៅ ដូច្នោះ ទើបកើតរហ័សនាម ទិដ្ឋមង្គលិកា ឈ្មោះដើមក៏បាត់ទៅ ។ ថ្ងៃមួយ នាងតាំងចិត្តនឹងលេងទឹកក្នុងស្ទឹងគង្គា ទើបបញ្ជាឲ្យតាក់តែងកំពង់ទឹក ដាក់របស់ទំពារបស់ស៊ីជាច្រើនពេញរទេះ យកគ្រឿងក្រអូប និងផ្កាជាដើមឡើងជិះយានដែលបិទជិត មានពួកញាតិហែហម ចេញអំពីគ្រឹះហាទៅ ។ សម័យនោះ ព្រះមហាបុរសកើតក្នុងកំណើតមនុស្សចណ្ឌាល អាស្រ័យនៅក្នុងផ្ទះ ដែលប្រក់ដោយស្បែក ក្រៅព្រះនគរ មានឈ្មោះថា មាតង្គៈ ។ លុះមានអាយុ ១៦ ឆ្នាំ ត្រូវចូលទៅក្នុងព្រះនគរដោយកិច្ចឯណានីមួយ ទើបស្លៀកសំពត់ចាស់ពណ៌ខៀវមួយផ្ទាំង ចងកដៃមួយផ្ទាំង ដៃម្ខាងកាន់កំប្រោង ម្ខាងកាន់កណ្ដឹង ហាមមនុស្សនោះៗ ដើម្បីឲ្យគេដឹងថា នៃលោកម្ចាស់ សូមរឭកថាខ្ញុំជាចណ្ឌាលទាំងសាច់ ទាំងឈាម ណែនាំមនុស្សទាំងឡាយដែលគេបានជួប ចូលទៅកាន់ព្រះនគរតាមផ្លូវធំ ។

នាងទិដ្ឋមង្គលិកា បានឮសំឡេងកណ្ដឹងមើលតាមចន្លោះវាំងនន ឃើញមាតង្គៈដើរមកអំពីចម្ងាយ សួរថា នុ៎ះជាអ្វី មនុស្សរបស់នាងឆ្លើយថា នាយមាតង្គៈ អ្នកនាង ។ នាងពោលថា អញធ្វើអ្វីមិនល្អហ្ន៎ នេះជាផលកម្មអ្វី ទើបការលំបាកប្រាកដដល់អញហ្ន៎ អញកំពុងទៅដោយកិច្ចដែលជាមង្គល បែរជាបានជួបមនុស្សចណ្ឌាល រង្កៀសរហូតញ័រខ្លួន ស្ដោះទឹកមាត់ ហើយប្រាប់អ្នកបម្រើស្រីឲ្យប្រញាប់នាំទឹកមកដើម្បីលាងភ្នែក ព្រោះឃើញមនុស្សចណ្ឌាល ខ្ពុរមាត់ដែលនិយាយដល់ឈ្មោះ ហើយលាងភ្នែក និងមាត់ ឲ្យត្រឡប់រថ បញ្ជូនរបស់ដែលត្រៀមទៅកាន់គ្រឹះហា ខ្លួនឯងក៏ឡើងទៅកាន់ប្រាសាទ ពួកអ្នកលេងសុរា និងពួកអ្នកដែលបម្រើនាងជាដើមសួរគ្នាថា នាងទិដ្ឋមង្គលិកាទៅណា ទើបមិនមកក្នុងវេលានេះ ស្ដាប់រឿងរ៉ាវហើយ ទោមនស្សថា អាស្រ័យអាចណ្ឌាល ទើបពួកយើងមិនបានទទួលរង្វាន់ធំ ដូចជាសុរា សាច់ គ្រឿងក្រអូប ផ្កាជាដើម ចូរចាប់អាចណ្ឌាលទាំងអស់គ្នាចុះ ហើយក៏ស្វែងរករហូតជួបត្រង់ទីដែលមាតង្គៈទៅ ជេរប្រទេចមាតង្គបណ្ឌិតដែលមិនខុសថា វ៉ឺយ អាមាតង្គៈ ព្រោះអាស្រ័យឯង ទើបពួកអញមិនបានរង្វាន់ឈ្មោះនេះៗ ថាហើយ ក៏ចាប់សក់ទាញមកឲ្យដួលចុះត្រង់ផែនដី អុកដោយកែង និងដុំថ្មជាដើម សម្គាល់ថា ស្លាប់ ទើបនាំគ្នាចាប់អូសទៅបោលត្រង់គំនរសំរាម ។

ឯមហាបុរសដឹងខ្លួន ស្ទាបដៃជើងមើល គិតថា ទុក្ខនេះអាស្រ័យនរណាហ្ន៎ ទើបកើតឡើងបាន មិនមែនអាស្រ័យអ្នកដទៃណា គឺអាស្រ័យនាងទិដ្ឋ-

មង្គលិកានេះពិត ទើបកើតឡើង អញជាកូនប្រុស នឹងត្រូវឲ្យនាងឱនចុះត្រង់ជើងឲ្យបាន មានសេចក្ដីក្រោធញ័រខ្លួន ទៅកាន់ទ្វារផ្ទះត្រកូលរបស់នាងទិដ្ឋ-មង្គលិកា ដេកត្រង់ទីទ្វារផ្ទះ ដោយតាំងចិត្តថា អញបាននាងទិដ្ឋមង្គលិកាទើបក្រោក បើមិនបាន ក៏នឹងស្លាប់ក្នុងទីនេះឯង ។ សម័យនោះ ជម្ពូទ្វីបមានប្រពៃណីថា មនុស្សចណ្ឌាលក្រោធ ដេកស្លាប់ក្បែរទ្វារបន្ទប់របស់បុគ្គលណា អ្នកដែលនៅក្នុងបន្ទប់ទាំងអស់នោះ ត្រូវធ្លាក់ទៅជាចណ្ឌាល បើមនុស្សចណ្ឌាលស្លាប់កណ្ដាលផ្ទះ អ្នកដែលនៅក្នុងផ្ទះទាំងអស់ ត្រូវជាចណ្ឌាល បើមនុស្សចណ្ឌាលស្លាប់ត្រង់ទ្វារផ្ទះ មនុស្សដែលនៅក្នុងផ្ទះសងខាង ត្រូវជាមនុស្សចណ្ឌាល កាលបើស្លាប់ត្រង់ទីធ្លាផ្ទះ មនុស្សដែលនៅក្នុងផ្ទះទាំង ១៤ ខ្នង ខាងនោះ ៧ ខាងនេះ ៧ ត្រូវធ្លាក់ជាចណ្ឌាល តែព្រះពោធិសត្វ ដេកត្រង់ទីធ្លាផ្ទះ ។ ទើបមនុស្សទាំងឡាយប្រាប់ដល់សេដ្ឋីថា លោកម្ចាស់ នាយមាតង្គៈដេកត្រង់ទីធ្លាផ្ទះរបស់លោកម្ចាស់ សេដ្ឋីពោលថា ធាប់ទៅក្លាមនាយព្រោះហេតុអ្វី ពួកអ្នកចូរឲ្យទ្រព្យវា ១ មាសក ឲ្យវាក្រោកទៅ ។ មនុស្សទាំងនោះចេញទៅប្រាប់ថា ចូរក្រោកឡើង ទទួលមាសកនេះចេញទៅចុះ ។ មាតង្គៈប្រាប់ថា ខ្ញុំមិនមែនដេកដោយត្រូវការមាសកទេ តែខ្ញុំដេកដើម្បីនាងទិដ្ឋមង្គលិកា ។ មនុស្សទាំងឡាយសួរថា នាងទិដ្ឋមង្គលិកា មានទោសអ្វីឬ មាតង្គៈឆ្លើយថា ពួកលោកមើលមិនឃើញទោសណាមួយរបស់នាងទេ ខ្ញុំមិនមានអ្វីខុស ពួកមនុស្សរបស់នាងធ្វើខ្ញុំឲ្យលំបាក ខ្ញុំបាននាងទើបក្រោក បើមិនបានក៏មិនក្រោក ។ ទើបមនុស្សទាំងនោះ នាំគ្នាទៅប្រាប់សេដ្ឋីៗ ដឹងទោស

របស់ធីតា ទើបបញ្ជូនមនុស្សទៅ ព្រមទាំងប្រាប់ថា ពួកឯងចូរទៅ ឲ្យវានូវកហាបណៈ ១ ។ មាតង្គៈនោះប្រាប់ថា ខ្ញុំមិនប្រាថ្នាកហាបណៈ ប្រាថ្នាតែនាងម្នាក់ប៉ុណ្ណោះ ។ សេដ្ឋី និងភរិយាបានស្តាប់ ក៏សង្វេគថា ធីតាដែលជាទីស្រឡាញ់របស់យើងមានតែម្នាក់ ក៏មកទម្លាយបវេណី សូម្បីក្មេងដទៃក៏មិនមាន ទើបប្រាប់មនុស្សទាំងឡាយថា ទៅចុះ លោក ឥឡូវនេះ អ្នកណាមួយ កុំផ្តាច់ជីវិតវាឡើយ កាលវាស្លាប់ យើងគ្រប់គ្នាក៏វិនាស ពួកអ្នកចូររក្សាវា ហើយក៏ចោមរោម ចាត់ចែងរក្សា បញ្ជូនបបរបាយទ្រព្យទៅឲ្យ ទោះយ៉ាងនោះ មាតង្គៈនោះ ក៏បដិសេធគ្រប់យ៉ាង កាលវេលាកន្លងទៅ ១-២-៣-៤-៥ ថ្ងៃ មនុស្សដែលនៅក្នុងផ្ទះ មួយកន្លែង ៧ បន្តអំពីផ្ទះនោះៗ ក៏ក្រោកឡើងនិយាយថា ពួកយើងមិនអាចក្លាយជាចណ្ឌាលព្រោះពួកលោកបានទេ ពួកលោកកុំធ្វើឲ្យយើងវិនាសឡើយ ចូរឲ្យនាងទិដ្ឋមង្គលិកា ហើយឲ្យមាតង្គៈក្រោកឡើង ។ សេដ្ឋី និងភរិយាបញ្ជូនទ្រព្យទៅឲ្យ មួយរយខ្លះ មួយពាន់ខ្លះ មួយសែនខ្លះ មាតង្គៈនោះបដិសេធតែម្យ៉ាង ៦ ថ្ងៃកន្លងទៅយ៉ាងនេះ ដល់ថ្ងៃទី ៧ មនុស្សក្នុងផ្ទះទាំង ១៤ សងខាងក៏ប្រជុំគ្នាទៀតថា យើងមិនអាចក្លាយជាមនុស្សចណ្ឌាលផង ពួកអ្នកក៏មិនត្រូវការផង យើងនឹងឲ្យនាងទិដ្ឋមង្គលិកាដល់មាតង្គៈនោះ ។ មាតាបិតារបស់នាងដល់ព្រមដោយការសោយសោក ក៏នៅស្ងៀម ផ្កាប់មុខ ត្រង់ទីដេក ។

មនុស្សក្នុងផ្ទះទាំង ១៤ ខ្នង ក៏នាំគ្នាឡើងប្រាសាទ ដោះគ្រឿងប្រដាប់គ្រប់យ៉ាងរបស់នាង ហាក់បីដូចបេះផ្កាចារដែលរីកហើយ យកក្រចកវែក

សក់ ហើយចងសក់ ឲ្យស្លៀកសំពត់ខៀវចាស់ ចងចម្រៀកសំពត់ចាស់ពណ៌ខៀវ ឲ្យប្រដាប់កុណ្ឌលធ្វើអំពីសំណាត្រង់ត្រចៀក ប្រគល់កំប្រោងស្លឹកត្នោត ឲ្យចុះអំពីប្រាសាទ ចាប់ដើមដៃទាំង ២ ទៅប្រគល់ឲ្យមហាបុរស ព្រមទាំងពោលថា ចូរនាំប្តីហ្នឹងទៅ ទិដ្ឋមង្គលិកាជាទារិកាសុខុមាលជាតិ មិនធ្លាប់លើករបស់ធ្ងន់ ដោយហោចសូម្បីតែផ្កាឈូក ក៏ធ្ងន់ណាស់ទៅហើយ ក៏ពោលថា ក្រោកឡើងលោក យើងនឹងទៅ ។ ព្រះពោធិសត្វក៏ដេកព្រងើយ ពោលថា ខ្ញុំមិនក្រោកទេ ។ នាងសួរថា ឲ្យខ្ញុំនិយាយដូចម្តេច មាតង្គៈក៏បង្រៀនថា នាងចូរនិយាយនឹងខ្ញុំថា បងមាតង្គៈ សូមក្រោកឡើង នាងក៏ពោលយ៉ាងនោះ ។ មាតង្គៈប្រាប់ថា ពួកមនុស្សរបស់នាងមិនមែនឬ ធ្វើឲ្យខ្ញុំមិនអាចក្រោកឡើង ចូរនាងចាប់ដៃខ្ញុំឲ្យក្រោកឡើងចុះ នាងក៏ធ្វើតាម ព្រះពោធិសត្វធ្វើអាការជាក្រោក តែក៏ទម្លាក់ខ្លួនចុះទៅត្រង់ផែនដី ស្រែកខ្លាំងថា នែនាងទិដ្ឋមង្គលិកា ប្រើមនុស្សឲ្យវាយខ្ញុំ រហូតដល់ទុរន់ទុរាហើយ ឥឡូវនេះ ខ្លួនឯងនៅតែវាយទៀតហ៎ះ នាងពោលថា ឲ្យខ្ញុំធ្វើដូចម្តេច ។ ចូរចាប់ដៃ ២ ទាញឲ្យក្រោកឡើង នាងទាញឲ្យក្រោកឡើងបានហើយ ពោលថា យើងទៅជាមួយគ្នាចុះ ។ ព្រះពោធិសត្វពោលថា ធម្មតាសត្វតិរច្ឆាន មាននៅក្នុងព្រៃ ឯខ្ញុំជាមនុស្ស ត្រូវមនុស្សរបស់នាងវាយធ្វើបាប មិនអាចដើរទៅដោយជើងបាន នាងចូរយកខ្នងព្រនាក់ខ្ញុំទៅ ។ នាងក៏ឱនបែរខ្នងឲ្យ ព្រះពោធិសត្វក៏ឡើងលើខ្នង នាងនាំទៅកាន់ទ្វារទិសខាងកើត ហើយសួរថា លំនៅរបស់បងនៅទីនេះឬ មាតង្គៈឆ្លើយថា ត្រង់ទ្វារក្រុងទិសខាងកើត ពួកកូនចណ្ឌាលនៅ

មិនបានទេ មាតង្គៈមិនប្រាប់លំនៅរបស់ខ្លួន ឲ្យនាងអៀវទៅគ្រប់ទ្វារ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមាតង្គៈគិតថា អញនឹងធ្វើមានះនាង ដែលឡើងដល់អគ្គកព ឲ្យធ្លាក់ចុះទាល់តែបាន ។ មហាជនធ្វើការសរសើរកងរំពងថា ក្រៅអំពីមនុស្សដូចលោក មិនមានអ្នកដទៃដែលទម្លាយនូវមានះរបស់នាងបានឡើយ ។ ដល់ទ្វារទិសខាងលិច នាងសួរថា លំនៅរបស់បងនៅទីនេះឬ មាតង្គៈសួរថា នេះជាទីណា នាងឆ្លើយថា ទ្វារទិសខាងលិច ។ មាតង្គៈប្រាប់ថា ចេញអំពីផ្លូវទិសខាងលិចហើយ សម្លឹងឃើញផ្ទះប្រក់ស្បែក ចូលទៅចុះ ។ នាងដើរទៅដល់ហើយ ក៏សួរថា ផ្ទះប្រក់ស្បែកមួយនេះ ជាលំនៅរបស់បងឬ មាតង្គៈឆ្លើយហើយក៏ចុះអំពីខ្នង ដើរចូលទៅកាន់ផ្ទះប្រក់ដោយស្បែក ។ ព្រះពោធិសត្វជាបណ្ឌិត ស្វែងរកនូវសព្វញ្ញុតញ្ញាណក្នុងផ្ទះស្បែកនោះ ៧-៨ ថ្ងៃ មិនបានធ្វើការរួមរស់ដោយជាតិក្នុងថ្ងៃទាំងនោះ ។ គិតហើយ គិតទៀត ធីតារបស់ត្រកូលធំអាស្រ័យអញនឹងមិនជួបនូវយសធំក្រៃលែង អញនៅក្នុងសម្នាក់របស់ព្រះពុទ្ធ ដល់ទៅ ២៤ អង្គ ក៏គង់មិនអាចធ្វើកិច្ច គឺអភិសេកព្រះរាជាទាំងឡាយក្នុងសកលជម្ពូទ្វីប ដោយទឹកលាងជើងរបស់នាងបាន បន្ទាប់អំពីនោះ ក៏ត្រិះរិះថា បើអញនៅកណ្តាលផ្ទះ គឺជាគ្រហស្ថ គង់មិនអាច តែបើបួសហើយ ទើបអាច ហើយក៏ហៅនាងមកប្រាប់ថា មង្គលិកា អំពីមុនខ្ញុំនៅម្នាក់ឯង ធ្វើការងារខ្លះ ក៏ល្មមចិញ្ចឹមជីវិតបាន តែឥឡូវនេះ ខ្ញុំមានភរិយា មិនធ្វើការ មិនអាចចិញ្ចឹមជីវិតបានទេ នាងកុំអផ្សុកឡើយ ទម្រាំខ្ញុំត្រឡប់មកវិញ ។ ព្រះពោធិសត្វចូលទៅព្រៃ រើស

យកសំពត់ចាស់ៗ ត្រង់ព្រៃខ្មោចជាដើម មកធ្វើជាសំពត់ស្លៀក សំពត់ដណ្តប់ បួសជាសមណៈ ត្រាច់ទៅម្នាក់ឯង បានទូវកាយវិវេក បរិកម្មកសិណ ធ្វើសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតហើយ ត្រិះរិះថា ឥឡូវនេះ អញអាចជាទីពឹងអាស្រ័យរបស់នាងទិដ្ឋមង្គលិកាបានហើយ ទើបដើរឆ្ពោះទៅកាន់ក្រុងពារាណសី ដណ្តប់ចីវរត្រាច់បិណ្ឌបាត មានមុខទៅកាន់ផ្ទះរបស់នាងទិដ្ឋមង្គលិកានោះឯង ។

នាងឃើញព្រះពោធិសត្វឈរនៅត្រង់ទ្វារ ចាំមិនបានក៏ពោលថា សូមអញ្ជើញទៅខាងមុខចុះ លោកម្ចាស់ នេះជាលំនៅរបស់ពួកមនុស្សចណ្ឌាលទេ ព្រះពោធិសត្វក៏ឈរក្នុងទីនោះឯង ។ នាងមើលហើយមើលទៀត ក៏ចាំបាន យកដៃរឹតទ្រូង ទ្រហោយំ ក្រាបចុះក្បែរជើង ពោលថា បើលោកម្ចាស់ មានចិត្តបែបនេះ ហេតុអ្វី ទើបធ្វើខ្ញុំឲ្យវិនាសចាកយសធំ ធ្វើឲ្យខ្ញុំអស់ទីពឹង ហើយរៀបរាប់ផ្សេងៗ ជូតភ្នែកទាំង ២ ក្រោកឡើង ទទួលភាជនៈអាហារ និមន្តឲ្យចូលទៅអង្គុយខាងក្នុងផ្ទះ ប្រគេនអាហារ ។ ព្រះមហាបុរសឆាន់ហើយ ក៏ពោលថា ទិដ្ឋមង្គលិកា នាងកុំសោយសោកឡើយ កុំទោមនស្សឡើយ អាត្មាអាចធ្វើឲ្យកិច្ច គឺការអភិសេកព្រះរាជាទាំងឡាយក្នុងសកលជម្ពូទ្វីប ដោយទឹកលាងជើងរបស់នាង តែនាងត្រូវធ្វើតាមពាក្យរបស់អាត្មាម្យ៉ាង នាងចូលទៅកាន់ព្រះនគរ ប្រកាសឲ្យពេញព្រះនគរថា ប្តីរបស់ខ្ញុំ មិនមែនចណ្ឌាលទេ តែជាស្តេចមហាព្រហ្ម កាលព្រះពោធិសត្វពោលយ៉ាងនោះហើយ នាងទិដ្ឋមង្គលិកាក៏ពោលថា លោកម្ចាស់ សូម្បីដោយ

ប្រក្រតី ខ្ញុំក៏ដល់នូវការលំបាក ព្រោះទោសនៃមាត់ ខ្ញុំមិនអាចនិយាយបានទេ ព្រះពោធិសត្វពោលថា កាលអាត្មានៅក្នុងផ្ទះ នាងធ្លាប់បានឮអាត្មាពោលពាក្យផ្តេសផ្តាសឬទេ អាត្មាមិនពោលផ្តេសផ្តាសសូម្បីក្នុងកាលនោះ ទម្រាំឥឡូវនេះ អាត្មាបួសហើយ នឹងពោលផ្តេសផ្តាសបានដូចម្តេច ខ្ញុំឈ្មោះថាបុរសពោលតែពាក្យពិត រួចពោលបន្តទៀតថា ថ្ងៃនេះជាថ្ងៃទី ៨ នៃបក្ខ ចូរនាងប្រកាសថា ក្នុងថ្ងៃឧបោសថកន្លង ៧ ថ្ងៃ រាប់អំពីថ្ងៃនេះ មហាព្រហ្មជាប្តីរបស់ខ្ញុំ នឹងទម្លាយមណ្ឌលព្រះចន្ទ ហើយមកកាន់សម្នាក់របស់ខ្ញុំ កាលពោលហើយ ក៏ចៀសចេញទៅ ។ នាងជឿ ត្រេកអរក្នុងចិត្ត ក្លាហាន ចូលទៅកាន់ព្រះនគរក្នុងវេលាព្រឹក ល្ងាច ប្រកាសយ៉ាងនោះ មនុស្សទាំងឡាយក៏ទះដៃសើចចំអកថា មើលចុះ ទិដ្ឋមង្គលិការបស់ពួកយើង ធ្វើកូនចណ្ឌាលឲ្យជាមហាព្រហ្ម ។ សូម្បីថ្ងៃស្អែកឡើង នាងក៏ចូលទៅព្រឹក ល្ងាច ប្រកាសយ៉ាងនោះឯងថា ឥឡូវនេះ កន្លងទៅ ១-២-៣-៤-៥-៦ ថ្ងៃ ឥឡូវនេះស្តេចមហាព្រហ្មជាប្តីរបស់ខ្ញុំ នឹងទម្លាយមណ្ឌលព្រះចន្ទមកកាន់សម្នាក់របស់ខ្ញុំ ។ ព្រាហ្មណ៍ទាំងឡាយគិតគ្នាថា នាងទិដ្ឋមង្គលិកានេះ ក្លាហានក្នុងការពោលចេញទៅ ជួនកាល អាចនឹងពិតយ៉ាងនោះក៏បាន មកចុះពួកយើងនឹងចាត់ចែងលំនៅរបស់នាងទិដ្ឋមង្គលិកា ហើយនាំគ្នាធ្វើរាជ័រវិញខាងក្រៅផ្ទះរោយខ្សាច់ សូម្បីនាងក៏ចូលទៅកាន់ព្រះនគរអំពីព្រលឹម ក្នុងថ្ងៃឧបោសថស្រែកប្រកាសថា បានឮថា ថ្ងៃនេះ ប្តីរបស់ខ្ញុំនឹងមក ។ ព្រាហ្មណ៍ទាំង-ឡាយគិតថា នាងទិដ្ឋមង្គលិកានេះ អាងមិនឆ្ងាយឡើយ បានឮថា ថ្ងៃនេះ

ស្ដេចមហាព្រហ្មនឹងមក ពួកយើងជួយគ្នាចាត់ចែងលំនៅចុះ ហើយក៏បោសសម្អាតផ្ទះដែលប្រក់ដោយស្បែក ធ្វើផ្ទៃដីឲ្យខៀវស្រងាត់ បាំងដោយសំពត់ថ្មីៗ ក្រាលបល្ល័ង្កដែលសមគួរដ៏ធំ ចងពិតាននៅខាងលើ សំយុងគ្រឿងក្រអូប និងកម្រងផ្កា កាលព្រាហ្មណ៍ទាំងនោះកំពុងចាត់ចែង ព្រះអាទិត្យក៏អស្តង្គត ។

លុះព្រះចន្ទរះឡើង ព្រះមហាបុរស ក៏ចូលបាទកជ្ឈាន និងអភិញ្ញា ចេញអំពីអភិញ្ញាហើយ ក៏បរិកម្មដោយកាមាវចរចិត្ត និម្មិតអត្តភាពជាព្រហ្មប្រមាណ ១២ យោជន៍ ដោយចិត្តដែលប្រកបដោយឫទ្ធិ ហោះឡើងកាន់វេហាស៍ ចូលខាងក្នុងចន្ទវិមាន ទម្លាយមណ្ឌលព្រះចន្ទដែលកំពុងអណ្ដែតឡើងអំពីជាយព្រៃ លះចន្ទវិមានហើយ ក៏នៅខាងមុខ អធិដ្ឋានថា ចូរមហាជនឃើញអញ មហាជនឃើញហើយ ក៏ពោលថា អ្នកដ៏ចម្រើនទាំងឡាយពាក្យរបស់នាងទិដ្ឋមង្គលិកាពិតហ្ន៎ ស្ដេចមហាព្រហ្មយាងមក ពួកយើងនឹងបូជាលោក ហើយកាន់យកគ្រឿងក្រអូប និងកម្រងផ្កា ឈរចោមរោមផ្ទះរបស់នាងទិដ្ឋមង្គលិកា ។ ព្រះមហាបុរស ហោះទៅជុំវិញក្រុងពារាណសី ៧ ជុំ លើក្បាល ដឹងថា មហាជនឃើញហើយ លះអត្តភាពប្រមាណ ១២ យោជន៍ ហើយនិម្មិតអត្តភាពជាមនុស្សធម្មតា កាលមនុស្សកំពុងមើល ក៏ចូលកាន់ផ្ទះប្រក់ស្បែក ។ មហាជនឃើញហើយ ក៏ពោលថា មហាព្រហ្មរបស់ពួកយើងយាងមកហើយ ពួកយើងចូរនាំរាំងននមក ព័ទ្ធនិវេសន៍ដោយរាំងននធំ ឈរចោមរោម ព្រះមហាបុរសក៏អង្គុយកណ្ដាលទីដេកដ៏មានសិរី នាងទិដ្ឋ-

មន្តលិកាក៏ឈរនៅក្បែរៗ ។ គ្រានោះ ព្រះមហាបុរសសួរថា ម្នាលទិដ្ឋ-មន្តលិកា នាងមានរដូវឬ នាងឆ្លើយថា ពិតហើយ លោកម្ចាស់។ ព្រះមហា-បុរសពោលថា ចូរនាងទទួលបុត្រដែលយើងឲ្យ ហើយយកចុងម្រាមប៉ះត្រង់បរិវេណពោះ ។ ដោយការស្ទាបត្រង់ផ្ចិតប៉ុណ្ណោះ នាងក៏តាំងគភ៌ ។ ព្រះមហាបុរសពោលថា ម្នាលនាងទិដ្ឋមន្តលិកា ដោយហេតុមានប្រមាណប៉ុណ្ណេះ ទឹកលាងជើងរបស់នាង នឹងជាទឹកអភិសេកព្រះរាជាទាំងឡាយក្នុងសកលជម្ពូទ្វីប នាងចូរឈរឡើង ដូច្នេះហើយ និម្មិតអត្តភាពជាព្រហ្ម កាលមហាជនកំពុងមើលនោះឯង ក៏ចេញអំពីផ្ទះហោះទៅកាន់អាកាស ចូលទៅកាន់មណ្ឌលព្រះចន្ទនោះឯង ។ តាំងអំពីពេលនោះមក នាងបានឈ្មោះថា ព្រហ្មបជាបតី ឈ្មោះថា បុគ្គលដែលបានទឹកសម្រាប់លាងជើងមិនមាន ។ ពួកព្រាហ្មណ៍ប្រឹក្សាគ្នាថា ពួកយើងនឹងយាងព្រហ្មបជាបតី ឲ្យចូលទៅខាងក្នុងព្រះនគរសែនដោយវិមាស មិនឲ្យមនុស្សដែលមានជាតិមិនបរិសុទ្ធ ៧ ជួរមនុស្សសែនរឡើយ ។ ព្រាហ្មណ៍ដែលមានជាតិ និងមន្ត ១៦ នាក់សែងទៅ ។ មនុស្សដ៏សេសបូជាដោយគ្រឿងក្រអូប និងផ្កាជាដើម ចូលទៅកាន់នគរប្រឹក្សាគ្នាថា អ្នកដ៏ចម្រើនទាំងឡាយ ព្រហ្មបជាបតី មិនអាចនៅក្នុងផ្ទះដែលនាងធ្លាប់នៅបានឡើយ ពួកយើងនឹងរកដីសាងផ្ទះដល់នាង នាងចូរនៅត្រង់មណ្ឌបដែលពួកយើងកំពុងសាង ដូច្នេះហើយ ឲ្យនាងនៅត្រង់មណ្ឌបនោះ ។ តាំងអំពីនោះមក មនុស្សទាំងឡាយបានត្រឹមតែឈរល្មមឃើញនាង បុគ្គលត្រូវការថ្វាយបង្គំត្រូវឲ្យ ១ កហាបណៈ ទើបថ្វាយបង្គំបាន ត្រូវការថ្វាយ

បន្ទំក្នុងទីជុំវិញ លុះមបានឮសំឡេងត្រូវឲ្យ ១០០ កហាបណៈ ទើបថ្វាយបន្ទំបាន អ្នកត្រូវការថ្វាយបន្ទំជិត ដែលបានឮសំឡេងនិយាយតាមប្រក្រតីត្រូវឲ្យ ៥០០ កហាបណៈ ទើបថ្វាយបន្ទំបាន ត្រូវការដាក់ក្បាលលើជើងហើយថ្វាយបន្ទំត្រូវឲ្យ ១០០០ កហាបណៈ អ្នកប្រាថ្នាទឹកជម្រះត្រូវឲ្យ ១ ម៉ឺនកហាបណៈ ទើបបាន ។ គ្រាន់តែនាងមកអំពីខាងក្រៅព្រះនគរដល់មណ្ឌបខាងក្នុងព្រះនគរបានទ្រព្យ ១០០ កោដិ ។ សកលជម្ពូទ្វីប ក៏ល្បីរន្ទឺ ព្រះរាជាទាំងពួងគិតថា យើងនឹងធ្វើការអភិសេកដោយទឹកលាងជើងរបស់ព្រហ្មបជាបតី បញ្ជូនទ្រព្យទៅ ១ សែនកហាបណៈ ទើបបានទឹកមក ។ នាងនៅក្នុងមណ្ឌបនោះឯង ក៏ប្រសូតបុត្រ កុមារដែលអាស្រ័យព្រះមហាបុរសបានមក ក៏ផូរផង់ ដល់ព្រមដោយលក្ខណៈ ។ សកលជម្ពូទ្វីបក៏កោលាហលដូចគ្នាថា បុត្ររបស់មហាព្រហ្មកើតហើយ ទ្រព្យដែលបានមកអំពីមនុស្សនោះៗ ក៏ប្រមាណ ១ ពាន់កោដិ ដោយបំណាងថា ជាថ្លៃខីរមណី គឺទឹកដោះរបស់កុមារ សូម្បីនិវេសន៍ គឺទីលំនៅក៏សម្រេចដោយទ្រព្យមានប្រមាណប៉ុណ្ណោះ ។ មនុស្សទាំងឡាយប្រឹក្សាគ្នាថា ពួកយើងនឹងថ្វាយនាមរបស់កុមារ ហើយតាក់តែងនិវេសន៍ឲ្យកុមារស្រេចស្រង់ដោយទឹកក្រអូប ប្រដាប់តាក់តែងហើយ ដាក់នាមថា មណ្ឌព្យ ព្រោះកើតក្នុងមណ្ឌប ។ កុមារចម្រើនមកដោយសេចក្ដីសុខ ក៏ដល់វ័យរៀនសិប្បៈ អ្នកប្រាជ្ញដែលចេះសិប្បៈក្នុងសកលជម្ពូទ្វីប ក៏មកកាន់សម្នាក់របស់កុមារ ឲ្យកុមារសិក្សាសិប្បៈ កុមារជាអ្នកឈ្លាស ជាអ្នកមានបញ្ញា ក៏រៀនសិប្បៈដែលស្ដាប់មកហើយបាន ដូចដោតកែវមុក្តា

ដូច្នោះ សិប្បៈដែលរៀនហើយ ក៏ទ្រទ្រង់ចាំដូចប្រេងដែលដាក់ក្នុងថ្នាំងមាស ដូច្នោះ ជរាបរហូតបរិយត្តិរត់មាត់ ព្រោះដូច្នោះ បរិយត្តិដែលឈ្មោះថា មិនរៀនមិនមាន ។ ព្រាហ្មណ៍ទាំងឡាយក៏ចោមរោមកុមារនោះ គ្រាច់ទៅ សូម្បីកុមារនោះក៏ជាបុគ្គលដែលព្រាហ្មណ៍ចិញ្ចឹមហើយ ព្រាហ្មណ៍ ៨ ម៉ឺន ទទួលនិច្ចភត្តក្នុងផ្ទះ សូម្បីផ្ទះរបស់កុមារនោះក៏ធំទូលាយ មានខ្លោងទ្វារ ៧ ជាន់ ។ ទ្រព្យដែលមហាជនក្នុងជម្ពូទ្វីបបញ្ជូនឲ្យក្នុងថ្ងៃមង្គល ក្នុងផ្ទះប្រមាណមួយសែនកោដិ ។

ឯព្រះពោធិសត្វក៏ពុកថា កុមារប្រមាទ ឬមិនប្រមាទហ្ន៎ ក៏ជ្រាបរឿងរ៉ាវរបស់កុមារនោះសព្វគ្រប់ ក៏ត្រិះរិះថា កុមារនេះកើតហើយ ព្រាហ្មណ៍ចិញ្ចឹម ទានដែលឲ្យក្នុងខេត្តណាមានផលច្រើន កុមារនោះមិនទាន់ស្គាល់ដល់ខេត្តនោះ អញនឹងទៅទូន្មានកុមារនោះ ហើយដណ្តប់ចីវរ កាន់ភាជនៈដាក់អាហារ គិតថា ខ្លោងទ្វារទាំងឡាយ ចង្អៀតពេកណាស់ អញមិនអាចចូលតាមខ្លោងទ្វារបាន ទើបមកតាមអាកាស ចុះក្នុងទីដែលពួកព្រាហ្មណ៍ ៨ ម៉ឺន នាក់បរិភោគអាហារ សូម្បីមណ្ឌព្យកុមារ ក៏ឲ្យមនុស្សច្រាប់វែកមាសអង្គាសខ្លួនឯង ដោយប្រាប់ថា ពួកអ្នកចូរឲ្យបាយត្រង់នេះ ឲ្យបាយត្រង់នេះ កាលឃើញព្រះពោធិសត្វ ក៏ក្រោធ ប្រៀបដូចពស់ពិស ត្រូវវាយដោយដំបងទើបពោលគាថានេះថា

កុតោ នុ អាគច្ឆសិ ទុម្មវាសី ឱតល្លកោ បំសុបិសាចកោវ
សង្ការចោលំ បដិមុញ្ច កណ្ឋេ កោ រេ តុវំ ហោសិ អទក្ខិណេយ្យោ

អ្នកមកអំពីណា បានជាមានប្រដាប់ស្លៀកពាក់អាក្រក់លាមក ដូចបិសាចលើអាចម៍ដី ពាក់នូវកំណាត់សំពត់ ដែលគេចោលលើគនរសំរាមឰដ៏ក ខ្លួនអ្នកជាបុគ្គលផ្តេសផ្តាស មិនមែនជាទក្ខិណេយ្យបុគ្គលទេ ។

ព្រះពោធិសត្វមិនក្រោធ ទើបពោលទូន្មានថា

**អន្នំ តវយិទំ បកតំ យសស្សិនំ តំ ខជ្ជរេ ភុញ្ជរេ បិយ្យរេ ច**
**ជានាសិ មំ ត្វំ បរទត្តូបជីវី ឧត្តិដ្ឋបិណ្ឌំ លភតំ សបាកោ**

គ្រឿងបរិភោគនេះ បរិបូណ៌ដោយបរិវារ អ្នកបានតាក់តែងហើយ ពួកជនតែងទំពាស៊ី បរិភោគ ផឹកនូវគ្រឿងបរិភោគនោះ អ្នកស្គាល់ហើយនូវយើង ថាជាអ្នកចិញ្ចឹមជីវិត ដោយសារអ្នកដទៃឲ្យ សូមឲ្យមនុស្សចណ្ឌាលបាននូវដុំបាយ ដែលបុគ្គលគប្បីទៅឈរជិត ។

មណ្ឌព្យកុមារនោះ កាលសម្តែងថា បាយនេះ មិនមែនចាត់ទុកសម្រាប់មនុស្សដូចលោក ទើបពោលថា

> គ្រឿងភោជននេះ ខ្ញុំបានតាក់តែងបម្រុងពួកព្រាហ្មណ៍ នេះជាភោជនរបស់ខ្ញុំ ដែលជឿចំពោះសេចក្តីចម្រើនរបស់ខ្លួន អ្នកចូរចៀសចេញអំពីទីនេះ អ្នកមកឋិតនៅក្នុងទីនេះធ្វើអ្វី នែបុគ្គលថោកទាប បុគ្គលទាំងឡាយ ប្រហែលយើង មិនឲ្យភោជនដល់អ្នកទេ ។

គ្រានោះ ព្រះពោធិសត្វ កាលសម្តែងថា ធម្មតាទាន គួរឲ្យដល់បុគ្គល

ណាមួយ ទាំងដែលមានគុណធម៌ ទាំងដែលមិនមានគុណធម៌ ដូចពូជដែលគេដាំក្នុងទីទាបក្តី ទីទួលក្តី អាស្រ័យរស់ដី និងរស់ទឹក តែងដុះចេញផ្លែយ៉ាងណា ទានដែលឈ្មោះថា ឥតផល មិនមានដូច្នោះ ទានដែលឲ្យដល់បុគ្គលដែលមានគុណធម៌ រមែងមានផលច្រើន ដូចពូជដែលព្រោះចូលក្នុងស្រែដែលល្អ ដូច្នោះ ទើបពោលគាថានេះថា

ពួកអ្នកប្រាថ្នាផលស្រូវ រមែងព្រោះពូជក្នុងទីទួល ឬទីទំនាប
និងទីដែលមិនមែនជាស្រែ អ្នកចូរឲ្យទានដោយសទ្ធាបែបនេះ
ចុះ សូមអ្នកញុំាងទក្ខិណេយ្យបុគ្គល ឲ្យត្រេកអរផង ។

កាលនោះ កុមារក្រោធពន់ពេក គំហកឲ្យអ្នករក្សាទ្វារជាដើមថា អ្នកណាឲ្យមនុស្សក្បាលត្រងោលនេះចូលមក ហើយពោលគាថាថា

យើងព្រោះពូជទាំងឡាយក្នុងស្រែណា ស្រែទាំងនោះក្នុង
លោក យើងស្គាល់ច្បាស់ ពួកព្រាហ្មណ៍ណា ជាអ្នក
ប្រកបដោយជាតិ និងមន្ត ពួកព្រាហ្មណ៍ទាំងនោះ មាន
សីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ ។

ហើយបញ្ជាថា ពួកឯងចូរវាយបុគ្គលថោកទាបនេះដោយដំបង អូសគេត្រង់កឲ្យចេញទៅខាងក្រៅ ឲ្យផុតខ្លោងទ្វារ ៧ ជាន់ ។ គ្រានោះ ទើបព្រះមហាបុរសពោលនឹងមណ្ឌព្យនោះថា

**គិរឹ នខេន ខណសិ អយោ ទន្តេភិ ខាទសិ**
**ជាតវេទំ បទហសិ យោ ឥសឹ បរិភាសសិ ។**

អ្នកណាជេរប្រទេចនូវឥសី អ្នកនោះ ឈ្មោះថា ជីកភ្នំដោយក្រចក ឈ្មោះថា ខាំទំពាដែកដោយធ្មេញ ឈ្មោះថា ព្យាយាមលេបភ្លើង ។ កាលពោលដូច្នោះហើយ ត្រិះរិះថា បើកុមារនេះ គប្បីឲ្យគេចាប់អញត្រង់ដៃ ត្រង់ជើង ក៏នឹងធ្វើឲ្យទុក្ខកើត គប្បីជួបនូវវត្ថុដែលមិនមែនជាបុណ្យដ៏ច្រើន ហើយក៏ហោះឡើងកាន់វេហាស៍ ព្រោះករុណាសត្វ ទៅចុះត្រង់ចន្លោះផ្លូវ ។

ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ កាលទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់គាថានេះថា

ឥសីឈ្មោះ មាតង្គៈ ជាអ្នកមានសេចក្តីព្យាយាមទៀងទាត់
លុះពោលពាក្យនេះហើយ ក៏ចេញទៅឰដ៏អាកាស ចំពោះ
មុខពួកព្រាហ្មណ៍កំពុងក្រឡេកមើល ។

រំពេចនោះឯង ទេវរាជដែលជាប្រធានទេវតា ជាអ្នករក្សាព្រះនគរ ក៏មួលកមណ្ឌព្យកុមារ មុខរបស់គេបែរទៅខាងខ្នង ភ្នែកក៏ត្រឡប់ ទឹកមាត់ហូរតាមមាត់ ខ្លួនក៏រឹង ដូចត្រូវលំពែងដោត ដូច្នោះ ពួកយក្សដែលជាបរិវារចំនួន ៨ ម៉ឺននាក់ ក៏ធ្វើព្រាហ្មណ៍ ៨ ម៉ឺននាក់នោះដូចគ្នា មនុស្សទាំងឡាយក៏ប្រញាប់ទៅប្រាប់ដល់ព្រហ្មបជាបតី ទើបនាងប្រញាប់ប្រញាល់មក ឃើញអាការប្លែកនោះហើយ ក៏ពោលយ៉ាងនេះថា

ក្បាល ( របស់កូនអញ ) រមួលទៅខាងក្រោយ ដើមដៃ
លាតចេញទៅ មិនគួរដល់ការងារ ភ្នែកទាំងឡាយសដូច

ជាបុគ្គលស្លាប់ អ្នកណាហ្ន៎ ធ្វើកូនអញនេះ ឲ្យទៅជា
យ៉ាងនេះ ។

មនុស្សទាំងឡាយ ក៏ប្រាប់ដល់នាងថា

មានសមណៈ ( មួយរូប ) មកក្នុងទីនេះ មានប្រដាប់
ស្លៀកពាក់អាក្រក់លាមក ដូចជាបិសាចលើអាចម៍ដី ពាក់
នូវកំណាត់សំពត់ ដែលគេចោលលើគំនរសំរាមឲ្យជ៏ក
សមណៈនោះបានធ្វើនូវកូនរបស់នាងនេះ ឲ្យយ៉ាងនេះ ។

នាងបានស្តាប់ហើយ ក៏ដឹងច្បាស់ថា លោកម្ចាស់ដែលឲ្យយសដល់អញ ដឹងថា បុត្រប្រមាទ គង់នឹងមកដើម្បីអនុគ្រោះដើម្បីបុត្រនោះ ទើបសួរអ្នកបម្រើថា

សមណៈមានប្រាជ្ញាក្រាស់ ដូចផែនដីនោះ ទៅក្នុងទិសដូច
ម្តេច ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយចូរប្រាប់នូវ
សេចក្តីនុ៎ះដល់ខ្ញុំ យើងនឹងទៅសូមខមាទោសចំពោះ
សមណៈនោះ ធ្វើដូចម្តេចហ្ន៎ យើងនឹងបានកូននោះ មាន
ជីវិតរស់នៅ ។

មនុស្សទាំងនោះ ក៏ប្រាប់ថា

សមណៈមានប្រាជ្ញាក្រាស់ដូចផែនដី បានទៅក្នុងអាកាស
ដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត ដើរទៅតាមផ្លូវនៃអាកាស
មួយទៀត សមណៈនោះជាឥសី មានការប្តេជ្ញាដ៏ទៀងទាត់

មានសភាពដ៏ល្អ បានទៅកាន់ទិសខាងកើតហើយ ។

សូម្បីព្រះមហាបុរស ក៏អធិដ្ឋានថា តាំងអំពីទីដែលអញចុះ ក្នុងចន្លោះស្នាមជើងរបស់អញ កុំបីបាត់ទៅ ដោយអំណាចរបស់ដីរ សេះជាដើមឡើយ ទិដ្ឋមង្គលិកាម្នាក់ ចូរឃើញអញ អ្នកដទៃកុំឃើញឡើយ ហើយចេញត្រាច់ទៅសូមអាហារ សូមនូវបាយដែលឆ្អិនស្រាប់ បានល្មមញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ អង្គុយបរិភោគត្រង់សាលាសម្នាក់ ដាក់អាហារដែលសល់អំពីបរិភោគបន្តិចក្នុងភាជនៈដាក់អាហារនោះឯង សូម្បីនាងទិដ្ឋមង្គលិកា ចុះអំពីប្រាសាទដើរទៅតាមត្រង់ចន្លោះផ្លូវ ជួបស្នាមជើងក៏ស្គាល់ថា នេះជាស្នាមជើងរបស់លោកម្ចាស់ដែលឲ្យយសដល់អញ ក៏ដើរតាមស្នាមជើង ជួបហើយ ថ្វាយបង្គំពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អត់ទោស កំហុសដែលទាសៈរបស់លោកម្ចាស់ធ្វើទុកឲ្យខ្ញុំផងចុះ ឯលោកឈ្មោះថា មិននៅក្នុងអំណាចសេចក្ដីក្រោធ មេត្តាឲ្យជីវិតដល់បុត្ររបស់ខ្ញុំផងចុះ ក៏ពោលជាគាថាថា

ក្បាល ( របស់កូនខ្ញុំ ) រមួលទៅខាងក្រោយ ដើមដៃលាតចេញទៅ មិនគួរដល់ការងារ ភ្នែកទាំងឡាយសដូចភ្នែកបុគ្គលស្លាប់ អ្នកណាហ្ន៎ ធ្វើកូននេះ ឲ្យទៅជាយ៉ាងនេះ ។

ព្រះមហាបុរសពោលថា យើងមិនបានធ្វើយ៉ាងនោះទេ តែកាលពួកយក្ខនិងទេវតា ដែលគោរពក្នុងអ្នកបួស ឃើញបុគ្គលបៀតបៀនអ្នកបួស នឹងធ្វើក៏បានទេដឹង ។ នាងពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់គង់មិនមានចិត្តប្រទូស្តដោយពិត គង់ជាពួកទេវតាធ្វើពិត ពួកទេវតាសូមខមាទោសនាយ

ឬទេ ខ្ញុំនឹងបដិបត្តិដូចម្តេច ។ ព្រះមហាបុរសពោលថា បើយ៉ាងនោះ អាត្មានឹងប្រាប់ថ្នាំដល់នាង អាហារដែលសល់អំពីអាត្មាបរិភោគ មាននៅក្នុងភាជនៈដាក់អាហាររបស់អាត្មា នាងចូរចាក់ទឹកបន្តិចចូលក្នុងភាជនៈនោះ ហើយកាន់យកបន្តិចដាក់ក្នុងមាត់កូនរបស់នាង ចំណែកដ៏សេស ដាក់ក្នុងភាជនៈទឹកហើយយកដាក់ក្នុងមាត់ពួកព្រាហ្មណ៍ ៨ ម៉ឺននាក់ ។ នាងក៏ទទួលពាក្យហើយធ្វើតាម កាន់អាហារ ថ្វាយបង្គំមហាបុរសហើយ ក៏ទៅធ្វើតាមពាក្យប្រាប់ គ្រាន់តែអាហារដាក់ចូលក្នុងមាត់ ស្តេចទេវតាដែលជាប្រធានដឹងថាលោកម្ចាស់ ធ្វើថ្នាំដោយខ្លួនឯង ពួកយើងក៏មិនអាចធ្វើអ្វីបាន ហើយក៏ដោះលែងកុមារ កុមារនោះលេបអាហារ ហើយក៏មានអាការជាប្រក្រតី ដូចមិនបានកើតទុក្ខណាមួយឡើយ ។ កាលនោះមាតា ក៏ពោលនឹងកុមារនោះថា នែបា កូនចូរមើលអាការប្លែកៗ របស់ពួកព្រាហ្មណ៍ប្រចាំត្រកូលរបស់អ្នកដែលប្រាសចាកហិរិឱត្តប្បៈនេះចុះ ជាសមណៈ មិនគួរជាយ៉ាងនេះឡើយអ្នកឲ្យពួកសមណៈឆាន់ចុះ ។ បន្ទាប់អំពីនោះ នាងក៏ឲ្យមនុស្សយកអាហារដែលសល់ដាក់ក្នុងភាជនៈទឹក ហើយឲ្យដាក់មាត់ក្នុងព្រាហ្មណ៍ទាំងឡាយពួកយក្ខក៏រំសាយឫទ្ធិ ហើយចៀសទៅ ពួកព្រាហ្មណ៍លេបអាហារហើយ ក៏ក្រោកឡើង សួរថា យកអ្វីដាក់ក្នុងមាត់របស់យើង ។ នាងឆ្លើយថា អាហារដែលសល់របស់មាតង្គឥសី ។ ព្រាហ្មណ៍ទាំងនោះមិនសម្តែងការស្ទើកាគថាពួកយើងត្រូវបង្គាប់ឲ្យស៊ីអាហារសល់របស់មនុស្សចណ្ឌាល មិនមែនជាព្រាហ្មណ៍ ហើយឥឡូវនេះ ព្រាហ្មណ៍ទាំងនេះ មិនមែនព្រាហ្មណ៍បរិសុទ្ធ

បន្ទាប់អំពីនោះ ទើបនាំគ្នាចៀសចេញអំពីទីនោះ ទៅកាន់ដែនមេជ្ឈៈ រំពឹងថា ពួកយើងឈ្មោះថា ព្រាហ្មណ៍ដែលត្រូវភ័យខ្លាច ក្នុងនគររបស់ព្រះបាទមេជ្ឈៈ ។ ដូច្នេះហើយ ក៏បរិភោគតែក្នុងក្រុងរាជគ្រឹះ ។

សម័យនោះ ព្រះពោធិសត្វ ត្រាច់ធ្វើការសង្កត់សង្កិនមនុស្សអាក្រក់ ទូន្មានបុគ្គលដែលប្រកបដោយមានះ ។ កាលនោះតាបសមួយរូប ឈ្មោះជាតិមន្ត សម្គាល់ខ្លួនឯងថា មិនមានអ្នកណាស្មើ មិនព្រមសូម្បីតែនឹងយល់មនុស្សដទៃៗ ព្រះពោធិសត្វជួបតាបសនោះអាស្រ័យនៅត្រង់ច្រាំងស្ទឹងគង្គា ក៏ដើរទៅក្នុងទីនោះ ដោយបំណងនឹងសង្កត់សង្កិនមានះរបស់តាបសនោះ ។ ទើបជាតិមន្តតាបសសួរថា លោកដ៏ចម្រើន ជាជាតិអ្វី ព្រះពោធិសត្វឆ្លើយថា លោកអាចារ្យ ខ្ញុំជាជាតិចណ្ឌាល ។ តាបសក៏បណ្តេញថា ទៅ ចេញទៅ តាបសចណ្ឌាល ចូរនៅខាងក្រោមខ្សែទឹកស្ទឹងគង្គា កុំធ្វើទឹកខាងលើឲ្យជាសំណល់ឡើយ ព្រះពោធិសត្វក៏ទទួលថា សាធុ លោកអាចារ្យ ខ្ញុំនឹងនៅក្នុងទីដែលលោកម្ចាស់ប្រាប់ ហើយក៏ទៅនៅខាងក្រោមនៃស្ទឹងគង្គាអធិដ្ឋានថា ទឹករបស់ស្ទឹងគង្គា ចូរហូរបញ្រ្ចាស់ ។ ព្រឹកឡើង ជាតិមន្តតាបស ក៏ចុះទៅកាន់ស្ទឹងគង្គា ខ្ពុរមាត់ លុបមុខ ជម្រះជដា ព្រះពោធិសត្វនោះ ទំពាឈើស្ទន់ ស្តោះទឹកមាត់ជាដុំៗ ចូលទៅក្នុងទឹក ឈើជម្រះធ្មេញ និងទឹកមាត់ដែលស្តោះ ក៏អណ្តែតទៅកន្លែងតាបសនោះ ព្រះពោធិសត្វអធិដ្ឋានថា ឈើជម្រះធ្មេញ និងទឹកមាត់នោះ កុំជាប់ក្នុងទីដទៃ ចូរជាប់ត្រង់ផ្នួងសក់តាបសនោះឯង ទឹកមាត់ និងឈើស្ទន់ ក៏ជាប់នៅត្រង់ជដារបស់តាបស

នោះប៉ុណ្ណោះ ។ តាបសក្តៅក្រហាយរំខានចិត្ត គិតថា កម្មនេះ ជាកម្មរបស់ ឥសីចណ្ឌាលពិត ទើបដើរទៅសួរថា លោកចណ្ឌាលដ៏ចម្រើន ទឹករបស់ ស្ទឹងគង្គានេះ ឯងធ្វើឲ្យហូរបញ្ច្រាស់ឬ ព្រះពោធិសត្វឆ្លើយថា អើ លោក អាចារ្យ ។ បើយ៉ាងនោះ ឯងកុំនៅខាងក្រោមស្ទឹងគង្គាឡើយ ចូរនៅខាងលើ ស្ទឹងគង្គាចុះ ។ ព្រះពោធិសត្វក៏ទទួលពាក្យថា អើ លោកអាចារ្យ ខ្ញុំនឹងនៅ ក្នុងទីតាមដែលលោកប្រាប់ ហើយក៏នៅក្នុងទីនោះ រំសាយឫទ្ធិ ទឹកក៏ហូរ តាមប្រក្រតី តាបសក៏ជួបនូវការលំបាកនោះទៀត ទើបទៅសួរព្រះពោធិសត្វ ថា នៃចណ្ឌាលដ៏ចម្រើន ទឹករបស់ស្ទឹងគង្គានេះ ឯងធ្វើឲ្យហូរបញ្ច្រាស់ ជួន កាល ក៏ធ្វើឲ្យវាហូរបណ្តោយឬ ព្រះពោធិសត្វពោលថា អើ លោកអាចារ្យ ។ ទើបតាបសផ្តាសាថា ឯងមិនឲ្យអ្នកបួសនៅជាសុខដោយប្រក្រតី នៅដោយ ស្រួលឡើយ ក្បាលរបស់ឯង នឹងបែកចេញជា ៧ ភាគ ក្នុងថ្ងៃជាគម្រប់ ៧ រាប់អំពីថ្ងៃនេះទៅ ។ ព្រះពោធិសត្វពោលថា សាធុ លោកអាចារ្យ ឯខ្ញុំ ក៏មិនឲ្យព្រះអាទិត្យរះឡើង កាលនោះ មហាសត្វគិតថា បណ្តាសានឹងធ្លាក់ លើតាបសនោះប៉ុណ្ណោះ អញនឹងត្រូវរក្សាតាបសនោះ ។ ស្អែកឡើង ក៏មិន ឲ្យព្រះអាទិត្យរះដោយឫទ្ធិ ព្រោះករុណាសត្វ ធម្មតាឥទ្ធិវិស័យនៃអ្នកមានឫទ្ធិ ជាអចិន្តេយ្យ តាំងអំពីនោះមក ក៏មិនប្រាកដថា ព្រះអាទិត្យរះ កំណត់ពេល ថ្ងៃ និងយប់ក៏មិនបាន មិនមានអ្នកប្រកបការងារ ដូចជាធ្វើស្រែ លក់ដូរ ជាដើម មនុស្សទាំងឡាយក៏ជួបនូវអន្តរាយ ដោយមិនដឹងថា យក្ខបណ្តាល ភូត ខ្មោច ទេវតា នាគ គ្រុឌ បណ្តាល គិតគ្នាថា គួរធ្វើដូចម្តេចហ្ន៎ ធម្មតា

ថា រាជត្រកូលមានបញ្ញាច្រើន នឹងមិនអាចគិតដល់ប្រយោជន៍របស់លោកឬមកពួកយើង ទៅកាន់រាជត្រកូលចុះ ហើយក៏នាំគ្នាទៅកាន់រាជត្រកូល ប្រាប់នូវសេចក្តីនោះ ។

ព្រះរាជាស្តាប់ហើយ ទ្រង់តក់ស្លុត ក៏ធ្វើជាមិនតក់ស្លុត ត្រាស់ថា កុំខ្វាចអ្វីឡើយ តាបសឈ្មោះជាតិមន្ត នៅត្រង់ប្រាំងស្ទឹងគង្គាគង់នឹងដឹងហេតុនោះ យើងនឹងទៅសួរលោកឲ្យអស់សង្ស័យ លុះ ២-៣ ថ្ងៃ ក៏យាង មួយអន្លើដោយពួកមនុស្សដែលបំពេញប្រយោជន៍ ចូលទៅរកតាបស បានទទួលបដិសណ្ឋារៈ ហើយក៏ត្រាស់សួររឿងនោះ តាបសក៏ទូលថា ថ្វាយព្រះពរមហាបពិត្រ មានចណ្ឌាលម្នាក់គេធ្វើទឹកស្ទឹងគង្គានេះ ជួនកាលក៏ហូរបណ្តោយជួនកាលក៏ហូរបញ្ច្រាស់ ពាក្យណាមួយដែលអាត្មាពោលដើម្បីប្រយោជន៍នោះក៏មាន សូមព្រះអង្គត្រាស់សួរចណ្ឌាលនោះ គេគង់នឹងដឹង ។ ព្រះរាជាយាងទៅសម្នាក់មាតង្គឥសី ត្រាស់សួរថា លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់មិនឲ្យព្រះអាទិត្យរះឬ ព្រះពោធិសត្វពោលថា ថ្វាយព្រះពរមហាបពិត្រ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី ព្រះពោធិសត្វពោលថា ព្រោះជាតិមន្តតាបសផ្តាសាអាត្មាភាព ដែលជាអ្នកមិនមានកំហុស អាត្មាភាពនឹងឲ្យព្រះអាទិត្យរះ ទាល់តែជាតិមន្តតាបសនោះមកថ្វាយបង្គំអាត្មា សូមខមាទោសហើយ ។ ព្រះរាជាយាងទៅត្រាស់បបួលថា មកចុះ លោកអាចារ្យ សូមខមាទោសតាបស ។ ឥសីជាតិមន្តទូលថា មហាបពិត្រ អាត្មាមិនថ្វាយបង្គំមនុស្សចណ្ឌាលទេ ។ ព្រះរាជាត្រាស់ថា កុំធ្វើយ៉ាងនេះឡើយ

លោកអាចារ្យ មេត្តាយល់ដល់ពួកអ្នកដែនចុះ ។ ជាតិមន្តតាបសនោះ ក៏បដិសេធយ៉ាងនោះទៀត ព្រះរាជាក៏ចូលទៅរកព្រះពោធិសត្វត្រាស់ថា បពិត្រលោកអាចារ្យ ជាតិមន្តតាបសមិនប្រាថ្នាសូមខមាទោសឡើយ ព្រះពោធិសត្វទូលថា បើជាតិមន្តតាបសមិនសូមខមាទោស អាត្មាក៏មិនលែងព្រះអាទិត្យ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ជាតិមន្តតាបសនេះ មិនព្រមសូមខមាទោសមាតង្គឥសីនេះ បើជាតិមន្តតាបសមិនសូមខមាទោស លោកក៏មិនព្រមលែងព្រះអាទិត្យ ប្រយោជន៍អ្វីដល់ពួកយើងដោយតាបសនោះ យើងនឹងឃើញអ្នកស្រុក រួចត្រាស់បញ្ជាមនុស្សទាំងឡាយថា លោកដ៏ចម្រើន ពួកលោកចូរទៅចាប់ដៃ ជើង ជាតិមន្តតាបសនោះ មកកាន់សម្នាក់មាតង្គតាបស ចូរនាំជាតិមន្តតាបសនោះមក ហើយឲ្យថ្វាយបង្គំទៀបបាទជើងរបស់មាតង្គឥសី ត្រាស់ថា អាណិតសត្វលោក អ្នកដែនសូមខមាទោសមាតង្គឥសីនោះចេញ ។ ព្រះពោធិសត្វទូលថា អាត្មាភាពអត់ទោសដល់អ្នកដែលសូមខមាទោស តែពាក្យផ្តាសារបស់ជាតិមន្តតាបសនោះ ក៏នឹងធ្លាក់លើក្បាលរបស់ជាតិមន្តតាបសនោះឯង ក្នុងកាលដែលអាត្មាលែងព្រះអាទិត្យហើយ ពន្លឺរបស់ព្រះអាទិត្យនឹងធ្លាក់លើក្បាលជាតិមន្តតាបសនោះ កាលបើដូច្នោះ ក្បាលរបស់តាបសនោះ នឹងបែកជា ៧ ភាគ ចូរតាបសនោះ កុំជួបនូវការលំបាកនោះឡើយ ណ្ហើយចុះ ចូរចុះទឹកប្រមាណត្រឹមក ចូរដាក់ដុំដីស្អិតមួយដុំធំលើក្បាល អាត្មានឹងលែងព្រះអាទិត្យ ពន្លឺព្រះអាទិត្យនឹងធ្លាក់ត្រូវដុំដីស្អិតនោះនឹងទម្លាយដុំដីនោះបែកជា ៧ បំណែក ។ កាលតាបសនោះចោលដុំដីស្អិត

ហើយមុជទឹកទៅផុសត្រង់កំពង់ដទៃ អ្នកទាំងឡាយចូរប្រាប់តាបសនោះដូច្នេះ តាបសនោះនឹងមានសួស្តីផុតភ័យ ។ មនុស្សទាំងឡាយ ក៏ទទួលពាក្យថា នឹងធ្វើយ៉ាងនោះ ហើយក៏ធ្វើតាមពាក្យគ្រប់ប្រការ ។ សួស្តីក៏មានដល់តាបសនោះឯង ដោយប្រការដូច្នោះ ។ តាំងអំពីនោះមក ជាតិមន្តតាបសនោះក៏បានគិតថា ដែលឈ្មោះថា ជាតិ មិនជាហេតុ គុណខាងក្នុងរបស់ពួកអ្នកបួសឯណោះ ទើបជាហេតុ ក៏លះមានះ គឺការប្រកាន់ជាតិ និងគោត្រ មិនស្រវឹងទៀតឡើយ ។ ដូច្នោះ កាលជាតិមន្តតាបសត្រូវទូន្មានហើយ មហាជនក៏បានដឹងដល់កម្លាំងរបស់ព្រះពោធិសត្វ កើតកោលាហលគគ្រឹកគគ្រេងយ៉ាងធំ ព្រះរាជាត្រាស់ឲ្យនិមន្តព្រះពោធិសត្វ ទៅកាន់ព្រះនគររបស់ព្រះអង្គ ។ ព្រះពោធិសត្វថ្វាយបដិញ្ញាទទួលសំណូមពរ ត្រិះរិះថា នឹងទូន្មានព្រាហ្មណ៍ ៨ ម៉ឺននាក់នោះ នឹងដោះនូវបដិញ្ញា ហើយទៅកាន់ព្រះនគររបស់ព្រះបាទមេជ្ឈៈ ។

ព្រាហ្មណ៍ទាំងឡាយ ឃើញព្រះពោធិសត្វប៉ុណ្ណោះ ក៏ប្រឹក្សាគ្នាថា លោកដ៏ចម្រើន នេះមហាចោរនោះមកហើយ ឥឡូវនេះ នឹងធ្វើពួកយើងឲ្យប្រាកដ គឺនឹងប្រាប់អ្នកដទៃថា ពួកយើងទាំងអស់នេះ ជាអ្នកស៊ីដែល មិនជាព្រាហ្មណ៍ កាលបើដូច្នេះ ពួកយើងនឹងនៅក្នុងទីនេះមិនបាន យើងត្រូវសម្លាប់វាមុន រួចនាំគ្នាចូលទៅគាល់ព្រះរាជា ទូលថា សូមថ្វាយព្រះពរ សូមមហាបពិត្រ ទ្រង់កុំសម្គាល់អ្នកបួសចណ្ឌាលនេះថា ជាមនុស្សល្អឡើយ អ្នកបួសចណ្ឌាលនេះចេះមន្តច្រើន នឹងធ្វើផែនដីឲ្យទៅជាអាកាសក៏បាន ចាប់អាកាសឲ្យជាផែនដីក៏បាន ធ្វើទីឆ្ងាយឲ្យជិតក៏បាន ធ្វើទីជិតឲ្យឆ្ងាយក៏បាន ធ្វើស្ទឹងគង្គាឲ្យហូរ

បញ្ហោស់ក៏បាន បើប្រាថ្នាផ្សារផែនដីក៏បាន ធ្វើអន្តរាយជន្មជីពក៏បាន ឬថា ដែលឈ្មោះថា ចិត្តរបស់អ្នកដទៃមិនអាចគ្រប់គ្រងបាន គ្រប់ពេលឡើយ អ្នកបួសចណ្ឌាលនេះ កាលបានទីពឹងក្នុងនគរ ក៏គប្បីធ្វើរាជសម្បត្តិរបស់មហាបពិត្រឲ្យវិនាសក៏បាន ធ្វើអន្តរាយជន្មជីពក៏បាន កាត់ផ្តាច់ព្រះរាជវង្សក៏បាន សូមមហាបពិត្រ ជឿពាក្យរបស់អាត្មាចុះ សូមសម្លាប់វាក្នុងថ្ងៃនេះក៏គួរ ។ ដែលឈ្មោះថា ព្រះរាជាទាំងឡាយ រមែងមានបរបក្ខ ដូច្នោះ ទើបទ្រង់តក់ស្លុតក្នុងព្រះហឫទ័យ ដោយពាក្យសម្តីរបស់ព្រាហ្មណ៍ទាំងនោះ ។ ឯព្រះពោធិសត្វត្រាច់សូមអាហារក្នុងព្រះនគរ ដើរទៅកាន់ព្រះរាជឧទ្យាន ប្រាសចាកសេចក្តីសង្ស័យ ព្រោះជាអ្នកមិនមានកំហុស អង្គុយលើដុំថ្មដែលជាមង្គល មិនមានសតិ ក្នុងវេលាត្រឹមតែមួយសន្ទុះ ញាណដែលអាចរឭកបាន ៨០ កប្ប គឺអតីត ៤០ កប្ប អនាគត ៤០ កប្ប ក៏រឭកមិនបាន ។ ព្រះរាជាទ្រង់មិនឲ្យអ្នកដទៃដឹង ទ្រង់យាងទៅមួយព្រះអង្គឯង ទ្រង់យកដាវកាត់ព្រះមហាបុរសដែលអង្គុយភ្លេចខ្លួន ព្រោះរឭកមិនបានដាច់ជាពីរកំណាត់ ។ ភ្លៀងគឺពូជលោហ: ៨ ភ្លៀង គឺកក់ជាគម្រប់ ៩ ក៏ធ្លាក់ ចុះក្នុងដែនព្រះរាជាអង្គនោះ ភ្លៀង ៩ ប្រភេទធ្លាក់ចុះក្នុងដែនព្រះរាជាអង្គនេះ ដោយប្រការដូច្នេះ ។ ព្រះរាជាអង្គនោះ មួយអន្លើដោយបរិស័ទទៅកើតក្នុងនរក ។

ដោយហេតុនោះ ទើបសង្គិច្ចបណ្ឌិតពោលថា

**ឧបហច្ច មនំ មេជ្ឈោ មាតង្គស្មឹ យសស្សិនេ**

**សបារិសជ្ជោ ឧច្ឆិន្នោ មេជ្ឈារញ្ញំ តទា អហុ ។**

ព្រះរាជាព្រះនាមមេជ្ឈៈ ព្រមទាំងបរិស័ទ ញុំាងចិត្តឲ្យប្រទូស្តក្នុង តាបសឈ្មោះ មាតង្គបណ្ឌិត មានយស ហើយក៏ដល់នូវសេចក្តី វិនាស ក្នុងកាលនោះ ដែនឈ្មោះមេជ្ឈៈក៏ទៅជាព្រៃ ។

គប្បីជ្រាបថា ព្រៃមេជ្ឈៈ ក្លាយជាព្រៃទៅ ដោយប្រការដូច្នេះ ។ តែ ព្រៃមេជ្ឈៈនោះ លោកហៅថា ព្រៃមាតង្គៈ ព្រោះអំណាចរបស់ឥសី ឈ្មោះ មាតង្គៈ ។

[ ៧១ ] បទថា **បញ្ហាបដិភាណានិ** គឺបញ្ហាព្យាករ ។ បទថា **បច្ច-នីកាតព្វំ** សេចក្តីថា សម្គាល់ថា គួរធ្វើឲ្យជាសត្រូវ គឺធ្វើឲ្យដូចជាចំណែក ដែលបដិបក្ខ ។

[ ៧២ ] បទថា **អនុវិច្ចការំ** លោកអធិប្បាយថា ចូរធ្វើឲ្យជាគោល ពិចារណា គឺពិចារណាហើយ សឹមធ្វើ ។ បទថា **សាធុ ហោតិ** ប្រែថា ជាការប្រពៃ ។ ព្រះមានព្រះភាគទ្រង់សម្តែងថា កាលមនុស្សដូចអ្នកជួប តថាគត ដល់តថាគតថាជាសរណៈ កាលជួបនិគ្រន្ថហើយ ក៏ដល់នូវនិគ្រន្ថ ជាសរណៈ ពាក្យគេហានិន្ទាក៏រមែងកើតឡើងបានថា ឧបាលីនេះ ដល់នូវ បុគ្គលដែលបានជួបនោះឯងជាសរណៈឬ ព្រោះដូច្នោះ ការពិចារណាមុន ហើយធ្វើ ទើបជាការល្អសម្រាប់មនុស្សដូចជាអ្នក ។ បទថា **បដាកំ បរិហរេយ្យុំ** សេចក្តីថា បានឮថា ពួកនិគ្រន្ថទាំងនោះបានសាវកបែបនោះ ហើយ ក៏លើកទង់ គឺអួត ត្រាច់ប្រកាសថា ព្រះរាជា អមាត្យរបស់ព្រះរាជា ឬសេដ្ឋីឈ្មោះនោះៗ ជាសាវក ដល់នូវយើងថាជាសរណៈ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភាពដែលពួកយើងជាធំ និង ប្រាកដច្បាស់ដោយវិធីយ៉ាងនេះ ព្រោះថា បើបុគ្គលនោះគប្បីកើតវិប្បដិសារៈ គឺក្តៅក្រហាយ ដោយសម្គាល់ថា អញដល់សរណៈដោយហេតុអ្វី បុគ្គល នោះក៏បន្ទោបង់នូវការក្តៅក្រហាយនោះថា មនុស្សទាំងនោះ ដោយច្រើន ដឹង ដល់ភាពដែលខ្លួនមានការដល់សរណៈហើយ ឥឡូវនេះ មិនត្រឡប់ជាទុក្ខ ក្នុងការដែលដកខ្លួនត្រឡប់ទៅ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **បដាកំ បរិហរេយ្យុំ** ដូច្នេះ ។

[ ៧៣ ] បទថា **ឱបានភូតំ** ប្រែថា តាំងនៅដូចជាអណ្តូង ។ បទថា **កុលំ** គឺនិវេសន៍របស់អ្នក ។ បទថា **ទាតព្វំ មញ្ញេយ្យាសិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ទូន្មានថា ឃើញមនុស្ស ១០ នាក់ខ្លះ ២០ នាក់ខ្លះ ៦០ នាក់ខ្លះ មកហើយ កុំពោលថា មិនមាន ចូរឲ្យចុះ កុំកាត់ទេយ្យធម៌សម្រាប់ និគ្រន្ថទាំងនេះ ដោយហេតុត្រឹមតែដល់តថាគតជាសរណៈក្នុងឥឡូវនេះ ពិត ហើយ គួរឲ្យដល់ពួកបុគ្គលដែលមកដល់ហើយ ដោយពិត ។ ពាក្យថា **សុតមេតំ ភន្តេ** សេចក្តីថា ឧបាលិគហបតីទូលសួរថា ទ្រង់បានឮមកអំពី ណាព្រះអង្គ ព្រះមានព្រះភាគត្រាស់តបថា អំពីសម្នាក់របស់និគ្រន្ថទាំង-ឡាយ ឮថា និគ្រន្ថទាំងនោះប្រកាសក្នុងផ្ទះរបស់ត្រកូលទាំងឡាយយ៉ាងនេះ ថា ពួកយើងពោលថា គួរឲ្យដល់បុគ្គលណាមួយដែលមកដល់ហើយ ឯព្រះ សមណគោតមពោលថា គួរឲ្យដល់តថាគតប៉ុណ្ណោះ ។បេ។ ទានដែលឲ្យដល់ សាវកសាស្តាដទៃមិនមានផលច្រើនឡើយ គហបតីសំដៅយកពាក្យនោះ

ទើបពោលថា **សុតមេតំ** ដូច្នេះ ។

[ ៧៤ ] បទថា **អនុបុព្វិកថំ** គឺកថាពោលតាមលំដាប់យ៉ាងនេះ គឺសីលលំដាប់អំពីទាន ស្ថានសួគ៌លំដាប់អំពីសីល ទោសនៃកាមទាំងឡាយលំដាប់អំពីសួគ៌ ។ អនុបុព្វីកថានោះ ពាក្យថា **ទានកថំ** គឺកថាដែលប្រកបដោយគុណ គឺទានជាដើមយ៉ាងនេះថា ធម្មតា ឈ្មោះថាទាននេះ ជាហេតុនៃសុខទាំងឡាយ ជាមូលនៃសម្បត្តិទាំងឡាយ ជាទីតាំងនៃភោគៈទាំងឡាយ ជាទីការពារ ជាទីពួនសម្ងំ ជាទីទៅ ជាទីទៅខាងមុខនៃបុគ្គលដែលដើរផ្លូវមិនរាបស្មើ ជាទីពឹង ជាទីតាំង ជាទីជាប់ស្អិត ជាទីការពារ ជាទីសម្ងំ ជាទីទៅ ជាទីទៅខាងមុខ ដូចគ្នានឹងទាន មិនមានក្នុងលោកនេះ និងលោកដទៃ ព្រោះថាទាននេះ ដូចគ្នានឹងសីហាសនៈ គឺទីអង្គុយរបស់សិង្ហ ធ្វើដោយរតនៈ ព្រោះអត្ថថា ជាទីពឹងអាស្រ័យ ។ ដូចគ្នានឹងផែនដីធំ ព្រោះអត្ថថា ជាទីតាំង ដូចគ្នានឹងខ្សែយោង ព្រោះអត្ថថា ជាទីជាប់ស្អិត ។ ពិតហើយ ទាននេះ ប្រៀបដូចនាវា ព្រោះអត្ថថា ឆ្លងទុក្ខបាន ។ ប្រៀបដូចបុគ្គលអង់អាចក្នុងសង្គ្រាម ព្រោះអត្ថថា លួងលោមចិត្ត ប្រៀបដូចព្រះនគរដែលទំនុកបម្រុងល្អហើយ ព្រោះអត្ថថា ការពារនូវភ័យបាន ។ ប្រៀបដូចផ្កាឈូក ព្រោះអត្ថថា មិនមានមន្ទិល គឺការកំណាញ់ជាដើមជ្រាបចូលទៅ ។ ប្រៀបដូចអគ្គី ព្រោះអត្ថថា ដុតមន្ទិលទាំងនោះ ។ ប្រៀបដូចពស់ពិស ព្រោះអត្ថថា ត្រូវអង្គុយឲ្យឆ្ងាយ ។ ប្រៀបដូចរាជសីហ៍ ព្រោះអត្ថថា មិនតក់ស្លុត ។ ប្រៀបដូចដំរី ព្រោះអត្ថថា មានកម្លាំង ។ ប្រៀបដូចគោស ព្រោះសន្មតថា ជាកំពូលនៃ

មង្គល ។ ប្រៀបដូចស្តេចសេះឈ្មោះ វលាហកៈ ព្រោះអត្ថថា ទៅដល់ដែនដីដ៏ក្សេម ។ ធម្មតាទាននោះ ជាផ្លូវដែលតថាគតធ្វើដំណើរហើយ ជាវង្សរបស់តថាគតប៉ុណ្ណោះ ជាមហាយញ្ញរបស់វេលាមព្រាហ្មណ៍ ជាមហាយញ្ញរបស់គោវិន្ទសាស្តា ជាមហាយញ្ញរបស់ព្រះបាទសុទស្សនចមចក្រពត្តិ ជាមហាយញ្ញរបស់ព្រះវេស្សន្តរ ជាមហាយញ្ញជាអនេក ដែលតថាគតបំពេញបារមី ១០ បំពេញមកដល់ព្រមហើយ ជាទានដែលតថាគត កាលនៅជាទន្សាយ រមែងលោតចូលទៅក្នុងគំនរភ្លើងដែលឆេះសន្ធៅ ទាញចិត្តរបស់ពួកយាចកដែលមកដល់ហើយបាន ពិតហើយ ទានរមែងឲ្យសគ្គសម្បត្តិក្នុងលោក ឲ្យមារសម្បត្តិ ឲ្យព្រហ្មសម្បត្តិ និងឲ្យចក្កវត្តិសម្បត្តិ ឲ្យសាវកបារមីញាណ បច្ចេកពោធិញ្ញាណ អភិសម្ពោធិញ្ញាណ បុគ្គលកាលឲ្យទានរមែងអាចសមាទានសីលបាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់សីលកថាក្នុងលំដាប់អំពីទាននោះ ។ បទថា **សីលកថំ** គឺកថាដែលប្រកបដោយគុណ គឺសីលជាដើមយ៉ាងនេះថា ធម្មតាសីលនេះ ជាទីពឹងពាក់ ជាទីតាំង ជាទីជាប់ស្អិត ជាទីការពារ ជាទីពួនសម្ងំ ជាទីទៅ ជាទីទៅខាងមុខ ធម្មតាសីលនេះ ជាវង្សរបស់តថាគត តថាគតបំពេញបរិបូណ៌ក្នុងអត្តភាពទាំងឡាយ មិនមានទីបំផុត គឺកាលនៅជាស្តេចនាគឈ្មោះ សង្ខបាល កាលនៅជានាគឈ្មោះ ភូរិទត្ត កាលនៅជានាគឈ្មោះ ចម្បេយ្យ កាលនៅជានាគឈ្មោះ សីលវៈ កាលនៅជាដំរីដែលចិញ្ចឹមមាតា កាលនៅជាដំរីឈ្មោះ ឆទ្ទន្ត ពិតហើយ ទីពឹងអាស្រ័យនៃសម្បត្តិទាំងឡាយក្នុងលោកនេះ និងលោកដទៃ

ដូចគ្មានទីងសីល ទីតាំង ទីបិទបាំង ទីការពារ ទីពួនសម្ងំ ជាទីទៅ ជាទីទៅខាងមុខ ដូចគ្មានទីងសីលមិនមាន ។ គ្រឿងប្រដាប់ ដូចគ្មានទីងគ្រឿងប្រដាប់ គឺសីលមិនមាន ផ្កា ដូចគ្មានទីងផ្កា គឺសីលមិនមាន ក្លិន ដូចគ្មានទីងក្លិន គឺសីលមិនមាន លោកនេះ និងទេវលោក សម្លឹងមើលបុគ្គលប្រដាប់ដោយគ្រឿងប្រដាប់ គឺសីល បុគ្គលមានផ្កា គឺសីលជាគ្រឿងប្រដាប់ បុគ្គលមានសីលជាគ្រឿងលាបស្រឡាប រមែងមិនឆ្អែត ដើម្បីទ្រង់សម្តែងថា បុគ្គលអាស្រ័យសីលនេះ រមែងបានស្ថានសួគ៌ ដូច្នេះ ទើបត្រាស់សគ្គកថាបន្ទាប់អំពីសីលនោះ ។ បទថា **សគ្គកថំ** បានដល់ កថាដែលប្រកបដោយគុណគឺសួគ៌ជាដើមយ៉ាងនេះថា ធម្មតាសួគ៌នេះ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ក្នុងសួគ៌នោះ មានការលេងជានិច្ច បានសម្បត្តិទាំងឡាយជានិច្ច ទេវតាជាន់ចាតុម្មហារាជ សោយទិព្វសម្បត្តិ ៩ លានឆ្នាំ ជាន់តាវត្តិង្ស ៣ កោដិនិង ៦ កោដិឆ្នាំ ។ ព្រះឱស្ឋរបស់ព្រះពុទ្ធទាំងឡាយ ដែលកំពុងត្រាស់ដល់សគ្គសម្បត្តិ ក៏មានមិនល្មម សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតគប្បីពោលសគ្គកថា ដោយបរិយាយជាអនេកដូច្នេះ ។ ព្រះមានព្រះភាគ កាលទ្រង់លួងលោមដោយសគ្គកថាយ៉ាងនេះហើយ ប្រៀបដូចទ្រង់ប្រដាប់ដំរីហើយ កាត់ប្រមោយរបស់ដំរីនោះចោលទៀត ទ្រង់សម្តែងថា ស្ថានសួគ៌នេះមិនទៀង មិនគួរធ្វើការត្រេកអរក្នុងស្ថានសួគ៌នោះ ទើបត្រាស់ថា កាមទាំងឡាយមានសេចក្តីរីករាយតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន ។ ក្នុង

បទទាំងនោះ បទថា **អាទីនវោ** ប្រែថា ទោស ។ ពាក្យថា **ឱការោ** ប្រែថា អាក្រក់ ថោកទាប ។ បទថា **សង្កិលេសោ** គឺការសៅហ្មងក្នុងសង្សារវដ្តនៃសត្វទាំងឡាយ ព្រោះកាមទាំងនោះ ដូចព្រះតម្រាស់ថា អើហ្ន៎ ពួកសត្វសៅហ្មងណាស់ អើហ្ន៎ ពួកសត្វសៅហ្មងណាស់ ។ ព្រះមានព្រះភាគទ្រង់សម្តែងដោយទោសរបស់កាមយ៉ាងនេះហើយ ទើបទ្រង់ប្រកាសអានិសង្សក្នុងនេក្ខម្ម: គឺការចេញចាកកាម ។ បទថា **កល្លចិត្តំ** គឺចិត្តមិនខូច ។ បទថា **សាមុក្កំសិកា** គឺដែលទ្រង់លើកឡើងឯង គឺដែលទ្រង់លើកឡើងកាន់យកដោយព្រះអង្គឯង អធិប្បាយថា ដែលទ្រង់ឃើញដោយព្រះសយម្ភូញាណ មិនទូទៅដល់អ្នកដទៃ ។ សួរថា នុ៎ះគឺអ្វី ឆ្លើយថា គឺអរិយសច្ចទេសនា ដោយហេតុនោះ ទើបលោកពោលថា ទុក្ខ សមុទយ: និរោធ មគ្គ ។ បទថា **វិរជំ វីតមលំ** សេចក្តីថា ដែលឈ្មោះថា ប្រាសចាកធូលី ព្រោះមិនមានធូលី គឺរាគ:ជាដើម ដែលឈ្មោះថា ប្រាសចាកមន្ទិល ព្រោះប្រាសចាកមន្ទិល គឺរាគ:ជាដើម ។ បទថា **ធម្មចក្ខុំ** នេះ ជាឈ្មោះរបស់មគ្គ ៣ ក្នុងព្រហ្មាយុសូត្រខាងមុខ និងរបស់អាសវក្ខយញ្ញាណ ក្នុងចូឡរាហុលោវាទសូត្រ ។ ឯក្នុងទីនេះ ទ្រង់បំណងយកសោតាបត្តិមគ្គ ។ ដើម្បីទ្រង់សម្តែងអាការកើតឡើងនៃធម្មចក្ខុនោះ ទើបត្រាស់ថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅជាធម្មតា ។ ធម្មចក្ខុនោះ ធ្វើនិរោធឲ្យជាអារម្មណ៍ហើយ ចាក់ធ្លុះសង្ខតធម៌ទាំងពួង ដោយអំណាចកិច្ចនោះកើតឡើង ។ អរិយសច្ចធម៌ដែលបុគ្គលនោះឃើញហើយ

ហេតុនោះ បុគ្គលនោះ ឈ្មោះថា **ទិដ្ឋធម្មោ** ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នា ។ ការសង្ស័យដែលបុគ្គលនោះឆ្លងហើយ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **តិណ្ណវិចិកិច្ឆោ** ។ ពាក្យពោលថា ដូចម្ដេចរបស់បុគ្គលនោះទៅប្រាសហើយ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **វិគតកថំកថោ** ។ បុគ្គលនោះដល់ហើយនូវការក្លៀវក្លា ហេតុនោះ បុគ្គលនោះ ឈ្មោះថា **វេសារជ្ជប្បត្តោ** ។ បុគ្គលនោះមិនមានអ្នកដទៃជាបច្ច័យ ក្នុងពាក្យទូន្មានរបស់ព្រះសាស្ដា ។ គឺមិនប្រព្រឹត្តទៅក្នុងពាក្យទូន្មានរបស់ព្រះសាស្ដានោះ ដោយការជឿអ្នកដទៃ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **អបរប្បច្ចយោ** ។ ឧបាលិគហបតីទទួលយកដោយចិត្តត្រេកអរហើយ សរសើរដោយវាចា រីករាយហើយ ។

[ ៧៥ ] បទថា **អាវរាមិ** ប្រែថា រាំង បិទ ។ បទថា **អនាវដំ** បានដល់ មិនហាម គឺបើកទ្វារហើយ ។

[ ៧៦ ] បទថា **អស្សោសិ ខោ ទីឃតបស្សី** សេចក្ដីថា បានឮថា ទីឃតបស្សីនិគ្រន្ថនោះ តាំងអំពីឧបាលិគហបតីនោះទៅហើយ ក៏ត្រាច់ផ្ទៀងត្រចៀកស្ដាប់ថា គហបតីដែលជាបណ្ឌិត និងព្រះសមណគោតម ដែលដល់ព្រមដោយទស្សនៈ មានវាចានាំសត្វចេញចាកទុក្ខ នឹងជ្រះថ្លាព្រោះហេតុឧបាលិបណ្ឌិតនោះ នឹងជ្រះថ្លាក្នុងធម្មកថា កាលជ្រះថ្លាហើយ នឹងដល់សរណៈ ព្រោះហេតុនោះ ឬ មិនដល់សរណៈ ព្រោះហេតុនោះមុនហ្ន៎ ។ ព្រោះដូច្នោះ ទីឃតបស្សីនិគ្រន្ថបានឮជាដំបូងនោះឯង ។

[ ៧៨ ] បទថា **តេនហិ សម្ម** សេចក្ដីថា ទីឃតបស្សីនិគ្រន្ថត្រូវសេចក្ដីសោកដ៏ខ្លាំងក្លាគ្របសង្កត់ សូម្បីបានឮពាក្យថា ចូរឈប់នៅក្នុងទីនេះចុះ តែកំណត់មិនបាន ទើបចរចាជាមួយអ្នកយាមទ្វារនោះឯង ។ បទថា **មជ្ឈិមាយំ ទ្វារសាលាយំ** សេចក្ដីថា ផ្ទះណាមានខ្លោងទ្វារ ៧ ខ្លោងទ្វារទី ៤ នៃផ្ទះនោះ រាប់អំពីខ្លោងទ្វារខាងក្នុងមក ឈ្មោះថា សាលាជិតទ្វារកណ្ដាល ផ្ទះណាមានខ្លោងទ្វារ ៥ ខ្លោង ទ្វារទី ៣ នៃផ្ទះនោះ ឈ្មោះថា សាលាជិតទ្វារកណ្ដាល ផ្ទះណាមានខ្លោងទ្វារ ៣ ខ្លោងទ្វារទី ២ នៃផ្ទះនោះ ឈ្មោះថា សាលាជិតទ្វារកណ្ដាល ឯផ្ទះដែលមានខ្លោងទ្វារ ១ ខ្លោងទ្វារដែលអាស្រ័យសសរមង្គលត្រង់កណ្ដាល ឈ្មោះថា សាលាក្បែរទ្វារកណ្ដាល តែផ្ទះរបស់ឧបាលិគហបតីនោះ មានខ្លោងទ្វារ ៧ ។ លោកពោលថា ខ្លោងទ្វារ ៥ ក៏មាន ។ បទទាំងអស់ មានបទថា **អគ្គំ** ជាដើម ជាវេវចនៈនៃគ្នានិងគ្នា ។

[ ៧៩ ] ក្នុងបទថា **យំ សុទំ** នេះ បទថា **យំ** សំដៅដល់នាដបុត្រ ។ បទថា **សុទំ** ត្រឹមតែជានិបាត ។ បទថា **បរិគ្គហេត្វា** សេចក្ដីថា យកសំពត់ដណ្ដប់មួយផ្ទាំងនោះឯងក្រាល ។ បទថា **និសីទាបេតិ** សេចក្ដីថា គ្រាប់ឲ្យអាចារ្យអង្គុយសន្សឹមៗ ប្រៀបដូចដាក់ក្អមទឹកដ៏ធំ ដូច្នោះ ។ បទថា **ឧម្មត្តោសិ** សេចក្ដីថា លោកកើតល្ងង់ទៅហើយឬ ។ បទថា **បដិមុក្កោ** សេចក្ដីថា ដាក់ត្រង់ក្បាល គឺពាក់ត្រង់ក្បាល ។ បទថា **អណ្ឌហារកោ** ជាដើម ជាពាក្យគ្រោតគ្រាត ទីឃតបស្សីនិគ្រន្ថក៏កំណត់មិនបានថា ពាក្យ

ពោលនេះគ្រោតគ្រាត ក៏ពោលចេញទៅ ព្រោះកើតទោមនស្សក្នុងចិត្តយ៉ាង ខ្លាំងក្លា ព្រោះឧបាលីក្លាយទៅជាដទៃ ។

[ ៨០ ] បទថា **ភទ្ទិកា ភន្តេ អាវដ្ដនី** សេចក្ដីថា និគ្រន្ថពោល សំដៅដល់មាយានោះឯង ឧបាលីសម្រេចសោតាបត្តិមគ្គ ចាក់ធ្លុះដោយខ្លួន ឯង ។ បទថា **តេនហិ** នេះ ត្រឹមតែជានិបាត សេចក្ដីថា លោកដ៏ចម្រើន ខ្ញុំនឹងធ្វើពាក្យប្រៀបធៀបដល់លោក ។ម្យ៉ាងទៀត ជាពាក្យប្រាប់ហេតុ ។ លោកអធិប្បាយថា ពាក្យប្រៀនប្រដៅរបស់ពួកលោក មិនមែនធម៌នាំសត្វ ចេញចាកទុក្ខ ដោយហេតុឯណា ខ្ញុំនឹងធ្វើពាក្យប្រៀបធៀបដល់លោក ដោយហេតុនោះ ។

[ ៨១ ] បទថា **ឧបវិជញ្ញា** ប្រែថា ជិតវេលាប្រសូត ។ បទថា **មក្កដច្ឆាបកំ** ប្រែថា កូនស្វា ។ បទថា **វិកិណិត្វា អានេហិ** សេចក្ដីថា ចូរឲ្យតម្លៃ ហើយនាំមក ។ ពិតហើយ ក្នុងផ្សារ អ្នកជំនួញសួម្បីលក់ រមែងលក់របស់លេងសម្រាប់ក្មេង ទាំងដែលមានវិញ្ញាណ ទាំងដែលមិន មានវិញ្ញាណ កិរិយារបស់ព្រាហ្មណ៍ចាស់នោះ ពោលសំដៅដល់របស់លេង នោះ ។ បទថា **រជិតំ** សេចក្ដីថា ខ្ញុំត្រូវការរបស់នេះ ដែលគេយកពណ៌ ជ្រលក់ រមែងជ្រលក់ដោយពណ៌លឿងឲ្យ ។ បទថា **អាកោដ្ដិតប្បច្ចា-កោដ្ដិតំ** សេចក្ដីថា ដែលគេជំត្រឡប់ទៅត្រឡប់មករឿយៗ ។ បទថា **ឧភតោ ភាគវិមដ្ឋំ** សេចក្ដីថា មានពណ៌ដែលគេខាត់រលីងល្អទាំងសងខាង ហើយដោយបូស្សី មណី និងថ្ម ។ បទថា **រង្គក្ខមោ ហិ ខោ** សេចក្ដីថា

របស់លេងដែលមានវិញ្ញាណផង មិនមានវិញ្ញាណផង រមែងស្រូបពណ៌ ជ្រលក់ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ ។ បទថា **ឆោ អាកោដ្ដនក្ខមោ** សេចក្ដីថា កាលរបស់លេងមានវិញ្ញាណ បុគ្គលនោះដាក់ចុះត្រង់បន្ទះក្ដារ សម្រាប់ដំ ហើយដំត្រង់ពោះមុន ពោះក៏បែក លាមកក៏បានហូរចេញ ដំត្រង់ ក្បាល ក្បាលក៏បែក ខួរក៏ហូរចេញ របស់លេងដែលមិនមានវិញ្ញាណ ក៏ បែកជាបំណែកតូចបំណែកធំ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ ។ បទថា **វិមជ្ជនក្ខមោ** សេចក្ដីថា របស់លេងដែលមានវិញ្ញាណដែលបុគ្គលខាត់ដោយ មណី និងថ្ម ក៏របករោម របកស្បែក របស់លេងដែលមិនមានវិញ្ញាណ ក៏ បែកល្អិត ទើបពោលយ៉ាងនេះ ។ បទថា **រង្គក្ខមោ ហិ ខោ ពាលានំ** សេចក្ដីថា បុគ្គលគួរដល់ការជ្រលក់ រមែងឲ្យកើតត្រឹមតែរាគៈ ជាទីស្រឡាញ់ នៃបុគ្គលល្ងង់ខ្លៅ មានការចេះដឹងតិច ឯវាទៈរបស់និគ្រន្ថក្ដី កថាមគ្គដទៃៗ ដែលឥតប្រយោជន៍ ដូចជារឿងការតយុទ្ធ និងរាមាយណៈជាដើមក្ដី មិនជា ទីស្រឡាញ់នៃជនជាបណ្ឌិតឡើយ ។ បទថា **ឆោ អនុយោគក្ខមោ ឆោ វិមជ្ជនក្ខមោ** សេចក្ដីថា មិនអត់ធន់ក្នុងការប្រកបតាម ឬ ការពិចារណា រមែងទទេ និងដូចបកអង្កាមរកអង្ករ និងដូចរកខ្លឹមក្នុងដើមចេក ។ បទថា **រង្គក្ខមោចេវ បណ្ឌិតានំ** សេចក្ដីថា ពិតហើយ កថាដែលពោលដោយ អរិយសច្ច ៤ រមែងជាទីស្រឡាញ់នៃពួកបណ្ឌិត សូម្បីស្ដាប់អស់រយៈនៃឆ្នាំ ក៏មិនមានឆ្អែត ។ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ ។ ពុទ្ធវចនៈរមែងមាន ជម្រៅតែម្យ៉ាង ដូចមហាសមុទ្រ ដោយប្រការដែលឈមចុះបាន ព្រោះហេតុ

នោះ ទើបឧបាលិគហបតីពោលថា **អនុយោគក្ខមោ ច វិមជ្ជនក្ខមោ ច ។**

[ ៨២ ] បទថា **សុណាហិ** សេចក្តីថា ឧបាលិគហបតីពោលពុទ្ធគុណនៃព្រះមានព្រះភាគថា ខ្ញុំជាសាវកនៃព្រះសាស្តាអង្គណា សូមស្តាប់ព្រះពុទ្ធគុណទាំងឡាយនៃព្រះសាស្តាអង្គនោះ ។

បណ្ឌិតហៅថា **ធីរៈ** ក្នុងបទថា **ធីរស្ស** ។ គប្បីជ្រាបសម្ពន្ធក្នុងបទទាំងពួងយ៉ាងនេះថា បញ្ញា ការដឹងដោយជុំវិញ ។បេ។ ការឃើញប្រពៃណា ខ្ញុំជាសាវករបស់ព្រះពុទ្ធ ទ្រង់ប្រកបដោយបញ្ញានោះ ទ្រង់ជាបណ្ឌិត ឈ្លាសក្នុងធាតុ អាតយនៈ បដិច្ចសមុប្បាទ ឋានៈ និងអឋានៈ ព្រះពុទ្ធអង្គនោះទ្រង់ជាព្រះសាស្តារបស់ខ្ញុំ ។ បទថា **បភិន្នខីលស្ស** ប្រែថា បុគ្គលមានកិលេសដូចសសរគោលដែលទម្លាយបានហើយ ។ សភាវៈពួកឯណា ឈ្នះហើយ កំពុងឈ្នះ នឹងឈ្នះនូវបុថុជ្ជនទាំងពួង ហេតុនោះ សភាវៈទាំងនោះឈ្មោះថា **វិជយ** ។ សួរថា សភាវៈទាំងនោះ គឺអ្វី ឆ្លើយថា គឺមច្ចុមារ កិលេសមារ និងទេវបុត្តមារ មារអ្នកឈ្នះទាំងនោះ ដែលព្រះពុទ្ធអង្គទ្រង់ឈ្នះហើយ ព្រោះហេតុនោះ ទើបព្រះពុទ្ធអង្គនោះ ឈ្មោះថា ជាអ្នកមានមារដែលទ្រង់ឈ្នះហើយ គឺព្រះមានព្រះភាគ ជាអ្នកមានមារដែលទ្រង់ឈ្នះហើយអង្គនោះ ។ បទថា **អនីឃស្ស** ប្រែថា បុគ្គលមិនមានទុក្ខ ទាំងកិលេសទុក្ខនិងវិបាកទុក្ខ ។ បទថា **សុសមចិត្តស្ស** គឺអ្នកមានចិត្តស្មើដោយល្អ ក្នុងកិក្ខុទេវទត្ត ដំរីឈ្មោះធនបាលក អង្គុលិមាល និងព្រះរាហុលជាដើម ។ បទថា **វុទ្ធសីលស្ស** ប្រែថា ជាអ្នកមានអាចារដែលចម្រើនហើយ ។ បទថា

**សាធុបញ្ញស្ស** ប្រែថា ជាអ្នកមានបញ្ញាល្អ ។ បទថា **វេសមន្តរស្ស** ប្រែថា ជាអ្នកច្នៃទីដែលមិនស្មើ មានរាគៈជាដើម បញ្ចាក់អះអាងហើយ ។ បទថា **វិមលស្ស** ប្រែថា ជាអ្នកមានមន្ទិល មានរាគៈជាដើមទៅប្រាសហើយ ។ បទថា **តុសិតស្ស** ប្រែថា អ្នកមានចិត្តត្រេកអរហើយ ។ បទថា **វន្ត-លោកាមិស្ស** គឺបុគ្គលមានកាមគុណខ្ជាក់ចោលហើយ ។ បទថា **មុទិតស្ស** គឺបុគ្គលលែងនូវការត្រេកអរហើយ ដោយអំណាចមុទិតាវិហារធម៌ ម្យ៉ាងទៀត ពាក្យនេះ ឧបាលិគហបតីពោលដដែលនោះឯង ។ ជាការពិត ឧបាលិគហបតីពោលព្រះពុទ្ធគុណតែមួយរឿយៗ ដោយជ្រះថ្លានោះឯង ។ បទថា **កតសមណស្ស** ប្រែថា អ្នកមានគុណជាគ្រឿងដែលសមណៈធ្វើហើយ អធិប្បាយថា ទ្រង់ដល់នូវទីបំផុតនៃធម៌របស់សមណៈ ។ បទថា **មនុជស្ស** ប្រែថា ជាសត្វម្នាក់ ដោយអំណាចលោកវោហារ ។ ឧបាលិគហបតីពោលដដែលទៀតថា ជានរៈ កាលគាត់ពោលដោយប្រការដទៃ ព្រះគុណ ១០ ប្រការ ពោលដោយគាថាមួយៗ រមែងមិនគ្រប់គ្រាន់ ។ បទថា **វេន-យិកស្ស** ប្រែថា ជាអ្នកនាំសត្វទាំងឡាយ ។ បទថា **រុចិរធម្មស្ស** ប្រែថា មានធម៌ស្អាត ។ បទថា **បភាសកស្ស** ប្រែថា ជាអ្នកធ្វើនូវពន្លឺ ។ បទថា **វីរស្ស** គឺដល់ព្រមដោយសេចក្តីព្យាយាម ។ បទថា **និសភស្ស** គឺបណ្ដាគោលំដាប់ឧសភៈ លំដាប់វសភៈ លំដាប់និសភៈ ដោយអត្ថថា មិនមានបុគ្គលប្រៀបបានក្នុងទីទាំងពួង ។ បទថា **គម្ភីរស្ស** ប្រែថា ទ្រង់មានព្រះគុណជ្រាលជ្រៅ ឬទ្រង់ជ្រៅដោយព្រះគុណទាំងឡាយ ។ បទថា **មោន-**

**ប្បត្តស្ស** គឺជាអ្នកសម្រេចញាណ ។ ញាណ គឺ បញ្ញា ឈ្មោះថា **វេទ** ក្នុងបទថា **វេទស្ស** បុគ្គលដល់ព្រមដោយការដឹង ដែលហៅថា វេទនោះ ។ បទថា **ធម្មដ្ឋស្ស** ប្រែថា ដែលតាំងនៅក្នុងធម៌ ។ បទថា **សំវុតស្ស** ជាអ្នកមានខ្លួនសង្រួមហើយ គឺមានខ្លួនបិទហើយ ។ បទថា **ឆាគស្ស** ប្រែថា បុគ្គលប្រសើរដោយហេតុ ៤ ប្រការ ។ បទថា **បន្តសេនស្ស** ប្រែថា ជាអ្នកមានទីដេក និងទីអង្គុយស្ងប់ស្ងាត់ ។ បទថា **បដិមន្តកស្ស** ប្រែថា បុគ្គលដល់ព្រមដោយបញ្ញាឆ្លើយនូវវេទ ។ ញាណ ហៅថា **មោន** ក្នុងបទថា **មោនស្ស** ទ្រង់ដល់ព្រមដោយញាណនោះ ឬដែលមានកិលេសកម្ចាត់បានហើយ ។ បទថា **ទន្តស្ស** គឺអស់ព្យសន៍ ។ បទថា **ឥសិសត្តមស្ស** គឺទ្រង់ជាឥសីអង្គទី ៧ រាប់អំពីឥសី ៦ អង្គ មានវិបស្សីឥសីជាដើម ។ បទថា **ព្រហ្មសត្តស្ស** ប្រែថា ជាសត្វដ៏ប្រសើរ ។ បទថា **ឆ្នាតកស្ស** ប្រែថា ជាអ្នកមានកិលេសលាងហើយ ។ បទថា **បទកស្ស** គឺជាអ្នកឈ្លាសក្នុងការចងអក្ខរៈទាំងឡាយជាបទគាថា ។ បទថា **វិទិតវេទស្ស** ប្រែថា ជាអ្នកមានញាណដឹងច្បាស់ ។ បទថា **បុរិន្ទទស្ស** ប្រែថា ទ្រង់ប្រទានធម្មទានមុនបុគ្គលដទៃទាំងអស់ ។ បទថា **សក្កស្ស** ប្រែថា ជាអ្នកអាច ។ បទថា **បត្តិបត្តស្ស** ប្រែថា ជាអ្នកសម្រេចគុណដែលគួរសម្រេច ។ បទថា **វេយ្យាករណស្ស** ប្រែថា ជាអ្នកសម្ដែងអត្ថបានទូលំទូលាយ ។ សេចក្ដីពិតបទថា **ព្យាកតន្ទាមេតំ** ប្រែថា មិនមាន ។ អត្ថនៃបទទាំងពួង ព្រះមានព្រះភាគត្រាស់ហើយ ។ បទថា **វិបស្សិស្ស** ប្រែថា ទ្រង់ឃើញច្បាស់ ។ បទ

ថា **អនភិណតស្ស** ប្រែថា មិនមែនជាអ្នកស្វាធ្យាយមន្ត ។ បទថា **នោអបណាតស្ស** សំដៅដល់ បុគ្គលមិនឈរតាម ។ បទថា **អននុគតន្តរស្ស** បានដល់ បុគ្គលមិនដើរតាម គឺមិនមានចិត្តទៅតាមកិលេសទាំងឡាយ ។ បទថា **អសិតស្ស** គឺមិនជាប់ជំពាក់ ។ ផែនដី ហៅថា **ភូរិ** ក្នុងបទថា **ភូរិប្បញ្ញស្ស** អធិប្បាយថា ជាអ្នកដល់ព្រមដោយបញ្ញាបរិបូណ៌ ធំទូលាយដូចផែនដី ។ បទថា **មហាបញ្ញស្ស** គឺដល់ព្រមដោយបញ្ញាដ៏ធំ ។ បទថា **អនុបលិត្តស្ស** គឺជាអ្នកដែលគ្រឿងប្រឡាក់ គឺតណ្ហា និងទិដ្ឋិមិនប្រឡាក់ហើយ ។ បទថា **អាហុនេយ្យស្ស** គឺបុគ្គលគួរទទួលរបស់បូជា ។ ព្រះមានព្រះភាគ ព្រះនាមថា **យក្ខ** ក្នុងបទថា **យក្ខស្ស** ព្រោះអត្ថថា ទ្រង់សម្តែងអានុភាពបាន ឬ ព្រោះអត្ថថា ដែលបុគ្គលណាមួយមើលមិនឃើញ ព្រោះហេតុនោះ ទើបឧបាលិគហបតីពោលថា **យក្ខស្ស** ។ បទថា **មហតោ** ប្រែថា ធំ ។ បទថា **តស្ស សាវកោហមស្មិ** សេចក្តីថា ខ្ញុំជាសាវករបស់ព្រះសាស្តាដែលជាអ្នកមានព្រះគុណ មានប្រការដូច្នោះ ។ បដិសម្ភិទា បញ្ញាបែកធ្លាយរបស់ឧបាសក មកដល់ដោយសោតាបត្តិមគ្គនោះឯង ។

ដូច្នោះ ឧបាលិគហបតីតាំងនៅក្នុងវិស័យនៃបញ្ញាបែកធ្លាយហើយ កាលនឹងពោលគុណនៃព្រះទសពល ក្នុងការលះកិលេស ១០០ បទ ទើបវិសជ្ជនាអត្ថនៃបញ្ហាដែលថា នៃគហបតី ពួកយើងចាំថា ខ្ញុនលោកជាសាវករបស់នរណា ។

[ ៨៣ ] បទថា **កទា សញ្ញូឡ្ហា** ប្រែថា ប្រមូលទុកអង្កាល់ណា ។

បានឮថា និគ្គណ្ឋនាដបុត្រនោះគិតយ៉ាងនេះ ឧបាលិគហបតីនេះទៅកាន់សម្នាក់ព្រះគោតម មកឥឡូវនេះឯង គេប្រមូលគុណទាំងនោះ តាំងពីពេលណា ព្រោះដូច្នោះ ទើបនិគ្គណ្ឋនាដបុត្រពោលយ៉ាងនេះ ។ បទថា **វិចិត្តំមាលំ គន្ថេយ្យ** សេចក្តីថា នាយមាលាការ កាលកូនជាងធ្វើផ្កា គប្បីដោតជារបៀបដ៏វិចិត្រ ដោយរបៀបផ្កាជាគោល មានទងតែមួយជាដើម ដោយភាពជាអ្នកឧស្សាហ៍ឯងខ្លះ ដោយភាពដែលផ្កាទាំងឡាយ មានពណ៌ផ្សេងៗខ្លះ ។ ក្នុងបទថា **ឯវមេវ ខោ ភន្តេ** នេះ គប្បីឃើញការប្រមូលពណ៌នាគុណមានប្រការផ្សេងៗ របស់ព្រះមានព្រះភាគប៉ុនភ្នំព្រះសិនេរុ ដូចគំនរផ្កាធំ ក្នុងបណ្តាផ្កាទាំងឡាយជាច្រើនប្រភេទ ។ ឧបាលិគហបតី ប្រៀបដូចជានាយមាលាការដ៏ឈ្លាស ក្រងនូវព្រះគុណដ៏វិចិត្ររបស់ព្រះតថាគត ដូចការក្រងនូវកម្រងផ្កាដែលវិចិត្រនៃនាយមាលាការ ដូច្នោះ ។

បទថា **ឧណ្ហំ លោហិតំ មុខតោ ឧគ្គញ្ឆិ** សេចក្តីថា និគ្គណ្ឋនាដបុត្រនោះ អត់ទ្រាំនឹងសក្ការៈរបស់ព្រះមានព្រះភាគមិនបាន ក៏គិតច្រើនថា តាំងអំពីស្អែកនេះ អញក៏នាំគណៈ ៥០-៦០ នាក់ ចូលទៅស្រុក បរិភោគមិនបាន ឆ្នាំងបាយរបស់យើងបែកហើយ ។ គ្រានោះ និគ្គណ្ឋនាដបុត្រនោះ កើតសេចក្តីសោកដ៏មានកម្លាំង ព្រោះឧបដ្ឋាកបូរទីទំនុកបម្រុង ។ សេចក្តីពិតសត្វទាំងនេះ គិតដើម្បីខ្លួនតែម្យ៉ាង ។ កាលសេចក្តីសោកនោះ កើតដល់និគ្គណ្ឋនាដបុត្រនោះហើយ កម្តៅខាងក្នុងក៏មាន លោហិតក៏រលាយ ។ លោហិតនោះត្រូវគំនរខ្យល់ធំបក់ឡើង ក៏ខ្ចុរចេញតាមមាត់ប្រមាណមួយបាត្រ

ដូចទឹកជ្រលក់ ដែលដាក់ចូលក្នុងផ្ទាំង ។ សត្វចំនួនតិចខ្លាក់លោហិត ដែលខ្មាស ហើយ ដែលអាចមានជីវិតនៅបាន ។ និគ្រន្ថលុតជង្គង់ដួលចុះក្នុងទីនោះឯង ។ ក្នាក់ងារខាងលីសែង ក៏នាំនិគ្គណ្ឋនាដបុត្រនោះចេញអំពីព្រះនគរទៅដោយគ្រែស្នែង ៥ នាក់ រហូតមកដល់នគរបាវា ។ បន្ទាប់មកមិនយូរប៉ុន្មាន និគ្គណ្ឋនាដបុត្រ ក៏ធ្វើកាលកិរិយាក្នុងនគរបាវា ។ ព្រះធម្មទេសនាក្នុងព្រះសូត្រនេះ ក៏សម្រេចដោយអំណាចបុគ្គល ដែលជាឧគ្ឃដិតញ្ញូ ដូច្នេះ ។

**ឧបាលិវាទសូត្រ ចប់**

**សូត្រទី ៦ ចប់**

# សុត្តន្តបិដក

## កុក្កុរោវាទសូត្រទី ៧

[ ៨៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងនិគម ឈ្មោះ ហលិទ្ទវសនៈ របស់អ្នកស្រុកកោលិយៈ ក្នុងកោលិយជនបទ ។ លំដាប់នោះ កោលិយបុត្រឈ្មោះបុណ្ណៈ ជាអ្នកសមាទានគោវត្ត និងអចេលក៍ ឈ្មោះ សេនិយៈ ជាអ្នកសមាទានកុក្កុរវត្ត បានចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបបុណ្ណកោលិយបុត្រ ជាអ្នកសមាទានគោវត្ត ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ចំណែកខាងសេនិយអចេលក៍អ្នកសមាទានកុក្កុរវត្ត ក៏រីករាយរាក់ទាក់ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយដើមហ៊ុម ធ្វើដូចជាសុនខនៅក្នុងទីដ៏សមគួរ ។ ឯបុណ្ណកោលិយបុត្រ ជាអ្នកសមាទានគោវត្ត អង្គុយនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សេនិយ-អចេលក៍នេះ ជាអ្នកសមាទានកុក្កុរវត្ត ជាអ្នកធ្វើនូវអំពើដ៏កម្រ បរិភោគនូវភោជនដាក់នៅលើផែនដី សេនិយអចេលក៍នោះបានធ្វើឲ្យពេញបរិបូណ៌ បានសមាទានកុក្កុរវត្តនោះ អស់កាលជាយូរអង្វែងមកហើយ ចុះសេនិយអចេលក៍នោះ មានគតិដូចម្តេច មានបរលោកដូចម្តេច ។ ព្រះអង្គត្រាស់ថា នែបុណ្ណៈណើយ ពាក្យនុ៎ះចូរលើកទុកចុះ អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ ។ បុណ្ណកោលិយបុត្រ ជាអ្នកសមាទានគោវត្ត បានក្រាបទូលព្រះមានព្រះភាគ

ជាគម្រប់ពីរដងថា បពិត្រព្រះអង្គដ៏ចម្រើន សេនិយអចេលក៍នេះ ជាអ្នកសមាទានកុក្កុរវត្ត ជាអ្នកធ្វើនូវអំពើដ៏កម្រ បរិភោគនូវភោជនដាក់នៅលើផែនដី សេនិយអចេលក៍នោះបានធ្វើឲ្យពេញបរិបូណ៌ បានសមាទានកុក្កុរវត្តនោះអស់កាលជាយូរអង្វែងមកហើយ សេនិយអចេលក៍នោះមានគតិដូចម្ដេច មានបរលោកដូចម្ដេច ។ នែបុណ្ណៈ ណ្ហើយ ពាក្យនុ៎ះចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ ។ បុណ្ណកោលិយបុត្រជាអ្នកសមាទានគោវត្ត ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ជាគម្រប់បីដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន សេនិយអចេលក៍នេះ ជាអ្នកសមាទានកុក្កុរវត្ត ជាអ្នកធ្វើនូវអំពើដ៏កម្រ បរិភោគភោជនដាក់នៅលើផែនដី សេនិយអចេលក៍នោះបានធ្វើឲ្យពេញបរិបូណ៌ បានសមាទានកុក្កុរវត្តនោះ អស់កាលជាយូរអង្វែងមកហើយ សេនិយអចេលក៍នោះ មានគតិដូចម្ដេច មានបរលោកដូចម្ដេច ។

[ ៨៥ ] នែបុណ្ណៈ តាមពិត តថាគតមិនចង់ប្រាប់អ្នកទេ ( បានជាពោលឃាត់ ) ថា ម្នាលបុណ្ណៈ ណ្ហើយ ពាក្យនុ៎ះចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ តែថា ណ្ហើយចុះ តថាគតនឹងប្រាប់ដល់អ្នក ម្នាលបុណ្ណៈ បុគ្គលពួកមួយក្នុងលោកនេះ ចម្រើនកុក្កុរវត្តឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរសីលឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរចិត្តឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរាកប្បៈឲ្យបរិបូណ៌ ឥតមានចន្លោះ បុគ្គលនោះលុះបានចម្រើនកុក្កុរវត្តឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរសីល ឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនកុក្កុរចិត្តឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើន

កុក្កុរកប្បៈឲ្យបរិបូណ៌ ឥតមានចន្លោះ ហើយដល់ទម្លាយរាងកាយបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងសុនខទាំងឡាយ ប្រសិនបើសេនិយអចេលក៍នោះ មានទិដ្ឋិយ៉ាងនេះថា អាត្មាអញគង់បានជាទេវតាធំ ឬជាទេវតាណាមួយ ដោយសីលនេះផង ដោយវត្តនេះផង ដោយតបៈនេះផង ដោយព្រហ្មចរិយៈនេះផងពុំខាន ទិដ្ឋិរបស់សេនិយអចេលក៍នោះ ឈ្មោះថា មិច្ឆាទិដ្ឋិ នែបុណ្ណៈ តថាគតពោលថា បណ្តាគតិទាំងឡាយពីរ គតិណាមួយ គឺនរក ឬ កំណើតនៃតិរច្ឆាន ជារបស់បុគ្គលដែលមានចិត្តតាំងនៅក្នុងមិច្ឆាទិដ្ឋិពិត នែបុណ្ណៈ កុក្កុរវត្តដែលបុគ្គលបានធ្វើឲ្យពេញ បើមិនកើតក្នុងនរក ក៏គង់ទៅកើតជាមួយនឹងសុនខទាំងឡាយ ពុំលែងឡើយ ។ កាលដែលព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលយ៉ាងនេះហើយ សេនិយអចេលក៍អ្នកសមាទានកុក្កុរវត្ត ក៏ទ្រហោយំ សម្រក់ទឹកភ្នែក ។

[ ៨៦ ] លំដាប់នោះ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលនឹងបុណ្ណ-កោលិយបុត្រអ្នកសមាទានគោវត្ត យ៉ាងនេះថា នែបុណ្ណៈ តថាគតមិនបានចង់និយាយហេតុនុ៎ះ ដល់អ្នកសោះ ( បានជាពោលឃាត់ ) ថា នែបុណ្ណៈ ណ្ហើយ ពាក្យនុ៎ះចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនយំចំពោះព្យាករ ដែលព្រះមានព្រះភាគសម្តែងដល់ខ្ញុំព្រះអង្គយ៉ាងនេះទេ បពិត្រព្រះអង្គដ៏ចម្រើន បានជាខ្ញុំព្រះអង្គយំ ព្រោះខ្ញុំព្រះអង្គបានបំពេញ សមាទានកុក្កុរវត្តនេះ អស់កាលជាយូរអង្វែងមកហើយ បពិត្រព្រះអង្គដ៏ចម្រើន ចុះបុណ្ណកោលិយបុត្រជាអ្នកសមាទានគោវត្ត

នេះ គេបានបំពេញ សមាទានគោវត្តនោះ អស់កាលជាយូរអង្វែងមកហើយដែរ គេមានគតិដូចម្តេច មានបរលោកដូចម្តេច ។ នែសេនិយៈ ណ្ហើយពាក្យនុ៎ះចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ ។ សេនិយអចេលក៍បានក្រាបទូល ជាគម្រប់ពីរដងផង ។បេ។ សេនិយអចេលក៍ អ្នកសមាទានកុក្កុរវត្ត ក៏ក្រាបទូលព្រះមានព្រះភាគ គម្រប់ ៣ ដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បុណ្ណកោលិយបុត្រនេះ ជាអ្នកសមាទានគោវត្ត គេបានបំពេញបានសមាទានគោវត្តនោះ អស់កាលជាយូរអង្វែងមកហើយ គេមានគតិដូចម្តេច មានបរលោកដូចម្តេច ។ ម្នាលសេនិយៈ តថាគតមិនចង់ប្រាប់ដល់អ្នកសោះ ( បានជាពោលឃាត់ ) ថា នែសេនិយៈ ណ្ហើយ ពាក្យនុ៎ះ ចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ តែថា ណ្ហើយចុះ តថាគតនឹងប្រាប់ដល់អ្នក ម្នាលសេនិយៈ បុគ្គលមួយពួកក្នុងលោកនេះ ចម្រើនគោវត្តឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនគោសីលឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនគោចិត្តឲ្យបរិបូណ៌ ឥតមានចន្លោះ ចម្រើនគវាកប្បៈឲ្យបរិបូណ៌ ឥតមានចន្លោះ បុគ្គលនោះ លុះបានចម្រើនគោវត្តឲ្យបរិបូណ៌ ឥតមានចន្លោះ បានចម្រើនគោសីលឲ្យបរិបូណ៌ ឥតមានចន្លោះ បានចម្រើនគោចិត្តឲ្យបរិបូណ៌ ឥតមានចន្លោះ បានចម្រើនគវាកប្បៈឲ្យបរិបូណ៌ ឥតមានចន្លោះហើយ ដល់ទម្លាយរាងកាយបន្ទាប់អំពីមរណៈ ក៏បានទៅកើតជាមួយនឹងគោទាំងឡាយ ប្រសិនបើបុណ្ណកោលិយបុត្រនោះ មានទិដ្ឋិយ៉ាងនេះថា អាត្មាអញគង់នឹងបានជាទេវតាធំ ឬ ជាទេវតាណាមួយ ដោយសីលនេះផង ដោយ

វត្តនេះផង ដោយតបៈនេះផង ដោយព្រហ្មចរិយៈនេះផងមិនខាន ទិដ្ឋិរបស់បុណ្ណកោលិយបុត្រនោះ ឈ្មោះថាមិច្ឆាទិដ្ឋិ ម្នាលសេនិយៈ តថាគតពោលថា បណ្តាគតិទាំងពីរ គតិណាមួយ គឺនរក ឬថា កំណើតនៃតិរច្ឆានជារបស់បុគ្គលដែលមានចិត្តតាំងនៅក្នុងមិច្ឆាទិដ្ឋិពិត ម្នាលសេនិយៈ គោវត្តដែលបុគ្គលបានបំពេញឲ្យបរិបូណ៌យ៉ាងនេះហើយ បើមិនកើតក្នុងនរក ក៏គង់ទៅកើតជាមួយនឹងគោទាំងឡាយមិនខានឡើយ ។ កាលបើព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលយ៉ាងនេះហើយ បុណ្ណកោលិយបុត្រ ជាអ្នកសមាទានគោវត្តក៏ទ្រហោយំ សម្រក់ទឹកភ្នែក ។

[ ៨៧ ] លំដាប់នោះ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលនឹងសេនិយ-អចេលអ្នកសមាទានកុក្កុរវត្ត យ៉ាងនេះថា ម្នាលសេនិយៈ តថាគតមិនបាន ( ចង់ប្រាប់ ) នូវហេតុនុ៎ះ ដល់អ្នកសោះ ( បានជាពោលឃាត់ ) ថា នែសេនិយៈ ណ្ហើយពាក្យនុ៎ះចូរលើកទុក អ្នកកុំសួរពាក្យនុ៎ះនឹងតថាគតឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនយំចំពោះព្យាករ ដែលព្រះមានព្រះភាគសម្តែងដល់ខ្ញុំព្រះអង្គយ៉ាងនេះទេ បពិត្រព្រះអង្គដ៏ចម្រើន បានជាខ្ញុំព្រះអង្គយំ ព្រោះខ្ញុំព្រះអង្គបានបំពេញ បានសមាទានគោវត្តនេះ អស់កាលយូរអង្វែងមកហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីជ្រះថ្លា ក្នុងព្រះមានព្រះភាគយ៉ាងនេះ សូមព្រះមានព្រះភាគសម្តែងធម៌ដែលគួរឲ្យខ្ញុំព្រះអង្គលះបង់គោវត្តនេះ និងសេនិយអចេលក៏ជាអ្នកសមាទានកុក្កុរវត្តនេះ ឲ្យលះបង់កុក្កុរវត្តនោះចេញបាន ។ ម្នាលបុណ្ណៈ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើ

ទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងឥឡូវនេះ ។ បុណ្ណកោលិយបុត្រ អ្នកសមាទានគោវត្ត ក៏ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ។

[ ៨៨ ] ព្រះមានព្រះភាគទ្រង់សម្តែងថា ម្នាលបុណ្ណៈ កម្មទាំងឡាយ ៤ ប្រការនេះ តថាគតបានធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងដោយប្រាជ្ញាខ្លួនឯង កម្មទាំង ៤ ប្រការ តើដូចម្តេច ម្នាលបុណ្ណៈ កម្មខ្មៅ មានវិបាកខ្មៅ ១ ម្នាលបុណ្ណៈ កម្មស មានវិបាកស ១ ម្នាលបុណ្ណៈ កម្មខ្មៅ និងកម្មស មានវិបាកខ្មៅ និងស ១ ម្នាលបុណ្ណៈ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស តែងប្រព្រឹត្តទៅដើម្បីការអស់ទៅនៃកម្ម ១ ។ ម្នាលបុណ្ណៈ ឯកម្មខ្មៅ មានវិបាកខ្មៅនោះ ដូចម្តេច ម្នាលបុណ្ណៈ បុគ្គលពួកមួយ ក្នុងលោកនេះ តាក់តែងនូវកាយសង្ខារ ប្រកបដោយព្យាបាទ តាក់តែងនូវវចីសង្ខារ ប្រកបដោយព្យាបាទ តាក់តែងនូវមនោសង្ខារ ប្រកបដោយព្យាបាទ បុគ្គលនោះលុះបាន តាក់តែងនូវកាយសង្ខារ ប្រកបដោយព្យាបាទ តាក់តែងនូវវចីសង្ខារប្រកប ដោយព្យាបាទ តាក់តែងនូវមនោសង្ខារ ប្រកបដោយព្យាបាទហើយ ក៏ទៅ កើតក្នុងលោកដែលប្រកបដោយព្យាបាទ ផស្សៈទាំងឡាយ ប្រកបដោយ ព្យាបាទ តែងពាល់ត្រូវបុគ្គលដែលទៅកើតក្នុងលោក ប្រកបដោយព្យាបាទ នោះឯង បុគ្គលនោះ កាលដែលផស្សៈទាំងឡាយ ប្រកបដោយព្យាបាទ ពាល់ត្រូវហើយ រមែងទទួលនូវវេទនា ប្រកបដោយព្យាបាទ ជាទុក្ខតែមួយ យ៉ាង ដូចសត្វទាំងឡាយដែលកើតក្នុងនរក ម្នាលបុណ្ណៈ កំណើតនៃសត្វ

រមែងកើតអំពីភូតកម្មដូច្នេះឯង បុគ្គលធ្វើកម្មណា តែងទៅកើតដោយអំណាចនៃកម្មនោះ ផស្សៈទាំងឡាយ តែងពាល់ត្រូវបុគ្គលដែលកើតឡើងហើយនោះ ម្នាលបុណ្ណៈ យ៉ាងនេះឯង បានជាតថាគតពោលថា សត្វទាំងឡាយមានកម្មជាមត៌ក ម្នាលបុណ្ណៈ នេះហៅថា កម្មខ្មៅ មានវិបាកខ្មៅ ។ ម្នាលបុណ្ណៈ កម្មស មានវិបាកស តើដូចម្តេច ម្នាលបុណ្ណៈ បុគ្គលពួកមួយ ក្នុងលោកនេះ តាក់តែងនូវកាយសង្ខារ មិនប្រកបដោយព្យាបាទ តាក់តែងនូវវចីសង្ខារ មិនប្រកបដោយព្យាបាទ តាក់តែងនូវមនោសង្ខារ មិនប្រកបដោយព្យាបាទ បុគ្គលនោះ លុះបានតាក់តែងនូវកាយសង្ខារ មិនប្រកបដោយព្យាបាទ តាក់តែងនូវវចីសង្ខារ មិនប្រកបដោយព្យាបាទ តាក់តែងនូវមនោ-សង្ខារ មិនប្រកបដោយព្យាបាទហើយ ក៏តែងទៅកើតក្នុងលោក មិនមានព្យាបាទឡើយ ផស្សៈទាំងឡាយ មិនមានព្យាបាទ តែងពាល់ត្រូវបុគ្គលដែលចូលទៅកើតក្នុងលោកមិនមានព្យាបាទនោះឯង បុគ្គលនោះ កាលដែលផស្សៈទាំងឡាយ មិនមានព្យាបាទ ពាល់ត្រូវហើយ រមែងទទួលនូវវេទនា ដែលមិនប្រកបដោយព្យាបាទ មានតែសេចក្តីសុខមួយយ៉ាង ដូចទេវតាទាំងឡាយនៅក្នុងឋានឈ្មោះសុភកិណ្ហៈ ម្នាលបុណ្ណៈ កំណើតនៃសត្វ រមែងកើតអំពីភូតកម្មដូច្នេះឯង បុគ្គលធ្វើកម្មណា តែងទៅកើតដោយអំណាចកម្មនោះ ផស្សៈទាំងឡាយតែងពាល់ត្រូវបុគ្គលដែលកើតឡើងហើយនោះ ម្នាលបុណ្ណៈ យ៉ាងនេះឯង បានជាតថាគតពោលថា សត្វទាំងឡាយមានកម្មជាមត៌ក ម្នាលបុណ្ណៈ នេះហៅថាកម្មស មានវិបាកស ។ ម្នាលបុណ្ណៈ កម្មខ្មៅ និងកម្មស មានវិបាក

ខ្មៅ និងស តើដូចម្តេច ម្នាលបុណ្ណៈ បុគ្គលពួកមួយក្នុងលោកនេះ តាក់តែង នូវកាយសង្ខារ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ តាក់តែងនូវវចីសង្ខារ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ តាក់តែងនូវមនោសង្ខារ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ បុគ្គលនោះ លុះបានតាក់តែងនូវកាយសង្ខារ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ បានតាក់តែងនូវវចីសង្ខារ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ បានតាក់តែងនូវមនោសង្ខារ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះហើយ តែងទៅកើតក្នុងលោក ដែលប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ ផស្សៈទាំងឡាយ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ តែងពាល់ត្រូវបុគ្គល ដែលទៅកើតក្នុងលោក ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះនោះឯង បុគ្គលនោះ កាលដែលផស្សៈទាំងឡាយ ប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ ពាល់ត្រូវហើយ រមែងទទួលនូវវេទនា ដែលប្រកបដោយព្យាបាទខ្លះ មិនប្រកបដោយព្យាបាទខ្លះ មានសុខ និងទុក្ខប្រឡូកប្រឡំគ្នា ដូចជាមនុស្សទាំងឡាយខ្លះ ទេវតាទាំងឡាយពួកខ្លះ វិនិបាតិកៈទាំង-ឡាយពួកខ្លះ ម្នាលបុណ្ណៈ កំណើតនៃសត្វ រមែងកើតអំពីភូតកម្មដូច្នេះឯង បុគ្គលធ្វើកម្មណា តែងទៅកើតដោយអំណាចកម្មនោះ ផស្សៈទាំងឡាយ តែងពាល់ត្រូវបុគ្គលដែលកើតឡើងហើយនោះឯង ម្នាលបុណ្ណៈ យ៉ាងនេះឯង បានជាតថាគតពោលថា សត្វទាំងឡាយមានកម្មជាមត៌ក ម្នាលបុណ្ណៈ នេះ

ហៅថា កម្មខ្មៅ និងកម្មស មានវិបាកខ្មៅ និងស ។ ម្នាលបុណ្ណៈ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស រមែងប្រព្រឹត្តទៅដើម្បីអស់កម្ម តើដូចម្តេច ម្នាលបុណ្ណៈ មគ្គចេតនាដែលសម្រាប់លះបង់កម្មខ្មៅមានផលខ្មៅ មគ្គចេតនាដែលសម្រាប់លះបង់កម្មសមានផលស មគ្គចេតនាដែលសម្រាប់លះបង់កម្មខ្មៅ និងស មានវិបាកខ្មៅ និងស ម្នាលបុណ្ណៈ បណ្តាកម្មទាំង ៣ យ៉ាងនោះ កម្មនេះ ហៅថា កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់ទៅនៃកម្ម ។ ម្នាលបុណ្ណៈ កម្ម ទាំងឡាយ ៤ នេះឯង ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងដោយបញ្ញាខ្លួនឯង ។

[ ៨៩ ] កាលដែលព្រះមានព្រះភាគ ទ្រង់មានព្រះវាចាយ៉ាងនេះហើយ ទើបបុណ្ណកោលិយបុត្រ ជាអ្នកសមាទាននូវគោវត្ត ក៏ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើនប្រកាសហើយ ដោយអនេកបរិយាយ យ៉ាងនេះឯង ( ភ្លឺច្បាស់ណាស់ ) ដូចជាបុគ្គលផ្ងាររបស់ដែលផ្កាប់ ឬក៏ដូចជាបុគ្គលបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចគេទ្រោលប្រទីបក្នុងទីងងឹត ឲ្យមនុស្សដែលមានភ្នែកភ្លឺ មើលឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះមានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះមានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមតាំងអំពី

ថ្ងៃនេះទៅ ។ ឯសេនិយអចេលក៍ ជាអ្នកសមាទានកុក្កុរវត្ត ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះ អង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ ចម្រើនទ្រង់ប្រកាស ដោយអនេកបរិយាយនេះឯង ( ភ្លឺច្បាស់ណាស់ ) ដូចជាបុគ្គលផ្ងាររបស់ដែលផ្កាប់ ឬ ដូចជាបុគ្គលបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចគេទ្រោលប្រទីប ក្នុងទីងងឹត ឲ្យមនុស្សមានភ្នែកភ្លឺ មើលឃើញនូវរូបទាំងឡាយបាន បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ជាទីពឹងទីរឭក ខ្ញុំព្រះអង្គគប្បីបាននូវបព្វជ្ជា និងឧបសម្បទា ក្នុងសម្នាក់នៃព្រះមានព្រះភាគ ។ ម្នាលសេនិយៈ បុគ្គលណាមួយធ្លាប់ជា អន្យតិរ្ថិយ ហើយប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទា ក្នុងធម្មវិន័យនេះ បុគ្គល នោះ លុះតែនៅបរិវាសអស់ ៤ ខែ លុះកាលកន្លងទៅអស់ ៤ ខែហើយ ទើបភិក្ខុទាំងឡាយដែលមានចិត្តខ្ជះខ្ជែង ក៏ឲ្យបព្វជ្ជា និងឧបសម្បទាជាភិក្ខុ-ភាវៈបាន មួយវិញទៀត ការផ្សេងនៃបុគ្គលក្នុងទីនេះ តថាគតបានដឹង ច្បាស់ហើយ ។

[ ៩០ ] បពិត្រព្រះអង្គដ៏ចម្រើន បើបុគ្គលទាំងឡាយ ធ្លាប់ជាអន្យ-តិរ្ថិយ ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទា ក្នុងធម្មវិន័យនេះហើយនៅបរិវាស អស់ ៤ ខែ លុះកាលកន្លងទៅអស់ ៤ ខែហើយ ភិក្ខុទាំងឡាយដែលមាន ចិត្តខ្ជះខ្ជែងក៏ឲ្យបព្វជ្ជា ឲ្យឧបសម្បទាជាភិក្ខុភាវៈបាន ខ្ញុំព្រះអង្គនឹងនៅបរិវាស

អស់ ៤ វស្សាក៏បាន លុះកាលកន្លងទៅអស់ ៤ វស្សាហើយ ភិក្ខុទាំងឡាយ ដែលមានចិត្តខ្ជាប់ខ្ជួន ក៏ឲ្យបព្វជ្ជា និងឧបសម្បទាជាភិក្ខុភាវៈ ។ ឯសេនិយ-អចេលក៏អ្នកសមាទាននូវកុក្កុរវត្ត ក៏បាននូវបព្វជ្ជា និងឧបសម្បទាក្នុងសម្នាក់ព្រះមានព្រះភាគ ។ លុះសេនិយភិក្ខុមានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង ជាបុគ្គលមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្រទាំង-ឡាយ ចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយត្រឹមត្រូវ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មានក៏បានត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ដែលមានព្រហ្មចរិយៈជាទីបំផុតដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ ដឹងច្បាស់ថា ជាតិរបស់អញអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ កិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះ មិនមានឡើយ ។ បណ្តាពួកព្រះអរហន្ត សេនិយភិក្ខុមានអាយុ បានជាព្រះអរហន្តមួយអង្គដែរ ។

កុក្កុរោវាទសូត្រទី ៧ ចប់

# អដ្ឋកថា

## កុក្កុរោវាទសូត្រទី ៧

[ ៨៤ ] កុក្កុរវតិកសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបណ្តាបទទាំងនោះ បទថា **កោលិយេសុ** គឺជនបទមានឈ្មោះយ៉ាងនេះ ។ កោលិយៈនោះជាជនបទមួយ ដែលហៅយ៉ាងនេះ ក៏ព្រោះថា ជាទឹកដីនៃព្រះរាជកុមារខាងកោលិយវង្ស ដែលតាំងនៅក្នុងកោលិយនគរ ។ ក្នុងជនបទឈ្មោះកោលិយៈនោះ ។ បទថា **ហលិទ្ទវសនំ** សេចក្តីថា មនុស្សទាំងឡាយស្លៀកដណ្តប់សំពត់ពណ៌លឿងលេងនក្ខត្តឫក្ស ក្នុងគ្រាសាងនិគមនោះ លុះចប់ការលេងនក្ខត្តឫក្សហើយ ពួកគេក៏លើកឈ្មោះនិគម ដោយដាក់ឈ្មោះថា **ហលិទ្ទវសន** អធិប្បាយថា ព្រះមានព្រះភាគ ទ្រង់ធ្វើហលិទ្ទវសននិគមនោះឲ្យជាគោចរគ្រាម ប្រថាប់នៅ ។ ឯទីនៅក្នុងហលិទ្ទវសននិគមនោះ មិនទាន់បានកំណត់ក៏ពិត សូម្បីយ៉ាងនោះក៏គប្បីជ្រាបថា ព្រះមានព្រះភាគប្រថាប់នៅក្នុងសេនាសនៈ ដែលសមគួរដល់ព្រះពុទ្ធទាំងឡាយ ។ បទថា **គោវត្តិកោ** សេចក្តីថា បុគ្គលសមាទានគោវត្ត ប្រព្រឹត្តដូចគោ គឺដាក់ស្នែងទាំង ២ លើក្បាល ចងកន្ទុយ ដើរស៊ីស្មៅដូចគោ ។ បទថា **អចេលោ** ប្រែថា អាក្រាត គឺមិនមានសំពត់ ។ បទថា **សេនិយោ** ជាឈ្មោះរបស់គាត់ ។ បទថា **កុក្កុរវត្តិកោ** សេចក្តីថា ជាអ្នកសមាទានកុក្កុរវត្ត ប្រព្រឹត្តដូចឆ្កែ ធ្វើកិរិយានៃឆ្កែគ្រប់យ៉ាង ។ បុណ្ណៈ និងសេនិយៈទាំង ២ នោះ ជាសម្លាញ់លេងធូលីជាមួយគ្នាមក ។ បទថា **កុក្កុរោវ បលិកុណ្ឋិត្វា** សេចក្តី

ថា ដែលឈ្មោះថា ក្អែ កាលអង្គុយជិតម្ចាស់ យកជើងទាំង ២ កាយដី អង្គុយព្រួសសំឡេងក្អែ សេនិយៈគិតថា សូម្បីអញនឹងធ្វើដូចកិរិយានៃក្អែ កាលពោលប្រាស្រ័យទាក់ទងជាមួយព្រះមានព្រះភាគ ក៏យកជើងទាំង ២ កាយដី រលាស់ក្បាល ធ្វើសំឡេង កុ កូ អង្គុយបត់ដៃ និងជើងដូចក្អែ ។ បទថា **ឆមាយំ និក្ខិត្តំ** ប្រែថា ដែលគេដាក់ត្រង់ផែនដី ។ បទថា **សមត្តំ សមាទិន្នំ** ប្រែថា ដែលធ្វើយ៉ាងបរិបូណ៌ ។ បទថា **កា គតិ** គឺផល សម្រេចដូចម្ដេច ។ បទថា **កោ អភិសម្បរាយោ** សំដៅដល់ កពខាងមុខ គឺកើតក្នុងទីណា ។ បទថា **អលំ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់ហាម ៣ ដង ដោយទ្រង់ត្រិះរិះថា វត្ថុដែលមិនជាទីស្រឡាញ់ នឹងមានដល់គេ ។ បទថា **កុក្កុរវត្តំ** គឺកាន់យកអាកប្បកិរិយារបស់ក្អែ ។

[ ៨៥ ] បទថា **ភាវេតិ** ប្រែថា ធ្វើឲ្យចម្រើន ។ បទថា **បរិបុណ្ណំ** គឺមិនខ្វះ ។ បទថា **អព្វោកិណ្ណំ** គឺឥតមានចន្លោះ ។ បទថា **កុក្កុរសីលំ** គឺការប្រព្រឹត្តរបស់ក្អែ ។ បទថា **កុក្កុរចិត្តំ** គឺកើតការគិតយ៉ាងនេះថា តាំងអំពីថ្ងៃនេះ អញនឹងធ្វើការដែលក្អែទាំងឡាយគប្បីធ្វើ ។ បទថា **កុក្កុរាកប្បំ** សេចក្ដីថា អាការដើរ អាការឈរ អាការអង្គុយ អាការដេក អាការបន្ទោបង់ឧច្ចារបស្សាវៈរបស់ក្អែទាំងឡាយ អាការដែលឃើញក្អែទាំងឡាយដទៃហើយ ញេញធ្មេញដើរទៅរបស់ក្អែទាំងឡាយមាន អាការនេះ ឈ្មោះថា អាការរបស់ក្អែ ។ គាត់ធ្វើអាការរបស់ក្អែនោះឲ្យប្រាកដ ។

[ ៨៦-៨៧ ] ក្នុងបទថា **ឥមិនាហំ សីលេន** ជាដើម សេចក្ដីថា ខ្ញុំ

ព្រះអង្គនឹងបានជាទេវតា ឬទេវតាអង្គណាមួយ ដោយការប្រព្រឹត្ត ដោយការសមាទានវត្ត ដោយការប្រព្រឹត្តតបៈ ដែលធ្វើបានលំបាក ឬដោយព្រហ្មចរិយៈ គឺការវៀរមេថុននេះ ។ បទថា **ទេវោ** គឺបណ្តាទេវតាទាំងឡាយមានសក្កទេវរាជ ស្តេចសុយាមជាដើម អង្គណាមួយ ។ បទថា **ទេវញ្ញតរោ** គឺបណ្តាទេវតាទាំងនោះ ជាទេវតាអង្គណាមួយ ក្នុងឋានៈទី ២ ទី ៣ ជាដើម ។ បទថា **មិច្ឆាទិដ្ឋិ** សេចក្តីថា ការឃើញនោះរបស់គាត់ ឈ្មោះថា មិច្ឆាទិដ្ឋិ ព្រោះការប្រកាន់ផ្លូវដែលមិនមែនជាផ្លូវទៅកាន់ទេវលោក ថាជាផ្លូវទៅកាន់ទេវលោក ។ បទថា **អញ្ញតរំ គតឹ វទាមិ** សេចក្តីថា គតិរបស់គាត់ដទៃទៅអំពីនរក ឬកំណើតសត្វតិរច្ឆានមិនមាន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។ បទថា **សម្បជ្ជមានំ** គឺកុក្កុរវត្តដែលគាត់បដិបត្តិមិនលាយដោយទិដ្ឋិ ។ បទថា **នាហំ ភន្តេ ឯតំ រោទាមិ យំ មំ ភគវា ឯវមាហ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគត្រាស់ព្យាករឯណាទីងខ្ញុំយ៉ាងនេះ ខ្ញុំមិនបានទ្រហោយំ មិនបានសោយសោក មិនបានញាប់ញ័រដល់ពាក្យព្យាករនោះរបស់ព្រះមានព្រះភាគទេ ។ បណ្ឌិតគប្បីជ្រាបសេចក្តីនោះ ដោយអំណាចកម្មរបស់ខ្លួនឯងដោយប្រការដូច្នេះ មិនគប្បីជ្រាបដោយអាការត្រឹមតែទឹកភ្នែកហូរ ។ ក្នុងសេចក្តីនោះ មានការប្រកបសេចក្តីដូច្នេះថា

**មតំ វា អម្ម រោទន្តិ យោ វា ជីវំ ន ទិស្សតិ**
**ជីវន្តំ អម្ម បស្សន្តី កស្មា មំ អម្ម រោទសិ ។**

សានុសាមណេរក្រោក់ឡើង និយាយថា ញោមពួកជនតែងយំរកបុគ្គល ដែលស្លាប់បាត់ទៅហើយ ឬបុគ្គលដែលរស់នៅ តែគេមិនឃើញញោម ញោមឃើញអាត្មា នៅរស់នៅឡើយ ញោមហេតុអ្វី ក៏ញោមយំរកអាត្មា ។

បទថា **អបិច មេ ឥទំ ភន្តេ** សេចក្តីថា នាយសេនិយៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ម្យ៉ាងទៀត កុក្កុរវត្តនេះ ខ្ញុំព្រះអង្គសមាទានអស់ កាលដ៏យូរមកហើយ សូម្បីកាលបដិបត្តិកុក្កុរវត្តនោះ ក៏មិនមានការចម្រើន កាលបដិបត្តិខុសក៏មិនមានការវិនាស កម្មដែលខ្ញុំព្រះអង្គធ្វើមក អស់កាល មានប្រមាណប៉ុណ្ណោះ ក៏កើតជាមោឃៈ ព្រោះដូច្នោះ ខ្ញុំព្រះអង្គកាលពិចា-រណាឃើញវិបត្តិរបស់ខ្លួនឯង ទើបទ្រហោយំ ។ បទថា **គោវត្តំ** ជាដើម ក៏គប្បីជ្រាបតាមន័យដែលពោលមកហើយ ក្នុងកុក្កុរវត្តជាដើមនោះឯង ។ បទ ថា **គវាកប្បំ** កាត់បទជា **គោអាកប្បំ** ប្រែថា កិរិយារបស់គោ ។ ពាក្យដ៏សេសដូចគ្នានឹងពាក្យដែលពោលមកហើយ ក្នុងអាការរបស់ឆ្កែនោះ ឯង ឃើញពួកឆ្កែដទៃៗ ហើយញេញធ្មេញដើរទៅ ក្នុងកុក្កុរវត្តនោះ យ៉ាង ណា ក៏គប្បីជ្រាបអាការដែលគោឃើញគោដទៃៗ ហើយ ក៏លើកត្រចៀកទាំង ២ ដើរទៅ ក្នុងគោវត្តនេះក៏ដូច្នោះ ។ ពាក្យក្រៅអំពីនោះ ដូចគ្នានោះឯង ។

[ ៨៨-៨៩ ] បទថា **ចត្តារិមានិ បុណ្ណ កម្មានិ** សេចក្តីថា ហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ប្រារព្ធធម្មទេសនានេះ ។ ព្រោះទេសនានេះ មក ដោយអំណាចការធ្វើកម្មខ្លះ កាលព្រះមានព្រះភាគត្រាស់កម្ម ៤ ពួកនេះ ហើយ កម្មរបស់បុគ្គលទាំងនេះនឹងប្រាកដ ព្រោះដូច្នោះ ទើបព្រះមានព្រះ

ភាគ ទ្រង់ប្រារព្ធទេសនានេះ ។ មយ៉ាងទៀត ព្រះមានព្រះភាគទ្រង់ជ្រាបថា អ្នកទាំង ២ នេះ នឹងយល់កម្ម ៤ ពួក ដែលទ្រង់កំពុងសម្តែងនេះប៉ុណ្ណោះ បុគ្គលម្នាក់នឹងដល់សរណៈ ម្នាក់ទៀត នឹងបួសសម្រេចអរហត្ត ដូច្នោះ ទេសនានេះប៉ុណ្ណោះ ជាសប្បាយរបស់ជនទាំងនោះ ទើបទ្រង់ប្រារព្ធទេសនា នេះ ។ បណ្តាបទទាំងនោះ បទថា **កណ្ហំ** ប្រែថា ខ្មៅ បានដល់ អកុសលកម្មបថ ១០ ។ បទថា **កណ្ហវិបាកំ** គឺមានវិបាកខ្មៅ ព្រោះធ្វើឲ្យកើតក្នុងអបាយ ។ បទថា **សុក្កំ** ប្រែថា ស បានដល់ កុសលកម្មបថ ១០ ។ បទថា **សុក្កវិបាកំ** គឺមានវិបាកស ព្រោះធ្វើឲ្យកើតក្នុងស្ថានសួគ៌ ។ បទថា **កណ្ហសុក្កំ** គឺកម្មលាយគ្នា ។ បទថា **កណ្ហសុក្កវិបាកំ** គឺមានសុខ និងទុក្ខជាវិបាក ។ ពិតហើយ បុគ្គលធ្វើកម្មលាយគ្នាហើយ កើតក្នុងកំណើតតិរច្ឆានក្នុងតំណែងដំរីមង្គលជាដើម ដោយអកុសលកម្ម តែសោយសុខក្នុងបវត្តិកាល ដោយកុសលកម្ម ។ សូម្បីបុគ្គលនោះ កើតក្នុងរាជត្រកូលដោយកុសលកម្ម ក៏សោយទុក្ខក្នុងបវត្តិកាលដោយអកុសលកម្ម ។ កម្ម គឺចេតនាក្នុងមគ្គ ៤ ដែលធ្វើឲ្យអស់កម្ម ទ្រង់បំណងយកថា កម្មមិនខ្មៅមិនស ។ ឧបមាថា កម្មនោះ ត្រឹមតែជាកម្ម ខ្មៅសោត ក៏គប្បីឲ្យវិបាកខ្មៅ ឧបមាថាជាកម្មសសោត ក៏គប្បីឲ្យវិបាកស ឯចេតនាកម្មក្នុងមគ្គ ៤ ត្រាស់ថា មិនខ្មៅ មិនស ក៏ព្រោះវិបាកមិនខ្មៅ មិនស ព្រោះមិនឲ្យវិបាកទាំង ២ ។ សេចក្តីក្នុងឧទ្ទេសមានប្រមាណប៉ុណ្ណោះ ឯក្នុងនិទ្ទេសគប្បីជ្រាបដូចតទៅនេះថា ។ បទថា **សព្យាបជ្ឈំ** ប្រែថា មានទុក្ខ ។ ក្នុងកាយសង្ខារជាដើម

អកុសលចេតនា ១២ ដែលដល់នូវការកម្រើក ដោយអំណាចការចាប់កាន់ ជាដើម ក្នុងកាយទ្វារ ឈ្មោះថា កាយសង្ខារជាទុក្ខ ។ អកុសលចេតនា ១២ នោះឯង ដែលធ្វើឲ្យការបន្លឺវាចាប្រព្រឹត្តទៅ ដោយការកម្រើកចង្កា ក្នុង វចីទ្វារ ឈ្មោះថា វចីសង្ខារ ។ អកុសលចេតនាដែលមិនដល់នូវការកម្រើក ទាំង ២ ប្រព្រឹត្តទៅក្នុងមនោទ្វារសម្រាប់បុគ្គលដែលកំពុងគិត ឈ្មោះថា មនោសង្ខារ ។ ដូច្នោះ អកុសលចេតនាប៉ុណ្ណោះ មានកាយទុច្ចរិតជាដើម ក្នុងទ្វារទាំងបី គប្បីជ្រាបថា សង្ខារ ។

ពិតហើយ ក្នុងព្រះសូត្រនេះ ចេតនា ឈ្មោះថា ធុរៈ ។ ក្នុងឧបាលិ-វាទសូត្រ ចេតនា ឈ្មោះថា កម្ម ។ បទថា **អភិសង្ខរិត្វា** គឺទាញមក ។ អធិប្បាយថា ប្រមូលមក ។ បទថា **សព្យាបជ្ឈំ លោកំ** គឺចូលដល់លោក ដែលមានទុក្ខ ។ បទថា **សព្យាបជ្ឈា ផស្សា ផុសន្តិ** គឺផស្សៈដែលមានទុក្ខ ជាវិបាក រមែងពាល់ត្រូវ ។ បទថា **ឯកន្តទុក្ខំ** បានដល់ ទុក្ខមិនមានចន្លោះ ។ បទថា **ភូតា** ជាបញ្ចមីវិភត្តិ ចុះក្នុងអត្ថថា ហេតុ ។ កាលចូលដល់ គឺបដិ-សន្ធិនៃសត្វដែលកើតហើយ រមែងមានព្រោះកម្មដែលមានហើយ ។ លោក អធិប្បាយថា សត្វទាំងឡាយរមែងធ្វើកម្មដែលមានហើយដូចម្តេច ការចូល ដល់នៃសត្វទាំងនោះ រមែងមានដោយអំណាចកម្មដែលមានចំណែកស្មើគ្នា នឹងកម្មដែលមានហើយដូចម្តេច ដោយហេតុនោះឯង ទើបព្រះមានព្រះភាគ ត្រាស់ថា សត្វធ្វើកម្មឯណា រមែងចូលដល់ព្រោះកម្មនោះ ។ បណ្តាបទ ទាំងនោះ បទថា **តេន** សេចក្តីថា សត្វទាំងឡាយ ព្រះអង្គត្រាស់ថា ហាក់

ដូចកើតព្រោះកម្ម តែឈ្មោះថា បដិសន្ធិ រមែងមានព្រោះវិបាក ក៏ព្រោះកម្មជាហេតុនៃវិបាក ដូច្នោះ សត្វរមែងកើតព្រោះកម្មដែលជាមូលនោះ ។ បទថា **ផស្សា ផុសន្តិ** សេចក្តីថា សត្វទាំងឡាយ កើតព្រោះផលនៃកម្មឯណា ផស្សៈរមែងពាល់ត្រូវផលនៃកម្មនោះ ។ បទថា **កម្មទាយាទា** គឺទាយាទរបស់កម្ម ។ តថាគតពោលកម្មនោះឯង ថាជាទាយាទ គឺជាមត៌កនៃសត្វទាំងនោះ ។

បទថា **អព្យាបជ្ឈំ** ប្រែថា មិនមានទុក្ខ ក្នុងវារៈនេះ ចេតនាខាងកាមាវចរកុសល ៨ ជាទីទៅក្នុងកាយទ្វារ ឈ្មោះថា កាយសង្ខារ ។ ចេតនាខាងកាមាវចរកុសល ៨ នោះឯង ដែលប្រព្រឹត្តទៅក្នុងវចីទ្វារ ឈ្មោះថា វចីសង្ខារ ។ ចេតនាខាងកាមាវចរកុសល ៨ ដែលប្រព្រឹត្តទៅក្នុងមនោទ្វារ និងចេតនាក្នុងឈានខាងក្រោម ៣ ឈ្មោះថា អព្យាបជ្ឈមនោសង្ខារ ។

សួរថា ចេតនាក្នុងឈាន ចូរលើកទុកសិនចុះ ហេតុអ្វី ទើបកាមាវចរឈ្មោះថា អព្យាបជ្ឈមនោសង្ខារដែរ ឆ្លើយថា អព្យាបជ្ឈមនោសង្ខាររមែងកើតបានក្នុងខណៈចូលកសិណ និងខណៈសេពកសិណរឿយៗ កាមាវចរចេតនាតជាមួយចេតនាបឋមជ្ឈាន ចេតនាក្នុងចតុត្ថជ្ឈាន តជាមួយចេតនាក្នុងតតិយជ្ឈាន ។ ដូច្នោះ កុសលចេតនា មានកាយទុច្ចរិតជាដើមប៉ុណ្ណោះ ក្នុងទ្វារទាំង ៣ គប្បីជ្រាបថា សង្ខារ ។ វារៈទី ៣ ក៏គប្បីជ្រាបដោយអំណាចដែលលាយឡំគ្នាទាំង ២ យ៉ាង ។ ក្នុងបទថា **សេយ្យថាបិ មនុស្សា** ជាដើម គប្បីជ្រាបថា សម្រាប់ពួកមនុស្ស ប្រាកដថា ជួនកាល

ក៏សុខ ជួនកាលក៏ទុក្ខ ឯក្នុងពួកទេវតាទាំងឡាយ ពួកភុម្មទេវតា ក្នុងពួកវិនិបាតិកសត្វទាំងឡាយ ពួកវេមានិកប្រេត ជួនកាលក៏សុខ ជួនកាលក៏ទុក្ខ ។ សុខរមែងកើតបាន សូម្បីក្នុងសត្វតិរច្ឆាន ដូចជាដំរីជាដើម ។ បទថា **តត្រ** ប្រែថា ក្នុងកម្មទាំង ៣ នោះ ។ បទថា **តស្ស បហានាយ យា ចេតនា** សេចក្ដីថា ចេតនាក្នុងមគ្គ ក៏ដើម្បីប្រយោជន៍ដល់ការលះកម្មនោះ ។ តែដល់កម្មហើយ ឈ្មោះថា កម្មដទៃដែលសជាងចេតនាក្នុងមគ្គមិនមាន ។ ឯអកុសលចេតនា ១០ ដល់កម្ម ៤ ពួកនេះហើយ ឈ្មោះថា ខ្មៅ ។ កុសលចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា ស ។ មគ្គចេតនាមកហើយថា មិនខ្មៅ មិនស ។ នាយសេនិយៈនោះគិតថា ខ្លួនអញហាក់ដូចជាផ្ទាស់ការគិតថា អញប្រកបខ្លួន ចំណែកធម៌ដែលមិននាំសត្វចេញចាកទុក្ខ មកអស់កាលយូរហើយហ្ន៎ ធ្វើខ្លួនឲ្យលំបាកទទេ និងដូតទឹកត្រង់ប្រាំងស្ងួតដែលស្ងួត និងដូចបុគ្គលបោះបង្គោលក្នុងអង្កាម មិនធ្វើប្រយោជន៍ណាមួយឲ្យសម្រេចឡើយ ណើយចុះ អញនឹងប្រកបខ្លួនក្នុងសេចក្ដីព្យាយាម ដូច្នេះហើយទើបពោលពាក្យនេះថា **លភេយ្យាហំ ភន្តេ** ។

កាលនោះ តិត្ថិយបរិវាសឯណា ព្រះមានព្រះភាគទ្រង់បញ្ញត្តហើយ ក្នុងខន្ធកវិន័យថា អ្នកធ្លាប់ជាតិត្ថិយ តាំងនៅក្នុងភូមិរបស់សាមណេរ ហើយសមាទានបរិវាស ដោយន័យថា បពិត្រលោកម្ចាស់ ខ្ញុំមានឈ្មោះនេះ ធ្លាប់ជាតិត្ថិយ បំណងនឹងឧបសម្បទាក្នុងធម្មវិន័យនេះ ខ្ញុំសូមនៅបរិវាស ៤ ខែនឹងសង្ឃ ។ ព្រះមានព្រះភាគទ្រង់សំដៅយកតិត្ថិយបរិវាសនោះ ទើបត្រាស់

ពាក្យជាដើមថា **យោ ខោ សេនិយ អញ្ញតិត្ថិយបុព្វោ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **បព្វជ្ជំ** ត្រាស់ដោយអំណាចកាលដែលទ្រង់មានព្រះវាចាទន់ផ្អែម ។ ពិតហើយ សេនិយៈនោះមិនទៅបរិវាសក៏បានបព្វជ្ជា ។ តែគាត់ត្រូវឧបសម្បទា បំពេញវត្ត ៨ ប្រការ មានការចូលស្រុកជាដើម គប្បីទៅបរិវាសលើសកាលកំណត់ ។ បទថា **អារទ្ធចិត្តា** គឺមានចិត្តត្រេកអរដោយការបំពេញវត្ត ៨ ប្រការ ។ នេះជាសេចក្តីសង្ខេបក្នុងរឿងតិត្ថិយបរិវាសនោះ ។ ឯសេចក្តីពិស្តាររបស់តិត្ថិយបរិវាសនោះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងបព្វជ្ជាខន្ធកកថា គម្ពីរអដ្ឋកថាវិន័យ ឈ្មោះសមន្តប្បាសាទិកាចុះ ។ បទថា **អបិច មេត្ថ** កាត់បទជា **អបិច មេ ឯត្ថ** ។ បទថា **បុគ្គលវេមត្តតា វិទិតា** គឺដឹងនូវភាពដែលបុគ្គលមានសភាពផ្សេងៗ គ្នា ។ ព្រះមានព្រះភាគទ្រង់សម្តែងថា ពាក្យនេះប្រាកដដល់តថាគតថា បុគ្គលនេះគួរទៅបរិវាស បុគ្គលនេះមិនគួរទៅបរិវាស ។ បន្ទាប់អំពីនោះ សេនិយៈគិតថា ឱ ! ព្រះពុទ្ធសាសនាគួរអស្ចារ្យពិត ដែលបុគ្គលធ្វើខុសយ៉ាងនេះហើយ ក៏ទាញយកទីដែលគួរ មិនគួរក៏បោះចោលទៅ ។

[ ៩០ ] បន្ទាប់អំពីនោះ គេក៏កើតឧស្សាហៈក្នុងបព្វជ្ជាថា ល្អជាង ទើបក្រាបទូលថា **សចេ ខោ ភន្តេ** ដូច្នេះ សេចក្តីនោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបភាពដែលគាត់មានឆន្ទៈខ្លាំងក្លា ទ្រង់ត្រិះរិះថា សេនិយៈមិនគួរទៅបរិវាស ទើបត្រាស់ហៅភិក្ខុមួយរូបមកថា ម្នាលភិក្ខុ អ្នកចូរទៅឲ្យសេនិយៈងូតទឹក ហើយបព្វជ្ជា សឹមនាំមក ។ ភិក្ខុក៏ធ្វើយ៉ាងនោះ ឲ្យសេនិយៈបព្វជ្ជា

ហើយ នាំមកកាន់សម្នាក់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគប្រថាប់គង់កណ្តាលគណៈសង្ឃ ឲ្យឧបសម្បទាហើយ ។ ដោយហេតុនោះ ទើបលោកពោលថា សេនិយនិគ្រន្ថដែលកាន់កុក្កុរវត្ត ក៏បានបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ នៃព្រះមានព្រះភាគ ។ បទថា **អចិរូបសម្បន្នោ** ប្រែថា ឧបសម្បទាហើយមិនយូរ ។ បទថា **វូបកដ្ឋោ** គឺដោះកាយ និងចិត្តចាកវត្ថុកាមនិងកិលេសកាម ។ បទថា **អប្បមត្តោ** គឺបុគ្គលមិនលះបង់សតិក្នុងកម្មដ្ឋាន ។ បទថា **អាតាបី** គឺជាអ្នកមានគុណជាគ្រឿងដុតកិលេស ដោយគុណ គឺសេចក្តីព្យាយាម ដែលរាប់បានថា ប្រព្រឹត្តទៅតាមកាយ និងតាមចិត្ត ។ បទថា **បហិតត្តោ** គឺបុគ្គលដែលមានខ្លួនបញ្ជូនទៅ មានអត្តភាពដែលលះបង់ហើយ ព្រោះជាអ្នកមិនជាប់ជំពាក់ក្នុងរាងកាយ និងជីវិត ។ បទថា **យស្សត្ថាយ** កាត់បទជា **យស្ស អត្ថាយ** ។ បទថា **កុលបុត្តា** គឺកូនដែលមានមារយាទ និងត្រកូល ។ បទថា **សម្មទេវ** គឺដោយហេតុ ដោយការណ៍ ។ បទថា **តទនុត្តរំ** កាត់បទជា **តំ អនុត្តរំ** ។ បទថា **ព្រហ្មចរិយបរិយោសានំ** គឺអរហត្តផលដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ ពិតហើយ កុលបុត្រទាំងឡាយ រមែងបួសដើម្បីប្រយោជន៍ដល់មគ្គព្រហ្មចរិយៈនោះ ។ ពីរបទថា **ទិដ្ឋេវ ធម្មេ** គឺក្នុងអត្តភាពនេះឯង ។ បទថា **សយំ អភិញ្ញា សច្ឆិកត្វា** គឺធ្វើឲ្យប្រចក្សដោយបញ្ញាដោយខ្លួនឯង អធិប្បាយថា ជាបុគ្គលមិនមានអ្នកដទៃជាបច្ច័យ គឺមិនជឿអ្នកដទៃ ។ បទថា **ឧបសម្បជ្ជ វិហាសិ** គឺសម្រេចហើយ ឲ្យដល់ព្រមហើយ ។ បុគ្គលនៅយ៉ាងនេះឯង ដឹងក្រៃលែងថា ជាតិ

អស់ហើយ ... ។ ព្រះមានព្រះភាគកាលទ្រង់សម្តែងបច្ចវេក្ខណភូមិ គឺញាណដល់សេនិយៈយ៉ាងនេះហើយ កាលទ្រង់ឲ្យទេសនាចប់ដោយកំពូល គឺអរហត្ត ទើបលោកពោលថា បណ្តាពួកព្រះអរហន្ត សេនិយភិក្ខុមានអាយុបានជាព្រះអរហន្តមួយអង្គដែរ ។ បណ្តាបទទាំងនោះ បទថា **អញ្ញតរោ** គឺមួយអង្គ ។ បទថា **អរហតំ** គឺនៃព្រះអរហន្តទាំងឡាយ ។ ក្នុងសេចក្តីនេះមានអធិប្បាយថា បណ្តាព្រះអរហន្តសាវកទាំងឡាយ នៃព្រះមានព្រះភាគសេនិយៈ ក៏ជាព្រះអរហន្តមួយអង្គដែរ ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើងាយយល់ទាំងអស់ហើយ ៕

## កុក្កុរោវាទសូត្រ ចប់
## សូត្រទី ៧ ចប់

# សុត្តន្តបិដក

## អភយរាជកុមារសូត្រទី ៨

[ ៩១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ក្នុងក្រុងរាជគ្រឹះ ។ គ្រានោះ អភយរាជកុមារ ចូលទៅរកនិគ្គន្ថនាដបុត្រ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំ និគ្គន្ថនាដបុត្រ រួចអង្គុយនៅក្នុងទីសមគួរ ។

[ ៩២ ] និគ្គន្ថនាដបុត្រ បាននិយាយនឹងអភយរាជកុមារ ដែលអង្គុយ នៅក្នុងទីសមគួរយ៉ាងនេះថា ម្នាលរាជកុមារទ្រង់ចូលមក ចូរទ្រង់លើកឡើង នូវវាទះ គឺលើកវាទះ ចំពោះព្រះសមណគោតម ទ្រង់នឹងមានកិត្តិសព្ទដ៏ពីរោះ ល្បីខ្ចរខ្ចាយទៅយ៉ាងនេះថា អភយរាជកុមារ ហ៊ានលើកវាទះនៃព្រះសមណ-គោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ។ អភយ-រាជកុមារសួរថា បពិត្រលោកដ៏ចម្រើន ខ្ញុំនឹងលើកវាទះនៃព្រះសមណគោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយប្រការដូចម្តេច ។ និគ្គន្ថនាដបុត្រឆ្លើយថា ម្នាលរាជកុមារ ទ្រង់ចូលមក ចូរទ្រង់ទៅរកព្រះសមណគោតម លុះចូលទៅដល់ហើយ ចូរពោលយ៉ាងនេះនឹងព្រះសមណ-គោតមថា បពិត្រព្រះអង្គដ៏ចម្រើន វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ ព្រះតថាគតគប្បីពោលវាចានោះដែរឬទេ ប្រសិនបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណគោតម នឹងដោះស្រាយយ៉ាងនេះថា ម្នាលរាជកុមារ វាចាណា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំង-

ឡាយដទៃ តថាគតគប្បីពោលវាចានោះដែរ ទ្រង់គប្បីពោលនឹងព្រះសមណ-គោតមយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ អំពើរបស់ព្រះអង្គ ផ្សេងអ្វីអំពីបុថុជ្ជន ព្រោះថា វាចាណា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ បុថុជ្ជនក៏ពោលនូវវាចានេះដែរ ប្រសិនបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណគោតមគង់នឹងដោះស្រាយយ៉ាងនេះថា ម្នាលរាជកុមារ វាចាណា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគតមិនពោលនូវវាចានោះទេ ទ្រង់គប្បីពោលនឹងសមណគោតមនោះយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ ហេតុអ្វី បានជាព្រះអង្គទ្រង់ព្យាករទេវទត្តថា ទេវទត្តកើតក្នុងអបាយ ទេវទត្តកើតក្នុងនរក ទេវទត្តឋិតនៅអស់ ១ កប្ប ទេវទត្ត ( បើទុកជាពាន់នៃព្រះពុទ្ធ ) ក៏មិនអាចជួយកែបានហើយទេវទត្ត ក៏ខឹងអាក់អន់ចិត្ត ព្រោះវាចារបស់ព្រះអង្គនោះ ។ ម្នាលរាជ-កុមារ កាលបើទ្រង់សួរនូវបញ្ហា ប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណគោតមក៏មិនអាចនឹងលេបចូល មិនអាចខ្ជាក់ចេញបានឡើយ ដូចជាក្រចាប់ដែក ស្ទាក់នៅក្នុងបំពង់កនៃបុរស បុរសនោះមិនអាចលេបចូល មិនអាចខ្ជាក់ចេញបាន យ៉ាងណា ម្នាលរាជកុមារ កាលបើទ្រង់សួរនូវបញ្ហាប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណគោតមក៏មិនអាចលេបចូល មិនអាចខ្ជាក់ចេញបាន យ៉ាងនោះឯង ។ អភយរាជកុមារ ទទួលស្តាប់ពាក្យនិគ្គន្ថនាដបុត្រ ដោយពាក្យថា ករុណាលោកម្ចាស់ ហើយក្រោកអំពីទីអង្គុយ ក្រាបថ្វាយបង្គំនិគ្គន្ថនាដបុត្ត ធ្វើប្រទក្សិណ ហើយចូលសំដៅទៅរក

ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ អភយរាជកុមារ លុះអង្គុយក្នុងទីសមគួរហើយ ក៏ក្រឡេកមើលព្រះអាទិត្យ មានសេចក្តីត្រិះរិះយ៉ាងនេះថា ថ្ងៃនេះ ជាកាលមិនសមគួរ ដើម្បីលើកវាទៈចំពោះព្រះមានព្រះភាគឡើយ អាត្មាអញនឹងលើកវាទៈចំពោះព្រះមានព្រះភាគ ក្នុងលំនៅរបស់ខ្លួន ក្នុងថ្ងៃស្អែកវិញ ។ ឯអភយ-រាជកុមារ ក៏ក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មានភិក្ខុជាគម្រប់ ៤ និងព្រះអង្គទៅទទួលភត្តរបស់ខ្ញុំ ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ អភយរាជកុមារ ដឹងច្បាស់នូវការទទួលនិមន្តន៍ របស់ព្រះមានព្រះភាគហើយ ក៏ក្រោកអំពីទីអង្គុយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ គ្រាកាលរាត្រីកន្លងទៅហើយ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ទ្រង់យាងសំដៅទៅកាន់លំនៅនៃអភយ-រាជកុមារ លុះទ្រង់ពុទ្ធដំណើរទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះ អភយរាជកុមារ បានអង្គាសនូវខាទនីយ-ភោជនីយាហារដ៏ថ្លៃថ្លាញ់ពីសា ដោយដៃខ្លួនឯង ថ្វាយព្រះមានព្រះភាគសោយឲ្យឆ្អែតស្កប់ស្កល់ ។ គ្រានោះ អភយរាជកុមារដឹងថា ព្រះមានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏កាន់យកនូវអាសនៈទាបមួយ អង្គុយក្នុងទីសមគួរ ។

[ ៩៣ ] អភយរាជកុមារ លុះអង្គុយក្នុងទីសមគួរហើយ បានក្រាបទូល

ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ ព្រះតថាគតគប្បីពោលវាចានោះដែរឬទេ ។ ព្រះអង្គត្រាស់ថា ម្នាលរាជកុមារ ការដោះស្រាយក្នុងបញ្ហានេះ មិនតែមួយចំណែកទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បើការដោះស្រាយក្នុងបញ្ហានេះ មិនតែមួយចំណែកហើយ និគ្រន្ថទាំងឡាយ មុខជាវិនាសមិនខាន ។ ម្នាលរាជកុមារ ហេតុដូចម្តេចបានជាអ្នកពោលយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន បើការដោះស្រាយក្នុងបញ្ហានេះ មិនតែមួយចំណែកហើយ ពួកនិគ្រន្ថមុខជានឹងវិនាសពុំខាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមកក្នុងទីនេះ ព្រោះខ្ញុំព្រះអង្គ បានចូលទៅរកនិគ្គន្ថនាដបុត្ត លុះចូលទៅដល់ហើយ ថ្វាយបង្គំនិគ្គន្ថនាដបុត្ត ហើយអង្គុយក្នុងទីសមគួរ បពិត្រព្រះអង្គដ៏ចម្រើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីសមគួរហើយ និគ្គន្ថនាដបុត្តក៏បាននិយាយថា ម្នាលរាជកុមារ សូមទ្រង់មក សូមទ្រង់លើកវាទៈចំពោះព្រះសមណគោតមចុះ ទ្រង់នឹងមានកិត្តិសព្ទល្បីខ្ចរខ្ចាយទៅ យ៉ាងនេះថា អភយរាជកុមារហ៊ានលើកវាទៈចំពោះព្រះសមណគោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះបាន កាលនិគ្គន្ថនាដបុត្តពោលយ៉ាងនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានពោលពាក្យនេះ នឹងនិគ្គន្ថនាដបុត្តថា បពិត្រលោកដ៏ចម្រើន ខ្ញុំនឹងលើកវាទៈចំពោះព្រះសមណគោតម ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយប្រការដូចម្តេចទៅ និគ្គន្ថនាដបុត្តក៏ពោលថា ម្នាលរាជកុមារ សូមទ្រង់មក សូមទ្រង់ចូលទៅរកព្រះសមណ-

គោតម លុះចូលទៅដល់ហើយ សូមទ្រង់ពោលយ៉ាងនេះនឹងព្រះសមណ-គោតមថា បពិត្រព្រះអង្គដ៏ចម្រើន វាចាណា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ ព្រះតថាគតគប្បីពោលវាចានោះដែរឬទេ កាលបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណគោតម នឹងដោះស្រាយយ៉ាងនេះថា ម្នាលរាជកុមារ វាចាណា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតគប្បីពោលវាចានោះដែរ ទ្រង់គប្បីពោលនឹងព្រះសមណគោតមយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ អំពើរបស់ព្រះអង្គ ផ្សេងអ្វីអំពីបុថុជ្ជនបាន ព្រោះថា វាចាណាមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ បុថុជ្ជនក៏ពោលវាចានោះដែរ ប្រសិនបើទ្រង់សួរយ៉ាងនេះហើយ ព្រះសមណគោតមមុខជានឹងដោះស្រាយយ៉ាងនេះថា ម្នាលរាជកុមារ វាចាណា មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតមិនពោលវាចានោះឡើយ ទ្រង់គប្បីពោលនឹងព្រះសមណគោតម យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ ហេតុអ្វីបានជាព្រះអង្គទ្រង់ព្យាករទេវទត្តថា ទេវទត្តកើតក្នុងអបាយ ទេវទត្តកើតក្នុងនរក ទេវទត្តឋិតនៅអស់ ១ កប្ប ទេវទត្ត ( ទុកជាពាន់នៃព្រះពុទ្ធទាំង-ឡាយ ) ក៏ជួយកែមិនបាន ដូច្នេះ ទេវទត្តខឹងអាក់អន់ចិត្តចំពោះព្រះអង្គ ព្រោះវាចានោះឯង ម្នាលរាជកុមារ កាលបើអ្នកសួរបញ្ហាប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណគោតមក៏មិនអាចលេបចូល មិនអាចខ្ជាក់ចេញបានឡើយ ដូចក្រចាប់ដែកដែលស្ទាក់នៅក្នុងបំពង់កនៃបុរស បុរសនោះមិន

អាចលេបចូល មិនអាចខ្ជាក់ចេញបានយ៉ាងណា ម្នាលរាជកុមារ កាលបើទ្រង់សួរបញ្ហាប្រកបដោយទីបំផុតទាំងពីរខាងនេះហើយ ព្រះសមណគោតមមិនអាចលេបចូល មិនអាចខ្ជាក់ចេញបាន យ៉ាងនោះឯង ។

[ ៩៤ ] សម័យនោះឯង មានកូនខ្ចីមិនទាន់ចេះក្រឡាប់ អង្គុយលើភ្លៅអភយរាជកុមារ ។ លំដាប់នោះ ព្រះមានព្រះភាគមានព្រះតម្រាស់នឹងអភយ-រាជកុមារថា ម្នាលរាជកុមារ ទ្រង់សម្គាល់កូនខ្ចីនោះ ដូចម្តេច បើកូនខ្ចីនេះបៀមនូវកំណាត់ឈើក្តី អំបែងក្តី ហើយលេបចូលទៅក្នុងមាត់ព្រោះសេចក្តីធ្វេសប្រហែសរបស់ទ្រង់ ឬព្រោះសេចក្តីធ្វេសប្រហែសរបស់មេនំ តើទ្រង់ត្រូវធ្វើក្មេងនោះដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គត្រូវតែលូកទាញចេញ បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គមិនអាចលូកទាញចេញ ដោយប្រយោគជាដំបូងបានទេ ខ្ញុំព្រះអង្គនឹងចាប់សង្កត់ក្បាល ដោយដៃឆ្វេង ខ្វេរម្រាមដៃស្តាំលូកខ្វេះទាញវត្ថុនោះចេញមកដោយទាំងឈាមផង ការខ្វេះទាញចេញវត្ថុនោះ ព្រោះហេតុដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាខ្ញុំព្រះអង្គមានសេចក្តីអាណិតកុមារ ។ ម្នាលរាជកុមារ យ៉ាងហ្នឹងឯង តថាគតដឹងនូវវាចាណា ដែលមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃផង តថាគតក៏មិនពោលវាចានោះ តថាគតដឹងនូវវាចាណា ដែលពិត ទៀង តែមិនប្រកបដោយប្រយោជន៍ វាចានោះមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃផង តថាគតក៏មិនពោលនូវវាចានោះដែរ មួយវិញទៀត តថាគតដឹងនូវ

វាចាណា ដែលពិត ទៀង ប្រកបដោយប្រយោជន៍ តែថាវាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតស្គាល់កាលគួរនឹងពោលវាចានោះ ក្នុងព្យាករណ៍នោះដែរ តថាគតដឹងនូវវាចាណា ដែលមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះ ទោះបីជាទីស្រឡាញ់ ជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតក៏មិនពោលវាចានោះឡើយ តថាគតដឹងនូវវាចាណា ដែលពិតទៀង តែមិនប្រកបដោយប្រយោជន៍ វាចានោះ ទោះបីជាទីស្រឡាញ់ ជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃ តថាគតក៏មិនពោលវាចានោះដែរ មួយវិញទៀត តថាគតដឹងនូវវាចាណា ដែលពិតទៀង ប្រកបដោយប្រយោជន៍ វាចានោះ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃផង តថាគតស្គាល់កាលគួរនឹងពោលនូវវាចានោះ ក្នុងព្យាករណ៍នោះ ម្នាលរាជកុមារ ព្រោះហេតុអ្វី ព្រោះថា តថាគតមានសេចក្តីអនុគ្រោះចំពោះសត្វទាំងឡាយ ។

[ ៩៥ ] អភយរាជកុមារក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយ ជាខត្តិយបណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណ-បណ្ឌិតក្តី បានតាក់តែងបញ្ហាដល់ខ្ញុំ ហើយចូលមកសួរព្រះតថាគត បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ បានត្រិះរិះបញ្ហានុ៎ះ ទុកក្នុងព្រះហឫទ័យស្រេច តាំងពីកាលមុនថា ជនទាំងឡាយណា ចូលមករកតថាគត ហើយសួរយ៉ាងនេះ លុះជនទាំងឡាយនោះ សួរតថាគតយ៉ាងនេះហើយ តថាគតនឹងដោះស្រាយយ៉ាងនេះដែរឬ ឬថាបញ្ហាកម្មនុ៎ះ ស្រាប់តែប្រាកដឡើង

ដល់ព្រះតថាគត ដោយញាណជាទីកើតឡើងនៃហេតុ ។ ព្រះអង្គត្រាស់ថា ម្នាលរាជកុមារ បើដូច្នោះ តថាគតនឹងត្រឡប់សួរទ្រង់ក្នុងដំណើរនុ៎ះវិញ ទ្រង់គាប់ចិត្តយ៉ាងណា គប្បីដោះស្រាយដំណើរនោះ យ៉ាងនោះចុះ ម្នាលរាជកុមារ តើទ្រង់សម្គាល់ហេតុនោះដូចម្ដេច ទ្រង់ជាបុគ្គលឈ្លាស ក្នុងអវយវៈតូចធំទាំងឡាយនៃរថដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកឈ្លាសក្នុងអវយវៈតូចធំនៃរថដែរ ។ ម្នាលរាជកុមារ ទ្រង់សម្គាល់ដំណើរនោះដូចម្ដេច ជនទាំងឡាយណា ចូលទៅរកទ្រង់ហើយសួរយ៉ាងនេះថា អវយវៈតូចធំនៃរថនេះ ឈ្មោះអ្វី ទ្រង់បានត្រិះរិះហេតុនេះទុកក្នុងចិត្តស្រេច តាំងពីកាលមុនថា ជនទាំងឡាយណា នឹងចូលមករកអាត្មាអញហើយសួរយ៉ាងនេះ ជនទាំងឡាយនោះ លុះសួរអាត្មាអញយ៉ាងនេះហើយ អាត្មាអញនឹងដោះស្រាយយ៉ាងនេះឬ ឬថាដំណើរនុ៎ះ ក៏ស្រាប់តែប្រាកដដល់ទ្រង់ ដោយញាណជាទីកើតឡើងនៃហេតុតែម្ដង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកចាំបាននូវរថ ជាអ្នកឈ្លាសក្នុងអវយវៈតូចធំនៃរថ អវយវៈតូចធំទាំងអស់របស់រថខ្ញុំព្រះអង្គស្គាល់ហើយ បានជាដំណើរនុ៎ះប្រាកដដល់ខ្ញុំព្រះអង្គ ដោយញាណជាទីកើតឡើងនៃហេតុតែម្ដង ។ ម្នាលរាជកុមារ ជនទាំងឡាយជាខត្តិយ-បណ្ឌិតក្តី ព្រាហ្មណបណ្ឌិតក្តី គហបតិបណ្ឌិតក្តី សមណបណ្ឌិតក្តី បានតាក់តែងបញ្ហាដល់អ្នក ហើយចូលមកសួរតថាគតថា ដំណើរនុ៎ះ ប្រាកដដល់ព្រះតថាគត ដោយញាណជាទីកើតឡើងនៃហេតុបាន ក៏យ៉ាងនោះដែរ ដំណើរនោះ ព្រោះហេតុដូចម្ដេច ម្នាលរាជកុមារ ព្រោះថាធម្មធាតុ ( សព្វញ្ញុ-

តញ្ញាណ ) គឺតថាគតចាក់ធ្លុះហើយ បានជាដំណើរទុ៎ះប្រាកដដល់តថាគត ដោយញាណជាទីកើតឡើងនៃហេតុតែម្តង ។

[ ៩៦ ] កាលដែលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ អភយ-រាជកុមារក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងបំភ្លឺហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចគេផ្ងាររបស់ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះ ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ឲ្យមនុស្សមានភ្នែកភ្លឺ មើលឃើញរូបទាំងឡាយបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង ទីរឭក សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសកអ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

## អភយរាជកុមារសូត្រទី ៨ ចប់

# អដ្ឋកថា

## អភយរាជកុមារសូត្រទី ៨

[ ៩១ ] អភយរាជកុមារសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបណ្ដាបទទាំងនោះ បទថា **អភយ** ជាឈ្មោះរបស់ព្រះរាជកុមារអង្គនោះ ។ បទថា **រាជកុមារ** គឺជាព្រះរាជឱរសរបស់ព្រះបាទពិម្ពិសារ ។

[ ៩២ ] បទថា **វាទំ អារោបេហិ** គឺលើកទោសក្នុងវាទៈ ។ បទថា **នេរយិកោ** ប្រែថា អ្នកកើតក្នុងនរក ។ បទថា **កប្បដ្ឋោ** ប្រែថា តាំងនៅអស់កប្ប ។ បទថា **អតេកិច្ឆោ** គឺសូម្បីព្រះពុទ្ធ ១ ពាន់អង្គ ក៏មិនអាចកែបាន ។ បទថា **ឧគ្គិលិតុំ** គឺព្រះតថាគត កាលមិនអាចពោលស្រាយបញ្ហាដែលមានកំណួច ២ បាន ក៏មិនអាចខ្ជាក់ គឺនាំចេញខាងក្រៅបាន ។ បទថា **ឱគ្គិលិតុំ** គឺមិនអាចឲ្យនាំទោសនៃប្រស្នាចេញទៅ ក៏មិនអាចលេប គឺចូលទៅខាងក្នុងបាន ។ បទថា **ឯវំ ភន្តេ** សេចក្ដីថា បានឮថា និគ្រន្ថគិតថា ព្រះសមណគោតមទម្លាយសាវ័ករបស់អញហើយ ទទួលយកខ្លួនឯងណ្ហើយចុះ អញនឹងចងប្រស្នាមួយ ដែលព្រះសមណគោតមត្រូវសួរហើយនឹងអន្តួយសុបសៅ មិនអាចក្រោកបាន ។ និគ្រន្ថនោះ ទទួលអាហារមកអំពីព្រះរាជដំណាក់របស់អភយរាជកុមារហើយ ធាន់កោជនដ៏មានឱជៈ ចងប្រស្នាទុកជាច្រើន គិតថា ព្រះសមណគោតមឃើញទោសនេះ ក្នុងបញ្ហានេះ ក្នុងសេចក្ដីនោះ ក៏ជាស្មៀត ហើយលះការងារទាំងពួងចេញ បានជញ្ជីងគិត

បញ្ហានេះ ក្នុងខួរក្បាលអស់ ៤ ខែ កាលនោះនិគ្រន្ថគិតថា ព្រះសមណ-គោតមមិនអាចឲ្យទោសក្នុងការសួរ ឬឆ្លើយបញ្ហានេះបាន បញ្ហានេះ ឈ្មោះឧវដ្ដិកសារៈ គឺបញ្ហាវិល នរណាម្នាក់ នឹងទទួលចង់វាទៈដល់ព្រះសមណ-គោតមបាន ។ បន្ទាប់អំពីនោះ ក៏សម្រេចចិត្តថា អភយរាជកុមារជាបណ្ឌិត គេនឹងអាច ហេតុនោះ អញនឹងឲ្យអភយរាជកុមាររៀនបញ្ហានេះ ហើយឲ្យអភយរាជកុមាររៀន អភយរាជកុមារនោះ មានអធ្យាស្រ័យចូលចិត្តលើកវាទៈ ទើបទទួលពាក្យនិគ្រន្ថនោះ ត្រាស់ថា ប្រពៃហើយ លោកអាចារ្យ ។ ទ្រង់យល់ក្នុងព្រះហឫទ័យថា ប្រស្នានេះ អាចារ្យចងអស់កាល ៤ ខែ កាលទទួលយកបញ្ហានេះទៅឲ្យព្រះសមណគោតមឆ្លើយ ពេលក៏គង់មិនគ្រប់គ្រាន់ ទើបត្រិះរិះយ៉ាងនេះថា ថ្ងៃមិនសមគួរ ។ បទថា **ស្វេ នាហំ** កាត់បទជា **ស្វេ នាទិ** ។ បទថា **អត្តចតុត្ថោ** សេចក្ដីថា ហេតុអ្វី ទើបអភយរាជកុមារមិននិមន្តភិក្ខុទាំងឡាយឲ្យច្រើនរូប ។ បានឮថា អភយរាជកុមារនោះ ទ្រង់ត្រិះរិះយ៉ាងនេះថា កាលភិក្ខុច្រើនរូបអង្គុយហើយ ព្រះមានព្រះភាគ ទ្រង់នឹងទាញសូត្រដទៃ ហេតុដទៃ ឬរឿងទំនងនោះដទៃមកសម្ដែងដល់អញ ទើបថ្វាយរបស់តិចតួច កំពុងពោល កាលបើដូច្នោះ ក៏នឹងមានតែការឈ្លោះ ការរុករាន វឹកវរប៉ុណ្ណោះ បើដូច្នោះ អញនឹងនិមន្តតែព្រះមានព្រះភាគមួយអង្គឯង ក៏នឹងកើតការតិះដៀលអញថា អភយរាជកុមារនេះប្រហែលជាកំណាញ់ទាំងដែលធ្លាប់ឃើញព្រះមានព្រះភាគទ្រង់បិណ្ឌបាត ព្រមដោយភិក្ខុ ១០០ រូបខ្លះ ១០០០ រូបខ្លះ រាល់ៗ ថ្ងៃ ក៏នៅតែនិមន្តព្រះមានព្រះភាគមួយអង្គ ឯ

ទោសយ៉ាងនោះ នឹងមិនមាន ។ ទើបនិមន្តព្រះមានព្រះភាគជាគម្រប់ ៤ ជាមួយភិក្ខុអង្គដទៃ ៣ រូបទៀត ។

បទថា **ន ខ្វេត្ថ រាជកុមារ ឯកំសេន** សេចក្តីថា ព្រះមានព្រះភាគត្រាស់ថា ម្នាលរាជកុមារ ក្នុងរឿងនេះ មិនមានការឆ្លើយបញ្ហាដោយកំណួច ១ ។ អធិប្បាយថា តថាគតគប្បីពោលក្តី មិនគប្បីពោលក្តីនូវវាចាបែបនោះ តថាគតឃើញប្រយោជន៍ ដោយបច្ច័យនៃភាសិត ទើបពោល មិនឃើញប្រយោជន៍ក៏មិនពោល ។ ដូច្នោះ ទើបព្រះមានព្រះភាគទ្រង់រំលាយបញ្ហាដែលនិគ្រន្ថចងមកអស់ ៤ ខែ ដោយព្រះតម្រាស់ ១ ប៉ុណ្ណោះ ប្រៀបដូចអសនីបាតបាញ់កំពូលបពិត ដូច្នោះ ។ ពីរបទថា **អនស្សុំ និគ្គន្ថា** ប្រែថា និគ្រន្ថទាំងឡាយវិនាសហើយ ។

[ ៩៤ ] បទថា **អង្កេ និសិន្នោ ហោតិ** គឺអង្គុយលើភ្លៅ ។ ពិតហើយ អ្នកពោលដោយលេសទាំងឡាយ តាំងវាទៈឡើងមក ក៏អង្គុយចាប់វត្ថុណាមួយ ដូចជាផ្លែឈើ ឬផ្កាឈើ ឬគម្ពីរ កាលខ្លួនឈ្នះក៏សង្កត់សង្កិនអ្នកដទៃ កាលខ្លួនចាញ់ ក៏សម្តែងកិរិយារាយមាយ ធ្វើហាក់ដូចជាស៊ីផ្លែឈើ ហិតផ្កា អានគម្ពីរ ដូច្នោះ ។ ឯអភយរាជកុមារនេះ ទ្រង់ត្រិះរិះថា ព្រះសម្មាសម្ពុទ្ធទ្រង់ចូលសង្គ្រាម ញាំញីវាទៈរបស់អ្នកដទៃ បើអញឈ្នះជាការល្អ បើមិនឈ្នះ ក៏នឹងក្តិចកូនឲ្យយំ បន្ទាប់អំពីនោះ អញនឹងពោលថា មើលចុះ លោកដ៏ចម្រើន ក្មេងនេះយំ ខ្ញុំសូមក្រោកឡើងសិន ខាងក្រោយសឹមជីងគ្នា ព្រោះដូច្នោះ ទើបទ្រង់ពរកូនមកប្រថាប់គង់ ។ ឯព្រះមានព្រះភាគ ជាអ្នកពោលដ៏

ប្រសើរជាងអភយរាជកុមារ ១ ពាន់ដង ១ សែនដង ទ្រង់ព្រះពុទ្ធតម្រិះថា ទ្រង់នឹងធ្វើក្មេងនេះឯងឲ្យជាឧបមា ទម្លាយវាទៈរបស់អភយរាជកុមារនោះចេញ ទើបត្រាស់ថា **តំ កិំ មញ្ញសិ រាជកុមារ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **មុខេ អាហារេយ្យ** ប្រែថា តាំងទុកក្នុងមាត់ ។ បទថា **អាហារេយ្យស្សាហំ** កាត់បទជា **អបនេយ្យំ អស្ស អហំ** ។ បទថា **អាទិកេនេវ** ប្រែថា ដោយប្រយោគដំបូងប៉ុណ្ណោះ ។ បទថា **អភូតំ** ប្រែថា មានអត្ថមិនពិត ។ បទថា **អតច្ឆំ** ប្រែថា មិនឥតប្រយោជន៍ ។ បទថា **អនត្ថសញ្ហិតំ** ប្រែថា មិនប្រកបដោយប្រយោជន៍ មិនអាស្រ័យសេចក្ដីចម្រើន ។ បទថា **អប្បិយា អមនាបា** ប្រែថា មិនគួរស្រឡាញ់ មិនគួរត្រេកអរ ។ គប្បីជ្រាបសេចក្ដីក្នុងទីគ្រប់អន្លើ ដោយន័យនេះឯង ។ បណ្ដាវាចា ២ ចំណែកនោះ ក្នុងវាចាដែលមិនជាទីស្រឡាញ់ វាចាដំបូងដែលប្រព្រឹត្តទៅ ចោទមនុស្សដែលមិនមែនចោរ ថាចោរ ចោទមនុស្សដែលមិនមែនជាទាសៈ ថាជាទាសៈ ចោទមនុស្សដែលមិនមែនអ្នកប្រកបកម្មអាក្រក់ ជាប្រកបកម្មអាក្រក់ តថាគតមិនពោលវាចានោះ វាចាទី ២ ប្រព្រឹត្តទៅដោយអំណាចវាចាដែលចន្លុលបុគ្គលជាចោរប៉ុណ្ណោះថា បុគ្គលនេះចោរដូច្នេះជាដើម តថាគតមិនពោលវាចានោះ នេះគប្បីជ្រាបវាចាទី ២ គឺវាចាដែលពោលដោយបំណងប្រយោជន៍ជាខាងមុខ ដោយប្រាថ្នាធម៌ជាទីទៅខាងមុខ ដោយប្រាថ្នាទូន្មានជាទីទៅខាងមុខ ដល់មហាជនយ៉ាងនេះថា ព្រោះភាពដែលអ្នកមិនបានធ្វើបុណ្យ ទើបអ្នកក្រីក្រ មានពណ៌សម្បុរអាក្រក់ មានអំណាច

តិច សូម្បីតាំងនៅក្នុងលោកនេះហើយ ក៏នៅតែមិនធ្វើបុណ្យទៀត ក្នុងអត្ត-ភាពទី ២ អ្នកនឹងផុតចាកអបាយ ៤ ដូចម្តេច ។ បណ្តាបទទាំងនោះ បទថា **កាលញ្ញូ តថាគតោ** សេចក្តីថា តថាគតជាអ្នកដឹងកាលដើម្បីប្រយោជន៍ដល់ការព្យាករណ៍វាចានោះ ក្នុងការព្យាករណ៍ទី ៣ នោះ អធិប្បាយថា តថាគតដឹងកាលដែលកាន់យករបស់គួរ កាលដែលរមែងទទួលរបស់មហាជន ហើយទើបព្យាករក្នុងចំណែកវាចាជាទីស្រឡាញ់ វាចាជំបូងឈ្មោះថា វាចាដែលមិនគួរតាំងទុក វាចាដែលមិនគួរតាំងទុកនោះ គប្បីជ្រាបយ៉ាងនេះ ។

បានឮមកថា បុរសចំណាស់ម្នាក់មកកាន់ព្រះនគរ ផឹកស្រានៅក្នុងរោងសុរា ពួកអ្នកលេងសុរាជាច្រើន ត្រូវការបោកបញ្ឆោតគាត់ ទើបឈរក្បែរទីដែលគាត់ផឹកស្រា ហើយផឹកស្រាជាមួយគាត់ គិតក្នុងចិត្តថា អញនឹងយកសំពត់ស្លៀកផង សំពត់ដណ្តប់ផង របស់បុរសចំណាស់នេះ និងទ្រព្យដែលនៅក្នុងដៃទាំងអស់ ទើបធ្វើកតិកាសញ្ញាដល់គ្នានិងគ្នាថា យើងនឹងនិទានរឿងដែលប្រចក្សដល់ខ្លួនម្នាក់មួយរឿង បុគ្គលណាពោលថា មិនពិត ឬមិនជឿរឿងដែលពោល យើងនឹងយកបុគ្គលនោះទៅជាទាសៈ ។ ទើបសួរបុរសនោះថា អ៊ំ ត្រូវចិត្តឬទេ បុរសចំណាស់ឆ្លើយថា យល់ព្រមអ្នកកំលោះ ។

ទើបអ្នកលេងស្រាម្នាក់ពោលថា អ្នកដ៏ចម្រើន កាលខ្ញុំនៅក្នុងពោះម៉ែខ្ញុំ ម៉ែចាញ់ផ្លែ ចង់បរិភោគផ្លែខ្វិត ម៉ែរកអ្នកបេះផ្លែខ្វិតមិនបាន ទើបប្រាប់ខ្ញុំឲ្យទៅឡើងដើមខ្វិត ឡើងមិនបាន ក៏ចាប់ជើងខ្លួនឯង បោះឡើងទៅលើដើមឈើ ដូចបោះដំបង ហើយក៏ស្ទូចពីមែកនោះមកមែកនេះ បេះផ្លែខ្វិតស្រេច

ហើយក៏ចុះមិនបាន ទើបត្រឡប់ទៅផ្ទះ យកជណ្តើរមកដាក់ ទើបចុះបាន រួចទៅរកម៉ែ ឲ្យផ្លែខ្វិតដល់ម៉ែ តែផ្លែខ្វិតទាំងនោះធំប៉ុនៗ ពាង បន្ទាប់អំពីនោះ ម៉ែខ្ញុំក៏អង្គុយក្នុងទីមួយកន្លែង បរិភោគផ្លែខ្វិតអស់ ៦០ ក្នុងចំនួនផ្លែខ្វិតដែលខ្ញុំនាំមកដោយចង្កេះម្ខាង ផ្លែខ្វិតដែលសល់ក៏ជារបស់ក្មេងនៃមនុស្សចាស់ក្នុងស្រុក និងរបស់ត្រកូល ផ្ទះរបស់ខ្ញុំទំហំ ១៦ ហត្ថ ជញ្ជូនគ្រឿងប្រើប្រាស់ដែលសល់ចេញទៅ ផ្លែខ្វិតក៏ពេញរហូតដល់ដំបូល ចំណែកដែលហៀរជាងដំបូលក៏គរទុកជិតទ្វារផ្ទះ មានកម្ពស់ដល់ទៅ ៨០ ហត្ថ ដូចភ្នំទ្រុងក្អែក លោកដ៏ចម្រើន ជឿរឿងនេះ ឬមិនជឿ ។

បុរសចំណាស់នោះអង្គុយស្ងៀម ត្រូវពួកអ្នកលេងសួរ កាលចប់រឿងក៏ឆ្លើយថា វាយ៉ាងនោះឯង អ្នកកំលោះ ខ្ញុំជឿ ព្រោះដែនវាធំ កាលពួកអ្នកលេងដ៏សេសនិទានរឿងដែលប្រាសចាកហេតុ គ្រប់ៗ គ្នា ដូចគ្នានឹងអ្នកលេងនោះពោលហើយ បុរសចំណាស់ក៏ប្រាប់ថា ស្តាប់ខ្ញុំម្តង អ្នកកំលោះ ត្រកូលរបស់អ្នកមិនធំទេ ត្រកូលរបស់ខ្ញុំធំពិតៗ ចម្ការរបស់ខ្ញុំក៏ធំជាងចម្ការណាៗទាំងអស់ កណ្តាលចម្ការមានផ្ទៃដីច្រើនរយករីសនោះ មានដើមកប្បាស ១ កម្ពស់ ៨០ ហត្ថ ទំហំធំ មានមែក ៥ មែកទាំង ៥ នោះ មែកដទៃៗ មិនមានផ្លែ មែកនៅទិសខាងកើតមានផ្លែ ១ ផ្លែប៉ុនពាងធំ ផ្លែនោះមាន ៦ ក្លែប ក្នុងក្លែប ៦ នោះ មានស្រោម ៦ ទើបខ្ញុំឲ្យគេតាក់តែងពុកចង្កា ហើយងូតទឹក ប្រោះព្រំខ្លួនឯងហើយ ក៏ទៅចម្ការ ឈរមើលផ្លែកប្បាសទាំងនោះ ផ្លែនោះបែកហើយ ទើបលូកដៃចូលទៅចាប់ស្រោមកប្បាសទាំងនោះ

ក៏ក្លាយជាទាសៈទៅ ពួកទាសៈទាំងនោះ ក៏រត់ទៅរៀងៗ ខ្លួន ខ្ញុំមិនបានជួបទាសៈទាំងនោះ រហូតទល់ឥឡូវនេះ ថ្ងៃនេះ ខ្ញុំបានជួបហើយ ទាសៈប្រាវឈ្មោះហៅថា នន្ទៈ បុណ្ណៈ វឌ្ឍមានៈ ធត្តៈ មង្គលៈ ហេដ្ឋិយៈ ហើយក្រោកចាប់ពួកអ្នកលេងត្រង់ផ្លូវសក់ ហើយឈរឡើង អ្នកលេងទាំងនោះអាចនឹងបដិសេធថា ពួកខ្ញុំមិនមែនជាទាសៈ ។ គ្រានោះ បុរសចំណាស់នោះ ក៏នាំខ្លួនអ្នកលេងទាំងនោះទៅឡើងសាលាក្តី លើកលក្ខណៈទាសៈឡើងឲ្យព្រមទទួល ធ្វើអ្នកលេងទាំងនោះឲ្យធ្លាក់ជាទាសៈ ជាអ្នកបម្រើអស់មួយជីវិត ។ តថាគតមិនពោលសម្តីបែបនេះ ។ វាចាទី ២ ជាវាចារបស់ចោរ សម្រាប់បុគ្គលដទៃមានប្រការផ្សេងៗ ព្រោះឃើញដល់អាមិស ឬព្រោះអំណាចការចង់ផឹកស្រាជាដើម និងជាតិរច្ឆានកថា ដែលប្រព្រឹត្តទៅដោយន័យថា រឿងចោរ រឿងព្រះរាជាជាដើម តថាគតមិនពោលវាចានោះ ។ វាចាទី ៣ ជាកថាដែលអាស្រ័យអរិយសច្ច ដែលពួកបណ្ឌិតស្តាប់សូម្បី ១០០ ឆ្នាំ ក៏មិនឆ្អែត ។ ដូច្នោះ ទើបតថាគតមិនពោលវាចាពិត ដែលមិនជាទីស្រឡាញ់ ទាំងជាទីស្រឡាញ់ ពោលតែវាចាទី ៣ ។ មិនឲ្យវេលាដែលគួរពោលវាចាទី ៣ កន្លងទៅឡើយ ។ គប្បីជ្រាបថា ឧបមាដោយរឿងក្មេងកំលោះ ដែលមកហើយខាងដើម ។ ក្នុងទីនោះ សំដៅយកវាចា ដែលមិនជាទីស្រឡាញ់ វាចាទី ៣ ។

[ ៩៥ ] បទថា **ឧទាហុ ឋានសោ វេតំ** សេចក្តីថា អភយរាជកុមារទូលសួរថា សេចក្តីនោះប្រាកដដល់ព្រះតថាគតភ្លាមៗ ដោយព្រះញាណ

ដែលកើតឡើងហើយដ៏ឆាប់រហ័ស ។ បទថា **បញ្ញាតោ** ប្រែថា បុគ្គលនោះដឹងហើយ ដឹងទូទៅហើយ ប្រាកដហើយ ។ បទថា **ធម្មធាតុ** សំដៅដល់សភាវៈនៃធម៌ ពាក្យនេះជាឈ្មោះរបស់ព្រះសព្វញ្ញុតញ្ញាណ ។ ពិតហើយ ព្រះសព្វញ្ញុតញ្ញាណនោះ ព្រះមានព្រះភាគត្រាស់ដឹងដោយល្អហើយ គឺនៅក្នុងព្រះហស្តនៃព្រះមានព្រះភាគ ព្រោះដូច្នោះ ព្រះអង្គទ្រង់បំណងសេចក្តីណាមួយ សេចក្តីទាំងអស់នោះ ក៏ជាក់ច្បាស់ឆាប់រួសរាន់ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ ងាយយល់ទាំងអស់ ព្រះធម្មទេសនានេះ ចប់ហើយដោយអំណាចនៃវេនេយ្យបុគ្គល ដូច្នេះ ។

**អភយរាជកុមារសូត្រ ចប់**

**សូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ពហុវេទនីយសូត្រទី ៩

[ ៩៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ លំដាប់នោះ មានជាងឈើម្នាក់ឈ្មោះបញ្ចកង្គៈ ចូលទៅរកព្រះថេរៈឈ្មោះឧទាយីមានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះឧទាយីមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។

[ ៩៨ ] ជាងឈើឈ្មោះបញ្ចកង្គៈនោះ លុះអង្គុយក្នុងទីសមគួរហើយ បាននិយាយនឹងព្រះឧទាយីមានអាយុយ៉ាងនេះថា បពិត្រព្រះឧទាយីដ៏ចម្រើន វេទនាដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ មានប៉ុន្មានយ៉ាង ។ ព្រះឧទាយីតបថា ម្នាលគហបតី វេទនាដែលព្រះមានព្រះភាគទ្រង់សម្តែង មាន ៣ យ៉ាង គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ម្នាលគហបតី វេទនាទាំង ៣ យ៉ាងនេះឯង ព្រះមានព្រះភាគទ្រង់សម្តែងហើយ ។ បពិត្រព្រះឧទាយីដ៏ចម្រើន វេទនាទាំង ៣ ព្រះមានព្រះភាគមិនទ្រង់សម្តែងទេ ព្រះមានព្រះភាគ ទ្រង់សម្តែងតែវេទនា ២ គឺសុខវេទនា ១ ទុក្ខវេទនា ១ បពិត្រលោកដ៏ចម្រើន ឯអទុក្ខមសុខវេទនានោះ ព្រះមានព្រះភាគ ទ្រង់សម្តែងចំពោះសេចក្តីសុខដ៏ល្អិតឧត្តម ។ ព្រះឧទាយីមានអាយុ បាននិយាយនឹងជាងឈើឈ្មោះបញ្ចកង្គៈជាគម្រប់ពីរដងថា ម្នាលគហបតី ព្រះមានព្រះភាគ មិនទ្រង់សម្តែងតែត្រឹមវេទនា ២ ទេ វេទនាទាំង ៣ គឺសុខវេទនា ១

ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ក៏ព្រះមានព្រះភាគទ្រង់សម្តែងដែរ ម្នាលគហបតី វេទនាទាំង ៣ នេះឯង ព្រះមានព្រះភាគទ្រង់សម្តែងហើយ ។ ជាងឈើឈ្មោះបញ្ចកង្គៈ បាននិយាយនឹងព្រះឧទាយីមានអាយុ ជាគម្រប់ពីរដងថា បពិត្រព្រះឧទាយីដ៏ចម្រើន វេទនាទាំង ៣ ព្រះមានព្រះភាគមិនទ្រង់សម្តែងទេ ព្រះមានព្រះភាគទ្រង់សម្តែងតែវេទនា ២ គឺសុខវេទនា ១ ទុក្ខវេទនា ១ បពិត្រលោកដ៏ចម្រើន ឯអទុក្ខមសុខវេទនានោះ ព្រះមានព្រះភាគទ្រង់សម្តែងចំពោះតែសេចក្តីសុខដ៏ល្អិតឧត្តម ។ ព្រះឧទាយីមានអាយុ បាននិយាយនឹងជាងឈើឈ្មោះបញ្ចកង្គៈជាគម្រប់ ៣ ដងទៀតថា ម្នាលគហបតី ព្រះមានព្រះភាគមិនទ្រង់សម្តែងតែត្រឹមវេទនា ២ ទេ វេទនា ៣ គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ក៏ព្រះមានព្រះភាគទ្រង់សម្តែងដែរ ម្នាលគហបតី វេទនា ៣ នេះឯង ព្រះមានព្រះភាគទ្រង់សម្តែងហើយ ។ ជាងឈើឈ្មោះបញ្ចកង្គៈ បាននិយាយនឹងព្រះឧទាយីមានអាយុ ជាគម្រប់ ៣ ដងទៀតថា បពិត្រព្រះឧទាយីដ៏ចម្រើន វេទនា ៣ ព្រះមានព្រះភាគមិនបានសម្តែងទេ ព្រះមានព្រះភាគទ្រង់សម្តែងតែវេទនា ២ គឺសុខវេទនា ១ ទុក្ខវេទនា ១ បពិត្រលោកដ៏ចម្រើន ឯអទុក្ខមសុខវេទនានោះ ព្រះមានព្រះភាគទ្រង់សម្តែងចំពោះតែសេចក្តីសុខដ៏ល្អិតឧត្តម ។ ព្រះឧទាយីមានអាយុ មិនអាចធ្វើជាងឈើឈ្មោះបញ្ចកង្គៈ ឲ្យយល់បានឡើយ ចំណែកខាងជាងឈើឈ្មោះបញ្ចកង្គៈសោត ក៏មិនអាចធ្វើព្រះឧទាយីមានអាយុឲ្យយល់បានដែរ ។

[ ៩៩ ] ព្រះអានន្ទមានអាយុ បានឮពាក្យចរចានេះ របស់ព្រះឧទាយី

មានអាយុ ជាមួយនឹងជាងឈើឈ្មោះបញ្ចកង្គៈ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ព្រះអានន្ទមានអាយុ លុះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលនូវពាក្យចរចារបស់ព្រះឧទាយីមានអាយុទាំងប៉ុន្មាន ដែលបានចរចាជាមួយនឹងជាងឈើឈ្មោះបញ្ចកង្គៈទាំងអស់នោះ ចំពោះព្រះមានព្រះភាគ ។ កាលព្រះអានន្ទ ពោលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់មានព្រះតម្រាស់នឹងព្រះអានន្ទមានអាយុដូច្នេះថា ម្នាលអានន្ទ ជាងឈើឈ្មោះបញ្ចកង្គៈ មិនអនុមោទនា ចំពោះបរិយាយដ៏ល្អិតហ្មត់ចត់របស់ឧទាយីភិក្ខុ ចំណែកខាងឧទាយីភិក្ខុសោត ក៏មិនបានអនុមោទនា ចំពោះបរិយាយដ៏ល្អិតហ្មត់ចត់ របស់ជាងឈើឈ្មោះបញ្ចកង្គៈដែរ ម្នាលអានន្ទ វេទនាពីរ ក៏តថាគតបានសម្តែងដោយបរិយាយ វេទនា ៣ ក៏តថាគតបានសម្តែងដោយបរិយាយ វេទនា ៤ ក៏តថាគតបានសម្តែងដោយបរិយាយ វេទនា ៥ ក៏តថាគតបានសម្តែងដោយបរិយាយ វេទនា ៦ ក៏តថាគតបានសម្តែងដោយបរិយាយ វេទនា ១៨ ក៏តថាគតបានសម្តែងដោយបរិយាយ វេទនា ៣៦ ក៏តថាគតបានសម្តែងដោយបរិយាយ វេទនា ១០៨ ក៏តថាគតបានសម្តែងដោយបរិយាយ ម្នាលអានន្ទ ធម៌ក៏តថាគតបានសម្តែងដោយបរិយាយ យ៉ាងនេះឯង ម្នាលអានន្ទ កាលបើធម៌ គឺតថាគតសម្តែងហើយដោយបរិយាយយ៉ាងនេះ ជនទាំងឡាយណា មិនដឹងតាម មិនយល់ព្រម មិនរីករាយ ចំពោះភាសិត និងពាក្យចរចាដ៏ពីរោះ នៃគ្នានិងគ្នាហើយ

ការបន្តុហេតុ ការឈ្លោះ ការទាស់ទែង និងការពោលបាក់ដោតគ្នានិងគ្នា ដោយលំពែង គឺមាត់ក៏ប្រាកដដល់ជនទាំងនោះ ដូច្នេះ ម្នាលអានន្ទ ធម៌តថាគត បានសម្តែងហើយដោយបរិយាយយ៉ាងនេះឯង ម្នាលអានន្ទ កាលបើធម៌ គឺ តថាគតសម្តែងដោយបរិយាយយ៉ាងនេះហើយ ជនទាំងឡាយណា នឹងដឹង តាម យល់ព្រមតាម រីករាយតាមចំពោះសុភាសិត និងពាក្យចរចាដ៏ពីរោះនៃ គ្នានិងគ្នាហើយ ការព្រមព្រៀងគ្នា ការរីករាយរាក់ទាក់រកគ្នា ការមិនទាស់ទែង គ្នា ដូចទឹកលាយដោយទឹកដោះស្រស់ មើលគ្នានិងគ្នាដោយភ្នែកជាទីស្រឡាញ់ ក៏នឹងប្រាកដដល់ជនទាំងឡាយនោះ ។

[ ១០០ ] ម្នាលអានន្ទ កាមគុណទាំងឡាយនេះ មាន ៥ យ៉ាង កាមគុណទាំងឡាយ ៥ តើដូចម្តេច គឺរូបទាំងឡាយ ដែលគប្បីដឹងដោយ ភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ប្រកប ដោយកាម ជាទីរីករាយ សំឡេងទាំងឡាយ ដែលគប្បីដឹងដោយត្រចៀក ... ក្លិនទាំងឡាយ ដែលគប្បីដឹងដោយច្រមុះ ... រសទាំងឡាយ ដែលគប្បីដឹង ដោយអណ្តាត ... ផោដ្ឋព្វៈទាំងឡាយ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម ជាទីរីករាយ ម្នាលអានន្ទ កាមគុណមាន ៥ យ៉ាងនេះឯង ។ ម្នាលអានន្ទ សេចក្តីសុខ សោមនស្សណាមួយ កើតឡើងព្រោះអាស្រ័យកាមគុណទាំង-ឡាយ ៥ នេះ សេចក្តីសុខ សោមនស្សនេះ ហៅថា កាមសុខ ។

[ ១០១ ] ម្នាលអានន្ទ បុគ្គលណាមួយ គប្បីពោលយ៉ាងនេះថា សត្វ

ទាំងឡាយ តែងទទួលសេចក្តីសុខ និងសោមនស្ស មានកំណត់អស់ត្រឹមប៉ុណ្ណេះ ពាក្យនេះរបស់បុគ្គលនោះ តថាគតមិនបានយល់តាមទេ ការដែលមិនយល់តាមនោះ ព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះថាសេចក្តីសុខដទៃដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ នៅមានទៀត ។ ម្នាលអានន្ទ មានសេចក្តីសុខដទៃដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនេះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ គឺនីវរណៈ ៥ ក៏បានដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្ក និងវិចារៈ មានបីតិ និងសុខកើតអំពីសេចក្តីស្ងាត់ចាកនីវរណធម៌ ទើបសម្រេចសម្រាន្តនៅដោយស្រួល ម្នាលអានន្ទ នេះឯងជាសេចក្តីសុខដទៃដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ បុគ្គលណាមួយគប្បីពោលយ៉ាងនេះថា សត្វទាំងឡាយ តែងទទួលសេចក្តីសុខ និងសោមនស្ស អស់ត្រឹមប៉ុណ្ណេះ ពាក្យនេះ របស់បុគ្គលនោះ តថាគតមិនយល់តាមទេ ការមិនយល់តាមនោះ តើព្រោះហេតុដូចម្តេច ម្នាលអានន្ទ ព្រោះថា សេចក្តីសុខដទៃដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ នៅមានទៀត ។ ម្នាលអានន្ទ សេចក្តីសុខដទៃដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះរម្ងាប់នូវវិតក្ក និងវិចារៈ ក៏ដល់នូវទុតិយជ្ឈាន ជាធម្មជាតមានប្រាកដក្នុងខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា ជាសភាពនៃចិត្តដ៏ខ្ពស់ឯក ឥតមានវិតក្ក និងវិចារៈ មានតែបីតិ និងសុខកើតអំពីសមាធិ ។បេ។ បានដល់

នូវតតិយជ្ឈាន ... បានដល់នូវចតុត្ថជ្ឈាន ក៏សម្រេចសម្រាន្តនៅដោយស្រួល ម្នាលអានន្ទ នេះឯង ជាសេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាង សេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវរូបសញ្ញា ព្រោះកម្ចាត់បង់នូវបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយកិរិយាធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ម្នាលអានន្ទ នេះឯង ជាសេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ សេចក្តីសុខដទៃដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ ម្នាលអានន្ទ នេះឯង ជាសេចក្តីសុខជាងសេចក្តីសុខនុ៎ះ ។បេ។ ម្នាលអានន្ទ សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វត្ថុបន្តិចបន្តួចមិនមាន ដូច្នេះ ម្នាលអានន្ទ នេះឯង ជាសេចក្តីសុខជាងសេចក្តីសុខនុ៎ះ ។បេ។ ម្នាលអានន្ទ សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវអាកិញ្ចញ្ញាយត-

នជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ម្នាលអានន្ទ នេះឯង ជាសេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ ។

[ ១០២ ] ម្នាលអានន្ទ បុគ្គលណាគប្បីពោលយ៉ាងនេះថា សត្វទាំងឡាយ តែងទទួលនូវសេចក្តីសុខ និងសោមនស្ស អស់កំណត់ត្រឹមតែប៉ុណ្ណោះ ពាក្យនេះ របស់បុគ្គលនោះ តថាគតមិនយល់តាមទេ ការមិនយល់តាមនោះ តើព្រោះហេតុដូចម្តេច ម្នាលអានន្ទ ព្រោះថា សេចក្តីសុខដទៃដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះនៅមានទៀត ។ ម្នាលអានន្ទ សេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លាជាងសេចក្តីសុខនុ៎ះ តើដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ទើបបានដល់នូវសញ្ញាវេទយិតនិរោធ ម្នាលអានន្ទ នេះឯង ជាសេចក្តីសុខដទៃ ដ៏ប្រសើរថ្លៃថ្លា ឧត្តមថ្លៃថ្លា ជាងសេចក្តីសុខនុ៎ះ ។ ម្នាលអានន្ទ ហេតុនេះតែងមានប្រាកដ ត្រង់ពាក្យដែលពួកបរិព្វាជក ជាអន្យតិរ្ថិយនិយាយយ៉ាងនេះថា ព្រះសមណគោតម ពោលអាងនូវសញ្ញាវេទយិតនិរោធ បញ្ញត្តនូវសញ្ញាវេទយិតនិរោធនោះ ថាជាសេចក្តីសុខ តើអ្វីជាសញ្ញាវេទយិតនិរោធនោះ សញ្ញាវេទយិតនិរោធនោះ តើដូចម្តេច ម្នាលអានន្ទ ( បើ ) ពួកបរិព្វាជក ជាអន្យតិរ្ថិយនិយាយយ៉ាងនេះ អ្នកគប្បីពោលតបយ៉ាងនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគមិនបានបញ្ញត្ត ( នូវសញ្ញាវេទយិតនិរោធ ) ថាជាសេចក្តីសុខ ព្រោះសំដៅយកសុខវេទនា ( នោះ ) ទេ ម្នាលអាវុសោ

មួយទៀត បុគ្គលតែងបានសេចក្ដីសុខ ក្នុងទីណាៗ ព្រះតថាគតក៏បញ្ញត្តនូវសញ្ញាវេទយិតនិរោធ ថាជាសេចក្ដីសុខត្រង់ទីនោះៗ ។ លុះព្រះមានព្រះភាគទ្រង់សម្ដែងសុភាសិតនោះចប់ហើយ ព្រះអានន្ទមានអាយុ ក៏ពេញចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## ពហុវេទនីយសូត្រទី ៩ ចប់

# អដ្ឋកថា

## ពហុវេទនិយសូត្រទី ៩

[ ៩៧ ] ពហុវេទនិយសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបណ្ដាបទទាំងនោះ បទថា **បញ្ចកង្គ** ក្នុងបទថា **បញ្ចកង្គោ ថបតិ** ជាឈ្មោះរបស់ជាងឈើនោះ គេដឹងទូទៅថាបញ្ចកង្គៈ ក៏ព្រោះជាអ្នកប្រកបដោយឧបករណ៍ ៥ យ៉ាង ពោល គឺកាំបិត ពូថៅ ពន្លាក ញញួរ និងខ្សែបន្ទាត់ ។ បទថា **ថបតិ** គឺជាប្រធាននៃពួកជាងឈើ ។ បទថា **ឧទាយី** គឺព្រះឧទាយិត្ថេរដែលជាបណ្ឌិត ។

[ ៩៩ ] បទថា **បរិយាយំ** ប្រែថា ហេតុ ។ បទថា **ទ្វេបានន្ទ** កាត់បទជា **ទ្វេបិ អានន្ទ** ។ បទថា **បរិយាយេន** គឺដោយហេតុ ។

បណ្ដាវេទនាទាំងនោះ គប្បីជ្រាបថា វេទនា មាន ២ គឺវេទនាដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងផ្លូវចិត្ត ។ មាន ៣ គឺសុខវេទនាជាដើម[១] ។ ពោលដោយឥន្ទ្រិយមាន ៥ គឺសុខិន្ទ្រិយជាដើម ពោលដោយទ្វារមាន ៦ គឺចក្ខុសម្ផស្សជាវេទនាជាដើម ពោលដោយឧបវិចារ មាន ១៨ គឺឃើញរូបដោយចក្ខុ ហើយក៏តាមពិចារណារូបដែលជាទីតាំងនៃសោមនស្ស ដូច្នេះ ។ មាន ៣៦ យ៉ាង គឺសោមនស្សដែលអាស្រ័យផ្ទះ ៦ សោមនស្សដែលអាស្រ័យនេក្ខម្មៈ ៦ ទោមនស្សដែល អាស្រ័យផ្ទះ ៦ ទោមនស្សដែលអាស្រ័យនេក្ខម្មៈ ៦ ឧបេក្ខាដែលអាស្រ័យផ្ទះ ៦ ឧបេក្ខាដែលអាស្រ័យ

---

១- ឯវេទនា ៤ មិនឃើញមានអដ្ឋកថាពន្យល់ឡើយ ។

នៃកម្ម: ៦ គប្បីជ្រាបវេទនាទាំងនោះ គឺអតីត ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ រួមជា ១០៨ ។

[ ១០០ ] ព្រះវាចាថា **បញ្ច ខោ ឥមេ អានន្ទ កាមគុណា** នេះ ជាអនុសន្ធិ បែកម្នាក់មួយចំណែក ពិតហើយ ព្រះមានព្រះភាគទ្រង់មិនមែនបញ្ញត្តវេទនា តាំងរៀងគ្នា ២ ប៉ុណ្ណោះទេ ទ្រង់ត្រាស់វេទនា ១ ដោយបរិយាយក៏មាន កាលទ្រង់សម្តែងវេទនានោះ ទើបទ្រង់ផ្តើមទេសនានេះ ដើម្បីឧបការៈពាក្យរបស់នាយជាងឈើ ឈ្មោះបញ្ចកង្គ: ។ បទថា **អភិក្កន្តតរំ** ប្រែថា ល្អជាង ។ បទថា **បណីតតរំ** ប្រែថា សមគួរជាង ។ ក្នុងវេទនាទាំងនោះឯង ត្រាស់ហៅថា អទុក្ខមសុខវេទនា តាំងអំពីចតុត្ថជ្ឈាន ។ អទុក្ខមសុខ-វេទនានោះ ត្រាស់ហៅថា **សុខ** ព្រោះអត្ថថា ស្ងប់ និងព្រោះអត្ថថា ប្រណីត ។ សោមនស្សដែលអាស្រ័យផ្ទះ ៦ ត្រាស់ហៅថា សុខ ។ និរោធ ឈ្មោះថា សុខ ព្រោះជាសុខដែលមិនមានអ្នកសោយ ។ ពិតហើយ សុខដែលកើតដោយអំណាចកាមគុណ ៥ និងដោយអំណាចសមាបត្តិ ៨ ឈ្មោះថា សុខដែលមានអ្នកសោយ ។ និរោធ ឈ្មោះថា សុខដែលមិនមានអ្នកសោយ ។ ដូច្នោះ មិនថាសុខដែលមានអ្នកសោយ ឬសុខដែលមិនមានអ្នកសោយឡើយ ក៏ចាត់ថា ជាសុខតែម្យ៉ាងនោះឯង ព្រោះអត្ថថា ជាសុខពោល គឺភាវៈដែលមិនមានទុក្ខ ។ បទថា **យត្ថ យត្ថ** ប្រែថា ក្នុងទីណាមួយ ។ បទថា **សុខំ ឧបលព្ភតិ** សេចក្តីថា រមែងកើតសុខដែលមានអ្នកសោយខ្លះ សុខដែលមិនមានអ្នកសោយខ្លះ ។ បទថា តថាគតរមែងបញ្ញត្ត

សុខនោះៗ ក្នុងសុខ គឺតថាគតរមែងបញ្ញត្តការៈ ដែលមិនមានទុក្ខទាំងអស់ នោះ ក្នុងសុខតែម្យ៉ាង ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើនិរោធសមាបត្តិឲ្យជាប្រធាន ហើយបញ្ចប់ទេសនា ដោយអគ្គធម៌ គឺព្រះអរហត្ត ដោយអំណាចវេនេយ្យបុគ្គល ដូច្នេះ ៕៚

## ពហុវេទនិយសូត្រ ចប់

## សូត្រទី ៩ ចប់

# សុត្តន្តបិដក

## អបណ្ណកសូត្រទី ១០

[ ១០៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងដែនកោសល មួយអន្លើដោយភិក្ខុសង្ឃច្រើន ក៏បានដល់ព្រាហ្មណគ្រាម ឈ្មោះសាលារបស់ពួកអ្នកកោសល ។ ពួកព្រាហ្មណ៍ និងគហបតីអ្នកស្រុកសាលា ក៏និយាយគ្នាថា ម្នាលគ្នាយើង ឮថា ព្រះសមណគោតម ជាសក្យបុត្ត ចេញចាកសក្យត្រកូលទ្រង់ព្រះផ្នួស ( ឥឡូវ ) ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុនដែនកោសល មួយអន្លើដោយភិក្ខុសង្ឃដ៏ច្រើន បានមកដល់សាលគ្រាមហើយ ។ កិត្តិសព្ទដ៏ល្អ នៃព្រះគោតមដ៏ចម្រើននោះ ឮខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ទ្រង់ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ទ្រង់បានត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ទ្រង់បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញា ចំពោះព្រះអង្គនូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយប្រកាស ទ្រង់សម្តែងនូវធម៌មានលម្អបទដើម បទ

កណ្តាល និងបទចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ក៏ការដែលបានឃើញ បានចួបនឹងព្រះអរហន្តទាំងឡាយមានសភាពដូច្នោះ ជាការប្រពៃណាស់ ។ លំដាប់នោះ ពួកព្រាហ្មណ៍ និងគហបតីអ្នកស្រុកសាលា ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ អ្នកខ្លះក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ អ្នកខ្លះក៏ពោលពាក្យសំណេះសំណាលរាក់ទាក់ ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យជាទីរីករាយ និងពាក្យជាទីរឭកហើយ អង្គុយក្នុងទីសមគួរ អ្នកខ្លះក៏អង្គុយក្នុងទីសមគួរ ប្រណម្យអញ្ជលីឆ្ពោះទៅព្រះមានព្រះភាគ អ្នកខ្លះក៏អង្គុយក្នុងទីសមគួរ ប្រកាសនាម និងគោត្រឲ្យឮ ក្នុងសម្នាក់នៃព្រះមានព្រះភាគ អ្នកខ្លះក៏អង្គុយនៅស្ងៀមក្នុងទីសមគួរ ។

[ ១០៤ ] លុះសាលេយ្យកព្រាហ្មណគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតីទាំងឡាយ ចុះអ្នកទាំងឡាយ មានគ្រូណាមួយ ជាទីគាប់ចិត្ត ល្មមឲ្យអ្នកទាំងឡាយមានសទ្ធាប្រកបដោយហេតុដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងឡាយ មិនមានគ្រូណាមួយ ជាទីគាប់ចិត្ត ល្មមឲ្យយើងខ្ញុំទាំងឡាយ មានសទ្ធាប្រកបដោយហេតុទេ ។ ម្នាលគហបតីទាំងឡាយ កាលបើអ្នកទាំងឡាយ មិនបានគ្រូជាទីគាប់ចិត្តហើយ ត្រូវប្រព្រឹត្តសមាទាននូវអបណ្ណកធម៌នេះវិញ ម្នាលគហបតីទាំងឡាយ ព្រោះថា អបណ្ណកធម៌ ដែលអ្នកទាំងឡាយបានធ្វើឲ្យបរិបូណ៌ បានសមាទានហើយ ជាធម៌ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បី

សេចក្ដីសុខ ដល់អ្នកទាំងឡាយ អស់កាលជាយូរអង្វែង ។ ម្នាលគហបតីទាំងឡាយ អបណ្ណកធម៌ តើដូចម្ដេច ។

[ ១០៥ ] ម្នាលគហបតីទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ និងធ្វើអាក្រក់មិនមាន លោកនេះមិនមាន បរលោកមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ សត្វទាំងឡាយជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ ជាអ្នកព្រមព្រៀងប្រតិបត្តិត្រឹមត្រូវ បានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញារបស់ខ្លួន នូវលោកនេះ និងបរលោកហើយ ប្រកាសបានក្នុងលោកនេះមិនមាន ម្នាលគហបតីទាំងឡាយ បណ្ដាសមណ-ព្រាហ្មណ៍ទាំងនោះ មានសមណព្រាហ្មណ៍ពួកមួយ មានវាទៈជាសឹកសត្រូវដោយត្រង់ ( ខុសទីទៃពីគ្នា ) ពោលទៅរកសមណព្រាហ្មណ៍ទាំងនោះវិញថា ទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាករបស់កម្មដែលសត្វធ្វើល្អ និងធ្វើអាក្រក់មាន លោកនេះមាន បរលោកមាន មាតាមានគុណ បិតាមានគុណ សត្វទាំងឡាយជាឱបបាតិកៈមាន ពួកសមណព្រាហ្មណ៍ ជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិត្រឹមត្រូវ បានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញារបស់ខ្លួននូវលោកនេះ និងបរលោក ហើយប្រកាសបានក្នុងលោកនេះមាន ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវហេតុនោះដូចម្ដេច ក្រែងសមណព្រាហ្មណ៍ទាំងឡាយនេះ ពោលពាក្យជា

សឹកសត្រូវដោយត្រង់ទៅរកគ្នានិងគ្នាមែនឬ ។ ព្រះករុណាព្រះអង្គ ។

[ ១០៦ ] ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល ។បេ។ បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញារបស់ខ្លួនឯង នូវលោកនេះ និងបរលោក ហើយប្រកាសបាន ក៏មិនមាន ហេតុនោះ ក៏ប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ ( សមណព្រាហ្មណ៍ទាំងនោះ ) ក៏លះបង់នូវកុសលធម៌ទាំង ៣ នេះ គឺកាយសុចរិត វចីសុចរិត មនោសុចរិត ហើយសមាទាន ប្រព្រឹត្តនូវអកុសលធម៌ទាំង ៣ នេះ គឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតវិញ ការប្រព្រឹត្តនោះ ព្រោះហេតុដូចម្តេច ព្រោះថា ពួកសមណ-ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ មិនឃើញទោស នៃអកុសលធម៌ទាំងឡាយ ដ៏លាមក ដ៏សៅហ្មង ព្រមទាំងមិនឃើញអានិសង្សនៃកុសលធម៌ទាំងឡាយជាចំណែកនៃសេចក្តីផូរផង់ ក្នុងកិរិយាចេញចាកកាម ។ បុគ្គលមានសេចក្តីយល់ឃើញបរលោកដែលមានប្រាកដមែនថា បរលោកមិនមានវិញ សេចក្តីយល់ឃើញរបស់អ្នកនោះ ឈ្មោះថាមិច្ឆាទិដ្ឋិ ។ បុគ្គលត្រិះរិះនូវបរលោកដែលមានប្រាកដមែនថា បរលោកមិនមានទៅវិញ សេចក្តីត្រិះរិះរបស់បុគ្គលនោះ ឈ្មោះថា មិច្ឆាសង្កប្ប ។ បុគ្គលពោលវាចាចំពោះបរលោក ដែលមានពិតប្រាកដមែនថា បរលោកមិនមានទៅវិញ វាចារបស់បុគ្គលនោះ ឈ្មោះថា មិច្ឆាវាចា ។ បុគ្គលពោលនូវបរលោកដែលមានពិតមែនថា បរលោកមិនមាន

ទៅវិញ បុគ្គលនេះ ឈ្មោះថាធ្វើសឹកសត្រូវចំពោះព្រះអរហន្តទាំងឡាយ ដែលជាអ្នកជ្រាបច្បាស់នូវបរលោក ។ បុគ្គលណា ពន្យល់អ្នកដទៃឲ្យយល់បរលោក ដែលមានពិតមែនថា បរលោកមិនមានទៅវិញ ការពន្យល់នោះ របស់បុគ្គលនោះ ឈ្មោះថា អសទ្ធម្មសញ្ញត្តិ គឺការពន្យល់ខុសចាកព្រះសទ្ធម្ម ហើយលើកតម្កើងខ្លួនឯង បន្អាប់បុគ្គលដទៃ ដោយអសទ្ធម្មសញ្ញត្តិនោះ ។ មួយវិញទៀត បុគ្គលលះបង់នូវភាវៈជាអ្នកមានសីលល្អក្នុងកាលមុន ហើយតាំងទុកនូវភាវៈជាអ្នកទ្រុស្តសីលវិញ នេះឈ្មោះថា មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្ប មិច្ឆាវាចា ជាសឹកសត្រូវនឹងព្រះអរិយៈទាំងឡាយ ជាសទ្ធម្មសញ្ញត្តិ ហៅថា លើកតម្កើងខ្លួនឯង បន្អាប់បុគ្គលដទៃ ។ ធម៌ជាអកុសលដ៏លាមកមានច្រើនទាំងអម្បាលនេះ កើតឡើងព្រម ព្រោះមានមិច្ឆាទិដ្ឋិជាបច្ច័យយ៉ាងនេះ ។

[ ១០៧ ] ម្នាលគហបតីទាំងឡាយ វិញ្ញូបុរសតែងពិចារណាឃើញក្នុងលទ្ធិរបស់ពួកសមណព្រាហ្មណ៍នោះ ដូច្នេះថា បើបរលោកមិនមានទេ បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ នឹងធ្វើខ្លួនឲ្យសួស្តីបានយ៉ាងនេះ បើបរលោកមានមែន បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ មុខជានឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក យ៉ាងនេះមិនខាន ។ បើបរលោកមិនមានដោយពិត ពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឈ្មោះថាជាពាក្យពិត តែថាបុរសបុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំងឡាយ លោកតិះដៀលក្នុងបច្ចុប្បន្ននេះថា បុរសបុគ្គលដ៏ចម្រើននេះ ជាអ្នកទ្រុស្តសីល ជាមិច្ឆាទិដ្ឋិ ជា

នត្ថិកវាទ ។ បើបរលោកមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ ទទួលចាញ់ក្នុងចំណែកទាំងពីរ គឺអ្នកប្រាជ្ញទាំងឡាយតិះដៀលក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ។ អបណ្ណកធម៌ ដែលបុគ្គលធ្វើមិនពេញលេញ សមាទានមិនល្អហើយ រមែងផ្សាយទៅតាមវាទៈរបស់ខ្លួន ដោយចំណែកមួយ ហើយវៀរបង់នូវហេតុជាទីតាំងនៃកុសលយ៉ាងនេះ ។

[ ១០៨ ] ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយ មានផល ។បេ។ សមណព្រាហ្មណ៍ទាំងឡាយណា បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញារបស់ខ្លួននូវលោកនេះ និងបរលោក ហើយប្រកាសបាន ក៏មាន ហេតុនោះ ក៏ប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ ( សមណព្រាហ្មណ៍ទាំងនោះ ) បានលះបង់អកុសលធម៌ទាំង ៣ នេះ គឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ហើយសមាទានប្រព្រឹត្តនូវកុសលធម៌ទាំងឡាយ ៣ គឺកាយសុចរិត វចីសុចរិត មនោសុចរិតវិញ ដំណើរនោះព្រោះហេតុដូចម្តេច ព្រោះថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើននោះ បានឃើញទោសនៃអកុសលធម៌ទាំងឡាយ ដ៏ថោកទាប សៅហ្មង ឃើញនូវអានិសង្សនៃកុសលធម៌ទាំងឡាយ ជាចំណែកនៃសេចក្តីផូរផង់ ក្នុងកិរិយាចេញចាកកាម ។ បរលោកមានពិតមែន បុគ្គលនោះមានសេចក្តីយល់ឃើញថា បរលោកមានមែន សេចក្តីយល់ច្បាស់ របស់បុគ្គលនោះ ឈ្មោះថា

សម្មាទិដ្ឋិ ។ បុគ្គលត្រិះរិះនូវបរលោកដែលមានពិតមែនថា បរលោកមានមែន សេចក្តីត្រិះរិះរបស់បុគ្គលនោះ ឈ្មោះថា សម្មាសង្កប្ប ។ បុគ្គលពោលវាចា ចំពោះបរលោកដែលមានពិតមែនថា បរលោកមានមែន វាចារបស់បុគ្គលនោះ ឈ្មោះថា សម្មាវាចា ។ បុគ្គលពោលនូវបរលោកដែលមានពិតមែនថា បរលោកមានមែន បុគ្គលនេះ ឈ្មោះថា មិនធ្វើនូវសឹកសត្រូវដល់ព្រះអរហន្តដែលជាអ្នកជ្រាបច្បាស់ នូវបរលោកទាំងនោះឡើយ ។ បុគ្គលពន្យល់អ្នកដទៃឲ្យយល់នូវបរលោកដែលមានពិតមែនថា បរលោកមានមែន សេចក្តីពន្យល់របស់បុគ្គលនោះ ឈ្មោះថាជាសទ្ធម្មសញ្ញត្តិ គឺការពន្យល់តាមព្រះសទ្ធម្ម ហើយក៏មិនលើកតម្កើងខ្លួនឯង មិនបង្អាប់បុគ្គលដទៃ ដោយសទ្ធម្មសញ្ញត្តិនោះឡើយ ។ មួយវិញទៀត បុគ្គលលះបង់នូវភាវៈជាអ្នកទ្រុស្ត-សីលអំពីកាលមុនពិត ហើយតាំងទុកនូវភាវៈជាអ្នកមានសីលល្អ នេះឈ្មោះថា សម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាចា មិនជាសឹកសត្រូវនឹងព្រះអរិយៈទាំងឡាយ ជាអ្នកពន្យល់តាមព្រះសទ្ធម្ម ហៅថា មិនលើកតម្កើងខ្លួនឯង មិនបង្អាប់បុគ្គលដទៃ ។ កុសលធម៌មានច្រើន ទាំងអម្បាលនេះ តែងកើតឡើងព្រម ព្រោះមានសម្មាទិដ្ឋិជាបច្ច័យយ៉ាងនេះ ។

[ ១០៩ ] ម្នាលគហបតីទាំងឡាយ វិញ្ញូបុរសតែងពិចារណាឃើញក្នុងលទ្ធិរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ដូច្នេះថា បើបរលោកមានមែន បុរសបុគ្គលដ៏ចម្រើននេះ បែកធ្លាយរាងកាយបន្ទាប់អំពីមរណៈ មុខជានឹងទៅកាន់សុគតិ សួគ៌ ទេវលោក យ៉ាងនេះ ។ បើបរលោកមិនមានដោយពិតទេ

ពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឈ្មោះថា ជាពាក្យពិត តែជាបុរសបុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំងឡាយ សរសើរក្នុងបច្ចុប្បន្ននេះថា បុរសបុគ្គលដ៏ចម្រើននេះ ជាអ្នកមានសីល ជាសម្មាទិដ្ឋិ ជាអត្ថិកវាទ ។ បើបរលោកមានមែន បុរសបុគ្គលដ៏ចម្រើននេះ ទទួលយកជ័យជម្នះ ក្នុងចំណែកទាំងពីរ គឺអ្នកប្រាជ្ញទាំងឡាយសរសើរក្នុងបច្ចុប្បន្ននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ នឹងទៅកាន់សុគតិ សួគ៌ ទេវលោក ។ អបណ្ណកធម៌នេះដែលបុគ្គលធ្វើឲ្យពេញលេញ សមាទានល្អហើយ ក៏ផ្សាយទៅតាមវាទៈរបស់ខ្លួន ដោយចំណែកទាំងពីរ ហើយវៀរបង់នូវហេតុជាទីតាំងនៃអកុសលបាន ។

[ ១១០ ] ម្នាលគហបតីទាំងឡាយ សមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលធ្វើបាបដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ កាត់ ( នូវអវយវៈគេ ) ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន ធ្វើគេឲ្យសោកសៅ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យសោកសៅ ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យលំបាក ធ្វើគេឲ្យញាប់ញ័រ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យញាប់ញ័រ សម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាន់យកទ្រព្យ ដែលគេមិនបានឲ្យ ( ឬប្រើអ្នកដទៃឲ្យកាន់យក ) កាត់ទី-តផ្ទះ ( ឬប្រើអ្នកដទៃឲ្យកាត់ ) ប្លន់ពួកអ្នកស្រុក ( ឬប្រើអ្នកដទៃឲ្យប្លន់ ) ប្លន់យកទ្រព្យផ្ទះមួយ ( ឬប្រើអ្នកដទៃឲ្យប្លន់ ) ឈរចាំដណ្ដើមទ្រព្យគេក្បែរផ្លូវ ( ឬប្រើអ្នកដទៃឲ្យឈរចាំដណ្ដើម ) លួចភរិយាបុគ្គលដទៃ ( ឬប្រើអ្នកដទៃ

ឲ្យលួច ) ពោលពាក្យកុហក ( ឬប្រើអ្នកដទៃឲ្យកុហក ) ( បុគ្គលនោះ ) ឈ្មោះថា មិនធ្វើបាបទេ ទុកជាបុគ្គលណា ធ្វើសត្វទាំងឡាយលើផែនដីនេះ ដោយគ្រឿងចក្រដែលមានខ្នងកង់ដ៏មុតដូចជាកាំបិតកោរ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ បាបមានអំពើនោះជាហេតុ នៃបុគ្គល ( នោះ ) មិនមានទេ អំពើបាប ក៏មិនមកឲ្យផលដល់បុគ្គលនោះទេ ទុកជាបុគ្គលចូល ទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាត់អវយវៈគេ ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន បាបមានអំពើនោះជាហេតុ នៃបុគ្គលនោះមិនមានឡើយ អំពើបាប ក៏មិនមកឲ្យផលដល់បុគ្គលនោះទេ ទុកជាបុគ្គលចូលទៅកាន់ត្រើយទន្លេគង្គាខាងជើង ហើយឲ្យទាន ឬប្រើអ្នកដទៃឲ្យឲ្យ បូជា ឬប្រើអ្នកដទៃឲ្យបូជា បុណ្យមានអំពើនោះជាហេតុ នៃបុគ្គលនោះមិនមានទេ បុណ្យមិនមកឲ្យផលដល់បុគ្គលនោះឡើយ បុណ្យមិនមានដោយការឲ្យទាន ដោយការទូន្មាននូវឥន្ទ្រិយ ដោយការសង្រួមកាយវាចា ដោយពោលពាក្យសច្ចៈទេ បុណ្យមិនមានមកដល់បុគ្គលនោះទេ ។ ម្នាលគហបតីទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ មានវាទៈជាសឹកសត្រូវដោយត្រង់ ទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយពោលយ៉ាងនេះថា បុគ្គលធ្វើបាប ឬប្រើអ្នកដទៃឲ្យធ្វើ កាត់អវយវៈគេ ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន ធ្វើគេឲ្យសោកសៅ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យសោកសៅ ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃ ឲ្យធ្វើគេឲ្យលំបាក ធ្វើគេឲ្យញាប់ញ័រ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យញាប់ញ័រ

សម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាន់យកទ្រព្យ ដែលគេមិនបានឲ្យ ( ឬប្រើអ្នកដទៃឲ្យកាន់យក ) កាត់ទី-តផ្ទះ ( ឬប្រើអ្នកដទៃឲ្យកាត់ ) ប្លន់ពួកអ្នកស្រុក ( ឬប្រើអ្នកដទៃឲ្យប្លន់ ) ប្លន់យកទ្រព្យតែផ្ទះមួយ ( ឬប្រើអ្នកដទៃឲ្យប្លន់ ) ឈរចាំដណ្តើមទ្រព្យគេក្បែរផ្លូវ ( ឬប្រើអ្នកដទៃឲ្យឈរចាំដណ្តើម ) លួចកិរិយាបុគ្គលដទៃ ( ឬប្រើអ្នកដទៃឲ្យលួច ) ពោលពាក្យកុហក ( ឬប្រើអ្នកដទៃឲ្យកុហក ) ( បុគ្គលនោះ ) ឈ្មោះថា ធ្វើបាប ទុកជាបុគ្គលណាធ្វើសត្វទាំងឡាយ លើផែនដីនេះ ដោយគ្រឿងចក្រដែលមានខ្នងកង់ដ៏មុតដូចជាកាំបិតកោរ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ បាបដែលមានអំពើនោះជាហេតុ តែងមាន បាបនៃបុគ្គល ( នោះ ) មាន ទុកជាបុគ្គលធ្វងទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់នូវសត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាត់អវយវៈគេ ឬប្រើគេឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន បាបមានអំពើនោះជាហេតុ តែងមាន បាបនៃបុគ្គលនោះមាន ចំណែកបុគ្គលធ្វងទៅកាន់ត្រើយទន្លេគង្គាខាងជើង ហើយឲ្យទាន ឬប្រើអ្នកដទៃឲ្យឲ្យ បូជា ឬប្រើអ្នកដទៃឲ្យបូជា បុណ្យមានអំពើនោះជាហេតុ តែងមាន បុណ្យនៃបុគ្គលនោះ មាន បុណ្យមានដោយការឲ្យទាន ដោយការទូន្មាននូវឥន្ទ្រិយ ដោយការសង្រួមកាយវាចា ដោយពោលពាក្យសច្ចៈ បុណ្យនៃបុគ្គល ( នោះ ) តែងមាន ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ សម្គាល់នូវហេតុនោះដូចម្តេច សមណព្រាហ្មណ៍ទាំងនេះ មានវាទៈជាសឹកសត្រូវដោយត្រង់ ទៅវកគ្នានិងគ្នា មិនមែនឬ ។ ព្រះករុណា

ព្រះអង្គ ។

[ ១១១ ] ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលធ្វើបាប ឬប្រើអ្នកដទៃឲ្យធ្វើ កាត់អវយវៈគេ ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន ធ្វើគេឲ្យសោកសៅ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យសោកសៅ ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យលំបាក ធ្វើគេឲ្យញាប់ញ័រ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យញាប់ញ័រ សម្លាប់សត្វ ( ឬប្រើអ្នកដទៃឲ្យសម្លាប់ ) កាន់យកទ្រព្យដែលគេមិនបានឲ្យ ( ឬប្រើគេឲ្យកាន់យក ) កាត់ទី-តផ្ទះ ( ឬប្រើគេឲ្យកាត់ ) ប្លន់ពួកអ្នកស្រុក ( ឬប្រើអ្នកដទៃឲ្យប្លន់ ) ប្លន់យកទ្រព្យតែផ្ទះមួយ ( ឬប្រើអ្នកដទៃឲ្យប្លន់ ) ឈរចាំដណ្តើមទ្រព្យគេក្បែរផ្លូវ ( ឬប្រើអ្នកដទៃឲ្យឈរចាំដណ្តើម ) លួចភរិយាបុគ្គលដទៃ ( ឬប្រើអ្នកដទៃឲ្យលួច ) ពោលពាក្យកុហក ( ឬប្រើអ្នកដទៃឲ្យពោលពាក្យកុហក ) បុគ្គលអ្នកធ្វើនោះ ឈ្មោះថា មិនធ្វើបាប ទុកជាបុគ្គលណា ធ្វើសត្វទាំងឡាយលើផែនដីនេះ ដោយគ្រឿងចក្រ មានខ្នងកង់ដ៏មុត ដូចជាកាំបិតកោរ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកសាច់តែមួយ បាបមានអំពើនោះជាហេតុ តែងមិនមាន បាបមិនមកឲ្យផលឡើយ ទុកជាបុគ្គលចូលទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វ ឬប្រើគេឲ្យសម្លាប់ ។បេ។ បុណ្យមិនមានដោយការឲ្យទាន ដោយការទូន្មានឥន្ទ្រិយ ដោយការសង្រួមកាយវាចា ដោយពោលពាក្យសច្ចៈទេ បុណ្យមិនមកឲ្យផលឡើយ ។ ហេតុ

នេះមានប្រាកដលស់សមណព្រាហ្មណ៍ទាំងនោះ គឺ ( សមណព្រាហ្មណ៍ទាំងនោះ ) លះបង់នូវកុសលធម៌ ៣ នេះ គឺកាយសុចរិត វចីសុចរិត មនោសុចរិត ហើយសមាទានប្រព្រឹត្តនូវអកុសលធម៌ ៣ នេះ គឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតវិញ ដំណើរនោះ ព្រោះហេតុដូចម្តេច ព្រោះថាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើននោះ មិនឃើញនូវទោសរបស់អកុសលធម៌ទាំងឡាយដ៏លាមក សៅហ្មង មិនឃើញនូវអានិសង្សនៃកុសលធម៌ទាំងឡាយ ជាចំណែកនៃសេចក្តីផូរផង់ ក្នុងកិរិយាចេញចាកកាម ។ សេចក្តីយល់ឃើញអំពើដែលមានពិតមែន របស់បុគ្គលនោះថា អំពើមិនមាន ដូច្នេះ សេចក្តីយល់ឃើញរបស់បុគ្គលនោះ ឈ្មោះថា មិច្ឆាទិដ្ឋិ ។ មួយទៀត បុគ្គលត្រិះរិះនូវអំពើដែលមានពិតមែនថា អំពើមិនមាន ដូច្នេះ សេចក្តីត្រិះរិះរបស់បុគ្គលនោះ ឈ្មោះថា មិច្ឆាសង្កប្ប ។ មួយទៀត បុគ្គលណា ពោលវាចាចំពោះអំពើដែលមានមែនពិតថា អំពើមិនមានវិញ វាចារបស់បុគ្គលនោះ ឈ្មោះថា មិច្ឆាវាចា ។ មួយទៀត បុគ្គលណាពោលនូវអំពើដែលមានពិតថា អំពើមិនមានវិញ បុគ្គលនេះ ឈ្មោះថាធ្វើសឹកសត្រូវចំពោះព្រះអរហន្តដែលជាកិរិយវាទ ។ មួយវិញទៀត បុគ្គលពន្យល់អ្នកដទៃឲ្យយល់ នូវអំពើដែលមានពិតថា អំពើមិនមានវិញ ការពន្យល់របស់បុគ្គលនោះ ឈ្មោះថាអសទ្ធម្មសញ្ញត្តិ ឯបុគ្គលនោះ ឈ្មោះថាលើកតម្កើងខ្លួនឯង បង្អាប់បុគ្គលដទៃដោយសារអសទ្ធម្មសញ្ញត្តិនោះ ។ ព្រោះហេតុនោះ បុគ្គលនោះលះបង់នូវភាវៈនៃសីលល្អក្នុងកាលមុនចោល ហើយតាំងទុកនូវភាវៈជាអ្នកទ្រុស្តសីលវិញ នេះ

ឈ្មោះថា មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្ប មិច្ឆាវាចា ជាសឹកសត្រូវនឹងព្រះអរិយៈទាំងឡាយ ជាអសទ្ធម្មសញ្ញត្តិ ឈ្មោះថា លើកតម្កើងខ្លួនឯង បន្ទុះបង្អាប់បុគ្គលដទៃ ។ អកុសលធម៌ទាំងឡាយដ៏លាមក ច្រើនប្រការទាំងនេះ តែងកើតឡើងព្រម ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យយ៉ាងនេះឯង ។

[ ១១២ ] ម្នាលគហបតីទាំងឡាយ វិញ្ញូបុរសតែងពិចារណាឃើញក្នុងលទ្ធិរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ដូច្នេះថា បើអំពើមិនមានទេ កាលបើយ៉ាងនេះ បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅនឹងធ្វើខ្លួនឲ្យសួស្តីបាន ។ តែបើអំពើមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក មិនលែងឡើយ ។ បើអំពើមិនមានដោយពិត ពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឈ្មោះថាជាពាក្យពិត តែថា បុរសបុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំងឡាយគប្បីតិះដៀលក្នុងបច្ចុប្បន្ននេះថា បុរសបុគ្គលនេះ ជាអ្នកទ្រុស្តសីល ជាមិច្ឆាទិដ្ឋិ ជាអកិរិយវាទ ។ ប្រសិនណាបើអំពើមានមែនពិត បុរសបុគ្គលដ៏ចម្រើននេះ ទទួលចាញ់ក្នុងចំណែកទាំងពីរ គឺអ្នកប្រាជ្ញទាំងឡាយតិះដៀលក្នុងបច្ចុប្បន្ននេះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ នឹងកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកមិនខាន ។ អបណ្ណកធម៌នេះ ដែលបុគ្គលនោះ ធ្វើមិនពេញលេញសមាទានមិនល្អហើយ រមែងផ្សាយទៅតាមវាទៈរបស់ខ្លួន ដោយចំណែកមួយ វៀរបង់នូវហេតុជាទីតាំងនៃកុសលយ៉ាងនេះឯង ។

[ ១១៣ ] ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុគ្គលធ្វើបាប ឬប្រើគេឲ្យធ្វើ កាត់អវយវៈគេ ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន ធ្វើគេឲ្យសោកសៅ ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យសោកសៅ ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យលំបាក ធ្វើគេឲ្យញាប់ញ័រ ឲ្យប្រើអ្នកដទៃឲ្យធ្វើគេឲ្យញាប់ញ័រ សម្លាប់សត្វខ្លួនឯង ( ឬប្រើអ្នកដទៃឲ្យសម្លាប់ ) កាន់យកទ្រព្យ ដែលគេមិនបានឲ្យ ( ឬប្រើគេឲ្យកាន់យក ) កាត់ទី-តផ្ទះ ( ឬប្រើអ្នកដទៃឲ្យកាត់ ) ប្លន់ពួកអ្នកស្រុក ( ឬប្រើអ្នកដទៃឲ្យប្លន់ ) ប្លន់យកទ្រព្យតែផ្ទះ ១ ( ឬប្រើគេឲ្យប្លន់ ) ឈរចាំដណ្តើមទ្រព្យគេក្បែរផ្លូវ ( ឬប្រើអ្នកដទៃឲ្យឈរចាំដណ្តើម ) លួចភរិយាបុគ្គលដទៃ ( ឬប្រើអ្នកដទៃឲ្យលួច ) ពោលពាក្យកុហក ( ឬប្រើអ្នកដទៃឲ្យកុហក ) បុគ្គលអ្នកធ្វើនោះ ឈ្មោះថា ធ្វើបាប ទោះបីបុគ្គលណា ធ្វើសត្វលើផែនដីនេះ ដោយគ្រឿងចក្រមានខ្នងកង់ដ៏មុតដូចជាកាំបិតកោរ ឲ្យមានគំនរសាច់តែ ១ ឲ្យមានពំនូកសាច់តែ ១ បាបមានអំពើនោះជាហេតុ តែងមានបាបនឹងមកឲ្យផល ទុកជាបុគ្គលនោះ ចូលទៅកាន់ត្រើយទន្លេគង្គាខាងត្បូង ហើយសម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាត់អវយវៈគេ ឬប្រើគេឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន បាបមានអំពើនោះជាហេតុ តែងមាន បាបនឹងមកឲ្យផល ចំណែកបុគ្គលចូលទៅកាន់ត្រើយទន្លេគង្គាខាងជើង ហើយឲ្យទាន ឬប្រើគេឲ្យឲ្យ បូជា ឬប្រើអ្នកដទៃឲ្យបូជា បុណ្យមានអំពើ

នោះជាហេតុ តែងមាន បុណ្យនឹងមកឲ្យផល បុណ្យមានដោយការឲ្យទាន ដោយការទូន្មានឥន្ទ្រិយ ដោយការសង្រួមកាយវាចា ដោយការពោលពាក្យសច្ចៈ បុណ្យនឹងមកឲ្យផល ។ ហេតុនោះមានប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ គឺ ( សមណព្រាហ្មណ៍ទាំងនោះ ) លះបង់នូវអកុសលធម៌ទាំង ៣ នេះ គឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ហើយសមាទានប្រព្រឹត្តនូវកុសលធម៌ទាំង ៣ នេះ គឺកាយសុចរិត វចីសុចរិត មនោសុចរិតវិញ ដំណើរនោះ ព្រោះហេតុដូចម្តេច ព្រោះថា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឃើញទោសរបស់អកុសលធម៌ទាំងឡាយដ៏លាមកសៅហ្មង ឃើញអានិសង្សនៃកុសលធម៌ទាំងឡាយ ជាចំណែកនៃសេចក្តីផូរផង់ ក្នុងកិរិយាចេញចាកកាម ។ មួយទៀត បុគ្គលមានសេចក្តីយល់ឃើញនូវអំពើដែលមានពិតមែនថា អំពើមានពិតមែន សេចក្តីយល់ឃើញរបស់បុគ្គលនោះ ឈ្មោះថាសម្មា-ទិដ្ឋិ ។ មួយទៀត បុគ្គលណា ត្រិះរិះនូវអំពើដែលមានពិតមែនថា អំពើមានពិតមែន សេចក្តីត្រិះរិះរបស់បុគ្គលនោះ ឈ្មោះថា សម្មាសង្កប្ប ។ មួយទៀត បុគ្គលណា ពោលវាចាចំពោះអំពើដែលមានពិតមែនថា អំពើមានពិតមែន វាចារបស់បុគ្គលនោះ ឈ្មោះថា សម្មាវាចា ។ មួយវិញទៀត បុគ្គលណា ពោលនូវអំពើដែលមានពិតមែនថា អំពើមានពិតមែន បុគ្គលនេះឈ្មោះថា មិនធ្វើសឹកសត្រូវ ចំពោះព្រះអរហន្តដែលជាកិរិយវាទឡើយ ។ មួយវិញទៀត បុគ្គលពន្យល់អ្នកដទៃឲ្យយល់នូវអំពើដែលមានពិតមែនថា អំពើមានពិតមែន សេចក្តីពន្យល់របស់បុគ្គលនោះ ឈ្មោះថា សទ្ធម្មសញ្ញត្តិ ៦

បុគ្គលនោះ ឈ្មោះថា មិនលើកតម្កើងខ្លួនឯង មិនបន្ទាប់បុគ្គលដទៃ ដោយសារសទ្ធម្មសញ្ញត្តិនោះ ។ ព្រោះហេតុនោះ បុគ្គលនោះ លះបង់នូវភាវៈទ្រុស្ត-សីលក្នុងកាលមុនចោលហើយ តាំងទុកនូវភាវៈជាអ្នកមានសីលល្អ នេះឈ្មោះថា សម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាចា មិនជាសឹកសត្រូវនឹងព្រះអរិយៈទាំងឡាយ ជាសទ្ធម្មសញ្ញត្តិ ឈ្មោះថា មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់បុគ្គលដទៃ ។ កុសលធម៌ទាំងឡាយ មានច្រើនប្រការទាំងនេះ តែងកើតឡើងព្រម ព្រោះសម្មាទិដ្ឋិជាបច្ច័យយ៉ាងនេះ ។

[ ១១៤ ] ម្នាលគហបតីទាំងឡាយ វិញ្ញូបុរសតែងពិចារណាឃើញក្នុងលទ្ធិរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ដូច្នេះថា បើអំពើមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ នឹងទៅកាន់សុគតិសួគ៌ទេវលោកយ៉ាងនេះ ។ បើអំពើមិនមានដោយពិតទេ ពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឈ្មោះថាជាពាក្យពិត តែថាបុរសបុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំងឡាយសរសើរក្នុងបច្ចុប្បន្ននេះថា បុរសបុគ្គលនេះ ជាអ្នកមានសីល ជាសម្មាទិដ្ឋិ ជាកិរិយវាទ ។ បើអំពើមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ ទទួលយកជ័យជម្នះ ក្នុងចំណែកទាំងពីរ គឺអ្នកប្រាជ្ញទាំងឡាយសរសើរក្នុងបច្ចុប្បន្ននេះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ នឹងបានទៅកាន់សុគតិសួគ៌ទេវលោក ។ អបណ្ណកធម៌ដែលបុគ្គលធ្វើឲ្យពេញលេញ សមាទានល្អហើយ ក៏ផ្សាយទៅតាមវាទៈរបស់ខ្លួនដោយចំណែកទាំងពីរ វៀរបង់នូវហេតុជាទីតាំងនៃអកុសលយ៉ាងនេះ ។

[ ១១៥ ] ម្នាលគហបតីទាំងឡាយ មានសមណព្រាហ្មណ៍ទាំងឡាយពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ហេតុបច្ច័យនាំឲ្យសត្វទាំង-ឡាយសៅហ្មង មិនមានឡើយ សត្វទាំងឡាយរមែងសៅហ្មងដោយឥតហេតុឥតបច្ច័យ ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយបរិសុទ្ធមិនមានឡើយ សត្វទាំង-ឡាយ តែងបរិសុទ្ធដោយឥតហេតុឥតបច្ច័យ កម្លាំងមិនមាន សេចក្តីព្យាយាមមិនមាន កម្លាំងរបស់បុរសក៏មិនមាន សេចក្តីសង្វាតរបស់បុរសក៏មិនមាន ពួកសត្វទាំងអស់ ( មានសត្វឱដ្ឋ គោជាដើម ) បាណៈទាំងអស់ ភូតទាំងអស់ ( មានសត្វកើតក្នុងស្រោមស៊ុតជាដើម ) ជីវៈ គឺធញ្ញជាតិជាដើមទាំងអស់ ឥតមានអំណាច ឥតមានកម្លាំង ឥតមានព្យាយាម មានតែសេចក្តីប្រែប្រួល ដោយនិយតិ សង្គតិ និងភាវៈ ( តាំងនៅ ) ក្នុងអភិជាតិទាំង ៦ ទើបទទួលសុខ និងទុក្ខ ម្នាលគហបតីទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយមានវាទៈជាសឹកសត្រូវដោយត្រង់ ទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយពោលនូវពាក្យយ៉ាងនេះថា ហេតុបច្ច័យ នាំឲ្យសត្វទាំងឡាយសៅហ្មងមានមែន សត្វទាំងឡាយតែងសៅហ្មង ដោយមានហេតុមានបច្ច័យ ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយបរិសុទ្ធ មានមែន សត្វទាំងឡាយតែងបរិសុទ្ធដោយមានហេតុមានបច្ច័យ កម្លាំងក៏មាន ព្យាយាមក៏មាន កម្លាំងរបស់បុរសក៏មាន សេចក្តីសង្វាតរបស់បុរសក៏មាន ពួកសត្វទាំងអស់ បាណៈទាំងអស់ ភូតទាំងអស់ ជីវៈទាំងអស់ មានអំណាច មានកម្លាំង មានព្យាយាម មានសេចក្តីប្រែប្រួល ដោយនិយតិ សង្គតិ និងភាវៈ ( តាំងនៅ ) ក្នុងអភិជាតិ

ទាំង ៦ ទើបទទួលសុខ និងទុក្ខបាន ។ ម្នាលគហបតីទាំងឡាយ អ្នកទាំង-ឡាយសម្គាល់នូវហេតុនោះដូចម្តេច ក្រែងសមណព្រាហ្មណ៍ទាំងនេះ មានវាទៈជាសឹកសត្រូវដោយត្រង់ ដល់គ្នានិងគ្នា មិនមែនឬ ។ ព្រះករុណាព្រះអង្គ ។

[ ១១៦ ] ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ហេតុបច្ច័យ នាំឲ្យសត្វទាំងឡាយសៅហ្មង មិនមានឡើយ សត្វទាំងឡាយនឹងសៅហ្មងដោយឥតហេតុឥតបច្ច័យ ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយបរិសុទ្ធមិនមាន សត្វទាំងឡាយបរិសុទ្ធដោយឥតហេតុឥតបច្ច័យ កម្លាំងមិនមាន សេចក្តីព្យាយាមមិនមាន កម្លាំងនៃបុរសមិនមាន សេចក្តីសង្វាតនៃបុរសមិនមាន សត្វទាំងអស់ បាណៈទាំងអស់ ភូតទាំងអស់ ជីវៈទាំងអស់ ឥតមានអំណាច ឥតមានកម្លាំង ឥតមានព្យាយាម មានតែសេចក្តីប្រែប្រួល ដោយនិយតិ សង្គតិ និងភាវៈ ( តាំងនៅ ) ក្នុងអភិជាតិទាំង ៦ ទើបទទួលសុខនិងទុក្ខបាន ហេតុនេះ ក៏ប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ ( សមណ-ព្រាហ្មណ៍ទាំងនោះ ) លះបង់កុសលធម៌ ៣ នេះ គឺកាយសុចរិត វចីសុចរិត មនោសុចរិត ហើយសមាទានប្រព្រឹត្តអកុសលធម៌ ៣ នេះ គឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតវិញ ដំណើរនោះព្រោះហេតុដូចម្តេច ព្រោះថាសមណ-ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ មិនបានឃើញទោសនៃអកុសលធម៌ទាំងឡាយដ៏លាមក សៅហ្មង ទាំងមិនឃើញអានិសង្សនៃកុសលធម៌ទាំងឡាយ ជាចំណែកនៃសេចក្តីផូរផង់ ក្នុងការចេញចាកកាម ។ មួយទៀត បុគ្គលណា

មានសេចក្តីយល់ឃើញនូវហេតុដែលមានមែនពិតថា ហេតុមិនមាន សេចក្តីយល់របស់បុគ្គលនោះ ឈ្មោះថាមិច្ឆាទិដ្ឋិ ។ មួយទៀត បុគ្គលត្រិះរិះនូវហេតុដែលមានមែនពិតថា ហេតុមិនមាន សេចក្តីត្រិះរិះរបស់បុគ្គលនោះ ឈ្មោះថាមិច្ឆាសង្កប្ប ។ មួយទៀត បុគ្គលពោលវាចាចំពោះហេតុដែលមានមែនពិតថា ហេតុមិនមាន វាចារបស់បុគ្គលនោះ ឈ្មោះថា មិច្ឆាវាចា ។ មួយទៀត បុគ្គលណា ពោលនូវហេតុដែលមានមែនពិតថា ហេតុមិនមាន បុគ្គលនេះ ឈ្មោះថា ធ្វើសឹកសត្រូវចំពោះព្រះអរហន្ត ដែលជាហេតុវាទ ។ មួយទៀត បុគ្គលណា ពន្យល់អ្នកដទៃឲ្យយល់នូវហេតុដែលមានពិតថា ហេតុមិនមាន សេចក្តីពន្យល់របស់បុគ្គលនោះ ឈ្មោះថាអសទ្ធម្មសញ្ញត្តិ ឯបុគ្គលនោះ ឈ្មោះថា លើកតម្កើងខ្លួនឯង តិះដៀលបុគ្គលដទៃ ដោយសារអសទ្ធម្មសញ្ញត្តិនោះ ។ ព្រោះហេតុនោះ បុគ្គលនោះ លះបង់នូវភាវៈជាអ្នកមានសីលល្អក្នុងកាលមុន ហើយតាំងទុកនូវភាវៈជាអ្នកទ្រុស្តសីលវិញ នេះឈ្មោះថា មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្ប មិច្ឆាវាចា ជាសឹកសត្រូវចំពោះព្រះអរិយៈទាំងឡាយ ជាអសទ្ធម្មសញ្ញត្តិ ឈ្មោះថា លើកតម្កើងខ្លួនឯង បង្អាប់បុគ្គលដទៃ ។ អកុសលធម៌ដ៏លាមកច្រើនប្រការទាំងនេះ តែងកើតព្រម ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យយ៉ាងនេះ ។

[ ១១៧ ] ម្នាលគហបតីទាំងឡាយ វិញ្ញូបុរសតែងពិចារណាឃើញក្នុងលទ្ធិរបស់សមណព្រាហ្មណ៍ទាំងនោះថា បើហេតុមិនមានទេ បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ នឹងធ្វើខ្លួនឲ្យមាន

សួស្តី ។ បើហេតុមានមែន បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក មិនខាន ។ មួយទៀត បើហេតុមិនមានដោយពិត ពាក្យរបស់សមណព្រាហ្មណ៍ ដ៏ចម្រើនទាំងនោះ ក៏នៅជាពាក្យពិត តែថា របស់បុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំងឡាយតិះដៀលក្នុងបច្ចុប្បន្ននេះថា បុរសបុគ្គលនេះជាអ្នកទ្រុស្តសីល ជាមិច្ឆាទិដ្ឋិ ជាអហេតុកវាទ ។ បើហេតុមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ ទទួលចាញ់ក្នុងចំណែកទាំងពីរ គឺអ្នកប្រាជ្ញទាំងឡាយ គប្បីតិះដៀលក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក មិនខាន ។ អបណ្ណកធម៌ដែលបុគ្គលធ្វើមិនពេញលេញ សមាទានមិនល្អហើយ ក៏ផ្សាយទៅតាមវាទៈរបស់ខ្លួនដោយចំណែកមួយ វៀរបង់នូវហេតុជាទីតាំងនៃកុសលយ៉ាងនេះ ។

[ ១១៨ ] ម្នាលគហបតីទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ហេតុបច្ច័យនាំឲ្យសត្វសៅហ្មង មានពិតមែន សត្វទាំងឡាយតែងសៅហ្មងដោយមានហេតុមានបច្ច័យ ហេតុបច្ច័យនាំឲ្យសត្វបរិសុទ្ធ មានពិតមែន សត្វទាំងឡាយ តែងបរិសុទ្ធដោយមានហេតុមានបច្ច័យ កម្លាំងមាន សេចក្តីព្យាយាមមាន កម្លាំងរបស់បុរសមាន សេចក្តីសង្វាតនៃបុរសមាន ពួកសត្វទាំងអស់ បាណៈទាំងអស់ ភូតទាំងអស់ ជីវៈទាំងអស់ មានអំណាច មានកម្លាំង មានព្យាយាម មានសេចក្តីប្រែប្រួលដោយនិយតិ សង្គតិ និងភាវៈ

( ឋិតនៅ ) ក្នុងអភិជាតិទាំង ៦ ទើបទទួលសុខ និងទុក្ខបាន ហេតុនោះ ក៏ប្រាកដដល់សមណព្រាហ្មណ៍ទាំងនោះ ( សមណព្រាហ្មណ៍ទាំងនោះ ) លះបង់អកុសល ៣ នេះ គឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ហើយសមាទានប្រព្រឹត្តកុសលធម៌ ៣ នេះ គឺកាយសុចរិត វចីសុចរិត មនោសុចរិតវិញ ដំណើរនោះ ព្រោះហេតុដូចម្តេច ព្រោះថា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឃើញទោសនៃអកុសលធម៌ទាំងឡាយដ៏លាមក សៅហ្មង ឃើញអានិសង្សនៃកុសលធម៌ទាំងឡាយ ជាចំណែកនៃសេចក្តីផូរផង់ ក្នុងកិរិយាចេញចាកកាម ។ មួយទៀត បុគ្គលមានសេចក្តីយល់ឃើញនូវហេតុដែលមានពិតមែនថា ហេតុមានពិតមែន សេចក្តីយល់ឃើញរបស់បុគ្គលនោះ ឈ្មោះថា សម្មាទិដ្ឋិ ។ មួយទៀត បុគ្គលណា ត្រិះរិះហេតុដែលមានពិតមែនថា ហេតុមានពិតមែន សេចក្តីត្រិះរិះរបស់បុគ្គលនោះ ឈ្មោះថា សម្មាសង្កប្ប ។ មួយទៀត បុគ្គលណា ពោលវាចាចំពោះហេតុដែលមានពិតមែនថា ហេតុមានពិតមែន វាចារបស់បុគ្គលនោះ ឈ្មោះថា សម្មាវាចា ។ មួយទៀត បុគ្គលណាពោលនូវហេតុដែលមានពិតមែនថា ហេតុមានពិតមែន បុគ្គលនេះឈ្មោះថាមិនធ្វើសឹកសត្រូវ ចំពោះព្រះអរហន្តជាហេតុវាទទាំងនោះ ។ មួយទៀត បុគ្គលណា ពន្យល់អ្នកដទៃឲ្យយល់នូវហេតុដែលមានពិតមែនថា ហេតុមានពិតមែន សេចក្តីពន្យល់របស់បុគ្គលនោះ ឈ្មោះថា សទ្ធម្មសញ្ញត្តិ មិនលើកតម្កើងខ្លួនឯង ឯបុគ្គលនោះ ឈ្មោះថា មិនបង្អាប់បុគ្គលដទៃដោយសារសទ្ធម្មសញ្ញត្តិនោះទេ ។ ព្រោះហេតុនោះ បុគ្គលនោះ បានលះបង់នូវការៈជា

អ្នកទ្រុស្តសីលក្នុងកាលមុន ហើយតាំងទុកនូវភាវៈជាអ្នកមានសីលល្អវិញ នេះ ឈ្មោះថា សម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាចា មិនជាសឹកសត្រូវចំពោះព្រះអរិយៈទាំងឡាយ ជាសទ្ធម្មសញ្ញត្តិ ឈ្មោះថា មិនលើកតម្កើងខ្លួនឯង មិនបន្អាប់បុគ្គលដទៃ ។ កុសលធម៌ទាំងឡាយនេះច្រើនប្រការ កើតឡើងព្រមព្រោះសម្មាទិដ្ឋិជាបច្ច័យយ៉ាងនេះ ។

[ ១១៩ ] ម្នាលគហបតីទាំងឡាយ វិញ្ញុបុរសតែងពិចារណាឃើញក្នុងលទ្ធិរបស់សមណព្រាហ្មណ៍ទាំងនោះ ដូច្នេះថា បើហេតុមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈ នឹងចូលទៅកាន់សុគតិសួគ៌ទេវលោក ។ មួយទៀត បើហេតុមិនមានដោយពិត ពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ទុកជាពាក្យពិត តែថាបុរសបុគ្គលដ៏ចម្រើននេះ អ្នកប្រាជ្ញទាំងឡាយសរសើរក្នុងបច្ចុប្បន្នថា បុរសបុគ្គលនេះជាអ្នកមានសីល ជាសម្មាទិដ្ឋិ ជាហេតុវាទ ។ បើហេតុមានពិតមែន បុរសបុគ្គលដ៏ចម្រើននេះ ទទួលជ័យជម្នះ ក្នុងចំណែកទាំងពីរ គឺអ្នកប្រាជ្ញទាំងឡាយសរសើរក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ នឹងចូលទៅកាន់សុគតិសួគ៌ទេវលោក ។ អបណ្ណកធម៌នេះ ដែលបុគ្គលធ្វើឲ្យពេញលេញ សមាទានល្អហើយ ក៏ផ្សាយទៅតាមវាទៈរបស់ខ្លួន ដោយចំណែកទាំងពីរ វៀរបង់នូវហេតុជាទីតាំងនៃអកុសលយ៉ាងនេះ ។

[ ១២០ ] ម្នាលគហបតីទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា អរូបព្រហ្ម មិនមានដោយប្រការទាំង

ពួន ម្នាលគហបតីទាំងឡាយ សមណព្រាហ្មណ៍ពួកមួយ មានវាទៈជាសឹកសត្រូវដោយត្រង់ ទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយពោលយ៉ាងនេះថា អរូបព្រហ្មមានដោយប្រការទាំងពួង ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវហេតុនោះដូចម្តេច ក្រែងសមណព្រាហ្មណ៍ទាំងនេះ មានវាទៈជាសឹកសត្រូវដោយត្រង់ ទៅរកគ្នានិងគ្នា មិនមែនឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតីទាំងឡាយ វិញ្ញុបុរស តែងពិចារណាឃើញក្នុងលទ្ធិរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ដូច្នេះថា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា អរូបព្រហ្ម មិនមានដោយប្រការទាំងពួង ពាក្យនេះ យើងក៏មិនដែលឃើញសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា អរូបព្រហ្មមាន ដោយប្រការទាំងពួង ពាក្យនេះ យើងក៏មិនដែលដឹង ឯយើងកាលបើមិនដឹង មិនឃើញ គប្បីកាន់យកដោយចំណែកមួយ ហើយនិយាយថា ពាក្យនេះឯង ជាពាក្យពិត ពាក្យដទៃជាមោឃៈ ហេតុនេះ មិនសមគួរទេ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា អរូបព្រហ្មមិនមានដោយប្រការទាំងពួង បើពាក្យរបស់សមណ-ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ជាពាក្យពិត ពាក្យនុ៎ះ យកជាទីតាំងបានប្រាកដ ទេវតាទាំងឡាយណា មានរូបកើតដោយឈានចិត្ត ពាក្យនេះ ( មិនខុស ) ការទៅកើតក្នុងរូបព្រហ្មនោះនឹងមានដល់យើង មួយទៀត សមណព្រាហ្មណ៍ដ៏ចម្រើនទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា អរូបព្រហ្ម

មានដោយប្រការទាំងពួង បើពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ជាពាក្យពិត ពាក្យទុំះ យកជាទីតាំងបានប្រាកដ ទេវតាទាំងឡាយណា ដែលឥតរូប កើតដោយសញ្ញា ពាក្យនោះ ( មិនខុស ) ការទៅកើតក្នុងអរូបព្រហ្មនោះ នឹងមានដល់យើង ការកាន់យកដំបង ការកាន់យកគ្រឿងសស្ត្រា ការឈ្លោះទាស់ទែងគ្នា ការពោលជជែកគ្នា ការប្រកាន់ថាឯង អញ ការពោលញុះញង់ និងការពោលពាក្យកុហក ដែលប្រាកដឡើង ព្រោះមានរូបជាអធិករណ៍ ក៏ឯអធិករណ៍ទុំះមិនមានក្នុងអរូបព្រហ្ម ដោយប្រការទាំងពួង ។ វិញ្ញូបុរសនោះ លុះពិចារណាឃើញដូច្នេះហើយ ក៏ប្រតិបត្តិដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់នូវរូបទាំងឡាយ ។

[ ១២១ ] ម្នាលគហបតីទាំងឡាយ មានសមណព្រាហ្មណ៍ទាំងឡាយពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ការរលត់នៃភពដោយប្រការទាំងពួងមិនមានឡើយ ។ ម្នាលគហបតីទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ មានវាទៈជាសឹកសត្រូវដោយត្រង់ ទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយពោលថា ការរលត់នៃភពដោយប្រការទាំងពួងមាន ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវហេតុនោះដូចម្តេច ក្រែងសមណព្រាហ្មណ៍ទាំងឡាយនេះ មានវាទៈជាសឹកសត្រូវដោយត្រង់ទៅរកគ្នានិងគ្នាមិនមែនឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលគហបតីទាំងឡាយ វិញ្ញូបុរសតែងពិចារណាឃើញក្នុងលទ្ធិរបស់ពួកសមណព្រាហ្មណ៍ទាំងនោះដូច្នេះថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា

ការរលត់ទៅនៃភពដោយប្រការទាំងពួង មិនមានឡើយ ហេតុនេះ យើងមិនដែលឃើញទេ សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ការរលត់នៃភពដោយប្រការទាំងពួងមាន ហេតុនេះយើងមិនដឹង កាលបើយើងមិនដឹង មិនឃើញ គប្បីកាន់យកដោយចំណែកមួយ ហើយនិយាយថា ពាក្យនេះជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះ ពាក្យនេះ មិនសមគួរទេ សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ការរលត់នៃភពដោយប្រការទាំងពួងមិនមាន បើពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ជាពាក្យពិត ហេតុនេះ យកជាទីតាំងបានប្រាកដ ទេវតាទាំងឡាយណា ដែលឥតរូប កើតដោយអរូបជ្ឈានសញ្ញា ពាក្យនោះមិនខុស ការកើតក្នុងអរូបព្រហ្មនោះ នឹងមានដល់យើង មួយទៀត សមណព្រាហ្មណ៍ដ៏ចម្រើនទាំងឡាយណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ការរលត់នៃភពដោយប្រការទាំងពួងមាន បើពាក្យរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ជាពាក្យពិត ហេតុនេះ ទើបយកជាទីតាំងបានប្រាកដ យើងនឹងបរិនិព្វានក្នុងបច្ចុប្បន្ន ។ សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ការរលត់នៃភព ដោយប្រការទាំងពួងមិនមាន សេចក្តីយល់នេះ របស់សមណព្រាហ្មណ៍ទាំងនោះ ក៏ប្រព្រឹត្តទៅក្នុងទីជិតនៃសេចក្តីត្រេកត្រអាល ក្នុងទីជិតនៃសំយោគធម៌ ក្នុងទីជិតនៃសេចក្តីរីករាយ ក្នុងទីជិតនៃសេចក្តីចូលចិត្តស៊ប់ ក្នុងទីជិតនៃឧបាទាន មួយទៀត សមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនណា

មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា កិរិយារលត់ទៅនៃភព មានដោយប្រការទាំងពួង សេចក្តីយល់នេះ របស់សមណព្រាហ្មណ៍ទាំងនោះ ប្រព្រឹត្តទៅក្នុងទីជិតនៃសេចក្តីមិនត្រេកត្រអាល ក្នុងទីជិតនៃសំយោគធម៌ ក្នុងទីជិតនៃសេចក្តីមិនរីករាយ ក្នុងទីជិតនៃសេចក្តីមិនចូលចិត្តស៊ប់ ក្នុងទីជិតនៃសេចក្តីមិនមានឧបាទាន ។ វិញ្ញូបុរសនោះ ពិចារណាឃើញដូច្នេះហើយ ក៏ប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីរម្ងត់នូវភពទាំងឡាយ ។

[ ១២២ ] ម្នាលគហបតីទាំងឡាយ បុគ្គលទាំងឡាយក្នុងលោកមាន ៤ ពួកនេះ បុគ្គលទាំង ៤ ពួក តើដូចម្តេចខ្លះ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកប្រកបព្យាយាមរឿយៗ ដុតកម្តៅខ្លួនឯង ឈ្មោះអត្តន្តបៈ ១ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកប្រកបព្យាយាមរឿយៗ ដុតកម្តៅបុគ្គលដទៃ ឈ្មោះបរន្តបៈ ១ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកប្រកបព្យាយាមរឿយៗ ដុតកម្តៅខ្លួនឯង ឈ្មោះអត្តន្តបៈផង ជាអ្នកប្រកបព្យាយាមរឿយៗ ដុតកម្តៅបុគ្គលដទៃ ឈ្មោះបរន្តបៈផង ១ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកប្រកបព្យាយាមរឿយៗ មិនដុតកម្តៅខ្លួនឯង ឈ្មោះនេវត្តន្តបៈផង ជាអ្នកប្រកបព្យាយាមរឿយៗ មិនដុតកម្តៅបុគ្គលដទៃ ឈ្មោះនបរន្តបៈផង ១ អនត្តន្តបបុគ្គលនិងអបរន្តបបុគ្គលនោះ ជាអ្នកលែងមានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ មានត្រជាក់កើតហើយ មានប្រក្រតីទទួលសុខ មានខ្លួនដូចជាព្រហ្ម នៅក្នុងបច្ចុប្បន្ននេះ ។

[ ១២៣ ] ម្នាលគហបតីទាំងឡាយ បុគ្គលប្រកបព្យាយាមរឿយៗ ដុតកម្ដៅខ្លួនឯង ឈ្មោះអត្តន្តបៈ តើដូចម្ដេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកប្រព្រឹត្តអាក្រាត លះមារយាទល្អចេញ ប្រព្រឹត្តស៊ីលិទ្ធដៃ ។ សេចក្ដីពិស្ដារដូចគ្នានឹងកន្ទរកសូត្រ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រកបព្យាយាមរឿយៗ ញុំាងកាយឲ្យក្ដៅក្រហល់ក្រហាយ មានប្រការផ្សេងៗ ជាអ្នកប្រកបព្យាយាមរឿយៗ ដុតកម្ដៅខ្លួនឯង មានសភាពយ៉ាងនេះ បុគ្គលនេះហៅថា អត្តន្តបៈ ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រកបព្យាយាមរឿយៗ ដុតកម្ដៅបុគ្គលដទៃ ឈ្មោះថា បរន្តបៈ តើដូចម្ដេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលក្នុងលោកនេះ ជាអ្នកសម្លាប់ចៀមចិញ្ចឹមជីវិត សម្លាប់ជ្រូកចិញ្ចឹមជីវិត ។បេ។ ឬក៏បុគ្គលណាមួយ មានការងាររឹករឹរ ជាអ្នកប្រកបព្យាយាមរឿយៗ ដុតកម្ដៅបុគ្គលដទៃ ម្នាលគហបតីទាំងឡាយ បុគ្គលនេះ ហៅថា បរន្តបៈ ។ ម្នាលគហបតីទាំងឡាយ ចុះបុគ្គលប្រកបព្យាយាមរឿយៗ ដុតកម្ដៅខ្លួនឯង ឈ្មោះអត្តន្តបៈផង ជាអ្នកប្រកបព្យាយាមរឿយៗ ដុតកម្ដៅនូវបុគ្គលដទៃ ឈ្មោះថា បរន្តបៈផង តើដូចម្ដេច ។ ម្នាលគហបតីទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ គឺស្ដេចជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ។បេ។ ក៏បុគ្គលទាំងនោះ តែងមានសេចក្ដីតក់ស្លុតដោយអាជ្ញា តក់ស្លុតដោយភ័យ មានមុខទទឹកដោយទឹកភ្នែក ទួញយំ ធ្វើការងារទាំងឡាយ ជាអ្នកប្រកបព្យាយាមរឿយៗ ដុតកម្ដៅខ្លួនឯង ម្នាលគហបតីទាំងឡាយ បុគ្គលនេះ ហៅថា អត្តន្តបៈផង ជាអ្នកប្រកបព្យាយាម

រឿយៗ ដុតកម្តៅបុគ្គលដទៃ ហៅថា បរន្តបៈផង ។ ម្នាលគហបតីទាំងឡាយ បុគ្គលប្រកបព្យាយាមរឿយៗ មិនដុតកម្តៅខ្លួនឯង ហៅថា នអត្តន្តបៈផង ជាអ្នកប្រកបព្យាយាមរឿយៗ មិនដុតកម្តៅបុគ្គលដទៃ ហៅថា នបរន្តបៈផង តើដូចម្តេច អនត្តន្តបៈ និងអបរន្តបបុគ្គលនោះ លែងមានសេចក្តីស្រេកឃ្លាន មានទុក្ខរម្ងត់ហើយ មានត្រជាក់កើតហើយ មានប្រក្រតីទទួលសេចក្តីសុខ មានខ្លួនដូចជាព្រហ្ម នៅក្នុងបច្ចុប្បន្ននេះ ។ ម្នាលគហបតីទាំងឡាយ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោកនេះ ។បេ។ ព្រះតថាគតនោះ លះបង់នីវរណធម៌ទាំង ៥ នេះ ដែលជាឧបក្កិលេសក្នុងហឫទ័យ ជាធម៌ធ្វើបញ្ញាឲ្យថយកម្លាំង មានហឫទ័យស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្ក វិចារៈ មានតែបីតិ និងសុខដែលកើត អំពីសេចក្តីស្ងប់ស្ងាត់ ( ជាអារម្មណ៍ ) ព្រោះរម្ងាប់វិតក្ក និងវិចារៈហើយ ក៏បានដល់ទុតិយជ្ឈាន ដែលមានក្នុងខ្លួន ជាទីជ្រះថ្លា មានភាវៈជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារៈទេ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិប៉ុណ្ណោះ ព្រោះប្រាសចាកបីតិ ។បេ។ បានដល់ តតិយជ្ឈាន ព្រោះលះបង់នូវសេចក្តីសុខផង ។បេ។ ក៏បានដល់ចតុត្ថជ្ឈាន ។ ព្រះតថាគតនោះ កាលបើចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ ព្រះតថាគតនោះ រឭកជាតិដែលបាន

អាស្រ័យនៅមកពីមុនជាអនេកជាតិ រឭកជាតិបានដូចម្តេច គឺរឭកបាន ១ ជាតិ ២ ជាតិ ។បេ។ រឭកជាតិ ដែលអាស្រ័យនៅមកពីមុនបានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ។ ព្រះតថាគតនោះ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅដើម្បីចុតូបបាតញាណនៃសត្វទាំងឡាយ ។ ព្រះតថាគតនោះ មានចក្ខុដូចជាទិព្វ បរិសុទ្ធជាងចក្ខុរបស់មនុស្សសាមញ្ញ បានឃើញសត្វទាំងឡាយ ដែលចុតិ និងបដិសន្ធិ ទាបថោក និងឧត្តម មានសណ្ឋានល្អ និងអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិ ។បេ។ ក៏ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ។ ព្រះតថាគតនោះ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ ។ ព្រះតថាគតនោះដឹងប្រាកដតាមពិតថា នេះជាទុក្ខ ។បេ។ ដឹងប្រាកដតាមពិតថា នេះជាបដិបទា ដំណើរទៅដើម្បីរលត់អាសវៈ ។ កាលដែលព្រះតថាគតនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតចាកកាមាសវៈផង ចិត្តក៏ផុតចាកភវាសវៈផង ចិត្តក៏ផុតចាកអវិជ្ជាសវៈផង ញាណក៏កើតឡើងប្រាកដថា ចិត្តផុតស្រឡះហើយ ព្រះតថាគតក៏ដឹងដូច្នេះថា ជាតិអស់ហើយ មគ្គព្រហ្មចរិយធម៌ បាននៅរួចហើយ កិច្ចដែលគួរធ្វើ ក៏បាន

ធ្វើរួចហើយ កិច្ចដទៃក្រៅពីនេះ មិនមានឡើយ ម្នាលគហបតីទាំងឡាយ បុគ្គលនេះ ហៅថា ជាអ្នកប្រកបរឿយៗ នូវព្យាយាមមិនដុតកម្តៅខ្លួនឯង ហៅថា នៅត្តន្តបៈផង ជាអ្នកប្រកបរឿយៗ នូវព្យាយាមមិនដុតកម្តៅបុគ្គលដទៃ ហៅថា បរន្តបៈផង អនត្តន្តបបុគ្គល និងអបរន្តបបុគ្គលនោះ តែង មានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ហើយ មានត្រជាក់កើតហើយ មាន ប្រក្រតីទទួលនូវសុខ មានខ្លួនដូចជាព្រហ្មក្នុងបច្ចុប្បន្ន ។

[ ១២៤ ] កាលដែលព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះ ហើយ ពួកព្រាហ្មណគហបតីអ្នកស្រុកសាលា ក៏បានក្រាបទូលព្រះមានព្រះ ភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ ចម្រើនប្រកាសហើយ ដោយអនេកបរិយាយនេះឯង ( ភ្លឺច្បាស់ណាស់ ) ដូចជាបុគ្គលផ្ងារបស់ដែលគេផ្កាប់ ឬដូចជាបុគ្គលបើកបង្ហាញរបស់ដែលកំបាំង ពុំនោះ ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាគេទ្រោលប្រទីប បំភ្លឺក្នុងទីងងឹត ឲ្យមនុស្សដែលមានភ្នែកភ្លឺ មើលឃើញនូវរូបទាំងឡាយបាន យើងខ្ញុំទាំងឡាយនេះ សូមដល់ព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុ សង្ឃផង ជាទីពឹង ទីរឭក សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវយើងខ្ញុំទាំង-ឡាយ ថាជាឧបាសក ដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមតាំងអំពី ថ្ងៃនេះតទៅ ។

**អបណ្ណកសូត្រទី ១០ ចប់**

**គហបតិវគ្គទី ១ ចប់**

## បញ្ជីរឿងនៃវគ្គនោះ ដូច្នេះ

កន្ទរកសូត្រ ១ អដ្ឋកនាគរសូត្រ ១ សំវរៈ គឺសេក្ខប្បដិបទាសូត្រ ១ បោតលិយសូត្រ ១ ជីវកកកច្ចសូត្រ ១ ឧបាលិទមសូត្រ គឺឧបាលិវាទសូត្រ ១ កុក្កុរោវាទសូត្រ ១ អភយសូត្រ ១ ពហុវេទនីយសូត្រ ១ ជា ១០ និង អបណ្ណកសូត្រ ( នេះ គឺ ) វគ្គដ៏ប្រសើរ ជាបឋម ។

# អដ្ឋកថា

## អបណ្ណកសូត្រ

[ ១០៣ ] អបណ្ណកសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបណ្ដាបទទាំងនោះ បទថា **ចារិកំ** គឺចារិកទៅមិនប្រញាប់ប្រញាល់ ។

[ ១០៤ ] ហេតុអ្វីទើបលោកពោលថា **អត្ថិ បន វោ គហបតយោ ។** បានឮមកថា ស្រុកនោះ តាំងនៅជិតមាត់ព្រៃ ពួកសមណព្រាហ្មណ៍ប្រភេទផ្សេងៗ ធ្វើដំណើរមករាល់ថ្ងៃ រមែងចូលទៅកាន់ស្រុកនោះ ដើម្បីស្នាក់អាស្រ័យក្នុងពេលល្ងាចខ្លះ ព្រឹកខ្លះ អ្នកស្រុកទាំងឡាយ ក៏ក្រាលគ្រែ តាំងប្រគេនសមណព្រាហ្មណ៍ទាំងនោះ លាងជើង លាបជើង ប្រគេនទឹកផឹកដ៏សមគួរ ស្អែកឡើងក៏ឲ្យទាន ។ សមណព្រាហ្មណ៍ទាំងនោះ ក៏មានចិត្តផូរផង់ សន្ទនានឹងអ្នកស្រុកទាំងនោះ ពោលយ៉ាងនេះថា ម្នាលគហបតីទាំង-ឡាយ ទស្សនៈណាមួយ ដែលអ្នកទាំងឡាយប្រកាន់មានឬ ។ អ្នកស្រុកក៏ឆ្លើយថា មិនមានទេ លោកម្ចាស់ សមណព្រាហ្មណ៍ក៏ពោលថា គហបតីទាំងឡាយ វៀរទស្សនៈចេញ លោកក៏ប្រព្រឹត្តទៅមិនបាន ពួកអ្នកពេញចិត្តក្នុងទស្សនៈណាមួយ សមគួរទទួលក៏គួរ ។ ពួកអ្នកចូរកាន់ទស្សនៈមួយថា លោកទៀង ដូច្នេះ ក៏នាំគ្នាចេញទៅ ។ ថ្ងៃបន្ទាប់ៗ មក សមណព្រាហ្មណ៍ពួកដទៃក៏មក ហើយសួរក៏យ៉ាងនោះឯង អ្នកស្រុកទាំងនោះ ក៏ឆ្លើយនឹងសមណព្រាហ្មណ៍នោះថា ករុណាលោកម្ចាស់ ហើយក៏ប្រាប់ដូចថ្ងៃមុនៗ ពួក

សមណព្រាហ្មណ៍ដូចគ្នានឹងពួកលោកម្ចាស់ មកប្រាប់ឲ្យពួកខ្ញុំឲ្យកាន់ទស្សនៈថា លោកទៀង ដូច្នេះក៏ទៅ សមណព្រាហ្មណ៍ទាំងនោះក៏ពោលថា ពួកនោះវាល្ងង់ ដឹងខ្យល់អ្វី លោកនេះដាច់សូន្យទេតើ ពួកអ្នកចូរកាន់ទស្សនៈថា ដាច់សូន្យ ឲ្យអ្នកស្រុកទាំងនោះកាន់ទស្សនៈថា ដាច់សូន្យយ៉ាងនេះ ហើយក៏ចៀសចេញទៅ ។ ដោយទំនងនេះ សមណព្រាហ្មណ៍ទាំងឡាយ ក៏បានឲ្យកាន់យកនូវទិដ្ឋិ ៦២ យ៉ាង គឺពួកមួយឲ្យប្រកាន់ថា លោកទៀង ពួកមួយឲ្យប្រកាន់ថា លោកមានទីបំផុត លោកមិនមានទីបំផុត ពួកមួយឲ្យប្រកាន់ទិដ្ឋិកម្រើកបាន មិនស្លាប់ខ្ជួន ។ តែអ្នកស្រុកទាំងនោះ មិនអាចតាំងនៅក្នុងទិដ្ឋិណាមួយបាន ។ ព្រះមានព្រះភាគ បានយាងទៅខាងក្រោយសមណ-ព្រាហ្មណ៍ទាំងអស់ ។ ត្រាស់សួរដើម្បីប្រយោជន៍របស់អ្នកស្រុកទាំងនោះ ទើបត្រាស់ថា **អត្ថិ បន វោ គហបតយោ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អាការវតី** ប្រែថា មានការណ៍ មានហេតុ ។ បទថា **អបណ្ណកោ** ប្រែថា មិនខុស មិនដល់នូវផ្លូវបែកជា ២ គឺកាន់យកបានដោយចំណែកមួយ ។

[ ១០៥ ] មិច្ឆាទិដ្ឋិ គឺការឃើញខុស មានវត្ថុ ១០ មាន **នត្ថិទិន្នំ** គឺទានដែលឲ្យហើយ មិនមានផលដូច្នេះជាដើម លោកពោលពិស្តារហើយក្នុងសាលេយ្យកសូត្រខាងដើម សម្មាទិដ្ឋិ ការឃើញត្រូវដែលជាសត្រូវចំពោះការឃើញខុសនោះក៏ដូចគ្នា ។

[ ១០៦ ] បទថា **នេក្ខម្មេ អានិសំសំ** សេចក្តីថា អានិសង្សឯណាក្នុងភាពដែលបុគ្គលទាំងនោះចេញចាកអកុសល និងចំណែកជមិស ចំណែក

ធម៌បរិសុទ្ធឯណា មនុស្សទាំងនោះ រមែងមិនឃើញអានិសង្ស និងធម៌ចំណែក សនោះ ។ បទថា **អសទ្ធម្មសញ្ញត្តិ** ប្រែថា ការបញ្ញត្តិធម៌ដែល មិនពិត ។ បទថា **អត្តានុក្កំសេតិ** សេចក្ដីថា លើកខ្លួនថា វៀរអញចេញហើយ អ្នកដទៃណានឹងអាចឲ្យអ្នកដទៃៗ កាន់យកទស្សនៈរបស់ខ្លួនបាន ។ បទថា **បរំ វម្ភេតិ** សេចក្ដីថា ត្អឹះអ្នកដទៃទុកខាងក្រោយយ៉ាងនេះថា ក្នុងជនទាំងឡាយ មានចំនួនដល់ម៉្លេះ សូម្បីតែម្នាក់ក៏មិនអាចធ្វើអ្នកដទៃណាម្នាក់ ឲ្យកាន់យកទស្សនៈរបស់ខ្លួនបាន ។ បទថា **បុព្វេវ ខោ បនស្ស** សេចក្ដីថា កាលបុគ្គលប្រកាន់នូវការឃើញមកអំពីមុននោះឯង ក៏ដូចគ្នានឹងការលះនូវភាពជាបុគ្គលមានសីលដែលល្អ ប្រាកដច្បាស់តែភាពទ្រុស្តសីល ។ បទថា **ឯវំសិមេ** សេចក្ដីថា ធម៌ ៧ យ៉ាង មានមិច្ឆាទិដ្ឋិជាដើមទាំងនេះរមែង មានដល់បុគ្គលយ៉ាងនេះ ។ តែធម៌ចំណែកបាបអកុសលជាអនេក ដែលមានមិច្ឆាទិដ្ឋិជាបច្ច័យទាំងនោះឯង ឈ្មោះថា កើតឡើងដោយអំណាចការកើតឡើងហើយ កើតឡើងទៀត ។

[ ១០៧ ] បទថា **តត្រ** ប្រែថា នោះ គឺក្នុងលទ្ធិទាំងឡាយរបស់សមណព្រាហ្មណ៍ទាំងនោះ ។ បទថា **កលិគ្គាហោ** ប្រែថា កាន់យកនូវការចាញ់ ។ បទថា **ទុស្សមត្តោ ទុស្សមាទិន្នោ** ប្រែថា កាន់យកអាក្រក់ គឺកាន់យកខុស ។ បទថា **ឯកំសំ ផរិត្វា តិដ្ឋតិ** សេចក្ដីថា ផ្សាយពង្រីកវាទៈរបស់ខ្លួននោះឯងទៅម្ខាង ចំណែកមួយទៀតតាំងនៅ ។ កាលប្រកាន់យ៉ាងនេះថា លោកដទៃមិនមាន ក៏នាំមកនូវភាពសួស្ដី ។ បទថា **រិញ្ចតិ**

ប្រែថា រមែងលះ ។

[ ១០៨ ] បទថា **សច្ចូម្មសញ្ញត្តិ** សេចក្តីថា បញ្ញត្តធម៌ដែលមានពិត ។

[ ១០៩ ] បទថា **កដគ្គាហោ** សេចក្តីថា ការមានជ័យជម្នះ ។ បទថា **សុសមត្តោ សមាទិន្នោ** ប្រែថា កាន់យកល្អ ពាល់ត្រូវល្អ ។ បទថា **ឧភយំ សំដរិត្វា តិដ្ឋតិ** សេចក្តីថា ពង្រីកវាទៈរបស់ខ្លួន និងវាទៈរបស់អ្នកដទៃទៅសងខាងពីរចំណែក តាំងនៅ ។ កាលបើប្រកាន់យ៉ាងនេះថា លោកដទៃមិនមាន ក៏នឹងនាំមកនូវសួស្តីភាពនោះឯង គប្បីជ្រាបអត្ថក្នុងបញ្ហាចំណែកមួយ និងពីរចំណែករបស់ចំណែកដទៃ ក៏ដោយន័យនេះ ។

[ ១១០ ] បទថា **ករោតោ** គឺការធ្វើដោយដៃរបស់ខ្លួន ។ បទថា **ការយតោ** គឺប្រើឲ្យអ្នកដទៃធ្វើ ។ បទថា **ឆិន្ទតោ** គឺកាត់ដៃជាដើមរបស់អ្នកដទៃ ។ បទថា **បចតោ** គឺបៀតបៀន ឬគំរាមអ្នកដទៃដោយរបស់ក្តៅគឺភ្លើង ។ បទថា **សោចយតោ** គឺធ្វើឯងក្តី ប្រើឲ្យអ្នកដទៃធ្វើក្តី នូវការសោយសោកដល់អ្នកដទៃ ដោយការលួចទ្រព្យជាដើម ។ បទថា **កិលមតោ** គឺលំបាកឯងក្តី ធ្វើឲ្យអ្នកដទៃលំបាកក្តី ដោយការបង្អត់អាហារ និងបង្ខាំងក្នុងគុកជាដើម ។ បទថា **ផន្ទតោ ផន្ទាបយតោ** គឺបម្រះនទៀលឯងក្តី ធ្វើឲ្យអ្នកដទៃបម្រះនទៀលក្តី ក្នុងវេលាចងអ្នកដទៃដែលកំពុងកន្ទក់កន្ទេញ ។ បទថា **ចាណាមតិចាតយតោ** គឺសម្លាប់ឯងក្តី ប្រើអ្នកដទៃឲ្យសម្លាប់ក្តី នូវជីវិតសត្វ ។ គប្បីជ្រាបអត្ថក្នុងទីគ្រប់អន្លើ ដោយការធ្វើឯង និងប្រើឲ្យអ្នកដទៃធ្វើ ដោយន័យដែលពោលមកនេះ ។ បទថា **សន្ធិំ** គឺកាត់ទី-ត ។ បទ

ថា **និល្លោបំ** គឺប្លន់គំរាម ។ បទថា **ឯកាគារិកំ** គឺព័ទ្ធផ្ទះមួយប៉ុណ្ណោះប្លន់ ។ បទថា **បរិបន្ថេ តិដ្ឋតោ** គឺឈរស្កាត់ត្រង់ផ្លូវ ដើម្បីដណ្តើមទ្រព្យរបស់អ្នកដំណើរ ។ បទថា **ករោតោ ន ករីយតិ បាបំ** សេចក្តីថា បាបនៃ បុគ្គលដែលធ្វើដោយយល់ថា អញធ្វើបាបឯណានីមួយ ឈ្មោះថា មិនធ្វើបាបមិនមាន សត្វទាំងឡាយរមែងយល់យ៉ាងនេះថា អញធ្វើ ។ បទថា **ខុរបរិយន្តេន** គឺមុខមុត ។ បទថា **ឯកំមំសខលំ** គឺគំនរសាច់មួយគំនរ ។ បទថា **បុញ្ជំ** ជាវេវចនៈនៃបទថា **ឯកំមំសខលំ** នោះឯង ។ បទថា **តតោនិទានំ** ប្រែថា មានហេតុអំពីការធ្វើឲ្យជាគំនរសាច់មួយពំនូកនោះ ។ ពួកមនុស្សដែលនៅត្រើយខាងត្បូង ជាមនុស្សរឹងត្អឹង ទារុណ លោកសំដៅយកមនុស្សទាំងនោះ ទើបពោលថា **ហនន្តោ** ជាដើម ។ ពួកមនុស្សដែលនៅត្រើយខាងជើង ជាអ្នកមានសទ្ធាជ្រះថ្លា រាប់អានព្រះពុទ្ធ ថាជារបស់យើង ព្រះធម៌ថាជារបស់យើង ព្រះសង្ឃថាជារបស់យើង លោកសំដៅយកមនុស្សទាំងនោះ ទើបពោលថា **ទទន្តោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យជន្តោ** គឺធ្វើការបូជាធំ ។ បទថា **ទមេន** គឺដោយការទូន្មានឥន្ទ្រិយ គឺឧបោសថកម្ម ។ បទថា **សំយមេន** គឺដោយការសង្រួមក្នុងសីល ។ បទថា **សច្ចវជ្ជេន** គឺដោយពាក្យសច្ចៈ ។ បទថា **អាគមោ** អធិប្បាយថា ការប្រព្រឹត្តទៅ ឈ្មោះថា **អាគម** ។ សមណព្រាហ្មណ៍ដែលបដិសេធការធ្វើបាប និងបុណ្យទាំងឡាយ ដោយប្រការទាំងពួង ។ សូម្បីក្នុងសុក្កបក្ខ គឺធម៌ចំណែកស ក៏គប្បីជ្រាបផ្ទុយគ្នាដោយន័យ

ដែលពោលមកហើយ ។ ពាក្យដ៏សេសក្នុងសុក្កបក្ខនោះ ក៏ដូចពាក្យដែលពោលមកហើយ ក្នុងវារៈមុន ។

[ ១១៥ ] ក្នុងបទថា **នត្ថិ ហេតុ នត្ថិ បច្ចយោ** នេះ បច្ច័យដែលជាវេវចនៈនៃហេតុ សមណព្រាហ្មណ៍ពួកខ្លះ រមែងបដិសេធបច្ច័យនៃការសៅហ្មង មានកាយទុច្ចរិតជាដើម បច្ច័យនៃកិច្ចបរិសុទ្ធ មានកាយសុចរិតជាដើមដែលមានដោយហេតុ និងបច្ច័យទាំង ២ ។

បទថា **នត្ថិ ពលំ នត្ថិ វីរិយំ នត្ថិ បុរិសត្ថាមោ នត្ថិ បុរិសបរក្កមោ** សេចក្តីថា កម្លាំងក្តី សេចក្តីព្យាយាមក្តី ថាមពលនៃបុរសក្តី ការប្រឹងប្រែងរបស់បុរសក្តី ឈ្មោះថា ដែលបុរសគប្បីធ្វើ ដើម្បីការសៅហ្មង ឬដើម្បីបរិសុទ្ធនៃសត្វទាំងឡាយ មិនមាន ។ សមណព្រាហ្មណ៍ពួកខ្លះ សម្តែងដល់សត្វទាំងឡាយ មានអូដ្ឋ គោ និងពពែជាដើម មិនឲ្យសល់ ដោយបទថា **សព្វេ សត្តា** ។ ពោលដោយអំណាចពាក្យជាដើមថា សត្វមានជីវិតិន្ទ្រិយ ១ សត្វមានជីវិតិន្ទ្រិយ ២ ដោយបទថា **សព្វេ បាណា** ពោលសំដៅសត្វ មានបាណទាំងអស់ ។ សមណព្រាហ្មណ៍ពួកខ្លះ ពោលសំដៅដល់សត្វដែលស្វែងរកកពកើត ក្នុងពង និងស្បូន ដោយបទថា **សព្វេ ភូតា** ។ ពោលសំដៅដល់ធញ្ញជាតិ មានស្រូវសាលី ស្រូវជំណើប ស្រងែជាដើម ដោយបទថា **សព្វេ ជីវា** ។ ព្រោះថា សមណព្រាហ្មណ៍ទាំងនោះ មានការយល់ថា ក្នុងធញ្ញជាតិទាំងនោះ មានជីវៈ ព្រោះដុះបាន ។ បទថា **អវសា អពលា អវីរិយា** សេចក្តីថា ទាំងនោះមិនមានអំណាច កម្លាំង ឬសេចក្តីព្យាយាមជា

របស់ខ្លួន ។ ក្នុងបទថា **និយតិសង្គតិភាវបរិណតា** នេះ ការជួបនូវបាប-គ្រោះ ឈ្មោះថា **និយតិ** ការទៅក្នុងទីនោះៗ នៃអភិជាតិទាំង ៦ ឈ្មោះថា **សង្គតិ** គឺការប្រជុំគ្នា ។ សភាពនោះ ឈ្មោះថា **ភាវៈ** សមណព្រាហ្មណ៍ពួកខ្លះសម្តែងថា សត្វទាំងពួងប្រែប្រួលទៅ គឺដល់នូវភាពជាប្រការផ្សេងៗ ក៏ព្រោះការជួបនូវបាបគ្រោះ ព្រោះការប្រជុំគ្នា និងព្រោះសភាវៈដោយប្រការនេះ ។ សមណព្រាហ្មណ៍ពួកខ្លះ រមែងសម្តែងថា សភាវៈណាគប្បីមានយ៉ាងណា សភាវៈនោះ ក៏រមែងមានយ៉ាងនោះ ។ សភាវៈណាមិនមាន សភាវៈនោះក៏មិនមានផងដែរ ។ បទថា **ឆស្វេវាភិជាតីសុ** សេចក្តីថា សមណ-ព្រាហ្មណ៍ពួកខ្លះសម្តែងថា សត្វទាំងពួងតាំងនៅក្នុងអភិជាតិ ៦ ប៉ុណ្ណោះ ទើបសោយសុខ និងទុក្ខបាន ភូមិនៃសុខ និងទុក្ខដទៃមិនមាន ។ ក្នុងបទថា **ឆស្វេវាភិជាតីសុ** នោះ ឈ្មោះថា អភិជាតិ ៦ គឺ **កណ្ហាភិជាតិ** ជាតិខ្មៅ **នីលាភិជាតិ** ជាតិខៀវ **លោហិតាភិជាតិ** ជាតិក្រហម **ហលិទ្ទាភិជាតិ** ជាតិលឿង **សុក្កាភិជាតិ** ជាតិស **បរមសុក្កាភិជាតិ** ជាតិសដ៏ក្រៃលែង ។ បណ្តាអភិជាតិ ៦ នោះ អ្នកសម្លាប់បក្សី សម្លាប់ជ្រូក ព្រាន មនុស្សសម្លាប់ត្រី ចោរ អ្នកសម្លាប់ចោរ ឬបុគ្គលដែលមានការងារចោកទាបពួកដទៃ នេះឈ្មោះថា **កណ្ហាភិជាតិ** ។ សមណព្រាហ្មណ៍ពួកខ្លះពោលថា ពួកភិក្ខុ ឈ្មោះថា **នីលាភិជាតិ** ។ សមណព្រាហ្មណ៍ទាំងនោះ មានលទ្ធិយ៉ាងនេះថា ពួកភិក្ខុទាំងនោះ ដាក់បន្ទាក្នុងបច្ច័យ ៤ បរិភោគ ទើបភិក្ខុឈ្មោះថា ប្រព្រឹត្តកណ្តកវត្ត ។ ម្យ៉ាងទៀត សមណព្រាហ្មណ៍ពួកខ្លះពោល

ថា បព្វជិតមួយពួកពោលថា ប្រព្រឹត្តកណ្តកវត្តនោះឯង ។ ពិតហើយ សូម្បីពាក្យថា សមណៈអ្នកប្រព្រឹត្តកណ្តកវត្ត ក៏ជាលទ្ធិរបស់សមណព្រាហ្មណ៍ទាំងនោះ ។ សមណព្រាហ្មណ៍ពួកខ្លះពោលថា ពួកនិគ្រន្ថចូលចិត្តកន្ទុកកន្ទេញក្នុងលទ្ធិរបស់ខ្លួនតែម្យ៉ាង ឈ្មោះថា **លោហិតាភិជាតិ** ។ បានឮថា និគ្រន្ថទាំងនោះសជាង ២ ពួកមុន សមណព្រាហ្មណ៍ពួកខ្លះពោលថា គ្រហស្ថជាសាវករបស់អចេលក៍ ឈ្មោះថា **ហលិទ្ទាភិជាតិ** ដូច្នោះ សាវករបស់ពួកអចេលក៍ ដែលឲ្យបច្ច័យដល់ខ្លួនជាធំជាង និគ្រន្ថទាំងឡាយ ។ សមណ-ព្រាហ្មណ៍ពួកខ្លះពោលថា នន្ទៈ វច្ចៈ សង្កិច្ចៈ នេះឈ្មោះថា **សុក្កាភិជាតិ** ។ បានឮថា មនុស្សទាំងនោះគង់សជាង ៤ ពួកមុន ។ សមណព្រាហ្មណ៍ពួកខ្លះពោលថា ឯអាជីវក ឈ្មោះថា **បរមសុក្កាភិជាតិ** បានឮថា អាជីវកទាំងនោះសជាងគ្រប់ពួក ។ សមណព្រាហ្មណ៍ទាំងនោះ មានលទ្ធិយ៉ាងនេះថា បណ្តាអភិជាតិ ៦ នោះ សត្វទាំងពួង មានអ្នកសម្លាប់បក្សីជាដើមមុន ។ ពួកសមណសក្យបុត្រ គង់បរិសុទ្ធជាងអ្នកសម្លាប់បក្សីជាដើមនោះ ពួកនិគ្រន្ថគង់បរិសុទ្ធជាងពួកសមណសក្យបុត្រនោះ សាវកអាជីវកគង់បរិសុទ្ធជាងពួកនិគ្រន្ថនោះ ។ នន្ទៈជាដើម គង់បរិសុទ្ធជាងពួកសាវករបស់អាជីវក អាជីវកគង់បរិសុទ្ធជាងនន្ទៈជាដើមនោះ ។ គប្បីជ្រាបធម៌ចំណែកស ដោយន័យដែលផ្ទុយគ្នាដូចពោលមកហើយ ។ ពាក្យដ៏សេសក្នុងទីនេះ ក៏ដូចគ្នានឹងពោលក្នុងវារៈមុន ។

[ ១១៧-១៩ ] បណ្តាទិដ្ឋិទាំង ៣ នេះ នត្ថិកទិដ្ឋិហាមវិបាក អកិរិយ-

ទិដ្ឋិហាមកម្ម អហេតុកទិដ្ឋិហាមសូម្បីទាំង ២ ក្នុងកម្ម និងវិបាកទាំង ២ នោះ វាទៈដែលហាមកម្ម ក៏ឈ្មោះថា ហាមវិបាកផងដែរ វាទៈដែលហាមវិបាក ក៏ឈ្មោះថា ហាមកម្មផងដែរ ដូច្នោះ ដោយអត្ថ វាទៈទាំងអស់នោះ ទោះជាអហេតុកវាទ ឬអកិរិយវាទ និងនត្ថិកវាទ ក៏ហាមកម្ម និងវិបាកទាំង ២ ។ បុគ្គលពួកណា កាន់យកលទ្ធិរបស់សមណព្រាហ្មណ៍ទាំងនោះ អង្គុយពិចារណាក្នុងទីសម្រាកពេលយប់ និងពេលថ្ងៃ មិច្ឆាសតិរបស់មនុស្សទាំងនោះ រមែងតាំងមាំក្នុងអារម្មណ៍នោះថា ទានដែលឲ្យហើយមិនមានផល យញ្ញដែលបូជាហើយមិនមានផល បាបរបស់បុគ្គលដែលធ្វើហើយ ក៏ឈ្មោះថាមិនធ្វើ ហេតុមិនមាន ផលមិនមាន ចិត្តក៏មានអារម្មណ៍មួយ ជវនទាំងឡាយក៏ស្ទុះទៅ ។ ក្នុងជវនទី ១ គង់ល្មមកែខៃបាន ក្នុងជវនទី ២ ជាដើមក៏ដូចគ្នា ។ ក្នុងជវនទី ៧ សូម្បីព្រះពុទ្ធទាំងឡាយ ក៏កែមិនបាន ជាបុគ្គលមិនវិលត្រឡប់ ដូចគ្នានឹងអរិដ្ឋភិក្ខុ និងកណ្ដកភិក្ខុ ក្នុងជវនទាំងនោះ បុគ្គលខ្លះក៏ឈមចុះកាន់ទស្សនៈ ១ ខ្លះ បុគ្គលខ្លះឈមកាន់ចុះទស្សនៈ ២ បុគ្គលខ្លះឈមចុះកាន់ទស្សនៈ ៣ កាលបុគ្គលនោះឈមចុះកាន់ទស្សនៈ ១-២-៣ ក៏ឈ្មោះថា ឈមចុះហើយ បុគ្គលនោះ ក៏ជាមិច្ឆាទិដ្ឋិប្រភេទនិយតនោះឯងហាមសួគ៌ និងព្រះនិព្វាន មិនគួរទៅសួគ៌បន្ទាប់អំពីអត្តភាពនោះ នឹងពោលថ្វីដល់ព្រះនិព្វាន ។ សត្វនេះជាអ្នកចាំផែនដី ឈ្មោះថា ជាដង្គត់នៃវដ្ដៈ ។

សួរថា មិច្ឆាទិដ្ឋិសត្វនេះ ធ្លាក់ចុះក្នុងអត្តភាពមួយប៉ុណ្ណោះ ឬក្នុងអត្តភាពដទៃដែរ ឆ្លើយថា ធ្លាក់ចុះក្នុងអត្តភាពមួយប៉ុណ្ណោះ ។ តែសត្វនោះគង់ពេញ

ចិត្តក្នុងទិដ្ឋិនោះៗ នៅក្នុងចន្លោះភព ដោយអំណាចការសេពរឿយៗ បុគ្គលប្រភេទនោះ ដោយច្រើនក៏ចេញទៅអំពីភពមិនបាន ។

**តស្មា អកល្យាណជនំ អាសីវិសមិវោរគំ**
**អារកា បរិវជ្ជេយ្យ ភូតិកាមោ វិចក្ខណោ ។**

ព្រោះដូច្នោះ បុគ្គលមានបញ្ញាឃើញប្រចក្ស ជាអ្នកត្រូវការសេចក្ដីចម្រើន គប្បីវៀរបុគ្គលបាប ដែលប្រៀបដូចអាសិរពិស ចេញឲ្យឆ្ងាយ ។

[ ១២០ ] បទថា **នត្ថិ សព្វសោ អារុប្បា** សេចក្ដីថា ឈ្មោះថា ចំណែកអរូបព្រហ្មលោក រមែងមិនមានដោយអាការទាំងពួង ។ បទថា **មនោមយា** គឺសម្រេចដោយចិត្តដែលប្រកបដោយឈាន ។ បទថា **សញ្ញាមយា** គឺសម្រេចដោយសញ្ញាក្នុងអរូបជ្ឈាន ។ បទថា **រូបានំយេវ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ** សេចក្ដីថា បុគ្គលនេះជាអ្នកបានក៏មាន ជាអ្នកត្រិះរិះក៏មាន ។ បុគ្គលបានរូបាវចរជ្ឈាន ឈ្មោះថា ជាអ្នកបាន ។ បុគ្គលបានរូបាវចរជ្ឈាននោះ មិនមានការសង្ស័យក្នុងរូបាវចរជ្ឈាន តែនៅមានសង្ស័យក្នុងលោកខាងអរូបាវចរ ។ អ្នកបានឈាននោះ រមែងបដិបត្តិយ៉ាងនោះដោយ យល់ថា អ្នកស្ដាប់បុគ្គលពោលថា អរូបព្រហ្មទាំងឡាយមានក៏មាន បុគ្គលពោលថា មិនមានក៏មាន តែអញមិនដឹងថា មាន ឬក៏មិនមានហ្ន៎ អញនឹងធ្វើចតុត្ថជ្ឈានឲ្យជាបទដ្ឋានហើយ ធ្វើអរូបាវចរជ្ឈានឲ្យកើត បើអរូបព្រហ្មទាំងឡាយមាន អញនឹងកើតក្នុងអរូបព្រហ្មនោះ បើមិនមាន

អញនឹងកើតក្នុងរូបាវចរព្រហ្មលោក ធម៌ដែលមិនខុសរបស់អញ នឹងជាធម៌មិនខុស មិនក្ដាំងក្ដាត់ ដោយបដិបទាយ៉ាងនេះ ។ ឯបុគ្គលត្រិះរិះបុគ្គលមិនបាន សូម្បីបុគ្គលនោះមិនមានការសង្ស័យក្នុងរូបជ្ឈាន តែក៏គង់មានការសង្ស័យក្នុងអរូបព្រហ្មលោក ។ បុគ្គលត្រិះរិះនោះ រមែងបដិបត្តិយ៉ាងនោះ ដោយយល់ថា អញស្ដាប់បុគ្គលពោលអរូបព្រហ្មទាំងឡាយថា មិនមានក៏មាន អ្នកពោលថា មានក៏មាន តែអញមិនដឹងថា មាន ឬក៏អត់ហ្ន៎ អញនឹងធ្វើបរិកម្មក្នុងកសិណ ញុំាងចតុត្ថជ្ឈានឲ្យកើត ហើយធ្វើចតុត្ថជ្ឈាននោះឲ្យជាបទដ្ឋាន នឹងញុំាងរូបាវចរជ្ឈានឲ្យកើត បើអរូបព្រហ្មទាំងឡាយមាន អញក៏នឹងកើតក្នុងអរូបព្រហ្មនោះ បើមិនមាន អញនឹងកើតក្នុងរូបាវចរព្រហ្មលោក ធម៌ដែលមិនខុស និងជាធម៌មិនខុស មិនក្ដាំងក្ដាត់ដោយការបដិបត្តិយ៉ាងនេះឯង ។

[ ១២១ ] បទថា **ភវនិរោធោ** គឺព្រះនិព្វាន ។ បទថា **សរាគាយ សន្តិកេ** គឺជិតនឹងការត្រេកអរ ក្នុងវដ្ដៈ ដោយអំណាចតម្រេក ។ បទថា **សំយោគាយ** គឺជិតនឹងការប្រកបខ្លួនដោយតណ្ហា និងការចង់បាន ។ បទថា **អភិនន្ទនាយ** គឺជិតចំពោះការត្រេកអរ ដោយអំណាចតណ្ហា និងទិដ្ឋិ ។ បទថា **បដិបន្នោ ហោតិ** សេចក្ដីថា បុគ្គលនេះជាអ្នកបានក៏មាន ជាអ្នកត្រិះរិះក៏មាន ។ បុគ្គលបានសមាបត្តិ ៨ ឈ្មោះថា ជាអ្នកបាន ។ បុគ្គលណាបានសមាបត្តិ ៨ នោះ មិនមានការសង្ស័យក្នុងអរូបព្រហ្ម តែគង់មានការសង្ស័យក្នុងព្រះនិព្វាន ។ បុគ្គលនោះបដិបត្តិយ៉ាងនេះ ដោយយល់ថា អញ

ពួគេពោលថា និរោធក៏មាន មិនមានក៏មាន អញមិនដឹងឯង អញនឹងធ្វើសមាបត្តិឲ្យជាបាទ ហើយចម្រើនវិបស្សនា បើនិរោធនឹងមានសោត អញក៏នឹងសម្រេចអរហត្ត បរិនិព្វាន បើមិនមាន អញនឹងកើតក្នុងអរូបព្រហ្ម ឯបុគ្គលត្រិះរិះមិនបានសូម្បីតែសមាបត្តិត្រឹមតែមួយ ។ បុគ្គលនោះ ក៏មិនមានការសង្ស័យក្នុងអរូបព្រហ្ម តែគង់មានការសង្ស័យក្នុករនិរោធ គឺព្រះនិព្វាន ។ បុគ្គលនោះបដិបត្តិយ៉ាងនេះ ដោយយល់ថា អញពួគេពោលថា និរោធមានក៏ធ្លាប់ពួ ថាមិនមានក៏ធ្លាប់ពួ អញមិនដឹងឯង អញនឹងធ្វើបរិកម្មក្នុងកសិណ ហើយធ្វើសមាបត្តិ ៨ ឲ្យកើត ចម្រើនវិបស្សនា មានសមាបត្តិជាបទដ្ឋាន បើនិរោធមានសោត អញនឹងសម្រេចអរហត្ត បរិនិព្វាន បើមិនមាន អញនឹងកើតក្នុងអរូបព្រហ្ម ។

សួរថា ព្រះមានព្រះភាគត្រាស់ក្នុងព្រះសូត្រនោះ ពាក្យថា ទានដែលឲ្យហើយមានផល ដូច្នេះជាដើម ជាពាក្យមិនខុស ណ្ហើយចុះ ឯពាក្យថា ទានដែលឲ្យហើយមិនមានផល ដូច្នេះជាដើម មិនខុស ដោយហេតុអ្វី ឆ្លើយថា ដោយអំណាចការប្រកាន់ ពិតហើយ ពាក្យទាំងនោះដែលកើត ជឿថាមិនខុស ក៏ព្រោះបុគ្គលនោះប្រកាន់យ៉ាងនេះថា មិនខុស មិនខុស ។

[ ១២២ ] សព្ទថា **ចត្តារោមេ** នេះ បែកជា ២ ចំណែក តែអត្ថជាប់ជាមួយគ្នា ។ បុគ្គលទាំង ៥ ពួកនេះ គឺនត្ថិកវាទ ១ អកិរិយាវាទ ១ អហេតុកវាទ ១ បុគ្គលដែលមានវាទៈយ៉ាងនេះថា អរូបព្រហ្មមិនមាន ១ និរោធមិនមាន ១ បុគ្គល ៣ ពួកក្រោយប៉ុណ្ណោះ មាន ។ បុគ្គល ៥ ពួក

មានអត្ថិកវាទជាដើម បុគ្គលពួកទី ៤ តែមួយពួកប៉ុណ្ណោះ ( មាន ) ។ ដើម្បីទ្រង់សម្ដែងសេចក្ដីនោះ ទើបព្រះមានព្រះមានព្រះភាគទ្រង់ផ្ដើមទេសនានេះ ។ ដោយអត្ថ ពាក្យទាំងអស់ក្នុងវាទៈទាំងនោះងាយយល់ហើយ ៕

**អបណ្ណកសូត្រ ចប់**

**សូត្រទី ១០ ចប់**

**គហបតិវគ្គទី ១ ចប់**

# ក្បាលទី ១៩

# សុត្តន្តបិដក ចាលីប្រែ -២២

## មជ្ឈិមនិកាយ មូលបណ្ណាសក តតិយភាគ មហាយមកវគ្គ

សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ


| មាតិកា | លេខទំព័រ |
|---|---|
| ចូឡគោសិង្គសាលសូត្រទី ១ ...... ...... ...... ...... ...... ...... ...... | ២ |
| អដ្ឋកថា ចូឡគោសិង្គសាលសូត្រ ...... ...... ...... ...... ...... ...... ...... | ១៦ |
| មហាគោសិង្គសាលសូត្រទី ២ ...... ...... ...... ...... ...... ...... ...... | ៣៤ |
| អដ្ឋកថា មហាគោសិង្គសាលសូត្រ ...... ...... ...... ...... ...... ...... ...... | ៥០ |
| មហាគោបាលសូត្រទី ៣ ...... ...... ...... ...... ...... ...... ...... | ៧១ |
| អដ្ឋកថា មហាគោបាលសូត្រ ...... ...... ...... ...... ...... ...... ...... | ៨១ |
| ចូឡគោបាលសូត្រទី ៤ ...... ...... ...... ...... ...... ...... ...... | ៩៤ |
| អដ្ឋកថា ចូឡគោបាលសូត្រ ...... ...... ...... ...... ...... ...... ...... | ១០០ |
| ចូឡសច្ចកសូត្រទី ៥ ...... ...... ...... ...... ...... ...... ...... | ១០៥ |
| អដ្ឋកថា ចូឡសច្ចកសូត្រ ...... ...... ...... ...... ...... ...... ...... | ១២៦ |
| មហាសច្ចកសូត្រទី ៦ ...... ...... ...... ...... ...... ...... ...... | ១៥៥ |
| អដ្ឋកថា មហាសច្ចកសូត្រ ...... ...... ...... ...... ...... ...... ...... | ១៩២ |
| ចូឡតណ្ហាសង្ខយសូត្រទី ៧ ...... ...... ...... ...... ...... ...... ...... | ២១៤ |
| អដ្ឋកថា ចូឡតណ្ហាសង្ខយសូត្រ ...... ...... ...... ...... ...... ...... ...... | ២២៥ |
| មហាតណ្ហាសង្ខយសូត្រទី ៨ ...... ...... ...... ...... ...... ...... ...... | ២៤៣ |
| អដ្ឋកថា មហាតណ្ហាសង្ខយសូត្រ ...... ...... ...... ...... ...... ...... ...... | ២៧៨ |
| មហាអស្សបុរសូត្រទី ៩ ...... ...... ...... ...... ...... ...... ...... | ២៩៣ |

អដ្ឋកថា មហាអស្សបុរសូត្រ ...... ...... ...... ...... ...... ...... ...... ៣១៥
- ដំណេក ៤ យ៉ាង ...... ...... ...... ...... ...... ...... ...... ៣២៤
- អធិប្បាយ ឧបមានីវរណៈ ៥ ...... ...... ...... ...... ...... ...... ...... ៣២៨
ចូឡអស្សបុរសូត្រទី ១០ ...... ...... ...... ...... ...... ...... ...... ៣៤១
អដ្ឋកថា ចូឡអស្សបុរសូត្រ ...... ...... ...... ...... ...... ...... ...... ៣៥២

## សុត្តន្តបិដក

## មជ្ឈិមនិកាយ មូលបណ្ណាសក តតិយភាគ ចូឡយមកវគ្គ

សាលេយ្យកសូត្រទី ១ ...... ...... ...... ...... ...... ...... ...... ៣៥៦
អដ្ឋកថា សាលេយ្យកសូត្រ ...... ...... ...... ...... ...... ...... ...... ៣៧០
វេរញ្ជកសូត្រទី ២ ...... ...... ...... ...... ...... ...... ...... ៣៨៥
អដ្ឋកថា វេរញ្ជកសូត្រ ...... ...... ...... ...... ...... ...... ...... ៣៩៥
មហាវេទល្លសូត្រទី ៣ ...... ...... ...... ...... ...... ...... ...... ៣៩៦
អដ្ឋកថា មហាវេទល្លសូត្រ ...... ...... ...... ...... ...... ...... ...... ៤១០
ចូឡវេទល្លសូត្រទី ៤ ...... ...... ...... ...... ...... ...... ...... ៤៥១
អដ្ឋកថា ចូឡវេទល្លសូត្រ ( រឿងព្រះនាងធម្មទិន្នា ) ... ...... ...... ...... ៤៦៣
ចូឡធម្មសមាទានសូត្រទី ៥ ...... ...... ...... ...... ...... ...... ...... ៤៩២
អដ្ឋកថា ចូឡធម្មសមាទានសូត្រ ...... ...... ...... ...... ...... ...... ...... ៥០១
មហាធម្មសមាទានសូត្រទី ៦ ...... ...... ...... ...... ...... ...... ...... ៥០៧
អដ្ឋកថា មហាធម្មសមាទានសូត្រ ...... ...... ...... ...... ...... ...... ...... ៥២៤
វីមំសកសូត្រទី ៧ ...... ...... ...... ...... ...... ...... ...... ៥៣២
អដ្ឋកថា វីមំសកសូត្រ ...... ...... ...... ...... ...... ...... ...... ៥៣៩
កោសម្ពិយសូត្រទី ៨ ...... ...... ...... ...... ...... ...... ...... ៥៦១
អដ្ឋកថា កោសម្ពិយសូត្រ ( ប្រវត្តិឃោសិតារាម ) ... ...... ...... ៥៧៣

- រឿងព្រះសោលាគិរិវនវាសីតិស្សត្ថេរ ...... ...... ...... ...... ..... ៥៨៧
ព្រហ្មនិមន្តនិកសូត្រទី ៩ ...... ...... ...... ...... ...... ...... ...... ៦០១
អដ្ឋកថា ព្រហ្មនិមន្តនិកសូត្រ ...... ...... ...... ...... ...... ...... ...... ៦១៥
- រឿងបុព្វកម្មរបស់ពកាព្រហ្ម ...... ...... ...... ...... ...... ...... ...... ៦២៣
មារតជ្ជនីយសូត្រទី ១០ ...... ...... ...... ...... ...... ...... ...... ៦៣៦
អដ្ឋកថា មារតជ្ជនីយសូត្រ ...... ...... ...... ...... ...... ...... ...... ៦៥១

## សុត្តន្តបិដក បាលីប្រែ -២៣

កន្ទរកសូត្រទី ១ ...... ...... ...... ...... ...... ...... ...... ៦៦៥
អដ្ឋកថា កន្ទរកសូត្រ ...... ...... ...... ...... ...... ...... ...... ៦៨៧
- អត្តរបស់សត្តសត្វ ...... ...... ...... ...... ...... ...... ...... ៦៩៧
អដ្ឋកថា នាគរសូត្រទី ២ ...... ...... ...... ...... ...... ...... ...... ៧០២
អដ្ឋកថា អដ្ឋកនាគរសូត្រ ...... ...... ...... ...... ...... ...... ...... ៧១០
សេក្ខប្បដិបទាសូត្រទី ៣ ...... ...... ...... ...... ...... ...... ...... ៧១៦
អដ្ឋកថា សេក្ខប្បដិបទាសូត្រ ...... ...... ...... ...... ...... ...... ...... ៧២៨
បោតលិយសូត្រទី ៤ ...... ...... ...... ...... ...... ...... ...... ៧៥៣
អដ្ឋកថា បោតលិយសូត្រ ...... ...... ...... ...... ...... ...... ...... ៧៧៤
- អធិប្បាយ វចនៈរបស់វោហារសត្វ .... ...... ...... ...... ...... ...... ៧៨០
ជីវកសូត្រទី ៥ ...... ...... ...... ...... ...... ...... ...... ៧៨៧
អដ្ឋកថា ជីវកសូត្រ ...... ...... ...... ...... ...... ...... ...... ៧៩៤
ឧបាលិវាទសូត្រទី ៦ ...... ...... ...... ...... ...... ...... ...... ៨០៤
អដ្ឋកថា ឧបាលិវាទសូត្រ ...... ...... ...... ...... ...... ...... ...... ៨៣៥
- រឿងព្រៃទណ្ឌកី ...... ...... ...... ...... ...... ...... ...... ៨៤៦
- រឿងព្រៃកាលិង្គ ...... ...... ...... ...... ...... ...... ...... ៨៥៣

- រឿងព្រៃមាតង្គៈ ...... ...... ...... ...... ...... ...... ...... ៨៥៧

កុក្កុរវោទសូត្រទី ៧ ...... ...... ...... ...... ...... ...... ...... ៨៩៨

អដ្ឋកថា កុក្កុរវោទសូត្រ ...... ...... ...... ...... ...... ...... ...... ៩០៩

អភយរាជកុមារសូត្រទី ៨ ...... ...... ...... ...... ...... ...... ...... ៩២០

អដ្ឋកថា អភយរាជកុមារសូត្រ ...... ...... ...... ...... ...... ...... ...... ៩២៩

ពហុវេទនីយសូត្រទី ៩ ...... ...... ...... ...... ...... ...... ...... ៩៣៧

អដ្ឋកថា ពហុវេទនីយសូត្រ ...... ...... ...... ...... ...... ...... ...... ៩៤៥

អបណ្ណកសូត្រទី ១០ ...... ...... ...... ...... ...... ...... ...... ៩៤៨

អដ្ឋកថា អបណ្ណកសូត្រ ...... ...... ...... ...... ...... ...... ...... ៩៧៩